# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
# ព្រះអដ្ឋកថា

## ភាគ១២

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី១

# ព្រះ

# សុត្តន្តបិដក

## និង

# សុមង្គលវិលាសិនី អដ្ឋកថា

### សេចក្ដីប្រែជាភាសាខ្មែរ

## ទីឃនិកាយ

## បាដិកវគ្គ

## បញ្ចមភាគ-ឆដ្ឋភាគ

## ១២

## បាលីប្រែ ១៨-១៩



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ១២

## ចក្កវត្តិសូត្រទី ៣

[ ៣៣ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅ ( ក្នុងដងព្រៃ ) ជិតមាតុលានគរ ក្នុងដែនមគធៈ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរមានខ្លួនជាទីពឹង មានខ្លួនជាទីពំនាក់ កុំមានរបស់ដទៃជាទីពឹងពំនាក់ឡើយ ចូរមានធម៌ជាទីពឹង មានធម៌ជាទីពំនាក់ កុំមានរបស់ដទៃជាទីពឹងពំនាក់ឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានខ្លួនជាទីពឹង មានខ្លួនជាទីពំនាក់ មិនមានរបស់ដទៃជាទីពឹងពំនាក់ មានធម៌ជាទីពឹង មានធម៌ជាទីពំនាក់ មិនមានរបស់ដទៃជាទីពឹងពំនាក់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណានូវកាយក្នុងកាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានប្រាជ្ញាដឹងសព្វ មានស្មារតីកម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកបាន ។ ពិចារណានូវវេទនាក្នុងវេទនាទាំងឡាយជាប្រក្រតី ។ ពិចារណានូវចិត្តក្នុងចិត្តជាប្រក្រតី ។ ពិចារណានូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានប្រាជ្ញាដឹងសព្វ មានស្មារតីកម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកបាន ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះហៅថា ភិក្ខុមានខ្លួនជាទីពឹង មានខ្លួនជាទីពំនាក់ មិនមានរបស់ដទៃជាទី

ពីងពំនាក់ មានធម៌ជាទីពឹង មានធម៌ជាទីពំនាក់ មិនមានរបស់ដទៃជាទីពឹងពំនាក់ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរប្រព្រឹត្តក្នុងគោចរ ជាវិស័យដែលមានមកអំពីបិតារបស់ខ្លួន ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយប្រព្រឹត្តក្នុងគោចរ ជាវិស័យដែលមានមកអំពីបិតារបស់ខ្លួន មារក៏មិនបាននូវចន្លោះ មិនបាននូវអារម្មណ៍ឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុណ្យនេះរមែងចម្រើនឡើងព្រោះហេតុសមាទាននូវកុសលធម៌ទាំងឡាយយ៉ាងនេះ ។

[ ៣៤ ] ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយមក មានព្រះរាជា ( ព្រះអង្គ ) ទ្រង់ព្រះនាមទឡ្ហនេមិ ជាស្ដេចចក្រពត្តិ ព្រះអង្គជាធម្មិកធម្មរាជ ជាឥស្សរៈលើផែនដី ដែលមានសមុទ្រទាំង ៤ ជាទីបំផុត ជាស្ដេចឈ្នះសង្គ្រាម ទ្រង់មានជនបទដល់នូវថិរភាព ( សេចក្ដីមាំមួន ) ទ្រង់បរិបូណ៌ដោយរ័តន៍ទាំង ៧ ប្រការ ។ ឯរ័តន៍ទាំង ៧ ប្រការ របស់ព្រះបាទទឡ្ហនេមិនោះ គឺចក្ករ័តន៍ ( ចក្រកែវ ) ១ ហត្ថិរ័តន៍ ( ដំរីកែវ ) ១ អស្សរ័តន៍ ( សេះកែវ ) ១ មណិរ័តន៍ ( កែវមណី ) ១ ឥត្ថិរ័តន៍ ( ស្ត្រីកែវ ) ១ គហបតិរ័តន៍ ( គហបតិកែវ ) ១ បរិនាយករ័តន៍ ( នាយពលកែវ ) ១ រួមត្រូវជា ៧ ប្រការ ។ ឯព្រះបាទទឡ្ហនេមិនោះ មានព្រះរាជបុត្រច្រើនជាងពាន់សុទ្ធសឹងតែក្លៀវក្លា អង់អាច អាចសង្កត់សង្កិននូវសេនារបស់ស្ដេចដទៃបាន ។ ព្រះបាទទឡ្ហនេមិនោះ ទ្រង់ត្រួតត្រាគ្រប់គ្រងផែនដីដែលមានសាគរជាព្រំប្រទល់នេះ ដោយធម៌ដ៏ស្មើ មិនបាច់ប្រើអាជ្ញា មិនបាច់ប្រើគ្រឿងសស្ត្រាវុធទេ ។ ម្នាលភិក្ខុទាំងឡាយ លុះកាលកន្លងទៅបានច្រើនឆ្នាំ ច្រើន

រយឆ្នាំ ច្រើនពាន់ឆ្នាំ ទើបព្រះបាទទឡ្ហនេមិទ្រង់ត្រាស់នឹងបុរសម្នាក់ថា ម្នាល បុរសដ៏ចម្រើន ( បើ ) អ្នកឃើញចក្ករ័តន៍ជាទិព្វ ឃ្លាតច្យុតចាកទីក្នុងកាល ណា អ្នកត្រូវប្រាប់ដល់យើងក្នុងកាលនោះ ។ ម្នាលភិក្ខុទាំងឡាយ បុរស នោះទទួលស្តាប់ព្រះរាជឱង្ការនៃព្រះបាទទឡ្ហនេមិថា ព្រះករុណាថ្លៃវិសេស ។ ម្នាលភិក្ខុទាំងឡាយ លុះកាលកន្លងទៅបានច្រើនឆ្នាំ ច្រើនរយឆ្នាំ ច្រើនពាន់ ឆ្នាំ បុរសនោះបានឃើញចក្ករ័តន៍ជាទិព្វឃ្លាតច្យុតចាកទី ក៏ចូលទៅគាល់ព្រះ បាទទឡ្ហនេមិ លុះចូលទៅដល់ហើយ ក៏ក្រាបបង្គំទូលព្រះបាទទឡ្ហនេមិដូច្នេះ ថា សូមព្រះរាជតេជះតម្កល់លើត្បូង បពិត្រព្រះសម្មតិទេព សូមទ្រង់ជ្រាប ( ដ្បិត ) ចក្ករ័តន៍ជាទិព្វរបស់ព្រះអង្គ ឃ្លាតច្យុតចាកទីហើយ ។ ម្នាលភិក្ខុ ទាំងឡាយ គ្រានោះឯង ព្រះបាទទឡ្ហនេមិ ទ្រង់ហៅព្រះរាជកុមារ ជាបុត្រ ច្បងមកហើយ ទ្រង់ត្រាស់ដូច្នេះថា ម្នាលកុមារមាសឪពុក ឮថា ចក្ករ័តន៍ជា ទិព្វរបស់យើង ឃ្លាតច្យុតចាកទីហើយ សេចក្តីនេះ ឪពុកធ្លាប់ឮថា ( បើ ) ចក្ករ័តន៍ជាទិព្វរបស់ស្តេចចក្រពត្តិអង្គណា ឃ្លាតច្យុតចាកទីហើយ តពីនោះ មក ស្តេចអង្គនោះ មិនរស់នៅបានយូរឡើយ ឯកាមជារបស់មនុស្ស ឪពុក បានបរិភោគ ( ឆ្អែតស្កប់ស្កល់ហើយ) សម័យនេះជាសម័យដែលឪពុក គួរ ស្វែងរកកាមជាទិព្វវិញ ម្នាលកុមារមាសឪពុក ចូរអ្នកគ្រប់គ្រង់ផែនដី ដែល មានសមុទ្រជាព្រំប្រទល់នេះចុះ ឯឪពុកនឹងកោរសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្តប់កាសាវពស្ត្រចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ។ ម្នាលភិក្ខុទាំង-ឡាយ លំដាប់នោះឯង ព្រះបាទទឡ្ហនេមិ ទ្រង់លួងលោមព្រះរាជកុមារ ជា

បុត្រច្បងឲ្យគ្រប់គ្រងរាជសម្បត្តិ ដោយប្រពៃហើយ ក៏ទ្រង់ដាក់ព្រះកេសា និងព្រះមស្សុ ទ្រង់ស្លៀកដណ្តប់កាសាវពស្ត្រ រួចចេញចាករាជាគារដ្ឋាន ចូលទៅកាន់ផ្នួស ។ ម្នាលភិក្ខុទាំងឡាយ កាលព្រះរាជឥសី ទើបនឹងទ្រង់ព្រះផ្នួសបាន ៧ ថ្ងៃ ចក្ករតន៍ជាទិព្វបាត់ទៅ ។

[ ៣៥ ] ម្នាលភិក្ខុទាំងឡាយលំដាប់នោះ មានបុរសម្នាក់ចូលទៅគាល់ព្រះរាជាជាក្សត្រដែលបានមុទ្ធាភិសេកហើយ លុះចូលទៅដល់ហើយ ក៏ក្រាបបង្គំទូលព្រះរាជាជាក្សត្រដែលបានមុទ្ធាភិសេកហើយថា សូមព្រះរាជតេជះតម្កល់លើត្បូង បពិត្រព្រះសម្មតិទេព សូមទ្រង់ជ្រាប ( ផ្សិត ) ចក្ករតន៍ជាទិព្វបាត់ទៅហើយ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង កាលបើចក្ករតន៍ជាទិព្វបាត់ទៅ ព្រះរាជាជាក្សត្រដែលបានមុទ្ធាភិសេកហើយ ក៏តូចព្រះហឫទ័យ និងសោយនូវសេចក្តីមិនសប្បាយព្រះហឫទ័យ ។ ព្រះមហាក្សត្រអង្គនោះ ក៏ចូលទៅគាល់ព្រះរាជឥសីលុះចូលទៅដល់ហើយ ក៏ក្រាបបង្គំទូលព្រះរាជឥសីដូច្នេះថា សូមព្រះរាជតេជះតម្កល់លើត្បូង បពិត្រព្រះសម្មតិទេព សូមទ្រង់ជ្រាប ( ផ្សិត ) ចក្ករតន៍ជាទិព្វបាត់ទៅហើយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើព្រះមហាក្សត្រក្រាបបង្គំទូលយ៉ាងនេះ ព្រះរាជឥសី ទ្រង់ត្រាស់នឹងព្រះរាជាជាក្សត្រដែលបានមុទ្ធាភិសេកហើយដូច្នេះថា ម្នាលបា កាលបើចក្ករតន៍ជាទិព្វបាត់ទៅ អ្នកកុំមានសេចក្តីតូចចិត្ត កុំសោយនូវសេចក្តីមិនសប្បាយចិត្តឡើយ ម្នាលបា ព្រោះថា ចក្ករតន៍ជាទិព្វនេះ មិនមែនជាមត៌កដែលមានមកអំពីបិតាអ្នកទេ ម្នាលបា ណ្ហើយចុះ អ្នកចូរប្រព្រឹត្តចក្កវត្តិវត្ត ( វត្តរបស់ស្តេច

ចក្រពត្តិ ) ដ៏ប្រសើរវិញចុះ កាលបើចក្កពត្តិវត្ត ដែលអ្នកប្រព្រឹត្តហើយ ចក្ករតន៍ជាទិព្វ មានកាំ ១ ពាន់ ព្រមទាំងខ្នងកង់ ព្រមទាំងដុំបរិបូណ៌ដោយអាការសព្វគ្រប់ នឹងកើតប្រាកដដល់បា ដែលកក់កេសាហើយរក្សាឧបោសថ ឋិតនៅលើប្រាសាទដ៏ប្រសើរ ក្នុងថ្ងៃ ១៥ ជាថ្ងៃឧបោសថនោះ ហេតុនេះរមែងមានប្រាកដ ។ ព្រះមហាក្សត្រក្រាបបង្គំទូលសួរថា បពិត្រព្រះសម្មតិទេព ចុះចក្កពត្តិវត្តដ៏ប្រសើរនុ៎ះ តើដូចម្តេច ។ ព្រះរាជឥសីត្រាស់ថា ម្នាលបា បើដូច្នោះ ចូរអ្នកអាស្រ័យនូវធម៌តែម្យ៉ាង ហើយធ្វើសក្ការៈចំពោះធម៌ គោរពធម៌ រាប់អានធម៌ បូជាធម៌ កោតក្រែងធម៌ យកធម៌ជាទង់ជ័យ យកធម៌ជាស្លាក យកធម៌ជាអធិបតី ចាត់ចែងនូវការរក្សាទប់ទល់ គ្រប់គ្រងប្រកបដោយធម៌ ចំពោះជនខាងក្នុង គឺបុត្រភរិយា ចំពោះពួកពល ពួកក្សត្រ ពួកជនចុះចូល ពួកព្រាហ្មណ៍ គហបតី ពួកអ្នកនិគម អ្នកជនបទ ពួកសមណព្រាហ្មណ៍ និងពួកម្រឹគ បក្សី ម្នាលបា អ្នកកុំធ្វើអកុសលធម៌ ក្នុងដែនរបស់អ្នកឡើយ ម្នាលបា បើពួកជនណាក្នុងដែនរបស់អ្នក មិនមានទ្រព្យ អ្នកគប្បីផ្តល់ទ្រព្យដល់ជនទាំងនោះ ម្នាលបា បើពួកសមណព្រាហ្មណ៍ណា ក្នុងដែនរបស់អ្នក ជាអ្នកវៀរចាកសេចក្តីស្រវឹង និងសេចក្តីប្រមាទ តាំងនៅក្នុងខន្តី និងសោរច្ចៈ តែងទូន្មានខ្លួនឯងតែម្នាក់ឯង ធ្វើខ្លួនឯងឲ្យស្ងប់រម្ងាប់តែម្នាក់ឯង ធ្វើខ្លួនឯងឲ្យរលត់ ( ចាករាគាទិក្កិលេស ) តែម្នាក់ឯង អ្នកគប្បីចូលទៅរកសមណ-ព្រាហ្មណ៍ទាំងនោះ សព្វៗ កាល ហើយគប្បីសាកសួរ គប្បីចោទដណ្តឹងថា បពិត្រលោកដ៏ចម្រើន អ្វីជាកុសល បពិត្រលោកដ៏ចម្រើន អ្វីជាអកុសល អ្វី

ជាអំពើប្រកបដោយទោស អ្វីជាអំពើមិនប្រកបដោយទោស អ្វីគួរសេព អ្វីមិនគួរសេព អំពើដូចម្តេចដែលខ្ញុំធ្វើទៅហើយ មិនជាប្រយោជន៍ ជាទុក្ខអស់កាលយូរអង្វែង មួយទៀត អំពើដូចម្តេច ដែលខ្ញុំធ្វើទៅហើយជាប្រយោជន៍ ជាសុខអស់កាលយូរអង្វែង លុះអ្នកបានស្តាប់ពាក្យសមណព្រាហ្មណ៍ទាំងនោះហើយ គប្បីវៀរនូវអំពើដែលជាអកុសល ហើយសមាទានប្រព្រឹត្តនូវអំពើដែលជាកុសល ម្នាលបា នេះឯងជាចក្កវត្តិវត្តដ៏ប្រសើរនោះ ។ ម្នាលភិក្ខុទាំងឡាយ ព្រះរាជាជាក្សត្រដែលបានមុទ្ធាភិសេកហើយ បានទទួលស្តាប់ពាក្យព្រះរាជឥសីថា ព្រះករុណាថ្លៃវិសេស ហើយក៏ប្រព្រឹត្តចក្កវត្តិវត្តដ៏ប្រសើរ ។ កាលដែលព្រះរាជានោះ កំពុងប្រព្រឹត្តចក្កវត្តិវត្តដ៏ប្រសើរ កក់ព្រះកេសា សមាទានឧបោសថ ហើយស្តេចទៅខាងលើប្រាសាទដ៏ប្រសើរ ក្នុងថ្ងៃទី ១៥ ដែលជាថ្ងៃឧបោសថនោះ ចក្ករតន៍ជាទិព្វមានកាំ ១ ពាន់ ព្រមទាំងខ្នងកង់ ព្រមទាំងដុំ បរិបូណ៌ដោយអាការសព្វគ្រប់ ក៏កើតប្រាកដឡើង ។ ព្រះរាជាជាក្សត្រដែលបានមុទ្ធាភិសេក ទ្រង់ទតឃើញហើយ ទ្រង់ព្រះរាជតម្រិះថា អាត្មាអញបានឮមកដូច្នេះថា ចក្ករតន៍ជាទិព្វមានកាំ ១ ពាន់ ព្រមទាំងខ្នងកង់ ព្រមទាំងដុំ បរិបូណ៌ដោយអាការគ្រប់យ៉ាង កើតប្រាកដឡើងដល់ព្រះរាជា ជាក្សត្រអង្គណា ដែលបានមុទ្ធាភិសេកហើយ កក់ព្រះកេសាសមាទានឧបោសថ ស្តេចទៅខាងលើប្រាសាទដ៏ប្រសើរ ក្នុងថ្ងៃទី ១៥ ដែលជាថ្ងៃឧបោសថនោះ ព្រះរាជាអង្គនោះ នឹងជាស្តេចចក្រពត្តិ ឱហ្ន៎! អាត្មាអញប្រាកដជាស្តេចចក្រពត្តិហើយតើ ។

[ ៣៦ ] ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះរាជាជាក្សត្រ ដែលបាន មុទ្ធាភិសេកហើយ ទ្រង់ក្រោកអំពីអាសនៈ ធ្វើសំពត់ឧត្តរាសង្គៈឆៀងស្មាម្ខាង ទើបយកព្រះហស្តខាងឆ្វេងកាន់កុណ្ឌី យកព្រះហស្តខាងស្តាំប្រោះព្រំចក្ករ័តន៍ ហើយអធិដ្ឋានថា សូមឲ្យចក្ករ័តន៍ដ៏ចម្រើនប្រព្រឹត្តទៅ សូមឲ្យចក្ករតន៍ដ៏ ចម្រើន មានជ័យជម្នះចុះ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ចក្ករ័តន៍នោះ ក៏ អណ្តែតត្រសែត ទៅកាន់ទិសខាងកើត ។ ទើបព្រះបាទចក្រពត្តិ ស្តេចទៅ តាម ( ចក្ករ័តន៍នោះ ) ព្រមដោយចតុរង្គសេនា ។ ម្នាលភិក្ខុទាំងឡាយ បើ ចក្ករ័តន៍ទៅប្រតិស្ឋានក្នុងប្រទេសណា ព្រះបាទចក្រពត្តិ ក៏ស្តេចចូលទៅតាំង ព្រះរាជនិវេសន៍ ក្នុងប្រទេសនោះ ព្រមដោយចតុរង្គសេនា ។ ម្នាលភិក្ខុទាំង-ឡាយ ចំណែកខាងស្តេចជាសឹកសត្រូវទាំងឡាយណា ដែលនៅក្នុងទិសខាង កើត ស្តេចទាំងនោះ ក៏ចូលទៅគាល់ព្រះបាទចក្រពត្តិ ហើយក្រាបបង្គំទូល យ៉ាងនេះថា បពិត្រមហារាជ សូមព្រះអង្គស្តេចចូលមកចុះ បពិត្រមហារាជ ព្រះអង្គមានព្រះរាជដំណើរ មកស្រួលហើយ បពិត្រមហារាជ ដែនរបស់ខ្ញុំ ព្រះអង្គ ជាដែនរបស់ព្រះអង្គហើយ បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រៀន ប្រដៅចុះ ។ ព្រះបាទចក្រពត្តិ មានព្រះបន្ទូល ( ប្រដៅ ) យ៉ាងនេះថា អ្នក ទាំងឡាយមិនត្រូវសម្លាប់សត្វ មិនត្រូវលួចទ្រព្យដែលគេមិនបានឲ្យ មិនត្រូវ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ មិនត្រូវពោលពាក្យមុសាវាទ មិនត្រូវផឹកទឹក ស្រវឹងឡើយ ចូរបរិភោគតែរបស់ដែលគួរបរិភោគចុះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ស្តេចជាសឹកសត្រូវទាំងឡាយណា ដែលនៅក្នុងទិសខាងកើត ស្តេច

ទាំងនោះ ក៏ទៅជាចុះចូលព្រះបាទចក្រពត្តិវិញ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ចក្ករ័តន៍នោះ ក៏ចុះកាន់សមុទ្រក្នុងទិសខាងកើត រួចឆ្លងឡើងចុះ ទៅកាន់សមុទ្រក្នុងទិសខាងត្បូង រួចឆ្លងឡើងអណ្តែតត្រសែតទៅកាន់ទិស ខាងលិច ។ ព្រះបាទចក្រពត្តិ ក៏ស្តេចទៅតាម ( ចក្ករ័តន៍នោះ ) ព្រមដោយចតុរង្គសេនា ។ ម្នាលភិក្ខុទាំងឡាយ បើចក្ករ័តន៍ទៅប្រតិស្ឋានក្នុងប្រទេសណា ព្រះបាទចក្រពត្តិក៏ស្តេចចូលទៅកាន់ទីសម្រាកក្នុងប្រទេសនោះ ព្រមដោយចតុរង្គសេនា ។ ម្នាលភិក្ខុទាំងឡាយ ឯស្តេចជាសឹកសត្រូវទាំងឡាយណា ដែលនៅក្នុងទិសខាងលិច ស្តេចទាំងនោះក៏នាំគ្នាចូលទៅគាល់ព្រះបាទចក្រពត្តិ ហើយក្រាបបង្គំទូលយ៉ាងនេះថា បពិត្រមហារាជ សូមព្រះអង្គស្តេចចូលមកចុះ បពិត្រមហារាជ ព្រះអង្គមានព្រះរាជដំណើរមកស្រួលហើយ បពិត្រមហារាជ ដែនរបស់ខ្ញុំព្រះអង្គ ជាដែនរបស់ព្រះអង្គហើយ បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រៀនប្រដៅចុះ ។ ព្រះបាទចក្រពត្តិទ្រង់មានព្រះរាជឱង្ការ ( ប្រដៅ ) យ៉ាងនេះថា អ្នកទាំងឡាយ មិនត្រូវសម្លាប់សត្វ មិនត្រូវលួចទ្រព្យដែលគេមិនបានឲ្យ មិនត្រូវប្រព្រឹត្តខុសក្នុងកាមទាំងឡាយ មិនត្រូវពោលពាក្យមុសាវាទ មិនត្រូវផឹកទឹកស្រវឹងឡើយ ចូរបរិភោគតែរបស់ដែលគួរបរិភោគចុះ ។ ម្នាលភិក្ខុទាំងឡាយ ឯស្តេចដែលជាសឹកសត្រូវទាំង-ឡាយណា ដែលនៅក្នុងទិសខាងលិច ស្តេចទាំងនោះ ក៏ទៅជាចុះចូលព្រះបាទចក្រពត្តិវិញ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ចក្ករ័តន៍នោះក៏ចុះកាន់សមុទ្រក្នុងទិសខាងលិច ឆ្លងឡើងអណ្តែតត្រសែតទៅកាន់ទិសខាងជើង ។

ព្រះបាទចក្រពត្តិក៏ស្តេចទៅតាម ( ចក្ករ័តន៍នោះ ) ព្រមដោយចតុរង្គសេនា ។ ម្នាលភិក្ខុទាំងឡាយ បើចក្ករ័តន៍ទៅប្រតិស្ឋានក្នុងប្រទេសណា ព្រះបាទចក្រ-ពត្តិ ក៏ស្តេចចូលទៅកាន់ទីសម្រាកក្នុងប្រទេសនោះ ព្រមដោយចតុរង្គសេនា ។ ម្នាលភិក្ខុទាំងឡាយ ឯស្តេចជាសឹកសត្រូវទាំងឡាយណា ដែលនៅក្នុងទិសខាងជើង ស្តេចទាំងនោះក៏ចូលទៅគាល់ព្រះបាទចក្រពត្តិ ហើយក្រាបបង្គំទូលយ៉ាងនេះថា បពិត្រមហារាជ សូមព្រះអង្គស្តេចចូលមកចុះ បពិត្រមហារាជ ព្រះអង្គមានព្រះរាជដំណើរមកស្រួលហើយ បពិត្រមហារាជ ដែនរបស់ខ្ញុំព្រះអង្គជាដែនរបស់ព្រះអង្គហើយ បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រៀនប្រដៅចុះ ។ ព្រះបាទចក្រពត្តិទ្រង់មានព្រះរាជឱង្ការ ( ប្រដៅ ) យ៉ាងនេះថា អ្នកទាំងឡាយមិនត្រូវសម្លាប់សត្វ មិនត្រូវលួចទ្រព្យដែលគេមិនបានឲ្យ មិនត្រូវប្រព្រឹត្តខុសក្នុងកាមទាំងឡាយ មិនត្រូវពោលពាក្យមុសាវាទ មិនត្រូវផឹកទឹកស្រវឹងឡើយ ចូរបរិភោគតែរបស់ដែលគួរបរិភោគចុះ ។ ម្នាលភិក្ខុទាំងឡាយ ឯស្តេចជាសឹកសត្រូវទាំងឡាយណា ដែលនៅក្នុងទិសខាងជើង ស្តេចទាំងនោះក៏ទៅជាចុះចូលព្រះបាទចក្រពត្តិវិញ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះចក្ករ័តន៍នោះ ក៏បង្ក្រាបដែនដី ដែលមានសមុទ្រជាព្រំប្រទល់ ហើយត្រឡប់មកកាន់ព្រះរាជធានីនោះវិញ ឋិតនៅក្នុងរបៀងនៃសាលាវិនិច្ឆ័យ ទៀបទ្វារព្រះរាជវាំង របស់ព្រះបាទចក្រពត្តិ (នៅនឹងថ្កល់) ហាក់ដូចជាបាក់ក្ដៅ បំភ្លឺព្រះរាជវាំងរបស់ព្រះបាទចក្រពត្តិ ឲ្យភ្លឺព្រោងព្រាត ។

[ ៣៧ ] ម្នាលភិក្ខុទាំងឡាយ ស្តេចចក្រពត្តិទី ២ ក្តី ។ ម្នាលភិក្ខុទាំង-

ទ្បាយ ស្តេចចក្រពត្តិទី ៣ក្តី ។ ម្នាលភិក្ខុទាំងឡាយ ស្តេចចក្រពត្តិទី ៤ក្តី ។ ម្នាលភិក្ខុទាំងឡាយ ស្តេចចក្រពត្តិទី ៥ ក្តី ។ ម្នាលភិក្ខុទាំងឡាយ ស្តេចចក្រពត្តិទី ៦ក្តី ។ ម្នាលភិក្ខុទាំងឡាយ ស្តេចចក្រពត្តិទី ៧ក្តី លុះកន្លងកាលទៅបានច្រើនឆ្នាំ ច្រើនរយឆ្នាំ ច្រើនពាន់ឆ្នាំ ត្រាស់នឹងបុរសម្នាក់ថា ម្នាលបុរសដ៏ចម្រើន បើអ្នកបានឃើញចក្ករ័តន៍ជាទិព្វ ឃ្លាតច្យុតចាកទីកាលណា អ្នកគប្បីប្រាប់ដល់យើងក្នុងកាលនោះ ។ ម្នាលភិក្ខុទាំងឡាយ បុរសនោះក៏ទទួលព្រះរាជឱង្ការ ព្រះបាទចក្រពត្តិថា ព្រះករុណាថ្លៃវិសេស ។ ម្នាលភិក្ខុទាំងឡាយ លុះកន្លងទៅជាច្រើនឆ្នាំ ច្រើនរយឆ្នាំ ច្រើនពាន់ឆ្នាំ បុរសនោះបានឃើញចក្ករ័តន៍ជាទិព្វ ឃ្លាតច្យុតចាកទី ក៏ចូលទៅគាល់ស្តេចចក្រពត្តិ លុះចូលទៅដល់ហើយ ក្រាបបង្គំទូលព្រះបាទចក្រពត្តិដូច្នេះថា សូមព្រះរាជតេជះតម្កល់លើត្បូង បពិត្រព្រះសម្មតិទេព សូមទ្រង់ជ្រាប ( ដ្បិត ) ចក្ករ័តន៍ជាទិព្វរបស់ព្រះអង្គ ឃ្លាតច្យុតចាកទីហើយ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះព្រះបាទចក្រពត្តិ ទ្រង់ហៅព្រះរាជកុមារ ជាបុត្រច្បងមកហើយ ទ្រង់ត្រាស់ដូច្នេះថា ម្នាលកុមារមាសឪពុក ឮថាចក្ករ័តន៍ជាទិព្វរបស់យើង ឃ្លាតចាកទីហើយ សេចក្តីនេះឪពុកធ្លាប់បានឮមកថា ( បើ ) ចក្ករ័តន៍ជាទិព្វរបស់ស្តេចចក្រពត្តិអង្គណា ឃ្លាតច្យុតចាកទីហើយ តពីនោះមក ស្តេចអង្គនោះមិនរស់នៅបានយូរឡើយ ឯកាមជារបស់មនុស្ស ឪពុកបានបរិភោគ ( ឆ្អែតស្កប់ស្កល់ហើយ ) សម័យនេះជាសម័យដែលឪពុកគួរស្វែងរកកាមជាទិព្វវិញ ម្នាលកុមារមាសឪពុក ចូរអ្នកគ្រប់គ្រងផែនដី ដែលមានសមុទ្រជាព្រំប្រទល់នេះ

ចុះ ឯឪពុកនឹងកោរសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្តប់កាសាវពស្ត្រ ចេញចាកអគារស្ថាន ចូលទៅកាន់ផ្នួស ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង ព្រះបាទចក្រពត្តិ ទ្រង់លួងលោមព្រះរាជកុមារ ជាបុត្រច្បងឲ្យគ្រេគអរក្នុងរាជសម្បត្តិដោយប្រពៃ ទ្រង់ដាក់ព្រះកេសា និងព្រះមស្សុ រួចទ្រង់ស្លៀកដណ្តប់កាសាវពស្ត្រ ចេញចាករាជាគារស្ថាន ចូលទៅទ្រង់ព្រះផ្នួស ។ ម្នាលភិក្ខុទាំងឡាយ កាលព្រះរាជឥសី ទើបនឹងទ្រង់ព្រះផ្នួសបាន ៧ ថ្ងៃ ចក្ករ័តន៍ជាទិព្វក៏បាត់ទៅ ។

[ ៣៨ ] ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង បុរសម្នាក់បានក្រាបបង្គំទូលព្រះរាជាដែលបានមុទ្ធាភិសេកហើយ ។បេ។ ថាចក្ករ័តន៍ជាទិព្វបាត់ទៅហើយ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង កាលបើចក្ករ័តន៍ជាទិព្វបាត់ទៅ ព្រះរាជាជាក្សត្រដែលបានមុទ្ធាភិសេកហើយ ក៏ទ្រង់តូចព្រះហឫទ័យ និងសោយនូវសេចក្តីមិនសប្បាយក្នុងព្រះហឫទ័យ តែមិនចូលទៅសួរវត្តរបស់ស្តេចចក្រពត្តិដ៏ប្រសើរនឹងព្រះរាជឥសីឡើយ ។ បានឮថា ព្រះរាជា ជាក្សត្រដែលបានមុទ្ធាភិសេកហើយនោះ ទ្រង់ប្រៀនប្រដៅអ្នកជនបទ តាមព្រះយោបល់របស់ព្រះអង្គ កាលព្រះរាជានោះប្រៀនប្រដៅអ្នកជនបទ តាមព្រះយោបល់របស់ព្រះអង្គហើយ លុះចំណេរមកខាងក្រោយ អ្នកជនបទក៏មិនចម្រើនស្មើនឹងកាលមុន ដូចកាលស្តេចទាំងឡាយជាន់ដើម ដែលប្រព្រឹត្តវត្តរបស់ស្តេចចក្រពត្តិដ៏ប្រសើរនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ពួកអាមាត្យពួកបរិស័ទ ពួកហោរា និងមហាមាត្យ ពួកហ្មដំរី ពួកអ្នករក្សាទ្វារនិងពួកជន

អ្នកចិញ្ចឹមជីវិតដោយមន្ត្រ ក៏ប្រជុំគ្នា ( ចូលទៅ ) ក្រាបបង្គំទូលព្រះរាជា ជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេកហើយដូច្នេះថា បពិត្រព្រះសម្មតិទេព បាន ឮថា កាលព្រះអង្គទ្រង់ប្រៀនប្រដៅអ្នកជនបទ ដោយព្រះយោបល់របស់ ព្រះអង្គ លុះចំណេរមកខាងក្រោយ ពួកអ្នកជនបទមិនចម្រើនស្មើនឹងកាល មុន ដូចកាលព្រះរាជាទាំងឡាយជាន់ដើម ដែលប្រព្រឹត្តចក្កវត្តិវត្តដ៏ប្រសើរ នោះឡើយ បពិត្រព្រះសម្មតិទេព ពួកអាមាត្យ ពួកបរិស័ទ ពួកហោរា និង មហាមាត្យ ពួកហ្មដីរ ពួកអ្នករក្សាទ្វារ និងពួកជនអ្នកចិញ្ចឹមជីវិតដោយមន្ត្រ ទាំងពួកខ្ញុំព្រះអង្គក្តី ពួកជនដទៃក្តី ក៏មាននៅក្នុងដែន របស់ព្រះអង្គស្រាប់ ហើយ យើងខ្ញុំទាំងឡាយ ( សុទ្ធតែ ) ចាំស្ទាត់ នូវចក្កវត្តិវត្តដ៏ប្រសើរ បពិត្រព្រះសម្មតិទេព ពួកខ្ញុំព្រះអង្គសូមរំឭក សូមព្រះអង្គទ្រង់សួរនូវចក្ក- វត្តិវត្តដ៏ប្រសើរនឹងពួកខ្ញុំព្រះអង្គចុះ ពួកខ្ញុំព្រះអង្គ បើព្រះអង្គទ្រង់ត្រាស់សួរ នូវចក្កវត្តិវត្តដ៏ប្រសើរហើយ មុខជានឹងព្យាករបាន ។

[ ៣៩ ] ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះរាជា ជាក្សត្រដែល បានមុទ្ធាភិសេកហើយ ទ្រង់ត្រាស់បង្គាប់ពួកអាមាត្យ ពួកបរិស័ទ ពួកហោរា និងមហាមាត្យ ពួកហ្មដីរ ពួកអ្នករក្សាទ្វារ និងពួកជនអ្នកចិញ្ចឹមជីវិតដោយ មន្ត្រ ឲ្យប្រជុំគ្នាហើយ ទ្រង់សួរនូវចក្កវត្តិវត្តដ៏ប្រសើរ ។ ជនទាំងនោះ ដែល ព្រះរាជាអង្គនោះទ្រង់សួរនូវចក្កវត្តិវត្តដ៏ប្រសើរហើយ ក៏បានព្យាករថ្វាយ ។ លុះព្រះរាជា ទ្រង់ព្រះសវនាការពាក្យព្យាករ របស់ជនទាំងនោះហើយ ទើប ទ្រង់ចាត់ចែងនូវការរក្សា ទប់ទល់គ្រប់គ្រងប្រកបដោយធម៌វិញ តែទ្រង់មិន

បានព្រះរាជទានព្រះរាជទ្រព្យ ដល់ពួកអ្នកខ្វត់ទ្រព្យឡើយ ។ កាលបើព្រះរាជទ្រព្យ ដែលទ្រង់មិនបានព្រះរាជទានដល់ពួកអ្នកខ្វត់ទ្រព្យ សេចក្តីទ័លក្រ ក៏មានច្រើនឡើង ។ កាលបើសេចក្តីទ័លក្រ មានច្រើនឡើងហើយ មានបុរសម្នាក់កាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច ។ ពួករាជបុរស ចាប់បុរសនោះបាន នាំយកទៅថ្វាយព្រះរាជាជាក្សត្រិយ៍ដែលបានមុទ្ធាភិសេកហើយ ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព បុរសនេះកាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច ។ ម្នាលភិក្ខុទាំងឡាយ កាលបើពួករាជបុរស ក្រាបបង្គំទូលយ៉ាងនេះ ព្រះរាជាជាក្សត្រដែលបានមុទ្ធាភិសេកហើយ ទ្រង់ត្រាស់សួរបុរសនោះដូច្នេះថា នែបុរស អ្នកឯងកាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច ពិតមែនឬ ។ បុរសនោះ ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ពិតមែន ។ ព្រះរាជាទ្រង់ត្រាស់សួរថា ព្រោះហេតុអ្វី ( បានជាអ្នកលួចទ្រព្យគេ ) ។ បុរសនោះក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ព្រោះខ្ញុំព្រះអង្គមិនមាន ( របស់អ្វី ) នឹងចិញ្ចឹមជីវិត ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះរាជា ជាក្សត្រិយ៍ដែលបានមុទ្ធាភិសេកហើយ ក៏ទ្រង់ព្រះរាជទានព្រះរាជទ្រព្យដល់បុរសនោះ រួចទ្រង់ត្រាស់បង្គាប់ថា ម្នាលបុរសដ៏ចម្រើន អ្នកចូរយកទ្រព្យនេះទៅចិញ្ចឹមជីវិតខ្លួនផង ចិញ្ចឹមមាតាបិតាផង ចិញ្ចឹមបុត្រភរិយាផង ប្រកបការងារផង ចូរតម្កល់ទក្ខិណាទាន ដែលមានផលខ្ពង់ខ្ពស់ ចំពោះសមណព្រាហ្មណ៍ទាំងឡាយ ជា

ទានអាចនាំសត្វឲ្យកើតក្នុងឋានសួគ៌ មានផលជាសុខ ប្រព្រឹត្តទៅ ដើម្បីកើតក្នុងឋានសួគ៌ផងចុះ ។ ម្នាលភិក្ខុទាំងឡាយ បុរសនោះ ក៏ទទួលព្រះរាជឱង្ការនៃព្រះរាជា ជាក្សត្រិយ៍ដែលបានមុទ្ធាភិសេកហើយ ដោយពាក្យថា ព្រះករុណាថ្លៃវិសេស ។ ម្នាលភិក្ខុទាំងឡាយ មានបុរសម្នាក់ទៀត កាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលគេហៅថា លួច ។ ពួករាជបុរសចាប់បុរសនោះបាន ក៏នាំយកទៅថ្វាយព្រះរាជា ជាក្សត្រិយ៍ដែលបានមុទ្ធាភិសេកហើយ ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព បុរសនេះកាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច ។ ម្នាលភិក្ខុទាំងឡាយ កាលបើពួករាជបុរសក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះរាជាជាក្សត្រដែលបានមុទ្ធាភិសេកហើយ ក៏ទ្រង់ត្រាស់សួរបុរសនោះយ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន អ្នកឯងកាន់យកទ្រព្យរបស់ជនទាំង-ឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច ពិតមែនឬ ។ បុរសនោះក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ពិតមែន ។ ព្រះរាជាទ្រង់ត្រាស់សួរថា ព្រោះហេតុអ្វី ( បានជាអ្នកឯងលួចទ្រព្យគេ ) ។ បុរសនោះក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ព្រោះខ្ញុំព្រះអង្គមិនមាន ( របស់អ្វី ) នឹងចិញ្ចឹមជីវិត ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង ព្រះរាជា ជាក្សត្រដែលបានមុទ្ធាភិសេកហើយ ក៏ទ្រង់ព្រះរាជទានព្រះរាជទ្រព្យដល់បុរសនោះ រួចទ្រង់ត្រាស់បង្គាប់ថា ម្នាលបុរសដ៏ចម្រើន អ្នកចូរយកទ្រព្យនេះទៅចិញ្ចឹមជីវិតដោយខ្លួនឯងផង ចិញ្ចឹមមាតាបិតាផង ចិញ្ចឹមបុត្រភរិយាផង ប្រកបការងារ

ផង បូរតម្កល់នូវទក្ខិណាទាន ដែលមានផលខ្ពង់ខ្ពស់ ចំពោះសមណព្រាហ្មណ៍ទាំងឡាយ ជាទានអាចនាំសត្វឲ្យកើតក្នុងឋានសួគ៌ មានផលជាសុខ ប្រព្រឹត្តទៅដើម្បីកើតក្នុងឋានសួគ៌ផងចុះ ។ ម្នាលភិក្ខុទាំងឡាយ បុរសនោះ ក៏ទទួលព្រះរាជឱង្ការ ព្រះរាជា ជាក្សត្រិយ៍ដែលបានមុទ្ធាភិសេកហើយ ដោយពាក្យថា ព្រះករុណាថ្លៃវិសេស ។ ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សបានឮដំណឹងថា ព្រះរាជាទ្រង់ព្រះរាជទាននូវព្រះរាជទ្រព្យ ដល់ពួកមនុស្សដែលកាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យដែលហៅថា លួច ។ លុះមនុស្សទាំងនោះបានឮហើយ ក៏មានសេចក្តីត្រិះរិះដូច្នេះថា បើដូច្នេះ មានតែពួកយើងនាំគ្នាទៅកាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច ( កុំខាន ) ។

[ ៤០ ] ម្នាលភិក្ខុទាំងឡាយ លុះគ្រាជាខាងក្រោយមក មានបុរសម្នាក់កាន់យកទ្រព្យ របស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច ។ ពួករាជបុរសចាប់បុរសនោះបាន ក៏នាំយកទៅថ្វាយព្រះរាជា ជាក្សត្រិយ៍ដែលបានមុទ្ធាភិសេកហើយ ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព បុរសនោះឯងកាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច ។ ម្នាលភិក្ខុទាំងឡាយ កាលបើពួករាជបុរសក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះរាជា ជាក្សត្រដែលបានមុទ្ធាភិសេកហើយ ក៏ទ្រង់ត្រាស់សួរបុរសនោះយ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន អ្នកឯងកាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច ពិត

មែនឬ ។ បុរសនោះ ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ពិតមែន ។ ព្រះរាជាទ្រង់ត្រាស់សួរថា ព្រោះហេតុអ្វី ( បានជាអ្នកឯងលួចទ្រព្យគេ ) ។ បុរសនោះក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ព្រោះខ្ញុំព្រះអង្គមិនមាន ( របស់អ្វី ) នឹងចិញ្ចឹមជីវិត ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះរាជា ជាក្សត្រដែលបានមុទ្ធាភិសេកហើយ ទ្រង់មានសេចក្តីត្រិះរិះដូច្នេះថា បើអាត្មាអញនៅតែឲ្យទ្រព្យដល់អ្នកដែលកាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច តែយ៉ាងនេះ មុខជាអទិន្នាទាននេះ នឹងរីងរឹតតែចម្រើនឡើង បើដូច្នោះ គួរតែអាត្មាអញផ្ចាញ់ផ្ចាលបុរសនេះ គួរធ្វើនូវការផ្តាច់ផ្តិលឫសគល់ គឺកាត់ក្បាលវាចេញ ។ ម្នាលភិក្ខុទាំងឡាយ ទើបព្រះរាជា ជាក្សត្រិយ៍ដែលបានមុទ្ធាភិសេកហើយ ទ្រង់ត្រាស់បង្គាប់ពួករាជ-បុរសថា នែព្រះស្នេហ៍ បើដូច្នោះ ចូរអ្នកទាំងឡាយចងស្លាបសេកបុរសនេះឲ្យជាប់ដោយខ្សែដ៏មាំ ហើយកោរក្បាលឲ្យរលីង រួច ( ត្រូវទូង ) ស្គរដែលមានសំឡេងឮខ្លាំង នាំបណ្តើរជុំវិញសព្វច្រក សព្វផ្លូវបំបែករួចនាំចេញទៅតាមទ្វារខាងត្បូង ហើយចូរផ្ចាញ់ផ្ចាល ធ្វើនូវការផ្តាច់ឫសគល់ គឺកាត់ក្បាលវាចេញ ក្នុងទិសខាងត្បូងនៃក្រុងចុះ ។ ម្នាលភិក្ខុទាំងឡាយ រាជបុរសទាំងនោះ ទទួលព្រះរាជឱង្ការព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេកហើយដោយពាក្យថា ព្រះករុណាថ្លៃវិសេស ហើយចងស្លាបសេកបុរសនោះឲ្យជាប់ដោយខ្សែដ៏មាំ រួចកោរក្បាលឲ្យរលីង ( ទូង ) ស្គរដែលមានសំឡេងឮខ្លាំង នាំបណ្តើរជុំវិញសព្វច្រក សព្វផ្លូវបំបែក នាំចេញតាមទ្វារខាងត្បូង ហើយ

ផ្ចាញ់ផ្ចាល ធ្វើនូវការផ្តាច់ផ្តិលឫសគល់ គឺកាត់ក្បាលបុរសនោះ ក្នុងទិសខាងត្បូងនៃក្រុង ។

[ ៤១ ] ម្នាលភិក្ខុទាំងឡាយ ពួកមនុស្សបានឮដំណឹងថា ពួកជនណាកាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច ព្រះរាជាទ្រង់ផ្ចាញ់ផ្ចាលនូវជនទាំងនោះ ទ្រង់ធ្វើនូវការផ្តាច់ផ្តិលឫសគល់ គឺទ្រង់កាត់ក្បាលពួកជនទាំងនោះ ។ លុះមនុស្សទាំងនោះបានឮហើយ ក៏គិតយ៉ាងនេះថា បើដូច្នោះ មានតែពួកយើងនាំគ្នាធ្វើគ្រឿងសាស្ត្រាវុធដ៏មុតក្លា លុះនាំគ្នាធ្វើគ្រឿងសាស្ត្រាវុធដ៏មុតក្លារួចហើយ នឹងកាន់យកទ្រព្យរបស់ពួកជនណា ដែលគេមិនបានឲ្យ ដែលហៅថា លួច ហើយពួកយើងនឹងផ្ចាញ់ផ្ចាលនូវជនទាំងនោះ នឹងធ្វើនូវការផ្តាច់ផ្តិលនូវឫសគល់ គឺកាត់ក្បាលរបស់ជនទាំងនោះចេញ ។ មនុស្សទាំងនោះ ក៏នាំគ្នាធ្វើគ្រឿងសាស្ត្រាវុធដ៏មុតក្លា លុះនាំគ្នាធ្វើគ្រឿងសាស្ត្រាវុធដ៏មុតក្លារួចហើយ ក៏ព្យាយាមធ្វើនូវការសម្លាប់អ្នកស្រុកខ្លះ ព្យាយាមធ្វើនូវការសម្លាប់អ្នកនិគមខ្លះ ព្យាយាមធ្វើនូវការសម្លាប់អ្នកនគរខ្លះ ព្យាយាមធ្វើនូវការប្លន់អ្នកដើរផ្លូវខ្លះ ។ មនុស្សទាំងនោះតែងកាន់យកទ្រព្យរបស់ពួកជនណា ដែលគេមិនបានឲ្យ ដែលហៅថា លួច ហើយផ្ចាញ់ផ្ចាលពួកជនទាំងនោះ ធ្វើនូវការផ្តាច់ផ្តិលឫសគល់ គឺកាត់ក្បាលជនទាំងនោះ ។

[ ៤២ ] ម្នាលភិក្ខុទាំងឡាយ កាលបើព្រះមហាក្សត្រ មិនទ្រង់ព្រះរាជទានព្រះរាជទ្រព្យដល់ពួកអ្នកខ្សត់ទ្រព្យដូច្នេះ សេចក្តីទាល់ក្រក៏មានច្រើន

ឡើង កាលបើសេចក្តីទល័ក្រមានច្រើនឡើងហើយ អទិន្នាទាន ក៏មានច្រើនឡើង កាលបើអទិន្នាទានមានច្រើនឡើងហើយ បាណាតិបាត ក៏មានច្រើនឡើង កាលបើបាណាតិបាត មានច្រើនឡើងហើយ មុសាវាទ ក៏មានច្រើនឡើង កាលបើមុសាវាទ មានច្រើនឡើងហើយ ទាំងអាយុ ទាំងពណ៌សម្បុររបស់សត្វទាំងនោះក៏ថយចុះ កាលសត្វទាំងនោះថយទាំងអាយុ ថយទាំងពណ៌សម្បុរចុះហើយ កូនទាំងឡាយរបស់មនុស្សដែលមានអាយុ ៨ ម៉ឺនឆ្នាំ ក៏ថយមកមានអាយុត្រឹម ៤ ម៉ឺនឆ្នាំវិញ ម្នាលភិក្ខុទាំងឡាយ បណ្តាពួកមនុស្សដែលមានអាយុត្រឹម ៤ ម៉ឺនឆ្នាំ ( នោះ ) មានបុរសម្នាក់ កាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច ។ ពួករាជបុរសក៏ចាប់បុរសនោះ នាំយកទៅថ្វាយព្រះរាជា ជាក្សត្រិយ៍ដែលបានមុទ្ធាភិសេកហើយក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព បុរសនេះកាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច ។ ម្នាលភិក្ខុទាំងឡាយ កាលបើពួករាជបុរសក្រាបបង្គំទូលយ៉ាងនេះហើយ ទើបព្រះរាជា ជាក្សត្រិយ៍ដែលបានមុទ្ធាភិសេក ទ្រង់ត្រាស់សួរបុរសនោះយ៉ាងនេះថា នែបុរសដ៏ចម្រើន អ្នកឯងកាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច ពិតមែនឬ ។ បុរសនោះ ក៏ពោលសម្បជានមុសាវាទថា បពិត្រព្រះសម្មតិទេព មិនមែនទេ ។

[ ៤៣ ] ម្នាលភិក្ខុទាំងឡាយ កាលបើព្រះមហាក្សត្រិយ៍ មិនទ្រង់ព្រះរាជទានព្រះរាជទ្រព្យដល់ពួកអ្នកខ្វះទ្រព្យដូច្នេះហើយ សេចក្តីទល័ក្រ ក៏មាន

ច្រើនឡើង កាលបើសេចក្តីទ័លក្រ មានច្រើនឡើងហើយ អទិន្នាទាន ក៏មានច្រើនឡើង កាលបើអទិន្នាទាន មានច្រើនឡើងហើយ គ្រឿងសស្ត្រាវុធក៏មានច្រើនឡើង កាលបើគ្រឿងសស្ត្រាវុធមានច្រើនឡើងហើយ បាណាតិបាត ក៏មានច្រើនឡើង កាលបើបាណាតិបាតមានច្រើនឡើងហើយ មុសាវាទក៏មានច្រើនឡើង កាលបើមុសាវាទមានច្រើនឡើងហើយ ទាំងអាយុ ទាំងពណ៌សម្បុររបស់សត្វទាំងនោះក៏ថយចុះ កាលសត្វទាំងនោះថយទាំងអាយុ ថយទាំងពណ៌សម្បុរចុះហើយ កូនទាំងឡាយរបស់មនុស្សដែលមានអាយុ ៤ ម៉ឺនឆ្នាំ ក៏ថយមកមានអាយុត្រឹម ២ ម៉ឺនឆ្នាំវិញ ម្នាលភិក្ខុទាំងឡាយ បណ្តាពួកមនុស្សដែលមានអាយុត្រឹម ២ ម៉ឺនឆ្នាំ ( នោះ ) មានបុរសម្នាក់កាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច ។ បុរសម្នាក់នាំយកសេចក្តីនុ៎ះ ទៅក្រាបបង្គំទូល ញុះញង់ព្រះរាជា ជាក្សត្រិយ៍ដែលបានមុទ្ធាភិសេកហើយថា បពិត្រព្រះសម្មតិទេព បុរសឈ្មោះនេះ កាន់យកទ្រព្យរបស់ជនទាំងឡាយដទៃ ដែលគេមិនបានឲ្យ ដែលហៅថា លួច ។

[ ៤៤ ] ម្នាលភិក្ខុទាំងឡាយ កាលបើព្រះមហាក្សត្រិយ៍ មិនទ្រង់ព្រះរាជទានព្រះរាជទ្រព្យ ដល់អ្នកខ្វត់ទ្រព្យដូច្នេះហើយ សេចក្តីទ័លក្រ ក៏មានច្រើនឡើង កាលបើសេចក្តីទ័លក្រ មានច្រើនឡើងហើយ ។បេ។ បិសុណាវាចា ក៏មានច្រើនឡើង កាលបើបិសុណាវាចាមានច្រើនឡើងហើយ ទាំងអាយុ ទាំងពណ៌សម្បុររបស់សត្វទាំងនោះក៏ថយចុះ កាលសត្វទាំងនោះថយទាំងអាយុ ថយទាំងពណ៌សម្បុរចុះហើយ កូនទាំងឡាយរបស់មនុស្សដែល

មានអាយុ ២ ម៉ឺនឆ្នាំ ក៏ថយចុះមកមានអាយុត្រឹម ១ ម៉ឺនឆ្នាំវិញ ម្នាលភិក្ខុទាំងឡាយ បណ្តាពួកមនុស្សដែលមានអាយុ ១ ម៉ឺនឆ្នាំ ( នោះ ) សត្វពួកខ្លះមានពណ៌សម្បុរល្អ សត្វពួកខ្លះមានពណ៌សម្បុរអាក្រក់ បណ្តាសត្វទាំងពីរពួកនោះ សត្វណា ដែលមានពណ៌សម្បុរអាក្រក់ ក៏ស្រឡាញ់ពួកសត្វដែលមានពណ៌សម្បុរល្អ ក៏ប្រព្រឹត្តមិច្ឆាចារក្នុងភរិយារបស់ពួកជនដទៃ ។

[ ៤៥ ] ម្នាលភិក្ខុទាំងឡាយ កាលបើព្រះមហាក្សត្រ មិនទ្រង់ព្រះរាជទានព្រះរាជទ្រព្យ ដល់ពួកអ្នកខ្វះទ្រព្យ ដូច្នេះហើយ សេចក្តីទ័លក្រ ក៏មានច្រើនឡើង កាលបើសេចក្តីទ័លក្រ មានច្រើនឡើងហើយ អទិន្នាទាន ក៏មានច្រើនឡើង កាលបើអទិន្នាទាន មានច្រើនឡើងហើយ ។ សេចក្តីសង្ខេប ។ កាមេសុមិច្ឆាចារ ក៏មានច្រើនឡើង កាលបើកាមេសុមិច្ឆាចារ មានច្រើនឡើងហើយ ទាំងអាយុទាំងពណ៌សម្បុរ របស់សត្វទាំងនោះក៏ថយចុះ កាលសត្វទាំងនោះ ថយទាំងអាយុ ថយទាំងពណ៌សម្បុរចុះហើយ កូនទាំងឡាយរបស់មនុស្សដែលមានអាយុ ១ ម៉ឺនឆ្នាំ ក៏ថយចុះមកមានអាយុត្រឹម ៥ ពាន់ឆ្នាំវិញ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ២ ប្រការ គឺផរុសវាចា ១ សម្ផប្បលាបៈ ១ ក៏មានច្រើនឡើង ក្នុងពួកមនុស្ស ដែលមានអាយុត្រឹម ៥ ពាន់ឆ្នាំ កាលបើធម៌ទាំងពីរប្រការមានច្រើនឡើងហើយ ទាំងអាយុ ទាំងពណ៌សម្បុររបស់សត្វទាំងនោះក៏ថយចុះ កាលសត្វទាំងនោះថយទាំងអាយុ ថយទាំងពណ៌សម្បុរចុះហើយ កូនទាំងឡាយរបស់ពួកមនុស្សដែលមានអាយុ ៥ ពាន់ឆ្នាំ ពួកខ្លះក៏ថយមកមានអាយុត្រឹម ២ ពាន់ ៥ រយឆ្នាំវិញ ពួកខ្លះ

ក៏ថយមកមានអាយុត្រឹម ២ ពាន់ឆ្នាំវិញ ម្នាលភិក្ខុទាំងឡាយ អភិជ្ឈា និង ព្យាបាទ ក៏មានច្រើនឡើង ក្នុងពួកមនុស្សដែលមានអាយុត្រឹម ២ ពាន់ ៥ រយឆ្នាំ កាលអភិជ្ឈា និងព្យាបាទ មានច្រើនឡើងហើយ ទាំងអាយុទាំងពណ៌សម្បុររបស់សត្វទាំងនោះក៏ថយចុះ កាលសត្វទាំងនោះថយទាំងអាយុ ថយទាំងពណ៌សម្បុរចុះហើយ កូនទាំងឡាយរបស់មនុស្សដែលមានអាយុ ២ ពាន់ ៥ រយឆ្នាំ ក៏ថយមកមានអាយុត្រឹម ១ ពាន់ឆ្នាំវិញ ម្នាលភិក្ខុទាំងឡាយ មិច្ឆាទិដ្ឋិក៏មានច្រើនឡើងក្នុងពួកមនុស្សដែលមានអាយុត្រឹម ១ ពាន់ឆ្នាំ កាលបើមិច្ឆាទិដ្ឋិមានច្រើនឡើងហើយ ទាំងអាយុ ទាំងពណ៌សម្បុររបស់សត្វទាំងនោះក៏ថយចុះ កាលសត្វទាំងនោះថយទាំងអាយុ ថយទាំងពណ៌សម្បុរចុះហើយ កូនទាំងឡាយរបស់មនុស្សដែលមានអាយុ ១ ពាន់ឆ្នាំ ក៏ថយមកមានអាយុត្រឹម ៥ រយឆ្នាំវិញ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ៣ ប្រការ គឺអធម្មរាគៈ ១ វិសមលោភៈ ១ មិច្ឆាធម្មៈ ១ ក៏មានច្រើនឡើងក្នុងពួកមនុស្សដែលមានអាយុត្រឹម ៥ រយឆ្នាំ កាលបើធម៌ ៣ ប្រការ មានច្រើនឡើងហើយ ទាំងអាយុ ទាំងពណ៌សម្បុររបស់សត្វទាំងនោះក៏ថយចុះ កាលសត្វទាំងនោះថយទាំងអាយុ ថយទាំងពណ៌សម្បុរចុះហើយ កូនទាំងឡាយរបស់មនុស្សដែលមានអាយុ ៥ រយឆ្នាំ ពួកខ្លះក៏ថយមកមានអាយុត្រឹម ២ រយ ៥០ ឆ្នាំវិញ ពួកខ្លះក៏ថយមកមានអាយុត្រឹម ២ រយឆ្នាំវិញ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយនេះ គឺការមិនគោរពមាតា មិនគោរពបិតា មិនគោរពសមណៈ មិនគោរពព្រាហ្មណ៍ មិនប្រព្រឹត្តកោតក្រែងដល់បុគ្គលជាធំក្នុង

ត្រកូល ក៏មានច្រើនឡើង ក្នុងពួកមនុស្សដែលមានអាយុត្រឹម ២ រយ ៥០ ។ ម្នាលភិក្ខុទាំងឡាយ កាលបើព្រះមហាក្សត្រ មិនទ្រង់ព្រះរាជទានព្រះរាជ-ទ្រព្យដល់ពួកអ្នកខ្សត់ទ្រព្យដូច្នេះហើយ សេចក្តីទំលក្រ ក៏មានច្រើនឡើង កាលបើសេចក្តីទំលក្រ មានច្រើនឡើងហើយ អទិន្នាទាន ក៏មានច្រើនឡើង កាលអទិន្នាទាន មានច្រើនឡើងហើយ គ្រឿងសស្ត្រាវុធក៏មានច្រើនឡើង កាលគ្រឿងសស្ត្រាវុធមានច្រើនឡើងហើយ បាណាតិបាត ក៏មានច្រើនឡើង កាលបាណាតិបាតមានច្រើនឡើងហើយ មុសាវាទក៏មានច្រើនឡើង កាលមុសាវាទមានច្រើនឡើងហើយ បិសុណាវាចា ក៏មានច្រើនឡើង កាលបិសុ-ណាវាចាមានច្រើនឡើងហើយ កាមេសុមិច្ឆាចារ ក៏មានច្រើនឡើង កាលកាមេសុមិច្ឆាចារមានច្រើនឡើងហើយ ធម៌ ២ ប្រការ គឺផរុសវាចា ១ សម្ផប្បលាបៈ ១ ក៏មានច្រើនឡើង កាលធម៌ ២ ប្រការ មានច្រើនឡើងហើយ អភិជ្ឈា និងព្យាបាទ ក៏មានច្រើនឡើង កាលអភិជ្ឈា និងព្យាបាទមានច្រើនឡើងហើយ មិច្ឆាទិដ្ឋិ ក៏មានច្រើនឡើង កាលមិច្ឆាទិដ្ឋិមានច្រើនឡើងហើយ ធម៌ ៣ ប្រការ គឺអធម្មរាគៈ ១ វិសមលោភៈ ១ មិច្ឆាធម្មៈ ១ ក៏មានច្រើនឡើង កាលធម៌ ៣ ប្រការមានច្រើនឡើងហើយ ធម៌ទាំង-ឡាយនេះ គឺការមិនគោរពមាតា មិនគោរពបិតា មិនគោរពសមណៈ មិនគោរពព្រាហ្មណ៍ មិនប្រព្រឹត្តកោតក្រែងដល់បុគ្គលជាធំក្នុងត្រកូល ក៏មានច្រើនឡើង កាលធម៌ទាំងនេះ មានច្រើនឡើងហើយ ទាំងអាយុ ទាំងពណ៌សម្បុររបស់សត្វទាំងនោះ ក៏ថយចុះ កាលសត្វទាំងនោះ ថយទាំងអាយុ

ថយទាំងពណ៌សម្បុរចុះហើយ កូនទាំងឡាយរបស់មនុស្ស ដែលមានអាយុ ២ រយ ៥០ ឆ្នាំ ក៏ថយមកមាន អាយុត្រឹម ១ រយឆ្នាំវិញ ។

[ ៤៦ ] ម្នាលភិក្ខុទាំងឡាយ ( តទៅខាងមុខ ) នឹងមានសម័យដែលកូនរបស់មនុស្សទាំងនេះ មានអាយុ ១០ ឆ្នាំ កាលបើមនុស្សមានអាយុ ១០ ឆ្នាំ ពួកនាងកុមារិកាអាយុ ៥ ឆ្នាំ នឹងល្មមឲ្យមានប្តី ម្នាលភិក្ខុទាំងឡាយ កាលបើមនុស្សមានអាយុ ១០ ឆ្នាំ រស ( ដ៏ប្រសើរ ) ទាំងនេះ គឺទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ទឹកអំពៅ អំបិល នឹងបាត់ទៅ ម្នាលភិក្ខុទាំងឡាយ កាលបើពួកមនុស្សមានអាយុ ១០ ឆ្នាំ ស្មៅគែលលក នឹងជាភោជនដ៏ប្រសើរ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលឥឡូវនេះ បាយស្រូវសាលីលាយដោយសាច់ ជាភោជនដ៏ប្រសើរដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ កាលបើពួកមនុស្សមានអាយុ ១០ ឆ្នាំ ស្មៅគែលលកនឹងជាភោជនដ៏ប្រសើរយ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ កាលបើពួកមនុស្សមានអាយុ ១០ ឆ្នាំ កុសល-កម្មបថទាំង ១០ នឹងសាបសូន្យទៅគ្រប់អន្លើ អកុសលកម្មបថទាំង ១០ នឹងចម្រើនឡើង ម្នាលភិក្ខុទាំងឡាយ កាលបើពួកមនុស្ស មានអាយុ ១០ ឆ្នាំ សូម្បីពាក្យថា កុសលក៏មិនមាន បើដល់ម៉្លោះទៅហើយ មនុស្សអ្នកធ្វើកុសលតើនឹងមានមកពីណា ម្នាលភិក្ខុទាំងឡាយ កាលបើពួកមនុស្សមានអាយុ ១០ ឆ្នាំ ជនទាំងឡាយណា ជាអ្នកមិនគោរពមាតា មិនគោរពបិតា មិនគោរពសមណៈ មិនគោរពព្រាហ្មណ៍ មិនប្រព្រឹត្តកោតក្រែងបុគ្គលជាច្បងក្នុងត្រកូល ជនទាំងនោះនឹងជាអ្នកគួរគេបូជាផង នឹងជាអ្នកគួរគេសរសើរផង ម្នាលភិក្ខុ

ទាំងឡាយ មនុស្សក្នុងកាលឥឡូវនេះ ដែលជាអ្នកគោរពមាតា គោរពបិតា គោរពសមណៈ គោរពព្រាហ្មណ៍ ប្រព្រឹត្តកោតក្រែងបុគ្គល ជាច្បងក្នុងត្រកូល មនុស្សទាំងនោះ ទើបជាអ្នកគួរគេបូជាផង គួរសរសើរផង ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ កាលដែលពួកមនុស្សមានអាយុ ១០ ឆ្នាំ ជនណាមិនគោរពមាតា មិនគោរពបិតា មិនគោរពសមណៈ មិនគោរពព្រាហ្មណ៍ មិនប្រព្រឹត្តកោតក្រែងបុគ្គលជាច្បងក្នុងត្រកូល ជនទាំងនោះ ទើបជាអ្នកគួរគេបូជាផង គួរគេសរសើរផង ដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ កាលដែលមនុស្សមានអាយុ ១០ ឆ្នាំ នឹងមិនមានសេចក្តីគោរពកោតក្រែងថា ( អ្នកនេះ ) ជាមាតា ជាម្តាយមីងខាងមាតា ជាបិតា ជាម្តាយមីងខាងបិតា ជាម្តាយធំខាងមាតា ជាភរិយារបស់អាចារ្យ ឬថាជាប្រពន្ធរបស់គ្រូ ( នៃខ្លួន ) ដូច្នេះឡើយ សត្វលោកនឹងប្រឡូកប្រឡំគ្នា ដូចជាពពែ មាន់ ជ្រូក ឆ្កែ ចចក ដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ កាលដែលមនុស្សមានអាយុ ១០ ឆ្នាំ គំនុំដ៏ក្លៀវក្លា ព្យាបាទដ៏ក្លៀវក្លា ចិត្តប្រទូស្តដ៏ក្លៀវក្លា ចិត្តប្រាថ្នានឹងសម្លាប់ដ៏ក្លៀវក្លា នឹងកើតប្រាកដដល់គ្នានិងគ្នា គឺមាតានិងបុត្ត ។ បុត្តនិងមាតា ។ បិតានិងបុត្ត ។ បុត្តនិងបិតា ។ បងប្អូនប្រុសនិងបងប្អូនស្រី ។ គំនុំដ៏ក្លៀវក្លា ព្យាបាទដ៏ក្លៀវក្លា ចិត្តប្រទូស្តដ៏ក្លៀវក្លា ចិត្តប្រាថ្នានឹងសម្លាប់ដ៏ក្លៀវក្លារបស់បងប្អូន ស្រីនឹងកើតប្រាកដឡើងដល់បងប្អូនប្រុស ម្នាលភិក្ខុទាំងឡាយ គំនុំដ៏ក្លៀវក្លា ព្យាបាទដ៏ក្លៀវក្លា ចិត្តប្រទូស្តដ៏ក្លៀវក្លា ចិត្តប្រាថ្នានឹងសម្លាប់ដ៏ក្លៀវក្លារបស់ព្រានម្រឹគ កើតឡើងប្រាកដ ព្រោះឃើញម្រឹគ មានឧបមាដូច

ម្តេចមិញ ម្នាលភិក្ខុទាំងឡាយ កាលដែលមនុស្សមានអាយុ ១០ ឆ្នាំ គំនុំដ៏ក្លៀវក្លា ព្យាបាទដ៏ក្លៀវក្លា ចិត្តប្រទូស្តដ៏ក្លៀវក្លា ចិត្តប្រាថ្នានឹងសម្លាប់ដ៏ក្លៀវក្លា របស់សត្វទាំងនោះ នឹងកើតប្រាកដដល់គ្នានិងគ្នា មានឧបមេយ្យដូច្នោះឯង គឺមាតានិងបុត្ត ។ បុត្តនិងមាតា ។ បិតានិងបុត្ត ។ បុត្តនិងបិតា ។ បងប្អូនប្រុសនិងបងប្អូនស្រី ។ គំនុំដ៏ក្លៀវក្លា ព្យាបាទដ៏ក្លៀវក្លា ចិត្តប្រទូស្តដ៏ក្លៀវក្លា ចិត្តប្រាថ្នានឹងសម្លាប់ដ៏ក្លៀវក្លា របស់បងប្អូនស្រីនឹងកើតប្រាកដដល់បងប្អូនប្រុស ។

[ ៤៧ ] ម្នាលភិក្ខុទាំងឡាយ កាលដែលមនុស្សមានអាយុ ១០ ឆ្នាំ សត្ថន្តរកប្ប ( លោកវិនាសទៅដោយគ្រឿងសស្ត្រាវុធ ) នឹងកើតមានឡើងអស់ ៧ ថ្ងៃ មនុស្សទាំងនោះនឹងសម្គាល់គ្នាថា ដូចជាម្រឹគ គ្រឿងសស្ត្រាវុធដ៏មុតក្លានឹងជាប់នៅតែក្នុងដៃនៃមនុស្សទាំងនោះ មនុស្សទាំងនោះសម្គាល់ថានេះជាម្រឹគ ហើយក៏ផ្តាច់ជីវិតគ្នានិងគ្នា ដោយគ្រឿងសស្ត្រាវុធដ៏មុតក្លា ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង បណ្តាសត្វទាំងនោះ សត្វពួកខ្លះនឹងគិតគ្នាយ៉ាងនេះថា ពួកយើងកុំសម្លាប់បុរសណាមួយឡើយ ទាំងបុរសណាមួយក៏កុំសម្លាប់ពួកយើងឡើយ បើដូច្នោះ ពួកយើងគួរចូលទៅរកស្មៅស្បាត ព្រៃស្បាត ឈើស្បាត ស្ទឹងដែលទៅមកបានដោយលំបាក ឬភ្នំដែលមិនរាបស្មើ ហើយយកមើម និងផ្លែក្នុងព្រៃ ជាអាហារចិញ្ចឹមជីវិត ។ សត្វទាំងនោះ នឹងចូលទៅរកស្មៅស្បាត ព្រៃស្បាត ឈើស្បាត ស្ទឹងដែលទៅមកបានដោយលំបាក ឬភ្នំដែលមិនរាបស្មើ ហើយយកមើម និងផ្លែក្នុងព្រៃ ជាអាហារ

ចិញ្ចឹមជីវិតអស់ ៧ ថ្ងៃ ។ លុះថ្ងៃ ៧ នោះកន្លងទៅ ទើបសត្វអម្បាលនោះ ចេញមកអំពីស្មៅស្បាត អំពីព្រៃស្បាត អំពីឈើស្បាត អំពីស្ទឹងដែលទៅមកបានដោយលំបាក អំពីភ្នំដែលមិនរាបស្មើ ហើយឱបគ្នាទៅវិញទៅមក រួចហើយនិយាយរាក់ទាក់ លួងលោមគ្នាក្នុងរវាងទាំងឡាយដោយពាក្យថា ម្នាលអ្នកដ៏ចម្រើន អ្នករស់នៅដូចពួកសត្វដែលយើងបានឃើញហើយ ម្នាលអ្នកដ៏ចម្រើន អ្នករស់នៅដូចពួកសត្វដែលយើងបានឃើញហើយ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង សត្វអម្បាលនោះ នឹងមានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកយើងនេះឯង បានជាដល់នូវការអស់ទៅនៃញាតិជាច្រើន ដូច្នេះព្រោះហេតុតែកាន់ធម៌ជាអកុសលទាំងឡាយ បើដូច្នោះ មានតែពួកយើងធ្វើកុសលវិញ តើគួរធ្វើកុសលដូចម្តេច ណ្ហើយចុះ ពួកយើង គួរវៀរចាកបាណាតិបាត ប្រព្រឹត្តសមាទាននូវកុសលធម៌នេះចុះ ។ ទើបសត្វទាំងនោះនាំគ្នាវៀរចាកបាណាតិបាត ប្រព្រឹត្តសមាទាននូវកុសលធម៌នេះ សត្វទាំងនោះក៏ចម្រើនអាយុ ចម្រើនពណ៌សម្បុរឡើង ព្រោះហេតុដែលបានសមាទាននូវកុសលធម៌ទាំងឡាយ កាលសត្វទាំងនោះបានចម្រើនអាយុ ចម្រើនពណ៌សម្បុរហើយ កូនទាំងឡាយរបស់ពួកមនុស្ស ដែលមានអាយុ ១០ ឆ្នាំ ក៏ត្រឡប់ទៅជាមានអាយុ ២០ ឆ្នាំឡើងវិញ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង សត្វអម្បាលនោះ នឹងមានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកយើងបានចម្រើនអាយុ បានចម្រើនពណ៌សម្បុរឡើងវិញ ព្រោះហេតុតែបានសមាទាននូវកុសលធម៌ទាំងឡាយ បើដូច្នោះ ពួកយើងគួរធ្វើកុសលឲ្យច្រើនក្រៃលែង

ជាងនេះទៅទៀត តើគួរធ្វើកុសលអ្វី ណ្ហើយចុះ ពួកយើងគួរវៀរចាកអទិន្នាទាន គួរវៀរចាកកាមេសុមិច្ឆាចារ គួរវៀរចាកបិសុណាវាចា គួរវៀរចាកផរុសវាចា គួរវៀរចាកសម្ផប្បលាបៈ គួរលះបង់អភិជ្ឈា គួរលះបង់ព្យាបាទ គួរលះបង់មិច្ឆាទិដ្ឋិចេញ គួរលះបង់ធម៌ ៣ ប្រការ គឺអធម្មរាគៈ ១ វិសមលោភៈ ១ មិច្ឆាធម្មៈ ១ ចេញ បើដូច្នោះ ពួកយើងគួរជាអ្នកគោរពមាតា គោរពបិតា គោរពសមណៈ គោរពព្រាហ្មណ៍ និងជាអ្នកប្រព្រឹត្តកោតក្រែងបុគ្គលជាច្បង ក្នុងត្រកូល ពួកយើងគួរនាំគ្នាប្រព្រឹត្ត សមាទាននូវកុសលធម៌ទាំងនេះចុះ ។ សត្វទាំងនោះ ក៏ជាអ្នកគោរពមាតា គោរពបិតា គោរពសមណៈ គោរពព្រាហ្មណ៍ និងជាអ្នកប្រព្រឹត្តកោតក្រែងត្រកូលរៀមច្បង ប្រព្រឹត្តសមាទាននូវកុសលធម៌នេះ ក៏បានចម្រើនអាយុ ចម្រើនពណ៌សម្បុរឡើងវិញ ព្រោះហេតុដែលបានសមាទាននូវកុសលធម៌ទាំងនោះ កាលសត្វអម្បាលនោះចម្រើនអាយុ ចម្រើនពណ៌សម្បុរឡើងហើយ កូនទាំងឡាយរបស់ពួកមនុស្សដែលមានអាយុ ២០ ឆ្នាំ ក៏មានអាយុ ៤០ ឆ្នាំឡើងវិញ ។ កូនទាំងឡាយរបស់ពួកមនុស្សដែលមានអាយុ ៤០ ឆ្នាំ ក៏មានអាយុ ៨០ ឆ្នាំឡើងវិញ ។ កូនទាំងឡាយរបស់ពួកមនុស្សដែលមានអាយុ ៨០ ឆ្នាំ ក៏មានអាយុ ១៦០ ឆ្នាំឡើងវិញ ។ កូនទាំងឡាយរបស់ពួកមនុស្សដែលមានអាយុ ១៦០ ឆ្នាំ ក៏មានអាយុ ៣២០ ឆ្នាំឡើងវិញ ។ កូនទាំងឡាយរបស់ពួកមនុស្សដែលមានអាយុ ៣២០ ឆ្នាំ ក៏មានអាយុ ៦៤០ ឆ្នាំឡើងវិញ ។ កូនទាំងឡាយរបស់ពួកមនុស្សដែលមានអាយុ ៦៤០ ឆ្នាំ ក៏មានអាយុ ២ ពាន់ឆ្នាំ

ឡើងវិញ ។ កូនទាំងឡាយរបស់ពួកមនុស្ស ដែលមានអាយុ ២ ពាន់ឆ្នាំ ក៏មានអាយុ ៤ ពាន់ឆ្នាំឡើងវិញ ។ កូនទាំងឡាយ របស់ពួកមនុស្សដែលមានអាយុ ៤ ពាន់ឆ្នាំ ក៏មានអាយុ ៨ ពាន់ឆ្នាំឡើងវិញ ។ កូនទាំងឡាយរបស់ពួកមនុស្សដែលមានអាយុ ៨ ពាន់ឆ្នាំ ក៏មានអាយុ ២ ម៉ឺនឆ្នាំឡើងវិញ ។ កូនទាំងឡាយរបស់ពួកមនុស្សដែលមានអាយុ ២ ម៉ឺនឆ្នាំ ក៏មានអាយុ ៤ ម៉ឺនឆ្នាំឡើងវិញ ។ កូនទាំងឡាយរបស់ពួកមនុស្ស ដែលមានអាយុ ៤ ម៉ឺនឆ្នាំ ក៏មានអាយុ ៨ ម៉ឺនឆ្នាំឡើងវិញ ។

[ ៤៨ ] ម្នាលភិក្ខុទាំងឡាយ កាលបើពួកមនុស្សមានអាយុ ៨ ម៉ឺនឆ្នាំ ពួកនាងកុមារិកា មានអាយុ ៥០០ ឆ្នាំ ទើបល្មមឲ្យមានប្តី ។ ម្នាលភិក្ខុទាំង-ឡាយ កាលបើពួកមនុស្សមានអាយុ ៨ ម៉ឺនឆ្នាំ នឹងមានអាពាធតែ ៣ យ៉ាង គឺចំណង់ក្នុងអាហារ ១ បរិភោគអាហារមិនបាន ១ សេចក្តីគ្រាំគ្រារាងកាយ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលដែលពួកមនុស្សមានអាយុ ៨ ម៉ឺនឆ្នាំ ជម្ពូទ្វីបនេះ នឹងជាទ្វីបស្តុកស្តម្ភធំទូលាយ មានស្រុក និគម រាជធានី ( តៗ គ្នា ) មួយរយៈមាន់ហើរធ្លាក់ ។ ម្នាលភិក្ខុទាំងឡាយ កាលបើពួកមនុស្សមានអាយុ ៨ ម៉ឺនឆ្នាំ ជម្ពូទ្វីបនេះនឹងពេញដោយពួកមនុស្ស ( រកចន្លោះគ្មាន ) ដូចអវិចីនរក ពុំនោះសោត ដូចព្រៃបបុស ឬព្រៃរំងភ្នំ ។ ម្នាលភិក្ខុទាំងឡាយ កាលបើពួកមនុស្សមានអាយុ ៨ ម៉ឺនឆ្នាំ ក្រុងពារាណសីនេះ នឹងប្រែឈ្មោះជាកេតុមតីរាជធានីវិញ ជារាជធានីស្តុកស្តម្ភ ធំទូលាយ មានជនក៏ច្រើន មានមនុស្សកុះករ និងមានភិក្ខាហារដ៏សម្បូណ៌ ។ ម្នាលភិក្ខុទាំងឡាយ កាលបើ

ពួកមនុស្សមានអាយុ ៨ ម៉ឺនឆ្នាំ ក្នុងជម្ពូទ្វីបនេះ នឹងមាននគរ ៨ ម៉ឺន ៤ ពាន់ មានកេតុមតីរាជធានី ឯងជាប្រធាន ។ ម្នាលភិក្ខុទាំងឡាយ កាលបើពួកមនុស្សមានអាយុ ៨ ម៉ឺនឆ្នាំ នឹងមានព្រះរាជា ( ១ ព្រះអង្គ ) ព្រះនាមសង្ខៈទ្រង់កើតឡើង ក្នុងកេតុមតីរាជធានី ជាស្តេចចក្រពត្តិ ទ្រង់ជាធម្មិក-ធម្មរាជ ជាឥស្សរៈលើផែនដី មានសមុទ្រទាំង ៤ ជាទីបំផុត ជាស្តេចឈ្នះសង្គ្រាម ទ្រង់មានជនបទដល់នូវបិរកាព ទ្រង់បរិបូណ៌ដោយរ័តន៍ ៧ ប្រការ ។ ឯរ័តន៍ទាំង ៧ ប្រការរបស់ ព្រះបាទសង្ខៈនោះ គឺចក្ករ័តន៍ ១ ហត្ថិរ័តន៍ ១ អស្សរ័តន៍ ១ មណិរ័តន៍ ១ ឥត្ថីរ័តន៍ ១ គហបតិរ័តន៍ ១ រាប់បរិនាយក-រ័តន៍ ១ ផង ជាគម្រប់ ៧ ។ ឯព្រះបាទសង្ខៈនោះ នឹងមានព្រះរាជបុត្រច្រើនជាងពាន់ សុទ្ធសឹងក្លៀវក្លា អង់អាច សង្កត់សង្កិននូវពួកសេនារបស់ស្តេចដទៃបាន ។ ព្រះបាទសង្ខៈនោះ ទ្រង់ត្រួតត្រាគ្រប់គ្រងនូវផែនដី ដែលមានសាគរជាទីបំផុត ដោយធម៌ មិនបាច់ប្រើអាជ្ញា មិនបាច់ប្រើគ្រឿងសស្ត្រាវុធទេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើពួកមនុស្សមានអាយុ ៨ ម៉ឺនឆ្នាំ ព្រះមានព្រះភាគ ទ្រង់ព្រះនាមមេត្តេយ្យៈ នឹងកើតឡើងក្នុងលោក ទ្រង់ឆ្ងាយចាកកិលេស ទ្រង់ត្រាស់ដឹងញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ទ្រង់មានព្រះដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណ ឥតមានបុគ្គលណាស្មើ ទ្រង់ទូន្មាននូវបុរសដែលគួរទូន្មាន ទ្រង់ជាសាស្តានៃទេវតា និងមនុស្សទាំងឡាយ ទ្រង់ជ្រាបច្បាស់នូវចតុរារិយសច្ច ទ្រង់មានដំណើរទៅកាន់ត្រៃភព

ខ្ជាក់ចោលហើយ ដូចជាតថាគតដែលឆ្ងាយចាកកិលេស ត្រាស់ដឹងញេយ្យ-ធម៌ទាំងពួង ដោយប្រពៃចំពោះខ្លួនឯង បរិបូណ៌ដោយវិជ្ជា និងចរណៈ មានដំណើរល្អ ជ្រាបច្បាស់នូវត្រៃលោក ប្រសើរដោយសីលាទិគុណ ឥតមានបុគ្គលណាស្មើ ទូន្មាននូវបុរសដែលគួរទូន្មាន ជាសាស្តានៃទេវតា និងមនុស្សទាំងឡាយ ជ្រាបច្បាស់នូវចតុរារិយសច្ច មានដំណើរទៅកាន់ត្រៃភព ខ្ជាក់ចោលហើយ ដែលកើតឡើងក្នុងលោកក្នុងកាលឥឡូវនេះដែរ ។ ព្រះមេត្តេយ្យៈមានព្រះភាគអង្គនោះ ទ្រង់ត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានចំពោះព្រះអង្គ ហើយញុំាងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ញុំាងពពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសឲ្យត្រាស់ដឹងផង ដូចតថាគតដែលបានត្រាស់ដឹង ហើយធ្វើឲ្យជាក់ច្បាស់ នូវព្រះនិព្វានចំពោះខ្លួនឯង ហើយញុំាងលោកនេះព្រមទាំងទេវលោក មារលោក ព្រហ្មលោក ញុំាងពពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសឲ្យត្រាស់ដឹងផង ក្នុងកាលឥឡូវនេះដែរ ។ ព្រះមេត្តេយ្យៈមានព្រះភាគអង្គនោះនឹងទ្រង់សំដែងធម៌ពីពេះបទដើម ពីពេះបទកណ្តាល ពីពេះបទចុង ទាំងទ្រង់ប្រកាសព្រហ្មចរិយធម៌ ព្រមទាំងអត្ថ និងព្យញ្ជនៈ ដ៏ពេញបរិបូណ៌ បរិសុទ្ធទាំងអស់ ដូចតថាគតដែលសំដែងធម៌ ពីពេះបទដើម ពីពេះបទកណ្តាល ពីពេះបទចុង ប្រកាសព្រហ្មចរិយធម៌ ព្រមទាំងអត្ថ និងព្យញ្ជនៈដ៏ពេញបរិបូណ៌បរិសុទ្ធទាំងអស់ ក្នុងកាលឥឡូវនេះដែរ ។ ព្រះមេត្តេយ្យៈមានព្រះ

ភាគអន្តនោះ នឹងគ្រប់គ្រងនូវភិក្ខុសង្ឃច្រើនពាន់ ដូចតថាគតដែលគ្រប់គ្រងនូវភិក្ខុសង្ឃច្រើនរយ ក្នុងកាលឥឡូវនេះដែរ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង ព្រះបាទសង្ខៈ ទ្រង់ត្រាស់បង្គាប់ឲ្យលើកប្រាសាទ ដែលព្រះបាទមហាបនាទៈឲ្យកសាង ហើយទ្រង់ប្រថាប់នៅ ( ក្នុងប្រាសាទនោះ ) ទ្រង់លះបង់ ( ប្រាសាទនោះ ) ឲ្យជាទាន ដល់ពួកសមណព្រាហ្មណ៍ កបណៈ ( មនុស្សកំព្រា ) អទ្ធិកៈ ( អ្នកដំណើរ ) វណិព្វកៈ ( អ្នកនិយាយសរសើរហើយសូម ) និងពួកយាចក ( សូម ) រួចទ្រង់ដាក់ព្រះកេសា និងព្រះមស្សុ ទ្រង់ស្លៀកដណ្តប់កាសាវពស្ត្រ ចេញចាករាជាគារស្ថាន ចូលទៅកាន់ផ្នួស ក្នុងសម្នាក់នៃព្រះមេត្តេយ្យៈមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ។ កាលព្រះបាទសង្ខៈនោះ ទ្រង់ព្រះផ្នួសយ៉ាងនេះហើយ ទ្រង់គេចចេញទៅតែមួយព្រះអង្គឯង ឥតមានសេចក្តីប្រមាទឡើយ មានសេចក្តីព្យាយាម ជាគ្រឿងដុតនូវកិលេស មានព្រះហឫទ័យបែរឆ្ពោះទៅរកព្រះនិព្វាន ពួកកុលបុត្រ ដែលចេញចាកផ្ទះ ទៅបួសក្នុងភាពជាបុគ្គលមិនមានផ្ទះ ដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា ពុំយូរប៉ុន្មាន ក៏ព្រះសង្ខត្ថេរ បានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់ នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃព្រហ្មចារ្យ ដោយខ្លួនឯង ក្នុងបច្ចុប្បន្ននេះ ក៏សម្រាកសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ។

[ ៤៩ ] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរមានខ្លួនជាទីពឹង មានខ្លួនជាទីពំនាក់ កុំមានរបស់ដទៃ ជាទីពឹងពំនាក់ឡើយ ចូរមានធម៌ជាទីពឹង

មានធម៌ជាទីពំនាក់ កុំមានរបស់ដទៃជាទីពឹងពំនាក់ឡើយ ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុមានខ្លួនជាទីពឹង មានខ្លួនជាទីពំនាក់ មិនមានរបស់ដទៃ ជាទីពឹងពំនាក់ មានធម៌ជាទីពឹង មានធម៌ជាទីពំនាក់ មិនមានរបស់ដទៃ ជាទីពឹងពំនាក់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណានូវកាយក្នុងកាយជាប្រក្រតី មានព្យាយាម ជាគ្រឿងដុតកម្តៅនូវកិលេស មានប្រាជ្ញាដឹងសព្វ មានស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកបាន ពិចារណានូវវេទនាក្នុងវេទនាទាំងឡាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតនូវកិលេស មានប្រាជ្ញាដឹងសព្វ មានស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកបាន ពិចារណានូវចិត្តក្នុងចិត្តជាប្រក្រតី មានព្យាយាមជាគ្រឿងដុតនូវកិលេស មានប្រាជ្ញាដឹងសព្វ មានស្មារតីកម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកបាន ពិចារណានូវធម៌ ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាម ជាគ្រឿងដុតនូវកិលេស មានប្រាជ្ញាដឹងសព្វ មានស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្ស ក្នុងលោកបាន ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះហៅថា ភិក្ខុមានខ្លួនជាទីពឹង មានខ្លួនជាទីពំនាក់ មិនមានរបស់ដទៃជាទីពឹងពំនាក់ មានធម៌ជាទីពឹង មានធម៌ជាជាទីពំនាក់ មិនមានរបស់ដទៃជាទីពឹងពំនាក់ឡើយ ។

[ ៥០ ] ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរប្រព្រឹត្តក្នុងគោចរ ជាវិស័យដែលមានមកអំពីបិតានៃខ្លួន ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំង-ឡាយ ប្រព្រឹត្តក្នុងគោចរ ជាវិស័យដែលមានមកអំពីបិតានៃខ្លួនហើយ នឹង

ចម្រើនអាយុផង ចម្រើនពណ៌សម្បុរផង ចម្រើនសេចក្តីសុខផង ចម្រើនភោគៈផង ចម្រើនកម្លាំងផង ។ ម្នាលភិក្ខុទាំងឡាយ ចុះអ្វី ( ជាហេតុឲ្យចម្រើន ) អាយុរបស់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើន ឥទ្ធិបាទប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ចម្រើនឥទ្ធិបាទប្រកបដោយវីរិយសមាធិ និងបធានសង្ខារ ... ចិត្តសមាធិ និងបធាន-សង្ខារ ... វិមំសាសមាធិ និងបធានសង្ខារ ភិក្ខុនោះបើមានបំណង ( នឹងរស់នៅ ) គប្បីឋិតនៅអស់ ១ អាយុកប្ប ឬ ១ អាយុកប្បបន្តិច ព្រោះហេតុដែលបានចម្រើន បានធ្វើឲ្យច្រើននូវឥទ្ធិបាទទាំង ៤ នេះ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ( ជាហេតុឲ្យចម្រើន ) អាយុរបស់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ចុះអ្វី ( ជាហេតុឲ្យចម្រើន ) ពណ៌សម្បុររបស់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខ-សំវរៈ បរិបូណ៌ដោយអាចារ និងគោចរ ជាអ្នកឃើញភ័យក្នុងទោស សូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ( ជាហេតុឲ្យចម្រើន ) សម្បុររបស់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ចុះអ្វី ( ជាហេតុឲ្យចម្រើន ) សេចក្តីសុខរបស់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំង-ឡាយ ចូលបឋមជ្ឈានដែលប្រកបដោយវិតក្ក វិចារៈ មានបីតិ និងសុខដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ជាអារម្មណ៍ ភិក្ខុនោះ លុះរម្ងាប់វិតក្កវិចារៈរួចហើយ ។បេ។ ក៏ចូលទុតិយជ្ឈាន ។ ចូលតតិយជ្ឈាន ។ ចូលចតុត្ថជ្ឈាន ។

ម្នាលភិក្ខុទាំងឡាយ នេះឯង ( ជាហេតុឲ្យចម្រើន ) សេចក្ដីសុខរបស់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ចុះអ្វី ( ជាហេតុឲ្យចម្រើន ) ភោគៈរបស់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានចិត្តប្រកបដោយមេត្តាផ្សាយទៅកាន់ទិស ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នា តាមទំនងនេះ សូម្បីទិសខាងលើ ទិសខាងក្រោម ទិសទទឹង ក៏មានចិត្តប្រកបដោយមេត្តាដ៏ធំទូលាយ រកប្រមាណមិនបាន ជាចិត្តឥតមានចងពៀរ ឥតមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ព្រោះតែហេតុប្រៀបផ្ទឹមខ្លួន ឲ្យស្មើនឹងសត្វទាំងអស់ក្នុងទិសទាំងពួង ។ មានចិត្តប្រកបដោយករុណា ។ មានចិត្តប្រកបដោយមុទិតា ។ មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិស ១ ទិសទី ២ ក៏ដូចគ្នា ទិសទី ៣ ក៏ដូចគ្នា ទិសទី ៤ ក៏ដូចគ្នាតាមទំនងនេះ សូម្បីទិសខាងលើ ទិសខាងក្រោម ទិសទទឹង ក៏មានចិត្តប្រកបដោយឧបេក្ខាដ៏ធំទូលាយ រកប្រមាណមិនបាន ជាចិត្តឥតមានចងពៀរ ឥតមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ព្រោះហេតុប្រៀបផ្ទឹមខ្លួនឲ្យស្មើនឹងសត្វទាំងអស់ក្នុងទិសទាំងពួង ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ( ជាហេតុឲ្យចម្រើន ) ភោគៈរបស់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ចុះអ្វី ( ជាហេតុឲ្យចម្រើន ) កម្លាំងរបស់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានត្រាស់ដឹង បានធ្វើជាក់ច្បាស់ដោយខ្លួនឯង នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយក្នុងបច្ចុប្បន្ននេះ ហើយសម្រេចសម្រាន្តដោយឥរិយាបថទាំង ៤ ។ ម្នាលភិក្ខុ

ទាំងឡាយនេះឯង(ជាហេតុឲ្យចម្រើន)កម្លាំងរបស់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាមើលមិនឃើញកម្លាំងដទៃសូម្បីតែកម្លាំង ១ ដែលបុគ្គលគ្របសង្កត់បានដោយកម្រ ឲ្យដូចជាកម្លាំងនៃមារនេះឡើយ ម្នាលភិក្ខុទាំង-ឡាយ បុណ្យនេះតែងចម្រើនឡើងយ៉ាងនេះ ព្រោះហេតុសមាទាននូវកុសលធម៌ទាំងឡាយ ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងនូវព្រះសូត្រនេះចប់ហើយ ។ ភិក្ខុទាំងនោះក៏មានចិត្តត្រេកអររីករាយចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

## ចក្កវត្តិសូត្រទី ៣ ចប់

# អដ្ឋកថា

## ចក្កវត្តិសូត្រ

[ ៣៣ ] ចក្កវត្តិសូត្រមានពាក្យផ្ដើមថា **ឯវំមេ សុតំ** ដូច្នេះ ។ ក្នុងព្រះសូត្រនោះ មានពណ៌នាបទដែលលំបាកដូចតទៅនេះ បទថា **មាតុលាយំ** បានដល់ ក្នុងព្រះនគរដែលមានឈ្មោះយ៉ាងនោះ ។ ព្រះមានព្រះភាគ ទ្រង់ធ្វើព្រះនគរនោះឲ្យជាគោចរគ្រាម ប្រថាប់នៅក្នុងដងព្រៃមិនឆ្ងាយ ។ ក្នុងបទថា **តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ** នេះ មានអនុបុព្វីកថា ដូច្នេះ

បានឮមកថា ក្នុងសម័យដែលព្រះសូត្រនេះកើតឡើង ព្រះមានព្រះភាគចេញចាកមហាករុណាសមាបត្តិក្នុងពេលទៀបភ្លឺ ទ្រង់ប្រមើលមើលសត្វលោកទតឃើញការត្រាស់ដឹងធម៌របស់ពួកសត្វ ៨៤០០០ ដែលនៅក្នុងមាតុលនគរដោយការសម្ដែងព្រះសូត្រ ដែលសម្ដែងដល់អនាគតវង្សនេះ ។ ទើបព្រះសាស្ដាព្រមដោយភិក្ខុ ២០០០០ អង្គ យាងទៅកាន់មាតុលនគរអំពីព្រលឹម ។ ស្ដេចមាតុលនគរ ឮដំណឹងថា ព្រះមានព្រះភាគទ្រង់យាងមក ទើបទូលអារាធនាព្រះទសពល ឲ្យស្ដេចចូលកាន់ព្រះនគរដោយគ្រឿងសក្ការៈជាច្រើន ទ្រង់រៀបចំទីកន្លែងប្រថាប់គង់ អារាធនាឲ្យព្រះមានព្រះភាគប្រថាប់គង់លើបល្ល័ង្ក ដ៏មានតម្លៃ បានថ្វាយមហាទានចំពោះភិក្ខុសង្ឃ ដែលមានព្រះពុទ្ធជាប្រធាន ។ ព្រះមានព្រះភាគ ទ្រង់ធ្វើភត្តកិច្ចស្រេចហើយ ទ្រង់ត្រិះរិះថា បើតថាគតសម្ដែងធម៌ដល់ពួកមនុស្សទាំងនេះ ក្នុងទីនេះសោត ទីនេះចង្អៀត ពួកមនុស្សមិនមានឱកាសនឹងឈរ នឹងអង្គុយ តែសមាគមធំគប្បីមាន ។ លំដាប់នោះ ព្រះមាន

ព្រះភាគ ទ្រង់មិនធ្វើកត្តានុមោទនាដល់ពួករាជត្រកូលឡើយ ទ្រង់កាន់បាត្រ យាងចេញចាកព្រះនគរទៅ ។ ពួកមនុស្សគិតថា ព្រះសាស្តាទ្រង់មិនធ្វើ អនុមោទនាដល់ពួកយើង យាងចេញទៅ អាហារមានរសដ៏ប្រសើរ គង់មិន សព្វព្រះទ័យដោយពិត ឈ្មោះថា ព្រះពុទ្ធទាំងឡាយ បុគ្គលណាម្នាក់ មិន អាចផ្គាប់ព្រះហឫទ័យត្រូវបាន ធម្មតាថា ការធ្វើសេចក្តីស្និទ្ធស្នាលនឹងព្រះពុទ្ធ ទាំងឡាយ ក៏ដូចជាការចាប់កអាសិរពិស ដែលកំពុងបើកពពារ មកចុះលោក ដ៏ចម្រើនទាំងឡាយ ពួកយើងនឹងសូមខមាទោសព្រះតថាគត ។ ពួកអ្នកនគរ ទាំងអស់ នាំគ្នាចេញទៅតាមព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ខណៈ ស្តេចយាងទៅនៅទុំះឯង ទ្រង់ទតឃើញដើមមាតុលៈ ( ដើមស្វាក់ ) មួយ ដើម ដុះនៅក្នុងស្រែរបស់អ្នកមគធៈ បរិបូណ៌ដោយមែក និងប្រគាប មាន ម្ឆប់ត្រឈឹងផ្សាយទៅ តាំងនៅក្នុងភូមិភាគប្រមាណមួយករីសៈ ទ្រង់ត្រិះរិះថា តថាគតនឹងអង្គុយត្រង់គល់ឈើនេះ កាលតថាគតសម្តែងធម៌ មហាជននឹង មានឱកាសឈរ និងអង្គុយបាន ទើបទ្រង់ចៀសចេញពីផ្លូវ ចូលរកគល់ឈើ ទតព្រះអានន្ទ ដែលជាធម្មភណ្ឌាគារិក ( ឃ្លាំងព្រះធម៌ ) ព្រះថេរៈជ្រាបថា ព្រះសាស្តាបំណងនឹងប្រថាប់គង់ ដោយសញ្ញាដែលព្រះអង្គទ្រង់ទតប៉ុណ្ណោះ ទើបក្រាលមហាចីវរថ្វាយព្រះសុគត ។ ព្រះមានព្រះភាគ គង់លើអាសនៈ ដែលព្រះអានន្ទក្រាលថ្វាយ ។ លំដាប់នោះ ពួកមនុស្សនាំគ្នាអង្គុយក្នុងទី ចំពោះព្រះភក្ត្រព្រះតថាគត ។ ពួកភិក្ខុអង្គុយសងខាង និងផ្នែកខាងក្រោយ ពួកទេវតាឈរក្នុងអាកាស ។ ព្រះមានព្រះភាគ ប្រថាប់ត្រង់កណ្តាលមហា

បរិស័ទនោះឯង ដោយអាការយ៉ាងនេះ ទើបបានត្រាស់ហៅ ភិក្ខុទាំងឡាយ ។ ពីរបទថា **តេ ភិក្ខូ** សេចក្ដីថា ភិក្ខុជាធម្មបដិគ្គាហកទទួលធម៌ ចូលទៅក្នុងសមាគមនោះ ។ បទថា **អត្តទីបា** សេចក្ដីថា ពួកអ្នកចូរធ្វើខ្លួន ឲ្យជាកោះ ជាទីជ្រកកោន ជាទីពួន ជាគតិ ជាទីទៅខាងមុខ ជាទីពឹងចុះ ។ បទថា **អត្តសរណា** នេះជាវេវចនៈរបស់បទថា **អត្តទីបា** នុ៎ះឯង ។ បទថា **អនញ្ញ-សរណា** ជាពាក្យបដិសេធទីពឹងដទៃ ។ សេចក្ដីពិត បុគ្គលដទៃ ជាទីពឹងដល់បុគ្គលដទៃមិនបាន ព្រោះអ្នកដទៃបរិសុទ្ធដោយសេចក្ដីព្យាយាម របស់អ្នកដទៃមិនបាន ។ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ថា ខ្លួនជាទីពឹងរបស់ខ្លួន អ្នកដទៃជាទីពឹងដូចម្ដេចបាន ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **អនញ្ញសរណា** ។ សួរថា ក្នុងបទថា **អត្តទីបា** នេះ អ្វីហ្ន៎ ឈ្មោះថា ខ្លួន ឆ្លើយថា លោកិយធម៌ និងលោកុត្តរធម៌ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ធម្មទីបា ធម្មសរណា អនញ្ញសរណា** មានធម៌ជាកោះ មានធម៌ជាទីពឹង មិនមានវត្ថុដទៃជាទីពឹង ដូច្នេះ ។

បទថា **កាយេ កាយានុបស្សី** ជាដើម បានពោលពិស្ដារហើយ ក្នុងមហាសតិប្បដ្ឋានសូត្រ ។ បទថា **គោចរេ** បានដល់ ក្នុងស្ថានទីគួរត្រាច់ទៅ ។ បទថា **សកេ** គឺកន្លែងដែលជារបស់មាននៃខ្លួន ។ បទថា **បេត្តិកេ វិសយេ** គឺក្នុងទីដែលមកពីវិស័យរបស់បិតា ។ បទថា **ចរតំ** គឺត្រាច់ទៅ បាលីថា **ចរន្តំ** ដូច្នេះក៏មាន ។ ឯអត្ថក៏ដូចគ្នា ។ បទថា **ន លច្ឆតិ** សេចក្ដីថា នឹងមិនបាន គឺនឹងមិនឃើញ ។ បទថា **មារោ** បានដល់ ទេវបុត្តមារខ្លះ កិលេសមារ

ខ្ទះ ។ បទថា **ឱតារំ** បានដល់ ស្នាម គឺចន្លោះផ្លូវបើក ។ ឯសេចក្ដីនេះ បណ្ឌិតគប្បីសម្ដែងដោយរឿងសត្វខ្លែង ដែលចាបយកសត្វប្រចៀច ហើរចេញពីដីអាចម៍បំណះ ហើរឡើងទៅទំនៅលើសសរខឿន នៅក្រោមកម្ដៅថ្ងៃស្រទន់ ។ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ រឿងធ្លាប់មានមកហើយថា មានសត្វខ្លែងបានចាបសត្វប្រចៀចដោយរហ័សយកទៅ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង សត្វប្រចៀច កាលដែលសត្វខ្លែងកំពុងនាំទៅ ក៏យំរៀបរាប់យ៉ាងនេះថា ពួកយើងនុ៎ះឯង ត្រាច់ទៅក្នុងទីអគោចរ ដែលជាដែនរបស់សត្រូវ រាប់ថា មិនមានបុណ្យ មានបុណ្យតិច ។ ប្រសិនបើថ្ងៃនេះ យើងត្រាច់ទៅក្នុងទីគោចរ ជាដែនរបស់មាតាបិតាសោត សត្វខ្លែងនឹងមិនអាចចាប់យើងបាន ដោយការប្រយុទ្ធបែបនេះ ។ សត្វខ្លែងសួរថា នែប្រចៀច ចុះទីណា ជាទីគោចររបស់ឯង ដែលជាដែននៃបិតារបស់ឯង សត្វប្រចៀចឆ្លើយថា គឺទីមានដីអាចម៍បំណះដែលគេទើបនឹងភ្ជួរដោយនង្គ័ល ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង សត្វខ្លែងមិនប្រមាណក្នុងកម្លាំងរបស់ខ្លួន ជឿជាក់ក្នុងកម្លាំងរបស់ខ្លួន ក៏លែងសត្វប្រចៀចទៅ ដោយពោលថា នែប្រចៀច ឯងចូរទៅចុះ ទោះជាឯងទៅក្នុងទីនោះ ក៏មិនរួចអំពីអញដែរ ។ គ្រានោះឯង សត្វប្រចៀច ក៏ហើរទៅកាន់ទីដីអាចម៍បំណះ ហើយទំលើដីអាចម៍បំណះ និយាយនឹងសត្វខ្លែងថា នែខ្លែង ឯងចូរមករកយើងក្នុងកាលឥឡូវនេះចុះ នែខ្លែង ឯងចូរមករកយើងក្នុងកាលឥឡូវនេះចុះ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ សត្វខ្លែងមិនប្រមាណក្នុងកម្លាំងខ្លួន

ជើងជាក់ក្នុងកម្លាំងរបស់ខ្លួន ហើយសម្របស្លាបទាំងពីរ បោះពួយតម្រង់សត្វប្រចៀច ។ ម្នាលភិក្ខុទាំងឡាយ សត្វប្រចៀចបានដឹងខ្លួនថា សត្វខ្លែងនេះបោះពួយចុះមកហើយ គ្រានោះឯង សត្វប្រចៀចក៏ចូលពួនត្រង់ចន្លោះដីអាចម៍បំណះនោះឯង ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង សត្វខ្លែងក៏ទន្លិចទ្រូងនឹងដីអាចម៍បំណះនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ប្រការនោះ ក៏ដូចគ្នានឹងភិក្ខុដែលត្រាច់ទៅក្នុងទីមិនមែនគោចរ ដែលជាដែនរបស់សត្រូវ ។ ម្នាលភិក្ខុទាំង-ឡាយ ព្រោះហេតុនោះ ពួកអ្នក ចូរកុំត្រាច់ទៅក្នុងទីមិនមែនជាគោចរ ដែលជាដែនរបស់សត្រូវ ។ កាលបើអ្នកត្រាច់ទៅក្នុងទីមិនមែនជាគោចរ ដែលជាដែនរបស់សត្រូវ មាររែងបាននូវចន្លោះ មាររែងបាននូវអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ អ្វី គឺអគោចរដែលជាដែនរបស់សត្រូវចំពោះភិក្ខុ គឺកាមគុណ ៥ ។ កាមគុណ ៥ ដូចម្តេច បានដល់ រូបដែលគប្បីដឹងបានដោយចក្ខុ ដែលគួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត ប្រកបដោយសេចក្តីស្រឡាញ់ ជាទីតាំងនៃតម្រេក ។បេ។ ផោដ្ឋព្វៈដែលគប្បីដឹងដោយកាយ ។បេ។ ដែលជាទីតាំងនៃតម្រេក ។ ម្នាលភិក្ខុទាំងឡាយ នេះគឺអគោចរ ដែលជាដែនរបស់សត្រូវសម្រាប់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ពួកអ្នកទាំងឡាយ ចូរត្រាច់ទៅក្នុងទីជាគោចរ ។បេ។ មាររមែងមិនបាននូវអារម្មណ៍ ។ ម្នាលភិក្ខុទាំងឡាយ អ្វីគឺជាគោចររបស់ភិក្ខុ ដែលជាដែននៃបិតារបស់ខ្លួន គឺសតិប្បដ្ឋានទាំង ៤ ។ សតិ-ប្បដ្ឋាន ៤ តើដូចម្តេច ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ពិចារណាឃើញនូវកាយក្នុងកាយ ។បេ។ ធម៌ដែលជាដែននៃបិតាខ្លួន ។

បទថា **កុសលានំ** គឺធម៌ដែលមិនមានទោស ជាលក្ខណៈ ។ បទថា **សមាទានហេតុ** គឺព្រោះហេតុសមាទានហើយប្រព្រឹត្ត ។ បទថា **ឯវមិទំ បុញ្ញំ បវឌ្ឍតិ** សេចក្ដីថា ផលបុណ្យដែលជាលោកិយ និងលោកុត្តរនេះ រមែងចម្រើនយ៉ាងនេះ ។ ម្យ៉ាងទៀត ពាក្យថា ផលបុណ្យនោះ គប្បីជ្រាបថា បានដល់ ទាំងបុណ្យ ទាំងផលរបស់បុណ្យជាន់ខ្ពស់ផងដែរ ។

ក្នុងបទថា **បុញ្ញផលំ** នោះ កុសលមាន ២ យ៉ាង គឺវដ្ដគាមីកុសល កុសលជាផ្លូវទៅកាន់វដ្ដៈ ១ វិវដ្ដគាមីកុសល កុសលជាផ្លូវទៅកាន់វិវដ្ដៈ ១ ។ ក្នុងកុសល ២ យ៉ាងនោះ ចិត្តដែលបង្អោនទៅរបស់មាតាបិតា ដោយអំណាចនៃសេចក្ដីស្រឡាញ់ក្នុងបុត្រធីតា និងចិត្តដែលបង្អោនទៅរបស់បុត្តធីតា ដោយអំណាចនៃសេចក្ដីស្រឡាញ់ ក្នុងមាតាបិតា ឈ្មោះថា វដ្ដគាមីកុសល ។ ពោធិបក្ខិយធម៌ ៣៧ ប្រការ មានប្រភេទជាដើមថា សតិប្បដ្ឋាន ៤ ឈ្មោះថា វិវដ្ដគាមីកុសល ។ ក្នុងកុសលទាំងនោះ ចំពោះកុសលដែលជាវដ្ដគាមី មានទីបំផុតត្រឹមសិរីសម្បត្តិរបស់ស្ដេចចក្រពត្តិក្នុងមនុស្សលោក ។ ចំពោះកុសលដែលជាវិវដ្ដគាមី មានទីបំផុត គឺមគ្គផល និងនិញ្វានសម្បត្តិ ។ ក្នុងកុសល ២ យ៉ាងនោះ ព្រះមានព្រះភាគ ទ្រង់សម្ដែងវិបាករបស់វដ្ដគាមីកុសលក្នុងខាងចុងរបស់សូត្រ ។ តែក្នុងទីនេះ ដើម្បីសម្ដែងវិបាកនៃវដ្ដគាមីកុសល ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលណាបុត្រធីតា មិនតាំងនៅក្នុងឱវាទរបស់មាតាបិតា កាលនោះ ពួកជនទាំងនោះសាបសូន្យអាយុខ្លះ ពណ៌សម្បុរខ្លះ ភាពជាធំខ្លះ ប៉ុន្តែ កាលណាជនទាំងនោះតាំងនៅក្នុងឱវាទ កាលនោះ ទើប

ចម្រើន ដូច្នេះហើយ ទើបផ្តើមព្រះធម៌ទេសនា ដោយអំណាចការបន្តវដ្ត-គាមីកុសលថា **ភូតបុព្វំ ភិក្ខវេ** ជាដើម ។

[ ៣៤ ] ក្នុងបទទាំងនោះ បទថា **ចក្កវត្តិ** ជាដើម បានពោលពិស្តារហើយ ក្នុងមហាបទានសូត្រនោះឯង បទថា **ឱសក្កិតំ** ប្រែថា ឃ្លាតចាកទីបន្តិចបន្តួច ។ បទថា **ឋានា ចុតំ** ប្រែថា ឃ្លាតទៅចាកស្ថាន ដោយប្រការទាំងពួង ។ បានឮថា ចក្រកែវនោះ បានអណ្តែតឡើងទៅតាំងនៅក្នុងអាកាសដូចនាំទៅដោយកង់នៅលើទ្វារព្រះរាជវាំងជាន់ខាងក្នុង ។ គ្រានោះ ព្រះរាជាត្រាស់បង្គាប់ឲ្យកប់សសរគគីរ ២ ដើម ត្រង់ទីខាងទាំង ២ នៃចក្រនោះ ទីខាងលើបំផុតរបស់ចក្រកែវ ចងខ្សែអំបោះមួយសរសៃឲ្យនៅត្រង់កង់ ។ ក្នុងផ្នែកខាងក្រោម ក៏ចងខ្សែអំបោះមួយសរសៃឲ្យនៅត្រង់កង់ ។ ចក្រកែវស្រុតចុះបន្តិចអំពីខ្សែអំបោះសរសៃខាងលើ ក្នុងបណ្តាខ្សែពីរសរសៃនោះ ក៏ឈ្មោះថា ឃ្លាត ។ ទីបំផុតនៃចក្រកែវនោះ ក៏ឃ្លាតចាកទីតាំងរបស់ខ្សែអំបោះខាងក្រោម ឈ្មោះថា ច្យុត ។ កាលមានទោសខ្លាំងក្លា ចក្រកែវនោះ នឹងមានសភាពយ៉ាងនេះ គឺឃ្លៀងឃ្លាតចាកស្ថាន សូម្បីប្រមាណប៉ុនសរសៃអំបោះឬប្រមាណមួយធ្នាប់ពីរធ្នាប់ ។ លោកសំដៅយកហេតុនោះ ទើបពោលថា **ឱសក្កិតំ ឋានា ចុតំ** ឃ្លាតច្យុតចាកទី ដូច្នេះ ។ បទថា **អថ មេ អារោចេយ្យាសិ** សេចក្តីថា ព្រះរាជាត្រាស់បង្គាប់ថា នែបា រាប់ពីថ្ងៃនេះជាដើមទៅ អ្នកចូរទៅកាន់ទីរក្សាចក្រកែវ មួយថ្ងៃ ៣ ដង អ្នកកាលទៅយ៉ាងនោះ ឃើញចក្រកែវឃ្លាតចាកទីសូម្បីតែបន្តិចណា គប្បីប្រាប់ដល់យើងកាលនោះ ព្រោះ

ថា ជីវិតរបស់យើងផ្ញើក្នុងដៃរបស់អ្នក ។ បទថា **អទ្ធស** សេចក្ដីថា បុរស នោះមិនប្រមាទឡើយ ទៅមើលមួយថ្ងៃ ៣ ដង ថ្ងៃមួយក៏បានឃើញ ។

បទថា **អថខោ ភិក្ខវេ** សេចក្ដីថា ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះបាទទល្ហនេមិ ទ្រង់ព្រះសណ្ដាប់ថា ចក្រកែវឃ្លាតចាកទីហើយ ក៏កើតទោមនស្សយ៉ាងខ្លាំង ត្រិះរិះថា អញនឹងមានជីវិតមិនយឺនយូរ អាយុរបស់អញនៅសល់តិចណាស់ ឥឡូវនេះ អញនឹងមិនមានពេលបរិភោគកាមទៀតឡើយ ពេលនៃបព្វជ្ជារមែងមានដល់អញ ក្នុងកាលឥឡូវនេះ ដូច្នេះហើយ ទ្រង់ព្រះកន្សែង ត្រាស់ឲ្យហៅព្រះរាជកុមារ ជាឱរសច្បងមកហើយ ត្រាស់ពាក្យនេះ ។ បទថា **សមុទ្ទបរិយន្តំ** គឺមានសមុទ្រមួយដែលព័ទ្ធជុំវិញ ជាព្រំប្រទល់នុ៎ះឯង ។ ពិតហើយ ទ្រព្យ គឺផែនដីនេះជារបស់ប្រចាំរាជត្រកូលរបស់ព្រះរាជាអង្គនោះ ។ ម្យ៉ាងទៀត ចក្រកែវនោះ មានចក្រវាលជាព្រំប្រទល់ កើតឡើងបានដោយអំណាចបុញ្ញឫទ្ធិ បុគ្គលណាម្នាក់ក៏មិនអាចនឹងឲ្យគ្នាបាន ។ ព្រះរាជា កាលប្រគល់ចក្រកែវ ដែលជាវត្ថុប្រចាំរាជត្រកូល ទើបត្រាស់ថា **សមុទ្ទបរិយន្តំ** ដូច្នេះ ។ បទថា **កេសមស្សុំ** សេចក្ដីថា ការពិតបុគ្គលទាំងឡាយ សូម្បីកាលនឹងបួសជាតាបស ក៏កោរសក់ និងពុកមាត់ចេញជាមុន អំពីនោះទៅ ទើបបានបួងសក់ដែលដុះឡើងមកគ្រាច់ទៅ ព្រោះហេតុនោះ ទើបលោកពោលថា **កេសមស្សុំ ឱហារេត្វា** ។ បទថា **កាសាយានិ** បានដល់ សំពត់ដែលជ្រលក់ដោយទឹកម្ចត់ ។ អធិប្បាយថា ខាងដើមបានធ្វើយ៉ាងនោះ ខាងក្រោយ ទើបទ្រទ្រង់សំពត់សម្បកឈើ ។

បទថា **បព្វជិ** ប្រែថា បួសហើយ អធិប្បាយថា កាលបួសហើយ បានប្រថាប់នៅក្នុងព្រះរាជឧទ្យាន ដែលជាមង្គលរបស់ព្រះអង្គនុ៎ះឯង ។ បទថា **រាជិសិទ្ធិ** គឺរាជឥសី ។ ពិតហើយ អ្នកបួសចេញចាកវណ្ណព្រាហ្មណ៍ លោកហៅថា ព្រាហ្មណឥសី ។ ចំណែកអ្នកលះបង់ស្វេតច្ឆត្រ បួសពីវណ្ណក្សត្រិយ៍ ហៅថា រាជឥសី ។ បទថា **អន្តរធាយិ** ប្រែថា បាត់ទៅហើយ គឺដល់នូវការមិនមាន ដូចអណ្តាតប្រទីបដែលរលត់ហើយ ។

[ ៣៥ ] បទថា **បដិសំវេទេសិ** សេចក្តីថា រាជអមាត្យទូលឲ្យជ្រាបហើយ ព្រះរាជឱរសទ្រង់ព្រះកន្សែងរៀបរាប់ ។ បទថា **បេត្តិកំ** គឺលោកសម្តែងថា មិនមែនទ្រព្យមត៌កដែលមកពីខាងរាជបិតា ដែលបុគ្គលមានការខ្ជិលច្រអូស មានការព្យាយាមថោកថយ សមាទានប្រព្រឹត្តអកុសលកម្មបថ ១០ មិនអាចលះបង់បាន តែបុគ្គលដែលអាស្រ័យកុសលកម្មរបស់ខ្លួន បំពេញវត្តរបស់ស្តេចចក្រពត្តិ ១០ យ៉ាង ឬ ១២ យ៉ាងប៉ុណ្ណោះ ទើបបានចក្រកែវនោះ ។ គ្រានោះ រាជឥសី កាលដាស់តឿនរាជបុត្រនោះក្នុងវត្តបដិបត្តិ ទើបត្រាស់ថា **តេន្ហ ត្វំ** ជាដើម ។

ក្នុងវត្តបដិបត្តិនោះ បទថា **អរិយេ** គឺអស់នូវទោស ។ បទថា **ចក្ក-វត្តិវត្តេ** បានដល់ ក្នុងវត្តរបស់ស្តេចចក្រពត្តិ ។ បទថា **ធម្មំ** បានដល់ ធម៌ គឺកុសលកម្មបថ ១០ ។ បទថា **និស្សាយ** គឺធ្វើធម៌នោះប៉ុណ្ណោះ ឲ្យជាទីអា-ស្រ័យ ដោយព្រះហឫទ័យដែលអធិដ្ឋានធម៌នោះហើយ ។ បទថា **ធម្មំ សក្ករោន្តោ** សេចក្តីថា ធម៌នោះដែលព្រះរាជកុមារបំពេញហើយ គឺបំពេញ

ដោយល្អដូចម្តេច លោកក៏បំពេញធម៌យ៉ាងនោះដូចគ្នា ។ ពីរបទថា **ធម្មំ គរុករោន្តោ** គឺធ្វើធម៌នោះឲ្យក្រៃលែងដោយការចូលដល់ សេចក្តីគោរពក្នុងធម៌នោះ ។ បទថា **ធម្មំ មានេន្តោ** គឺធ្វើធម៌នោះប៉ុណ្ណោះ ឲ្យជាទីស្រឡាញ់ និងឲ្យគួរដល់ការលើកតម្កើង ។ បទថា **ធម្មំ បូជេន្តោ** គឺអាស្រ័យធម៌នោះហើយ ធ្វើការបូជាចំពោះធម៌នោះដោយការបូជា ដោយវត្ថុមានផ្កាកម្រង និងគ្រឿងក្រអូបជាដើម ។ បទថា **ធម្មំ អបចាយមានោ** សេចក្តីថា ធ្វើការប្រព្រឹត្តឱនលំទោនចំពោះធម៌នោះនុ៎ះឯង ដោយសាមីចិកម្ម មានការផ្គងអញ្ជលីជាដើម ។ បទថា **ធម្មទ្ធជោ ធម្មកេតុ** អធិប្បាយថា ឈ្មោះថា មានធម៌ដូចជាទង់ជ័យ និងឈ្មោះថា មានធម៌ជាកំពូល ព្រោះលើកស្ទួយធម៌នោះទុកខាងមុខដូចទង់ជ័យ និងលើកធម៌នោះឡើង ធ្វើឲ្យដូចកំពូល ហើយប្រព្រឹត្ត ។ បទថា **ធម្មាធិបតេយ្យោ** គឺមានធម៌ជាធំ បានដល់ ជាធម្មាធិបតេយ្យ ព្រោះភាវៈនៃធម៌ដែលមានមកហើយ និងព្រោះធ្វើកិរិយាទាំងអស់ ដោយអំណាចធម៌ប៉ុណ្ណោះ ។ បទថា **ធម្មិកំ រក្ខាវរណគុត្តឹ សំវិទហស្សុ** មានវិគ្គហៈដូច្នេះថា ធម៌នៃការរក្សាមាន ហេតុនោះ ការរក្សានោះ ឈ្មោះថា **ធម្មិកំ** ការរក្សា ការការពារ និងការឃុំគ្រង ឈ្មោះថា **រក្ខាវរណគុត្តិ** ។ បណ្តាធម៌ ជាគ្រឿងរក្សាទាំងនោះ ធម៌ទាំងឡាយ មានខន្តីជាដើម ឈ្មោះថា ការរក្សា ព្រោះព្រះបាលីថា បុគ្គលកាលរក្សាអ្នកដទៃ ឈ្មោះថា រក្សាខ្លួន ។ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុកាលរក្សាអ្នកដទៃ ឈ្មោះថា

រក្សាខ្លួន តើដូចម្តេច ។ គឺដោយអំណត់ដោយសេចក្តីមិនបៀតបៀន ដោយមេត្តាចិត្ត ដោយសេចក្តីអាណិត ។ ការការពារវត្ថុ មានសំពត់ស្លៀក សំពត់ដណ្តប់ និងផ្ទះជាដើម ឈ្មោះថា **អាវរណ**។ ការឃុំគ្រងដើម្បីហាមឧបទ្រវន្តរាយមានចោរជាដើម ឈ្មោះថា **គុត្តិ** អធិប្បាយថា ចូរបាចាត់ចែងកិច្ចទាំងអស់នោះ គឺឲ្យប្រព្រឹត្តទៅ ឲ្យតាំងនៅដោយល្អ ។ ឥឡូវនេះ កាលទ្រង់សម្តែងវត្ថុដែលគប្បីចាត់ការរក្សាការពារឃុំគ្រង ទើបឥសីពោលថា **អន្តោជនស្មឹ** សេចក្តីសង្ខេបក្នុងពាក្យនោះ មានដូចតទៅនេះ

## វត្តរបស់ស្តេចចក្រពត្តិ

ចូរបាញុំាងបុត្រ និងភរិយា ពោល គឺជនខាងក្នុងរបស់បាឲ្យតាំងនៅក្នុងសីលសំវរៈ ចូរឲ្យវត្ថុមានសំពត់ ផ្កាកម្រង និងគ្រឿងក្រអូបជាដើម ដល់ពួកបុត្រ និងភរិយានោះ និងចូរការពារឧបទ្រវទាំងអស់ឲ្យដល់ជនទាំងនោះ ។ ក្នុងពួកទាហានជាដើម ក៏ន័យនេះដូចគ្នា ។ តែមានប្រការផ្សេងគ្នាដូច្នេះ ។ ពួកទាហានដែលព្រះរាជាគួរសង្គ្រោះ ដោយការបន្ថែមប្រាក់បំណាច់រង្វាន់ឲ្យ មិនឲ្យកន្លងហួសកាលវេលា ។ ក្សត្រដែលបានទទួលអភិសេក គួរសង្គ្រោះដោយការឲ្យរតនៈ មានសេះអាជានេយ្យដ៏ស្អាតសង្ហារជាដើម ។ ក្សត្រដែលជាបទេសរាជ គួរឲ្យត្រេកអរ ដោយការប្រគល់ឲ្យនូវយានពាហនៈ ដែលសមគួរដល់ភាពជាក្សត្រនោះ ។ ព្រាហ្មណ៍ទាំងឡាយ គួរឲ្យត្រេកអរដោយទេយ្យធម៌ មានបាយ ទឹក និងសំពត់ជាដើម ។ ពួកគហបតី គួរសង្គ្រោះ

ដោយការឲ្យពូជស្រូវ នង្គ័ល ផាល និងគោជាដើម ។ អ្នកនៅក្នុងនិគម ឈ្មោះនេគមៈ និងអ្នកនៅក្នុងជនបទ ឈ្មោះថា ជនបទា ក៏ដូចគ្នា ( គឺគួរសង្គ្រោះដោយការឲ្យពូជស្រូវ នង្គ័ល ផាល និងគោជាដើម ) ។

ពួកសមណព្រាហ្មណ៍ ដែលមានបាបស្ងប់ហើយ មានបាបបន្សាត់ហើយ គួរធ្វើសក្ការៈដោយការប្រគេនបរិក្ខារសម្រាប់សមណព្រាហ្មណ៍ ។ ម្រឹគ និងបក្សី គួរឲ្យរីករាយចិត្ត ដោយការឲ្យអភ័យ ។ បទថា **វិជិតេ** គឺក្នុងដែនដីដែលនៅក្នុងអំណាចគ្រប់គ្រងរបស់ខ្លួន ។ បទថា **អធម្មការោ** គឺការធ្វើដែលមិនប្រកបដោយធម៌ ។ បទថា **មា បវត្តិត្ថ** អធិប្បាយថា ចូរញ៉ាំងការធ្វើដែលជាអធម៌នោះ មិនឲ្យប្រព្រឹត្តទៅ ។ បទថា **សមណព្រាហ្មណា** បានដល់អ្នកមានបាបស្ងប់រម្ងាប់ គឺមានបាបបន្សាត់ហើយ ។ បទថា **មទប្បមាទា បដិវិរតា** គឺវៀរចាកសេចក្ដីស្រវឹងដោយអំណាចមានះ ៩ យ៉ាង និងចាកសេចក្ដីប្រមាទ ពោល គឺការបណ្ដោយចិត្តទៅក្នុងកាមគុណ ៥ ។ បទថា **ខន្តិសោរច្ចេ និវិដ្ឋា** សេចក្ដីថា តាំងនៅក្នុងអធិវាសនខន្តី និងក្នុងភាពជាអ្នកស្ងប់រម្ងាប់ ។ បទថា **ឯកមត្តានំ** សេចក្ដីថា សមណព្រាហ្មណ៍ទាំងឡាយលោកពោលថា រមែងទូន្មានខ្លួន ស្ងប់ រម្ងាប់ រម្ងត់ម្នាក់ឯង ដោយការសង្កត់កិលេស មានរាគៈជាដើមរបស់ខ្លួន ។ បទថា **កាលេន កាលំ** គឺសព្វកាល ។ បទថា **អភិនិវជ្ជេយ្យាសិ** សេចក្ដីថា គប្បីវៀរចេញនូវអកុសល ដែលប្រៀបដូចលាមក ដូចថ្នាំពិស និងដូចភ្លើងកំពុងឆេះ ។ បទថា **សមាទាយ** គឺគប្បីកាន់យកនូវកុសល ដែលប្រៀបដូចជាកម្រងផ្កា ដែលមានក្លិនក្រអូប និង

ប្រៀបដូចទឹកអម្រឹត ហើយបដិបត្តិដោយប្រពៃ ។ បណ្ឌិតតាំងនៅក្នុងកុសលធម៌នេះ ហើយគប្បីនាំវត្តមកបដិបត្តិដោយល្អ ។ វត្តនោះ មាន ១០ ប្រការ យ៉ាងនេះ គឺវត្តដែលគប្បីបដិបត្តិក្នុងពួកទាហាន ដែលជាជនខាងក្នុង ១ ក្នុងពួកក្សត្រ ១ ក្នុងក្សត្របទេសរាជ ១ ក្នុងព្រាហ្មណ៍ និងគហបតី ១ ក្នុងអ្នកនិគម និងអ្នកជនបទ ១ ក្នុងសមណព្រាហ្មណ៍ ១ ក្នុងពួកម្រឹគ និងពួកបក្សា ១ ការហាមការធ្វើដែលមិនមែនជាធម៌ ១ ការប្រគល់ទ្រព្យឲ្យដល់អ្នកមិនមានទ្រព្យ ១ ការចូលទៅរកសមណព្រាហ្មណ៍ហើយសួរបញ្ហា ១ តែកាលកាន់យកគហបតី និងពួកបក្សាជាតិជាផ្នែកមួយហើយ ក៏នឹងមាន ១២ យ៉ាង ។ បណ្ឌិតអ្នកកាន់យកពាក្យដែលមិនបានពោលក្នុងគ្រាមុន គប្បីជ្រាបថា វត្តមាន ១២ យ៉ាង ដោយអាស្រ័យការលះអធម្មរាគៈ និងវិសមលោភៈជាដើម ។ បទថា **ឥទំ ខោ តាត តំ** ដូច្នេះ សេចក្តីថា វត្តទាំង ១០ យ៉ាង និង ១២ យ៉ាងនេះ ឈ្មោះថា វត្តបដិបត្តិរបស់ស្តេចចក្រពត្តិដ៏ប្រសើរ ។ បទថា **វត្តមានស្ស** គឺបំពេញឲ្យបរិបូណ៌ ។ បទថា **តនពហុទោសេ** ជាដើម បានពោលទុកហើយក្នុងមហាសុទស្សនសូត្រ ។

[ ៣៨ ] បទថា **សមតេន** គឺតាមមតិរបស់ខ្លួន ។ បទថា **សុទំ** ត្រឹមតែជានិបាត ។ បទថា **បសាសតិ** គឺឃុំគ្រង អធិប្បាយថា ព្រះរាជាទ្រង់លះបង់រាជវង្សពីអតីត បានដល់ រាជធម៌ ដែលជារាជបវេណីចោលហើយ តាំងនៅក្នុងធម៌ត្រឹមតែជាមតិរបស់ខ្លួនគ្រប់គ្រងប្រទេស កាលបើដូច្នោះ ទើបព្រះរាជាអង្គនោះ ជាព្រះរាជាអង្គចុងក្រោយ ដែលជាអ្នកទម្លាយវង្សរបស់

ព្រះបាទទល្ហនេមិ ដូចអ្នកឲ្យកើតសេចក្តីសៅហ្មងដល់វង្សមឃទេព ដូច្នោះ ។ បទថា **បុព្វេនាបរំ** គឺក្នុងកាលតមក ប្រជារាស្ត្រមិនរុងរឿង គឺមិនចម្រើនដូចកាលមុន ។ បទថា **យថា តំ បុព្វកានំ** សេចក្តីថា ប្រជារាស្ត្រចម្រើនហើយដូចគ្នា ទាំងក្នុងរជ្ជកាលមុន និងរជ្ជកាលក្រោយរបស់ព្រះរាជាអង្គមុនៗ យ៉ាងណា នឹងចម្រើនរុងរឿង ដូច្នោះ មិនបាន គឺក្នុងទីណាក៏ទទេ ត្រូវចោរប្លន់ អធិប្បាយថា សូម្បីឱជាក្នុងប្រេង ទឹកឃ្មុំ ទឹកអំពៅជាដើម និងក្នុងយាគូ កត្តជាដើម ក៏សាបសូន្យទៅ ។ ពីរបទថា **អមច្ចា ចារិសជ្ជា** គឺពួកអមាត្យ និងអ្នកត្រាច់ទៅក្នុងបរិស័ទ ។ បទថា **គណកមហាមត្តា** បានដល់ ពួកហោរាដែលជំនាញក្នុងបាឋៈ មានអច្ឆិទ្ទិកៈ គឺទាយសំពត់កណ្តុរកាត់ជាដើម និងពួកអមាត្យថ្នាក់ធំ ។ បទថា **អនីកដ្ឋា** គឺពួកអាចារ្យទាំងឡាយ មានហត្ថាចារ្យ ( អាចារ្យដំរី ) ជាដើម ។ បទថា **ទោវារិកា** គឺពួកអ្នកយាមទ្វារ ។ បញ្ញាហៅថា មន្តក្នុងបទថា **មន្តស្សាជីវិនោ** នេះ ។ អាមាត្យទាំងឡាយណាដែលជាធំ ធ្វើបញ្ញានោះឲ្យជាគ្រឿងចិញ្ចឹមជីវិត អមាត្យថ្នាក់ធំពួកនោះ ឈ្មោះថា **បណ្ឌិត**។ បទថា **មន្តស្សាជីវិនោ** នោះ ជាឈ្មោះនៃមហាមាត្យទាំងនោះ ។

[ ៣៩ ] បទថា **នោ ច ខោ អធនានំ** សេចក្តីថា ដល់មនុស្សអ្នកគ្មានទ្រព្យ គឺអ្នកក្រលំបាក ព្រោះខ្លួនមានសេចក្តីលោភខ្លាំងក្លា ។ បទថា **ធនេ នានុប្បទិយមានេ** សេចក្តីថា ដែលគេមិនប្រគល់ទ្រព្យឲ្យ ។ ម្យ៉ាងទៀត បាលី ក៏ជាដូច្នេះដូចគ្នា ។ បទថា **ទាលិទ្ទិយំ** ប្រែថា ទ័លក្រ ។ បទថា

**អត្តនា ច ជីវាហិ** សេចក្តីថា ចូររស់នៅ គឺចូរញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅឯង ។ បទថា **ឧទ្ធគ្គិកំ** មានវិគ្គហៈថា ផលរបស់ទក្ខិណានោះ ទៅខាងលើដោយអំណាចឲ្យផលក្នុងភូមិខ្ពស់ៗ ឡើងទៅ ហេតុនោះ ទើបទក្ខិណានោះ ឈ្មោះថា មានផលទៅខាងលើ ។ ទក្ខិណាឈ្មោះថា **សោវគ្គិកា** ព្រោះជាប្រ-យោជន៍ដល់សួគ៌ ព្រោះឲ្យកើតក្នុងសួគ៌នោះ ។ ទក្ខិណាឈ្មោះថា មានវិបាកជាសុខ ព្រោះមានវិបាកជាសុខ ក្នុងទីដែលខ្លួនកើតហើយ ។ ទក្ខិណាឈ្មោះថា ប្រព្រឹត្តទៅដើម្បីសួគ៌ ព្រោះឲ្យកើតផលវិសេស ១០ យ៉ាង ពណ៌សម្បុរដែលជាទិព្វជាដើម ដែលប្រសើរក្រៃលែង អធិប្បាយថា អ្នកចូរញ៉ាំងទក្ខិ-ណាទានបែបនេះឲ្យតាំងនៅ ។

[ ៤០ ] បទថា **បវឌ្ឍិស្សតិ** សេចក្តីថា នឹងចម្រើន គឺនឹងមានច្រើន ។ បទថា **សុនិសេធំ និសេធេយ្យំ** សេចក្តីថា អាត្មាអញនឹងធ្វើការហាម គឺគប្បីបដិសេធដាច់ខាត ។ បទថា **មូលឃច្ចំ** គឺផ្តាច់ផ្តិលឫសគល់ ។ បទថា **ខុរស្សរេន** គឺមានសំឡេងគ្រោតគ្រាត ។ បទថា **បណាទេន** គឺស្គរពិឃាត ។

[ ៤១ ] បទថា **សីសានិ នេសំ ឆិន្ទិស្សាមិ** សេចក្តីថា ដោយហោចពួកយើងលួចត្រាវ ដំឡូង ត្រឹមតែមួយក្តាប់របស់អ្នកណាទៅ យើងនឹងកាត់ក្បាលរបស់អ្នកនោះ ដោយប្រការដែលបុគ្គលណាមួយមិនដឹងរឿងដែលយើងសម្លាប់ ឥឡូវនេះ ក្នុងទីនេះ នឹងមានប្រយោជន៍អ្វីដល់ពួកយើង សូម្បីស្តេចក៏ក្រោកឡើងយ៉ាងនោះហើយ ត្រាស់បង្គាប់ឲ្យសម្លាប់បុគ្គលដទៃ ។ គប្បីជ្រាបអធិប្បាយនៃពាក្យទាំងនោះ ដូចពោលមកនេះ ។

បទថា **ឧបក្កមឹសុ** គឺផ្តើមហើយ ។ បទថា **បន្ថទូហានំ** សេចក្តីថា ស្ទាក់ប្លន់អ្នកដើរផ្លូវ ។

[ ៤២ ] បទថា **ន ហិ នោ** សេចក្តីថា បានឮមកថា បុរសនោះគិតថា ស្តេចនេះ ត្រាស់បង្គាប់ឲ្យប្រហារតាមដែលឲ្យការសារភាពថា ពិតហើយ ព្រះអង្គ ណ្ហើយចុះ អញនឹងឲ្យនូវការកុហក ដូច្នេះហើយ ព្រោះខ្លាចស្លាប់ ទើបទូលថា មិនពិតទេ ព្រះអង្គ ។

[ ៤៤ ] បទថា **ឥធំ** ក្នុងបទថា **ឯកិធំ** នេះ ត្រឹមតែជានិបាត ។ អធិប្បាយថា សត្វពួកមួយ ។ បទថា **ចារិត្តំ** បានដល់ ការប្រព្រឹត្តខុស ។

[ ៤៥ ] បទថា **អភិជ្ឈា ព្យាបាទា** បានដល់ អភិជ្ឈា និងព្យាបាទ ។ បទថា **មិច្ឆាទិដ្ឋិ** បានដល់ ទិដ្ឋិដែលជាសត្រូវ មានអន្តគាហិកទិដ្ឋិ ដែលយល់ថា ទានដែលបុគ្គលឲ្យហើយមិនមានផលដូច្នេះជាដើម ។ បទថា **អធម្មរាគោ** បានដល់ តម្រេកក្នុងឋានៈដែលមិនសមគួរក្នុងមាតា ១ ប្អូនស្រីរបស់មាតា ១ ប្អូនស្រីរបស់បិតា ១ បងស្រីរបស់មាតាបិតា ១ ជាដើម ។ បទថា **វិសម-លោភោ** បានដល់ ការលោភដ៏ខ្លាំងក្លាក្នុងឋានៈគួរបរិភោគ ។ បទថា **មិច្ឆា-ធម្មោ** សេចក្តីថា តម្រេកដោយអំណាចសេចក្តីពេញចិត្ត រវាងប្រុសនិងប្រុស ស្ត្រីនិងស្ត្រី ។ ក្នុងបទថា **អមត្តេយ្យតា** ជាដើម មានវិគ្គហៈថា អ្នកជួយសង្គ្រោះមាតា ឈ្មោះ **មត្តេយ្យ** ការៈនៃមត្តេយ្យៈនោះ ឈ្មោះ **មត្តេយ្យតា** ។ បទថា **មត្តេយ្យតា** នោះ ជាឈ្មោះនៃបដិបត្តិប្រពៃក្នុងមាតា ការមិនមាននៃ

មត្តេយ្យតានោះ និងភាពជាបដិបក្ខចំពោះមត្តេយ្យតានោះ ឈ្មោះថា **អមត្តេយ្យតា** ។ សូម្បីក្នុងបទថា **អបេត្តេយ្យតា** ជាដើម ក៏ន័យនេះឯង ។ បទថា **ន កុលេជេដ្ឋាបចាយិតា** សេចក្តីថា ភាវៈ គឺការមិនធ្វើសេចក្តីកោតក្រែង គឺការប្រព្រឹត្តឱនលំទោនចំពោះបុគ្គលដែលចម្រើនក្នុងត្រកូល ។

[ ៤៦ ] បទថា **យំ ឥមេសំ** គឺក្នុងសម័យណានៃមនុស្សទាំងនេះ ។ បទថា **អលំបតេយ្យ** សេចក្តីថា គួរឲ្យមានប្តី ។ បទថា **ឥមានិ រសានិ** សេចក្តីថា រសទាំងនេះ ជារសដ៏ប្រសើរក្នុងលោក ។ បទថា **អតិព្យា-ធិប្បិស្សន្តិ** បានដល់ នឹងរុងរឿងយ៉ាងក្រៃលែង ។ ម្យ៉ាងទៀត បាលីក៏យ៉ាងនេះដូចគ្នា ។ បទថា **កុសលន្តិបិ ន ភវិស្សតិ** សេចក្តីថា ឈ្មោះថា កុសលដូច្នេះ ក៏មិនមាន អធិប្បាយថា សូម្បីត្រឹមតែបញ្ញត្តិនឹងមិនប្រាកដ ។ បទថា **បុជ្ជា ច ភវិស្សន្តិ បាសំសា** សេចក្តីថា នឹងជាអ្នកគួរបូជា និងគួរសរសើរ ។ បានឮថា ក្នុងសម័យនោះ ពួកមនុស្សគិតគ្នាថា បុគ្គលឈ្មោះឯណោះ វាយមាតា វាយបិតា ផ្តាច់ជីវិតសមណព្រាហ្មណ៍ គួរសង្វេគហ្ន៎ បុរសរមែងមិនដឹងភាពជារៀមច្បងក្នុងត្រកូលមាន ដូច្នេះហើយ នឹងបូជា នឹងសរសើរបុរសនោះ ។ បទថា **ន ភវិស្សតិ មាតាតិ វា** សេចក្តីថា ចិត្តដែលប្រកបដោយសេចក្តីគោរពថា អ្នកនេះជាមាតារបស់អញមិនមានឡើយ ។ មនុស្សទាំងឡាយកាលពោលពាក្យអសប្បុរសប្រការផ្សេងៗ ដូចពោលនឹងមាតុគ្រាមក្នុងផ្ទះ ក៏នឹងចូលទៅរកដោយអាការមិនគោរព ។ សូម្បីក្នុងញាតិទាំងឡាយ មានម្តាយ

មីងជាដើម ក៏ន័យនេះដូចគ្នា ។ ក្នុងបទថា **មាតុច្ឆា** ជាដើមនេះ គឺប្អូន ឈ្មោះថា **មាតុច្ឆា** បានដល់ ប្អូនស្រីរបស់ម្ដាយ ឈ្មោះថា **មាតុលានី** បានដល់ ភរិយារបស់អ៊ំ ។ ឈ្មោះថា **អាចរិយភរិយា** បានដល់ ភរិយារបស់អាចារ្យដែលឲ្យសិក្សាសិល្បវិជ្ជា ។ បទថា **គរុនំ ទារា** បានដល់ ភរិយារបស់ញាតិ មានឪពុកមា និងឪពុកធំជាដើម ។ បទថា **សម្ភេទំ** សេចក្ដីថា ការៈដែលលាយលំ ឬការទម្លាយបវេណី ។ បទថា **តិព្វោ អាឃាតោ បច្ចុប្បដ្ឋិតោ ភវិស្សតិ** សេចក្ដីថា សេចក្ដីក្រោធដែលខ្លាំងក្លានឹងកើតឡើងចំពោះ ដោយកើតឡើងរឿយៗ ។ ពីរបទក្រោយ ក៏ជាវេវចនៈរបស់សេចក្ដីក្រោធនោះឯង ។ ពិតហើយ សេចក្ដីក្រោធរមែងធ្វើចិត្តឲ្យចងអាឃាត ហេតុនោះ ទើបឈ្មោះថា **អាឃាត** ។ សេចក្ដីក្រោធរមែងធ្វើប្រយោជន៍ សេចក្ដីចម្រើន និងសេចក្ដីសុខរបស់ខ្លួន និងអ្នកដទៃឲ្យវិនាស ហេតុនោះ ទើបឈ្មោះថា **ព្យាបាទ** នឹងពោលថាការប្រទូស្តនៃចិត្តក៏បាន ព្រោះប្រទូស្តដោយចិត្ត ។ បទថា **តិព្វំ វធកចិត្តំ** សេចក្ដីថា ចិត្តគិតនឹងសម្លាប់ ដើម្បីឲ្យអ្នកដទៃស្លាប់ រមែងមានដល់អ្នកដែលមានចិត្តស្រឡាញ់គ្នា ។ ដើម្បីសម្ដែងរឿងនៃចិត្តគិតនឹងសម្លាប់នោះ ទើបពោលពាក្យជាដើមថា **មាតុបិ បុត្តម្ហិ** ដូច្នេះ ។ បទថា **មាគវិកស្ស** បានដល់ ព្រានព្រៃ ។

[ ៤៧ ] បទថា **សត្តន្តរកប្បា** សេចក្ដីថា កប្បដែលវិនាសក្នុងចន្លោះដោយសស្ត្រា គឺនៅមិនទាន់ដល់សំវដ្តកប្ប លោកក៏វិនាសក្នុងចន្លោះ ។ ឈ្មោះ

ថា អន្តរកប្បនេះ មាន ៣ យ៉ាង គឺទុព្ភិក្ខន្តរកប្ប កប្បដែលលោកវិនាស ក្នុងចន្លោះដោយទុព្ភិក្ខភ័យ ១ រោគន្តរកប្ប កប្បដែលលោកវិនាសក្នុងចន្លោះ ដោយរោគ ១ សត្ថន្តរកប្ប កប្បដែលលោកវិនាសក្នុងចន្លោះដោយសស្ត្រា ១ ។ ក្នុងកប្បទាំងនោះ ទុព្ភិក្ខន្តរកប្បកើតឡើង មានឡើងដល់ពួកសត្វ ដែល ក្រាស់ដោយសេចក្តីលោភ ។ រោគន្តរកប្បកើតឡើង មានឡើងដល់ពួកសត្វ ដែលក្រាស់ដោយមោហៈ ។ សត្ថន្តរកប្បកើតឡើង មានឡើង ដល់ពួកសត្វ ដែលក្រាស់ដោយទោសៈ ។

ក្នុងកប្បទាំងនោះ ពួកសត្វដែលវិនាស ព្រោះទុព្ភិក្ខន្តរកប្ប រមែងកើត ឡើងក្នុងបិត្តិវិស័យដោយច្រើន ។ ព្រោះអ្វី ព្រោះមានសេចក្តីប្រាថ្នាក្នុងអាហារ ជាកម្លាំង ។ ពួកសត្វដែលវិនាស ព្រោះរោគន្តរកប្ប កើតក្នុងសួគ៌ដោយ ច្រើន ។ ព្រោះអ្វី ព្រោះសត្វទាំងនោះ កើតមេត្តាចិត្តឡើងថា ឱហ្ន៎ រោគ បែបនេះ មិនគប្បីមានដល់សត្វពួកដទៃ ។ ពួកសត្វដែលវិនាស ព្រោះ សត្ថន្តរកប្ប រមែងកើតក្នុងនរកដោយច្រើន ។ ព្រោះអ្វី ព្រោះមានអាឃាត ចំពោះគ្នានិងគ្នាយ៉ាងខ្លាំងក្លា ។ បទថា **មិគសញ្ញំ** សេចក្តីថា មនុស្សកើត សេចក្តីសម្គាល់ឡើងថា អ្នកនេះជាម្រឹគ អ្នកនេះជាម្រឹគ ។ បទថា **តិណ្ហានិ សត្ថានិ ហត្ថេសុ ចាតុភវិស្សន្តិ** សេចក្តីថា បានឮមកថា សម្រាប់មនុស្ស ទាំងនោះ វត្ថុណាម្នាក់គ្រាន់តែយកដៃចាប់ ដោយហោចទៅ សូម្បីតែស្លឹកស្មៅ ក៏ក្លាយជាអាវុធទាំងអស់ ។ បទថា **មា ច មយំ កញ្ចិ** សេចក្តីថា ពួកយើង កុំសម្លាប់សូម្បីបុរសណាម្នាក់ឲ្យស្លាប់ឡើយ ។ បទថា **មា ច អម្ហេ កោចិ**

សេចក្តីថា បុរសដទៃណាមួយ កុំសម្លាប់ពួកយើងឡើយ ។ បទថា **យន្នូនមយំ** សេចក្តីថា ពួកសត្វនឹងសម្គាល់គិតយ៉ាងនេះថា សេចក្តីវិនាសនៃលោកនេះប្រាកដចំពោះហើយ ដែលយើងទាំងឡាយពីរនាក់ នៅក្នុងទីជាមួយគ្នាមិនអាចមានជីវិតរស់នៅបាន ។ បទថា **វនគហនំ** សេចក្តីថា ទីព្រៃក្រាស់ដោយព្រឹក្សជាតិ មានគុម្ពស្មៅ និងវល្លិជាដើម ដែលរាប់ថា ព្រៃ ។ បទថា **រុក្ខគហនំ** គឺដោយដើមឈើ គឺព្រៃក្រាស់ដោយដើមឈើ គឺដែលចូលទៅបានលំបាក ។ បទថា **នទីវិទុគ្គំ** គឺទីកន្លែងដែលទៅបានដោយលំបាក ក្នុងទីដែលមានកោះនៅត្រង់ចន្លោះនៃស្ទឹងទាំងឡាយជាដើម ។ បទថា **បព្វតវិសមំ** គឺកន្លែងដែលមិនរាបស្មើដោយភ្នំទាំងឡាយ ។ ឬកន្លែងដែលក្រហែងក្រហូងក្នុងភ្នំទាំងឡាយ ។ បទថា **សភាគាយិស្សន្តិ** សេចក្តីថា ពួកសត្វនឹងធ្វើមនុស្សទាំងនោះ ឲ្យស្មើនឹងខ្លួនដោយពាក្យដែលណែនាំឲ្យរីករាយយ៉ាងនេះថា លោកដ៏ចម្រើនទាំងឡាយ យើងរស់នៅដោយប្រការណា សត្វទាំងឡាយលោកក៏ជួបឃើញហើយ សូម្បីលោកក៏រស់នៅដោយប្រការនោះ ។ បទថា **អាយតំ** គឺច្រើន ។ បទថា **ចាណាតិបាតា វិរមេយ្យាម** សេចក្តីថា ពួកយើងគួរវៀរបាណាតិបាតចេញ ។ អាចារ្យពួកខ្លះសូធ្យថា **ចាណាតិបាតំ វិរមេយ្យាម** ក៏មាន ។ ក្នុងពាក្យនោះ មានអធិប្បាយថា ពួកយើងគួរវៀរបាណាតិបាត ។ បទថា **វីសតិវស្សាយុកា** សេចក្តីថា មាតាបិតាវៀរចាកបាណាតិបាត ព្រោះហេតុអ្វី ទើបបុត្រទាំងឡាយ មានអាយុត្រឹមតែ ២០ ឆ្នាំ

ព្រោះមានខេត្តបរិសុទ្ធ ។ ពិតហើយ មាតាបិតានៃបុត្រទាំងនោះ ជាអ្នកមាន សីល ដូច្នោះ ទើបពួកគេមានអាយុវែង ព្រោះខេត្តបរិសុទ្ធនេះ ព្រោះកូនទាំង-ឡាយចម្រើនក្នុងគភ៌អ្នកមានសីល ។ សត្វពួកណាស្លាប់ក្នុងទីនេះ ហើយ កើតក្នុងទីនុ៎ះឯង សត្វទាំងនោះមានអាយុវែងដោយសម្បត្តិ គឺសីលរបស់ខ្លួន ប៉ុណ្ណោះ ។ បទថា **អស្សាម** ប្រែថា គប្បីមាន ។ បទថា **ចត្តាឡីសវស្សា-យុកា** សេចក្តីថា ចំណែកដែលជាខាងដើម បណ្ឌិតគប្បីជ្រាបដោយអំណាច បុគ្គល ដែលវៀរជាច់ខាតចាក អទិន្នាទានជាដើម ។

[ ៤៨ ] បទថា **ជិឃច្ឆា** សេចក្តីថា តណ្ហាដែលកើតឡើងយ៉ាងនេះថា ពួកលោកចូរឲ្យអាហារដល់យើង ។ បទថា **អនសនំ** សេចក្តីថា មិនមានការ បរិភោគ គឺការៈដែលមិនស្រស់ស្រាយ បានដល់ សេចក្តីខ្ជិលច្រអូសផ្លូវ កាយ គឺការប្រាថ្នានឹងដេកព្រោះបច្ច័យ គឺសេចក្តីស្រវឹងក្នុងអាហាររបស់អ្នក បរិភោគអាហារ អធិប្បាយថា ការៈនៃកាយមានកម្លាំងទន់ខ្សោយ ព្រោះការ បរិភោគ ។ បទថា **ជរា** បានដល់ ជរាប្រាកដ ។ បទថា **កុក្កុដសម្បាតិកា** មានវិគ្គហៈថា ការធ្លាក់ព្រមនៃមាន់ ពោល គឺការដែលមាន់ហើរឡើងពីដំបូល ផ្ទះមួយហើយ ចុះលើដំបូលផ្ទះមួយទៀត មានក្នុងគាមនិគម និងរាជធានីទាំង នេះ ហេតុនោះ គាមនិគម និងរាជធានីទាំងនេះ ឈ្មោះថា មានចម្ងាយមួយ មាន់ហើរ ។ បាលីថា **សម្បាធិកា** ដូច្នេះក៏មាន ។ អធិប្បាយថា ការដល់ ព្រមនៃមាន់ ពោល គឺការដើរទៅ ដោយជើងនៃមាន់ពីចន្លោះផ្ទះមួយ ទៅកាន់ ចន្លោះផ្ទះមួយទៀត មានក្នុងគាមនិគម និងរាជធានីទាំងនេះ ។ លោកសម្តែង

កាពដែលសត្វនៅរួមគ្នាជាក្រុមនោះឯង សូម្បីទាំងពីរនោះ ។ បទថា **អវីចិ មញ្ញេ ផុដោ ភវិស្សតិ** សេចក្តីថា នឹងពេញណែនតាន់តាប់ ដូចអវីចិ-មហានរក ។

ព្រះមានព្រះភាគ មិនត្រាស់ដោយអំណាចនៃអាយុសត្វ ដែលច្រើនថា ម្នាលភិក្ខុទាំងឡាយ ក្នុងវេលាមនុស្សមានអាយុ ៨០០០០ ឆ្នាំ ព្រះមានព្រះភាគនាមថា មេត្តេយ្យៈ នឹងកើតឡើងក្នុងលោក ។ ព្រោះព្រះពុទ្ធទាំងឡាយ រមែងមិនកើតក្នុងវេលាសត្វដែលមានអាយុកំពុងចម្រើនឡើង តែរមែងកើតក្នុងវេលាសត្វមានអាយុថយចុះ ។ អធិប្បាយថា ព្រោះហេតុនោះ វេលាណា អាយុនោះចម្រើនដល់ ១ អសង្ខេយ្យហើយ ថយចុះមកវិញ នឹងតាំងនៅក្នុងកាលដែលសត្វមានអាយុ ៨០០០០ ឆ្នាំ ក្នុងកាលនោះ ព្រះពុទ្ធនឹងកើតឡើង ។ បទថា **បរិហរិស្សតិ** នេះ លោកពោលដោយអំណាចនៃសត្វ ដែលចោមរោមត្រាច់ទៅ ។ បទថា **យូបោ** បានដល់ ប្រាសាទ ។ បទថា **រញ្ញា មហាបនាទេន ការាបិតោ** សេចក្តីថា មានព្រះរាជាដែលជាដើមហេតុ ទើបសក្កទេវរាជបញ្ជូនវិស្សកម្មទេវបុត្រឲ្យទៅសាងប្រាសាទ ដើម្បីជាប្រយោជន៍ ដល់ព្រះរាជាអង្គនោះ ។

បានឮមកថា កាលមុន បិតា និងបុត្រពីរនាក់ ជាជាងផែង នាំគ្នាយកដើមបបុស និងដើមល្វា សាងបណ្ណសាលាថ្វាយចំពោះព្រះបច្ចេកពុទ្ធ ហើយនិមន្តឲ្យលោកគង់ក្នុងទីនោះ ទំនុកបម្រុងដោយបច្ច័យ ៤ ។ លុះធ្វើកាល-កិរិយាហើយ ក៏កើតក្នុងទេវលោក ។ បិតា និងបុត្រ ទាំងពីរនាក់នោះ បិតាក៏

នៅក្នុងទេវលោកនុ៎ះឯង ។ បុត្រច្យុតិចាកទេវលោកហើយ កើតក្នុងព្រះគភ៌ របស់ព្រះនាងសុមេធា ជាទេវីរបស់ព្រះបាទសុរុចិត្ត ជាព្រះរាជកុមារព្រះនាមថា មហាបនាទ ។ លុះក្រោយមក ព្រះអង្គក៏បានទទួលអភិសេក បានជាព្រះរាជាព្រះនាមថា មហាបនាទ ។ លំដាប់នោះ ដោយបុញ្ញានុភាពរបស់ព្រះអង្គ ទើបសក្កទេវរាជ បញ្ជូនវិស្សកម្មទេវបុត្រ ឲ្យទៅសាងប្រាសាទថ្វាយ ។ វិស្សកម្មទេវបុត្រនោះ និម្មិតប្រាសាទមួយថ្វាយព្រះអង្គ មានកម្ពស់ដល់ ២៥ យោជន៍ ៧ ជាន់ សុទ្ធតែប្រកបដោយរតនៈទាំង ៧ ប្រការ ដែលលោកពោលក្នុងជាតកថា

ព្រះរាជាអង្គនោះ ទ្រង់ព្រះនាមបនាទៈ មានប្រាសាទមាស មានទទឹងប្រវែងកិរិយាធ្លាក់ចុះនៃកូនសរ ១៦ ( កន្ទះយោជន៍ ) ( អ្នកប្រាជ្ញទាំងឡាយ ) ពោលថា ប្រាសាទនោះ កម្ពស់ ១ ពាន់តំណនៃកូនសរ ( ២៥ យោជន៍ ) ។ ប្រាសាទនោះ កម្ពស់ ១ ពាន់តំណនៃកូនសរ មានជាន់ ៧ បរិបូណ៌ដោយទង់ ព័ន្ធព័ទ្ធហើយដោយកែវមណីមានពណ៌ខៀវ ពួករបាំ ៦០០០ ចែកជា ៧ ចំណែក បានរាំលើប្រាសាទនោះ ( គ្រប់ៗ ថ្នាក់ ) ។ ម្នាលភទ្ទជិ អ្នកពោលហើយយ៉ាងណា ប្រាសាទនោះ មានហើយក្នុងកាលនោះយ៉ាងនោះ តថាគតកើតជាព្រះឥន្ទ្រ ជាវេយ្យាវច្ចកររបស់អ្នក ដូច្នេះ ។

ព្រះរាជានោះ គង់នៅត្រង់ប្រាសាទនោះ ដរាបដល់អស់ព្រះជន្មាយុ ចូលទីវង្គត់ហើយ ទៅកើតក្នុងទេវលោក ។ កាលទ្រង់កើតក្នុងទេវលោក ប្រាសាទនោះ ក៏លិចចុះក្នុងស្ទឹងគង្គា ។ ព្រះនគរ ឈ្មោះបយាគបតិដ្ឋ ដែលទេវតានិម្មិតហើយក្នុងទីជិតក្បាលជណ្តើរ របស់ប្រាសាទនោះ ។ ស្រុកឈ្មោះកោដិគ្រាម មានក្នុងទីត្រង់កំពូលប្រាសាទ ។ ក្រោយមក កាលព្រះសាស្តានៃយើងកើតឡើងក្នុងលោក ទេវបុត្រជាងតម្បាញនោះ ចុតិចាកទេវលោក បានជាសេដ្ឋីឈ្មោះភទ្ទជិ ក្នុងមនុស្សលោកបួសក្នុងសម្នាក់ព្រះសាស្តា បានសម្រេចព្រះអរហត្ត ។ គប្បីឲ្យរឿងពិស្តារ ដោយពាក្យថា ភទ្ទជិភិក្ខុនោះ បង្ហាញប្រាសាទនោះ ដល់ពួកភិក្ខុក្នុងថ្ងៃដែលយកទូកឆ្លងទន្លេគង្គា ។ សួរថា ព្រោះហេតុអ្វី ទើបប្រាសាទនេះ មិនអន្តរធានទៅ ឆ្លើយថា ព្រោះអានុភាពបុណ្យទេវបុត្រក្រៅពីនេះ ។ ដែលធ្វើបុណ្យរួមជាមួយលោក កើតក្នុងទេវ-លោកក្នុងអនាគត នឹងបានជាព្រះរាជាព្រះនាមថា សង្ខ: ប្រាសាទនោះ នឹងតាំងឡើងសម្រាប់ឲ្យព្រះរាជានោះប្រើប្រាស់ ព្រោះហេតុនោះ ទើបប្រាសាទនោះមិនអន្តរធាន ។

បទថា **ឧស្សាបេត្វា** សេចក្តីថា ឲ្យប្រាសាទនោះតាំងឡើង ។ បទថា **អជ្ឈាវសិត្វា** បានដល់ គង់នៅក្នុងទីនោះ ។ បទថា **តំទត្វា វិសជ្ជិត្វា** សេចក្តីថា ឲ្យប្រាសាទនោះ ដោយអំណាចទាន និងលះបង់ដោយអំណាចបរិច្ចាគ ដោយមិនសង្ឃឹមផលតបស្នង ។ សួរថា ឲ្យប្រាសាទយ៉ាងនោះដល់អ្នកណា ឆ្លើយថា ដល់ពួកសមណៈជាដើម ។ ព្រោះហេតុនោះ ទើបលោក

បានពោលថា ឲ្យទានដល់សមណព្រាហ្មណ៍ មនុស្សកំព្រា អ្នកដើរផ្លូវ វណិព្វក: និងយាចក ។ សួរថា ព្រះរាជា ( សង្ខ: ) នោះ ឲ្យទានប្រាសាទមួយខ្នងដល់បដិគ្គាហកដ៏ច្រើនបានដូចម្តេច ឆ្លើយថា បានឮថា ចិត្តរបស់ទ្រង់កើតឡើងយ៉ាងនេះថា ប្រាសាទនេះ ចូរបែកទៅ ។ ប្រាសាទនោះក៏បែកជាបំណែកតូច ធំ ទ្រង់មិនមានចិត្តជាប់ជំពាក់នឹងប្រាសាទនោះឡើយ លះបង់ដោយអំណាចទាន ដោយព្រះតម្រាស់ថា អ្នកណាប្រាថ្នាចំនួនប៉ុនណា អ្នកនោះចូរកាន់យកចំនួនប៉ុណ្ណោះចុះ ដោយហេតុនោះ ទើបលោកពោលថា **ធានំ ទត្វា មេត្តេយ្យស្ស ភគវតោ ។បេ។ វិហរិស្សតិ** ដូច្នេះ ។ ព្រះសាស្តាមានព្រះភាគ ទ្រង់សម្តែងអនុសន្ធិបន្តនៃវដ្តគាមីកុសល ដោយព្រះតម្រាស់មានប្រមាណប៉ុណ្ណេះ ។

[ ៤៩-៥០ ] ឥឡូវនេះ កាលទ្រង់សម្តែងអនុសន្ធិនៃវដ្តគាមីកុសល ទើបត្រាស់ពាក្យថា **អត្តទីបា ភិក្ខវេ វិហរថ** ទៀតជាដើម ។ បទថា **ឥធំ ខោ ភិក្ខវេ ភិក្ខុនោ អាយុស្មិំ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់សម្តែងថា ម្នាលភិក្ខុទាំងឡាយ តថាគតបានពោលពាក្យណានឹងអ្នកថា អ្នកទាំងឡាយ នឹងចម្រើនដោយអាយុខ្លះ ពាក្យនេះ រមែងមានក្នុងអាយុរបស់ភិក្ខុនោះ គឺពាក្យនេះជាហេតុនៃអាយុ ។ ព្រោះដូច្នោះ ពួកអ្នកកាលត្រូវការឲ្យអាយុចម្រើន ត្រូវចម្រើនឥទ្ធិបាទទាំង ៤ យ៉ាងនេះ ។ បទថា **វណ្ណស្មិំ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់សម្តែងថា តថាគតបានពោលពាក្យណានឹងអ្នកថា ពួកអ្នកនឹងចម្រើនដោយពណ៌សម្បុរខ្លះ នេះជាហេតុ ( ចម្រើន ) ពណ៌សម្បុរក្នុង

វណ្ណៈនោះ ព្រោះថា ពណ៌សម្បុរនៃសរីរៈរបស់អ្នកមានសីល រមែងចម្រើន ដោយអំណាចសេចក្ដីមិនក្ដៅក្រហាយជាដើម សូម្បីវណ្ណៈ គឺគុណ ក៏ចម្រើន ដោយអំណាចកេរ្តិ៍ឈ្មោះ ព្រោះដូច្នោះ ពួកអ្នកកាលត្រូវការឲ្យពណ៌សម្បុរ ចម្រើន ត្រូវមានសីលបរិបូណ៌ ។

បទថា **សុខស្មឹ** សេចក្ដីថា ព្រះមានព្រះភាគ ទ្រង់សម្ដែងថា តថាគត បានពោលពាក្យណានឹងពួកអ្នកថា ពួកអ្នកនឹងចម្រើនដោយសេចក្ដីសុខខ្លះ ដូច្នេះ ពាក្យនេះ រមែងមានសេចក្ដីសុខដែលកើតពីឈាន មានប្រការផ្សេងៗ មានបីតិ និងសុខកើតអំពីវិវេក ក្នុងសេចក្ដីសុខនោះ គឺព្រោះហេតុនោះ ពួកអ្នកកាលត្រូវការឲ្យចម្រើន ដោយសេចក្ដីសុខ ត្រូវចម្រើនឈានទាំង ៤ យ៉ាងនេះ ។ បទថា **ភោគស្មឹ** សេចក្ដីថា ព្រះមានព្រះភាគ ទ្រង់សម្ដែងថា តថាគតបានពោលពាក្យណានឹងពួកអ្នកថា ពួកអ្នកនឹងចម្រើនដោយភោគៈ ដូច្នេះ គឺភោគៈ បានដល់ ព្រហ្មវិហារ ដែលគប្បីផ្សាយបានទូទៅគ្រប់ទិស ដែលនាំមកនូវភាពជាអ្នកមិនស្អប់ពួកសត្វ ដែលរកប្រមាណមិនបាន មានអានិសង្ស ១១ ប្រការ ដូចជាដេកជាសុខជាដើម ព្រោះដូច្នោះ ពួកអ្នកកាលត្រូវការឲ្យភោគៈចម្រើន ត្រូវចម្រើនព្រហ្មវិហារទាំងនេះ ។ បទថា **ពលស្មឹ** សេចក្ដីថា ព្រះមានព្រះភាគ ទ្រង់សម្ដែងថា តថាគតបានពោលពាក្យណានឹងពួកអ្នកថា ពួកអ្នកនឹងចម្រើនដោយកម្លាំង ដូច្នេះ ពាក្យនេះ កម្លាំង ពោល គឺអរហត្តផល ដែលកើតឡើងក្នុងទីបំផុតក្នុងការអស់ទៅនូវអាសវៈ ព្រោះហេតុនោះ ពួកអ្នកកាលត្រូវការនឹងឲ្យកម្លាំងចម្រើន ត្រូវប្រារព្ធសេចក្ដីព្យាយាម

ដើម្បីការសម្រេចអរហត្ត ។ បទថា **យថយិទំ ភិក្ខវេ មារពលំ** សេចក្ដីថា ព្រះមានព្រះភាគទ្រង់សម្ដែងថា តថាគតរមែងពិចារណា មិនឃើញសូម្បីកម្លាំងដែលជាឯកក្នុងលោកដទៃ ដែលគ្របសង្កត់បានដោយលំបាក កម្ចាត់បានដោយលំបាក ដូចកម្លាំងរបស់ទេវបុត្តមារ មច្ចុមារ កិលេសមារនេះឡើយ អរហត្តផលនេះប៉ុណ្ណោះ រមែងគ្របសង្កត់កម្លាំងនោះបាន ព្រោះហេតុនោះ ពួកអ្នកគួរប្រារព្ធសេចក្ដីព្យាយាមក្នុងព្រះអរហត្តនេះប៉ុណ្ណោះ ។

បទថា **ឯវមិទំ បុញ្ញំ** សេចក្ដីថា សូម្បីបុណ្យដែលជាលោកុត្តរនេះ រមែងចម្រើនរហូតអស់អាសវៈ ។ ព្រះមានព្រះភាគ កាលញ៉ាំងអនុសន្ធិបទនៃវិវដ្ដគាមីកុសលឲ្យចប់ ទើបញ៉ាំងទេសនាឲ្យចប់សព្វគ្រប់ដល់កំពូល គឺព្រះអរហត្ត ។ ក្នុងវេលាចប់ព្រះសូត្រ ភិក្ខុ ២០០០០ រូប បានសម្រេចព្រះអរហត្ត សត្វ ៨៤០០០ បានផឹកនូវទឹកអម្រឹត ដូច្នេះឯង ។ អដ្ឋកថាចក្កវត្តិសូត្រ ក្នុងទីឃនិកាយ ឈ្មោះសុមង្គលវិលាសិនី ចប់ ។

**ចក្កវត្តិសូត្រ ចប់**

**សូត្រទី ៣**

# សុត្តបិដក

## អគ្គញ្ញសូត្រទី ៤

[ ៥១ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងប្រាសាទរបស់មិគារមាតា ( នាងវិសាខា ) ក្នុងវត្តបុព្វារាម ជិតក្រុងសាវត្ថី ។ សម័យនោះឯង វាសេដ្ឋសាមណេរ និងភារទ្វាជសាមណេរ មានប្រាថ្នានឹងបួសជាភិក្ខុ ទើបធ្វើតិត្ថិយបរិវាសក្នុងសម្នាក់ភិក្ខុទាំងឡាយ ។ លំដាប់នោះឯង វេលាថ្ងៃរសៀល ព្រះមានព្រះភាគទ្រង់ចេញអំពីទីសម្ងំ ហើយចុះអំពីប្រាសាទទៅចង្រ្កមក្នុងទីវាលត្រង់ម្លប់ប្រាសាទ ។ ឯវាសេដ្ឋសាមណេរ ក៏បានឃើញព្រះមានព្រះភាគ ដែលទ្រង់ចេញអំពីទីសម្ងំក្នុងវេលាថ្ងៃរសៀល ហើយចុះអំពីប្រាសាទទៅចង្រ្កមក្នុងទីវាលត្រង់ម្លប់ប្រាសាទ លុះឃើញហើយ ក៏ប្រាប់ភារទ្វាជសាមណេរថា ម្នាលអាវុសោភារទ្វាជៈ ព្រះមានព្រះភាគនេះ ទ្រង់ចេញអំពីទីសម្ងំក្នុងវេលាថ្ងៃរសៀល ហើយចុះអំពីប្រាសាទកំពុងចង្រ្កម ក្នុងទីវាលត្រង់ម្លប់ប្រាសាទ ម្នាលអាវុសោភារទ្វាជៈ មកយើងនឹងចូលទៅគាល់ព្រះមានព្រះភាគ ក្រែងលោយើងនឹងបានស្តាប់ធម្មីកថាចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ។ ភារទ្វាជសាមណេរ ក៏បានទទួលស្តាប់ពាក្យវាសេដ្ឋ-សាមណេរថា អើអាវុសោ ។ គ្រានោះឯង វាសេដ្ឋសាមណេរ និងភារទ្វាជ-សាមណេរនាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយក៏ដើរតាមព្រះមានព្រះភាគដែលកំពុងចង្រ្កម ។ លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលនឹងវាសេដ្ឋសាមណេរ

ថា ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ អ្នកទាំងឡាយជាជាតិព្រាហ្មណ៍ ជាត្រកូលព្រាហ្មណ៍ បានលះបង់ត្រកូលព្រាហ្មណ៍ ចេញចាកផ្ទះចូលមកកាន់ផ្នួស ចុះពួកព្រាហ្មណ៍ដ៏ប្រសើរមិនជេរ មិនប្រទេចអ្នកទាំងឡាយទេឬ ។ វាសេដ្ឋសាមណេរក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកព្រាហ្មណ៍ជេរប្រទេចយើងទាំងឡាយ ដោយពាក្យប្រទេចតាមចិត្តគេពេញទី មិនមែនខ្វះកន្ទះទេ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ចុះពួកព្រាហ្មណ៍ ជេរប្រទេចអ្នកទាំងឡាយ ដោយពាក្យប្រទេចតាមចិត្តគេពេញទី មិនមែនខ្វះកន្ទះទេ តើដូចម្ដេច ។ វាសេដ្ឋសាមណេរក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកព្រាហ្មណ៍និយាយយ៉ាងនេះថា មានតែព្រាហ្មណ៍ទើបជាវណ្ណៈប្រសើរបំផុត ពួកជនឯទៀតជាវណ្ណៈថយថោក មានតែព្រាហ្មណ៍ ទើបជាវណ្ណៈស ពួកជនឯទៀតជាវណ្ណៈខ្មៅ មានតែពួកព្រាហ្មណ៍ ទើបបរិសុទ្ធ ពួកជនដែលមិនមែនជាព្រាហ្មណ៍មិនបរិសុទ្ធទេ ពួកព្រាហ្មណ៍ជាបុត្រ ជាឱរសរបស់ព្រហ្ម កើតអំពីព្រះឱស្ឋព្រហ្ម កើតមកអំពីព្រហ្ម ព្រហ្មបានតាក់តែងមកជាទាយាទរបស់ព្រហ្ម ឯអ្នកទាំងឡាយនោះ លះចោលវណ្ណៈដ៏ប្រសើរចេញហើយត្រឡប់មកកាន់វណ្ណៈថយថោកវិញ គឺត្រឡប់ចូលទៅក្នុងសម្នាក់សមណៈត្រងោល ជាគហបតី វណ្ណៈខ្មៅ ជាពួកនៃមារ កើតអំពីព្រះបាទព្រហ្ម ក៏អ្នកទាំងឡាយលះចោលវណ្ណៈដ៏ប្រសើរចេញ ហើយត្រឡប់មកកាន់វណ្ណៈថយថោកវិញ គឺត្រឡប់ចូលទៅក្នុងសម្នាក់សមណៈត្រងោល ជាគហបតី វណ្ណៈខ្មៅ ជាពួកនៃមារ កើតមកអំពីព្រះបាទព្រហ្មដោយហេតុណា ហេតុនោះ

ពុំប្រពៃ ពុំសមគួរឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកព្រាហ្មណ៍ជេរប្រទេចយើងទាំងឡាយដោយពាក្យប្រទេចតាមចិត្តគេពេញទី មិនមែនខ្វះកន្ទះទេ យ៉ាងនេះឯង ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា អើវាសេដ្ឋៈ និងភារទ្វាជៈ ពួកព្រាហ្មណ៍របស់អ្នកទាំងឡាយ មិនបានដឹងនូវការកើតឡើងនៃលោកអំពីដើមមកទេ ទើបបានជានិយាយយ៉ាងនេះថា មានតែព្រាហ្មណ៍ទើបជាវណ្ណៈប្រសើរបំផុត ពួកជនឯទៀតជាវណ្ណៈថយថោក មានតែព្រាហ្មណ៍ទើបជាវណ្ណៈស ពួកជនឯទៀតជាវណ្ណៈខ្មៅ មានតែពួកព្រាហ្មណ៍ទើបបរិសុទ្ធ ពួកជនដែលមិនមែនជាព្រាហ្មណ៍ មិនបរិសុទ្ធទេ ពួកព្រាហ្មណ៍ជាបុត្រ ជាឱរសរបស់ព្រហ្ម កើតអំពីព្រះឱស្ឋព្រហ្ម កើតអំពីព្រហ្ម ព្រហ្មបានតាក់តែងមក ជាទាយាទរបស់ព្រហ្ម ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ឯពួកនាងព្រាហ្មណី ដែលមានរដូវក្តី មានគភ៌ក្តី កំពុងសម្រាលកូនក្តី កំពុងបំបៅកូនក្តី សឹងប្រាកដដល់ពួកព្រាហ្មណ៍ ឯព្រាហ្មណ៍ទាំងនោះ ក៏សុទ្ធតែកើតអំពីយោនី ( នាងព្រាហ្មណី ) តែត្រឡប់ជានិយាយយ៉ាងនេះវិញថា មានតែព្រាហ្មណ៍ទើបជាវណ្ណៈប្រសើរបំផុត ។បេ។ ជាទាយាទរបស់ព្រហ្មដូច្នេះ ។ ឯព្រាហ្មណ៍ទាំងនោះឈ្មោះថា និយាយបន្តាប់ព្រហ្មផង និយាយកុហកផង រមែងទទួលនូវបាបច្រើន ។

[ ៥២ ] ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ វណ្ណៈទាំងឡាយនេះមាន៤ពួក គឺខត្តិយៈ ១ ព្រាហ្មណ៍ ១ វេស្សៈ ១ សុទ្ទៈ ១ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ទោះខត្តិយៈពួកខ្លះ ក្នុងលោកនេះ ក៏ជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ

ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ និយាយពាក្យកុហក និយាយពាក្យញុះញង់ និយាយពាក្យទ្រគោះ និយាយពាក្យឥតប្រយោជន៍ ជាអ្នកមានសេចក្តីលោភ មានចិត្តប្រកបដោយព្យាបាទ មានសេចក្តីយល់ខុសដែរ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ព្រោះហេតុនេះឯង ធម៌ទាំងឡាយណាជាអកុសល ក៏រាប់ថាជាអកុសល ដែលមានទោស ក៏រាប់ថាមានទោស ដែលមិនគួរសេព ក៏រាប់ថាមិនគួរសេព ដែលមិនសមគួរក្នុងអរិយភាវៈ ក៏រាប់ថាមិនសមគួរក្នុងអរិយភាវៈ ជាធម៌ខ្មៅ មានផលខ្មៅ ដែលវិញ្ញូជនតែងតិះដៀល ។ ធម៌ទាំងឡាយនោះតែងប្រាកដក្នុងខត្តិយៈពួកខ្លះ ក្នុងលោកនេះឯង ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ទោះព្រាហ្មណ៍ ។បេ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ទោះវេស្សៈ ។បេ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ទោះសុទ្ទៈ ពួកខ្លះក្នុងលោកនេះ ក៏ជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ។បេ។ មានសេចក្តីយល់ខុសដែរ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ព្រោះហេតុនេះឯង ធម៌ទាំងឡាយណាជាអកុសល ក៏រាប់ថាជាអកុសល ។បេ។ ជាធម៌ខ្មៅ មានផលខ្មៅ ដែលវិញ្ញូជនតែងតិះដៀល ។ ធម៌ទាំងឡាយនោះតែងប្រាកដក្នុងសុទ្ទៈពួកខ្លះក្នុងលោកនេះឯង ។

[ ៥៣ ] ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ទោះខត្តិយៈពួកខ្លះ ក្នុងលោកនេះ ក៏ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកបិសុណាវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ ជាអ្នកមិនមានសេចក្តីលោភ មិនមានចិត្តព្យាបាទ មានសេចក្តីយល់ត្រូវដែរ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ព្រោះហេតុនេះឯង

ធម៌ទាំងឡាយណាជាកុសល ក៏រាប់ថាជាកុសល ដែលមិនមានទោស ក៏រាប់ថាមិនមានទោស ដែលគួរសេព ក៏រាប់ថាគួរសេព ដែលសមគួរក្នុងអរិយ-ការៈ ក៏រាប់ថាសមគួរក្នុងអរិយការៈ ជាធម៌ស មានផលស ដែលវិញ្ញូជនតែងសរសើរ ។ ធម៌ទាំងឡាយនោះ តែងប្រាកដក្នុងខត្តិយៈពួកខ្លះក្នុងលោកនេះឯង ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ទោះព្រាហ្មណ៍ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ទោះវេស្សៈ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ទោះសុទ្ទៈពួកខ្លះក្នុងលោកនេះ ក៏ជាអ្នកវៀរចាកបាណាតិបាត ។បេ។ ជាអ្នកមិនមានសេចក្តីលោភ មិនមានចិត្តព្យាបាទ មានសេចក្តីយល់ត្រូវដែរ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ព្រោះហេតុនេះឯង ធម៌ទាំងឡាយណាជាកុសល ក៏រាប់ថាជាកុសល ដែលមិនមានទោស ក៏រាប់ថាមិនមានទោស ដែលគួរសេព ក៏រាប់ថា គួរសេព ដែលសមគួរក្នុងអរិយការៈ ក៏រាប់ថាសមគួរក្នុងអរិយការៈ ជាធម៌ស មានផលស ដែលវិញ្ញូជនតែងសរសើរ ។ ធម៌ទាំងឡាយនោះតែងប្រាកដក្នុងសុទ្ទៈពួកខ្លះក្នុងលោកនេះឯង ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ កាលបើវណ្ណៈទាំង ៤ ពួកនេះឯង ប្រព្រឹត្តប្រឡូកប្រឡំគ្នាក្នុងធម៌ពីរពួក គឺធម៌ខ្មៅនិងធម៌ស ដែលវិញ្ញូជន តែងតិះដៀលខ្លះ សរសើរខ្លះ បើពួកព្រាហ្មណ៍ ( ដែលកំពុងប្រព្រឹត្ត ) ក្នុងធម៌ខ្មៅ និងធម៌សនោះ និយាយយ៉ាងនេះថា មានតែព្រាហ្មណ៍ ទើបជាវណ្ណៈប្រសើរបំផុត ពួកជនឯទៀត ជាវណ្ណៈថោកទាប មានតែព្រាហ្មណ៍ ទើបជាវណ្ណៈស ពួកជនឯទៀតជាវណ្ណៈខ្មៅ មានតែពួកព្រាហ្មណ៍ ទើបបរិសុទ្ធ ពួកជនដែលមិនមែនជាព្រាហ្មណ៍ មិនបរិសុទ្ធទេ ពួក

ព្រាហ្មណ៍ជាបុត្រ ជាឱរសរបស់ព្រហ្ម កើតអំពីព្រះឱស្ឋព្រហ្ម កើតអំពីព្រហ្ម ព្រហ្មបានតាក់តែងមកជាទាយាទរបស់ព្រហ្ម ដូច្នេះ ។ វិញ្ញូជនទាំងឡាយមិនយល់ព្រមតាម គឺមិនសរសើរនូវពាក្យរបស់ព្រាហ្មណ៍ទាំងនោះទេ ។ ដំណើរនោះ តើព្រោះហេតុអ្វី ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ព្រោះថា បណ្ដាវណ្ណៈទាំង ៤ ពួកនេះ វណ្ណៈណាជាភិក្ខុ ឆ្ងាយចាកកិលេស អស់អាសវៈហើយ ប្រព្រឹត្តព្រហ្មចារ្យរួចស្រេចហើយ បានធ្វើសោឡសកិច្ចស្រេចហើយ មានភារៈ គឺកិលេស និងខន្ធដាក់ចុះហើយ បានសម្រេចប្រយោជន៍របស់ខ្លួនតាមលំដាប់ហើយ មានតណ្ហាជាគ្រឿងចងក្នុងភពអស់រលីងហើយ មានចិត្តផុតស្រឡះហើយ ព្រោះបានត្រាស់ដឹងដោយប្រពៃ វណ្ណៈនោះប្រាកដជាបុគ្គលប្រសើរលើសជាងវណ្ណៈទាំងនោះ ដោយធម៌ពិត មិនមែនដោយអធម៌ទេ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ព្រោះថា ធម៌ជាគុណដ៏ប្រសើរបំផុតក្នុងប្រជុំជនទាំងបច្ចុប្បន្ន និងបរលោក ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ បើដោយបរិយាយនេះឯង អ្នកគប្បីដឹងយ៉ាងនេះថា ធម៌ជាគុណដ៏ប្រសើរបំផុតក្នុងប្រជុំជន ទាំងបច្ចុប្បន្ន និងបរលោក ។

[ ៥៤ ] ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ព្រះបាទបសេនទិកោសល ទ្រង់ជ្រាបថាព្រះសមណគោតម ជាបុគ្គលខ្ពង់ខ្ពស់ចេញចាកសក្យត្រកូល មកទ្រង់ព្រះផ្នួស ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ប៉ុន្តែអម្បាលពួកសក្យៈគង់ជាចំណុះព្រះបាទបសេនទិកោសលមិនមានចន្លោះ ។ ម្នាលវាសេដ្ឋៈ និងភារ-ទ្វាជៈ ពួកសក្យៈតែងធ្វើសេចក្ដីគោរពថ្វាយបង្គំ ក្រោកទទួល អញ្ជលិកម្ម និង

សាមីចិកម្មចំពោះព្រះបាទបសេនទិកោសល ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ពួកសក្យៈតែងធ្វើសេចក្ដីគោរពថ្វាយបង្គំ ក្រោកទទួល អញ្ជលិកម្ម និង សាមីចិកម្មណាៗ ចំពោះព្រះបាទបសេនទិកោសល ឯព្រះបាទបសេនទិកោសល ក៏ទ្រង់ធ្វើសេចក្ដីគោរពថ្វាយបង្គំ ក្រោកទទួល អញ្ជលិកម្ម និងសាមីចិកម្ម នោះៗ ចំពោះតថាគតដែរ ដោយទ្រង់ព្រះតម្រិះថា ព្រះសមណគោតម ព្រះអង្គមានជាតិបរិសុទ្ធ អាត្មាអញជាមនុស្ស មានជាតិមិនបរិសុទ្ធ ព្រះ សមណគោតម ព្រះអង្គមានកម្លាំង អាត្មាអញជាមនុស្សមានកម្លាំងថយ ព្រះសមណគោតម ព្រះអង្គមានសម្បុរជ្រះថ្លា អាត្មាអញជាមនុស្សមាន សម្បុរសៅហ្មង ព្រះសមណគោតម ព្រះអង្គមានសក្ដានុភាពច្រើន អាត្មា អញជាមនុស្សមានសក្ដានុភាពតិច ដូច្នេះ តពីនោះមក ទ្រង់ក៏ធ្វើសក្ការៈ ចំពោះធម៌នោះ ធ្វើសេចក្ដីគោរពធម៌ រាប់អានធម៌ បូជាធម៌ កោតក្រែងធម៌ ដោយប្រការដូច្នេះឯង ។ ព្រះបាទបសេនទិកោសល ទ្រង់ធ្វើសេចក្ដីគោរព ថ្វាយបង្គំ ក្រោកទទួល អញ្ជលិកម្ម និងសាមីចិកម្មចំពោះតថាគតយ៉ាងនេះ ឯង ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ បើដោយបរិយាយនេះឯង អ្នកគប្បី ដឹងយ៉ាងនេះថា ធម៌ជាគុណប្រសើរបំផុត ក្នុងប្រជុំជនទាំងបច្ចុប្បន្ន និង បរលោក ។

[ ៥៥ ] ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ អ្នកទាំងឡាយ មានជាតិផ្សេងៗ គ្នា មានឈ្មោះផ្សេងៗ គ្នា មានគោត្រផ្សេងៗ គ្នា មានត្រកូលផ្សេងៗ គ្នា ចេញចាកផ្ទះមកកាន់ផ្នួស បើមានគេសួរថា លោកទាំងឡាយជាអ្វីដូច្នេះ ចូរ

ប្រាប់ទៅគេវិញថា យើងជាសមណសក្យបុត្ត ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ បើជនណាមានសទ្ធា គឺការជឿស្កប់ចុះស៊ប់ហើយ មានឫសដុះតាំងខ្ជាប់មាំមួនក្នុងតថាគត ទោះបីសមណព្រាហ្មណ៍ ទេវតា ព្រហ្ម ឬនរណាមួយក្នុងលោក ក៏មិនអាចនឹងបំបែរឲ្យត្រឡប់បានឡើយ ជននោះគួរនិយាយយ៉ាងនេះថា ខ្ញុំជាបុត្រ ជាឱរសនៃព្រះមានព្រះភាគ កើតមកអំពីព្រះឱស្ឋរបស់ព្រះមានព្រះភាគ កើតមកអំពីធម៌ ធម៌តាក់តែងមក ជាទាយាទរបស់ធម៌ ។ ព្រោះហេតុអ្វីបានជាតថាគតថា ដូច្នោះ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ព្រោះពាក្យថា ធម្មកាយ ដូច្នេះក្តី ព្រហ្មកាយ ដូច្នេះក្តី ធម្មភូតដូច្នេះក្តី ព្រហ្មភូតដូច្នេះក្តី ជាឈ្មោះរបស់តថាគត ។

[ ៥៦ ] ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានសម័យដែលលោកនេះត្រូវវិនាសម្តងៗ ដោយការកន្លងកាលជាយូរអង្វែង កាលដែលលោកកំពុងតែវិនាសទៅ មានពួកសត្វបានទៅកើតក្នុងអាភស្សរព្រហ្មដោយច្រើន ពួកសត្វទាំងនោះជាអ្នកកើតដោយឈានចិត្ត មានបីតិជាអាហារ មានរស្មីភ្លឺចេញឯង ត្រាច់ទៅក្នុងអាកាសបាន ឋិតនៅក្នុងវិមានដ៏ល្អ នៅអស់កាលជាយូរអង្វែង ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានសម័យដែលលោកនេះត្រូវចម្រើនឡើងម្តង ដោយកាលកន្លងជាយូរអង្វែងទៅ កាលដែលលោកកំពុងតែចម្រើនឡើង សត្វទាំងឡាយច្យុតចាកអាភស្សរព្រហ្មមកកាន់ភាពជាមនុស្សនេះ ឯសត្វទាំងនោះ ជាអ្នកកើតដោយឈានចិត្ត មានបីតិជាអាហារ មានពន្លឺភ្លឺចេញឯង ត្រាច់ទៅក្នុងអាកាសបាន ឋិតនៅក្នុងវិមានដ៏ល្អ នៅអស់កាល

យូរអង្វែង ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ សម័យនោះឯងចក្រវាលទាំងអស់ ក៏រលាយទៅជាទឹកចូលគ្នា មានងងឹតអ័ព្ទសូន្យសុង ព្រះចន្ទ្រ និងព្រះអាទិត្យក៏មិនប្រាកដ នក្ខត្តឫក្សដែលមានរូបជាផ្កាយទាំងឡាយ ក៏មិនប្រាកដ យប់ និងថ្ងៃក៏មិនប្រាកដ ខែមួយ និងកន្លះខែ ក៏មិនប្រាកដ រដូវ និងឆ្នាំ ក៏មិនប្រាកដ ស្ត្រី និងបុរសក៏មិនប្រាកដ ។ សត្វទាំងឡាយក៏គ្រាន់តែរាប់ថាជាសត្វប៉ុណ្ណោះឯង ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ លុះកាលកន្លងទៅជាយូរអង្វែងម្តងៗ ផែនដី មានរសអណ្តែតជាសលើទឹកសម្រាប់សត្វទាំងនោះប្រាកដដូចជាទឹកដោះក្តៅរលាយអណ្តែតជាសនៅលើទឹក ដូច្នោះ ផែនដីមានរសនោះ មានសម្បុរល្អ មានក្លិនក្រអូប មានរសផ្អែម មានសម្បុរស ដូចទឹកដោះថ្លា ឬដូចទឹកដោះ ខាប់ដែលមានរសផ្អែម ផែនដីនុ៎ះមានរសឆ្ងាញ់ពិសា ដូចទឹកឃ្មុំតូច ( ឃ្មុំផ្លិត ) ដែលឥតទោស ( គ្មានកូនឃ្មុំ ) ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ គ្រានោះឯង សត្វម្នាក់ មានជាតិជាអ្នកឡេះឡោះ គិតថា យីអើ នេះជាអ្វីអេះ ក៏យកចង្អុលដៃ ( ធ្លុះយក ) ផែនដីមានរសមកលិទ្ធមើល កាលសត្វនោះយកចង្អុលដៃ ( ធ្លុះយក ) ផែនដីមានរសមកលិទ្ធភ្លក្សមើល រសផែនដីក៏ជ្រួតជ្រាបទៅសព្វសរសៃ សម្រាប់ទទួលនូវរស ឯសេចក្តីប្រាថ្នាក្នុងរសក៏កើតដល់សត្វនោះ ។ ម្នាលវាសេដ្ឋៈ និងភារ-ទ្វាជៈ មានពួកសត្វដទៃទៀត កាលយកតម្រាប់តាមសត្វនោះ ក៏នាំគ្នាយកចង្អុលដៃ ( ធ្លុះយក ) ផែនដីមានរសមកលិទ្ធភ្លក្សមើល ។ កាលពួកសត្វទាំងនោះ លិទ្ធភ្លក្សរសផែនដីនឹងចង្អុលដៃ រសផែនដីក៏ជ្រួតជ្រាបទៅ ( សព្វ

សរសៃសម្រាប់ទទួលនូវរស ) ឯសេចក្ដីប្រាថ្នាក្នុងរស ក៏កើតឡើងដល់ពួកសត្វទាំងនោះ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ លំដាប់នោះ ក៏សត្វទាំងនោះនាំគ្នាយកដៃកកាយផែនដី ដែលមានរសមកធ្វើជាពំនូត ហើយបរិភោគ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ កាលដែលសត្វទាំងឡាយ នាំគ្នាយកដៃកកាយផែនដី ដែលមានរសមកធ្វើជាពំនូត ហើយបរិភោគ ពន្លឺដែលភ្លឺចេញឯង ( អំពីកាយ ) របស់សត្វទាំងនោះក៏សាបសូន្យបាត់ទៅ ។ លុះពន្លឺដែលភ្លឺចេញឯងសាបសូន្យទៅហើយ ព្រះចន្ទ្រ និងព្រះអាទិត្យក៏កើតប្រាកដឡើង លុះព្រះចន្ទ្រ និងព្រះអាទិត្យកើតប្រាកដឡើងហើយ នក្ខត្តឫក្សដែលមានរូបជាផ្កាយទាំងឡាយក៏កើតប្រាកដឡើង លុះនក្ខត្តឫក្ស ដែលមានរូបជាផ្កាយទាំងឡាយ កើតប្រាកដឡើងហើយ យប់ និងថ្ងៃក៏កើតប្រាកដឡើង លុះយប់ និងថ្ងៃកើតប្រាកដឡើងហើយ ខែ ១ និងកន្លះខែក៏កើតប្រាកដឡើង លុះខែ ១ និងកន្លះខែកើតប្រាកដឡើងហើយ រដូវ និងឆ្នាំក៏កើតប្រាកដឡើង ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ លោកនេះចម្រើនឡើងវិញដោយហេតុប៉ុណ្ណោះឯង ។

[ ៥៧ ] ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ គ្រាកាលពួកសត្វទាំងនោះនាំគ្នាបរិភោគផែនដីមានរស យកផែនដីនោះជាចំណី យកផែនដីនោះជាអាហារ ហើយឋិតនៅអស់កាលជាយូរអង្វែង ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ កាលពួកសត្វទាំងនោះបរិភោគផែនដីមានរស យកផែនដីនោះជាចំណី យកផែនដីនោះជាអាហារ ហើយឋិតនៅអស់កាលយូរអង្វែង ដោយប្រការ

យ៉ាងណាៗ សេចក្តីរឹងប៉ឹងក្នុងរាងកាយរបស់សត្វទាំងនោះក៏កើតឡើង ទាំងពណ៌សម្បុរក៏ប្លែកៗ គ្នា ប្រាកដឡើងដោយប្រការយ៉ាងនោះៗ ។ សត្វពួកខ្លះមានសម្បុរល្អ សត្វពួកខ្លះមានសម្បុរអាក្រក់ ។ បណ្តាសត្វទាំងពីរពួកនោះ ពួកសត្វណាដែលមានសម្បុរល្អ ពួកសត្វនោះ តែងមើលងាយពួកសត្វដែលមានសម្បុរអាក្រក់ថា ពួកយើងមានសម្បុរល្អលើសជាងពួកសត្វនុ៎ះ ពួកសត្វនុ៎ះមានសម្បុរអាក្រក់ជាងពួកយើង ។ កាលសត្វទាំងនោះមានសេចក្តីប្រកាន់ខ្លួន និងការមើលងាយកើតឡើង ព្រោះបច្ច័យនៃសេចក្តីមើលងាយនូវសម្បុរគ្នា ផែនដីដែលមានរសក៏សាបសូន្យអស់ទៅ ។ លុះផែនដីដែលមានរសសាបសូន្យហើយ សត្វទាំងឡាយក៏មកប្រជុំគ្នា លុះមកប្រជុំគ្នាហើយ ក៏ត្អូញត្អែរថា ឱ រស ( ឆ្ងាញ់របស់យើង ) ឱ រស ( ឆ្ងាញ់របស់យើង ) ។ ហេតុនោះក៏ដូចគ្នានឹងមនុស្សទាំងឡាយ ក្នុងកាលឥឡូវនេះដែរ ដែលបានវត្ថុអ្វីមួយ មានរសឆ្ងាញ់ហើយ តែងនាំគ្នាលាន់មាត់យ៉ាងនេះថា ឱ រស ( ឆ្ងាញ់របស់យើង ) ឱ រស ( ឆ្ងាញ់របស់យើង ) ។ សត្វទាំងឡាយនាំគ្នានឹករកអក្ខរៈ ដែលជាច្បាប់ចាស់នោះឯង ប៉ុន្តែមិនអាចនឹងយល់សេចក្តីនៃអក្ខរៈនោះបានឡើយ ។

[ ៥៨ ] ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ លុះផែនដីមានរសរបស់សត្វទាំងនោះសាបសូន្យអស់ទៅហើយ ក្រមរផែនដីក៏កើតប្រាកដឡើង ។ ក្រមរផែនដីនោះកើតប្រាកដឡើងដូចជាផ្សិត ។ ក្រមរផែនដីនោះ បរិបូណ៌ដោយសម្បុរ មានក្លិន ( ក្រអូប ) មានរស ( ឆ្ងាញ់ ) មានពណ៌ដូចជាសប្បិ

សុទ្ធ ឬដូចជានវនីតសុទ្ធ មានរស ( ឆ្ងាញ់ពិសា ) ដូចទឹកឃ្មុំតូច ( ឃ្មុំផ្អិត ) ដែលឥតទោស ( គ្មានកូនឃ្មុំ ) ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ គ្រានោះឯង សត្វទាំងឡាយនោះ ក៏នាំគ្នាបរិភោគក្រមរផែនដី កាលសត្វទាំងនោះនាំគ្នាបរិភោគក្រមរផែនដី យកក្រមរផែនដីនោះជាចំណី យកក្រមរផែនដីនោះជាអាហារ ក៏ឋិតនៅអស់កាលជាយូរអង្វែង ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ កាលពួកសត្វទាំងនោះនាំគ្នាបរិភោគក្រមរផែនដី យកក្រមរផែនដីនោះជាចំណី យកក្រមរផែនដីនោះជាអាហារ ឋិតនៅអស់កាលជាយូរអង្វែងដោយប្រការយ៉ាងណាៗ សេចក្តីរឹងប៉ឹង ក្នុងរាងកាយរបស់សត្វទាំងនោះ ក៏កើតដោយក្រៃលែងលើសប្រមាណ ពណ៌សម្បុរក៏ប្លែកៗ គ្នា ប្រាកដឡើងដោយប្រការយ៉ាងនោះៗ ។ សត្វពួកខ្លះមានសម្បុរល្អ សត្វពួកខ្លះមានសម្បុរអាក្រក់ ។ បណ្តាសត្វទាំងពីរពួកនោះ សត្វពួកណាមានសម្បុរល្អ សត្វពួកនោះរមែងមើលងាយពួកសត្វដែលមានសម្បុរអាក្រក់ថា ពួកយើងមានសម្បុរល្អជាងពួកសត្វនុ៎ះ ពួកសត្វទាំងនោះ មានសម្បុរអាក្រក់ជាងពួកយើង ។ កាលសត្វទាំងឡាយនោះ មានសេចក្តីប្រកាន់ខ្លួន និងការមើលងាយកើតឡើង ព្រោះសេចក្តីមើលងាយនូវសម្បុរគ្នាជាបច្ច័យ ក្រមរផែនដី ក៏សាបសូន្យអស់ទៅ លុះក្រមរផែនដីសាបសូន្យទៅហើយ បទាលតាក៏កើតប្រាកដឡើង ។ បទាលតានោះកើតប្រាកដឡើង ដូចជាវល្លិត្រកួន ។ បទាលតានោះមានសម្បុរល្អ មានក្លិន ( ក្រអូប ) មានរស ( ឆ្ងាញ់ ) វល្លិនោះមានសម្បុរដូចសប្បិសុទ្ធ ឬដូចនវនីតសុទ្ធ មានរស (ឆ្ងាញ់ពិសា) ដូចទឹកឃ្មុំតូច

( ឃ្មុំផ្អិត ) ដែលឥតទោស ( គ្មានកូនឃ្មុំ ) ។ ម្នាលវាសេដ្ឋៈ និង ភារទ្វាជៈ គ្រានោះឯង សត្វទាំងឡាយនោះក៏នាំគ្នាបរិភោគបទាលតា កាល ពួកសត្វទាំងនោះបរិភោគបទាលតា យកវល្លិនោះជាចំណី យកវល្លិនោះជា អាហារ ក៏ឋិតនៅអស់កាលជាយូរអង្វែង ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ កាលសត្វទាំងនោះបរិភោគបទាលតា យកវល្លិនោះជាចំណី យកវល្លិនោះ ជាអាហារ ឋិតនៅអស់កាលជាយូរអង្វែង ដោយប្រការយ៉ាងណាៗ សេចក្តី រឹងប៉ឹងក្នុងរាងកាយរបស់សត្វទាំងនោះ ក៏កើតឡើងដោយក្រៃលែងលើស ប្រមាណ ទាំងពណ៌សម្បុរក៏ប្លែកៗ គ្នា ប្រាកដឡើងដោយប្រការយ៉ាង នោះៗ ។ សត្វពួកខ្លះមានសម្បុរល្អ សត្វពួកខ្លះមានសម្បុរអាក្រក់ ។ បណ្តា សត្វទាំងពីរពួកនោះ ពួកសត្វណាដែលមានសម្បុរល្អ ពួកសត្វនោះ តែង មើលងាយពួកសត្វដែលមានសម្បុរអាក្រក់ថា ពួកយើងមានសម្បុរល្អលើស ជាងពួកសត្វនុ៎ះ ពួកសត្វនោះមានសម្បុរអាក្រក់ជាងពួកយើង ។ កាលសត្វ ទាំងឡាយនោះ មានសេចក្តីប្រកាន់ខ្លួន និងការមើលងាយកើតឡើង ព្រោះ សេចក្តីមើលងាយនូវសម្បុរគ្នាជាបច្ច័យ ឯបទាលតាក៏សាបសូន្យទៅ ។ លុះ បទាលតាសាបសូន្យហើយ សត្វទាំងឡាយក៏មកប្រជុំគ្នា លុះមកប្រជុំគ្នា ហើយ ក៏គ្រូញគ្រូរថា ឱហ្ន៎ បទាលតារបស់យើងធ្លាប់មានហើយ ឱហ្ន៎ បទាលតា របស់យើងបាត់អស់ទៅហើយ ។ ហេតុនោះក៏ដូចគ្នា នឹងមនុស្សទាំងឡាយ ក្នុងកាលឥឡូវនេះដែរ ដែលធម៌ជាទុក្ខណាមួយប៉ះពាល់ ក៏និយាយគ្នាយ៉ាង នេះថា ឱហ្ន៎ យើងធ្លាប់មានឱហ្ន៎ យើងសាបសូន្យអស់ហើយ ។ សត្វទាំង-

ឡាយនាំគ្នានឹករកអក្សរដែលជាច្បាប់ចាស់នោះឯង ប៉ុន្តែមិនអាចនឹងយល់សេចក្តីនៃអក្សរនោះបានឡើយ ។

[ ៥៩ ] ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ គ្រាកាលបទាលតារបស់សត្វទាំងនោះ សាបសូន្យទៅហើយ ស្រូវសាលីកើតឯង ជាស្រូវគ្មានកុណ្ឌក គ្មានអង្កាម សស្អាត មានក្លិនក្រអូប មានផ្លែចេញមកជាអង្ករតែម្តង ក៏កើតប្រាកដឡើង ។ មនុស្សទាំងឡាយនាំយកស្រូវសាលី ត្រង់ទីណាក្នុងវេលាល្ងាច សម្រាប់បរិភោគក្នុងវេលាល្ងាច លុះព្រឹកឡើងទីនោះក៏មានស្រូវសាលីដុះទ្រុបទ្រុល មានផ្លែទុំឡើងវិញ មនុស្សទាំងឡាយនាំយកស្រូវសាលី ត្រង់ទីណាក្នុងវេលាព្រឹក សម្រាប់បរិភោគក្នុងវេលាព្រឹក លុះវេលាល្ងាច ទីនោះក៏មានស្រូវសាលីដុះទ្រុបទ្រុល មានផ្លែទុំឡើងវិញ ទីនោះក៏ប្រាកដហាក់ដូចជាមិនបានច្រូតឡើយ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ គ្រានោះឯង សត្វទាំង-ឡាយក៏បរិភោគស្រូវសាលីកើតឯង យកស្រូវសាលីនោះជាចំណី យកស្រូវសាលីនោះជាអាហារ ក៏ឋិតនៅអស់កាលជាយូរអង្វែង ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ កាលសត្វទាំងនោះនាំគ្នាបរិភោគស្រូវសាលីកើតឯង យកស្រូវសាលីនោះជាចំណី យកស្រូវសាលីនោះជាអាហារ ឋិតនៅអស់កាលជាយូរអង្វែងដោយប្រការយ៉ាងណាៗ សេចក្តីរឹងប៉ឹងក្នុងរាងកាយរបស់សត្វទាំងនោះ ក៏កើតឡើងលើសប្រមាណ ទាំងពណ៌សម្បុរក៏ប្លែកៗ គ្នា ប្រាកដឡើងដោយប្រការយ៉ាងនោះ ។ ភេទស្ត្រី ក៏ប្រាកដឡើងដល់ស្ត្រី ភេទប្រុស ក៏ប្រាកដឡើងដល់ប្រុស ។ បានឮថា ស្ត្រីសម្លឹងមើលប្រុសទាល់តែហួសវេលា

ចំណែកខាងប្រុសក៏សម្លឹងមើលស្ត្រីទាល់តែហួសវេលា ។ កាលសត្វទាំងនោះសម្លឹងមើលគ្នាទៅវិញទៅមកទាល់តែហួសវេលា តម្រេកក៏កើតឡើង សេចក្តីក្តៅក្រហាយព្រោះតម្រេកក៏ប្រជុំចុះក្នុងកាយ ។ សត្វទាំងនោះ ក៏នាំគ្នាសេពមេថុនធម្ម ព្រោះសេចក្តីពេលរាលជាបច្ច័យ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ សម័យនោះ ពួកសត្វណាបានឃើញនូវពួកសត្វដែលកំពុងតែសេពមេថុនធម្ម ពួកសត្វខ្លះក៏យកអាចម៍ដីបោះទៅ សត្វខ្លះយកផេះបាចដាក់ សត្វខ្លះយកអាចម៍គោបោះទៅ និយាយថា នែវសលិ លាញទៅ នែវសលិ លាញទៅ ហងលាញទៅ ។ ចុះហេតុដូចម្តេច បានជាសត្វហ៊ានធ្វើអំពើដល់សត្វយ៉ាងនេះ ។ ហេតុនោះ ក៏ដូចគ្នានឹងពួកមនុស្សក្នុងកាលឥឡូវនេះដែរ កាលបើស្ត្រីក្នុងជនបទនីមួយ មានគេចាប់នាំយកទៅ ពួកខ្លះក៏យកអាចម៍ដីបោះទៅ ពួកខ្លះក៏យកផេះបាចដាក់ ពួកខ្លះក៏យកអាចម៍គោបោះទៅ ។ សត្វទាំងឡាយនាំគ្នានឹករកអក្ខរៈដែលជាច្បាប់ចាស់នោះឯង ប៉ុន្តែមិនអាចនឹងយល់សេចក្តីនៃអក្ខរៈនោះបានឡើយ ។

[ ៦០ ] ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ សម័យនោះឯងអំពើមានការបោះអាចម៍ដីជាដើមនោះ គេសន្មតថា មិនមែនធម៌ តែអំពើនោះក្នុងកាលឥឡូវនេះ គេត្រឡប់សន្មតថា ជាធម៌វិញ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ សម័យនោះ បើពួកសត្វណាសេពមេថុនធម្ម សត្វទាំងនោះមិនហ៊ានចូលមកកាន់ស្រុក ឬនិគម អស់ ៣ ខែក៏មាន ពីរខែក៏មាន ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ កាលណាបើពួកសត្វទាំងនោះ ដល់ស៊ប់នូវភាពជាអ្នកសេពចំពោះ

អសទ្ធម្មនោះហួសវេលាហើយ ក៏នាំគ្នាផ្ដើមធ្វើផ្ទះដើម្បីបិទបាំងអសទ្ធម្មនោះឯង ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ គ្រានោះឯង មានសត្វម្នាក់ប្រកបដោយជាតិ ជាអ្នកខ្ជិលច្រអូស បានគិតយ៉ាងនេះថា យីអើ អាត្មាអញកាលដែលនាំយកស្រូវសាលីក្នុងវេលាល្ងាច សម្រាប់បរិភោគក្នុងវេលាល្ងាច នាំយកស្រូវសាលីក្នុងវេលាព្រឹក សម្រាប់បរិភោគក្នុងវេលាព្រឹក ហៅពេញជាលំបាកខ្លួនអ្វីម្ល៉េះ ណ្ហើយចុះ អាត្មាអញ គួរតែនាំយកស្រូវសាលីក្នុងវេលាល្ងាចតែម្ដងហើយទុកបរិភោគក្នុងវេលព្រឹកផង ។ ម្នាលវាសេដ្ឋៈ និងភារ-ទ្វាជៈ គ្រានោះឯង សត្វនោះក៏ទៅយកស្រូវសាលី ក្នុងវេលាល្ងាចតែម្ដងប៉ុណ្ណោះ សម្រាប់បរិភោគក្នុងវេលាព្រឹកផង ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ គ្រានោះឯង មានសត្វម្នាក់ចូលទៅរកសត្វនោះ លុះចូលទៅដល់ហើយ បាននិយាយបបួលសត្វនោះដូច្នេះថា នែសត្វដ៏ចម្រើន អ្នកចូលមក យើងនឹងទៅនាំយកស្រូវសាលីជាអាហារ ។ សត្វនោះឆ្លើយតបថា នែសត្វដ៏ម្រើនណ្ហើយកុំ ខ្ញុំបាននាំយកស្រូវសាលីក្នុងវេលាល្ងាចតែម្ដង ហើយទុកបរិភោគក្នុងវេលាព្រឹកផង ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ទើបសត្វនោះ បានយកតម្រាប់តាមសត្វនោះ ក៏ទៅនាំយកស្រូវសាលី មកដោយគិតថា យីអើ ការដែលនាំយកស្រូវសាលីមកតែម្ដងប៉ុណ្ណោះ សម្រាប់បរិភោគបានពីរថ្ងៃយ៉ាងនេះ ជាការស្រួលមែន ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ គ្រានោះឯង មានសត្វម្នាក់ទៀត ចូលទៅរកសត្វនោះ លុះចូលទៅដល់ហើយ បាននិយាយបបួលសត្វនោះដូច្នេះថា នែសត្វដ៏ចម្រើន អ្នកចូរមក យើងនឹងទៅនាំយក

ស្រូវសាលីជាអាហារ ។ សត្វនោះឆ្លើយតបថា នែសត្វដ៏ចម្រើន ណ្ហើយកុំ ខ្ញុំបាននាំយកស្រូវសាលីក្នុងវេលាល្ងាចតែម្តង ហើយទុកបរិភោគវេលាព្រឹកផង ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ទើបសត្វនោះយកតម្រាប់តាមសត្វនោះ ក៏នាំយកស្រូវសាលីមកដោយគិតថា យីអើ ការដែលនាំយកស្រូវសាលីមកតែម្តងប៉ុណ្ណោះ សម្រាប់បរិភោគបានបួនថ្ងៃយ៉ាងនេះ ជាការស្រួលមែន ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ គ្រានោះឯង មានសត្វម្នាក់ទៀតចូលទៅរកសត្វនោះ លុះចូលទៅដល់ហើយ បាននិយាយបបួលសត្វនោះដូច្នេះថា ម្នាលសត្វដ៏ចម្រើន អ្នកចូរមក យើងនឹងទៅនាំយកស្រូវសាលីជាអាហារ ។ សត្វនោះឆ្លើយតបថា ម្នាលសត្វដ៏ចម្រើន ណ្ហើយកុំ ខ្ញុំបាននាំយកស្រូវសាលីមកតែម្តង ហើយទុកបរិភោគបានបួនថ្ងៃ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ទើបសត្វនោះយកតម្រាប់តាមសត្វនោះ ក៏នាំយកស្រូវសាលីមកដោយគិតថា យីអើ ការដែលនាំយកស្រូវសាលីមកតែម្តងប៉ុណ្ណោះ ទុកសម្រាប់បរិភោគបាន ៨ ថ្ងៃយ៉ាងនេះ ជាការស្រួលមែន ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ លុះពួកសត្វទាំងនោះ បាននាំគ្នាផ្តើមបរិភោគនូវស្រូវសាលី ដែលខ្លួនសន្សំទុកក្នុងកាលណាហើយ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ កាលនោះឯង កុណ្ឌកក៏រុំព័ទ្ធអង្ករ ទាំងអង្កាមក៏រុំព័ទ្ធអង្ករ សូម្បីកន្លែងដែលគេច្រូតហើយក៏លែងដុះឡើងវិញ ប្រាកដជាមិនពេញដូចដើម ស្រូវសាលីទាំងឡាយក៏ដុះមួយគុម្ពៗ ( ហាក់ដូចជាគេចងជាបាច់ ) ។

[ ៦១ ] ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ គ្រានោះឯង ពួកសត្វទាំងនោះ

មកប្រជុំគ្នា លុះមកប្រជុំគ្នាហើយ ត្អូញត្អែរថា ម្នាលអ្នកទាំងឡាយដ៏ចម្រើន ឱហ្ន៎ ធម៌ដ៏លាមកទាំងឡាយ បានកើតប្រាកដក្នុងពួកសត្វហើយ ព្រោះកាលពីដើម ពួកយើងជាអ្នកកើតដោយឈានចិត្ត មានបីតិជាអាហារ មានពន្លឺភ្លឺចេញឯងអំពីកាយ ត្រាច់ទៅក្នុងអាកាសបាន ឋិតនៅក្នុងទីដ៏ល្អ បានឋិតនៅអស់កាលជាយូរអង្វែង លុះកាលកន្លងជាយូរអង្វែងទៅ ផែនដីមានរសក៏អណ្តែតជាសលើទឹក ដើម្បីពួកយើងទាំងនោះ ឯផែនដីនោះមានសម្បុរ ( ល្អ ) មានក្លិន ( ក្រអូប ) មានរស ( ផ្អែម ) ពួកយើងទាំងនោះបាននាំគ្នាយកដៃកកាយផែនដីដែលមានរសមកធ្វើជាពំនូត ហើយបរិភោគ កាលពួកយើងទាំងនោះ នាំគ្នាយកដៃកកាយផែនដីដែលមានរសធ្វើជាពំនូត ហើយបរិភោគពន្លឺ ដែលភ្លឺចេញឯង ( អំពីកាយ ) ក៏សាបសូន្យទៅ លុះពន្លឺដែលភ្លឺចេញឯង សាបសូន្យទៅហើយ ព្រះចន្ទ្រ និងព្រះអាទិត្យក៏កើតប្រាកដឡើង លុះព្រះចន្ទ្រ និងព្រះអាទិត្យកើតប្រាកដឡើងហើយ នក្ខត្តឫក្សដែលមានរូបជាផ្កាយទាំងឡាយក៏កើតប្រាកដឡើង លុះនក្ខត្តឫក្សដែលមានរូបជាផ្កាយទាំងឡាយកើតប្រាកដឡើងហើយ យប់ និងថ្ងៃក៏កើតប្រាកដឡើង លុះយប់ និងថ្ងៃកើតប្រាកដឡើងហើយ ខែ ១ និងកន្លះខែ ក៏កើតប្រាកដឡើង លុះខែ១ និងកន្លះខែកើតប្រាកដឡើងហើយ រដូវ និងឆ្នាំក៏កើតប្រាកដឡើង កាលពួកយើងទាំងនោះ បរិភោគផែនដីមានរស យកផែនដីនោះជាចំណី យកផែនដីនោះជាអាហារ ក៏ឋិតនៅអស់កាលជាយូរអង្វែង ស្រាប់តែផែនដីមានរសសាបសូន្យទៅ ព្រោះហេតុនៃធម៌ទាំងឡាយជាអកុសលដ៏លាមក

កើតប្រាកដដល់យើងទាំងឡាយនោះ លុះផែនដីមានរសសាបសូន្យហើយ ក្រមរផែនដីក៏កើតប្រាកដឡើង ឯក្រមរផែនដីនោះមានសម្បុរ ( ល្អ ) មានក្លិន ( ក្រអូប ) មានរស ( ផ្អែម ) ពួកយើងទាំងនោះ ក៏នាំគ្នាផ្តើមបរិភោគក្រមរផែនដី កាលពួកយើងទាំងនោះបរិភោគក្រមរផែនដីនោះ យកក្រមរផែនដីនោះជាចំណី យកក្រមរផែនដីនោះជាអាហារ ក៏ឋិតនៅអស់កាលជាយូរអង្វែង ស្រាប់តែក្រមរផែនដីនោះសាបសូន្យទៅ ព្រោះហេតុនៃធម៌ទាំងឡាយជាអកុសលដ៏លាមកកើតប្រាកដដល់យើងទាំងឡាយនោះ លុះក្រមរផែនដីសាបសូន្យហើយ បទាលតាក៏កើតប្រាកដឡើង ឯបទាលតានោះមានសម្បុរ( ល្អ ) មានក្លិន( ក្រអូប ) មានរស( ផ្អែម ) ពួកយើងទាំងនោះក៏នាំគ្នាផ្តើមបរិភោគបទាលតា កាលពួកយើងទាំងនោះ បរិភោគបទាលតានោះ យកបទាលតានោះជាចំណី យកបទាលតានោះជាអាហារ ក៏ឋិតនៅអស់កាលជាយូរអង្វែង ស្រាប់តែបទាលតានោះសាបសូន្យទៅ ព្រោះហេតុនៃធម៌ទាំងឡាយ ជាអកុសលដ៏លាមកកើតប្រាកដឡើង ដល់យើងទាំង-ឡាយនោះ បទាលតាសាបសូន្យហើយ ទើបស្រូវសាលីកើតឯង មិនមានកុណ្ឌក មិនមានអង្កាម ជាស្រូវសស្អាត មានក្លិនក្រអូប មានផ្លែចេញមកជាអង្ករ ក៏កើតប្រាកដឡើង ពួកយើងនាំយកស្រូវសាលីត្រង់ទីណាក្នុងវេលាល្ងាច សម្រាប់បរិភោគក្នុងវេលាល្ងាច លុះព្រឹកឡើងទីនោះ ក៏មានស្រូវសាលីដុះទ្រុបទ្រុល មានផ្លែទុំឡើងវិញ ពួកយើងនាំយកស្រូវសាលីត្រង់ទីណាមក ក្នុងវេលាព្រឹក សម្រាប់បរិភោគក្នុងវេលាព្រឹក លុះវេលាល្ងាច ទី

នោះក៏មានស្រូវសាលីដុះទ្រុបទ្រុល មានផ្លែទុំឡើងវិញ ទីនោះក៏ប្រាកដជាហាក់ដូចជាមិនបានប្រូតឡើយ កាលពួកយើងទាំងនោះបរិភោគស្រូវសាលីកើតឯងយកស្រូវសាលីនោះជាចំណី យកស្រូវសាលីនោះជាអាហារ ក៏ឋិតនៅអស់កាលជាយូរអង្វែង ស្រាប់តែកុណ្ឌកុំព័ទ្ធអង្ករ ទាំងអង្កាមក៏រុំព័ទ្ធអង្ករ សូម្បីទីដែលប្រូតក៏មិនដុះឡើងវិញប្រាកដពេញដូចដើម ស្រូវសាលីទាំងឡាយក៏ដុះមួយគុម្ពៗ ( ហាក់ដូចជាគេចងជាបាច់ ) ព្រោះហេតុនៃធម៌ទាំងឡាយជាអកុសលដ៏លាមក កើតប្រាកដដល់យើងទាំងឡាយនោះ បើដូច្នោះ គួរតែយើងចែកស្រូវសាលីគ្នា គួរតែបោះព្រំខណ្ឌ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ លំដាប់នោះឯង សត្វទាំងឡាយក៏នាំគ្នាចែកស្រូវសាលី បោះព្រំខណ្ឌដោយខ្លួនៗ ។

[ ៦២ ] ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ គ្រានោះមានសត្វម្នាក់ ជាតិជាអ្នកឡេះឡោះ លាក់សំចៃចំណែករបស់ខ្លួនទុក លួចយកចំណែករបស់អ្នកដទៃ ដែលគេមិនបានឲ្យមកបរិភោគ ។ សត្វទាំងឡាយក៏បានចាប់សត្វនោះលុះចាប់បានហើយក៏ស្តីឲ្យដូច្នេះថា ឱសត្វអើយ ឯងធ្វើអំពើអាក្រក់ណាស់មិនគួរបើឯងលាក់សំចៃចំណែករបស់ខ្លួនទុក លួចយកចំណែករបស់អ្នកដទៃដែលគេមិនបានឲ្យមកបរិភោគសោះ នែសត្វអើយ ឯងកុំធ្វើអំពើបែបនេះទៀតឡើយ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ សត្វនោះបានទទួលតបពាក្យរបស់ពួកសត្វទាំងនោះថា អើអ្នកដ៏ចម្រើន ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ សត្វនោះ ( លួចយកចំណែករបស់អ្នកដទៃ ) ជាគម្រប់ពីរដងផង ។បេ។ ម្នាល

វាសេដ្ឋៈ និងភារទ្វាជៈ សត្វនោះបានលាក់សំចៃចំណែករបស់ខ្លួនទុក លួចយកចំណែករបស់អ្នកដទៃ ដែលគេមិនបានឲ្យមកបរិភោគជាគម្រប់ ៣ ដងផង ។ សត្វទាំងឡាយក៏បានចាប់សត្វនោះ លុះចាប់បានហើយ ក៏ស្តីឲ្យដូច្នេះថា ឱ សត្វអើយ ឯងធ្វើអំពើអាក្រក់ណាស់ មិនគួរបើឯងលាក់សំចៃរបស់ខ្លួនទុក លួចយកចំណែករបស់អ្នកដទៃ ដែលគេមិនបានឲ្យមកបរិភោគសោះ នែសត្វអើយ ឯងកុំធ្វើអំពើបែបនេះទៀតឡើយ ។ ពួកសត្វខ្លះតប់ទះ ( សត្វនោះ ) នឹងដៃ ពួកសត្វខ្លះចោលនឹងដុំដី ពួកសត្វខ្លះវាយនឹងដំបង ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ការលួចទ្រព្យគេក៏ប្រាកដឡើង ការតិះដៀលក៏ប្រាកដឡើង ការនិយាយកុហកក៏ប្រាកដឡើង ការដាក់អាជ្ញាក៏ប្រាកដឡើងតាំងពីកាលនោះជាដើមមក ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ គ្រានោះឯងពួកសត្វទាំងនោះមកប្រជុំគ្នា លុះប្រជុំគ្នាហើយក៏ត្អូញត្អែរថា យីអើហ្ន៎ ធម៌ដ៏លាមកទាំងឡាយកើតប្រាកដដល់សត្វទាំងឡាយហើយ ព្រោះថា ការលួចទ្រព្យគេក៏កើតប្រាកដឡើង ការតិះដៀលក៏កើតប្រាកដឡើង ការនិយាយកុហកក៏កើតប្រាកដឡើង ការដាក់អាជ្ញាក៏កើតប្រាកដឡើង បើដូច្នោះ គួរតែពួកយើងសន្មតសត្វណាម្នាក់ ឲ្យជាអ្នកបន្ទោសសត្វដែលយើងគួរបន្ទោសតាមហេតុ ឲ្យតិះដៀលសត្វ ដែលយើងគួរតិះដៀលតាមហេតុ ឲ្យបណ្តេញសត្វដែលយើងគួរបណ្តេញតាមហេតុ ចំណែកខាងពួកយើងត្រូវជូនចំណែកស្រូវសាលីទាំងឡាយឲ្យដល់សត្វនោះ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ទើបពួកសត្វទាំងនោះ នាំគ្នាចូលទៅរកសត្វ ដែលជាអ្នកមានរូបល្អគួររមិលមើល

គួរជ្រះថ្លា មានសក្តិធំជាងពួកសត្វទាំងនោះ លុះចូលទៅដល់ហើយ បាន និយាយដូច្នេះថា បពិត្រសត្វដ៏ចម្រើន អ្នកចូរមកបន្ទោសសត្វដែលគួរបន្ទោស តាមហេតុ ចូរតិះដៀលសត្វ ដែលគួរតិះដៀលតាមហេតុ ចូរបណ្តេញសត្វ ដែលគួរបណ្តេញតាមហេតុចុះ សឹមពួកយើងនឹងជូនចំណែកស្រូវសាលីទាំង-ឡាយដល់អ្នក ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ សត្វនោះបានទទួលតបពាក្យ របស់សត្វទាំងនោះថា អើអ្នកដ៏ចម្រើនទាំងឡាយ ហើយក៏បន្ទោសសត្វដែល គួរបន្ទោសតាមហេតុ តិះដៀលសត្វ ដែលគួរតិះដៀលតាមហេតុ បណ្តេញ សត្វដែលគួរបណ្តេញតាមហេតុ ។ ពួកសត្វទាំងនោះ ក៏បានជូនចំណែកស្រូវ សាលីទាំងឡាយដល់សត្វនោះ ។

[ ៦៣ ] ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ សត្វនោះមហាជនសន្មតហើយ ព្រោះហេតុនោះឯង ទើបអក្ខរៈជាដំបូងក៏កើតឡើងថា មហាសន្មត ដូច្នេះ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ សត្វនោះជាអធិបតីនៃស្រែទាំងឡាយ ព្រោះ ហេតុនោះឯង ទើបអក្ខរៈទី ២ ក៏កើតឡើងថា ខត្តិយៈ ខត្តិយៈ ដូច្នេះ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ សត្វនោះញុំាងសត្វទាំងឡាយដទៃឲ្យពេញចិត្ត ដោយធម៌ ព្រោះហេតុនោះឯង ទើបអក្ខរៈទី ៣ ក៏កើតឡើងថា រាជា រាជា ដូច្នេះ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ហេតុដូច្នោះ អក្ខរៈដែលជាច្បាប់ ចាស់បានកើតឡើងដល់ខត្តិយមណ្ឌលនោះយ៉ាងនេះឯង ។ ការកើតឡើងនៃ អក្ខរៈដល់ពួកសត្វទាំងនោះឯង ដូចគ្នានឹងសត្វទាំងឡាយដទៃដែរ មិនមែន ខុសគ្នាទេ កើតឡើងតែដោយធម៌ប៉ុណ្ណោះឯង មិនមែនដោយអធម៌ទេ ។

ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ព្រោះថា ធម៌ជាគុណដ៏ប្រសើរបំផុតក្នុងប្រជុំជនទាំងបច្ចុប្បន្ន និងបរលោក ។

[ ៦៤ ] គ្រានោះឯង បណ្ដាសត្វទាំងឡាយនោះ សត្វពួកខ្លះបានគិតគ្នាយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ធម៌ដ៏លាមកទាំងឡាយ កើតប្រាកដដល់ពួកសត្វហើយ ព្រោះថា ការលួចទ្រព្យគេ ក៏ប្រាកដឡើង ពាក្យតិះដៀលក៏ប្រាកដឡើង ការនិយាយកុហកក៏ប្រាកដឡើង ការដាក់អាជ្ញាក៏ប្រាកដឡើង ការបណ្ដេញក៏ប្រាកដឡើង បើដូច្នោះ ពួកយើងគួរតែបន្សាត់នូវធម៌ជាអកុសលដ៏លាមកទាំងឡាយចេញ ។ សត្វទាំងនោះ ក៏បានបន្សាត់នូវធម៌ជាអកុសលដ៏លាមកចេញ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ សត្វទាំងឡាយនោះបន្សាត់នូវធម៌ជាអកុសលដ៏លាមក ព្រោះហេតុនោះឯង ទើបអក្ខរៈទី ១ ក៏កើតឡើងថា ព្រាហ្មណៈ ព្រាហ្មណៈ ដូច្នេះ ។ សត្វទាំងឡាយនោះ បានធ្វើជំរំស្លឹកក្នុងព្រៃរំលោង ហើយសម្ងំអារម្មណ៍ក្នុងជំរំប្រក់ស្លឹកទាំងឡាយ ។ ពួកសត្វទាំងនោះមិនមានភ្លើង មិនមានផ្សែង មិនមានអង្រែ ត្រាច់ទៅកាន់ស្រុកនិគម និងរាជធានី ស្វែងរកអាហារក្នុងវេលាល្ងាច សម្រាប់បរិភោគក្នុងវេលាល្ងាច ស្វែងរកក្នុងវេលាព្រឹក សម្រាប់បរិភោគក្នុងវេលាព្រឹក ។ ពួកសត្វទាំងនោះ លុះបានអាហារហើយ ក៏នៅសម្ងំអារម្មណ៍ ក្នុងជំរំស្លឹកទាំង-ឡាយ ក្នុងព្រៃរំលោងទៀត ។ មនុស្សទាំងឡាយ លុះឃើញសត្វទាំងនោះហើយ ក៏និយាយយ៉ាងនេះថា នែគ្នាយើងអើយ ពួកសត្វទាំងនេះឯង ធ្វើជំរំស្លឹកទាំងឡាយ ក្នុងព្រៃរំលោង ហើយនៅសម្ងំអារម្មណ៍ក្នុងជំរំស្លឹកទាំង-

ឡាយ ជាសត្វមិនមានភ្លើង មិនមានផ្សែង មិនមានអង្រែ តែងត្រាច់ទៅកាន់ស្រុក និគម និងរាជធានី ស្វែងរកអាហារក្នុងវេលាល្ងាច សម្រាប់បរិភោគក្នុងវេលាល្ងាច ស្វែងរកក្នុងវេលាព្រឹក សម្រាប់បរិភោគក្នុងវេលាព្រឹក ។ ពួកសត្វទាំងនោះ លុះបានអាហារហើយ ក៏សម្ងំងអារម្មណ៍ក្នុងជំរំស្លឹក ក្នុងព្រៃរំលោងទៀត ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ពួកសត្វទាំងនោះឯង តែងសម្ងំងអារម្មណ៍ ព្រោះហេតុនោះឯង ទើបអក្ខរៈទី ២ ក៏កើតឡើងថា ឈាយិកា ឈាយិកា ( អ្នកសម្ងំងអារម្មណ៍ ) ។ ម្នាលវាសេដ្ឋៈ និងភារ-ទ្វាជៈ បណ្តាសត្វទាំងនោះឯង សត្វពួកខ្លះកាលមិនអាចនឹងសម្ងំងអារម្មណ៍ក្នុងជំរំស្លឹកទាំងឡាយ ក្នុងព្រៃរំលោងបាន ក៏ចូលទៅកាន់ស្រុកជិត និគមជិត គាក់តែងបង្រៀននូវគន្ថៈ ( គឺវេទមន្ត ) រួចត្រឡប់មកវិញ ។ មនុស្សទាំងឡាយ លុះបានឃើញសត្វទាំងនោះហើយ និយាយគ្នាយ៉ាងនេះថា ម្នាលគ្នាយើងអើយ ពួកសត្វទាំងនេះឯង មិនអាចនឹងសម្ងំងអារម្មណ៍ក្នុងជំរំស្លឹកទាំងឡាយ ក្នុងព្រៃរំលោងបាន ក៏ចូលមកកាន់ស្រុកជិត និគមជិត គាក់តែងបង្រៀននូវគន្ថៈ រួចត្រឡប់ទៅវិញ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ សត្វទាំងនេះរមែងមិនសម្ងំងអារម្មណ៍ ក្នុងកាលឥឡូវនេះ សត្វទាំងនេះរមែងមិនសម្ងំងអារម្មណ៍ក្នុងកាលឥឡូវនេះ ព្រោះហេតុនោះឯង ទើបអក្ខរៈទី ៣ ក៏កើតឡើងថា អជ្ឈាយិកា អជ្ឈាយិកា (អ្នកមិនសម្ងំងអារម្មណ៍ ) ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈក្នុងសម័យនោះ ការទ្រទ្រង់ និងការបង្រៀននូវមន្ត គេសន្មតថាជាការថោកទាបទេ តែក្នុងកាលឥឡូវនេះ ការទ្រទ្រង់ និងការបង្រៀននូវ

មន្តនោះ គេសន្មតថា ជាការប្រសើរវិញ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ហេតុដូច្នោះឯង អក្ខរៈដែលជាច្បាប់ចាស់ បានកើតឡើងដល់ព្រាហ្មណ- មណ្ឌលនោះយ៉ាងនេះ ។ ការកើតនៃអក្ខរៈដល់ពួកសត្វទាំងនោះឯង ដូចគ្នានឹងសត្វទាំងឡាយដទៃដែរ មិនមែនខុសគ្នាទេ កើតឡើងដោយធម៌តែម្យ៉ាងប៉ុណ្ណោះឯង មិនមែនដោយអធម៌ទេ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ព្រោះថា ធម៌ជាគុណដ៏ប្រសើរបំផុត ក្នុងប្រជុំជន ទាំងបច្ចុប្បន្ន និងបរលោក ។

[ ៦៥ ] ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ បណ្តាសត្វទាំងនោះឯង សត្វពួកខ្លះ ប្រព្រឹត្តកាន់នូវមេថុនធម្ម ហើយប្រកបការងារផ្សេងៗ គ្នា ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ សត្វទាំងឡាយប្រព្រឹត្តកាន់នូវមេថុនធម្មហើយ ប្រកបការងារផ្សេងគ្នា ព្រោះហេតុនោះឯង ទើបអក្ខរៈក៏កើតថា វេស្សៈ វេស្សៈ ដូច្នេះ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ( ការកើតឡើងនៃអក្ខរៈដែលជាច្បាប់ចាស់ក៏មានឡើង ) ដល់វេស្សមណ្ឌលនុ៎ះយ៉ាងនេះ ដោយហេតុនេះឯង ។ សេចក្តីបង្រួញ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ហេតុដូច្នោះឯង អក្ខរៈដែលជាច្បាប់ចាស់ បានកើតឡើងដល់សុទ្ទមណ្ឌលនុ៎ះយ៉ាងនេះឯង ការកើតឡើងនៃអក្ខរៈដល់ពួកសត្វទាំងនោះឯង ដូចគ្នានឹងសត្វទាំងឡាយដទៃដែរ មិនមែនខុសគ្នាទេ កើតឡើងដោយធម៌តែប៉ុណ្ណោះឯង មិនមែនដោយអធម៌ទេ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ព្រោះថា ធម៌ជាគុណដ៏ប្រសើរបំផុត ក្នុងប្រជុំជនទាំងបច្ចុប្បន្ន និងបរលោក ។

[ ៦៦ ] ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានសម័យដែលខត្តិយៈខ្លះ

តិះដៀលធម៌របស់ខ្លួន ហើយចេញចាកផ្ទះចូលមកបួស ដោយបំណងថា អាត្មាអញនឹងធ្វើជាសមណៈដូច្នេះក៏មាន ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ព្រាហ្មណ៍ខ្លះ ។បេ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ វេស្សៈខ្លះ ។បេ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ សុទ្ទៈខ្លះ តិះដៀលធម៌របស់ខ្លួន ចេញចាកផ្ទះ ចូលទៅបួស ដោយបំណងថា អាត្មានឹងធ្វើជាសមណៈដូច្នេះក៏មាន ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ការកើតឡើងនៃសមណមណ្ឌល ក៏បានមានឡើងដោយសារមណ្ឌលទាំង ៤ នេះឯង ការកើតឡើងនៃសមណមណ្ឌល ដល់សត្វទាំងនោះឯង ដូចគ្នានឹងសត្វទាំងឡាយដទៃដែរ មិនមែនខុសគ្នាទេ កើតឡើងដោយធម៌តែប៉ុណ្ណោះឯង មិនមែនដោយខុសធម៌ទេ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ព្រោះថា ធម៌ជាគុណដ៏ប្រសើរបំផុត ក្នុងប្រជុំជនទាំងបច្ចុប្បន្ន និងបរលោក ។

[ ៦៧ ] ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានខត្តិយៈខ្លះប្រព្រឹត្តអាក្រក់ដោយកាយ ប្រព្រឹត្តអាក្រក់ដោយវាចា ប្រព្រឹត្តអាក្រក់ដោយចិត្ត ជាមិច្ឆាទិដ្ឋិ ប្រកាន់នូវកម្មជាមិច្ឆាទិដ្ឋិ ព្រោះហេតុតែប្រកាន់នូវកម្មជាមិច្ឆាទិដ្ឋិនោះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ ក៏ទៅកើតក្នុងកំណើតសត្វតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានព្រាហ្មណ៍ខ្លះ ។បេ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានវេស្សៈខ្លះ ។បេ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានសុទ្ទៈខ្លះ ។បេ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានសមណៈខ្លះ ប្រព្រឹត្តអាក្រក់ដោយកាយ ប្រព្រឹត្តអាក្រក់ដោយវាចា ប្រព្រឹត្តអាក្រក់

ដោយចិត្ត ជាមិច្ឆាទិដ្ឋិ ប្រកាន់នូវកម្មជាមិច្ឆាទិដ្ឋិ ព្រោះហេតុតែប្រកាន់នូវកម្មជាមិច្ឆាទិដ្ឋិនោះ លុះបែកធ្លាយរាងកាយ បន្ទាប់ពីសេចក្ដីស្លាប់ ក៏ទៅកើតក្នុងកំណើតសត្វតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ។

[ ៦៨ ] ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានខត្តិយៈខ្លះ ប្រព្រឹត្តល្អដោយកាយ ប្រព្រឹត្តល្អដោយវាចា ប្រព្រឹត្តល្អដោយចិត្តជាសម្មាទិដ្ឋិ ប្រកាន់នូវកម្មជាសម្មាទិដ្ឋិ ព្រោះហេតុតែប្រកាន់នូវកម្មជាសម្មាទិដ្ឋិនោះ លុះបែកធ្លាយរាងកាយបន្ទាប់អំពីសេចក្ដីស្លាប់ ក៏ទៅកើតក្នុងសុគតិសួគ៌ ទេវលោក ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានព្រាហ្មណ៍ខ្លះ ។បេ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មាន វេស្សៈខ្លះ ។បេ។ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានសុទ្ទៈខ្លះ ។បេ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានសមណៈខ្លះ ប្រព្រឹត្តល្អដោយកាយ ប្រព្រឹត្តល្អដោយវាចា ប្រព្រឹត្តល្អដោយចិត្ត ជាសម្មាទិដ្ឋិ ប្រកាន់នូវកម្មជាសម្មាទិដ្ឋិ ព្រោះហេតុតែប្រកាន់នូវកម្មជាសម្មាទិដ្ឋិនោះ លុះបែកធ្លាយរាងកាយបន្ទាប់អំពីសេចក្ដីស្លាប់ ក៏ទៅកើតក្នុងសុគតិសួគ៌ ទេវលោក ។

[ ៦៩ ] ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានខត្តិយៈខ្លះ ជាអ្នកធ្វើអំពើទាំងពីរ គឺជួនកាលធ្វើអំពើអាក្រក់ ជួនកាលធ្វើអំពើល្អដោយកាយ ធ្វើអំពើទាំងពីរដោយវាចា ធ្វើអំពើទាំងពីរដោយចិត្ត មានទិដ្ឋិច្រឡំគ្នាផ្សេងៗ ប្រកាន់នូវកម្មដែលច្រឡំគ្នាផ្សេងៗ ព្រោះហេតុតែប្រកាន់នូវកម្មដែលច្រឡំគ្នាផ្សេងៗនោះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ ក៏បានទទួលសុខខ្លះទុក្ខខ្លះ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានព្រាហ្មណ៍ខ្លះ ជាអ្នកធ្វើអំពើទាំង

ពីរដោយកាយ ធ្វើអំពើទាំងពីរដោយវាចា ធ្វើអំពើទាំងពីរដោយចិត្ត មានទិដ្ឋិប្រឡំគ្នាផ្សេងៗ ប្រកាន់នូវកម្មដែលប្រឡំគ្នាផ្សេងៗ ព្រោះហេតុតែប្រកាន់នូវកម្មដែលប្រឡំគ្នាផ្សេងៗ នោះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ ក៏បានទទួលសុខខ្លះ ទុក្ខខ្លះ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានវេស្សៈខ្លះ ជាអ្នកធ្វើអំពើទាំងពីរដោយកាយ ធ្វើអំពើទាំងពីរដោយវាចា ធ្វើអំពើទាំងពីរដោយចិត្ត មានទិដ្ឋិប្រឡំគ្នាផ្សេងៗ ប្រកាន់នូវកម្មដែលប្រឡំគ្នាផ្សេងៗ ព្រោះហេតុតែប្រកាន់នូវកម្មដែលប្រឡំគ្នាផ្សេងៗ នោះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ ក៏បានទទួលសុខខ្លះ ទុក្ខខ្លះ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានសុទ្ទៈខ្លះ ជាអ្នកធ្វើអំពើទាំងពីរដោយកាយ ធ្វើអំពើទាំងពីរដោយវាចា ធ្វើអំពើទាំងពីរដោយចិត្ត មានទិដ្ឋិប្រឡំគ្នាផ្សេងៗ ប្រកាន់នូវកម្មដែលប្រឡំគ្នាផ្សេងៗ ព្រោះហេតុតែប្រកាន់នូវកម្មដែលប្រឡំគ្នាផ្សេងៗ នោះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ ក៏បានទទួលនូវសេចក្តីសុខខ្លះ ទុក្ខខ្លះ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានសមណៈខ្លះ ជាអ្នកធ្វើអំពើទាំងពីរដោយកាយ ធ្វើអំពើទាំងពីរដោយវាចា ធ្វើអំពើទាំងពីរដោយចិត្ត មានទិដ្ឋិប្រឡំគ្នាផ្សេងៗ ប្រកាន់នូវកម្មដែលប្រឡំគ្នាផ្សេងៗ ព្រោះហេតុតែប្រកាន់នូវកម្មដែលប្រឡំគ្នាផ្សេងៗ នោះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ ក៏បានទទួលសុខខ្លះ ទុក្ខខ្លះ ។

[ ៧០ ] ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានខត្តិយៈខ្លះ ជាអ្នកសង្រួមដោយកាយ សង្រួមដោយវាចា សង្រួមដោយចិត្ត អាស្រ័យនូវការចម្រើន

ពោធិបក្ខិយធម៌ ៧ កង ក៏បរិនិព្វានក្នុងបច្ចុប្បន្ននេះឯង ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានព្រាហ្មណ៍ខ្លះ ជាអ្នកសង្រួមដោយកាយ សង្រួមដោយវាចា សង្រួមដោយចិត្ត អាស្រ័យនូវការចម្រើនពោធិបក្ខិយធម៌ ៧ កង ក៏បរិនិព្វាន ក្នុងបច្ចុប្បន្ននេះឯង ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានវេស្សៈខ្លះ ជាអ្នកសង្រួមដោយកាយ សង្រួមដោយវាចា សង្រួមដោយចិត្ត អាស្រ័យនូវការចម្រើនពោធិបក្ខិយធម៌ ៧ កង ក៏បរិនិព្វានក្នុងបច្ចុប្បន្ននេះឯង ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ មានសុទ្ទៈខ្លះ ជាអ្នកសង្រួមដោយកាយ សង្រួមដោយវាចា សង្រួមដោយចិត្ត អាស្រ័យនូវការចម្រើនពោធិបក្ខិយធម៌ ៧ កង ក៏បរិនិព្វានក្នុងបច្ចុប្បន្ននេះឯង ។

[ ៧១ ] ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ក៏បណ្តាវណ្ណៈទាំង ៤ នេះ វណ្ណៈណាជាភិក្ខុ ជាអរហន្ត ជាខីណាស្រព ប្រព្រឹត្តព្រហ្មចារ្យរួចស្រេចហើយ បានធ្វើសោឡសកិច្ចស្រេចហើយ មានភារៈដាក់ចុះហើយ បានសម្រេចប្រយោជន៍របស់ខ្លួនដោយលំដាប់ហើយ មានតណ្ហាជាគ្រឿងចងក្នុងភព អស់រលីងហើយ មានចិត្តផុតស្រឡះហើយ ព្រោះបានត្រាស់ដឹងដោយប្រពៃ អ្នកនោះប្រាកដថា ជាបុគ្គលប្រសើរលើសជាងវណ្ណៈទាំង ៤ នោះតាមធម៌ពិត មិនមែនមិនដោយធម៌ទេ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ព្រោះថាធម៌ជាគុណដ៏ប្រសើរបំផុត ក្នុងប្រជុំជនទាំងបច្ចុប្បន្ននិងបរលោក ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ សូម្បីព្រហ្មឈ្មោះសនង្កុមារ ក៏បានពោលគាថាទុកថា

[ ៧២ ] ខត្តិយៈ ជាជាតិប្រសើរបំផុត ក្នុងប្រជុំជន ដែល

ជាអ្នករឭកដល់គោត្រ អ្នកដែលបរិបូណ៌ដោយវិជ្ជា និង
ចរណៈ ប្រសើរបំផុតក្នុងពួកទេវតា និងមនុស្ស ។

ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ឯគាថានេះឯង ព្រហ្មឈ្មោះសនង្កុមារ បានពោលពីរោះហើយ មិនមែនពោលមិនពីរោះទេ បានសម្តែងល្អហើយ មិនមែនសម្តែងមិនល្អទេ ជាគាថាប្រកបដោយប្រយោជន៍ មិនមែនជាមិនប្រកបដោយប្រយោជន៍ឡើយ តថាគតក៏យល់ព្រមតាមដែរ ។ ម្នាលវាសេដ្ឋៈ និងភារទ្វាជៈ ចំណែកខាងតថាគត ក៏បានពោលយ៉ាងនេះថា

ខត្តិយៈ ជាជាតិប្រសើរបំផុត ក្នុងប្រជុំជន ដែលជាអ្នក
រឭកដល់គោត្រ ដែលជាអ្នកបរិបូណ៌ដោយវិជ្ជា និងចរណៈ
ប្រសើរបំផុតក្នុងពួកទេវតា និងមនុស្ស ។

លុះព្រះមានព្រះភាគទ្រង់ត្រាស់ព្រះសូត្រនេះ ចប់ហើយ ។ វាសេដ្ឋសាមណេរ និងភារទ្វាជសាមណេរ ក៏មានចិត្តត្រេកអររីករាយចំពោះភាសិតរបស់ព្រះមានព្រះភាគ ដោយប្រការដូច្នេះឯង ។

## អគ្គញ្ញសូត្រទី ៤ ចប់

# អដ្ឋកថា

## អគ្គញ្ញសូត្រ

[ ៥១ ] *អគ្គញ្ញសូត្រ មានពាក្យផ្ដើមថា* **ឯវម្មេ សុតំ** *ដូច្នេះ ។ ក្នុងអគ្គញ្ញសូត្រនោះ មានពណ៌នាបទដែលនៅមានអត្ថមិនទាន់ជាក់ច្បាស់ដូច្នេះ ក្នុងបទថា* **បុព្វារាមេ មិគារមាតុបាសាទេ** *នេះ មានអនុបុព្វីកថាដូចតទៅ*

*បានឮថា ក្នុងអតីតកាល ក្នុងទីបំផុតនៃ ១ សែនកប្ប ឧបាសិកាម្នាក់យាងព្រះមានព្រះភាគ ព្រះនាម បទុមុត្តរៈ ហើយថ្វាយទានដល់ភិក្ខុសង្ឃមួយសែន មានព្រះពុទ្ធជាប្រធាន បានក្រាបចុះទៀបបាទមូលរបស់ព្រះមានព្រះភាគ ហើយបានតាំងសេចក្ដីប្រាថ្នាថា ក្នុងអនាគតកាល នាងខ្ញុំសូមបានជាឧបដ្ឋាកយិកាដ៏ប្រសើររបស់ព្រះពុទ្ធ ដូចជាព្រះអង្គ ។ ឧបាសិកានោះអន្ទោលទៅក្នុងទេវលោក និងមនុស្សលោកអស់សែនកប្ប ហើយបានបដិសន្ធិក្នុងគភ៌របស់នាងសុមនាទេវី ក្នុងផ្ទះរបស់ធនញ្ជយសេដ្ឋី ដែលជាបុត្ររបស់មេណ្ឌកសេដ្ឋី ក្នុងភទ្ទិយនគរ ក្នុងពុទ្ធបាទកាលរបស់ព្រះមានព្រះភាគនៃយើងទាំងឡាយ ។ ក្នុងវេលាដែលនាងកើតហើយ ពួកញាតិបានតាំងឈ្មោះឲ្យនាងថា វិសាខា ។ នាងវិសាខានោះ កាលដែលព្រះមានព្រះភាគស្ដេចយាងទៅកាន់ភទ្ទិយនគរ នាងក៏បានទៅធ្វើការទទួលព្រះមានព្រះភាគមួយអន្លើដោយទារិកាឯទៀត ៥០០ នាក់ ក្នុងការបានឃើញព្រះមានព្រះភាគត្រឹមតែគ្រាដំបូងប៉ុណ្ណោះ នាងក៏បានជាព្រះសោតាបន្ន ក្នុងកាលតមក នាងបានទៅកាន់ផ្ទះរបស់បុណ្ណវឌ្ឍនកុមារ បុត្ររបស់មិគារសេដ្ឋីក្នុងក្រុងសាវត្ថី ។*

មិគារសេដ្ឋី តាំងនាងទុកក្នុងតំណែងជាមាតាក្នុងផ្ទះនោះ ។ ដូច្នោះ ទើបជនទាំងឡាយហៅនាងថា មិគារមាតា ។ កាលនាងទៅកាន់ត្រកូលស្វាមី បិតាឲ្យជាងធ្វើគ្រឿងប្រដាប់ ឈ្មោះថា **មហាលតាបសាធន៍** ។ ពេជ្រ ៣ នាឡិ កែវមុក្តា ១១ នាឡិ កែវប្រវាល ២២ នាឡិ កែវមណី ៣៣ នាឡិ បានប្រកបចូលក្នុងគ្រឿងប្រដាប់នោះ ។ គ្រឿងប្រដាប់នោះ បានសម្រេចដោយរតនៈទាំងឡាយនេះ ដូចពោលមកនេះ និងដោយរតនៈ ៧ ពណ៌ដទៃទៀត ។ គ្រឿងប្រដាប់នោះ ពាក់លើសីសៈ រមែងគ្របដរាបដល់ខ្នងជើង ។ ស្ត្រីដែលមានកម្លាំងស្មើដំរី ៥ ប៉ុណ្ណោះ ទើបអាចទ្រទ្រង់គ្រឿងប្រដាប់នោះបាន ។ ក្នុងកាលតមក នាងវិសាខានោះ បានជាឧបដ្ឋាយិកាដ៏ប្រសើររបស់ព្រះទសពល នាងបានលះបង់គ្រឿងប្រដាប់នោះ ហើយឲ្យសាងវិហារថ្វាយព្រះមានព្រះភាគ ដោយទ្រព្យ ៩ កោដិ ហើយឲ្យសាងប្រាសាទលើភូមិភាគប្រមាណមួយករីសៈ ។ ប្រាសាទនោះ ប្រដាប់ដោយបន្ទប់ ១០០០ យ៉ាងនេះ គឺជាន់ខាងលើមាន ៥០០ បន្ទប់ ជាន់ខាងក្រោមក៏មាន ៥០០ បន្ទប់ ។ នាងគិតថា មានប្រាសាទតែម្យ៉ាង រមែងមិនល្អ ដូច្នេះ ទើបឲ្យសាងផ្ទះ ២ ជាន់ ៥០០ ខ្នង ប្រាសាទតូច ៥០០ ខ្នង សាលាវែង ៥០០ ខ្នង ចោមរោមប្រាសាទនោះ ។ ធ្វើការឆ្លងវិហារអស់ ៤ ខែ ។ ដែលឈ្មោះថា បរិច្ចាគទ្រព្យទុកក្នុងព្រះពុទ្ធសាសនារបស់ស្ត្រីដទៃ ដូចការធ្វើបរិច្ចាគរបស់នាងវិសាខា ដែលតាំងនៅក្នុងភាពជាមាតុគ្រាមមិនមាន ។ ការធ្វើបរិច្ចាគទ្រព្យក្នុងព្រះពុទ្ធសាសនា របស់បុរសដទៃ ដូចជាការធ្វើរបស់អនាថបិណ្ឌិកសេដ្ឋី ដែលតាំងនៅក្នុងភាពជា

បុរស ក៏មិនមាន ។ ព្រោះអនាថបិណ្ឌិកសេដ្ឋីនោះលះបង់ទ្រព្យ ៥៤ កោដិ ឲ្យសាងមហាវិហារ ឈ្មោះថា ជេតវន ក្នុងទិសខាងត្បូងនៃក្រុងសាវត្ថី ដូចគ្នានឹងមហាវិហារ ក្នុងអនុរាធបុរីដែរ ។ នាងវិសាខាឲ្យសាងវិហារ ឈ្មោះថា បុព្វារាម ក្នុងទីដូចជាវិហាររបស់នាងឧត្តមទេវី ក្នុងទិសខាងកើត នៃក្រុងសាវត្ថី ។ ព្រះមានព្រះភាគ ទ្រង់ប្រថាប់នៅក្នុងក្រុងសាវត្ថីជាប្រចាំ ក្នុងវិហារទាំង ២ នេះ ដោយអនុគ្រោះត្រកូលទាំង ២ នេះ ។ ខាងក្នុងវស្សាមួយ ប្រថាប់នៅជេតវនវិហារ ។ ខាងក្នុងវស្សាមួយ ប្រថាប់នៅក្នុងបុព្វារាមវិហារ ។ ក្នុងសម័យនោះ ព្រះមានព្រះភាគ ប្រថាប់នៅត្រង់បុព្វារាម ។ ដោយហេតុនោះ ទើបលោកពោលថា **បុព្វារាមេ មិគារមាតុបាសាទេ** ដូច្នេះ ។

បទថា **វាសេដ្ឋភារទ្វាជា** បានដល់ វាសេដ្ឋសាមណេរ និងភារទ្វាជ-សាមណេរ ។ ពីរបទថា **ភិក្ខូសុ បរិវសន្តិ** សេចក្តីថា សាមណេរទាំងពីរនៅបរិវាសដូចតិត្ថិយ មិននៅបរិវាសដើម្បីផុតអាបត្តិ ។ តែសាមណេរទាំងនោះ ព្រោះមានអាយុមិនទាន់បរិបូណ៌ ទើបប្រាថ្នាភាពជាភិក្ខុ ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា **ភិក្ខុភាវំ អាកង្ខមានា** ។ ពិតហើយ សាមណេរទាំងពីរនោះ កើតក្នុងត្រកូលព្រាហ្មណមហាសាល ឈ្មោះឧទិច្ច មួយអន្លេៗ មានទ្រព្យសម្បត្តិ ៤០ កោដិ សម្រេចដល់ត្រើយនៃត្រៃវេទ បានស្តាប់វាសេដ្ឋសូត្រ ក្នុងមជ្ឈិមនិកាយ បានដល់ សរណៈ ស្តាប់តេវិជ្ជសូត្រ ហើយបានបព្វជ្ជា ក្នុងវេលានេះប្រាថ្នាភាពជាភិក្ខុ ទើបនៅបរិវាស ។ បទថា **អព្ភោ-កាសេ ចង្កមតិ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់រុងរោចន៍ដោយព្រះរស្មី

ដែលមានពណ៌ ៦ ដែលផ្សាយចេញទៅក្នុងអាកាស ប្រៀបដូចមាស ដែលមានតម្លៃ កម្ពស់ ១១ ហត្ថ ដែលបុគ្គលទាញមកដោយខ្សែយន្តដូច្នោះ ទ្រង់ចង្ក្រមទៅមកៗ នៅត្រង់មួប់របស់ប្រាសាទ ក្នុងទិសបូព៌ារបស់ប្រាសាទ ដែលជាប់តគ្នានឹងផ្លូវទិសឧត្តរ និងទិសទក្សិណ ។ បទថា **អនុចង្កមីសុ** សេចក្តីថា សាមណេរទាំងពីរ ផ្គងអញ្ជលី បង្អោនសរីរៈចុះ ហើយចង្ក្រមតាមព្រះមានព្រះភាគ ។ បទថា **វាសេដ្ឋំ អាមន្តេសិ** សេចក្តីថា វាសេដ្ឋៈ និងភារទ្វាជ-សាមណេរទាំងនោះ វាសេដ្ឋៈសាមណេរឈ្លាសវៃជាង តែងដឹងដល់វត្ថុដែលគួរកាន់យក និងវត្ថុដែលគួរលះបង់ ដូច្នោះ ទើបព្រះមានព្រះភាគ ត្រាស់ហៅវាសេដ្ឋសាមណេរនោះមក ។ បទថា **តុម្ហេ ខ្វត្ថ** កាត់បទជា **តុម្ហេ ខោ អត្ថ** ។ បទថា **ព្រាហ្មណជច្ចា** សេចក្តីថា ជាព្រាហ្មណ៍ដោយជាតិ ។ បទថា **ព្រាហ្ម-ណកុលីនា** សេចក្តីថា មានត្រកូល គឺបរិបូណ៌ដោយត្រកូល ក្នុងពួកព្រាហ្មណ៍ ។ បទថា **ព្រាហ្មណកុលា** សេចក្តីថា ចាកត្រកូលព្រាហ្មណ៍ អធិប្បាយថា លះត្រកូលព្រាហ្មណ៍ ដែលបរិបូណ៌ដោយគោត្តៈជាដើម ។ បទថា **ន អក្កោសន្តិ** សេចក្តីថា រមែងមិនជេរ ដោយអក្កោសវត្ថុ ១០ ។ បទថា **ន បរិភាសន្តិ** សេចក្តីថា រមែងមិនប្រទេចដោយការពោលដល់ការលះបង់ដែលមានវិធីផ្សេងៗ ។ ព្រះមានព្រះភាគទ្រង់ជ្រាបថា ព្រាហ្មណ៍ទាំងឡាយរមែងជេរ រមែងប្រទេចសាមណេរទាំងនេះ ដូច្នេះ ទើបបានត្រាស់សួរដោយប្រការដូច្នេះ ។ សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់សួរ ឆ្លើយថា ព្រះអង្គទ្រង់ត្រិះរិះថា សាមណេរទាំងនេះ បើតថាគតមិនសួរ នឹងមិន

និយាយឡើងមុន កាលតថាគតមិនពោល វាចាក៏មិនកើតឡើង ដូច្នេះ ហេតុនោះ ទើបទ្រង់ត្រាស់សួរដើម្បីឲ្យវាចាផ្ដើមឡើង ។

បទថា **តគ្ឃ** ជានិបាតប្រើក្នុងពាក្យតែមួយ ។ អធិប្បាយថា បពិត្រព្រះអង្គដ៏ចម្រើន ព្រាហ្មណ៍ទាំងឡាយ រមែងជេរ រមែងប្រទេចខ្ញុំព្រះអង្គទាំងពីរ ដោយចំណែកតែមួយ ។ បទថា **អត្តរូបាយ** សេចក្ដីថា តាមសមគួរដល់ខ្លួន ។ បទថា **បរិបុណ្ណាយ** សេចក្ដីថា ដែលលើកបទ និងព្យញ្ជនៈមកពោលបរិបូណ៌ តាមសេចក្ដីពេញចិត្តរបស់ខ្លួន ។ បទថា **នោ អបរិបុណ្ណាយ** សេចក្ដីថា ដែលមិនឈប់ក្នុងចន្លោះ ពោលជាប់តទៅរហូត ។ សួរថា ព្រោះហេតុអ្វី ទើបពួកព្រាហ្មណ៍ជេរសាមណេរទាំងនេះ ។ ឆ្លើយថា ព្រោះមិនតាំងនៅ ( ក្នុងឋានៈរបស់ខ្លួន ) ។ សាមណេរទាំងនេះ ជាបុត្ររបស់ព្រាហ្មណ៍អ្នកខ្ពង់ខ្ពស់ សម្រេចដល់ត្រើយនៃត្រៃវេទ មានឈ្មោះបោះសំឡេងប្រាកដ បានទទួលការលើកតម្កើងក្នុងរវាងព្រាហ្មណ៍ទាំងឡាយក្នុងជម្ពូទ្វីប ។ ព្រោះសាមណេរទាំងពីរនោះបួស បុត្ររបស់ព្រាហ្មណ៍ដទៃជាច្រើន ក៏បានបួសតាម ។ លំដាប់នោះ ពួកព្រាហ្មណ៍ទាំងឡាយគិតថា យើងទាំងឡាយអស់ទីពឹងអាស្រ័យដូច្នេះ ព្រោះខ្លួនឯងមិនមានទីពឹងនេះឯង ជួបសាមណេរទាំងនោះត្រង់ទ្វារស្រុកក្ដី ខាងក្នុងស្រុកក្ដី ទើបពោលថា ពួកលោកទម្លាយលទ្ធិរបស់ព្រាហ្មណ៍ ពួកលោកជាអ្នកជាប់ក្នុងរស ទើបត្រាច់តាមក្រោយ សមណៈត្រងោល ដូច្នេះជាដើម និងពោលពាក្យជាដើមថា ព្រាហ្មណ៍ប៉ុណ្ណោះ មានវណ្ណៈប្រសើរបំផុត ដូច្នេះ ដែលមកក្នុងព្រះបាលីហើយ ទើបជេរ ។ កាល

ព្រាហ្មណ៍ទាំងនោះនាំគ្នាជេរ សាមណេរទាំងឡាយ ក៏មិនបានធ្វើសេចក្ដីក្រោធ ឬចងអាឃាតឡើយ ព្រោះត្រូវព្រះមានព្រះភាគត្រាស់សួរ ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកព្រាហ្មណ៍ទាំងឡាយ រមែងនាំគ្នាជេរ នាំគ្នាប្រទេច ពួកខ្ញុំព្រះអង្គ ដូច្នេះ ។ លំដាប់នោះ ព្រះមានព្រះភាគ កាលត្រាស់សួរអាការ គឺការជេរ ទើបត្រាស់សួរថា **យថាកថំ** ដូច្នេះ ។ សាមណេរទាំងនោះកាល ក្រាបទូលអាការ គឺការជេរ ទើបក្រាបទូលថា **ព្រាហ្មណា ភន្តេ** ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **សេដ្ឋោ វណ្ណោ** ដូច្នេះ សេចក្ដីថា ព្រាហ្មណ៍ទាំងឡាយ រមែងសម្ដែងថា ព្រាហ្មណ៍ប៉ុណ្ណោះ ជាវណ្ណៈប្រសើរបំផុត ដូច្នេះ ក្នុងឋានៈជាទីប្រាកដនៃជាតិ និងគោត្រជាដើម ។ បទថា **ហីនោ អញ្ញោ វណ្ណោ** សេចក្ដីថា ព្រាហ្មណ៍ទាំងឡាយ តែងពោលថា វណ្ណៈ បីក្រៅពីនេះ អាក្រក់ ថោកទាប ដូច្នេះ ។ បទថា **សុក្កោ** ប្រែថា ស ។ បទថា **កណ្ហោ** ប្រែថា ខ្មៅ ។ បទថា **សុជ្ឈន្តិ** សេចក្ដីថា ព្រាហ្មណ៍ទាំងឡាយ រមែងបរិសុទ្ធក្នុងឋានៈ មានជាតិ និងគោត្រជាដើមប្រាកដ ។ បទថា **ព្រហ្មុនោ បុត្តា** សេចក្ដីថា ព្រាហ្មណ៍ទាំងឡាយ ជាបុត្ររបស់មហាព្រហ្ម ។ បទថា **ឱរសា មុខតោ ជាតា** សេចក្ដីថា ព្រាហ្មណ៍ទាំងឡាយនៅក្នុងទ្រូង ហើយព្រហ្មខ្ជាក់មកអំពី មាត់ ។ ម្យ៉ាងទៀត ឈ្មោះថា ជាឱរស ព្រោះមហាព្រហ្ម ធ្វើទុកក្នុងទ្រូង ហើយ ឲ្យចម្រើនហើយ ។

បទថា **ព្រហ្មជា** សេចក្ដីថា កើតហើយ អំពីមហាព្រហ្ម ។ បទថា **ព្រហ្មនិម្មិតា** សេចក្ដីថា ដែលមហាព្រហ្មនិម្មិតឡើង ។ បទថា **ព្រហ្មទាយាទា**

សេចក្តីថា ជាមតិករបស់ព្រះព្រហ្ម ។ បទថា **ហីនមត្តាវណ្ណំ អជ្ឈុបគតា** សេចក្តីថា ពួកលោកបានជាអ្នកចូលដល់វណ្ណៈដែលថោកទាប ។ បទថា **មុណ្ឌកេ សមណកេ** សេចក្តីថា ព្រាហ្មណ៍ទាំងឡាយនិន្ទា ស្អប់ខ្ពើម ទើបពោល មិនមែនពោលសំដៅយកភាពជាមនុស្សក្បាលត្រងោល និងភាពជាសមណៈឡើយ ។ បទថា **ឥព្ភេ** បានដល់ គហបតីទាំងឡាយ ។ បទថា **កណ្ហេ** គឺខ្មៅ ។ បទថា **ពន្ធុ** ប្រែថា ជាផៅពង្សរបស់មារ គឺជាបក្សពួករបស់មារ ។ បទថា **បាទាបច្ចេ** សេចក្តីថា ជាពួកអ្នកកើតពីជើង របស់មហាព្រហ្ម អធិប្បាយថា កើតពីព្រះបាទ ។

បទថា **វោ** ក្នុងបទថា **តគ្ឃ វោ វាសេដ្ឋ ព្រាហ្មណា បោរាណំ អស្សរន្តា ឯវមាហំសុ** នេះ ត្រឹមតែជានិបាត ម្យ៉ាងទៀត ជាឆដ្ឋីវិភត្តិ ។ អធិប្បាយថា ព្រាហ្មណ៍ទាំងឡាយរឭករឿងបុរាណរបស់លោកមិនបាន ទើបពោលយ៉ាងនោះ ។ បទថា **បោរាណំ** សេចក្តីថា វង្សនៃការប្រព្រឹត្តដែលកើតឡើងក្នុងលោក ដែលសន្មតថា ប្រសើរជារបស់បុរាណ ។ បទថា **អស្សរន្តា** ប្រែថា ដឹងមិនបាន ។ មានពាក្យអធិប្បាយ ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលវាសេដ្ឋៈ ព្រាហ្មណ៍ទាំងឡាយ រឭកមិនបាន ដឹងមិនបាន នូវការកើតឡើងក្នុងលោក ដែលជារបស់បុរាណ ទើបនាំគ្នាពោលយ៉ាងនេះ ។ បទថា **និស្សន្តិ ខោ បន** ដូច្នេះជាដើម ព្រះមានព្រះភាគត្រាស់ទុកដើម្បីប្រយោជន៍ដល់ការទម្លាយទិដ្ឋិរបស់ព្រាហ្មណ៍ទាំងនោះ ។ បណ្តាបទទាំងនោះ បទថា **ព្រាហ្មណិយោ** សេចក្តីថា ព្រាហ្មណីទាំងឡាយ ដែលពួកព្រាហ្មណ៍

នាំមកកាន់ត្រកូល ដោយអំណាចអាវាហមង្គល និងវិវាហមង្គល ដើម្បីប្រយោជន៍ដល់ការបានបុត្រ ក៏ប្រាកដ ។ សម័យតមក ព្រាហ្មណីទាំងឡាយនោះឯង ក៏ជាស្ត្រីមានរដូវ អធិប្បាយថា មានរដូវកើតឡើង ។ បទថា **គព្ភិនិយោ** ប្រែថា មានគភ៌ ។ បទថា **វិជាយមានា** ប្រែថា សម្រាលបុត្រនិងធីតា ។ បទថា **ចាយមានា** សេចក្ដីថា ឲ្យទារកបៅទឹកដោះ ។ បទថា **យោនិជា វ សមានា** សេចក្ដីថា ជាអ្នកកើតហើយដោយយោនីរបស់ព្រាហ្មណីទាំងឡាយពិត ។ បទថា **ឯវមាហំសុ** សេចក្ដីថា រមែងពោលយ៉ាងនេះ ។ សួរថា ពោលថា ដូចម្ដេច ឆ្លើយថា ពោលថា មានតែព្រាហ្មណ៍ទើបជាវណ្ណៈប្រសើរបំផុត ។បេ។ ជាទាយាទរបស់ព្រហ្ម ។ សួរថា បើពាក្យរបស់ព្រាហ្មណ៍ទាំងនោះ គប្បីជាពាក្យពិតសោត ដូច្នេះ ផ្ទៃរបស់ព្រាហ្មណីគប្បីជាទ្រូងរបស់មហាព្រហ្ម យោនីរបស់ព្រាហ្មណី ក៏គប្បីជាមាត់របស់មហាព្រហ្មដោយពិត ។ ឆ្លើយថា ប្រការនោះ មិនគប្បីយល់ឃើញយ៉ាងនោះ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគ មានព្រះតម្រាស់ជាដើមថា **តេ ច ព្រហ្មានញ្ចេវ អព្ភាចិក្ខន្តិ** ដូច្នេះ ។

[ ៥២ ] ព្រះមានព្រះភាគត្រាស់មុខច្ឆេទវាទនេះ ដោយព្រះបំណងថា ចូរព្រាហ្មណ៍ទាំងឡាយកុំគប្បីពោលថា ពួកយើងនៅក្នុងព្រះឧរៈ ចេញមកពីព្រះឱស្ឋរបស់មហាព្រហ្មដូច្នេះ ដោយព្រះតម្រាស់ត្រឹមតែប៉ុណ្ណោះ ទើបទ្រង់សម្ដែងថា វណ្ណៈទាំង ៤ សមាទានប្រព្រឹត្តកុសលធម៌ពិត ទើបបរិសុទ្ធបានដូច្នេះទៀត ទើបត្រាស់ថា **ចត្តារោមេ វាសេដ្ឋ វណ្ណា** ជាដើម ។ បទថា

**អកុសលសង្ខាតា** សេចក្តីថា រាប់ថា ជាអកុសលដូច្នេះ ឬជាចំណែកនៃអកុសល ។ ក្នុងគ្រប់ៗ បទ ក៏ន័យនេះ ។ បទថា **ន អលមរិយា** សេចក្តីថា មិនអាចក្នុងភាពជាព្រះអរិយៈបាន ។ បទថា **កណ្ហា** ប្រែថា មានប្រក្រតីខ្មៅ ។ បទថា **កណ្ហវិបាកា** សេចក្តីថា វិបាករបស់ធម៌ពួកនោះ ខ្មៅ អធិប្បាយថា ជាទុក្ខ ។ បទថា **ខត្តិយេបិ តេ** សេចក្តីថា ធម៌ទាំងនោះ មានក្នុងព្រះមហាក្សត្រ ។ បទថា **ឯកច្ចេ** បានដល់ **ឯកស្មឹ** ។ ក្នុងគ្រប់ៗ បទ ក៏ន័យនេះ ។

[ ៥៣ ] បទថា **សុក្កា** ប្រែថា ស ដោយភាវៈដែលអស់កិលេស ។ បទថា **សុក្កវិបាកា** សេចក្តីថា សូម្បីវិបាករបស់ធម៌ទាំងនោះជារបស់ស អធិប្បាយថា ឲ្យផលជាសុខ ។ បទថា **ឧភយព្យាកិណ្ណេសុ** សេចក្តីថា រួមគ្នា គឺប្រឡូកប្រឡំលាយគ្នាក្នុងជន ២ ពួក ។ សួរថា ក្នុងជន ២ ពួកណា ឆ្លើយថា ក្នុងធម៌ចំណែកខ្មៅ ដែលវិញ្ញូជនតិះដៀលមួយពួក និងក្នុងធម៌ចំណែកស ដែលវិញ្ញូជនសរសើរមួយពួក ។ ក្នុងបទថា **យទេត្ថ ព្រាហ្មណា ឯវមាហំសុ** នេះ មានវិនិច្ឆ័យថា ព្រាហ្មណ៍ទាំងឡាយ សូម្បីប្រព្រឹត្តក្នុងធម៌ ទាំងចំណែកខ្មៅ និងចំណែកសនោះ រមែងពោលយ៉ាងនេះថា **ព្រាហ្មណោ វ សេដ្ឋោ វណ្ណោ** ជាដើម ។ ត្រង់បទថា **តទ្ទេសំ វិញ្ញូ ឆានុជានន្តិ** សេចក្តីថា ជនដែលជាបណ្ឌិតក្នុងលោកមិនត្រេកអរ អធិប្បាយថា រមែងមិនសរសើរ ។ សេចក្តីនោះព្រោះហេតុអ្វី ។ ក្នុងបទថា **ឥមេសញ្ហិ វាសេដ្ឋា** ជាដើមនេះ មានសេចក្តីសង្ខេប ដូច្នេះ ។ បើមានពាក្យសួរថា ព្រោះហេតុអ្វី លោកពោលពាក្យថា **ឆានុជានន្តិ** ដូច្នេះ ។ គប្បីឆ្លើយថា ព្រោះថា បណ្តាវណ្ណៈទាំង ៤ ពួកនេះ

វណ្ណៈណា ជាភិក្ខុឆ្ងាយចាកកិលេស ។បេ។ មានចិត្តផុតស្រឡះហើយ ព្រោះបានត្រាស់ដឹងដោយប្រពៃ វណ្ណៈនោះ ប្រាកដជាបុគ្គលប្រសើរលើសជាងវណ្ណៈទាំងនោះ ដោយធម៌ពិត មិនមែនដោយអធម៌ទេ ដូច្នោះ ទើបអ្នកប្រាជ្ញទាំងឡាយ មិនទទួលស្គាល់ពាក្យរបស់ព្រាហ្មណ៍ទាំងនោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **អរហំ** ជាដើមតទៅ ដែលឈ្មោះថា **អរហន្ត** ព្រោះហេតុ មានកិលេសទាំងឡាយនៅឃ្លាតឆ្ងាយ ដែលឈ្មោះថា **ខីណាស្រព** ព្រោះអស់អាសវៈហើយ ។ ព្រះសេក្ខៈ ៧ ពួក និងកល្យាណ-បុថុជ្ជន ឈ្មោះថា អ្នកនៅប្រព្រឹត្តព្រហ្មចរិយៈ ។ ភិក្ខុនេះ មានធម៌ជាគ្រឿងនៅចប់ស្រេចហើយ ដូច្នោះ ទើបឈ្មោះថា ប្រព្រឹត្តព្រហ្មចារ្យរួចស្រេចហើយ ។ កិច្ចដែលនឹងគប្បីធ្វើ មានការកំណត់ដឹងក្នុងសច្ចៈទាំង ៤ ជាដើម ដោយមគ្គ ៤ ដែលភិក្ខុនោះធ្វើហើយ ដូច្នោះ ទើបភិក្ខុនោះឈ្មោះថា បានធ្វើសោឡសកិច្ចស្រេចហើយ ។ កិលេសភារៈ និងខន្ធភារៈ ក៏ភិក្ខុនោះដាក់ចុះហើយ ដូច្នោះ ទើបលោកឈ្មោះថា មានភារៈ គឺកិលេស និងខន្ធ ដាក់ចុះហើយ ។ បទថា **ឱហិតោ** ប្រែថា ដាក់ចុះហើយ ។ ប្រយោជន៍ដ៏ល្អ ឬប្រយោជន៍ដែលជារបស់ខ្លួន ដូច្នោះ ទើបឈ្មោះថា ប្រយោជន៍ខ្លួន ។ ប្រយោជន៍របស់ខ្លួន ដែលភិក្ខុនោះតាមសម្រេចបានហើយ ដូច្នោះ ទើបលោកឈ្មោះថា បានសម្រេចប្រ-យោជន៍របស់ខ្លួនតាមលំដាប់ហើយ ។ តណ្ហា លោកហៅថា សញ្ញោជនៈគ្រឿងចងសត្វទុកក្នុងភព ។ តណ្ហានោះ របស់ភិក្ខុនោះអស់ហើយ ដូច្នោះ ទើបលោកឈ្មោះថា មានតណ្ហាជាគ្រឿងចងក្នុងភពអស់រលីងហើយ ។ បទថា

**សម្មទញ្ញា វិមុត្តោ** សេចក្តីថា ផុតហើយ ព្រោះដឹងដោយប្រពៃ គឺដោយហេតុ ដោយការណ៍ ។ បទថា **ឥធេតស្មឹ** កាត់បទជា **ឥធ ឯតស្មឹ** អធិប្បាយថា ក្នុងលោកនេះ ។ ច្រើនបទថា **ធិដ្ឋេ ចេវ ធម្មេ អភិសម្បរាយញ្ច** សេចក្តីថា ក្នុងអត្តភាពនេះ និងក្នុងអត្តភាពដែលសត្វគប្បីដល់ក្នុងលោកខាងមុខ ។

[ ៥៤ ] បទថា **អនន្តរា** សេចក្តីថា វៀរហើយចាកចន្លោះ អធិប្បាយថា ដូចគ្នាដោយត្រកូលរបស់ខ្លួន ។ បទថា **អនុយន្តា** សេចក្តីថា ប្រព្រឹត្តទៅក្នុងអំណាច ។ បទថា **និបច្ចការា** សេចក្តីថា ពួកសក្យៈទាំងឡាយដែលចាស់ជាង រមែងសម្តែងការគោរព បើក្មេងជាង រមែងធ្វើកិច្ច មានការអភិវាទជាដើម ។ បណ្តាបទទាំងនោះ បទថា **សាមីចិកម្មំ** ដូច្នោះ គឺកម្មដែលសមគួរ មានការធ្វើវត្តចំពោះព្រះបាទបសេនទិនោះជាដើម ។

[ ៥៥ ] បទថា **និវិដ្ឋា** សេចក្តីថា តាំងមាំហើយ គឺតាំងនៅមិនញាប់ញ័រ ។ សួរថា សទ្ធាបែបនេះ រមែងមានដល់បុគ្គលណា ឆ្លើយថា រមែងមានដល់ព្រះសោតាបន្ន ។

ព្រះសោតាបន្ននោះ មានសទ្ធាតាំងមាំ សូម្បីកាលត្រូវគេយកដាវកាត់ក្បាល ក៏មិនពោលថា ព្រះពុទ្ធមិនមែនព្រះពុទ្ធដូច្នេះខ្លះ ព្រះធម៌ មិនមែនព្រះធម៌ដូច្នេះខ្លះ ព្រះសង្ឃមិនមែនជាព្រះសង្ឃដូច្នេះខ្លះ ។ ព្រះសោតាបន្ន ជាអ្នកមានសទ្ធាតាំងមាំដោយពិត ដូចសូរអម្ពដ្ឋឧបាសក ដូច្នោះ ។ បានឮថា ឧបាសកនោះ ស្តាប់ព្រះធម៌ទេសនារបស់ព្រះបរមសាស្តាហើយ បានជាព្រះសោតាបន្ន ក៏ត្រឡប់ទៅផ្ទះវិញ ។ ពេលនោះ មារនិម្មិតព្រះពុទ្ធរូប ដែល

ប្រដាប់ដោយលក្ខណៈដ៏ប្រសើរ ៣២ ប្រការ ឈរត្រង់ទ្វារផ្ទះរបស់ឧបាសក នោះ ហើយអ្នកបម្រើឲ្យដំណឹងថា ព្រះសាស្តាទ្រង់យាងមក ដូច្នេះ ។ សូរ-អម្ពដ្ឋឧបាសកគិតថា អញស្តាប់ព្រះធម៌ក្នុងសម្នាក់នៃព្រះសាស្តា អម្បាញ់មិញនេះឯង នឹងមានរឿងអ្វីហ្ន៎ ដូច្នេះហើយ ក៏ចូលទៅថ្វាយបង្គំដោយសម្គាល់ថា ជាព្រះសាស្តា ហើយឈរស្ងៀម ។ មារពោលថា អម្ពដ្ឋៈ ពាក្យណាដែលតថាគតពោលដល់អ្នកថា រូបមិនទៀង ។បេ។ វិញ្ញាណមិនទៀង ដូច្នេះ ពាក្យនោះ តថាគតពោលខុសទេ ព្រោះតថាគតមិនទាន់ពិចារណា ទើបពោលពាក្យនោះទៅ ដូច្នោះ អ្នកចូរកាន់យកថា រូបទៀង ។បេ។ វិញ្ញាណទៀង ដូច្នេះចុះ ។ សូរអម្ពដ្ឋឧបាសកគិតថា សេចក្តីណា ដែលព្រះពុទ្ធទាំង-ឡាយមិនពិចារណា មិនធ្វើការត្រួតត្រាយ៉ាងប្រចក្ស ហើយត្រាស់ អ្វីនោះមិនជាឋានៈដែលនឹងមាន មារនេះ មកដើម្បីប្រាថ្នាទម្លាយអញយ៉ាងពិតប្រាកដ ។ លំដាប់នោះ សូរអម្ពដ្ឋឧបាសក ពោលនឹងមារនោះថា អ្នកជាមារឬ ដូច្នេះ ។ មារនោះមិនអាចនឹងពោលមុសាវាទបាន ទើបទទួលថា មែន យើងជាមារ ដូច្នេះ ។ ឧបាសកសួរថា ព្រោះហេតុអ្វី ទើបអ្នកមក ។ មារឆ្លើយថា ខ្ញុំមកដើម្បី ធ្វើសទ្ធារបស់អ្នកឲ្យញាប់ញ័រ ។ ឧបាសកពោលថា នែមារមានចិត្តបាបឃោរឃៅ អ្នកតែម្នាក់ចូរបញ្ឈប់ទៅ ពួកមារដូចអ្នក ១ រយក្តី ១ ពាន់ក្តី ១ សែនក្តី ក៏មិនអាចនឹងញ៉ាំងសទ្ធារបស់យើងឲ្យញាប់ញ័របាន ឈ្មោះថា សទ្ធា ដែលមកហើយដោយមគ្គ ជារបស់រឹងមាំ មិនញាប់ញ័រ ដូចភ្នំសិនេរុដែលតាំងនៅលើផែនដី ដែលសម្រេចដោយធម៌ អ្នកនឹងធ្វើអ្វីក្នុងការ

មកនេះ ដូច្នេះហើយ ក៏ទះដៃឡើង ។ មារនោះ កាលមិនអាចនឹងបិតនៅបាន ទើបបាត់ទៅក្នុងទីនោះឯង ។ បទថា **ឆវិជ្ជា** នោះ ព្រះមានព្រះភាគ ត្រាស់សំដៅយកសទ្ធាយ៉ាងនេះ ។ បទថា **មូលជាតា បតិដ្ឋិតា** សេចក្តីថា តាំងមាំហើយដោយមគ្គនោះ ដែលជាមូល ព្រោះជាឫសគល់ គឺមគ្គកើតព្រមហើយ ។ បទថា **ឧឡ្ហា** ប្រែថា រឹងមាំ ។

បទថា **អសំហារិយា** សេចក្តីថា ដែលបុគ្គលណាម្នាក់ មិនអាចឲ្យញាប់ញ័របាន ប្រៀបដូចសសរខឿនដែលគេកប់យ៉ាងមាំ ។ បទថា **តស្សេតំ កល្លំ វចនាយ** នោះ សេចក្តីថា ពាក្យនោះ គួរនឹងហៅព្រះអរិយសាវ័ក ។ លោកពោលដូចម្តេច ។ លោកពោលពាក្យជាដើមថា ខ្ញុំជាបុត្រកើតអំពីទ្រូងរបស់ព្រះមានព្រះភាគ ដូច្នេះ ។

សេចក្តីពិត ព្រះអរិយសាវ័កនោះ អាស្រ័យព្រះមានព្រះភាគ ទើបកើតឡើងក្នុងភូមិរបស់ព្រះអរិយៈ ដូច្នោះ ទើបឈ្មោះថា ជាបុត្ររបស់ព្រះមានព្រះភាគ និងឈ្មោះថា ជាឱរសកើតអំពីព្រះឱស្ឋ ព្រោះនៅក្នុងទ្រូង ហើយតាំងនៅក្នុងមគ្គ និងផល ដោយអំណាចការពោលធម៌ដែលចេញមកពីព្រះឱស្ឋ ឈ្មោះថា កើតអំពីធម៌ ព្រោះកើតអំពីអរិយធម៌ និងឈ្មោះថា ដែលធម៌និម្មិតឡើង ព្រោះត្រូវអរិយៈនិម្មិតឡើង ឈ្មោះថា ធម្មទាយាទ ព្រោះគួរទទួលមត៌កគឺនវលោកុត្តរធម៌ ។

បទថា **តំ កិស្ស ហេតុ** សេចក្តីថា ប្រសិនបើមានពាក្យសួរថា ព្រះមានព្រះភាគត្រាស់ថា **ភគវតោម្ហិ បុត្តោ** ដូច្នេះហើយ ត្រាស់ទៀតថា **ធម្មជោ**

**ធម្មនិម្មិតោ** ដូច្នេះទៀត ពាក្យនោះ ព្រះអង្គត្រាស់ព្រោះហេតុអ្វី ។ ឥឡូវនេះ កាលនឹងសម្ដែងអត្ថរបស់ពាក្យនោះ ទើបលោកពោលពាក្យថា **តថាគតស្ស ហេតំ** ដូច្នេះជាដើម ។ ក្នុងបាលី បទថា **ធម្មកាយោ ឥតិបិ** សេចក្ដីថា ព្រោះហេតុអ្វី ទើបព្រះតថាគតបានទទួលនាមថា **ធម្មកាយ** ។ ព្រោះព្រះតថាគតទ្រង់ព្រះតម្រិះព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដកដោយព្រះហឫទ័យ ហើយទ្រង់នាំចេញសម្ដែងដោយព្រះវាចា ។ ព្រោះហេតុនោះ ទើបព្រះវរកាយរបស់ព្រះមានព្រះភាគ ចាត់ជាធម៌ពិត ព្រោះសម្រេចដោយធម៌ ។ ព្រះធម៌ ជាកាយរបស់ព្រះមានព្រះភាគនោះ ដូចពណ៌នាមកនេះ ដូច្នោះ ទើបព្រះមានព្រះភាគឈ្មោះថា **ធម្មកាយ** ។

ឈ្មោះថា **ព្រហ្មកាយ** ព្រោះមានធម៌ជាកាយនោះឯង ពិតហើយ ព្រះធម៌ លោកហៅថា **ព្រហ្ម** ព្រោះជារបស់ប្រសើរ ។ បទថា **ធម្មភូតោ** បានដល់ សភាវធម៌ ។ ឈ្មោះថា **ព្រហ្មភូត** ព្រោះជាអ្នកកើតពីព្រះធម៌នោះឯង ។

[ ៥៦ ] ព្រះមានព្រះភាគ លុះទ្រង់សម្ដែងវាទៈដែលជាគ្រឿងទម្លាយភាពជាអ្នកប្រសើរដោយព្រះតម្រាស់មានប្រមាណប៉ុណ្ណេះហើយ ឥឡូវនេះ កាលទ្រង់សម្ដែងវាទៈ ដែលជាគ្រឿងទម្លាយភាពជាអ្នកប្រសើរ ដោយន័យដទៃទៀត ទើបត្រាស់ថា **ហោតិ ខោ សោ វាសេដ្ឋា សមយោ** ដូច្នេះជាដើម បណ្ដាបទទាំងនោះ កថាពោលអំពីសំវដ្ដៈ និងវិវដ្ដៈ បានពណ៌នាដោយពិស្ដារហើយក្នុងព្រហ្មជាលសូត្រ ។

បទថា **ឥត្ថត្តំ អាគច្ឆន្តិ** សេចក្ដីថា រមែងមកកាន់ភាពជាយ៉ាងនេះ គឺ

កាន់ភាពជាមនុស្ស ។ បទថា **តេ ច ហោន្តិ មនោមយា** សេចក្តីថា សត្វទាំងនោះស្លាប់មកកើតក្នុងមនុស្សលោកនេះ ក៏ជាពួកឱបបាតិកកំណើតកើតឡើងដោយចិត្តប៉ុណ្ណោះ ដូច្នោះ ទើបឈ្មោះថា អ្នកមានសេចក្តីសម្រេចផ្លូវចិត្ត ។ បីតិប៉ុណ្ណោះ រមែងឲ្យសម្រេចកិច្ចដោយអាហារដល់សត្វទាំងនោះ ស្លាប់ក្នុងមនុស្សលោកនេះ ដូចក្នុងព្រហ្មលោក ដូច្នោះ ទើបសត្វទាំងនោះ ឈ្មោះថាមានបីតិជាអាហារ ។ គប្បីជ្រាបហេតុ មានរស្មីឯងជាដើម ដោយន័យនេះ ។ បទថា **ឯកោទកីភូតំ** សេចក្តីថា ចក្រវាលទាំងអស់ ជាទីដែលមានទឹកដូចគ្នា ។ បទថា **អន្ធការោ** ប្រែថា សេចក្តីងងឹត ។ បទថា **អន្ធការតិមិសា** សេចក្តីថា ញុំាងភាពងងឹត គឺមានភាពងងឹតឈឹង ដោយការហាមការកើតឡើងនៃចក្ខុវិញ្ញាណ ។ បទថា **សមន្តានិ** សេចក្តីថា តាំងនៅ គឺផ្សាយទៅជុំវិញ ។ បទថា **បយតត្តស្ស** ប្រែថា ទឹកដោះដែលរម្ងាស់ឲ្យរីង ។ បទថា **វណ្ណសម្បន្នា** សេចក្តីថា ដល់ព្រមដោយពណ៌ ។ ឯពណ៌នៃក្រមរផែនដីនោះ ដូចជាផ្កាកណិការ ។ បទថា **គន្ធសម្បន្នា** សេចក្តីថា ដល់ព្រមដោយក្លិន គឺក្លិនដែលជាទិព្វ រមែងផ្សាយទៅ ។ បទថា **រសសម្បន្នា** សេចក្តីថា ដល់ព្រមដោយរស ដូចដាក់ឱជាទិព្វចូលទៅ ដូច្នោះ ។ បទថា **ខុទ្ទមធុំ** សេចក្តីថា ទឹកឃ្មុំដែលមេឃ្មុំតូចៗ ធ្វើ ។ បទថា **អនេឡកំ** សេចក្តីថា មានទោសទៅប្រាសហើយ គឺវៀរចាកពងរុយ ។

បទថា **លោលជាតិកោ** សេចក្តីថា មានសេចក្តីលោភជាសភាវៈ ។ ស្លាប់ក្នុងកប្បបន្ទាប់ទៅ ដែលកន្លងទៅហើយ ក៏មានសេចក្តីលោភដូចគ្នា សត្វ

នោះកើតសេចក្តីអស្ចារ្យ ទើបពោលថា **អម្ភោ** ដូច្នេះ ។ បទថា **កិមេវិទំ ភវិស្សតិ** សេចក្តីថា ពណ៌ក្តី ក្លិនក្តី នៃក្រមរផែនដីនោះ គួរពេញចិត្ត តើរសរបស់ក្រមរផែនដីនោះ ដូចម្តេចហ្ន៎ ។ អ្នកដែលកើតសេចក្តីលោភក្នុងក្រមរផែនដីនោះ ក៏យកចង្អុលដៃឆ្កឹះដីនោះមកលិទ្ធភ្លក្សមើល លុះយកចង្អុលដៃឆ្កឹះមកហើយ ក៏យកមកដាក់ត្រង់អណ្តាត ។ បទថា **អច្ឆាទេសិ** សេចក្តីថា រសដីនោះ គ្រាន់តែសត្វនោះយកមកដាក់ត្រង់ចុងអណ្តាត ក៏ជ្រួតជ្រាបទៅគ្រប់សរសៃទទួលរសអាហារទាំង ៧០០០ ជារបស់គួរពេញចិត្ត ។ បទថា **តណ្ហា ចស្ស ឱក្កមិ** សេចក្តីថា ការប្រាថ្នារសក្នុងក្រមរផែនដីនោះ ក៏កើតឡើងដល់សត្វអ្នកមានសេចក្តីលោភនោះ ។ ច្រើនបទថា **អាលុប្បការកំ ឧបក្កមឹសុ បរិភុញ្ជិតុំ** សេចក្តីថា សត្វនោះពូតជាពំនូត គឺបែងចែកចេញជាដុំហើយ ផ្តើមបរិភោគ ។ ព្រះចន្ទ និងព្រះអាទិត្យ ឈ្មោះថា **ចន្ទិមសុរិយា** ។ បទថា **ចាតុរហេសុំ** ប្រែថា ប្រាកដឡើង ។ បណ្តាព្រះចន្ទ និងព្រះអាទិត្យនោះ តើណាមួយប្រាកដមុន តើមួយណានៅក្នុងទីណា តើប្រមាណរបស់មួយណាមានទំហំប៉ុនណា តើមួយណានៅខ្ពស់ តើមួយណាវិលរហ័ស វិថិរបស់ព្រះចន្ទ និងព្រះអាទិត្យនោះ តើដូចម្តេច តើគោចរទៅបានដូចម្តេច តើធ្វើពន្លឺក្នុងទីមានប្រមាណប៉ុនណា ។

ព្រះចន្ទ និងព្រះអាទិត្យទាំងពីរ មិនប្រាកដព្រមគ្នា ។ ព្រះអាទិត្យប្រាកដឡើងមុន ។ កាលរស្មីនៃកាយរបស់សត្វទាំងនោះ បានបាត់ទៅភាពងងឹត ក៏មានឡើង ។ សត្វទាំងនោះ ក៏ភ័យខ្លាចតក់ស្លុត ហើយគិតគ្នាថា បើ

ពន្លឺប្រាកដឡើងមក គង់នឹងល្អហ្ន៎ ដូច្នេះ បន្ទាប់ពីនោះ ព្រះអាទិត្យក៏កើតឡើង ដល់មហាជន ។ ដោយហេតុនោះ ទើបព្រះអាទិត្យនោះបាននាមថា **សុរិយោ** ដូច្នេះ ។ កាលព្រះអាទិត្យនោះ ធ្វើពន្លឺហួតដល់អស់មួយថ្ងៃ ហើយអស្តង្គតទៅ កាពងងឹត ក៏ត្រឡប់មានឡើងទៀត ។ សត្វទាំងនោះនាំគ្នាគិតថា គង់ជាការល្អហ្ន៎ ប្រសិនបើមានពន្លឺដទៃកើតឡើង ដូច្នេះ ។ ពេលនោះ ព្រះចន្ទដ៏ឯនូវសេចក្តីពេញចិត្តរបស់សត្វទាំងនោះ ទើបកើតឡើង ។ ដោយហេតុនោះឯង ទើបព្រះចន្ទបាននាមថា **ចន្ទោ** ដូច្នេះ ។ បណ្តាព្រះចន្ទ និងព្រះអាទិត្យនោះ ព្រះចន្ទនៅក្នុងវិមានខាងក្នុង ដែលសម្រេចដោយកែវមណី វិមានខាងក្រៅសម្រេចដោយប្រាក់ ទាំងខាងក្នុង និងខាងក្រៅនោះ មានកាពត្រជាក់តែម្យ៉ាង ។ ព្រះអាទិត្យនៅក្នុងវិមាន ខាងក្នុងសម្រេចដោយមាស វិមានខាងក្រៅសម្រេចដោយកែវផលិក ។ ទាំងខាងក្នុង និងខាងក្រៅ ក្តៅទាំងអស់ ។

ព្រះចន្ទមានវិជ្ជមាត្រ ៤៩ យោជន៍ រង្វង់ជុំវិញប្រវែង ២៤៩ យោជន៍ ។ ព្រះអាទិត្យមានវិជ្ជមាត្រ ៥០ យោជន៍ រង្វង់ជុំវិញប្រវែង ២៥០ យោជន៍ ។

ព្រះចន្ទនៅខាងក្រោម ព្រះអាទិត្យនៅខាងលើ ។ ព្រះចន្ទ និងព្រះអាទិត្យនោះ នៅឆ្ងាយពីគ្នា ១ យោជន៍ ។ ចំណែកក្រោមរបស់ព្រះចន្ទ ដល់ចំណែកលើរបស់ព្រះអាទិត្យ មានរយៈ ១០០ យោជន៍ ។

ព្រះចន្ទវិលទៅផ្លូវត្រង់យឺត ប៉ុន្តែវិលទៅផ្លូវខាងស្តាំរហ័ស ពួកផ្កាយនក្ខត្តឫក្ស ក៏វិលទៅក្នុងពីរផ្នែក ព្រះចន្ទវិលទៅជិតពួកផ្កាយនោះៗ ដូចមេគោចូលទៅរកកូនគោ ដូច្នោះ ។ ចំណែកពួកផ្កាយ មិនលះបង់ទីគោចររបស់ខ្លួន

ឡើយ ។ ការវិលទៅរបស់ព្រះអាទិត្យផ្លូវត្រង់រហ័ស ទៅផ្លូវទទឹងយឺត ។ ព្រះអាទិត្យនេះ គោចរឆ្ងាយពីព្រះចន្ទ ១ សែនយោជន៍ ក្នុងថ្ងៃបាដិបទអំពីថ្ងៃឧបោសថកាឡបក្ខ ។ វេលានោះ ព្រះចន្ទប្រាកដដូចស្នាមគំនូស ដូច្នោះ ។ ព្រះអាទិត្យ គោចរឆ្ងាយទៅជារយៈ ១ សែនយោជន៍ ក្នុងបក្ខទី ២ ព្រះអាទិត្យបានគោចរឆ្ងាយទៅ ដូចដែលពោលហើយនេះ ជារយៈ ១ សែនយោជន៍ៗ រហូតដល់ថ្ងៃឧបោសថ ។ លំដាប់នោះ ព្រះចន្ទក៏ធំឡើងដោយលំដាប់ ហើយពេញវង់ក្នុងថ្ងៃឧបោសថ ។ គោចរឆ្ងាយចេញទៅ ១ សែនយោជន៍ ក្នុងថ្ងៃបាដិបទ ( រនោច ) ទៀត ។ គោចរឆ្ងាយចេញទៅជារយៈ ១ សែនយោជន៍ ក្នុងបក្ខទី ២ ព្រះអាទិត្យគោចរឆ្ងាយទៅ ដូចពោលហើយនេះ ជារយៈ ១ សែនៗ យោជន៍ រហូតដល់ថ្ងៃឧបោសថ ។ ពេលនោះ ព្រះចន្ទថយពន្លឺចុះដោយលំដាប់ ហើយមិនប្រាកដទាំងវង់ក្នុងថ្ងៃឧបោសថ ។ ព្រះអាទិត្យអណ្តែតនៅខាងលើ ឲ្យព្រះចន្ទនៅខាងក្រោម (ព្រះអាទិត្យ) រមែងបិទបាំងព្រះចន្ទបានដូចភាជន៍តូចត្រូវភាជន៍ធំបិទបាំង ដូច្នោះ ។ ស្រមោលរបស់ព្រះចន្ទមិនប្រាកដដូចស្រមោលផ្ទះមិនប្រាកដក្នុងវេលាថ្ងៃត្រង់ ។ ព្រះអាទិត្យនោះ កាលស្រមោលមិនប្រាកដ សូម្បីខ្លួនឯងក៏មិនប្រាកដ ដូចប្រទីបក្នុងពេលថ្ងៃ មិនប្រាកដដល់ពួកជនអ្នកឈរនៅទីឆ្ងាយ ដូច្នោះ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា វិថិរបស់ព្រះអាទិត្យ និងព្រះចន្ទ តើដូចម្តេច តទៅនេះវិថិមានដូច្នេះ គឺវិថិពពែ វិថិដំរី វិថិរបស់គោ ។ បណ្តាវិថិទាំងនោះ ទឹកជារបស់គួរខ្ពើមសម្រាប់ពពែទាំងឡាយ តែទឹកនោះ ជាទីពេញចិត្តរបស់ដំរីទាំងឡាយ ជាទីសប្បាយរបស់ហ្វូង

គោ ព្រោះមានភាពត្រជាក់ និងភាពក្ដៅស្មើគ្នា ។ ដូច្នោះ ក្នុងវេលាណា ព្រះចន្ទ និងព្រះអាទិត្យ ឡើងកាន់វិថីរបស់ពពែ វេលានោះ ភ្លៀងមិនធ្លាក់ឡើយ សូម្បីត្រឹមតែមួយគ្រាប់ កាលណា ព្រះចន្ទ និងព្រះអាទិត្យឡើងកាន់វិថីរបស់ដំរី កាលនោះ ភ្លៀងនឹងធ្លាក់ខ្លាំងដូចធ្លាយមេឃ ។ កាលណា ព្រះចន្ទ និងព្រះអាទិត្យឡើងកាន់វិថីរបស់គោ កាលនោះ សភាពស្មើរបស់រដូវ ក៏រមែងដល់ព្រម ។ ព្រះចន្ទ និងព្រះអាទិត្យ រមែងគោចរនៅខាងក្រៅ ភ្នំសិនេរុអស់ ៦ ខែ និងគោចរនៅខាងក្នុង ៦ ខែទៀត ។ ពិតហើយ ព្រះចន្ទ និងព្រះអាទិត្យនោះ តែងគោចរទៅជិតភ្នំសិនេរុក្នុងខែអាសាឍ ។ បន្ទាប់អំពីនោះ គោចរចេញទៅខាងក្រៅ ២ ខែ ហើយគោចរទៅត្រង់កណ្ដាល ក្នុងខែបឋមកត្តិក[១] ។ បន្ទាប់អំពីនោះ គោចរមានមុខឆ្ពោះចក្រវាល ហើយគោចរនៅជិតៗចក្រវាល អស់វេលា ៣ ខែ ហើយគោចរចេញឆ្ងាយមកទៀត ទៅនៅត្រង់កណ្ដាលចក្រវាល ក្នុងខែចេត្រ បន្ទាប់អំពីនោះ ក្នុងខែជេដ្ឋក៏វិលមុខឆ្ពោះភ្នំសិនេរុ ហើយគោចរនៅជិតៗ ភ្នំសិនេរុ ក្នុងខែអាសាឍទៀត ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា ព្រះអាទិត្យ និងព្រះចន្ទធ្វើពន្លឺក្នុងទីនេះប្រមាណប៉ុនណា ដូច្នេះថា ព្រះចន្ទ និងព្រះអាទិត្យ រមែងធ្វើពន្លឺក្នុងទ្វីបទាំង ៣ ដោយព្រមគ្នា ។ ធ្វើបានដូចម្ដេច ។ កាលព្រះអាទិត្យរះឡើងក្នុងជម្ពូទ្វីបនេះ ជាពេលថ្ងៃត្រង់ក្នុងបុព្វវិទេហទ្វីប ជាពេលដែលព្រះអាទិត្យលិចក្នុងឧត្តរកុរុទ្វីប និងជាមជ្ឈិមយាមក្នុងអមរគោយានទ្វីប ។ កាលព្រះអាទិត្យរះឡើង

១- ខែបឋមកត្តិក ក្នុងព្រះវិន័យ គឺនៅក្នុងខែអស្សុជនៅឡើយ បើទុតិយកត្តិក ទើបជាខែកត្តិក ។

ក្នុងបុព្វវិទេហទ្វីប ជាពេលថ្ងៃត្រង់ ក្នុងឧត្តរកុរុទ្វីបជាពេលថ្ងៃលិច ក្នុងអមរគោយានទ្វីប និងជាមជ្ឈិមយាមក្នុងជម្ពូទ្វីបនេះ ។ ពេលដែលព្រះអាទិត្យរះឡើង ក្នុងឧត្តរកុរុទ្វីប ជាពេលថ្ងៃត្រង់ ក្នុងអមរគោយានទ្វីប ជាពេលថ្ងៃលិច ក្នុងជម្ពូទ្វីបនេះ និងជាពេលមជ្ឈិមយាម ក្នុងបុព្វវិទេហទ្វីប ។ កាលដែលព្រះអាទិត្យរះឡើងក្នុងអមរគោយានទ្វីប ជាពេលថ្ងៃត្រង់ក្នុងជម្ពូទ្វីបនេះ ជាពេលព្រះអាទិត្យលិចក្នុងបុព្វវិទេហទ្វីប និងជាពេលមជ្ឈិមយាម ក្នុងឧត្តរកុរុទ្វីប ដូច្នេះឯង ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពីរបទថា **នក្ខត្តានិ តារករូបានិ** តទៅនេះថា ផ្កាយនក្ខត្ត មានផ្កាយឫក្សជាដើម និងពួកផ្កាយទាំងឡាយដ៏សេសរមែងប្រាកដព្រមនឹងព្រះចន្ទ និងព្រះអាទិត្យ ។ បទថា **រត្តិន្ទិវា** សេចក្តីថា តាំងពីព្រះអាទិត្យលិច ដរាបដល់រះឡើង ជាពេលយប់ តាំងពីវេលាព្រះអាទិត្យរះឡើង ដរាបដល់ព្រះអាទិត្យលិច ចាត់ជាពេលថ្ងៃ ពេលយប់ និងពេលថ្ងៃ រមែងប្រាកដដូចពោលមកនេះ ។ តអំពីនោះ ១៥ រាត្រី ចាត់ជាកន្លះខែ ២ កន្លះខែ ជាមួយខែ កន្លះខែ និងមួយខែ ប្រាកដដូចពោលមកនេះ ។ ដូច្នេះ ៤ ខែ ចាត់ជា ១ រដូវ ៣ រដូវជា ១ ឆ្នាំ ទាំងរដូវ និងឆ្នាំ ទើបប្រាកដដូចពោលមកនេះ ។

[ ៥៧ ] បទថា **វណ្ណវេវណ្ណតា ច** បានដល់ ការមានពណ៌សម្បុរផ្សេងគ្នា ។ បទថា **តេសំ វណ្ណាតិមានប្បច្ចយា** សេចក្តីថា ព្រោះការប្រកាន់ខ្លួនខ្ពង់ដែលកើតឡើង ព្រោះប្រារព្ធពណ៌សម្បុររបស់សត្វទាំងឡាយនោះជាបច្ច័យ ។ បទថា **មានាតិមានជាតិកានំ** សេចក្តីថា អ្នកមានមានះ និង

អតិមានះ កើតឡើងរឿយៗ ជាសភាវៈ ។ បទថា **រសបឋវិយា** សេចក្ដីថា ផែនដីដែលបានឈ្មោះថា **រស** ព្រោះបរិបូណ៌ដោយរស ។ បទថា **អនុត្ថុនឹសុ** សេចក្ដីថា នាំគ្នាត្អូញត្អែរ ។ បទថា **អហោ រសំ** សេចក្ដីថា ឱ រសឆ្ងាញ់មានដល់ពួកយើង ។ បទថា **អគ្គញ្ញំ អក្ខរំ** នេះ ជាពាក្យពោលដល់វង្សដែលកើតឡើងក្នុងលោក ។ បទថា **អនុបទន្តិ** សេចក្ដីថា រមែងទៅតាម ។

[ ៥៨ ] បទថា **ឯវមេវ ចាតុរហោសិ** សេចក្ដីថា បានជាដូច្នេះតាំងឡើង និងបានតាំងឡើងដូចជាកក់ ដែលស្ងួតកើតឡើង ក្នុងកាលទឹកខាងក្នុងស្រះរីងស្ងួតទៅ ដូច្នោះ ។ វល្លិដែលចម្រើនមានរសផ្អែមយ៉ាង ឈ្មោះថា **បទាលតា** ។ បទថា **កលម្ពកា** បានដល់ វល្លិត្រកួន ។ បទថា **អហុ វត នោ** សេចក្ដីថា វល្លិមានរសផ្អែម មានដល់យើងទាំងឡាយហើយហ្ន៎ ។ បទថា **អហាយិ វត នោ** សេចក្ដីថា វល្លិនោះ របស់ពួកយើងវិនាសទៅហើយក្នុងកាលឥឡូវនេះ ។

[ ៥៩ ] បទថា **អកដ្ឋបាកោ** សេចក្ដីថា កើតឡើងឯងលើដីដែលមិនបានភ្ជួររាស់ឡើយ ។ បទថា **អកណោ** ប្រែថា មិនមានកុណ្ឌកលាយឡំ ។ បទថា **អថុសោ** ប្រែថា មិនមានអង្កាម ។ បទថា **សុគន្ធោ** សេចក្ដីថា ក្លិនទិព្វ រមែងសាយកាយទៅ ។ បទថា **តណ្ឌុលប្ផលោ** សេចក្ដីថា រមែងបញ្ចេញផ្លែជាគ្រាប់អង្ករសបរិសុទ្ធ ។ បទថា **បក្កំ បដិរុឡ្ហំ** សេចក្ដីថា កន្លែងដែលគេប្រមូលក្នុងវេលាល្ងាច ក្នុងពេលព្រឹកឡើងក៏ដុះល្អ តាមប្រក្រតីទៀត

ទីដែលប្រូតមិនប្រាកដទេ ។ បទថា **ឆាបធានំ បញ្ញាយតិ** សេចក្តីថា រមែង ប្រាកដជាផ្ទៃ ដែលបួតមិនអស់ ហើយមិនចាំបាច់រក្សា បទថា **ឥត្ថិយា ច** សេចក្តីថា ភេទស្ត្រីរបស់ស្ត្រីក្នុងវេលាជាមនុស្ស ក្នុងជាតិមុនៗ ក៏ប្រាកដ ភេទប្រុសរបស់បុរស ក្នុងកាលមុនៗ នោះក៏ប្រាកដ ។ ពិតហើយ មាតុគ្រាម កាលត្រូវការភាវៈជាបុរស ក៏ព្យាយាមបំពេញធម៌ ដែលជាបច្ច័យនៃភាពជា បុរស ដោយលំដាប់ ក៏រមែងសម្រេចបាន ។ បុរសកាលត្រូវការភាពជាស្ត្រី ក៏ប្រព្រឹត្តកាមេសុមិច្ឆាចារ រមែងសម្រេចបាន ។ ក្នុងវេលានោះ តាមប្រក្រតី ភេទស្ត្រី រមែងប្រាកដឡើងដល់មាតុគ្រាម ភេទប្រុស ក៏ប្រាកដឡើងដល់ បុរស ។ បទថា **ឧបនិជ្ឈាយតំ** សេចក្តីថា សម្លឹងមើល គឺក្រឡេកមើល ។ បទថា **បរិឡាហោ** បានដល់ ពេលរាលដោយអំណាចរាគៈ ។ បទថា **សេដ្ឋី** បានដល់ ផេះ ។ បទថា **និព្ពុយ្ហមានាយ** សេចក្តីថា នាំចេញទៅ ។

[ ៦០ ] បទថា **អធម្មសម្មតំ** សេចក្តីថា ការបោះអាចម៍ដីជាដើមនោះ សន្មតគ្នាថា មិនមែនជាធម៌ ។ បទថា **តទេតរហិ ធម្មសម្មតំ** សេចក្តីថា តែក្នុងកាលឥឡូវនេះ ការបោះអាចម៍ជាដើមនេះ សន្មតថា ជាធម៌ ។ ពួក ព្រាហ្មណ៍ទាំងឡាយ នាំគ្នាកាន់យកការបោះអាចម៍ជាដើមនោះថា ជាធម៌ត្រាច់ ទៅ ។ ពិតហើយ ក្នុងជនបទខ្លះ ពួកស្ត្រីទាំងឡាយឈ្លោះគ្នា រមែងពោល ថា ព្រោះហេតុអ្វី ទើបនាងពោល នាងមិនបានអ្វីសូម្បីត្រឹមតែអាចម៍ស្រស់ ។ បទថា **ធាតព្យតំ** បានដល់ ការសេព ។ បទថា **សន្និធិការកំ** បានដល់ ធ្វើការសន្សំ ។ បទថា **អធានានំ បញ្ញាយិត្ថ** សេចក្តីថា កន្លែងដែលប្រូត

ហើយ បានប្រាកដជារបស់ទទេ ។ បទថា **សណ្ឌសណ្ឌា** សេចក្តីថា ដុះជាគុម្ពៗ ដូចបង់ជាបាច់ក្នុងទីនីមួយៗ ។

[ ៦១ ] បទថា **មរិយាទំ ឋបេយ្យាម** សេចក្តីថា ពួកយើងនឹងបែងចែកស្រែគ្នា ។

[ ៦២ ] បទថា **យត្រ ហិ នាម** បានដល់ **យោ ហិ នាម** ។ ពីរបទថា **ទាណ្ឌេន បហរឹសុ** សេចក្តីថា សត្វទាំងនោះយកដៃវាយអ្នកដែលមិនស្តាប់ពាក្យខ្លួនដល់ ៣ ដង ។ បទថា **តទគ្គេ ខោ បន** ប្រែថា ព្រោះធ្វើហេតុនោះជាគ្រឿងសម្គាល់ ។ បទថា **ខីយិតព្វំ ខីយេយ្យ** អធិប្បាយថា គប្បីប្រកាសប្រាប់បុគ្គលដែលគួរប្រកាស គឺតិះដៀលបុគ្គលដែលគួរតិះដៀល បណ្តេញអ្នកដែលគួរបណ្តេញ ។ បទថា **យោ នេសំ សត្តោ** សេចក្តីថា បណ្តាសត្វទាំងនោះ សត្វពួកណា ។ សួរថា សត្វនោះជាអ្នកណា ឆ្លើយថា គឺព្រះពោធិសត្វនៃយើងទាំងឡាយ ។ ច្រើនបទថា **សាលីនំ ភាគំ អនុប្បទស្សាម** សេចក្តីថា យើងនឹងនាំស្រូវសាលីមកពីស្រែរបស់យើងម្នាក់មួយនាឡិៗ ហើយនឹងឲ្យចំណែកស្រូវសាលីដល់លោក លោកមិនចាំបាច់ធ្វើការងារអ្វី សូមលោកតាំងនៅក្នុងឋានៈជាប្រមុខរបស់យើងទាំងឡាយចុះ ។

[ ៦៣ ] បទថា **អក្ខរំ ឧបនិព្វត្តំ** សេចក្តីថា កើតបញ្ញត្តិវោហារដែលយល់គ្នាបានដោយការរាប់ ។ បទថា **ខត្តិយោ ខត្តិយោ** ដូច្នេះ ជាពាក្យដែលកើតឡើងទីពីរ ។ បទថា **អក្ខរំ** សេចក្តីថា មិនមែនចំពោះអក្ខរៈតែម៉្យាងប៉ុណ្ណោះ តែពួកសត្វទាំងនោះ នៅបានធ្វើការអភិសេកបុគ្គលនោះ ដោយការ

លើកតម្កើង ៣ ដងថា សូមឲ្យលោកជាធំក្នុងស្រែរបស់ពួកយើង ដូច្នេះ ។ បទថា **រញ្ជេតិ** ប្រែថា រមែងញុំាងអ្នកដទៃឲ្យមានសេចក្ដីសុខស្កប់ស្កល់ ។ បទថា **អគ្គញ្ញេន** សេចក្ដីថា ការកើតឡើងដោយអក្ខរៈ ដែលកើតឡើងក្នុងសម័យនៃលោកកើតឡើង ដែលសន្មតថា ប្រសើរ ឬសន្មតក្នុងចំណែកដ៏ប្រសើរ ។

[ ៦៤ ] បទថា **វីតង្គារា វីតធូមា** សេចក្ដីថា ប្រាសចាកផ្សែង និងរងើកភ្លើង ព្រោះមិនមានអាហារ ដែលនឹងគប្បីចម្អិន ហើយបរិភោគ ។ បទថា **បន្នមុសលា** សេចក្ដីថា មិនមានការបុក ព្រោះមិនមានអាហារ ដែលគប្បីបុក ហើយចម្អិន ។ បទថា **ឃាសមេសនា** សេចក្ដីថា ស្វែងរកយាគូ និងភត្តដោយអំណាចកិក្ខាចារ ។ បទថា **តមេនំ មនុស្សា ទិស្វា** សេចក្ដីថា ពួកមនុស្សទាំងនោះបានឃើញបុគ្គលទាំងនោះ ។ បទថា **អនភិសម្ភុនមានា** ប្រែថា អត់ទ្រាំមិនបាន គឺមិនអាចអត់ទ្រាំបាន ។ បទថា **គន្ថេ ករោន្តា** សេចក្ដីថា តាក់តែង គឺបង្រៀនត្រៃវេទ ។ បទថា **អច្ឆន្តិ** ប្រែថា រមែងអាស្រ័យនៅ ។ បាលីថា **អច្ចេន្តិ** ដូច្នេះក៏មាន ឯសេចក្ដីក៏ដូចគ្នា ។ បទថា **ហីនសម្មតំ** សេចក្ដីថា ម្នាលវាសេដ្ឋៈ ដោយសម័យនោះ ពាក្យថា ពួកព្រាហ្មណ៍ រមែងទ្រទ្រង់ចាំមន្ត្រ រមែងប្រាប់មន្ត្រ ដូច្នេះ ជាពាក្យសន្មតថាថោកទាប ។ បទថា **តទេតរហិ សេដ្ឋសម្មតំ** សេចក្ដីថា ឥឡូវនេះ ពាក្យថា ព្រាហ្មណ៍ទាំងឡាយ រមែងទ្រទ្រង់ចាំមន្ត្រ មានប្រមាណប៉ុណ្ណេះ រមែងពោលប្រាប់មន្ត្រ មានប្រមាណប៉ុណ្ណេះ ជាពាក្យសន្មតថា ប្រសើរ ។ បទថា **ព្រាហ្មណមណ្ឌលស្ស** បានដល់ ពួកព្រាហ្មណ៍ ។

[ ៦៥ ] បទថា **មេថុនំ ធម្មំ សមាចរាយ** ប្រែថា កាន់យកមេថុនធម្ម ។ ច្រើនបទថា **វិស្សុំ កម្មន្តេ បយោជេសុំ** សេចក្តីថា ពួកសត្វនាំគ្នាប្រកបការងារដែលមានឈ្មោះបោះសំឡេង គឺបានទទួលការលើកតម្កើង មានការចិញ្ចឹមគោនិងការធ្វើជំនួញជាដើម ។ បទថា **សុទ្ទា សុទ្ទា** នេះ អធិប្បាយថា ពួកសូទ្រៈទៅយ៉ាងគួរស្អប់ខ្ពើម គឺវិនាសធាប់ៗ ហៅថា **សុទ្ទំ សុទ្ទំ** ព្រោះការងារដែលប្រព្រឹត្តថោកទាប និងការងារដែលប្រព្រឹត្តបន្តិចបន្តួចនោះ ។

[ ៦៦ ] បទថា **អហុ ខោ** បានដល់ **ហោតិ ខោ** ។ បទថា **សកំ ធម្មំ គរហមានោ** សេចក្តីថា ក្សត្រអង្គខ្លះ តិះដៀលខត្តិយធម៌របស់ខ្លួនឯង យ៉ាងនេះថា បុគ្គលណាម្នាក់ក៏មិនអាចបរិសុទ្ធបាន ដោយគ្រាន់តែឲ្យលើកស្វេតច្ឆត្រ ។ ក្នុងគ្រប់បទក៏ន័យនេះ ។ ដោយបទនេះថា **ឥមេហិ ខោ វាសេដ្ឋា ចតូហិ មណ្ឌលេហិ** នេះ ព្រះមានព្រះភាគ ទ្រង់សម្តែងពាក្យនេះថា ពួកសមណៈរមែងមិនមានការបែងចែក ។ តែព្រោះបុគ្គលណា ក៏មិនអាចនឹងបរិសុទ្ធដោយជាតិបាន សេចក្តីបរិសុទ្ធិនឹងមាន ក៏ដោយបដិបទាប្រពៃរបស់ខ្លួនឯង ដូច្នោះ ការកើតរបស់ព្រះសមណៈ ទើបកើតឡើងបាន ដោយពួកទាំង ៤ នេះ ពួកទាំងឡាយនេះ រមែងអនុវត្តតាមពួកសមណៈ និងពួកដែលអនុវត្តតាមទាំងនោះ ក៏រមែងអនុវត្តតាមធម៌ប៉ុណ្ណោះ មិនអនុវត្តតាមអធម៌ទេ សេចក្តីពិត ពួកសត្វទាំងឡាយអាស្រ័យពួកសមណៈ បំពេញសម្មាបដិបទា រមែងដល់នូវសេចក្តីបរិសុទ្ធិ ដូច្នេះ ។

[ ៦៧-៦៨ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់ធ្វើសេចក្តីនោះថា

បុគ្គលណាម្នាក់ ក៏មិនអាចបរិសុទ្ធតាមជាតិ តែពួកសត្វនឹងបរិសុទ្ធបាន ក៏ដោយការប្រព្រឹត្តប្រពៃប៉ុណ្ណោះ ដូច្នេះ យ៉ាងច្បាស់លាស់ ទើបផ្ដើមទេសនាថា **ខត្តិយោបិ ខោ វាសេដ្ឋា** ដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា **មិច្ឆាទិដ្ឋិ-កម្មសមាទានហេតុ** សេចក្ដីថា ព្រោះហេតុ គឺការសមាទានកម្ម ដោយអំណាចមិច្ឆាទិដ្ឋិ ។ម្យ៉ាងទៀត សេចក្ដីថា ព្រោះហេតុដែលសមាទាននូវមិច្ឆាទិដ្ឋិកម្ម ។

[ ៦៩ ] បទថា **ទ្វយការី** សេចក្ដីថា រមែងធ្វើកម្មទាំងពីរចំណែកយ៉ាងនេះ គឺវេលាខ្លះធ្វើកុសលកម្ម វេលាខ្លះធ្វើអកុសលកម្ម ។ បទថា **សុខ-ទុក្ខប្បដិសំវេទី** សេចក្ដីថា ធម្មតាថា ស្ថានទីដែលឲ្យផលព្រមគ្នាទាំងពីរចំណែកក្នុងពេលព្រមគ្នាមិនមាន ។ បុគ្គលណា បានធ្វើអកុសលកម្មច្រើន ធ្វើកុសលកម្មតិច បុគ្គលនោះអាស្រ័យកុសលកម្មនោះ ទៅកើតក្នុងត្រកូលក្សត្រ ឬត្រកូលព្រាហ្មណ៍ ។ ពេលនោះ អកុសលកម្មនោះ រមែងធ្វើឲ្យបុគ្គលនោះឲ្យជាបុគ្គលខ្វាក់ខ្លះ ខ្វិនខ្លះ ឆ្កួតលេលាខ្លះ បុគ្គលនោះរមែងមិនគួរដល់រាជសម្បត្តិ ឬបុគ្គលនោះនឹងជាយ៉ាងនេះហើយ ក្នុងពេលដែលបានទទួលការអភិសេកហើយ ក៏មិនអាចនឹងប្រើប្រាស់ភោគសម្បត្តិបាន ។ តមក ក្នុងវេលាស្លាប់របស់បុគ្គលនោះ ទាំងកុសលកម្ម និងអកុសលកម្មទាំងពីរនោះ ក៏ប្រាកដ ដូចអ្នកប្រដាល់ដែលមានកម្លាំងខ្លាំង ២ នាក់ ។ បណ្ដាកម្មទាំងពីរនោះ អកុសល-កម្មមានកម្លាំងខ្លាំងជាង ទើបហាមកុសលកម្ម ហើយឲ្យសត្វនោះកើតក្នុង

កំណើតសត្វតិរច្ឆាន ។ ចំណែកកុសលកម្ម ជាកម្មដែលសត្វត្រូវសោយក្នុងបវត្តិកាល កុសលកម្មនោះ រមែងកសាងដីរមែងផ្លខ្លះ សេះមង្គលខ្លះ គោមង្គលខ្លះ បុគ្គលនោះរមែងបានសោយសម្បត្តិនោះ ។ ព្រះមានព្រះភាគ ទ្រង់សំដៅយកកុសលកម្មនេះ ទើបត្រាស់ថា **សុខទុក្ខប្បដិសំវេទី ហោតិ** ដូច្នេះ ។

[ ៧០ ] បទថា **សត្តន្នំ ពោធិបក្ខិយានំ** សេចក្ដីថា ពោធិបក្ខិយធម៌ ៣៧ ប្រការ ដែលបែងចែកជា ៧ ពួក តាមលំដាប់ដោយចែកធម៌ប្រការដើមថា សតិប្បដ្ឋាន ៤ ។ បទថា **ភាវនមន្វាយ** សេចក្ដីថា ទៅតាមការនា អធិប្បាយថា បដិបត្តិការនា ។ បទថា **បរិនិព្វាតិ** សេចក្ដីថា រមែងរលត់ដោយការរលត់កិលេស ។

ព្រះមានព្រះភាគ ទ្រង់សម្ដែងវណ្ណៈ ៤ ដូចពណ៌នាមកដូច្នេះហើយ ទើបត្រឡប់មកសម្ដែង លើកយកព្រះខីណាស្រពអ្នកសម្រេចសច្ចៈទាំង ៤ បានហើយថា ជាអ្នកប្រសើរក្នុងពួកទេវតា និងមនុស្ស ។

[ ៧១ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងសេចក្ដីនោះធ្វើឲ្យមុតមាំ តាមទំនងការសម្ដែងពាក្យរបស់ព្រហ្មដែលសត្វលោកលើកតម្កើង ទើបត្រាស់ថា **ឥមេសំ ហិ វាសេដ្ឋា ចតុន្នំ វណ្ណានំ** ជាដើម ។ បទថា **ព្រាហ្មណោ វេស្សោ** ជាដើម បានអធិប្បាយពិស្ដារក្នុងអម្ពដ្ឋសូត្រហើយ ។ ព្រះមានព្រះភាគ ទ្រង់សម្ដែងវាទៈដែលជាគ្រឿងទម្លាយភាពជាអ្នកប្រសើរ

ដោយកថាមគ្គនេះត្រឹមតែប៉ុណ្ណេះ ដោយប្រការដូច្នេះ ហើយទ្រង់ត្រឡប់មកសម្តែងទេសនាឲ្យចប់ ដោយធម៌ដែលជាកំពូល គឺអរហត្ត ។

[ ៧២ ] បទថា **អត្តមនា វាសេដ្ឋភារទ្វាជា** សេចក្តីថា វាសេដ្ឋៈ និងភារទ្វាជសាមណេរទាំងពីរនោះ កំពុងបង្អោនរព្ទកតាមព្រះសូត្រនេះឯង បានសម្រេចអរហត្ត ព្រមដោយបដិសម្ភិទាទាំងឡាយ ដូច្នេះឯង ។ អដ្ឋកថា អគ្គញ្ញសូត្រ ក្នុងទីឃនិកាយ ឈ្មោះសុមង្គលវិលាសិនី ចប់ ។៚

**អគ្គញ្ញសូត្រ ចប់**

**សូត្រទី ៤ ចប់**

# សុត្តន្តបិដក

## សម្បសាទនីយសូត្រទី ៥

[ ៧៣ ] ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងព្រៃស្វាយ របស់បាវារិកសេដ្ឋី ទៀបក្រុងនាឡន្ទា ។ លំដាប់នោះឯង ព្រះសារីបុត្រមានអាយុ ចូលទៅគាល់ព្រះមានជោគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះសារីបុត្រមានអាយុ អង្គុយក្នុងទីដ៏សមគួរស្រេចហើយ ទើបក្រាបបង្គំទូលចំពោះព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជ្រះថ្លាចំពោះព្រះមានព្រះភាគយ៉ាងនេះថា សមណៈ ឬព្រាហ្មណ៍ឯទៀត ដែលមានញាណដ៏លើសលុបជាងព្រះមានព្រះភាគ ក្នុងការត្រាស់ដឹង ក្នុងកាលកន្លងទៅហើយ ក៏មិនមាន ក្នុងកាលខាងមុខក៏មិនមាន ក្នុងកាលឥឡូវនេះ ក៏មិនមាន ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលសារីបុត្រ អាសភិវាចា ( វាចាដ៏អង់អាច ) ដែលអ្នកបានពោលមកនេះ ហួសពេកណាស់ អ្នកបានកាន់យកនូវសេចក្តីដាច់ស្រេចហើយ បានទាំងបន្លឺសីហនាទថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជ្រះថ្លាចំពោះព្រះមានព្រះភាគយ៉ាងនេះថា សមណៈ ឬព្រាហ្មណ៍ឯទៀត ដែលមានញាណដ៏លើសលុប ជាងព្រះមានព្រះភាគ ក្នុងការត្រាស់ដឹង ក្នុងកាលកន្លងទៅហើយ ក៏មិនមាន ក្នុងកាលខាងមុខ ក៏មិនមាន ទាំងក្នុងកាលឥឡូវនេះ ក៏មិនមាន ។

[ ៧៤ ] ព្រះមានព្រះភាគត្រាស់ថា ម្នាលសារីបុត្រ ព្រះអរហន្តសម្មា-

សម្ពុទ្ធទាំងឡាយ ដែលកន្លងទៅហើយ អ្នកបានកំណត់នូវព្រះហឫទ័យរបស់ព្រះអរហន្តសម្មាសម្ពុទ្ធមានព្រះភាគទាំងអស់នោះ ដោយចិត្ត ( របស់ខ្លួន ) ថា ព្រះមានព្រះភាគទាំងនោះមានសីលយ៉ាងនេះក្តី ព្រះមានព្រះភាគទាំងនោះមានធម៌យ៉ាងនេះក្តី ព្រះមានព្រះភាគទាំងនោះ មានបញ្ញាយ៉ាងនេះក្តី ព្រះមានព្រះភាគទាំងនោះ មានវិហារធម៌យ៉ាងនេះក្តី ព្រះមានព្រះភាគទាំងនោះ មានវិមុត្តិយ៉ាងនេះក្តី ដូច្នេះៗ ដែរឬ ។ ព្រះសារីបុត្រក្រាបបង្គំទូលថា ដំណើរនុ៎ះមិនមែនដូច្នេះទេព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលសារីបុត្រ ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយ ដែលនឹងមានក្នុងខាងមុខ អ្នកបានកំណត់នូវព្រះហឫទ័យ របស់ព្រះអរហន្តសម្មាសម្ពុទ្ធមានព្រះភាគទាំងអស់នោះ ដោយចិត្ត ( របស់ខ្លួន ) ថា ព្រះមានព្រះភាគទាំងនោះ នឹងមានសីលយ៉ាងនេះក្តី នឹងមានធម៌យ៉ាងនេះក្តី ដែរឬ ។ នឹងមានបញ្ញាយ៉ាងនេះ ។ នឹងមានវិហារធម៌យ៉ាងនេះ ។ ព្រះមានព្រះភាគទាំងនោះ នឹងមានវិមុត្តិយ៉ាងនេះ ដូច្នេះៗ ដែរឬ ។ ព្រះសារីបុត្រក្រាបបង្គំទូលថា ដំណើរនុ៎ះមិនមែនដូច្នោះទេ ព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលសារីបុត្រ តថាគតដែលជាព្រះអរហន្តសម្មា-សម្ពុទ្ធ ក្នុងកាលឥឡូវនេះ អ្នកបានកំណត់នូវចិត្តរបស់តថាគត ដោយចិត្ត ( របស់ខ្លួន ) ថា ព្រះមានព្រះភាគ មានសីលយ៉ាងនេះក្តី មានធម៌យ៉ាងនេះក្តី ។ មានបញ្ញាយ៉ាងនេះ ។ មានវិហារធម៌យ៉ាងនេះ ។ ព្រះមានព្រះភាគមានវិមុត្តិយ៉ាងនេះ ដូច្នេះៗ ដែរឬ ។ ព្រះសារីបុត្រក្រាបបង្គំទូលថា ដំណើរនុ៎ះ មិនមែនដូច្នោះទេព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលសារីបុត្រ

អ្នកមិនមានចេតោបរិយញ្ញាណ គឺប្រាជ្ញាជាគ្រឿងកំណត់ដឹងនូវចិត្ត ក្នុងព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយនេះ ដែលជាអតីត អនាគត បច្ចុប្បន្នទេ កាលបើមិនមានញាណដូច្នេះ ហេតុអ្វីបានជាអ្នកនិយាយយ៉ាងនេះ ម្នាលសារីបុត្រ អ្នកបាននិយាយអាសភិវាចា ដែលអ្នកបានពោលមកនេះ ហួសពេកណាស់ អ្នកបានកាន់យកនូវសេចក្តីដាច់ស្រេច ហើយបានទាំងបន្លឺនូវសីហនាទថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជ្រះថ្លាក្នុងព្រះមានព្រះភាគ យ៉ាងនេះថា សមណៈ ឬព្រាហ្មណ៍ឯទៀត ដែលមានញាណដ៏លើសលុបជាងព្រះមានព្រះភាគ ក្នុងការត្រាស់ដឹង ក្នុងកាលកន្លងទៅហើយ ក៏មិនមាន ក្នុងកាលខាងមុខ ក៏មិនមាន ក្នុងកាលឥឡូវនេះ ក៏មិនមាន ។ ព្រះសារីបុត្រក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនមានចេតោបរិយញ្ញាណនេះ ក្នុងព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយ ដែលជាអតីត អនាគត បច្ចុប្បន្នទេ ប៉ុន្តែខ្ញុំព្រះអង្គបានដឹងតាមទំនងធម៌ បពិត្រព្រះអង្គដ៏ចម្រើន នគរបុងដែនរបស់ព្រះរាជា មានជើងបន្ទាយមាំ មានសសរខ្លោងទ្វារកំពែងមាំ មានប្រកទ្វារតែមួយ អ្នករក្សាទ្វារនៃនគរនោះ ជាបណ្ឌិតឈ្លាសវៃ មានប្រាជ្ញា ហាមប្រាមនូវពួកមនុស្សដែលខ្លួនមិនធ្លាប់ស្គាល់ ( មិនឲ្យចូលទៅ ) បើកឲ្យតែពួកមនុស្សដែលខ្លួនធ្លាប់ស្គាល់ ឲ្យចូលទៅ អ្នករក្សាទ្វារនោះ កាលដើរត្រួតត្រាមើលផ្លូវ កំពែងខាត់ខ្វែង ដោយជុំវិញនៃនគរនោះ ក៏មិនបានឃើញនូវទីតនៃកំពែង ឬចន្លោះនៃកំពែងឡើយ ដោយហោចទៅសូម្បីគ្រាន់តែឆ្មាចេញរួច ( ក៏ពុំមាន ) អ្នករក្សាទ្វារនោះ មានគំនិតយ៉ាងនេះថា ពួកសត្វដែលធំៗ ណា

មួយចូលមកកាន់នគរនេះក្តី ចេញទៅវិញក្តី សត្វទាំងអស់នោះ រមែងចូលមក ឬចេញទៅតាមទ្វារនេះប៉ុណ្ណោះ សេចក្តីនេះយ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានដឹងតាមទំនងធម៌ យ៉ាងនោះដែរថា ព្រះអរហន្ត-សម្មាសម្ពុទ្ធទាំងឡាយ ដែលកន្លងទៅហើយ ព្រះអរហន្តសម្មាសម្ពុទ្ធមានព្រះភាគទាំងនោះ ទ្រង់លះនូវនីវរណៈទាំង ៥ ប្រការ ជាឧបក្កិលេសរបស់ចិត្ត ជាគ្រឿងធ្វើបញ្ញាឲ្យទុព្វលភាព មានព្រះហឫទ័យតាំងខ្ជាប់ល្អ ក្នុងសតិប្បដ្ឋានទាំង ៤ បានចម្រើននូវសម្ពោជ្ឈង្គទាំង ៧ តាមគួរដល់សេចក្តីពិត ក៏បានត្រាស់ដឹងនូវព្រះអនុត្តរសម្មាសម្ពោធិញ្ញាណ បពិត្រព្រះអង្គដ៏ចម្រើន ទោះបីព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយ ដែលនឹងមានក្នុងអនាគតកាល ព្រះអរហន្តសម្មាសម្ពុទ្ធមានព្រះភាគទាំងអស់នោះ ទ្រង់លះនូវនីវរណៈទាំង ៥ ប្រការ ជាឧបក្កិលេសរបស់ចិត្ត ជាគ្រឿងធ្វើបញ្ញាឲ្យទុព្វលភាព មានព្រះហឫទ័យតាំងខ្ជាប់ល្អ ក្នុងសតិប្បដ្ឋានទាំង ៤ បានចម្រើននូវសម្ពោជ្ឈង្គទាំង ៧ តាមគួរដល់សេចក្តីពិត និងបានត្រាស់ដឹងនូវព្រះអនុត្តរសម្មាសម្ពោធិញ្ញាណ បពិត្រព្រះអង្គដ៏ចម្រើន ទោះបីព្រះមានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធក្នុងកាលឥឡូវនេះ ទ្រង់លះនូវនីវរណៈទាំង ៥ ប្រការ ជាឧបក្កិលេសរបស់ចិត្ត ជាគ្រឿងធ្វើបញ្ញាឲ្យទុព្វលភាព មានព្រះហឫទ័យតាំងខ្ជាប់ល្អ ក្នុងសតិប្បដ្ឋានទាំង ៤ បានចម្រើននូវសម្ពោជ្ឈង្គទាំង ៧ តាមគួរដល់សេចក្តីពិត បានត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានចូលមកគាល់ព្រះមានព្រះភាគ ក្នុងទីនេះ ដើម្បីស្តាប់ ។ បពិត្រ

ព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់សំដែងធម៌ដ៏ប្រសើរថ្លៃថ្លា ព្រម ទាំងគ្រឿងប្រៀបធៀបទាំងចំណែកខ្មៅ ទាំងចំណែកស ដល់ខ្ញុំព្រះអង្គ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់សំដែងធម៌ដ៏ប្រសើរថ្លៃថ្លា ព្រម ទាំងគ្រឿងប្រៀបធៀបទាំងចំណែកខ្មៅ ទាំងចំណែកស ដោយប្រការយ៉ាង ណាៗ ខ្ញុំព្រះអង្គបានដឹងក្នុងធម៌នោះ បានចូលចិត្តធម៌ពួកខ្លះ ក្នុងធម៌ទាំង-ឡាយ ក៏ជ្រះថ្លាក្នុងព្រះសាស្តា ដោយប្រការយ៉ាងនោះៗ ថា ព្រះមានព្រះ ភាគ ព្រះអង្គត្រាស់ដឹងប្រពៃហើយ ព្រះធម៌ដែលព្រះមានព្រះភាគពោលប្រពៃ ហើយ ព្រះសង្ឃ លោកប្រតិបត្តិប្រពៃហើយ ដូច្នេះ ។

[ ៧៥ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានតទៅទៀត ព្រះ មានព្រះភាគទ្រង់សំដែងធម៌ ក្នុងកុសលធម៌ទាំងឡាយ ដោយទេសនាណា ទេសនានុ៎ះ ប្រសើរក្រៃលែង បណ្តាធម៌ទាំងនោះ កុសលធម៌នោះតើដូចម្តេច កុសលធម៌នោះ គឺសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ។ បពិត្រព្រះអង្គ ដ៏ចម្រើន ភិក្ខុក្នុងសាសនានេះ ធ្វើឲ្យច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ មិន មានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយបញ្ញារបស់ខ្លួន ក្នុង បច្ចុប្បន្ន សម្រេចសម្រាន្តនៅដោយឥរិយាបថ ។ បពិត្រព្រះអង្គដ៏ចម្រើន នេះជាទេសនាដ៏ប្រសើរ ក្នុងកុសលធម៌ទាំងឡាយ ព្រះមានព្រះភាគទ្រង់ជ្រាប នូវទេសនានោះឥតមានសល់ កាលព្រះមានព្រះភាគ ជ្រាបច្បាស់នូវទេសនា នោះ ឥតមានសេសសល់ហើយ ក៏នឹងរកបុគ្គលដែលគួរដឹងច្បាស់ជាងព្រះ

អង្គនោះទៅទៀតគ្មាន សមណៈ ឬព្រាហ្មណ៍ឯទៀត កាលបើដឹង ក៏នឹងដឹងជាងព្រះមានព្រះភាគ ក្នុងកុសលធម៌ទាំងឡាយមិនមានដែរ ។

[ ៧៦ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានតទៅទៀត ព្រះមានព្រះភាគទ្រង់សម្តែងធម៌ ក្នុងអាយតនបណ្ណត្តិ គឺកិរិយាញុំាងបុគ្គលឲ្យស្គាល់នូវអាយតនៈទាំងឡាយ ដោយទេសនាណា ទេសនានុ៎ះ ប្រសើរក្រៃលែង ។ បពិត្រព្រះអង្គដ៏ចម្រើន អាយតនៈទាំងឡាយខាងក្នុង ៦ ខាងក្រៅ ៦ នេះ គឺចក្ខុ ១ រូប ១ សោតៈ ១ សទ្ទៈ ១ ឃានៈ ១ គន្ធៈ ១ ជិវ្ហា ១ រស ១ កាយ ១ ផោដ្ឋព្វៈ ១ មនោ ១ ធម្មៈ ១ ។ បពិត្រព្រះអង្គដ៏ចម្រើន នេះជាទេសនាដ៏ប្រសើរ ក្នុងអាយតនបណ្ណត្តិទាំងឡាយ ព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់នូវទេសនានោះ ឥតមានសល់ កាលព្រះមានព្រះភាគជ្រាបច្បាស់នូវទេសនានោះ ឥតមានសេសសល់ហើយ និងរកបុគ្គលដែលគួរដឹងច្បាស់ជាងព្រះអង្គទៅទៀតគ្មាន សមណៈ ឬព្រាហ្មណ៍ឯទៀត កាលបើដឹង ក៏នឹងដឹងឲ្យជាងព្រះមានព្រះភាគ ក្នុងអាយតនបណ្ណត្តិទាំង-ឡាយ ក៏មិនមានដែរ ។

[ ៧៧ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានតទៅទៀត ព្រះមានព្រះភាគទ្រង់សម្តែងធម៌ ក្នុងដំណើរចុះកាន់គភ៌ទាំងឡាយ ដោយទេសនាណា ទេសនានុ៎ះ ប្រសើរក្រៃលែង ។ បពិត្រព្រះអង្គដ៏ចម្រើន ដំណើរចុះកាន់គភ៌ទាំងឡាយនេះមាន ៤ យ៉ាង ។ បពិត្រព្រះអង្គដ៏ចម្រើន សត្វពួកខ្លះក្នុងលោកនេះចុះកាន់ផ្ទៃមាតា ក៏មិនដឹងខ្លួន ឋិតនៅក្នុងផ្ទៃមាតា ក៏មិនដឹងខ្លួន

ប្រសូតចេញចាកផ្ទៃមាតា ក៏មិនដឹងខ្លួន នេះជាដំណើរចុះកាន់គភ៌ទី ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានទៀត សត្វពួកខ្លះក្នុងលោកនេះ ចុះកាន់ផ្ទៃមាតា ក៏ដឹងខ្លួន តែឋិតនៅក្នុងផ្ទៃមាតា ក៏លែងដឹងខ្លួន ប្រសូតចេញចាកផ្ទៃមាតា ក៏លែងដឹងខ្លួន នេះជាដំណើរចុះកាន់គភ៌ទី ២ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានទៀត សត្វពួកខ្លះក្នុងលោកនេះ ចុះកាន់ផ្ទៃមាតា ក៏ដឹងខ្លួន ឋិតនៅក្នុងផ្ទៃមាតាក៏ដឹងខ្លួន លុះប្រសូតចេញចាកផ្ទៃមាតា ក៏លែងដឹងខ្លួនទៅវិញ នេះជាដំណើរចុះកាន់គភ៌ទី ៣ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានទៀត សត្វពួកខ្លះក្នុងលោកនេះ ចុះកាន់ផ្ទៃមាតា ក៏ដឹងខ្លួន ឋិតនៅក្នុងផ្ទៃមាតា ក៏ដឹងខ្លួន ប្រសូតចេញចាកផ្ទៃមាតា ក៏ដឹងខ្លួន នេះជាដំណើរចុះកាន់គភ៌ទី ៤ ។ បពិត្រព្រះអង្គដ៏ចម្រើន នេះជាទេសនាដ៏ប្រសើរក្នុងដំណើរចុះកាន់គភ៌ទាំងឡាយ ។

[ ៧៨ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានតទៅទៀត ព្រះមានព្រះភាគទ្រង់សម្តែងធម៌ ក្នុងអាទេសនវិធី គឺវិធីសម្រាប់ទាយទាំងឡាយ ដោយទេសនាណា ទេសនានុ៎ះ ប្រសើរក្រៃលែង ។ បពិត្រព្រះអង្គដ៏ចម្រើន អាទេសនវិធីនេះ មាន ៤ យ៉ាង ។ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលពួកខ្លះក្នុងលោកនេះ ចេះទាយតាមនិមិត្តថា ចិត្តរបស់អ្នកយ៉ាងនេះខ្លះ ចិត្តរបស់អ្នកមានប្រការយ៉ាងនេះខ្លះ ចិត្តរបស់អ្នកដូច្នេះខ្លះ ។ ទោះបីបុគ្គលនោះ ទាយច្រើនតទៅទៀត ចិត្តនោះក៏ដូច្នោះឯង មិនមែនជាយ៉ាងដទៃទេ ។ នេះចាត់ជាអាទេសនវិធីទី ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានទៀត

បុគ្គលពួកខ្លះក្នុងលោកនេះ នឹងបានទាយតាមនិមិត្តក៏ទេ គ្រាន់តែស្តាប់សំឡេង ពួកមនុស្ស និងអមនុស្ស ឬទេវតាទាំងឡាយ ហើយទើបទាយថា ចិត្តរបស់អ្នកយ៉ាងនេះខ្លះ ចិត្តរបស់អ្នកមានប្រការដូច្នេះខ្លះ ចិត្តរបស់អ្នកដូច្នេះខ្លះ ។ ទោះបីបុគ្គលនោះ ទាយច្រើនតទៅទៀត ចិត្តនោះក៏ដូច្នោះឯង មិនមែនទៅជាយ៉ាងដទៃវិញទេ ។ នេះចាត់ជាអាទេសនវិធីទី ២ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានទៀត បុគ្គលពួកខ្លះក្នុងលោកនេះ មិនបានទាយតាមនិមិត្ត ទាំងមិនបានស្តាប់សំឡេង ពួកមនុស្ស និងអមនុស្ស ឬទេវតាទាំងឡាយទេ ក៏ទាយត្រូវដែរ ប៉ុន្តែ លុះតែបានស្តាប់សំឡេង ដែលផ្សាយចេញអំពីសេចក្តីត្រិះរិះរបស់អ្នកដែលកំពុងនឹក កំពុងគិត ក៏ទាយថា ចិត្តរបស់អ្នកយ៉ាងនេះខ្លះ ចិត្តរបស់អ្នកមានប្រការដូច្នេះខ្លះ ចិត្តរបស់អ្នកដូច្នេះខ្លះ ទោះបីបុគ្គលនោះ ទាយច្រើនទៅទៀត ចិត្តនោះក៏ដូច្នោះឯង មិនមែនជាយ៉ាងដទៃទេ ។ នេះចាត់ជាអាទេសនវិធីទី ៣ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានទៀត បុគ្គលពួកខ្លះក្នុងលោកនេះ មិនបានទាយតាមនិមិត្ត ទាំងមិនបានស្តាប់សំឡេងនៃពួកមនុស្ស និងអមនុស្ស ឬទេវតាទាំងឡាយ ហើយទាយទេ នឹងថា បានស្តាប់សំឡេង ដែលផ្សាយចេញអំពីសេចក្តីត្រិះរិះរបស់អ្នកដែលកំពុងនឹក កំពុងគិត ហើយទាយក៏ទេដែរ តែថា បុគ្គលនោះកំណត់ដឹងនូវចិត្តរបស់អ្នកដែលចូលកាន់វិតក្កវិចារសមាធិ ដោយចិត្តរបស់ខ្លួនបានថា បុគ្គលដ៏ចម្រើននេះ តម្កល់ទុកនូវមនោសង្ខារ ដោយប្រការណា ចិត្តរបស់បុគ្គលនេះ នឹងនឹកដល់វិតក្កឈ្មោះនេះមិនមានចន្លោះ ទោះបីបុគ្គលនោះទាយ

ច្រើនទៅទៀត ចិត្តនោះ ក៏ដូច្នោះឯង មិនមែនជាយ៉ាងដទៃទេ ។ បពិត្រព្រះអង្គដ៏ចម្រើន នេះចាត់ជាអាទេសនវិធីទី ៤ ។ បពិត្រព្រះអង្គចម្រើន នេះជាទេសនាដ៏ប្រសើរ ក្នុងអាទេសនវិធីទាំងឡាយ ។

[ ៧៩ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានទៀត ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ក្នុងទស្សនសមាបត្តិទាំងឡាយ ។ បពិត្រព្រះអង្គដ៏ចម្រើន ទស្សនសមាបត្តិទាំងនេះមាន ៤ យ៉ាង ។ បពិត្រព្រះអង្គដ៏ចម្រើន សមណៈ ឬព្រាហ្មណ៍ពួកខ្លះក្នុងលោកនេះ អាស្រ័យសេចក្តីព្យាយាមជាគ្រឿងដុតកិលេស អាស្រ័យសេចក្តីព្យាយាមជាគ្រឿងតម្កល់មាំ អាស្រ័យសេចក្តីព្យាយាមជាគ្រឿងប្រកបរឿយៗ អាស្រ័យសេចក្តីមិនប្រមាទ អាស្រ័យនូវសេចក្តីធ្វើទុកក្នុងចិត្តដោយប្រពៃ កាលបើចិត្តខ្ជាប់ខ្ជួនហើយយ៉ាងណា ក៏បាននូវចេតោសមាធិ មានសភាពយ៉ាងនោះ ក៏ពិចារណាឃើញនូវកាយនេះឯង ខាងលើតាំងពីបាតជើងឡើងមក ខាងក្រោមតាំងពីចុងសក់ចុះទៅ មានស្បែករុំព័ទ្ធពីក្រៅ ដែលពេញទៅដោយរបស់មិនស្អាត មានប្រការផ្សេងៗ មាននៅក្នុងកាយនេះ គឺសក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង ទាច បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសម្បោរ ទឹករម្អិល ទឹកមូត្រ នេះជាទស្សនសមាបត្តិទី ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានទៀត សមណៈ ឬព្រាហ្មណ៍ពួកខ្លះក្នុងលោកនេះ អាស្រ័យសេចក្តីព្យាយាម ជាគ្រឿងដុត

កិលេស ។បេ។ កាលបើចិត្តខ្ជាប់ខ្ជួនហើយយ៉ាងណា ក៏បានទូវចេតោសមាធិ មានសភាពយ៉ាងនោះ ពិចារណាឃើញនូវកាយនេះឯង ខាងលើតាំងពីបាតជើងឡើងមក ខាងក្រោមតាំងពីចុងសក់ចុះទៅ មានស្បែករុំព័ទ្ធពីក្រៅ ដែលពេញដោយរបស់មិនស្អាតមានប្រការផ្សេងៗ មាននៅក្នុងកាយនេះ គឺសក់ រោម ។បេ។ ទឹករម្អិល ទឹកមូត្រ រហូតដល់ទៅពិចារណានូវពណ៌សម្បុរ សាច់ ឈាម ឆ្អឹងរបស់បុរស នេះជាទស្សនសមាបត្តិទី ២ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានទៀត សមណៈឬព្រាហ្មណ៍ពួកខ្លះក្នុងលោកនេះ អាស្រ័យសេចក្តីព្យាយាមជាគ្រឿងដុតកិលេស ។បេ។ កាលបើចិត្តខ្ជាប់ខ្ជួនហើយយ៉ាងណា ក៏បានទូវចេតោសមាធិ មានសភាពយ៉ាងនោះ ពិចារណាឃើញនូវកាយនេះឯង ខាងលើតាំងពីបាតជើងឡើងមក ខាងក្រោមតាំងពីចុងសក់ចុះទៅ មានស្បែករុំព័ទ្ធពីក្រៅ ដែលពេញដោយរបស់មិនស្អាត មានប្រការផ្សេងៗ មាននៅក្នុងកាយនេះ គឺសក់ រោម ។បេ។ ទឹករម្អិល ទឹកមូត្រ រហូតដល់ទៅពិចារណាពណ៌សម្បុរ សាច់ ឈាម ឆ្អឹងរបស់បុរស ទាំងដឹងច្បាស់នូវវិញ្ញាណសោតៈរបស់បុរសដែលមិនដាច់ចេញជាពីរចំណែក គឺតាំងនៅក្នុងលោកនេះ ១ ផ្នែក តាំងនៅក្នុងលោកខាងមុខ ១ ផ្នែក នេះជាទស្សនសមាបត្តិទី ៣ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានទៀត សមណៈ ឬព្រាហ្មណ៍ពួកខ្លះក្នុងលោកនេះ អាស្រ័យសេចក្តីព្យាយាម ជាគ្រឿងដុតកិលេស ។បេ។ ទឹករម្អិល ទឹកមូត្រ រហូតដល់ទៅពិចារណាពណ៌សម្បុរ សាច់ឈាម ឆ្អឹងរបស់បុរស ទាំងដឹងច្បាស់នូវ

វិញ្ញាណសោតៈរបស់បុរសដែលមិនដាច់ចេញជាពីរចំណែក គឺមិនតាំងនៅក្នុងលោកនេះ ១ ផ្នែក មិនតាំងនៅក្នុងលោកខាងមុខ ១ ផ្នែក នេះជាទស្សនសមាបត្តិទី ៤ ។ បពិត្រព្រះអង្គដ៏ចម្រើន នេះជាទេសនាដ៏ប្រសើរក្រៃលែងក្នុងទស្សនសមាបត្តិទាំងឡាយ ។

[ ៨០ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានតទៅទៀត ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ក្នុងបុគ្គលបញ្ញត្តិទាំងឡាយដោយទេសនាណា ទេសនានុ៎ះ ប្រសើរក្រៃលែង ។ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលទាំង ៧ ពួកនេះ គឺឧភតោភាគវិមុត្តបុគ្គល គឺបុគ្គលដែលរួចចាកចំណែកទាំងពីរ ១ បញ្ញាវិមុត្តបុគ្គល គឺបុគ្គលដែលរួចចាកអាសវៈដោយបញ្ញា ១ កាយសក្ខិបុគ្គល គឺបុគ្គលដែលធ្វើឲ្យច្បាស់នូវឈានផស្សៈ ដែលខ្លួនពាល់ត្រូវ ១ ទិដ្ឋិប្បត្តបុគ្គល គឺបុគ្គលដែលដល់នូវសេចក្តីឃើញច្បាស់ ១ សទ្ធាវិមុត្តបុគ្គល គឺបុគ្គលរួចចាកអាសវៈដោយសទ្ធា ១ ធម្មានុសារីបុគ្គល គឺបុគ្គលដែលរឭករឿយៗនូវ ( មគ្គដែលមានបញ្ញាជាប្រធាន ) ១ សទ្ធានុសារីបុគ្គល គឺបុគ្គលដែលរឭករឿយៗ នូវធម៌ គឺបញ្ញាដោយសទ្ធា ១ ។ បពិត្រព្រះអង្គដ៏ចម្រើន នេះជាទេសនាដ៏ប្រសើរក្រៃលែងក្នុងបុគ្គលបញ្ញត្តិទាំងឡាយ ។

[ ៨១ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានតទៅទៀត ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ ក្នុងបធានធម៌ គឺពោជ្ឈង្គទាំង ៧ ដោយទេសនាណា ទេសនានុ៎ះប្រសើរក្រៃលែង ។ បពិត្រព្រះអង្គដ៏ចម្រើន ពោជ្ឈង្គនេះមាន ៧ យ៉ាង គឺសតិសម្ពោជ្ឈង្គ ១ ធម្មវិចយសម្ពោជ្ឈង្គ ១ វីរិយ-

សម្ពោជ្ឈង្គ ១ បីតិសម្ពោជ្ឈង្គ ១ បស្សទ្ធិសម្ពោជ្ឈង្គ ១ សមាធិសម្ពោជ្ឈង្គ ១ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។ បពិត្រព្រះអង្គដ៏ចម្រើន នេះជាទេសនាដ៏ប្រសើរក្រៃលែងក្នុងបធានធម៌ទាំងឡាយ ។

[ ៨២ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានតទៅទៀត ព្រះមានព្រះភាគ ទ្រង់សំដែងធម៌ក្នុងបដិបទាទាំងឡាយ ដោយទេសនាណា ទេសនានុ៎ះប្រសើរក្រៃលែង ។ បពិត្រព្រះអង្គដ៏ចម្រើន បដិបទានេះមាន ៤ យ៉ាង គឺទុក្ខាបដិបទាទន្ធាភិញ្ញា ១ ទុក្ខាបដិបទាខិប្បាភិញ្ញា ១ សុខាបដិបទាទន្ធាភិញ្ញា ១ សុខាបដិបទាខិប្បាភិញ្ញា ១ បពិត្រព្រះអង្គដ៏ចម្រើន បណ្តាបដិបទាទាំង ៤ នោះ បដិបទាណាប្រកបដោយសេចក្តីលំបាក ត្រាស់ដឹងបានដោយយឺតយូរ បពិត្រព្រះអង្គដ៏ចម្រើន បដិបទានេះឯង រមែងប្រាកដជាថោកទាបដោយចំណែកទាំងពីរ គឺប្រកបដោយសេចក្តីលំបាកផង យឺតយូរផង ។ បពិត្រព្រះអង្គដ៏ចម្រើន បណ្តាបដិបទាទាំងនោះ បដិបទាណាប្រកបដោយសេចក្តីលំបាក តែត្រាស់ដឹងបានដោយឆាប់ បពិត្រព្រះអង្គដ៏ចម្រើន បដិបទានេះឯងរមែងប្រាកដជាថោកទាប ព្រោះប្រកបដោយសេចក្តីលំបាក ។ បពិត្រព្រះអង្គដ៏ចម្រើន បណ្តាបដិបទាទាំងនោះ បដិបទាណាប្រកបដោយសេចក្តីងាយ តែត្រាស់ដឹងបានដោយយឺតយូរ បពិត្រព្រះអង្គដ៏ចម្រើន បដិបទានេះឯងរមែងប្រាកដជាថោកទាប ព្រោះត្រាស់ដឹងដោយយឺតយូរ ។ បពិត្រព្រះអង្គដ៏ចម្រើន បណ្តាបដិបទាទាំងនោះ បដិបទាណាប្រកបដោយសេចក្តីងាយ ទាំងត្រាស់ដឹងបានដោយឆាប់ បពិត្រព្រះអង្គដ៏ចម្រើន បដិបទានេះឯង

រមែងប្រាកដជាប្រសើរដោយចំណែកទាំងពីរ គឺប្រកបដោយសេចក្តីងាយផង ទាំងត្រាស់ដឹងបានដោយឆាប់ផង ។ បពិត្រព្រះអង្គដ៏ចម្រើន នេះជាទេសនាដ៏ប្រសើរក្នុងបដិបទាទាំងឡាយ ។

[ ៨៣ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានតទៅទៀត ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ក្នុងភស្សសមាចារ ( កិរិយាប្រព្រឹត្តល្អដោយវាចា ) ដោយទេសនាណា ទេសនានុ៎ះ ប្រសើរក្រៃលែង ។ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលពួកខ្លះក្នុងលោកនេះ មិននិយាយសម្តីប្រកបដោយមុសាវាទផង មិននិយាយពាក្យញុះញង់ ដែលធ្វើឲ្យគេបែកបាក់ផ្សេងពីគ្នាផង មិននិយាយនូវពាក្យដែលកើតអំពីការប្រណាំងប្រជែងផង ជាអ្នកមិនប្រាថ្នាចង់ឈ្នះ ពិចារណាដោយបញ្ញា ( ទើបពោលផង ) និយាយនូវសម្តីគួរឲ្យអ្នកផងយកទុកក្នុងហឫទ័យតាមកាលគួរផង ។ បពិត្រព្រះអង្គដ៏ចម្រើន នេះជាទេសនាដ៏ប្រសើរក្នុងភស្សសមាចារ ។

[ ៨៤ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានតទៅទៀត ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ក្នុងបុរិសសីលសមាចារ ដោយទេសនាណា ទេសនានុ៎ះ ប្រសើរក្រៃលែង ។ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមានសច្ចធម៌ផង មានសទ្ធាផង មិនកុហកផង មិននិយាយរួសរាយ( ហួសហេតុ )ផង មិននិយាយបញ្ឆិតបញ្ឆៀងផង មិននិយាយគំរាមគេផង មិននាំទៅនូវលាភដើម្បីលាភផង ជាអ្នកមានទ្វារគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយ ដឹងប្រមាណក្នុងភោជន៍ទាំងឡាយ ប្រព្រឹត្តស្មើ ប្រកបរឿយៗ

នូវសេចក្តីព្យាយាម ជាគ្រឿងភ្ញាក់រឭក មិនខ្ជិលច្រអូស ប្រារព្ធសេចក្តីព្យាយាម មានឈាន មានសតិ មានបដិភាណដ៏ល្អ មានគតិ គឺប្រាជ្ញាជាគ្រឿងស៊ុះទៅ មានប្រាជ្ញាជាគ្រឿងទ្រទ្រង់ មានគំនិត ជាអ្នកមិនជាប់ជក់នៅក្នុងកាមទាំងឡាយផង មានសតិផង មានប្រាជ្ញាខ្ជាប់ខ្ជួនផង ។ បពិត្រព្រះអង្គដ៏ចម្រើន នេះជាទេសនាដ៏ប្រសើរក្នុងបុរិសសីលសមាចារ ។

[ ៨៥ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានតទៅទៀត ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ក្នុងអនុសាសនវិធាទាំងឡាយ ដោយទេសនាណា ទេសនានុ៎ះប្រសើរក្រៃលែង ។ បពិត្រព្រះអង្គដ៏ចម្រើន អនុសាសនវិធានេះមាន ៤ យ៉ាង ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់ជ្រាបនូវបុគ្គលដទៃ ព្រោះទ្រង់ធ្វើទុកក្នុងព្រះហឫទ័យចំពោះព្រះអង្គថា បុគ្គលនេះកាលប្រតិបត្តិតាមគួរដល់ពាក្យប្រៀនប្រដៅ នឹងបានជាសោតាបន្នបុគ្គល ព្រោះអស់ទៅនៃសំយោជនៈទាំងឡាយ ៣ ប្រការ មានកិរិយាមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀងទាត់ មានកិរិយាត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់ជ្រាបនូវបុគ្គលដទៃ ព្រោះទ្រង់ធ្វើទុកក្នុងព្រះហឫទ័យចំពោះព្រះអង្គថា បុគ្គលនេះកាលប្រតិបត្តិតាមគួរដល់ពាក្យប្រៀនប្រដៅ នឹងបានជាសកទាគាមិបុគ្គលព្រោះអស់ទៅនៃសំយោជនៈទាំង ៣ ប្រការ នឹងស្រាលស្តើងចាករាគៈ ទោសៈ មោហៈ នឹងមកកាន់លោកនេះតែម្តងទៀត ទើបធ្វើនូវទីបំផុតនៃទុក្ខបាន ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់ជ្រាបនូវបុគ្គលដទៃ ព្រោះទ្រង់ធ្វើទុកក្នុងព្រះ

ហឫទ័យចំពោះព្រះអង្គថា បុគ្គលនេះ កាលប្រតិបត្តិតាមគួរដល់ពាក្យប្រៀនប្រដៅ នឹងបានជាឱបបាតិកៈ ( ជាអនាគាមិបុគ្គល ) ព្រោះអស់ទៅនៃសំយោជនៈទាំងឡាយជាចំណែកខាងក្រោម ៥ ប្រការ នឹងបរិនិព្វានក្នុងភពនោះ មិនត្រឡប់ចាកលោកនោះជាធម្មតា ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់ជ្រាបបុគ្គលដទៃ ព្រោះទ្រង់ធ្វើទុកក្នុងព្រះហឫទ័យចំពោះព្រះអង្គថា បុគ្គលនេះកាលប្រតិបត្តិតាមគួរដល់ពាក្យប្រៀនប្រដៅ នឹងធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយដោយបញ្ញារបស់ខ្លួនក្នុងបច្ចុប្បន្ននេះ ក៏សម្រេចសម្រាន្តនៅដោយឥរិយាបថ ១ ។ បពិត្រព្រះអង្គដ៏ចម្រើន នេះជាទេសនាដ៏ប្រសើរក្នុងអនុសាសនវិធាទាំងឡាយ ។

[ ៨៦ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានតទៅទៀត ព្រះមានព្រះភាគ ទ្រង់សម្ដែងធម៌ក្នុងវិមុត្តិញាណ របស់បុគ្គលដទៃដោយទេសនាណា ទេសនានុ៎ះប្រសើរក្រៃលែង ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់ជ្រាបបុគ្គលដទៃ ព្រោះទ្រង់ធ្វើទុកក្នុងព្រះហឫទ័យចំពោះព្រះអង្គថា បុគ្គលនេះនឹងបានជាសោតាបន្នបុគ្គល ព្រោះអស់ទៅនៃសំយោជនៈទាំង ៣ ប្រការ មានកិរិយាមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀង មានកិរិយាត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់ជ្រាបនូវបុគ្គលដទៃ ព្រោះទ្រង់ធ្វើទុកក្នុងព្រះហឫទ័យចំពោះព្រះអង្គថា បុគ្គលនេះជាសកទាគាមិបុគ្គល ព្រោះអស់ទៅនៃសំយោជនៈ ទាំង ៣ ប្រការ ទាំង

ស្រោលស្តើងចាករាគៈ ទោសៈ មោហៈ នឹងមកកាន់លោកនេះម្តងទៀត ទើប ធ្វើនូវទីបំផុតទុក្ខបាន ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់ជ្រាបនូវបុគ្គលដទៃ ព្រោះទ្រង់ធ្វើទុកក្នុងព្រះហឫទ័យចំពោះព្រះអង្គថា បុគ្គលនេះជាឱបបាតិកៈ ( ជាអនាគាមិបុគ្គល ) ព្រោះអស់ទៅនៃសំយោជនៈទាំង-ឡាយ ជាចំណែកខាងក្រោម ៥ ប្រការ នឹងបរិនិព្វានក្នុងភពនោះ មិនត្រឡប់ចាកលោកនោះជាធម្មតា ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់ជ្រាបនូវបុគ្គលដទៃ ព្រោះទ្រង់ធ្វើទុកក្នុងព្រះហឫទ័យចំពោះព្រះអង្គថា បុគ្គលនេះនឹងធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញារបស់ខ្លួនក្នុងបច្ចុប្បន្ននេះ សម្រេចសម្រាន្តនៅដោយឥរិយាបថ ១ ។ បពិត្រព្រះអង្គដ៏ចម្រើន នេះជាទេសនាដ៏ប្រសើរ ក្នុងវិមុត្តិញាណរបស់បុគ្គលដទៃ ។

[ ៨៧ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានតទៅទៀត ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ក្នុងសស្សតវាទទាំងឡាយ ដោយទេសនាណា ទេសនានោះប្រសើរក្រៃលែង ។ បពិត្រព្រះអង្គដ៏ចម្រើនសស្សតវាទនេះមាន ៣ យ៉ាង ។ បពិត្រព្រះអង្គដ៏ចម្រើន សមណៈ ឬព្រាហ្មណ៍ពួកខ្លះក្នុងលោកនេះអាស្រ័យសេចក្តីព្យាយាមដុតកិលេស ។បេ។ កាលបើចិត្តតាំងនៅមាំហើយ យ៉ាងណា ក៏បាននូវចេតោសមាធិ មានសភាពយ៉ាងនោះ រឭកជាតិដែលធ្លាប់អាស្រ័យនៅក្នុងកាលមុនជាច្រើនជាតិ គឺរឭកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិ

ខ្វះ ៤០ ជាតិខ្វះ ៥០ ជាតិខ្វះ ១០០ ជាតិខ្វះ ១០០០ ជាតិខ្វះ ១០០០០០ ជាតិខ្វះ ច្រើនជាង ១០០ ជាតិខ្វះ ច្រើនជាង ១០០០ ជាតិខ្វះ ច្រើនជាង ១០០០០០ ជាតិខ្វះ ដូច្នេះថា អាត្មាអញកើតក្នុងភពឯនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណេះ អាត្មាអញនោះ លុះច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងភពឯនោះ ដែលទៅកើតក្នុងភពនោះ អាត្មាអញមានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណេះ អាត្មាអញនោះលុះច្យុតចាកអត្តភាពនោះហើយ ទើបបានមកកើតក្នុងភពនេះ ។ បុគ្គលនោះរមែងរឭកនូវជាតិដែលធ្លាប់អាស្រ័យនៅក្នុងកាលមុន ជាច្រើនជាតិព្រមទាំងអាការ ព្រមទាំងឧទ្ទេសដោយប្រការដូច្នេះ បុគ្គលនោះនិយាយយ៉ាងនេះថា អាត្មាអញតែងដឹងនូវអតីតកាលថា លោកវិនាស ឬលោកចម្រើនដូច្នេះ ។ អាត្មាអញតែងដឹងនូវអនាគតកាលថា លោកនឹងវិនាស ឬលោកនឹងចម្រើនដូច្នេះ ។ បុគ្គលនោះនិយាយថា ខ្លួន និងលោកជាសភាពទៀងទាត់ ផុតពូជជារឋិតនៅដូចភ្នំ ឋិតនៅដូចសសរគោល ចំណែកសត្វទាំងឡាយនោះ តែងត្រាច់ទៅ អន្ទោលទៅ ច្យុត កើតមាននៅប្រាកដស្មើដូចសស្សតិវត្ថុ ។ នេះជាសស្សតវាទទី ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានទៀត សមណៈ ឬព្រាហ្មណ៍ពួកខ្លះក្នុងលោកនេះ អាស្រ័យសេចក្តីព្យាយាម ជាគ្រឿងដុតកិលេស ។បេ។ កាលបើចិត្តតម្កល់មាំហើយយ៉ាងណា ក៏បាននូវចេតោ-

សមាធិ មានសភាពយ៉ាងនោះ រឭកនូវជាតិដែលធ្លាប់អាស្រ័យនៅក្នុងកាលមុនជាច្រើនជាតិ គឺរឭកបាន ១ សំវដ្តកប្ប និងវិវដ្តកប្ប ( កប្បវិនាស និងកប្បចម្រើន ) ខ្លះ ២ សំវដ្តកប្ប និងវិវដ្តកប្បខ្លះ ៣ សំវដ្តកប្ប និងវិវដ្ត-កប្បខ្លះ ៤ សំវដ្តកប្ប និងវិវដ្តកប្បខ្លះ ៥ សំវដ្តកប្ប និងវិវដ្តកប្បខ្លះ ១០ សំវដ្តកប្ប និងវិវដ្តកប្បខ្លះថា អាត្មាអញបានកើតក្នុងភពឯនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណេះ អាត្មាអញនោះលុះច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងភពឯនោះ ដែលទៅកើតក្នុងភពនោះ អាត្មាអញមានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ ។បេ។ មានកំណត់អាយុប៉ុណ្ណេះ អាត្មាអញលុះច្យុតចាកអត្តភាពនោះហើយ ទើបបានមកកើតក្នុងភពនេះ ។ បុគ្គលនោះរមែងរឭកនូវជាតិដែលធ្លាប់អាស្រ័យនៅក្នុងកាលមុនជាច្រើនជាតិ ព្រមទាំងអាការ ព្រមទាំងឧទ្ទេសដោយប្រការដូច្នេះ បុគ្គលនោះនិយាយយ៉ាងនេះថា អាត្មាអញតែងដឹងនូវអតីតកាលថា លោកវិនាស ឬលោកចម្រើនដូច្នេះ ។ បុគ្គលនោះនិយាយថា អាត្មាអញតែងដឹងនូវអនាគតកាលថា លោកនឹងវិនាស ឬលោកនឹងចម្រើនដូច្នេះ ។ បុគ្គលនោះនិយាយថា ខ្លួន និងលោកជាសភាពទៀងទាត់ផុតពូជជារ បិតនៅដូចភ្នំ បិតនៅដូចសសរគោល ចំណែកសត្វទាំងឡាយនោះ តែងត្រាច់ទៅ អន្ទោលទៅ ច្យុត កើត មាននៅ ប្រាកដស្មើដូចសស្សតិវត្ថុ ។ នេះជាសស្សតវាទទី ២ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានទៀត សមណៈ ឬព្រាហ្មណ៍ពួកខ្លះក្នុង

លោកនេះ អាស្រ័យសេចក្ដីព្យាយាមជាគ្រឿងដុតកិលេស ។បេ។ កាលបើចិត្តតម្កល់នៅមាំហើយយ៉ាងណា ក៏បាននូវចេតោសមាធិ មានសភាពយ៉ាងនោះ រឭកនូវជាតិដែលធ្លាប់អាស្រ័យនៅក្នុងកាលមុនជាច្រើនជាតិ គឺរឭកបាន ១០ សំវដ្តកប្ប និងវិវដ្តកប្បខ្លះ ២០ សំវដ្តកប្ប និងវិវដ្តកប្បខ្លះ ៣០ សំវដ្តកប្ប និងវិវដ្តកប្បខ្លះ ៤០ សំវដ្តកប្ប និងវិវដ្តកប្បខ្លះថា អាត្មាអញបានកើតក្នុងភពឯនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណេះ អាត្មាអញនោះ លុះច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងភពឯនោះ ដែលទៅកើតក្នុងភពនោះ អាត្មាអញមានឈ្មោះយ៉ាងនេះ ។បេ។ បុគ្គលនោះរមែងរឭកនូវជាតិ ដែលធ្លាប់អាស្រ័យនៅក្នុងកាលមុន បានច្រើនជាតិ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ បុគ្គលនោះនិយាយយ៉ាងនេះថា អាត្មាអញតែងដឹងនូវអតីតកាលថា លោកវិនាសទៅខ្លះ ឬលោកចម្រើនឡើងខ្លះ ដូច្នេះ ។ អាត្មាតែងដឹងនូវអនាគតកាលថា លោកនឹងវិនាសទៅខ្លះ ឬលោកនឹងចម្រើនឡើងខ្លះដូច្នេះ ។ បុគ្គលនោះនិយាយថា ខ្លួន និងលោកជាសភាពទៀងទាត់ ផុតពូជជារ ឋិតនៅដូចជាភ្នំ ឋិតនៅដូចជាសសរគោល ចំណែកសត្វទាំងឡាយនោះ តែងត្រាច់ទៅ តែងអន្ទោលទៅ ច្យុតកើតមាននៅប្រាកដស្មើដូចជាសស្សតិវត្ថុ ។ បពិត្រព្រះអង្គដ៏ចម្រើន នេះជាសស្សតវាទទី ៣ ។ បពិត្រព្រះអង្គដ៏ចម្រើន នេះជាទេសនាដ៏ប្រសើរក្នុងសស្សតវាទទាំងឡាយ ។

[ ៨៨ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានតទៅទៀត ព្រះមានព្រះភាគ សម្តែងធម៌ក្នុងបុព្វេនិវាសានុស្សតិញ្ញាណ ដោយទេសនាណា ទេសនានុ៎ះប្រសើរក្រៃលែង ។ បពិត្រព្រះអង្គដ៏ចម្រើន សមណៈ ឬព្រាហ្មណ៍ពួកខ្លះក្នុងលោកនេះ អាស្រ័យនូវសេចក្តីព្យាយាមជាគ្រឿងដុតកិលេស ។បេ។ កាលបើចិត្តតម្កល់នៅមាំហើយយ៉ាងណា ក៏បាននូវចេតោសមាធិ មានសភាពយ៉ាងនោះ រឭកនូវជាតិដែលធ្លាប់អាស្រ័យនៅក្នុងកាលមុន ជាច្រើនជាតិ គឺរឭកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ ១០០ ជាតិខ្លះ ១០០០ ជាតិខ្លះ ១០០០០០ ជាតិខ្លះ រឭកបានច្រើនសំវដ្តកប្បខ្លះ ច្រើនវិវដ្តកប្បខ្លះ ច្រើនសំវដ្តកប្ប និងវិវដ្តកប្បខ្លះ ។បេ។ បុគ្គលនោះ រមែងរឭកនូវជាតិដែលធ្លាប់អាស្រ័យនៅក្នុងកាលមុន ជាច្រើនជាតិ ព្រមទាំងអាការព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀតឥតមានបុគ្គលណាមួយ អាចរាប់អត្តភាពរបស់ពួកសត្វ ដែលធ្លាប់កើតក្នុងរូបភព អរូបភព សញ្ញិភព អសញ្ញិភព និងនេវសញ្ញិនាសញ្ញិភព ដោយការរាប់បូក ឬរាប់ដោយគំនិតបានឡើយ ( បុគ្គលដែលបាននូវចេតោសមាធិនោះ ) ទើបរឭកនូវជាតិដែលធ្លាប់អាស្រ័យនៅក្នុងកាលមុន ជាច្រើនជាតិ ព្រមទាំងអាការ ព្រមទាំងឧទ្ទេសបាន ដោយប្រការដូច្នេះ ។ បពិត្រព្រះអង្គដ៏ចម្រើន នេះជាទេសនាដ៏ប្រសើរ ក្នុងបុព្វេនិវាសានុស្សតិញ្ញាណ ។

[ ៨៩ ]បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានតទៅទៀត ព្រះ

មានព្រះភាគ ទ្រង់សម្ដែងធម៌ក្នុងចុតូបបាតញ្ញាណ គឺញាណជាគ្រឿងដឹងនូវចុតិ និងបដិសន្ធិរបស់សត្វទាំងឡាយ ដោយទេសនាណា ទេសនានុ៎ះ ប្រសើរក្រៃលែង ។ បពិត្រព្រះអង្គដ៏ចម្រើន សមណៈ ឬព្រាហ្មណ៍ពួកខ្លះ ក្នុងលោកនេះ អាស្រ័យសេចក្ដីព្យាយាម ជាគ្រឿងដុតកិលេស ។បេ។ កាលបើចិត្តតម្កល់នៅមាំហើយយ៉ាងណា ក៏បាននូវចេតោសមាធិ មានសភាពយ៉ាងនោះ ឃើញនូវសត្វទាំងឡាយដែលច្យុត និងចាប់បដិសន្ធិ ទាបថោក និងឧត្ដម មានសណ្ឋានល្អ និងអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដោយចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធលើសលែងជាងចក្ខុរបស់មនុស្សសាមញ្ញ រមែងដឹងច្បាស់នូវសត្វទាំងឡាយដែលអន្ទោលទៅតាមកម្មថា អើហ្ន៎ សត្វទាំងនេះ ជាអ្នកប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត តិះដៀលនូវពួកព្រះអរិយបុគ្គល ប្រកាន់ខាងមិច្ឆាទិដ្ឋិ កាន់យកនូវកម្មជាមិច្ឆា-ទិដ្ឋិ សត្វទាំងនោះលុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ចំណែកខាងពួកសត្វទាំងនេះ ជាអ្នកប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត មិនតិះដៀលនូវពួកព្រះអរិយបុគ្គល ប្រកាន់ខាងសម្មាទិដ្ឋិ កាន់យកនូវកម្មជាសម្មាទិដ្ឋិ សត្វទាំងនោះលុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅ ក៏ទៅកើតក្នុងសុគតិសួគ៌ ទេវលោក ។ បុគ្គលនោះ រមែងឃើញនូវសត្វទាំងឡាយដែលច្យុត និងចាប់បដិសន្ធិ ថោកទាប និងឧត្ដម មានសណ្ឋានល្អ និងអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដោយចក្ខុជាទិព្វដ៏បរិសុទ្ធលើសលែង

ជាងចក្ខុរបស់មនុស្សសាមញ្ញ ដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្ម ដោយប្រការដូច្នេះ ។ បពិត្រព្រះអង្គដ៏ចម្រើន នេះជាទេសនាដ៏ប្រសើរ ក្នុងចុតូបបាតញ្ញាណ របស់សត្វទាំងឡាយ ។

[ ៩០ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានតទៅទៀត ព្រះមានព្រះភាគសម្តែងនូវធម៌ ក្នុងឥទ្ធិវិធា ( វិធីនៃឫទ្ធិ ) ទាំងឡាយ ដោយទេសនាណា ទេសនានុ៎ះប្រសើរក្រៃលែង ។ បពិត្រព្រះអង្គដ៏ចម្រើន ឥទ្ធិវិធាមាន ២ យ៉ាង ។ បពិត្រព្រះអង្គដ៏ចម្រើន ឫទ្ធិប្រកបដោយអាសវៈ ប្រកបដោយឧបធិ ព្រះអង្គមិនត្រាស់ហៅថា ឫទ្ធិរបស់ព្រះអរិយៈឡើយ ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ឫទ្ធិមិនមានអាសវៈមិនមានឧបធិ ទើបព្រះអង្គត្រាស់ថា ឫទ្ធិរបស់ព្រះអរិយៈ ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះឫទ្ធិប្រកបដោយអាសវៈ ប្រកបដោយឧបធិ ដែលព្រះអង្គមិនត្រាស់ថា ឫទ្ធិរបស់ព្រះអរិយៈនោះ តើដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន សមណៈ ឬព្រាហ្មណ៍ពួកខ្លះក្នុងលោកនេះ អាស្រ័យសេចក្តីព្យាយាម ជាគ្រឿងដុតកិលេស អាស្រ័យសេចក្តីព្យាយាម ជាគ្រឿងតម្កល់មាំ អាស្រ័យសេចក្តីព្យាយាម ជាគ្រឿងប្រកបរឿយៗ អាស្រ័យសេចក្តីមិនប្រមាទ អាស្រ័យសេចក្តីធ្វើទុកក្នុងចិត្តដោយប្រពៃ កាលបើចិត្តតម្កល់មាំហើយ យ៉ាងណា ក៏បាននូវចេតោសមាធិមានសភាពយ៉ាងនោះ បាននូវឥទ្ធិវិធាច្រើនប្រការ មនុស្សតែម្នាក់ ( និម្មិត ) ទៅជាមនុស្សច្រើននាក់ក៏បាន មនុស្សច្រើននាក់ ( និម្មិត ) ទៅជាមនុស្សម្នាក់ក៏បាន ដើរ ( ចេញពីខាងក្នុង ) ទៅកាន់ទីវាល ទីខាងក្រៅក៏បាន ដើរ

ទម្លុះទៅខាងក្រៅជញ្ជាំង ខាងក្រៅកំពែង ខាងក្រៅភ្នំក៏បាន ឥតមានទើស ទាល់ ដូចជាដើរទៅឯអាកាស មុជងើបក្នុងផែនដី ដូចជាមុជងើបក្នុងទឹកក៏បាន ដើរទៅលើទឹកមិនបែកធ្លាយ ដូចជាដើរលើផែនដីក៏បាន ពែនភ្នែនចង្រ្កម ឯ អាកាសដូចសត្វបក្សីក៏បាន ។ ស្ទាបអង្អែលចាប់ពាល់ព្រះចន្ទ និងព្រះអាទិត្យ នេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ដោយដៃខ្លួន ឯងក៏បាន ញ៉ាំងកាយឲ្យប្រព្រឹត្តទៅរហូតដល់ព្រហ្មលោកក៏បាន ។ បពិត្រ ព្រះអង្គដ៏ចម្រើន នេះឫទ្ធិប្រកបដោយអាសវៈ ប្រកបដោយឧបធិ ដែលមិន ហៅថា ឫទ្ធិរបស់ព្រះអរិយៈឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះឫទ្ធិមិនមាន អាសវៈ មិនមានឧបធិ ដែលហៅថាឫទ្ធិរបស់ព្រះអរិយៈនោះ តើដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន បើភិក្ខុក្នុងសាសនានេះ ប្រាថ្នាថា អាត្មាអញគប្បីជា អ្នកសម្គាល់ថា មិនជាបដិកូល ក្នុងរបស់ជាបដិកូល ដូច្នេះ រមែងជាអ្នក សម្គាល់ថា មិនជាបដិកូលក្នុងរបស់ជាបដិកូលនោះ បើភិក្ខុប្រាថ្នាថា អាត្មា អញគប្បីជាអ្នកសម្គាល់ថា ជាបដិកូលក្នុងរបស់មិនជាបដិកូល ដូច្នេះ រមែង ជាអ្នកសម្គាល់ថា ជាបដិកូលក្នុងរបស់មិនជាបដិកូលនោះ បើភិក្ខុប្រាថ្នាថា អាត្មាអញគប្បីជាអ្នកសម្គាល់ថា មិនជាបដិកូលក្នុងរបស់ជាបដិកូល និងមិន ជាបដិកូល ដូច្នេះ រមែងជាអ្នកសម្គាល់ថា មិនជាបដិកូលក្នុងរបស់ជាបដិកូល និងមិនជាបដិកូលនោះ បើភិក្ខុប្រាថ្នាថា អាត្មាអញគប្បីជាអ្នកសម្គាល់ថាជា បដិកូល ក្នុងរបស់ជាបដិកូល និងមិនជាបដិកូល ដូច្នេះ រមែងជាអ្នកសម្គាល់ ថា ជាបដិកូលក្នុងរបស់ជាបដិកូល និងមិនមែនជាបដិកូលនោះ បើភិក្ខុប្រាថ្នា

ថា អាត្មាអញគប្បីជាអ្នកមានសតិ និងសម្បជញ្ញៈ វៀរនូវរបស់បដិកូលផង មិនមែនជារបស់បដិកូលផង ទាំងពីរយ៉ាងនោះចេញ ហើយជាអ្នកមានចិត្តព្រងើយ ដូច្នេះ រមែងជាអ្នកមានសតិ និងសម្បជញ្ញៈ មានចិត្តនៅព្រងើយក្នុងរបស់ជាបដិកូល និងមិនមែនជារបស់បដិកូលនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន នេះឯងជាឫទ្ធិមិនមានអាសវៈ មិនមានឧបធិ ដែលហៅថា ជាឫទ្ធិរបស់ព្រះអរិយៈ ។ បពិត្រព្រះអង្គដ៏ចម្រើន នេះជាទេសនាដ៏ប្រសើរក្នុងឥទ្ធិវិធាទាំងឡាយ ។ ព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់ នូវទេសនានោះ ឥតមានសេសសល់ កាលព្រះមានព្រះភាគជ្រាបច្បាស់នូវទេសនានោះ ឥតមានសល់ហើយ នឹងរកបុគ្គលដែលគួរដឹងច្បាស់ជាងព្រះអង្គនោះទៅទៀតគ្មាន សមណៈ ឬព្រាហ្មណ៍ឯទៀត កាលបើដឹង ក៏នឹងដឹងជាងព្រះមានព្រះភាគក្នុងឥទ្ធិវិធាទាំងឡាយ មិនមានឡើយ ។

[ ៩១ ] បពិត្រព្រះអង្គដ៏ចម្រើន អំពើណាដែលកុលបុត្រអ្នកមានសទ្ធា មានព្យាយាមមិនបន្ធូរបន្ថយ មានព្យាយាមខ្ជាប់ខ្ជួន គប្បីសម្រេចដោយព្យាយាមខ្ជាប់ខ្ជួនរបស់បុរស ដោយសេចក្តីប្រឹងប្រែងរបស់បុរស ដោយការខ្នះខ្នែងរបស់បុរស ដោយកិរិយានាំទៅនូវធុរៈរបស់បុរស អំពើនោះ ព្រះមានព្រះភាគ បានសម្រេចហើយដោយលំដាប់ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ មិនបានប្រកបនូវកាមសុខល្លិកានុយោគ ក្នុងកាមទាំងឡាយដ៏ទាបថោក ជារបស់អ្នកស្រុក របស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយៈ មិនប្រកបដោយប្រយោជន៍ផង មិនបានប្រកបនូវអត្តកិលមថានុយោគជាទុក្ខ មិន

មែនជារបស់ព្រះអរិយៈ មិនប្រកបដោយប្រយោជន៍ផង ព្រះមានព្រះភាគ ទ្រង់បានដូចសេចក្តីប្រាថ្នា បានដោយឥតលំបាក បានដោយធំទូលាយ នូវឈានទាំង ៤ ដ៏កន្លងបង់នូវកាមាវចរចិត្ត ជាសុខវិហារធម៌ ក្នុងបច្ចុប្បន្នផង ។ បពិត្រព្រះអង្គដ៏ចម្រើន បើមានអ្នកផង សួរខ្ញុំព្រះអង្គយ៉ាងនេះថា បពិត្រព្រះសារីបុត្រមានអាយុ ពួកសមណៈ ឬព្រាហ្មណ៍ឯទៀត ដែលកន្លងហួសទៅហើយ ជាអ្នកមានញាណដ៏លើសលុបជាងព្រះមានព្រះភាគ ក្នុងការត្រាស់ដឹង មានខ្លះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើមានអ្នកផងគេសួរយ៉ាងនេះ ខ្ញុំព្រះអង្គត្រូវប្រាប់គេថា មិនមានទេ ។ បើគេសួរថា បពិត្រព្រះសារីបុត្រមានអាយុ ពួកសមណៈ ឬព្រាហ្មណ៍ឯទៀត ក្នុងកាលដែលមិនទាន់មានមក ជាអ្នកមានញាណដ៏លើសលុប ជាងព្រះមានព្រះភាគ ក្នុងការត្រាស់ដឹង នឹងមានខ្លះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើមានអ្នកផងគេសួរយ៉ាងនេះ ខ្ញុំព្រះអង្គត្រូវប្រាប់គេថា មិនមានទេ ។ បើមានគេសួរថា បពិត្រព្រះសារីបុត្រមានអាយុ ពួកសមណៈ ឬព្រាហ្មណ៍ឯទៀត ក្នុងកាលឥឡូវនេះ ជាអ្នកមានញាណដ៏លើសលុប ជាងព្រះមានព្រះភាគក្នុងការត្រាស់ដឹង មានខ្លះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើមានអ្នកផងគេសួរយ៉ាងនេះ ខ្ញុំព្រះអង្គត្រូវប្រាប់គេថា មិនមានទេ ។ បពិត្រព្រះអង្គដ៏ចម្រើន បើមានអ្នកផង សួរខ្ញុំព្រះអង្គយ៉ាងនេះថា បពិត្រព្រះសារីបុត្រមានអាយុ ពួកសមណៈ ឬព្រាហ្មណ៍ឯទៀត ដែលកន្លងហួសទៅហើយ ជាអ្នកមានញាណស្មើៗ នឹងព្រះមានព្រះភាគ ក្នុងការត្រាស់ដឹង មានខ្លះដែរឬ ។ បពិត្រព្រះអង្គ

ដ៏ចម្រើន កាលបើមានអ្នកផងសួរយ៉ាងនេះ ខ្ញុំព្រះអង្គត្រូវប្រាប់គេថា បើយ៉ាង នោះមានមែន ។ បើមានគេសួរថា បពិត្រព្រះសារីបុត្រមានអាយុ ពួកសមណៈ ឬព្រាហ្មណ៍ឯទៀត ដែលមិនទាន់មានមក ជាអ្នកមានញាណស្មើៗ នឹងព្រះ មានព្រះភាគ ក្នុងការត្រាស់ដឹង មានខ្លះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើមានអ្នកផងសួរយ៉ាងនេះ ខ្ញុំព្រះអង្គត្រូវប្រាប់គេថា បើយ៉ាងនោះមាន មែន ។ បើមានគេសួរថា បពិត្រព្រះសារីបុត្រមានអាយុ ពួកសមណៈ ឬ ព្រាហ្មណ៍ឯទៀត ក្នុងកាលឥឡូវនេះ ជាអ្នកមានញាណស្មើៗ នឹងព្រះមាន ព្រះភាគ ក្នុងការត្រាស់ដឹង មានដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើ មានអ្នកផងសួរយ៉ាងនេះ ខ្ញុំព្រះអង្គត្រូវប្រាប់គេថា មិនមានទេ ។ បពិត្រ ព្រះអង្គដ៏ចម្រើន បើមានអ្នកផងសួរយ៉ាងនេះថា ព្រះសារីបុត្រមានអាយុ ព្រោះហេតុអ្វីបានជាដឹងខ្លះ មិនដឹងខ្លះ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើ មានអ្នកផងសួរយ៉ាងនេះ ខ្ញុំព្រះអង្គត្រូវព្យាករយ៉ាងនេះថា ម្នាលអ្នកមាន អាយុ ពាក្យនេះ អាត្មាបានស្តាប់ចំពោះព្រះភក្ត្រ បានទទួលចំពោះព្រះភក្ត្រ ព្រះមានព្រះភាគយ៉ាងនេះថា ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយ ដែលកន្លង ទៅហើយ ក៏មានញាណស្មើៗ នឹងតថាគតក្នុងការត្រាស់ដឹងដូច្នេះ ម្នាលអ្នក មានអាយុ ពាក្យនេះ អាត្មាបានស្តាប់ចំពោះព្រះភក្ត្រ បានទទួលចំពោះព្រះ ភក្ត្រព្រះមានព្រះភាគមកហើយថា ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយ ក្នុង កាលមិនទាន់មានមក នឹងមានញាណស្មើៗ នឹងតថាគត ក្នុងការត្រាស់ដឹង ដូច្នេះ ។ ម្នាលអ្នកមានអាយុ ពាក្យនេះ អាត្មាបានស្តាប់ចំពោះព្រះភក្ត្រ បាន

ទទួលចំពោះព្រះភក្ត្រព្រះមានព្រះភាគ យ៉ាងនេះថា មានព្រះអរហន្តសម្មា-សម្ពុទ្ធទាំងឡាយ ២ ព្រះអង្គត្រាស់ឡើង ក្នុងលោកធាតុមួយ មិនមុន មិនក្រោយ ( ជំណាលគ្នា ) ដំណើរនេះ មិនមែនជាឋានៈ គឺមិនមានហេតុជាទំនងដូច្នោះទេ ។

[ ៩២ ] បពិត្រព្រះអង្គដ៏ចម្រើន ចុះកាលបើមានអ្នកផងសួរយ៉ាងនេះ ខ្ញុំព្រះអង្គក៏ឆ្លើយតបទៅនឹងគេយ៉ាងនេះ ឈ្មោះថា និយាយទៅតាមព្រះពុទ្ធ-វចនៈរបស់ព្រះមានព្រះភាគ មិនបានពោលបង្កាច់ព្រះមានព្រះភាគដោយពាក្យមិនពិត ឆ្លើយនូវធម៌សមគួរតាមធម៌ ទាំងវាទានុវាទ ( ការពោលតាមវាទៈ ) ណាមួយដែលប្រកបដោយហេតុ ក៏ឈ្មោះថា មិនមកកាន់ទីដែលគួរតិះដៀលដែរឬ ។ ព្រះមានព្រះភាគត្រាស់ថា អើ សារីបុត្រ កាលបើមានអ្នកផងសួរយ៉ាងនេះ អ្នកក៏ឆ្លើយតបទៅនឹងគេយ៉ាងនេះ ឈ្មោះថា និយាយតាមពាក្យរបស់តថាគត មិនបាននិយាយបង្កាច់តថាគត ដោយពាក្យមិនពិត ឆ្លើយនូវធម៌សមគួរដល់ធម៌ហើយ ទាំងវាទានុវាទណាមួយ ដែលប្រកបដោយហេតុ ក៏ឈ្មោះថា មិនបានមកកាន់ទី គួរតិះដៀលឡើយ ។

[ ៩៣ ] កាលព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ ទើបឧទាយីមានអាយុ ក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះអស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះមិនដែលមានសោះ អម្បាលព្រះតថាគត មានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ គង់តែមិនធ្វើព្រះអង្គឲ្យប្រាកដ ព្រោះព្រះតថាគត ទ្រង់មិនមាន

សេចក្តីប្រាថ្នា ទ្រង់សន្តោស មានព្រះហឫទ័យផូរផង់ចាកកិលេស បពិត្រព្រះអង្គដ៏ចម្រើន ពួកបរិព្វាជក ជាអន្យតិរ្ថិយក្រៅចាកធម៌វិន័យនេះ ( បើ ) ពិចារណាឃើញនូវធម៌មួយៗ ក្នុងខ្លួនហើយ ពួកបរិព្វាជកទាំងនោះ នឹងលើកទង់ ដើរប្រកាសប្រាប់គ្នា ដោយហេតុមានប្រមាណប៉ុណ្ណោះថា ( រកអ្នកស្មើនឹងយើងបាន ) បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះអស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះមិនដែលមានសោះ អម្បាលព្រះតថាគត មានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ គង់តែមិនធ្វើព្រះអង្គឲ្យប្រាកដ ព្រោះព្រះតថាគត ទ្រង់មិនមានសេចក្តីប្រាថ្នា ទ្រង់សន្តោស មានព្រះហឫទ័យផូរផង់ចាកកិលេស ។ ព្រះអង្គត្រាស់ថា មាលឧទាយី អ្នកចូរមើលចុះ អម្បាលដូចតថាគតមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ គង់តែមិនធ្វើខ្លួនឲ្យប្រាកដ ព្រោះតថាគត ជាអ្នកមិនមានសេចក្តីប្រាថ្នា ជាអ្នកសន្តោស មានចិត្តផូរផង់ចាកកិលេស ម្នាលឧទាយី ពួកបរិព្វាជក ជាអន្យតិរ្ថិយក្រៅចាកធម៌វិន័យនេះ បើពិចារណាឃើញនូវធម៌មួយៗ ក្នុងខ្លួនហើយ ពួកបរិព្វាជកនោះ នឹងលើកទង់ដើរប្រកាសប្រាប់គ្នា ដោយហេតុ មានប្រមាណប៉ុណ្ណោះថា ( រកអ្នកណាស្មើនឹងយើងបាន ) ម្នាលឧទាយី អ្នកចូរមើលចុះ អម្បាលតថាគត មានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ គង់តែមិនធ្វើខ្លួនឲ្យប្រាកដ ព្រោះតថាគត ជាអ្នកមិនមានសេចក្តីប្រាថ្នា ជាអ្នកសន្តោស មានចិត្តផូរផង់ចាកកិលេស ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅព្រះសារីបុត្រមានអាយុមកថា ម្នាលសារីបុត្រ ចូរអ្នកពោល

ធម្មបរិយាយនេះ ដល់ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិការឿយៗ ចុះ ម្នាល សារីបុត្រ ព្រោះថា សេចក្ដីសង្ស័យ ឬសេចក្ដីងឿងឆ្ងល់ចំពោះតថាគត នឹងមានមកដល់មោឃបុរសពួកណា សេចក្ដីសង្ស័យ ឬសេចក្ដីងឿងឆ្ងល់របស់មោឃបុរសពួកនោះ ចំពោះតថាគតនេះ នឹងសាបសូន្យទៅព្រោះបានស្ដាប់ធម្មបរិយាយនេះមិនខាន ។ ព្រះសារីបុត្រមានអាយុ ក៏សម្ដែងនូវអំណរនេះចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ ដោយប្រការដូច្នេះឯង ។ ព្រោះហេតុដូច្នោះ សូត្រនេះឈ្មោះថា សម្បសាទនីយសូត្រ ដោយវេយ្យាករណ៍នេះដូច្នេះឯង ។

## សម្បសាទនីយសូត្រទី ៥ ចប់

# អដ្ឋកថា
# សម្បសាទនីយសូត្រ

[ ៣៧ ] សម្បសាទនីយសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះ ។ ក្នុងសម្បសាទនីយសូត្រនោះ មានពណ៌នាបទដែលនៅមិនទាន់ជាក់ច្បាស់ ដូច្នេះ បទថា **នាឡន្ទាយំ** សេចក្ដីថា ជិតព្រះនគរ ដែលបានឈ្មោះថា **នាលន្ទា** ព្រះមានព្រះភាគ ទ្រង់បានធ្វើក្រុងនាលន្ទានោះ ឲ្យជាទីគោចរគ្រាម ។ បទថា **បាវារិកម្ពវនេ** សេចក្ដីថា ជាចម្ការស្វាយរបស់សេដ្ឋី អ្នកមានសំពត់រោមដ៏ទន់ ។

បានឮថា ចម្ការស្វាយនោះ ជាចម្ការរបស់សេដ្ឋីនោះ ។ សេដ្ឋីនោះបានស្ដាប់ព្រះធម៌ទេសនារបស់ព្រះមានព្រះភាគហើយ មានសេចក្ដីជ្រះថ្លាក្នុងព្រះមានព្រះភាគ បានកសាងវិហារដែលប្រដាប់ដោយកុដិ និងមណ្ឌបជាដើម ក្នុងឧទ្យាននោះ បង្អោនថ្វាយព្រះមានព្រះភាគ វិហារនោះ បានដល់ ការរាប់ថា បាវារិកម្ពវន ដូចជីវកម្ពវន ដូច្នោះ អធិប្បាយថា ព្រះមានព្រះភាគ ប្រថាប់នៅត្រង់បាវារិកម្ពវននោះ ។ ព្រះសារីបុត្រ បានក្រាបទូលពាក្យនេះចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្ដីជ្រះថ្លាក្នុងព្រះមានព្រះភាគយ៉ាងនេះ ។ សួរថា ព្រោះហេតុអ្វី ទើបព្រះថេរៈទូលយ៉ាងនេះ ឆ្លើយថា ដើម្បីប្រកាសសោមនស្សដែលកើតដល់ខ្លួន ។

ក្នុងរឿងនេះ មានការពោលតាមលំដាប់ដូចតទៅនេះ បានឮថា ក្នុងថ្ងៃនោះ ព្រះថេរៈជម្រះរាងកាយពីព្រឹកព្រលឹម ស្លៀកដណ្ដប់រៀបរយហើយ

កាន់បាត្រ ចីវរ នាំសេចក្ដីជ្រះថ្លាមកឲ្យកើតដល់ពួកទេវតា និងមនុស្ស ដោយឥរិយាបថ មានការឈានទៅខាងមុខជាដើម ដែលគួរជ្រះថ្លា ប្រាថ្នាបំពេញប្រយោជន៍ និងសេចក្ដីសុខដល់អ្នកក្រុងនាលន្ទា ទើបចូលទៅដើម្បីបិណ្ឌបាតក្នុងវេលាក្រោយភត្ត ក៏ត្រឡប់ពីបិណ្ឌបាតទៅវិហារវិញ ក៏សម្ដែងវត្តចំពោះព្រះសាស្ដា កាលព្រះសាស្ដាទ្រង់ចូលព្រះគន្ធកុដិហើយ ថ្វាយបង្គំព្រះសាស្ដាហើយត្រឡប់ទៅកាន់ទីសម្រាកពេលថ្ងៃរបស់ខ្លួន កាលសទ្ធិវិហារិក និងអន្តេវាសិកក្នុងទីនោះ នាំគ្នាសម្ដែងវត្តហើយចៀសទៅ ព្រះថេរៈបានបោសសម្អាតទីសម្រាកពេលថ្ងៃនោះ ហើយក្រាលបន្ទះស្បែក យកទឹកអំពីកុណ្ឌីស្រលាបដៃ និងជើងឲ្យត្រជាក់ ហើយអង្គុយពត់ភ្នែន ៣ ជាន់ ធ្វើការកំណត់វេលាហើយ ទើបចូលផលសមាបត្តិ ។ ចេញចាកសមាបត្តិតាមវេលាដែលបានកំណត់ទុកហើយ ក៏ផ្ដើមរឭកដល់គុណរបស់ខ្លួន ។ ពេលនោះ លោកកំពុងរឭកដល់គុណ សីលក៏បានមកប្រាកដ បន្ទាប់អំពីនោះ សមាធិ បញ្ញា វិមុត្តិ វិមុត្តិញាណទស្សនៈ បឋមជ្ឈាន ។បេ។ ចតុត្ថជ្ឈាន អាកាសានញ្ចាយតនសមាបត្តិ ។បេ។ នេវសញ្ញានាសញ្ញាយតនសមាបត្តិ ។បេ។ វិបស្សនាញាណ ។បេ។ ទិព្វចក្ខុញាណ ។បេ។ សោតាបត្តិមគ្គ សោតាបត្តិផល ។បេ។ អរហត្តមគ្គ អរហត្តផល អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា សាវកបារមីញាណ ក៏ប្រាកដឡើងតាមលំដាប់ ។ ចាប់ផ្ដើមតាំងពីនោះ ដែលលោកកំពុងរឭកគុណរបស់ខ្លួន ចាប់ផ្ដើមតាំងពីអភិនីហារដែលបាន (ធ្វើទុក) ទៀបបាទមូលរបស់ព្រះពុទ្ធទ្រង់ព្រះនាម

នាមថា អនោមទស្សី អស់ ១ អសង្ខេយ្យ និង ១ សែនកប្ប ដរាបដល់វេលាដែលកំពុងអង្គុយពែនភ្នែន គុណទាំងឡាយក៏បានប្រាកដ ។ ព្រះថេរៈពូកដល់គុណរបស់ខ្លួនដ៏ច្រើនយ៉ាងនេះ ក៏មិនអាចប្រមាណ ឬកំណត់នូវគុណទាំងឡាយបានឡើយ ។ លោកគិតថា ប្រមាណឬកំណត់នូវគុណទាំងឡាយរបស់ព្រះសាវក ដែលតាំងនៅក្នុងញាណចំណែកខ្លះ រមែងមិនមានដល់អញ តែអញបួសឧទ្ទិសព្រះសាស្តាអង្គណា ព្រះសាស្តាព្រះអង្គនោះ មានព្រះគុណដូចម្តេចហ្ន៎ ដូច្នេះហើយ ទើបផ្តើមរឭកដល់ព្រះគុណរបស់ព្រះទសពល ។ លោកបានអាស្រ័យ សីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញាណទស្សនៈ សតិប្បដ្ឋាន ៤ របស់ព្រះមានព្រះភាគ អាស្រ័យសម្មប្បធាន ៤ ឥទ្ធិបាទ ៤ មគ្គ ៤ ផល ៤ បដិសម្ភិទា ៤ យោនិបរិច្ឆេទកញ្ញាណ ៤ អរិយវង្ស ៤ របស់ព្រះទសពល ហើយផ្តើមរឭកដល់ព្រះគុណរបស់ព្រះទសពល ។ម្យ៉ាងទៀត ព្រះថេរៈអាស្រ័យអង្គរបស់បធាន ៥ សម្មាសមាធិមានអង្គ ៥ ឥន្ទ្រិយ ៥ ពល ៥ និស្សរណីយ ធាតុ ៥ វិមុត្តាយតនៈ ៥ បញ្ញាគ្រឿងសន្សំវិមុត្តិ ៥ សារាណីយធម៌ ៦ អនុស្សតិកម្មដ្ឋាន ៦ គារវៈ ៦ និស្សរណីយធាតុ ៦ សត្តវិហារធម៌ ៦ អនុត្តរិយៈ ៦ បញ្ញាដែលជាចំណែកនៃការត្រាស់ដឹង ៦ អភិញ្ញា ៦ អសាធារណញ្ញាណ ៦ អបរិហានិយធម៌ ៧ អរិយទ្រព្យ ៧ ពោជ្ឈង្គ ៧ សប្បុរិសធម៌ ៧ និទ្ទសវត្ថុ ( រឿងរ៉ាវរបស់ទេវាតា ) ៧ បញ្ញា ៧ ទក្ខិណេយ្យបុគ្គល ៧ ខីណាសវពល ៧ បញ្ញាបដិលាភហេតុ ៨ សម្មត្តធម៌ ៨ ការឈានកន្លងលោកធម៌ ៨ អារព្ភវត្ថុ ៨ អក្ខណទេសនា ៨ មហាបុរិស-

វិតក្ក ៨ អភិភាយតនៈ ៨ វិមោក្ខ ៨ ធម៌ ដែលជាមូលរបស់យោនិសោមនសិការ ៩ អង្គនៃសេចក្តីព្យាយាមដ៏បរិសុទ្ធ ៩ សត្តាវាសទេសនា ៩ អាឃាតបដិវិន័យ ៩ បញ្ញា ៩ នានត្តធម៌ ៩ អនុបុព្វវិហារ ៩ នាថករណធម៌ ១០ កសិណាយតនៈ ១០ កុសលកម្មបថ ១០ តថាគតពលៈ ១០ សម្មត្តធម៌ ១០ អរិយវាសធម៌ ១០ អសេក្ខធម៌ ១០ អានិសង្សមេត្តា ១១ ធម្មចក្រមានអាការ ១២ ធុតង្គគុណ ១៣ ពុទ្ធញាណ ១៤ ធម៌គ្រឿងអប់រំវិមុត្តិ ១៥ អានាបានស្សតិ ១៦ ពុទ្ធធម៌ ១៨ បច្ចវេក្ខណញ្ញាណ ១៩ ញាណវត្ថុ ៤៤ កុសលធម៌ជាង ៥០ ញាណវត្ថុ ៧៧ សមាបត្តិ ២៤ សែនកោដិ សញ្ចារិតមហាវជិរញ្ញាណ ហើយផ្តើមរឭកដល់គុណរបស់ព្រះទសពល ។

ព្រះសារីបុត្រអង្គុយក្នុងទីសម្រាកពេលថ្ងៃនោះឯង អាស្រ័យធម៌ ដែលជាក្រសែធម៌ដទៃទៀត ១៦ ប្រការ ដែលនឹងមានតទៅ ដោយព្រះបាលីថា **អបរំ បន ភន្តេ ឯតទានុត្តរិយំ** ទើបបានផ្តើមរឭកដល់ព្រះគុណរបស់ព្រះទសពល ។ ព្រះសារីបុត្រនោះរឭកដល់ព្រះគុណរបស់ព្រះទសពលយ៉ាងនេះថា ព្រះសាស្តានៃយើង ទ្រង់ជាបុគ្គលកំពូលក្នុងកុសលប្បញ្ញត្តិ កំពូលក្នុងអាយតនប្បញ្ញត្តិ កំពូលក្នុងការយាងចុះកាន់ព្រះគភ៌ កំពូលក្នុងវិធីសម្តែងធម៌ស្ទាក់ចិត្តអ្នកស្តាប់ កំពូលក្នុងទស្សនសម្បត្តិ កំពូលក្នុងបុគ្គលប្បញ្ញត្តិ កំពូលក្នុងបធាន កំពូលក្នុងបដិបទា កំពូលក្នុងភស្សសមាចារ កំពូលក្នុងបុរិសសីលសមាចារ កំពូលក្នុងអនុសាសនីវិធី កំពូលក្នុងបុគ្គលវិមុត្តិញ្ញាណ កំពូលក្នុងបុព្វេនិវាសញ្ញាណ កំពូលក្នុងទិព្វចក្ខុញ្ញាណ កំពូលក្នុងឥទ្ធិវិធី

កំពូលដោយធម៌នេះ ដូច្នេះ ក៏មិនឃើញទីបំផុត មិនឃើញប្រមាណនៃព្រះគុណទាំងឡាយរបស់ព្រះមានព្រះភាគបាន ។ ព្រះថេរៈមិនឃើញទីបំផុត មិនឃើញប្រមាណនៃគុណទាំងឡាយរបស់ខ្លួនមុន នឹងឃើញព្រះគុណទាំងឡាយរបស់ព្រះមានព្រះភាគបានដូចម្តេច ។

បុគ្គលណាមានបញ្ញាច្រើន និងមានញាណចាស់ក្លា បុគ្គលនោះ រមែងជឿពុទ្ធគុណយ៉ាងច្រើន ។ លោកិយមហាជន ក្អកក្តី កណ្តាស់ក្តី តាំងនៅក្នុងឧបនិស្ស័យរៀងៗ ខ្លួន រមែងរឭកដល់ព្រះគុណរបស់ព្រះពុទ្ធទាំងឡាយ ( ក្លាត់មាត់ ) ថា **នមោ ពុទ្ធានំ ។** ព្រះសោតាបន្នម្នាក់ រមែងជឿព្រះពុទ្ធគុណច្រើនជាងលោកិយមហាជនទាំងអស់ ។ ព្រះសកទាគាមីម្នាក់ ជឿព្រះពុទ្ធ-គុណច្រើនជាង ព្រះសោតាបន្នរាប់រយរាប់ពាន់ ។ ព្រះអនាគាមីម្នាក់ ជឿក្នុងព្រះពុទ្ធគុណច្រើនជាង ព្រះសកទាគាមី រាប់រយរាប់ពាន់ ។ ព្រះអរហន្តតែមួយអង្គ ជឿព្រះពុទ្ធគុណច្រើនជាងព្រះអនាគាមីរាប់រយរាប់ពាន់ ព្រះអសីតិ-មហាថេរៈ ជឿព្រះពុទ្ធគុណច្រើនជាងព្រះអរហន្តដ៏សេស ។ ព្រះមហាថេរៈ ៤ រូប ជឿព្រះពុទ្ធគុណច្រើនជាងព្រះអសីតិមហាថេរៈ ។ ព្រះអគ្គសាវកទាំងពីររូប ជឿព្រះពុទ្ធគុណច្រើនជាងព្រះមហាថេរៈទាំង ៤ រូប បណ្តាព្រះអគ្គ-សាវកទាំងពីរនោះ ព្រះសារីបុត្តត្ថេរ ជឿព្រះពុទ្ធគុណច្រើនជាង ព្រះមោគ្គល្លាន ។ ព្រះបច្ចេកពុទ្ធតែមួយព្រះអង្គ ក៏ជឿព្រះពុទ្ធគុណច្រើនជាង ព្រះសារីបុត្តត្ថេរ ព្រះសព្វញ្ញុពុទ្ធមួយអង្គប៉ុណ្ណោះ ជឿក្នុងព្រះពុទ្ធគុណច្រើនជាងព្រះបច្ចេកពុទ្ធទាំងឡាយ ដែលអង្គុយយកជាយសង្ឃាដី ប៉ះនឹងជាយសង្ឃាដី

ពេញផ្ទៃចក្រវាលទាំងមូល ហើយរឭកដល់ពុទ្ធគុណ ។

មហាជនវេញខ្សែទាំងឡាយ ដើម្បីចង់ដឹងថា មហាសមុទ្រ ជ្រៅ រាក់ប៉ុនណា ដូច្នេះ បណ្តាជនទាំងនោះ អ្នកខ្លះវេញបានមួយព្យាម អ្នកខ្លះវេញបាន ២ ព្យាម ។បេ។ អ្នកខ្លះ ១០ ព្យាម អ្នកខ្លះ ២០ ព្យាម អ្នកខ្លះ ៣០ ព្យាម អ្នកខ្លះ ៤០ ព្យាម អ្នកខ្លះ ៥០ ព្យាម អ្នកខ្លះ ១០០ ព្យាម អ្នកខ្លះបាន ១០០០ ព្យាម អ្នកខ្លះបាន ៨៤០០០ ព្យាម ជនទាំងនោះ នាំគ្នាចុះទូកហើយតាំងនៅត្រង់កណ្តាលមហាសមុទ្រ ឬលើក្តូខ្ពស់ជាដើម ហើយទម្លាក់ខ្សែរៀងៗខ្លួនចុះទៅ បណ្តាជនទាំងនោះ អ្នកណាមានខ្សែប្រវែងមួយព្យាម គេក៏ដឹងទឹកបាន ក្នុងទីប្រមាណមួយព្យាមប៉ុណ្ណោះ ។បេ។ បុគ្គលណាមានខ្សែប្រវែង ៨៤០០០ ព្យាម បុគ្គលនោះ រមែងដឹងទឹកបានក្នុងទីជម្រៅប្រមាណ ៨៤០០០ ព្យាមប៉ុណ្ណោះ តពីនោះទៅ រមែងមិនដឹងថា ទឹកក្នុងមហាសមុទ្រមានជម្រៅប៉ុនណា ដូច្នោះ ម្យ៉ាងទៀត ទឹកក្នុងមហាសមុទ្រ មិនមែនមានប្រមាណត្រឹមតែប៉ុណ្ណោះទេ សេចក្តីពិត រមែងមានច្រើនបំផុតប្រមាណមិនបាន ព្រោះមហាសមុទ្រ មានជម្រៅដល់ទៅ ៨៤០០០ យោជន៍ សេចក្តីនេះមានឧបមាយ៉ាងណា គប្បីជ្រាបព្រះពុទ្ធគុណ ដែលលោកិយមហាជនឃើញ ប្រៀបដូចទឹកដែលបុរសដឹងបានដោយខ្សែ គប្បីជ្រាបព្រះពុទ្ធគុណ មានឧបមេយ្យដូច្នោះ គឺតាំងពីមួយព្យាមដរាបដល់ ៩ ព្យាម គប្បីជ្រាបព្រះពុទ្ធគុណ ដែលលោកិយ-មហាជនឃើញ ប្រៀបដូចទឹកដែលបុរសដឹងបានដោយខ្សែតាំងអំពី ១ ព្យាមដរាបដល់ ៩ ព្យាម គប្បីជ្រាបព្រះពុទ្ធគុណ ដែលព្រះសោតាបន្នឃើញបាន

ប្រៀបដូចទឹកដែលបុរសដឹងបានក្នុងទីប្រមាណ ១០ ព្យាម ដោយខ្សែប្រវែង ១០ ព្យាម គប្បីជ្រាបព្រះពុទ្ធគុណ ដែលព្រះសកទាគាមីឃើញបាន ប្រៀបដូចទឹកដែលបុរសដឹងបានក្នុងទីជម្រៅ ២០ ព្យាមដោយខ្សែប្រវែង ២០ ព្យាម គប្បីជ្រាបព្រះពុទ្ធគុណ ដែលព្រះអនាគាមីឃើញបាន ប្រៀបដូចទឹកដែលបុរសដឹងបានក្នុងទីជម្រៅ ៣០ ព្យាម ដោយខ្សែប្រវែង ៣០ ព្យាម គប្បីជ្រាបព្រះពុទ្ធគុណ ដែលព្រះអរហន្តឃើញបាន ប្រៀបដូចទឹកដែលបុរសឃើញបានក្នុងទីជម្រៅ ៤០ ព្យាម ដោយខ្សែប្រវែង ៤០ ព្យាម គប្បីជ្រាបព្រះពុទ្ធគុណ ដែលព្រះអសីតិមហាថេរៈឃើញបាន ប្រៀបដូចទឹកដែលបុរសឃើញបានក្នុងទីជម្រៅ ៥០ ព្យាម ដោយខ្សែប្រវែង ៥០ ព្យាម គប្បីជ្រាបព្រះពុទ្ធគុណដែលព្រះមហាថេរៈ ៤ រូបឃើញបាន ប្រៀបដូចទឹកដែលបុរសឃើញបានក្នុងទីជម្រៅ ១០០ ព្យាម ដោយខ្សែប្រវែង ១០០ ព្យាម គប្បីជ្រាបព្រះពុទ្ធគុណដែលព្រះមហាមោគ្គល្លានឃើញបាន ប្រៀបដូចទឹកដែលបុរសឃើញបានក្នុងទីជម្រៅ ១០០០ ព្យាម ដោយខ្សែប្រវែង ១០០០ ព្យាម គប្បីជ្រាបព្រះពុទ្ធគុណ ដែលព្រះធម្មសេនាបតីសារីបុត្រឃើញបាន ប្រៀបដូចទឹកដែលបុរសដឹងបានក្នុងទីជម្រៅប្រមាណ ៨៤០០០ ព្យាម ដោយខ្សែប្រវែង ៨៤០០០ ព្យាម ក្នុងបណ្ដាជនទាំងនោះ ជនណាកាន់យកថា ទឹកក្នុងមហាសមុទ្រមិនមានត្រឹមប៉ុណ្ណេះ រមែងមិនមានទីបំផុតយ៉ាងណា ព្រះសារីបុត្រក៏ដូច្នោះដែរ តាំងនៅក្នុងសាវកបារមីញាណ រឭកដល់ព្រះគុណរបស់ព្រះទសពលដោយគន្លងនៃធម៌ គឺដោយដឹងតាមគ្នាមកអនុមាន កាន់យកដោយ

ន័យ ទើបជឿថា ព្រះពុទ្ធគុណមិនមានទីបំផុត មិនមានប្រមាណ ដូច្នេះ ។

ពិតហើយ ចំពោះព្រះពុទ្ធគុណ ដែលបុគ្គលគប្បីកាន់យកដោយគន្លងធម៌ មានច្រើនជាងព្រះពុទ្ធគុណដែលព្រះថេរៈឃើញហើយ ។ លោកអធិប្បាយថា ដូចអ្វី លោកអធិប្បាយថា បុរសម្នាក់យកប្រហោងម្ជុល ដួសយកទឹកអំពីទន្លេឈ្មោះចន្ទភាគា ដែលកំពុងហូរក្ដួចស្ពានទីដល់ ១៨ យោជន៍ គឺត្រើយអាយ ៩ យោជន៍ ត្រើយនាយ ៩ យោជន៍ ទឹកដែលបុរសមិនបានដួសទៅ មានច្រើនជាងទឹកដែលបុរសយកគូទម្ជុលដួសទៅ ឬក៏បុរសគប្បីយកម្រាមដៃក្ដិះយកធូលីអំពីមហាប្រឹថពី ធូលីដ៏សេសនោះឯង មានច្រើនជាងធូលីដែលបុរសនោះយកម្រាមដៃក្ដិះបានមក ឬក៏បុរសគប្បីយកចុងម្រាមដៃទៅជ្រលក់ក្នុងទឹកមហាសមុទ្រ ទឹកដែលសល់នោះឯង មានច្រើនជាងទឹកជាប់នឹងចុងម្រាមដៃទៅ និងបុរសគប្បីចង្អុលទៅកាន់អាកាស ចំណែកអាកាសដ៏សេស មានច្រើនជាងអាកាសត្រង់ដែលបុរសចង្អុលនោះ ព្រះពុទ្ធគុណទាំងឡាយ ដែលព្រះថេរៈមិនឃើញនោះឯង គប្បីជ្រាបថា មានច្រើនជាងព្រះពុទ្ធគុណដែលព្រះថេរៈបានឃើញហើយ ដូច្នោះ សមដូចពាក្យដែលលោកពោលថា ទោះបីព្រះពុទ្ធមិនត្រាស់ពាក្យដទៃ គប្បីពណ៌នាចំពោះព្រះពុទ្ធគុណ រហូតដល់អស់ ១ កប្ប កប្បគប្បីអស់ទៅក្នុងកាលយូរអង្វែង តែគុណរបស់ព្រះតថាគតមិនអស់ទៅឡើយ ដូច្នេះ ។

កាលព្រះថេរៈរឭកដល់គុណរបស់ខ្លួន និងព្រះគុណរបស់ព្រះសាស្ដាយ៉ាងនេះ បីតិ និងសោមនស្សក៏ពោរពេញខាងក្នុង ដូចជំនន់ទឹកធំ ហូរលិច

មហានទីពីរខ្សែ ញ៉ាំងសរីរៈគ្រប់ចំណែកឲ្យពេញប្រៀប ដូចខ្យល់ធ្វើឲ្យថង់ខ្យល់ ប៉ោងពេញ ( និង ) ដូចខ្សែទឹកដែលហូរបែកបាញ់ឡើង ញ៉ាំងអន្លង់ទឹកធំឲ្យពេញ ។ ដូច្នោះ លំដាប់នោះ ព្រះថេរៈគិតថា អញដែលបានបួសក្នុងសម្នាក់ របស់ព្រះសាស្ដាដូច្នេះ រាប់ថា បានតាំងសេចក្ដីប្រាថ្នាទុកល្អហើយ ការបួស របស់អញបានល្អហើយ ។ បីតិ និងសោមនស្សដ៏មានកម្លាំងច្រើន បានកើត ដល់ព្រះថេរៈដែលកំពុងគិត យ៉ាងនេះ ។ លំដាប់នោះ ព្រះថេរៈ គិតថា អញគួរប្រាប់បីតិ និងសោមនស្សនេះ ដល់នរណាហ្ន៎ ដូច្នេះហើយ គិតទៀតថា សមណៈក្ដី ព្រាហ្មណ៍ក្ដី ទេវតាក្ដី មារក្ដី ព្រហ្មក្ដី មិនអាចនឹងទទួលយកសេចក្ដីជ្រះថ្លារបស់អញនេះ ធ្វើឲ្យសមបាន អញនឹងក្រាបទូល សោមនស្សនេះចំពោះព្រះសាស្ដាប៉ុណ្ណោះ ។ ព្រះសាស្ដាប៉ុណ្ណោះ ដែលអាចទទួលយក សោមនស្សរបស់អញបាន បីតិសោមនស្សរបស់អញនោះ សូមលើកទុកសិនចុះ កាលសមណៈ ដូចអញ ១ រយក្ដី ១ ពាន់ក្ដី ១ សែនក្ដី ប្រកាសសោមនស្ស ព្រះសាស្ដារបស់អញ នឹងគ្រប់គ្រងចិត្តជនទាំងពួង ទ្រង់អាចទទួលបីតិសោមនស្សនោះបាន បឹង ឬជ្រលងភ្នំ មិនអាចទទួលទឹកអំពីស្ទឹងធំ ឈ្មោះចន្ទភាគា ដែលកំពុងហូរជន់ លិចទៅដល់ ១៨ យោជន៍បាន មហាសមុទ្រ ប៉ុណ្ណោះ ដែលទទួលទឹកនោះបាន ។ ស្ទឹងធំឈ្មោះចន្ទភាគា សូមលើកទុកចុះ ស្ទឹងបែបនេះ ១ រយក្ដី ១ ពាន់ក្ដី ១ សែនក្ដី មហាសមុទ្ររមែងទទួលបាន ទាំងអស់ ការខ្វះ ឬការពេញ ដោយទឹកនោះ របស់មហាសមុទ្រនោះ មិនប្រាកដ យ៉ាងណា

ព្រះសាស្ដារបស់អញក៏ដូច្នោះដែរ កាលសមណៈដូចអញ ១ រយក្ដី ១ ពាន់ក្ដី ១ សែនក្ដី កំពុងប្រកាសបីតិសោមនស្ស ព្រះអង្គទ្រង់គ្រប់គ្រងចិត្តជនទាំងពួង អាចទទួលទុកបាន សមណព្រាហ្មណ៍ ដ៏សេសមិនអាចទទួលសោមនស្សរបស់អញបាន ដូចបឹង និងជ្រលងភ្នំ មិនអាចទទួលទឹកស្ទឹងធំ ឈ្មោះចន្ទភាគាបាន ដូច្នោះ ឈ្មោយចុះ អញនឹងក្រាបទូលបីតិសោមនស្សរបស់អញដល់ព្រះសាស្ដាប៉ុណ្ណោះ ដូច្នេះហើយ ទើបក្រោកឡើងរលាស់កម្រាលស្បែក កាន់ចូលទៅគាល់ព្រះសាស្ដាក្នុងវេលាល្ងាច ដែលជាវេលាផ្កាឈើជ្រុះចាកទង កាលនឹងប្រកាសសោមនស្សរបស់ខ្លួន ទើបទូលថា **ឯវំ បសន្នោ អហំ ភន្តេ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនេះ បទថា **ឯវំ បសន្នោ** សេចក្ដីថា មានការជឿកើតឡើងហើយយ៉ាងនេះ អធិប្បាយថា ខ្ញុំព្រះអង្គជឿយ៉ាងនេះ ។ បទថា **ភិយ្យោ-ភិញ្ញតរោ** សេចក្ដីថា ដឹងក្រៃលែងជាង ឬអ្នកមានសេចក្ដីដឹងក្រៃលែងជាង ។ អធិប្បាយថា អ្នកមានញាណក្រៃលែងជាង ។ បទថា **សម្ពោធិយំ** សេចក្ដីថា ក្នុងសព្វញ្ញុតញ្ញាណ ឬក្នុងអរហត្តមគ្គញ្ញាណ ។ ព្រោះថា ព្រះពុទ្ធគុណទាំងឡាយ មិនមានចំណែកមួយផ្សេងដោយឡែក លោកកាន់យកដោយអរហត្តមគ្គនុ៎ះឯង ។ ពិតហើយ អគ្គសាវកទាំងពីរ រមែងបានចំពោះសាវកបារមីញាណដោយអរហត្តមគ្គនុ៎ះឯង ។ ព្រះបច្ចេកពុទ្ធ រមែងបានបច្ចេកពោធិញ្ញាណ ព្រះពុទ្ធទាំងឡាយ រមែងបានទាំងព្រះសព្វញ្ញុតញ្ញាណ និងព្រះពុទ្ធគុណទាំងអស់ ។ ពិតហើយ ព្រោះព្រះសព្វញ្ញុតញ្ញាណជាដើមនោះ រមែងសម្រេចដល់លោក

ទាំងនោះ ដោយអរហត្តមគ្គនោះឯង ។ ដូច្នោះ ទើបអរហត្តមគ្គញាណ ឈ្មោះថា **សម្ពោធិ** ។ បុគ្គលដែលក្រៃលែងជាងព្រះមានព្រះភាគ ដោយអរហត្តមគ្គនោះមិនមាន ដោយហេតុនោះ ទើបព្រះសារីបុត្រទូលថា **ភគវតា ភិយ្យោភិញ្ញតរោ យទិទំ សម្ពោធិយំ** ដូច្នេះ ។ បទថា **ឧឡារា** គឺប្រសើរ ពិតហើយ **ឧឡារ** សព្ទនេះ មកក្នុងអត្ថថា ឆ្ងាញ់ ប្រសើរបរិបូណ៌ ។

មកក្នុងអត្ថថា ឆ្ងាញ់ ដូចក្នុងប្រយោគជាដើមថា **ឧឡារានិ ឧឡារានិ ខាទនីយានិ ខាទន្តិ** ជួនកាលទំពាស៊ីនូវខាទនីយៈទាំងឡាយដ៏ឆ្ងាញ់ក្រៃលែង ។ មកក្នុងអត្ថថា ប្រសើរ ដូចក្នុងប្រយោគជាដើមថា **ឧឡារាយ ខលុ ភវំ វច្ឆាយនោ សមណំ គោតមំ បសំសាយ បសំសតិ** ម្តេចក៏វច្ឆាយនៈដ៏ចម្រើនពោលសរសើរព្រះសមណគោតម ដោយពាក្យសរសើរ ដ៏ប្រសើរដល់ម្ល៉េះ ។ មកក្នុងអត្ថថា បរិបូណ៌ ដូចក្នុងប្រយោគជាដើមថា **អប្បមាណោ ច ឧឡារោ ឱភាសោ** ទាំងពន្លឺដ៏បរិបូណ៌ ប្រមាណមិនបាន កន្លងលើសអានុភាពរបស់ទេវតាទាំងឡាយ ក៏កើតប្រាកដឡើងក្នុងលោក ដូច្នេះ ។ ក្នុងបាលីនេះ **ឧឡារ** សព្ទនោះ ប្រើក្នុងអត្ថថា ប្រសើរ ។

ដោយហេតុនោះ ទើបលោកពោលថា បទថា **ឧឡារា** ប្រែថា ប្រសើរ ។

បទថា **អាសភិ** សេចក្តីថា ជាវាចាមិនញាប់ញ័រ មិនរន្ធត់ ដូចជាវាចារបស់អ្នកអង់អាច ។ បទថា **ឯកំសោ គហិតោ** សេចក្តីថា កាន់យកចំណែកតែមួយ ដូចរឭកដឹងដោយញាណដោយប្រចក្ស មិនពោលព្រោះស្តាប់តាមគ្នាមក

ព្រោះជឿតាមអាចារ្យ ព្រោះជឿតាមការឮ ព្រោះអាងតម្រា ព្រោះត្រិះរិះតាមអាការ ព្រោះគាប់ចិត្តថា ត្រឹមត្រូវតាមការយល់ឃើញរបស់ខ្លួន ព្រោះហេតុនៃការដោយកខ្លួនឯង ឬព្រោះហេតុនៃការប៉ាន់ស្មាន អធិប្បាយថា លោកកាន់យកសន្និដ្ឋានកថាតែម្យ៉ាង ។ បទថា **សីហនាទោ** គឺការបន្លឺយ៉ាងប្រសើរ អធិប្បាយថា បន្លឺសំឡេងខ្លាំងដូចរាជសីហ៍ មិនមែនសំឡេងតិចៗ មិនមែនសំឡេងដូចស្នប់ ។

[ ៧៤ ] សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគ ទ្រង់ផ្ដើមទេសនាថា **កិន្នុ តេ សារិបុត្ត** ដូច្នេះ ។ ឆ្លើយថា ដើម្បីឲ្យលោកព្រមឲ្យសាកសួរបាន ព្រោះបុគ្គលខ្លះបន្លឺសីហនាទហើយ មិនអាចនឹងឆ្លើយពាក្យសាកសួរបាន ក្នុងការបន្លឺរបស់ខ្លួន ទាំងអត់ទ្រាំការបៀតបៀនមិនបាន រមែងដូចជាស្វាដែលជាប់ជ័រ ដូច្នោះ ។ ភ្លើងដែលឆេះសម្រាប់ដាំងមាស ប្រើបញ្ឆេះលោហៈដែលមិនបរិសុទ្ធយ៉ាងណា បុគ្គលនោះ ក៏ដូចជាភ្លើងដែលឆេះ ដូច្នោះ ។ បុគ្គលខ្លះកាលត្រូវសាកសួរក្នុងសីហនាទ រមែងអាចឆ្លើយបាន ទាំងអត់ធន់ចំពោះការបៀតបៀនបាន រមែងប្រសើរក្រៃលែងដូចមាសមិនមានទោស របស់ជាងមាស ដូច្នោះ ព្រះថេរៈក៏ដូច្នោះ ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបព្រះថេរៈនោះថា សារីបុត្រនេះ គួរដល់ការសួរនាំបាន ទើបទ្រង់ផ្ដើមទេសនា ដើម្បីឲ្យលោកព្រមឲ្យសួរនាំបានក្នុងការបន្លឺសីហនាទ ។

បណ្ដាបទទាំងនោះ បទថា **សព្វេ តេ** សេចក្ដីថា ព្រះពុទ្ធទាំងអស់នោះ ព្រះអង្គកំណត់ដឹងហើយ ។ ក្នុងបទជាដើមថា **ឯវំសីលា** ដូច្នេះ ព្រះមានព្រះភាគ

តែងត្រាស់សួរសីលជាដើម ដោយអំណាចសីល ទាំងដែលជាលោកិយ និង លោកុត្តរ ។ ពាក្យទាំងនោះ បានពោលពិស្តារមកហើយក្នុងមហាបទាន ។ ដោយបទថា **កឹ បន តេ សារីបុត្ត យេ តេ ភវិស្សន្តិ** នេះ ព្រះមានព្រះភាគ កាលត្រាស់សួរថា ព្រះពុទ្ធទាំងឡាយដែលមានក្នុងអតីតរលត់ទៅហើយ គឺ ដល់នូវភាពជាអ្នកមិនមានបញ្ញត្តិ បានដល់ រលត់ទៅដូចអណ្តាតប្រទីបដូច្នោះ កាលព្រះពុទ្ធរលត់ទៅ គឺដល់នូវភាពជាអ្នកមិនមានបញ្ញត្តិយ៉ាងនេះ អ្នកដឹង បានដូចម្តេច គុណរបស់ព្រះពុទ្ធក្នុងអនាគត អ្នកកំណត់ដឹងបានដោយចិត្ត របស់ខ្លួនដូចម្តេច ដូច្នេះ ទើបត្រាស់យ៉ាងនេះ ។ ដោយបទថា **កឹ បន តេ សារីបុត្ត អហំ ឯតរហិ** នេះ ព្រះមានព្រះភាគ កាលទ្រង់ត្រាស់សួរថា ព្រះ ពុទ្ធទាំងឡាយ សូម្បីនៅមិនទាន់មក គឺនៅមិនទាន់ប្រសូត នៅមិនទាន់កើត នៅមិនទាន់ឧប្បត្តិកឡើង អ្នកនឹងដឹងព្រះពុទ្ធទាំងនោះបានដូចម្តេច ព្រោះការ ដឹងដល់ព្រះពុទ្ធទាំងនោះ រមែងដូចជាការមើលស្នាមជើងក្នុងអាកាស ដែល មិនមានស្នាមជើងឡើយ ដូច្នោះ ។ ឥឡូវនេះ អ្នកនៅក្នុងវិហារជាមួយតថាគត ត្រាច់ភិក្ខាចាររួមគ្នា ក្នុងវេលាសម្តែងធម៌ អ្នកក៏អង្គុយនៅត្រង់ខាងស្តាំ (តថាគត) ឯគុណទាំងឡាយរបស់តថាគត អ្នកកំណត់ដឹងដោយចិត្តរបស់ខ្លួនហើយឬ ដូច្នេះហើយ ទើបត្រាស់សួរយ៉ាងនេះ ។ កាលព្រះមានព្រះភាគត្រាស់សួរ ហើយ ព្រះថេរៈក៏ក្រាបទូលបដិសេធថា ដំណើរនុ៎ះមិនដូច្នោះទេព្រះអង្គ ដូច្នេះ ។

សួរថា រឿងដែលព្រះថេរៈដឹងក៏មានខ្លះ រឿងដែលព្រះថេរៈមិនដឹងក៏ មានខ្លះ ព្រះថេរៈនោះ តែងធ្វើការជំទាស់ក្នុងទីដែលខ្លួនដឹង និងក្នុងទីដែលខ្លួនមិន

ដឹង ដូចម្តេច ឆ្លើយថា ក្នុងរឿងដែលខ្លួនដឹង ព្រះថេរៈមិនបានជំទាស់ទេ ក្នុងរឿងដែលខ្លួនមិនដឹង ទើបព្រះថេរៈជំទាស់ ។ បានឮថា កាលផ្តើមការសាកសួរនុ៎ះឯង ព្រះថេរៈបានដឹងថា នេះមិនមែនជាការសាកសួរក្នុងសាវកបារមីញាណ នេះជាការសួរក្នុងព្រះសព្វញ្ញុតញ្ញាណ ដូច្នេះ ។ ព្រះថេរៈមិនធ្វើការជំទាស់ក្នុងសាវកបារមីញាណរបស់ខ្លួន រមែងធ្វើការជំទាស់ក្នុងព្រះសព្វញ្ញុតញ្ញាណ ក្នុងឋានៈដែលខ្លួនមិនដឹង ។ ដោយហេតុនេះ ទើបព្រះសារីបុត្រសម្តែងសេចក្តីនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនមានចេតោបរិយញ្ញាណនេះ ក្នុងព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយ ដែលជាអតីត អនាគត បច្ចុប្បន្នទេ ប៉ុន្តែ ខ្ញុំព្រះអង្គបានដឹងតាមទំនងធម៌ ដូច្នេះ ។ បទថា **ឯត្ថ** បាន ដល់ ក្នុងបណ្តាព្រះពុទ្ធទាំងឡាយដែលផ្សេងគ្នា មានព្រះពុទ្ធក្នុងអតីតទាំងនោះជាដើម ។ បទថា **អថ កិញ្ចរហិ** ព្រះមានព្រះភាគត្រាស់ថា កាលញាណយ៉ាងនេះមិនមាន ដូច្នេះ ព្រោះហេតុអ្វីហ្ន៎ ទើបអ្នកពោលពាក្យយ៉ាងនេះ ដូច្នេះ ។ បទថា **ធម្មន្វយោ** បានដល់ អនុមានញ្ញាណនៃធម៌ គឺសេចក្តីដឹងដោយប្រចក្សដល់ធម៌ដែលកើតឡើង អនុលោមតាមការសាកសួរ គឺការកាន់យកដោយន័យដែលខ្ញុំព្រះអង្គជ្រាបហើយ ។ ព្រោះតាំងនៅក្នុងសាវកបារមីញាណប៉ុណ្ណោះ ទើបព្រះថេរៈក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គជ្រាបដោយអាការនេះប៉ុណ្ណោះ ។ សេចក្តីពិត ការកាន់យកន័យរបស់ព្រះថេរៈមិនមានប្រមាណ និងមិនមានទីបំផុត ។ ប្រមាណ ឬទីបំផុតនៃព្រះសព្វញ្ញុតញ្ញាណមិនមាន យ៉ាងណា ការកាន់យកន័យរបស់ព្រះធម្មសេនាបតី ក៏មិនមានទី

បំផុត ឬប្រមាណ ដូច្នោះ ។

ដោយហេតុនោះ ព្រះថេរៈរមែងដឹងថា ព្រះមានព្រះភាគ ទ្រង់ជាយ៉ាង នេះ ដោយវិធីនេះ ជាសាស្តា ទ្រង់ជាបុគ្គលកំពូលដោយវិធីនេះ ។ ពិតហើយ ការកាន់យកន័យរបស់ព្រះថេរៈ ក៏ប្រព្រឹត្តទៅតាមគន្លងនៃព្រះសព្វញ្ញុតញ្ញាណ នោះឯង ។ ឥឡូវនេះ ព្រះថេរៈកាលនឹងសម្តែងសេចក្តីឧបមា ដើម្បីនឹងធ្វើការ កាន់យកន័យនោះឲ្យប្រាកដច្បាស់ ទើបក្រាបទូលថា **សេយ្យថាបិ ភន្តេ** ដូច្នេះ ជាដើម ។

ក្នុងបទថា **សេយ្យថាបិ ភន្តេ** នោះ មានវិនិច្ឆ័យថា ជើងកំពែង និង កំពែងដ៏រឹងមាំជាដើមរបស់ព្រះនគរក្នុងមជ្ឈិមបទេស ទឹងជារបស់រឹងមាំក៏ដោយ មិនរឹងមាំក៏ដោយ ឬថា មិនមានដោយប្រការទាំងពួង ភាពរង្កៀសភ័យពីពួក ចោរក៏មិនមាន ដូច្នោះ ព្រះថេរៈមិនកាន់យកមជ្ឈិមបទេសនោះ ទើបទូលថា **បច្ចន្តិមំ នគរំ** ដូច្នេះ ។ បទថា **ទឡ្ហុទ្ទាបំ** បានដល់ មានជើងកំពែងរឹងមាំ ។ បទថា **ទឡ្ហបាការតោរណំ** គឺមានកំពែងរឹងមាំ និងមានសសរខ្លោងទ្វារ កំពែងរឹងមាំ ។ សួរថា ព្រោះហេតុអ្វី ទើបព្រះថេរៈពោលថា **ឯកទ្វារំ** ដូច្នេះ ឆ្លើយថា ព្រោះក្នុងព្រះនគរដែលមានទ្វារច្រើន ត្រូវមានឆ្មាំទ្វារដែលឈ្លាសវៃ ច្រើន ក្នុងព្រះនគរដែលមានទ្វារតែមួយ ក៏សមគួរមានឆ្មាំទ្វារត្រឹមតែម្នាក់ ។ ម្យ៉ាងទៀត មិនមានអ្នកដទៃណានឹងប្រៀបផ្ទឹមបញ្ញារបស់ព្រះថេរៈបាន ដូច្នោះ ដើម្បីនឹងសម្តែងឆ្មាំទ្វារតែម្នាក់ប៉ុណ្ណោះ ដើម្បីប្រៀបធៀបភាពជាបណ្ឌិតរបស់ ខ្លួន ទើបព្រះថេរៈពោលថា **ឯកទ្វារំ** ដូច្នេះ ។ បទថា **បណ្ឌិតោ** បានដល់

*ប្រកបដោយភាពជាបណ្ឌិត ។ បទថា* **ព្យត្តោ** *គឺប្រកបដោយសេចក្តីវាងវៃ ឬជាអ្នកមានញាណចាស់ក្លា ។ បទថា* **មេធាវី** *គឺប្រកបដោយមេធា គឺបញ្ញា ដែលកើតឡើងតាមឋានៈ ។ បទថា* **អនុបរិយាយបថំ** *បានដល់ ផ្លូវកំពែង ដែលបាននាមថា* **អនុបរិយាយ** *( វិលជុំវិញទៅមកបាន ) ។ បទថា* **ទាការសន្ធឹ** *បានដល់ ទីដែលមិនមានឥដ្ឋពីរជុំភ្ជាប់គ្នា ។ បទថា* **ទាការវិវរំ** *គឺស្នាមធ្លុះរបស់កំពែង ។ បទថា* **ចេតសោ ឧបក្កិលេសេ** *សេចក្តីថា នីវរណៈទាំង ៥ រមែងញុំាងចិត្តឲ្យសៅហ្មង គឺរមែងធ្វើចិត្តឲ្យចូលទៅរកភាព សៅហ្មង ឲ្យក្តៅក្រហាយ បានដល់ រមែងបៀតបៀនចិត្ត ដូច្នោះ នីវរណៈ ៥ នោះ ទើបលោកហៅថា ការសៅហ្មងនៃចិត្ត ។ បទថា* **បញ្ញាយ ទុព្វលីករណេ** *សេចក្តីថា នីវរណៈទាំងឡាយ កាលកើតឡើង រមែងមិនឲ្យបញ្ញាដែល នៅមិនទាន់កើត ឲ្យកើតឡើងបាន ទាំងមិនព្រមឲ្យបញ្ញា ដែលកើតឡើង ហើយចម្រើនបាន ដូច្នោះ ទើបនីវរណៈទាំងនេះ លោកហៅថា ជាគ្រឿងធ្វើ បញ្ញាឲ្យខ្សោយកម្លាំង ។ បទថា* **សុប្បតិដ្ឋិតចិត្តា** *សេចក្តីថា ជាអ្នកមានចិត្ត តាំងមាំល្អក្នុងសតិប្បដ្ឋាន ៤ ។ បទថា* **សត្ត សម្ពោជ្ឈង្គេ យថាភូតំ** *សេចក្តីថា ចម្រើនពោជ្ឈង្គទាំង ៧ តាមសភាវៈ ។ ដោយបទថា* **អនុត្តរំ សម្មាសម្ពោធឹ** *ព្រះថេរៈសម្តែងថា ព្រះពុទ្ធទាំងឡាយ ទ្រង់ចាក់ធ្លុះព្រះអរហត្ត ឬព្រះសព្វញ្ញុតញ្ញាណ ។ ម្យ៉ាងទៀត ពាក្យថា សតិប្បដ្ឋាន ក្នុងទីនេះ បាន ដល់ វិបស្សនា ពោជ្ឈង្គ បានដល់ មគ្គ អនុត្តរសម្មាសម្ពោធិញ្ញាណ បានដល់*

ព្រះអរហត្ត ។ម្យ៉ាងទៀត ពាក្យថា សតិប្បដ្ឋាន បានដល់ វិបស្សនា សម្មា-សម្ពោធិញ្ញាណដែលលាយដោយពោជ្ឈង្គ បានដល់ ព្រះអរហត្តនោះឯង ។ ព្រះមហាសិវត្ថេរ អ្នកពោលទីឃនិកាយ ពោលថា កាលលោកកាន់យក សតិប្បដ្ឋានថាជាវិបស្សនា ហើយកាន់យកពោជ្ឈង្គថាជាមគ្គ និងជាព្រះសព្វញ្ញុតញ្ញាណហើយ គប្បីមានបញ្ហាដែលល្អ តែប្រការនេះ លោកមិនបាន កាន់យកយ៉ាងនេះ ដូច្នេះ ។ ព្រះថេរៈបានសម្តែងសេចក្តីផ្សេងគ្នាត្រង់ កណ្តាល ក្នុងការលះនីវរណៈ ក្នុងការចម្រើនសតិប្បដ្ឋាន និងក្នុងសម្ពោ-ធិញ្ញាណរបស់ព្រះសព្វញ្ញុពុទ្ធទាំងឡាយ ដូចសម្តែងមាស និងប្រាក់ ផ្សេងគ្នា ដូច្នោះ ដោយប្រការដូច្នេះ ។ បណ្ឌិតតាំងនៅក្នុងទីនេះ គប្បីប្រៀបធៀប ឧបមា ។ ពិហើយ ព្រះសារីបុត្តត្ថេរ សម្តែងបច្ចន្តនគរ ១ សម្តែងកំពែង ១ ផ្លូវដើរជុំវិញកំពែង ១ សម្តែងទ្វារ ១ សម្តែងឆ្មាំទ្វារដ៏ឈ្លាស ១ សម្តែងសត្វ ធំ ដែលចេញចូលក្នុងព្រះនគរ ១ សម្តែងភាពប្រាកដនៃសត្វទាំងនោះ ដល់ឆ្មាំ ទ្វារនោះ ១ ក្នុងសេចក្តីឧបមានេះ បើមានពាក្យសួរថា អ្វីដូចគ្នានឹងអ្វី ដូច្នេះ គប្បីឆ្លើយថា ព្រះនិព្វានដូចព្រះនគរ សីលដូចកំពែង ហិរិដូចផ្លូវដើរជុំវិញ កំពែង អរិយមគ្គដូចទ្វារ ព្រះធម្មសេនាបតីដូចឆ្មាំទ្វារដ៏ឈ្លាស ព្រះពុទ្ធទាំង-ឡាយ ដែលឧប្បត្តិកឡើងក្នុងអតីត អនាគត និងបច្ចុប្បន្ន ដូចសត្វធំដែល ចេញចូលក្នុងព្រះនគរ ភាពប្រាកដដោយសីល និងសមថៈជាដើម របស់ព្រះ ពុទ្ធទាំងឡាយ ទាំងក្នុងអតីត អនាគត និងបច្ចុប្បន្នដល់ព្រះសារីបុត្រ ដូចគ្នា នឹងភាពប្រាកដនៃសត្វទាំងឡាយនោះ ដល់ឆ្មាំទ្វារនោះឯង ។ ពាក្យមានប្រមាណ

ប៉ុណ្ណោះ ជាពាក្យដែលព្រះថេរៈឆ្លើយតបការសាកសួរនៃសីហនាទរបស់ខ្លួន ថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គតាំងនៅក្នុងសាវកបារមីញាណយ៉ាងនេះ រមែងដឹងបានដោយអាការដែលជាគន្លងធម៌ ដោយការកាន់យកន័យ ដូច្នេះ ។

សួរថា ព្រោះហេតុអ្វី ទើបព្រះថេរៈផ្តើមធម៌ទេសនានេះថា **ឥធាហំ ភន្តេ យេន ភគវា** ដូច្នេះ ឆ្លើយថា ដើម្បីសម្តែងភាពសម្រេចនៃសាវក-បារមីញាណ ។ ក្នុងរឿងនេះ មានអធិប្បាយដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ កាលបានសាវកបារមីញាណ បានចូលទៅរកសមណៈ ឬព្រាហ្មណ៍ សូម្បីបុគ្គលខ្លះទៀត ក្នុងបណ្តាអ្នកបួសក្រៅសាសនាទាំង ៩៥ នាក់ហើយ ទើបបានសាវកបារមីញាណ ក៏មិនមែន ខ្ញុំព្រះអង្គចូលទៅរកព្រះអង្គប៉ុណ្ណោះ ចូលទៅអង្គុយជិតព្រះអង្គប៉ុណ្ណោះ ទើបបាន ។ ក្នុងបណ្តាបទទាំងនោះ បទថា **ឥធ** ត្រឹមតែជានិបាត ។ បទថា **ឧបសង្កមឹ ធម្មស្សវនាយ** សេចក្តីថា ម្យ៉ាងទៀត ខ្ញុំព្រះអង្គកាលចូលទៅគាល់ព្រះអង្គនោះ មិនបានចូលទៅគាល់ព្រោះហេតុនៃបច្ច័យ មានចីវរជាដើម ប៉ុន្តែចូលទៅគាល់ដើម្បីស្តាប់ធម៌ ទៅគាល់យ៉ាងនេះហើយ ទើបបានសាវកបារមីញាណ ។ សួរថា ព្រះថេរៈចូលទៅគាល់ដើម្បីស្តាប់ធម៌ ក្នុងកាលណា ទើបបានសាវកបារមីញាណ ។ ឆ្លើយថា ព្រះថេរៈចូលទៅគាល់ក្នុងថ្ងៃដែលព្រះមានព្រះភាគទ្រង់សម្តែង វេទនាបរិគ្គហ-សូត្រដល់ទីឃនខបរិព្វាជកជាក្មួយ ត្រង់គុហាសូករខាតា ទើបបានសាវក-បារមីញាណក្នុងវេលានោះ ។ ពិតហើយ ក្នុងថ្ងៃនោះ ព្រះថេរៈកាន់ផ្លិតស្លឹកត្នោត ព័តថ្វាយព្រះមានព្រះភាគ បានស្តាប់ទេសនានោះហើយ បានញ៉ាំង

សាវកបារមីញាណឲ្យធ្លាក់នៅក្នុងកណ្តាប់ដៃក្នុងទីនោះឯង ។ បទថា **ឧត្តរុត្តរំ បណីតបណីតំ** សេចក្តីថា ព្រះអង្គទ្រង់សម្តែងយ៉ាងកំពូល និងយ៉ាងប្រណីតក្រៃលែងណាស់ ។ បទថា **កណ្ហសុក្កំ សប្បដិភាគំ** សេចក្តីថា ព្រះអង្គទ្រង់សម្តែងទាំងចំណែកខ្មៅ និងចំណែកស និងទ្រង់សម្តែងធម៌ចំណែកខ្មៅ និងចំណែកសនោះ ឲ្យជាបដិភាគចំពោះគ្នា គឺឲ្យជាបដិបក្ខចំពោះគ្នា ព្រះអង្គទ្រង់សម្តែងធម៌ចំណែកខ្មៅ និងចំណែកស ឲ្យជាបដិភាគគ្នាយ៉ាងនេះ គឺទ្រង់ហាមធម៌ចំណែកខ្មៅ សម្តែងចំណែកស និងហាមចំណែកស សម្តែងចំណែកខ្មៅ ។ ម្យ៉ាងទៀត ព្រះអង្គកាល ទ្រង់សម្តែងធម៌ចំណែកខ្មៅ ក៏ទ្រង់សម្តែងព្រមនឹងឧស្សាហៈ មួយអន្លើដោយវិបាក ។ កាលទ្រង់សម្តែងធម៌ចំណែកស ក៏ទ្រង់សម្តែងព្រមគ្នានឹងឧស្សាហៈ មួយអន្លើដោយវិបាក ។ ប្រើនបទនេះថា **តស្មឹ ធម្មេ អភិញ្ញា ឥធេកច្ចំ ធម្មំ ធម្មេសុ និដ្ឋមគមំ** សេចក្តីថា កាលព្រះអង្គទ្រង់សម្តែងធម៌នោះហើយ ខ្ញុំព្រះអង្គបានដឹងសាវកបារមីញាណ ដែលចាត់ជាធម៌ចំណែកខ្លះ បានដល់ ការសម្រេចក្នុងធម៌ទាំងឡាយ ។ សួរថា ក្នុងធម៌ពួកណា ។ ឆ្លើយថា ក្នុងសច្ចធម៌ ៤ ប្រការ ។ ក្នុងរឿងនេះ មានការសន្ទនារបស់ព្រះថេរៈដូចតទៅនេះ

ព្រះសុមនត្ថេរអ្នកនៅក្នុងកាឡវល្លិវិហារ ពោលមុនថា ឥឡូវនេះ មិនមានហេតុនៃការដល់សេចក្តីសម្រេចក្នុងសច្ចធម៌ ៤ ។ ពិតហើយ ក្នុងថ្ងៃដែលជួបព្រះអស្សជិមហាថេរៈនោះ ព្រះសារីបុត្រនោះ បានដល់នូវការសម្រេចក្នុងសច្ចធម៌ ៤ ដោយមគ្គទី ១ ក្នុងវេលាតមក បានដល់ សេចក្តីសម្រេចក្នុង

សច្ចធម៌ទាំង ៤ ដោយមគ្គ ៣ ខាងលើ ត្រង់ទ្វារគុហាសូករខាតា តែក្នុងទីនេះ លោកបានដល់នូវការសម្រេចក្នុងព្រះពុទ្ធគុណទាំងឡាយ ឈ្មោះថា សម្រេចក្នុងធម៌ទាំងឡាយ ។ ចំណែកព្រះចូឡសិវត្ថេរ អ្នកនៅក្នុងលោកន្តរវិហារ ពោលពាក្យទាំងអស់ដូចគ្នានោះឯង ហើយពោលទៀតថា ក្នុងទីនេះ ព្រះថេរៈបានដល់ សេចក្តីសម្រេចក្នុងអរហត្ត ឈ្មោះថា សម្រេចក្នុងធម៌ទាំងឡាយ ។ ចំណែកព្រះមហាសិវត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដក អ្នកពោលទីឃនិកាយ ពោលពាក្យខាងដើមដូចគ្នា ហើយពោលថា ក្នុងទីនេះ ព្រះថេរៈបានដល់សេចក្តីសម្រេចក្នុងសាវកបារមីញាណ ឈ្មោះថា សម្រេចក្នុងធម៌ទាំងឡាយ ដូច្នេះហើយ ពោលទៀតថា ព្រះពុទ្ធគុណទាំងឡាយមកហើយដោយន័យ ដូច្នេះ ។

បទថា **សត្ថរិ បសីទឹ** សេចក្តីថា ខ្ញុំព្រះអង្គនោះ បានដល់សេចក្តីសម្រេចក្នុងធម៌ គឺសាវកបារមីញាណយ៉ាងនេះហើយ មានសេចក្តីជ្រះថ្លាក្នុងព្រះសាស្តាដោយប្រមាណយ៉ាងក្រៃលែងថា ព្រះមានព្រះភាគនោះ ត្រាស់ដឹងដោយព្រះអង្គឯង ដោយប្រពៃហ្ន៎ ដូច្នេះ ។ បទថា **ស្វាក្ខាតោ ភគវតា ធម្មោ** គឺមគ្គដែលជានិយ្យានិកធម៌ ដែលព្រះពុទ្ធត្រាស់ល្អហើយ គឺទ្រង់ពោលល្អហើយ រមែងនាំចេញទៅ ដើម្បីឲ្យសម្រេចអរិយផល អាចបន្ទោបង់រាគៈ ទោសៈ និងមោហៈបាន ។ ពីរបទថា **សុបដិបន្នោ សង្ឃោ** គឺព្រះថេរៈសម្តែងថា ខ្ញុំព្រះអង្គមានសេចក្តីជ្រះថ្លា ក្នុងព្រះមានព្រះភាគថា ព្រះសង្ឃសាវក របស់ព្រះមានព្រះភាគ ឈ្មោះថា បដិបត្តិល្អហើយ ព្រោះបដិបត្តិសម្មាបដិបទា ដែលវៀរចាកទោស មានសេចក្តីវៀចវេរជាដើម ដូច្នេះ ។

[ ៧៨ ] ឥឡូវនេះ ព្រះថេរៈអន្ទយក្នុងទីសម្រាកពេលថ្ងៃ ដើម្បីសម្តែងធម៌ ដែលជាបវេណីប្រការដទៃទៀត ១៦ ប្រការដែលខ្លួនសម្រេចព្រមហើយ ទើបបានផ្តើមទេសនានេះថា **អបរំ បន ភន្តេ ឯតទានុត្តរិយំ** ជាដើម ។ ក្នុងបណ្តាបទទាំងនោះ ភាពជាអ្នកកំពូល ឈ្មោះថា **អនុត្តរិយ** ។ បទថា **យថា ភគវា ធម្មំ ទេសេតិ** នេះ ព្រះថេរៈទូលថា ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ដោយប្រការណា គឺដោយអាការដូចម្តេច ដោយទេសនាដូចម្តេច ទេសនារបស់ព្រះអង្គនោះ ចាត់ជាទេសនាដ៏កំពូល ។ ដោយបទថា **កុសលេសុ ធម្មេសុ** ព្រះថេរៈសម្តែងថា ព្រះមានព្រះភាគ ទ្រង់ជាអគ្គបុគ្គលក្នុងកុសលធម៌ទាំងឡាយ ដែលព្រះអង្គទ្រង់សម្តែងហើយ ដោយទេសនានោះ ។ម្យ៉ាងទៀត ព្រះថេរៈកាលនឹងសម្តែងភូមិរបស់ទេសនានោះ ទើបក្រាបទូលថា **កុសលេសុ ធម្មេសុ** ដូច្នេះ ។ បទថា **តត្រិមេ កុសលា ធម្មា** សេចក្តីថា ក្នុងបទដែលពោលថា **កុសលេសុ ធម្មេសុ** នោះ គប្បីជ្រាបធម៌ដែលចាត់ជាកុសលធម៌ទាំងនេះ ។ ក្នុងបទថា **កុសលេសុ ធម្មេសុ** នោះ គប្បីយល់អត្ថក្នុងកុសលធម៌ដោយចំណែក ៥ គឺ

ដោយអត្ថថា មិនមានរោគ ដោយអត្ថថា មិនមានទោស ដោយអត្ថថា ជាប្រកពកើតនៃសេចក្តីឈ្លាស ដោយអត្ថថា អស់សេចក្តីក្រវល់ក្រវាយ និងដោយអត្ថថា មានសុខជាផល ។ ក្នុងអត្ថទាំងនោះ កុសល មានអត្ថថា មិនមានរោគ ព្រោះកាន់យកតាមគន្លងជាតក ។ កុសល មានអត្ថថា មិនមាន

ទោស ព្រោះកាន់យកតាមគន្ថព្រះសូត្រ ។ កុសលមានអត្ថថា ជាប្រកព កើតនៃភាពឈ្លាសវៃ អស់សេចក្តីក្រវល់ក្រវាយ និងមានសុខជាផល ព្រោះ កាន់យកតាមគន្ថព្រះអភិធម្ម ។ តែក្នុងទីនេះ គប្បីឃើញថា ជាកុសល ដោយអត្ថថា មិនមានទោស តាមគន្ថនៃពាហិយសូត្រ ។ បទថា **ចត្តារោ សតិប្បដ្ឋានា** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់បែកចេញដោយន័យផ្សេងៗ ហើយទ្រង់សម្តែងសតិប្បដ្ឋាន ៤ ប្រការ ដែលលាយឡំគ្នា ទាំងចំណែក លោកិយ និងលោកុត្តរ ដោយអំណាចនៃសមថវិបស្សនា និងមគ្គយ៉ាងនេះថា កាយានុបស្សនាសតិប្បដ្ឋានដោយ ១៤ វិធី វេទនានុបស្សនាសតិប្បដ្ឋាន ៩ វិធី ចិត្តានុបស្សនាសតិប្បដ្ឋាន ១៦ វិធី ធម្មានុបស្សនាសតិប្បដ្ឋាន ៥ វិធី ។ តែក្នុង ទីនេះ មិនបំណងយកសតិប្បដ្ឋានដែលជាផល ។ បទថា **ចត្តារោ សម្មប្ប-ធានា** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់សម្តែងសម្មប្បធាន ៤ ប្រការ ដែល មានលក្ខណៈតែម្យ៉ាង ដោយអត្ថថា ជាគ្រឿងផ្គងចិត្តផ្សេងគ្នាដោយអំណាច កិច្ច ដែលលាយឡំគ្នា ទាំងផ្នែកលោកិយ និងផ្នែកលោកុត្តរ ដោយអំណាច នៃសមថវិបស្សនា និងមគ្គ ដោយន័យជាដើមថា ភិក្ខុក្នុងសាសនានេះ រមែង ប្រារព្ធសេចក្តីព្យាយាម ដើម្បីការមិនកើតនៃបាបអកុសលធម៌ ដែលមិនទាន់ កើតឡើង ។ បទថា **ចត្តារោ ឥទ្ធិបាទា** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់ សម្តែងឥទ្ធិបាទ ៤ ជាពួកមួយ ដោយអត្ថថា ជាគ្រឿងសម្រេចមានសភាព ផ្សេងគ្នា ដោយអំណាចសភាពមានការពេញចិត្តជាដើម ដែលលាយគ្នា ទាំង ផ្នែកលោកិយ និងផ្នែកលោកុត្តរ ដោយអំណាចនៃសមថវិបស្សនា និងមគ្គ

ដោយន័យជាដើមថា ភិក្ខុក្នុងសាសនានេះ រមែងចម្រើនឥទ្ធិបាទ ដែលប្រកប ដោយសេចក្តីពេញចិត្ត សេចក្តីតាំងចិត្តមាំ សេចក្តីព្យាយាម និងការគាក់តែង ដូច្នេះ ។ បទថា **បញ្ចិន្ទ្រិយានិ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់សម្តែង ឥន្ទ្រិយ ៥ មានសទ្ធិន្ទ្រិយជាដើម ដែលមានលក្ខណៈតែម្យ៉ាង ដោយអត្ថថា ជាធំ មានសភាពផ្សេងគ្នា ដោយអំណាចសភាពបង្អោនចិត្តជឿជាដើម ដែល លាយគ្នា ទាំងផ្នែកលោកិយ និងផ្នែកលោកុត្តរ ដោយអំណាចនៃសមថ-វិបស្សនា និងមគ្គ ។ បទថា **បញ្ច ពលានិ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់សម្តែងពល ៥ ប្រការ មានសទ្ធាជាដើម ជាមួយពួក ដោយអត្ថថា ជា គ្រឿងឧបត្ថម្ភ ឬដោយអត្ថថា មិនញាប់ញ័រ មានសភាពផ្សេងគ្នាតាមលក្ខណៈ របស់ខ្លួន ដែលលាយគ្នា ទាំងផ្នែកលោកិយ និងផ្នែកលោកុត្តរ ដោយអំណាច នៃសមថវិបស្សនា និងមគ្គ ។ បទថា **សត្ត ពោជ្ឈង្គា** សេចក្តីថា ព្រះមាន ព្រះភាគ ទ្រង់សម្តែងពោជ្ឈង្គ ៧ ប្រការ ជាមួយពួក ដោយអត្ថថា ជាគ្រឿងនាំ ចេញ មានសភាពផ្សេងគ្នា តាមលក្ខណៈរបស់ខ្លួន មានការប្រាកដជាដើម ដែលលាយគ្នាទាំងផ្នែកលោកិយ និងផ្នែកលោកុត្ត ដោយអំណាចនៃសមថៈ វិបស្សនា និងមគ្គនោះឯង ។ បទថា **អរិយោ អដ្ឋង្គិកោ មគ្គោ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់សម្តែងមគ្គដែលប្រកបដោយអង្គ ៨ ដ៏ប្រសើរ ជាមួយ ពួក ដោយអត្ថថា ជាតួហេតុ និងមានសភាពផ្សេងៗ គ្នា តាមលក្ខណៈរបស់ ខ្លួន មានការឃើញជាដើម លាយគ្នាទាំងផ្នែកលោកិយ និងផ្នែកលោកុត្តរ ដោយអំណាចនៃសមថវិបស្សនា និងមគ្គនោះឯង ។

សួរថា ព្រោះហេតុអ្វី ទើបព្រះថេរៈ ផ្តើមពាក្យនេះថា **ឥធ ភន្តេ ភិក្ខុ អាសវានំ ខយា** ដូច្នេះ ឆ្លើយថា ដើម្បីសម្តែងទីបំផុតនៃព្រះសាសនា ពិតហើយ ទីបំផុតនៃព្រះសាសនាមិនមានដោយមគ្គតែម្យ៉ាងប៉ុណ្ណោះទេ រមែងមានសូម្បីដោយព្រះអរហត្តផល ដូច្នោះ គប្បីជ្រាបថា ព្រះថេរៈផ្តើមពាក្យនេះក៏ដើម្បីសម្តែងទីបំផុតនៃព្រះសាសនានោះ ។ ច្រើនបទថា **ឯតទានុត្តរិយំ ភន្តេ កុសលេសុ ធម្មេសុ** សេចក្តីថា បពិត្រព្រះអង្គដ៏ចម្រើន ការសម្តែងយ៉ាងនេះ ចាត់ជាធម៌ដ៏ប្រសើរ ក្នុងផ្នែកកុសលធម៌ទាំងឡាយ ។ បទថា **តំ ភគវា** គឺព្រះមានព្រះភាគ ទ្រង់រមែងជ្រាបច្បាស់ទេសនាទាំងអស់នោះ មិនមានសល់ ។ បទថា **តំ ភគវតោ** សេចក្តីថា កាលព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់ទេសនានោះ ដោយមិនសេសសល់ ។ បទថា **ឧត្តរិ អភិញ្ញេយ្យំ នត្ថិ** សេចក្តីថា ធម៌ដែលគប្បីដឹងក្រៃលែងឡើងជាងនេះ មិនមានទេ គឺពាក្យនេះថា ធម៌ ឬបុគ្គល ដែលព្រះមានព្រះភាគ ទ្រង់មិនជ្រាបក្រៅពីនេះ មិនមាន ។ បទថា **យទភិជានំ អញ្ញោ សមណោ វា** សេចក្តីថា សមណៈ ឬព្រាហ្មណ៍ដទៃ ដឹងធម៌ដែលព្រះអង្គទ្រង់មិនដឹង គប្បីជាអ្នកមានសេចក្តីដឹងក្រៃលែងជាង គឺមានបញ្ញាក្រៃលែងជាងព្រះមានព្រះភាគ ។ បទថា **យទិទំ** ក្នុងបទថា **យទិទំ កុសលេសុធម្មេសុ** នេះ ត្រឹមតែជានិបាត ។ ក្នុងសេចក្តីនេះ មានពាក្យអធិប្បាយដូច្នេះថា សមណៈ ឬព្រាហ្មណ៍ដែលក្រៃលែងជាងព្រះមានព្រះភាគ ក្នុងចំណែកកុសលធម៌ មិនមាន ។ ព្រះសារីបុត្រ កាលនឹងសម្តែងថា ព្រះមាន

ព្រះភាគប៉ុណ្ណោះ ទ្រង់ជាអគ្គបុគ្គលក្នុងកុសលធម៌ទាំងឡាយ ដោយប្រការដូច្នេះហើយ សម្ដែងថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ មានសេចក្ដីជ្រះថ្លាក្នុងព្រះមានព្រះភាគយ៉ាងនេះ ដោយហេតុនេះ ដូច្នេះ ។

[ ៧៦ ] ក្នុងបទថា **អបរំ បន** ជាដើម ក្រៅពីនេះ ខ្ញុំនឹងពណ៌នាត្រឹមតែសេចក្ដីដែលផ្សេងគ្នាប៉ុណ្ណោះ ។ ចំណែកពាក្យដែលដូចគ្នានឹងវារៈខាងដើម គប្បីជ្រាបតាមន័យដែលពោលហើយនោះចុះ ។ បទថា **អាយតនបណ្ណត្តីសុ** គឺក្នុងការបញ្ញត្តិអាយតនៈ ។ ឥឡូវនេះ កាលនឹងសម្ដែងអាយតនបញ្ញត្តិទាំងឡាយនោះ ទើបព្រះសារីបុត្តត្ថេរទូលថា **ឆយិមានិ ភន្តេ** ដូច្នេះជាដើម ។ ឯកថាពោលដោយអាយតនៈនេះ លោកពោលយ៉ាងពិស្ដារក្នុងបករណ-វិសេស ឈ្មោះវិសុទ្ធិមគ្គ ។ ដូច្នោះ ខ្ញុំមិនពណ៌នាអាយតនៈនោះឲ្យពិស្ដារ ។ ព្រោះដូច្នោះ គប្បីជ្រាបអាយតនកថានោះយ៉ាងពិស្ដារ ដោយន័យដែលបានពោលហើយ ក្នុងវិសុទ្ធិមគ្គនោះចុះ ។ បទថា **ឯតទានុត្តរិយំ ភន្តេ អាយត-នបណ្ណត្តីសុ** គឺការសម្ដែងយ៉ាងនេះ ដោយអំណាចការកំណត់ជាអាយតនៈខាងក្នុង និងខាងក្រៅជាដើមនេះ ចាត់ជាធម៌ដ៏កំពូលក្នុងអាយតនបញ្ញត្តិនេះ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។

[ ៧៧ ] បទថា **គព្ភាវក្កន្តីសុ** គឺក្នុងការឈានចុះកាន់គភ៌ ។ ព្រះសារីបុត្តត្ថេរ កាលសម្ដែងការឈានចុះកាន់គភ៌ទាំងនោះ ទើបក្រាបទូលថា **ចតស្សោ ឥមា ភន្តេ** ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **អសម្ប-ជានោ** គឺមិនដឹង បានដល់ វង្វេងព្រម ។ បទថា **មាតុ កុច្ឆឹ ឱក្កមតិ** គឺ

រមែងចូលទៅកាន់គភ៌ ដោយអំណាចបដិសន្ធិ ។ បទថា **ឋាតិ** ប្រែថា រមែងនៅ ។ បទថា **និក្ខមតិ** គឺសូម្បីកាលប្រសូតក៏មិនដឹង គឺវង្វេងព្រមចេញទៅ ( ចាកគភ៌ ) ។ បទថា **អយំ បឋមា** គឺនេះចាត់ជាការឈានចុះកាន់គភ៌របស់ពួកមនុស្សលោក តាមប្រក្រតីប្រការទី ១ ។ បទថា **សម្បជានោ ហិ ២ា** គឺសត្វកាលនឹងឈានចុះ ក៏ជាអ្នកដឹង មិនវង្វេងក្នុងការឈានចុះកាន់គភ៌ ។ បទថា **អយំ ទុតិយា** គឺនេះចាត់ជាការឈានចុះកាន់គភ៌ប្រការទី ២ របស់អសីតិមហាសាវកទាំងឡាយ ។ ពិតហើយ ព្រះមហាសាវកទាំងនោះ កាលនឹងចូលទៅកាន់គភ៌ប៉ុណ្ណោះ រមែងដឹង កាលតាំងនៅ និងកាលប្រសូត មិនដឹង ។ បទថា **អយំ តតិយា** សេចក្តីថា នេះចាត់ជាការឈានចុះកាន់គភ៌ប្រការទី ៣ នៃព្រះអគ្គសាវកទាំងពីរ និងនៃព្រះបច្ចេកពោធិសត្វទាំងឡាយ ។ បានឮថា លោកទាំងនោះ ត្រូវខ្យល់កម្មជវាតបក់សីសៈឲ្យត្រឡប់ចុះទៅខាងក្រោម ឲ្យជើងឡើងលើ មកនៅត្រង់មាត់ទ្វារប្រសូត ដូចនៅក្នុងជ្រោះដ៏ជ្រៅច្រើនរយជួរបុរស ចេញចាកទ្វារប្រសូតដ៏ចង្អៀត ក៏ជួបទុក្ខដ៏ច្រើន ប្រៀបដូចដំរីដែលចេញចាកប្រហោងនុកទ្វារ រមែងប្រសព្វសេចក្តីទុក្ខ ដូច្នោះ ។ ដោយហេតុនោះ សត្វទាំងនោះរមែងមិនមានសេចក្តីដឹងថា អញចេញហើយដូច្នេះ ។ សេចក្តីទុក្ខយ៉ាងខ្លាំងក្លា ក្នុងឋានៈបែបនេះ រមែងកើតឡើងដល់ពួកសត្វ សូម្បីអ្នកបំពេញបារមីមកហើយយ៉ាងនេះ ដូច្នោះ គួរនឿយណាយគួរលះ ប្រាសចាកតម្រេក ក្នុងការនៅក្នុងគភ៌ ។ បទថា **អយំ ចតុត្ថា** គឺនេះជាការឈានចុះកាន់គភ៌ប្រការទី ៤ ដោយអំណាចនៃព្រះសព្វញ្ញូពោធិសត្វទាំងឡាយ ។ ពិតហើយ ព្រះសព្វញ្ញូពោធិសត្វទាំងឡាយ កាលបដិសន្ធិក្នុងគភ៌របស់មាតាក៏ដឹង កាលនៅក្នុងគភ៌ក៏ដឹង ក្នុងវេលាប្រសូតចាកគភ៌ ខ្យល់

កម្មជ្ជវាតទាំងឡាយ មិនអាចបក់នាំឲ្យព្រះសព្វញ្ញុពោធិសត្វទាំងនោះ ត្រឡប់ជើងទៅខាងលើ និងសីសៈមកខាងក្រោមបាន ។ ព្រះសព្វញ្ញុពោធិសត្វទាំងនោះ សណ្ដូកព្រះហស្ដទាំងពីរ ហើយបើកព្រះនេត្រ ប្រថាប់ឈរប្រសូតចេញមក ។ វៀរតែព្រះសព្វញ្ញុពោធិសត្វចេញ សត្វដទៃក្នុងចន្លោះអវិចី ដរាបដល់ភវគ្គព្រហ្ម ដែលឈ្មោះថា ជីងក្នុងពេលទាំងបី មិនមានឡើយ ។ ដោយហេតុនោះឯង ក្នុងវេលាដែលព្រះសព្វញ្ញុពោធិសត្វទាំងឡាយនោះ ឈានចុះកាន់ព្រះគភ៌មាតា និងក្នុងវេលាប្រសូត ម៉ឺនលោកធាតុ ទើបបានញាប់ញ័រ ។ ពាក្យដ៏សេសក្នុងរឿងឈានចុះកាន់គភ៌នេះ គប្បីជ្រាបតាមន័យ ដែលពោលហើយនោះចុះ ។

[ ៧៨ ] បទថា **អាទេសនាវិធាសុ** គឺក្នុងចំណែកនៃការសម្ដែងព្រះធម៌ ។ ឥឡូវនេះ ព្រះសារីបុត្រ កាលនឹងសម្ដែងវិធីការសម្ដែងធម៌ទាក់ចិត្តមនុស្សទាំងនោះ ទើបក្រាបទូលថា **ចតស្សោ ឥមា** ដូច្នេះជាដើម ។ ដោយបទថា **និមិត្តេន អាទិសតិ** នេះ ព្រះសារីបុត្រសម្ដែងថា ឈ្មោះថា ការសម្ដែងធម៌ទាក់ចិត្តមនុស្សនេះនឹងមាន ដោយអនាគតនិមិត្តខ្លះ ដោយគតិនិមិត្តខ្លះ ដោយឋិតិនិមិត្តខ្លះ ។ ក្នុងសេចក្ដីនោះ មានរឿងនេះជាឧទាហរណ៍ ។ ព្រះរាជាមួយអង្គ ទ្រង់កាន់យកកែវមុក្ដា ៣ ហើយត្រាស់សួរបុរោហិតថា អាចារ្យ អ្វីនៅក្នុងដៃរបស់យើងនេះ ។ ទើបបុរោហិតនោះ សម្លឹងមើលទៅខាងនោះ និងខាងនេះ ។ ដោយសម័យនោះ សត្វតុកកែមួយរត់ចេញទៅ ដោយបំណងថា នឹងចាប់រុយស៊ី ដូច្នេះ ។ ក្នុងវេលាដែលចាប់ រុយហើរគេចទៅ ។ បុរោហិតនោះទូលថា បពិត្រមហារាជ កែវមុក្ដា ព្រះអង្គ ដូច្នេះ ព្រោះហេតុរុយហើរ

ចៀសចេញផុតទៅបាន ។ ទើបព្រះរាជាត្រាស់សួរទៀតថា កែវមុក្តា ចូរលើកទុកចុះ ( តែ ) កែវមុក្តាមានប៉ុន្មាន ។ ទើបបុរោហិតនោះ សម្លឹងមើលនិមិត្តនោះទៀត ។ លំដាប់នោះ មាន់រងាវឡើង ៣ ដង ក្នុងទីមិនឆ្ងាយ ។ ទើបព្រាហ្មណ៍ក្រាបទូលថា ៣ ព្រះអង្គ ដូច្នេះ ។ អ្នកខ្លះ រមែងនិយាយដោយនិមិត្តដែលមកប្រាកដយ៉ាងនេះ ។ គប្បីជ្រាបការពោលដោយគតិនិមិត្ត និងឋិតិនិមិត្ត ដោយឧបាយនោះ ។ បទថា **អមនុស្សានំ** គឺពួកយក្ខ និងបិសាចជាដើម ។ បទថា **ទេវតានំ** គឺពួកទេវតាអ្នកតាំងនៅក្នុងជាន់ចាតុម្មហារាជជាដើម ។ បទថា **សទ្ទំ សុត្វា** សេចក្តីថា ស្តាប់សំឡេងរបស់ពួកទេវតា និងអមនុស្ស ក៏ដឹងចិត្តរបស់អ្នកដទៃហើយពោល ។ បទថា **វិតក្កវិប្ផារសទ្ទំ** បានដល់ សំឡេងរបស់ពួកជនអ្នកដេកលក់ និងប្រមាទហើយជាដើម ដែលមមើ កើតឡើងមកដោយការផ្សាយទៅនៃវិតក្ក ។ បទថា **សុត្វា** គឺបានឮសំឡេងនោះ ។ សំឡេងនោះ កើតឡើងដល់បុគ្គលអ្នកត្រិះរិះរឿងណា បុគ្គលនោះរមែងដាក់ចិត្តបានថា ចិត្តរបស់លោកយ៉ាងនេះ ដោយអំណាចនៃការត្រិះរិះនោះ ។ បទថា **មនោសង្ខារា បណិហិតា** គឺចិត្តសង្ខារតាំងមាំដោយល្អហើយ ។ បទថា **វិតក្កេស្សតិ** គឺគេរមែងដឹងថា អ្នកនេះនឹងត្រិះរិះ គឺនឹងឲ្យ ( ចិត្តសង្ខារ ) ប្រព្រឹត្តទៅ ។ម្យ៉ាងទៀត បុគ្គលកាលដឹង រមែងដឹងដោយការមករបស់និមិត្ត រមែងដឹងដោយនិមិត្ត ដែលជាចំណែកខាងដើម ពិចារណាមើលចិត្តក្នុងខាងក្នុងសមាបត្តិ រមែងដឹងបាន ។ បុគ្គលរមែងដឹងថា ក្នុងវេលាបរិកម្មកសិណនោះឯង បុគ្គលនេះ ផ្តើមការនាកសិណ ដោយអាការណា នឹង

ញុំាងបឋមជ្ឈាន ។បេ។ ឬចតុត្ថជ្ឈាន ឬសមាបត្តិ ៨ ឲ្យកើតបាន បុគ្គលនេះ ឈ្មោះថា រមែងដឹង ដោយការមកប្រាកដរបស់និមិត្ត ។ បុគ្គលខ្លះ រមែងដឹង កាលផ្តើមបំពេញសមថវិបស្សនា គឺដឹងថា បុគ្គលនេះ ផ្តើមបំពេញវិបស្សនា ដោយអាការណា នឹងញុំាងសោតាបត្តិមគ្គឲ្យកើត ។បេ។ ឬញុំាងអរហត្តមគ្គឲ្យ កើត បុគ្គលនេះឈ្មោះថា រមែងដឹងបានដោយនិមិត្តដែលជាចំណែកខាងដើម ។ បុគ្គលខ្លះ រមែងដឹងថា មនោសង្ខាររបស់បុគ្គលនេះតាំងមាំដោយល្អ ដោយ អាការណា បុគ្គលនេះនឹងត្រិះរិះដល់វិតក្កឈ្មោះនេះ ជាលំដាប់នៃចិត្តឈ្មោះ នេះ កាលបុគ្គលនោះចេញចាកវិតក្កនេះ សមាធិដែលជាចំណែកវិនាស ឬជា ចំណែកតាំងនៅ ឬជាចំណែកនៃភាពវិសេសឡើង ឬជាចំណែកទម្លាយ កិលេសនឹងមាន ឬនឹងញុំាងអភិញ្ញាឲ្យកើតឡើង បុគ្គលនេះ ឈ្មោះថា ពិចា- រណាមើលចិត្តខាងក្នុងសមាបត្តិហើយ ទើបដឹងបាន ។ ក្នុងបណ្តាជនទាំង នោះ បុថុជ្ជនអ្នកបានចេតោបរិយញ្ញាណ រមែងដឹងចិត្តរបស់បុថុជ្ជនប៉ុណ្ណោះ មិនដឹងចិត្តរបស់ព្រះអរិយៈទាំងឡាយបានឡើយ ។ ក្នុងព្រះអរិយៈទាំងឡាយ ព្រះអរិយបុគ្គលដែលតាំងនៅក្នុងមគ្គខាងក្រោម រមែងមិនដឹងចិត្តរបស់ព្រះ អរិយបុគ្គលដែលតាំងនៅក្នុងមគ្គខាងលើបាន ។ ចំណែកព្រះអរិយបុគ្គល ដែលតាំងនៅក្នុងមគ្គខាងលើ រមែងដឹងចិត្តរបស់ព្រះអរិយបុគ្គល ដែលតាំង នៅក្នុងមគ្គខាងក្រោមបាន ។ ក្នុងបណ្តាលោកទាំងនោះ ព្រះសោតាបន្ន ចូល សោតាបត្តិផលសមាបត្តិ ព្រះសកទាគាមី ចូលសកទាគាមិផលសមាបត្តិ ព្រះអនាគាមី ចូលអនាគាមិផលសមាបត្តិ ព្រះអរហន្ត ក៏ចូលអរហត្តផល-

សមាបត្តិ ព្រះអរិយបុគ្គលដែលតាំងនៅក្នុងផលខាងលើ រមែងមិនចូលសមាបត្តិខាងក្រោម ។ ពិតហើយ សមាបត្តិខាងក្រោមរបស់លោកទាំងនោះ ក៏មានការប្រព្រឹត្តទៅក្នុងសមាបត្តិនោះដូចគ្នា ។ បទថា **តញ្ច តំ ហោតិ** សេចក្តីថា រឿងនេះ រមែងយ៉ាងនោះឯង ដោយចំណែកតែមួយ ។ សេចក្តីពិត ឈ្មោះថា ភាពជាប្រការដទៃ ដែលដឹងដោយ អំណាចចេតោបរិយញ្ញាណ រមែងមិនមាន ។ ពាក្យដ៏សេស គប្បីប្រកបចូលដោយន័យមុននោះឯង ។

[ ៧ ] បទជាដើមថា **អាតប្បមន្វាយ** ព្រះមានព្រះភាគត្រាស់ឲ្យពិស្តារហើយក្នុងព្រហ្មជាលសូត្រ ។ ចំណែកសេចក្តីសង្ខេបក្នុងទីនេះ មានដូច្នេះ ។ សេចក្តីព្យាយាម ឈ្មោះថា អាតប្ប ។ សេចក្តីព្យាយាមនោះឯង ឈ្មោះថា បធាន ព្រោះជារបស់ដែលបុគ្គលគប្បីតាំងទុក ឈ្មោះថា អនុយោគ ព្រោះជារបស់ដែលបុគ្គលគប្បីប្រកប ។ បទថា **អប្បមាទំ** គឺការមិនទៅប្រាសចាកសតិ ។ បទថា **សម្មា មនសិការំ** គឺការធ្វើមនសិការដោយឧបាយដែលប្រព្រឹត្តទៅដោយអំណាចការពិចារណាក្នុងធម៌ដែលមិនទៀង ថាមិនទៀងជាដើម ។ បទថា **ចេតោសមាធឹ** បានដល់ សមាធិក្នុងបឋមជ្ឈាន ។ ច្រើនបទថា **អយំ បឋមា ទស្សនសមាបត្តិ** សេចក្តីថា បឋមជ្ឈានសមាបត្តិដែលព្រះយោគាវចរពិចារណាអាការ ៣២ ដោយជារបស់បដិកូលហើយ ឲ្យកើតឡើង ដោយអំណាចការឃើញថា ជារបស់បដិកូលនេះ ឈ្មោះថា ទស្សនសមាបត្តិទី ១ តែបើព្រះយោគាវចរធ្វើឈាននោះឲ្យជាបាទ ហើយបានជាព្រះសោតាបន្ន នេះចាត់ជាទស្សនសមាបត្តិទី ១ ដោយត្រង់នោះឯង ។ បទថា **អតិក្កម្ម ច** គឺឈានកន្លង ។ បទថា **ឆវិមំសលោហិតំ** គឺសម្បុរថ្ងៃ

សាច់ និងឈាម ។ បទថា **អដ្ឋឹ បច្ចវេក្ខតិ** គឺរមែងពិចារណាថា ឆ្អឹង ឆ្អឹង ដូច្នេះ ។ បទថា **អដ្ឋិ អដ្ឋិ** សេចក្តីថា ឈានសមាបត្តិ ដែលមានទិព្វចក្ខុជាបាទ មានឆ្អឹងជាអារម្មណ៍ ដែលព្រះយោគាវចរពិចារណាហើយ ឲ្យកើតឡើង ឈ្មោះថា ទស្សនសមាបត្តិទី ២ ។ តែបើព្រះយោគាវចរ ធ្វើឈាននោះឲ្យជាបាទហើយ រមែងឲ្យសកទាគាមិមគ្គកើតឡើងបាន ប្រការនេះ ក៏ចាត់ថាជាទស្សនសមាបត្តិទី ២ ដោយត្រង់ ។ ចំណែកព្រះសុមនត្ថេរដែលនៅក្នុងកាឡវល្លិវិហារ ពោលថា រមែងគួរតាំងអំពីមគ្គទី ៣ ។ វិញ្ញាណនោះឯង ឈ្មោះថា វិញ្ញាណសោត ។ បទថា **ឧភយតោ អព្វោច្ឆិន្នំ** សេចក្តីថា ក្រសែវិញ្ញាណនោះ លោកកាត់ផ្តាច់បានហើយ ដោយចំណែកទាំងពីរ ។ បទថា **ឥធ លោកេ បតិដ្ឋិតញ្ច** គឺដែលតាំងនៅហើយក្នុងលោកនេះ ដោយអំណាចឆន្ទ-រាគៈ ។ សូម្បីក្នុងបទទី ២ ក៏ន័យនេះដូចគ្នា ។ ម្យ៉ាងទៀត ក្រសែវិញ្ញាណកាលចូលដល់កម្មដោយកម្ម ឈ្មោះថា តាំងនៅចំពោះហើយក្នុងលោកនេះ ។ ក្រសែវិញ្ញាណ កាលទាញមកបាននូវកម្មភព ឈ្មោះថា តាំងនៅចំពោះក្នុងបរលោក ។ សួរថា ដោយបទនេះ លោកពោលអ្វី ឆ្លើយថា លោកពោលចេតោបរិយញ្ញាណរបស់សេក្ខបុថុជ្ជនទាំងឡាយ ។ ពិតហើយ ចេតោបរិ-យញ្ញាណរបស់សេក្ខបុថុជ្ជនទាំងឡាយ ឈ្មោះថា ទស្សនសមាបត្តិ ប្រការទី ៣ ។ បទថា **ឥធ លោកេ អប្បតិដ្ឋិតញ្ច** គឺតាំងនៅមិនបានក្នុងលោកនេះ ព្រោះមានតម្រេក ដោយអំណាចលះសេចក្តីពេញចិត្តចេញហើយ ។ សូម្បីក្នុងបទទី ២ ក៏ន័យនេះ ។ ម្យ៉ាងទៀត ក្រសែវិញ្ញាណមិនចូលដល់កម្មដោយកម្ម ឈ្មោះថា តាំងនៅក្នុងលោកនេះមិនបាន ។ កាលទាញកម្មភពមកមិនបាន

ឈ្មោះថា តាំងនៅក្នុងបរលោកមិនបាន ។ សួរថា ដោយបទនេះ លោកពោល អ្វី ឆ្លើយថា លោកពោលចេតោបរិយញ្ញាណរបស់ព្រះខីណាស្រព ។ ពិត ហើយ ចេតោបរិយញ្ញាណរបស់ព្រះខីណាស្រព ឈ្មោះថា ក្នុងទស្សន- សមាបត្តិប្រការទី ៤ ។ ម្យ៉ាងទៀត សូម្បីវិបស្សនាដែលព្រះយោគាវចរប្រារព្ធ អាការ ៣២ ក៏ចាត់ជាទស្សនសមាបត្តិប្រការទី ១ ។ វិបស្សនាដែលព្រះ យោគាវចរប្រារព្ធកម្មដ្ឋាន ដែលមានឆ្អឹងជាអារម្មណ៍ ចាត់ជាទស្សនសមាបត្តិ ប្រការទី ២ ។ ទាំងពីរបទនេះថា ចេតោបរិយញ្ញាណរបស់សេក្ខបុថុជ្ជន ចេតោបរិយញ្ញាណរបស់ព្រះខីណាស្រព ដូច្នេះ មិនញាប់ញ័រឡើយ ។ ម្យ៉ាង ទៀត បឋមជ្ឈាន ឈ្មោះថា ទស្សនសមាបត្តិប្រការទី ១ ។ ទុតិយជ្ឈាន ឈ្មោះថា ទស្សនសមាបត្តិប្រការទី ២ ។ តតិយជ្ឈាន ឈ្មោះថា ទស្សន- សមាបត្តិប្រការទី ៣ ។ ចតុត្ថជ្ឈាន ឈ្មោះថា ទស្សនសមាបត្តិប្រការទី ៤ ។ ម្យ៉ាងទៀត បឋមមគ្គ ឈ្មោះថា ទស្សនសមាបត្តិប្រការទី ១ មគ្គទី ២ ឈ្មោះ ថា ទស្សនសមាបត្តិប្រការទី ២ មគ្គទី ៣ ឈ្មោះថា ទស្សនសមាបត្តិប្រការទី ៣ មគ្គទី ៤ ឈ្មោះថា ទស្សនសមាបត្តិប្រការទី ៤ ។ ពាក្យដ៏សេសក្នុងបទនេះ គប្បីប្រកបចូល ដោយន័យមុននោះឯង ។

[ ៨០ ] បទថា **បុគ្គលបណ្ណត្តីសុ** គឺក្នុងលោកប្បញ្ញត្តិ ដែលបុគ្គល គប្បីបញ្ញត្តិយ៉ាងនេះថា **សត្ត បុគ្គល នរ បោស** ដូច្នេះ តាមវោហារផ្លូវ លោក ។ ពិតហើយ កថាទាំងពីរ គឺសម្មតិកថា បរមត្ថកថា របស់ព្រះពុទ្ធ ទាំងឡាយ ទ្រង់ធ្វើឲ្យពិស្តារហើយ ក្នុងបោដ្ឋបាទសូត្រ ក្នុងបណ្តាកថាទាំង ពីរនោះ កថានេះថា ក្នុងបុគ្គលប្បញ្ញត្តិទាំងឡាយ ដូច្នេះ ឈ្មោះសម្មតិកថា ។

ព្រះសាស្តា កាលទ្រង់បញ្ញត្តបុគ្គលពួកណា ទ្រង់ជាអគ្គបុគ្គលក្នុងបុគ្គល-ប្បញ្ញត្តិទាំងឡាយ ឥឡូវនេះ ព្រះសារីបុត្តត្ថេរ កាលនឹងសម្តែងបុគ្គលទាំងនោះ ទើបទូលពាក្យថា **សត្តិមេ ភន្តេ បុគ្គលា ឧភតោភាគវិមុត្តោ** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **ឧភតោភាគវិមុត្តោ** សេចក្តីថា បុគ្គលដែលរួចផុតហើយ ដោយចំណែកពីរ គឺអ្នករួចផុតចាករូបកាយ ដោយអរូប-សមាបត្តិ រួចផុតចាកនាមកាយ ដោយមគ្គ ។ បុគ្គលនោះចេញចាកបណ្តាអរូបសមាបត្តិទាំង ៤ ណាមួយ ហើយពិចារណាសង្ខារ រមែងជាបុគ្គលពួក ៥ ដោយអំណាចនៃបុគ្គល គឺព្រះអរិយបុគ្គល ៤ ដែលសម្រេចព្រះអរហត្តនិងព្រះអនាគាមី ចេញចាកនិរោធហើយ សម្រេចព្រះអរហត្ត ។ ឯព្រះបាលីក្នុងទីនេះថា បុគ្គលជាឧភតោភាគវិមុត្តិ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះបានវិមោក្ខ ៨ ដោយនាមកាយ ទាំងអាសវៈរបស់បុគ្គលនោះក៏អស់ទៅ ព្រោះឃើញដោយបញ្ញា នេះហៅថា បុគ្គលជាឧភតោភាគវិមុត្តិ ។ ព្រះបាលីនេះមកហើយដោយអំណាចនៃលោកអ្នកបានវិមោក្ខ ៨ យ៉ាងនេះ ។ បទថា **បញ្ញាវិមុត្តោ** ប្រែថា រួចផុតហើយដោយបញ្ញា ។ បុគ្គលដែលរួចផុតបានដោយបញ្ញានោះ មាន ៥ ពួក ដោយអំណាចនៃបុគ្គលទាំងនេះ គឺសុក្ខវិបស្ស-កបុគ្គល ១ និងបុគ្គលដែលចេញចាកឈានទាំង ៤ ហើយសម្រេចព្រះអរហត្ត ៤ ពួក ១ ។ ឯព្រះបាលីក្នុងទីនេះមកហើយ ដោយអំណាចធម៌ ដែលជាបដិបក្ខចំពោះវិមោក្ខ ៨ សមដូចដែលព្រះមានព្រះភាគត្រាស់ថា បុគ្គលជាបញ្ញាវិមុត្តិ តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ មិនបានវិមោក្ខ ៨ ដោយនាមកាយទេ អាសវៈរបស់បុគ្គលនោះក៏អស់ទៅ ព្រោះឃើញដោយបញ្ញា នេះហៅថា បុគ្គលជាបញ្ញាវិមុត្តិ ។

បុគ្គល រមែងធ្វើឲ្យច្បាស់នូវកាយ ដែលពាល់ត្រូវ ដូច្នោះ ទើបឈ្មោះថា កាយសក្ខី ។ បុគ្គលនោះ រមែងពាល់ត្រូវឈានជាមុន ទើបធ្វើឲ្យច្បាស់នូវនិរោធ គឺនិព្វានក្នុងខាងក្រោយ ។ កាយសក្ខីនោះ គប្បីជ្រាបថា មាន ៦ ពួក ផ្តើមតាំងអំពីបុគ្គលតាំងនៅក្នុងសោតាបត្តិផល រហូតដល់បុគ្គលដែលតាំងនៅក្នុងអរហត្តមគ្គ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា បុគ្គលជាកាយសក្ខី តើដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ បានវិមោក្ខ ៨ ដោយនាមកាយ ទាំងអាសវៈពួកខ្លះរបស់បុគ្គលនោះ ក៏អស់ទៅ ព្រោះឃើញដោយបញ្ញា នេះហៅថា បុគ្គលជាកាយសក្ខី ។ បុគ្គលសម្រេចដល់ទីបំផុតនៃទិដ្ឋិ ដូច្នោះ ទើបឈ្មោះថា អ្នកសម្រេចទិដ្ឋិ ។ ក្នុងសេចក្តីនោះ មានលក្ខណៈដោយសង្ខេបដូចតទៅនេះ រីបុគ្គលណា បានដឹង បានឃើញ បានជ្រាប បានធ្វើឲ្យច្បាស់ ពាល់ត្រូវដោយបញ្ញាថា សង្ខារទាំងឡាយជាទុក្ខ ការរលត់នៃសង្ខារទាំងឡាយនោះ ជាសុខ ដូច្នេះ ហេតុនោះ បុគ្គលនោះ ឈ្មោះថា អ្នកសម្រេចទិដ្ឋិ ។ បុគ្គលដែលសម្រេចទិដ្ឋិនេះ មាន ៦ ពួក ដោយពិស្តារដូចកាយសក្ខីបុគ្គល ។ ដោយហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា បុគ្គលខ្លះក្នុងលោកនេះ ដឹងច្បាស់តាមពិតថា នេះទុក្ខ ។បេ។ នេះបដិបទាជាដំណើរទៅកាន់ធម៌រលត់ទុក្ខ ធម៌ទាំងឡាយដែលព្រះតថាគតសម្តែងហើយ បុគ្គលនោះបានឃើញដោយល្អ បានប្រព្រឹត្តដោយល្អ ដោយបញ្ញាផង អាសវៈពួកខ្លះ របស់បុគ្គលនោះ ក៏អស់ទៅ ព្រោះឃើញដោយបញ្ញាផង នេះហៅថា បុគ្គលជាទិដ្ឋិប្បត្ត ដូច្នេះ ។

បទថា **សទ្ធាវិមុត្តោ** គឺបុគ្គលដែលរួចផុតហើយ ដោយសទ្ធា ។ សួម្បី បុគ្គលដែលរួចផុតដោយសទ្ធានោះ មាន ៦ ពួក ដូចន័យមុននោះឯង ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា បុគ្គលខ្លះ ក្នុងលោកនេះ ដឹងច្បាស់តាមពិតថា នេះទុក្ខ ។បេ។ នេះជាបដិបទា ជាដំណើរទៅកាន់ធម៌ រលត់ទុក្ខ ធម៌ទាំងឡាយដែលព្រះតថាគតសម្តែងហើយ បុគ្គលនោះ បាន ឃើញដោយល្អ បានប្រព្រឹត្តដោយល្អ ដោយបញ្ញាផង អាសវៈពួកខ្លះ របស់ បុគ្គលនោះ ក៏អស់ទៅ ព្រោះឃើញដោយបញ្ញាផង តែមិនដូចទិដ្ឋិប្បត្តបុគ្គល ទេ នេះហៅថា បុគ្គលជាសទ្ធាវិមុត្ត ។ ក្នុងបុគ្គល ២ ប្រភេទនេះ ការអស់ កិលេសរបស់បុគ្គលដែលជាសទ្ធាវិមុត្ត ដូចគ្នានឹងការជឿ ដាក់ចិត្តជឿ និង បង្អោនចិត្តជឿ ក្នុងខណៈនៃមគ្គ ដែលជាចំណែកខាងដើម ។ ញាណដែលជា គ្រឿងកាត់កិលេសរបស់ទិដ្ឋិប្បត្តបុគ្គល ជាញាណមិនយឺតយូរ ជាញាណមុត ស្រួច និងក្លៀវក្លា រមែងនាំទៅក្នុងខណៈនៃមគ្គ ដែលជាចំណែកខាងដើម ព្រោះដូច្នោះ ទើបដូចកាលបុគ្គលយកដាវ ដែលមិនមុតកាប់ដើមចេក កន្លែង ដែលបុគ្គលកាប់ ក៏មិនរលោង ទាំងដាវក៏មិនធ្លុងទៅបានដោយរហ័ស បុគ្គល រមែងបានឮសំឡេង បុគ្គលត្រូវធ្វើសេចក្តីព្យាយាមដោយកម្លាំងច្រើនជាង យ៉ាង ណា មគ្គភាវនាដែលជាបុព្វភាគរបស់សទ្ធាវិមុត្តបុគ្គលនោះ ក៏គប្បីជ្រាប ដូច្នោះ ។ មួយ៉ាងទៀត ដូចកាលបុគ្គលយកដាវដែលមុតល្អ ហើយកាប់ដើមចេក កន្លែងដែលគេកាប់ក៏រលោង ទាំងដាវក៏ធ្លុងទៅបានរហ័ស បុគ្គលក៏មិនបានឮ សំឡេង កិច្ច គឺសេចក្តីព្យាយាម ដោយកម្លាំងច្រើនក៏មិនមាន យ៉ាងណា មគ្គ-

ភាវនា ដែលជាបុព្វភាគ របស់បញ្ញាវិមុត្តបុគ្គលនោះ ក៏គប្បីជ្រាបដូច្នោះ ។ បុគ្គលរមែងតាមរឭកដល់ធម៌ ដូច្នោះ ទើបឈ្មោះថា **ធម្មានុសារី** ។ បញ្ញា ឈ្មោះថា ធម៌ អធិប្បាយថា បុគ្គលរមែងចម្រើនមគ្គ ដែលមានបញ្ញាជាខាងដើម ។ សូម្បីក្នុងសទ្ធានុសារីបុគ្គល ក៏ន័យនេះដូចគ្នា ។ បុគ្គលទាំងពីរនោះ គឺបុគ្គលដែលតាំងនៅក្នុងសោតាបត្តិមគ្គនុ៎ះឯង ។ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ថា បុគ្គលណា កំពុងប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល មានឥន្ទ្រិយ គឺបញ្ញាដ៏ក្រៃលែង ចម្រើនអរិយមគ្គ មានបញ្ញាជាគ្រឿងនាំ មានបញ្ញាជាប្រធាន នេះហៅថា បុគ្គលជាធម្មានុសារី ។ ម្យ៉ាងទៀត បុគ្គលណា ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល មានឥន្ទ្រិយ គឺសទ្ធាដ៏ក្រៃលែង ចម្រើនអរិយមគ្គ មានសទ្ធាជាគ្រឿងនាំ មានសទ្ធាជាប្រធាន នេះហៅថា បុគ្គលជាសទ្ធានុសារី ។ សេចក្តីសង្ខេបក្នុងរឿងនេះ មានប្រមាណប៉ុណ្ណោះ ចំណែកឧភតោភាគវិមុត្តកថាជាដើមនេះ លោកពោលហើយ ក្នុងអធិការនៃបញ្ញាភាវនា ក្នុងបករណ៍វិសេស ឈ្មោះវិសុទ្ធិមគ្គដោយពិស្តារ ។ ដូច្នោះ គប្បីជ្រាបវិត្ថារកថា ដោយន័យដែលលោកពោលក្នុងវិសុទ្ធិមគ្គនោះចុះ ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីប្រកបចូលដោយន័យមុននោះឯង ។

[ ៨១ ] ពោជ្ឈង្គ ៧ ព្រះមានព្រះភាគត្រាស់ថា **បធាន**ដោយអំណាចការផ្តើមតាំងសេចក្តីព្យាយាម ក្នុងបទនេះថា **បធានេសុ** ដូច្នេះ ។ កថាដោយពិស្តាររបស់ពោជ្ឈង្គទាំង ៧ នោះ គប្បីជ្រាបដោយន័យដែលព្រះមានព្រះភាគ

ត្រាស់ទុកក្នុងមហាសតិប្បដ្ឋាន ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីប្រកបចូលដោយន័យមុននោះចុះ ។

[ ៨២ ] ក្នុងបទថា **ទុក្ខាបដិបទា** ជាដើម មានន័យដោយពិស្តារដូច្នេះ ក្នុងបាលីប្រទេសនោះ បណ្តាញាណទាំងនោះ បដិបទា ៤ តើដូចម្តេច បញ្ញាដែលប្រតិបត្តិលំបាក មានការត្រាស់ដឹងយូរ ១ បញ្ញាដែលប្រតិបត្តិលំបាក មានការត្រាស់ដឹងឆាប់ ១ បញ្ញាដែលប្រតិបត្តិងាយ មានការត្រាស់ដឹងយូរ ១ បញ្ញាដែលប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ១ ។ បណ្តាបញ្ញាទាំង ៤ នោះ បញ្ញាដែលប្រតិបត្តិលំបាក មានការត្រាស់ដឹងយូរ តើដូចម្តេច ។ បុគ្គលញ៉ាំងលោកុត្តរសមាធិឲ្យកើតដោយលំបាក ដោយកម្រ កាលត្រាស់ដឹងនូវហេតុ គឺលោកុត្តរសមាធិនោះ ដោយយឺតយូរ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណា កើតឡើង នេះហៅថា បញ្ញាដែលប្រតិបត្តិលំបាក មានការត្រាស់ដឹងយូរ ។

ក្នុងបាលីប្រទេសនោះ បណ្តាបញ្ញាទាំងនោះ បញ្ញាដែលប្រតិបត្តិលំបាក មានការត្រាស់ដឹងឆាប់ តើដូចម្តេច ។ កាលបុគ្គលញ៉ាំងលោកុត្តរសមាធិឲ្យកើត ដោយលំបាក ដោយកម្រ កាលត្រាស់ដឹងនូវហេតុ គឺលោកុត្តរសមាធិនោះ ដោយឆាប់ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណាកើតឡើង នេះហៅថា បញ្ញាដែលប្រតិបត្តិលំបាក មានការត្រាស់ដឹងឆាប់ ។

ក្នុងបាលីប្រទេសនោះ បណ្តាបញ្ញាទាំងនោះ បញ្ញាដែលប្រតិបត្តិងាយ

មានការត្រាស់ដឹងយូរ តើដូចម្តេច កាលបុគ្គលញុំាងលោកុត្តរសមាធិឲ្យកើត ដោយមិនលំបាក ដោយមិនក្រ កាលដឹងច្បាស់នូវហេតុ គឺលោកុត្តរសមាធិនោះ ដោយយឺតយូរ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចារណាធម៌ ការឃើញត្រូវណាកើតឡើង នេះហៅថា បញ្ញាដែលប្រតិបត្តិងាយ មានការត្រាស់ដឹងយូរ ។

ក្នុងបាលីប្រទេសនោះ បណ្តាបញ្ញាទាំងនោះ បញ្ញាដែលប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ តើដូចម្តេច ។ កាលបុគ្គលញុំាងលោកុត្តរសមាធិឲ្យកើតដោយមិនលំបាក ដោយមិនក្រ កាលដឹងច្បាស់នូវហេតុ គឺលោកុត្តរ-សមាធិនោះដោយឆាប់ បញ្ញា ការដឹងច្បាស់ ។បេ។ ការមិនវង្វេង ការពិចា-រណាធម៌ ការឃើញត្រូវណាកើតឡើង នេះហៅថា បញ្ញាដែលប្រតិបត្តិងាយ មានការត្រាស់ដឹងឆាប់ ។ សេចក្តីសង្ខេបក្នុងទីនេះប៉ុណ្ណោះ ។ ចំណែកសេចក្តីពិស្តារ លោកពោលហើយ ក្នុងវិសុទ្ធិមគ្គ ។ ពាក្យដ៏សេស ក្នុងទីនេះ គប្បីប្រកបដោយន័យដូចពោលហើយនោះឯង ។

[ ៨៣ ] បទថា **ន ចេវ មុសាវាទូបសញ្ហិតំ** សេចក្តីថា ភិក្ខុរូបខ្លះ ក្នុងសាសនានេះ តាំងនៅក្នុងកស្សសមាចារ ( មារយាទជាប់ទាក់ទងនឹងការនិយាយ ) ក្តី មិនចូលទៅកាត់កថាមគ្គក្តី រមែងមិនពោលវាចាដែលប្រកបដោយមុសាវាទឡើយ វៀរវោហារដែលមិនប្រសើរ ៨ យ៉ាងចេញ ពោលវាចាដែលប្រកបដោយវោហារដ៏ប្រសើរ ៨ យ៉ាងប៉ុណ្ណោះ ។ បទថា **ន ច វេភូតិយំ** សេចក្តីថា ភិក្ខុរូបខ្លះក្នុងសាសនានេះ សូម្បីតាំងនៅក្នុងកស្សសមាចារ

រមែងមិនពោលវាចា ដែលធ្វើឲ្យបែកបាក់គ្នា ។ បទថា **បេសុណិយំ** នោះ ជាវេវចនៈរបស់បទថា **វេភូតិយំ** នោះ ។ ពិតហើយ វាចាដែលធ្វើឲ្យបែកបាក់គ្នា លោកហៅថា **បេសុណិយំ** ព្រោះញុំាងភាពជាទីស្រឡាញ់គ្នាឲ្យវិនាស ។ ព្រះមហាសិវត្ថេរពោលថា បទថា **បេសុណិយំ** នោះ ជាឈ្មោះរបស់វាចានោះ ។ បទថា **ន ច សារម្ភជំ** សេចក្តីថា វាចាណាកើតព្រោះការប្រណាំងប្រជែង ភិក្ខុរមែងមិនពោលវាចានោះ កាលជនដទៃពោលថា លោកទ្រុស្ត-សីលក្តី ថាលោក និងអាចារ្យរបស់លោកទ្រុស្តសីលក្តី ឬកាលជនដទៃពោលថា លោកត្រូវអាបត្តិ រមែងមិនពោលវាចា ដែលប្រព្រឹត្តទៅដោយ ការពោលបាចសាចទៅខាងក្រៅ ឬវាចាដែលក្រៃលែងជាងការធ្វើ ដោយន័យជាដើមថា យើងត្រាច់បិណ្ឌបាតរហូតដល់ក្រុងបាដលីបុត្ត ដូច្នេះ ។ បទថា **ជយាបេក្ខោ** គឺជាអ្នកប្រាថ្នាចំពោះជ័យជម្នះ ។ អធិប្បាយថា ភិក្ខុដែលសម្លឹងដល់ជ័យជម្នះ គឺប្រាថ្នាជ័យជម្នះជាប្រមុខ រមែងមិនពោល ដូចហត្ថកសក្យបុត្រ ពោលវាចាពិត និងវាចាឡេះឡោះណាមួយថា ធម្មតាពួកតិរ្ថិយ បុគ្គលគប្បីឈ្នះដោយធម្មិខះ ដោយអធម្មិខះ ដូច្នេះ ។ បញ្ញាលោកហៅថា **មន្តា** ក្នុងបទថា **មន្តា មន្តា ច វាចំ ភាសតិ** នេះ ។ ពោលវាចាដោយបញ្ញា ឈ្មោះថា **មន្តា** ។ ម្យ៉ាងទៀត បទថា **មន្តា** គឺពិចារណាហើយ ។ មានពាក្យអធិប្បាយដែលព្រះមានព្រះភាគត្រាស់ថា ភិក្ខុក្នុងសាសនានេះ តាំងនៅក្នុងកស្សសមាចារ កាលពោលរហូតដល់អស់មួយថ្ងៃ ក៏ពិចារណាដោយបញ្ញា ពោលចំពោះពាក្យដែលសមគួរប៉ុណ្ណោះ ។ បទថា **និធានវតី** គឺគួរដើម្បីនឹង យកទុកក្នុងចិត្ត ។

បទថា **កាលេន** គឺតាមកាលដ៏គួរហើយ និងជល់ហើយ ។ ពិតហើយ វាចាដែលបុគ្គលពោលហើយយ៉ាងនេះ រមែងជាវាចាដែលមិនកុហក មិនញុះញង់ មិនបោកទាប មិនអួតអាង មិនផ្តេសផ្តាស ។ វាចាបែបនេះ ហៅថា វាចាអាស្រ័យសច្ចៈ ៤ ខ្លះ វាចាអាស្រ័យត្រៃសិក្ខាខ្លះ វាចាអាស្រ័យកថាវត្ថុ ១០ ខ្លះ វាចាអាស្រ័យធុតង្គគុណ ១៣ ខ្លះ វាចាអាស្រ័យពោធិបក្ខិយធម៌ ៣៧ ប្រការខ្លះ វាចាអាស្រ័យមគ្គខ្លះ ។ ដោយហេតុនោះ ទើបព្រះសារីបុត្រពោលថា **ឯតទានុត្តរិយំ ភន្តេ ភាសសមាចារេ** ដូច្នេះ ។ ពាក្យនោះ គប្បីប្រកបចូលដោយន័យមុននោះចុះ ។

[ ៨៤ ] ប្រើនបទថា **សច្ចោ ចស្ស សទ្ធោ ច** សេចក្តីថា ភិក្ខុក្នុងសាសនានេះ ជាអ្នកតាំងនៅក្នុងសីលាចារ គប្បីជាអ្នកពិតត្រង់ ពោលវាចាពិត គប្បីជាអ្នកមានសទ្ធា និងជល់ព្រមដោយសទ្ធា ។ សួរថា សច្ចៈ ព្រះមានព្រះភាគត្រាស់ខាងដើមហើយមិនមែនឬ ព្រោះហេតុអ្វី ទើបក្នុងទីនេះទ្រង់ត្រាស់ទៀត ឆ្លើយថា សច្ចវាចា ទ្រង់ត្រាស់ហើយខាងដើម ។ ក្នុងទីនេះ ទ្រង់ត្រាស់ដើម្បីសម្តែងថា ភិក្ខុតាំងនៅក្នុងសីលាចារហើយ រមែងមិនពោលមុសាវាទដោយហោចទៅសូម្បីដោយការពោលឲ្យសើច ។ ឥឡូវនេះ ព្រះថេរៈដើម្បីនឹងសម្តែងថា ភិក្ខុនោះសម្រេចការរស់នៅដោយធម៌ស្មើ ដូច្នេះ ទើបពោលពាក្យថា **ន ច កុហកោ** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **កុហកោ** ជាដើម ព្រះមានព្រះភាគ ទ្រង់អធិប្បាយពិស្តារហើយ ក្នុងព្រហ្មជាលសូត្រ ។ ប្រើនបទថា **ឥន្ទ្រិយេសុ គុត្តទ្វារោ ភោជនេ មត្តញ្ញូ** សេចក្តីថា ជាអ្នកឃុំគ្រង

ទ្វារល្អហើយក្នុងឥន្ទ្រិយទាំង ៦ ទាំងជាអ្នកស្គាល់ប្រមាណក្នុងភោជន ។ បទថា **សមការី** គឺអ្នកមានប្រក្រតីប្រព្រឹត្តស្មើ អធិប្បាយថា ភិក្ខុក្នុងព្រះសាសនានេះ វៀរចាកហេតុ មានការវៀចវៀរផ្លូវកាយជាដើម ប្រព្រឹត្តស្មើក្នុងផ្លូវកាយវាចា និងចិត្ត ។ បទថា **ជាគរិយានុយោគមនុយុត្តោ** សេចក្តីថា ភិក្ខុរមែងខ្វល់ខ្វាយប្រកបដោយភាពជាអ្នកភ្ញាក់រឭក ដោយន័យដែលព្រះមានព្រះភាគត្រាស់ថា ភិក្ខុគប្បីបែងចែកពេលថ្ងៃ និងពេលយប់ចេញជា ៦ ចំណែក ហើយគប្បីប្រកបសេចក្តីព្យាយាមក្នុងពេលថ្ងៃ ដោយការចង្ក្រម និងអង្គុយ ។ បទថា **អតន្ទិតោ** គឺបានដល់ មិនខ្ជិលច្រអូស គឺវៀរចាកការខ្ជិលច្រអូសផ្លូវកាយ ។ បទថា **អារទ្ធវិរិយោ** សេចក្តីថា ជាអ្នកផ្តើមសេចក្តីព្យាយាម ដោយសេចក្តីព្យាយាមផ្លូវកាយ បន្ទោបង់ការជាប់ជំពាក់ដោយពួកចេញ ហើយនៅម្នាក់ឯង ដោយអំណាចអារព្ភវត្ថុ ៨ ក្នុងឥរិយាបថទាំង ៤ ។ ជាអ្នកផ្តើមសេចក្តីព្យាយាម ដោយសេចក្តីព្យាយាមផ្លូវចិត្ត បន្ទោបង់ការជាប់ជំពាក់ដោយកិលេសចេញ នៅម្នាក់ឯង ដោយអំណាចសមាបត្តិ ៨ ។ ម្យ៉ាងទៀត ហាមការកើតឡើងនៃកិលេស ដោយប្រការណាមួយ ក៏ចាត់ថា ជាអ្នកផ្តើមសេចក្តីព្យាយាម ដោយសេចក្តីព្យាយាមផ្លូវចិត្តដូចគ្នា ។ បទថា **ឈាយី** គឺជាអ្នកសម្លឹងដោយអារម្មណូបនិជ្ឈាន និងលក្ខណូបនិជ្ឈាន ។ បទថា **សតិមា** គឺប្រកបដោយសតិ ដែលអាចរឭកដល់កិច្ចដែលធ្វើទុកយូរហើយបានជាដើម ។ បទថា **កល្យាណប្បដិភាណោ** គឺបរិបូណ៌ដោយការនិយាយល្អ និងបរិបូណ៌ដោយបដិភាណ ។ បុគ្គលនោះ ជាអ្នកប្រកបដោយបដិភាណមិនមែនជាអ្នកខ្វះ

បដិភាណ ។ ពិតហើយ ភិក្ខុដែលតាំងនៅក្នុងសីលសមាចារ មិនមែនខ្វះបដិភាណទេ ។ ម្យ៉ាងទៀត ភិក្ខុដែលប្រកបដោយបដិភាណ ដូចជាព្រះវង្គីសៈដូច្នោះ ។ បទថា **គតិមា** គឺប្រកបដោយបញ្ញា ដែលអាចក្នុងការដើរទៅ ។ បទថា **ធិតិមា** គឺប្រកបដោយបញ្ញាដែលអាចក្នុងការទ្រទ្រង់ចាំ ។ ឯបទថា **មតិ** ក្នុងបទថា **មតិមា** នេះ ជាឈ្មោះរបស់បញ្ញា ដូច្នោះ អធិប្បាយថា អ្នកមានបញ្ញា ។ បញ្ញានោះឯង លោកពោលដោយបទទាំង ៣ នេះ ដូចពណ៌នាមកដូច្នេះ ។ ក្នុងបាលីប្រទេសនោះ សេចក្តីព្យាយាម ជាគ្រឿងធ្វើសមណធម៌ លោកពោលខាងដើមហើយ ។ ក្នុងទីនេះ លោកពោលសេចក្តីព្យាយាម ជាគ្រឿងរៀនសូត្រព្រះពុទ្ធវចនៈ ។ ម្យ៉ាងទៀត វិបស្សនាបញ្ញា លោកពោលទុកហើយក្នុងខាងដើម ។ ក្នុងទីនេះ លោកពោលដល់បញ្ញាដែលជាគ្រឿងរៀនសូត្រព្រះពុទ្ធវចនៈ ។ ច្រើនបទថា **ន ច កាមេសុ គិទ្ធោ** គឺជាអ្នកមិនជាប់ក្នុងវត្ថុកាម និងកិលេសកាម ។ ច្រើនបទថា **សតោ ច និបកោ ចរេ** សេចក្តីថា ភិក្ខុគប្បីជាអ្នកប្រកបដោយសតិ និងដោយញាណ ក្នុងឋានៈទាំង ៧ មានការឈានទៅខាងមុខជាដើម ត្រាច់ទៅ ។ បញ្ញា ឈ្មោះ **នេបក្ក** ភិក្ខុលោកពោលថា មានបញ្ញា ដូច្នេះ ព្រោះប្រកបដោយបញ្ញានោះ ពាក្យដ៏សេសក្នុងទីនេះ គប្បីប្រកបចូលដោយន័យមុននោះចុះ ។

[ ៨៥ ] បទថា **បច្ចត្តំ យោនិសោមនសិការា** គឺដោយយោនិសោមនសិការរបស់ព្រះអង្គ ។ បទថា **យថានុសិដ្ឋំ តថាបដិបជ្ជមានោ** គឺជាអ្នកបដិបត្តិតាមដែលតថាគតបានប្រៀនប្រដៅ ។ បទថា **តិណ្ណំ សញ្ញោជនានំ**

**បរិក្ខយា** ជាដើម មានសេចក្ដីដូចពោលហើយ ។ ពាក្យដ៏សេស ក្នុងទីនេះ គប្បីប្រកបចូលដោយន័យមុននោះឯង ។

[ ៨៦ ] បទថា **បរបុគ្គលវិមុត្តិញ្ញាណេ** គឺក្នុងញាណជាគ្រឿងរួចផុតចាកកិលេសដោយមគ្គនោះៗ របស់បុគ្គលដទៃ មានព្រះសោតាបន្នជាដើម ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីប្រកបចូលដោយន័យមុននោះឯង ។

[ ៨៧ ] បទថា **អមុត្រាសី ឯវំ ឆាមោ** សេចក្ដីថា បុគ្គលម្នាក់ កាលរឭកបុព្វេនិវាស រមែងកំណត់ឈ្មោះ និងគោត្រទៅបាន ។ បុគ្គលម្នាក់ទៀតរឭកបានតែខន្ធសុទ្ធៗ ប៉ុណ្ណោះ ។ បុគ្គលមួយពួក អាចរឭកបាន បុគ្គលមួយពួក មិនអាច ។ ក្នុងទីនេះ មិនបានកាន់យកដោយអំណាចនៃអ្នកអាច ។ បានកាន់យកដោយអំណាចនៃអ្នកមិនអាច អ្នកមិនអាច នឹងធ្វើអ្វីបាន ។ បុគ្គលនោះ រឭកចំពោះតែខន្ធសុទ្ធៗ តាំងនៅក្នុងទីបំផុតច្រើនសែនជាតិ ឈមចុះដោយញាណ កំណត់នាម និងគោត្រ ។ ព្រះសារីបុត្តត្ថេរ កាលសម្ដែងនាមនិងគោត្រនោះ ទើបពោលពាក្យថា **ឯវំ ឆាមោ** ដូច្នេះជាដើម ។ បទថា **សោ ឯវមាហ** គឺបុគ្គលដែលប្រកាន់ដោយទិដ្ឋិនោះ បានពោលយ៉ាងនេះ ។ ក្នុងបាលីប្រទេសនោះ កាលបុគ្គលនោះពោលថា ទៀង ហើយពោលថា សត្វទាំងនោះរមែងអន្ទោលទៅ ដូច្នេះ វាចារមែងមានខាងដើម និងខាងចុងខ្វាស់គ្នាក៏ពិត តែបុគ្គលនោះ កំណត់ពាក្យនោះមិនបាន ព្រោះជាអ្នកប្រកាន់ទិដ្ឋិ ។ សេចក្ដីពិត ឋាន: ឬការកំណត់របស់អ្នកប្រកាន់ទិដ្ឋិ រមែងមិនមាន ។ ពាក្យនោះ លោកឲ្យពិស្ដារហើយក្នុងព្រហ្មជាលសូត្រថា បុគ្គលនោះប្រកាន់យក

វត្ថុនេះហើយ ក៏លែងវត្ថុនោះ លុះលែងវត្ថុនោះហើយ ក៏ប្រកាន់យកវត្ថុនេះ ដូច្នេះ ។ ដោយបទថា **អយំ តតិយោ សស្សតវាទោ** នេះ ព្រះថេរៈពោលបុគ្គលដែលជាសស្សតវាទទុក ៣ ប្រភេទ ដោយអំណាចនៃឈាន-លាភីបុគ្គលប៉ុណ្ណោះ ។ ប៉ុន្តែ ព្រះមានព្រះភាគបានត្រាស់បុគ្គល ៤ ប្រភេទក្នុងព្រហ្មជាលសូត្រ ព្រោះសង្គ្រោះបុគ្គលដែលជាតក្កីវាទនោះចូលផង ។ ឯពាក្យពោលពិស្តាររបស់បុគ្គលដែលមានវាទៈ ៣ ប្រភេទនោះ គប្បីជ្រាបតាមន័យដែលលោកពោលទុកហើយ ក្នុងព្រហ្មជាលសូត្រ ។ ពាក្យដ៏សេសក្នុងទីនេះ គប្បីធ្វើឲ្យពិស្តារដោយន័យដែលពោលហើយ ក្នុងកាលមុន ។

[ ៨៨ ] បទថា **គណនាយ វា** គឺដោយការរាប់ជាពួក ។ បទថា **សង្ខានេន** គឺដោយការរាប់ដោយចិត្ត មិនឲ្យដាច់ខ្សែតាមពីរវិធីនោះ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងចំពោះការរាប់ជាពួក មានពាក្យអធិប្បាយដែលព្រះសារីបុត្រពោលទុកថា នរណាមិនអាចនឹងធ្វើជាពួក ដោយអំណាចរយ ពាន់សែន កោដិនៃឆ្នាំទាំងឡាយ ហើយរាប់ថា មួយរយឆ្នាំប៉ុណ្ណោះ ដូច្នេះ ឬថា ។បេ។ កោដិឆ្នាំប៉ុណ្ណោះ ។ ព្រះថេរៈរមែងសម្តែងថា ព្រោះព្រះអង្គទ្រង់បំពេញបារមី ១០ ប្រការ ព្រោះព្រះអង្គ ទ្រង់សម្រេចសព្វញ្ញុតញ្ញាណ ព្រោះព្រះអនាវរណញ្ញាណរបស់ព្រះអង្គប្រព្រឹត្តទៅចាស់ក្លា ទើបព្រះអង្គទ្រង់ឈ្លាសក្នុងទេសនាញាណជាប្រមុខ ធ្វើឲ្យមានទីបំផុតដោយការរាប់ឆ្នាំ សូម្បីដោយការរាប់កប្ប ក៏កំណត់សម្តែងថា មានប្រមាណប៉ុណ្ណោះបាន ។ សេចក្តីក្នុងបាលី មានន័យដូចពោលហើយក្នុងបាលីនេះ ។ ពាក្យដ៏សេសក្នុងទីនេះ ក៏គប្បី

ប្រកប ចូលដោយន័យមុននោះចុះ ។

[ ៨៩ ] ប្រើនបទថា **ឯតទានុត្តរិយំ ភន្តេ សត្តានំ ចុតូបបាតញ្ញាណេ** ព្រះថេរៈរមែងសម្តែងថា បពិត្រព្រះអង្គដ៏ចម្រើន ញាណទេសនា ដោយអំណាចចុតិ និងបដិសន្ធិនៃសត្វទាំងឡាយនេះ មានហើយ ញាណទេសនានោះ ចាត់ជាកំពូលរបស់ព្រះអង្គ សូម្បីព្រះពុទ្ធក្នុងអតីតទាំងឡាយ ក៏ទ្រង់សម្តែងយ៉ាងនេះដូចគ្នា ។ សូម្បីព្រះពុទ្ធក្នុងអនាគត ក៏នឹងទ្រង់សម្តែងយ៉ាងនេះដូចគ្នា ។ ទ្រង់ប្រៀបធៀបដោយព្រះញាណរបស់ព្រះពុទ្ធ ទាំងក្នុងអតីត និងក្នុងអនាគតទាំងនោះ ហើយទ្រង់សម្តែង បពិត្រព្រះអង្គដ៏ចម្រើន ដោយហេតុនេះ ខ្ញុំព្រះអង្គមានសេចក្តីជ្រះថ្លាក្នុងព្រះសាស្តាយ៉ាងនេះ ។ សេចក្តីរបស់ព្រះបាលីក្នុងទីនេះ លោកក៏ឲ្យពិស្តារហើយដូចគ្នា ។

[ ៩០ ] ពីរបទថា **សាសវា សឧបធិកា** គឺឫទ្ធិដែលមានទោស គឺមានការតិះដៀល ។ ប្រើនបទថា **នោ អរិយាតិ វុច្ចតិ** សេចក្តីថា ឫទ្ធិដូច្នោះ មិនហៅថា ឫទ្ធិរបស់អរិយៈឡើយ ។ ពីរបទថា **អនាសវា អនុបធិកា** គឺមិនមានទោស បានដល់ មិនមានប្រការគួរតិះដៀល ។ ពីរបទថា **អរិយាតិ វុច្ចតិ** គឺឫទ្ធិដូច្នេះ ហៅថា ឫទ្ធិរបស់អរិយៈ ។ ប្រើនបទថា **អប្បដិក្កូលសញ្ញី តត្ថ វិហរតិ** សេចក្តីថា ភិក្ខុរមែងមានការសម្គាល់ក្នុងវត្ថុបដិកូលថា មិនបដិកូល យ៉ាងណា ។ គឺលោករមែងផ្សាយមេត្តាទៅក្នុងសត្វដែលបដិកូល គឺរួមសេចក្តីសម្គាល់ថា ជាធាតុចុះក្នុងសង្ខារ ។ ដូចដែលលោកពោលថា ភិក្ខុជាអ្នកមានសេចក្តីសម្គាល់ក្នុងវត្ថុបដិកូលថា មិនគួរខ្ពើមនោះ ដូចម្តេច គឺ

លោករមែងផ្សាយមេត្តាទៅក្នុងវត្ថុដែលមិនគួរប្រាថ្នា ឬសង្គ្រោះដោយជាធាតុ ដូច្នេះ ។ ច្រើនបទថា **បដិក្កូលសញ្ញី តត្ថ វិហរតិ** សេចក្ដីថា ភិក្ខុរមែងផ្សាយអសុភសញ្ញាទៅក្នុងសត្វដែលមិនបដិកូល គឺសង្គ្រោះអនិច្ចសញ្ញាចុះក្នុងសង្ខារ ។ ដូចដែលលោកពោលថា ភិក្ខុជាអ្នកមានការសម្គាល់ក្នុងវត្ថុមិនបដិកូលថាបដិកូល យ៉ាងណា គឺលោករមែងផ្សាយទៅដោយអសុភសញ្ញាក្នុងវត្ថុដែលគួរប្រាថ្នា ឬរួមចុះដោយជារបស់មិនទៀង ដូច្នេះ ។ គប្បីជ្រាបសេចក្ដីក្នុងបទដ៏សេសយ៉ាងនេះ ។ ច្រើនបទថា **ឧបេក្ខកោ តត្ថ វិហរតិ** សេចក្ដីថា ភិក្ខុមិនត្រេកត្រអាលក្នុងអារម្មណ៍ដែលគួរប្រាថ្នា និងមិនថ្នាំងថ្នាក់ក្នុងអារម្មណ៍ដែលមិនគួរប្រាថ្នា ទាំងមិនឲ្យមោហៈកើតឡើង ដូចជនពួកដទៃឲ្យមោហៈកើតឡើង ដោយការសម្លឹងអារម្មណ៍ដែលមិនមានចំណែកស្មើ ជាអ្នកព្រងើយក្នុងអារម្មណ៍ទាំង ៦ ដោយឧបេក្ខាមានអង្គ ៦ ។ ច្រើនបទថា **ឯត-ទានុត្តរិយំ ភន្តេ ឥទ្ធិវិធាសុ** សេចក្ដីថា បពិត្រព្រះអង្គដ៏ចម្រើន នេះចាត់ថាជាទេសនាដ៏កំពូលយ៉ាងនេះ ក្នុងចំណែកឫទ្ធិទាំងពីរ ។ បទថា **តំ ភគវា** សេចក្ដីថា ព្រះមានព្រះភាគ រមែងដឹងក្រៃលែងនូវទេសនាទាំងអស់នោះ មិនមានសល់ឡើយ ។ ពីរបទថា **តំ ភគវតោ** សេចក្ដីថា កាលព្រះមានព្រះភាគទ្រង់ដឹងក្រៃលែងនូវទេសនានោះ ដោយមិនមានសល់ ។ ច្រើនបទថា **ឧត្តរិ អភិញ្ញេយ្យំ នត្ថិ** សេចក្ដីថា ធម៌ដែលនឹងគប្បីដឹងក្រៃលែងទៅជាងនេះរមែងមិនមាន គឺពាក្យនេះថា ធម៌ ឬបុគ្គលដទៃអំពីនេះ ដែលព្រះមានព្រះភាគទ្រង់មិនជ្រាប មិនដឹង មិនមានឡើយ ។ ច្រើនបទថា **យទភិជានំ អញ្ញោ**

**សមណោ វា** សេចក្តីថា វត្ថុណាដែលព្រះអង្គមិនដឹង សមណៈ ឬព្រាហ្មណ៍ដទៃនឹងដឹងវត្ថុនោះ ជាអ្នកមានសេចក្តីដឹងក្រៃលែងជាង គឺមានបញ្ញាច្រើនជាងព្រះមានព្រះភាគ ។ បទថា **យទិទំ** ក្នុងបទថា **យទិទំ ឥទ្ធិវិធាសុ** ត្រឹមតែជានិបាត ។ បុគ្គលដែលក្រៃលែងជាងព្រះមានព្រះភាគ ក្នុងចំណែកឥទ្ធិវិធីមិនមានឡើយ ។ ពិតហើយ សូម្បីព្រះពុទ្ធក្នុងអតីតទាំងឡាយ ក៏ទ្រង់សម្តែងឫទ្ធិទាំង ២ យ៉ាងនេះ ។ សូម្បីព្រះពុទ្ធក្នុងអនាគត ក៏នឹងសម្តែងឫទ្ធិទាំង ២ នេះ ។ សូម្បីព្រះអង្គទ្រង់ប្រៀបផ្ទឹមដោយញាណរបស់ព្រះពុទ្ធទាំងនោះហើយ ក៏ទ្រង់សម្តែងឫទ្ធិទាំងនេះ ។ ព្រះថេរៈកាលសម្តែងថា ព្រះមានព្រះភាគប៉ុណ្ណោះ ទ្រង់ជាកំពូលក្នុងចំណែកឥទ្ធិវិធីដូចពណ៌នាមកដូច្នេះ ដូច្នេះ ទើបសម្តែងថា បពិត្រព្រះអង្គដ៏ចម្រើន ដោយហេតុនេះ ទើបខ្ញុំព្រះអង្គ មានសេចក្តីជ្រះថ្លាក្នុងព្រះសាស្តា ។

ដោយពាក្យមានប្រមាណប៉ុណ្ណោះ ព្រះធម្មសេនាបតី អង្គុយក្នុងទីសម្រាកពេលថ្ងៃ ហើយពិចារណាធម៌ដទៃតទៅ ១៦ យ៉ាង ពួកណា ធម៌ពួកនោះ ជាធម៌ដែលលោកសម្តែងហើយ ។

[ ៩១ ] ឥឡូវនេះ ព្រះថេរៈកាលសម្តែងគុណរបស់ព្រះមានព្រះភាគដោយអាការដទៃទៀត ទើបទូលពាក្យថា **យន្តំ ភន្តេ** ជាដើមដូច្នេះ ។ បណ្តាបទទាំងនោះ ពីរបទថា **សទ្ធេន កុលបុត្តេន** សេចក្តីថា ព្រះពោធិសត្វដែលមានក្នុងអតីត អនាគត និងបច្ចុប្បន្ន ឈ្មោះថា កុលបុត្រអ្នកមានសទ្ធា ។ ព្រោះដូច្នោះ ទើបមានពាក្យអធិប្បាយថា ធម៌ណាដែលព្រះសព្វញ្ញូពោធិសត្វ

គប្បីសម្រេច ។ សួរថា អ្វីដែលព្រះសព្វញ្ញូពោធិសត្វ គប្បីសម្រេច ឆ្លើយថា លោកុត្តរធម៌ ៩ ដែលព្រះសព្វញ្ញូពោធិសត្វនោះ គប្បីសម្រេច ។ ពាក្យទាំងអស់ មាន **វីរិយំ ថាមោ** ជាដើម ក្នុងបទថា **អារទ្ធវីរិយេន** ជាដើមនេះ ជាវេវចនៈរបស់សេចក្តីព្យាយាម ។ បណ្តាបទទាំងនោះ បទថា **អារទ្ធវីរិយេន** គឺអ្នកផ្គងសេចក្តីព្យាយាម ។ បទថា **ថាមវតា** គឺបរិបូណ៌ដោយកម្លាំង គឺមានសេចក្តីព្យាយាមខ្លាំងក្លា ។ បទថា **បុរិសថាមេន** អធិប្បាយថា វត្ថុណាដែលព្រះសព្វញ្ញូពោធិសត្វអ្នកមានកម្លាំងនោះ គប្បីសម្រេចដោយកម្លាំងរបស់បុរស ។ ក្នុងពីរបទបន្ទាប់ទៅ ក៏មានន័យដូច្នេះដូចគ្នា ។ បទថា **បុរិសធោរេយ្យេន** គឺមហាបុរសដែលអាចដើម្បីនាំធុរៈ ដែលព្រះពុទ្ធទាំងឡាយ អ្នកមានធុរៈ មិនមានបុគ្គលស្មើ គប្បីនាំទៅ ។ ពីរបទថា **អនុប្បត្តំ តំ ភគវតា** ព្រះថេរៈរមែងសម្តែងថា ធម៌ទាំងអស់នោះ ដែលព្រះពុទ្ធទាំងក្នុងអតីត ទាំងក្នុងអនាគតគប្បីសម្រេច ធម៌ទាំងអស់នោះ ព្រះមានព្រះភាគ ទ្រង់តាមសម្រេចបានហើយ គុណណាមួយនឹងខ្វះទៅក៏មិនមាន ដូច្នេះ ។ ពីរបទថា **កាមេសុ កាមសុខល្លិកានុយោគំ** គឺព្រះមានព្រះភាគ ទ្រង់មិនតាមប្រកបកាមសុខក្នុងចំណែកវត្ថុកាម ។ ព្រះថេរៈរមែងសម្តែងថា សមណព្រាហ្មណ៍ពួកដទៃ មានកេណិយជដិលជាដើម គិតគ្នាថា នរណានឹងដឹងបរលោក ការដែលបរិព្វាជិកានេះយកដៃដែលមានរោមទន់ មកថ្នាក់ថ្នម ជាសេចក្តីសុខ ដូច្នេះ ទើបប្រឡូកប្រឡំដោយបរិព្វាជិកាទាំងឡាយ ដែលចងផ្នួងសក់ ៣ ពួកព្រាហ្មណ៍នាំគ្នាសោយអារម្មណ៍ មានរូបជាដើម ដែលបរិបូណ៌យ៉ាងក្រៃលែង តាមប្រកប

សេចក្ដីសុខក្នុងកាម យ៉ាងណា ព្រះមានព្រះភាគ ទ្រង់មិនប្រកបដូច្នោះឡើយ ។ បទថា **ហីនំ** គឺថោកទាប ។ បទថា **គម្មំ** គឺជាធម៌របស់អ្នកស្រុក ។ បទថា **បោថុជ្ជនិកំ** គឺដែលបុថុជ្ជនគួរសេព ។ បទថា **អនរិយំ** គឺជាធម៌មានទោស ឬដែលព្រះអរិយៈទាំងឡាយមិនគួរសេព ។ បទថា **អនត្ថសញ្ហិតំ** គឺមិនប្រកបដោយប្រយោជន៍ ។ បទថា **អត្តកិលមថានុយោគំ** គឺការតាមប្រកបសេចក្ដីព្យាយាម ដែលធ្វើខ្លួនឲ្យក្ដៅក្រហាយ និងអន្ទះអន្ទែង ។ បទថា **ទុក្ខំ** គឺប្រកបដោយទុក្ខ ឬទ្រាំបានដោយលំបាក ។ សមណព្រាហ្មណ៍ពួកខ្លះ គិតគ្នាថា ពួកយើងនឹងលះបង់នូវការប្រកបសេចក្ដីសុខផ្លូវកាម ដូច្នេះ ទើបនាំគ្នាស្ទុះទៅកាន់សេចក្ដីលំបាកផ្លូវកាយ តអំពីនោះ ក៏គិតថា យើងនឹងផុតពីសេចក្ដីលំបាកនោះ ដូច្នេះ ទើបនាំគ្នាស្ទុះទៅកាន់សេចក្ដីសុខផ្លូវកាយ យ៉ាងណា ព្រះមានព្រះភាគ មិនដូច្នោះឡើយ ។ តែព្រះមានព្រះភាគ ទ្រង់វៀរអន្តធម៌ទាំង ២ យ៉ាងនោះហើយ ទ្រង់បដិបត្តិបដិបទាប្រពៃ ដែលព្រះអង្គត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ មជ្ឈិមាបដិបទា ដែលព្រះតថាគត ដឹងក្រៃលែងហើយ ធ្វើឲ្យច្បាស់ដោយចក្ខុហើយ ដូច្នេះ ដូច្នោះ ទើបព្រះអង្គត្រាស់ថា **ន ច អត្តកិលមថានុយោគំ** ដូច្នេះ ជាដើម ។

បទថា **អាភិចេតសិកានំ** គឺកើតឡើងក្នុងអភិចិត្ត អធិប្បាយថា កន្លងកាមាវចរចិត្ត ហើយតាំងនៅ ។ បទថា **ទិដ្ឋធម្មសុខវិហារានំ** គឺដែលឲ្យនៅយ៉ាងសប្បាយក្នុងអត្តភាពនេះឯង ។ ពិតហើយ ទុតិយជ្ឈានផលសមាបត្តិ ព្រមដោយបីតិ ព្រះមានព្រះភាគត្រាស់ក្នុងបោដ្ឋបាទសូត្រ ។ ឈានដែលជាបាទ

នៃវិបស្សនា ព្រមដោយមគ្គ ព្រះមានព្រះភាគត្រាស់ក្នុងបាសាទិកសូត្រ ។ ផលសមាបត្តិ ដែលទាក់ទងក្នុងចតុត្ថជ្ឈាន ព្រះអង្គត្រាស់ក្នុងទសុត្តរសូត្រ ។ ក្នុងសម្បសាទនីយសូត្រនេះ បានត្រាស់ឈានដែលជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្ន ។ បទថា **និក្កាមលាភី** គឺព្រះមានព្រះភាគ ទ្រង់បានឈានតាមសេចក្តីប្រាថ្នា ។ បទថា **អកិច្ឆលាភី** គឺទ្រង់បានដោយមិនលំបាក ។ បទថា **អកសិរលាភី** គឺទ្រង់បានយ៉ាងបរិបូណ៌ ។

បទថា **ឯកិស្សា លោកធាតុយា** គឺក្នុង ១ ម៉ឺនលោកធាតុ ។ ពិតហើយ ខេត្តមាន ៣ យ៉ាង គឺជាតិខេត្ត ១ អាណាខេត្ត ១ វិសយខេត្ត ១ ក្នុងបណ្តាខេត្តទាំង ៣ នោះ លោកធាតុ ១ ម៉ឺន ឈ្មោះថា ជាតិខេត្ត ។ ក្នុងវេលាដែលព្រះតថាគតឈានចុះកាន់គភ៌នៃព្រះមាតា ក្នុងវេលាទ្រង់ប្រសូត ក្នុងវេលាត្រាស់ដឹង ក្នុងវេលាប្រកាសព្រះធម្មចក្រ ក្នុងវេលាដាក់ព្រះជន្មាយុសង្ខារ និងក្នុងគ្រាបរិនិព្វាន លោកធាតុទាំង ១ ម៉ឺននោះ រមែងញាប់ញ័រ ។ ចំណែក ១ សែនកោដិចក្រវាល ឈ្មោះថា អាណាខេត្ត ។ ពិតហើយ អាណានៃអាដានាដិយបរិត្ត មោរបរិត្ត ធជគ្គបរិត្ត និងរតនបរិត្តជាដើម រមែងប្រព្រឹត្តទៅក្នុង ១ សែនកោដិចក្រវាល ។ ចំណែកវិសយខេត្ត មិនមានប្រមាណឡើយ ។ ពិតហើយ ឈ្មោះថា ធម៌ដែលមិនមែនវិស័យរបស់ព្រះពុទ្ធទាំងឡាយ រមែងមិនមាន ព្រោះព្រះបាលីថា ញាណមានប៉ុនណា ធម៌ដែលព្រះអង្គគប្បីដឹងក៏មានត្រឹមនោះ ធម៌ដែលព្រះអង្គគប្បីដឹងមានប៉ុនណា ញាណក៏មានត្រឹមនោះ ធម៌ដែលព្រះអង្គគប្បីដឹង មានញាណជាទីបំផុត ញាណក៏មាន

ធម៌ដែលព្រះអង្គគប្បីដឹងជាទីបំផុត ដូច្នេះ ។ ព្រះសូត្រថា ក្នុងខេត្តទាំង ៣ នេះ ព្រះពុទ្ធទាំងឡាយ ទ្រង់ឧប្បត្តិកឡើងក្នុងចក្រវាលដទៃ វៀរចក្រវាលនេះ ដូច្នេះ រមែងមិនមាន តែព្រះសូត្រថា ព្រះពុទ្ធទាំងឡាយ រមែងទ្រង់មិនឧប្បត្តិកឡើង ដូច្នេះមាន ។

បិដកមាន ៣ គឺវិនយបិដក ១ សុត្តន្តបិដក ១ អភិធម្មបិដក ១ ។ សង្គាយនាមាន ៣ លើក គឺសង្គាយនាដែលព្រះមហាកស្សបធ្វើ ១ សង្គាយនាដែលព្រះយសត្ថេរធ្វើ ១ សង្គាយនាដែលព្រះមោគ្គលីបុត្តត្ថេរធ្វើ ១ ក្នុងព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដក ដែលព្រះធម្មសង្គាហកាចារ្យ លើកឡើងកាន់សង្គាយនាទាំង ៣ លើកនេះ ក៏មិនមានព្រះសូត្រសម្តែងថា ព្រះពុទ្ធទាំង-ឡាយ រមែងឧប្បត្តិកក្នុងចក្រវាលដទៃក្រៅពីចក្រវាលនេះទេ តែព្រះសូត្រសម្តែងថា ព្រះពុទ្ធទាំងឡាយ ទ្រង់រមែងមិនឧប្បត្តិកឡើង ដូច្នេះមាន ។

បទថា **អបុព្វំ អចរិមំ** សេចក្តីថា ព្រះពុទ្ធទាំងឡាយ ទ្រង់មិនឧប្បត្តិកឡើងព្រមគ្នា មិនមុន មិនក្រោយ មានពាក្យអធិប្បាយថា ទ្រង់ឧប្បត្តិកឡើងក្នុងកាលមុន ឬក្នុងខាងក្រោយ ។ រយៈវេលា រាប់តាំងពីព្រះពុទ្ធ គង់នៅត្រង់ពោធិបល្ល័ង្កនោះ ដោយតាំងចិត្តថា អញមិនបានសម្រេចព្រះពោធិញាណនឹងមិនក្រោកចេញ ដរាបដល់ចុះកាន់បដិសន្ធិក្នុងព្រះគភ៌របស់ព្រះមាតា មិនគួរយល់ថា ជាវេលាមុន ។ ព្រោះបានធ្វើការកំណត់ខេត្តទុកហើយ ដោយការញ្រាប់ញ័រនៃចក្រវាល ១ ម៉ឺន ក្នុងខណៈដែលព្រះពោធិសត្វបដិសន្ធិ សូម្បីការឧប្បត្តិកឡើងនៃព្រះពុទ្ធអង្គដទៃ ឈ្មោះថា ហាមហើយ ។ ម្យ៉ាងទៀត

រយៈវេលាពប់ពីបរិនិព្វាន ដរាបដល់ព្រះធាតុទាំងឡាយ សូម្បីប៉ុនគ្រាប់ស្ពៃ តាំងនៅ ក៏មិនគប្បីយល់ថា ជាវេលាខាងក្រោយ ។ ព្រោះកាលព្រះធាតុទាំងឡាយតាំងនៅ ព្រះពុទ្ធទាំងឡាយ ក៏ឈ្មោះថា តាំងនៅនោះឯង ។ ព្រោះដូច្នោះ ការកើតឡើងរបស់ព្រះពុទ្ធអង្គដទៃក្នុងចន្លោះនេះ ទើបជាការហាមឃាត់ហើយ ។ តែកាលធាតុបរិនិព្វានកើតឡើង ការកើតឡើងរបស់ព្រះពុទ្ធព្រះអង្គដទៃមិនជាការហាមឡើយ ។

ពិតហើយ អន្តរធាន មាន ៣ យ៉ាង គឺបរិយត្តិអន្តរធាន ១ បដិវេធអន្តរធាន ១ បដិបត្តិអន្តរធាន ១ ។ ក្នុងអន្តរធានទាំងនោះ ព្រះត្រៃបិដកឈ្មោះថា បរិយត្តិ ។ ការចាក់ធ្លុះសច្ចៈ ឈ្មោះថា បដិវេធ ។ បដិបទាឈ្មោះថា បដិបត្តិ ។ ក្នុង ៣ យ៉ាងនោះ បដិវេធ និងបដិបត្តិ រមែងមានខ្លះរមែងមិនមានខ្លះ ។ ក្នុងកាលណា ពួកភិក្ខុដែលទ្រទ្រង់បដិវេធមានច្រើន ភិក្ខុនោះគប្បីត្រូវលើកដៃចង្អុលប្រាប់ថា ភិក្ខុរូបនេះជាបុថុជ្ជន ។ ក្នុងទីបមួយដែលឈ្មោះថា ភិក្ខុដែលជាបុថុជ្ជនក្នុងវារៈតែមួយមិនមាន[១] ។ ពួកភិក្ខុសូម្បីបំពេញបដិបទាក្នុងកាលខ្លះ មានច្រើន ក្នុងកាលខ្លះ មានតិច នេះឈ្មោះថា បដិវេធ និងបដិបត្តិ មានខ្លះ មិនមានខ្លះ ។ ប៉ុន្តែ បរិយត្តិរមែងជាប្រមាណនៃការតាំងនៅបានរបស់ព្រះសាសនា ។ ព្រោះបណ្ឌិតទាំងឡាយបានស្តាប់ព្រះត្រៃបិដកហើយ រមែងបំពេញធម៌ទាំងពីរ គឺបដិបត្តិ និងបដិវេធបាន ។ ព្រះពោធិសត្វនៃយើងឲ្យអភិញ្ញា ៥ និងសមាបត្តិ ៨ កើតឡើងក្នុងសម្នាក់របស់

១- មិនអាចនិយាយបានថា ១ ទីបនេះ មានសុទ្ធតែបុថុជ្ជន ។

អាឡារតាបស ហើយត្រាស់សួរបរិកម្មរបស់នេវសញ្ញានាសញ្ញាយតនសមាបត្តិ អាឡារតាបសទូលថា ខ្ញុំព្រះអង្គមិនជ្រាប ដូច្នេះ តអំពីនោះ ព្រះពោធិសត្វនោះ ក៏យាងទៅកាន់សម្នាក់របស់ឧទកតាបស ហើយទ្រង់ប្រៀបផ្ទឹមគុណវិសេស ដែលព្រះអង្គសម្រេចហើយ ត្រាស់សួរការបរិកម្មនៃនេវសញ្ញានាសញ្ញាយតនសមាបត្តិ ឧទកតាបសនោះ ក៏ទូលឲ្យទ្រង់ជ្រាប ព្រះមហាសត្វក៏ទ្រង់ញ៉ាំងឈាននោះឲ្យកើតឡើង ក្នុងលំដាប់នៃពាក្យរបស់ឧទកតាបសនោះ យ៉ាងណា ភិក្ខុដែលមានបញ្ញា ក៏ដូច្នោះដូចគ្នា បានស្តាប់បរិយត្តិធម៌ហើយ ក៏រមែងបំពេញធម៌ទាំងពីរ គឺបដិបត្តិ និងបដិវេធបាន ។ ព្រោះដូច្នោះ កាលព្រះបរិយត្តិតាំងនៅបាន សាសនាក៏ឈ្មោះថា តាំងនៅបាន ។ តែក្នុងកាលណា បរិយត្តិនោះអន្តរធានទៅ ក្នុងកាលនោះ អភិធម្មបិដក រមែងសាបសូន្យទៅមុន ។ ក្នុងអភិធម្មនោះ មហាបដ្ឋាន រមែងអន្តរធានទៅមុន ។ ធម្មសង្គហៈ រមែងសាបសូន្យទៅតាមក្រោយ តាមលំដាប់ ។ កាលអភិធម្មបិដកនោះសាបសូន្យទៅ សូម្បីកាលបិដកទាំង ២ ក្រៅពីនេះតាំងនៅ សាសនាក៏ឈ្មោះថា តាំងនៅដោយពិត ។ ក្នុងបិដកទាំងនោះ កាលព្រះសុត្តន្តបិដកអន្តរធាន អង្គុត្តរនិកាយ រមែងសាបសូន្យទៅមុន តាំងពីឯកាទសកនិបាត ចុះមកដល់ឯកនិបាត ។ ក្នុងលំដាប់នោះ សំយុត្តនិកាយ ក៏សាបសូន្យទៅ ផ្តើមពីចក្កបេយ្យាល ចុះមកដល់ឱឃតរណសូត្រ ។ ក្នុងលំដាប់នោះ មជ្ឈិមនិកាយក៏អន្តរធានផ្តើមតាំងអំពីឥន្ទ្រិយភាវនា ចុះមកដល់មូលបរិយាយសូត្រ ។ ក្នុងលំដាប់នោះ ទីឃនិកាយក៏អន្តរធាន តាំងអំពីទសុត្តរសូត្រ ចុះមកដល់ព្រហ្ម-

ជាលសូត្រ ។ ពាក្យសួររបស់មួយគាថាក្តី ពីរគាថាក្តី រមែងតាំងនៅបានយូរ តែមិនអាចធ្វើសាសនាឲ្យតាំងនៅបានឡើយ ដូចសភិយបុច្ឆា និងអាឡវកបុច្ឆា ។ បានឮថា ប្រស្នានេះ អាឡវកយក្ខទ្រទ្រង់ទុកមួយចន្លោះកាលនៃព្រះកស្សបសម្ពុទ្ធ មិនអាចនឹងតាំងសាសនាទុកបាន ។ កាលបិដកទាំងពីរអន្តរធានទៅ បើវិនយបិដកតាំងនៅ សាសនាក៏តាំងនៅបាន ។ កាលបរិវារក្ខន្ធកៈអន្តរធានទៅ បើឧភតោវិភង្គតាំងនៅ សាសនាក៏ឈ្មោះថា តាំងនៅបានពិត ។ កាលឧភតោវិភង្គ អន្តរធានទៅ បើមាតិកាតាំងនៅ សាសនាក៏ឈ្មោះថា តាំងនៅបានពិត ។ កាលមាតិកាអន្តរធានទៅ បើបាតិមោក្ខ បព្វជ្ជា និងឧបសម្បទាតាំងនៅ សាសនាឈ្មោះថា តាំងនៅបាន ។ ភេទក៏ប្រព្រឹត្តទៅបានយូរ ។ តែវង្សរបស់សមណៈដែលស្លៀកសំពត់ស មិនអាចនឹងទ្រទ្រង់សាសនាបានទេ តាំងពីកាលរបស់ព្រះពុទ្ធទ្រង់ព្រះនាមថា កស្សប ។ សាសនាតាំងនៅបាន ១ ពាន់ឆ្នាំ ដោយភិក្ខុដែលសម្រេចបដិសម្ភិទា តាំងនៅបាន ១ ពាន់ឆ្នាំ ដោយភិក្ខុដែលទ្រទ្រង់អភិញ្ញា ៦ តាំងនៅបាន ១ ពាន់ឆ្នាំ ដោយភិក្ខុដែលទ្រទ្រង់វិជ្ជា ៣ តាំងនៅបាន ១ ពាន់ឆ្នាំ ដោយភិក្ខុដែលជាសុក្ខវិបស្សកៈ តាំងនៅបាន ១ ពាន់ឆ្នាំ ដោយពួកភិក្ខុដែលទ្រទ្រង់បាតិមោក្ខ ។ សាសនារមែងមានការស្រុតចុះ តាំងពីការបាក់ធុះសច្ចៈរបស់ភិក្ខុអង្គក្រោយៗ និងចាកការទម្លាយសីលរបស់ភិក្ខុអង្គក្រោយៗ ។ ចាប់ផ្តើមតាំងពីនោះទៅ ការឧប្បត្តិឡើងរបស់ព្រះពុទ្ធព្រះអង្គដទៃ លោកមិនបានហាមទុក ។

ឈ្មោះថា បរិនិព្វានមាន ៣ យ៉ាង គឺកិលេសបរិនិព្វាន ១ ខន្ធបរិនិព្វាន

១ ធាតុបរិនិព្វាន ១ ។ ក្នុងបរិនិព្វានទាំង ៣ យ៉ាងនោះ ការរម្ងត់មិនមានសល់នៃកិលេសមានហើយត្រង់ពោធិបល្ល័ង្ក ការរម្ងត់មិនមានសល់នៃខន្ធ មានហើយ ត្រង់នគរកុសិនារា ការរម្ងត់នៃធាតុ នឹងមានក្នុងអនាគត ។ បានឮថា ក្នុងវេលាដែលសាសនាសាបសូន្យ ព្រះធាតុទាំងឡាយ ក៏នឹងទៅរួមគ្នានៅត្រង់មហាចេតិយក្នុងកោះតម្ពបណ្ណិទ្វីប តអំពីមហាចេតិយ ក៏នឹងទៅរួមគ្នាត្រង់រាជាយតនចេតិយក្នុងនាគទ្វីប តអំពីនោះ ក៏នឹងទៅកាន់មហាពោធិបល្ល័ង្ក ។ ព្រះធាតុទាំងឡាយមកពីពិភពនៃនាគក្តី មកពីព្រហ្មលោកក្តី នឹងទៅកាន់មហាពោធិបល្ល័ង្កតែម្យ៉ាង ។ ព្រះធាតុមានប្រមាណប៉ុនគ្រាប់ស្ពៃ ក៏នឹងមិនអន្តរធានទៅឡើយ ។ ព្រះធាតុទាំងអស់ ក៏នឹងសមោធានជាគំនរនៅត្រង់មហាពោធិបល្ល័ង្ករួមគ្នា ប្រៀបដូចគំនរមាសដូច្នោះ បញ្ចេញឆព្វណ្ណរង្សី ។ ព្រះធាតុទាំងនោះ នឹងផ្សាយទៅរហូតដល់អស់លោកធាតុ ១ ម៉ឺន ។ បន្ទាប់អំពីនោះ ទេវតាក្នុង ១ ម៉ឺនចក្រវាល ក៏ប្រជុំព្រមគ្នា ហើយនាំគ្នាពោលថា ព្រះសាស្តានឹងបរិនិព្វាន ទៅក្នុងថ្ងៃនេះ សាសនាក៏រមែងសាបសូន្យទៅក្នុងថ្ងៃនេះ នេះជាការបានឃើញគ្រាចុងក្រោយបង្អស់របស់យើងទាំងឡាយ ក្នុងកាលឥឡូវនេះ ដូច្នេះហើយ យើងនឹងនាំគ្នាធ្វើសេចក្តីករុណាដ៏ធំក្រៃលែង ជាងថ្ងៃដែលព្រះទសពលបរិនិព្វាន ។ វៀរព្រះអនាគាមី និងព្រះខីណាស្រពចេញ សត្វដ៏សេសក៏នឹងមិនអាចតាំងនៅបានដោយភាវៈរបស់ខ្លួន ។ តេជោធាតុ ក្នុងបណ្តាធាតុទាំងឡាយ ក៏នឹងឆេះត្របាញ់ឡើងទៅ ដរាបដល់ព្រហ្មលោក កាលមានព្រះធាតុប៉ុនគ្រាប់ស្ពៃនៅសល់ ក៏នឹងឆេះជាអណ្តាតភ្លើងតែម្យ៉ាង កាលធាតុទាំង-

ឡាយដល់នូវការអស់ហើយ គេជាធាតុក៏រលត់បាត់ទៅ ។ កាលព្រះធាតុទាំងឡាយ បានសម្តែងអានុភាពដ៏ធំយ៉ាងនេះបាត់ទៅហើយ សាសនាក៏ឈ្មោះថា អន្តរធានទៅ ។ សាសនានៅមិនទាន់អន្តរធានយ៉ាងនេះ ដរាបណា សាសនាចាត់ថា នៅមិនទាន់អស់ដរាបនោះ ។ ការដែលព្រះសាស្តាកើតឡើង មិនមុនមិនក្រោយយ៉ាងនេះ ជាអឋានៈ ។

សួរថា ព្រោះហេតុអ្វី ព្រះពុទ្ធទាំងឡាយ ទ្រង់មិនកើតឡើង មិនមុន មិនក្រោយ ដូច្នេះ ឆ្លើយថា ព្រោះជាវត្ថុដែលមិនគួរអស្ចារ្យ ពិតហើយ ព្រះពុទ្ធទាំងឡាយ ជាមនុស្សដែលអស្ចារ្យ ។ ដូចដែលព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលឯក កាលកើតឡើងក្នុងលោក រមែងកើតឡើងជាមនុស្សអស្ចារ្យ បុគ្គលឯក តើដូចម្តេច គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ។ ប្រសិនបើព្រះពុទ្ធទាំងឡាយ ទ្រង់ឡើងក្នុងគ្រាតែមួយជាមួយគ្នា ២ ព្រះអង្គខ្លះ ៤ ព្រះអង្គខ្លះ ៨ ព្រះអង្គខ្លះ ១៦ ព្រះអង្គខ្លះសោត ព្រះពុទ្ធទាំងឡាយ ក៏គប្បីជាបុគ្គលដែលមិនគួរអស្ចារ្យ ។ សូម្បីព្រះចេតិយ ២ កន្លែង ក្នុងវត្តតែមួយជាមួយគ្នា លាភសក្ការៈក៏មិនច្រើន ទាំងភិក្ខុទាំងឡាយក៏មិនគួរអស្ចារ្យ ព្រោះមានច្រើន យ៉ាងណា សូម្បីព្រះពុទ្ធទាំងឡាយ ដូច្នោះដែរ ព្រោះហេតុនោះ ទើបព្រះពុទ្ធទាំងឡាយ ទ្រង់មិនកើតឡើងយ៉ាងនេះ ។

ម្យ៉ាងទៀត ព្រះពុទ្ធទាំងឡាយ ទ្រង់មិនកើតឡើងព្រមគ្នា ក៏ព្រោះទេសនាមិនផ្សេងគ្នា ។ ពិតហើយ ព្រះពុទ្ធមួយអង្គ ទ្រង់សម្តែងធម៌ផ្សេងគ្នា មានសតិប្បដ្ឋានជាដើម យ៉ាងណា ព្រះធម៌ទុំះឯង ព្រះពុទ្ធអង្គដទៃ ដែលទ្រង់

កើតឡើងហើយ ក៏គប្បីសម្ដែងដូច្នោះ ព្រះពុទ្ធក៏នឹងជាបុគ្គលមិនគួរអស្ចារ្យ ។ តែកាលព្រះពុទ្ធមួយព្រះអង្គសម្ដែងធម៌ សូម្បីព្រះទេសនា ក៏ជារបស់ដែលគួរអស្ចារ្យ ។ម្យ៉ាងទៀត ព្រះពុទ្ធទាំងឡាយ ទ្រង់មិនកើតឡើងព្រមគ្នា ព្រោះមិនមានវិវាទគ្នា ។ ពិតហើយ កាលព្រះពុទ្ធច្រើនព្រះអង្គកើតឡើង ភិក្ខុទាំង-ឡាយគប្បីវិវាទគ្នាថា ព្រះពុទ្ធរបស់យើងទាំងឡាយគួរជ្រះថ្លា ព្រះពុទ្ធរបស់ពួកយើង មានព្រះសូរសៀងពីរោះ មានលាភ និងមានបុណ្យ ដូច្នេះ ដូចអន្តេវាសិករបស់អាចារ្យច្រើនអង្គ ។ ព្រោះដូច្នោះ ទើបព្រះពុទ្ធទាំងឡាយទ្រង់មិនកើតឡើងយ៉ាងនេះ ។ ម្យ៉ាងទៀត ប្រការនេះ ព្រះនាគសេនត្ថេរត្រូវស្ដេចមិលិន្ទត្រាស់សួរ ក៏បានឆ្លើយយ៉ាងពិស្ដារ ។ ពិតហើយ ក្នុងមិលិន្ទ-បញ្ហានោះ ស្ដេចមិលិន្ទត្រាស់ថា ព្រះនាគសេនដ៏ចម្រើន ព្រះមានព្រះភាគទ្រង់បានសម្ដែងថា ម្នាលភិក្ខុទាំងឡាយ ប្រការនោះមិនមែនជាឋានៈ មិនមែនឱកាស គឺប្រការដែលព្រះអរហន្តសម្មាសម្ពុទ្ធ ២ ព្រះអង្គ ឧប្បត្តិកឡើងមិនមុន មិនក្រោយ ក្នុងលោកធាតុនេះ នោះជាអឋានៈ ដូច្នេះ ព្រះនាគសេនដ៏ចម្រើន ព្រះតថាគតទាំងអស់ កាលទ្រង់សម្ដែងធម៌ ទ្រង់សម្ដែងពោធិ-បក្ខិយធម៌ ៣៧ ប្រការ និងកាលត្រាស់ក៏រមែងត្រាស់អរិយសច្ចធម៌ ៤ និងកាលទ្រង់ឲ្យសិក្សា រមែងទ្រង់ឲ្យសិក្សាក្នុងត្រៃសិក្ខា កាលទ្រង់ទូន្មាន ក៏ទ្រង់ទូន្មានបដិបទា គឺសេចក្ដីមិនប្រមាទ ព្រះនាគសេនដ៏ចម្រើន បើព្រះតថាគតទាំងអស់ មានឧទ្ទេសតែម្យ៉ាង មានកថាតែម្យ៉ាង មានសិក្ខាបទតែម្យ៉ាង មានអនុសន្ធិតែម្យ៉ាង ព្រោះហេតុអ្វី ទើបព្រះតថាគត ២ ព្រះអង្គ ទ្រង់មិនកើត

ឡើងក្នុងខណៈតែមួយ លោកនេះ កើតមានពន្លឺដោយឧប្បត្តិកឡើងរបស់ព្រះពុទ្ធមួយព្រះអង្គ បើព្រះពុទ្ធអង្គទី ២ គប្បីមានឡើង លោកនេះ គប្បីមានពន្លឺឡើងមក មានប្រមាណក្រៃលែងដោយព្រះរស្មីរបស់ព្រះពុទ្ធ ២ ព្រះអង្គ និងព្រះតថាគតទាំងពីរព្រះអង្គ កាលទ្រង់ប្រទានឱវាទ ក៏គប្បីប្រទានឱវាទយ៉ាងសប្បាយ កាលទ្រង់ទូន្មាន ក៏គប្បីទូន្មានយ៉ាងសប្បាយ សូមលោកម្ចាស់សម្ដែងហេតុក្នុងសេចក្ដីនោះឲ្យញោម អស់សេចក្ដីសង្ស័យផង ។ ព្រះនាគសេនត្រេរថ្វាយព្រះពរថា មហាបពិត្រ លោកធាតុ ១ ម៉ឺននេះ ទ្រទ្រង់ទុកបាននូវព្រះពុទ្ធត្រឹមតែមួយព្រះអង្គ ទ្រទ្រង់ទុកបាននូវព្រះគុណរបស់ព្រះតថាគតមួយអង្គដូចគ្នា បើអង្គទីពីរគប្បីកើតឡើង លោកធាតុ ១ ម៉ឺននេះ ក៏ទ្រទ្រង់មិនបាន គប្បីញាប់ញ័រកម្រើកទៅ បង្អោនទៅ ឱនទៅ ទោរទៅ រាត់រាយខ្ចាត់ខ្ចាយ វិនាសទៅ មិនគប្បីចូលដល់ការតាំងនៅបាន មហាបពិត្រ ប្រៀបដូចទូកដែលផ្ទុកបុរសបានតែម្នាក់ កាលបុរសម្នាក់ឡើងទៅ ទូកគប្បីតាំងនៅបានល្មម ប្រសិនបើបុរសទីពីរ ដែលដូចជាគ្នាដោយអាយុ ដោយពណ៌ ដោយវ័យ ដោយប្រមាណ ដោយធាត់ និងស្គម ដោយអវយវៈតូចធំប៉ុនគ្នា និងបុរសនោះ គប្បីឡើងកាន់ទូកនោះ មហាបពិត្រ ទូកនោះនឹងទ្រទ្រង់បុរសទាំងពីរនោះបានឬទេ ។ ស្ដេចមិលិន្ទត្រាស់ឆ្លើយថា លោកម្ចាស់ដ៏ចម្រើន ទូកនោះ ទ្រទ្រង់មិនបាន គប្បីញាប់ញ័រ កម្រើក បង្អោនទៅ ឱនទៅ រាត់រាយខ្ចាត់ខ្ចាយទៅ វិនាសទៅ មិនគប្បីចូលដល់ការតាំងនៅបានឡើយ ទូកនោះគប្បីលិចចុះទៅក្នុងទឹកដោយពិត ដូច្នេះ ។ ព្រះនាគសេនថ្វាយព្រះពរថា មហា

បពិត្រ ប្រការនេះ ក៏មានឧបមាដូច្នោះដែរ លោកធាតុ ១ ម៉ឺននេះ ទ្រទ្រង់ព្រះពុទ្ធបានតែមួយព្រះអង្គ ទាំងទ្រទ្រង់គុណរបស់ព្រះតថាគត បានតែមួយព្រះអង្គប៉ុណ្ណោះ បើព្រះពុទ្ធអង្គទីពីរ គប្បីកើតឡើង លោកធាតុ ១ ម៉ឺននេះក៏ទ្រទ្រង់មិនបាន ។បេ។ មិនគប្បីចូលដល់សេចក្តីតាំងនៅបាន មហាបពិត្រន័យម្យ៉ាងទៀត ប្រៀបដូចបុរសអ្នកមានសេចក្តីសុខ គប្បីបរិភោគភោជនតាមសេចក្តីត្រូវការ គឺកាលឃ្លាន ក៏បរិភោគរហូតដល់ក បុរសនោះក៏ឆ្អែតពេញពោះ ហាល់ ឱនមិនចុះ កាលបរិភោគនោះ ក្នុងថ្ងៃស្អែក ក៏បរិភោគភោជនត្រឹមប៉ុណ្ណោះ មហាបពិត្រ បុរសនោះ ចាត់ថា ជាអ្នកមានសេចក្តីសុខ បានឬមិនបាន ដូច្នេះ ។ ស្តេចមិលិន្ទត្រាស់ឆ្លើយថា លោកម្ចាស់ដ៏ចម្រើន បុរសនោះ បរិភោគគ្រាតែមួយ គប្បីស្លាប់បាន ដូច្នេះ ។ ព្រះនាគសេនថ្វាយព្រះពរថា មហាបពិត្រ ប្រការនេះ ក៏ដូច្នោះដែរ លោកធាតុ ១ ម៉ឺននេះ ទ្រទ្រង់ព្រះពុទ្ធបានតែមួយព្រះអង្គ ។បេ។ មិនគប្បីចូលដល់សេចក្តីតាំងនៅបានឡើយ ដូច្នេះ ។ ស្តេចមិលិន្ទត្រាស់ថា ព្រះនាគសេនដ៏ចម្រើន ផែនដីរមែងញ័រដោយធម៌ដែលធ្ងន់ក្រៃលែង យ៉ាងណាហ្ន៎ ។ ព្រះនាគសេនថ្វាយព្រះពរថា មហាបពិត្រ ក្នុងលោកនេះ រទេះ ២ គ្រឿង ផ្ទុកដោយរតនៈជរាបពេញ មនុស្សទាំងឡាយក៏នាំគ្នាជញ្ជូនយករតនៈអំពីរទេះមួយ មកដាក់ក្នុងរទេះមួយទៀត មហាបពិត្ររទេះនោះ គប្បីទ្រទ្រង់រតនៈរបស់រទេះទាំងពីរគ្រឿងនោះបានឬទេ ដូច្នេះ ។ ស្តេចមិលិន្ទត្រាស់ថា លោកម្ចាស់ដ៏ចម្រើន រទេះនោះ រមែងទ្រទ្រង់មិនបានទេ ដុំរបស់រទេះនោះ គប្បីញ័រខ្លះ កាំរបស់រទេះនោះ គប្បីបាក់ទៅខ្លះ ភ្លៅរបស់

រទេះនោះ គប្បីបាក់ទៅខ្លះ ដូច្នេះ ។ ព្រះនាគសេនទូលសួរថា រទេះរមែងបាក់ព្រោះការផ្ទុករតនៈដែល ច្រើនពេក មែនឬ មិនមែន ។ ស្តេចមិលិន្ទត្រាស់ឆ្លើយថា មែនហើយ លោកម្ចាស់ដ៏ចម្រើន ដូច្នេះ ។ ព្រះនាគសេនថ្វាយព្រះពរថា មហាបពិត្រ ប្រការនេះ ក៏មានឧបមេយ្យដូច្នោះដូចគ្នា ផែនដីរមែងញាប់ញ័រ ដោយធម៌ដ៏ធ្ងន់ក្រៃលែង ។ម្យ៉ាងទៀត មហាបពិត្រ ហេតុនេះជាការរួមចុះក្នុងការសម្តែងកម្លាំងនៃព្រះពុទ្ធ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ហេតុដែលសមគួរយ៉ាងដទៃ ក្នុងការសម្តែងកម្លាំងរបស់ព្រះពុទ្ធនោះ ព្រោះហេតុអ្វី ទើបព្រះសម្មាសម្ពុទ្ធ ២ ព្រះអង្គ ទ្រង់មិនកើតឡើងក្នុងខណៈតែមួយបើព្រះសម្មាសម្ពុទ្ធ ២ ព្រះអង្គ ទ្រង់កើតឡើងក្នុងខណៈជាមួយគ្នាសោត ការឈ្លោះវិវាទរបស់បរិស័ទគប្បីកើតឡើង មនុស្សទាំងឡាយ ក៏នឹងមានជាពីរចំណែក ដោយពោលថា ព្រះពុទ្ធរបស់ពួកលោក ព្រះពុទ្ធរបស់ពួកយើងដូច្នេះ មហាបពិត្រ ប្រៀបដូចបរិស័ទនៃអមាត្យអ្នកមានកម្លាំង ២ នាក់ គប្បីវិវាទគ្នា មនុស្សទាំងនោះក៏នឹងជា ២ ចំណែក ដោយពោលថា អមាត្យរបស់ពួកលោក អមាត្យរបស់ពួកយើងដូច្នេះ យ៉ាងណា មហាបពិត្រ ប្រការនេះក៏ដូច្នោះដូចគ្នាដែរ ប្រសិនបើ ព្រះសម្មាសម្ពុទ្ធ ២ ព្រះអង្គ គប្បីកើតឡើងក្នុងខណៈជាមួយគ្នាសោត វិវាទរបស់បរិស័ទ គប្បីកើតឡើងបាន ហើយមនុស្សទាំងឡាយ ក៏ទៅជាពីរចំណែក ដោយពោលថា ព្រះពុទ្ធរបស់ពួកលោក ព្រះពុទ្ធរបស់ពួកយើងដូច្នេះ សូមព្រះអង្គព្រះសណ្តាប់ហេតុទី ១ នេះ ដោយហេតុណា ទើបព្រះសម្មាសម្ពុទ្ធ ២ ព្រះអង្គ ទ្រង់មិនកើតឡើងក្នុងពេលជាមួយគ្នា

សូមព្រះអង្គព្រះសណ្ដាប់ហេតុដែលក្រៃលែងដទៃទៀត ដោយហេតុណា ព្រះសម្មាសម្ពុទ្ធ ២ ព្រះអង្គ ទ្រង់មិនកើតឡើងក្នុងខណៈជាមួយគ្នា មហាបពិត្រ បើព្រះសម្មាសម្ពុទ្ធ ២ ព្រះអង្គគប្បីកើតឡើងក្នុងខណៈជាមួយគ្នា ពាក្យថា ព្រះពុទ្ធជាអគ្គបុគ្គល ក៏ជាពាក្យខុស ពាក្យថា ព្រះពុទ្ធជាបុគ្គលចម្រើនបំផុត ពាក្យថា ព្រះពុទ្ធជាបុគ្គលប្រសើរបំផុត ពាក្យថា ព្រះពុទ្ធជាបុគ្គលវិសេសបំផុត ពាក្យថា ព្រះពុទ្ធជាបុគ្គលឧត្តមបំផុត ពាក្យថា ព្រះពុទ្ធជាបុគ្គលប្រសើរ ពាក្យថា ព្រះពុទ្ធមិនមានបុគ្គលស្មើ ពាក្យថា ព្រះពុទ្ធរកអ្នកស្មើដូចមិនបាន ពាក្យថា ព្រះពុទ្ធមិនមានអ្នកស្មើដូចពាក្យថា ព្រះពុទ្ធរកបុគ្គលប្រៀបមិនបាន ពាក្យថា ព្រះពុទ្ធមិនមានបុគ្គលប្រៀបដូច្នេះ គប្បីជាពាក្យខុស មហាបពិត្រ សូមព្រះអង្គ មេត្តាទ្រង់ព្រមទទួលហេតុដែលព្រះសម្មាសម្ពុទ្ធ ២ ព្រះអង្គ ទ្រង់មិនកើតក្នុងពេលតែមួយ ដោយន័យ ( ដែលនាំមកថ្វាយវិសជ្ជនាហើយ )ម្យ៉ាងទៀត មហាបពិត្រ ប្រការដែលព្រះពុទ្ធតែមួយព្រះអង្គ ទ្រង់កើតឡើងក្នុងលោកនេះ ជាសភាពតាមប្រក្រតីរបស់ព្រះពុទ្ធទាំងឡាយ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះគុណរបស់ព្រះសព្វញ្ញុពុទ្ធទាំងឡាយ មានហេតុក្រៃលែង មហាបពិត្រ គុណដ៏ប្រសើរធំក្រៃលែងដទៃនោះ ក៏មានប្រការតែមួយប៉ុណ្ណោះ មហាបពិត្រ ផែនដីធំនោះ មានផ្ទាំងតែមួយ សាគរធំ មានខ្សែតែមួយ ភ្នំសិនេរុជាភ្នំធំក្រៃលែង មានតែមួយ អាកាសធំមានតែមួយ សក្កទេវរាជជាធំមានតែមួយ មហាព្រហ្មមានតែមួយ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធជាធំ ក៏មានតែមួយព្រះអង្គប៉ុណ្ណោះ ទ្រង់កើតឡើងក្នុងទីណា ក្នុងទីនោះ

*ក៏មិនមានឱកាសដល់ព្រះពុទ្ធទាំងឡាយអង្គដទៃ ដូច្នោះ ព្រះតថាគតអរហន្ត-សម្មាសម្ពុទ្ធតែមួយព្រះអង្គប៉ុណ្ណោះ រមែងកើតឡើងក្នុងលោក ដូច្នេះ ។ ស្តេចមិលិន្ទបានត្រាស់ថា បពិត្រព្រះនាគសេនដ៏ចម្រើន លោកម្ចាស់បានពោលដោះស្រាយបញ្ហា ជាក់ច្បាស់ល្អហើយ ដោយឧបមាឧបមេយ្យទាំងឡាយ ។*

[ ៩២ ] *ពីរបទថា* **ធម្មស្ស ច អនុធម្មំ** *សេចក្តីថា បដិបទាដែលជាចំណែកខាងដើម ដែលជាធម៌សមគួរដល់លោកុត្តរធម៌ ៩ យ៉ាង ។ បទថា* **សហធម្មិកោ** *គឺការឆ្លើយឆ្លងដែលមានហេតុ ។*

[ ៩៣ ] *បទថា* **អាយស្មា ឧទាយិ** *សេចក្តីថា ព្រះថេរៈឈ្មោះឧទាយីមាន ៣ អង្គ គឺព្រះលោឡុទាយី ១ កាឡុទាយី ១ មហាឧទាយី ១ ក្នុងទីនេះបំណងយកមហាឧទាយី ។ បានឮថា កាលព្រះមហាឧទាយីនោះ ស្តាប់ព្រះសូត្រនេះ តាំងពីដើមដល់ចប់ បីតិ ៥ កើតឡើងខាងក្នុង រមែងផ្សាយទៅតាំងពីបាតជើងឡើងទៅដល់ក្បាល តាំងពីក្បាលផ្សាយចុះមកដល់បាតជើងទាំងពីរខាង រួមចុះត្រង់កណ្តាល តាំងពីកណ្តាលផ្សាយទៅទាំងពីរខាង ។ ព្រះមហាឧទាយីនោះ កាលបីតិពាល់ត្រូវពេញសរីរៈ ក៏ពោលគុណរបស់ព្រះទសពល ដោយសោមនស្សដ៏មានកម្លាំង ទើបពោលពាក្យថា* **អច្ឆរិយំ ភន្តេ** *ដូច្នេះជាដើម ។ ភាពជាអ្នកអស់តណ្ហា ឈ្មោះថា ភាពជាអ្នកប្រាថ្នាតិច ។ សេចក្តីគាប់ចិត្តដោយអាការ ៣ យ៉ាង ក្នុងបច្ច័យ ៤ ឈ្មោះថា ភាពជាអ្នកសន្តោស ។ ការជុសខាត់កិលេសគ្រប់យ៉ាង ឈ្មោះថា ភាពជាអ្នកជុសខាត់ ។ បទថា* **យត្រ ហិ នាម** *គឺ* **យោ ហិ នាម** *។ បទថា* **ន អត្តានំ ចាតុករិស្សតិ**

សេចក្តីថា ទ្រង់មិនធ្វើគុណរបស់ព្រះអង្គឲ្យប្រាកដ ។ បទថា **បជាកំ បរិ-ហារេយ្យុំ** សេចក្តីថា ពួកអន្យតិរ្ថិយបរិព្វាជកទាំងឡាយ កាលពោលថា អ្នកណាជាអ្នកដូចគ្នានឹងយើងមានទេ ដូច្នេះ ក៏លើកទង់សំពត់ឡើង ត្រាច់ទៅកាន់ក្រុងនាលន្ទា ។ ច្រើនបទថា **បស្ស ខោ ត្វំ ឧទាយិ តថាគតស្ស អប្បិច្ឆតា** នេះ ព្រះមានព្រះភាគ ត្រាស់ទទួលពាក្យរបស់ព្រះថេរៈថា ម្នាលឧទាយី អ្នកចូរមើលតថាគតមានសេចក្តីប្រាថ្នាតិច យ៉ាងណា ។ សូម្បីមិនមានពាក្យសួរថា ព្រោះហេតុអ្វី ទើបព្រះតថាគត ទ្រង់មិនធ្វើព្រះអង្គឲ្យប្រាកដ ទាំងមិនត្រាស់គុណរបស់ព្រះអង្គ ។ គប្បីឆ្លើយថា មិនត្រាស់ក៏ទេ ព្រះអង្គមិនត្រាស់ពាក្យដែលគួរត្រាស់ដោយគុណ មានភាពជាអ្នកប្រាថ្នាតិចជាដើម ព្រោះហេតុនៃលាភ មានចីវរជាដើម ។ ដោយហេតុនោះ ទើបទ្រង់ត្រាស់ពាក្យជាដើមថា ម្នាលឧទាយី អ្នកចូរមើលការប្រាថ្នាតិចរបស់តថាគត ។ ព្រះមានព្រះភាគទ្រង់អាស្រ័យសត្វ អ្នកដែលនឹងត្រាស់ដឹង ទើបត្រាស់ដោយអំណាចវេនេយ្យសត្វ ។ ដូចទ្រង់ត្រាស់ថា អាចារ្យរបស់តថាគតមិនមាន បុគ្គលដូចជាតថាគតមិនមាន បុគ្គលអ្នកប្រៀបនឹងតថាគត មិនមានក្នុងលោកព្រមទាំងទេវលោក ។

គាថាក្តី ព្រះសូត្រក្តី ជាច្រើន ដែលជាគ្រឿងសម្តែងព្រះគុណរបស់ព្រះតថាគត ក៏គួរឲ្យពិស្តារយ៉ាងនេះ ។ បទថា **អភិក្ខណំ ភាសេយ្យាសិ** គឺលោកគប្បីពោលរឿយៗ អធិប្បាយថា កុំពោលក្នុងថ្ងៃត្រង់ជាដើម ព្រោះគិតថា យើងបានពោលក្នុងវេលាព្រឹកហើយ ឬកុំបានពោលក្នុងថ្ងៃស្អែកនេះជា

*ដើម ព្រោះគិតថា យើងបានពោលក្នុងថ្ងៃនេះហើយ ។ បទថា* **បវេទេសិ** *គឺពោលហើយ ។ ពីរបទថា* **ឥមស្មឹ វេយ្យាករណស្មឹ** *សេចក្តីថា ព្រះសូត្រនេះលោកពោលថា វេយ្យាករណ៍ ព្រោះមិនមានគាថា ។ បទថា* **អធិវចនំ** *គឺឈ្មោះ ។ ពាក្យនេះ ព្រះសង្គីតិកាចារ្យផ្តើមបទ តាំងពីបទថា* **ឥតិ ហិទំ ។** *ពាក្យដ៏សេសក្នុងគ្រប់ៗ បទ មានអត្ថងាយយល់ហើយ ដូច្នេះឯង ។*

*អដ្ឋកថាសម្បសាទនីយសូត្រ ក្នុងទីឃនិកាយ ឈ្មោះសុមង្គលវិលាសិនី*

*ចប់ ។*

**សម្បសាទនីយសូត្រ ចប់**

**សូត្រទី ៥ ចប់**

# សុត្តន្តបិដក

## ចាតុមាសិកសូត្រទី ៦

[ ៩៤ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងប្រាសាទ នាអម្ពវ័នរបស់ពួកសក្យៈ ដែលមានឈ្មោះថា វេធញ្ញៈ ( អ្នកហាត់បាញ់ធ្នូ ) ក្នុងសក្កជនបទទាំងឡាយ ។ សម័យនោះឯង និគណ្ឋនាដបុត្រ ទើបតែធ្វើមរណកាលហើយថ្មីៗ ក្នុងនគរបាវា ។ ព្រោះតែនិគណ្ឋនាដបុត្រនោះ ធ្វើមរណកាលទៅ ពួកនិគ្រន្ថកើតបែកគ្នាទៅជាពីរពួក កើតសេចក្តីប្រកួតប្រកាន់ កើតឈ្លោះប្រកែក ចាក់ដោតគ្នីគ្នា ដោយលំពែងមាត់ថា អ្នកមិនចេះធម្មវិន័យនេះទេ ខ្ញុំទើបចេះធម្មវិន័យនេះ អ្នកនឹងចេះធម្ម-វិន័យនេះ ដូចម្តេចបាន អ្នកជាអ្នកប្រតិបត្តិខុសហើយ ខ្ញុំទើបប្រតិបត្តិត្រូវ ពាក្យរបស់ខ្ញុំ ប្រកបដោយប្រយោជន៍ ពាក្យរបស់អ្នក មិនប្រកបដោយប្រយោជន៍ទេ ពាក្យដែលគេត្រូវនិយាយមុន អ្នកនិយាយក្រោយ ពាក្យដែលគេត្រូវនិយាយក្រោយ អ្នកនិយាយមុន អ្នកបានសន្សំច្រើនតែវត្ថុដែលខុសៗ ខ្ញុំលើកសេចក្តីខុសដាក់លើអ្នក អ្នកត្រូវខ្ញុំផ្ចាញ់ផ្ចាល់ហើយ ដើម្បីឲ្យផុតអំពីវាទៈរបស់សាស្តាដទៃ បើអ្នកអង់អាច ចូរដោះខ្លួនឲ្យរួចចុះ ។ហាក់ដូចជាសេចក្តីស្លាប់តែម្យ៉ាង ប្រព្រឹត្តទៅតាមពួកនិគ្រន្ថ ជាសិស្សរបស់នាដ-បុត្រ ។ ពួកគ្រហស្ថណាមានសម្លៀកបំពាក់ ដែលជាសាវ័ករបស់និគណ្ឋ-នាដបុត្រ ពួកគ្រហស្ថទាំងនោះ ជាអ្នកមានសេចក្តីធុញទ្រាន់ ប្រាសចាកសេចក្តីស្រឡាញ់ លែងគោរពក្នុងពួកនិគ្រន្ថ ដែលជាសិស្សរបស់នាដបុត្រ

ព្រោះតែនិគណ្ឋនាដបុត្រ សម្តែងនូវធម្មវិន័យមិនល្អ ប្រកាសទុកមិនល្អ មិនមែនជានិយ្យានិកធម៌ មិនមែនប្រព្រឹត្តទៅដើម្បីស្ងប់រម្ងាប់ ជាធម្មវិន័យដែលបុគ្គលមិនបានត្រាស់ដឹងខ្លួនឯងដោយប្រពៃ ប្រកាសទុកហើយ ទាំងមានស្តូប គឺទីពំនាក់ បែកធ្លាយហើយ មិនមានទីពឹងឡើយ ។

[ ៩៥ ] លំដាប់នោះ សមណុទ្ទេសឈ្មោះ ចុន្ទ នៅចាំវស្សាក្នុងក្រុងបាវា បានចូលទៅរកព្រះអានន្ទមានអាយុ គង់នៅនាសាមគ្រាម លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះអានន្ទមានអាយុ ហើយអង្គុយក្នុងទីសមគួរ ។ លុះចុន្ទសមណុទ្ទេស អង្គុយក្នុងទីសមគួរហើយ ក៏និយាយនឹងព្រះអានន្ទមានអាយុយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន និគណ្ឋនាដបុត្រ ទើបនឹងធ្វើមរណកាលហើយថ្មីៗ ក្នុងក្រុងបាវា ព្រោះកាលកិរិយានៃនិគណ្ឋនាដបុត្រនោះ ពួកនិគ្រន្ថបែកគ្នាទៅជាពីរពួក ។បេ។ មានស្តូប គឺទីពំនាក់បែកធ្លាយហើយ មិនមានទីពឹងឡើយ ។ កាលបើចុន្ទសមណុទ្ទេស និយាយយ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏និយាយនឹងចុន្ទសមណុទ្ទេសយ៉ាងនេះថា នែចុន្ទមានអាយុ ពាក្យមានមូលហេតុនេះ គួរក្រាបបង្គំទូលដល់ព្រះមានព្រះភាគ នែចុន្ទមានអាយុមក យើងនឹងទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ យើងត្រូវក្រាបបង្គំទូលសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ។ ចុន្ទសមណុទ្ទេស ក៏ទទួលស្តាប់ ព្រះអានន្ទមានអាយុថា បពិត្រលោកដ៏ចម្រើនយ៉ាងនោះមែនហើយ ។ លំដាប់នោះព្រះអានន្ទមានអាយុ និងចុន្ទសមណុទ្ទេស ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយ

អន្តរាយក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលនូវព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ចុន្ទសមណុទ្ទេសនេះ និយាយយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន និគណ្ឋ-នាដបុត្រទើបនឹងធ្វើមរណកាលហើយថ្មីៗ ក្នុងក្រុងបាវា ព្រោះកាលកិរិយានៃនិគណ្ឋនាដបុត្រនោះ ពួកនិគ្រន្ថបែកគ្នា ។បេ។ មានស្តូប គឺទីពំនាក់បែកធ្លាយហើយ មិនមានទីពឹងឡើយ ។

[ ៩៦ ] ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលចុន្ទ ការណ៍នុ៎ះ រមែងមានយ៉ាងហ្នឹងឯង ព្រោះតែបុគ្គលពោលនូវធម្មវិន័យមិនល្អ ប្រកាសទុកមិនល្អ មិនមែនជានិយ្យានិកធម៌ មិនមែនប្រព្រឹត្តទៅដើម្បីស្ងប់រម្ងាប់ ជាធម្មវិន័យដែលបុគ្គលមិនបានត្រាស់ដឹងខ្លួនឯងដោយប្រពៃ ប្រកាសទុកហើយ ។ ម្នាលចុន្ទ បើសាស្តាក្នុងលោកនេះ មិនមែនជាអ្នកត្រាស់ដឹងខ្លួនឯង ដោយប្រពៃ ទាំងធម៌សោតក៏សាស្តានោះ សម្តែងមិនល្អ ប្រកាសទុកមិនល្អ មិនមែនជានិយ្យានិកធម៌ មិនមែនប្រព្រឹត្តទៅដើម្បីស្ងប់រម្ងាប់ ជាធម្មវិន័យដែលបុគ្គលមិនបានត្រាស់ដឹងខ្លួនឯងដោយប្រពៃ ប្រកាសទុកហើយ តែសាវកមិនមែនជាអ្នកប្រតិបត្តិធម៌សមគួរតាមធម៌ មិនមែនជាអ្នកប្រតិបត្តិកោតក្រែង មិនមែនជាអ្នកប្រព្រឹត្តសមគួរតាមធម៌ ក្នុងធម៌នោះ រមែងប្រព្រឹត្តគេចចេញចាកធម៌នោះថែមទៀត សាវកនោះគួរគេសរសើរយ៉ាងនេះថា ម្នាលអាវុសោ ជាលាភរបស់អ្នកនោះហើយ អ្នកនោះឈ្មោះថា បានល្អហើយ ព្រោះសាស្តារបស់អ្នក មិនមែនជាអ្នកត្រាស់ដឹងខ្លួនឯង ដោយប្រពៃទេ ទាំងធម៌សោត ក៏

សាស្តានោះ បានសំដែងមិនល្អ ប្រកាសទុកមិនល្អ មិនមែនជានិយ្យានិកធម៌ មិនប្រព្រឹត្តទៅដើម្បីស្ងប់រម្ងាប់ ជាធម៌ដែលបុគ្គលមិនបានត្រាស់ដឹងខ្លួនឯង ដោយប្រពៃ ប្រកាសទុកហើយ ទាំងអ្នកសោតក៏មិនមែនជាអ្នកប្រតិបត្តិនូវធម៌សមគួរតាមធម៌ មិនប្រតិបត្តិកោតក្រែង មិនប្រព្រឹត្តសមគួរតាមធម៌ក្នុងធម៌នោះ គឺប្រព្រឹត្តគេចចេញចាកធម៌នោះ ។ ម្នាលចុន្ទ សូម្បីសាស្តាក៏គួរឲ្យអ្នកផងតិះដៀលក្នុងហេតុនោះ ទាំងធម៌ក៏គួរឲ្យអ្នកផងតិះដៀលក្នុងហេតុនោះ ដោយប្រការដូច្នេះឯង តែឯសាវកគួរគេសរសើរ ក្នុងហេតុនោះយ៉ាងនេះ ។ ម្នាលចុន្ទ អ្នកណាមួយនិយាយនឹងសាវក មានសភាពដូច្នោះយ៉ាងនេះថា អ្នកមានអាយុ ចូរមក ចូរប្រតិបត្តិធម៌ដែលសាស្តារបស់អ្នកបានសំដែងទុកហើយ បាន បញ្ញត្តទុកហើយយ៉ាងនោះចុះ ។ បុគ្គលណាបបួលក្តី បបួលនូវបុគ្គលណាក្តី បុគ្គលណាដែលគេបបួលហើយ ប្រតិបត្តិតាមដូច្នោះក្តី ពួកបុគ្គលទាំងអស់នោះ រមែងបាននូវបុណ្យដ៏ច្រើន ។ ដំណើរនោះ តើព្រោះហេតុអ្វី ។ ម្នាលចុន្ទ ព្រោះដំណើរនុ៎ះ រមែងមានយ៉ាងនេះ ក្នុងធម្មវិន័យដែលសាស្តាសំដែងមិនល្អហើយ ប្រកាសទុកមិនល្អហើយ មិនមែនជានិយ្យានិកធម៌ មិនមែនប្រព្រឹត្តទៅដើម្បីស្ងប់រម្ងាប់ ជាធម៌ដែលបុគ្គលមិនបានត្រាស់ដឹងខ្លួនឯង ដោយប្រពៃ ប្រកាសទុកហើយ ។

[ ៩៧ ] ម្នាលចុន្ទ មួយទៀត សាស្តាក្នុងលោកនេះ មិនមែនជាសម្មាសម្ពុទ្ធ ទាំងធម៌ក៏សាស្តានោះ សំដែងហើយមិនល្អ បានប្រកាសទុកហើយមិនល្អ មិនមែនជានិយ្យានិកធម៌ មិនមែនប្រព្រឹត្តទៅដើម្បីស្ងប់រម្ងាប់ ជាធម៌

ដែលបុគ្គលមិនបានត្រាស់ដឹងខ្លួនឯង ប្រកាសទុកហើយ តែឯសាវ័កជាអ្នកប្រតិបត្តិធម៌តាមធម៌ ប្រតិបត្តិកោតក្រែង ប្រព្រឹត្តតាមធម៌ ក្នុងធម៌នោះ សមាទាន ប្រព្រឹត្តធម៌នោះ សាវ័កនោះគួរគេនិយាយឲ្យយ៉ាងនេះថា ម្នាលអាវុសោ មិនមែនជាលាភរបស់អ្នកនោះទេ អ្នកនោះឈ្មោះថា បានអាក្រក់ហើយ ព្រោះតែសាស្តារបស់អ្នក មិនមែនជាអ្នកត្រាស់ដឹងឯងដោយប្រពៃទេ ទាំងធម៌សោត ក៏សាស្តានោះបានសម្តែងហើយមិនល្អ បានប្រកាសទុកមិនល្អ មិនមែនជានិយ្យានិកធម៌ មិនមែនប្រព្រឹត្តទៅដើម្បីស្ងប់រម្ងាប់ ជាធម៌ដែលបុគ្គលមិនបានត្រាស់ដឹងខ្លួនឯង ប្រកាសទុកឡើយ ឯអ្នកក៏ជាអ្នកប្រតិបត្តិធម៌តាមធម៌ ប្រតិបត្តិកោតក្រែង ប្រព្រឹត្តតាមធម៌ ក្នុងធម៌នោះ សមាទានប្រព្រឹត្តតាមធម៌នោះ ។ ម្នាលចុន្ទ ព្រោះហេតុនេះ បានជាសាស្តា ក៏គួរគេតិះដៀលក្នុងហេតុនោះ ធម៌ក៏គួរគេតិះដៀលក្នុងហេតុនោះ សាវ័កក៏គួរគេតិះដៀលក្នុងហេតុនោះ យ៉ាងនេះ ។ ម្នាលចុន្ទ បើអ្នកណាមួយ និយាយនឹងសាវ័កមានសភាពដូច្នោះ យ៉ាងនេះថា លោកមានអាយុ ជាអ្នកប្រតិបត្តិត្រូវហេតុហើយ មុខជានឹងសម្រេចហេតុមិនខាន ។ បុគ្គលណាសរសើរក្តី សរសើរនូវបុគ្គលណាក្តី អ្នកដែលគេសរសើរហើយ ប្រារព្ធព្យាយាមឲ្យលើសជាងប្រមាណក្តី ពួកអ្នកទាំងអស់នោះ តែងបាននូវបាបដ៏ច្រើន ។ ដំណើរនុ៎ះ តើព្រោះហេតុអ្វី ។ ម្នាលចុន្ទ ព្រោះដំណើរនុ៎ះ រមែងមានយ៉ាងនេះ ក្នុងធម្មវិន័យដែលសាស្តាសម្តែងហើយមិនល្អ ប្រកាសទុកមិនល្អ មិនមែនជានិយ្យានិកធម៌ មិនមែនប្រព្រឹត្តទៅដើម្បីស្ងប់រម្ងាប់ ជាធម៌ដែលបុគ្គល

មិនបានត្រាស់ដឹងខ្លួនឯង ប្រកាសទុកហើយ ។

[ ៩៨ ] ម្នាលចុន្ទ មួយទៀត សាស្តាក្នុងលោកនេះ ជាអ្នកត្រាស់ដឹងឯងដោយប្រពៃផង ទាំងធម៌សោត សាស្តានោះក៏សម្តែងទុកល្អហើយ ប្រកាសទុកល្អហើយ ជានិយ្យានិកធម៌ ជាធម៌ប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធ ប្រកាសទុកហើយ តែសាវកមិនមែនជាអ្នកប្រតិបត្តិធម៌ សមគួរតាមធម៌ មិនប្រតិបត្តិដោយកោតក្រែង មិនប្រព្រឹត្តសមគួរតាមធម៌ ក្នុងធម៌នោះ រមែងប្រព្រឹត្តគេចចេញចាកធម៌នោះថែមទៀត សាវកនោះគួរគេនិយាយឲ្យយ៉ាងនេះថា ម្នាលអាវុសោ មិនមែនជាលាភរបស់អ្នកនោះទេ អ្នកនោះឈ្មោះថា បានអាក្រក់ហើយ ព្រោះសាស្តារបស់អ្នក ជាសម្មាសម្ពុទ្ធស្រាប់ ទាំងធម៌សាស្តានោះ ក៏សម្តែងទុកល្អហើយ ប្រកាសទុកល្អហើយ ជានិយ្យានិកធម៌ ជាធម៌ប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រកាសទុកហើយ ទាស់តែអ្នក មិនមែនជាអ្នកប្រតិបត្តិធម៌សមគួរតាមធម៌ មិនប្រតិបត្តិកោតក្រែង មិនប្រព្រឹត្តសមគួរតាមធម៌ ក្នុងធម៌នោះ ទៅជាប្រព្រឹត្តគេចចេញចាកធម៌នោះវិញ ។ ម្នាលចុន្ទ ព្រោះហេតុនេះ សាស្តាក៏គួរគេសរសើរក្នុងហេតុនោះ ធម៌ក៏គួរគេសរសើរក្នុងហេតុនោះ ដោយប្រការដូច្នេះឯង ប៉ុន្តែឯសាវក គួរគេតិះដៀលក្នុងហេតុនោះ យ៉ាងនេះ ។ ម្នាលចុន្ទ បើអ្នកណាមួយនិយាយនឹងសាវក មានសភាពដូច្នោះ យ៉ាងនេះថា អ្នកមានអាយុចូលមក ចូរប្រព្រឹត្តតាមធម៌ ដែលសាស្តារបស់អ្នកសម្តែងទុកហើយ បញ្ញត្តទុកហើយយ៉ាងនោះចុះ ។ បុគ្គលណាបបួលក្តី បបួលនូវបុគ្គល

ណាក្តី អ្នកដែលគេបបួលហើយ ប្រតិបត្តិតាមយ៉ាងនោះក្តី ពួកអ្នកទាំងអស់នោះ រមែងបាននូវបុណ្យច្រើន ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលចុន្ទ ព្រោះដំណើរនុ៎ះ រមែងមានយ៉ាងនេះ ក្នុងធម្មវិន័យដែលសាស្តាសម្តែងល្អហើយ បានប្រកាសទុកល្អហើយ ជានិយ្យានិកធម៌ ជាធម៌ប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ទុកហើយ ។

[ ៩៩ ] ម្នាលចុន្ទ មួយទៀត សាស្តាក្នុងលោកនេះ ក៏ជាសម្មាសម្ពុទ្ធទាំងធម៌ សាស្តានោះក៏សម្តែងល្អហើយ ប្រកាសទុកល្អហើយ ជានិយ្យានិកធម៌ ជាធម៌ប្រព្រឹត្តទៅដើម្បីស្ងប់រម្ងាប់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រកាសទុកហើយ ទាំងសាវកសោត ក៏ជាអ្នកប្រតិបត្តិធម៌ សមគួរតាមធម៌ ប្រតិបត្តិកោតក្រែង ប្រព្រឹត្តសមគួរតាមធម៌ ក្នុងធម៌នោះ សមាទានប្រព្រឹត្តតាមធម៌នោះ សាវកនោះគួរគេនិយាយយ៉ាងនេះថា ម្នាលអាវុសោ ជាលាភល្អរបស់អ្នកនោះហើយ អ្នកនោះឈ្មោះថា បានល្អហើយ ព្រោះសាស្តារបស់អ្នក ជាអ្នកឆ្ងាយចាកកិលេស ត្រាស់ដឹងឯងដោយប្រពៃ ទាំងធម៌ សាស្តានោះក៏បានសម្តែងល្អហើយ ប្រកាសទុកល្អហើយ ជានិយ្យានិកធម៌ ជាធម៌ប្រព្រឹត្តទៅដើម្បីស្ងប់រម្ងាប់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រកាសទុកហើយ អ្នកសោត ក៏ជាអ្នកប្រព្រឹត្តធម៌ សមគួរតាមធម៌ ប្រតិបត្តិកោតក្រែង ប្រព្រឹត្តសមគួរតាមធម៌ ក្នុងធម៌នោះ សមាទានប្រព្រឹត្តតាមធម៌នោះ ។ ម្នាលចុន្ទ ព្រោះហេតុនេះ បានជាសាស្តា ក៏គួរគេសរសើរក្នុងហេតុនោះ ធម៌ក៏គួរគេសរសើរ ក្នុងហេតុនោះ សាវកក៏គួរគេសរសើរក្នុងហេតុនោះ យ៉ាងនេះ ។

ម្នាលចុន្ទ បើអ្នកណាមួយ និយាយនឹងសាវ័កមានសភាពដូច្នោះ យ៉ាងនេះថា លោកមានអាយុ ជាអ្នកប្រតិបត្តិត្រូវហេតុហើយ មុខជានឹងសម្រេចហេតុមិនខាន ។ បុគ្គលណាសរសើរក្តី សរសើរនូវបុគ្គលណាក្តី អ្នកដែលគេសរសើរហើយ ប្រារព្ធព្យាយាមយ៉ាងក្រៃលែងជាងប្រមាណក្តី ពួកអ្នកទាំងអស់នោះរមែងបាននូវបុណ្យច្រើន ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលចុន្ទ ព្រោះដំណើរនុ៎ះ រមែងមានយ៉ាងនេះ ក្នុងធម្មវិន័យដែលសាស្តាសម្តែងល្អហើយ ប្រកាសទុកល្អហើយ ជានិយ្យានិកធម៌ ជាធម៌ប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រកាសទុកហើយ ។

[ ១០០ ] ម្នាលចុន្ទ ព្រះសាស្តាជាអរហន្តសម្មាសម្ពុទ្ធ ក៏កើតឡើងហើយក្នុងលោកនេះ ទាំងធម៌សោតព្រះសាស្តាក៏សម្តែងល្អហើយ ប្រកាសទុកល្អហើយ ជានិយ្យានិកធម៌ ជាធម៌ប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រកាសទុកហើយ តែពួកសាវ័ករបស់ព្រះសាស្តានោះ មិនទាន់យល់សេចក្តីច្បាស់ក្នុងព្រះសទ្ធម្មឡើយ ទាំងព្រះសាស្តារបស់សាវ័កទាំងនោះ ក៏ពុំទាន់បានធ្វើឲ្យច្បាស់នូវព្រហ្មចរិយធម៌ ឲ្យបរិបូណ៌ទាំងអស់ ពុំទាន់ធ្វើឲ្យងាយ ពុំទាន់ធ្វើដោយបទចងក្រងសព្វគ្រប់ ពុំទាន់ធ្វើឲ្យជាធម៌ល្មមដឹកនាំគ្នាបានដល់ពួកសាវ័កនោះ ដរាបតែពួកទេវតា និងមនុស្សសម្តែងបានដោយប្រពៃនៅឡើយ ហើយព្រះសាស្តារបស់សាវ័កទាំងនោះបាត់ខ្លួនទៅ ។ ម្នាលចុន្ទ ព្រះសាស្តាមានសភាពយ៉ាងនេះ ឈ្មោះថា ធ្វើមរណកាល ឲ្យមានសេចក្តីក្តៅក្រហាយស្តាយក្រោយដល់ពួកសាវ័ក ។ ដំណើរ

នោះ ព្រោះហេតុអ្វី ។ ព្រោះ ( ពួកសាវ័កនោះមានសេចក្ដីស្ដាយក្រោយថា ) ព្រះសាស្ដាជាអរហន្តសម្មាសម្ពុទ្ធ បានកើតឡើងហើយក្នុងលោក ទាំងធម៌សោត ព្រះសាស្ដានោះក៏សម្ដែងល្អហើយ ប្រកាសទុកល្អហើយ ជានិយ្យា-និកធម៌ ជាធម៌ប្រព្រឹត្តទៅដើម្បីសេចក្ដីស្ងប់រម្ងាប់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធទ្រង់ប្រកាសទុកហើយ ប៉ុន្តែពួកយើងមិនទាន់យល់សេចក្ដីច្បាស់ក្នុងព្រះសទ្ធម្មឡើយ ទាំងព្រហ្មចរិយធម៌ដ៏បរិបូណ៌គ្រប់គ្រាន់ ព្រះសាស្ដាក៏មិនទាន់បានធ្វើឲ្យជាក់ច្បាស់ មិនទាន់ធ្វើឲ្យងាយ មិនទាន់បានធ្វើដោយបទចងក្រងសព្វគ្រប់ មិនទាន់បានធ្វើឲ្យជាធម៌គួរដឹកនាំគ្នាបានដល់យើងទាំងឡាយ ដរាបតែពួកទេវតា និងមនុស្ស ក៏សម្ដែងបានដោយប្រពៃនៅឡើយ ព្រះសាស្ដារបស់ពួកយើងបាត់បង់ទៅ ។ ម្នាលចុន្ទ ព្រះសាស្ដាមានសភាពយ៉ាងនេះឯង ឈ្មោះថា ធ្វើមរណកាល ឲ្យមានសេចក្ដីក្ដៅក្រហាយស្ដាយក្រោយដល់ពួកសាវ័ក ។

[ ១០១ ] ម្នាលចុន្ទ មួយទៀត ព្រះសាស្ដាជាអរហន្តសម្មាសម្ពុទ្ធកើតឡើងក្នុងលោកនេះ ទាំងធម៌ព្រះសាស្ដានោះក៏សម្ដែងល្អហើយ បានប្រកាសទុកល្អហើយ ជានិយ្យានិកធម៌ ជាធម៌ប្រព្រឹត្តទៅដើម្បីសេចក្ដីស្ងប់រម្ងាប់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធ បានប្រកាសទុកហើយ ទាំងពួកសាវ័ករបស់សាស្ដានោះ បានយល់សេចក្ដីច្បាស់ក្នុងព្រះសទ្ធម្មហើយ ព្រះសាស្ដាក៏បានធ្វើឲ្យជាក់ច្បាស់នូវព្រហ្មចរិយធម៌ដ៏បរិបូណ៌គ្រប់គ្រាន់ ធ្វើឲ្យងាយហើយ ធ្វើដោយបទចងក្រងសព្វគ្រប់ហើយ ធ្វើឲ្យជាធម៌គួរណែនាំគ្នាបានហើយ ដរាបតែពួកទេវតា និងមនុស្សក៏សម្ដែងបានដោយប្រពៃ ទើបព្រះសាស្ដារបស់សាវ័កទាំង

នោះអន្តរធានទៅ ។ ម្នាលចុន្ទ សាស្តាមានសភាពយ៉ាងនេះឯង ឈ្មោះថា ធ្វើមរណកាល មិនឲ្យមានសេចក្តីក្តៅក្រហាយស្តាយក្រោយដល់ពួកសាវ័ក ។ ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះថា ( ពួកសាវ័កទាំងនោះ មានសេចក្តីត្រេកអរយ៉ាងនេះថា ) ព្រះសាស្តាជាអរហន្តសម្មាសម្ពុទ្ធ កើតឡើងហើយក្នុងលោក ទាំងធម៌សោត ព្រះសាស្តាក៏បានសម្តែងល្អហើយ ប្រកាសទុកល្អហើយ ជានិយ្យានិកធម៌ ជាធម៌ប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធ បានប្រកាសទុកហើយ ពួកយើងសោតក៏បានយល់សេចក្តីច្បាស់ក្នុងព្រះសទ្ធម្មហើយ ព្រះសាស្តាបានធ្វើឲ្យច្បាស់នូវព្រហ្មចរិយធម៌ដ៏បរិបូណ៌ទាំងអស់ បានធ្វើឲ្យងាយហើយ បានធ្វើដោយបទចងក្រងសព្វគ្រប់ហើយ បានធ្វើឲ្យជាធម៌គួរណែនាំគ្នាបានហើយ ដរាបតែពួកទេវតានិងមនុស្សក៏សម្តែងបានដោយប្រពៃ ទើបព្រះសាស្តាបាត់បង់ទៅ ។ ម្នាលចុន្ទ សាស្តាមានសភាពយ៉ាងនេះឯង ឈ្មោះថា ធ្វើមរណកាល មិនឲ្យមានសេចក្តីក្តៅក្រហាយស្តាយក្រោយដល់ពួកសាវ័ក ។

[ ១០២ ] ម្នាលចុន្ទ ប្រសិនបើព្រហ្មចរិយធម៌ ប្រកបដោយអង្គទាំងនុ៎ះហើយ សាស្តាមិនមែនជាថេរៈ ជាអ្នកដឹងរាត្រី ជាអ្នកបួសយូរ តាំងនៅជាអង្វែង ជាអ្នកចម្រើនវ័យដោយលំដាប់ទេ ព្រហ្មចរិយធម៌នោះ ឈ្មោះថា មិនបរិបូណ៌ដោយអង្គនុ៎ះយ៉ាងនេះឡើយ ។ ម្នាលចុន្ទ បើព្រហ្មចរិយធម៌ ប្រកបដោយអង្គទាំងនេះហើយ ទាំងសាស្តាក៏ជាថេរៈ ជាអ្នកដឹងរាត្រី បួសយូរ តាំងនៅជាអង្វែង ចម្រើនវ័យដោយលំដាប់ក្នុងកាលណាហើយ ព្រហ្ម-

ចរិយធម៌នោះ ទើបឈ្មោះថា បរិបូណ៌ដោយអង្គនោះយ៉ាងនេះក្នុងកាលនោះ ។

[ ១០៣ ] ម្នាលចុន្ទ ប្រសិនបើព្រហ្មចរិយធម៌ ប្រកបដោយអង្គទាំងនុ៎ះ ទាំងសាស្តាក៏ជាថេរៈ ជាអ្នកដឹងរាត្រី បួសយូរតាំងនៅជាអង្វែង ចម្រើនវ័យដោយលំដាប់ហើយ តែមិនមានពួកភិក្ខុជាសាវ័ករបស់សាស្តានោះជាថេរៈ ជាអ្នកឈ្លាសវៃ ដឹកនាំ ក្លៀវក្លា បានដល់ធម៌ក្សេមចាកយោគៈ អាចនឹងប្រាប់នូវព្រះសទ្ធម្មបាន អាចសង្កត់សង្កិននូវបរប្បវាទដែលកើតឡើងហើយ ឲ្យជាពាក្យដែលខ្លួនសង្កត់សង្កិនរៀបរយដោយពាក្យប្រកបដោយធម៌ ហើយសម្តែងធម៌ព្រមទាំងបាដិហារិយ៍ ព្រហ្មចរិយធម៌នោះ ឈ្មោះថាមិនបរិបូណ៌ដោយអង្គនោះយ៉ាងនេះ ។ ម្នាលចុន្ទ បើព្រហ្មចរិយធម៌ប្រកបដោយអង្គទាំងនុ៎ះ ទាំងសាស្តាក៏ជាថេរៈ ជាអ្នកដឹងរាត្រី បួសយូរតាំងនៅជាអង្វែង ចម្រើនវ័យដោយលំដាប់ហើយ ទាំងពួកភិក្ខុជាសាវ័ករបស់សាស្តានោះក៏ជាថេរៈ ជាអ្នកឈ្លាសវៃដឹកនាំ ក្លៀវក្លា បានដល់ធម៌ក្សេមចាកយោគៈ អាចនឹងប្រាប់នូវព្រះសទ្ធម្មបាន អាចសង្កត់សង្កិននូវបរប្បវាទដែលកើតឡើងហើយ ឲ្យជាពាក្យដែលខ្លួនសង្កត់សង្កិន រៀបរយប្រកបដោយធម៌ ហើយសម្តែងធម៌ព្រមទាំងបាដិហារិយ៍ ក្នុងកាលណា ព្រហ្មចរិយធម៌នោះ ទើបឈ្មោះថា បរិបូណ៌ដោយអង្គនោះយ៉ាងនេះ ក្នុងកាលនោះ ។

[ ១០៤ ] ម្នាលចុន្ទ ប្រសិនបើព្រហ្មចរិយធម៌ប្រកបដោយអង្គទាំងនុ៎ះ ទាំងសាស្តាក៏ជាថេរៈ ជាអ្នកដឹងរាត្រី បួសយូរ តាំងនៅជាអង្វែង ចម្រើនវ័យដោយលំដាប់ហើយ ទាំងពួកភិក្ខុជាសាវ័ករបស់សាស្តានោះ ក៏ជាថេរៈ ជាអ្នក

ឈ្មោសវៃ ដឹកនាំក្បៀវក្សា ។បេ។ អាចសង្កត់សង្កិនទូវបរប្បវាទដែលកើតឡើង ហើយ ជាពាក្យដែលខ្ជួនសង្កត់សង្កិនរៀបរយដោយធម៌ ហើយសម្តែងធម៌ព្រមទាំងបាដិហារិយ៍បាន ប៉ុន្តែ ពួកភិក្ខុជាន់កណ្តាល ជាសាវ័ករបស់សាស្តានោះ មិនមាន ។ បើមានតែពួកភិក្ខុជាន់កណ្តាលជាសាវ័ក ។ តែសាស្តានោះ មិនមានពួកភិក្ខុខ្ចីជាសាវ័ក ។ សាស្តានោះមានតែពួកភិក្ខុនីខ្ចីជាសាវិកា ។ តែសាស្តានោះ មិនមានពួកភិក្ខុនីចាស់ជាសាវិកា ។ សាស្តានោះ មានតែពួកភិក្ខុនីចាស់ជាសាវិកា ។ តែសាស្តានោះ មិនមានពួកភិក្ខុនីជាន់កណ្តាលជាសាវិកា ។ សាស្តានោះ មានតែពួកភិក្ខុនីជាន់កណ្តាលជាសាវិកា ។ តែសាស្តានោះ មិនមានពួកភិក្ខុនីខ្ចីជាសាវិកា ។ សាស្តានោះ មានតែពួកភិក្ខុនីខ្ចី ជាសាវិកា ។ តែសាស្តានោះ មិនមានពួកគ្រហស្ថឧបាសក មានសម្លៀកបំពាក់ស ប្រព្រឹត្តព្រហ្មចារ្យជាសាវ័ក ។ បើសាស្តានោះ មានតែពួកគ្រហស្ថឧបាសក មានសម្លៀកបំពាក់ស ប្រព្រឹត្តព្រហ្មចារ្យជាសាវ័ក ។ តែសាស្តានោះ មិនមានពួកគ្រហស្ថឧបាសក មានសម្លៀកបំពាក់ស ជាអ្នកបរិភោគកាមជាសាវ័ក ។ បើសាស្តានោះ មានតែពួកគ្រហស្ថឧបាសក មានសម្លៀកបំពាក់ស បរិភោគកាមជាសាវ័ក ។ តែសាស្តានោះ មិនមានពួកគ្រហស្ថឧបាសិកា មានសម្លៀកបំពាក់ស ប្រព្រឹត្តព្រហ្មចារ្យជាសាវិកា ។ បើសាស្តានោះ មានតែពួកគ្រហស្ថឧបាសិកា មានសម្លៀកបំពាក់ស ប្រព្រឹត្តព្រហ្មចារ្យជាសាវិកា ។ តែសាស្តានោះ មិនមានពួកគ្រហស្ថឧបាសិកា មានសម្លៀកបំពាក់ស បរិភោគកាមជាសាវិកា ។ បើសាស្តានោះ មានតែពួកគ្រហស្ថ

ឧបាសិកា មានសម្លៀកបំពាក់ស បរិភោគកាមជាសាវិកា ។ តែព្រហ្មចរិយធម៌ របស់សាស្តានោះ មិនមាំមួនផ្សាយទូលាយទៅ ឥតមានគេចេះដឹងច្រើន ក្រាស់ក្រែលដរាបតែពួកទេវតា និងមនុស្សសម្តែងដោយប្រពៃមិនបាន បើទុក ជាព្រហ្មចារ្យរបស់សាស្តានោះ មាំមួន ផ្សាយទូលាយទៅ មានគេចេះដឹង ច្រើនក្រាស់ក្រែល ដរាបតែពួកទេវតា និងមនុស្សសម្តែងបានដោយប្រពៃ តែមិនបានដល់នូវលាភដ៏ប្រសើរ និងយសដ៏ប្រសើរ កាលបើដូច្នេះ ព្រហ្មចារ្យនោះ ឈ្មោះថា មិនបរិបូណ៌ដោយអង្គនោះទេ ។ ម្នាលចុន្ទ កាលណា បើព្រហ្មចារ្យ ប្រកបដោយអង្គទាំងនុ៎ះ ទាំងសាស្តាក៏ជាថេរៈ ជាអ្នកដឹងរាត្រី បួសយូរ តាំងនៅជាអង្វែង ចម្រើនដោយលំដាប់ ទាំងពួកភិក្ខុជាសាវ័ករបស់ ព្រះសាស្តានោះ ក៏ជាថេរៈ ជាអ្នកឈ្លាសវៃ អាចដឹកនាំគ្នៀវក្លា ។បេ។ អាច សម្តែងធម៌ ព្រមទាំងបាដិហារិយ៍បាន ។ សាស្តានោះ មានពួកភិក្ខុជាន់កណ្តាល ជាសាវ័កផង ។ សាស្តានោះ មានពួកភិក្ខុថ្មីជាសាវ័កផង ។ សាស្តានោះ មាន ពួកភិក្ខុនីចាស់ជាសាវិកាផង ។ សាស្តានោះ មានពួកភិក្ខុនីជាន់កណ្តាល ជាសាវិកាផង ។ សាស្តានោះ មានពួកភិក្ខុនីថ្មីជាសាវិកាផង ។ សាស្តា នោះ មានពួកគ្រហស្ថឧបាសក មានសម្លៀកបំពាក់ស ប្រព្រឹត្តព្រហ្មចារ្យជាសាវ័ក ផង ។ សាស្តានោះ មានពួកគ្រហស្ថឧបាសក មានសម្លៀកបំពាក់ស បរិភោគកាមជាសាវ័កផង ។ សាស្តានោះ មានពួកគ្រហស្ថឧបាសិកា មាន សម្លៀកបំពាក់ស ប្រព្រឹត្តព្រហ្មចារ្យជាសាវិកាផង ។ សាស្តានោះ មានពួក គ្រហស្ថឧបាសិកាមានសម្លៀកបំពាក់ស បរិភោគកាមជាសាវិកាផង ។ ទាំង

ព្រហ្មចារ្យរបស់សាស្ដានោះ ក៏មាំមួនផ្សាយទូលាយទៅ មានគេចេះដឹងច្រើន ក្រាស់ក្រែល ដរាបតែពួកទេវតា និងមនុស្សសម្ដែងបានដោយប្រពៃ ទាំងបានដល់នូវលាភដ៏ប្រសើរ និងយសដ៏ប្រសើរ កាលបើដូច្នេះ ព្រហ្មចារ្យនោះ ទើបឈ្មោះថា បរិបូណ៌ដោយអង្គនោះ ។

[ ១០៥ ] ម្នាលចុន្ទ ក៏ឥឡូវនេះ តថាគតជាសាស្ដា ជាអរហន្តសម្មាសម្ពុទ្ធ កើតឡើងហើយក្នុងលោក ទាំងធម៌សោត តថាគតបានសម្ដែងប្រពៃហើយ ប្រកាសទុកប្រពៃហើយ ជានិយ្យានិកធម៌ ជាធម៌ប្រព្រឹត្តទៅដើម្បីសេចក្ដីស្ងប់រម្ងាប់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធប្រកាសទុកហើយ ទាំងពួកសាវក ក៏តថាគតបានពន្យល់ឲ្យដឹងច្បាស់សេចក្ដីក្នុងព្រះសទ្ធម្មហើយ ទាំងព្រហ្មចរិយធម៌ដ៏បរិបូណ៌សព្វគ្រប់ ក៏តថាគតបានធ្វើឲ្យជាក់ច្បាស់ដល់សាវកទាំងនោះ ធ្វើឲ្យងាយឡើង ធ្វើដោយបទចង្រង ធ្វើឲ្យជាធម៌គួរដឹកនាំគ្នាបាន ដរាបតែពួកទេវតា និងមនុស្សសម្ដែងបានដោយប្រពៃ ។ ម្នាលចុន្ទ ឥឡូវនេះ តថាគតក៏ជាសាស្ដា ជាថេរៈ អ្នកដឹងរាត្រី បួសយូរ តាំងនៅអង្វែង ចម្រើនវ័យដោយលំដាប់ហើយ ។

[ ១០៦ ] ម្នាលចុន្ទ ក្នុងកាលឥឡូវនេះ តថាគតមានពួកភិក្ខុជាថេរៈជាសាវក ជាអ្នកឈ្លាសវៃ ដឹកនាំក្បៀវក្លា ដល់នូវធម៌ក្សេមចាកយោគៈ អាចប្រាប់នូវព្រះសទ្ធម្មបាន អាចសង្កត់សង្កិននូវបរប្បវាទដែលកើតឡើងហើយ ឲ្យជាពាក្យដែលខ្លួនសង្កត់សង្កិនរៀបរយ ដោយពាក្យប្រកបដោយធម៌ ហើយសម្ដែងធម៌ ព្រមទាំងបាដិហារិយ៍បាន ។ ម្នាលចុន្ទ ក្នុងកាលឥឡូវនេះ តថាគត

មានពួកភិក្ខុជាន់កណ្តាលជាសាវកផង ។ ម្នាលចុន្ទ ឥឡូវនេះតថាគតមានពួកភិក្ខុថ្មីជាសាវកផង ។ ម្នាលចុន្ទ ឥឡូវនេះ តថាគតមានពួកភិក្ខុនីចាស់ ជាសាវិកាផង ។ ម្នាលចុន្ទ ឥឡូវនេះ តថាគតមានពួកភិក្ខុនីជាន់កណ្តាល ជាសាវិកាផង ។ ម្នាលចុន្ទ ឥឡូវនេះ តថាគតមានពួកភិក្ខុនីថ្មី ជាសាវិកាផង ។ ម្នាលចុន្ទ ឥឡូវនេះ តថាគតមានពួកគ្រហស្ថឧបាសក មានសម្លៀកបំពាក់សប្រព្រឹត្តព្រហ្មចារ្យជាសាវកផង ។ ម្នាលចុន្ទ ឥឡូវនេះ តថាគតមានពួកគ្រហស្ថឧបាសក មានសម្លៀកបំពាក់ស បរិភោគកាមជាសាវកផង ។បេ។ ម្នាលចុន្ទ ឥឡូវនេះ តថាគតមានពួកគ្រហស្ថឧបាសិកា មានសម្លៀកបំពាក់ស បរិភោគកាមជាសាវិកា ។ ម្នាលចុន្ទ ឥឡូវនេះ ព្រហ្មចរិយធម៌របស់តថាគតក៏មាំមួន ផ្សាយទូលាយទៅ មានគេចេះដឹងច្រើនក្រាស់ក្រែល ទាំងពួកទេវតានិងមនុស្ស ក៏សម្តែងបានដោយប្រពៃហើយ ។

[ ១០៧ ] ម្នាលចុន្ទ ឥឡូវនេះ ទោះជាសាស្តាទាំងឡាយ កើតឡើងហើយក្នុងលោក ។ ម្នាលចុន្ទ តថាគតជ្រើសរើសមិនឃើញសាស្តាដទៃសូម្បីម្នាក់ដែលបានដល់នូវលាភដ៏ប្រសើរ និងយសដ៏ប្រសើរយ៉ាងនេះ ឲ្យដូចជាតថាគតឡើយ ។ ម្នាលចុន្ទ ឥឡូវនេះ ទោះជាសង្ឃក្តី គណៈក្តី របស់តថាគតកើតឡើងក្នុងលោកហើយ ។ ម្នាលចុន្ទ តថាគតជ្រើសរើសមិនឃើញសង្ឃដទៃសូម្បីមួយពួក ដែលបានដល់នូវលាភដ៏ប្រសើរ និងយសដ៏ប្រសើរយ៉ាងនេះ ឲ្យដូចជាភិក្ខុសង្ឃ ( ក្នុងសាសនានេះ ) ឡើយ ។ ម្នាលចុន្ទ បុគ្គលកាលនិយាយពាក្យណាឲ្យត្រូវនោះ គួរនិយាយថា ព្រហ្មចារ្យដល់ព្រម

ហើយ ដោយហេតុគ្រប់យ៉ាង បរិបូណ៌ហើយដោយអាការគ្រប់យ៉ាង មិនខ្វះ មិនលើស ដែលព្រះមានព្រះភាគត្រាស់ទុកល្អហើយ បរិបូណ៌ទាំងអស់ បានប្រកាសទុកល្អហើយ ។ បុគ្គលកាលនិយាយឲ្យត្រូវ គួរនិយាយពាក្យនេះឯងថា ព្រហ្មចារ្យដល់ព្រមហើយ ដោយអាការគ្រប់យ៉ាង បរិបូណ៌ដោយអាការគ្រប់យ៉ាង ។បេ។ បានប្រកាសល្អហើយ ដូច្នេះ ។ ម្នាលចុន្ទ ឮថាឧទ្ទករាមបុត្រ និយាយសម្តីយ៉ាងនេះថា បុគ្គលកាលឃើញ ក៏ឈ្មោះថា មិនឃើញ ។ ឃើញនូវអ្វី ឈ្មោះថា មិនឃើញ ។ បុគ្គលឃើញបានតែត្រឹមផ្ទៃនៃកាំបិតកោរដែលមុតល្អ តែមិនឃើញមុខកាំបិតកោរទេ ។ ម្នាលចុន្ទ នេះឯងដែលឧទ្ទករាមបុត្រនិយាយថា បុគ្គលកាលឃើញក៏ឈ្មោះថាមិនឃើញ ។ ម្នាលចុន្ទ ឯពាក្យដែលឧទ្ទករាមបុត្រពោលនោះ ជាពាក្យថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនរបស់ព្រះអរិយៈ មិនប្រកបដោយប្រយោជន៍ ព្រោះសំដៅកាំបិតកោរតែម្យ៉ាង ។ ម្នាលចុន្ទ កាលបើបុគ្គលនិយាយពាក្យណាឲ្យត្រូវនោះ គួរនិយាយថា បុគ្គលកាលឃើញក៏ឈ្មោះថាមិនឃើញ ។ បុគ្គលកាលនិយាយឲ្យត្រូវ គួរនិយាយពាក្យនេះឯងថា បុគ្គលកាលឃើញ ក៏ឈ្មោះថា មិនឃើញ ។ បុគ្គលឃើញនូវអ្វីខ្លះ ឈ្មោះថា មិនឃើញ ។ ពាក្យថា ព្រហ្មចារ្យដល់ព្រមហើយ ដោយហេតុគ្រប់យ៉ាង បរិបូណ៌ហើយដោយអាការគ្រប់យ៉ាង មិនខ្វះ មិនលើស ដែលតថាគតសម្តែងទុកល្អហើយ បរិបូណ៌ទាំងអស់ បានប្រកាសទុកល្អហើយយ៉ាងនេះ បុគ្គលមិនឃើញសេចក្តីនុ៎ះដូច្នេះសោះ សមជាដកពាក្យនេះចេញ ក្នុងរឿងនោះ ។ បុគ្គលនោះថែមទាំង

មិនឃើញសេចក្ដីនុ៎ះដូច្នេះថា ព្រហ្មចារ្យនុ៎ះបរិសុទ្ធក្រៃលែងយ៉ាងនេះ សមជាបញ្ចូលពាក្យនេះ ក្នុងរឿងនុ៎ះ ។ បុគ្គលនោះឈ្មោះថា មិនឃើញសេចក្ដីនៃពាក្យថា ព្រហ្មចារ្យនោះបរិសុទ្ធក្រៃលែងដូច្នេះយ៉ាងនេះ ។ នេះហៅថា បុគ្គលកាលឃើញ ឈ្មោះថា មិនឃើញ ។ ម្នាលចុន្ទ បុគ្គលកាលនិយាយពាក្យណាឲ្យត្រូវនោះ គួរនិយាយថា ព្រហ្មចារ្យ ដល់ព្រមហើយដោយហេតុគ្រប់យ៉ាង ។បេ។ បានប្រកាសទុកល្អហើយ ។ បុគ្គលកាលនិយាយឲ្យត្រូវ គួរនិយាយពាក្យនេះឯងថា ព្រហ្មចារ្យដល់ព្រមហើយ ដោយហេតុគ្រប់យ៉ាងបរិបូណ៌ហើយដោយអាការគ្រប់យ៉ាង មិនខ្វះ មិនលើស ដែលតថាគតសម្ដែងទុកល្អហើយ បរិបូណ៌ទាំងអស់ ប្រកាសទុកល្អហើយ ដូច្នេះ ។

[ ១០៨ ] ម្នាលចុន្ទ ព្រោះហេតុនោះធម៌ទាំងឡាយណា ដែលតថាគតបានត្រាស់ដឹង សម្ដែងទុកល្អហើយក្នុងលោកនេះ គួរឲ្យអ្នកទាំងអស់រួមគំនិតមកប្រជុំរួបរួមផ្ទៀងផ្ទាត់ នូវអត្ថដោយអត្ថ ព្យញ្ជនៈដោយព្យញ្ជនៈ ក្នុងធម៌នោះ ដែលជាហេតុឲ្យព្រហ្មចារ្យនេះ តាំងនៅមាំ ឋិតថេរអស់កាលយូរដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។ ម្នាលចុន្ទ ធម៌ទាំងឡាយដែលតថាគត បានសម្ដែងហើយដល់អ្នក ព្រោះសេចក្ដីដឹងដ៏ក្រៃលែងនោះ តើដូចម្ដេច ។ ពួកអ្នកទាំងអស់គ្នាត្រូវរួមគំនិត មកប្រជុំគ្នារួបរួមផ្ទៀងផ្ទាត់ នូវអត្ថដោយអត្ថព្យញ្ជនៈដោយព្យញ្ជនៈ ក្នុងពួកធម៌ណាដែលជាហេតុឲ្យព្រហ្មចារ្យនេះតាំងនៅ

បានមាំមួន ឋិតថេរអស់កាលយូរ ដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។ ពួកធម៌នោះ ដូចម្តេចខ្លះ ។ ពួកធម៌នោះ គឺសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ សម្ពោជ្ឈង្គ ៧ និងអរិយមគ្គប្រកបដោយអង្គ ៨ ។ ម្នាលចុន្ទ ធម៌ទាំងឡាយនេះឯង ដែលតថាគតបានត្រាស់ដឹងសម្តែងហើយ ដែលពួកបរិស័ទទាំងអស់ ត្រូវរួមគំនិត ប្រជុំគ្នារួបរួមផ្ទៀងផ្ទាត់ នូវអត្ថដោយអត្ថ ព្យញ្ជនៈដោយព្យញ្ជនៈ ដែលជាហេតុឲ្យព្រហ្មចារ្យនេះ ឋិតនៅបានមាំ តាំងនៅអស់កាលយូរ ដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំង-ឡាយ ។

[ ១០៩ ] ម្នាលចុន្ទ ពួកអ្នកនោះឯង ជាអ្នកព្រមព្រៀងគ្នា ជាអ្នកមានចិត្តរីករាយ មិនទាស់ទែងគ្នា គប្បីសិក្សាចុះ ។ សព្រហ្មចារីបុគ្គលណាមួយនិយាយធម៌ ក្នុងការនិយាយធម៌នោះ បើអ្នកទាំងឡាយ មានសេចក្តីយល់យ៉ាងនេះថា ម្នាលអាវុសោ លោកមានអាយុនេះឯង កាន់យកនូវអត្ថខុស សម្តែងនូវព្យញ្ជនៈក៏ខុស ។ អ្នកទាំងឡាយ មិនត្រូវត្រេកអរ មិនត្រូវហាមឃាត់គេឡើយ ។ លុះពួកអ្នកមិនត្រេកអរ មិនជំទាស់ហើយ គួរនិយាយនឹងគេ យ៉ាងនេះថា ម្នាលអាវុសោ ព្យញ្ជនៈទាំងនេះ ឬថា ព្យញ្ជនៈទាំងនុ៎ះ

របស់អត្ថនេះ ពួកណាស្រួលជាង មួយទៀត អត្ថនេះ ឬក៏អត្ថទាំះ របស់ព្យញ្ជនៈពួកនេះ អត្ថណាស្រួលជាង ។ ប្រសិនបើគេនិយាយយ៉ាងនេះថា ម្នាលអាវុសោ ពួកព្យញ្ជនៈនេះឯង របស់អត្ថនេះ ជាព្យញ្ជនៈស្រួលជាង អត្ថនេះឯង របស់ពួកព្យញ្ជនៈទាំះ ជាអត្ថស្រួលជាង ។ ភិក្ខុមិនត្រូវលើក មិនត្រូវបន្អាប់គេឡើយ ។ លុះមិនលើក មិនបន្អាប់គេហើយ គួរពន្យល់គេដោយស្រួលបួល ដើម្បីចាំទុកនូវអត្ថនោះ និងពួកព្យញ្ជនៈនោះ ។

[ ១១០ ] ម្នាលចុន្ទ បើសព្រហ្មចារីដទៃ និយាយធម៌ ក្នុងការនិយាយនោះ បើអ្នកទាំងឡាយ មានសេចក្ដីយល់យ៉ាងនេះថា លោកមានអាយុនេះឯង កាន់យកនូវអត្ថខុស ( តែ ) សម្ដែងព្យញ្ជនៈទាំងឡាយត្រូវ ។ អ្នកទាំងឡាយ ក៏មិនត្រូវត្រេកអរ មិនត្រូវជំទាស់គេឡើយ ។ លុះមិនត្រេកអរ មិនជំទាស់ហើយ ត្រូវនិយាយនឹងគេយ៉ាងនេះថា ម្នាលអាវុសោ អត្ថនេះ ឬអត្ថទាំះ របស់ពួកព្យញ្ជនៈទាំងនេះអត្ថណាស្រួលជាង ។ ប្រសិនបើគេនិយាយយ៉ាងនេះថា ម្នាលអាវុសោ អត្ថនេះឯង របស់ព្យញ្ជនៈពួកនេះ ជាអត្ថស្រួលជាង ។ អ្នកទាំងឡាយមិនត្រូវលើក មិនត្រូវបន្អាប់គេឡើយ ។ លុះមិនបានលើក មិនបានបន្អាប់ហើយ គួរពន្យល់គេដោយស្រួលបួល ដើម្បីចាំទុកនូវអត្ថនោះ ។

[ ១១១ ] ម្នាលចុន្ទ បើសព្រហ្មចារីដទៃទៀតនិយាយធម៌ ក្នុងការនិយាយនោះ បើអ្នកទាំងឡាយ មានសេចក្ដីយល់យ៉ាងនេះថា លោកមានអាយុនេះឯង កាន់យកនូវអត្ថត្រូវ ( តែ ) សម្ដែងនូវព្យញ្ជនៈខុស ។ អ្នក

ទាំងឡាយ មិនត្រូវត្រេកអរ មិនត្រូវជំទាស់គេឡើយ ។ លុះមិនត្រេកអរ មិនជំទាស់ហើយ ត្រូវនិយាយនឹងគេយ៉ាងនេះថា ម្នាលអាវុសោ ពួកព្យញ្ជនៈនេះ ឬពួកព្យញ្ជនៈនុ៎ះ របស់អត្ថនេះ ពួកណាស្រួលជាង ។ បើគេនិយាយយ៉ាងនេះថា ម្នាលអាវុសោ ពួកព្យញ្ជនៈនេះឯង របស់អត្ថនេះ ជាព្យញ្ជនៈស្រួលជាង ។ អ្នកទាំងឡាយមិនត្រូវលើក មិនត្រូវបង្អាប់គេឡើយ ។ លុះមិនលើក មិនបង្អាប់ហើយ គួរពន្យល់គេដោយស្រួលបួល ដើម្បីចាំទុកនូវព្យញ្ជនៈនោះ ។

[ ១១២ ] ម្នាលចុន្ទ បើសព្រហ្មចារីដទៃទៀត និយាយធម៌ក្នុងការនិយាយនោះ បើអ្នកទាំងឡាយ មានសេចក្តីយល់យ៉ាងនេះថា លោកមានអាយុនេះ កាន់យកនូវអត្ថ ក៏ត្រឹមត្រូវ សម្តែងនូវពួកព្យញ្ជនៈ ក៏ត្រឹមត្រូវ ។ អ្នកទាំងឡាយ ត្រូវត្រេកអរ ត្រូវអនុមោទនាចំពោះភាសិតរបស់ភិក្ខុនោះថា សាធុ ដូច្នេះ ។ លុះត្រេកអរ អនុមោទនា ចំពោះភាសិតរបស់ភិក្ខុនោះថា សាធុ ដូច្នេះហើយ ត្រូវនិយាយនឹងភិក្ខុនោះយ៉ាងនេះថា ម្នាលអាវុសោ ជាលាភរបស់ពួកយើង ម្នាលអាវុសោ ពួកយើងបានស្រួលហើយ ពួកយើងរឭកនូវលោកមានអាយុថា សព្រហ្មចារីប្រាកដដូចជាលោក ដែលជាអ្នកដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវព្យញ្ជនៈយ៉ាងនេះ ។

[ ១១៣ ] ម្នាលចុន្ទ តថាគតមិនសម្តែងធម៌ ដើម្បីរាំងនូវអាសវៈទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន តែមួយយ៉ាង ដល់ពួកអ្នកទេ ម្នាលចុន្ទ តថាគតមិនសម្តែងធម៌ ដើម្បីកម្ចាត់បង់នូវអាសវៈទាំងឡាយ ដែល

ប្រព្រឹត្តទៅក្នុងលោកខាងមុខប៉ុណ្ណោះទេ ម្នាលចុន្ទ តថាគតសម្តែងធម៌ដើម្បី រារាំងនូវអាសវធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នផង ដើម្បីកម្ចាត់ បង់នូវអាសវៈទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងលោកខាងមុខផង ។ ម្នាលចុន្ទ ព្រោះហេតុដូច្នោះ ចីវរណាដែលតថាគតបានអនុញ្ញាតហើយ ដល់អ្នកទាំង-ឡាយ ចីវរនោះ ក៏សមគួរដល់អ្នកទាំងឡាយ ដើម្បីការពារនូវត្រជាក់ ដើម្បី ការពារនូវកម្តៅ ដើម្បីការពារនូវសម្ផស្សរបោម មូស ខ្យល់ កម្តៅថ្ងៃ និង ពស់តូច ពស់ធំទាំងឡាយប៉ុណ្ណោះ ទាំងដើម្បីបិទបាំងនូវអវយវៈ ជាគ្រឿង ញុំាងសេចក្តីអៀនខ្មាសឲ្យកម្រើកប៉ុណ្ណោះឯង ចង្ហាន់បិណ្ឌបាតណា ដែល តថាគតបានអនុញ្ញាតហើយ ដល់អ្នកទាំងឡាយ ចង្ហាន់បិណ្ឌបាតនោះ ក៏គួរ ដល់អ្នកទាំងឡាយ ដើម្បីគ្រាន់តែឲ្យកាយនេះ តាំងនៅបាន ប្រព្រឹត្តទៅបាន ដើម្បីកម្ចាត់បង់នូវសេចក្តីលំបាក ដើម្បីអនុគ្រោះដល់ព្រហ្មចារ្យ ដើម្បីធ្វើទុក ក្នុងចិត្តថា អាត្មាអញនឹងបំបាត់នូវវេទនាចាស់ផង ទាំងមិនឲ្យវេទនាថ្មីកើត ឡើងបានផង ការប្រព្រឹត្តទៅ ( នៃឥរិយាបថទាំង ៤ ក្តី ) សេចក្តីមិនមាន ទោសក្តី ការនៅសប្បាយក្តី នឹងមានដល់អាត្មាអញ ( ដោយការបរិភោគ នូវចង្ហាន់បិណ្ឌបាតនេះ ) ទីសេនាសនៈណា ដែលតថាគតបានអនុញ្ញាតហើយ ដល់អ្នកទាំងឡាយ ទីសេនាសនៈនោះសមគួរដល់អ្នកទាំងឡាយ ដើម្បីការពារ នូវត្រជាក់ ដើម្បីការពារនូវកម្តៅ ដើម្បីការពារនូវសម្ផស្សរបោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់តូច ពស់ធំទាំងឡាយប៉ុណ្ណោះ ដើម្បីបន្ទោបង់នូវក្រវល់ ក្រវាយដែលកើតអំពីរដូវ អភិរម្យសម្ងំនៅក្នុងកម្មដ្ឋានប៉ុណ្ណោះឯង គ្រឿងបរិក្ខារ

ជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យដល់អ្នកជំងឺណា ដែលតថាគតបានអនុញ្ញាត ហើយ ដល់អ្នកទាំងឡាយ គ្រឿងបរិក្ខារជាទីរក្សានូវជីវិត គឺថ្នាំជាបច្ច័យ ដល់អ្នកជំងឺនោះ សមគួរដល់អ្នកទាំងឡាយ ដើម្បីការពារនូវវេទនាទាំងឡាយ ដែលបៀតបៀនផ្សេងៗ ដែលកើតឡើងហើយ ដើម្បីប្រាសចាកទុក្ខខ្លាំង ជាធម្មតា ។

[ ១១៤ ] ម្នាលចុន្ទ ហេតុជាទីតាំងរមែងមានយ៉ាងនេះ គឺពួកបរិព្វាជក ជាអន្យតិរ្ថិយ សមបើជានិយាយយ៉ាងនេះថា ពួកសមណសក្យបុត្តិយ៍ជាអ្នក ប្រកបរឿយៗ ក្នុងសុខល្លិកានុយោគ ( ប្រកបខ្លួនឲ្យប្រព្រឹត្តទៅក្នុងការ ស្រួល ) ។ ម្នាលចុន្ទ កាលបើពួកបរិព្វាជក ជាអន្យតិរ្ថិយនិយាយយ៉ាងនេះ ត្រូវអ្នកទាំងឡាយនិយាយយ៉ាងនេះថា ម្នាលអាវុសោ សុខល្លិកានុយោគ នោះ ដូចម្តេចខ្លះ ព្រោះថា សុខល្លិកានុយោគមានច្រើន មិនមែនតែមួយ មានប្រការផ្សេងៗ ។ ម្នាលចុន្ទ សុខល្លិកានុយោគនេះ មាន ៤ ជារបស់ ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយៈ មិនមែនប្រកបដោយប្រយោជន៍ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាសចាករាគៈ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តី រលត់ទុក្ខ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅ ដើម្បី សេចក្តីដឹងក្រៃលែង មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីត្រាស់ដឹង មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វានទេ ។ សុខល្លិកានុយោគ ៤ យ៉ាងនោះ ដូចម្តេចខ្លះ ។ ម្នាល ចុន្ទ ជនពាលខ្លះក្នុងលោកនេះ សម្លាប់សត្វទាំងឡាយ ហើយធ្វើខ្លួនឲ្យបាន

សុខ ឲ្យបានធាត់ធំ នេះឈ្មោះថា សុខល្លិកានុយោគទី ១ ។ ម្នាលចុន្ទ មួយទៀត ជនពាលពួកខ្លះក្នុងលោកនេះ កាន់យកនូវវត្ថុដែលគេមិនបានឲ្យហើយ ធ្វើខ្លួនឲ្យបានសុខ ឲ្យបានធាត់ធំ នេះឈ្មោះថា សុខល្លិកានុយោគទី ២ ។ ម្នាលចុន្ទ មួយទៀត ជនពាលពួកខ្លះ ក្នុងលោកនេះ ពោលពាក្យមុសាវាទ ហើយធ្វើខ្លួនឲ្យបានសុខ ឲ្យបានធាត់ធំ នេះឈ្មោះថា សុខល្លិកានុយោគទី ៣ ។ ម្នាលចុន្ទ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកឆ្អែតស្កប់ស្កល់ បម្រើដោយកាមគុណទាំង ៥ នេះឈ្មោះថា សុខល្លិកានុយោគទី ៤ ។ ម្នាលចុន្ទ សុខល្លិកានុយោគ ៤ យ៉ាងនេះឯង ជាធម៌ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនរបស់ព្រះអរិយៈ មិនមែនប្រកបដោយប្រយោជន៍ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាសចាករាគៈ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីរលត់ទុក្ខ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីដឹងក្រៃលែង មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីត្រាស់ដឹង មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វានទេ ។ ម្នាលចុន្ទ ហេតុជាទីតាំង រមែងមានយ៉ាងនេះ គឺពួកបរិព្វាជក ជាអន្យតិរ្ថិយ សមបើនិយាយយ៉ាងនេះថា ពួកសមណសក្យបុត្តិយ៍ ជាអ្នកប្រកបរឿយៗ នូវសុខល្លិកានុយោគទាំង ៤ នេះ ។ អ្នកទាំងឡាយ ត្រូវនិយាយតបទៅនឹងពួកបរិព្វាជកនោះថា ពួកលោកកុំនិយាយយ៉ាងនោះ ឯពួកបរិព្វាជកទាំងនោះ មិនមែននិយាយដោយត្រឹមត្រូវនឹងពួកអ្នកទេ ពួកបរិព្វាជកទាំងនោះ មិនគប្បីបង្កាច់ពួកអ្នក ដោយពាក្យមិនមែន ដោយពាក្យមិនពិតទេ ។

[ ១១៥ ] ម្នាលចុន្ទ សុខល្លិកានុយោគនេះមាន ៤ ប្រព្រឹត្តទៅ ដើម្បីសេចក្ដីនឿយណាយ ដើម្បីសេចក្ដីប្រាសចាករាគៈ ដើម្បីសេចក្ដីរលត់ទុក្ខ ដើម្បីសេចក្ដីស្ងប់រម្ងាប់ ដើម្បីសេចក្ដីដឹងក្រៃលែង ដើម្បីសេចក្ដីត្រាស់ដឹង ដើម្បីព្រះនិព្វានដោយពិត ។ សុខល្លិកានុយោគ ៤ យ៉ាងដូចម្ដេចខ្លះ ។ ម្នាលចុន្ទ ភិក្ខុក្នុងសាសនានេះ ស្ងាត់ស្រឡះចាកកាមទាំងឡាយ ស្ងាត់ស្រឡះចាកធម៌ទាំងឡាយជាអកុសល ដល់នូវបឋមជ្ឈាន ដែលប្រកបដោយវិតក្កវិចារៈ មានបីតិ និងសុខដែលកើតពីសេចក្ដីស្ងប់ស្ងាត់ ( ជាអារម្មណ៍ ) នេះឈ្មោះថា សុខល្លិកានុយោគទី ១ ។ ម្នាលចុន្ទ មួយទៀត ព្រោះសេចក្ដីរម្ងាប់នូវវិតក្ក និងវិចារៈទាំងឡាយ ។បេ។ ភិក្ខុដល់នូវទុតិយជ្ឈាន នេះឈ្មោះថា សុខល្លិកានុយោគទី ២ ។ ម្នាលចុន្ទ មួយទៀត ព្រោះនឿយណាយចាកបីតិ ។បេ។ ភិក្ខុដល់នូវតតិយជ្ឈាន នេះឈ្មោះថា សុខល្លិកានុយោគទី ៣ ។ ម្នាលចុន្ទ មួយទៀត ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង ។បេ។ ភិក្ខុដល់នូវចតុត្ថជ្ឈាន នេះឈ្មោះថា សុខល្លិកានុយោគទី ៤ ។ ម្នាលចុន្ទ សុខល្លិកានុយោគទាំង ៤ យ៉ាងនេះឯង ទើបប្រព្រឹត្តទៅ ដើម្បីសេចក្ដីនឿយណាយ ដើម្បីសេចក្ដីប្រាសចាករាគៈ ដើម្បីសេចក្ដីរលត់ទុក្ខ ដើម្បីសេចក្ដីរម្ងាប់ ដើម្បីសេចក្ដីដឹងក្រៃលែង ដើម្បីសេចក្ដីត្រាស់ដឹង ដើម្បីព្រះនិព្វានដោយចំណែកមួយ ។ ម្នាលចុន្ទ ហេតុជាទីតាំង រមែងមានយ៉ាងនេះ គឺពួកបរិព្វាជក ជាអន្យតិរ្ថិយ សមជានិយាយយ៉ាងនេះថា ពួកសមណៈជាសក្យបុត្តិយ៍ ជាអ្នកប្រកបរឿយៗ នូវសុខល្លិកានុយោគទាំង ៤ យ៉ាងនេះឯង ។ ពួកអ្នកទាំង-

ឡាយ គួរនិយាយទៅនឹងពួកបរិព្វាជកទាំងនោះថា យ៉ាងហ្នឹងហើយ ពួកគេកាលនិយាយឲ្យអ្នកទាំងឡាយ ឈ្មោះថា និយាយដោយត្រូវ ពួកគេមិនមែននិយាយបង្កាច់អ្នកទាំងឡាយ ដោយមិនមានមែន ដោយមិនពិតទេ ។

[ ១១៦ ] ម្នាលចុន្ទ ហេតុជាទីតាំងរមែងមានយ៉ាងនេះ គឺពួកបរិព្វាជកជាអន្យតិ្ថិយ សមបើជានិយាយយ៉ាងនេះថា ម្នាលអាវុសោ ផលប៉ុន្មានយ៉ាង អានិសង្សប៉ុន្មានយ៉ាង រមែងប្រាកដដល់បុគ្គលអ្នកប្រកបរឿយៗ នូវសុខល្លិកានុយោគទាំង ៤ យ៉ាងនេះ ។ ម្នាលចុន្ទ ពួកបរិព្វាជក ជាអន្យតិ្ថិយនិយាយយ៉ាងនេះ អ្នកទាំងឡាយត្រូវនិយាយយ៉ាងនេះថា ម្នាលអាវុសោ ផល ៤ យ៉ាង អានិសង្ស ៤ យ៉ាង រមែងប្រាកដដល់ពួកបុគ្គលអ្នកប្រកបរឿយៗ នូវសុខល្លិកានុយោគទាំង ៤ យ៉ាងនេះឯង ។ ផល និងអានិសង្សទាំង ៤ យ៉ាងដូចម្តេចខ្លះ ។ ម្នាលអាវុសោ ភិក្ខុក្នុងធម្មវិន័យនេះ ជាសោតាបន្នបុគ្គល មានកិរិយាមិនធ្លាក់ចុះជាធម្មតា ជាបុគ្គលទៀងទាត់ មានសេចក្តីត្រាស់ដឹងប្រព្រឹត្តទៅខាងមុខ ព្រោះអស់ទៅនៃសំយោជនៈទាំង ៣ នេះជាផលទី ១ ជាអានិសង្សទី ១ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុជាសកទាគាមិបុគ្គល ព្រោះអស់ទៅនៃសំយោជនៈទាំង ៣ ទាំងស្រាលស្តើងចាករាគៈ ទោសៈ និងមោហៈ មកកាន់លោកនេះម្តងទៀត រមែងធ្វើនូវទីបំផុតនៃទុក្ខបាន នេះជាផលទី ២ ជាអានិសង្សទី ២ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុបានកំណើតជាឱបបាតិកៈ ( អនាគាមិបុគ្គល ) តែងបរិនិព្វានក្នុងភពនោះ មានកិរិយាមិនត្រឡប់ចាកលោកនោះជាធម្មតា ព្រោះការអស់ទៅនៃសំយោជនៈ ជាចំណែក

ខាងក្រោម ៥ នេះជាផលទី ៣ ជាអានិសង្សទី ៣ ។ ម្នាលអាវុសោ មួយទៀត ភិក្ខុធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញារបស់ខ្លួន ដោយខ្លួនឯង ក្នុងបច្ចុប្បន្ននេះ រមែងសម្រេចសម្រាន្តនៅដោយឥរិយាបថ នេះជាផលទី ៤ ជាអានិសង្សទី ៤ ។ ម្នាលអាវុសោ ផលទាំង ៤ នេះ អានិសង្សទាំង ៤ នេះ រមែងប្រាកដដល់ពួកភិក្ខុអ្នកប្រកបរឿយៗ នូវសុខល្លិកានុយោគទាំងនេះឯង ។

[ ១១៧ ] ម្នាលចុន្ទ ហេតុជាទីតាំងរមែងមានយ៉ាងនេះ គឺពួកបរិព្វាជកជាអន្យតិរ្ថិយនិយាយយ៉ាងនេះថា ពួកសមណៈជាសក្យបុត្តិយ៍ ជាបុគ្គលមានសភាពមិនឋិតថេរ ។ ម្នាលចុន្ទ ពួកបរិព្វាជកជាអន្យតិរ្ថិយ និយាយយ៉ាងនេះ អ្នកទាំងឡាយត្រូវនិយាយយ៉ាងនេះថា ម្នាលអាវុសោ ធម៌ទាំងឡាយដែលព្រះមានព្រះភាគ ព្រះអង្គនោះ ទ្រង់ជ្រាប ទ្រង់ឃើញ ជាព្រះអរហន្តសម្មា-សម្ពុទ្ធសម្តែងហើយ បញ្ញត្តហើយ ដល់សាវកទាំងឡាយ ជាធម៌ដែលពួកសាវក មិនត្រូវប្រព្រឹត្តកន្លងដរាបដល់អស់ជីវិត ( នោះ ) រមែងមានពិត ។ ម្នាលអាវុសោ សសរគោល ឬសសរដែក ដែលលិចទៅក្នុងដីដ៏ជ្រៅ ដែលបុគ្គលដាំហើយដោយល្អមិនកម្រើក មិនរញ្ជួយយ៉ាងណាមិញ ម្នាលអាវុសោ ធម៌ទាំងឡាយដែលព្រះមានព្រះភាគ ព្រះអង្គនោះ ទ្រង់ជ្រាប ទ្រង់ឃើញ ជាព្រះអរហន្តសម្មាសម្ពុទ្ធ សម្តែងហើយ បញ្ញត្តហើយ ដល់សាវកទាំងឡាយ ជាធម៌ដែលពួកសាវក មិនត្រូវប្រព្រឹត្តកន្លងដរាបដល់អស់ជីវិត យ៉ាងនេះឯង ។ ម្នាលអាវុសោ ភិក្ខុណា ជាព្រះអរហន្តខីណាស្រព មានព្រហ្មចរិយធម៌ចប់

ស្រេចហើយ មានកិច្ចធ្វើហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍ដល់ហើយ ដោយលំដាប់ មានសំយោជនៈក្នុងភពអស់រលីងហើយ ជាអ្នកផុតស្រឡះហើយ ព្រោះដឹងដោយប្រពៃ ភិក្ខុនោះ ឈប់ប្រព្រឹត្តកន្លងនូវហេតុទាំងឡាយ ៩ យ៉ាង ។ ម្នាលអាវុសោ ភិក្ខុជាខីណាសវៈ ឈប់ក្លែងផ្តាច់បង់សត្វចាកជីវិត ភិក្ខុជាខីណាសវៈ ឈប់កាន់យកនូវវត្ថុដែលគេមិនបានឲ្យដែលហៅថា លួច ភិក្ខុជាខីណាសវៈ ឈប់សេពនូវមេថុនធម្ម ភិក្ខុជាខីណាសវៈ ឈប់ពោលពាក្យមុសាវាទដោយដឹងខ្លួន ភិក្ខុជាខីណាសវៈ ឈប់បរិភោគនូវកាម ដែលជាសន្និធិការកៈទាំងឡាយ ដូចកាលដែលខ្លួននៅជាគ្រហស្ថពីមុន ភិក្ខុជាខីណាសវៈ ឈប់លុះឆន្ទាគតិ ភិក្ខុជាខីណាសវៈ ឈប់លុះទោសាគតិ ភិក្ខុជាខីណាសវៈ ឈប់លុះមោហាគតិ ភិក្ខុជាខីណាសវៈ ឈប់លុះភយាគតិ ។ ម្នាលអាវុសោ ភិក្ខុណាជាព្រះអរហន្តខីណាស្រព មានព្រហ្មចរិយធម៌ចប់ស្រេចហើយ មានកិច្ចធ្វើហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍ដល់ហើយ ដោយលំដាប់ មានសំយោជនៈប្រព្រឹត្តទៅក្នុងភពអស់ហើយ ជាអ្នកផុតស្រឡះហើយ ព្រោះដឹងដោយប្រពៃ ភិក្ខុនោះ ឈប់ប្រព្រឹត្តកន្លងនូវហេតុទាំង ៩ យ៉ាងនេះឯង ។

[ ១១៨ ] ម្នាលចុន្ទ ហេតុជាទីតាំងរមែងមានយ៉ាងនេះ គឺពួកបរិព្វាជកជាអន្យតិរ្ថិយ និយាយយ៉ាងនេះថា ព្រះសមណគោតម រមែងបញ្ញត្តញាណ-ទស្សនៈដ៏លើសលុប ព្រោះប្រារព្ធនូវអតីតកាលប៉ុណ្ណោះ មិនបញ្ញត្តញាណ-ទស្សនៈដ៏លើសលុប ព្រោះប្រារព្ធនូវកាលជាអនាគតឡើយ ការមិនបញ្ញត្ត

នោះ ព្រោះហេតុអ្វី ការមិនបញ្ញត្តដូច្នោះ ព្រោះហេតុដូចម្ដេច ។ ឯពួកបរិញ្វាជក ជាអន្យតិ្ថយដទៃនោះ រមែងសម្គាល់នូវពាក្យដែលគួរបញ្ញត្ត នូវហេតុមិនមែនជាញាណទស្សនៈ ដែលឃ្វាងទៅកាន់ទីដទៃ ដោយញាណ-ទស្សនៈដែលបែរទៅកាន់ទីដទៃ ប្រៀបដូចជាពួកជនពាល ជាអ្នកមិនវាងវៃដូច្នោះឯង ។ ម្នាលចុន្ទ តថាគត រមែងមានសតានុសារិញ្ញាណ ប្រារព្ធតែកាលដែលកន្លងទៅហើយ តថាគតនោះ ប្រាថ្នាហេតុមានប្រមាណប៉ុនណា ក៏នឹកតាមហេតុមានប្រមាណប៉ុណ្ណោះបាន ឯញាណដែលកើតអំពីការត្រាស់ដឹងប្រារព្ធកាលជាអនាគត ក៏កើតឡើងដល់តថាគតថា ឥឡូវនេះ ជាតិនេះ ជាជាតិទីបំផុតហើយ ការកើតតទៅទៀតមិនមានទេ ។

[ ១១៩ ] ម្នាលចុន្ទ បើពាក្យដែលកន្លងហើយមិនពិត មិនមែន មិនប្រកបដោយប្រយោជន៍ តថាគតមិនព្យាករពាក្យនោះទេ ។ ម្នាលចុន្ទ បើពាក្យដែលកន្លងហើយ ជាពាក្យពិតប្រាកដ ( តែ ) មិនប្រកបដោយប្រយោជន៍ តថាគតក៏មិនព្យាករពាក្យនោះដែរ ។ ម្នាលចុន្ទ ប្រសិនបើពាក្យដែលកន្លងហើយ ជាពាក្យពិតប្រាកដ ប្រកបដោយប្រយោជន៍ តថាគតជាអ្នកដឹងកាលគួរ ក្នុងពាក្យនោះ ទើបព្យាករប្រស្នានោះ ។ ម្នាលចុន្ទ បើពាក្យជាអនាគត ។បេ។ ម្នាលចុន្ទ បើពាក្យជាបច្ចុប្បន្ន មិនពិតមិនមែន មិនប្រកបដោយប្រ-យោជន៍ តថាគតរមែងមិនព្យាករពាក្យនោះទេ ។ ម្នាលចុន្ទ បើពាក្យជាបច្ចុ-ប្បន្ន ដែលពិតមែន ( តែ ) មិនប្រកបដោយប្រយោជន៍ តថាគតរមែងមិនព្យាករពាក្យនោះទេ ។ ម្នាលចុន្ទ តែបើពាក្យជាបច្ចុប្បន្នដែលពិតមែន ប្រកប

ដោយប្រយោជន៍ តថាគតជាអ្នកដឹងកាលគួរ ក្នុងពាក្យនោះ ទើបព្យាករនូវប្រស្នានោះ ។ ម្នាលចុន្ទ តថាគត តែងនិយាយក្នុងកាលគួរ និយាយតែពាក្យសច្ចៈ និយាយតែពាក្យពិត និយាយតែពាក្យជាប្រយោជន៍ និយាយតែពាក្យជាធម៌ និយាយតែពាក្យជាវិន័យក្នុងធម៌ទាំងឡាយដែលជាអតីត អនាគត និងបច្ចុប្បន្ន ព្រោះហេតុនោះ បានជាហៅថា ព្រះតថាគត ដោយប្រការដូច្នេះឯង ។

[ ១២០ ] ម្នាលចុន្ទ របស់ណាដែលលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ទាំងពពួកសត្វ ព្រមទាំងសមណៈ និងព្រាហ្មណ៍ និងមនុស្សដែលជាសម្មតិទេពបានឃើញហើយ បានឮហើយ បានលិទ្ធភក្សហើយ បានដឹងច្បាស់ហើយ បានដល់ហើយ បានស្វែងរកហើយ បានជ្រើសរើសហើយដោយចិត្ត ( របស់នោះ ) តថាគតត្រាស់ដឹងហើយដោយប្រពៃ ហេតុដូច្នោះ បានជាគេហៅថា ព្រះតថាគត ។ ម្នាលចុន្ទ តថាគតត្រាស់ដឹងនូវសម្មាសម្ពោធិដ៏ប្រសើរ ក្នុងវេលាយប់ណាផង បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ក្នុងវេលាយប់ណាផង រមែងសម្តែងហៅ ចង្អុលបង្ហាញនូវហេតុណា ក្នុងចន្លោះនុ៎ះ ហេតុទាំងអស់នោះ សុទ្ធតែពិត មិនមែនត្រឡប់ទៅជាដទៃឡើយ ហេតុដូច្នោះហើយ បានជាគេហៅថា ព្រះតថាគត ។ ម្នាលចុន្ទ តថាគតនិយាយយ៉ាងណា តែងធ្វើយ៉ាងនោះ ធ្វើយ៉ាងណា តែងនិយាយយ៉ាងនោះ ព្រោះតែតថាគតនិយាយយ៉ាងណា តែងធ្វើយ៉ាងនោះ ធ្វើយ៉ាងណា តែងនិយាយយ៉ាងនោះ ហេតុដូច្នោះហើយ បានជាគេហៅថា ព្រះតថាគត ។ តថាគតជាអ្នកលើសលុប មិនមានបុគ្គលដទៃគ្របសង្កត់បាន ជាអ្នកចង្អុល

បង្ហាញនូវហេតុដោយពិត ជាអ្នកផ្សាយនូវអំណាចទៅ ក្នុងលោក ព្រមទាំងទេវលោក ព្រមទាំងមារលោក ព្រមទាំងព្រហ្មលោក ព្រមទាំងសមណព្រាហ្មណ៍ និងពពួកសត្វ ព្រមទាំងមនុស្សជាសម្មតិទេព ព្រោះហេតុនោះ បានជាគេហៅថា ព្រះតថាគត ។

[ ១២១ ] ម្នាលចុន្ទ ហេតុជាទីតាំងរមែងមានយ៉ាងនេះ គឺពួកបរិព្វាជកជាអន្យតិរ្ថិយ និយាយយ៉ាងនេះថា ម្នាលអាវុសោ ខាងមុខអំពីសេចក្តីស្លាប់ទៅ សត្វនឹងកើតទៀតឬហ្ន៎ ការយល់ឃើញនេះឯង ជាសច្ចៈ ពាក្យដទៃជាមោឃៈឬ ។ ម្នាលចុន្ទ ( កាលបើ ) ពួកបរិព្វាជកជាអន្យតិរ្ថិយនិយាយយ៉ាងនេះហើយ អ្នកត្រូវនិយាយយ៉ាងនេះថា ម្នាលអាវុសោ ព្រះមានព្រះភាគមិនដែលសម្តែងថា ខាងមុខអំពីសេចក្តីស្លាប់ទៅសត្វគង់កើតទៀត ការយល់នេះឯង ជាសច្ចៈ ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ ម្នាលចុន្ទ ហេតុជាទីតាំងរមែងមានយ៉ាងនេះ គឺពួកបរិព្វាជកជាអន្យតិរ្ថិយ និយាយយ៉ាងនេះថា ម្នាលចុន្ទ ខាងមុខអំពីសេចក្តីស្លាប់ទៅ សត្វមិនកើតទៀតឬហ្ន៎ ការយល់ឃើញនេះឯង ជាសច្ចៈ ពាក្យដទៃជាមោឃៈឬ ។ ម្នាលចុន្ទ ( កាលបើ ) ពួកបរិព្វាជកជាអន្យតិរ្ថិយដទៃ និយាយយ៉ាងនេះហើយ អ្នកត្រូវនិយាយយ៉ាងនេះថា ម្នាលអាវុសោ ពាក្យនុ៎ះឯង ព្រះមានព្រះភាគ មិនព្យាករថា ខាងមុខអំពីសេចក្តីស្លាប់ទៅ សត្វមិនកើតទៀត ការយល់ឃើញនេះឯង ជាសច្ចៈ ពាក្យដទៃ ជាមោឃៈ ដូច្នេះទេ ។ ម្នាលចុន្ទ ហេតុជាទីតាំងរមែងមានយ៉ាងនេះ គឺពួកបរិព្វាជកជាអន្យតិរ្ថិយ និយាយយ៉ាងនេះថា ម្នាលអាវុសោ ខាង

មុខអំពីសេចក្ដីស្លាប់ទៅ សត្វកើតទៀតខ្លះ មិនកើតទៀតខ្លះ ការយល់ឃើញនេះឯង ជាសច្ចៈ ពាក្យដទៃជាមោឃៈឬហ្ន៎ ។ ម្នាលចុន្ទ ( កាលបើ ) ពួកបរិព្វាជកជាអន្យតិ្ថិយ និយាយយ៉ាងនេះហើយ អ្នកត្រូវនិយាយយ៉ាងនេះថា ម្នាលអាវុសោ ពាក្យនុ៎ះឯង ព្រះមានព្រះភាគមិនព្យាករថា ខាងមុខអំពីសេចក្ដីស្លាប់ទៅ សត្វកើតទៀតខ្លះ មិនកើតទៀតខ្លះ ការយល់ឃើញនេះឯង ជាសច្ចៈ ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។ ម្នាលចុន្ទ ហេតុជាទីតាំងរមែងមានយ៉ាងនេះ គឺពួកបរិព្វាជកជាអន្យតិ្ថិយនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខាងមុខអំពីសេចក្ដីស្លាប់ទៅ សត្វកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ការយល់ឃើញនេះឯង ជាសច្ចៈ ពាក្យដទៃ ជាមោឃៈឬហ្ន៎ ។ ម្នាលចុន្ទ ( កាលបើ ) ពួកបរិព្វាជកជាអន្យតិ្ថិយ និយាយយ៉ាងនេះហើយ អ្នកត្រូវនិយាយយ៉ាងនេះថា ម្នាលអាវុសោ ពាក្យនុ៎ះឯង ព្រះមានព្រះភាគ មិនព្យាករថា ខាងមុខអំពីសេចក្ដីស្លាប់ទៅ សត្វកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ការយល់ឃើញនេះឯង ជាសច្ចៈ ពាក្យដទៃជាមោឃៈ ដូច្នេះទេ ។

[ ១២២ ] ម្នាលចុន្ទ ហេតុជាទីតាំងរមែងមានយ៉ាងនេះ គឺពួកបរិព្វាជកជាអន្យតិ្ថិយ និយាយយ៉ាងនេះថា ម្នាលអាវុសោ ហេតុអ្វីបានជាព្រះសមណគោតម មិនព្យាករពាក្យនុ៎ះ ។ ម្នាលចុន្ទ ( កាលបើ ) ពួកបរិព្វាជក ជាអន្យតិ្ថិយ និយាយយ៉ាងនេះហើយ អ្នកត្រូវនិយាយយ៉ាងនេះថា ម្នាលអាវុសោ ព្រោះថា ពាក្យនុ៎ះ មិនប្រកបដោយប្រយោជន៍ មិនប្រកបដោយធម៌ មិនមែន

ជាដើមចមនៃសាសនព្រហ្មចារ្យ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាសចាករាគៈ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីរម្ងាត់ទុក្ខ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីដឹងក្រៃលែង មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីត្រាស់ដឹង មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន ព្រោះហេតុនោះហើយ បានជាព្រះមានព្រះភាគ មិនព្យាករពាក្យនោះឡើយ ។ ម្នាលចុន្ទ ហេតុជាទីតាំងរមែងមានយ៉ាងនេះ គឺពួកបរិព្វាជកជាអន្យតិ្ថិយ និយាយយ៉ាងនេះថា ម្នាលអាវុសោ ចុះព្រះសមណគោតម ព្យាករដូចម្តេចទៅវិញ ។ ម្នាលចុន្ទ ( កាលបើ ) ពួកបរិព្វាជកជាអន្យតិ្ថិយ និយាយយ៉ាងនេះហើយ អ្នកត្រូវនិយាយយ៉ាងនេះថា ម្នាលអាវុសោ ព្រះមានព្រះភាគព្យាករថា នេះជាទុក្ខដូច្នេះ ម្នាលអាវុសោ ព្រះមានព្រះភាគព្យាករថា នេះជាទុក្ខសមុទយដូច្នេះ ម្នាលអាវុសោ ព្រះមានព្រះភាគព្យាករថា នេះជាទុក្ខនិរោធដូច្នេះ ម្នាលអាវុសោ ព្រះមានព្រះភាគព្យាករថា នេះជាទុក្ខនិរោធគាមិនីបដិបទាដូច្នេះ ។ ម្នាលចុន្ទ ហេតុជាទីតាំងរមែងមានយ៉ាងនេះ គឺពួកបរិព្វាជកជាអន្យតិ្ថិយ និយាយយ៉ាងនេះថា ម្នាលអាវុសោ ព្រោះហេតុអ្វី បានជាព្រះសមណគោតម ព្យាករពាក្យនុ៎ះ ។ ម្នាលចុន្ទ ( កាលបើ ) ពួកបរិព្វាជកជាអន្យតិ្ថិយ និយាយយ៉ាងនេះហើយ អ្នកត្រូវនិយាយយ៉ាងនេះថា ម្នាលអាវុសោ ព្រោះថា ពាក្យនុ៎ះជាពាក្យប្រកបដោយប្រយោជន៍ ប្រកបដោយធម៌ ពាក្យនុ៎ះជាដើមចមនៃសាសនព្រហ្មចារ្យ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយ ប្រព្រឹត្តទៅ ដើម្បីប្រាសចាករាគៈ ប្រព្រឹត្តទៅ

ដើម្បីសេចក្ដីរម្ងាប់ទុក្ខ ប្រព្រឹត្តទៅ ដើម្បីសេចក្ដីស្ងប់រម្ងាប់ ប្រព្រឹត្តទៅ ដើម្បីសេចក្ដីដឹងក្រៃលែង ប្រព្រឹត្តទៅ ដើម្បីសេចក្ដីត្រាស់ដឹង ប្រព្រឹត្តទៅ ដើម្បីព្រះនិព្វានដោយពិត ព្រោះហេតុនោះ បានជាព្រះមានព្រះភាគ ទ្រង់ព្យាករពាក្យនោះ ។

[ ១២៣ ] ម្នាលចុន្ទ ទិដ្ឋិនិស្ស័យទាំងឡាយណា ដែលប្រព្រឹត្តទៅក្នុងចំណែកខាងដើម តថាគតក៏បានសម្ដែង ទិដ្ឋិនិស្ស័យទាំងឡាយនោះដល់អ្នកហើយ តថាគតត្រូវសម្ដែងទិដ្ឋិនិស្ស័យទាំងនោះ យ៉ាងណា មួយវិញទៀត តថាគតមិនត្រូវសម្ដែងទិដ្ឋិនិស្ស័យទាំងនោះ យ៉ាងណា តថាគតនឹងសម្ដែងទិដ្ឋិនិស្ស័យទាំងនោះ ដើម្បីអ្នក ចំពោះពួកអន្យតិរ្ថិយដទៃ ក្នុងហេតុនោះដូចម្ដេចកើត ។ ម្នាលចុន្ទ ទិដ្ឋិនិស្ស័យទាំងឡាយណា ដែលប្រព្រឹត្តទៅក្នុងខាងមុខ តថាគតក៏បានសម្ដែងទិដ្ឋិនិស្ស័យទាំងនោះ ដល់អ្នកហើយ តថាគតត្រូវសម្ដែងទិដ្ឋិនិស្ស័យទាំងនោះ យ៉ាងណា មួយវិញទៀត តថាគតមិនត្រូវសម្ដែងទិដ្ឋិនិស្ស័យទាំងនោះ យ៉ាងណា តថាគតនឹងមិនសម្ដែងទិដ្ឋិនិស្ស័យទាំងនោះ ដើម្បីអ្នក ក្នុងហេតុនោះទេឬ ។ ម្នាលចុន្ទ ទិដ្ឋិនិស្ស័យទាំងឡាយណា ដែលប្រព្រឹត្តទៅក្នុងចំណែកខាងដើម តថាគតសម្ដែងទិដ្ឋិនិស្ស័យទាំងឡាយនោះហើយ តថាគតត្រូវសម្ដែងទិដ្ឋិនិស្ស័យទាំងនោះយ៉ាងណា មួយវិញទៀត មិនត្រូវសម្ដែងទិដ្ឋិនិស្ស័យទាំងនោះយ៉ាងណា ទិដ្ឋិនិស្ស័យទាំងនោះតើដូចម្ដេច ។ ម្នាលចុន្ទ មានសមណៈ និងព្រាហ្មណ៍មួយពួក ធ្លាប់និយាយយ៉ាងនេះ ធ្លាប់យល់ឃើញយ៉ាងនេះថា ខ្លួន និងលោកជាសភាវៈទៀង ការយល់ឃើញនេះ

ឯងជាសច្ចៈ ពាក្យដទៃជាមោឃៈ ។ ម្នាលចុន្ទ មួយទៀត រមែងមាន សមណៈ និងព្រាហ្មណ៍មួយពួក ធ្លាប់និយាយយ៉ាងនេះ ធ្លាប់យល់ឃើញ យ៉ាងនេះថា ខ្លួន និងលោកជាសភាវៈមិនទៀង ។ សេចក្តីសង្ខេប ។ ខ្លួន និងលោកជាសភាវៈទៀងក៏មាន មិនទៀងក៏មាន ។ ខ្លួន និងលោកជាសភាវៈ ទៀងក៏មិនមែន មិនទៀងក៏មិនមែន ។ ខ្លួន និងលោក គឺខ្លួនឯងធ្វើ ។ ខ្លួន និងលោក គឺអ្នកដទៃធ្វើ ។ ខ្លួន និងលោក គឺខ្លួនឯងធ្វើក៏មាន អ្នកដទៃធ្វើក៏ មាន ។ ខ្លួន និងលោក គឺខ្លួនឯងធ្វើក៏មិនមែន អ្នកដទៃធ្វើក៏មិនមែន គឺកើត ឡើងដោយឥតហេតុ ការយល់ឃើញនេះឯងជាសច្ចៈ ពាក្យដទៃជាមោឃៈ ។ សុខ និងទុក្ខជាធម្មជាតិទៀង ។ សុខ និងទុក្ខជាធម្មជាតិមិនទៀង ។ សុខ និងទុក្ខជាធម្មជាតិទៀងខ្លះ មិនទៀងខ្លះ ។ សុខ និងទុក្ខជាធម្មជាតិទៀងក៏មិន មែន មិនទៀងក៏មិនមែន ។ សុខ និងទុក្ខខ្លួនឯងធ្វើ ។ សុខ និងទុក្ខអ្នក ដទៃធ្វើ ។ សុខ និងទុក្ខខ្លួនឯងធ្វើខ្លះ អ្នកដទៃធ្វើខ្លះ។ សុខ និងទុក្ខមិនមែន ខ្លួនឯងធ្វើ មិនមែនអ្នកដទៃធ្វើ គឺកើតឡើងដោយឥតហេតុ ការយល់ឃើញ នេះឯងជាសច្ចៈ ពាក្យដទៃជាមោឃៈ ។

[ ១២៤ ] ម្នាលចុន្ទ បណ្តាពួកសមណៈ និងព្រាហ្មណ៍ទាំងនោះ ពួក សមណៈ និងព្រាហ្មណ៍ណាធ្លាប់និយាយយ៉ាងនេះ ធ្លាប់យល់ឃើញយ៉ាងនេះ ថា ខ្លួន និងលោកជាសភាវៈទៀង ការយល់ឃើញនេះឯងជាសច្ចៈ ពាក្យដទៃ ជាមោឃៈដូច្នេះ តថាគតក៏ចូលទៅរកពួកសមណៈ និងព្រាហ្មណ៍ទាំងនោះ ហើយសួរយ៉ាងនេះថា ម្នាលអាវុសោ ការយល់ឃើញថា ខ្លួន និងលោកជា

សកាវៈទៀងនេះ អ្នកនិយាយមែនឬ ។ ពួកសមណៈ និងព្រាហ្មណ៍ទាំងនោះ បាននិយាយនូវពាក្យណាយ៉ាងនេះថា ការយល់ឃើញនេះឯងជាសច្ចៈ ពាក្យដទៃជាមោឃៈ ។ តថាគតក៏មិនយល់តាមពាក្យនោះ របស់ពួកសមណៈ និងព្រាហ្មណ៍នោះទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលចុន្ទ ព្រោះថាគង់មានសត្វពួក ១ មានសេចក្តីសម្គាល់ដោយឡែកក្នុងដំណើរនេះដែរ ។ ម្នាលចុន្ទ តថាគតពិចារណាមិនឃើញបុគ្គលស្មើដោយញាណ ដ៏ស្មើរបស់តថាគតដោយបញ្ញត្តិនេះសោះ មានពីណាក្រៃលែងជាង មានតែតថាគតហ្នឹងឯងក្រៃលែង ( ជាងគេ ) ក្នុងអធិប្បញ្ញត្តិទាំងនោះ ។

[ ១២៥ ] ម្នាលចុន្ទ បណ្តាពួកសមណៈ និងព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ធ្លាប់និយាយយ៉ាងនេះ ធ្លាប់យល់ឃើញយ៉ាងនេះថា ខ្លួន និងលោកជាសកាវៈមិនទៀង ។ សេចក្តីសង្ខេប ។ ខ្លួន និងលោកជាសកាវៈទៀងខ្លះ មិនទៀងខ្លះ ។ ខ្លួន និងលោកជាសកាវៈទៀងក៏មិនមែន មិនទៀងក៏មិនមែន ។ ខ្លួន និងលោក ខ្លួនឯងធ្វើ ។ ខ្លួន និងលោកអ្នកដទៃធ្វើ ។ ខ្លួន និងលោកខ្លួនឯងធ្វើក៏មាន អ្នកដទៃធ្វើក៏មាន ។ ខ្លួននិងលោកខ្លួនឯងតាក់តែងក៏មិនមែន អ្នកដទៃតាក់តែងក៏មិនមែន កើតឡើងដោយឥតហេតុ ។ សុខ និងទុក្ខជាធម្មជាតិទៀង ។ សុខ និងទុក្ខជាធម្មជាតិមិនទៀង ។ សុខ និងទុកជាធម្មជាតិទៀងខ្លះ មិនទៀងខ្លះ ។ សុខ និងទុក្ខជាធម្មជាតិទៀងក៏មិនមែន មិនទៀងក៏មិនមែន ។ សុខ និងទុក្ខខ្លួនឯងតាក់តែង ។ សុខ និងទុក្ខអ្នកដទៃតាក់តែង ។ សុខ និងទុក្ខខ្លួនឯងតាក់តែងក៏មាន អ្នកដទៃតាក់តែង

ក៏មាន ។ សុខ និងទុក្ខខ្លួនឯងធ្វើ តាក់តែងក៏មិនមែន អ្នកដទៃតាក់តែងក៏មិនមែន កើតឡើងដោយឥតហេតុ ។ ការយល់ឃើញនេះឯងជាសច្ចៈ ពាក្យដទៃជាមោឃៈដូច្នេះ ។ តថាគតក៏ចូលទៅរកពួកបរិព្វាជកទាំងនោះ ហើយសួរយ៉ាងនេះថា ម្នាលអាវុសោ ការយល់ឃើញថា សុខ និងទុក្ខមិនមែនខ្លួនឯងធ្វើ មិនមែនបុគ្គលដទៃធ្វើ កើតឡើងដោយឥតហេតុ នេះអ្នកនិយាយមែនឬ ។ ពួកសមណៈ និងព្រាហ្មណ៍ទាំងនោះ និយាយនូវពាក្យណាយ៉ាងនេះថា ការយល់ឃើញនេះឯងជាសច្ចៈ ពាក្យដទៃ ជាមោឃៈ ។ តថាគតក៏មិនយល់តាមពាក្យនោះ របស់សមណព្រាហ្មណ៍ទាំងនោះទេ ។ ដំណើរនុ៎ះព្រោះហេតុអ្វី ។ ម្នាលចុន្ទ ព្រោះថា គង់មានសត្វពួកខ្លះ មានសេចក្តីសម្គាល់ដោយឡែកក្នុងរឿងនេះដែរ ។ ម្នាលចុន្ទ តថាគតពិចារណាមិនឃើញនូវបុគ្គលស្មើដោយញាណដ៏ស្មើរបស់តថាគតក្នុងបញ្ញត្តិនេះ មានពីណាក្រៃលែងជាង មានតែតថាគតហ្នឹងឯងក្រៃលែងជាគេ ក្នុងអធិប្បញ្ញត្តិនោះ ។ ម្នាលចុន្ទ ទិដ្ឋិនិស្ស័យទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងចំណែកខាងដើមនេះឯង តថាគតបានសម្តែងដល់អ្នកហើយ តថាគតត្រូវសម្តែងទិដ្ឋិនិស្ស័យទាំងឡាយនោះយ៉ាងណា មួយវិញទៀត តថាគតមិនត្រូវសម្តែងទិដ្ឋិនិស្ស័យទាំងនោះ យ៉ាងណា តថាគត នឹងសម្តែងទិដ្ឋិនិស្ស័យទាំងនោះ ដើម្បីអ្នកក្នុងហេតុទាំងនោះដូចម្តេចកើត ។

[ ១២៦ ] ម្នាលចុន្ទ ទិដ្ឋិនិស្ស័យទាំងឡាយណា ដែលប្រព្រឹត្តទៅក្នុងខាងមុខ តថាគតបានសម្តែងទិដ្ឋិនិស្ស័យទាំងនោះហើយ តថាគតត្រូវសម្តែង

ទិដ្ឋិនិស្ស័យទាំងនោះ យ៉ាងណា តថាគតមិនត្រូវសម្តែងទិដ្ឋិនិស្ស័យទាំងនោះ យ៉ាងណា ឯទិដ្ឋិនិស្ស័យទាំងនោះតើដូចម្តេច តថាគតនឹងសម្តែងទិដ្ឋិនិស្ស័យ ទាំងនោះ ដើម្បីអ្នកក្នុងហេតុនោះដូចម្តេចកើត ។ ម្នាលចុន្ទ មានសមណ-ព្រាហ្មណ៍ ១ ពួកនេះ ធ្លាប់និយាយយ៉ាងនេះ ធ្លាប់យល់ឃើញយ៉ាងនេះថា ខាងមុខអំពីសេចក្តីស្លាប់ទៅ ខ្លួនមានរូបមិនមានរោគ ការយល់ឃើញនេះឯង ជាសច្ចៈ ពាក្យដទៃជាមោឃៈដូច្នេះ ។ ម្នាលចុន្ទ មានសមណព្រាហ្មណ៍ ១ ពួកធ្លាប់និយាយយ៉ាងនេះ ធ្លាប់យល់ឃើញយ៉ាងនេះថា ខ្លួនមិនមានរូប ។ ខ្លួនមានរូបក៏មាន ឥតមានរូបក៏មាន ។ ខ្លួនមានរូបក៏មិនមែន ឥតរូបក៏មិនមែន ។ ខ្លួនមានសញ្ញា ។ ខ្លួនមិនមានសញ្ញា ។ ខ្លួនមានសញ្ញាក៏មាន ឥតសញ្ញាក៏មាន ។ ខ្លួនមានសញ្ញាក៏មិនមែន ឥតសញ្ញាក៏មិនមែន ។ ខាងមុខអំពីសេចក្តីស្លាប់ទៅ ខ្លួនរមែងដាច់សូន្យទៅ វិនាសទៅ មិនកើតទៀត ការយល់ឃើញនេះឯងជាសច្ចៈ ពាក្យដទៃជាមោឃៈដូច្នេះ ។ ម្នាលចុន្ទ បណ្តាសមណ-ព្រាហ្មណ៍ទាំងឡាយនោះ សមណព្រាហ្មណ៍ទាំងឡាយណា ធ្លាប់និយាយយ៉ាងនេះ ធ្លាប់យល់ឃើញយ៉ាងនេះថា ខាងមុខអំពីសេចក្តីស្លាប់ ខ្លួននៅមានរូប មិនមានរោគ ការយល់នេះឯងជាសច្ចៈ ពាក្យដទៃជាមោឃៈ ដូច្នេះ តថាគតក៏ចូលទៅរកពួកសមណព្រាហ្មណ៍ទាំងនោះ ហើយនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខាងមុខអំពីសេចក្តីស្លាប់ ខ្លួននៅមានរូប មិនមានរោគនេះ អ្នកនិយាយមែនឬ ។ មួយទៀត ពួកសមណព្រាហ្មណ៍ទាំងនោះ បាននិយាយពាក្យណាយ៉ាងនេះថា ការយល់ឃើញនេះឯងជាសច្ចៈ ពាក្យដទៃជាមោឃៈ ។

តថាគតមិនយល់តាមពាក្យនោះ របស់សមណព្រាហ្មណ៍ទាំងឡាយនោះទេ ។ ដំណើរនុ៎ះព្រោះហេតុអ្វី ។ ម្នាលចុន្ទ ព្រោះថា គង់មានសត្វពួកខ្លះ មានសេចក្តីសម្គាល់ដោយឡែក ក្នុងដំណើរនេះដែរ ។ ម្នាលចុន្ទ តថាគតពិចារណាមិនឃើញបុគ្គលស្មើដោយញាណ ដ៏ស្មើរបស់តថាគតក្នុងបញ្ញត្តិនេះទេ មានពីណាក្រៃលែងជាង មានតែតថាគតហ្នឹងឯងក្រៃលែង ( ជាងគេ ) ក្នុងអធិប្បញ្ញត្តិនោះ ។

[ ១២៧ ] ម្នាលចុន្ទ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ធ្លាប់និយាយយ៉ាងនេះ ធ្លាប់យល់យ៉ាងនេះថា ខ្លួនមិនមានរូប ។ ខ្លួនមានរូបក៏មាន ឥតរូបក៏មាន ។ ខ្លួនមានរូបក៏មិនមែន ឥតរូបក៏មិនមែន ។ ខ្លួនមានសញ្ញា ។ ខ្លួនឥតសញ្ញា ។ ខ្លួនមានសញ្ញាក៏មាន ឥតសញ្ញាក៏មាន ។ ខ្លួនមានសញ្ញាក៏មិនមែន ឥតសញ្ញាក៏មិនមែន ។ ខាងមុខអំពីសេចក្តីស្លាប់ ខ្លួនរមែងដាច់សូន្យទៅ វិនាសទៅ មិនកើតទៀត ការយល់ឃើញនេះឯងជាសច្ចៈ ពាក្យដទៃជាមោឃៈ ដូច្នេះ តថាគតក៏ចូលទៅរកពួកសមណព្រាហ្មណ៍ទាំងនោះ ហើយនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខាងមុខអំពីសេចក្តីស្លាប់ ខ្លួនរមែងដាច់សូន្យទៅ វិនាសទៅ មិនកើតទៀតនេះ អ្នកនិយាយមែនឬ ។ ម្នាលចុន្ទ ពួកសមណព្រាហ្មណ៍ទាំងនោះ និយាយនូវពាក្យណាយ៉ាងនេះថា ការយល់ឃើញនេះឯងជាសច្ចៈ ពាក្យដទៃជាមោឃៈ ដូច្នេះ ។ តថាគតមិនយល់តាមពាក្យរបស់ពួកគេនោះទេ ។ ដំណើរនុ៎ះព្រោះហេតុអ្វី ។ ម្នាលចុន្ទ ព្រោះថា មានសត្វ ១ ពួក តែងមានសេចក្តីសម្គាល់

ដោយឡែកក្នុងជំណើរនេះ ។ ម្នាលចុន្ទ តថាគតពិចារណាមិនឃើញ បុគ្គល ស្មើដោយញាណដ៏ស្មើរបស់តថាគត ក្នុងបញ្ញត្តិនេះសោះ មានពីណាក្រៃលែង ជាង មានតែតថាគតហ្នឹងឯង ក្រៃលែង ( ជាងគេ ) ក្នុងអធិប្បញ្ញត្តិនោះ ។ ម្នាលចុន្ទ ទិដ្ឋិនិស្ស័យទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងខាងមុខនេះឯង តថាគត បានសម្តែងដល់អ្នកហើយ តថាគតត្រូវសម្តែងទិដ្ឋិនិស្ស័យទាំងនោះ យ៉ាងណា មួយវិញទៀត មិនត្រូវសម្តែងទិដ្ឋិនិស្ស័យទាំងនោះ យ៉ាងណា តថាគតនឹង សម្តែងនូវទិដ្ឋិនិស្ស័យទាំងនោះ ដើម្បីអ្នកក្នុងហេតុទាំងនោះ ដូចម្តេចកើត ។

[ ១២៨ ] ម្នាលចុន្ទ សតិប្បដ្ឋានទាំង ៤ ដែលតថាគតសម្តែងហើយ បញ្ញត្តហើយយ៉ាងនេះ ដើម្បីលះបង់ ដើម្បីឈានកន្លងនូវពួកទិដ្ឋិនិស្ស័យ ដែលប្រព្រឹត្តទៅក្នុងចំណែកខាងដើមនេះផង នូវពួកទិដ្ឋិនិស្ស័យដែលប្រព្រឹត្ត ទៅក្នុងចំណែកខាងមុខនេះផង ។ សតិប្បដ្ឋានទាំង ៤ ដូចម្តេច ។ ម្នាលចុន្ទ ភិក្ខុក្នុងធម្មវិន័យនេះ រមែងមានកិរិយាពិចារណារឿយៗ នូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី គប្បីកម្ចាត់ បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ។ ក្នុងវេទនាទាំងឡាយ ។ ក្នុងចិត្ត ។ ភិក្ខុមានកិរិយាពិចារណារឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាម ជា គ្រឿងដុតនូវកិលេស ជាអ្នកដឹងខ្លួន មានស្មារតី គប្បីកម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ម្នាលចុន្ទ សតិប្បដ្ឋានទាំង ៤ នេះ ដែលតថាគត សម្តែងហើយ បញ្ញត្តហើយយ៉ាងនេះ ដើម្បីលះបង់ ដើម្បីឈានកន្លងនូវពួក ទិដ្ឋិនិស្ស័យដែលប្រព្រឹត្តទៅ ក្នុងចំណែកខាងដើមនេះផង នូវពួកទិដ្ឋិនិស្ស័យ

ដែលប្រព្រឹត្តទៅ ក្នុងចំណែកខាងមុខនេះផង ។

[ ១២៩ ] សម័យនោះឯង ព្រះឧបវាណមានអាយុ ឈរបក់ព្រះមានព្រះភាគ អំពីខាងក្រោយនៃព្រះមានព្រះភាគ លំដាប់នោះ ព្រះឧបវាណមានអាយុ បានក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះអស្ចារ្យណាស់ មិនគួរកើតបានសោះ បពិត្រព្រះអង្គដ៏ចម្រើន ធម្មបរិយាយនេះ គួរជាទីជ្រះថ្លាហ្ន៎ បពិត្រព្រះអង្គដ៏ចម្រើន ធម្មបរិយាយនេះ គួរជាទីជ្រះថ្លាហ្ន៎ បពិត្រព្រះអង្គដ៏ចម្រើន ធម្មបរិយាយនេះ ឈ្មោះអ្វី ។ ព្រះអង្គត្រាស់ថា ម្នាលឧបវាណ ហេតុដូច្នោះ អ្នកចូរចាំទុកនូវធម្មបរិយាយនេះថា ជាបាសាទិកៈ ដូច្នេះចុះ ។ លុះព្រះមានព្រះភាគ បានសម្តែងសូត្រនេះ ( ចប់ ) ហើយ ។ ឧបវាណមានអាយុ ក៏មានចិត្តត្រេកអរ រីករាយចំពោះភាសិតរបស់ព្រះមានព្រះភាគ ដោយប្រការដូច្នេះឯង ។

បាសាទិកសូត្រទី ៦ ចប់

# អដ្ឋកថា

## បាសាទិកសូត្រ

[ ៩៤ ] បាសាទិកសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** នឹងអធិប្បាយនូវបទដែលលំបាកក្នុងបាសាទិកសូត្រនោះ ។ បទថា **វេធញ្ញា នាម សក្យា** នោះ សំដៅដល់ពួកសក្យៈមួយពួក ឈ្មោះវេធញ្ញា ដែលជាអ្នកសិក្សាការហាត់បាញ់ធ្នូ ។ បទថា **តេសំ អម្ពវនេ បាសាទេ** អធិប្បាយថា មានប្រាសាទវែង ដែលសាងដើម្បីរៀនសិល្បៈ នាអម្ពវ័នរបស់ពួកសក្យៈទាំងនោះ ព្រះភគវាប្រថាប់នៅក្នុងឧទ្យានវ័ននោះ ។ បទថា **អធុនា កាលកតោ** បានដល់និគណ្ឋនាដបុត្រធ្វើកាលកិរិយាថ្មីៗ ។ បទថា **ទ្វេធិកជាតា** គឺបែកគ្នាជាពីរចំណែក ។ ក្នុងបណ្ដាការទាស់ទែងជាដើម ការឈ្លោះគ្នាក្នុងពេលដំបូង ហៅថា **ភណ្ឌន** ការទាស់ទែងនោះបានចម្រើនឡើង ដោយអំណាចការកាន់ដំបងជាដើម និងដោយអំណាចការកន្ទងបញ្ញត្តិ ឈ្មោះថា **កលហ** ពាក្យទម្លាយគ្នាដោយន័យជាដើមថា លោកមិនដឹងទូទៅដល់ធម្មវិន័យនេះ ឈ្មោះថា **វិវាទ**។ បទថា **វិតុទន្តា** ចាក់ដោយលំពែង គឺមាត់ ។ បទថា **សហិតំ មេ** គឺពាក្យរបស់ខ្ញុំប្រកបដោយអត្ថ ។ បទថា **អធិចិណ្ណន្តេ វិបរាវត្តំ** អធិប្បាយថា វត្ថុណា ដែលលោកសន្សំមកហើយ គឺជំនាញហើយ ដោយអំណាចសេពមកអស់កាលជាយូរ វត្ថុនោះ បានប្រែប្រួលទៅហើយ ព្រោះអាស្រ័យវាទៈរបស់ខ្ញុំ ។ បទថា **អារោបិតោ តេ វាទោ** គឺខ្ញុំបានដាក់កំហុសលើលោក ។ បទថា **ចរវាទប្បមោក្ខាយ** អធិប្បាយថា លោកចូរកាន់កញ្ចប់បាយ ចូលទៅកាន់ប្រជុំ

ជននោះហើយៗ នៅស្វែងរកឲ្យក្រៃលែងឡើងៗ ដើម្បីឲ្យផុតវាទៈ ។ បទថា **និព្ពេឋេហិ វា** អធិប្បាយថា ម្យ៉ាងទៀត លោកចូរដោះខ្លួនពីទោសដែលយើងលើកឡើង ។ បទថា **សចេ បហោសិ** ប្រែថា បើអ្នកអាច ។ បទថា **វធោយេវ** គឺស្លាប់ទុ៎ះឯង ។ បទថា **នាដបុត្តិយេសុ** គឺអន្តេវាសិករបស់នាដបុត្រ ។ បទថា **និព្វិន្នរូបា** គឺសាវករបស់និគណ្ឋនាដបុត្រ មានការធុញទ្រាន់ជាសភាវៈ រមែងមិនធ្វើសូម្បីការអភិវាទជាដើម ។ បទថា **វិរត្តរូបា** គឺប្រាសចាកសេចក្តីស្រឡាញ់ ។ បទថា **បដិវានរូបា** គឺមានសេចក្តីរាថយចាកការធ្វើសេចក្តីគោរពនៃពួកសាវក របស់និគណ្ឋនាដបុត្រ ។ បទថា **យថា តំ** អធិប្បាយថា បានកើតឡើង ដោយហេតុដែលសាវកទាំងនោះ គប្បីជាអ្នកមានសេចក្តីធុញទ្រាន់ ប្រាសចាកសេចក្តីស្រឡាញ់ រួញរាក្នុងធម្មវិន័យ ដែលនិគណ្ឋនាដបុត្រពោលមិនល្អជាដើម ។ បទថា **ទុរក្ខាតេ** គឺពោលមិនល្អ ។ បទថា **ទុប្បវេទិតេ** គឺទូន្មានមិនល្អ ។ បទថា **អនុបសមសំវត្តនិកេ** គឺមិនអាចនឹងធ្វើរាគៈជាដើមឲ្យស្ងប់បាន ។ បទថា **ភិន្នថូបេ** គឺមានទីពំនាក់ ដែលបែកធ្លាយហើយ ។ ក្នុងបទនេះ និគណ្ឋនាដបុត្រ ឈ្មោះថា ជាទីពំនាក់ ព្រោះអត្ថថា ជាទីពឹងរបស់សាវកទាំងនោះ ។ តែគេបានបែកធ្លាយ គឺស្លាប់ហើយ ។ ព្រោះដូច្នោះ ទើបលោកពោលថា ជាធម្មវិន័យមានទីពំនាក់ ដែលទម្លាយចេញហើយ ។ បទថា **អប្បដិសរណោ** គឺខ្វះទីពឹងអាស្រ័យ ព្រោះមិនមាននិគណ្ឋនាដបុត្រនោះឯង ។

នាដបុត្រនេះ អាស្រ័យនៅក្នុងក្រុងនាលន្ទាមិនមែនឬ ហេតុអ្វី ទើបគាត់ស្លាប់នៅក្រុងបាវា ។ បានឮថា នាដបុត្រនោះ ស្តាប់ពុទ្ធគុណ ដែលឧបាលិគហបតីអ្នកដឹងច្បាស់សច្ចធម៌ ពោលដោយគាថា ១០ គាថា ទើបក្អួតឈាមចេញមកក្តៅៗ គ្រានោះ ទើបសាវ័កទាំងឡាយបាននាំនាដបុត្រ ដែលមិនមានសេចក្តីសប្បាយទៅក្រុងបាវា ទើបគេស្លាប់ក្នុងទីនោះ ម្យ៉ាងទៀត កាលនាដបុត្រទៀបនឹងស្លាប់ ក៏គិតថា លទ្ធិរបស់អញ ជាលទ្ធិដែលមិននាំចេញទៅបាន ជាលទ្ធិដែលមិនមានសារៈ អញវិនាសទៅចុះ កុំឲ្យជនដ៏សេស បានទៅពេញក្នុងអបាយ ប្រសិនបើអញពោលថា ពាក្យទូន្មានរបស់ខ្ញុំ មិនមែនជានិយ្យានិក ជនទាំងឡាយនឹងមិនជឿ បើដូច្នោះ អញមិនគួរឲ្យជនពីរនាក់ កាន់បែបតែមួយ កាលអញស្លាប់ទៅ ជនទាំងនោះនឹងវិវាទគ្នា ព្រះសាស្តានឹងត្រាស់ធម្មកថាមួយបទ អាស្រ័យវិវាទនោះ បន្ទាប់អំពីនោះ ជនទាំងឡាយនឹងដឹងភាពដែលព្រះសាស្តា ជាសាសនា ដែលមានគុណធំ ដូច្នេះ ។ គ្រានោះ អន្តេវាសិកម្នាក់ចូលទៅរកនាដបុត្រនោះ ហើយពោលថា លោកម្ចាស់ លោកទុព្វលភាពហើយ សូមប្រាប់សារៈ ដែលជាអាចរិយៈប្រមាណក្នុងធម៌នេះ ដល់ខ្ញុំខ្លះចុះ ដូច្នេះ ។ នាដបុត្រពោលថា ម្នាលអ្នកមានអាយុ កាលបើយើងស្លាប់ទៅ អ្នកគប្បីកាន់យកថា ទៀង ដូច្នេះ ។ កាលអន្តេវាសិកម្នាក់ទៀតចូលទៅរកនាដបុត្រ ឲ្យអន្តេវាសិកនោះកាន់យកថា សូន្យ ។ នាដបុត្រមិនធ្វើឲ្យជនទាំងពីរនាក់ មានលទ្ធិតែមួយយ៉ាងនេះហើយ ឲ្យជនជាច្រើនកាន់បែបផ្សេងៗ គ្នា លុះស្លាប់ហើយ ជនទាំងឡាយធ្វើឈាបនកិច្ចនាដបុត្រនោះ រួច

ស្រេច ទើបប្រជុំសួរគ្នាថា នែអាវុសោ អាចារ្យប្រាប់ធម៌ដែលជាសារៈឲ្យដល់អ្នកណា ។ សិស្សម្នាក់ក្រោកឡើងពោលថា ដល់ខ្ញុំ ដូច្នេះ ។ ជនទាំងឡាយសួរថា ប្រាប់ដូចម្ដេច ។ សិស្សនោះពោលថា ប្រាប់ថា ទៀង សិស្សម្នាក់ទៀត ជំទាស់ ហើយពោលថា អាចារ្យបានប្រាប់ធម៌ដែលជាសារៈដល់ខ្ញុំដោយអាការយ៉ាងនេះ ជនទាំងអស់គ្នា ក៏វិវាទគ្នាខ្លាំងក្លាឡើងថា អាចារ្យប្រាប់ធម៌ ដែលជាសារៈដល់ខ្ញុំ ខ្ញុំជាធំ ហើយក៏ដល់ការជេរប្រទេចគ្នា និងប្រទូស្តគ្នាដោយដៃ និងជើងជាដើម មិនរួមផ្លូវគ្នាតែមួយ បែកគ្នាទៅផ្លូវម្នាក់មួយ ។

[ ៩៥ ] បទថា **អាយស្មា ចុន្ទោ សមណុទ្ទេសោ** អធិប្បាយថា ព្រះថេរៈរូបនេះ ជាប្អូនរបស់ព្រះធម្មសេនាបតីសារីបុត្រ ភិក្ខុទាំងឡាយ ហៅលោកថា ព្រះចុន្ទសមណុទ្ទេស ក្នុងកាលជាអនុបសម្បន្ន សូម្បីកាលជាថេរៈក៏នៅតែហៅយ៉ាងនោះដូចគ្នា ។ ព្រោះដូច្នោះ ទើបពោលថា ព្រះចុន្ទសមណុទ្ទេស ដូច្នេះ ។ ក្នុងបទទាំងឡាយថា **ចាវាយំ វស្សំ វុត្ថោ យេន សាមគាមោ យេនាយស្មា អានន្ទោ តេនុបសង្កមិ** ដូច្នេះ ព្រោះហេតុអ្វីទើបចូលទៅរក ។ បានឮថា កាលនាដបុត្រស្លាប់ហើយ ពួកមនុស្សក្នុងជម្ពូទ្វីបម្នាក់ៗ នាំគ្នានិយាយតៗ គ្នា ក្នុងទីនោះៗ ថា និគណ្ឋនាដបុត្រប្រកាសជាសាស្ដាម្នាក់ឯង កាលគាត់ស្លាប់ ពួកសាវ័កកើតវិវាទគ្នាដល់បែបនេះ ក៏ព្រះសមណគោតមប្រាកដហើយ ក្នុងជម្ពូទ្វីប ដូចព្រះចន្ទ និងព្រះអាទិត្យ សូម្បីព្រះសាវ័ករបស់ព្រះអង្គ ក៏ប្រាកដហើយដូចគ្នា កាលព្រះសមណគោតម-

បរិនិព្វានហើយ ពួកសាវកនឹងវិវាទគ្នាយ៉ាងណាហ្ន៎ ដូច្នេះ ។ ព្រះថេរៈស្តាប់ពាក្យនោះហើយ គិតថា អញនឹងនាំពាក្យនេះទៅទូលចំពោះព្រះទសពល ព្រះសាស្តានឹងធ្វើពាក្យនោះឲ្យជាអត្ថុប្បត្តិហេតុ ហើយទ្រង់ទេសនា ១ កណ្ឌ ព្រះថេរៈនោះក៏ចេញទៅរកព្រះអានន្ទក្នុងសាមគ្រាម ។ បទថា **សាមគាមោ** ជាឈ្មោះរបស់ស្រុកនោះ ព្រោះមានថ្លៃ និងស្លួយច្រើន ។ បទថា **យេនាយស្មា អានន្ទោ** អធិប្បាយថា ព្រះចុន្ទត្ថេរមិនទៅគាល់ព្រះមានព្រះភាគត្រង់តែម្តង ប៉ុន្តែ ចូលទៅរកព្រះអានន្ទដែលជាឧបជ្ឈាយ៍ ។

បានឮថា ក្នុងសម័យពុទ្ធកាល ព្រះសារីបុត្តត្ថេរ និងព្រះអានន្ទ រាប់អានគ្នាណាស់ ព្រះសារីបុត្តត្ថេររាប់អានព្រះអានន្ទថា ព្រះអានន្ទ ធ្វើឧបដ្ឋាកព្រះសាស្តា ដែលខ្ញុំគួរធ្វើ ព្រះអានន្ទរាប់អានព្រះសារីបុត្រថា ព្រះសារីបុត្រជាកំពូលជាងសាវកទាំងឡាយនៃព្រះមានព្រះភាគ ព្រះអានន្ទឲ្យទារកក្នុងត្រកូលបព្វជ្ជា ហើយឲ្យទទួលការមើលថែរក្នុងសម្នាក់របស់ព្រះសារីបុត្រ សូម្បីព្រះសារីបុត្រ ក៏បានធ្វើយ៉ាងនោះដូចគ្នា មានភិក្ខុប្រមាណ ១០០០ រូប មួយរូបៗបានឲ្យបាត្រ និងចីវររៀងៗ ខ្លួន ហើយឲ្យបព្វជ្ជា ឲ្យទទួលការមើលថែ ។ ព្រះអានន្ទបានបណីតចីវរជាដើម ក៏ប្រគេនព្រះថេរៈ ។ បានឮថា ព្រាហ្មណ៍ម្នាក់គិតថា ការបូជាព្រះពុទ្ធរតនៈ និងព្រះសង្ឃរតនៈ រមែងប្រាកដច្បាស់ ឈ្មោះថា ការបូជាព្រះធម្មរតនៈដូចម្តេចហ្ន៎ ទើបព្រាហ្មណ៍នោះចូលទៅគាល់ព្រះមានព្រះភាគ ទូលសួរសេចក្តីនោះ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលព្រាហ្មណ៍ ប្រសិនបើអ្នកប្រាថ្នានឹងបូជាព្រះធម្មរតនៈ ក៏ចូរបូជាភិក្ខុដែលជា

ពហុស្សុតមួយរូប ដូច្នេះ ។ ព្រាហ្មណ៍ទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គបង្ហាញភិក្ខុដែលជាពហុស្សុតផង ព្រះសាស្តាត្រាស់ថា ចូរអ្នកសួរភិក្ខុសង្ឃចុះ ។ ព្រាហ្មណ៍នោះចូលទៅរកភិក្ខុទាំងឡាយ ហើយពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ប្រាប់ភិក្ខុដែលជាពហុស្សុតឲ្យទាន ភិក្ខុទាំងឡាយពោលថា ម្នាលព្រាហ្មណ៍ ព្រះអានន្ទជាពហុស្សុត ព្រាហ្មណ៍ក៏បូជាព្រះថេរៈដោយត្រៃចីវរមានតម្លៃមួយពាន់ ។ ព្រះថេរៈបាននាំព្រាហ្មណ៍នោះ ទៅគាល់ព្រះសាស្តា ព្រះសាស្តាត្រាស់សួរថា អានន្ទអ្នកបានត្រៃចីវរមកពីណា ព្រះអានន្ទទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រាហ្មណ៍ម្នាក់ប្រគេន តែខ្ញុំព្រះអង្គប្រាថ្នានឹងប្រគេនត្រៃចីវរនេះដល់ព្រះសារីបុត្តត្ថេរ ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទចូរឲ្យចុះ ។ ព្រះអានន្ទទូលថា ព្រះសារីបុត្តត្ថេរចេញចារិក ព្រះសាស្តាត្រាស់ថា អ្នកចូរឲ្យក្នុងវេលាដែលសារីបុត្រត្រឡប់មកចុះ ។ ព្រះអានន្ទទូលថា ព្រះអង្គបានបញ្ញត្តសិក្ខាបទហើយ ព្រះសាស្តាត្រាស់ថា សារីបុត្រត្រឡប់មកពេលណា ព្រះអានន្ទទូលថា ប្រមាណ ១០ ថ្ងៃទៀត ។ ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ តថាគតអនុញ្ញាតឲ្យទុកអតិរេកចីវរបាន ១០ ថ្ងៃ យ៉ាងច្រើន ដោយប្រការដូច្នេះ ។ ព្រះតថាគតបានបញ្ញត្តសិក្ខាបទហើយ ។ សូម្បីព្រះសារីបុត្តត្ថេរបានវត្ថុដែលពេញចិត្តណាមួយ ក៏ប្រគេនវត្ថុនោះ ដល់ព្រះអានន្ទយ៉ាងនោះដូចគ្នា ។ ព្រះសារីបុត្តត្ថេរនោះ បានឲ្យព្រះចុន្ទសមណុទ្ទេសដែលជាប្អូនរបស់ខ្លួន ជាសទ្ធិវិហារិករបស់ព្រះថេរៈ ព្រោះដូច្នោះ ទើបលោកពោលថា ព្រះចុន្ទសមណុទ្ទេសចូលទៅរកព្រះអានន្ទត្ថេរ ដែលជាព្រះឧបជ្ឈាយ៍

ដូច្នេះ ។ បានឮថា ព្រះចុន្ទសមណុទ្ទេសមានការគិតយ៉ាងនេះថា ព្រះឧបជ្ឈាយ៍របស់អញមានបញ្ញាច្រើន លោកនឹងក្រាបទូលពាក្យនេះ ចំពោះព្រះសាស្តាពេលនោះ ព្រះសាស្តា នឹងសម្តែងធម៌អនុរូបដល់កថានោះ ដូច្នេះ ។ បទថា **កថាបាភតំ** ប្រែថា មូលនៃពាក្យ ។ ពិតហើយ ពាក្យថា មូល លោកថា **បាភតំ** ( ដើមហេតុ ) សមដូចព្រះមានព្រះភាគត្រាស់ថា

**អប្បកេនបិ មេធាវី បាភតេន វិចក្ខណោ**
**សមុដ្ឋាបេតិ អត្តានំ អណុំ អគ្គឹវ សន្ធមំ ។**

អ្នកប្រាជ្ញឈ្លាសវៃ រមែងតាំងខ្លួនបាន ដោយទ្រព្យជាដើមទុន សូម្បីមានប្រមាណតិច ដូចបុគ្គលបង្កាត់ភ្លើងដ៏តូច ។

បទថា **ភគវន្តំ ទស្សនាយ** ប្រែថា ដើម្បីឃើញព្រះមានព្រះភាគ ។ មានពាក្យសួរថា ព្រះអានន្ទត្ថេរនោះ មិនធ្លាប់ឃើញព្រះមានព្រះភាគឬ ។ ឆ្លើយថា មិនមែនមិនធ្លាប់ឃើញទេ ។ ព្រោះព្រះអានន្ទត្ថេរនេះ ទៅគាល់ព្រះមានព្រះភាគ មួយថ្ងៃ ១៨ ដង គឺពេលថ្ងៃ ៩ ដង ពេលយប់ ៩ ដង សូម្បីប្រាថ្នានឹងទៅ ១០០ ដង ១០០០ ដង ចំពោះថ្ងៃក៏មិនទៅ ព្រោះមិនមានហេតុ លោកចាប់លើកបញ្ហាប្រការណាមួយឡើង ហើយទើបទៅគាល់ក្នុងថ្ងៃនោះ ព្រះអានន្ទត្ថេរនោះ ប្រាថ្នានឹងទៅដោយមូលហេតុនៃកថានោះ ទើបពោលហើយយ៉ាងនេះ ។

[ ៩៦ ] បទថា **ឯវញ្ចេតំ ចុន្ទ ហោតិ** សេចក្តីថា ព្រះអានន្ទត្ថេរក្រាបទូលសេចក្តីនោះចំពោះព្រះមានព្រះភាគ ព្រោះព្រះអានន្ទត្ថេរ មិនមែនជាម្ចាស់

នៃកថានេះ តែព្រះចុន្ទត្ថេរជាម្ចាស់នៃកថា មួយទៀត ព្រះចុន្ទត្ថេរនោះ តែងដឹងខាងដើម កណ្តាល ខាងចុងរបស់កថានោះ ដូច្នោះ ព្រះមានព្រះភាគកាលត្រាស់ជាមួយព្រះចុន្ទត្ថេរនោះ ទើបត្រាស់ពាក្យថា **ឯវញ្ចេតំ ចុន្ទ ហោតិ** ដូច្នេះជាដើម ។ អធិប្បាយថា ម្នាលចុន្ទ ការណ៍នេះ រមែងមានយ៉ាងនេះ សាវកក្នុងធម្មវិន័យដែលមានសភាពជាដើមថា ពោលទុកមិនល្អ កើតការបែកគ្នាជាពីរពួក ធ្វើការទាស់ទែងគ្នាជាដើម ចាក់ដោតគ្នាដោយលំពែង គឺមាត់ ព្រោះពាក្យទូន្មានដែលនឹងនាំអ្នកបដិបត្តិឲ្យចេញចាកទុក្ខបាន ជាការប្រាកដដោយពាក្យទូន្មានដែលមិននាំអ្នកបដិបត្តិឲ្យចេញចាកទុក្ខបាន ក្នុងកាលឥឡូវនេះ ដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងពាក្យទូន្មាន ដែលមិននាំអ្នកបដិបត្តិឲ្យចេញចាកទុក្ខបានអំពីដើម ទើបត្រាស់ពាក្យជាដើមថា ម្នាលចុន្ទ បើសាស្តាក្នុងលោកនេះ មិនមែនជាអ្នកត្រាស់ដឹងខ្លួនឯងដោយប្រពៃ ដូច្នេះ ។ ក្នុងបទថា **វោក្កម្ម ច តម្ហា ធម្មា វត្តតិ** គឺមិនបំពេញជាប់តគ្នា ។ អធិប្បាយថា ប្រព្រឹត្តឃ្លៀងឃ្លាត គឺធ្វើឲ្យមានចន្លោះប្រហោង ។ បទថា **តស្ស តេ អាវុសោ លាភា** គឺបដិបត្តិធម៌សមគួរដល់ធម៌ជាដើម ទាំងនេះជាលាភរបស់លោកនោះ ។ បទថា **សុលទ្ធំ** គឺលោកបានភាពជាមនុស្សល្អហើយ ។ ក្នុងបទថា **តថា បដិបជ្ជតុ** គឺបដិបត្តិយ៉ាងនោះ ។ បទថា **យថា តេ សត្ថារា ធម្មោ ទេសិតោ** គឺសាស្តារបស់លោកសម្តែងធម៌ដោយអាការណា ។ បទថា **យោ ច សមាទបេតិ** គឺអាចារ្យណាបបួល ។ បទថា **យញ្ច សមាទបេតិ** គឺបបួលអន្តេវាសិកណា ។ បទថា **យោ ច សមាទបិតោ** គឺអន្តេវាសិក ត្រូវ

បបួលដោយទីបដិបត្តិ ដែលអាចារ្យបបួល ដើម្បីភាពជាយ៉ាងនោះ ។ បទថា **សព្វេ តេ** គឺមនុស្សទាំង ៣ ពួកនោះ អធិប្បាយថា ក្នុងបុគ្គលទាំង ៣ នេះ អាចារ្យជួបធម៌ដែលមិនមែនបុណ្យ ព្រោះជាអ្នកដឹកនាំអន្តេវាសិក ជាបុគ្គលត្រូវដឹកនាំ រមែងជួបធម៌ដែលមិនមែនបុណ្យ ព្រោះជាអ្នកត្រូវដឹកនាំ អ្នកបដិបត្តិរមែងជួបធម៌ដែលមិនមែនបុណ្យ ព្រោះជាអ្នកបដិបត្តិ ហេតុនោះ ទើបលោកពោលថា ពួកបុគ្គលទាំងអស់នោះ រមែងបាននូវបាបដ៏ច្រើន ។ គប្បីជ្រាបអត្ថក្នុងវារៈទាំងអស់ ដោយទំនងនេះ ។

[ ៩៧ ] ម្យ៉ាងទៀត ក្នុងបទនេះថា **ញាយប្បដិបន្នោ** គឺបដិបត្តិតាមហេតុ ។ បទថា **ញាយំ អារាធេស្សតិ** គឺនឹងញ៉ាំងហេតុឲ្យសម្រេច ។ បទថា **វីរិយំ អារភតិ** គឺធ្វើសេចក្តីព្យាយាមដែលនឹងឲ្យកើតទុក្ខដល់ខ្លួន ដូចដែលព្រះមានព្រះភាគត្រាស់ថា

ម្នាលភិក្ខុទាំងឡាយ អ្នកណា ប្រារព្ធនូវសេចក្តីព្យាយាម ក្នុងធម្មវិន័យដែលសាស្តាពោលទុកមិនល្អ អ្នកនោះ រមែងនៅជាទុក្ខ អ្នកណាខ្ជិលច្រអូស អ្នកនោះ រមែងនៅជាសុខ ដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់សម្តែងពាក្យទូន្មាន ដែលមិននាំអ្នកបដិបត្តិ ឲ្យចេញចាកទុក្ខបានយ៉ាងនេះហើយ កាលទ្រង់សម្តែងពាក្យទូន្មានដែល នាំអ្នកបដិបត្តិឲ្យចេញចាកទុក្ខបានក្នុងកាលឥឡូវនេះ ទើបត្រាស់ពាក្យថា ម្នាលចុន្ទមួយទៀត សាស្តាក្នុងលោកនេះ ជាអ្នកត្រាស់ដឹងឯង ដោយប្រពៃជាដើមដូច្នេះ ។

[ ៩៨-៩៩ ] ក្នុងបទទាំងនោះ បទថា **និយ្យានិកោ** គឺនាំទៅដើម្បីប្រយោជន៍នៃមគ្គ និងដើម្បីប្រយោជន៍នៃផល ។ បទថា **វីរិយំ អារភតិ** គឺប្រារព្ធសេចក្តីព្យាយាមដែលនឹងឲ្យសម្រេចសុខដល់ខ្លួន ដូចព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកណាខ្ជិលច្រអូស ក្នុងធម្មវិន័យដែលតថាគតពោលទុកល្អហើយ អ្នកនោះ រមែងនៅជាទុក្ខ អ្នកណាមានសេចក្តីព្យាយាមដែលប្រារព្ធហើយ អ្នកនោះ រមែងនៅជាសុខ ដូច្នេះ ។

[ ១០០ ] ដោយប្រការដូច្នេះ ព្រះមានព្រះភាគ ទ្រង់សម្តែងអានិសង្សនៃកុលបុត្រដែលបដិបត្តិប្រពៃក្នុងពាក្យទូន្មាន ដែលនឹងធ្វើអ្នកបដិបត្តិឲ្យចេញចាកទុក្ខបាន កាលទ្រង់អធិប្បាយព្រះធម៌ទេសនាទៀត ទើបត្រាស់ពាក្យថា ម្នាលចុន្ទ ព្រះសាស្តាជាអរហន្តសម្មាសម្ពុទ្ធ កើតហើយក្នុងលោកនេះជាដើម ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **អវិញ្ញាបិតត្ថ** គឺមិនមានបញ្ញាដែលនឹងត្រាស់ដឹងបាន ។ បទថា **សព្វសង្គាហបទកតំ** គឺធ្វើដោយបទ ដែលរួបរួមទុកទាំងអស់ អធិប្បាយថា មិនមែនរួបរួមទុកតែមួយ ។ បាឋៈថា **សព្វ-សង្គាហបទគតំ** ដូច្នេះក៏មាន គឺមិននៅក្នុងបទដែលសង្គ្រោះទុក អធិប្បាយថា មិនសង្គ្រោះចូលជាមួយគ្នា ។ បទថា **សប្បាដិហីរកតំ** គឺជាធម៌ដែលនាំអ្នកបដិបត្តិឲ្យចេញចាកទុក្ខបាន ។ បទថា **យាវ ទេវមនុស្សេហិ** គឺប្រកាសដោយល្អហើយ តាំងអំពីមនុស្សលោកដរាបដល់ទេវលោក ។ បទថា **អនុ-តប្បោ ហោតិ** គឺជាអ្នកធ្វើសេចក្តីក្តៅក្រហាយក្នុងកាលជាខាងក្រោយ ។ បទថា **សត្ថា ច នោ លោកេ** ព្រះមានព្រះភាគត្រាស់ ដើម្បីសម្តែងដល់អាការ

ដែលធ្វើឲ្យក្តៅក្រហាយរបស់សាវកទាំងនោះ ។

[ ១០០ ] បទថា **អននុតប្បោ ហោតិ** អធិប្បាយថា ឈ្មោះថា រមែង មិនធ្វើសេចក្តីក្តៅក្រហាយ ក្នុងកាលជាខាងក្រោយ ព្រោះកិច្ចដែលសាវកទាំង-ឡាយអាស្រ័យព្រះសាស្តា គប្បីសម្រេច បានសម្រេចហើយ ។

[ ១០២ ] បទថា **ថេរោ** បានដល់ អ្នករឹងមាំ គឺប្រកបដោយធម៌ ដែលធ្វើឲ្យជាអ្នករឹងមាំ ។ បទថា **រត្តញ្ញូ** ជាដើម មានអត្ថដូចបានពោលហើយ ។

[ ១០៣ ] បទថា **ឯតេហិ ចេបិ** គឺដោយពាក្យទាំងនេះ លោកពោលទុកផ្នែកខាងដើម ។ បទថា **បត្តយោគក្ខេមា** សេចក្តីថា អរហត្ត ឈ្មោះថា ជាដែនក្សេមចាកយោគៈក្នុងធម្មវិន័យនេះ ព្រោះអរហត្តជាដែនក្សេមចាកយោគៈ ៤ សាវកទាំងឡាយសម្រេចអរហត្តនោះ ។ បទថា **អលំ សម្មក្ខាតុំ សទ្ធម្មស្ស** អធិប្បាយថា គប្បីជាអ្នកអាចពោលព្រះសទ្ធម្មបានដោយប្រពៃ ព្រោះរៀនសូត្រមកចំពោះមុខ ។

[ ១០៤ ] បទថា **ព្រហ្មចារិនោ** គឺអរិយសាវកទាំងឡាយ ជាអ្នកកំពុងប្រព្រឹត្តព្រហ្មចារ្យ ។ បទថា **កាមភោគិនោ** គឺគ្រហស្ថដែលជាព្រះសោតា-បន្ន ។ បទទាំងឡាយថា **ឥទ្ធញ្ចេវ** ជាដើម ពិស្តារហើយក្នុងមហាបរិនិព្វាន-សូត្រនុ៎ះឯង ។ បទថា **លាភគ្គយសគ្គប្បត្តំ** ប្រែថា ដល់នូវការប្រសើរដោយលាភ និងដោយយស ។

[ ១០៦ ] បទទាំងឡាយថា **សន្តិ ខោ បន មេ ចុន្ទ ឯតរហិ ថេរា ភិក្ខូ សាវកា** ដូច្នេះ អ្នកជាថេរៈក្នុងបទនេះ បានដល់ ព្រះថេរៈ មានព្រះសារីបុត្រ

*និងព្រះមោគ្គល្លានជាដើម ។ បទថា* **ភិក្ខុនិយោ** *បានដល់ ខេមាថេរី និង ឧប្បលវណ្ណាថេរីជាដើម ។ បទទាំងឡាយថា* **ឧបាសកា សាវកា គិហី ឱទាតវសនា ព្រហ្មចារិនោ** *ដូច្នេះ ឧបាសកក្នុងទីនេះ បានដល់ ចិត្តគហបតី និងហត្ថកអាឡវកៈជាដើម ។ បទថា* **កាមភោគី** *បានដល់ ចុល្លអនាថ-បិណ្ឌិក និងមហាអនាថបិណ្ឌិកជាដើម ។ បទថា* **ព្រហ្មចារិនិយោ** *បានដល់ ស្រ្តីទាំងឡាយ មាននន្ទមាតាជាដើម ។ បទថា* **កាមភោគនិយោ** *បានដល់ ស្រ្តីទាំងឡាយ មាននាងខុជ្ជុត្តរាជាដើម ។*

*[ ១០៧ ] បទថា* **សព្វាការសម្បន្នំ** *បានដល់ អ្នកដល់ព្រមដោយការណ៍ទាំងពួង ។ បទថា* **ឥទមេវ តំ** *សេចក្តីថា បុគ្គលកាលនឹងពោលដល់ព្រហ្មចរិយៈនេះ គឺធម៌នេះ គប្បីពោលដោយហេតុ ដោយន័យដ៏ប្រពៃ ។ បទថា* **ឧទ្ទកស្សុទំ** *កាត់បទជា* **ឧទ្ទកោ សុទំ** *។ បទថា* **បស្សំ ន បស្សតិ** *គឺបុគ្គលកាលឃើញ ក៏ឈ្មោះថា រមែងមិនឃើញ ។ បានឮថា ឧទ្ទករាមបុត្រនោះ សួរបញ្ហានេះចំពោះមហាជន ។ មហាជនពោលថា លោកអាចារ្យ ពួកយើងមិនដឹង សូមលោកអាចារ្យមេត្តាប្រាប់ដល់ពួកយើងផង ទើបឧទ្ទករាម-បុត្រពោលថា បញ្ហានេះជ្រាលជ្រៅ កាលមានអាហារសប្បាយ អាចគិតបានភ្លាម ធ្វើយភ្លាម តពីនោះមក មហាជនទាំងឡាយនោះ ក៏នាំគ្នាធ្វើសក្ការៈធំអស់ ៤ ខែ ឧទ្ទករាមបុត្រ កាលពោលបញ្ហានោះ បានពោលពាក្យជាដើមថា បុគ្គលឃើញនូវអ្វី ទើបឈ្មោះថា ឃើញ ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា* **សាធុនិសិតស្ស** *គឺសំលៀងយ៉ាងមុត ក្នុងសេចក្តីនេះ មានអធិប្បាយថា*

កាំបិតកោរ សំលៀងល្អហើយ រមែងប្រាកដ តែមុខកាំបិតកោរមិនប្រាកដ ។

[ ១០៨ ] បទថា **សង្គម្ម សមាគម្ម** គឺពិនិត្យពិច័យអត្ថដោយអត្ថ ព្យញ្ជនៈដោយព្យញ្ជនៈនោះ អធិប្បាយថា នាំមកប្រៀបធៀបអត្ថ និងអត្ថ ព្យញ្ជនៈ និងព្យញ្ជនៈ ។ បទថា **សង្គាយិតព្វំ** គឺគប្បីប្រាប់បាន គប្បីសូធ្យបាន ។ បទថា **យថយិទំ ព្រហ្មចរិយំ** សេចក្ដីថា សាសនព្រហ្មចរិយៈទាំងអស់នេះ ។

[ ១០៩-១១១ ] បទថា **តត្រ ចេ** គឺត្រង់កណ្ដាលជំនុំសង្ឃនោះ ឬក្នុងកាសិតរបស់សព្រហ្មចារីនោះ ។ ក្នុងបទទាំងឡាយថា **អត្ថញ្ចេវ មិច្ឆា គណ្ហាតិ ព្យញ្ជនានិ ច មិច្ឆា រោបេតិ** ដូច្នេះ អធិប្បាយថា ក្នុងបទនេះថា សតិប្បដ្ឋាន ៤ រមែងកាន់យកអត្ថថា អារម្មណ៍ គឺសតិប្បដ្ឋាន លើកព្យញ្ជនៈឡើងថា **សតិប្បដ្ឋានានិ** ។ បទថា **ឥមស្ស នុ ខោ អាវុសោ អត្ថស្ស** សេចក្ដីថា ព្យញ្ជនៈទាំងឡាយនេះ គឺ **ចត្តារោ សតិប្បដ្ឋានា** ឬថា ព្យញ្ជនៈទាំងឡាយនោះ គឺ **ចត្តារិ សតិប្បដ្ឋានានិ** របស់អត្ថថា សតិនុ៎ះឯង គឺសតិប្បដ្ឋាន ។ បទថា **កតមានិ ឱបាយិកតរានិ** គឺព្យញ្ជនៈ ទាំងឡាយរបស់អត្ថនេះយ៉ាងដូចម្ដេច ។ បទថា **ឥមេសំ វា ព្យញ្ជនានំ** គឺព្យញ្ជនៈទាំងឡាយថា **ចត្តារោ សតិប្បដ្ឋានា** សួរថា អត្ថនេះថា សតិនុ៎ះឯង គឺសតិប្បដ្ឋានឬ ឬមួយអារម្មណ៍ គឺសតិប្បដ្ឋាន ។ បទថា ម្នាលអ្នកមានអាយុ **ឥមស្ស ខោ អាវុសោ អត្ថស្ស** គឺរបស់អត្ថនេះថា អារម្មណ៍ ជាសតិប្បដ្ឋាន ។ បទថា **យានិ ចេវ ឯតានិ** សេចក្ដីថា ព្យញ្ជនៈទាំងនេះ ដែលខ្ញុំពោលហើយ ។ បទថា **យោ ចេវ**

**ឯសោ** *សេចក្ដីថា សេចក្ដីនេះ ដែលខ្ញុំពោលហើយ ។ បទថា* **សោ នេវ ឧស្សាទេតព្វោ** *សេចក្ដីថា ពួកលោកគួរតាំងនៅក្នុងអត្ថ និងក្នុងព្យញ្ជនៈដោយប្រពៃសិន តែសព្រហ្មចារីនោះ ពួកលោកមិនគួរត្រេកអរ មិនគួររុកកួន ។ បទថា* **សញ្ញាបេតព្វោ** *ប្រែថា គួរឲ្យដឹង ។ បទថា* **តស្ស ច អត្ថស្ស** *គឺនៃអត្ថថា សតិទុំះឯង គឺសតិប្បដ្ឋាន ។ បទថា* **តេសញ្ច ព្យញ្ជនានំ** *គឺនៃព្យញ្ជនៈថា* **សតិប្បដ្ឋានា** ។ *បទថា* **និសន្តិយា** *គឺដើម្បីពិចារណា ដើម្បីទ្រទ្រង់ ។ គប្បីជ្រាបអត្ថក្នុងវារៈទាំងអស់ ដោយន័យនេះ ។*

[ ១១២ ] *បទថា* **តាទិសំ** *ប្រែថា ដូចគ្នានឹងលោក ។ បទថា* **អត្ថុបេតំ** *បានដល់ ចូលដល់ដោយអត្ថ គឺដឹងនូវអត្ថ ។ បទថា* **ព្យញ្ជនូបេតំ** *បានដល់ ចូលដល់ដោយព្យញ្ជនៈ គឺដឹងនូវព្យញ្ជនៈ ពួកលោកសរសើរភិក្ខុនោះយ៉ាងនេះ ពិតហើយ ភិក្ខុនោះមិនឈ្មោះថា ជាសាវ័ករបស់ពួកលោក ម្នាលចុន្ទ ភិក្ខុនោះ ឈ្មោះថា ជាព្រះពុទ្ធ ដោយប្រការដូច្នេះ ព្រះមានព្រះភាគទ្រង់តែងតាំងភិក្ខុពហុស្សូតក្នុងតំណែងរបស់ខ្លួន ។*

[ ១១៣ ] *ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់សម្ដែងព្រះធម៌ទេសនាឲ្យក្រៃលែងឡើងៗ ជាងនោះ ទើបត្រាស់បទថា ម្នាលចុន្ទ តថាគតមិនសម្ដែងធម៌ ដើម្បីរាំងនូវអាសវៈទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នតែម្យ៉ាងដល់ពួកអ្នកទេ ដូច្នេះ ។*

*ក្នុងបទនោះ អាសវៈទាំងឡាយដែលកើតឡើង ព្រោះមានបច្ច័យជាហេតុក្នុងលោកនេះ ឈ្មោះថា អាសវៈប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន អាសវៈទាំងឡាយ*

ដែលកើតឡើង ព្រោះមានការទាស់ទែងគ្នាជាហេតុ ក្នុងបរលោក ឈ្មោះថា អាសវៈប្រព្រឹត្តទៅក្នុងភពខាងមុខ ។ បទថា **សំវរាយ** គឺដើម្បីបិទនូវអាសវៈ ទាំងនោះមិនឲ្យចូលទៅ ។ បទថា **បដិឃាតាយ** គឺដើម្បីកម្ចាត់ ដោយការទម្លាយឫសគល់ ។ ក្នុងបទទាំងឡាយថា **អលំ វោ តំ យាវទេវ សីតស្ស បដិឃាតាយ** ដូច្នេះ អធិប្បាយថា ចីវរនោះអាចដើម្បីកម្ចាត់ត្រជាក់ដល់ពួកអ្នក សេចក្តីនេះ ព្រះមានព្រះភាគត្រាស់ថា ចីវរណា ដែលតថាគតអនុញ្ញាតដល់ពួកអ្នក ពួកអ្នកនឹងដណ្តប់ចីវរនោះ ហើយធ្វើសេចក្តីសប្បាយក្តី ប្រកាន់ខ្ពង់ខ្ពស់ក្តី ដូច្នេះ តថាគតមិនអនុញ្ញាត តែពួកអ្នកដណ្តប់ចីវរនោះហើយ ធ្វើការកម្ចាត់រងាជាដើម ហើយធ្វើយោនិសោមនសិការសមណធម៌ងាយ ដូច្នេះ តថាគតអនុញ្ញាត សូម្បីបិណ្ឌបាតជាដើម ក៏មានន័យដូចចីវរ ឯពណ៌នាអនុបទក្នុងទីនេះ គប្បីជ្រាបដោយន័យដែលពោលហើយក្នុងវិសុទ្ធិមគ្គនោះចុះ ។

[ ១១៤-១០៦ ] បទថា **សុខល្លិកានុយោគំ** ប្រែថា ប្រកបសេចក្តីព្យាយាមជោកជាំក្នុងសេចក្តីសុខ អធិប្បាយថា ភាពជាអ្នកពេញចិត្តក្នុងការសោយសុខ ។ បទថា **សុខេ** គឺធ្វើឲ្យតាំងនៅក្នុងសេចក្តីសុខ ។ បទថា **បីណេតិ** គឺធ្វើឲ្យឆ្អែតស្កប់ស្កល់ គឺឲ្យធាត់ ។

[ ១១៧ ] បទថា **អដ្ឋិតធម្មា** គឺជាបុគ្គលមានសភាព មិនយឺនយូរ ។ បទថា **ឋិត្វា នោ អត្ថិ** អធិប្បាយថា ប្រាជ្ញារឿងណាៗ កាលពោលដល់រឿងនោះៗ គ្រាខ្លះពោលដល់មគ្គ គ្រាខ្លះពោលដល់ផល គ្រាខ្លះពោលដល់និព្វាន ។ បទថា **ជានតា** គឺដឹងដោយសព្វញ្ញុតញ្ញាណ ។ បទថា **បស្សតា** គឺឃើញ

ដោយចក្ខុ ៥ ។ បទថា **គម្ភីរនេមោ** គឺកប់ជ្រៅទៅក្នុងដី ។ បទថា **សុនិខាតោ** គឺកប់ណែន ។ បទថា **ឯវមេវ ខោ អាវុសោ** សេចក្ដីថា ព្រះខីណាស្រព ជាអ្នកមិនគួរប្រព្រឹត្តកន្លងឋាន: ៩ ជាអ្នកមិនញាប់ញ័រ មិនកម្រើក ក្នុងការ ប្រព្រឹត្តកន្លងនោះ ។ ក្នុងការប្រព្រឹត្តកន្លងនោះ សូម្បីព្រះអរិយ:ទាំងឡាយ មានព្រះសោតាបន្នជាដើម ក៏មិនគួរក្នុងការក្លែងធ្វើសត្វឲ្យធ្លាក់ចុះជាដើម ។ បទថា **សន្និធិការកំ កាមេ បរិភុញ្ជិតុំ** សេចក្ដីថា ដើម្បីធ្វើការសន្សំវត្ថុកាម និងកិលេសកាម ហើយបរិភោគ ។ បទថា **សេយ្យថាបិ អាគារិកភូតោ** សេចក្ដីថា មិនគួរបរិភោគដូចដែលខ្លួននៅជាគ្រហស្ថ បរិភោគក្នុងកាលមុន ពិតហើយ ព្រះអរិយ: មានព្រះសោតាបន្នជាដើម នៅគ្រប់គ្រងផ្ទះ រមែងតាំង នៅដោយនិមិត្តរបស់គ្រហស្ថរហូតដល់អស់ជីវិត ។ តែព្រះខីណាស្រព សម្រេច អរហត្តហើយ ជាមនុស្សរមែងបរិនិព្វាន ឬបួស ព្រះខីណាស្រព មិនតាំងនៅ ក្នុងកាមាវចរទេវលោកទាំងឡាយ មានចាតុម្មហារាជិកាជាដើមសូម្បីត្រឹមតែ មួយក្លែត ព្រោះហេតុអ្វី ព្រោះមិនមានទីវិវេក ប៉ុន្តែ ព្រះខីណាស្រពតាំងនៅ ក្នុងអត្តភាពនៃភុម្មទេវតា សូម្បីសម្រេចអរហត្តហើយ ក៏តាំងនៅ បញ្ហានេះ មកដល់ដោយអំណាចនៃព្រះខីណាស្រពនោះ គប្បីជ្រាបកិច្ចការ:របស់ព្រះ ខីណាស្រពនោះ ព្រោះទម្លាយទោស:បានហើយ ។

[ ១១៨ ] បទថា **អតីរកំ** គឺមិនមានត្រើយ មិនមានកំណត់ ធំល្ហល្ហេវ ។ បទថា **នោ ច ខោ អនាគតំ** អធិប្បាយថា ព្រះសមណគោតម ទ្រង់មិនបាន បញ្ញត្តយ៉ាងនេះ ព្រោះប្រារព្ធកាលយូរអង្វែង ដែលជាអនាគត ព្រះសមណ-

គោតមទ្រង់ជ្រាបតែអតីតប៉ុណ្ណោះ ទ្រង់មិនជ្រាបអនាគតទេ ការពិតនោះ ការរឭកដល់កំណើត ៥៥០ ជាតិ ក្នុងអតីត រមែងប្រាកដដល់ព្រះសមណគោតមនោះ ការរឭកច្រើនយ៉ាងនេះ រមែងមិនប្រាកដក្នុងអនាគត ពួកបរិព្វាជកអន្យ-តិត្ថិយ ប្រហែលជាសម្គាល់សេចក្តីនោះដូច្នេះ ទើបពោលយ៉ាងនោះ ។ បទថា **តយិទំ កឹសុ** គឺមិនដឹងអនាគតជាដូចម្តេច ។ បទថា **កថំសុ** គឺដោយហេតុដូចម្តេចហ្ន៎ អធិប្បាយថា ព្រះសមណគោតម ទ្រង់មិនជ្រាបទេឬអ្វី ទើបទ្រង់មិនរឭកដល់អនាគត គឺថា ព្រោះទ្រង់មិនប្រាថ្នានឹងរឭក ទើបមិនរឭក ។ បទថា **អញ្ញាវិហិតកេន ញាណទស្សនេន** សេចក្តីថា ពួកបរិព្វាជកអន្យតិត្ថិយរមែងសម្គាល់វត្ថុដែលគប្បីកាន់យកវត្ថុដែលគប្បីបញ្ញត្ត ជាញាណទស្សនៈដែលប្រព្រឹត្តទៅ ព្រោះប្រារព្ធញាណទស្សនៈដទៃ ដោយញាណដែលជាទស្សនៈដទៃ ព្រោះភាពជាអ្នកអាចឃើញ ដូចធ្វើឲ្យប្រចក្ស ដែលជាប្រការដទៃ គឺប្រារព្ធញាណទស្សនៈដទៃប្រព្រឹត្តទៅ ពិតហើយ ពួកបរិព្វាជកអន្យ-តិត្ថិយទាំងនោះ រមែងសម្គាល់ញាណទស្សនៈ ដែលស្ងប់តាំងឡើងហើយចំពោះមុខរឿយៗ ដល់អ្នកដើរទៅ ឈរ ដេកលក់ និងភ្ញាក់ ។ ឈ្មោះថាញាណ ដូច្នោះ រមែងមិនមាន ព្រោះដូច្នោះ គប្បីជ្រាបបរិព្វាជកអន្យតិត្ថិយថាពួកគេរមែងសម្គាល់ ដូចជាអ្នកល្ងង់មិនឈ្លាស ដូច្នោះ ។

បទថា **សតានុសារី** បានដល់ ដែលសម្បយុត្តដោយបុព្វេនិវាសា-នុស្សតិញ្ញាណ ។ បទថា **យាវតកំ អាកង្ខតិ** សេចក្តីថា ព្រះតថាគត រមែងបញ្ជូនព្រះញាណទៅថា តថាគតនឹងដឹងស្មើ ដែលប្រាថ្នានឹងដឹងញាណរបស់

ព្រះតថាគតនោះ គ្មានអ្វីបិទបាំង គ្មានអ្វីរាំង រមែងស្ទុះទៅដូចព្រួញដែលគេបាញ់ ទៅក្នុងគំនរស្លឹកឈើពុក ដូច្នោះ ព្រោះហេតុនោះ ព្រះតថាគត រមែងទ្រង់រឭកបានស្មើតាមដែលទ្រង់ប្រាថ្នា ។ បទថា **ពោធិជំ** ប្រែថា កើតក្បែរគល់ពោធិព្រឹក្ស បទថា **ញាណំ ឧប្បជ្ជតិ** បានដល់ ចតុមគ្គញាណ រមែងកើត ។ បទថា **អយមន្តិមា ជាតិ** អធិប្បាយថា ជាតិនេះមានក្នុងទីបំផុត ព្រោះលះហេតុដែលធ្វើឲ្យមានជាតិ បានដោយញាណនោះ ។ បទថា **នត្ថិ-ទានិ បុនព្ភវោ** អធិប្បាយថា សូម្បីញាណដទៃទៀត ក៏កើតឡើង ។

[ ១១៩ ] បទថា **អនត្ថសញ្ហិតំ** សេចក្តីថា មិនអាស្រ័យប្រយោជន៍ក្នុងលោកនេះ ឬប្រយោជន៍ក្នុងលោកខាងមុខ ។ បទថា **ន តំ តថាគតោ ព្យាករោតិ** អធិប្បាយថា ព្រះតថាគត ទ្រង់រមែងមិនពោលដល់កថាដែលមិននាំអ្នកបដិបត្តិឲ្យចេញចាកទុក្ខបាន ដូចជារឿងការតយុទ្ធ និងរឿងលួចនាងសិតាជាដើម ។ បទថា **ភូតំ តច្ឆំ អនត្ថសញ្ហិតំ** សំដៅដល់តិរច្ឆានកថាមានរាជកថាជាដើម ។ បទថា **កាលញ្ញូ តថាគតោ ហោតិ** អធិប្បាយថា ព្រះតថាគតទ្រង់រមែងដឹងកាល គឺធ្វើឲ្យមានហេតុការណ៍ហើយ ទើបទ្រង់សម្តែង ក្នុងកាលដល់សេចក្តីសមគួរ ព្រោះដូច្នោះ ទើបហៅថា **តថាគត** អធិប្បាយថា ធ្វើ **ទ** អក្ខរៈឲ្យជា **ត** អក្ខរៈ ព្រោះត្រាស់ដោយប្រការដែលគួរត្រាស់ ទើបលោកពោលថា **តថាគត** ។

[ ១២០ ] បទថា **ទិដ្ឋំ** បានដល់ រូបាយតនៈ ។ បទថា **សុតំ** បានដល់ សទ្ទាយតនៈ ។ បទថា **មុតំ** បានដល់ គន្ធាយតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ

របស់វត្ថុ ដែលខ្លួនដឹងហើយ គឺដល់ហើយគប្បីកាន់យក ។ បទថា **វិញ្ញាតំ** បានដល់ ធម្មាយតនៈ មានសុខ និងទុក្ខជាដើម ។ បទថា **បត្តំ** បានដល់ ស្វែងរកក្តី មិនស្វែងរកក្តី សម្រេចហើយ ។ បទថា **បរិយេសិតំ** បានដល់ ស្វែងរកវត្ថុដែលសម្រេចហើយក្តី វត្ថុដែលនៅមិនទាន់សម្រេចក្តី ។ បទថា **អនុវិចរិតំ មនសា** គឺត្រាច់ទៅដោយចិត្ត ។ បទថា **តថាគតេន អភិសម្ពុទ្ធំ** នេះ មានអធិប្បាយថា រូបារម្មណ៍ មានពណ៌ខៀវ ពណ៌លឿងជាដើម របស់លោក ព្រមដោយទេវលោកនេះ ក្នុងលោកធាតុទាំងឡាយប្រមាណមិនបាន យ៉ាងណា រមែងមកកាន់គន្លងនៃចក្ខុទ្វារ សត្វនេះឃើញរូបារម្មណ៍នេះ ក្នុងខណៈនេះ ជាអ្នកពេញចិត្ត ទាស់ចិត្ត ឬមានខ្លួនជាកណ្តាល ដូច្នេះ រូបារម្មណ៍ទាំងអស់នោះ ដែលព្រះតថាគតត្រាស់ដឹងក្រៃលែងហើយ ដោយអាការយ៉ាងនេះ ។ ដូចគ្នានេះដែរ សទ្ទារម្មណ៍ណា មានសំឡេងស្គរ សំឡេងសម្ភោរជាដើម របស់លោក ព្រមទាំងទេវលោក ក្នុងលោកធាតុទាំងឡាយ ដែលប្រមាណមិនបាន រមែងមកកាន់គន្លងនៃសោតទ្វារ គន្ធារម្មណ៍ណា មានក្លិនដែលកើតអំពីឫស មានក្លិនកើតអំពីសម្បកជាដើម រមែងមកកាន់គន្លងនៃឃានទ្វារ រសារម្មណ៍ណា មានរសកើតអំពីឫស រសអំពីដើមជាដើម រមែងមកកាន់គន្លងនៃជិវ្ហាទ្វារ ផោដ្ឋព្វារម្មណ៍ណា មានបឋវីធាតុ តេជោធាតុ វាយោធាតុ មានរឹង មានទន់ជាដើម រមែងមកកាន់គន្លងនៃកាយទ្វារ សត្វនេះពាល់ត្រូវផោដ្ឋព្វារម្មណ៍នេះ ក្នុងខណៈនេះ ជាអ្នកពេញចិត្ត ជាអ្នកទាស់ចិត្ត ឬមានខ្លួនជាកណ្តាល អារម្មណ៍ទាំងអស់នោះ ព្រះតថាគតត្រាស់ដឹងក្រៃលែង

ហើយ ដោយប្រការដូច្នេះ ។ ដូចគ្នានេះដែរ ធម្មារម្មណ៍ណាមានសុខ និងទុក្ខជាដើម របស់លោក ព្រមដោយទេវលោកនេះ ក្នុងលោកធាតុទាំងឡាយដែលប្រមាណមិនបាន រមែងមកកាន់គន្លងនៃមនោទ្វារ សត្វនេះដឹងច្បាស់ធម្មារម្មណ៍នេះ ក្នុងខណៈនេះ ជាអ្នកពេញចិត្ត ជាអ្នកទាស់ចិត្ត ឬជាអ្នកមានខ្ជួនជាកណ្តាល ធម្មារម្មណ៍ទាំងអស់នោះ ដែលព្រះតថាគតត្រាស់ដឹងក្រៃលែងហើយ ដោយប្រការដូច្នេះ ។

ម្នាលចុន្ទ តថាគតមិនឃើញ មិនឮ មិនដឹង ឬមិនដឹងច្បាស់ ក្នុងវត្ថុដែលមនុស្សទាំងឡាយនេះ ឃើញហើយ ឮហើយ ដឹងហើយ ឬដឹងច្បាស់ហើយ រមែងមិនមាន វត្ថុដែលមហាជននេះស្វែងរកហើយ សម្រេចក៏មាន វត្ថុដែលមហាជននេះស្វែងរកហើយ មិនសម្រេចក៏មាន វត្ថុដែលមហាជនមិនស្វែងរកហើយសម្រេចក៏មាន វត្ថុដែលមហាជនមិនស្វែងរកហើយ មិនសម្រេចក៏មាន ទាំងអស់នោះ ឈ្មោះថា ព្រះតថាគតមិនសម្រេចហើយ ទ្រង់មិនធ្វើឲ្យច្បាស់ដោយញាណ រមែងមិនមាន ព្រោះដូច្នោះ ទើបហៅថា **តថាគត** ដូច្នេះ ដែលហៅថា **តថាគត** ព្រោះកន្លែងដែលស្តេចមិនយាងទៅក្នុងលោកមិនមាន ។ តែក្នុងបាលីពោលថា **អភិសម្ពុទ្ធំ** ពាក្យនោះ មានសេចក្តីស្មើគ្នានឹង **គត** សព្ទ គប្បីជ្រាបសេចក្តីនៃបទសរុបថា **តថាគតោ** ក្នុងវារៈទាំងអស់ ដោយន័យនេះ ការពោលត្រូវរបស់អត្ថនោះ លោកពោលសេចក្តីពិស្តារនៃ **តថាគត** សព្ទ ក្នុងព្រហ្មជាលសូត្រ ។

[ ១២១ ] ព្រះមានព្រះភាគ កាលទ្រង់បន្លឺព្រះសីហនាទថា តថាគត

ពោលដល់ភាពជាអ្នកមិនមានបុគ្គលស្មើ មិនមានបុគ្គលក្រៃលែងជាង ភាពជាអ្នកដឹងធម៌ទាំងពួង ភាពជាធម្មរាជារបស់ព្រះអង្គយ៉ាងនេះហើយ ឈ្មោះថា មិនដឹង មិនឃើញក្នុងលទ្ធិទាំងឡាយ របស់ពួកសមណព្រាហ្មណ៍ជាច្រើន ក្នុងកាលឥឡូវនេះ រមែងមិនមាន ធម៌ទាំងអស់រមែងប្រព្រឹត្តទៅខាងក្នុងញាណ របស់តថាគតនោះឯង ដូច្នេះ ទើបត្រាស់ពាក្យជាដើមថា ម្នាលចុន្ទ ហេតុជាទីតាំង រមែងមាន ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **តថាគតោ** សំដៅដល់សត្វ ។

[ ១២២ ] បទថា **ន ហេតំ អាវុសោ អត្ថ សំហិតំ** គឺមិនប្រកបដោយប្រយោជន៍ក្នុងលោកនេះ និងប្រយោជន៍ក្នុងបរលោកខាងមុខ ។ បទថា **ន ធម្ម សំហិតំ** គឺមិនអាស្រ័យនវលោកុត្តរធម៌ ។ បទថា **ន អាទិព្រហ្មចរិយកំ** គឺមិនជាខាងដើមនៃសាសនព្រហ្មចារ្យទាំងអស់ ដែលសង្គ្រោះដោយត្រៃសិក្ខា ។ ក្នុងបទទាំងឡាយថា **ឥទំ ទុក្ខន្តិ ខោ** ជាដើម មានអធិប្បាយថា ធម៌ទាំងឡាយប្រព្រឹត្តទៅក្នុងភូមិ ៣ ដ៏សេស វៀរតណ្ហា ព្រះមានព្រះភាគទ្រង់ព្យាករថា នេះជាទុក្ខ តណ្ហា ជាហេតុចម្រើន ជាហេតុកើតនៃទុក្ខនោះឯង ព្រះមានព្រះភាគទ្រង់ព្យាករថា ជាទុក្ខសមុទយៈ ការមិនប្រព្រឹត្តទៅនៃធម៌ទាំង ២ នោះ គឺទុក្ខ និងទុក្ខសមុទយៈ ព្រះមានព្រះភាគទ្រង់ព្យាករថា ជាទុក្ខនិរោធ អរិយមគ្គ គឺការដឹងជុំវិញទុក្ខ ការលះសមុទយៈ ការធ្វើឲ្យជាក់ច្បាស់នូវនិរោធ ព្រះមានព្រះភាគទ្រង់ព្យាករថា ជាទុក្ខនិរោធគាមិនីបដិបទា ។ ក្នុងបទទាំងឡាយថា **ឯតញ្ហិ អាវុសោ អត្ថ សំហិតំ** ជាដើម មានអធិប្បាយថា ប្រការ

នេះអាស្រ័យប្រយោជន៍ ក្នុងលោកនេះ និងប្រយោជន៍ក្នុងលោកខាងមុខ អាស្រ័យនវលោកុត្តរធម៌ជាខាងដើម គឺជាប្រធាន គឺជាប្រមុខ នៃសាសនព្រហ្មចរិយៈទាំងអស់ ។

[ ១២៣ ] ព្រះមានព្រះភាគ កាលទ្រង់បន្ទឹព្រះសីហនាទថា ឥឡូវនេះ ពួកបរិព្វាជកអន្យតិរ្ថិយទាំងឡាយ កុំគប្បីយល់យ៉ាងនេះថា ពាក្យណា ដែលតថាគតមិនព្យាករ ពាក្យនោះ តថាគតមិនដឹង ទើបមិនព្យាករ ដូច្នេះ តថាគតដឹងច្បាស់ តែមិនព្យាករ បើតថាគតព្យាករពាក្យនេះទៅ ក៏មិនមានប្រយោជន៍ ឯពាក្យណា ដែលតថាគតគួរព្យាករ យ៉ាងណា ពាក្យនោះ តថាគតក៏បានព្យាករហើយទុំ៎ះឯង ដូច្នេះ ទើបត្រាស់ទៀត ម្នាលចុន្ទ ទិដ្ឋិនិស្ស័យទាំងឡាយណាជាដើម ។

ទិដ្ឋិទាំងឡាយក្នុងបទនោះ អធិប្បាយថា បានដល់ ទិដ្ឋិនិស្ស័យ ទិដ្ឋិនិស្សិត ទិដ្ឋិគតិ ។ បទថា **ឥទមេវ សច្ចំ** គឺពាក្យនេះឯងជាទស្សនះដែលពិត ។ បទថា **មោឃមញ្ញំ** បានដល់ ពាក្យរបស់បុគ្គលដទៃ ជាពាក្យសោះសូន្យទទេ ។ បទថា **អសយំការោ** ប្រែថា មិនបានធ្វើដោយខ្លួនឯង ។

[ ១២៤-១២៧ ] បទថា **តត្រ** បានដល់ សមណៈ និងព្រាហ្មណ៍ទាំងនោះ ។ បទថា **អត្ថិ នុ ខោ ឥទំ អាវុសោ វុច្ចតិ** ដូច្នេះ អធិប្បាយថា តថាគតសួរពួកអ្នកយ៉ាងនេះថា ម្នាលអ្នកមានអាយុ ពាក្យណា ដែលពួកអ្នកពោលហើយថា ខ្លួន និងលោកទៀង ដូច្នេះ ពាក្យនេះមាន ឬមិនមាន ។ បទថា **យញ្ចខោ តេ ឯវមាហំសុ** សេចក្តីថា សមណព្រាហ្មណ៍ទាំងនោះ ពោលពាក្យ

ណាថា ពាក្យនេះឯងពិត ពាក្យដទៃទទេ តថាគតមិនអនុញ្ញាតពាក្យនោះដល់សមណព្រាហ្មណ៍ទាំងនោះ ។ បទថា **បញ្ញត្តិយា** គឺដោយទិដ្ឋិប្បញ្ញត្តិ ។ បទថា **សមសមំ** គឺសមដោយញាណដ៏ស្មើ ។ បទថា **យទិទំ អធិបញ្ញត្តិ** គឺនេះឈ្មោះអធិប្បញ្ញត្តិ ។ ក្នុងអធិប្បញ្ញត្តិនេះ តថាគតទុំះឯងក្រៃលែងជាង មិនមានអ្នកស្មើដោយតថាគត ពាក្យដែលអ្នកពោលដោយបញ្ញត្តិ និងអធិប្បញ្ញត្តិទាំង ២ ពាក្យនេះ ដូចគ្នាដោយអត្ថ ដោយប្រភេទ មានពីរ គឺជាបញ្ញត្តិ អធិប្បញ្ញត្តិ ក្នុងបញ្ញត្តិទាំង ២ នោះ ទិដ្ឋិប្បញ្ញត្តិ ហៅថា បញ្ញត្តិ បញ្ញត្តិ ៦ ដែលលោកពោលយ៉ាងនេះ គឺខន្ធប្បញ្ញត្តិ ធាតុប្បញ្ញត្តិ អាយតនប្បញ្ញត្តិ ឥន្ទ្រិយប្បញ្ញត្តិ សច្ចប្បញ្ញត្តិ បុគ្គលប្បញ្ញត្តិ ឈ្មោះថា អធិប្បញ្ញត្តិ តែក្នុងទីនេះ បទថា **បញ្ញត្តិយា** សំដៅយកទាំងបញ្ញត្តិ និងអធិប្បញ្ញត្តិ ពិតហើយព្រះមានព្រះភាគ ទ្រង់ជាអគ្គបុគ្គល មិនមានបុគ្គលដទៃក្រៃលែងជាង ទាំងដោយបញ្ញត្តិ ទាំងដោយអធិប្បញ្ញត្តិ ក្នុងបទថា **អធិប្បបញ្ញត្តិ** នេះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា មានតែតថាគតហ្នឹងឯង ក្រៃលែងជាងគេ ក្នុងអធិប្បញ្ញត្តិទាំងនោះ ។

[ ១២៨ ] បទថា **បហានាយ** គឺដើម្បីលះបង់ ។ បទថា **សមតិក្កមាយ** ជាវេវចនៈរបស់បទថា **បហានាយ** នោះ ។ បទថា **ទេសិតា** ប្រែថា ពោលហើយ ។ បទថា **បញ្ញត្តា** គឺតាំងទុកហើយ អធិប្បាយថា កាលធ្វើការចែកយនៈចេញ ដើម្បីបម្រើនសតិប្បដ្ឋាន បានឃើញវត្ថុទាំងពួងដោយសេចក្តីពិតប្រាកដ ឈ្មោះថា លះទិដ្ឋិនិស្ស័យទាំងអស់ ដោយបង្អោន

ការឃើញថា រមែងមិនចូលទៅទទួលដឹងភាពជាសត្វ ក្នុងគំនរសង្ខារសុទ្ធ ដូច្នេះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលចុន្ទ សតិប្បដ្ឋាន ទាំង ៤ ដែលតថាគតសម្តែងហើយ បញ្ញត្តហើយយ៉ាងនេះ ដើម្បីឈានកន្លង នូវពួកទិដ្ឋិនិស្ស័យ ដូច្នេះ បទដ៏សេសក្នុងទីទាំងពួង មានអត្ថងាយយល់ ហើយ ។ អដ្ឋកថាបាសាទិកសូត្រ ក្នុងទីឃនិកាយឈ្មោះ សុមង្គលវិលាសិនី ចប់ ៕

**បាសាទិកសូត្រ ចប់**

**សូត្រទី ៦ ចប់**

# សុត្តន្តបិដក ទីឃនិកាយ

## ទាដិកវគ្គ

## ចដ្ឋភាគ

## លក្ខណសូត្រទី ៧

[ ១ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងវេលានោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទ្លើយតបព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ពាក្យនេះថា ម្នាលភិក្ខុទាំងឡាយ មហាបុរសប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការនេះ មហាបុរស ( នោះ ) រមែងមានគតិ ២ យ៉ាង មិនមែនក្រៅពី ២ យ៉ាងនេះទេ គឺបើមហាបុរសនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិប្រកបដោយធម៌ ជាស្តេចទ្រង់ធម៌ មានជ័យជម្នះផ្សាយអំណាច រហូតដល់ផែនដីដែលមានមហាសមុទ្រទាំង ៤ ព័ទ្ធជុំវិញ ទ្រង់ដល់នូវភាវៈជាអ្នកមានជនបទដ៏មាំមួន ទ្រង់ប្រកបដោយរ័តន៍ ៧ ប្រការ ឯរ័តន៍ ៧ ប្រការនៃស្តេចចក្រពត្តិ នោះ គឺចក្ករ័តន៍ ១ ហត្ថិរ័តន៍ ១ អស្សរ័តន៍ ១ មណិរ័តន៍ ១ ឥត្ថីរ័តន៍ ១ គហបតិរ័តន៍ ១ បរិនាយករ័តន៍ ១ រួមត្រូវជា ៧ ប្រការ ។ ព្រះរាជបុត្ររបស់ស្តេចចក្រពត្តិនោះ ក៏មានចំនួនច្រើនពាន់ ច្រើនតែជាអ្នកក្លៀវក្លា មានរូបសណ្ឋានជាអ្នកអង់អាច អាចញាំញីនូវសេនា

របស់ស្តេចឯទៀតបាន ។ ព្រះអង្គប្រាបប្រាមគ្រប់គ្រងនូវផែនដីនេះ ដែលមានសាគរជាទីបំផុត ឲ្យជាផែនដីឥតមានគោល ឥតមាននិមិត្ត ឥតមានបន្លាគឺចោរឡើយ ជាផែនដីស្តុកស្តម្ភមាំមួន ក្សេមក្សាន្ត ឥតមានឧបទ្រព ឥតមានទីពួនរបស់ចោរ ដោយធម៌ដ៏ស្មើ គឺសីល ៥ មិនបាច់ពឹងអាជ្ញា មិនបាច់ពឹងគ្រឿងសស្ត្រាវុធឡើយ បើមហាបុរសនោះ ចេញចាកគេហដ្ឋាន ទៅទ្រង់ព្រះផ្នួសហើយ នឹងបានត្រាស់ជាអរហន្តសម្មាសម្ពុទ្ធក្នុងលោក មានដំបូល គឺកិលេសបើកចេញហើយ ។ ម្នាលភិក្ខុទាំងឡាយ មហាបុរសប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការនោះ តើដូចម្តេចខ្លះ ទើបបានជាមានគតិ ២ យ៉ាង មិនមែនក្រៅអំពី ២ យ៉ាងនេះឡើយ គឺបើមហាបុរសនៅគ្រប់គ្រងគេហដ្ឋាននឹងបានជាស្តេចចក្រពត្តិ ។ សេចក្តីបង្រួញ ។ បើមហាបុរសចេញចាកគេហដ្ឋានទៅទ្រង់ព្រះផ្នួស នឹងបានត្រាស់ជាអរហន្តសម្មាសម្ពុទ្ធក្នុងលោក មានដំបូល គឺកិលេសបើកចេញហើយ ។ ម្នាលភិក្ខុទាំងឡាយ មហាបុរសក្នុងលោកនេះ មានព្រះបាទប្រតិស្ឋានល្អ គឺមានផ្ទៃព្រះបាទទាំងគូរាបស្មើសព្វអន្លើ ។ ម្នាលភិក្ខុទាំងឡាយ មហាបុរសមានព្រះបាទប្រតិស្ឋានល្អ ដោយហេតុណា ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះឯង ជាមហាបុរិសលក្ខណៈរបស់មហាបុរស ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ត្រង់ផ្ទៃព្រះបាទទាំងគូខាងក្រោមរបស់មហាបុរស មានរូបចក្រកើតឡើង ប្រកបដោយខ្នងកង់ និងដុំព្រមទាំងកាំ ១០០០ មានចន្លោះស្មើគ្នាគ្រប់អន្លើ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ផ្ទៃព្រះបាទទាំងគូខាងក្រោមរបស់មហាបុរស មានរូបចក្រកើតឡើង ប្រកប

ដោយខ្នងកង់ និងដុំព្រមទាំងកាំ ១០០០ មានចន្លោះស្មើគ្នាគ្រប់អន្លើ ដោយហេតុណា ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះឯង ជាមហាបុរិសលក្ខណៈរបស់មហាបុរស ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត មហាបុរសមានព្រះបណ្ហិ គឺកែងវែង ។ មានព្រះអង្គុលិ គឺម្រាមព្រះហស្ត និងម្រាមព្រះបាទវែងៗ ។ មានផ្ទៃព្រះហស្ត និងផ្ទៃព្រះបាទដ៏ទន់ល្មើយ ។ មានផ្ទៃព្រះហស្ត និងផ្ទៃព្រះបាទប្រទាក់ដោយក្រឡា ដូចជាសំណាញ់ ។ មានព្រះបាទដូចជាអណ្តែតឡើងខាងលើ ។ មានព្រះជង្ឃា គឺស្មងរៀវមូលត្រសូល ស្រដៀងនឹងស្មងសត្វទ្រាយ ។ កាលបើទ្រង់ឈរ មិនបាច់ឱនព្រះអង្គចុះ អាចស្ទាបអង្អែលព្រះជាណុ គឺជង្គង់ដោយផ្ទៃព្រះហស្តទាំងពីរបាន ។ មានព្រះអង្គាវយវៈដែលត្រូវលាក់កំបាំងដោយសំពត់បិតនៅក្នុងស្រោម ។ មានស្បែកសម្បុរថ្ងៃ ( លឿងក្លឺអន្ទង ) ដូចជាសម្បុរនៃមាស ។ មានព្រះឆវី គឺសម្បុរថ្ងៃល្អិតផូរផង់រលើងស្រិល រអិលធូលីធ្លាក់មក មិនជាប់ព្រះកាយ ។ មានព្រះលោមាតែ ១ សរសៃៗ គឺក្នុងរណ្តៅរោម ១ មានរោម ១ ។ មានព្រះលោមាមានចុងងឡើងលើ ព្រះលោមាដែលដុះឡើងហើយ មានចុងឡើងលើជាទក្ខិណាវដ្ត វិលវង់ព័ទ្ធពេនទៅខាងស្តាំ មានសម្បុរខៀវ ដូចជាសម្បុរនៃផ្កាអញ្ចន់ ក្ងួចមូលដូចជាកុណ្ឌល ។ មានព្រះកាយត្រង់ដូចជាកាយនៃព្រហ្ម ។ មានព្រះមំសៈ គឺសាច់ ៧ អន្លើពេញបរិបូណ៌ ។ មានព្រះកាយពាក់កណ្តាលខាងលើ ដូចជាកាយនៃរាជសីហ៍ ។ មានព្រះបិដ្ឋិ គឺខ្នងដ៏ពេញបរិបូណ៌ ។ មានទ្រង់ទ្រាយព្រះកាយ ដូចជាបរិមណ្ឌលនៃដើមជ្រៃ កាយរបស់

មហាបុរសប្រវែងណា ព្យាមរបស់មហាបុរសក៏ប្រវែងនោះដែរ គឺមានកាយ និងព្យាមស្មើគ្នា ។ មានព្រះស្មួរងមូលសម ។ មានព្រះប្រសាទ គឺសរសៃល្អិតឆ្មារដ៏លើសលែង សម្រាប់ទទួលរសអាហារ ។ មានព្រះហនុកា ( ចង្កា ) ដូចជាចង្កានៃរាជសីហ៍ ។ មានព្រះទន្ត ៤០ គត់ ។ មានព្រះទន្តរាបស្មើ ។ មានព្រះទន្តជិតស្និទ្ធល្អ ។ មានព្រះទាឋា គឺចង្កូម ( ទាំង ៤ ) សស្អាត ។ មានព្រះជិវ្ហាដ៏ធំវែង ។ មានព្រះសូរសព្ទ ដូចជាសំឡេងនៃព្រហ្ម ។ កាលបើបញ្ចេញវាចាលាន់ឮពីរោះ ដូចជាសំឡេងនៃសត្វករវិក ។ មានព្រះនេត្រខៀវស្រស់ ។ មានដួងព្រះនេត្រដូចជាភ្នែកនៃ ( កូន ) គោ ។ មានព្រះឧណ្ណាលោម គឺរោមប្រជុំចិញ្ចើម ដុះត្រង់ចន្លោះនៃព្រះភមុកា ( ចិញ្ចើម ) មានពណ៌សក្បុស ទន់ល្មើយដូចជាសំឡី ។ ម្នាលភិក្ខុទាំងឡាយ មហាបុរសដែលមានព្រះឧណ្ណាលោមដុះត្រង់ចន្លោះនៃព្រះភមុកា មានពណ៌សក្បុសទន់ល្មើយដូចជាសំឡី ដោយហេតុណា ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះឯងជាមហាបុរិសលក្ខណៈរបស់មហាបុរស ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត មហាបុរិសៈមានព្រះសិរ្ស ហាក់ដូចជាប្រដាប់ដោយក្បាំងមកុដស្រេចស្រាប់ ។ ម្នាលភិក្ខុទាំងឡាយ មហាបុរសៈមានព្រះសិរ្ស ហាក់ដូចជាប្រដាប់ដោយក្បាំងមកុដស្រេចស្រាប់ ដោយហេតុណា ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះឯងជាមហាបុរិសលក្ខណៈរបស់មហាបុរស ។ ម្នាលភិក្ខុទាំងឡាយ មហាបុរសៈប្រកបដោយមហាបុរិសលក្ខណៈទាំង ៣២ ប្រការនេះឯង ទើបបានជាមានគតិជាពីរយ៉ាង មិនមែនក្រៅអំពី ២ យ៉ាងនេះឡើយ គឺបើមហាបុរសនៅ

គ្រប់គ្រងគេហដ្ឋាននឹងបានជាស្តេចចក្រពត្តិ ។ សេចក្តីបង្រួញ ។ បើទ្រង់ចេញចាកគេហដ្ឋានទៅទ្រង់ព្រះផ្នួស នឹងបានត្រាស់ជាព្រះអរហន្តសម្មាសម្ពុទ្ធក្នុងលោក មានដំបូល គឺកិលេសបើកចេញហើយ ។ ម្នាលភិក្ខុទាំងឡាយ ពួកឥសីជាខាងក្រៅ ( អួតថា ) តែងចេះចាំមហាបុរិសលក្ខណៈ របស់មហាបុរសៈទាំង ៣២ ប្រការនេះឯង តែឥសីទាំងនោះឥតដឹងសោះ ។ ព្រោះមហាបុរសបានធ្វើនូវកម្មនេះ ។បេ។ ទើបបាននូវលក្ខណៈនេះ ។

[ ២ ] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ( អាស្រ័យ ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលពីមុន ជាអ្នកបានសមាទានមាំមួន ក្នុងកុសលធម៌ទាំងឡាយ គឺជាអ្នកសមាទានជាប់មិនដាច់ក្នុងកាយសុចរិត វចីសុចរិត មនោសុចរិត ការបរិច្ចាគទាន ការសមាទានសីល ការរក្សាឧបោសថ វត្តដែលត្រូវធ្វើចំពោះមាតា វត្តដែលត្រូវធ្វើចំពោះបិតា វត្តដែលត្រូវធ្វើចំពោះសមណៈ វត្តដែលត្រូវធ្វើចំពោះព្រាហ្មណ៍ វត្តដែលត្រូវធ្វើចំពោះជន ដែលជាច្បងក្នុងត្រកូល និងក្នុងពួកធម៌ជាកុសលដ៏ក្រៃលែងឯទៀតៗ ។ ព្រះតថាគតនោះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ ក៏បានទៅកើតក្នុងសុគតិសួគ៌ ទេវលោក ព្រោះហេតុតែកុសលកម្ម ដែលមហាបុរសបានធ្វើសន្សំ បណ្តុះ ឲ្យធំទូលាយហើយនោះ ។ ព្រះតថាគតនោះ តែងគ្របសង្កត់ពួកទេវតាឯទៀតក្នុងឋានសួគ៌នោះ ដោយហេតុ ១០ ប្រការ គឺអាយុទិព្វ ១ សម្បុរទិព្វ ១ សុខទិព្វ ១ យសទិព្វ ១ ភាពជាធំដ៏ជាទិព្វ ១ រូបទិព្វ ១ សំឡេងទិព្វ ១ ក្លិនទិព្វ ១ រសទិព្វ ១

សម្មស្សទិព្យ ១ ។ លុះព្រះតថាគតច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈនេះ ។

[ ៣ ] ព្រះតថាគត មានជើងប្រតិស្ឋានល្អ ដាក់ជើងលើផែនដីក៏ស្មើ លើកឡើងក៏ស្មើ គឺបាតជើងជិតស៊ប់នឹងផែនដីសព្វផ្ទៃជើង ។ ព្រះតថាគតនោះ ប្រកបហើយដោយលក្ខណៈនោះ បើនៅគ្រប់គ្រងគេហដ្ឋាននឹងបានជាស្តេចចក្រពត្តិ ប្រកបដោយធម៌ ជាស្តេចទ្រង់ធម៌ មានជ័យជម្នះ ផ្សាយអំណាចរហូតដល់ផែនដី ដែលមានមហាសមុទ្រទាំង ៤ ព័ទ្ធជុំវិញ នឹងដល់នូវភាពជាអ្នកមានជនបទដ៏មាំមួន ប្រកបដោយរ័តន៍ទាំង ៧ ប្រការ ។ រ័តន៍ ៧ ប្រការរបស់ស្តេចចក្រពត្តិនោះ គឺចក្ករ័តន៍ ១ ហត្ថិរ័តន៍ ១ អស្សរ័តន៍ ១ មណិរ័តន៍ ១ ឥត្ថីរ័តន៍ ១ គហបតិរ័តន៍ ១ បរិនាយករ័តន៍ ១ រួមត្រូវជា ៧ ប្រការ ។ ព្រះរាជបុត្ររបស់ស្តេចចក្រពត្តិនោះ ក៏មានចំនួនច្រើនពាន់ ច្រើនតែជាអ្នកក្លៀវក្លា មានរូបសណ្ឋានជាអ្នកអង់អាច អាចញាំញីនូវសេនារបស់ស្តេចឯទៀតបាន ។ ស្តេចចក្រពត្តិនោះ ប្រាបប្រាមគ្រប់គ្រងផែនដីនេះ ដែលមានសាគរជាទីបំផុត ឲ្យជាផែនដី ឥតមានគោល ឥតមាននិមិត្ត ឥតមានបន្លា គឺចោរឡើយ ជាផែនដីស្តុកស្តម្ភ មាំមួន ក្សេមក្សាន្ត ឥតមានឧបទ្រពឥតមានទីពួនរបស់ចោរដោយធម៌ស្មើ គឺសីល ៥ មិនបាច់ពឹងអាជ្ញា មិនបាច់ពឹងគ្រឿងសស្ត្រាវុធឡើយ កាលបើព្រះតថាគតនៅសោយរាជ្យ នឹងបានរបស់អ្វី នឹងបានជាអ្នកមិនតក់ស្លុត ដោយមនុស្សណាមួយជាសឹកសត្រូវ ជាបច្ចាមិត្ត កាលបើព្រះតថាគតនៅសោយរាជ្យ នឹងបានរបស់នេះឯង ។ បើចេញចាក

គេហដ្ឋានទៅបួស នឹងបានត្រាស់ជាអរហន្តសម្មាសម្ពុទ្ធក្នុងលោក មានដំបូល គឺកិលេសបើកចេញហើយ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ បាននូវរបស់អ្វី ទើបជាអ្នកមិនតក់ស្លុតដោយសឹកសត្រូវ បច្ចាមិត្តខាងក្នុង ឬខាងក្រៅ គឺរាគៈក្តី ទោសៈក្តី មោហៈក្តី សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី អ្នកណាមួយក្តី ក្នុងលោក ( នេះ ) ។ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ បានរបស់នេះឯង ។ លុះព្រះមានព្រះភាគ បានពោលនូវសេចក្តីនេះរួចហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[ ៤ ] ព្រះតថាគត តែងត្រេកអរ ក្នុងវចីសច្ចៈផង ក្នុងធម៌ គឺកុសលកម្មបថ ១០ ផង ក្នុងការទូន្មាននូវឥន្ទ្រិយផង ក្នុងសេចក្តីសង្រួម ( ក្នុងសីល ) ផង ក្នុងការស្អាតផ្លូវកាយជាដើម និងសីលជាទីនៅអាស្រ័យ និងឧបោសថ-កម្មផង ក្នុងកិរិយាមិនបៀតបៀននូវពួកសត្វផង ក្នុងអំពើដែលមិនរួសរាន់ផង សមាទានមាំទាំ ប្រព្រឹត្តគ្រប់ទាំងអស់ ។ ព្រោះកម្មនោះឯង ទើបតថាគតបានទៅកាន់ឋានសួគ៌ សោយសេចក្តីសុខ សេចក្តីសម្រាន្ត និងសេចក្តីត្រេកអរ លុះច្យុតចាកឋានសួគ៌នោះ បានមកកើតក្នុងមនុស្សលោកនេះវិញ ក៏មានផ្ទៃជើងទាំងពីររាបស្មើល្អ ជាន់ត្រូវផែនដី ( ដោយព្រះបាទដ៏ស្មើ ) ។ ពួកជនអ្នកស្គាល់លក្ខណៈមកប្រជុំគ្នាហើយ ទាយថា ព្រះតថាគតដែលមាន

ព្រះបាទប្រតិស្ឋានល្អ ទោះបីនៅជាគ្រហស្ថក្តី ធ្វើជាបព្វជិតក្តី ក៏ឥតញាប់ញ័រ ( ដោយសត្រូវឡើយ ) ព្រោះមានលក្ខណៈនោះ ជាគ្រឿងចុះបំភ្លឺសេចក្តីនោះ ។ កាលបើនៅគ្រប់គ្រងគេហដ្ឋាន តែងមិនញាប់ញ័រ ( ដោយសត្រូវ ) អាចគ្របសង្កត់នូវជនដទៃបាន ពួកសត្រូវក៏មិនអាចញាំញីបាន ព្រះតថាគតមិនបានតក់ស្លុតនឹងមនុស្សណាមួយ ក្នុងលោកនេះ ដោយសារផលនៃកម្មនោះឯង ។ បើបុគ្គល ( មានលក្ខណៈ ) ដូចព្រះតថាគតនោះ ចូលទៅកាន់ផ្នួសរមែងពេញចិត្តត្រេកអរ ក្នុងនេក្ខម្មៈ បានជាអ្នកប្រាជ្ញប្រសើរបំផុត អ្នកប្រាជ្ញនោះ ជាអគ្គបុគ្គលប្រសើរជាងនរជន តែងមិនដល់នូវសេចក្តីញាប់ញ័រ ( ដោយកិលេស ) ជាដាច់ខាត នេះឯងជាធម្មតារបស់ព្រះតថាគតនោះ ។

[ ៥ ] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ( អាស្រ័យ ) នូវជាតិពីមុនភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលពីមុន ជាអ្នកបាននាំមកនូវសេចក្តីសុខ ឲ្យដល់ជនច្រើននាក់ផង ជាអ្នកកម្ចាត់បង់នូវភ័យ គឺសេចក្តីភ្ញាក់ផ្អើល និងសេចក្តីតក់ស្លុតផង ជាអ្នកចាត់ចែងនូវការរក្សាការពារគ្រប់គ្រងប្រកបដោយធម៌ផង បានឲ្យទាន ព្រមទាំងបរិវារ ( របស់ទាន ) ផង ។ ព្រះតថាគតនោះ លុះបែកធ្លាយរាងកាយខាងមុខអំពីសេចក្តីស្លាប់ក៏បានទៅកើតក្នុងសុគតិ សួគ៌ទេវលោក ព្រោះកុសលកម្មដែលព្រះតថាគត

បានធ្វើសន្សំ បណ្តុះបណ្តាល ឲ្យធំទូលាយនោះឯង ។ ព្រះតថាគតតែងគ្រប សង្កត់នូវទេវតាឯទៀត ក្នុងឋានសួគ៌នោះ ដោយហេតុ ១០ ប្រការ ។បេ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈនេះ គឺត្រង់ផ្ទៃជើងទាំងគូខាងក្រោមមានរូបចក្រ ប្រកបដោយខ្នងកង់ និងដុំព្រមទាំងកាំ ១០០០ មានចន្លោះស្មើគ្នាគ្រប់អន្លើ ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ។បេ។ បើបានជាស្តេចហើយ តើនឹងបានរបស់អ្វី ទើបជាអ្នកមានបរិវារច្រើន ឯបរិវារច្រើនរបស់ស្តេចនោះ គឺព្រាហ្មណ៍ គហបតី អ្នកនិគម អ្នកជនបទ ពួកស្មៀន និងមហាមាត្យ ពួកសេនាមានអង្គ ៤ ( មានសេនាដំរីជាដើម ) អ្នករក្សាទ្វារ អាមាត្យ ពួកបរិស័ទ ស្តេច (ចំណុះ ) ពួកអ្នកមានទ្រព្យ និងពួករាជកុមារ កាលបើបានជាស្តេច នឹងបានរបស់នេះ ។ បើចេញចាកគេហដ្ឋានទៅបួស នឹងបានត្រាស់ជាព្រះអរហន្តសម្មាសម្ពុទ្ធក្នុងលោក មានដំបូល គឺកិលេសបើកចេញហើយ កាលបើបានត្រាស់ជាព្រះពុទ្ធហើយ តើបានរបស់អ្វី ទើបជាអ្នកមានបរិវារច្រើន ឯបរិវារច្រើនរបស់ព្រះពុទ្ធនោះ គឺពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ទេវតា មនុស្ស អសុរ នាគ គន្ធព្វ កាលបើបានត្រាស់ជាព្រះពុទ្ធ បាននូវបរិស័ទនេះ ។ លុះព្រះមានព្រះភាគ បានត្រាស់សេចក្តីនេះចប់ហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[ ៦ ] ព្រះតថាគតកើតជាមនុស្សក្នុងកាលពីមុនៗ ជាតិ

ពីមុនៗ ជាអ្នកនាំនូវសេចក្ដីសុខមកឲ្យដល់ជនច្រើននាក់ ជាអ្នកបន្ទោបង់នូវភ័យ គឺសេចក្ដីភ្ញាក់ផ្អើល និងសេចក្ដីតក់ស្លុត ជាអ្នកខ្វល់ខ្វាយក្នុងការគ្រប់គ្រង ការរក្សាការពារ ។ ព្រោះកម្មនោះ ព្រះតថាគត បានទៅកាន់ឋានសួគ៌ ហើយសោយសេចក្ដីសុខ សេចក្ដីសម្រាន្ត និងសេចក្ដីត្រេកអរ លុះព្រះតថាគតច្យុត ចាកឋានសួគ៌នោះ មកកើតក្នុងមនុស្សលោកនេះទៀត ក៏បានទូវចក្រត្រង់ផ្ទៃជើងទាំងពីរ ប្រកបដោយខ្នងកង់ និងដុំ ព្រមទាំងកាំ ១០០០ មានចន្លោះស្មើគ្នា ។ ពួកជនអ្នកស្គាល់លក្ខណៈ បានឃើញរាជកុមារដែលមានលក្ខណៈនៃបុណ្យច្រើន ( យ៉ាងនេះ ) ទើបព្រមគ្នាព្យាករថា ( ព្រះរាជកុមារនេះ ) នឹងមានបរិវារច្រើន អាចញាំញីនូវសត្រូវបាន ដូចជាចក្រដែលមានខ្នងកង់ ( និងដុំ ព្រមទាំងកាំ ១០០០ ) មានចន្លោះស្មើគ្នាដូច្នោះឯង ។ បើព្រះរាជកុមារ ( ដែលប្រកបដោយលក្ខណៈ ) ដូច្នោះ មិនបានចេញទៅទ្រង់ព្រះផ្នួសទេ នឹងបានជាស្ដេចចក្រពត្តិ ទ្រង់ប្រាបប្រាមផែនដី មានពួកក្សត្រដែលចុះចូល មានយសសក្តិធំ ទៅតាមហែហមព្រះរាជ-កុមារនោះក្នុងទីនេះ ។ បើព្រះរាជកុមារ (ដែលប្រកបដោយលក្ខណៈ) ដូច្នោះ ចេញទៅទ្រង់ព្រះផ្នួស តែងពេញចិត្ត

ត្រេកអរចំពោះនេក្ខម្មៈ នឹងបានជាអ្នកប្រាជ្ញ មានទេវតា
មនុស្ស អសុរ ព្រះឥន្ទ្រ អារក្ស គន្ធព្វ នាគ សត្វបក្សី
សត្វជើង ៤ ដែលមានយសសក្តិធំ ចោមរោមព្រះពុទ្ធ
ដ៏ប្រសើរ ដែលទេវតា និងមនុស្ស បូជាហើយនោះ ។

[ ៧ ] ម្នាលភិក្ខុទាំងឡាយ កាលតថាគតអាស្រ័យនូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកបានលះបង់បាណាតិបាត វៀរស្រឡះចាកបាណាតិបាត ជាអ្នកដាក់ចុះនូវអាជ្ញា និងគ្រឿងសស្ត្រាវុធ មានសេចក្តីខ្មាសបាប មានចិត្តអាសូរករុណា តែងអនុគ្រោះសព្វសត្វដោយប្រយោជន៍ ។ ព្រះតថាគតនោះ ព្រោះបានធ្វើនូវកុសលកម្មនោះ ។បេ។ លុះព្រះតថាគតនោះច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំង ៣ នេះ គឺជាអ្នកមានកែងជើងវែង ១ មានម្រាមដៃ និងម្រាមជើងវែងៗ ១ មានកាយត្រង់ដូចជាកាយព្រហ្ម ១ ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈ ( ទាំង ៣ ) នោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ។បេ។ បើបានជាស្តេចហើយ តើនឹងបាននូវរបស់អ្វី គឺនឹងបានជាអ្នកមានអាយុវែង ប្រតិស្ឋាននៅអស់កាលយូរ គ្រប់គ្រងនូវជន្មាយុ ឲ្យរស់នៅបានយូរ មនុស្សជាសឹកសត្រូវ និងបច្ចាមិត្តណាមួយ មិនអាចនឹងផ្តាច់បង់ជីវិតត្រង់រវាងអាយុបានទេ កាលបើបានជាស្តេច នឹងបានរបស់នេះឯង ។បេ។ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងបានជាអ្នកមានអាយុវែង ប្រតិស្ឋាននៅអស់កាលយូរ គ្រប់

គ្រងជន្មាយុរស់នៅបានយូរ សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី អ្នកណាមួយក្តី ជាសឹកសត្រូវ ជាបច្ចាមិត្ត ក្នុងលោកនេះ មិនអាចនឹងផ្តាច់បង់ជីវិតត្រង់រវាងអាយុបានឡើយ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបាននូវរបស់នេះឯង ។ លុះព្រះមានព្រះភាគ បានត្រាស់សេចក្តីនេះរួចហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[ ៨ ] ព្រះតថាគតដឹងច្បាស់ នូវភ័យអំពីសេចក្តីស្លាប់
ដែលហៅថា មរណៈចំពោះខ្លួនឯងហើយ បានវៀរស្រឡះ
ចាកការសម្លាប់នូវសត្វដទៃ ព្រោះអំពើសុចរិតនេះឯង ព្រះ
តថាគតនោះ បានទៅកើតក្នុងឋានសួគ៌ សោយផលវិបាក
របស់កម្មដែលបានធ្វើទុកល្អហើយ ។ លុះច្យុតចាក ( ឋាន
សួគ៌ ) នោះ មកកើតក្នុងមនុស្សលោកនេះទៀត ក៏បាននូវ
លក្ខណៈទាំង ៣ នេះ ក្នុងភពនេះ គឺជាអ្នកមានកែងជើង
វែងទូលាយ ១ មានកាយត្រង់ល្អស្អាត ដូចជាកាយព្រហ្ម
១ ។ មានភ្នែនល្អ មានរូបនៅក្មេង មានទ្រង់ទ្រាយល្អ
មានជាតិល្អ មានអង្គុលិរបស់ព្រះតថាគតនោះ ទន់ល្វន់
វែងល្អ ព្រះតថាគត ប្រកបដោយមហាបុរិសលក្ខណៈ ៣
( នេះ ) ដើម្បីញុំាងជីវិត ឲ្យប្រព្រឹត្តទៅអស់កាលយូរ
ប្រហែលដូចជានៅក្មេង ។ បើព្រះតថាគត នៅជាគ្រហស្ថ
តែងញុំាងជីវិតឲ្យរស់នៅអស់កាលយូរ បើចេញទៅបួស

នឹងញុំាងជីវិតឲ្យរស់នៅ អស់កាលយូរជាងនោះទៅទៀត ព្រះតថាគតជាអ្នកស្ទាត់ជំនាញ រមែងញុំាងជីវិតឲ្យរស់នៅ ដោយការចម្រើនឫទ្ធិ លក្ខណៈទាំង ៣ នោះ ជានិមិត្តរូប នៃទីឃាយុភាពយ៉ាងនេះឯង ។

[ ៩ ] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ( អាស្រ័យ ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកឲ្យនូវខាទនីយភោជនីយាហារ មានរសជាតិដ៏ថ្លៃថ្លា ព្រមទាំងទឹក ( ៨ ប្រការ ) ដែលគួរភ្លក្ស គួរលិទ្ធ ។ ព្រះតថាគតនោះ ព្រោះបានធ្វើសន្សំកុសលកម្មនោះ ។បេ។ លុះបែកធ្លាយរាងកាយខាងមុខអំពីមរណៈ ក៏បានទៅកើតក្នុងសុគតិសួគ៌ទេវលោក ។បេ។ លុះព្រះតថាគតនោះច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈនេះ គឺជាអ្នកមានសាច់ដ៏ពេញក្នុងទីទាំង ៧ អន្លើ គឺសាច់ពេញត្រង់ខ្នងដៃទាំងពីរ សាច់ពេញត្រង់ខ្នងជើងទាំងពីរ សាច់ពេញត្រង់ចង្កូយស្មាទាំងពីរ សាច់ពេញត្រង់ក ។ ព្រះតថាគតនោះប្រកបដោយលក្ខណៈនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ។បេ។ កាលបើបានជាស្តេចហើយ តើនឹងបានរបស់អ្វី គឺនឹងបាននូវខាទនីយភោជនីយាហារ មានរសជាតិដ៏ថ្លៃថ្លា ព្រមទាំងទឹក ( ៨ ប្រការ ) ដែលគួរភ្លក្ស គួរលិទ្ធ បើបានជាស្តេចនឹងបាននូវរបស់នេះឯង ។បេ។ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងបាននូវខាទនីយ-ភោជនីយាហារ មានរសជាតិដ៏ថ្លៃថ្លា ព្រមទាំងទឹក ( ៨ ប្រការ ) ដែលគួរ

ភ្ញក្ស គួរលិទ្ធ កាលបើបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគបានត្រាស់សេចក្តីនេះរួចហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[ ១០ ] ព្រះតថាគត ជាអ្នកឲ្យនូវខាទនីយភោជនីយាហារ និងទឹកដែលគួរលិទ្ធ គួរភ្ញក្ស ដែលមានរសជាតិដ៏ឧត្តមថ្លៃថ្លា ព្រោះកម្មជាសុចរិតនោះ ព្រះតថាគតនោះ ទើបរីករាយក្នុងនន្ទវ័ន ( ឧទ្យាន ) អស់កាលយូរ ។ ( លុះច្យុតមកកើត ) ក្នុងមនុស្សលោកនេះ ក៏បាននូវសាច់ដ៏ពេញក្នុងទីទាំង ៧ អន្ទើផង បាននូវផ្នែដៃ និងផ្នែជើង ដ៏ទន់ល្វន់ផង ជនទាំង-ឡាយដែលជាអ្នកឈ្លាស ក្នុងការទាយនូវព្យញ្ជនៈ និងនិមិត្ត នាំគ្នាទាយ ( ព្រះតថាគត ) ព្រោះហេតុដែលព្រះតថាគតបានឲ្យនូវខាទនីយភោជនីយាហារ ទើបបាននូវខាទនីយ-ភោជនីយាហារ មានរស ( ជាតិដ៏ថ្លៃថ្លា ) ។ លក្ខណៈនោះ មិនមែនជាគ្រឿងឆ្កុះបំភ្លឺសេចក្តីដល់ព្រះតថាគត ដែលនៅជាគ្រហស្ថប៉ុណ្ណោះទេ ទោះបីតថាគតចេញទៅបួស ក៏គង់បានទទួលផលនោះដែរ អ្នកដែលបាននូវខាទនីយ-ភោជនីយាហារ មានរសជាតិដ៏ឧត្តម ហៅថា អ្នកកាត់បង់នូវចំណងរបស់គ្រហស្ថទាំងអស់បាន ។

[ ១១ ] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ( អាស្រ័យ ) នូវ ជាតិ

ពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកបានសង្គ្រោះដល់ពពួកជន ដោយសង្គហវត្ថុ ៤ ប្រការ គឺទាន ១ ពាក្យជាទីស្រឡាញ់ ១ ការប្រព្រឹត្តដែលជាប្រយោជន៍ ១ ការតាំងខ្លួនស្មើ គឺមិនប្រកាន់ខ្លួន ១ ។ ព្រះតថាគតនោះ លុះបែកធ្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ ក៏បានទៅកើតក្នុងសុគតិសួគ៌ទេវលោក ព្រោះកុសលកម្ម ដែលព្រះតថាគតបានធ្វើសន្សំ បណ្តុះបណ្តាល ឲ្យធំទូលាយនោះឯង ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បានទូវមហាបុរិសលក្ខណៈទាំងពីរនេះ គឺជាអ្នកមានផ្ទៃដៃ និងផ្ទៃជើងទន់ល្មន់ ( ដូចជាសំឡីដែលគេជ្រួចអស់ ១០០ ដង ) ១ មានផ្ទៃដៃ និងផ្ទៃជើង ប្រទាក់ដោយក្រឡា ដូចជាសំណាញ់ ១ ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈទាំងពីរនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ។បេ។ កាលបើបានជាស្តេចហើយ តើនឹងបានទូវរបស់អ្វី គឺនឹងបានជាអ្នកសង្គ្រោះទូវជនជាបរិស័ទ ជនបរិស័ទដែលព្រះតថាគតបានសង្គ្រោះនោះ គឺពួកព្រាហ្មណ៍ គហបតី អ្នកនិគម អ្នកជនបទ ពួកស្មៀន មហាមាត្យ ពួកសេនាមានអង្គ ៤ ( មានសេនាដំរីជាដើម ) ឆ្មាំទ្វារ អាមាត្យ រាជបរិស័ទ ស្តេចចំណុះ អ្នកមានភោគៈ និងរាជកុមារ កាលបើព្រះតថាគតនៅជាស្តេច នឹងបានរបស់នេះឯង ។បេ។ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានទូវរបស់អ្វី គឺនឹងបានជាអ្នកសង្គ្រោះទូវជនជាបរិស័ទ ជនជាបរិស័ទដែលព្រះតថាគតបានសង្គ្រោះនោះ គឺពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ទេវតា មនុស្ស អសុរ នាគ គន្ធព្វ កាល

បើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគត្រាស់សេចក្តីនេះរួចហើយ ។ ទើបទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[ ១២ ] ព្រះតថាគត បានធ្វើ បានប្រព្រឹត្តការសង្គ្រោះដោយល្អ ដល់ពួកជនច្រើននាក់ ( ដោយសង្គហវត្ថុ ៤ ប្រការ ) គឺទាន ១ ការប្រព្រឹត្តដែលជាប្រយោជន៍ ១ ពាក្យជាទីស្រឡាញ់ ១ សេចក្តីពេញចិត្តក្នុងការតាំងខ្លួនស្មើ ១ ទើបទៅកាន់ឋានសួគ៌ដោយគុណ គឺសេចក្តីមិនប្រមាទ ។ លុះព្រះតថាគត ( ច្យុតចាកឋានសួគ៌នោះ ) មកកើតក្នុងភពនេះទៀត ជាមនុស្សកំលោះ នៅក្មេងល្អ ក៏បាននូវអំពើដែលគួរធ្វើ គួរប្រព្រឹត្តទន់ភ្លន់ផង បាននូវសេចក្តីរុងរឿង សេចក្តីឈ្លាសវៃក្រៃលែង និងរូបដែលគួរឲ្យអ្នកផងពិតពិលរមិលមើល ដើម្បីចេញចាកសំណាញ់ពោល គឺសង្សារ ។ ព្រះតថាគត បានចាត់ចែងការងារបានគ្រប់គ្រងនូវផែនដីធំនេះ និងការសង្គ្រោះដោយល្អចំពោះជនជាបរិស័ទ ពោលពាក្យជាទីស្រឡាញ់ ស្វែងរកនូវប្រយោជន៍ និងសេចក្តីសុខ អើពើតែនឹងគុណដែលខ្លួនគាប់ចិត្តដ៏ក្រៃលែង ។ បើព្រះតថាគត លះបង់នូវការបរិភោគកាមគ្រប់យ៉ាងហើយ ( ចេញទៅបួស ) នឹងបាន

ជាព្រះជិនស្រី សម្តែងនូវធម្មកថាដល់ជនជាបរិស័ទ ពួក
ជនជាបរិស័ទដែលបានស្តាប់ធម្មកថានោះ ក៏ជ្រះថ្លា ហើយ
ធ្វើតាមពាក្យនៃព្រះតថាគតនោះ ទើបនាំគ្នាប្រព្រឹត្តនូវធម៌
ដ៏សមគួរដល់ធម៌ ។

[ ១៣ ] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ( អាស្រ័យ ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកបានពោលពាក្យប្រកបដោយប្រយោជន៍ ទាំងប្រកបដោយធម៌ បានពន្យល់ជនច្រើននាក់ តែងនាំមកនូវប្រយោជន៍ និងសេចក្តីសុខ ឲ្យដល់សត្វទាំងឡាយ ជាអ្នកបូជានូវធម្មទាន ។ ព្រោះកុសលកម្មដែលព្រះតថាគតបានធ្វើ សន្សំឲ្យធំទូលាយហើយនោះ ព្រះតថាគតនោះ ។បេ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំងពីរនេះ គឺជាអ្នកមានកជើងដូចជាអណ្តែតឡើងខាងលើ ១ មានចុងរោមងឡើងលើ ១ ។ ព្រះតថាគតនោះប្រកបដោយលក្ខណៈទាំងពីរនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ។បេ។ កាលបើព្រះតថាគតនៅសោយរាជ្យ នឹងបានរបស់អ្វី គឺនឹងបានជាចម្បង ប្រសើរ ជាប្រធាន ឧត្តម បវរ ជាងពួកជនដែលបរិភោគកាម កាលបើព្រះតថាគតនៅសោយរាជ្យ នឹងបានរបស់នេះឯង ។បេ។ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងបានជាចម្បង ប្រសើរ ជាប្រធាន ឧត្តម បវរ ជាងពួកសត្វទាំងអស់ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹង

បានរបស់នេះឯង ។ ព្រះមានព្រះភាគត្រាស់សេចក្តីនេះរួចហើយ ។ ទើបទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[ ១៤ ] ក្នុងភពពីមុន ព្រះតថាគតបានពោលពាក្យដែលប្រកបដោយអត្ថ ទាំងប្រកបដោយធម៌ បានពន្យល់ប្រយោជន៍ដល់ជនច្រើននាក់ ជាអ្នកបាននាំមកនូវប្រយោជន៍ និងសេចក្តីសុខ ឲ្យដល់សត្វទាំងឡាយ ជាអ្នកមិនមានសេចក្តីកំណាញ់ បានចាត់ចែងនូវការបូជាធម្មទាន ។ ព្រះតថាគតនោះ បានទៅកាន់ឋានសុគតិ រីករាយក្នុងឋានសុគតិនោះ ព្រោះកម្មជាសុចរិតនោះឯង ( លុះច្យុតចាកឋានសួគ៌នោះ ) មកកើតក្នុងភពនេះ ក៏បាននូវលក្ខណៈទាំងពីរ ដើម្បីភាពនៃសេចក្តីសុខដ៏ឧត្តម ។ ព្រះតថាគតមានចុងពេមងឡើងលើ មានសន្ទាក់កជើងប្រតិស្ឋានល្អ មានសាច់ និងឈាមប្រផូរ បិទបាំងដោយស្បែក មានជង្គង់ល្អ ។ ព្រះតថាគត បានប្រកបដោយលក្ខណៈដូច្នោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាអ្នកខ្ពង់ខ្ពស់ ជាងពួកជនអ្នកបរិភោគកាម មិនមានអ្នកដទៃក្រៃលែង ជាងព្រះតថាគតនោះបានឡើយ ព្រះតថាគត តែងគ្របសង្កត់នូវជម្ពូទ្វីប ( ទាំងមូល ) ។ សូម្បីបព្វជ្ជា ( របស់ព្រះតថាគត ) ក៏មិនថយថោកឡើយ តែងដល់នូវភាពជាអ្នក

ខ្ពង់ខ្ពស់ជាងពួកសត្វទាំងអស់ មិនមានសត្វឯទៀតលើស
លុបជាងព្រះតថាគតនោះឡើយ ព្រះតថាគតជាអ្នកគ្រប
សង្កត់នូវសត្វលោកទាំងអស់ ។

[ ១៥ ] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ( អាស្រ័យ ) នូវ ជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នក បង្ហាញនូវសិល្បសាស្រ្ត ( ថោកទាប និងសិល្បសាស្រ្តឧត្តម ) ផង នូវ វិជ្ជា ( ច្រើនប្រការ មានវិជ្ជាស្តោះពស់ជាដើម ) ផង នូវចរណៈ គឺសីល ៥ សីល ៨ ឬសីល ១០ ឬបាតិមោក្ខសំវរសីលផង នូវការងារផង ដោយយកចិត្តទុកដាក់ ដោយតាំងចិត្តថា ធ្វើដូចម្តេចហ្ន៎ ពួកជននេះ បាន ចេះដឹងឆាប់ បានទទួលសេចក្តីប្រតិបត្តិឆាប់ កុំឲ្យលំបាកអស់កាលជាយូរ អង្វែងឡើយ ។ ព្រះតថាគតនោះ ព្រោះបានធ្វើ សន្សំនូវកុសលកម្មនោះ ។បេ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈនេះ គឺជាអ្នកមានស្មងរៀវមូលត្រសូលស្រដៀង នឹងស្មងសត្វទ្រាយ ។ ព្រះតថាគតនោះ ប្រកបហើយដោយលក្ខណៈនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ។បេ។ កាលបើព្រះ តថាគតនៅសោយរាជ្យ នឹងបានរបស់អ្វី គឺនឹងបាននូវរាជវាហនៈដ៏សមគួរ ដល់ស្តេច និងវាហនៈជាអង្គនៃរាជសេនា និងគ្រឿងរាជូបភោគដ៏សមគួរដល់ ស្តេចដោយឆាប់រហ័ស កាលបើព្រះតថាគតនៅសោយរាជ្យ នឹងបានរបស់ នេះឯង ។បេ។ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី

គឺនឹងបានទូវបច្ច័យ ដ៏សមគួរដល់សមណៈ និងបរិស័ទដែលជាអង្គរបស់សមណៈ និងគ្រឿងសមណូបភោគ ដ៏សមគួរដល់សមណៈ ដោយឆាប់រហ័ស កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគ ត្រាស់នូវសេចក្ដីនេះរួចហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[ ១៦ ] ព្រះតថាគតតែងប្រាថ្នាដូច្នេះថា ធ្វើម្ដេចហ្ន៎ ជនទាំងឡាយនេះ នឹងចេះដឹងនូវសិល្បសាស្ត្រ វិជ្ជា ចរណៈ និងការងារទាំងឡាយ បានដោយឆាប់រហ័ស ឯសិល្បសាស្ត្រណា មិនបៀតបៀនដល់អ្នកណាមួយ ព្រះតថាគតបង្រៀននូវសិល្បសាស្ត្រនោះ យ៉ាងឆាប់រហ័ស មិនឲ្យលំបាកអស់កាលយូរឡើយ ។ ព្រោះព្រះតថាគត បានធ្វើកុសលកម្មនោះ ដែលជាកម្មញុំាងសុខឲ្យចម្រើន ទើបបាននូវស្មងដ៏ល្អ មានរបៀបរៀបរយល្អ ព្រះតថាគតមានចុងរោមងឡើងលើ វិលជាទក្ខិណាវដ្ដ ដុះឡើងល្អ ប្រាងឡើងលើទៅតាមលំដាប់ ទាំងមានស្បែកកាយដ៏ល្អិតម៉ដ្ឋព័ទ្ធជុំវិញ ។ បុគ្គលដែលប្រកបដោយលក្ខណៈ ដូច្នោះ អ្នកប្រាជ្ញទាំងឡាយពោលថា មានព្រះជង្ឃាវៀវមូល ដូចជាស្មងសត្វទ្រាយ ឯរោមមួយៗ ( ក៏ដុះឡើងល្អ ) ព្រះតថាគតប្រាថ្នានូវសម្បត្តិណា សម្បត្តិនោះ ទោះបីព្រះ-

តថាគតមិនបានបព្វជ្ជា ក៏គង់បានធាប់ក្នុងលោកនេះ ។ បើបុគ្គល ( មានលក្ខណៈ ) ដូចព្រះតថាគតនោះ ចេញទៅបួស នឹងបានជាអ្នកប្រាជ្ញ មានសេចក្ដីពេញចិត្ត ត្រេកអរចំពោះនេក្ខម្មៈ ជាអ្នកមានសេចក្ដីព្យាយាម មិនថោកថយឡើយ តែងបាននូវសម្បត្តិដ៏សមគួរដល់បុគ្គល ដែលមានសភាពដ៏សមគួរ ។

[ ១៧ ] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ( អាស្រ័យ ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកចូលទៅរកសមណព្រាហ្មណ៍ ហើយសាកសួរថា បពិត្រលោកដ៏ចម្រើន អំពើដូចម្ដេចជាកុសល អំពើដូចម្ដេចជាអកុសល អំពើដូចម្ដេចដែលប្រកបដោយទោស អំពើដូចម្ដេចដែលមិនប្រកបដោយទោស អំពើដូចម្ដេចគួរសេព អំពើដូចម្ដេច មិនគួរសេព អំពើដូចម្ដេចដែលខ្ញុំធ្វើហើយ ប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីទុក្ខអស់កាលយូរអង្វែង មួយទៀត អំពើដូចម្ដេចដែលខ្ញុំធ្វើហើយ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ អស់កាលយូរអង្វែង ។ ព្រះតថាគតនោះ ព្រោះបានធ្វើសន្សំកសាងនូវកុសលកម្មនោះ ។បេ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈនេះ គឺជាអ្នកមានឆវី ( សម្បុរថ្ងៃ ) ដ៏ល្អិតផូរផង់ រលីងស្រិលរអិលធូលីធ្លាក់មកត្រូវមិនជាប់កាយ ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្ដេច

ចក្រពត្តិ ។បេ។ កាលបើព្រះតថាគតនៅសោយរាជ្យ នឹងបានរបស់អ្វី គឺនឹងបានជាអ្នកមាន ប្រាជ្ញាច្រើន បណ្តាអ្នកបរិភោគកាមទាំងឡាយ នឹងរកអ្នកណាមួយឲ្យមាន ប្រាជ្ញាប្រហែល ឬប្រសើរវិសេស ជាងបញ្ញារបស់ព្រះតថាគតនោះគ្មានឡើយ កាលបើព្រះតថាគតនៅសោយរាជ្យ នឹងបានរបស់នេះឯង ។បេ។ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងបានជាអ្នកមានប្រាជ្ញាច្រើន មានប្រាជ្ញាក្រាស់ មានប្រាជ្ញារីករាយ មានប្រាជ្ញារហ័ស មានប្រាជ្ញាដ៏មោះមុត មានប្រាជ្ញាជាគ្រឿងសង្កត់សង្កិន ឬទម្លាយ ( នូវគំនរកិលេស មានលោភៈជាដើម ) បណ្តាសត្វទាំងពួង នឹងរកសត្វណាមួយឲ្យមានប្រាជ្ញាស្មើ ឬប្រសើរវិសេស ជាងបញ្ញារបស់ព្រះតថាគតនោះគ្មានឡើយ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធនឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគត្រាស់សេចក្តីនេះរួចហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[ ១៨ ] ក្នុងកាលមុន ភពមុន ជាតិពីមុន ព្រះតថាគតជាអ្នកចង់ចេះដឹង បានចូលទៅរកបព្វជិត ហើយសាកសួរ ( នូវប្រស្នា ) បានស្តាប់ដោយគោរព ធ្វើសេចក្តីឲ្យតាំងនៅខាងក្នុង ហើយចំណាំនូវពាក្យ ដែលប្រកបដោយប្រយោជន៍តែមួយយ៉ាង ។ ព្រោះកម្មដែលប្រព្រឹត្តទៅ ដើម្បីបាននូវប្រាជ្ញា ( នោះ ) ទើបព្រះតថាគត កើតមកជាមនុស្សមានឆវីដ៏ល្អិតផូរផង់ ពួកអ្នកប្រាជ្ញ ឈ្លាសក្នុងការ

ទាយនូវឧប្បាត និងនិមិត្តនាំគ្នាទាយថា ព្រះតថាគតនឹង
ពិចារណាឃើញច្បាស់ នូវអត្ថដ៏ល្អិតសុខុមទាំងឡាយបាន ។
បើបុគ្គល ( មានលក្ខណៈ ) ដូចព្រះតថាគតនោះ មិន
បានចេញទៅបព្វជ្ជាទេ ក៏គង់ញុំាងចក្រឲ្យប្រព្រឹត្តទៅ នឹង
គ្រប់គ្រងផែនដីបាន បណ្ដាពួកអ្នកប្រៀនប្រដៅនូវអត្ថ និង
ពួកអ្នកកំណត់កត់ចាំ ( នូវអត្ថ ) នឹងរកបុគ្គលណាមួយ
ឲ្យត្រឹមស្មើ ឬប្រសើរជាងព្រះតថាគតនោះគ្មានឡើយ ។
បើបុគ្គល ( មានលក្ខណៈ ) ដូចព្រះតថាគតនោះ ចេញ
ទៅបព្វជ្ជា នឹងបានជាអ្នកប្រាជ្ញ មានសេចក្ដីពេញចិត្ត ទាំង
ត្រេកអរក្នុងនេក្ខម្មៈ ជាអ្នកមានប្រាជ្ញាដ៏ប្រសើរ ប្រៀប
ដោយផែនដី នឹងបានដល់ពោធិញ្ញាណដ៏ខ្ពង់ខ្ពស់ មាន
ចំណែកដ៏ប្រសើរក្នុងផ្លូវប្រាជ្ញា ។

[ ១៩ ] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ( អាស្រ័យ ) នូវ
ជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកមិន
មានសេចក្ដីក្រោធ មិនច្រើនដោយសេចក្ដីចង្អៀតចង្អល់ចិត្ត សូម្បីជនច្រើន
នាក់ នាំគ្នាស្ដីថាឲ្យ ក៏មិនឈឺចិត្ត មិនក្រោធ មិនចងកំហឹងទុក មិនតម្កល់
ទុកនូវសេចក្ដីក្រោធ ទាំងមិនបានធ្វើនូវសេចក្ដីក្រោធ នូវការប្រទូស្ត និង
សេចក្ដីតូចចិត្តឲ្យប្រាកដឡើង ( ដោយកាយវិការ ឬវចីវិការ ) ឡើយ ព្រះ
តថាគតជាអ្នកបានឲ្យនូវកម្រាល និងសំពត់ដណ្ដប់មានសាច់ល្អិតទន់ល្មើ គឺ

សំពត់ធ្វើពីសម្បកឈើ មានសាច់ម៉ដ្ឋ សំពត់ធ្វើពីកប្បាសមានសាច់ម៉ដ្ឋ សំពត់ធ្វើពីសូត្រមានសាច់ម៉ដ្ឋ សំពត់ធ្វើពីរោមសត្វមានសាច់ម៉ដ្ឋ ។ ព្រះតថាគតនោះ ព្រោះបានធ្វើសន្សំនូវកុសលកម្មនោះ ។បេ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈនេះ គឺជាអ្នកមានពណ៌សម្បុរ ( លឿងភ្លឺបំព្រង ) ដូចជាសម្បុរនៃមាស និងមានស្បែកជិតស្និទ្ធល្អដូចជាមាស ។ ព្រះតថាគតនោះប្រកបដោយលក្ខណៈនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ។បេ។ កាលបើព្រះតថាគតនៅសោយរាជ្យ នឹងបានរបស់អ្វី គឺនឹងបាននូវកម្រាល និងសំពត់ដណ្តប់ មានសាច់ល្អិតទន់ល្មៃ គឺសំពត់ធ្វើដោយសម្បកឈើមានសាច់ម៉ដ្ឋ សំពត់ធ្វើដោយកប្បាសមានសាច់ម៉ដ្ឋ សំពត់ធ្វើដោយសូត្រមានសាច់ម៉ដ្ឋ សំពត់ធ្វើដោយរោមសត្វមានសាច់ម៉ដ្ឋ កាលបើព្រះតថាគតនៅសោយរាជ្យ នឹងបានរបស់នេះឯង ។បេ។ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងបាននូវកម្រាល និងសំពត់មានសាច់ល្អិតទន់ល្មៃ គឺសំពត់ធ្វើដោយសម្បកឈើមានសាច់ម៉ដ្ឋ សំពត់ធ្វើដោយកប្បាសមានសាច់ម៉ដ្ឋ សំពត់ធ្វើដោយសូត្រមានសាច់ម៉ដ្ឋ សំពត់ធ្វើដោយរោមសត្វមានសាច់ម៉ដ្ឋ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគ បានត្រាស់សេចក្តីនេះរួចហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[ ២០ ] ព្រះតថាគត តាំងទុកនូវសេចក្តីមិនក្រោធផង នូវ

ទានផង ហើយបានឲ្យនូវសំពត់ទាំងឡាយ មានសាច់ម៉ដ្ត មានពណ៌ស្រស់ ព្រះតថាគត ឋិតនៅក្នុងភពពីមុន បានបរិច្ចាគ ( ទាន ) ហាក់ដូចជាទឹកភ្លៀង ដែលធ្លាក់ចុះមកលើផែនដីដូច្នោះឯង ។ ព្រះតថាគត ព្រោះបានធ្វើនូវកុសលកម្មនោះ លុះច្យុតចាកអត្តភាពនេះហើយ ចូលទៅកាន់ទិព្វវិមាន បានសោយផលវិបាកនៃអំពើដែលខ្លួនបានធ្វើហើយ ជាអ្នកមានខ្លួនដូចជាមាស ( លុះមកកើត ) ក្នុងភពនេះ បានគ្របសង្កត់ ( នូវមនុស្សទាំងអស់ ) ហាក់ដូចជាព្រះឥន្ទ្រ ដែលប្រសើរជាងពួកទេវតា ដូច្នោះឯង ។ បើព្រះតថាគតនៅជាមនុស្ស គ្រប់គ្រងគេហដ្ឋាន មិនប្រាថ្នានឹងបួសទេ ក៏គង់តែបានគ្រប់គ្រងនូវផែនដីធំ គ្របសង្កត់ ( នូវពួកបច្ចាមិត្ត ) ព្រមទាំងបាននូវរតនៈ ៧ ប្រការក្នុងលោកនេះផង បាននូវសំពត់ដ៏ធំទូលាយ មានសាច់ល្អិតម៉ដ្ត មានសម្បុរស្រស់ស្អាតផង ។ បើព្រះតថាគតចេញទៅទ្រង់ព្រះផ្នួស នឹងបានសំពត់សម្រាប់ស្លៀក និងសំពត់សម្រាប់ដណ្តប់ដ៏ប្រសើរ ព្រះតថាគត រមែងបានសោយផលរបស់កម្ម ដែលបានទំនុកបម្រុងល្អហើយ និងបានធ្វើទុកមកពីជាតិមុន សេចក្តីវិនាសនៃកម្ម ដែលព្រះតថាគតធ្វើនោះ មិនមានឡើយ ។

[ ២១ ] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ( អាស្រ័យ ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកបានរាប់អាននូវញាតិមិត្ត សម្លាញ់ស្និទ្ធស្នាល ដែលព្រាត់ប្រាសនិរាស បាត់មុខយូរហើយផង ជាអ្នករាប់អានមាតា ព្រមទាំងកូនផង រាប់អាននូវកូន ព្រមទាំងមាតាផង រាប់អានបិតា ព្រមទាំងកូនផង រាប់អានកូន ព្រមទាំងបិតាផង រាប់អានបិតា ព្រមទាំងបងប្អូនប្រុស រាប់អានបងប្អូនប្រុស ព្រមទាំងបងប្អូនស្រីផង រាប់អានបងប្អូនស្រី ព្រមទាំងបងប្អូនប្រុសផង ហើយជាអ្នកត្រេកអរក្រៃលែង ព្រោះបានធ្វើគេឲ្យព្រមព្រៀងគ្នាផង ។ ព្រះតថាគតនោះ ព្រោះបានធ្វើនូវកុសលកម្មនោះ ។បេ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជា មនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈនេះ គឺថា ជាអ្នកមានអង្គាវយវៈ ដែលត្រូវលាក់ឲ្យកំបាំងដោយសំពត់ ឋិតនៅក្នុងស្រោម ( ដូចជាអង្គជាតនៃដំរី ) ។ ព្រះតថាគតនោះ ប្រកបដោយ លក្ខណៈនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ។បេ។ កាលបើព្រះតថាគតនៅសោយរាជ្យ នឹងបានរបស់អ្វី គឺនឹងបានជាអ្នកមានបុត្រច្រើន ឯបុត្ររបស់ព្រះតថាគតនោះ មានចំនួនច្រើនពាន់ សុទ្ធសឹងតែជាអ្នកក្លៀវក្លា អង់អាច អាចញាំញីនូវសេនារបស់ស្តេចដទៃបាន កាលបើព្រះតថាគតនៅសោយរាជ្យ នឹងបានរបស់នេះឯង ។បេ។ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងបានជាអ្នកមានបុត្រច្រើន ឯបុត្ររបស់ព្រះតថាគតនោះចំនួនច្រើនពាន់ សុទ្ធសឹងតែជាអ្នកក្លៀវក្លា អង់អាច អាចញាំញី

នូវសេនារបស់ស្តេចឯទៀតបាន កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគបានត្រាស់សេចក្តីនេះរួចហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងកម្មជាដើមនោះថា

[ ២២ ] ក្នុងកាលពីមុន ភពពីមុន ជាតិពីមុន ព្រះតថាគត រាប់អាននូវញាតិ មិត្ត និងសម្លាញ់ស្និទ្ធស្នាល ដែលព្រាត់ប្រាស និរាសបាត់មុខ អស់កាលយូរហើយផង ជាអ្នកត្រេកអរក្រៃលែង ព្រោះបានធ្វើគេឲ្យព្រមព្រៀងគ្នាផង ។ ព្រោះកម្មនោះ ព្រះតថាគតបានទៅកាន់ឋានសួគ៌ សោយសេចក្តីសុខ សេចក្តីសម្រាន្ត និងសេចក្តីត្រេកអរ លុះច្យុតចាកឋានសួគ៌នោះ មកកើតក្នុងមនុស្សលោកនេះទៀត ក៏បាននូវគុយ្ហប្រទេសដ៏កំបាំងនៅក្នុងស្រោម ដែលគេត្រូវបិទបាំងដោយសំពត់ ។ បុគ្គលដែលមានលក្ខណៈបែបនោះ រមែងមានកូនច្រើន ឯកូនដែលកើតអំពីខ្លួនជាច្រើនពាន់ ( នោះ ) សុទ្ធសឹងជាអ្នកក្លៀវក្លា អង់អាច អាចញាំញីនូវពួកសត្រូវបាន កាលបើព្រះតថាគត នៅជាគ្រហស្ថ ក៏គង់ញ៉ាំងបីតិឲ្យកើតឡើងបាន ព្រោះតែពោលពាក្យគួរស្រឡាញ់ ។ កាលបើព្រះតថាគតចេញទៅ ទ្រង់ព្រះផ្នួស ក៏មានកូនច្រើនជាងនោះទៅទៀត ឯកូនទាំងនោះ សុទ្ធតែជាអ្នកជឿស្តាប់ពាក្យ ( របស់ព្រះតថាគត ) ទោះ

ព្រះតថាគតនៅជាគ្រហស្ថ ឬទៅជាបព្វជិត មានលក្ខណៈ
នោះជាគ្រឿងបំភ្លឺនូវសេចក្តីនោះ ។

[ ២៣ ] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ( អាស្រ័យ ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងភពមុន ជាអ្នកបានពិចារណានូវការសង្គ្រោះមហាជន តែងស្គាល់ស្មើ គឺស្គាល់ថា អ្នកនេះស្មើនឹងអ្នកនោះ ស្គាល់ដោយខ្លួនឯង ស្គាល់បុរស ស្គាល់គុណវិសេសរបស់បុរសថា បុរសនេះ គួរទទួលនូវទាន និងគ្រឿងសក្ការៈនេះ បុរសនេះ គួរទទួលនូវទាន និងគ្រឿងសក្ការៈនេះ ( លុះស្គាល់ដូច្នោះហើយ ) ក៏បានធ្វើនូវប្រយោជន៍ប្លែកៗ គ្នា តម្រូវទៅតាមគុណវិសេសរបស់បុរសជាន់នោះៗ ។ ព្រះតថាគតនោះ ព្រោះបានធ្វើកុសលកម្មនោះ ។បេ។ លុះព្រះតថាគតនោះច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំងពីរនេះ គឺជាអ្នកមានបរិមណ្ឌល ( នៃកាយ ) ដូចជាបរិមណ្ឌលនៃដើមជ្រៃ ១ កាលបើឈរ មិនបាច់ឱនខ្លួនចុះ អាចស្ទាបពាល់ជង្គង់ដោយដៃទាំងពីរបាន ១ ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈទាំងពីរនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ។បេ។ កាលបើបានជាស្តេចហើយ តើនឹងបានរបស់អ្វី គឺនឹងបានជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានគ្រឿងប្រើប្រាស់ច្រើន មានមាសប្រាក់ច្រើន មានគ្រឿងឧបករណ៍ដែលធ្វើចិត្តឲ្យរីករាយច្រើន មានធញ្ញាហារជាទ្រព្យច្រើន មានឃ្លាំងដ៏ពេញប្រៀប កាលបើព្រះតថាគតនៅសោយរាជ្យ នឹងបានរបស់នេះឯង ។បេ។

កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងបានជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានគ្រឿងប្រើប្រាស់ច្រើន ទ្រព្យរបស់តថាគតទាំងនេះ គឺសទ្ធាធនំ ( ទ្រព្យ ពោល គឺការជឿ ) ១ សីលធនំ ( ទ្រព្យ គឺការសង្រួមកាយវាចាឲ្យរៀបរយ ) ១ ហិរិធនំ ( ទ្រព្យ គឺសេចក្តីខ្មាសបាប ) ១ ឱត្តប្បធនំ ( ទ្រព្យ គឺសេចក្តីក្តៅក្រហាយនឹងបាប ) ១ សុតធនំ ( ទ្រព្យ គឺការស្តាប់ ) ១ចាគធនំ ( ទ្រព្យ គឺការលះ ) ១ បញ្ញាធនំ ( ទ្រព្យ គឺកិរិយាដឹងសព្វ ) ១ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបាននូវរបស់នេះឯង ។ លុះព្រះមានព្រះភាគបានសម្តែងសេចក្តីនេះរួចហើយ ។ ទើបទ្រង់ត្រាស់គាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[ ២៤ ] ព្រះតថាគតបានលៃលក ពិចារណា គិតហើយ
ទើបសម្លឹងមើលនូវការសង្គ្រោះមហាជន ដោយស្មោះស្មើ
ជាអ្នកបានធ្វើនូវគ្រឿងសក្ការៈ តម្រូវតាមគុណវិសេស
របស់បុរសនោះៗ ក្នុងកាលមុនថា បុរសនេះគួរបាននូវ
ទាន និងគ្រឿងសក្ការៈនេះ ។ ព្រះតថាគតជាបុគ្គលមាន
កាយស្មើ កាលបើឈរ មិនបាច់ឱនខ្លួនចុះ អាចស្ទាប
ជង្គង់ដោយដៃទាំងពីរបាន មានបរិមណ្ឌល ( នៃកាយ )
ដូចបរិមណ្ឌលនៃដើមជ្រៃ ដែលដុះឡើងអំពីផែនដី ព្រោះ
សេសសល់វិបាកនៃអំពើសុចរិត ( នោះឯង ) ។ ពួក
មនុស្សដែលមានប្រាជ្ញាល្អិតជ្រាលជ្រៅ ដឹងនូវលក្ខណៈនៃ

និមិត្តផ្សេងៗ ជាច្រើន នាំគ្នាទាយថា ព្រះរាជកុមារកំលោះ
ក្មេងនេះ នឹងបាននូវរបស់ដ៏សមគួរ ដល់គ្រហស្ថច្រើន
ប្រការផង ជាអ្នកមានភោគសម្បត្តិ ដែលគួរប្រាថ្នារបស់
ស្តេច និងសមគួរដល់ពួកគ្រហស្ថ ក្នុងលោកនេះជាច្រើន
ផង បើព្រះរាជកុមារនេះ លះបង់នូវកាមភោគៈទាំងអស់
( ហើយចេញទៅទ្រង់ព្រះផ្នួស ) នឹងបានទ្រព្យដ៏ខ្ពង់ខ្ពស់
ថ្លៃថ្លា រកទ្រព្យឯទៀតឲ្យលើសលុបជាងមិនមានឡើយ ។

[ ២៥ ] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ( អាស្រ័យ ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលពីមុន ជាអ្នកប្រាថ្នានូវសេចក្តីចម្រើន ប្រាថ្នានូវប្រយោជន៍ ប្រាថ្នានូវសេចក្តីសុខ ប្រាថ្នាសេចក្តីក្សេមក្សាន្តចាកយោគៈ ដល់ពួកជនច្រើនថា ធ្វើដូចម្តេចជនទាំងនេះនឹងបានចម្រើនដោយសទ្ធា ចម្រើនដោយសីល ចម្រើនដោយសុតៈ ចម្រើនដោយវុឌ្ឍិ ចម្រើនដោយចាគៈ ចម្រើនដោយលោកិយធម៌ ចម្រើនដោយប្រាជ្ញា ចម្រើនដោយទ្រព្យ និងធញ្ញាហារ ចម្រើនដោយស្រែ និងចម្ការ ចម្រើនដោយសត្វជើង ២ និងសត្វជើង ៤ ចម្រើនដោយកូន និងប្រពន្ធ ចម្រើនដោយពួកបុរសជាទាសៈ និងកម្មករ ចម្រើនដោយពួកញាតិ ចម្រើនដោយពួកមិត្ត ចម្រើនដោយពួកផៅពង្ស ។ ព្រះតថាគតនោះ ព្រោះបានធ្វើសន្សំកុសលកម្មនោះ ។បេ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំង ៣ នេះ គឺ

មានចំណែកកន្ទះកាយខាងលើ ស្រដៀងនឹងចំណែកកន្ទះកាយនៃរាជសីហ៍ ១ មានខ្នងពេញស្មើ ឥតមានចង្អូរផតខ្នងត្រង់កណ្តាល ១ មានកម្ពុលសម ១ ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈទាំងនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ។បេ។ កាលបើបានជាស្តេចហើយ តើនឹងបានរបស់អ្វី គឺនឹងបានជាអ្នកមិនសាបសូន្យជាធម្មតា គឺមិនសាបសូន្យចាកទ្រព្យ និងធញ្ញាហារ ស្រែចម្ការ សត្វជើង ២ និងសត្វជើង ៤ កូនប្រពន្ធ ពួកបុរសជាទាសៈ និងកម្មករ ពួកញាតិ មិត្ត និងផៅពង្ស មិនបានសាបសូន្យចាកសម្បត្តិទាំងពួងឡើយ កាលបើបានជាស្តេច នឹងបានរបស់នេះឯង ។បេ។ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងបានជាអ្នកមិនសាបសូន្យជាធម្មតា គឺមិនសាបសូន្យចាកសទ្ធា សីលៈ សុតៈ ចាគៈ បញ្ញា ទាំងមិនសាបសូន្យចាកសម្បត្តិទាំងពួងឡើយ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគបានសម្តែងសេចក្តីនេះរួចហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[ ២៦ ] ព្រះតថាគត តែងប្រាថ្នា និងប៉ុនប៉ងនូវសេចក្តីមាំមួន និងសេចក្តីបរិបូណ៌ដល់ជនដទៃថា ធ្វើដូចម្តេច កុំឲ្យជនទាំងឡាយ សាបសូន្យចាកសទ្ធា សីលៈ សុតៈ បញ្ញា ចាគៈ និងលោកិយធម៌ និងគុណ គឺសេចក្តីល្អច្រើនប្រការ និងទ្រព្យ ធញ្ញាហារ ស្រែចម្ការ កូនប្រពន្ធ ( សត្វជើង ២ ) សត្វជើង ៤ ញាតិ មិត្ត ផៅពង្ស និង

កម្លាំង ពណ៌សម្បុរកាយ និងសុខទាំង ២ ប្រការ ។ ព្រះតថាគតជាបុគ្គលមានចំណែកកន្ទះកាយខាងលើ ស្រដៀងគ្នានឹងចំណែកកន្ទះកាយនៃរាជសីហ៍ មានទ្រង់ទ្រាយល្អ ១ មានកម្ពុលក្ខំ ១ មានខ្នងពេញស្មើ ឥតមានផតខូងត្រង់កណ្តាល ១ ព្រោះកម្មដែលព្រះតថាគតបានសន្សំ កសាងពីជាតិមុនមក ទើបមិនបានសាបសូន្យ បុព្វនិមិត្តរបស់ព្រះតថាគតនោះ មិនបានសាបសូន្យឡើយ ។ បើព្រះតថាគតនៅជាគ្រហស្ថ តែងចម្រើនដោយធញ្ញាហារ ទ្រព្យ កូនប្រពន្ធ ( សត្វជើង ២ ) និងសត្វជើង ៤ ( បើ ) ព្រះតថាគតឥតមានកង្វល់ ចេញទៅបួស ក៏បានសម្រេចសម្ពោធិញ្ញាណ រកគុណជាតឯទៀតឲ្យក្រៃលែងជាងគ្មាន ជាធម៌មិនបានសាបសូន្យ ។

[ ២៧ ] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ( អាស្រ័យ ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលពីមុន ជាអ្នកមិនបៀតបៀនសត្វទាំងឡាយដោយដៃ ឬដុំដី ឬក៏ដំបង គ្រឿងសស្ត្រាវុធឡើយ ។ ព្រះតថាគតនោះ ព្រោះបានធ្វើសន្សំនូវកុសលកម្មនោះ ។បេ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈនេះ គឺជាអ្នកមានប្រសាទ គឺសរសៃល្អិតឆ្មារដ៏លើសលែងសម្រាប់ទទួលរសអាហារ ឯប្រសាទសម្រាប់ទទួលរសអាហារ របស់ព្រះ

តថាគតនោះ មានចុងឯងឡើងលើ ប្រជុំស្រោបត្រង់កសម្រាប់ទទួលរសអាហារ ជ្រួតជ្រាបផ្សព្វផ្សាយស្មោះស្មើគ្នា ( សព្វសាកិន្ទកាយ ) ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ។បេ។ កាលបើបានជាស្តេចហើយ តើនឹងបានរបស់អ្វី គឺនឹងបានជាអ្នកមាន អាពាធតិច មានទុក្ខតិច ប្រកបដោយឧទរមានភ្លើងធាតុដ៏ស្មើ គឺមិនត្រជាក់ពេក មិនក្តៅពេក កាលបើនៅជាស្តេច នឹងបានរបស់នេះឯង ។បេ។ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធនឹងបានរបស់អ្វី គឺនឹងបានជាអ្នកមាន អាពាធតិច មានទុក្ខតិច ប្រកបដោយឧទរមានភ្លើងធាតុដ៏ស្មើ គឺមិនត្រជាក់ពេក មិនក្តៅពេក ជាយ៉ាងកណ្តាល ល្មមសមគួរដល់សេចក្តីព្យាយាម កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគ បានពោលសេចក្តីនេះរួចហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[ ២៨ ] ព្រះតថាគត ជាអ្នកមិនបានបៀតបៀន មិនបាន
ប្រទូស្តដល់ប្រជុំជន ដោយដៃ ឬដោយដំបង និងដុំដី ឬក៏
ដោយគ្រឿងសស្ត្រាវុធ ពុំនោះសោត ដោយការប្រើគេឲ្យ
សម្លាប់ និងបៀតបៀន ឬដោយកិរិយាចងក្រៀក និងការ
គំរាមឡើយ ។ ព្រោះកម្មនោះឯង ទើបព្រះតថាគតលះ
លោកនេះទៅ ក៏រមែងរីករាយក្នុងឋានសួគ៌ បាននូវសេចក្តី
សុខ ព្រោះធ្វើនូវអំពើដែលមានផលជាសុខ ប្រសាទសម្រាប់

ទទួលរសអាហារជាទីត្រេកអរ ( ណា ) បានតម្កល់នៅស៊ប់ល្អហើយ លុះព្រះតថាគត មកកើតក្នុងមនុស្សលោកនេះ ក៏បាននូវប្រសាទ គឺសរសៃល្អិតឆ្មារ ដ៏លើសលែងសម្រាប់ទទួលរសអាហារ ( នោះ ) ។ ព្រោះហេតុនោះ បានជាអ្នកប្រាជ្ញទាំងឡាយ មានប្រាជ្ញាដ៏ល្អិតនាំគ្នាទាយព្រះតថាគតនោះថា ជននេះ មុខជានឹងច្រើនទៅដោយសេចក្តីសុខ ទោះបីនៅជាគ្រហស្ថ ឬទៅជាបព្វជិត ក៏គង់មានលក្ខណៈនោះ ជាគ្រឿងបំភ្លឺនូវសេចក្តីនោះ ។

[ ២៩ ] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ( អាស្រ័យ ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកមិនសម្លក់មើល ( ដោយទោសចិត្ត ) មិនមៀងមើលដោយចុងភ្នែក មិនលបសម្លក់គេ ( ដោយស្អប់ ) ជាអ្នកមានចិត្តស្មោះត្រង់ រមិលមើលត្រង់ពេញភ្នែក ជាអ្នកសម្លឹងមើលជនច្រើន ដោយចក្ខុគួរឲ្យស្រឡាញ់ ។ ព្រះតថាគតនោះ ព្រោះបានធ្វើសន្សំកុសលកម្មនោះ ។បេ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំងពីរនេះ គឺជាអ្នកមានភ្នែកខៀវស្រស់ ១ មានកែវភ្នែកស្រដៀងនឹងកែវភ្នែកកូនគោ ១ ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈនោះ បើនៅគ្រប់គ្រងគេហដ្ឋាននឹងបានជាស្តេចចក្រពត្តិ ។បេ។ កាលបើបានជាស្តេចហើយ នឹងបានរបស់អ្វី គឺនឹងបានជាអ្នកគួរឲ្យអ្នកផងពិតពិលរមិលមើល ដោយ

សេចក្តីពេញចិត្ត ជាទីស្រឡាញ់នៃជនច្រើន ជាទីគាប់ចិត្តរបស់ពួកព្រាហ្មណ៍ និងគហបតី អ្នកនិគម អ្នកជនបទ ពួកស្មៀន ពួកមហាមាត្យ ពួកសេនា មានអង្គ ៤ ( មានសេនាដំរីជាដើម ) អ្នករក្សាទ្វារ អាមាត្យ ពួកបរិស័ទ ពួកស្តេចចំណុះ អ្នកមានភោគសម្បត្តិ និងពួករាជកុមារ កាលបើនៅជាស្តេច នឹងបានរបស់នេះឯង ។បេ។ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងបានជាអ្នកគួរឲ្យអ្នកផងពិតពិលរមិលមើល ដោយសេចក្តីពេញចិត្ត ជាទីស្រឡាញ់នៃជនច្រើន ជាទីគាប់ចិត្តរបស់ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ទេវតា មនុស្ស អសុរ នាគ គន្ធព្វ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគបានពោលសេចក្តីនេះរួចហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[ ៣០ ] ព្រះតថាគត ជាអ្នកមិនសម្លក់មើល ( ដោយទោសចិត្ត ) មិនមៀងមើលដោយចុងភ្នែក មិនលបសម្លក់គេ ( ដោយស្អប់ ) ជាអ្នកមានចិត្តស្មោះត្រង់ ពិតពិលរមិលមើលត្រង់ពេញភ្នែក ជាអ្នកសម្លឹងមើលមហាជនដោយចក្ខុគួរស្រឡាញ់ ។ ព្រះតថាគតនោះ បានទៅសោយផលវិបាកក្នុងសុគតិ រីករាយក្នុងសុគតិនោះ ( លុះច្យុតចាកឋានសួគ៌ ) មកកើតក្នុងមនុស្សលោកនេះ បានជាអ្នកមានកែវភ្នែក ស្រដៀងនឹងកែវភ្នែកកូនគោ ១ ជាអ្នកមាន

ភ្នែកខៀវស្រស់ គួរឲ្យរមិលមើល ( ដោយចិត្តរាប់អាន )
១ ។ មនុស្សទាំងឡាយ ជាអ្នកប្រកបក្នុងលក្ខណសាស្រ្ត
មានប្រាជ្ញាដ៏ល្អិត ឈ្លាសវៃ ក្នុងបទ និងនិមិត្តដ៏ច្រើន និង
ជាអ្នកជាឈ្លាសវៃក្នុងការទាយនូវភ្នែក ដែលដូចជាភ្នែកកូន
គោ នាំគ្នាទាយព្រះតថាគតនោះថា ព្រះរាជកុមារនេះ គួរ
ឲ្យពិតពិលរមិលមើលដោយចិត្តជាទីស្រឡាញ់ ។ បើព្រះ
តថាគតនៅជាគ្រហស្ថ ជាបុគ្គលគួរឲ្យពិតពិលរមិលមើល
ដោយចិត្តជាទីស្រឡាញ់ ជាទីរាប់អានរបស់ជនជាច្រើន
នេះបើនៅជាគ្រហស្ថ បើទៅជាសមណៈវិញ ក៏គង់ជាទី
ស្រឡាញ់ នឹងជាអ្នកធ្វើសេចក្តីសោករបស់ជនច្រើនឲ្យ
វិនាសបាន ។

[ ៣១ ] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ( អាស្រ័យ ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលពីមុន ជាចម្បងរបស់ជនច្រើន ក្នុងកុសលធម៌ទាំងឡាយ ជាប្រធានរបស់ជនច្រើន ក្នុងកាយសុចរិត វចីសុចរិត មនោសុចរិត ការបរិច្ចាគទាន សមាទានសីល កិរិយារក្សាឧបោសថ វត្តដែលត្រូវធ្វើចំពោះមាតា វត្តដែលត្រូវធ្វើចំពោះបិតា វត្តដែលត្រូវធ្វើចំពោះសមណៈ វត្តដែលត្រូវធ្វើចំពោះព្រាហ្មណ៍ វត្តដែលត្រូវធ្វើចំពោះជនដែលជាច្បងក្នុងត្រកូល និងក្នុងពួកកុសលធម៌ដ៏ក្រៃលែងឯទៀតៗ ។ ព្រះតថាគតនោះ ព្រោះបានធ្វើកុសលកម្មនោះ ។បេ។ លុះព្រះ

តថាគតច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈនេះ គឺជាអ្នកមានសីសៈដូចជាប្រដាប់ដោយក្បាំងស្រេចស្រាប់ ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ។បេ។ កាលបើបានជាស្តេចហើយ តើនឹងបានរបស់អ្វី គឺនឹងមានជនច្រើននាក់ជាបរិវារ គឺពួកព្រាហ្មណ៍ គហបតី អ្នកនិគម អ្នកជនបទ ពួកស្មៀន ពួកមហាមាត្យ សេនាប្រកបដោយអង្គ ៤ អ្នករក្សាទ្វារ អាមាត្យ បរិស័ទ ស្តេចចំណុះ អ្នកមានភោគសម្បត្តិ ព្រះរាជកុមារ កាលបើនៅជាស្តេច នឹងបានរបស់នេះឯង ។បេ។ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងមានជនច្រើននាក់ជាបរិវារ គឺពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ទេវតា មនុស្ស អសុរ នាគ គន្ធព្វ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគបានត្រាស់សេចក្តីនេះរួចហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[ ៣២ ] ព្រះតថាគតជាចម្បង ( របស់ជនច្រើន ) ក្នុង
សុចរិតធម៌ទាំងឡាយ ជាអ្នកត្រេកអរ ក្នុងការប្រព្រឹត្តធម៌
មានជនច្រើននាក់ជាបរិវារ លុះព្រះតថាគតលះលោកនេះ
ក៏បានទៅសោយផល នៃបុណ្យក្នុងឋានសួគ៌ ។ លុះព្រះ
តថាគតសោយផលសុចរិតនោះហើយ ច្យុតមកកើតក្នុង
មនុស្សលោកនេះ ក៏បានជាអ្នកមានសីសៈ ហាក់ដូចជា

ប្រដាប់ដោយក្បាំងស្រេចស្រោប់ ឯពួកមនុស្ស ជាអ្នកចេះចាំនូវព្យញ្ជនៈ និងនិមិត្ត នាំគ្នាទាយថា ព្រះតថាគតនេះ នឹងបានជាចម្បងរបស់ជនច្រើន ។ បណ្ដាពួកមនុស្ស ក្នុងលោកនេះ នឹងមានមនុស្សជាអ្នកខ្វល់ខ្វាយបម្រើ ( ព្រះតថាគតនេះជាច្រើន ) សូម្បីកាលព្រះតថាគត នៅពីក្មេង ក្នុងកាលនោះឯង ក៏មានពួកមនុស្សទាយព្រះតថាគតនោះថា បើព្រះតថាគតជាក្សត្រិយ៍ នៅគ្រប់គ្រងផែនដី នឹងបានពួកជនច្រើននាក់ ធ្វើការខ្វល់ខ្វាយបម្រើ ។ បើមនុស្សនោះចេញទៅបួស នឹងបានជាអ្នកស្ទាត់ជំនាញក្នុងធម៌ទាំង-ឡាយ ជនជាច្រើនតែងត្រេកអរក្នុងគុណ គឺការប្រៀនប្រដៅរបស់មនុស្សនោះ ជាអ្នកប្រព្រឹត្តតាម ( ព្រះតថាគត ) ។

[ ៣៣ ] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ( អាស្រ័យ ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលពីមុន ជាអ្នកលះបង់នូវមុសាវាទ វៀរស្រឡះហើយចាកមុសាវាទ ជាអ្នកនិយាយតែពាក្យពិត បញ្ចេញតែពាក្យពិត ជាអ្នកទៀងត្រង់ និយាយពាក្យគួរឲ្យគេជឿ ជាអ្នកមិនពោលបំភ្លាត់សត្វលោកឡើយ ។ ព្រះតថាគតនោះ ព្រោះបានធ្វើកុសលកម្មនោះ ។បេ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំងពីរនេះ គឺជាអ្នកមានរោមក្នុង

រណ្ដៅមួយៗ តែមួយសរសៃៗ ( រាល់រណ្ដៅទាំងអស់ ) ១ មានរោមប្រជុំចិញ្ចើម ដុះត្រង់ចន្លោះចិញ្ចើម មានពណ៌សក្បុសទន់ល្មន់ដូចជាសំឡី ១ ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្ដេចចក្រពត្តិ ។បេ។ កាលបើបានជាស្ដេចហើយ តើនឹងបានរបស់អ្វី គឺនឹងបានជនច្រើននាក់ គឺពួកព្រាហ្មណ៍ គហបតី អ្នកនិគម អ្នកជនបទ ពួកស្មៀន ពួកមហាមាត្យ សេនាប្រកបដោយអង្គ ៤ អ្នករក្សាទ្វារ អាមាត្យបរិស័ទ ស្ដេចចំណុះ អ្នកមានភោគសម្បត្តិ និងព្រះរាជកុមារ តែងប្រព្រឹត្តតាមអធ្យាស័យរបស់តថាគតនោះ កាលបើនៅជាស្ដេច នឹងបានរបស់នេះឯង ។បេ។ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងបានជនច្រើននាក់ គឺពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ទេវតា មនុស្ស អសុរ នាគ និងគន្ធព្វ តែងប្រព្រឹត្តតាមអធ្យាស្រ័យ របស់ព្រះតថាគតនោះ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគ បានសម្ដែងសេចក្ដីនេះរួចហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[ ៣៤ ] ក្នុងជាតិពីមុនៗ ព្រះតថាគត ជាអ្នកកាន់ពាក្យសត្យ មានវាចាគួរជឿ វៀរចាកពាក្យមិនពិត ព្រះតថាគតនោះ ជាអ្នកមិនក្លែងពោលពាក្យមិនពិត ចំពោះជនណាមួយឡើយ និយាយតែពាក្យពិត ទៀងទាត់ ត្រឹមត្រូវ ។ ព្រះតថាគត មានរោមប្រជុំចិញ្ចើមសម្បុរសក្បុស ទន់ល្មន់

ដូចជាសំឡី ដុះត្រង់ចន្លោះចិញ្ចើមក្នុងរណ្តៅរោមមួយៗ មិនដុះរោមពីរសរសៃឡើយ គឺព្រះតថាគត មានសរីរៈដុះរោមតែមួយសរសៃៗ ។ ពួកជនជាច្រើន ដែលជាអ្នកដឹងនូវលក្ខណៈ ឈ្លាសក្នុងការទាយនូវឧប្បាត និងនិមិត្ត មកប្រជុំគ្នា ហើយទាយព្រះតថាគតនោះថា នឹងមានជនជាច្រើនប្រព្រឹត្តទៅតាមអធ្យាស្រ័យរបស់តថាគត ដែលជាអ្នកមានរោមប្រជុំចិញ្ចើម ប្រតិស្ឋានល្អហើយបែបនេះ ។ បើព្រះតថាគតនៅជាគ្រហស្ថ នឹងមានជនជាច្រើនប្រព្រឹត្តតាមអធ្យាស្រ័យ ព្រោះកុសលកម្មដែលតថាគតបានធ្វើទុកមកពីកាលមុន ទោះបីព្រះតថាគត ចេញទៅធ្វើជាបព្វជិតឥតមានកង្វល់ នឹងបានត្រាស់ជាព្រះពុទ្ធដ៏ប្រសើរ នឹងមានជនប្រព្រឹត្តតាមអធ្យាស្រ័យដូចគ្នា ។

[ ៣៥ ] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ( អាស្រ័យ ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលពីមុន ជាអ្នកលះបង់នូវវាចាស៊កសៀត វៀរស្រឡះហើយចាកវាចាស៊កសៀត ជាអ្នកឮពាក្យអំពីជនឯនេះ មិននាំទៅប្រាប់ជនឯនោះ ដើម្បីបំបែកជនទាំងពីរចំណែកនេះឡើយ ឬបានឮពាក្យអំពីជនឯនោះ មិននាំមកប្រាប់ជនឯនេះ ដើម្បីបំបែកជនឯនោះឡើយ ជាអ្នកផ្សះផ្សានូវជនដែលបាក់បែកគ្នាហើយ ជាអ្នកទំនុកបម្រុងនូវពួកជនដែលព្រមព្រៀងគ្នា ជាអ្នករីករាយនឹងការព្រមព្រៀង ត្រេកអរនឹង

ការព្រមព្រៀងគ្នា ពេញចិត្តនឹងការព្រមព្រៀងគ្នា និងពោលតែវាចាដែលធ្វើឲ្យកើតសេចក្តីព្រមព្រៀងគ្នា ។ ព្រះតថាគតនោះ ព្រោះបានធ្វើកុសលកម្មនោះ ។បេ។ លុះព្រះតថាគត ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បានទូវមហាបុរិសលក្ខណៈទាំងពីរនេះ គឺជាអ្នកមានធ្មេញ ៤០ គត់ ១ មានធ្មេញជិតស្និទ្ធល្អ ១ ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈទាំងពីរនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ។បេ។ កាលបើបានជាស្តេចហើយ តើនឹងបានរបស់អ្វី គឺនឹងបានជាអ្នកមិនបែកបាក់បរិស័ទ ឯបរិស័ទរបស់ស្តេច ដែលមិនបែកបាក់គ្នានោះ គឺពួកព្រាហ្មណ៍ គហបតី អ្នកនិគម អ្នកជនបទ ពួកស្មៀន ពួកមហាមាត្យ សេនាមានអង្គ ៤ អ្នករក្សាទ្វារ អាមាត្យ បរិស័ទ ស្តេចចំណុះ អ្នកមានភោគសម្បត្តិ និងព្រះរាជកុមារ កាលបើនៅជាស្តេច នឹងបានទូវរបស់នេះឯង ។បេ។ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធនឹងបានរបស់អ្វី គឺនឹងមានបរិស័ទមិនបែកបាក់គ្នា បរិស័ទរបស់ព្រះតថាគតដែលមិនបែកបាក់គ្នានោះ គឺពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ទេវតា មនុស្ស អសុរ នាគ គន្ធព្វ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគ បានសម្តែងសេចក្តីនេះរួចហើយ ។ ទើបទ្រង់ត្រាស់ទូវគាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[ ៣៦ ] ព្រះតថាគតនោះ មិនបានពោលទូវពាក្យមិនពិត
ពាក្យដែលបង្កហេតុឲ្យបែកបាក់ ចាកការព្រមព្រៀង ពាក្យ
ដែលធ្វើសេចក្តីបែកបាក់គ្នា និងទាស់ទែងគ្នា ឲ្យចម្រើន

ពាក្យដែលធ្វើជម្លោះ និងអំពើមិនគួរ ឲ្យចម្រើន និងពាក្យដែលនាំឲ្យជនដែលមានបំណងព្រមព្រៀង ឲ្យបែកបាក់គ្នា ។ ព្រះតថាគតពោលតែពាក្យល្អ ជាពាក្យធ្វើសេចក្តីមិនវិវាទ ឲ្យចម្រើន និងពាក្យផ្សះផ្សាជនដែលបែកបាក់គ្នាហើយ ព្រះតថាគតបន្ទោបង់នូវជម្លោះរបស់ជន ទាំងធ្វើឲ្យព្រមព្រៀងគ្នា ព្រះតថាគតតែងរីករាយ ត្រេកអរ មួយអន្លើដោយសត្វទាំងឡាយ ព្រះតថាគតបានទៅសោយផលវិបាកក្នុងសុគតិ រីករាយក្នុងសុគតិនោះ លុះច្យុតចាកឋានសួគ៌ ( មកកើត ) ក្នុងមនុស្សលោកនេះ ក៏មានធ្មេញជិតស្និទ្ធល្អ និងមានធ្មេញ ៤០ គត់ ប្រតិស្ឋានដោយល្អនៅក្នុងមាត់ ។ បើព្រះតថាគតនៅ ( គ្រប់គ្រងគេហដ្ឋាន ) នឹងបានជាក្សត្រិយ៍គ្រប់គ្រងផែនដី មានបរិស័ទមិនបែកបាក់គ្នាឡើយ ទោះបីជាសមណៈ ក៏ជាអ្នកឥតមានធូលី ឥតមានមន្ទិលគឺរាគាទិក្កិលេសឡើយ ជាអ្នកមានបរិស័ទ តាមចោមរោមមិនញាប់ញ័រឡើយ ។

[ ៣៧ ] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ( អាស្រ័យ ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលពីមុន ជាអ្នកបានលះបង់នូវផរុសវាចា វៀរស្រឡះហើយចាកផរុសវាចា ជាអ្នកនិយាយតែពាក្យដែលឥតទោស ពាក្យដែលជាសុខដល់ត្រចៀកគេ គួរឲ្យស្រឡាញ់ គួរ

ឲ្យតាំងទុកក្នុងហឫទ័យ ជាសម្ចីអ្នកក្រង ទាំងជាទីស្រឡាញ់នៃជនច្រើន ជាទីពេញចិត្តនៃជនច្រើន ។ ព្រះតថាគតនោះ ព្រោះបានធ្វើសន្សំកសាង នូវកុសលកម្មនោះ ។បេ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំងពីរនេះ គឺជាអ្នកមានអណ្តាតវែង ១ មានសូរសព្ទសំឡេងក្រាងក្រអៅ ដូចជាសំឡេងព្រហ្មកាលបើបញ្ចេញវាចា លាន់ឮពីរោះ ដូចជាសំឡេងសត្វករវិក ១ ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ។បេ។ កាលបើបានជាស្តេចហើយ តើនឹងបានរបស់អ្វី គឺនឹងបានជាអ្នកមានវាចាគួរឲ្យអ្នកផងកាន់តាម គឺពួកព្រាហ្មណ៍ គហបតី អ្នកនិគម អ្នកជនបទ ពួកស្មៀន ពួកមហាមាត្យ សេនាមានអង្គ ៤ អ្នករក្សាទ្វារ អាមាត្យ បរិស័ទ ស្តេចចំណុះ អ្នកមានភោគសម្បត្តិ និងព្រះរាជកុមារ តែងកាន់តាមពាក្យរបស់ព្រះតថាគតនោះ កាលបើនៅជាស្តេច នឹងបានរបស់នេះឯង ។បេ។ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងបានជាអ្នកមានវាចាគួរឲ្យអ្នកផងកាន់តាម គឺពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ទេវតា មនុស្ស អសុរ នាគ គន្ធព្វ តែងកាន់តាមពាក្យរបស់ព្រះតថាគតនោះ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគ បានសម្តែងសេចក្តីនេះរួចហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[ ៣៨ ] ព្រះតថាគតនោះ មិនបានពោលពាក្យអាក្រក់

ក្រៃលែង ដែលជាពាក្យជេរ ជាពាក្យបង្កហេតុ ឲ្យទាស់ទែងគ្នា បៀតបៀនគ្នា ពាក្យដែលធ្វើឲ្យឈឺចិត្ត ពាក្យជាគ្រឿងមើលងាយនូវជនច្រើនឡើយ ព្រះតថាគតពោលតែពាក្យផ្អែមល្ហែម ទន់ភ្លន់ ប្រកបដោយប្រយោជន៍ ។ ព្រះតថាគតនោះ ពោលតែពាក្យដែលជាទីស្រឡាញ់ពេញចិត្ត គួរតម្កល់ទុកក្នុងហឫទ័យ នាំមកនូវសេចក្ដីសុខដល់ត្រចៀក ( របស់មនុស្សដែលបានស្ដាប់ ) ព្រះតថាគត បានសោយផលនៃបុណ្យក្នុងឋានសួគ៌ បានសោយផលនៃអំពើសុចរិត លុះព្រះតថាគត ច្យុតចាកមកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវភាពជាអ្នកមានសំឡេង ដូចសំឡេងព្រហ្ម អណ្ដាតរបស់ព្រះតថាគតនោះ ធំទូលាយ ព្រះតថាគតមានពាក្យដែលគួរឲ្យអ្នកផងកាន់តាម សូម្បីកាលព្រះតថាគត នៅជាគ្រហស្ថ និយាយយ៉ាងណាទៅហើយ ក៏តែងនាំឲ្យសម្រេចប្រយោជន៍យ៉ាងនោះ បើព្រះតថាគតនោះ ជាមនុស្សចេញទៅបួស ក៏មានពួកជនជឿកាន់តាមពាក្យរបស់ព្រះតថាគតនោះ ដែលជាអ្នកពោលនូវពាក្យល្អច្រើន ។

[ ៣៩ ] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ( អាស្រ័យ ) នូវជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកលះបង់នូវសម្ផប្បលាបៈ ( ពាក្យរោយរាយ ) វៀរស្រឡះហើយចាកសម្ផប្បលាបៈ

ជាអ្នកពោលតាមកាលគួរ ពោលតែពាក្យពិត ពោលពាក្យប្រកបដោយហេតុ ពោលពាក្យប្រកបដោយផល ពោលពាក្យទូន្មាន ពោលពាក្យដែលគួរឲ្យអ្នកផងតម្កល់ទុកក្នុងហឫទ័យ ជាពាក្យប្រកបដោយគ្រឿងអាង មានទីបំផុតប្រកបដោយប្រយោជន៍ ត្រូវតាមកាល ។ ព្រះតថាគតនោះ ព្រោះបានធ្វើសន្សំនូវកុសលកម្ម ។បេ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈនេះ គឺជាអ្នកមានចង្កាមានសណ្ឋានដូចជាចង្កានៃរាជសីហ៍ ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិ ។បេ។ កាលបើបានជាស្តេចហើយ តើនឹងបានរបស់អ្វី គឺនឹងបានជាអ្នកដែលមនុស្សជាសឹកសត្រូវបច្ចាមិត្តនីមួយ មិនអាចកម្ចាត់បង់បានឡើយ កាលបើនៅជាស្តេច នឹងបានរបស់នេះឯង ។បេ។ កាលបើព្រះតថាគត បានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងបានជាអ្នកដែលសត្រូវបច្ចាមិត្តខាងក្នុង ឬខាងក្រៅ គឺរាគៈក្តី ទោសៈក្តី មោហៈក្តី សមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬអ្នកណាមួយក្នុងលោក មិនអាចធ្វើព្រះតថាគតឲ្យឃ្លាត ( ចាកគុណ ឫទ្ធី ) បានឡើយ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគ បានសម្តែងសេចក្តីនេះរួចហើយ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[ ៤០ ] ព្រះតថាគត មិនពោលពាក្យឥតប្រយោជន៍ មិន

ពោលពាក្យរាយមាយ ជាអ្នកមានគន្លងនៃពាក្យ មិនរាយ

រាយ ព្រះតថាគតតែងបន្ទោបង់នូវពាក្យ ដែលឥតប្រ-
យោជន៍ផង ពោលតែពាក្យមានប្រយោជន៍ ដែលជាពាក្យ
នាំមកនូវសេចក្ដីសុខដល់ជនច្រើនផង ។ ព្រះតថាគត ធ្វើ
នូវកុសលកម្មនោះហើយ លុះច្យុតចាកមនុស្សលោកនេះ
បានទៅកើតក្នុងឋានសួគ៌ បានសោយនូវផលវិបាក របស់
កម្មដែលធ្វើល្អ លុះច្យុត ( ចាកឋានសួគ៌ ) នោះ មក
កាន់អត្តភាពជាមនុស្សនេះវិញ ក៏បាននូវភាពជាអ្នកមាន
ចង្កាដូចចង្កាសីហៈ ដែលជាសត្វប្រសើរជាងពួកសត្វជើង
៤ ។ ព្រះតថាគត ជាស្ដេចកំពូលនៃមនុស្សជាធំជាង
មនុស្ស មានអានុភាពច្រើន ទោះបីអ្នកណាៗ ក៏មិនអាច
ញាំញីបានឡើយ ព្រះតថាគតស្មើដោយព្រះឥន្ទ្រ ដែល
ប្រសើរក្នុងភពឈ្មោះតាវត្តិង្ស ទាំងក្មៀវក្លាប្រសើរក្រៃលែង
ដូចជាព្រះឥន្ទ្រាធិរាជដូច្នោះឯង ។ ព្រះតថាគតជាអ្នកមាន
អត្តភាពដូច្នោះ ទោះបីគន្ធព្វ អសុរ សក្កទេវរាជ អារក្ខទេព
ទាំងឡាយ ដែលក្មៀវក្លា ក៏មិនអាចញាំញីបាន បើអ្នកណា
មានលក្ខណៈ ដូចជាព្រះតថាគតនោះ ក្នុងលោកនេះ នឹង
បានជាធំក្នុងទិស គឺទិសតូច និងទិសធំ ។

[ ៤១ ] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគត ( អាស្រ័យ ) នូវ
ជាតិពីមុន ភពពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលពីមុន បានលះបង់

នូវមិច្ឆាជីវៈ ( ការចិញ្ចឹមជីវិតខុស ) ចិញ្ចឹមជីវិតដោយសម្មាអាជីវៈ ( ការចិញ្ចឹមជីវិតត្រូវ ) ជាអ្នកបានវៀរចាកការបញ្ឆោត ឬបន្លំដោយជញ្ជីង បញ្ឆោតដោយមាស បញ្ឆោតដោយរង្វាល់រង្វាស់ បន្ទុសបំភាន់ បញ្ឆោតបោកប្រាស និងបន្លំ ដោយរបស់ប្លម វៀរចាកកិរិយាកាត់នូវអវយវៈ មានដៃជាដើម សម្លាប់ចង ធ្វើមនុស្សឲ្យវង្វេងផ្លូវ ប្លន់ កំហែងយកទ្រព្យ ។ ព្រះតថាគតនោះ ព្រោះបានធ្វើ សន្សំ កសាងកុសលកម្មនោះ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ ក៏បានទៅកើតក្នុងឋានសុគតិសួគ៌ទេវលោក ។ ព្រះតថាគតនោះ គ្របសង្កត់នូវទេវតាឯទៀតក្នុងឋានសួគ៌នោះ ដោយហេតុ ១០ ប្រការ គឺអាយុទិព្យ ១ សម្បុរទិព្យ ១ យសទិព្យ ១ សុខទិព្យ ១ អធិបតីទិព្យ ១ រូបទិព្យ ១ សំឡេងទិព្យ ១ ក្លិនទិព្យ ១ រសទិព្យ ១ សម្ផ័ស្សទិព្យ ១ ។ លុះព្រះតថាគតនោះ ច្យុតចាកឋានសួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិសលក្ខណៈទាំងឡាយពីរនេះ គឺជាអ្នកមានធ្មេញជិតស្និទ្ធល្អ ១ មានចង្កូម ( ទាំង ៤ ) សស្អាត ១ ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈទាំងពីរនោះ បើនៅគ្រប់គ្រងគេហដ្ឋាន នឹងបានជាស្តេចចក្រពត្តិប្រកបដោយធម៌ សោយរាជ្យដោយធម៌ មានជ័យជម្នះ ផ្សាយរាជអំណាចរហូតដល់ផែនដីដែលមានសមុទ្រទាំង ៤ ព័ទ្ធជុំវិញ ទ្រង់ដល់នូវភាពជាអ្នកមាំមួនក្នុងជនបទ ប្រកបដោយរ័តន៍ ៧ ប្រការ ។ រ័តន៍ ៧ ប្រការនេះរបស់ស្តេចនោះ គឺចក្ករ័តន៍ ១ ហត្ថិរ័តន៍ ១ អស្សរ័តន៍ ១ មណិរ័តន៍ ១ ឥត្ថីរ័តន៍ ១ គហបតិរ័តន៍ ១ បរិនាយករ័តន៍ ១ រួមត្រូវជា ៧ ប្រការ ។ បុត្រ

របស់ស្តេចចក្រពត្តិនោះ ក៏មានចំនួនច្រើនពាន់ សុទ្ធសឹងតែជាអ្នកក្លៀវក្លា មានរូបសណ្ឋានជាអ្នកក្លៀវក្លា អាចញាំញីនូវសេនារបស់ស្តេចឯទៀតបាន ។ ទ្រង់ប្រាបប្រាមគ្រប់គ្រងនូវផែនដីនេះ ដែលមានសាគរជាទីបំផុត ឲ្យជាផែនដីឥតមានគោល ឥតមាននិមិត្ត ឥតមានបន្លា គឺចោរឡើយ ជាផែនដីស្តុកស្តម្ភមាំមួនក្សេមក្សាន្ត ឥតមានឧបទ្រព ឥតមានទីពួនរបស់ចោរ ដោយធម៌ដ៏ស្មើ មិនបាច់ពឹងអាជ្ញា មិនបាច់ពឹងគ្រឿងសស្ត្រាវុធឡើយ កាលបើនៅជាស្តេច នឹងបានរបស់អ្វី គឺនឹងបានជាអ្នកមានបរិវារស្អាតបាត ឯបរិវារស្អាតបាតរបស់ស្តេចចក្រពត្តិនោះ គឺពួកព្រាហ្មណ៍ គហបតី អ្នកនិគម អ្នកជនបទ ពួកស្មៀន ពួកមហាមាត្យ សេនាមានអង្គ ៤ អ្នករក្សាទ្វារ អាមាត្យ បរិស័ទស្តេចចំណុះ អ្នកមានភោគសម្បត្តិ និងព្រះរាជកុមារ កាលបើនៅជាស្តេច នឹងបានរបស់នេះឯង ។ បើព្រះតថាគត ចេញចាកគេហដ្ឋានទៅបួស នឹងបានត្រាស់ជាអរហន្តសម្មាសម្ពុទ្ធក្នុងលោក ( នេះ ) មានដំបូល គឺរាគាទិក្កិលេសបើកចេញហើយ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់អ្វី គឺនឹងបានជាអ្នកមានបរិវារស្អាតបាត ឯបរិវារស្អាតបាត របស់តថាគតនោះ គឺពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ទេវតា មនុស្ស អសុរ នាគ គន្ធព្វ កាលបើព្រះតថាគតបានត្រាស់ជាព្រះពុទ្ធ នឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគពោលនូវសេចក្តីនេះរួចហើយ ។ ទើបទ្រង់ត្រាស់នូវគាថាព័ន្ធនេះ ក្នុងលក្ខណៈនោះថា

[ ៤២ ] ព្រះតថាគតនោះ បានលះបង់ការចិញ្ចឹមជីវិតខុស

បានបំពេញសេចក្ដីប្រព្រឹត្តដោយស្អាតល្អ ជាធម៌ដ៏ស្មោះស្មើផង បានកម្ចាត់បង់នូវកម្ម ដែលឥតប្រយោជន៍ផង ប្រព្រឹត្តនូវកម្មដែលមានប្រយោជន៍ ទាំងនាំមកនូវសេចក្ដីសុខ ដល់ជនច្រើនផង ។ ព្រះតថាគត ជានរជនបានធ្វើនូវអំពើមានផលដ៏ល្អ ដែលពួកសប្បុរសជាអ្នកប្រាជ្ញ មានប្រាជ្ញាល្អិត តែងសរសើរហើយ ទើបសោយនូវសេចក្ដីសុខក្នុងឋានសួគ៌ ព្រះតថាគតជាអ្នកស្មើដោយសក្កទេវរាជដែលជាកំពូលនៃទេវតា ក្នុងភពឈ្មោះតាវត្តិង្ស តែងត្រេកអរ និងមូលមិត្រដោយសេចក្ដីរីករាយ និងសេចក្ដីសុខសម្រាន្ត ។ លុះព្រះតថាគត ច្យុតចាកឋានសួគ៌នោះបានមកកើតជាមនុស្សនេះម្ដងទៀត ក៏បាននូវធ្មេញរាបស្មើល្អផង នូវចង្កូម ( ទាំង ៤ ) ស្អាតល្អផង ព្រោះសេសនៃផលវិបាករបស់កម្មដែលបានធ្វើល្អហើយ ។ ពួកមនុស្សជាច្រើន ជាអ្នកដឹងនូវលក្ខណៈ ដែលសន្មតថា ជាអ្នកមានប្រាជ្ញាល្អិត មកប្រជុំគ្នាទាយព្រះលក្ខណៈព្រះតថាគតនោះថា ព្រះតថាគតដែលមានព្រះទន្តស្មើស្អាតល្អ រមែងមានពួកជនស្អាតជាបរិវារ ។ បើព្រះតថាគតនៅសោយរាជ្យនឹងបានជនច្រើនជាបរិវារស្អាតល្អ ព្រះតថាគតប្រៀនប្រដៅនូវមនុស្សលើផែនដីធំនេះ គ្របសង្កត់សង្កិន មិនឲ្យមាន

គ្រឿងចាក់ដោតដល់ជនបទឡើយ ព្រះតថាគតប្រព្រឹត្តនូវ
អំពើជាប្រយោជន៍ ទាំងសេចក្តីសុខដល់ជនច្រើន បើព្រះ
តថាគតចេញទៅបួស រមែងជាអ្នកបន្សាត់បង់នូវបាប ជា
អ្នកស្ងប់រម្ងាប់ មានធូលី គឺរាគាទិក្កិលេស ស្ងប់រម្ងាប់
ហើយ មានកិលេសដូចជាដំបូល បើកចេញហើយ ជាអ្នក
ប្រាសចាកសេចក្តីក្រវល់ក្រវាយ និងសេចក្តីលំបាកកាយ
តែងឃើញនូវលោកនេះ និងលោកខាងមុខ ។ ពួកគ្រហស្ថ
និងបព្វជិតជាច្រើន ដែលជាអ្នកធ្វើតាមឱវាទ របស់ព្រះ
តថាគតនោះ តែងជាអ្នកប្រាសចាកសេចក្តីសៅហ្មង ព្រោះ
ថា ព្រះតថាគត ដែលមានបាបបន្សាត់ចោលហើយនោះ
រមែងមានតែពួកមនុស្សស្អាតល្អ ដែលជាអ្នកកម្ចាត់បង់នូវ
មន្ទិល និងជន្លត់ គឺរាគាទិក្កិលេស នូវកំហុស គឺទោស
និងកិលេសទាំងពួង មកចោមរោមជុំវិញ ។

លុះព្រះមានព្រះភាគ បានសម្តែងលក្ខណសូត្រនេះចប់ហើយ ។ ពួកភិក្ខុទាំងនោះ ក៏មានសេចក្តីពេញចិត្ត ត្រេកអរចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

### លក្ខណសូត្រទី ៧ ចប់

# អដ្ឋកថា

## លក្ខណសូត្រ

[ ១ ] *លក្ខណសូត្រ មានពាក្យផ្ដើមថា* **ឯវម្មេ សុតំ** *ដូច្នេះ ។ បន្ទាប់អំពីនេះ នឹងពណ៌នាបទដែលលំបាកក្នុងលក្ខណសូត្រនោះ ។ បទថា* **ទ្វត្តឹ-សីមានិ** *កាត់បទជា* **ទ្វត្តឹស ឥមានិ** ។ *បទថា* **មហាបុរិសលក្ខណានិ** *សេចក្ដីថា ការប្រាកដនៃមហាបុរស និមិត្តនៃមហាបុរសជាហេតុឲ្យដឹងថា នេះគឺមហាបុរស ។ បទថា* **យេហិ សមន្នគតស្ស មហាបុរិសស្ស** *ដូច្នេះ គប្បីជ្រាបដោយន័យពិស្ដារហើយក្នុងមហាបទាន ព្រោះហេតុអ្វី ទើបលោកពោលថា ពួកឥសីខាងក្រៅនៅចាំមហាបុរិសលក្ខណៈរបស់ព្រះមហាបុរស ៣២ ប្រការនេះបាន តែពួកឥសីទាំងនោះមិនដឹងថា ខាងមុខអំពីស្លាប់ ព្រោះកាយបែកធ្លាយ រមែងចូលដល់សុគតិសួគ៌ ព្រោះកម្មដែលខ្លួនសន្សំកពូនបរិបូណ៌ លុះចុតិចាកសួគ៌នោះហើយ មកកាន់សភាពយ៉ាងនេះ រមែងបានមហាបុរិស-លក្ខណៈនេះ ដូច្នេះ ព្រោះអនុរូបដល់រឿងនេះកើតឡើង ព្រោះថា សូត្រនេះមានអត្ថុប្បត្តិហេតុតាំងឡើងក្នុងទីណា តាំងឡើងក្នុងរវាងពួកមនុស្សខាងក្នុងស្រុក ។*

*បានឮថា ក្នុងគ្រានោះ អ្នកក្រុងសាវត្ថី អង្គុយប្រជុំសន្ទនាគ្នាក្នុងស្រុកត្រង់ទ្វារផ្ទះ និងត្រង់បន្ទប់អង្គុយជាដើម រៀងៗ ខ្លួនថា ព្រះវរកាយរបស់ព្រះមានព្រះភាគបរិបូណ៌ដោយអនុព្យញ្ជនៈ ៨០ មានព្រះរស្មីផ្សាយចេញចាកព្រះវរកាយមួយព្យាម មហាបុរិសលក្ខណៈ ៣២ កាលបញ្ចេញព្រះរស្មីមាន*

ពណ៌ ៦ ប្រការ ... ពន្លឺផ្សាយចេញពីខាងនេះខាងនោះ រមែងស្អាតដ៏ក្រៃលែង ដូចផ្កាស្មួគិ ដូចគុម្ពឈូកដែលរីក ដូចជាសសរខឿនវិចិត្រដោយកែវផ្សេងៗ ដូចផ្ទៃមេឃប្រកបដោយផ្កាយព្រោងព្រាត និងដូចថ្ងៃបណ្តើរកូន ព្រះដ៏មានព្រះភាគមិនបានប្រាប់ថា លក្ខណៈនេះ កើតឡើងដោយកម្មនេះ លក្ខណៈនេះកើតឡើងយ៉ាងនេះ ព្រោះតថាគតឲ្យទាន សូម្បីត្រឹមតែបបរមួយវែក ឬត្រឹមតែបាយមួយវែកជាបច្ច័យ លក្ខណៈទាំងនេះ រមែងកើតឡើងដល់ព្រះមានព្រះភាគអង្គនោះ តើព្រះសាស្តាទ្រង់បានធ្វើកម្មអ្វីមកហ្ន៎ ។

លំដាប់នោះ ព្រះអានន្ទត្ថេរ ចារិកទៅខាងក្នុងស្រុកបានស្តាប់នូវសន្ទនានេះ ធ្វើភត្តកិច្ចស្រេចហើយ មកកាន់វិហារ ធ្វើវត្តបដិបត្តិចំពោះព្រះសាស្តា ហើយថ្វាយបង្គំ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានកថាមួយ អំពីក្នុងស្រុក កាលព្រះមានព្រះភាគត្រាស់សួរថា ម្នាលអានន្ទ អ្នកបានឮដូចម្តេច ក៏ក្រាបទូលឲ្យទ្រង់ជ្រាបទាំងអស់ ។ ព្រះសាស្តា ស្តាប់ពាក្យរបស់ព្រះថេរៈ ហើយ ត្រាស់ហៅភិក្ខុទាំងឡាយ ដែលអង្គុយចោមរោម ទ្រង់សម្តែងលក្ខណៈទាំងឡាយដោយលំដាប់ថា ម្នាលភិក្ខុទាំងឡាយ មហាបុរស ប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការនេះ ទ្រង់ត្រាស់យ៉ាងនោះ ដើម្បីសម្តែងដល់លក្ខណៈ ដែលកើតឡើងព្រោះកម្ម ។

[ ២ ] ក្នុងបទទាំងឡាយថា **បុរិមំ ជាតឹ** ជាដើម សេចក្តីថា ខន្ធដែលធ្លាប់អាស្រ័យនៅ ព្រះមានព្រះភាគត្រាស់ថា **ជាតិ** ដោយអំណាចកើតហើយ ត្រាស់ថា **ភវំ** ដោយអំណាចកើតយ៉ាងនោះ ត្រាស់ថា **និកេតោ** ដោយ

អំណាចអាស្រ័យនៅ ឬដោយអត្ថថា ជាទីនៅ បទទាំង ៣ នោះ មាន អធិប្បាយថា ក្នុងខន្ធសន្តានដែលធ្លាប់អាស្រ័យនៅ ដូច្នេះ ។

ឥឡូវនេះ ព្រោះខន្ធសន្តាននោះ រមែងប្រព្រឹត្តទៅក្នុងទេវលោកជាដើម តែកុសលកម្មដែលអាចញុំាងលក្ខណៈឲ្យកើត មិនងាយធ្វើក្នុងទេវលោកនោះ កាលជាមនុស្សនោះឯង ទើបធ្វើបានងាយ ដូច្នោះ កាលព្រះមានព្រះភាគ ទ្រង់សម្តែងដល់កម្មដែលទ្រង់ធ្វើហើយ តាមសេចក្តីពិត ទើបត្រាស់ថា **បុព្វេ មនុស្សភូតោ សមានោ** ដូច្នេះ ឬថា នុះមិនមែនហេតុ ពិតហើយ មហាបុរស សូម្បីជាដំរី សេះ គោ ក្របី ស្វាជាដើម ក៏ទ្រង់បំពេញបារមីបានដូចគ្នា តែ ព្រោះព្រះអង្គតាំងនៅក្នុងអត្តភាពបែបនោះ មិនអាចសម្តែងកម្ម ដែលទ្រង់ ធ្វើហើយដោយងាយ តែព្រះអង្គតាំងនៅក្នុងភាពជាមនុស្ស ទើបអាចសម្តែង កម្ម ដែលព្រះអង្គទ្រង់ធ្វើហើយដោយងាយ ដូច្នោះ ទើបត្រាស់ថា **បុព្វេ មនុស្សភូតោ សមានោ** ដូច្នេះ ។ បទថា **ទឡ្ហសមាទានោ** គឺសមាទាន មាំមួន ។ បទថា **កុសលេសុ ធម្មេសុ** សំដៅដល់ កុសលកម្មបថ ១០ ។ បទថា **អវត្ថិតសមាទានោ** បានដល់ ជាប់ជានិច្ច គឺសមាទានមាំ មិនដកថយ ពិតហើយ ចិត្តរបស់ព្រះមហាសត្វ រមែងរួញចាកអកុសលកម្ម ដូចស្លាបមាន់ ត្រូវភ្លើង ដូច្នោះ ចិត្តរបស់ព្រះមហាបុរសសម្រេចកុសល រមែងសន្ធឹងដូច ពិតាន ព្រោះដូច្នោះ ព្រះតថាគតទ្រង់សមាទានមាំមួនមិនដកថយ ដែលបុគ្គល ណាមួយ ជាសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ក៏មិនអាចឲ្យ ព្រះអង្គលះបង់ការកាន់យកដ៏មាំទាំក្នុងកុសលបាន ។

បានឮថា ក្នុងអតីតកាលព្រះមហាបុរស កើតក្នុងកំណើតសត្វកង្អែន កាលនោះ មានភ្លៀងធ្លាក់ ខ្សែទឹកក៏ហូរនាំយកសម្បុករបស់កង្អែន ចូលទៅក្នុងមហាសមុទ្រ មហាបុរសគិតថា អញនឹងនាំកូនតូចចេញឲ្យបាន ទើបយកកន្ទុយជ្រលក់ទឹកពីមហាសមុទ្រ ហើយរលាស់ទៅខាងក្រៅ ក្នុងថ្ងៃ ទី ៧ សក្កទេវរាជទ្រង់ពិចារណាហើយ យាងមកក្នុងទីនោះ សួរថា អ្នកធ្វើអ្វី មហាបុរសប្រាប់រឿងរ៉ាវដល់សក្កទេវរាជនោះ ។ សក្កទេវរាជនោះ ទ្រង់ប្រាប់ដល់ភាពដែលនាំទឹកចេញចាកមហាសមុទ្របានលំបាក ។ ព្រះពោធិសត្វតិះដៀលថា ខ្ញុំមិនគួរនិយាយជាមួយអ្នកខ្ជិលច្រអូសដូចអ្នក អ្នកកុំឈរត្រង់នេះឡើយ សក្កទេវរាជគិតថា អញមិនអាចឲ្យអ្នកមានចិត្តប្រសើរ លះបង់វត្ថុដែលខ្លួនសមាទានបាន ទើបនាំកូនតូចមកប្រគល់ឲ្យ ។

សូម្បីក្នុងកាលដែលព្រះពោធិសត្វ កាន់យកកំណើតជាមហាជនក ព្រះពោធិសត្វទ្រង់ហែលឆ្លងមហាសមុទ្រ ទេវតាសួរថា ព្រោះហេតុអ្វី ទើបលោកហែលឆ្លងមហាសមុទ្រ ។ ទ្រង់ពោលថា ខ្ញុំហែលឆ្លងដើម្បីទៅដល់ត្រើយ ហើយនឹងគ្រងរាជសម្បត្តិក្នុងដែនដែលជារបស់ត្រកូល ហើយបរិច្ចាគទាន ។ កាលទេវតាពោលថា មហាសមុទ្រនេះជ្រៅ និងធំល្វឹងល្វើយ កាលណានឹងឆ្លងបាន ព្រះពោធិសត្វត្រាស់ថា មហាសមុទ្រនេះ ក៏ដូចមហាសមុទ្ររបស់នាង តែអាស្រ័យសេចក្តីតាំងចិត្តរបស់ខ្ញុំ ប្រាកដដូចប្រឡាយតូចៗ នាងនោះឯង នឹងឃើញខ្ញុំដែលហែលឆ្លងមហាសមុទ្រ ហើយនាំទ្រព្យពីត្រើយមហាសមុទ្រ មកគ្រងរាជសម្បត្តិក្នុងដែនដែលជារបស់ត្រកូល ហើយបរិច្ចាគទាន

ដូច្នេះ ។ ទេវតាគិតថា អញមិនអាចនឹងឲ្យបុរស អ្នកមានចិត្តដ៏ប្រសើរ លះបង់ វត្ថុដែលខ្លួនកាន់យកយ៉ាងមុតមាំបាន ទើបបីព្រះពោធិសត្វ នាំទៅឲ្យផ្ដុំក្នុង ឧទ្យាន ព្រះមហាសត្វនោះ ញុំាងមហាជនឲ្យលើកនូវស្វេតច្ឆត្រហើយ ទ្រង់ បរិច្ចាគនូវទាន មួយថ្ងៃ ១០ សែន តមក ស្ដេចចេញបួស ។ ព្រះមហាសត្វ ដែលបុគ្គលណាម្នាក់ ជាសមណៈក្ដី ព្រាហ្មណ៍ក្ដី ទេវតាក្ដី មារក្ដី ព្រហ្មក្ដី ក៏មិនអាចឲ្យលះបង់កុសលសមាទានបាន ដូច្នេះ ព្រោះហេតុនោះ ទើបព្រះ មានព្រះភាគត្រាស់ថា តថាគតជាអ្នកបានសមាទានមាំមួន ក្នុងកុសលធម៌ ទាំងឡាយ ដូច្នេះ ។ ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីទ្រង់សម្ដែងការ សមាទានមាំ មិនដកថយក្នុងធម៌ដែលជាកុសល ទើបត្រាស់បទថា **កាយ-សុចរិតេ** ដូច្នេះជាដើម ។ ក្នុងបទនេះថា **ទានសំវិភាគេ** គឺការឲ្យដោយ អំណាចការឲ្យទាននុ៎ះឯង បរិច្ចាគ ដោយអំណាចធ្វើបរិច្ចាគ ។ បទថា **សីល-សមាទានេ** គឺក្នុងកាលបំពេញសីល ៥ សីល ៨ សីល ១០ និងចតុប្បារិ-សុទ្ធិសីល ។ បទថា **ឧបោសថុបវាសេ** គឺក្នុងការសមាទានឧបោសថ មាន ថ្ងៃ ១៤ ជាដើម ។ បទថា **មត្តេយ្យតាយ** គឺក្នុងវត្តដែលគួរធ្វើចំពោះមាតា ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះឯង ។ បទថា **អញ្ញតរញ្ញតរេសុ ច** គឺក្នុងកុសលធម៌ដទៃទៀតដែលមានសភាពបែបនេះ ។ ក្នុងបទថា **អធិកុ-សលេសុ** នេះ អធិប្បាយថា កុសល មានអធិកុសល មានកាមាវចរកុសល ទាំងអស់ ក៏ឈ្មោះថា ជាកុសល រូបាវចរៈ ជាអធិកុសល ទាំងពីរនោះ ក៏ ឈ្មោះថា ជាកុសល អរូបាវចរៈ ជាអធិកុសល សូម្បីទាំងអស់នោះ ឈ្មោះ

ថា ជាកុសល កុសលដែលជាបច្ច័យនៃការបានសាវកបារមី ជាអធិកុសល កុសលទាំងនោះ ឈ្មោះថា ជាកុសល កុសលដែលជាបច្ច័យនៃការបានបច្ចេកពោធិ ជាអធិកុសល អធិកុសលទាំងនោះ ឈ្មោះថា ជាកុសល តែកុសលដែលជាបច្ច័យនៃការបានសព្វញ្ញុតញ្ញាណ លោកបំណងយកថា ជាអធិកុសលក្នុងទីនេះ ព្រះតថាគតទ្រង់ជាអ្នកសមាទានមាំ ជាអ្នកសមាទានមិនដាច់ ក្នុងធម៌ជាអធិកុសលទាំងនោះ ។ ក្នុងបទនេះថា **កតត្តា ឧបចិតត្តា** អធិប្បាយថា កម្មដែលខ្លួនធ្វើ សូម្បីតែម្តងក៏ឈ្មោះថា ធ្វើដូចគ្នា តែព្រោះធ្វើរឿយៗ ជាកម្មដែលខ្លួនសន្សំ ។ បទថា **ឧស្សន្នត្តា** គឺកម្មដែលខ្លួន ធ្វើឲ្យជាគំនរ លោកពោលថា កពូន ព្រះមានព្រះភាគ កាលទ្រង់ពោលបទថា ព្រោះកម្មដែលកពូន ទើបទ្រង់សម្តែងថា កាលតថាគតធ្វើកម្ម ចក្រវាលតូចចង្អៀត ភវគ្គព្រហ្មទាប កម្មដែលតថាគតកពូនមកយ៉ាងនេះ ។ បទថា **វិបុលត្តា** គឺព្រោះមិនមានប្រមាណ ។ ព្រះមានព្រះភាគទ្រង់សម្តែងថា កម្មដែលតថាគតធ្វើមិនមានទីបំផុត មិនមានប្រមាណ ។ បទថា **អធិគណ្ហាតិ** គឺរមែងគ្របសង្កត់ អធិប្បាយថា បានក្រៃលែងជាងទេវតាទាំងឡាយ ។ បទថា **បដិលភតិ** គឺសម្រេច ។

[ ៣ ] បទថា **សព្វាវន្តេហិ បាទតលេហិ** ជាពាក្យពិស្តាររបស់បទថា **សមំ បាទំ ភូមិយំ និក្ខិបតិ** ។ ក្នុងបទទាំងឡាយនោះ បទថា **សព្វាវន្តេហិ** អធិប្បាយថា ព្រះមហាបុរស ទ្រង់មិនសង្កត់ចុងព្រះបាទដោយចំណែកមួយ ទ្រង់មិនសង្កត់កែងព្រះបាទដោយចំណែកមួយ ទ្រង់ដាក់បាតព្រះបាទលើផែនដី

ស្មើគ្នាគ្រប់ចំណែក ទ្រង់លើកឡើងក៏ស្មើគ្នា ។ ប្រសិនបើព្រះតថាគត ទ្រង់ព្រះបាទដោយព្រះតម្រិះថា តថាគតនឹងជាន់ត្រង់ជ្រោះ ដែលមានជម្រៅច្រើនយោជន៍របុរស ក្លាមនោះ ទីអន្ទង់ក៏ខ្ពស់ឡើងមានទីស្មើនឹងផែនដី ដូចពុម្ពមាសពេញដោយខ្យល់ ដូច្នោះ ។ ព្រះតថាគតនឹងចូលទៅកាន់ទីខ្ពស់ ក្នុងខាងក្នុងកាលលើកព្រះបាទឡើង ដោយទ្រង់ព្រះតម្រិះថា តថាគតនឹងជាន់ក្នុងទីឆ្ងាយភ្នំសូម្បីប្រមាណប៉ុនភ្នំព្រះសិនេរុ ក៏បង្អោនចុះមកជិតព្រះបាទ ដូចចុងផ្តៅដែលត្រូវភ្លើងភ្លើង ដូច្នោះ ពិតហើយ កាលព្រះតថាគតទ្រង់លើកព្រះបាទដោយទ្រង់ព្រះតម្រិះថា តថាគតនឹងធ្វើបាដិហារ្យជាន់ភ្នំយុគន្ធរ ភ្នំក៏បង្អោនចុះមកជិតព្រះបាទ ព្រះអង្គក៏ជាន់ភ្នំនោះ ហើយជាន់ដល់កពតាវត្តិង្សដោយព្រះបាទទីពីរ កន្លែងដែលចក្កលក្ខណៈ គួរប្រតិស្ឋាន មិនអាចនឹងជាទីមិនរៀបស្មើដង្កត់ បន្លា ក្រួស អំបែង ឧច្ចារៈ បស្សាវៈ ទឹកមាត់ ទឹកសម្បោរជាដើមឬរបស់ដែលមានពីមុន វិនាសទៅអស់ ឬបាត់ទៅ ចូលកាន់ផែនដីទាំងអស់ក្នុងទីនោះៗ ។ ពិតហើយ មហាប្រឹថពីនេះ មានផ្ទៃដីរាបស្មើដេរដាសទៅដោយផ្កាវីក រមែងកើតឡើងដោយសីលតេជះ ដោយបុញ្ញតេជះ ដោយធម្មតេជះ ដោយអានុភាពនៃទសបារមីរបស់ព្រះតថាគត ។ បទថា **សាគរបរិយន្តំ** គឺសាគរជាសីមា អធិប្បាយថា កាលព្រះមហាបុរស ទ្រង់គ្រងរាជសម្បត្តិ ដើមឈើក្តី ភ្នំក្តី ទន្លេក្តី ក្នុងចន្លោះនោះ មិនបានជាព្រំដែន មហាសមុទ្រទុំះឯងជាព្រំដែន ព្រោះដូច្នោះ ទើបលោកពោលថា មានសាគរជាទីបំផុត ។ បទថា **អខិលមនិមិត្តមកណ្តកំ** គឺមិនមានចោរ ពិតហើយ ចោរ

ទាំងឡាយលោកពោលថា ជាបង្គោល ព្រោះអត្ថថា មានសម្មស្សរឹង ជានិមិត្ត ព្រោះអត្ថថា ជាបច្ច័យនៃអន្តរាយ ជាបន្ទា ព្រោះអត្ថថា ចាក់ដោត ។ បទថា **ឥទ្ធំ** គឺសម្រេច ។ បទថា **ផីតំ** គឺឧត្តមបរិបូណ៌ដោយសម្បត្តិគ្រប់យ៉ាង ។ បទថា **ខេមំ** គឺមិនមានភ័យ ។ បទថា **សិវំ** គឺមិនមានអន្តរាយ ។ បទថា **និរព្ពុទំ** អធិប្បាយថា វៀរចាកពួកចោរ គឺវៀរចាកចោរ ដែលប្រមូលគ្នាជាពួកៗ ត្រាច់ទៅ ។ បទថា **អក្ខម្ភិយោ** គឺសឹកសត្រូវគ្របសង្កត់មិនបាន អធិប្បាយថា បុគ្គលណាម្នាក់ ក៏មិនអាចនឹងឲ្យគេញាប់ញ័រចាកស្ថានទីបាន ។ បទថា **បច្ចត្ថិកេហិ** គឺប្រាថ្នាជាបដិបក្ខ ។ បទថា **បច្ចាមិត្តេហិ** គឺអមិត្តដែលប្រទូស្តតប សូម្បីទាំងពីរនោះ ក៏ជាវេវចនៈរបស់សត្រូវ ។ បទថា **អព្ភន្តរេហិ** បានដល់ កិលេស មានរាគៈជាដើម ដែលតាំងឡើងក្នុងខាងក្នុង ។ បទថា **ពាហិរេហិ** បានដល់ ពួកសមណៈជាដើម ពិតហើយ សូម្បីពួកសមណៈ មានទេវទត្ត និងកោកាលិកៈជាដើម សូម្បីព្រាហ្មណ៍ មានសោណទណ្ឌៈ និងកូដទណ្ឌៈជាដើម សូម្បីទេវតា ដូចសក្កៈទេវរាជ ។ សូម្បីមារអ្នកជាប់តាមរហូតដល់អស់ ៧ ឆ្នាំ សូម្បីព្រហ្ម មានពកាព្រហ្មជាដើម ក៏មិនអាចនឹងគ្របសង្កត់ព្រះសម្ពុទ្ធបាន ដោយហេតុនេះ ទើបព្រះសាស្ដាត្រាស់កម្ម ធម៌ប្រហែលនឹងកម្មលក្ខណៈ និងអានិសង្សនៃលក្ខណៈ កម្មដែលបុគ្គលអ្នកមានសេចក្តីព្យាយាមមាំធ្វើហើយ អស់ ៤ អសង្ខេយ្យ និងមួយសែនមហាកប្ប ឈ្មោះថា កម្ម មហាបុរិសលក្ខណៈ គឺមានព្រះបាទប្រតិស្ឋានល្អហើយ កើតឡើងដោយន័យថា លោក ព្រមទាំងទេវលោក ចូរដឹងភាវៈនៃកម្ម ដែលអ្នក

មុតមាំធ្វើហើយ ឈ្មោះថា ធម៌ប្រហែលនឹងកម្ម ភាពជាអ្នកមានព្រះបាទប្រតិស្ឋានទុកល្អហើយ ឈ្មោះថា លក្ខណៈ ភាពជាអ្នកដែលសឹកសត្រូវគ្របសង្កត់មិនបាន ឈ្មោះថា អានិសង្សនៃលក្ខណៈ ។

បទថា **តត្ថេតំ វុច្ចតិ** សេចក្តីថា កាលព្រះមានព្រះភាគ ត្រាស់ប្រភេទនៃកម្មជាដើម ក្នុងព្រះលក្ខណៈនោះហើយ ទើបព្រះបុរាណកត្ថេរពោលពាក្យនេះតទៅ លោកពោលសំដៅដល់គាថាព័ន្ធ បុរាណកត្ថេរទាំងឡាយជ្រាបថា គាថាវណ្ណនា ដែលព្រះអានន្ទត្ថេរតាំងទុក ទើបពោលគាថាទាំងនេះ តមក ព្រះថេរៈទាំងឡាយពោលថា ការលើកអត្ថឡើងមួយបទ ។

[ ៤ ] បទថា **សច្ចេ** គឺវចីសច្ចៈ ។ បទថា **ធម្មេ** គឺក្នុងធម៌ បានដល់កុសលកម្មបថ ១០ ។ បទថា **ទមេ** គឺក្នុងការទូន្មានឥន្ទ្រិយ ។ បទថា **សំយមេ** គឺក្នុងការសង្រួមដោយសីល ។ ក្នុងបទនេះថា **សោចេយ្យសីលាលយុ-បោសថេសុ ច** អធិប្បាយថា ភាពជាអ្នកស្អាត ៣ យ៉ាង មានស្អាតផ្លូវកាយជាដើម សីលដែលជាទីអាល័យ គឺសីលាលយ ឧបោសថកម្ម គឺឧបោសថ ។ បទថា **អហឹសាយ** គឺមិនបៀតបៀន ។ បទថា **សមន្តមាចរិ** គឺប្រព្រឹត្តគ្រប់ទាំងអស់ ។ បទថា **អនុភិ** ប្រែថា សោយហើយ ។ បទថា **វេយ្យញ្ជនិកា** គឺអ្នកទាយលក្ខណៈ ។ បទថា **បរាភិភូ** គឺអាចគ្របសង្កត់អ្នកដទៃ ។ បទថា **សត្តុភិ** គឺសត្រូវគ្របសង្កត់មិនបាន ។ ក្នុងបទថា **ន សោ គច្ឆតិ ជាតុ ខម្ភនំ** ព្រះមហាបុរសនោះ ជាអគ្គបុគ្គលដោយចំណែកមួយប៉ុណ្ណោះ រមែងមិនដល់ភាពជាអ្នកដែលបុគ្គលណាម្នាក់ គប្បីគ្របសង្កត់បាន ។ បទថា **ឯសោ ហិ**

**តស្ស ធម្មតា** សេចក្តីថា នេះជាធម្មតា គឺនេះជាសភាវៈរបស់មហាបុរសនោះ ។

[ ៥ ] បទថា **ឧព្វេគឧត្តាសភយំ** បានដល់ ភ័យ គឺការតក់ស្លុត និង ភ័យ គឺការស្រៀវខ្លាច អធិប្បាយថា ក្នុងភ័យទាំងពីរនោះ ភ័យអាស្រ័យ ការប្លន់ ការចងជាដើម អំពីចោរក្តី អំពីព្រះរាជាក្តី អំពីបច្ចាមិត្តក្តី ឈ្មោះថា ភ័យ គឺការតក់ស្លុត ភ័យធ្វើឲ្យកើតការព្រឺរោមព្រឺស្បែក ព្រោះអាស្រ័យសត្វ មានដំរីក្តី សេះកាចក្តី ពស់ក្តី និងយក្ខជាដើមក្តី ត្រឹមតែមួយភ្លែត ឈ្មោះថា ភ័យ គឺស្រៀវខ្លាច ។ ធ្វើឲ្យភ័យទាំងអស់នោះ បន្ទាបធំ គឺស្ងប់ ។ បទថា **សំវិធាតា** គឺចាត់ចែងហើយ ។ សួរថា តើចាត់ចែងដូចម្តេច គឺសាងរោងទាន ក្នុងទីដែលរង្កៀសក្នុងព្រៃ ហើយឲ្យអ្នកដែលមកក្នុងព្រៃនោះបរិភោគ ហើយ ឲ្យពួកមនុស្សនាំទៅ កាលជនទាំងឡាយមិនអាចចូលទៅកាន់ទីនោះបាន ក៏ បញ្ជូនពួកមនុស្សឲ្យនាំចូលទៅ ចាត់ចែងរក្សាក្នុងទីនោះៗ សូម្បីក្នុងក្រុងជា ដើម ក៏ចាត់ចែងយ៉ាងនេះ ។ បទថា **សបរិវារញ្ច ទានំ អាទាសិ** សេចក្តីថា បានឲ្យទានវត្ថុ ១០ យ៉ាង មាន **អន្នំ ទានំ** ជាដើម ។

ក្នុងពាក្យទាំងឡាយនោះ ពាក្យថា **អន្នំ** បានដល់ បបរ អធិប្បាយថា កាលឲ្យបបរនោះ មិនបានដាក់ត្រង់ទ្វារ ហើយឲ្យ បានរោយលាជ និងផ្កា ក្នុងទីបូកលាបដោយរបស់ខៀវខាងក្នុងនិវេសន៍ ក្រាលអាសនៈ ចងពិតាន ធ្វើសក្ការៈដោយរបស់ក្រអូប និងផ្សែងក្រអូបជាដើម និមន្តភិក្ខុសង្ឃឲ្យគង់ ហើយប្រគេន ម្យ៉ាងទៀត កាលប្រគេនបបរ បានប្រគេនម្ហូបផងដែរ ។ កាល សម្រេចការឆាន់បបរ បានលាងជើង យកប្រេងលាប ប្រគេនរបស់ទំពាទាំង-

ឡាយច្រើនយ៉ាង ក្នុងទីបំផុតបានប្រគេនបណីតភោជន មានស្ងួបៈ និងព្យញ្ជនៈច្រើនយ៉ាង ។ កាលប្រគេនទឹកបាន ប្រគេនគ្រឿងផឹក ៨ យ៉ាង មានអម្ពបានជាដើម ។ លុះប្រគេនបបរទាំងនោះហើយ កាលប្រគេនសំពត់ មិនបានប្រគេនសំពត់សុទ្ធៗ ប៉ុណ្ណោះ តែប្រគេនសំពត់ដ៏គ្រប់គ្រាន់ មានសំពត់មួយជាន់ និងពីរជាន់ជាដើម បានប្រគេនម្ជុលខ្លះ អំបោះខ្លះ ហុងអំបោះខ្លះ ក្នុងទីដែលធ្វើការដេរខ្លះ បានប្រគេនអាសនៈ បបរ ប្រេងលាបជើង ប្រេងលាបខ្នង គ្រឿងជ្រលក់ ស្លឹកឈើប្រភេទផ្សេងៗ ស្នូកជ្រលក់សំពត់ ដោយហោចទៅ ពណ៌ជ្រលក់ចីវរខ្លះ កប្បិយការកៈខ្លះ ។ ពាក្យថា យាន គឺស្បែកជើង ។ កាលប្រគេនស្បែកជើងនោះ ក៏បានប្រគេនថង់ដាក់ស្បែកជើង ឈើព្យួរស្បែកជើង ប្រេងលាបស្បែកជើង និងទានវត្ថុ មានបាយជាដើម ដូចពោលហើយខាងដើម ធ្វើឲ្យជាបរិវាររបស់ស្បែកជើងនោះឯង ។ កាលប្រគេនផ្កាកម្រង ក៏មិនបានប្រគេនផ្កាសុទ្ធៗ ដូចគ្នា បានប្រោះផ្កាឈើនោះដោយគ្រឿងក្រអូប ហើយប្រគេនវត្ថុទាំង ៤ យ៉ាងនេះ ក្នុងខាងក្រោយ ធ្វើឲ្យជាបរិវាររបស់ផ្កានោះ ។ កាលប្រគេនគ្រឿងក្រអូប ដើម្បីបូជាពោធិព្រឹក្ស ចេតិយ អាសនៈ និងគម្ពីរជាដើម និងខឿនចេតិយ ក៏មិនបានប្រគេនគ្រឿងក្រអូបសុទ្ធៗ តែម្យ៉ាង បានប្រគេនវត្ថុទាំង ៥ យ៉ាងនេះខាងក្រោយ ព្រមដោយគ្រឿងកិន គ្រឿងជុសនិងភាជនៈសម្រាប់ប្រើ ។ កាលប្រគេនគ្រឿងលាប មានហរិតាល មនោ-សិលា ជាតហិង្គុលជាដើម ក៏មិនបានប្រគេនគ្រឿងលាបសុទ្ធៗ តែម្យ៉ាង បានប្រគេនវត្ថុ ៦ យ៉ាងទាំងនេះ ក្នុងខាងក្រោយ ព្រមទាំងភាជនៈដាក់គ្រឿង

លាប ឲ្យជាបរិវារនៃគ្រឿងលាបនោះ ។ ពាក្យថា ទីដេក គឺគ្រែ និងតាំង សូម្បីកាលប្រគេនគ្រែ និងតាំងនោះ ក៏មិនបានប្រគេនគ្រែ និងតាំងតែម្យ៉ាង បានប្រគេនបន្ទះក្តារ និងឈើជម្រះ ព្រមដោយសំពត់កោជវ សំពត់កម្ពល កម្រាល និងគ្រែ ធ្វើវត្ថុ ៧ យ៉ាងខាងដើម ឲ្យជាបរិវារនៃគ្រែ និងតាំងនោះ ។ កាលឲ្យទីនៅ ក៏មិនបានឲ្យត្រឹមតែផ្ទះប៉ុណ្ណោះទេ បានធ្វើគ្រែ និងតាំង ដែលតាក់តែងយ៉ាងល្អ ប្រដាប់ដោយមាលាកម្ម និងលតាកម្ម ហើយថ្វាយវត្ថុទាំង ៨ យ៉ាងនេះ ក្នុងកាលជាក្រោយ ធ្វើឲ្យជាបរិវារនៃទីនៅនោះ ។ ពាក្យថា ប្រទីប គឺប្រេងប្រទីប អធិប្បាយថា កាលប្រគេនប្រេងប្រទីប មិនបានប្រគេនប្រេងតែម្យ៉ាងប៉ុណ្ណោះទេ ដោយពាក្យថា លោកម្ចាស់ទាំងឡាយ សូមញ៉ាំងប្រទីបឲ្យភ្លឺដោយប្រេងនេះ ក្នុងវៀនព្រះចេតិយ វៀនពោធិព្រឹក្ស រោងស្តាប់ធម៌ កុដិ ទីប្រាប់គម្ពីរ បានប្រគេនវត្ថុទាំង ៩ យ៉ាងនេះ ក្នុងកាលខាងក្រោយ ព្រមដោយប្រឆេះចង្កៀង ឆ្នាំងដីតូចៗ និងភាជនៈដាក់ប្រេងជាដើម ធ្វើឲ្យជាបរិវារនៃប្រេងប្រទីបនោះឯង ។

បទថា **សុរិភត្តន្តរានិ** កាត់បទជា **សុរិភត្ត អន្តរានិ ។** បទថា **រាជានោ** គឺក្សត្រដែលអភិសេកហើយ ។ បទថា **ភោគិកា** គឺចៅហ្វាយស្រុក ។ បទថា **កុមារា** គឺពួករាជកុមារ ។ ការឲ្យព្រមដោយបរិវារ ឈ្មោះថា កម្ម ក្នុងទីនេះ ។ ចក្កលក្ខណៈដែលកើតឡើង ដោយន័យថា លោក ព្រមទាំងទេវលោកចូរដឹង ដោយហេតុនេះថា ព្រះមហាបុរសបានថ្វាយទាន ធ្វើឲ្យមានរបស់ជាបរិវារ ដូច្នេះ ឈ្មោះថា ធម៌ដែលប្រហែលនឹងកម្ម ។ ចក្កលក្ខណៈ

នោះឯង ឈ្មោះថា លក្ខណៈ ។ ភាពជាអ្នកមានបរិវារច្រើន ឈ្មោះថា អានិសង្ស ។

បទថា **តត្ថេតំ វុច្ចតិ** លោកពោលគាថានេះ សម្តែងដល់អត្ថនោះ ។ ពិតហើយ គាថាមាន ២ យ៉ាង គឺសម្តែងអត្ថនោះ ១ សម្តែងអត្ថពិសេស ១ ។ ក្នុងពីរយ៉ាងនោះ គាថាដែលលោកសម្តែងអត្ថ ដែលមកក្នុងបាលីទុំះឯង ឈ្មោះថា សម្តែងអត្ថនោះ ។ គាថាដែលលោកសម្តែងអត្ថ ដែលមិនបានមកក្នុងបាលី ឈ្មោះថា សម្តែងអត្ថពិសេស តែគាថានេះ សម្តែងអត្ថនោះ ។

[ ៦ ] ក្នុងបទទាំងនោះ បទថា **បុរេ** ប្រែថា ក្នុងជាតិមុន ។ បទថា **បុរត្ថ** ជាវេវចនៈរបស់បទនោះឯង ។ បទថា **បុរិមាសុ ជាតីសុ** គឺជាការសម្តែងសេចក្តីបំណាងដល់កម្មដែលខ្លួនធ្វើហើយក្នុងជាតិមុន អំពីជាតិនេះ ។ បទថា **ឧព្ពេគឧត្តាសភយាបនូទនោ** សេចក្តីថា បន្ទោបង់ភ័យ គឺសេចក្តីភ័យខ្លាច និងភ័យ គឺសេចក្តីតក់ស្លុត ។ បទថា **ឧស្សុក្កោ** គឺបង្អោនទៅហើយ ។ បទថា **សតបុញ្ញលក្ខណំ** សេចក្តីថា លក្ខណៈនីមួយៗ កើតឡើងដោយបុញ្ញកម្មទាំងរយៗ កាលបើយ៉ាងនេះ ជនទាំងឡាយ រមែងមិនពេញចិត្តថា បុគ្គលម្នាក់គប្បីជាព្រះពុទ្ធបាន តែសត្វទាំងពួងក្នុងចក្រវាល ដែលមិនមានទីបំផុត គប្បីធ្វើកម្មនីមួយៗ អស់ ៧ ដង ព្រះពោធិសត្វតែមួយព្រះអង្គប៉ុណ្ណោះកើតឡើង ព្រោះធ្វើកម្មដែលជនទាំងឡាយប្រមាណប៉ុណ្ណោះ ធ្វើហើយម្តងៗគុណនឹងមួយរយ ព្រោះដូច្នោះ ជនទាំងឡាយពេញចិត្តសេចក្តីនេះថា ព្រះពោធិសត្វមានលក្ខណៈប្រកបដោយបុណ្យទាំងរយ ។ បទថា **មនុស្សាសុរ-**

**សត្តារក្ខសា** គឺមនុស្ស ១ អសុរ ១ សក្កទេវរាជ ១ អារក្សទឹក ១ ។

[ ៧ ] បទថា **អន្តរា** គឺក្នុងរវាងចុតិបន្តមកពីបដិសន្ធិ ការវៀរចាកពីបាណាតិបាត ឈ្មោះថា កម្មក្នុងទីនេះ ។ ជនទាំងឡាយកាលធ្វើបាណាតិបាតដើរដោយចុងជើង ព្រោះខ្លាចឮសំឡេងជើង ទៅសម្លាប់អ្នកដទៃ ឈ្មោះថាធម៌ប្រហែលនឹងកម្ម ។ តអំពីនោះ ជនទាំងនោះគិតថា ជនចូរជីងកម្មនោះរបស់អ្នកទាំងនោះ ដោយហេតុនេះ ជាអ្នកមានជើងកោងខាងមុខ កោងខាងក្រោយ មានជើងប្រហោង ចុងជើងកំបុត កែងជើងកំបុត ឯលោក ព្រមទាំងទេវលោក ចូរជីងព្រះតថាគតទ្រង់យាងទៅដោយចុងជើង មិនត្រូវអ្នកដទៃសម្លាប់ ព្រោះដូច្នោះ មហាបុរិសលក្ខណៈ គឺមានកែងវែងកើតឡើង ។ ជនទាំងឡាយមានកាយខ្ពស់ នឹងទៅសម្លាប់អ្នកដទៃ ក្រែងថា អ្នកដទៃនឹងឃើញទើបឱនចុះសម្លាប់អ្នកដទៃ ម្យ៉ាងទៀត ជនទាំងនោះគិតថា ជនទាំងនេះទៅសម្លាប់អ្នកដទៃយ៉ាងនេះ អ្នកដទៃចូរជីងកម្មនោះរបស់ជនទាំងនោះ ដោយហេតុនេះ ទើបធ្វើជាមនុស្សគម ជាមនុស្សតឿ ឬជាមនុស្សពិការ លោក ព្រមទាំងទេវលោក ចូរជីងភាពដែលព្រះតថាគតទ្រង់ទៅយ៉ាងនោះ មិនត្រូវអ្នកដទៃសម្លាប់ដោយហេតុនេះ ព្រោះដូច្នោះ មហាបុរិសលក្ខណៈ គឺមានព្រះវរកាយត្រង់ដូចកាយព្រហ្មកើតឡើង ។ ម្យ៉ាងទៀត ជនទាំងឡាយមានដៃកាន់អាវុធ ឬដំបង និងកណ្តាប់ដៃសម្លាប់អ្នកដទៃ ជនទាំងនោះគិតថា ជនចូរជីងភាពដែលជនទាំងនោះ ត្រូវអ្នកដទៃសម្លាប់ ដោយហេតុនេះ ជាអ្នកមានម្រាមខ្វី មានដៃខ្វី មានម្រាមង ឬដៃខ្វេ លោក ព្រមទាំងទេវលោក ចូរជីង

ចំពោះព្រះតថាគត ជាបុគ្គលមិនត្រូវអ្នកដទៃសម្លាប់យ៉ាងនេះ ដោយហេតុនេះ ព្រោះដូច្នោះ មហាបុរិសលក្ខណៈ គឺមានព្រះអង្គុលីវែងកើតឡើង នេះ គឺធម៌ដែលស្រដៀងកម្ម ក្នុងបទនេះ ឯលក្ខណៈ ៣ យ៉ាងនេះឯង ឈ្មោះថាលក្ខណៈ ។ ភាពជាអ្នកមានអាយុវែង ជាអានិសង្សនៃលក្ខណៈ ។

[ ៨ ] ក្នុងបទនេះថា **មរណវធភយមត្តនោ** អធិប្បាយថា ការសម្លាប់ពោល គឺមរណៈ ជាភ័យពីការសម្លាប់ឲ្យស្លាប់ គឺសម្លាប់ជាហេតុឲ្យសត្វស្លាប់ ជាភ័យ ដឹងភ័យនោះរបស់ខ្លួនហើយ វៀរចេញ ។ បទថា **បដិវិរតោ បរំ មរណាយ** សេចក្តីថា បុគ្គលដឹងថា ភ័យអំពីសេចក្តីស្លាប់របស់យើង ជីវិតជាទីស្រឡាញ់របស់យើង យ៉ាងណា សូម្បីរបស់អ្នកដទៃក៏ដូច្នោះ បានជាអ្នកវៀរស្រឡះខាងមុខអំពីសេចក្តីស្លាប់ ។ បទថា **សុចរិតេន** សេចក្តីថា ប្រព្រឹត្តល្អហើយ ។ បទថា **សគ្គមគមាសិ** ប្រែថា ទៅកាន់ស្ថានសួគ៌ ។ បទថា **ចវិយ បុនរិធាគតោ** គឺឃ្លាតទៅហើយ ត្រឡប់មកក្នុងមនុស្សលោកនេះទៀត ។ បទថា **ទីឃបាសុណ្ហិកោ** ប្រែថា មានកែងព្រះបាទវែង ។ បទថា **ព្រហ្មាវ សុជុ** គឺមានព្រះវរកាយត្រង់ល្អដូចព្រហ្ម ។ បទថា **សុភុជោ** គឺព្រះពាហាល្អ ។ បទថា **សុសុ** គឺសូម្បីក្នុងវេលាចាស់ ក៏នៅតែក្មេង ។ បទថា **សុសណ្ឋិតោ** គឺដល់ព្រមដោយទ្រទ្រង់ទ្រាយល្អ ។ បទថា **មុទុតលុនង្គុលិយស្ស** គឺមានព្រះអង្គុលីទន់ល្វន់ ។ បទថា **បុរិសវរគ្គលក្ខណោហិ** ប្រែថា ដោយលក្ខណៈដ៏ប្រសើររបស់បុរសដ៏ប្រសើរ ។ បទថា **ចិរយាបនាយ** បានដល់ ដើម្បីឲ្យប្រព្រឹត្តទៅយូរ គឺដើម្បីភាពជាបុគ្គលមានអាយុវែង ។ បទថា **ចិរំ យបេតិ** គឺឲ្យប្រព្រឹត្តទៅ

ទៅយូរ ។ បទថា **ចិរតរំ បព្វជតិ យទិ តតោ ហិ** សេចក្ដីថា ប្រសិនបើឲ្យប្រព្រឹត្តទៅយូរជាងនោះ រមែងបួសដោយពិត ។ បទថា **យាបយតិ វសិទ្ធិការវធាយ** សេចក្ដីថា ជាអ្នកដល់នូវភាពជំនាញ រមែងឲ្យជីវិតរស់នៅដោយឥទ្ធិការនា ។

[ ៩ ] បទថា **រសិតានំ** គឺបរិបូណ៌ដោយរស ។ ក្នុងបទថា **ខាទ-នីយានំ** ជាដើម បានដល់ របស់ទំពា មាននំម្សៅជាដើម ឈ្មោះថា របស់គួរទំពា ។ បទថា **ភោជនីយានិ** បានដល់ ភោជន ៥ យ៉ាង ។ បទថា **សាយនីយានិ** បានដល់ សប្បិ នវនីតជាដើម ដែលគួរលិទ្ធភក្ស ។ បទថា **លេហនីយានិ** បានដល់ បាយាសធ្វើដោយម្សៅជាដើម ដែលគួរលិទ្ធ ។ បទថា **ចានានិ** បានដល់ ទឹកបាន ៨ ។ ការឲ្យភោជនដែលប្រណីតនេះ ព្រះតថាគតបានឲ្យហើយ អស់ ៤ អសង្ខេយ្យ និង ១ សែនកប្ប ឈ្មោះថា កម្មក្នុងទីនេះ ។ កាលភោជនសៅហ្មងធ្លាក់ដល់ពោះ លោហិតស្មោកស្មាំង សាច់ស្អួត ឈ្មោះថា ធម៌ប្រហែលនឹងកម្ម ព្រោះដូច្នោះ សត្វទាំងឡាយអ្នកឲ្យរបស់សៅហ្មង គិតថា ជនចូរដឹងភាពនៃរបស់សៅហ្មង ដែលសត្វទាំងនោះឲ្យហើយ ដោយហេតុនេះ ជាអ្នកមានសាច់តិច មានឈាមតិច មានបាយនិងទឹកបានលំបាក ដូចមនុស្សប្រេត ។ តែកាលភោជនប្រណីតធ្លាក់ដល់ពោះ សាច់ និងឈាម រមែងចម្រើន សត្វទាំងឡាយមានកាយបរិបូណ៌ គួរជ្រះថ្លា គួរស្រឡាញ់ គួរករុណា ព្រោះដូច្នោះ លោក ព្រមទាំងទេវលោក ចូរដឹងភាពដែលព្រះតថាគត ជាបុគ្គលឲ្យភោជនដ៏ប្រណីត រហូតអស់កាលយូរ

ដោយហេតុនេះ ព្រោះដូច្នោះ មហាបុរិសលក្ខណៈ គឺមានមំសៈពេញក្នុងទី ៧ អន្លើ រមែងកើតឡើង ព្រះលក្ខណៈពេញក្នុងទី ៧ អន្លើនេះឯង ឈ្មោះថា លក្ខណៈ ភាពជាអ្នកបានរបស់ប្រណីត ឈ្មោះថា អានិសង្ស ។

[ ១០ ] បទថា **ខជ្ជភោជនំ អថ លេយ្យសាយិតំ** បានដល់ របស់ទំពា របស់បរិភោគ របស់លិទ្ធ និងរបស់ក្លក្ស ។ បទថា **ឧត្តមគ្គរសទាយកោ** ប្រែថា អ្នកឲ្យរសប្រណីត ជាអ្នកខ្ពង់ខ្ពស់ ឬអ្នកឲ្យរសដ៏ឧត្តមប្រសើរ ។ បទថា **សត្ត ចុស្សទេ** គឺព្រះលក្ខណៈពេញក្នុងទី ៧ កន្លែង ។ បទថា **តនត្ត-ជោតកំ** គឺសម្តែងអាហារ មានរបស់ទំពា របស់បរិភោគជាដើម អធិប្បាយថា ញុំាងលាភឲ្យប្រព្រឹត្តទៅដល់បរិព្វាជកទាំងនោះ ។ បទថា **បព្វជ្ជំបិ ច** ប្រែថា សូម្បីបួសហើយ ។ បទថា **តទាធិគច្ឆតិ** កាត់បទជា **តំ អធិគច្ឆតិ ។** បទថា **លាភិរុត្តមំ** កាត់បទជា **លាភិ ឧត្តមំ ។**

[ ១១ ] ក្នុងបទថា **ទានេន** ជាដើម សេចក្តីថា បុគ្គលពួកខ្លះ ជាអ្នកគួរសង្គ្រោះដោយការឲ្យតែម្យ៉ាង ក៏សង្គ្រោះបុគ្គលនោះដោយការឲ្យបាន ឲ្យគ្រឿងបរិក្ខារអ្នកបួសដល់អ្នកបួស ឲ្យគ្រឿងប្រើប្រាស់គ្រហស្ថ ដល់ពួកគ្រហស្ថ ។ បទថា **បិយវាចេន** សេចក្តីថា បុគ្គលពួកខ្លះ ជាអ្នកនិយាយថា អ្នកនេះ រមែងឲ្យទានដែលគួរឲ្យ តែមើលងាយទានទាំងនោះ ដោយពាក្យតែម្យ៉ាង ហើយធ្វើឲ្យវិនាស ការឲ្យរបស់អ្នកនោះ នឹងមានប្រយោជន៍អ្វី ពួកខ្លះជាអ្នកនិយាយថា បុគ្គលនេះមិនឲ្យទានក៏ពិត តែកាលនិយាយ រមែងមើលងាយដូចប្រេង អ្នកនេះឲ្យក៏ដោយ មិនឲ្យក៏ដោយ ពាក្យនិយាយរបស់គេ រមែង

មានតម្លៃមួយពាន់ ។ បុគ្គលបែបនេះ មិនប្រាថ្នាទាន ប្រាថ្នាពាក្យនិយាយគួរស្រឡាញ់តែម្យ៉ាង សង្គ្រោះគេដោយពាក្យជាទីស្រឡាញ់ ។ បទថា **អត្ថចរិយាយ** គឺដោយពាក្យដែលចម្រើនដោយប្រយោជន៍ ព្រោះបុគ្គលពួកខ្លះមិនប្រាថ្នាទាន មិនប្រាថ្នាពាក្យនិយាយគួរស្រឡាញ់ រមែងប្រាថ្នាពាក្យជាប្រយោជន៍ ឲ្យកើតសេចក្តីចម្រើនដល់ខ្លួនប៉ុណ្ណោះ សង្គ្រោះបុគ្គលបែបនេះដោយការប្រព្រឹត្តវត្តដែលជាប្រយោជន៍យ៉ាងនេះថា អ្នកគួរធ្វើវត្តនេះ អ្នកមិនគួរធ្វើវត្តនេះ គួរសេពគប់បុគ្គលបែបនេះ មិនគួរសេពគប់បុគ្គលបែបនេះ ។ បទថា **សមានត្តតាយ** គឺដោយភាពជាអ្នកមានសុខ និងទុក្ខស្មើគ្នា ពិតហើយបុគ្គលពួកខ្លះ មិនប្រាថ្នាសូម្បីតែម្យ៉ាងក្នុងទានជាដើម ប្រាថ្នាភាពជាអ្នកមានសុខ និងទុក្ខស្មើគ្នាយ៉ាងនេះថា អង្គុយលើទីអង្គុយជាមួយគ្នា ដេកលើគ្រែជាមួយគ្នា បរិភោគរួមគ្នា ក្នុងបុគ្គលទាំងនោះ បុគ្គលអាក្រក់ដោយជាតិ តែមានភោគៈច្រើន ជាអ្នកសង្គ្រោះលំបាក ព្រោះមិនអាចធ្វើការបរិភោគ រួមនឹងបុគ្គលនោះបាន កាលមិនធ្វើយ៉ាងនោះ បុគ្គលនោះក៏ក្រោធ អ្នកដែលមានភោគៈតិច សូម្បីក្រៃលែងដោយជាតិ ក៏ជាអ្នកសង្គ្រោះលំបាក ព្រោះបុគ្គលនោះមិនប្រាថ្នាបរិភោគរួមនឹងអ្នកដែលបរិបូណ៌ដោយភោគៈ ព្រោះប្រកាន់ថាអញជាអ្នកមានជាតិ កាលបុគ្គលនោះធ្វើ រមែងក្រោធ តែបុគ្គលដែលថោកថយទាំងពីរយ៉ាង ក៏ជាអ្នកសង្គ្រោះងាយ ព្រោះបុគ្គលនោះ មិនប្រាថ្នាបរិភោគរួមនឹងបុគ្គលក្រៅអំពីនេះ កាលមិនធ្វើ ក៏មិនក្រោធ សូម្បីបុគ្គលដូចជាបុគ្គលទាំងពីរ ក៏ជាអ្នកសង្គ្រោះងាយ បណ្តាភិក្ខុទាំងឡាយ ភិក្ខុទ្រុស្តសីល ជាអ្នក

សង្គ្រោះលំបាក ព្រោះមិនអាចធ្វើការបរិភោគរួមនឹងភិក្ខុនោះបាន កាលមិនធ្វើ យ៉ាងនោះ រមែងក្រោធ ភិក្ខុមានសីលជាអ្នកសង្គ្រោះងាយ ព្រោះជាអ្នកមាន សីល កាលភិក្ខុនោះធ្វើខ្លះ មិនធ្វើខ្លះ ក៏មិនក្រោធ រមែងមិនឃើញអ្នកដទៃ ធ្វើការបរិភោគរួមនឹងខ្លួនដោយចិត្តលាមក ការបរិភោគរួមនឹងអ្នកមានសីល ក៏ធ្វើបានងាយ ព្រោះដូច្នោះ សង្គ្រោះបុគ្គលបែបនេះ ដោយភាពជាអ្នកមាន ខ្លួនស្មើ ដោយប្រការដូច្នេះ ។ បទថា **សុសំគហិតស្ស ហោន្តិ** ប្រែថា ជា បុគ្គលដែលគេសង្គ្រោះបានងាយ អធិប្បាយថា ជននោះចូរឲ្យក្តី មិនឲ្យក្តី ចូរ ធ្វើក្តី មិនធ្វើក្តី ជនទាំងឡាយជាការសង្គ្រោះយ៉ាងល្អហើយ រមែងមិនទម្លាយគ្នា រមែងឲ្យក្នុងកាល ដែលគួរឲ្យដល់បុគ្គលនោះ ជនទាំងឡាយ រមែងគិតយ៉ាង នេះថា ឥឡូវនេះ បុគ្គលនោះប្រហែលមិនមាន ទើបមិនឲ្យដោយហេតុនោះ រឿងអ្វី អញនឹងទំនុកបម្រុងអ្នកឲ្យតែម្យ៉ាង អញនឹងមិនទំនុកបម្រុងអ្នកមិនឲ្យ អ្នកមិនធ្វើ ដូច្នេះ ។ កម្ម គឺការសង្គ្រោះ មានទានជាដើម ដែលបុគ្គលនោះ ធ្វើអស់កាលយូរ ឈ្មោះថា កម្ម ក្នុងទីនេះ ។ ជនណាជាអ្នកមិនសង្គ្រោះ យ៉ាងនេះ ជននោះ ចូរដឹងភាពដែលបុគ្គលនោះ មិនសង្គ្រោះដោយហេតុនេះ ដូច្នោះ ក្នុងរឿងនេះ ទើបបុគ្គលនោះជាអ្នកមានដៃ និងជើងវែង និងជាអ្នក មានលក្ខណៈរបស់អ្នកដែលតាំងនៅមិនរៀបរយ ឈ្មោះថា ធម៌មានសភាព ប្រហែលនឹងកម្ម ឯលោក ព្រមទាំងទេវលោក ចូរដឹងភាពដែលព្រះតថាគត ទ្រង់ជាអ្នកសង្គ្រោះអស់កាលយូរដោយហេតុនេះ ដូច្នោះ លក្ខណៈ ២ យ៉ាងនេះ រមែងកើតឡើង ។ លក្ខណៈទាំងពីរនេះឯង ឈ្មោះថា លក្ខណៈ ។ ភាពជាអ្នក

មានបរិវារដែលសង្គ្រោះហើយយ៉ាងល្អ ឈ្មោះថា អានិសង្ស ។

[ ១២ ] បទថា **ការិយ** គឺធ្វើហើយ ។ បទថា **ចរិយ** គឺប្រព្រឹត្តហើយ ។ បទថា **អនវមតេន** គឺដោយមិនមើលងាយ អធិប្បាយថា មិនមែនដោយសេចក្តីមិនប្រមាទ មិនមែនដោយទាន ដែលខ្ជីទឲ្យហើយ មិនបានដោយសេចក្តីចំអក ។ បទថា **ចរិយ** គឺឃ្វាតហើយ ។ បទថា **អតិរុចិរសុវគ្គុនស្សរេយ្យំ** សេចក្តីថា ស្អាតក្រៃលែង គួរជ្រះថ្លា មានចំណែកល្អ គឺឈ្លាសដោយល្អ និងគួរសរសើរ គឺប្រកបដោយវត្ថុគប្បីសរសើរ ។ បទថា **សុសុក្កុមារោ** គឺកុមារល្អ ។ បទថា **បរិជនស្ស ហោ** សេចក្តីថា ព្រះអង្គមានបរិវារជនអ្នកធ្វើតាមពាក្យរបស់ព្រះអង្គ ។ បទថា **វិធេយ្យា** គឺគួរត្រួតត្រាតាមសេចក្តីពេញចិត្តក្នុងវត្ថុដែលគួរធ្វើ និងមិនគួរធ្វើ ។ បទថា **មហិមំ** កាត់បទជា **មហឹ ឥមំ** ។ បទថា **បិយវទូ ហិតសុខតំ ជិគីសមានោ** គឺជាអ្នកនិយាយគួរស្រឡាញ់ ប្រាថ្នានូវប្រយោជន៍ និងសុខ ។ បទថា **វចនបដិករស្សាភិប្បសន្នា** កាត់បទជា **វចនបដិករា អស្ស អភិប្បសន្នា** ។ បទថា **ធម្មានុធម្មំ** គឺធម៌ដ៏សមគួរដល់ធម៌ ។

[ ១៣ ] បទថា **អត្ថុបសញ្ហិតំ** បានដល់ អាស្រ័យប្រយោជន៍លោកនេះ និងលោកខាងមុខ ។ បទថា **ធម្មូបសំហិតំ** គឺអាស្រ័យកុសលកម្មបថ ១០ ។ បទថា **ពហុជនំ និទស្សេតិ** គឺពោលពាក្យចង្អុលបង្ហាញ ដល់ជនដ៏ច្រើន ។ បទថា **ទាណីនំ** បានដល់ សត្វទាំងឡាយ ។ បទថា **អគ្គោ** ជាដើម

ជាវេវចនៈនៃគ្នានិងគ្នា ។ វាចាជាវាចាភាសិត ជាវាចាគួរលើកសរសើរ ជាវាចាប្រកបដោយប្រយោជន៍ អស់កាលយូរ ឈ្មោះថា កម្ម ក្នុងទីនេះ ។ ជនណា មិនពោលវាចាលើកសរសើរបែបនេះ ជននោះ ចូរដឹងដល់អ្នកមិនពោលដោយវាចាលើកសរសើរដោយហេតុនេះ ដូច្នោះ ទើបជាអ្នកមានជើងដូចស័ន្ទក្នុងខាងក្រោម និងមានរោមចុះខាងក្រោម ឈ្មោះថា ជាធម៌មានសភាពប្រហែលនឹងកម្ម លោក ព្រមទាំងទេវលោក ចូរដឹងភាពដែលព្រះតថាគត ទ្រង់ពោលវាចាលើកសរសើរ បែបនេះអស់កាលយូរដោយហេតុនេះ ដូច្នោះ ព្រះលក្ខណៈ គឺមានព្រះបាទដូចស័ន្ទផ្កាប់ និងព្រះលក្ខណៈ គឺមានព្រះលោមា មានចុងងឡើងខាងលើ រមែងកើតឡើង ។ លក្ខណៈទាំងពីរនេះឯង ឈ្មោះលក្ខណៈ ។ ភាពជាអ្នកខ្ពង់ខ្ពស់ ឈ្មោះថា អានិសង្ស ។

[ ១៤ ] បទថា **ឃរិយំ** បានដល់ កំពុងពោល ។ បទថា **ពហុជនំ និធំសយិ** បានដល់ សម្តែងប្រយោជន៍ដល់ជនដ៏ច្រើន ។ បទថា **ធម្មយាគំ** បានដល់ យញ្ញ គឺធម្មទាន ។ បទថា **ឧព្ភមុប្បតិតលោមវា សសោ** សេចក្តីថា មានព្រះលោមាតាំងឡើង ។ បទថា **ចានគណ្ឋិរហុ** បានដល់ កព្រះបាទទាំងពីរ ។ បទថា **សាធុ សណ្ឋិតា** បានដល់ តាំងទុកយ៉ាងល្អ ។ បទថា **មំសលោហិតាចិតា** សេចក្តីថា មានព្រះមំសៈ និងព្រះលោហិតបិទបាំង ។ បទថា **តចោត្ថតា** បានដល់ បិទបាំង គឺស្រោបដោយស្បែក ។ បទថា **វជតិ** ប្រែថា ទៅ ។ បទថា **អនោមនិក្កមោ** បានដល់ គឺរស់នៅប្រសើរ រស់នៅមិនអាក្រក់ ។

[ ១៥ ] ក្នុងបទថា **សិប្បំ វា** ជាដើម សេចក្តីថា សិល្បៈពីរយ៉ាងនេះ គឺសិល្បៈថោកទាប និងសិល្បៈខ្ពង់ខ្ពស់ ឈ្មោះថា សិល្បៈ ។ សិល្បៈថោកទាប បានដល់ សិល្បៈត្បាញផែង សិល្បៈធ្វើឆ្នាំង សិល្បៈជាងតម្បាញ សិល្បៈជាងកាត់សក់ ។ សិល្បៈខ្ពស់ បានដល់ សិល្បៈជាងចម្លាក់ សិល្បៈគណនាដោយម្រាមដៃ ។ បទថា **វិជ្ជា** សេចក្តីថា វិជ្ជាមានច្រើនយ៉ាង មានវិជ្ជាស្តោះពស់ជាដើម ។ បទថា **ចរណា** បានដល់ សីល ៥ សីល ១០ បាតិមោក្ខសំវរសីល ។ បទថា **កម្ម** បានដល់ បញ្ញា សេចក្តីដឹងដល់សត្វមានកម្មជារបស់ខ្លួន ។ បទថា **កិលិសេយ្យុំ** ប្រែថា គប្បីលំបាក អធិប្បាយថា ព្រះមហាបុរសគិតថា ដែលឈ្មោះថា អន្តេវាសិកវត្តជាទុក្ខ អន្តេវាសិកវត្តនោះ កុំមានដល់ពួកបុគ្គលនោះយូរពេក ។ បទថា **រាជារហានិ** សេចក្តីថា រាជពាហនៈ មានដំរី និងសេះជាដើម ដែលសមគួរដល់ព្រះរាជា រាជពាហនៈទាំងនោះឯង លោកពោលថា **រាជង្គានិ** ព្រោះជាអង្គនៃសេនារបស់ព្រះរាជា ។ ព្រោះបទថា **រាជូបភោគ** គឺរាជភណ្ឌៈដែលជាគ្រឿងឧបភោគ និងបរិភោគ និងរតនៈទាំង ៧ យ៉ាងនោះឯងរបស់ព្រះរាជា ។ បទថា **រាជានុច្ឆវិកានិ** នេះ កាន់យកគ្រឿងរាជូបភោគទាំងអស់នោះ។ បទថា **សមណារហានិ** បានដល់ ត្រៃចីវរជាដើម ដែលសមគួរដល់ពួកសមណៈ ។ បទថា **សមណង្គានិ** បានដល់ បរិស័ទ ៤ ដែលជាចំណែកពួកសមណៈ ។ បទថា **សមណូបភោគានិ** បានដល់ បរិក្ខារដែលជាគ្រឿងឧបភោគរបស់សមណៈ ។ បទថា **សមណានុច្ឆវិកានិ** ជាឈ្មោះរបស់បរិក្ខារទាំងនោះ ។ ក៏

ប្រាប់សិល្បៈជាដើម ដោយសេចក្តីគោរពអស់កាលយូរ ឈ្មោះថា កម្មក្នុងទីនេះ មិនប្រាប់សិល្បៈដោយសេចក្តីគោរពយ៉ាងនេះ ញុំាងពួកអន្តេវាសិក ឲ្យលំបាក ដោយការអង្គុយរោយកោងខ្នង និងចុកស្រពន់ជាដើម រមែងដូចសាច់ស្មងរបស់អ្នកនោះ ត្រូវធូតឲ្យធ្លាក់ទៅ ។ តែលោក ព្រមទាំងទេវលោកចូរដឹងភាពដែលព្រះតថាគត ទ្រង់ប្រាប់ដោយសេចក្តីគោរព ដោយហេតុនេះដូច្នោះ ព្រះលក្ខណៈ គឺមានព្រះជង្ឃា ដូចស្មងសត្វទ្រាយ រៀវស្រួចឡើងទៅតាមលំដាប់ រមែងកើតឡើង ឈ្មោះថា ជាធម៌ប្រហែលគ្នានឹងកម្ម ។ លក្ខណៈនេះឯង ឈ្មោះថា លក្ខណៈ ។ ភាពជាអ្នកមានលាភដែលសមគួរ ឈ្មោះថាអានិសង្ស ។

[ ១៦ ] បទថា **យតុបឃាតាយ** គឺសិល្បៈណា រមែងមិនប្រព្រឹត្តដើម្បីចូលទៅបៀតបៀនបុគ្គលណាម្នាក់ ។ បទថា **កិលិស្សតិ** ប្រែថា នឹងលំបាក ។ បទថា **សុខុមត្តចោត្តជា** ប្រែថា ស្រោបដោយស្បែកដ៏ល្អិត ។

សួរថា លក្ខណៈដទៃ រមែងកើតឡើងដោយកម្មដទៃឬ ឆ្លើយថា មិនកើត ។ លក្ខណៈដែលកើតឡើងជាអនុព្យញ្ជនៈ ព្រោះដូច្នោះ ទើបលោកពោលក្នុងសេចក្តីនេះ ។

[ ១៧ ] បទថា **សមណំ វា** ឈ្មោះថា សមណៈ ព្រោះអត្ថថា មានបាបស្ងប់ហើយ ។ បទថា **ព្រាហ្មណំ វា** សេចក្តីថា ឈ្មោះថា ព្រាហ្មណ៍ព្រោះអត្ថថា មានបាបដែលបន្សាត់ហើយ ។ ក្នុងបទថា **មហាបញ្ញោ** ជាដើមសេចក្តីថា ជាអ្នកប្រកបដោយមហាបញ្ញាជាដើម សេចក្តីផ្សេងគ្នារបស់មហា-

បញ្ញាជាដើម មានដូចតទៅនេះថា

តើប្រាជ្ញាជាធំ[១] ដូចម្តេច ។ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវអត្ថជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវធម៌ជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវនិរុត្តិជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវបដិភាណជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវសីលក្ខន្ធជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវសមាធិក្ខន្ធជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវបញ្ញាខន្ធជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវវិមុត្តិក្ខន្ធជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវវិមុត្តិ-ញ្ញាណទស្សនក្ខន្ធជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវឋានាឋានៈជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវវិហារសមាបត្តិជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវអរិយសច្ចជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវសតិប្បដ្ឋានជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវសម្មប្បធានជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវឥទ្ធិបាទជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវឥន្ទ្រិយជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវពលជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវពោជ្ឈង្គជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវអរិយមគ្គជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវសាមញ្ញផលជាធំ ឈ្មោះថា ប្រាជ្ញាជាធំ

១- ក្នុងលក្ខណសូត្រនេះ លោកប្រែថា ប្រាជ្ញាច្រើន តែក្នុងទីនេះ ព្រះអដ្ឋកថា លោកលើកយក អំពីបដិសម្ភិទាមគ្គ ។

ព្រោះកំណត់យកនូវអភិញ្ញាជាធំ ឈ្មោះថា ប្រាជ្ញាជាធំ ព្រោះកំណត់យកនូវព្រះនិព្វាន ដែលមានអត្ថដ៏ឧត្តមជាធំ ។

តើបញ្ញាដ៏ក្រាស់ដូចម្តេច ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងខន្ធផ្សេងៗ ដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងធាតុផ្សេងៗ ដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងអាយតនៈផ្សេងៗ ដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងបដិច្ចសមុប្បាទផ្សេងៗ ដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងធម៌ដ៏សូន្យ និងធម៌ដែលបណ្ឌិតគប្បីបានផ្សេងៗ ដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងអត្ថផ្សេងៗ ដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងធម៌ផ្សេងៗ ដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងនិរុត្តិផ្សេងៗ ដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងបដិភាណផ្សេងៗ ដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងសីលក្ខន្ធផ្សេងៗ ដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងសមាធិក្ខន្ធផ្សេងៗ ដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងបញ្ញាក្ខន្ធផ្សេងៗ ដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងវិមុត្តិក្ខន្ធផ្សេងៗ ដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងវិមុត្តិញាណទស្សនក្ខន្ធផ្សេងៗ ដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងហេតុនិងមិនមែនហេតុផ្សេងៗ ដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណ

ប្រព្រឹត្តទៅក្នុងវិហារសមាបត្តិផ្សេងៗ ដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងអរិយសច្ចផ្សេងៗ ដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងសតិប្បដ្ឋានផ្សេងៗ ដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងសម្មប្បធានផ្សេងៗ ដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងឥទ្ធិបាទផ្សេងៗ ដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងឥន្ទ្រិយផ្សេងៗ ដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងពលផ្សេងៗ ក៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងពោជ្ឈង្គផ្សេងៗ ដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងអរិយមគ្គផ្សេងៗ ដ៏ក្រាស់ ឈ្មោះថាបញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងសាមញ្ញផលផ្សេងៗ ដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងអភិញ្ញាផ្សេងៗ ដ៏ក្រាស់ ឈ្មោះថា បញ្ញាដ៏ក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងប្រយោជន៍ដ៏ក្រៃលែង គឺព្រះនិព្វាន កន្លងនូវធម៌ដែលទូទៅដល់បុថុជ្ជន ។

តើបញ្ញានាំឲ្យរីករាយដូចម្ដេច ឈ្មោះថា បញ្ញានាំឲ្យរីករាយ ព្រោះបុគ្គលពួកខ្លះក្នុងលោកនេះ ច្រើនដោយសេចក្ដីរីករាយ ច្រើនដោយសេចក្ដីស្រស់ស្រាយ ច្រើនដោយសេចក្ដីត្រេកអរ ច្រើនដោយសេចក្ដីស្រួលចិត្ត រមែងញ៉ាំងសីលឲ្យពេញលេញ ឈ្មោះថា បញ្ញានាំឲ្យរីករាយ ព្រោះបុគ្គលអ្នកច្រើនដោយសេចក្ដីរីករាយ ច្រើនដោយសេចក្ដីស្រស់ស្រាយ ច្រើនដោយសេចក្ដីត្រេកអរ ច្រើនដោយសេចក្ដីស្រួលចិត្ត រមែងញ៉ាំងឥន្ទ្រិយសំវរៈឲ្យ

ពេញលេញ ឈ្មោះថា បញ្ញានាំឲ្យរីករាយ ព្រោះបុគ្គលអ្នកច្រើនដោយសេចក្តីរីករាយ ច្រើនដោយសេចក្តីស្រស់ស្រាយ ច្រើនដោយការត្រេកអរ ច្រើនដោយការស្រួលចិត្ត រមែងញ៉ាំងសេចក្តីដឹងប្រមាណក្នុងភោជនឲ្យពេញលេញ ឈ្មោះថា បញ្ញានាំឲ្យរីករាយ ព្រោះបុគ្គលអ្នកច្រើនដោយសេចក្តីរីករាយ ច្រើនដោយសេចក្តីស្រស់ស្រាយ ច្រើនដោយសេចក្តីត្រេកអរ ច្រើនដោយសេចក្តីស្រួលចិត្ត រមែងញ៉ាំងសេចក្តីប្រកបរឿយៗ ក្នុងសេចក្តីភ្ញាក់រឭកឲ្យពេញលេញ ឈ្មោះថា បញ្ញានាំឲ្យរីករាយ ព្រោះបុគ្គលអ្នកច្រើនដោយការរីករាយ ច្រើនដោយការស្រស់ស្រាយ ច្រើនដោយការត្រេកអរ ច្រើនដោយការស្រួលចិត្ត រមែងញ៉ាំងសីលក្ខន្ធ ។បេ។ សមាធិក្ខន្ធ បញ្ញាខន្ធ វិមុត្តិក្ខន្ធ វិមុត្តិញាណទស្សនក្ខន្ធឲ្យពេញលេញ ឈ្មោះថា បញ្ញានាំឲ្យរីករាយ ព្រោះចាក់ធ្លុះចំពោះនូវហេតុ និងមិនមែនហេតុ ព្រោះញ៉ាំងវិហារសមាបត្តិឲ្យពេញលេញ ព្រោះចាក់ធ្លុះនូវអរិយសច្ច ព្រោះញ៉ាំងសតិប្បដ្ឋានឲ្យចម្រើន ព្រោះញ៉ាំងសម្មប្បធានឲ្យចម្រើន ព្រោះញ៉ាំងឥទ្ធិបាទឲ្យចម្រើន ព្រោះញ៉ាំងឥន្ទ្រិយឲ្យចម្រើន ព្រោះញ៉ាំងពលឲ្យចម្រើន ព្រោះញ៉ាំងពោជ្ឈង្គឲ្យចម្រើន ព្រោះញ៉ាំងអរិយមគ្គឲ្យចម្រើន ព្រោះធ្វើឲ្យជាក់ច្បាស់នូវសាមញ្ញផល ឈ្មោះថា បញ្ញានាំឲ្យរីករាយ ព្រោះបុគ្គលអ្នកច្រើនដោយសេចក្តីរីករាយ ច្រើនដោយសេចក្តីស្រស់ស្រាយ ច្រើនដោយសេចក្តីត្រេកអរ ច្រើនដោយសេចក្តី

ស្រួលចិត្ត រមែងចាក់ធ្លុះនូវអភិញ្ញា ឈ្មោះថា បញ្ញានាំឲ្យរីករាយ ព្រោះបុគ្គលអ្នកច្រើនដោយសេចក្ដីរីករាយ ច្រើនដោយសេចក្ដីស្រស់ស្រាយ ច្រើនដោយសេចក្ដីត្រេកអរ ច្រើនដោយសេចក្ដីស្រួលចិត្ត រមែងធ្វើឲ្យជាក់ច្បាស់នូវប្រយោជន៍ដ៏ក្រៃលែង គឺនិព្វាន ។

តើបញ្ញាជាគ្រឿងស្ទុះទៅដូចម្ដេច ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះរូបណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ខាងក្នុងក្ដី ខាងក្រៅក្ដី គ្រោតគ្រាតក្ដី ល្អិតក្ដី ថោកទាបក្ដី ឧត្ដមក្ដី រូបណាក្នុងទីឆ្ងាយក្ដី ក្នុងទីជិតក្ដី បញ្ញាស្ទុះទៅ ចាប់កាន់រូបទាំងអស់នោះថាមិនទៀង ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះស្ទុះទៅចាប់ថាជាទុក្ខ ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះស្ទុះទៅចាប់ថា មិនមែនជារបស់ខ្លួន ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះវេទនាណាមួយ ។បេ។ សញ្ញាណាមួយ សង្ខារទាំងឡាយណាមួយ វិញ្ញាណណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ខាងក្នុងក្ដី ខាងក្រៅក្ដី គ្រោតគ្រាតក្ដី ល្អិតក្ដី ថោកទាបក្ដី ឧត្ដមក្ដី វិញ្ញាណណាមួយ ក្នុងទីឆ្ងាយក្ដី ក្នុងទីជិតក្ដី បញ្ញាស្ទុះទៅចាប់កាន់វិញ្ញាណទាំងអស់( នោះ ) ថាមិនទៀង ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះស្ទុះទៅចាប់ថាជាទុក្ខ ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះស្ទុះទៅចាប់ថាមិនមែនជារបស់ខ្លួន ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះស្ទុះទៅចាប់កាន់ចក្ខុ ។បេ។ កាន់ជរាមរណៈ ជាអតីត

អនាគត បច្ចុប្បន្នថាមិនទៀង ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះស្ទុះទៅចាប់ថាជាទុក្ខ ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះស្ទុះទៅចាប់ថាមិនមែនជារបស់ខ្លួន ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះថ្លឹង ពិចារណា អប់រំ ធ្វើឲ្យជាក់ច្បាស់ថារូប ជាអតីត អនាគត បច្ចុប្បន្ន ឈ្មោះថា មិនទៀងដោយអត្ថថា អស់ទៅ ឈ្មោះថា ជាទុក្ខ ដោយអត្ថថា ជាភ័យ ឈ្មោះថា ជាអនត្តា ដោយអត្ថថា គ្មានខ្លឹម ហើយស្ទុះទៅចាប់ក្នុងទីជាទីរលត់រូប គឺព្រះនិព្វាន ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះថ្លឹង ពិចារណា អប់រំ ធ្វើឲ្យជាក់ច្បាស់ថា វេទនា សញ្ញា សង្ខារ វិញ្ញាណ ចក្ខុ ។បេ។ ជរាមរណៈ ជាអតីត អនាគត បច្ចុប្បន្ន ឈ្មោះថា មិនទៀង ដោយអត្ថថា អស់ទៅ ឈ្មោះថា ជាទុក្ខ ដោយអត្ថថា ជាភ័យ ឈ្មោះថា ជាអនត្តា ដោយអត្ថថា មិនមានខ្លឹម ហើយស្ទុះទៅចាប់ក្នុងទីជាទីរលត់នូវជរាមរណៈ គឺព្រះនិព្វាន ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះថ្លឹង ពិចារណា អប់រំ ធ្វើឲ្យជាក់ច្បាស់ថារូប ជាអតីត អនាគត បច្ចុប្បន្ន ឈ្មោះថា មិនទៀង មានបច្ច័យតាក់តែងអាស្រ័យនូវបច្ច័យហើយកើតឡើង មានការអស់ទៅជាធម្មតា មានការវិនាសទៅជាធម្មតា មានការប្រាសចាករាគៈជាធម្មតា មានការរលត់ជាធម្មតា ហើយស្ទុះទៅចាប់ក្នុងទីជាទីរលត់រូប គឺព្រះនិព្វាន ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះថ្លឹង ពិចារណា អប់រំ ធ្វើឲ្យជាក់ច្បាស់ថា វេទនា សញ្ញា សង្ខារ

វិញ្ញាណ ចក្ខុ ។បេ។ ជរាមរណៈ ជាអតីត អនាគត បច្ចុប្បន្ន ឈ្មោះថា មិនទៀង មានបច្ច័យប្រជុំតាក់តែង អាស្រ័យនូវបច្ច័យហើយកើតឡើង មានការអស់ទៅជាធម្មតា មានការវិនាសទៅជាធម្មតា មានការប្រាសចាករាគៈជាធម្មតា មានការរលត់ជាធម្មតា ហើយស្ងប់ទៅបាត់ ក្នុងទីជាទីរលត់ជរាមរណៈ គឺព្រះនិព្វាន ។

តើបញ្ញាដ៏មុតដូចម្ដេច ឈ្មោះថា បញ្ញាដ៏មុត ព្រោះទម្លាយនូវកិលេសរហ័ស ឈ្មោះថា បញ្ញាដ៏មុត ព្រោះមិនទទួល លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតនូវកាមវិតក្កដែលកើតឡើងហើយ ឈ្មោះថា បញ្ញាដ៏មុត ព្រោះមិនទទួល លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវព្យាបាទវិតក្កដែលកើតឡើងហើយ ឈ្មោះថា បញ្ញាដ៏មុត ព្រោះមិនទទួលនូវវិហិង្សាវិតក្កដែលកើតឡើងហើយ ។បេ។ ឈ្មោះថា បញ្ញាដ៏មុត ព្រោះមិនទទួល លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាន នូវអកុសលធម៌ដ៏លាមកដែលកើតឡើងហើយ ឈ្មោះថា បញ្ញាដ៏មុត ព្រោះមិនទទួល លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវរាគៈដែលកើតឡើងហើយ ឈ្មោះថា បញ្ញាដ៏មុត ព្រោះមិនទទួល លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតមាននូវទោសៈដែលកើតឡើងហើយ ។បេ។ នូវមោហៈដែលកើតឡើងហើយ នូវសេចក្ដីក្រោធដែលកើតឡើងហើយ នូវការចងសេចក្ដីក្រោធទុក ការលុបគុណគេ ការវាយឫកស្មើ ឫស្យា ការកំណាញ់ ការលាក់ពុត ការអួតអាង

ការរឹងត្អឹង ការប្រណាំងប្រជែង ការប្រកាន់ ការមើលងាយ ការស្រវឹង ការប្រហែសធ្វេស កិសេលទាំងអស់ ទុច្ចរិតទាំងអស់ អភិសង្ខារទាំងអស់ ។បេ។ ភវគាមិកម្មទាំងអស់ដែលកើតឡើងហើយ ឈ្មោះថា បញ្ញាដ៏មុត ព្រោះអរិយមគ្គ ៤ សាមញ្ញផល ៤ បដិសម្ភិទា ៤ និងអភិញ្ញា ៦ ជាគុណជាតិដែលបុគ្គលចាក់ធ្លុះ ធ្វើឲ្យជាក់ច្បាស់ ពាល់ត្រូវហើយដោយប្រាជ្ញាក្នុងអាសនៈ ១ ។

តើបញ្ញាជាគ្រឿងទម្លុះទម្លាយដូចម្តេច ឈ្មោះថា បញ្ញាជាគ្រឿងទម្លុះទម្លាយ ព្រោះបុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកច្រើនដោយសេចក្តីរន្ធត់ ច្រើនដោយសេចក្តីតក់ស្លុត ច្រើនដោយសេចក្តីអផ្សុក ច្រើនដោយសេចក្តីមិនត្រេកអរ ច្រើនដោយសេចក្តីនឿយណាយក្នុងសង្ខារទាំងពួង មានមុខងាកចេញក្រៅ មិនត្រេកអរក្នុងសង្ខារទាំងពួង រមែងទម្លុះទម្លាយនូវគំនរលោភៈដែលខ្លួនមិនធ្លាប់ទម្លុះ មិនធ្លាប់ទម្លាយហើយ ឈ្មោះថា បញ្ញាជាគ្រឿងទម្លុះទម្លាយ ព្រោះទម្លុះទម្លាយនូវគំនរទោសៈ ដែលខ្លួនមិនធ្លាប់ទម្លុះ មិនធ្លាប់ទម្លាយហើយ ឈ្មោះថា បញ្ញាជាគ្រឿងទម្លុះទម្លាយ ព្រោះទម្លុះទម្លាយនូវគំនរមោហៈ ដែលខ្លួនមិនធ្លាប់ទម្លុះ មិនធ្លាប់ទម្លាយហើយ ឈ្មោះថា បញ្ញាជាគ្រឿងទម្លុះទម្លាយ ព្រោះទម្លុះទម្លាយនូវក្រោធ ។បេ។ នូវការចងក្រោធទុក ការលុបគុណគេ ការវាយឫកស្មើ ឫស្យា កំណាញ់ ការលាក់ពុត ការអួតអាង ការរឹងត្អឹង ការប្រណាំងប្រជែង ការប្រកាន់ ការមើលងាយ ការស្រវឹង ការប្រហែសធ្វេស កិលេសទាំងអស់ ទុច្ចរិតទាំងអស់ អភិសង្ខារ

ទាំងអស់ ។បេ។ កវគាមិកម្មទាំងអស់ ដែលខ្លួនមិនធ្លាប់ទម្លុះ មិនធ្លាប់ទម្លាយហើយ ។

[ ១៨ ] បទថា **បញ្ឈិតំ ឧបាសិតា** គឺចូលទៅរកជិតបព្ជិតដែលជាបណ្ឌិត ។ បទថា **អត្ថន្តរោ** សេចក្តីថា បុគ្គលខ្លះ មានប្រក្រតីស្វែងទោសធ្វើទោសទុកខាងក្នុង ព្រោះខ្លួនមានចិត្តអាក់អន់ ហើយត្រិះរិះ យ៉ាងណា ព្រះពោធិសត្វទ្រង់មិនបានត្រិះរិះយ៉ាងនោះ ទ្រង់ធ្វើប្រយោជន៍ទុកខាងក្នុង ហើយទ្រង់ត្រិះរិះ គឺពិចារណាដោយពាក្យដែលប្រកបដោយប្រយោជន៍ ។ បទថា **បដិលាភគតេន** គឺទៅដើម្បីប្រាថ្នាលាភ ។ បទថា **ឧប្បាទនិមិត្តកោវិទា** គឺជាអ្នកឈ្លាសក្នុងឧប្បាត និងនិមិត្ត ។ បទថា **អវេច្ច ឧក្ខតិ** សេចក្តីថា ដឹងហើយនឹងឃើញ ។ បទថា **អត្ថានុសិដ្ឋីសុ បរិគ្គហេសុ ច** សេចក្តីថា ក្នុងការកំណត់ ក្នុងការប្រៀនប្រដៅដែលជាប្រយោជន៍ គឺញាណទាំងឡាយដែលកំណត់ដល់ប្រយោជន៍ និងមិនមែនប្រយោជន៍ ។

[ ១៩ ] បទថា **អក្កោធនោ** សេចក្តីថា មិនមែនព្រោះខ្លួនលះសេចក្តីក្រោធបានដោយអនាគាមិមគ្គទេ ព្រោះខ្លួនមិននៅក្នុងអំណាច របស់សេចក្តីក្រោធយ៉ាងនេះថា បើសេចក្តីក្រោធកើតឡើងដល់អញ អញនឹងបន្ទោបង់សេចក្តីក្រោធនោះដោយឆាប់រហ័ស ។ បទថា **ឆាភិសង្គិ** គឺមិនជាប់ដូចបន្ទាមុត ត្រង់រាងកាយក្នុងទីនោះៗ ។ ក្នុងបទថា **ន កុប្បិ ន ព្យាបជ្ជិ** ជាដើម សេចក្តីថា សេចក្តីក្រោធកើតឡើងមុន សេចក្តីព្យាបាទមានកម្លាំងជាងសេចក្តី

ក្រោធនោះ ការចងគំនុំមានកម្លាំងជាងសេចក្ដីព្យាបាទនោះ ព្រះតថាគត ទ្រង់មិនធ្វើពាក្យទាំងអស់នោះ ទើបមិនក្រោធ មិនព្យាបាទ មិនចងគំនុំ ។ បទថា **ឆ ចាគ្គាកាសិ** គឺមិនធ្វើឲ្យប្រាកដដោយកាយវិការ ឬវចីវិការ ភាពជាអ្នកមិនក្រោធអស់កាលយូរ និងឲ្យកម្រាលសាច់ម៉ដ្ឋជាដើម ឈ្មោះថា កម្មក្នុងទីនេះ ។ ពិតហើយ ពណ៌សម្បុររបស់អ្នកមានសេចក្ដីក្រោធ មានពណ៌សម្បុរសៅហ្មង មុខមាត់មើលគួរស្អប់ ឈ្មោះថា គ្រឿងតាក់តែង ដូចសំពត់សម្រាប់បិទបាំងក៏មិនមាន ព្រោះដូច្នោះ ជនណាក្រោធសូម្បីតែម្ដង និងមិនឲ្យសំពត់សម្រាប់បិទបាំង ជននោះ ចូរដឹងដល់បុគ្គលជាអ្នកមានពណ៌សម្បុរសៅហ្មង មានទ្រង់ទ្រាយគួរស្អប់ ។ តែមុខរបស់អ្នកមិនក្រោធ រមែងស្រស់ថ្លា ពណ៌សម្បុររមែងថ្លាផូរផង់ ។

ពិតហើយ សត្វជាបុគ្គលដែលគួរឲ្យអ្នកផងជ្រះថ្លា ដោយហេតុ ៤ យ៉ាង គឺដោយឲ្យអាមិស ១ ដោយឲ្យសំពត់ ១ ដោយឲ្យអម្បោស ១ ឬដោយភាពជាអ្នកមិនក្រោធ ១ ។ ហេតុ ៤ យ៉ាងនេះ ក៏ព្រះតថាគតទ្រង់បានធ្វើហើយ អស់កាលយូរ ដោយហេតុនោះ លោក ព្រមទាំងទេវលោក ចូរដឹងនូវហេតុទាំងនេះ ព្រះតថាគតទ្រង់ធ្វើហើយ ដោយហេតុនេះ ព្រោះដូច្នោះ មហាបុរិសលក្ខណៈ មានពណ៌ដូចមាស រមែងកើតឡើង ឈ្មោះថា **កម្ម-សរិក្ខក** ( ធម៌ប្រហែលគ្នានឹងកម្ម ) ។ លក្ខណៈនេះឯង ឈ្មោះថា លក្ខណៈ ភាពជាអ្នកបានគ្រឿងស្លៀកដណ្ដប់ មានសាច់ម៉ដ្ឋទន់ជាដើម ឈ្មោះថា អានិសង្ស ។

[ ២០ ] បទថា **អភិវិសដ្ឋ** ប្រែថា ធ្លាក់ហើយ សេចក្ដីថា ភ្លៀងធ្លាក់ពេញលើផែនដី ភ្លៀងលោកពោលថា **សុរ** ។ ដូចភ្លៀងធ្លាក់ពេញមហាប្រឹថពី ។ បទថា **សុរវរតរោរិវ ឥន្ទោ** គឺដូចព្រះឥន្ទ្រដែលប្រសើរជាងអសុរទាំងឡាយ ។ បទថា **អបព្វជ្ជ មិជ្ជំ** គឺប្រាថ្នាភាពជាគ្រហស្ថ មិនមែនអ្នកបួស ។ បទថា **មហាតី មហី** គឺផែនដីធំ ។ បទថា **អច្ឆាទនវត្ថមោក្ខចាបុរណានំ** គឺសំពត់ស្លៀក និងសំពត់ដណ្ដប់ដ៏ឧត្ដម ។ បទថា **បធាសោ** គឺសេចក្ដីវិនាស ។

[ ២១ ] បទថា **មាតរំបិ បុត្តេន សមាគេតា អហោសិ** សេចក្ដីថា ព្រះរាជាដែលតាំងនៅក្នុងរាជសម្បត្តិ អាចធ្វើកម្មនេះបាន ព្រោះដូច្នោះ ព្រះពោធិសត្វកាលគ្រងរាជសម្បត្តិ ក៏ទ្រង់តាំងមនុស្សទាំងឡាយថា ពួកលោកចូរធ្វើការងារត្រង់ទ្វារព្រះនគរ ៤ កន្លែង មានផ្លូវបែកជា ៤ ជាដើម ខាងក្នុងព្រះនគរ ក្នុងទិសទាំង ៤ ក្រៅព្រះនគរ ពួកមនុស្សទាំងនោះ ឃើញមាតាកន្ទក់កន្ទេញរកបុត្រថា កូនខ្ញុំទៅឯណា ខ្ញុំមិនឃើញកូន ដូច្នេះ ហើយនិយាយថា មកនេះចុះនាង នាងនឹងឃើញកូន បាននាំមាតានោះទៅងូតទឹក ឲ្យបរិភោគ ហើយស្វែងរកបុត្របង្ហាញដល់មាតានោះ ។ ក្នុងបទទាំងពួងក៏មានន័យនេះ ។ ការធ្វើឲ្យញាតិទាំងឡាយ មានសេចក្ដីព្រមព្រៀងគ្នាអស់កាលយូរ ឈ្មោះថា កម្ម ក្នុងទីនេះ ។ ញាតិទាំងឡាយ ជាអ្នកមានសេចក្ដីព្រមព្រៀងគ្នាហើយ រមែងបិទបាំងទោសនៃគ្នានិងគ្នា ។ ពិតហើយ ជនទាំងនោះ ក្នុងវេលាឈ្លោះគ្នា រមែងឈ្លោះគ្នាក៏ពិត តែកាលកើតទោសដល់បុគ្គលណាម្នាក់ ក៏មិនប្រាថ្នាឲ្យអ្នកដទៃដឹង កាលបើមានអ្នកនិយាយថា នេះជាទោសរបស់បុគ្គលណា

ម្នាក់នោះ ទាំងអស់គ្នានឹងក្រោកឡើងនិយាយថា អ្នកណាឃើញ អ្នកណាបានឮ ក្នុងបណ្តាញាតិរបស់យើង មិនមានអ្នកធ្វើបែបនេះ ឯព្រះតថាគតកាលទ្រង់ធ្វើការសង្គ្រោះញាតិនោះ ទ្រង់ធ្វើកម្ម គឺការបិទបាំងទោសនេះអស់កាលយូរ លំដាប់នោះ លោក ព្រមទាំងទេវលោក ចូរដឹងនូវកម្មបែបនេះដែលព្រះតថាគតនោះ ទ្រង់ធ្វើដោយហេតុនេះ ដូច្នោះ លក្ខណៈ គឺមានព្រះគុយ្ហៈលាក់នៅក្នុងស្រោម រមែងកើតឡើង ឈ្មោះថា **កម្មសរិក្ខក** ។ លក្ខណៈនេះឯង ឈ្មោះថា លក្ខណៈ ។ ភាពជាអ្នកមានឱរសច្រើន ឈ្មោះថា អានិសង្ស ។

[ ២២ ] បទថា **វត្តច្ឆាទិយំ** បានដល់ បិទបាំងដោយសំពត់ គឺលាក់ក្នុងសំពត់ ។ បទថា **អមិត្តតាបនា** គឺដុតពោលពួកអមិត្ត ។ បទថា **គិហិស្ស បីតិជននា** គឺញុំាងបីតិឲ្យកើត ដើម្បីជាគ្រហស្ថ ។

[ ២៣ ] បទថា **សមំ ជានាតិ** សេចក្តីថា រមែងដឹងបុគ្គលដែលស្មើគ្នាដោយហេតុនោះៗ យ៉ាងនេះថា អ្នកនេះស្មើដោយតារុក្ខនិគ្រន្ធ អ្នកនេះស្មើដោយបោក្ខរសាតិ ។ បទថា **បុរិសំ ជានាតិ** គឺស្គាល់បុរសថា បុរសនេះជាបុគ្គលប្រសើរបំផុត ។ បទថា **បុរិសវិសេសំ ជានាតិ** គឺមិនធ្វើសណ្តែកបាយឲ្យស្មើដោយសណ្តែករាជមាស រមែងដឹងសេចក្តីវិសេសរបស់បុគ្គលដែលប្រសើរដោយគុណ ។ បទថា **អយមិធមរហាតិ** នេះ សេចក្តីថា បុរសនេះគួរទទួលសក្ការៈឈ្មោះនេះ ព្រះពោធិសត្វបានការកបុគ្គល ព្រោះស្គាល់បុរសពិសេសថា បុរសនេះបានធ្វើឲ្យជាបុរសពិសេសមកពីមុន ព្រះពោធិសត្វ

បានឲ្យទានដល់អ្នកគួរ ពិតហើយ អ្នកណាឲ្យកន្ទះកហាបណៈ ដល់អ្នកដែលគួរឲ្យមួយកហាបណៈ បុគ្គលនោះ រមែងធ្វើឲ្យកន្ទះកហាបណៈរបស់អ្នកដទៃវិនាសទៅ បុគ្គលណាឲ្យពីរកហាបណៈ បុគ្គលនោះ រមែងធ្វើឲ្យមួយកហាបណៈរបស់ខ្លួនវិនាសទៅ ព្រោះដូច្នោះ មិនធ្វើសូម្បីទាំងពីរយ៉ាងនេះ ឈ្មោះថា បានឲ្យទានដល់បុគ្គលដែលគួរឲ្យ ។ ក្នុងបទថា **សទ្ធាធនំ** ជាដើម គប្បីជ្រាបភាពដែលសទ្ធាជាដើមជាទ្រព្យ ដោយអត្ថ គឺឲ្យបានសម្បត្តិ កម្ម គឺការសង្គ្រោះដល់បុគ្គលអ្នកស្មើគ្នា ដែលបុគ្គលអ្នកដឹងវិសេស ធ្វើហើយអស់កាលយូរ ឈ្មោះថា កម្ម ក្នុងទីនេះ ។ លោក ព្រមទាំងទេវលោក ចូរដឹងកម្មនោះរបស់ព្រះពោធិសត្វ ដោយហេតុនេះ ដូច្នោះ លក្ខណៈពីរយ៉ាងនេះ រមែងកើតឡើង ឈ្មោះថា **កម្មសរិក្ខក** ។ លក្ខណៈពីរយ៉ាងនេះឯង ឈ្មោះថា លក្ខណៈ ។ ទ្រព្យសម្បត្តិឈ្មោះថា អានិសង្ស ។

[ ២៤ ] បទថា **តុលិយ** ប្រែថា ពិចារណាហើយ ។ បទថា **បវិចិយ** ប្រែថា ស្រាវជ្រាវហើយ ។ បទថា **មហាជនសង្គាហកំ** គឺសង្គ្រោះមហាជន ។ បទថា **សមេក្ខមានោ** គឺសម្លឹងដោយស្មោះស្មើ។ បទថា **អជិនិបុណា មនុជា** សេចក្តីថា មនុស្សអ្នកទាយលក្ខណៈ មានបញ្ញាក្រៃលែង គឺមានបញ្ញាល្អិតល្អន់ ។ បទថា **ពហុវិវិធគិហីធំ អរហានិ** គឺដ៏សមគួរដល់ពួកគ្រហស្ថច្រើនយ៉ាង ។ បទថា **បដិលភតិ ទហរោ សុសុ កុមារោ** សេចក្តីថា ពួកអ្នកព្យាករទាយថា ព្រះពោធិសត្វ គឺទារកនេះ នឹងបានជាព្រះរាជកុមារ ។ បទថា **មហិបតិស្ស** គឺព្រះរាជា ។

[ ២៥ ] បទថា **យោគក្ខេមកាមោ** គឺប្រាថ្នាភាពក្សេមចាកយោគៈ ។ បទថា **បញ្ញាយ** គឺដោយបញ្ញានៃកម្មដែលខ្លួនធ្វើហើយ ភាពជាអ្នកប្រាថ្នាប្រយោជន៍ដល់មហាជន ឈ្មោះថា កម្ម ក្នុងទីនេះ ។ លោក ព្រមទាំងទេវលោក ចូរដឹងនូវភាពជាអ្នកប្រាថ្នាសេចក្ដីចម្រើនតែម្យ៉ាង ព្រោះភាពជាអ្នកប្រាថ្នានូវប្រយោជន៍ដល់មហាជនដោយហេតុនេះ របស់ព្រះពោធិសត្វនោះ ដូច្នោះ ព្រះលក្ខណៈ ៣ ប្រការ ដែលបរិបូណ៌គ្រប់គ្រាន់ ដែលមិនសាបសូន្យទាំងនេះ រមែងកើតឡើង នោះឈ្មោះថា **កម្មសរិក្ខក** ។ លក្ខណៈ ៣ ប្រការនេះឯង ឈ្មោះថា លក្ខណៈ ។ ការមិនសាបសូន្យចាកទ្រព្យជាដើម និងចាកសទ្ធាជាដើម ឈ្មោះថា អានិសង្ស ។

[ ២៦ ] បទថា **សទ្ធាយ** សេចក្ដីថា ដោយសេចក្ដីជឿ ព្រោះការសម្រេចដោយសេចក្ដីជឿ ព្រោះសេចក្ដីជ្រះថ្លា ។ បទថា **សីលេន** គឺដោយសីល ៥ ដោយសីល ១០ ។ បទថា **សុតេន** គឺដោយការស្ដាប់ព្រះបរិយត្តិ ។ បទថា **ពុទ្ធិយា** គឺដោយសេចក្ដីចម្រើននៃធម៌ទាំងនោះ អធិប្បាយថា ព្រះពោធិសត្វទ្រង់ត្រិះរិះយ៉ាងនេះថា ជនទាំងឡាយ គប្បីចម្រើនដោយធម៌ទាំងនេះបានដូចម្ដេចហ្ន៎ ។ បទថា **ធម្មេន** គឺដោយលោកិយធម៌ ។ បទថា **ពហូហិ សាធូហិ** គឺដោយគុណដ៏ឧត្ដមសូម្បីដទៃៗ ។ បទថា **អហានធម្មតំ** គឺធម៌ដែលមិនសាបសូន្យ ។

[ ២៧ ] បទថា **សមាភិវាហិនិយោ** សេចក្ដីថា វត្ថុសូម្បីប្រមាណប៉ុនគ្រាប់ល្ង តាំងនៅត្រង់ចុងអណ្ដាត រមែងផ្សាយទៅក្នុងទីទាំងអស់ យ៉ាងណា

សរសៃរបសាទ រមែងធ្វើរសអាហារ ផ្សាយជ្រួតជ្រាបទៅស្មើ ដូច្នោះ ជាហេតុ គឺធ្វើឲ្យមិនមានរោគ ឈ្មោះថា កម្ម ក្នុងទីនេះ ។ លោហិតរបស់អ្នកត្រូវប្រហារដោយបាតដៃជាដើម រមែងកកនៅក្នុងទីនោះៗ ជាពកខាងក្នុង និងបែកខាងក្នុងដោយអាការយ៉ាងនេះ បុគ្គលនោះ រមែងជាអ្នកមានរោគច្រើន ។ តែព្រះតថាគតទ្រង់ធ្វើកម្ម ដែលធ្វើឲ្យមិនមានរោគនេះអស់កាលយូរ ។ លោកព្រមទាំងទេវលោក ចូរដឹងកម្មនោះ របស់ព្រះតថាគតនោះ ដោយហេតុនេះ ដូច្នោះ លក្ខណៈ គឺមានសរសៃរបសាទសម្រាប់នាំអាហារដ៏ប្រសើរ ដែលធ្វើមិនឲ្យមានរោគ រមែងកើតឡើង ឈ្មោះថា **កម្មសរិក្ខក** ។ លក្ខណៈនេះឯង ឈ្មោះថា លក្ខណៈ ភាពជាអ្នកមានអាពាធតិច ឈ្មោះថា អានិសង្ស ។

[ ២៨ ] បទថា **មរណវធេន** គឺដោយបង្គាប់យ៉ាងនេះថា អ្នកទាំងឡាយ ចូរឲ្យអ្នកនេះស្លាប់ ចូរសម្លាប់អ្នកនេះ ដូច្នេះ ។ បទថា **ឧព្វាធនាយ** គឺដោយឲ្យបុគ្គលនោះទៅនៅក្នុងគុក ។ បទថា **ឧជសា** ប្រែថា មានរសជាតិ ។

[ ២៩ ] បទថា **ន ច វិសដំ** គឺមិនសម្លឹងដោយអំណាចសេចក្តីក្រោធ ដូចភ្នែកក្តាមដែលលៀនចេញ ។ បទថា **ន ច វិសាចិ** គឺមិនមើលដោយកន្ទុយភ្នែក ។ បទថា **ន ច បន វិចេយ្យ បេក្ខិតា** សេចក្តីថា អ្នកដែលក្រោធ ធ្មេចភ្នែក មិនមើលក្នុងខណៈដែលអ្នកដទៃគេមើល ត្រឡប់ជាក្រោធ សម្លឹងមើលអ្នកដែលដើរទៅ ព្រះតថាគតមិនបានមើលយ៉ាងនោះ ។ បាលីថា **វិតេយ្យ-បេក្ខិតា** ដូច្នេះក៏មាន ឯសេចក្តីក៏ដូចគ្នា ។ បទថា **ឧជុំ តថា បសដមុជុមនោ** សេចក្តីថា ជាអ្នកមានចិត្តត្រង់ ជាអ្នកសម្លឹងត្រង់ គឺជាអ្នកសម្លឹងដោយពេញ

ភ្នែក បរិបូណ៌ ធំទូលាយដូចគ្នានឹងចិត្តត្រង់ ។ បទថា **បិយចក្ខុនោ** គឺគប្បី មើលដោយចិត្តស្រឡាញ់ ។ កម្ម គឺការមើលដោយចក្ខុជាទីស្រឡាញ់ របស់ មហាជនអស់កាលយូរ ឈ្មោះថា កម្ម ក្នុងទីនេះ ។ អ្នកក្រោធ កាលសម្លឹង មើល រមែងដូចមានភ្នែកខ្វាក់ម្ខាង ដូចជាភ្នែកភ្អែក នឹងជាបុគ្គលភ្នែកស្រលៀង និងភ្នែកកករល្អក់តែម្យ៉ាង ។ តែអ្នកមានចិត្តថា ផូរផង់ កាលក្រឡេកមើល បសាទមានពណ៌ ៥ របស់ភ្នែកទាំងពីរនោះប្រាកដ ។ ឯព្រះតថាគត ទ្រង់ សម្លឹងមើលយ៉ាងនោះ ម្យ៉ាងទៀត លោក ព្រមទាំងទេវលោក ចូរដឹងព្រះ តថាគតនោះ ទ្រង់សម្លឹងមើលដោយចក្ខុជាទីស្រឡាញ់អស់កាលយូរ ដោយ ហេតុនេះ ដូច្នោះ មហាបុរិសលក្ខណៈ ២ ប្រការ ដែលធ្វើភាពបរិបូណ៌ដល់ ព្រះនេត្រ រមែងកើតឡើង ឈ្មោះថា **កម្មសរិក្ខក** ។ លក្ខណៈទាំងពីរ ប្រការនេះឯង ឈ្មោះថា លក្ខណៈ ។ ភាពជាអ្នកមើលដោយសេចក្តីស្រឡាញ់ ឈ្មោះថា អានិសង្ស ។

[ ៣០ ] បទថា **អភិយោគិនោ** គឺប្រកបក្នុងលក្ខណសាស្ត្រ ។

[ ៣១ ] បទថា **ពហុជនបុព្វង្គមោ អហោសិ** សេចក្តីថា បានជាប្រធាន គឺជាអ្នកជំក្នុងពួករបស់ជនដ៏ច្រើន ជនពួកដទៃ រមែងកាន់យកទិដ្ឋានុគតិ របស់ ព្រះតថាគតនោះ ភាពជាប្រធាន ឈ្មោះថា កម្ម ក្នុងទីនេះ ។ អ្នកណាជា ប្រធានធ្វើកុសលធម៌ មានទានជាដើម អ្នកនោះ ជាអ្នកមិនឱនសីសៈ ជាអ្នក មានសីសៈបរិបូណ៌ដោយបីតិ និងបាមោជ្ជត្រាច់ទៅ ព្រះមហាបុរស ក៏ដូច្នោះ លោក ព្រមទាំងទេវលោក ចូរដឹងកម្ម គឺភាពជាប្រធាននេះ របស់ព្រះមហាបុរស

នោះ ដោយហេតុនេះ ដូច្នោះ លក្ខណៈ គឺមានព្រះសីសៈដូចប្រដាប់ដោយក្បាំងមុខ រមែងកើតឡើង ឈ្មោះថា **កម្មសរិក្ខក**។ លក្ខណៈនេះឯង ឈ្មោះថា លក្ខណៈ ។ ភាពដែលមហាជនអនុវត្តតាម ឈ្មោះថា អានិសង្ស ។

[ ៣២ ] បទថា **ពហុជនំ ហេស្សតិ** គឺពួកជនដែលធ្វើការបម្រើច្រើននាក់នឹងមានដល់ព្រះអង្គ ។ បទថា **អភិហរន្តិ តទា** សេចក្ដីថា ពួកព្រាហ្មណ៍ព្យាករយ៉ាងនោះ ក្នុងគ្រាដែលព្រះអង្គទ្រង់នៅក្មេង ។

បទថា **បដិហារកំ** ប្រែថា ភាពជាអ្នកខ្វល់ខ្វាយបម្រើ ។ បទថា **វិសវី** ប្រែថា មានភាពជំនាញសន្សំហើយ ។

[ ៣៣ ] បទថា **ឧបវត្តតិ** គឺប្រព្រឹត្តតាមអធ្យាស្រ័យ ។ ការពោលសេចក្ដីពិតអស់កាលយូរ ឈ្មោះថា កម្មក្នុងទីនេះ ។ លោក ព្រមទាំងទេវលោក ចូរដឹងភាពដែលព្រះអង្គត្រាស់ពាក្យមិនមានពីរ គឺពាក្យបរិសុទ្ធអស់កាលយូរ ដោយហេតុនេះ ដូច្នោះ ព្រះលក្ខណៈ គឺព្រះលោមាមួយសរសៃៗស្មើគ្នាគ្រប់ៗ រណ្ដៅរោម និងព្រះលក្ខណៈ គឺព្រះឧណ្ណាលោម រមែងកើតឈ្មោះថា **កម្មសរិក្ខក** ។ លក្ខណៈទាំងពីរនេះឯង ឈ្មោះថា លក្ខណៈ ភាពជាអ្នកអនុវត្តតាម ដោយការអនុវត្តតាមអធ្យាស្រ័យដល់មហាជន ឈ្មោះថា អានិសង្ស ។

[ ៣៤ ] ការពោលវាចាមិនស៊ីកសៀតអស់កាលយូរ ឈ្មោះថា កម្មក្នុងទីនេះ ។

[ ៣៥ ] បទថា **អភេជ្ជបរិសោ** ប្រែថា មិននាំបរិស័ទឲ្យបែកគ្នា ។ បាន

ពួថា អ្នកពោលវាចាស៊កសៀតទម្លាយសាមគ្គីភាព ធ្មេញរមែងមិនបរិបូណ៌ និងរមែងជាអ្នកមានធ្មេញរង្វើល ម្យ៉ាងទៀត លោក ព្រមទាំងទេវលោក ចូរដឹងភាពដែលព្រះតថាគត មានព្រះវាចាមិនស៊កសៀតអស់កាលយូរ ដោយហេតុនេះ ដូច្នោះ លក្ខណៈទាំងពីរនេះរមែងកើត ឈ្មោះថា **កម្មសរិក្ខក** ។ លក្ខណៈទាំងពីរនេះឯង ឈ្មោះថា លក្ខណៈ ។ ភាពដែលបរិស័ទមិនបែកគ្នា ឈ្មោះថា អានិសង្ស ។

[ ៣៦ ] បទថា **ចត្តារោ ទស** ប្រែថា ៤០ ។

[ ៣៧ ] បទថា **អាទេយ្យវាចោ** គឺមានពាក្យគួរជឿកាន់យកបាន ។ ភាពជាអ្នកមិនពោលពាក្យទ្រគោះបោះបោកអស់កាលយូរ ឈ្មោះថា កម្មក្នុងទីនេះ ។ បុគ្គលណាជាអ្នកមានវាចាទ្រគោះ ជនចូរដឹងដល់បុគ្គលទាំងនោះ ត្រឡប់អណ្តាត ពោលវាចាទ្រគោះដោយហេតុនេះ ។ ដូច្នោះ អ្នកនោះនឹងមានអណ្តាតរឹង មានអណ្តាតលាក់បាំង មានអណ្តាតព្រែកជាពីរ ឬនិយាយត្រដិត ម្យ៉ាងទៀត អ្នកណាត្រឡប់អណ្តាតទៅមក មិននិយាយវាចាគ្រោតគ្រាត អ្នកនោះ នឹងមិនមានអណ្តាតរឹង មិនមានអណ្តាតលាក់បាំង មិនមានអណ្តាតព្រែកជាពីរ អណ្តាតរបស់បុគ្គលនោះទន់ មានពណ៌ដូចសំពត់កម្ពលក្រហម ព្រោះដូច្នោះ លោក ព្រមទាំងទេវលោក ចូរដឹងភាពដែលព្រះតថាគត មិនបានត្រឡប់អណ្តាតទៅមក ហើយត្រាស់វាចាទ្រគោះដោយហេតុនេះ ដូច្នោះ ព្រះលក្ខណៈ គឺមានព្រះជិវ្ហាធំ រមែងកើតឡើង ម្យ៉ាងទៀត សំឡេងរបស់អ្នកពោលវាចាទ្រគោះ រមែងបែក ជនចូរដឹងដល់បុគ្គលមានសំឡេងបែក ហើយ

ពោលវាចាទ្រគោះ ដូច្នោះ បុគ្គលនោះ រមែងជាអ្នកមានសំឡេងដាច់ ឬមាន សំឡេងបែក ឬមានសំឡេងដូចក្អែក ។ ម្យ៉ាងទៀត អ្នកណាមិនពោលវាចាទ្រគោះដែលធ្វើឲ្យសំឡេងបែក សំឡេងរបស់អ្នកនោះ រមែងមានសំឡេងពីរោះ និងមានសំឡេងគួរស្រឡាញ់ ព្រោះដូច្នោះ លោក ព្រមទាំងទេវលោក ចូរដឹងព្រះតថាគតមិនត្រាស់វាចាគ្រោតគ្រាត ដែលធ្វើឲ្យសំឡេងបែកអស់កាលយូរ ដោយហេតុនេះ ។ ដូច្នោះ ព្រះលក្ខណៈ គឺមានសំឡេងដូចសំឡេងព្រហ្ម រមែងកើតឡើង ឈ្មោះថា **កម្មសរិក្ខក** ។ ព្រះលក្ខណៈទាំងពីរនេះឯង ឈ្មោះថា លក្ខណៈ ។ ភាពជាអ្នកមានវាចាគួរជឿកាន់យកបាន ឈ្មោះថា អានិសង្ស ។

[ ៣៨ ] បទថា **ឧព្ពាធិកំ** គឺធ្វើសេចក្តីឈឺចិត្ត ព្រោះប្រកបដោយការជេរ ។ បទថា **ពហុជនប្បមទ្ទនំ** ប្រែថា ញាំញីជនដ៏ច្រើន ។ គប្បីប្រកប **អ** អក្ខរៈ ក្នុងបទនេះថា **អពាឡ្ហំគិរំ សោ ឧភណិ ជរុសំ** ដោយ **ភណិ** សព្ទខាងមុខ ។ បទថា **ពាឡ្ហំ** គឺពាក្យធ្ងន់មានកម្លាំង គឺគ្រោតគ្រាតក្រៃលែង ។ ក្នុងបទនេះ មានអធិប្បាយថា ព្រះពោធិសត្វមិនបាននិយាយពាក្យធ្ងន់ ។ បទថា **សុសំហិតំ** ប្រែថា ប្រកបសេចក្តីស្រឡាញ់ដោយល្អ ។ បទថា **សខិលំ** គឺទន់ភ្លន់ ។ បទថា **វាចា** គឺពាក្យនិយាយទាំងឡាយ ។ បទថា **កណ្ណសុខា** សេចក្តីថា សេចក្តីសុខផ្លូវត្រចៀក បាឋៈថា **កណ្ណសុខំ** ក៏មាន អធិប្បាយថា សេចក្តីសុខ រមែងមានដល់ត្រចៀកយ៉ាងណា រមែងពោលយ៉ាងនោះ ។

បទថា **វេទយិថ** គឺសោយហើយ ។ បទថា **ព្រហ្មស្សរ** ប្រែថា ជាអ្នក

មានសំឡេង ដូចសំឡេងព្រហ្ម ។

[ ៣៩ ] បទថា **អប្បដិសិកោ ហោតិ** សេចក្តីថា ជាអ្នកដែលបុគ្គលណាម្នាក់មិនអាចកម្ចាត់ គឺឲ្យឃ្លាតចាកគុណ ឬឋានៈបាន ការមិននិយាយពាក្យរោយរាយ ឈ្មោះថា កម្មក្នុងទីនេះ ។ បុគ្គលណាពោលពាក្យដូច្នោះ ជនចូរដឹងចំពោះបុគ្គលទាំងនោះ មានចង្កាខ្ទី ហើយនិយាយពាក្យរោយរាយ ដោយហេតុនោះ ដូច្នោះ អ្នកនោះ រមែងជាអ្នកមានចង្កាចូលទៅហើយខាងក្នុង ឬមានចង្កាវៀច ឬមានចង្កាដូចញកក្ដី តែព្រះតថាគត មិនត្រាស់យ៉ាងនោះ លោក ព្រមទាំងទេវលោក ចូរដឹងព្រះតថាគតនោះ មិនមានចង្កាខ្ទី ហើយត្រាស់ពាក្យរោយរាយ ដោយហេតុនេះ ដូច្នោះ ព្រះលក្ខណៈ គឺមានព្រះហនុ ដូចចង្កាសីហៈ រមែងកើតឡើង ឈ្មោះថា **កម្មសរិក្ខក** ។ ព្រះលក្ខណៈនេះឯង ឈ្មោះថា លក្ខណៈ ។ ភាពជាអ្នកដែលអ្នកណាកម្ចាត់មិនបាន ឈ្មោះថា អានិសង្ស ។

[ ៤០ ] បទថា **អវិកិណ្ណវចនព្យបថោ ច** គឺមានគន្លងវាចា របស់បុរិមពោធិសត្វ គឺពោធិសត្វក្នុងអតីតកាល ដែលជាសត្វមានវាចាមិនឡេះឡោះ ។ បទថា **ទ្វិទុគ្គមវរតរហនុត្តមលត្ត** សេចក្តីថា ឈ្មោះថា **ទ្វិទុគ្គម** ព្រោះទៅដោយជើង ៤ អធិប្បាយថា បានភាពជាសីហៈប្រសើរជាងសត្វជើង ៤ ។ បទថា **មនុជាធិបតិ** បានដល់ ជាធំក្នុងពួកមនុស្ស ។ បទថា **តថត្តោ** គឺសភាពដែលពិត ។

[ ៤១ ] បទថា **សុចិបរិវារោ** បានដល់ មានបរិវារបរិសុទ្ធ ។ ភាពជា

អ្នកមានអាជីវៈប្រពៃ ឈ្មោះថា កម្ម ក្នុងទីនេះ ។ បុគ្គលណាសម្រេចជីវិតដោយអាជីវៈសៅហ្មងមិនស្មើ ធ្មេញរបស់បុគ្គលនោះក៏មិនស្មើ សូម្បីចង្កូមក៏ស្មោកគ្រោក លោក ព្រមទាំងទេវលោក ចូរដឹងភាពដែលព្រះតថាគត ទ្រង់សម្រេចជីវិតដោយអាជីវៈបរិសុទ្ធស្មើ ដោយហេតុនេះ ដូចព្រះលក្ខណៈ គឺមានព្រះទន្តរាបស្មើគ្នា និងព្រះលក្ខណៈ គឺមានព្រះទាឋៈសស្អាត រមែងកើតឡើង ឈ្មោះថា **កម្មសរិក្ខក** ។ ព្រះលក្ខណៈទាំងពីរនេះឯង ឈ្មោះថា លក្ខណៈ ។ ភាពជាអ្នកមានបរិវារស្អាត ឈ្មោះថា អានិសង្ស ។

[ ៤២ ] បទថា **អវស្សុជិ** សេចក្តីថា ការជិះជាន់ ឬបៀតបៀនដល់អ្នកដទៃរបស់អ្នកជនបទ ដែលកំណត់ដោយចក្រវាល រមែងមិនមាន ។ បទថា **តិទិវបុរវរសមោ** សេចក្តីថា ស្មើដោយសក្កទេវរាជ ដែលមានសគ្គនគរដ៏ប្រសើរ ។ បទថា **លបនជំ** គឺធ្មេញដែលកើតក្នុងមាត់ ។ បទថា **ទិជសមសុក្កសុចិសោភនទន្តោ** សេចក្តីថា ឈ្មោះថា **ទិជសមសុក្កសុចិសោភនទន្តោ** ព្រោះមានធ្មេញសស្អាតល្អ ។ ឈ្មោះថា **ទិជ** ព្រោះកើតពីរដង ។ បទថា **ន ច ជនបទតុទនំ** សេចក្តីថា ជនបទដែលកំណត់ដោយចក្រវាល មិនមានការបៀតបៀន និងជំងឺដង្កាត់ ។ បទថា **ហិតមបិ ច ពហុជនសុខញ្ច ចរន្តិ** សេចក្តីថា ជនដ៏ច្រើន ជាអ្នកមានសុខ និងទុក្ខស្មើគ្នា រមែងប្រព្រឹត្តវត្តដែលជាប្រយោជន៍ និងសេចក្តីសុខដល់គ្នានិងគ្នាក្នុងជនបទនោះ ។ បទថា **វិគតោ** គឺប្រាសចាកបាប ។ បទថា **វិគតទរថកិលមថោ** សេចក្តីថា ប្រាសចាកសេចក្តីខ្វល់ខ្វាយ និងសេចក្តីលំបាកផ្លូវកាយ ។ បទថា **មលខិលកលិកិ-**

**លេសេមន្ទុធោភីតិ** សេចក្ដីថា កម្ចាត់កិលេសទាំងពួងមានរាគមន្ទិល រាគខិល ( ជង្គត់ គឺរាគៈ ) ជាដើម និងទោសកលិ ( កំហុស គឺទោសៈ ) ជាដើម ។ បទដ៏សេស មានអត្ថងាយយល់ហើយ ។ អដ្ឋកថា លក្ខណសូត្រ ក្នុងទីឃនិកាយ ឈ្មោះសុមង្គលវិលាសិនី ចប់ ។៙

**លក្ខណសូត្រ ចប់**

**សូត្រទី ៧ ចប់**

# សុត្តន្តបិដក

## សិង្គាលកសូត្រទី ៨

[ ៤៣ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង កូនគហបតីឈ្មោះសិង្គាលកៈ ក្រោកឡើងអំពីព្រឹក មានសំពត់ស្លៀកជណ្តប់ទទឹក និងសក់ទទឹក ចេញពីក្រុងរាជគ្រឹះ ប្រណម្យអញ្ជលីថ្វាយបង្គំទិសទាំងឡាយច្រើន គឺទិសខាងកើត ខាងត្បូង ខាងលិច ខាងជើង ខាងក្រោម និងទិសខាងលើ ។

[ ៤៤ ] លំដាប់នោះឯង ព្រះមានព្រះភាគ ស្តេចទ្រង់ស្បង់ និងបាត្រចីវរក្នុងបុព្វណ្ហសម័យ ហើយស្តេចចូលទៅកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត ។ ព្រះមានព្រះភាគ ទ្រង់ទតឃើញសិង្គាលកគហបតិបុត្ត ក្រោកឡើងអំពីព្រឹក មានសំពត់ស្លៀកជណ្តប់ទទឹក និងសក់ទទឹក ចេញពីក្រុងរាជគ្រឹះ កំពុងផ្គងអញ្ជលី ថ្វាយបង្គំទិសទាំងឡាយច្រើន គឺទិសខាងកើត ខាងត្បូង ខាងលិច ខាងជើង ខាងក្រោម និងទិសខាងលើ លុះទ្រង់ឃើញហើយ ទើបទ្រង់ត្រាស់សួរសិង្គាលកគហបតិបុត្តដូច្នេះថា នែគហបតិបុត្ត ហេតុអ្វី ទើបអ្នកក្រោកអំពីព្រឹក មានសំពត់ស្លៀកជណ្តប់ទទឹក និងសក់ទទឹក ចេញពីក្រុងរាជគ្រឹះ ផ្គងអញ្ជលីថ្វាយបង្គំទិសទាំងឡាយច្រើន គឺទិសខាងកើត ។បេ។ ទិសខាងលើ ។ សិង្គាលកគហបតិបុត្តក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលបិតារបស់ខ្ញុំជិតនឹងធ្វើមរណកាល បានផ្តាំនឹងខ្ញុំព្រះអង្គយ៉ាងនេះថា ហៃបា អ្នក

ត្រូវតែថ្វាយបង្គំទិសទាំងឡាយ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនោះ ធ្វើសក្ការៈ គោរព រាប់អាន បូជា នូវពាក្យរបស់បិតា បានជាក្រោកឡើងអំពីព្រឹក មានសំពត់ស្លៀកជណ្តប់ទទឹក និងសក់ទទឹក ចេញពីក្រុងរាជគ្រឹះ ផ្គងអញ្ជលី ថ្វាយបង្គំទិសទាំងឡាយដ៏ច្រើន គឺទិសខាងកើត ។បេ។ ទិសខាងលើ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា នែគហបតិបុត្ត ក្នុងវិន័យរបស់ព្រះអរិយៈ គេមិនត្រូវថ្វាយបង្គំទិសទាំង ៦ យ៉ាងដូច្នេះទេ ។ សិង្គាលកគហបតិបុត្តក្រាបបង្គំទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ចំណែកក្នុងអរិយវិន័យ គេគប្បីថ្វាយបង្គំទិសទាំង ៦ ដូចម្តេច បពិត្រព្រះអង្គដ៏ចម្រើន បើក្នុងវិន័យរបស់ព្រះអរិយៈគេគប្បីថ្វាយបង្គំ ចំពោះទិសទាំង ៦ យ៉ាងណា សូមព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ដល់ខ្ញុំព្រះអង្គ ដូច្នោះចុះ ។

[ ៨៥ ] ព្រះមានព្រះភាគទ្រង់ត្រាស់ថា នែគហបតិបុត្ត បើដូច្នោះ អ្នកចូរស្តាប់ចុះ ចូរកំណត់ទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែងប្រាប់ ។ សិង្គាលកគហបតិបុត្ត ក៏ទទួលស្តាប់ព្រះពុទ្ធដីកាព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងហ្នឹងហើយ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលគហបតិបុត្ត អរិយសាវក លះបង់នូវកម្មកិលេស ( អំពើដ៏សៅហ្មង ) ៤ ប្រការផង មិនធ្វើនូវបាបកម្ម ( អំពើអាក្រក់ ) ព្រោះហេតុ ៤ យ៉ាងផង មិនសេពនូវអបាយមុខ ( គឺប្រធាននៃសេចក្តីវិនាស ) នៃភោគៈ ៦ យ៉ាងផង អរិយសាវកនោះ លោកវៀរចាកបាបធម៌ទាំង ១៤ យ៉ាងនេះ ឈ្មោះថាជាអ្នកបិទបាំងទិសទាំង ៦ ប្រតិបត្តិដើម្បីជម្នះក្នុងលោកទាំងពីរ គឺលោកនេះ

ក៏អរិយសាវកនោះ បានប្រារព្ធ គឺថា បានពេញចិត្តហើយ លោកខាងមុខក៏ពេញចិត្តទៀត ។ លុះអរិយសាវកនោះ ទម្លាយរាងកាយទៅ រមែងកើតក្នុងមនុស្ស សុគតិសួគ៌ទេវលោក ។ កម្មក្កិលេស ៤ ប្រការ ដែលអរិយសាវកនោះលះបង់ហើយដូចម្ដេច ។ ម្នាលគហបតិបុត្ត ការធ្វើសត្វមានជីវិតឲ្យធ្លាក់ចុះកន្លង ( សម្លាប់សត្វ ) ជាកម្មក្កិលេស ១ ការកាន់យកទ្រព្យដែលម្ចាស់គេមិនឲ្យ ជាកម្មក្កិលេស ១ ការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ជាកម្មក្កិលេស ១ ការនិយាយពាក្យកុហក ជាកម្មក្កិលេស ១ កម្មក្កិលេស ៤ ប្រការនេះដែលអរិយសាវកនោះ បានលះបង់ហើយ ។ ព្រះមានព្រះភាគ បានសម្ដែងពាក្យនេះហើយ ព្រះសុគតជាសាស្ដា លុះទ្រង់សម្ដែងពាក្យនេះហើយ ទើបសម្ដែងគាថាព័ន្ធនេះ តទៅទៀតថា

[ ៤៦ ] ការសម្លាប់សត្វ ១ លួចទ្រព្យគេ ១ និយាយ
កុហក ១ សេពភរិយាបុគ្គលដទៃ ១ ហៅថា ( កម្មក្កិ-
លេស ) បណ្ឌិតទាំងឡាយ មិនសរសើរឡើយ ។

[ ៤៧ ] អរិយសាវកមិនធ្វើនូវបាបកម្ម ព្រោះហេតុ ៤ យ៉ាង ដូចម្ដេចខ្លះ បុថុជ្ជនលុះអគតិព្រោះស្រឡាញ់ ក៏ធ្វើបាបកម្ម លុះអគតិព្រោះស្អប់ ក៏ធ្វើបាបកម្ម លុះអគតិព្រោះល្ងង់ ក៏ធ្វើបាបកម្ម លុះអគតិព្រោះខ្លាច ក៏ធ្វើបាបកម្ម ។ ម្នាលគហបតិបុត្ត អរិយសាវក មិនលុះអគតិព្រោះស្រឡាញ់ មិនលុះអគតិព្រោះស្អប់ មិនលុះអគតិព្រោះល្ងង់ មិនលុះអគតិព្រោះខ្លាច ព្រោះហេតុទាំង ៤ ណា ។ អរិយសាវកនោះ ឈ្មោះថា មិនធ្វើបាបកម្ម

ព្រោះហេតុ ៤ យ៉ាងនេះ ។ ព្រះមានព្រះភាគបានសម្តែងពាក្យនេះហើយ ព្រះសុគតជាសាស្តា លុះទ្រង់សម្តែងពាក្យនេះហើយ ទើបសម្តែងគាថាព័ន្ធនេះតទៅទៀតថា

[ ៤៨ ] អ្នកណា ប្រព្រឹត្តកន្លងធម៌ ព្រោះសេចក្តី
ស្រឡាញ់ ព្រោះសេចក្តីស្អប់ ព្រោះសេចក្តីខ្លាច ព្រោះ
សេចក្តីវង្វេង យសរបស់អ្នកនោះ រមែងសាបសូន្យទៅ
ដូចព្រះចន្ទខាងរនោច ។ អ្នកណា មិនប្រព្រឹត្តកន្លងធម៌
ព្រោះសេចក្តីស្រឡាញ់ ព្រោះសេចក្តីស្អប់ ព្រោះសេចក្តី
ខ្លាច ព្រោះសេចក្តីវង្វេង យសរបស់អ្នកនោះ រមែងពេញ
បរិបូណ៌ ដូចព្រះចន្ទខាងខ្នើត ។

[ ៤៩ ] អរិយសាវក មិនសេពនូវធម៌ ជាប្រធាននៃសេចក្តីវិនាសភោគៈ ៦ យ៉ាង ដូចម្តេចខ្លះ ។ ម្នាលគហបតិបុត្ត កិរិយាប្រកបរឿយៗ នូវការផឹកទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាហេតុ ជាទីតាំងនៃសេចក្តីប្រមាទ ជាប្រធាននៃសេចក្តីវិនាសភោគៈ ១ បានប្រកបរឿយៗ នូវការត្រាច់ទៅតាមច្រកល្ហកខុសកាល ជាប្រធាននៃសេចក្តីវិនាសភោគៈ ១ ការដើរមើលមហោស្រព ជាប្រធាននៃសេចក្តីវិនាសភោគៈ ១ ការប្រកបរឿយៗ នូវហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺលេងល្បែងភ្នាល់ ជាប្រធាននៃសេចក្តីវិនាសភោគៈ ១ ការសេពគប់នូវបាបមិត្ត ជាប្រធាននៃសេចក្តីវិនាសភោគៈ ១ ការប្រកបរឿយៗ នូវសេចក្តីខ្ជិល ជាប្រធាននៃសេចក្តីវិនាសភោគៈ ១ ។

[ ៥០ ] ម្នាលគហបតិបុត្ត ទោសក្នុងកិរិយាប្រកបរឿយៗ នូវការផឹកទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាហេតុជាទីតាំងនៃសេចក្ដីប្រមាទនេះមាន ៦ យ៉ាង គឺវិនាសទ្រព្យដែលឃើញជាក់ស្ដែងខ្លួនឯង ១ ការកឲ្យកើតជម្លោះ ១ ហេតុនាំឲ្យកើតរោគទាំងឡាយ ១ ការនាំឲ្យខូចឈ្មោះ ១ ការបង្ហាញកេរ្ដិ៍ខ្មាស ១ ហេតុជាគម្រប់ ៦ គឺធ្វើបញ្ញាឲ្យមានកម្លាំងថយ ១ ។ ម្នាលគហបតិបុត្ត ទោសក្នុងការប្រកបរឿយៗ នូវការផឹកទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាហេតុជាទីតាំងនៃសេចក្ដីប្រមាទមាន ៦ យ៉ាងនេះឯង ។

[ ៥១ ] ម្នាលគហបតិបុត្ត ទោសក្នុងការប្រកបរឿយៗ នូវការដើរទៅតាមច្រកល្ហកខុសកាលនេះមាន ៦ យ៉ាង គឺអ្នកនោះ ឈ្មោះថា មិនគ្រប់គ្រង មិនរក្សាខ្លួន ១ អ្នកនោះ ឈ្មោះថា មិនគ្រប់គ្រង មិនរក្សាកូនប្រពន្ធ ១ អ្នកនោះ ឈ្មោះថា មិនគ្រប់គ្រង មិនរក្សាទ្រព្យសម្បត្តិ ១ សេចក្ដីរង្កៀសតែងកើតមានក្នុងកន្លែង ( ដែលខ្លួនទៅដល់ ) នោះៗ ១ ពាក្យមិនពិតតែងធ្លាក់មកត្រូវលើបុគ្គលនោះ ១ បុគ្គលនោះ ឈ្មោះថា បំពេញនូវធម៌ជាទុក្ខច្រើន ១ ។ ម្នាលគហបតិបុត្ត ទោសក្នុងការប្រកបរឿយៗ នូវកិរិយាត្រាច់ទៅតាមច្រកល្ហកខុសកាល មាន ៦ យ៉ាងនេះឯង ។

[ ៥២ ] ម្នាលគហបតិបុត្ត ទោសក្នុងការដើរមើលល្បែងមហោស្រពនេះ ៦ យ៉ាង គឺរបាំក្នុងទីណា ក៏ទៅក្នុងទីនោះ ១ ចម្រៀងក្នុងទីណា ក៏ទៅក្នុងទីនោះ ១ ការប្រគំក្នុងទីណា ក៏ទៅក្នុងទីនោះ ១ គេប្រជុំនិយាយរឿងព្រេង ឥតប្រយោជន៍ ( មានរឿងចម្បាំងនៃមហាភារតៈ និងរឿងនាងសិតា

ជាដើម ) ក្នុងទីណា ក៏ទៅក្នុងទីនោះ ១ ល្បែងវាយគងក្នុងទីណា ក៏ទៅក្នុងទីនោះ ១ ល្បែងវាយរនាតក្នុងទីណា ក៏ទៅក្នុងទីនោះ ១ ។ ម្នាលគហបតិបុត្ត ទោសក្នុងកិរិយាដើរមើលល្បែងមហោស្រព មាន ៦ យ៉ាងនេះឯង ។

[ ៥៣ ] ម្នាលគហបតិបុត្ត ទោសក្នុងការប្រកបរឿយៗ នូវការលេងល្បែងភ្នាល់ ដែលជាហេតុជាទីតាំងនៃសេចក្តីប្រមាទនេះ មាន ៦ យ៉ាង គឺ បុគ្គលនោះបើឈ្នះគេតែងបានពៀរ ១ បើចាញ់គេ តែងសោកស្តាយទ្រព្យសម្បត្តិ ១ វិនាសទ្រព្យសម្បត្តិ ដែលឃើញជាក់ស្តែងទាន់ភ្នែក ១ កាលបើទៅសាលាវិនិច្ឆ័យ គេមិនជឿស្តាប់ពាក្យ ១ ពួកមិត្តអាមាត្យ តែងបោះបង់ចោល ១ ជាបុគ្គលដែលគេមិនត្រូវការដណ្តឹង ឬឲ្យកូនស្រី ព្រោះគេគិតថា បុរសបុគ្គលអ្នកលេងល្បែងភ្នាល់ មិនអាចចិញ្ចឹមប្រពន្ធបានទេ ១ ។ ម្នាលគហបតិបុត្ត ទោសក្នុងការប្រកបរឿយៗ នូវការលេងល្បែងភ្នាល់ ដែលជាហេតុជាទីតាំងនៃសេចក្តីប្រមាទ មាន ៦ យ៉ាងនេះឯង ។

[ ៥៤ ] ម្នាលគហបតិបុត្ត ទោសក្នុងការសេពគប់នូវបាបមិត្តនេះ មាន ៦ យ៉ាង គឺពួកជនដែលជាអ្នកលេងល្បែងភ្នាល់ ១ ជនដែលជាអ្នកលេងស្រី ១ ជនដែលជាអ្នកលេងផឹកសុរា ១ ជនដែលជាអ្នកបោកប្រាសបញ្ឆោតអ្នកដទៃ ដោយរបស់ក្លែង ១ ជនដែលជាអ្នកបំបាត់ប្រវញ្ចអ្នកដទៃ ក្នុងទីចំពោះមុខ ១ ជនដែលជាអ្នកឆក់ដណ្តើមទ្រព្យអ្នកដទៃ ១ ជនទាំងនោះជាមិត្តសម្លាញ់របស់ជននោះ ។ ម្នាលគហបតិបុត្ត ទោសក្នុងការសេពគប់នូវបាបមិត្ត មាន ៦ យ៉ាងនេះឯង ។

[ ៥៥ ] ម្នាលគហបតិបុត្ត ទោសក្នុងការប្រកបរឿយៗ នូវសេចក្តីខ្ជិលនេះ មាន ៦ យ៉ាង គឺមិនធ្វើការងារ ដោយអាងថា ត្រជាក់ណាស់ ១ មិនធ្វើការងារ ដោយអាងថា ក្តៅណាស់ ១ មិនធ្វើការងារ ដោយអាងថា ល្ងាចណាស់ ១ មិនធ្វើការងារ ដោយអាងថា ព្រឹកណាស់ ១ មិនធ្វើការងារ ដោយអាងថា ឃ្លានណាស់ ១ មិនធ្វើការងារ ដោយអាងថា ស្រេកណាស់ ១ កាលបើជនអ្នកខ្ជិលប្រអូសនោះ ច្រើនដោយការពោលអាងកិច្ចយ៉ាងនេះ ភោគៈទាំងឡាយដែលមិនទាន់កើត ក៏ខានកើតឡើងផង ភោគៈទាំងឡាយដែលកើតឡើងហើយ ក៏ដល់នូវសេចក្តីវេចរឹលទៅវិញផង ។ ម្នាលគហបតិបុត្ត ទោសក្នុងការប្រកបរឿយៗ នូវសេចក្តីខ្ជិល មាន ៦ យ៉ាងនេះឯង ។ ព្រះមានព្រះភាគ ទ្រង់បានសម្តែងធម៌នេះហើយ ព្រះសុគតជាសាស្តា លុះសម្តែងធម៌នេះហើយ ទ្រង់សម្តែងគាថាព័ន្ធនេះតទៅទៀតថា

[ ៥៦ ] បុគ្គលខ្លះ ជាមិត្តសម្លាញ់ បានតែក្នុងរោងសុរា
ក៏មាន បុគ្គលខ្លះថា សម្លាញ់ៗ តែនៅចំពោះមុខក៏មាន
បុគ្គលណា កាលបើប្រយោជន៍ ( ខ្លួន ) កើតឡើង ទើប
ធ្វើជាសម្លាញ់ បុគ្គលនោះ មកជាសម្លាញ់នឹងខ្លួនក៏មាន ។
កិរិយាដេកដល់ថ្ងៃ ១ ធ្វើសេវនកិច្ចនឹងប្រពន្ធអ្នកដទៃ ១
ភាវៈជាអ្នកមានពៀរច្រើន ១ ភាវៈជាអ្នកធ្វើអំពើឥតប្រ-
យោជន៍ ១ បាបមិត្ត ១ ភាវៈជាអ្នកកំណាញ់ស្វិតស្វាញ ១
ហេតុទាំង ៦ នុ៎ះ រមែងបំផ្លាញបុរស ( ឲ្យវិនាស ) ។

នវជនដែលមានមិត្តអាក្រក់ មានសម្លាញ់អាក្រក់ មានមារយាទ និងគោចរអាក្រក់ តែងវិនាសចាកលោកទាំងពីរ គឺលោកនេះ និងលោកខាងមុខ ។ ល្បែងភ្នាល់ ល្បែងស្រី និងល្បែងសុរា ១ របាំ និងចម្រៀង ១ ការដេកថ្ងៃ ១ ការឲ្យគេបម្រើខ្លួនក្នុងកាលមិនគួរ ១ ពួកមិត្តអាក្រក់ ១ ភាវៈជាអ្នកមានសេចក្តីកំណាញ់ស្វិតស្វាញ ១ ហេតុទាំង ៦ នេះ តែងបំផ្លាញបុរសឲ្យវិនាស ។ ពួកជនដែលលេងល្បែងភ្នាល់ ផឹកសុរា ធ្វើសេវនកិច្ចនឹងស្រីដែលស្មើដោយជីវិតរបស់បុរសដទៃ សេពគប់នឹងបុគ្គលថោកទាប ( ខាតលក្ខណ៍ ) មិនសេពគប់នឹងបុគ្គលដែលមានសេចក្តីចម្រើន ( គ្រប់លក្ខណ៍ ) យសរបស់ពួកជននោះ តែងសាបសូន្យដូចព្រះចន្ទខាងរនោច ។ ជនដែលជាអ្នកផឹកសុរា ជាអ្នកខ្សត់ទ្រព្យ ជាអ្នកឥតមានកន្លល់ដោយការងារចិញ្ចឹមជីវិត មានតែស្រវឹងជានិច្ច ប្រាសចាកសេចក្តីចម្រើន លិចចុះក្នុងបំណុល ដូចដុំថ្មលិចចុះទៅក្នុងទឹក បុគ្គលនោះ តែងធ្វើការងារឲ្យវឹកវរដល់ខ្លួនដោយឆាប់ ។ បុគ្គលដេកក្នុងវេលាថ្ងៃ ជាប្រក្រតី មិនក្រោកឡើងពីយប់ជាប្រក្រតី ជាអ្នកស្រវឹងជានិច្ច ជាអ្នកលេងល្បែង មិនអាចនឹងគ្រប់គ្រងផ្ទះសម្បែងបាន ។ ប្រយោជន៍ទាំងឡាយ តែងកន្លងហួស

មនុស្សដែលលះបង់ចោលនូវការងារ ដោយពោលអាងថា
វេលានេះ ត្រជាក់ណាស់ ក្តៅណាស់ ល្ងាចណាស់ ។
ជនណាមួយ ធ្វើនូវកិច្ចការរបស់បុរស មិនអើពើនូវត្រជាក់
និងក្តៅ ក្រៃលែងជាងស្មៅ ( ទៅទៀត ) ជននោះ រមែង
មិនសាបសូន្យចាកសេចក្តីសុខឡើយ ។

[ ៥៧ ] ម្នាលគហបតិបុត្ត អ្នកត្រូវស្គាល់ពួកមនុស្សដែលមិនមែនជាមិត្ត គ្រាន់តែជាមិត្តប្ញម ៤ ពួកនេះ គឺអ្នកត្រូវស្គាល់មនុស្សដែលគិតយកតែប្រយោជន៍ខ្លួន ជាមិនមែនជាមិត្ត គ្រាន់តែជាមិត្តប្ញម ១ អ្នកត្រូវស្គាល់មនុស្សល្អតែសម្តី ជាមិនមែនជាមិត្ត គ្រាន់តែជាមិត្តប្ញម ១ អ្នកត្រូវស្គាល់មនុស្សដែលនិយាយចាក់បណ្តោយឲ្យគាប់ចិត្ត ជាមិនមែនជាមិត្ត គ្រាន់តែជាមិត្តប្ញម ១ អ្នកត្រូវស្គាល់មនុស្សជាសម្លាញ់ ក្នុងការវិនាសភោគៈទាំងឡាយ ជាមិនមែនជាមិត្ត គ្រាន់តែជាមិត្តប្ញម ១ ។

[ ៥៨ ] ម្នាលគហបតិបុត្ត មនុស្សគិតយកតែប្រយោជន៍ខ្លួន មិនមែនជាមិត្ត គ្រាន់តែជាមិត្តប្ញម ( នោះ ) អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាង គឺមិត្តគិតយកតែប្រយោជន៍ខ្លួន ១ មិត្តប្រាថ្នាយករបស់ច្រើនដោយ ( ឲ្យ ) របស់តិចតួច ១ ទាល់តែមានភ័យទើបជួយធ្វើកិច្ចរបស់មិត្ត ១ សេពគប់មិត្តព្រោះហេតុតែប្រយោជន៍ ១ ។ ម្នាលគហបតិបុត្ត មិត្តគិតយកតែប្រយោជន៍ខ្លួន មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្ញម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងនេះឯង ។

[ ៥៩ ] ម្នាលគហបតិបុត្ត មិត្តល្អតែសម្តី មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន ៤ គឺមិត្តទទួលរាក់ទាក់ដោយរបស់ដែលកន្លងហើយ ១ ទទួលរាក់ទាក់ដោយរបស់ដែលមិនទាន់មានមក ១ សង្គ្រោះដោយអំពើឥតប្រយោជន៍ កាលកិច្ចទាំងឡាយ កើតឡើងភ្លាមៗ ក៏សម្តែងអាងរបស់ខូចខាត ១ ម្នាលគហបតិបុត្ត មិត្តល្អតែសម្តី មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងនេះឯង ។

[ ៦០ ] ម្នាលគហបតិបុត្ត មិត្តនិយាយចាក់បណ្តោយឲ្យគាប់ចិត្ត មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាង គឺបើមិត្តធ្វើអំពើអាក្រក់ ក៏យល់ព្រមតាម ១ មិត្តធ្វើអំពើល្អ ក៏យល់ព្រមតាម ១ ពណ៌នាគុណមិត្ត តែក្នុងទីចំពោះមុខ ១ ពោលទោសមិត្ត ក្នុងទីកំបាំងមុខ ១ ។ ម្នាលគហបតិបុត្ត មិត្តនិយាយចាក់បណ្តោយឲ្យគាប់ចិត្ត មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងនេះឯង ។

[ ៦១ ] ម្នាលគហបតិបុត្ត មនុស្សជាសម្លាញ់ក្នុងផ្លូវវិនាស មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្លម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាង គឺជាសម្លាញ់ក្នុងកិរិយាប្រកបរឿយៗ នូវការផឹកទឹកស្រវឹង គឺសុរាមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ១ ជាសម្លាញ់ក្នុងការប្រកបរឿយៗ នូវការត្រាច់ទៅតាមច្រកល្ហកខុសកាល ១ ជាសម្លាញ់ក្នុងកិរិយាដើរមើលល្បែងមហោស្រព ១ ជាសម្លាញ់ក្នុងកិរិយាប្រកបរឿយៗ នូវល្បែងភ្នាល់ ដែលជាហេតុជាទីតាំងនៃសេចក្តីប្រមាទ ១ ។ ម្នាលគហបតិបុត្ត មនុស្សជាសម្លាញ់ក្នុងផ្លូវ

វិនាស មិនមែនជាមិត្តទេ គ្រាន់តែជាមិត្តប្ញម អ្នកត្រូវស្គាល់ដោយស្ថាន ៤ យ៉ាងនេះឯង ។ ព្រះមានព្រះភាគទ្រង់បានសម្តែងសេចក្តីនេះ លុះព្រះសុគតជាសាស្តាសម្តែងសេចក្តីនេះហើយ ទើបទ្រង់សម្តែងពាក្យគាថាព័ន្ធតទៅទៀតថា

[ ៦២ ] បុគ្គលដែលជាមិត្ត គិតយកតែប្រយោជន៍ខ្លួន ១
បុគ្គលដែលជាមិត្តល្អតែសម្តី ១ បុគ្គលដែលនិយាយចាក់
បណ្តោយឲ្យគាប់ចិត្ត ១ បុគ្គលដែលជាសម្លាញ់ ក្នុងផ្លូវ
វិនាស ១ បណ្ឌិតដឹងថា បុគ្គលទាំង ៤ ពួកនុ៎ះ មិនមែន
ជាមិត្តហើយ គប្បីចៀសវាងឲ្យឆ្ងាយ ដូចជាអ្នកដំណើរ
ចៀសវាងផ្លូវ ដែលប្រកបដោយភ័យ ដូច្នោះ ។

[ ៦៣ ] ម្នាលគហបតិបុត្ត មនុស្ស ៤ ពួកនេះ អ្នកត្រូវដឹងថា ជាមិត្តមានសន្តានល្អ គឺមិត្តមានឧបការៈ អ្នកត្រូវដឹងថា ជាមិត្តមានសន្តានល្អ ១ មិត្តរួមសុខទុក្ខ អ្នកត្រូវដឹងថា មិត្តមានសន្តានល្អ ១ មិត្តប្រាប់ប្រយោជន៍ អ្នកត្រូវដឹងថា ជាមិត្តមានសន្តានល្អ ១ មិត្តមានសេចក្តីឈឺឆ្អាល អ្នកត្រូវដឹងថា ជាមិត្តមានសន្តានល្អ ១ ។

[ ៦៤ ] ម្នាលគហបតិបុត្ត មិត្តមានឧបការៈ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង គឺរក្សាមិត្តដែលធ្វេសប្រហែស ១ រក្សាសម្បត្តិរបស់មិត្តដែលធ្វេសប្រហែស ១ ជាទីពឹងពំនាក់នៃមិត្ត ដែលមានសេចក្តីភិតភ័យ ១ កាលបើកិច្ចដែលត្រូវធ្វើកើតឡើងហើយ តែងជួយផ្តល់ភោគៈជាទ្វិគុណជាងទ្រព្យដែលមិត្តត្រូវការនោះ ១ ។ ម្នាលគហបតិបុត្ត មិត្ត

មានឧបការៈ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងនេះឯង ។

[ ៦៥ ] ម្នាលគហបតិបុត្ត មិត្តរួមសុខទុក្ខ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង គឺប្រាប់នូវអាថ៌កំបាំងរបស់ខ្លួនដល់មិត្ត ១ ជួយបិទបាំងនូវអាថ៌កំបាំងរបស់មិត្ត ១ មិនបោះបង់គ្នាក្នុងគ្រាមានវិបត្តិ សូម្បីជីវិតក៏ហ៊ានលះបង់ ដើម្បីប្រយោជន៍ដល់មិត្ត ( ស៊ូប្តូរជីវិត ) ១ ។ ម្នាលគហបតិបុត្ត មិត្តរួមសុខទុក្ខ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងនេះឯង ។

[ ៦៦ ] ម្នាលគហបតិបុត្ត មិត្តប្រាប់ប្រយោជន៍ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង គឺហាមមិត្តឲ្យឃ្លាតចាកអំពើអាក្រក់ ១ ដឹកនាំឲ្យមិត្តតម្កល់នៅតែក្នុងអំពើល្អ ១ ឲ្យបានឮពាក្យដែលមិនធ្លាប់បានឮ ១ ប្រាប់ផ្លូវឋានសួគ៌ ១ ។ ម្នាលគហបតិបុត្ត មិត្តប្រាប់ប្រយោជន៍ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងនេះឯង ។

[ ៦៧ ] ម្នាលគហបតិបុត្ត មិត្តមានសេចក្តីឈឺឆ្អាល ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង គឺជួយព្រួយចិត្ត ពីព្រោះមិត្តបានសេចក្តីវិនាស ១ ជួយត្រេកអរ ព្រោះមិត្តបានសេចក្តីចម្រើន ១ ទទឹងទាស់នឹងមនុស្សដែលពោលទោសមិត្ត ១ សរសើរតែមនុស្ស ដែលពណ៌នាគុណមិត្ត ១ ។ ម្នាលគហបតិបុត្ត មិត្តមានសេចក្តីឈឺឆ្អាល ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាងនេះឯង ។ ព្រះមានព្រះភាគ ទ្រង់បានសម្តែងសេចក្តីនេះ លុះព្រះសុគតជាសាស្តា ត្រាស់សេចក្តីនេះហើយ ទើប

ទ្រង់សម្តែងពាក្យជាគាថាព័ន្ធតទៅទៀតថា

[ ៦៨ ] មិត្តដែលមានឧបការៈ សម្លាញ់ដែលរួមសុខទុក្ខ មិត្តដែលប្រាប់ប្រយោជន៍ មិត្តដែលមានសេចក្តីឈឺឆ្អាល បណ្ឌិតស្គាល់ជាក់នូវបុគ្គលទាំង ៤ ពួកនុ៎ះ ថាជាមិត្តមែនទែន ហើយគប្បីចូលទៅអង្គុយជិតស្និទ្ធស្នាល ដូចជាមាតានិងបុត្ត ដែលកើតពីទ្រូង ។ អ្នកប្រាជ្ញបរិបូណ៌ដោយសីល តែងរុងរឿង ដូចជាភ្លើងដែលភ្លឺ ដូច្នោះឯង កាលបុគ្គលសន្សំទ្រព្យ រមែងធ្វើទ្រព្យឲ្យជាគំនរដូចជាឃ្មុំ ដូច្នោះឯង ។ ភោគៈទាំងឡាយ តែងដល់នូវការពូនជាគំនរ ដូចជាដំបូកដែលកណ្តៀរកពូន ដូច្នោះឯង ។ គ្រហស្ថក្នុងត្រកូលបានសន្សំភោគៈទាំងឡាយយ៉ាងនេះហើយ ទើបអាច ( តាំងខ្លួន ) កុលបុត្រដែលចែកភោគៈទាំងឡាយជា ៤ ចំណែក គឺបរិភោគភោគៈទាំងឡាយ ១ ចំណែក ប្រកបការងារ ២ ចំណែក ទាំងតម្កល់ទុកនូវចំណែកទី ៤ ដោយក្រែងមានអន្តរាយទាំងឡាយ ( ទៅខាងមុខ ) កុលបុត្រនោះ ទើបឈ្មោះថា ចងបាច់មិត្តទាំងឡាយបាន ។

[ ៦៩ ] ម្នាលគហបតិបុត្ត អរិយសាវកបិទបាំងទិសទាំង ៦ ដូចម្តេច ។ ម្នាលគហបតិបុត្ត អ្នកត្រូវដឹងទិសទាំង ៦ ដូច្នេះ គឺមាតាបិតា អ្នកត្រូវដឹងថា ទិសខាងកើត ១ អាចារ្យ អ្នកត្រូវដឹងថា ទិសខាងត្បូង ១ កូន និង

ប្រពន្ធ អ្នកត្រូវដឹងថា ទិសខាងលិច ១ មិត្តអាមាត្យ អ្នកត្រូវដឹងថា ទិសខាងជើង ១ ទាសៈ និងកម្មករ អ្នកត្រូវដឹងថា ទិសខាងក្រោម ១ សមណព្រាហ្មណ៍ អ្នកត្រូវដឹងថា ទិសខាងលើ ១ ។

[ ៧០ ] ម្នាលគហបតិបុត្ត មាតាបិតាជាទិសខាងកើត កូនត្រូវទំនុកបម្រុង ដោយស្ថានទាំងឡាយ ៥ យ៉ាង គឺកូនត្រូវតាំងចិត្តថា អាត្មាអញមាតាបិតាបានចិញ្ចឹមរក្សាមកហើយ នឹងចិញ្ចឹមមាតាបិតាវិញ ១ នឹងជួយធ្វើការងាររបស់មាតាបិតា ១ ទាំងតម្កល់វង្សត្រកូល ១ ប្រតិបត្តិឲ្យជាអ្នកសមគួរទទួលទ្រព្យមត៌កបាន ១ មួយទៀត ឧទ្ទិសទក្ខិណាទានដល់មាតាបិតាដែលធ្វើកាលកិរិយាទៅកាន់បរលោកហើយ ១ ។ ម្នាលគហបតិបុត្ត មាតាបិតាជាទិសខាងកើត ដែលកូនត្រូវទំនុកបម្រុង ដោយស្ថានទាំងឡាយ ៥ យ៉ាងនេះឯង ហើយរមែងអនុគ្រោះកូន ដោយស្ថានទាំងឡាយ ៥ យ៉ាងវិញ ដូច្នេះ គឺហាមឃាត់កូនចាកអំពើអាក្រក់ ១ ឲ្យកូនតម្កល់នៅតែក្នុងអំពើល្អ ១ ឲ្យកូនរៀនសូត្រសិល្បសាស្ត្រ ១ ដណ្តឹងភរិយាស្វាមីសមគួរឲ្យ ១ ចែកទ្រព្យឲ្យកូនក្នុងសម័យគួរ ១ ។ ម្នាលគហបតិបុត្ត មាតាបិតាជាទិសខាងកើត ដែលកូនត្រូវទំនុកបម្រុងដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះកូនដោយស្ថាន ៥ យ៉ាងនេះ ទិសខាងកើតនោះ ដែលកូនបានបិទបាំងហើយ ជាទិសមានសេចក្តីក្សេម ឥតមានភយន្តរាយយ៉ាងនេះ ។

[ ៧១ ] ម្នាលគហបតិបុត្ត អាចារ្យ ជាទិសខាងត្បូង សិស្សត្រូវប្រតិបត្តិដោយស្ថាន ៥ យ៉ាង គឺដោយការក្រោកឡើងទទួល ១ ដោយការ

គាល់បម្រើ ១ ដោយការជឿស្តាប់ឱវាទ ១ ដោយការបម្រើតូចៗ ( មានឲ្យទឹកលុបមុខ និងឈើស្ទន់ជាដើម ) ១ ដោយការរៀនសិល្បសាស្ត្រដោយគោរព ១ ។ ម្នាលគហបតិបុត្ត អាចារ្យ ជាទិសខាងត្បូង ដែលសិស្សត្រូវប្រតិបត្តិដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះសិស្សដោយស្ថាន ៥ យ៉ាងវិញ គឺដឹកនាំល្អ ១ ឲ្យរៀនល្អ ១ ប្រៀនប្រដៅសិស្សឲ្យចេះត្រឹមត្រូវក្នុងសិល្បសាស្ត្រសព្វគ្រប់ ១ តែងលើកតម្កើងក្នុងទីប្រជុំមិត្តអាមាត្យ ១ ធ្វើសេចក្តីការពារក្នុងទិសទាំងឡាយ ១ ។ ម្នាលគហបតិបុត្ត អាចារ្យ ជាទិសខាងត្បូង ដែលសិស្សត្រូវប្រតិបត្តិដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះសិស្សដោយស្ថាន ៥ យ៉ាងនេះ ទិសខាងត្បូងនោះ ដែលសិស្សបានបិទបាំងហើយ ជាទិសមានសេចក្តីក្សេម ឥតមានភយន្តរាយយ៉ាងនេះ ។

[ ៧២ ] ម្នាលគហបតិបុត្ត ភរិយាជាទិសខាងលិច ស្វាមីត្រូវទំនុកបម្រុងដោយស្ថានទាំងឡាយ ៥ យ៉ាង គឺដោយការរាប់អានជាភរិយាពេញទី ១ ដោយមិនមើលងាយ ១ ដោយមិនប្រព្រឹត្តក្បត់ចិត្ត ១ ដោយប្រគល់ឲ្យជាធំ ( ក្នុងការផ្ទះ ) ១ ដោយការឲ្យគ្រឿងតែងខ្លួន ១ ។ ម្នាលគហបតិបុត្ត ភរិយាជាទិសខាងលិច ស្វាមីត្រូវទំនុកបម្រុងដោយស្ថានទាំងឡាយ ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះស្វាមីដោយស្ថានទាំងឡាយ ៥ យ៉ាងវិញ គឺចាត់ចែងការងារដោយល្អ ១ សង្គ្រោះជនជាញាតិទាំងពីរខាងដោយល្អ ១ មិនប្រព្រឹត្តក្បត់ចិត្ត ១ ថែទាំទ្រព្យដែលស្វាមីរកបានមក ១ ឈ្លាស មិនខ្ជិល

ប្រអូស ក្នុងកិច្ចការសព្វគ្រប់ ១ ។ ម្នាលគហបតិបុត្ត ភរិយា ជាទិសខាងលិច ស្វាមីត្រូវទំនុកបម្រុងដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះស្វាមីដោយស្ថាន ៥ យ៉ាងនេះ ទិសខាងលិចនោះ ដែលស្វាមីបិទបាំងហើយ ជាទិសមានសេចក្តីក្សេម ឥតមានភយន្តរាយយ៉ាងនេះ ។

[ ៧៣ ] ម្នាលគហបតិបុត្ត មិត្តអាមាត្យជាទិសខាងជើង កុលបុត្តត្រូវប្រតិបត្តិដោយស្ថានទាំងឡាយ ៥ យ៉ាង គឺដោយការឲ្យរបស់ ១ ដោយការនិយាយតែពាក្យគាប់ចិត្ត ១ ដោយការប្រព្រឹត្ត ឲ្យជាប្រយោជន៍ ១ ដោយការប្រព្រឹត្តខ្លួនស្មើ ១ ដោយការមិនកុហកបញ្ឆោត ១ ។ ម្នាលគហបតិបុត្ត មិត្តអាមាត្យ ជាទិសខាងជើង ដែលកុលបុត្តប្រតិបត្តិដោយស្ថាន ៥ នេះឯងហើយ រមែងអនុគ្រោះកុលបុត្រដោយស្ថាន ៥ យ៉ាង គឺរក្សាមិត្តដែលធ្វេសប្រហែស ១ ជួយថែទាំទ្រព្យសម្បត្តិរបស់មិត្តដែលធ្វេសប្រហែស ១ ជាទីពឹង របស់មិត្តដែលមានភ័យ ១ មិនបោះបង់គ្នាក្នុងគ្រាវិបត្តិ ១ រាប់អានរហូតដល់ផៅពង្សរបស់មិត្ត ១ ។ ម្នាលគហបតិបុត្ត មិត្តអាមាត្យ ជាទិសខាងជើង ដែលកុលបុត្តប្រតិបត្តិដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះកុលបុត្រដោយស្ថាន ៥ យ៉ាងនេះ ទិសខាងជើងនុ៎ះ ដែលកុលបុត្តបានបិទបាំងហើយ ជាទិសមានសេចក្តីក្សេម ឥតមានភយន្តរាយយ៉ាងនេះ ។

[ ៧៤ ] ម្នាលគហបតិបុត្ត ទាសៈ និងកម្មករ ជាទិសខាងក្រោម ចៅហ្វាយនាយត្រូវទំនុកបម្រុងដោយស្ថាន ៥ យ៉ាង គឺដោយការចាត់ចែងការងារ សមគួរតាមកម្លាំង ១ ដោយការឲ្យនូវភត្តាហារ និងថ្លៃឈ្នួល ១

ដោយការព្យាបាលក្នុងវេលាឈឺថ្កាត់ ១ ការចែករំលែកនូវរបស់មានរសឆ្ងាញ់ ១ ដោយការឲ្យឈប់សម្រាកក្នុងសម័យគួរ ១ ។ ម្នាលគហបតិបុត្ត ទាសៈ និងកម្មករ ជាទិសខាងក្រោមដែលចៅហ្វាយនាយទំនុកបម្រុងដោយស្ថាន៥ នេះឯងហើយ រមែងអនុគ្រោះចៅហ្វាយនាយដោយស្ថាន ៥ យ៉ាង គឺក្រោកឡើងធ្វើការងារមុនចៅហ្វាយនាយ ១ ឈប់ធ្វើការងារក្រោយចៅហ្វាយនាយ ១ កាន់យកតែរបស់ដែលចៅហ្វាយនាយឲ្យ ១ ធ្វើការងាររបស់ចៅហ្វាយនាយ ដោយយកចិត្តទុកដាក់ ១ នាំកិត្តិគុណរបស់ចៅហ្វាយនាយទៅថ្លែងក្នុងទីនោះៗ ១ ។ ម្នាលគហបតិបុត្ត ទាសៈ និងកម្មករ ជាទិសខាងក្រោម ដែលចៅហ្វាយនាយទំនុកបម្រុងដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះចៅហ្វាយនាយដោយស្ថាន ៥ យ៉ាងនេះ ទិសខាងក្រោមនុ៎ះ ដែលចៅហ្វាយនាយបានបិទបាំងហើយ ជាទិសមានសេចក្តីក្សេម ឥតមានភយន្តរាយយ៉ាងនេះ ។

[ ៧៥ ] ម្នាលគហបតិបុត្ត សមណព្រាហ្មណ៍ ជាទិសខាងលើ កុលបុត្តត្រូវផ្គត់ផ្គង់ដោយស្ថាន ៥ យ៉ាង គឺដោយកាយកម្មប្រកបដោយមេត្តា ១ ដោយវចីកម្មប្រកបដោយមេត្តា ១ ដោយមនោកម្មប្រកបដោយមេត្តា ១ ជាអ្នកមិនបិទទ្វារផ្ទះ ១ ដោយកិរិយាឲ្យអាមិសទាន ១ ។ ម្នាលគហបតិបុត្ត សមណព្រាហ្មណ៍ ជាទិសខាងលើ ដែលកុលបុត្តទំនុកបម្រុងដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះកុលបុត្តដោយស្ថាន ៦ គឺហាមឃាត់កុលបុត្តចាកអំពើអាក្រក់ ១ ឲ្យតាំងនៅតែក្នុងអំពើល្អ ១ អនុគ្រោះដោយ

ចិត្តដ៏ល្អ ១ ឲ្យបានស្តាប់ពាក្យដែលមិនធ្លាប់ស្តាប់ ១ បំភ្លឺសេចក្តីដែលធ្លាប់ស្តាប់ហើយ ១ ប្រាប់ផ្លូវសួគ៌ ១ ។ ម្នាលគហបតិបុត្ត សមណព្រាហ្មណ៍ជាទិសខាងលើ ដែលកុលបុត្តផ្គត់ផ្គង់ដោយស្ថាន ៥ យ៉ាងនេះឯងហើយ រមែងអនុគ្រោះកុលបុត្តដោយស្ថាន ៦ នេះ ទិសខាងលើនុ៎ះ ដែលកុលបុត្តបានបិទបាំងហើយ ជាទិសមានសេចក្តីក្សេម ឥតមានភ័យអន្តរាយយ៉ាងនេះ ។ ព្រះមានព្រះភាគ បានសម្តែងសេចក្តីនេះ ព្រះសុគតជាសាស្តា លុះសម្តែងសេចក្តីនេះហើយ ទ្រង់ត្រាស់ពាក្យជាគាថាព័ន្ធតទៅទៀតថា

[ ៧៦ ] មាតាបិតា ជាទិសខាងកើត អាចារ្យ ជាទិស
ខាងត្បូង កូនប្រពន្ធ ជាទិសខាងលិច មិត្តអាមាត្យ ជា
ទិសខាងជើង ទាសៈ និងកម្មករ ជាទិសខាងក្រោម
សមណព្រាហ្មណ៍ ជាទិសខាងលើ គ្រហស្ថក្នុងត្រកូល
ដែលអាចគ្រប់គ្រងផ្ទះ គប្បីនមស្ការទិសទាំងឡាយនុ៎ះ ។
បណ្ឌិតបរិបូណ៌ដោយសីល មានវាចាដ៏ពីរោះ មានប្រាជ្ញាវៃ
មានកិរិយាប្រព្រឹត្តឱនលំទោនជាប្រក្រតី មិនរឹងត្អឹង បុគ្គល
មានសភាពដូច្នោះ រមែងបានយស បុគ្គលមានព្យាយាម
រវៀសរវៃ មិនខ្ជិលច្រអូស រមែងមិនញាប់ញ័រក្នុងអន្តរាយ
ទាំងឡាយ បុគ្គលមានកិរិយាប្រព្រឹត្តឥតចន្លោះ មានប្រាជ្ញា
វាងវៃ បុគ្គលមានសភាពដូច្នោះ រមែងបានយស ។ បុគ្គល
មានសេចក្តីសង្គ្រោះ ជាអ្នកចងមិត្ត ជាអ្នកដឹងដំណើរពាក្យ

ជាអ្នកប្រាសចាកសេចក្តីកំណាញ់ ជាអ្នកដឹកនាំពន្យល់ការណ៍ផ្សេងៗ ជាអ្នកណែនាំរឿយៗ បុគ្គលមានសភាពដូច្នោះ រមែងបានយស ។ ទាន ១ ពាក្យពីរោះ ១ សេចក្តីប្រព្រឹត្តជាប្រយោជន៍ក្នុងលោកនេះ ១ ភាវៈជាអ្នកមានចិត្តស្មើក្នុងធម៌ទាំងឡាយ និងក្នុងបុគ្គលនោះៗ តាមសមគួរ ១ ។ សង្គហធម៌ទាំងនេះ ( មានក្នុងលោក ទើបលោកប្រព្រឹត្តទៅបាន ) ដូចជារថមានប្រែកទប់ ទើបប្រព្រឹត្តទៅបានដូច្នោះឯង បើសង្គហធម៌ទាំងនេះមិនមានហើយ មាតាក្តី បិតាក្តី ក៏មិនបានទូវសេចក្តីរាប់អាន និងការបូជា អំពីកិច្ចដែលកូនត្រូវធ្វើ ។ ព្រោះហេតុតែអ្នកប្រាជ្ញទាំងឡាយសម្លឹងឃើញសង្គហធម៌ទាំងនោះ ដោយប្រពៃ ហេតុនោះ បានជាលោកដល់នូវភាវៈជាធំផង គួរគេសរសើរផង ។

[ ៧៧ ] កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ សិង្គាលកគហបតិបុត្ត បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលព្រះអង្គសម្តែងហើយ ដោយអនេកបរិយាយយ៉ាងនេះ ( ភ្លឺច្បាស់ណាស់ ) ដូចជាមនុស្សផ្ងាររបស់ដែលគេផ្កាប់ ឬដូចគេបើកបង្ហាញរបស់ដែលបិទបាំង ឬក៏ដូចគេប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោតដូចជាគេទ្រោលប្រទីបក្នុងទីងងឹត ដោយគិតថា មនុស្សអ្នកមានចក្ខុទាំង-

ឡាយ រមែងឃើញនូវរូបទាំងឡាយ ខ្ញុំព្រះអង្គនោះ សូមដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ជាជាសរណៈ ចាប់ដើមតាំងពីថ្ងៃនេះទៅ សូមព្រះមានព្រះភាគទ្រង់ជ្រាបនូវខ្ញុំព្រះអង្គ ថាជាឧបាសក ដល់នូវសរណៈស្មើដោយជីវិត ចាប់ដើមតាំងពីថ្ងៃនេះរៀងទៅ ។

## សិង្គាលកសូត្រទី ៨ ចប់

# អដ្ឋកថា
# សិង្គាលកសូត្រ

[ ៤៣ ] សិង្គាលកសូត្រមានបទផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះ ។ តទៅនេះ នឹងពណ៌នាបទដែលលំបាក ក្នុងសិង្គាលកសូត្រនោះ ។ បទថា **វេឡុវនេ** ក្នុងបទថា **វេឡុវនេ កលន្ទកនិវាបេ** ជាឈ្មោះរបស់ឧទ្យាននោះ ។ បានឮថា ឧទ្យាននោះ បានឡោមព័ទ្ធដោយឫស្សី ប្រកបដោយខ្លោងទ្វារ និងប៉ម ដោយកំពែងកម្ពស់ ១៨ ហត្ថ មានពន្លឺខៀវ ជាទីគួររីករាយ ដោយហេតុនោះ ទើបលោកហៅថា **វេឡុវន** ម្យ៉ាងទៀត ជនទាំងឡាយបានឲ្យចំណីដល់សត្វកង្ហែន ក្នុងឧទ្យានវេឡុវ័ននេះ ដោយហេតុនោះ ទើបហៅថា **កលន្ទកនិវាប** ។

មានរឿងតំណាលថា ក្នុងកាលមុន ព្រះរាជាមួយអង្គ ស្ដេចប្រពាតឧទ្យានក្នុងទីនោះ សោយទឹកច័ណ្ឌជរាបដល់ទ្រង់ស្រវឹង ផ្ទំលក់ក្នុងពេលថ្ងៃ ។ ជនបរិវាររបស់ព្រះអង្គគិតគ្នាថា ព្រះរាជាផ្ទំលក់ហើយ ពួកយើងនាំគ្នាទៅរកផ្កា និងផ្លែឈើជាដើម ទើបចៀសចេញទៅពីទីនោះៗ ។ គ្រានោះ ពស់វែកព្រោះបានក្លិនសុរា ទើបលូនចេញចាកព្រង់ឈើមួយដើម មកចំពោះព្រះភក្ត្រព្រះរាជា ។ រុក្ខទេវតា ឃើញពស់នោះគិតថា អញនឹងឲ្យជីវិតដល់ព្រះរាជាដូច្នេះ ទើបជំណែងខ្លួនជាសត្វកង្ហែន មកហើយធ្វើសំឡេងជិតព្រះកាណ៌ ។ ព្រះរាជាទ្រង់ភ្ញាក់ ។ ពស់វែកក៏លូនចៀសចេញទៅ ។ ព្រះរាជាទតឃើញកង្ហែននោះ ទ្រង់ព្រះតម្រិះថា កង្ហែននេះឲ្យជីវិតអញ ទើបត្រាស់បង្គាប់ឲ្យរកចំណីមកទុកក្នុងទីនោះ ត្រាស់បង្គាប់ឲ្យប្រកាស ឲ្យអភ័យដល់សត្វកង្ហែនទាំង-

ឡាយ ។ ព្រោះដូច្នោះ តាំងពីនោះមក ទើបទីនោះឈ្មោះថា **កលន្ទកនិវាប-ស្ថាន** ។ ម្យ៉ាងទៀត បទថា **កលន្ទកា** នេះ ជាឈ្មោះរបស់កំប្រុក ។ បទថា **តេន ខោ បន សមយេន** សេចក្តីថា ដោយសម័យដែលព្រះមានព្រះភាគទ្រង់ធ្វើក្រុងរាជគ្រឹះឲ្យជាគោចរគ្រាមហើយ គង់នៅក្នុងវេឡុវនវិហារ ដែលជាទីព្រះរាជទានចំណីដល់សត្វកំប្រុក ។ បទថា **សិង្គាលកោ គហបតិបុត្តោ** ជាឈ្មោះរបស់គហបតីបុត្រនោះ ។ បទថា **គហបតិបុត្តោ** គឺជាកូនរបស់គហបតី ។ បានឮថា បិតារបស់គហបតីបុត្រនោះ ជាគហបតិមហាសាល ។ គហបតីនោះ មានទ្រព្យរក្សាទុកក្នុងផ្ទះ ៤០ កោដិ ។ គហបតីនោះ មានការជឿមុតមាំក្នុងព្រះមានព្រះភាគ ជាឧបាសកសម្រេចសោតាបន្ន ។ ភរិយារបស់គាត់ ក៏ជាសោតាបន្នដូចគ្នា ។ តែបុត្ររបស់គហបតិនោះមិនមានសទ្ធា មិនជ្រះថ្លា ។ គ្រានោះ មាតា និងបិតា រមែងប្រៀនប្រដៅបុត្រនោះរឿយៗ យ៉ាងនេះថា នែកូន ចូរបាចូលទៅគាល់ព្រះសាស្តា ចូលទៅរកព្រះធម្មសេនាបតីសារីបុត្រ ព្រះមហាមោគ្គល្លាន ព្រះមហាកស្សប ព្រះមហាសាវ័ក ៨០ ។ បុត្រនោះ ពោលយ៉ាងនេះថា ការចូលទៅរកសមណៈទាំងឡាយរបស់ពុកនិងម៉ែ រមែងមិនមានដល់ខ្ញុំ ព្រោះការចូលទៅរកសមណៈទាំងឡាយ ក៏ត្រូវថ្វាយបង្គំ កាលឱនថ្វាយបង្គំ ខ្នងក៏ឈឺ ជង្គង់ក៏ក្រិន ចាំបាច់ត្រូវអង្គុយលើផែនដី កាលអង្គុយលើផែនដីនោះ សំពត់ក៏ប្រឡាក់ ចាស់ ចាប់ផ្តើមតាំងពីវេលាអង្គុយជិត រមែងមានការសន្ទនា កាលមានការសន្ទនា រមែងកើតសេចក្តីស្និទ្ធស្នាល បន្ទាប់អំពីនោះ រមែងត្រូវនិមន្តហើយថ្វាយចីវរ និងបិណ្ឌបាតជាដើម

បើដូច្នោះ ប្រយោជន៍រមែងសាបសូន្យ ការចូលទៅរកពួកសមណៈរបស់ពុក និងម៉ែ រមែងមិនមានដល់ខ្ញុំ ដូច្នេះ ។ មាតាបិតាទូន្មានបុត្ររបស់ខ្លួនរហូតអស់ជីវិត ដោយប្រការដូច្នេះ ក៏មិនអាចនឹងនាំបុត្រនោះ ទៅកាន់សាសនាបាន ។ តមក បិតារបស់សិង្គាលកៈនោះ ដេកលើគ្រែសម្រាប់ស្លាប់ គិតថា គួរនឹងឲ្យឱវាទដល់បុត្ររបស់អញ ហើយគិតទៀតថា អញនឹងឲ្យឱវាទដល់បុត្រយ៉ាងនេះថា នែកូន ចូរកូនថ្វាយបង្គំទិសទាំងឡាយ សិង្គាលកៈមិនដឹងអត្ថន័យ ទើបថ្វាយបង្គំទិសទាំងឡាយ លំដាប់នោះ ព្រះសាស្តា ឬព្រះសាវកទាំង-ឡាយ ឃើញកូនអញហើយ នឹងសួរថា អ្នកធ្វើអ្វី បន្ទាប់ពីនោះ សិង្គាលកៈនឹងប្រាប់ថា ឪពុករបស់ខ្ញុំប្រៀនប្រដៅថា នែកូន ចូរបាធ្វើការថ្វាយបង្គំទិសទាំងឡាយ លំដាប់នោះ ព្រះសាស្តា ឬសាវកទាំងឡាយ នឹងសម្តែងធម៌ដល់កូនអញថា ឪពុករបស់អ្នកមិនឲ្យអ្នកថ្វាយបង្គំទិសទាំងឡាយនោះ តែឲ្យអ្នកថ្វាយបង្គំទិសទាំងនេះ សិង្គាលកៈនឹងដឹងគុណក្នុងព្រះពុទ្ធសាសនា ហើយនឹងធ្វើបុណ្យ ដូច្នេះ ។ លំដាប់នោះ គហបតីឲ្យមនុស្សហៅកូនមកហើយពោលថា នែកូន កូនគួរក្រោកពីព្រលឹម ហើយថ្វាយបង្គំទិសទាំងឡាយដូច្នេះ ។ ធម្មតាពាក្យរបស់បិតា ដែលដេកលើគ្រែសម្រាប់ស្លាប់ រមែងជាពាក្យដែលបុត្រគប្បីរឭកដល់ដរាបអស់ជីវិត ។ ព្រោះដូច្នោះ គហបតីបុត្រនោះ កាលរឭកដល់ពាក្យរបស់បិតា ទើបធ្វើយ៉ាងនោះ ។ ព្រោះដូច្នោះ ទើបលោកពោលថា កូនគហបតីឈ្មោះសិង្គាលកៈ ក្រោកអំពីព្រឹក មានសំពត់ស្លៀកដណ្តប់ទទឹក និងសក់ទទឹក ចេញពីក្រុងរាជគ្រឹះជាដើម ។ បទថា

**បុថុទ្ទិសា** ប្រែថា ទិសច្រើន សេចក្ដីថា ឥឡូវនេះ គហបតីបុត្រ កាលសម្ដែងដល់ទិសទាំងឡាយនោះ ទើបពោលពាក្យថា ទិសខាងកើតជាដើម ។

[ ៤៤ ] បទថា **ចារិសិ** សេចក្ដីថា ព្រះមានព្រះភាគទ្រង់មិនទាន់ចូលទៅ ព្រោះទ្រង់ត្រិះរិះថា តថាគតនឹងចូលទៅ ហើយទ្រង់ចេញទៅ ប្រព្រឹត្តទៅក្នុងចន្លោះផ្លូវ ទើបត្រាស់យ៉ាងនេះ ។ បទថា **អទ្ទសា ខោ ភគវា** សេចក្ដីថា មិនបានឃើញតែម្ដង ។ ព្រះមានព្រះភាគ ទ្រង់ប្រមើលមើលលោកដោយពុទ្ធចក្ខុ ក្នុងពេលព្រឹកឃើញសិង្គាលកគហបតីបុត្រនោះ កំពុងថ្វាយបង្គំទិសទាំងឡាយ ទ្រង់ត្រិះរិះថា ថ្ងៃនេះ តថាគតនឹងសម្ដែងសិង្គាលកសូត្រ ដែលជាវិន័យរបស់គ្រហស្ថ ដល់សិង្គាលកគហបតីបុត្រ ពាក្យនោះ នឹងមានផលដល់មហាជន តថាគតគួរទៅក្នុងទីនោះ ដូច្នេះ ព្រោះហេតុនោះ ទ្រង់ចេញអំពីព្រលឹម ចូលទៅកាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌបាត មយ៉ាងទៀត កាលទ្រង់ចូលទៅ បានទតឃើញសិង្គាលកគហបតីបុត្រយ៉ាងនោះ ។ ដោយហេតុនោះ ទើបលោកពោលថា ព្រះមានព្រះភាគ ទ្រង់ទតឃើញគហបតីបុត្រ ។ បទថា **ឯតទវោច** សេចក្ដីថា សិង្គាលកគហបតីបុត្រនោះ មិនឃើញព្រះសាស្ដា សូម្បីប្រថាប់ឈរក្នុងទីជិត នៅតែថ្វាយបង្គំទិសទាំងឡាយទុំះឯង ។ គ្រានោះ ព្រះមានព្រះភាគទ្រង់បើកព្រះឱស្ឋ ដូចមហាបទុមកំពុងរីក ដោយសម្ផស្សពន្លឺព្រះអាទិត្យដូច្នោះ បានត្រាស់ព្រះវាចានេះថា ម្នាលគហបតីបុត្រ អ្នកធ្វើអ្វីដូច្នេះជាដើម ។ បទថា **យថា កថំ បន ភន្តេ** សេចក្ដីថា សិង្គាលកគហបតីបុត្រស្ដាប់ព្រះតម្រាស់នោះ របស់ព្រះមានព្រះភាគហើយ គិតថា បានឮថា

ទិសដែលបិតារបស់អញពោល គួរថ្វាយបង្គំទិស ៦ នោះ មិនមែនទិសនេះ បានឮថា អរិយសាវកនមស្ការទិស ៦ យ៉ាងដទៃ ណ្ហើយចុះ អញនឹងទូលសួរដល់ទិសដែលព្រះអរិយសាវកគប្បីថ្វាយបង្គំហើយ សឹមថ្វាយបង្គំ ដូច្នេះ សិង្គាលកគហបតីបុត្រនោះ កាលទូលសួរដល់ទិសទាំងនោះ ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ចំណែកក្នុងអរិយវិន័យ គេគប្បីថ្វាយបង្គំទិសទាំង ៦ ដូចម្ដេច ។ ក្នុងបទទាំងនោះ បទថា **យថា** ត្រឹមតែជានិបាត ។ បទថា **កថំ បន** នេះ ជាបទសួរ ។

## ឧបក្កិលេស ៤ យ៉ាង

[ ៤៥ ] បទថា **កម្មក្កិលេសា** សេចក្ដីថា សត្វទាំងឡាយនឹងសៅហ្មងដោយកម្មទាំងឡាយនោះ ព្រោះហេតុនោះ ទើបលោកពោលថា កម្មក្កិលេសទាំងឡាយ ។ បទថា **ឋានេហិ** ប្រែថា ដោយហេតុទាំងឡាយ ។ បទថា **អបាយមុខានិ** ប្រែថា ផ្លូវនៃសេចក្ដីវិនាស ។ បទថា **សោ** គឺព្រះអរិយ-សាវកជាសោតាបន្ន ។ បទថា **ចុទ្ទសបាបកាបគតោ** ប្រែថា ប្រាសចាកបាប គឺអំពើអាក្រក់ទាំង ១៤ យ៉ាងនេះ ។ បទថា **ឆទិសា បដិច្ឆាទី** គឺបិទបាំងទិស ៦ ។ បទថា **ឧភោលោកវិជយាយ** សេចក្ដីថា ដើម្បីឈ្នះលោកទាំងពីរ គឺលោកនេះ និងលោកខាងមុខ ។

បទថា **អយញ្ចេវ លោកោ អារទ្ធោ ហោតិ** សេចក្ដីថា ពិតហើយពៀរវេរាទាំង ៥ ក្នុងលោកនេះ រមែងមិនមានដល់ព្រះអរិយសាវកបែបនោះ

ដោយហេតុនោះ លោកនេះ ដែលព្រះអរិយសាវកនោះបានប្រារព្ធហើយ គឺត្រេកអរហើយ និងសម្រេចហើយ ពៀរវេរាទាំង ៥ មិនមានក្នុងលោកខាងមុខ ដោយហេតុនោះ លោកខាងមុខ ព្រះអរិយសាវកត្រេកអរហើយ ។ ព្រោះដូច្នោះ ព្រះអរិយសាវកនោះ ខាងមុខពីស្លាប់ ព្រោះកាយបែកធ្លាយចូលដល់សុគតិសួគ៌ ។ ដោយប្រការដូច្នេះ ព្រះមានព្រះភាគ ទ្រង់បានតាំងបទមាតិកាដោយសង្ខេប ឥឡូវនេះ កាលនឹងញ៉ាំងបទមាតិកានោះឲ្យពិស្តារ ទើបត្រាស់ថា កម្មក្កិលេស ៤ ប្រការ ដែលអរិយសាវកនោះលះបង់ហើយ ដូចម្តេចជាដើម ។

បទថា **កម្មក្កិលេសោ** សេចក្តីថា ឈ្មោះថា កម្មក្កិលេស ព្រោះកម្មនោះជាកិលេស ព្រោះសម្បយុត្តដោយកិលេស ។ ពិតហើយ អ្នកមានកិលេសប៉ុណ្ណោះ សម្លាប់សត្វ អ្នកមិនមានកិលេស មិនសម្លាប់សត្វឡើយ ព្រោះដូច្នោះ ទើបបាណាតិបាត លោកពោលថា ជាកម្មក្កិលេស ។ ក្នុងកម្មក្កិលេស មានអទិន្នាទានជាដើម ក៏មានន័យនេះឯង ។ បទថា **អបាបរំ** សេចក្តីថា ព្រះមានព្រះភាគបានត្រាស់គាថាព័ន្ធសម្តែងសេចក្តីនោះតទៅ ។

[ ៤៧ ] បទថា **ឋាបកម្មំ ករោតិ** សេចក្តីថា ព្រះមានព្រះភាគ កាលទ្រង់សម្តែងដល់បុគ្គលដែលធ្វើហើយ អ្នកមិនធ្វើរមែងប្រាកដ ដូច្នោះ សូម្បីទ្រង់តាំងមាតិកាថា អរិយសាវកមិនធ្វើនូវបាបកម្ម ព្រោះទ្រង់ឈ្លាសក្នុងទេសនា កាលទ្រង់សម្តែងបុគ្គលដែលធ្វើ ទើបត្រាស់បទនេះថា បុគ្គលរមែងធ្វើកម្មដ៏លាមក ។ ក្នុងបទទាំងឡាយនោះ បទថា **ឆន្ទាគតឹ គច្ឆន្តោ** សេចក្តី

ថា ដល់នូវអគតិដោយសេចក្ដីពេញចិត្ត គឺដោយសេចក្ដីស្រឡាញ់ ធ្វើវត្ថុមិនគួរធ្វើ ។ សូម្បីក្នុងបទដទៃ ក៏មានន័យនេះឯង ។ ក្នុងបទទាំងឡាយនោះ បុគ្គលណាធ្វើម្ចាស់ទ្រព្យ ឲ្យមិនមែនជាម្ចាស់ទ្រព្យ ដោយអំណាចសេចក្ដីពេញចិត្តថា អ្នកនេះជាមិត្តរបស់អញ ជាអ្នកពេញចិត្តនឹងអញ ជាអ្នករាប់អានគ្នា ជាញាតិជិតស្និទ្ធរបស់អញ ឬឲ្យរបស់ជាទីពេញចិត្តដល់អញ ដូច្នេះ បុគ្គលនេះ ឈ្មោះថា ដល់នូវឆន្ទាគតិ រមែងធ្វើកម្មដ៏លាមក ។ បុគ្គលណាធ្វើបុគ្គលម្ចាស់ទ្រព្យ ឲ្យមិនមែនជាម្ចាស់ទ្រព្យ ដោយអំណាចមានពៀរនឹងគ្នាជាប្រក្រតីថា អ្នកនេះ ជាអ្នកមានពៀរនឹងអញ ដូច្នេះ ឬដោយអំណាចសេចក្ដីក្រោធដែលកើតឡើងក្នុងខណៈនោះ បុគ្គលនេះ ឈ្មោះថា ដល់នូវទោសាគតិ រមែងធ្វើកម្មដ៏លាមក ។ មួយវិញទៀត បុគ្គលណា ព្រោះជាអ្នកមានបញ្ញាទន់ខ្សោយ ព្រោះភាពជាអ្នកល្ងង់ខ្លៅ និយាយមិនដឹងរឿង ធ្វើបុគ្គលមិនជាម្ចាស់ទ្រព្យ ឲ្យជាម្ចាស់ទ្រព្យ បុគ្គលឈ្មោះថា ដល់នូវមោហាគតិ រមែងធ្វើកម្មដ៏លាមក ។ មួយទៀត បុគ្គលណា មានសេចក្ដីភ័យខ្លាចថា បុគ្គលនេះជារាជវល្លភៈ ឬជាអ្នកអាស្រ័យនៅនឹងសត្រូវ គប្បីធ្វើសេចក្ដីវិនាសដល់អញ ដូច្នេះហើយ ធ្វើបុគ្គលមិនជាម្ចាស់ទ្រព្យ ឲ្យជាម្ចាស់ទ្រព្យ បុគ្គលនេះដល់នូវភយាគតិ រមែងធ្វើកម្មដ៏លាមក ។ មួយទៀត បុគ្គលណា កាលបែងចែករបស់ឯណាមួយ រមែងឲ្យរបស់ដ៏ប្រសើរ ដោយអំណាចសេចក្ដីស្រឡាញ់ថា បុគ្គលនេះ ជាសម្លាញ់របស់អញ ឬជាអ្នកបរិភោគរួមជាមួយអញ រមែងឲ្យរបស់ថោកទាបទៅ ដោយអំណាចសេចក្ដីក្រោធថា បុគ្គលនេះ

*ជាសត្រូវរបស់អញ ដូច្នេះ ព្រោះសេចក្ដីល្ងង់ខ្លៅមិនដឹងរបស់ដែលឲ្យហើយ និងមិនទាន់ឲ្យ រមែងឲ្យរបស់ខ្វះដល់បុគ្គលខ្លះ ឲ្យរបស់លើសដល់បុគ្គលខ្លះ ព្រោះខ្លាចថា បុគ្គលនេះ កាលអញមិនឲ្យវត្ថុនេះ គប្បីធ្វើអន្តរាយដល់អញ រមែងឲ្យរបស់ដ៏ប្រសើរដល់បុគ្គលខ្លះ បុគ្គលនោះ ជាអ្នកមានអគតិ ៤ យ៉ាងនេះ ក៏ដល់នូវអគតិ មានឆន្ទាគតិជាដើមតាមលំដាប់ រមែងធ្វើកម្មដ៏លាមក តែព្រះអរិយសាវក ទោះបីលះបង់ជីវិត ក៏មិនលុះក្នុងអគតិ មានឆន្ទាគតិជាដើម ដោយហេតុនោះ ទើបលោកពោលថា អរិយសាវកនោះ ឈ្មោះថា មិនធ្វើបាបកម្ម ព្រោះហេតុ ៤ យ៉ាងនេះ ។*

[ ៤៨ ] *បទថា* **ឆហិយតិ តស្ស យសោ** *សេចក្ដីថា កិត្តិយស បរិវារយសរបស់បុគ្គលដែលលុះក្នុងអគតិនោះ រមែងវិនាស គឺរមែងអន្តរធានទៅ ។*

## អបាយមុខ ៦ យ៉ាង
## មានភាពជាអ្នកលេងសុរាជាដើម

[ ៤៩ ] *សុរា ៥ ប្រភេទ គឺសុរាធ្វើដោយនំ សុរាធ្វើដោយម្សៅ សុរាធ្វើដោយបាយ សុរាដាក់មេសុរា សុរាប្រកបដោយគ្រឿងផ្សំផ្សេងៗ ឈ្មោះថា* **សុរា** *ក្នុងបទនេះថា* **សុរាមេរយមជ្ជប្បមាទដ្ឋានានុយោគោ** *នេះ ។ គ្រឿងត្រាំ ៥ ប្រភេទ គឺគ្រឿងត្រាំដោយផ្កា គ្រឿងត្រាំដោយផ្លែឈើ គ្រឿងត្រាំដោយទឹកឃ្មុំ គ្រឿងត្រាំដោយទឹកអំពៅ គ្រឿងត្រាំប្រកបដោយគ្រឿងផ្សំផ្សេងៗ ឈ្មោះថា* **មេរយ។** *ទាំងអស់នេះ ឈ្មោះថា* **មជ្ជ**ដោយអំណាចធ្វើឲ្យស្រវឹង ។ *បទថា* **បមាទដ្ឋានំ** *គឺហេតុនៃសេចក្ដីប្រមាទ ។ បទនេះ ជាឈ្មោះរបស់ចេតនា*

នៃអ្នកផឹកទឹកស្រវឹង ។ បទថា **អនុយោគោ** អធិប្បាយថា ប្រកបរឿយៗ គឺធ្វើញយៗ នូវការផឹកទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្ដីប្រមាទ ។ ព្រោះកាលបុគ្គលប្រកបរឿយៗ ក្នុងការផឹកទឹកស្រវឹងនេះ ភោគៈទាំងឡាយដែលកើតឡើងហើយ តែងតែវិនាស និងដែលមិនទាន់កើតឡើងរមែងមិនកើត ដូច្នោះ ទើបលោកពោលថា ជាផ្លូវវិនាសនៃភោគៈទាំងឡាយ ។ បទថា **វិកាលវិសិខាចរិយានុយោគោ** សេចក្ដីថា ភាពជាអ្នកត្រាច់ទៅក្នុងច្រកល្ហក ដែលមិនមែនជាកាល ។ បទថា **សមជ្ជាភិចរណំ** គឺទៅមើលមហោស្រព ដោយការមើលរបាំជាដើម ។ បទថា **អាលស្សានុយោគោ** អធិប្បាយថា ព្រោះភាពជាអ្នកខ្វល់ខ្វាយ ក្នុងការប្រកបដោយសេចក្ដីខ្ជិលច្រអូសតាមផ្លូវកាយ ។

[ ៥០ ] ព្រះមានព្រះភាគ ទ្រង់តាំងបទមាតិការបស់ផ្លូវនៃសេចក្ដីវិនាស ៦ ប្រការយ៉ាងនេះហើយ កាលទ្រង់ចែកបទមាតិកាទាំងនោះ ក្នុងឥឡូវនេះ ទើបត្រាស់ថា ម្នាលគហបតីបុត្រ ទោសក្នុងកិរិយាប្រកបរឿយៗនូវការផឹកទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាហេតុ ជាទីតាំងនៃសេចក្ដីប្រមាទនេះ មាន ៦ យ៉ាង ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **សន្ទិដ្ឋិកា** គឺការរស់នៅក្នុងលោកនេះ ដែលខ្លួនគប្បីឃើញ ។ បទថា **ធនជានិ** ប្រែថា វិនាសទ្រព្យ ។ បទថា **កលហប្បវឌ្ឍនី** សេចក្ដីថា បង្កការឈ្លោះដោយវាចា និងការឈ្លោះដោយដៃជាដើម ។ បទថា **រោគានំ អាយតនំ** សេចក្ដីថា ទឹកស្រវឹង ជាប្រភពនៃរោគទាំងនោះ មានរោគភ្នែកជាដើម ។ បទថា **អកិត្តិ-**

**សញ្ជននី** សេចក្តីថា ព្រោះជនផឹកទឹកស្រវឹងហើយ រមែងប្រហារមាតា បិតាបាន រមែងពោលពាក្យដែលមិនគួរពោល សូម្បីដទៃទៃច្រើនទៀត រមែងធ្វើវត្ថុដែលមិនគួរធ្វើ ដោយហេតុនេះ ជនទាំងឡាយដល់នូវការតិះដៀលខ្លះ ដាក់ទោសខ្លះ កាត់អវយវៈមានដៃ និងជើងជាដើមខ្លះ ដល់កាពជាអ្នកខូចកេរ្តិ៍ឈ្មោះក្នុងលោកនេះខ្លះ ក្នុងលោកខាងមុខខ្លះ ។ ដោយហេតុនេះ ទើបសុរានោះឈ្មោះថា ជាហេតុខូចឈ្មោះរបស់ជនទាំងនោះ ។ បទថា **ហិរិកោបីនពិធំសនី** សេចក្តីថា ព្រោះទឹកស្រវឹង រមែងញ៉ាំងកេរ្តិ៍ខ្មាសដែលគួរលាក់ គួរបិទបាំងឲ្យកម្រើក ឲ្យវិនាស ព្រោះដូច្នោះ ទើបលោកពោលថា ញ៉ាំងហិរិឲ្យកម្រើកដូច្នេះ ។ ម្យ៉ាងទៀត អ្នកស្រវឹងស្រា បើកអវយវៈនោះៗ ហើយត្រាច់ទៅបាន ។ ដោយហេតុនោះ ទើបសុរានោះ លោកពោលថា ជាហេតុមិនខ្មាស ព្រោះធ្វើហិរិឲ្យកម្រើក ។ បទថា **បញ្ញាយ ទុព្វលិករណី** សេចក្តីថា ទឹកស្រវឹងរមែងធ្វើឲ្យការដឹងថា សត្វមានកម្មជារបស់ខ្លួនថយចុះ ដូចបញ្ញារបស់ព្រះសាគតៈដូច្នោះ ព្រោះដូច្នោះ ទើបលោកពោលថា ទឹកស្រវឹងជាហេតុឲ្យបញ្ញាទុព្វល ។ តែទឹកស្រវឹង មិនអាចធ្វើឲ្យអ្នកបានមគ្គប្បញ្ញាទុព្វលទេ ។ ព្រោះសុរានោះរមែងមិនចូលទៅខាងក្នុងមាត់ របស់លោកដែលសម្រេចមគ្គហើយ ។ បទថា **ឆដ្ឋំ បទំ** ប្រែថា ហេតុជាគម្រប់ ៦ ។

[ ៥១ ] បទថា **អត្តាបិស្ស អគុត្តោ អរក្ខិតោ ហោតិ** អធិប្បាយថា ព្រោះបុគ្គលត្រាច់ទៅខុសកាល រមែងជាន់ដង្គត់ និងបន្លាជាដើមខ្លះ ជួបពស់ខ្លះ យក្ខជាដើមខ្លះ សត្រូវដឹងថា នឹងទៅកាន់ទីនោះៗ ក៏លបចាប់ខ្លួន ឬ

សម្លាប់ ។ ដោយហេតុនេះ ទើបឈ្មោះថា មិនឃុំគ្រង មិនរក្សាខ្លួន ។ សូម្បីបុត្រ និងភរិយាគិតថា បិតារបស់អញ ស្វាមីរបស់អញ ត្រាច់ក្នុងពេលយប់ នឹងពោលទៅថ្វីដល់ខ្លួនអញ ដូច្នេះ ។ ដោយហេតុនេះ បុត្រធីតា ភរិយារបស់បុគ្គលនោះ ធ្វើកិច្ចធុរៈក្រៅស្រុក ត្រាច់ទៅក្នុងពេលយប់ ក៏រមែងដល់សេចក្ដីវិនាស ។ បុត្ត ភរិយារបស់បុគ្គលនោះ ក៏ឈ្មោះថា ជាអ្នកមិនគ្រប់គ្រងខ្លួន មិនរក្សាខ្លួន ដោយអាការយ៉ាងនេះ ។ បទថា **សាបតេយ្យំ** សេចក្ដីថា ពួកចោរដឹងភាពដែលបរិវារជន ព្រមដោយបុត្រភរិយានោះ ត្រាច់ក្នុងពេលយប់ នឹងចូលទៅកាន់ផ្ទះដែលគ្មានមនុស្ស នាំយករបស់ដែលត្រូវការទៅ ។ ដោយអាការយ៉ាងនេះ ឈ្មោះថា មិនគ្រប់គ្រង មិនរក្សាទ្រព្យសម្បត្តិ ។ បទថា **សង្កិយោ ច ហោតិ** សេចក្ដីថា ជាអ្នកដែលគួររង្កៀសថា អ្នកនេះនឹងជាអ្នកធ្វើក្នុងកម្មដ៏លាមកដែលអ្នកដទៃធ្វើ ។ កាលពោលពាក្យថា បុគ្គលទៅដោយទ្វារផ្ទះរបស់អ្នកណាៗ ចោរកម្ម ឬបរទារិកកម្ម ការសម្លុតកំហែងណាដែលអ្នកដទៃធ្វើក្នុងទីនោះ កម្មនោះ ឈ្មោះថា បុគ្គលនេះធ្វើកម្មនោះ សូម្បីមិនពិត មិនមាន ក៏រមែងប្រាកដ គឺរមែងតាំងនៅក្នុងបុគ្គលនោះ ។ បទថា **ពហូនញ្ច ទុក្ខធម្មានំ** សេចក្ដីថា បុគ្គលណាម្នាក់មិនអាចពោលថា ទុក្ខមានប្រមាណប៉ុណ្ណោះ ទោមនស្សមានប្រមាណប៉ុណ្ណោះ របស់អ្នកដែលត្រូវគេរង្កៀសក្នុងបុគ្គលដទៃនោះឯង ។ ដោយប្រការដូច្នេះ អ្នកដើរពេលយប់នោះ ឈ្មោះថា ជួបនូវហេតុនៃទុក្ខដ៏ច្រើន គឺបានទទួលសេចក្ដីលំបាកច្រើន ។

[ ៥២ ] បទថា **ក្វ នច្ចំ** សេចក្ដីថា របាំ មានការរាំ និងល្ខោនជាដើម

មាននៅក្នុងទីណា ហើយគប្បីទៅក្នុងស្រុក ឬនិគមដែលមានរបាំនោះ ។ កាលបុគ្គលដែលត្រៀមសំពត់ ផ្កាកម្រង គ្រឿងក្រអូបជាដើម ក្នុងថ្ងៃនេះ ដោយគិតថា ស្អែកនេះអញនឹងទៅមើលការរាំ ក៏បោះបង់ការងារចោលអស់មួយថ្ងៃ ។ រមែងប្រាកដក្នុងទីនោះ អស់ ១ ថ្ងៃខ្លះ ២ ថ្ងៃខ្លះ ៣ ថ្ងៃខ្លះ ដោយការមើលការរាំ ។ កាលអ្នកដើរពេលយប់ សូម្បីដល់ព្រមដោយភ្លៀងជាដើម ក៏មិនធ្វើការសោបព្រោះ កាលដល់ការសោបព្រោះជាដើម គោគៈទាំងឡាយដែលនៅមិនទាន់កើត រមែងមិនកើត ។ កាលផ្ទះមិនមានមនុស្ស ពួកចោរដឹងភាពដែលម្ចាស់ផ្ទះទៅខាងក្រៅ រមែងលួចរបស់ដែលត្រូវការយកទៅ ។ ដោយហេតុនោះ គោគៈដែលកើតដល់បុគ្គលនោះក៏រមែងវិនាស ។ ក្នុងបទថា **ក្វ គីតំ** ជាដើម ក៏មានន័យដូចគ្នា ។ ការធ្វើផ្សេងៗ របស់ជនទាំងនោះ លោកពោលហើយ ក្នុងព្រហ្មជាលសូត្រ ។

[ ៥៣ ] បទថា **ជយំ វេរំ** សេចក្តីថា អ្នកឈ្នះ រមែងកាន់យកនូវសំពត់សាដក ឬសំពត់ជួតក្បាលរបស់អ្នកដទៃ ត្រង់កណ្តាលប្រជុំជន ដោយគិតថា អញឈ្នះហើយ ដូច្នេះ ។ អ្នកចាញ់រមែងចងពៀរវេរា ក្នុងបុគ្គលនោះថា គេមើលងាយអញក្នុងកណ្តាលប្រជុំជន ណ្ហើយចុះ អញនឹងឲ្យមេរៀនដល់គេ ដូច្នេះ ។ កាលឈ្នះយ៉ាងនេះ រមែងជួបនូវពៀរវេរា ។ បទថា **ជិតោ** សេចក្តីថា អ្នកចាញ់រមែងសោកស្តាយដល់សំពត់ជួត សំពត់សាដក ឬទ្រព្យ-សម្បត្តិ មានប្រាក់ និងមាសជាដើមណាមួយរបស់ខ្លួន ដែលអ្នកដទៃយកទៅ បុគ្គលនោះ រមែងសោយសោក ព្រោះទ្រព្យនោះជាហេតុថា ទ្រព្យនោះ មាន

ហើយដល់អញហ្ន៎ ទ្រព្យនោះ មិនមានដល់យើងហ្ន៎ ដូច្នេះ ដោយអាការយ៉ាងនេះ អ្នកចាញ់រមែងស្តាយទ្រព្យ ។ បទថា **សភាគតស្ស វចនំ ន រូហតិ** សេចក្តីថា កាលបុគ្គលនោះត្រូវសួរ ព្រោះភាពជាសាក្សី ក្នុងទីវិនិច្ឆ័យ ដោយពាក្យមិនគួរជឿ ។ ជនទាំងឡាយ នឹងនាំគ្នានិយាយថា អ្នកនេះជាអ្នកលេងបាសកា លេងល្បែងភ្នាល់ ពួកលោកកុំជឿពាក្យនិយាយរបស់បុគ្គលនេះ ។ បទថា **មិត្តា មច្ចានំ បរិភូតោ ហោតិ** សេចក្តីថា ពិតហើយ ពួកមិត្តអមាត្យ និងនិយាយចំពោះបុគ្គលនោះយ៉ាងនេះថា សម្លាញ់ អ្នកជាបុត្ររបស់អ្នកមានត្រកូលលេងល្បែងភ្នាល់ ជាអ្នកកាត់ ជាអ្នកទម្លាយ ត្រាច់ទៅមិនសមគួរដល់ជាតិ និងគោត្ររបស់អ្នក តាំងពីនេះទៅ អ្នកមិនគប្បីធ្វើយ៉ាងនេះ ។ អ្នកលេងល្បែងភ្នាល់នោះ ទោះគេពោលយ៉ាងនេះ ក៏មិនជឿ ។ បន្ទាប់ពីនោះ ពួកមិត្ត និងសម្លាញ់ទាំងនោះ មិនឈរ មិនអង្គុយរួមជាមួយ ។ សូម្បីពួកជននោះត្រូវសួរដើម្បីជាសាក្សី ក៏មិនព្រមនិយាយ ព្រោះហេតុអ្នកលេងល្បែងភ្នាល់នោះ ។ ដោយអាការយ៉ាងនេះ ទើបអ្នកលេងល្បែងភ្នាល់ជាបុគ្គលដែលត្រូវមិត្ត និងសម្លាញ់មើលងាយ ។ បទថា **អាវាហវិវាហកានំ** សេចក្តីថា បុគ្គលបំណាងនាំកូនស្រីទៅ អំពីផ្ទះរបស់បុគ្គលនោះ ឈ្មោះថា **អាវាហ** ។ បុគ្គលបំណាងនឹងឲ្យកូនស្រីនៅក្នុងផ្ទះរបស់បុគ្គលនោះ ឈ្មោះថា **វិវាហ** ។ បទថា **អប្បត្ថិតោ ហោតិ** ប្រែថា មិនមានអ្នកណាប្រាថ្នា ។ បទថា **នាលំ ទារភរណាយ** សេចក្តីថា អ្នកលេងល្បែងភ្នាល់ មិនអាចនឹងចិញ្ចឹមករិយាបាន ។ សេចក្តីថា ទោះបីឲ្យស្រីក្រមុំនៅក្នុងផ្ទះរបស់បុគ្គលនោះ សូម្បី

មកពីផ្ទះរបស់បុគ្គលនោះ ពួកយើងក៏គប្បីចិញ្ចឹមរក្សាបាន ។

[ ៥៤ ] បទថា **ធុត្តា** គឺអ្នកលេងល្បែងភ្នាល់ ។ បទថា **សោណ្ឌា** សេចក្តីថា អ្នកលេងស្រី អ្នកលេងកត្ត អ្នកលេងស្រា អ្នកលេងមើមឈើ ។ បទថា **បិបាសា** ប្រែថា អ្នកលេងផឹកសុរា ។ បទថា **នេកតិកា** គឺបញ្ឆោតដោយរបស់ក្លែងក្លាយ ។ បទថា **វញ្ចនិកា** គឺជាអ្នកប្រវ័ញ្ច ដោយការប្រវ័ញ្ចចំពោះមុខ ។ បទថា **សាហសិកា** សេចក្តីថា ជាអ្នកធ្វើការងាររួមនឹងអ្នកដែលនៅក្នុងអាគារជាមួយគ្នាជាដើម ។ បទថា **ត្យាស្ស មិត្តា ហោន្តិ** គឺ បុគ្គលនោះមិនត្រេកអរនឹងអ្នកដទៃ ដែលជាមនុស្សល្អ ចូលទៅរកមិត្តអាក្រក់ទាំងនោះតែម្យ៉ាង ដូចជ្រូកដែលគេប្រដាប់ដោយផ្កាកម្រងគ្រឿងក្រអូបជាដើមហើយ ឲ្យដេកលើដំណេកយ៉ាងល្អ ក៏នៅចូលទៅកាន់រណ្តៅលាមក ដូច្នោះ ព្រោះហេតុនោះ អ្នកសេពគប់មិត្តអាក្រក់ រមែងចូលដល់សេចក្តីវិនាសជាច្រើន ទាំងក្នុងភពនេះ និងភពខាងមុខ ។

[ ៥៥ ] បទថា **អតិសីតន្តិ កម្មំ ន ករោតិ** សេចក្តីថា ពួកមនុស្សក្រោកឡើងពីព្រឹកព្រលឹមនិយាយថា ម្នាលអ្នកដ៏ចម្រើន មក ទៅធ្វើការងារជាមួយគ្នាចុះ អ្នកខ្ជិលប្រអូសនិយាយថា នៅត្រជាក់ណាស់ ធ្មេញនឹងបែក ពួកអ្នកនាំគ្នាទៅចុះ ខ្ញុំនឹងទៅជាខាងក្រោយ ហើយអង្គុយអាំងភ្លើង ។ មនុស្សទាំងនោះ ក៏ទៅធ្វើការងារ ។ ការងាររបស់អ្នកខ្ជិលប្រអូសរមែងវិនាស ។ ក្នុងបទទាំងឡាយថា ក្តៅពេក ក៏មានន័យនេះឯង ។

[ ៥៦ ] បទថា **ហោតិ បានសខា នាម** សេចក្តីថា បុគ្គលខ្លះ ជាមិត្ត

សម្លាញ់នឹងគ្នាបានតែក្នុងតៀមស្រា ដែលជាកន្លែងស៊ីផឹកនុ៎ះឯង ។ បាឋៈថា **បន្នសខា** ដូច្នេះក៏មាន ឯសេចក្តីក៏ដូចគ្នា ។ បទថា **សម្មិយសម្មិយោ** សេចក្តីថា អ្នកខ្លះនិយាយថា សម្លាញ់ សម្លាញ់ ជាសម្លាញ់ចំពោះមុខប៉ុណ្ណោះ កំបាំងមុខដូចជាសត្រូវ តែងស្វែងរកឱកាសតែម្យ៉ាង ។ បទថា **អត្ថេសុ ជាតេសុ** សេចក្តីថា កាលកិច្ចបែបនោះកើតឡើងហើយ ។ បទថា **វេរប្បសង្គោ** ប្រែថា ច្រើនដោយពៀរវេរា ។ បទថា **អនត្ថតា** ប្រែថា ធ្វើសេចក្តីវិនាស ។ បទថា **សុកទរិយតា** សេចក្តីថា ភាពជាអ្នកកំណាញ់ស្វិតស្វាញ គឺភាពជាអ្នកកំណាញ់ខ្លាំង ។ បទថា **ឧទកមិវ ឥណំ វិគាហតិ** ដូច្នោះ សេចក្តីថា បុគ្គលនោះលិចចុះក្នុងបំណុល ដូចដុំថ្មលិចចុះក្នុងទឹក ដូច្នោះ ។ បទថា **រត្តិនុដ្ឋាន-ទេស្សិនា** គឺមិនក្រោកឡើងក្នុងពេលយប់ជាប្រក្រតី ។ បទថា **អតិសាយមិទំ អហុ** គឺបុគ្គលនោះពោលយ៉ាងនេះថា វេលានេះល្ងាចណាស់ ហើយមិនធ្វើការងារ ។ បទថា **ឥតិ វិស្សដ្ឋកម្មន្តេ** គឺនិយាយយ៉ាងនេះហើយ មិនធ្វើការងារ ។ បទថា **អត្ថា អច្ចេន្តិ មាណវេ** សេចក្តីថា ប្រយោជន៍ទាំងឡាយរមែងកន្លងហួសបុគ្គលបែបនេះ គឺមិនតាំងនៅក្នុងបុគ្គលទាំងនោះ ។ បទថា **តិណ្ណា ភិយ្យោ** ប្រែថា ក្រៃលែងជាងស្មៅ ។ បទថា **សោ សុខា ន វិហាយតិ** សេចក្តីថា បុរសនោះ រមែងមិនលះបង់សេចក្តីសុខ រមែងជាអ្នកបរិបូណ៌ដោយសេចក្តីសុខនោះឯង ។ ព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនេះ ដោយកថាមគ្គនេះ ។

ឯអ្នកគ្រប់គ្រងផ្ទះ មិនគួរធ្វើកម្មនេះ ឈ្មោះថា សេចក្ដីចម្រើន រមែងមិនមានដល់អ្នកធ្វើ អ្នកធ្វើរមែងបានទទួលការតិះដៀលតែម្យ៉ាង ទាំងក្នុងលោកនេះផង លោកខាងមុខផង ។

[ ៥៧ ] ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីទ្រង់សំដែងដល់អ្នកមិនមែនមិត្ត ជាមិត្តប្ញម ជាជនពាលថា បុគ្គលណាធ្វើយ៉ាងនេះ សេចក្ដីវិនាសរមែងកើតឡើងដល់បុគ្គលនោះ ឬភ័យយ៉ាងដទៃៗ អន្តរាយណាមួយ ឧបសគ្គណាមួយ ទាំងអស់នោះ រមែងកើតឡើង ព្រោះអាស្រ័យបុគ្គលពាល ព្រោះដូច្នោះ មិនគួរសេពគប់ បុគ្គលពាលបែបនោះ ដូច្នេះ ទើបត្រាស់ពាក្យថា ម្នាលគហបតីបុត្រ អ្នកត្រូវស្គាល់ពួកមនុស្សដែលមិនមែនជាមិត្រ គ្រាន់តែជាមិត្តប្ញម ៤ ពួកនេះ ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **អញ្ញទត្ថុហរោ** សេចក្ដីថា ខ្លួនឯងមានដៃទទេមកហើយ ទៅវិញនាំយករបស់ណាមួយទៅ ។ បទថា **វចីបរមោ** សេចក្ដីថា ដូចជាឲ្យ ដោយធ្វើត្រឹមតែនិយាយប៉ុណ្ណោះ ។ បទថា **អនុប្បិយភាណី** គឺតែងតែនិយាយចាក់បណ្ដោយតាម ។ បទថា **អបាយសហាយោ** គឺជាមិត្រក្នុងផ្លូវវិនាសនៃភោគៈទាំងឡាយ ។

[ ៥៨ ] ព្រះមានព្រះភាគ ទ្រង់សំដែងដល់អ្នកដែលមិនមែនមិត្រ ៤ ពួកយ៉ាងនេះហើយ កាលទ្រង់ចែកហេតុនីមួយៗ ក្នុងអ្នកដែលមិនមែនមិត្រនោះ ដោយហេតុ ៤ យ៉ាង ទើបត្រាស់ពាក្យថា **ចតូហិ ខោ គហបតិបុត្តា** ដូច្នេះ ។

ក្នុងបទទាំងឡាយនោះ បទថា **អញ្ញទត្ថុហរោ ហោតិ** សេចក្ដីថា ជា

អ្នកនាំទៅដោយចំណែកតែមួយប៉ុណ្ណោះ ។ សេចក្ដីថា ជាអ្នកមានដៃទទេមក កាន់ផ្ទះរបស់សម្លាញ់ ហើយនិយាយដល់គុណរបស់សំពត់សាដក ដែលខ្លួន ស្លៀកជាដើម ។ មិត្រគិតតែប្រយោជន៍ខ្លួននោះនិយាយថា នែសម្លាញ់ អ្នក នោះ រមែងពោលដល់គុណរបស់សំពត់ផ្ទាំងនេះនឹងអ្នក ដូច្នេះហើយ ស្លៀក សំពត់ផ្ទាំងដទៃឲ្យផ្ទាំងនោះទៅ ។ បទថា **អប្បេន ពហុមិច្ឆតិ** គឺឲ្យរបស់ណា មួយតែបន្តិចបន្តួច ហើយប្រាថ្នារបស់ច្រើនអំពីមិត្រនោះមកវិញ ។ បទថា **ភយស្ស កិច្ចំ ករោតិ** សេចក្ដីថា កាលភ័យកើតឡើងដល់ខ្លួន រមែងធ្វើកិច្ច ទាំងនោះដូចជាទាសៈ មិត្រគិតយកតែប្រយោជន៍ខ្លួននេះ មិនធ្វើក្នុងកាលទាំង ពួង កាលភ័យកើតឡើង ទើបធ្វើ មិនធ្វើដោយសេចក្ដីស្រឡាញ់ ព្រោះដូច្នោះ ទើបឈ្មោះថា មិនមែនជាមិត្រ ។ បទថា **សេវតិ អត្ថការណា** សេចក្ដីថា មិនសេពគប់ ដោយអំណាចជាមិត្រដ៏ជិតដិត ប្រាថ្នាប្រយោជន៍របស់ខ្លួនតែ ម្យ៉ាង ទើបសេពគប់ ។

[ ៥៩ ] បទថា **អតីតេន បដិសន្ថរតិ** សេចក្ដីថា មិត្រល្អតែសម្ដី រមែងសង្គ្រោះដោយវត្ថុដែលកន្លងហើយយ៉ាងនេះថា កាលសម្លាញ់មក កាល វេលានេះលោកមិនមក វេលានេះ ស្រូវរបស់ពួកយើង សម្រេចរៀបរយ ពួកយើងតាំងស្រូវសាលី ស្រូវដំណើប និងពូជជាដើមជាច្រើន ហើយអង្គុយ មើលផ្លូវ តែថ្ងៃនេះអស់ទៅទាំងអស់ហើយ ដូច្នេះ ។ បទថា **អនាគតេន** សេចក្ដីថា មិត្រល្អតែសម្ដី រមែងសង្គ្រោះដោយវត្ថុដែលនៅមិនទាន់មកដល់ យ៉ាងនេះថា ក្នុងថ្ងៃខាងមុខ ស្រូវរបស់ពួកខ្ញុំ នឹងជាទីរីករាយចិត្ត ខ្ញុំនឹងធ្វើការ

សង្គ្រោះដោយស្រូវ មានស្រូវសាលីជាដើម ដែលមានផលបរិបូណ៌ហើយ ខ្ញុំអាចធ្វើការសង្គ្រោះ ដល់ពួកអ្នកបាន ដូច្នេះ ។ បទថា **ឆិន្នកោឆ** សេចក្តីថា មិត្តល្អតែសម្តី អង្គុយលើ-កដីរ ឬលើខ្នងសេះ កាលឃើញសម្លាញ់ហើយ ពោលថា សម្លាញ់អើយ សម្លាញ់ចូរមកអង្គុយក្នុងទីនេះចុះ មិត្រល្អតែសម្តី ស្លៀកសំពត់សាជកផ្ទាំងដែលល្អ ហើយពោលថា សំពត់ផ្ទាំងនេះ សមគួរ ដល់សម្លាញ់របស់ខ្ញុំពិតហ្ន៎ តែខ្ញុំមិនមានសំពត់ដទៃយ៉ាងនេះ ឈ្មោះថា សង្គ្រោះ ដោយវត្ថុមិនមានប្រយោជន៍ ។ បទថា **បច្ចុប្បន្នេសុ កិច្ចេសុ ព្យសនំ ទស្សេតិ** សេចក្តីថា កាលមានអ្នកពោលថា ខ្ញុំត្រូវការរទេះ មិត្រល្អតែសម្តីពោលពាក្យ ជាដើមថា ស្តាយណាស់ កង់រទេះ ភ្លៅរទេះបាក់ហើយ ។

[ ៦០ ] បទថា **ទាបកម្មំបិស្ស អនុជានាតិ** សេចក្តីថា កាលសម្លាញ់ និយាយថា ពួកយើងនឹងធ្វើបាណាតិបាតជាដើមយ៉ាងណាមួយ មិត្រអែបអប ក៏យល់ព្រមតាមចិត្តមិត្រ ដោយពាក្យថា ល្អហើយសម្លាញ់ធ្វើចុះ ។ សូម្បី ក្នុងការធ្វើល្អ ក៏មានន័យនេះឯង ។

[ ៦១ ] បទថា **សហាយោ ហោតិ** សេចក្តីថា កាលសម្លាញ់និយាយ ថា ជនទាំងឡាយនាំគ្នាផឹកស្រាក្នុងទីឯណោះ លោកចូរមក យើងនឹងទៅក្នុង ទីនោះ បុគ្គលជាសម្លាញ់ក្នុងផ្លូវវិនាសទទួលថា សាធុ ហើយក៏ទៅ ។ ក្នុង បទទាំងពួង ក៏មានន័យនេះ ។

[ ៦២ ] បទថា **ឥតិ វិញ្ញាយ** សេចក្តីថា ដឹងយ៉ាងនេះថា ពួកនេះ ជា មិត្របួម ដូច្នេះ ។

[ ៦៣ ] ព្រះមានព្រះភាគ កាលទ្រង់សម្តែងមិត្រអាក្រក់ មិនគួរសេព គប់យ៉ាងនេះហើយ កាលទ្រង់សម្តែងមិត្រល្អ គួរសេពគប់ក្នុងឥឡូវនេះ ទើប ត្រាស់ពាក្យថា ម្នាលគហបតីបុត្រ មិត្រ ៤ ពួកនេះជាដើម ។ ក្នុងបទទាំង នោះ បទថា **សុហទា** ប្រែថា មិត្រមានចិត្តល្អ ។

[ ៦៤ ] បទថា **បមត្តំ រក្ខតិ** សេចក្តីថា មិត្រមានឧបការៈ ឃើញ សម្លាញ់ផឹកទឹកស្រវឹង ហើយដេកត្រង់កណ្តាលស្រុក ត្រង់ទ្វារស្រុក ត្រង់ផ្លូវ គិតថា កាលសម្លាញ់ដេកយ៉ាងនេះ បុគ្គលណាម្នាក់ គប្បីលួចសំពត់ស្លៀក និងសំពត់ដណ្តប់ ដូច្នេះ ទើបអង្គុយជិតសម្លាញ់ កាលសម្លាញ់ភ្ញាក់ ក៏នាំទៅ ។ បទថា **បមត្តស្ស សាបតេយ្យំ** សេចក្តីថា មិត្តមានឧបការៈគិតថា សម្លាញ់ ទៅខាងក្រៅ ឬផឹកស្រាស្រវឹង ផ្ទះមិនមានអ្នកចាំ បុគ្គលណាម្នាក់ នឹងគប្បី លួចរបស់ណាមួយទៅ ដូច្នេះ ទើបចូលទៅកាន់ផ្ទះការពារទ្រព្យរបស់សម្លាញ់ នោះ ។ បទថា **ភីតស្ស** សេចក្តីថា កាលភ័យណាមួយកើតឡើង មិត្រមាន ឧបការៈពោលថា កុំខ្លាច កាលសម្លាញ់ដូចខ្ញុំនៅមាន អ្នកខ្លាចអ្វី ហើយ កម្ចាត់ភ័យនោះចេញទៅ ជាទីពឹងពាក់បាន ។ បទថា **តទ្ទិគុណំ ភោគំ** សេចក្តីថា កាលកិច្ចដែលគួរធ្វើកើតឡើង មិត្រមានឧបការៈ ឃើញសម្លាញ់ មករកខ្លួនហើយ សួរថា អ្នកមកព្រោះហេតុអ្វី ។ មិត្រនោះឆ្លើយថា មាន ការងារក្នុងរាជត្រកូល ។ សម្លាញ់នោះសួរថា អ្នកត្រូវការអ្វី សម្លាញ់នោះ ឆ្លើយថា ខ្ញុំសូមមួយ ១ កហាបណៈ មិត្រនោះឆ្លើយថា ធម្មតាការងារក្នុងនគរ នឹង មិនសម្រេចត្រឹមតែ ១ កហាបណៈ អ្នកយក ២ កហាបណៈចុះ ។ សម្លាញ់

នោះឲ្យ ២ ជង តាមដែលនិយាយ ។

[ ៦៥ ] បទថា **គុយ្ហមស្ស អាចិក្ខតិ** សេចក្តីថា មិនប្រាប់អាថ៌កំបាំងរបស់ខ្លួនដល់អ្នកដទៃ ហើយប្រាប់ដល់សម្លាញ់ប៉ុណ្ណោះ ។ បទថា **គុយ្ហមស្ស បរិគូហតិ** សេចក្តីថា មិត្រមានឧបការៈ រមែងរក្សាអាថ៌កំបាំងដែលសម្លាញ់ពោល ដែលអ្នកដទៃមិនដឹង ។ បទថា **អាបទាសុ ន វិជហតិ** សេចក្តីថា កាលភ័យកើតឡើង មិត្រមានឧបការៈ រមែងមិនលះបង់ចោល ។ បទថា **ជីវិតំបិស្ស អត្ថាយ** សេចក្តីថា សូម្បីជីវិតរបស់ខ្លួន ក៏ជារបស់មិត្ររួមសុខរួមទុក្ខ លះបង់ដើម្បីប្រយោជន៍ដល់សម្លាញ់បាន មិត្ររួមសុខរួមទុក្ខ មិនគិតដល់ជីវិតរបស់ខ្លួន ធ្វើការងារឲ្យដល់សម្លាញ់តែម្យ៉ាង ។

[ ៦៦ ] បទថា **បាបា និវារេតិ** សេចក្តីថា មិត្រប្រាប់ប្រយោជន៍ រមែងហាមថា កាលខ្ញុំនៅឃើញ អ្នកកុំធ្វើយ៉ាងនេះ អ្នកកុំធ្វើបញ្ចវេរ អកុសលកម្មបថ ១០ ឡើយ ។ បទថា **កល្យាណេ និវេសេតិ** សេចក្តីថា មិត្រប្រាប់ប្រយោជន៍ រមែងឲ្យប្រកបសេចក្តីល្អយ៉ាងនេះថា អ្នកចូរប្រព្រឹត្តទៅក្នុងកល្យាណកម្ម ក្នុងសរណៈ ៣ ក្នុងសីល ៥ ក្នុង កុសលកម្មបថ ១០ ចូរឲ្យទាន ចូរធ្វើបុណ្យ ចូរស្តាប់ធម៌ ដូច្នេះ ។ បទថា **អស្សុតំ សាវេតិ** គឺឲ្យស្តាប់ពាក្យដែលល្អិតល្អន់ ធ្វើឲ្យឈ្លាសក្នុងវត្ថុមិនធ្លាប់បានស្តាប់ ។ បទថា **សគ្គស្ស មគ្គំ** សេចក្តីថា មិត្រប្រាប់ប្រយោជន៍ រមែងប្រាប់ផ្លូវសួគ៌យ៉ាងនេះថា ជន ទាំងឡាយ ធ្វើកម្មនេះ រមែងកើតក្នុងឋានសួគ៌ ។

[ ៦៧ ] បទថា **អដវេនស្ស ននន្ទតិ** សេចក្តីថា មិត្រមានសេចក្តីឈឺធ្ងាលឃើញ ឬបានឮសេចក្តីវិនាសបែបនោះរបស់បុត្រភរិយា ឬរបស់បរិវារជន ព្រោះសេចក្តីវិនាស គឺព្រោះសេចក្តីមិនចម្រើនរបស់មិត្ត រមែងមិនត្រេកអរ គឺមិនពេញចិត្ត ។ បទថា **ភវេន** សេចក្តីថា មិត្រមានសេចក្តីឈឺធ្ងាល ឃើញ ឬបានឮសេចក្តីបរិបូណ៌របស់ស្រូវជាដើម ឬការបានភាពជាធំ ព្រោះសេចក្តីចម្រើនរបស់សម្លាញ់បែបនោះ រមែងត្រេកអរពេញចិត្ត ។ បទថា **អវណ្ណំ ភណមានំ និវារេតិ** សេចក្តីថា កាលមានអ្នកនិយាយថា អ្នកឯណោះរូបអាក្រក់ មិនគួរជ្រះថ្លា មានជាតិអាក្រក់ ឬជាអ្នកទ្រុស្តសីល ដូច្នេះ មិត្រមានសេចក្តីឈឺធ្ងាល រមែងហាមអ្នកដទៃ ដែលពោលតិះដៀលសម្លាញ់របស់ខ្លួនដោយពាក្យទាំងឡាយជាដើមថា អ្នកកុំនិយាយយ៉ាងនេះ បុគ្គលនោះមានរូបល្អគួរជ្រះថ្លា មានជាតិល្អ និងដល់ព្រមដោយសីល ។ បទថា **វណ្ណំ ភណមានំ បសំសតិ** សេចក្តីថា កាលមានអ្នកនិយាយថា បុគ្គលឈ្មោះនោះ មានរូបល្អគួរជ្រះថ្លា មានជាតិល្អ ដល់ព្រមដោយសីល មិត្រជាទីស្រឡាញ់ រមែងសរសើរអ្នកដទៃដែលនិយាយសរសើរសម្លាញ់របស់ខ្លួនយ៉ាងនេះថា លោកនិយាយល្អ លោកនិយាយពាក្យយ៉ាងនេះ ល្អហើយ បុរសនេះ មានរូបល្អគួរជ្រះថ្លា មានជាតិល្អ ដល់ព្រមហើយដោយសីល ។

[ ៦៨ ] បទថា **ជលំ អគ្គិវ ភាសតិ** សេចក្តីថា រមែងរុងរឿងដូចភ្លើងដែលឆេះលើកំពូលភ្នំក្នុងពេលយប់ ។ បទថា **ភោគេ សំហារមានស្ស** សេចក្តីថា កាលបុគ្គលមិនបៀតបៀនខ្លួនខ្លះ អ្នកដទៃខ្លះ ប្រមូលភោគៈដោយធម៌ស្មើ

គឺធ្វើឲ្យជាគំនរ ។ បទថា **ភមរស្សេវ ឥរិយតោ** សេចក្ដីថា ធ្វើភោគៈឲ្យជាគំនរធំតាមលំដាប់ ដូចសត្វឃ្មុំមិនទម្លាយពណ៌ និងក្លិនរបស់ផ្កា នាំកេសរដោយមាត់ខ្លះ ដោយស្លាបទាំងពីរខ្លះ ហើយធ្វើសសម្បុកប្រមាណប៉ុនកង់រថដោយលំដាប់ ។ បទថា **ភោគា សន្និចយំ យន្តិ** សេចក្ដីថា ភោគៈទាំងឡាយរបស់បុគ្គលនោះ រមែងដល់នូវការចម្រើនដូចម្ដេច ដូចដំបូកដែលកណ្ដៀរទាំងឡាយពូនឡើងដោយលំដាប់ ។ ដោយហេតុនោះ ទើបលោកពោលថា ដូចជាដំបូកដែលកណ្ដៀរកពូន ដូច្នោះឯង អធិប្បាយថា ភោគៈទាំងឡាយ រមែងដល់នូវការចម្រើន ដូចដំបូកដែលណ្ដៀរកពូន ដូច្នោះ ។ បទថា **សមាហរិត្វា** សេចក្ដីថា រួបរួមហើយ ។ បទថា **អលមត្ថោ** សេចក្ដីថា គ្រហស្ថជាអ្នកមានសភាពសមរម្យ ឬជាអ្នកមានសមត្ថភាព ឬជាអ្នកប្រាថ្នាដើម្បីការនៅគ្រប់គ្រងផ្ទះ ។ ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់ប្រទានព្រះឱវាទ ដោយប្រការដល់អ្នកដែលនៅគ្រប់គ្រងផ្ទះ គប្បីតាំងនៅ ទើបត្រាស់បទជាដើមថា **ចតុធា វិភជេ ភោគេ** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **សវេ មិត្តានិ គន្ថតិ** សេចក្ដីថា អ្នកគ្រប់គ្រងផ្ទះនោះ កាលបែងចែកភោគៈយ៉ាងនេះ ឈ្មោះថា រមែងចងមិត្របាន គឺតាំងនូវការមិនបែកគ្នា ។ អ្នកដែលមានភោគៈ រមែងអាចទំនាក់ទំនងមិត្របាន អ្នកក្រៅពីនោះ មិនអាច ។ បទថា **ឯកេន ភោគេ ភុញ្ជេយ្យ** សេចក្ដីថា គប្បីបរិភោគភោគៈ ១ ចំណែក ។ បទថា **ទ្វីហិ កម្មំ បយោជយេ** សេចក្ដីថា គប្បីប្រកបការងារ មានកសិកម្ម និងពាណិជ្ជកម្មជាដើម ២ ចំណែក ។ បទថា **និធាបេយ្យ** គឺគប្បីរក្សាចំណែកទី

៤ ។ បទថា **អាបទាសុ ភវិស្សតិ** សេចក្តីថា ព្រោះការងាររបស់ត្រកូលទាំងឡាយ មិនមែនប្រព្រឹត្តទៅបានសព្វកាលឡើយ ជួនកាលអន្តរាយ មានរាជភ័យជាដើម រមែងកើតឡើងបាន ។ ព្រោះដូច្នោះ ការប្រើទ្រព្យនឹងមានក្នុងពេលអន្តរាយទាំងឡាយកើតឡើងយ៉ាងនេះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា តម្កល់នូវចំណែកទី ៤ ដូច្នេះ ។ ក្នុងចំណែកទាំងឡាយ ៤ នេះ គប្បីរក្សាចំណែកណាមួយ ដើម្បីបំពេញកុសល ។ កាន់យកចំណែកដែលលោកពោលក្នុងបទថា **ភោគេ ភុញ្ជេយ្យ** ។ គួរកាន់យកអំពីចំណែកនោះ បរិច្ចាគទានដល់ភិក្ខុទាំងឡាយខ្លះ ដល់មនុស្សកំព្រា និងអ្នកធ្វើដំណើរជាដើមខ្លះ គួរឲ្យរង្វាន់ដល់ជាងតម្បាញ និងអ្នកកោរកាត់ជាដើមខ្លះ ។

## អធិប្បាយទិស ៦

[ ៦៩ ] ដោយកថាមគ្គ ត្រឹមតែប៉ុណ្ណេះ ព្រះមានព្រះភាគ ទ្រង់ប្រទានព្រះឱវាទដើម្បីវៀរធម៌ដែលគួរវៀរ និងដើម្បីសេពធម៌ដែលគួរសេពថា ម្នាលគហបតីបុត្រ អរិយសាវក លះអកុសលដោយហេតុទាំងឡាយ ៤ វៀរផ្លូវវិនាសនៃភោគៈទាំងឡាយ ដោយហេតុទាំងឡាយ ៦ សេពគប់មិត្រ ១៦ ពួក នៅគ្រប់គ្រងផ្ទះ ធ្វើការចិញ្ចឹមកិរិយា រមែងរស់នៅដោយអាជីវៈដែលជាធម៌ រមែងរុងរឿងដូចគំនរភ្លើងក្នុងចន្លោះទេវតា និងមនុស្សទាំងឡាយ ឥឡូវនេះ កាលនឹងទ្រង់សម្តែងទិស ៦ ដែលគួរនមស្ការ ទើបត្រាស់ពាក្យជាដើមថា ម្នាលគហបតីបុត្រ អរិយសាវកបិទបាំងទិសទាំង ៦ ដូចម្តេច ។

ក្នុងបទទាំងនោះ បទថា **ឆទិសាបដិច្ឆាទិ** សេចក្តីថា ព្រះមានព្រះភាគ

ទ្រង់នៅដោយភ័យដែលមកអំពីទិសទាំង ៦ មិនមកដល់ ជាដែនក្សេម ប្រាស ចាកភ័យ ទើបត្រាស់ថា អរិយសាវកជាអ្នកបិទបាំងទិសទាំង ៦ ដូច្នេះ ។ ក្នុង ពាក្យទាំងឡាយថា មាតា បិតា អ្នកត្រូវដឹងថា ទិសខាងកើត ដូច្នេះ គឺគប្បី ជ្រាបថា មាតា បិតា ជាទិសខាងកើត ព្រោះជាអ្នកមានឧបការៈមុន អាចារ្យ ជាទិសខាងត្បូង ព្រោះជាអ្នកគួរដល់ទក្ខិណា បុត្រភរិយា ជាទិសខាងលិច ដោយអំណាចដើរតាមអំពីខាងក្រោយ មិត្រសម្លាញ់ ជាទិសខាងជើង ព្រោះ កុលបុត្រនោះ អាស្រ័យមិត្រ និងសម្លាញ់ ទើបឆ្លងផុតទុក្ខពិសេសទាំងនោះ ទាសៈ និងកម្មករ ជាទិសខាងក្រោម ដោយអំណាចតាំងនៅទៀបជើង សមណព្រាហ្មណ៍ ជាទិសខាងលើ ព្រោះភាពជាអ្នកតាំងនៅក្នុងខាងលើ ដោយ គុណទាំងឡាយ ។

[ ៧០ ] បទថា **ភតោ នេ ភរិស្សាមិ** សេចក្តីថា អាត្មាអញ ដែលមាតា បិតាឲ្យចៅដោះ ញុំាងដៃ និងជើងឲ្យចម្រើន បឹតសម្បោរឲ្យ ផ្លូតទឹកឲ្យ ស្អិត ស្អាងឲ្យ ចិញ្ចឹមរក្សា និងផ្គត់ផ្គង់ អាត្មាអញនឹងចិញ្ចឹមមាតាបិតាទាំងនោះ ដែលមានវ័យចាស់ ដោយការលាងជើង ផ្លូតទឹក ឲ្យបបរ និងបាយជាដើម ។ បទថា **កិច្ចំ នេសំ ករិស្សាមិ** សេចក្តីថា អញនឹងវៀរការងាររបស់ខ្លួន មាន កិច្ចដែលកើតឡើងក្នុងរាជសម្នាក់ជាដើម ហើយជួយធ្វើកិច្ចដល់មាតាបិតា ។ បទថា **កុលវំសំ ឋបេស្សាមិ** សេចក្តីថា បុត្រមិនធ្វើឲ្យវត្ថុ ប្រាក់ និងមាស ជាដើម ដែលជារបស់មាតាបិតាឲ្យវិនាស ហើយថែរក្សា ក៏ឈ្មោះថា តាំង វង្សត្រកូល បុត្រធ្វើឲ្យមាតាបិតាវិនាសចាកវង្សដែលប្រកបដោយអធម៌ ឲ្យ

តាំងនៅក្នុងវង្សដែលប្រកបដោយធម៌ មិនចូលទៅហាមសលាកភត្តជាដើម ដែលមកដល់ហើយដោយវង្សត្រកូល ឲ្យប្រព្រឹត្តទៅ ក៏ឈ្មោះថា រក្សាវង្ស-ត្រកូល ។ លោកពោលសំដៅដល់បទនេះ ទើបពោលថា អាត្មាអញនឹងរក្សាវង្សត្រកូល ដូច្នេះ ។ បទថា **ទាយជ្ជំ បដិបជ្ជាមិ** សេចក្តីថា មាតាបិតាទៅដល់កោងប្រជុំ ធ្វើទារកដែលមិនប្រព្រឹត្តតាមឱវាទរបស់ខ្លួន ដែលបដិបត្តិខុស មិនឲ្យកាន់យកថាជាបុត្រ បុត្រទាំងនោះ ក៏ជាអ្នកមិនសមគួរទទួលមត៌កតែមាតាបិតា រមែងធ្វើទារកដែលប្រព្រឹត្តតាមឱវាទ ឲ្យជាម្ចាស់ទ្រព្យ ដែលមាននៅក្នុងត្រកូល លោកពោលថា ប្រតិបត្តិឲ្យសមគួរជាអ្នកទទួលទ្រព្យមត៌កបាន ដោយបំណងថា យើងនឹងប្រព្រឹត្តយ៉ាងនេះដូច្នេះ ។ បទថា **ទក្ខិណំ អនុប្បទស្សាមិ** សេចក្តីថា អាត្មាអញនឹងធ្វើទាន ឧទ្ទិសចំណែកបុណ្យឲ្យដល់មាតាបិតាទាំងនោះហើយ នឹងផ្តើមធ្វើទានឧទ្ទិសឲ្យ តាំងពីថ្ងៃទីបីឡើងទៅ ។

បទថា **បាបា និវារេន្តិ** សេចក្តីថា មាតាបិតា ពោលដល់ទោស ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងភពខាងមុខនៃបាណាតិបាតជាដើម ហើយឃាត់ថា នៃកូន បាកុំធ្វើកម្មមានសភាពបែបនេះឡើយ ដូច្នេះ ស្តីបន្ទោសបុត្រ ដែលធ្វើហើយ ។ បទថា **កល្យាណេ និវេសេន្តិ** សេចក្តីថា មាតាបិតា សូម្បីឲ្យតម្លៃឈ្នួល ដូចអនាថបិណ្ឌិកសេដ្ឋី ក៏នៅតែឲ្យបុត្រតាំងនៅក្នុងការសមាទានសីលជាដើម ។ បទថា **សិប្បំ សិក្ខាបេន្តិ** សេចក្តីថា មាតាបិតាដឹងភាពដែលបុត្រតាំងនៅក្នុងឱវាទរបស់ខ្លួនហើយ ញ៉ាំងបុត្រឲ្យសិក្សាសិល្បៈ មានមុទ្ទាគណនា ( រាប់ដោយមេដៃ ) ជាដើម ដែលប្រព្រឹត្តទៅតាមវង្សត្រកូល ។ បទថា **បដិ-**

**រូបេន** គឺសមគួរដោយត្រកូល មានសីល និងរូបជាដើម ។ បទថា **សមយេ ទាយជ្ជំ និយ្យាទេន្តិ** សេចក្តីថា ឲ្យទ្រព្យក្នុងសម័យដែលគួរ ។ ក្នុងបទនោះ សម័យមាន ២ យ៉ាង គឺនិច្ចសម័យ ១ កាលសម័យ ១ ។ មាតាបិតាឲ្យ ដោយពាក្យថា ចូរកូនប្រញាប់ប្រញាល់ កាន់យកវត្ថុដែលគួរកាន់យកនេះ នេះចូរជាទ្រព្យសម្រាប់ចំណាយរបស់កូន កូនចូរធ្វើកុសលដោយទ្រព្យសម្រាប់ ចំណាយនេះ ដូច្នេះ ឈ្មោះថា ឲ្យក្នុងនិច្ចសម័យ ។ មាតាបិតា រមែងឲ្យក្នុង សម័យកោរជុក និងរៀបការជាដើម ឈ្មោះថា ឲ្យក្នុងសម័យ ។ ម្យ៉ាងទៀត មាតាបិតាឲ្យដោយពាក្យថា ចូរកូនធ្វើកុសលដោយទ្រព្យនេះ ដល់បុត្រដែល ដេកលើគ្រែមរណៈ ក្នុងគ្រាចុងក្រោយ ឈ្មោះថា ឲ្យក្នុងសម័យ ។ បទថា **បដិច្ឆន្នា ហោតិ** សេចក្តីថា ទិសខាងកើតដែលបុត្របិទបាំងហើយ ដោយ ភ័យដែលគប្បីមកអំពីទិសខាងកើត រមែងមិនមកដល់ ។ បើបុត្រទាំងឡាយ បដិបត្តិខុស មាតាបិតាជាអ្នកបដិបត្តិប្រពៃ ដោយការចិញ្ចឹមជាដើម តាំងពីនៅ ជាក្មេង ទារកទាំងនោះ ជាអ្នកមិនសមគួរដល់មាតាបិតា ព្រោះដូច្នោះ ភ័យ នោះ គប្បីមកដល់ ។ បុត្រទាំងឡាយ ជាអ្នកបដិបត្តិប្រពៃ មាតាបិតាជាអ្នក បដិបត្តិខុស មាតាបិតាក៏មិនសមគួរដល់បុត្រទាំងឡាយ ដូច្នោះ ភ័យនេះគប្បី មកដល់ ។ កាលទាំងពីរបដិបត្តិខុស ក៏មានភ័យទាំងពីរយ៉ាង ។ កាលទាំង ពីរបដិបត្តិត្រូវ ក៏មិនមានភ័យទាំងអស់ ។ ដោយហេតុនោះ ទើបលោកពោល ថា ទិសខាងកើតនោះ ដែលកូនបិទបាំងឲ្យក្សេម មិនឲ្យមានភ័យ ដូច្នេះ ។ លុះព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ បានត្រាស់ដល់សិង្គាលកៈថា

ម្នាលគហបតីបុត្រ បិតារបស់អ្នក មិនបានឲ្យអ្នកនមស្ការទិសខាងមុខ ដែលលោកសន្មត តែបិតារបស់អ្នក ធ្វើមាតាបិតាឲ្យដូចជាទិសខាងកើត ហើយឲ្យអ្នកនមស្ការ បិតារបស់អ្នកពោលដល់ទិសខាងកើតយ៉ាងនេះ មិនមែនយ៉ាងដទៃឡើយ ។

[ ៧១ ] បទថា **ឧដ្ឋានេន** គឺដោយក្រោកឡើងអំពីទីអង្គុយ ។ ពិតហើយ សិស្សឃើញអាចារ្យមកអំពីចម្ងាយ ក្រោកអំពីទីអង្គុយ ធ្វើបដិសណ្ឋារៈ ទទួលរបស់អំពីដៃ ក្រាលអាសនៈឲ្យអាចារ្យអង្គុយហើយ គប្បីធ្វើការបក់ លាងជើង ប្របាច់ជើងជាដើមនោះ លោកពោលសំដៅយកបទថា **ឧដ្ឋានេន** ដូច្នេះ ។ បទថា **ឧបដ្ឋានេន** សេចក្ដីថា ដោយចូលទៅបម្រើ ១ ថ្ងៃ ៣ ដង ។ តែដែលពិត ក៏គួរទៅក្នុងកាលរៀនសិល្បៈ ។ បទថា **សុស្សូសាយ** សេចក្ដីថា កាលសិស្សមិនជឿ មិនស្ដាប់តាម រមែងមិនសម្រេចគុណវិសេស ។ បទថា **ចារិ-ចរិយាយ** គឺដោយការប្រតិបត្តិបន្តិចបន្តួច មិនហួសពីសមត្ថភាព ។ ពិតហើយ សិស្សគួរក្រោកឡើងអំពីព្រឹក ឲ្យទឹកខ្ពុរមាត់ ឈើស្ទន់ ទោះក្នុងវេលាអាហារ ក៏កាន់យកទឹកផឹកទៅឲ្យ ហើយធ្វើការបម្រើ រួចស្រេចហើយ គួរត្រឡប់មកបាន គួរបោកសំពត់ដែលសៅហ្មង គួរតាំងទឹកងូតក្នុងវេលាល្ងាច គួរឧបដ្ឋាកក្នុងវេលាលោកមានជំងឺ ។ សូម្បីបព្វជិត ក៏គួរធ្វើអន្តេវាសិកវត្តគ្រប់យ៉ាង ។ នេះលោកសំដៅយកបទថា **ចារិចរិយាយ** ។ បទថា **សក្កច្ចំ សិប្បំ បដិគ្គ-ហណេន** សេចក្ដីថា ការរៀនបន្តិចបន្តួច ហើយទន្ទេញ ច្រើនៗ ដង សូម្បីមួយបទ ក៏គួររៀនឲ្យដឹងពិត ឈ្មោះថា រៀនដោយសេចក្ដីគោរព ។

បទថា **សុវិនីតំ វិនេន្តិ** សេចក្តីថា អាចារ្យទាំងឡាយ រមែងឲ្យសិស្សសិក្សា គឺអប់រំមារយាទនេះថា អ្នកគួរអង្គុយយ៉ាងនេះ គួរឈរយ៉ាងនេះ គួរទំពាយ៉ាងនេះ គួរបរិភោគយ៉ាងនេះ គួរវៀរមិត្រអាក្រក់ គួរសេពគប់មិត្តល្អ ដូច្នេះ ។ បទថា **សុគ្គហិតំ គាហាបេន្តិ** សេចក្តីថា អាចារ្យទាំងឡាយ ជម្រះអត្ថ និងព្យញ្ជនៈ បង្ហាញប្រយោគ ហើយឲ្យសិស្សរៀន ដោយអាការដែលសិស្សរៀនបានល្អ ។ បទថា **មិត្តាមច្ចេសុ បដិវេទេន្តិ** សេចក្តីថា អាចារ្យទាំងឡាយ ពោលដល់គុណរបស់សិស្សយ៉ាងនេះថា សិស្សរបស់ខ្ញុំម្នាក់នេះឈ្លាស ជាពហូសូតប្រហែលនឹងខ្ញុំ ពួកអ្នកចូរចាំសិស្សនេះ ហើយឲ្យសិស្សប្រាកដក្នុងពួកមិត្រទាំងឡាយ ។ បទថា **ទិសាសុ បរិត្តាណំ ករោន្តិ** សេចក្តីថា អាចារ្យ តែងការពារសិស្សក្នុងទិសទាំងពួង ដោយឲ្យសិក្សាសិល្បៈ ។ ព្រោះថា លាភសក្ការៈ រមែងកើតដល់អ្នករៀនសិល្បៈ ក្នុងទិសដែលទៅសម្តែងលាភសក្ការៈនោះ បានឈ្មោះថា អាចារ្យធ្វើហើយ ។ មហាជនកាលពោលដល់គុណរបស់សិស្សនោះ រមែងពោលដល់គុណរបស់អាចារ្យមុនដោយពិតថា សិស្សរបស់លោកនេះ ជាសិស្សដែលលាងជើងអាចារ្យហើយ ដូច្នេះ ។ លាភរមែងកើតឡើងដល់សិស្សនោះ សូម្បីប្រមាណដល់ព្រហ្មលោក ក៏ជារបស់អាចារ្យនុ៎ះឯង ។ម្យ៉ាងទៀត ចោរទាំងឡាយក្នុងព្រៃរមែងមិនឃើញ អមនុស្សក្តី ពស់ជាដើមក្តី រមែងមិនបៀតបៀន សិស្សណាដែលចង់បានវិជ្ជាដើរទៅ អាចារ្យឲ្យសិស្សនោះសិក្សា ក៏ឈ្មោះថា ធ្វើការការពារក្នុងទិសទាំងឡាយ ។ អាចារ្យទាំងឡាយ លើកតម្កើងសិស្សយ៉ាងនេះថា សិស្សរបស់ខ្ញុំនៅក្នុងទិស

នេះ មិនមានសេចក្តីផ្សេងគ្នាក្នុងសិល្បៈនេះ របស់សិស្ស និងរបស់ខ្ញុំ ពួកអ្នកចូរទៅសួរសិស្សនោះចុះ ដល់មនុស្សដែលកើតសង្ស័យ អំពីទិសដែលសិស្សនោះទៅ ហើយមករកខ្លួន ក៏ឈ្មោះថា រមែងធ្វើការការពារ ព្រោះលាភសក្ការៈកើតឡើងដល់សិស្សក្នុងទីនោះ អធិប្បាយថា រមែងធ្វើឲ្យជាទីពឹង ។ បទដ៏សេសក្នុងរឿងនេះ គប្បីប្រែកបដោយន័យមុននោះឯង ។

[ ៧២ ] គប្បីជ្រាបសេចក្តីក្នុងវារៈទិសទី ៣ បទថា **សម្មាននាយ** សេចក្តីថា ដោយពោលពាក្យរាប់អានយ៉ាងនេះថា នាងទេវៈ នាងតិស្សៈ ដូច្នេះ ។ បទថា **អវមាននាយ** សេចក្តីថា ដោយមិនពោលមើលងាយ មើលថោក វាយដំ ហើយនិយាយ ដូចនិយាយចំពោះទាសៈ និងកម្មករជាដើម ដូច្នោះ ។ បទថា **អនតិចរិយាយ** សេចក្តីថា ស្វាមីលះបង់កិរិយាហើយ ទៅរីករាយនឹងស្រីដទៃ ឈ្មោះថា ប្រព្រឹត្តក្បត់ចិត្តភរិយា ដោយមិនធ្វើយ៉ាងនោះ ។ បទថា **ឥស្សរិយវោស្សគ្គេន** សេចក្តីថា ពិតហើយ ស្ត្រីទាំងឡាយបានអាភរណៈមានមហាលតាបសាធន៍ក៏ដោយ កាលមិនបានចាត់ចែងអាហារ រមែងក្រោធកាលស្វាមីដាក់វែកក្នុងដៃ ហើយពោលថា នាងចូរធ្វើតាមចិត្តរបស់នាងចុះ ដូច្នេះ ហើយប្រគល់ផ្ទះបាយឲ្យ ឈ្មោះថា ប្រគល់ភាពជាធំឲ្យទាំងអស់ អធិប្បាយថា ដោយធ្វើយ៉ាងនោះ ។ បទថា **អលង្ការានុប្បទានេន** សេចក្តីថា ដោយប្រគល់គ្រឿងប្រដាប់តាមសមគួរដល់សម្បត្តិរបស់ខ្លួន ។

បទថា **សុសំវិហិតកម្មន្តា** សេចក្តីថា ភរិយាមិនលះបង់វេលា ដាំបបរដាំបាយជាដើម ហើយចាត់ចែងការងារឲ្យល្អ ដោយការធ្វើសេចក្តីល្អដល់

ស្វាមី ។ បទថា **សុសង្គហិតបរិជនា** សេចក្តីថា សង្គ្រោះបរិជនដោយសេចក្តីរាប់អានជាដើម និងដោយការបញ្ជូនដំណឹងជាដើម ។ ជនជាញាតិរបស់ស្វាមីនិងរបស់ខ្លួន ឈ្មោះថា បរិជនក្នុងទីនេះ ។ បទថា **អនតិចារិនី** សេចក្តីថា មិនបោះបង់ស្វាមីចោល ហើយប្រាថ្នាប្រុសដទៃ ទោះដោយចិត្ត ។ បទថា **សម្ភតំ** សេចក្តីថា ទ្រព្យដែលស្វាមីធ្វើកសិកម្ម និងពាណិជ្ជកម្មជាដើម ហើយនាំមករក្សា ។ បទថា **ទក្ខា ច ហោតិ** សេចក្តីថា ជាអ្នកឈ្លាស ល្អិតល្អន់ក្នុងការរៀបចំបបរ និងកត្តជាដើម ។ បទថា **អនលសា** សេចក្តីថា មិនខ្ជិល កិរិយាមិនដូចជាស្រីពួកដទៃ ដែលខ្ជិលច្រអូស អង្គុយនៅទីឯកន្លែងដែលខ្លួនអង្គុយឈរនៅទីឯកន្លែងដែលខ្លួនឈរ ដូច្នោះ រមែងញ៉ាំងកិច្ចទាំងពួងឲ្យសម្រេចដោយចិត្តដ៏ទូលាយ ។ គប្បីប្រកបបទដ៏សេសក្នុងរឿងនេះ ដោយន័យមុននុ៎ះឯង ។

[ ៧៣ ] គប្បីជ្រាបសេចក្តីក្នុងវារៈទិសទី ៤ បទថា **អវិសំវាទនតាយ** សេចក្តីថា ដោយមិនក្លែងពោលឲ្យឃ្លាតចាកសេចក្តីពិត ដល់បុគ្គលដែលកាន់យកហើយ មិនក្លែងពោលឲ្យឃ្លាតចាកសេចក្តីពិត ហើយឲ្យយ៉ាងនេះថា របស់ឈ្មោះនេះក៏មាន នៅក្នុងផ្ទះរបស់ពួកខ្ញុំ របស់ឈ្មោះនេះក៏មាន សូមទទួលយកចុះ ។

បទថា **អបរបជាចស្ស** សេចក្តីថា បុត្រធីតារបស់សម្លាញ់ ឈ្មោះប្រជា បុត្រធីតារបស់បុត្រធីតាទាំងនោះ ជាក្មួយ និងជាចៅ ឈ្មោះថា ប្រជាដទៃៗ រមែងបូជា រមែងត្រេកអរ រមែងរាប់អានពួកជនទាំងនោះ ធ្វើការមង្គល

ជាដើមដល់ពួកជនទាំងនោះ ក្នុងការធ្វើពិធីមង្គលជាដើម ។ បទដ៏សេសក្នុងរឿងនេះ គប្បីប្រកបដោយន័យមុននោះឯង ។

[ ៧៤ ] បទថា **យថាពលំ កម្មន្តំ សំវិធានេន** សេចក្ដីថា ដោយមិនឲ្យមនុស្សចាស់ធ្វើការងាររបស់មនុស្សកំលោះ ឬមិនឲ្យមនុស្សកំលោះធ្វើការងាររបស់មនុស្សចាស់ មិនឲ្យបុរសធ្វើការងារដែលស្ត្រីធ្វើ ឬមិនឲ្យស្ត្រីធ្វើការងារដែលបុរសធ្វើ ហើយចាត់ការងារតាមកម្លាំងរបស់បុគ្គលនោះឯង ។

បទថា **ភត្តវេតនានុប្បទានេន** សេចក្ដីថា ដោយកំណត់សេចក្ដីសមគួររបស់បុគ្គលនោះៗ ថា បុគ្គលនេះ មានកូនខ្ចី បុគ្គលនេះនៅរួមគ្នាមកដូច្នេះហើយ ឲ្យអាហារ និងឲ្យតម្លៃចាយវាយ ។ បទថា **គិលានុបដ្ឋានេន** សេចក្ដីថា ដោយមិនឲ្យធ្វើការងារក្នុងវេលាឈឺ ហើយឲ្យថ្នាំធ្វើឲ្យជាសះស្បើយជាដើម ហើយថែរក្សា ។ បទថា **អច្ឆរិយានំ រសានំ សំវិភាគេន** សេចក្ដីថា កាលបានរបស់មានរសឆ្ងាញ់ប្លែកៗ ហើយ មិនបរិភោគដោយខ្លួនឯងទាំងអស់ ចែកឲ្យទាសៈ និងកម្មករទាំងនោះ ។ បទថា **សមយេ វោស្សគ្គេន** សេចក្ដីថា ដោយឲ្យឈប់សម្រាកក្នុងនិច្ចសម័យ និងកាលសម័យ ។ ទាសៈ និងកម្មករធ្វើការងារអស់មួយថ្ងៃ តែងនឿយហត់ ព្រោះដូច្នោះ ការដឹងវេលាហើយ ឲ្យឈប់សម្រាក ដោយប្រការដែលទាសៈ និងកម្មករមិននឿយហត់ ឈ្មោះថា ឲ្យឈប់សម្រាកក្នុងនិច្ចសម័យ ។ ការឲ្យរបស់ទំពា និងរបស់បរិភោគជាដើម ក្នុងថ្ងៃមានមហោស្រព នក្ខត្តឫក្ស និងលេងកីឡាជាដើម ហើយឲ្យឈប់សម្រាក ឈ្មោះថា ឲ្យឈប់សម្រាកក្នុងកាលសម័យ ។

បទថា **ឆិន្នាទាយិនោ** សេចក្ដីថា មិនកាន់យកទ្រព្យណាមួយដូចជាចោរ កាន់យកតែរបស់ដែលចៅហ្វាយឲ្យប៉ុណ្ណោះ ។ បទថា **សុកតកម្មករា** សេចក្ដីថា មិនសម្ដីងទោសថា រឿងអ្វីដែលយើងនឹងធ្វើការងារឲ្យដល់គេ យើងមិនបានអ្វីឡើយ ហើយមានចិត្តត្រេកអរធ្វើការងារ ជាអ្នកធ្វើការងារដែលធ្វើល្អហើយ ។ បទថា **កិត្តិវណ្ណហរា** សេចក្ដីថា កាលដល់គ្រាសន្ទនាគ្នាត្រង់កណ្ដាលបរិស័ទ នាំគុណរបស់នាយចៅហ្វាយទៅសរសើរថា មិនមានអ្នកណា ដូចចៅហ្វាយរបស់ខ្ញុំ ខ្ញុំមិនដឹងភាពជាទាសៈរបស់ខ្លួន មិនដឹងភាពដែលលោកទាំងនោះជាចៅហ្វាយ គាត់អនុគ្រោះពួកខ្ញុំយ៉ាងនេះ ។ បទដ៏សេសក្នុងរឿងនេះ គប្បីប្រកបដោយន័យមុននោះឯង ។

[ ៧៥ ] លោកពោលមេត្តាកាយកម្មជាដើម ដែលកុលបុត្រចូលទៅតាំងមេត្តាចិត្តធ្វើហើយ ក្នុងបទទាំងឡាយជាដើមថា **មេត្តេន កាយកម្មេន** ដូច្នេះ ។ ក្នុងបទទាំងនោះ ការទៅវត្តដោយគិតថា អញនឹងនិមន្តភិក្ខុទាំងឡាយ ការកាន់ធម្មក្រក ( តម្រងទឹក ) និងការធ្វើ មានការគក់ខ្នង និងប្របាច់ជើងជាដើម ឈ្មោះថា កាយកម្មប្រកបដោយមេត្តា ។ ការឃើញភិក្ខុទាំងឡាយចូលទៅបិណ្ឌបាត ហើយពោលពាក្យជាដើមថា ពួកអ្នកចូរប្រគេនបបរ ពួកអ្នកចូរប្រគេនបាយ ដោយគោរព ដូច្នេះ ការឲ្យសាធុការហើយ ស្ដាប់ធម៌ និងការធ្វើបដិសណ្ឋារៈជាដើម ដោយសេចក្ដីគោរព ឈ្មោះថា វចីកម្មប្រកបដោយមេត្តា ។ ការគិតយ៉ាងនេះថា ព្រះថេរៈអ្នកចូលទៅកាន់ត្រកូលរបស់ពួកយើង ចូរជាអ្នកមិនមានពៀរ ចូរជាអ្នកមិនបៀតបៀនគ្នាចុះ ឈ្មោះថា មនោកម្ម

ប្រកបដោយមេត្តា ។ បទថា **អនាវដទ្វារតាយ** ប្រែថា ដោយភាពជាអ្នកមិនបិទទ្វារ ។ ក្នុងបទនោះ អធិប្បាយថា កុលបុត្រទោះបីបើកទ្វារ តែមិនឲ្យមិនទទួលអ្នកមានសីលទាំងឡាយ ក៏ឈ្មោះថា ជាអ្នកបិទទ្វារនុ៎ះឯង ។ កុល-បុត្រទោះបិទទ្វារ តែជាអ្នកឲ្យ ទទួលអ្នកមានសីលទាំងនោះ ក៏ឈ្មោះថា ជាអ្នកបើកទ្វារនោះឯង ។ កាលអ្នកមានសីលមកដល់ទ្វារផ្ទះ មិនគួរពោលវត្ថុដែលមានថា មិនមាន ហើយប្រគេន យ៉ាងនេះ ឈ្មោះថា ភាពជាអ្នកមិនបិទទ្វារ ។ បទថា **អាមិសានុប្បទានេន** អធិប្បាយថា របស់ដែលគួរបរិភោគមុនកត្តាហារ ឈ្មោះថា អាមិស ព្រោះដូច្នោះ គួរប្រគេនបបរ និងកត្តដល់អ្នកមានសីលទាំងឡាយ ដូច្នេះ។

បទថា **អនុកម្បំ** សេចក្តីថា ដោយផ្សាយប្រយោជន៍យ៉ាងនេះថា សូមសត្វទាំងឡាយទាំងពួង ចូរជាអ្នកមានសេចក្តីសុខ មិនមានពៀរ មិនមានរោគកុំបៀតបៀនគ្នាចុះ ។ម្យ៉ាងទៀត សមណព្រាហ្មណ៍ សូម្បីនាំសព្រហ្មចារីអ្នកមានសីលពួកដទៃ ហើយចូលទៅកាន់ផ្ទះរបស់ឧបដ្ឋាកទាំងឡាយ ក៏ឈ្មោះថា អនុគ្រោះដោយចិត្តស្អាត ។ បទថា **សុតំ បរិយោទបេន្តិ** សេចក្តីថា ធម៌ណាដែលកុលបុត្រទាំងនោះ ស្តាប់ហើយតាមប្រក្រតី សមណព្រាហ្មណ៍ទាំង-ឡាយប្រាប់អត្ថនៃធម៌នោះហើយ បន្ទោបង់សេចក្តីសង្ស័យ ឬឲ្យបដិបត្តិតាមសេចក្តីពិត ។ បទដ៏សេសក្នុងរឿងនេះ ក៏គប្បីប្រកបដោយន័យមុននោះឯង ។

[ ៧៦ ] បទថា **អលមត្ថោ** សេចក្តីថា គ្រហស្ថដែលអាចធ្វើការចិញ្ចឹមរក្សាបុត្រភរិយា ហើយគ្រប់គ្រងផ្ទះ ។ បទថា **បណ្ឌិតោ** គឺជាអ្នកឈ្លាសក្នុង

ឋាន: ថ្វាយបង្គំទិសទាំងឡាយ ។ បទថា **សណ្ហោ** គឺជាអ្នកល្អិតល្អន់ ដោយការឃើញសេចក្ដីដែលសុខុម ឬដោយពោលវាចាដ៏ពីរោះ ។ បទថា **បដិ-ភាណវា** គឺជាអ្នកមានបញ្ញាក្នុងឋាន:ថ្វាយបង្គំទិសទាំងឡាយ ។ បទថា **និវា-តវុត្តិ** គឺប្រព្រឹត្តបន្ទាប ។ បទថា **អត្ថទ្ធោ** គឺវៀរចាកការរឹងត្អឹង ។ បទថា **ឧដ្ឋានកោ** គឺដល់ព្រមដោយសេចក្ដីប្រឹងប្រែង និងសេចក្ដីព្យាយាម ។ បទថា **អនលសោ** សេចក្ដីថា ប្រាសចាកសេចក្ដីខ្ជិលច្រអូស ។ បទថា **អច្ឆិន្នវុត្តិ** គឺមានការប្រព្រឹត្តមិនដាច់ ដោយអំណាចធ្វើជាប់តគ្នា ។ បទថា **មេធាវី** គឺប្រកបដោយបញ្ញា ដែលធ្វើឲ្យកើតឋាន: ។ បទថា **សង្គាហកោ** គឺធ្វើការសង្គ្រោះដោយសង្គហវត្ថុ ៤ ។ បទថា **មិត្តករោ** គឺស្វែងរកមិត្រ ។ បទថា **វទញ្ញូ** គឺដឹងពាក្យដែលបុព្វការីពោល អធិប្បាយថា ក្នុងវេលាទៅផ្ទះសម្លាញ់ វេកដល់ពាក្យនិយាយដែលបុព្វការីនិយាយថា ពួកអ្នកចូរឲ្យសំពត់ជូតក្បាល ចូរឲ្យសំពត់សាដកដល់សម្លាញ់របស់ខ្ញុំ ចូរឲ្យអាហារ និងតម្លៃឈ្នួលដល់មនុស្សទាំងឡាយ កាលជនទាំងនោះមកផ្ទះរបស់ខ្លួន ជាអ្នកធ្វើតបត្រឹមតែប៉ុណ្ណោះ ឬក្រៃលែងជាងនោះ ។ ម្យ៉ាងទៀត ដឹងវាចារបស់សម្លាញ់នោះ សូម្បីជាវាចាដែលប្រព្រឹត្តតាមគ្នាតៗ មក មិនអាចទទួលបាន ដោយការខ្មាសសម្លាញ់ដែលមក ដោយគិតថា អញនឹងទៅផ្ទះរបស់សម្លាញ់ ហើយនឹងកាន់យកវត្ថុនេះ ដូច្នេះ គេមកដោយប្រយោជន៍យ៉ាងណា ញុំាងប្រយោជន៍យ៉ាងនោះឲ្យសម្រេច ឈ្មោះថា ដឹងវាចា ។ សូម្បីពិនិត្យមើលហើយ ឲ្យវត្ថុដែលសម្លាញ់ខ្វះខាត ក៏ឈ្មោះថា ជាអ្នកដឹងវាចាដូចគ្នា ។ បទថា **នេតា** សេចក្ដីថា

កាលទឹងចន្ទុលបង្ហាញសេចក្ដីនោះៗ ជាអ្នកណែនាំដោយបញ្ញា ។ បង្ហាញហេតុច្រើនយ៉ាង ណែនាំ ឈ្មោះថា **វិនេតា** ។ ណែនាំរឿយៗ ឈ្មោះថា **អនុនេតា** ។ បទថា **តត្ថ តត្ថ** សេចក្ដីថា ក្នុងបុគ្គលទាំងនោះ ។ បទថា **រថស្សាណីវ យាយតោ** សេចក្ដីថា កាលការសង្គ្រោះទាំងនេះនៅមានដោយពិត លោកនៅប្រព្រឹត្តទៅបាន កាលមិនមាន លោកក៏ប្រព្រឹត្តទៅមិនបាន ដូចប្រែកទប់នៅមាន រថ រមែងស៊ុះទៅបាន កាលប្រែកទប់មិនមាន រថក៏ស៊ុះទៅមិនបាន ដូច្នោះ ព្រោះហេតុនោះ ទើបលោកពោលថា សង្គហធម៌ទាំងនេះ ( មានក្នុងលោក ទើបលោកប្រព្រឹត្តទៅបាន ) ដូចជារថមានប្រែកទប់ ទើបប្រព្រឹត្តទៅបាន ដូច្នោះឯង ។ បទថា **ន មាតា បុត្តការណា** ព្រោះហេតុនៃបុត្រ សេចក្ដីថា ប្រសិនបើមាតាមិនគប្បីធ្វើការសង្គ្រោះទាំងនេះដល់បុត្រ មាតាមិនគប្បីបានការរាប់អាន ឬការបូជា ព្រោះហេតុនៃបុត្រ ។ បទថា **សង្គហា ឯតេ** ជាបឋមាវិភត្តិចុះក្នុងអត្ថទុតិយាវិភត្តិ ។ បាឋៈថា **សង្គហោ ឯតេ** ដូច្នេះក៏មាន ។ បទថា **សម្មបេក្ខន្តិ** កាត់បទជា **សម្មា បេក្ខន្តិ** ។ បទថា **បសំសា ច ភវន្តិ** ប្រែថា គួរបានទទួលការសរសើរ ។

[ ៧៧ ] ដោយប្រការដូច្នេះ ព្រះមានព្រះភាគត្រាស់ថា ម្នាលគហបតីបុត្រ អ្នកចូរនមស្ការទិស ដែលបិតារបស់អ្នកពោលសំដៅដល់ ហើយទ្រង់សម្ដែងទិសទាំង ៦ នេះថា ប្រសិនបើអ្នកធ្វើតាមពាក្យបិតា អ្នកចូរនមស្ការទិសទាំងនេះ ទ្រង់តាំងពាក្យសួរដល់សិង្គាលកៈ ញុំាងទេសនាឲ្យដល់ទីបំផុតហើយ ទ្រង់ចូលទៅកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត ។ សិង្គាលកៈ ក៏បានតាំងនៅ

ក្នុងសរណៈទាំងឡាយ ហើយរោយរាយទ្រព្យ ៤០ កោដិ ក្នុងព្រះពុទ្ធ-សាសនា ធ្វើកម្មដែលជាបុណ្យ បានជាអ្នកមានសួគ៌ជាទីទៅក្នុងខាងមុខ ។ ក្នុងសូត្រនេះ ឈ្មោះថា កម្មណា ដែលគ្រហស្ថគួរធ្វើយ៉ាងណាមួយ កម្មនោះដែលព្រះមានព្រះភាគមិនបានត្រាស់ រមែងមិនមាន ព្រះសូត្រនេះ ឈ្មោះថា គិហិវិន័យ ព្រោះដូច្នោះ កាលស្តាប់ព្រះសូត្រនេះហើយ បដិបត្តិតាមដែលបានទូន្មាន សេចក្តីចម្រើនប៉ុណ្ណោះ រមែងជាការប្រាថ្នាបាន មិនមានសេចក្តីវិនាសឡើយ ដូច្នេះ ។ អដ្ឋកថា សិង្គាលកសូត្រ ក្នុងទីឃនិកាយ ឈ្មោះសុមង្គលវិលាសិនី ចប់ ៕

**សិង្គាលកសូត្រ ចប់**

**សូត្រទី ៨ ចប់**

# សុត្តន្តបិដក

## អាដានាដិយសូត្រទី ៩

[ ៧៨ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់លើភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ លំដាប់នោះឯង ស្តេចធំទាំង ៤ អង្គ តាំងការរក្សាទុកក្នុងទិសទាំង ៤ តាំងកងពលទុកក្នុងទិសទាំង ៤ តាំងបុគ្គលជាអ្នកត្រួតត្រាទុក ក្នុងទិសទាំង ៤ ដោយសេនាយក្ខដ៏ច្រើន ដោយសេនាគន្ធព្វដ៏ច្រើន ដោយសេនាកុម្ភណ្ឌដ៏ច្រើន ដោយសេនានាគដ៏ច្រើន កាលវេលារាត្រី ( បឋមយាម ) កន្លងទៅហើយ ( ស្តេចទាំងនោះ ) មានពន្លឺដ៏រុងរឿង ញុំាងភ្នំគិជ្ឈកូដទាំងមូលឲ្យភ្លឺ ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគក្នុងទីនោះ លុះចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំព្រះមានព្រះភាគ ដោយគោរព ហើយអង្គុយក្នុងទីដ៏សមគួរ ។ ឯយក្ខទាំងឡាយនោះ ពួកខ្លះ ថ្វាយបង្គំព្រះមានព្រះភាគដោយគោរព ហើយអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះ គ្រាន់តែពោលពាក្យរាក់ទាក់សំណេះសំណាល ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះ គ្រាន់តែអង្គុយប្រណម្យអញ្ជលី ចំពោះព្រះមានព្រះភាគក្នុងទីដ៏សមគួរ ពួកខ្លះ គ្រាន់តែប្រកាសនាម និងគោត្រ អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះ គ្រាន់តែអង្គុយស្ងៀម ក្នុងទីដ៏សមគួរ ។

[ ៧៩ ] ស្តេចជាធំឈ្មោះវេស្សវ័ណ គង់នៅក្នុងទីដ៏សមគួរ ហើយក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកយក្ខជាន់

ខ្ពស់ មិនជ្រះថ្លាចំពោះព្រះមានព្រះភាគក៏មាន បពិត្រព្រះអង្គដ៏ចម្រើន ពួកយក្ខជាន់ខ្ពស់ជ្រះថ្លាចំពោះព្រះមានព្រះភាគក៏មាន បពិត្រព្រះអង្គដ៏ចម្រើន ពួកយក្ខជាន់កណ្តាលមិនជ្រះថ្លា ចំពោះព្រះមានព្រះភាគក៏មាន ពួកយក្ខជាន់កណ្តាលជ្រះថ្លា ចំពោះព្រះមានព្រះភាគក៏មាន បពិត្រព្រះអង្គដ៏ចម្រើន ពួកយក្ខជាន់ទាបមិនជ្រះថ្លា ចំពោះព្រះមានព្រះភាគក៏មាន បពិត្រព្រះអង្គដ៏ចម្រើន ពួកយក្ខជាន់ទាបជ្រះថ្លា ចំពោះព្រះមានព្រះភាគក៏មាន ។ បពិត្រព្រះអង្គដ៏ចម្រើន ឯយក្ខដែលមិនជ្រះថ្លា ចំពោះព្រះមានព្រះភាគច្រើនណាស់ ការនោះព្រោះហេតុអ្វី បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ព្រះមានព្រះភាគទ្រង់សម្តែងធម៌ ដើម្បីឲ្យវៀរចាកបាណាតិបាត ទ្រង់សម្តែងធម៌ដើម្បីឲ្យវៀរចាកអទិន្នាទាន ទ្រង់សម្តែងធម៌ ដើម្បីឲ្យវៀរចាកកាមេសុមិច្ឆាចារ ទ្រង់សម្តែងធម៌ ដើម្បីឲ្យវៀរចាកមុសាវាទ ទ្រង់សម្តែងធម៌ ដើម្បីឲ្យវៀរចាកទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាហេតុជាទីតាំងនៃសេចក្តីប្រមាទ ។ បពិត្រព្រះអង្គដ៏ចម្រើន ចំណែកខាងយក្ខទាំងឡាយ ច្រើនតែមិនវៀរចាកបាណាតិបាតសោះ មិនវៀរចាកអទិន្នាទានសោះ មិនវៀរចាកកាមេសុមិច្ឆាចារសោះ មិនវៀរចាកមុសាវាទសោះ មិនវៀរចាកទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាហេតុជាទីតាំងនៃសេចក្តីប្រមាទសោះ បានជាពួកយក្ខទាំងនោះ មិនគាប់ចិត្ត មិនពេញចិត្តនឹងការវៀរនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកសាវករបស់ព្រះមានព្រះភាគអាស្រ័យនូវសេនាសនៈស្ងាត់ ដែលតាំងនៅក្នុងព្រៃ មានសូរសព្ទ គឺកកងរំពងតិច ប្រាសចាកសម្តីរបស់មនុស្សអ្នកដើរទៅមក សមគួរដល់ការកំបាំង

អំពីពួកមនុស្ស ជាទីគួរដល់ការលោកខ្ពួនពួនអាត្មាបាន ពួកយក្ខជាន់ខ្ពស់ តែង នៅជានិច្ចក្នុងព្រៃនោះ ( គេ ) មិនជ្រះថ្លាក្នុងសាសនា របស់ព្រះមានព្រះភាគ នេះក៏មាន បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុនោះ សូមព្រះមានព្រះភាគ ប្រៀនប្រដៅនូវព្រះបរិត្តសម្រាប់រក្សាក្នុងនគរឈ្មោះអាដានាដាដល់ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ដើម្បីឲ្យយក្ខទាំងនោះជ្រះថ្លា ដើម្បីការគ្រប់គ្រងរក្សា ដើម្បីមិនបៀតបៀនគ្នា ដើម្បីនៅសប្បាយ ។ ព្រះមានព្រះភាគ ទ្រង់ទទួល និមន្តន៍ដោយតុណ្ហីភាព ។ លំដាប់នោះ ស្តេចជាធំឈ្មោះវេស្សវណ ជ្រាប នូវការទទួលនិមន្តន៍ព្រះមានព្រះភាគហើយ ទើបសម្តែងនូវព្រះបរិត្ត សម្រាប់ រក្សាដែលជាប់ទាក់ទងក្នុងអាដានាដានគរនេះ ក្នុងវេលានោះ ។

[ ៨០ ] សូមនមស្ការចំពោះព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាម វិបស្សី ព្រះអង្គមានចក្ខុ ព្រះអង្គមានសិរី សូមនមស្ការ ចំពោះព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមសិខី ព្រះអង្គមាន សេចក្តីអនុគ្រោះ ដល់សត្វទាំងពួង ជាប្រក្រតី ។ សូម នមស្ការចំពោះព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមវេស្សភូ ព្រះ អង្គជម្រះកិលេសចេញហើយ ព្រះអង្គមានតបធម៌ សូម នមស្ការចំពោះព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមកកុសន្ធៈ ព្រះ អង្គញាំញីនូវមារ ព្រមទាំងសេនានៃមារ ។ សូមនមស្ការ ចំពោះព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមកោនាគមនៈ ព្រះអង្គ មានបាបបន្សាត់បង់ហើយ មានព្រហ្មចរិយធម៌ នៅរួច

ហើយ សូមនមស្ការចំពោះព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមកស្សប ព្រះអង្គរួចផុតស្រឡះចាកកិលេសទាំងពួងហើយ ។ សូមនមស្ការចំពោះព្រះសម្មាសម្ពុទ្ធ ជាសក្យបុត្ត ទ្រង់មានព្រះកាយផ្សាយចេញនូវព្រះរស្មី ទ្រង់មានសិរី ដែលសម្ដែងធម៌នេះ ជាគ្រឿងបន្ទោបង់សេចក្ដីទុក្ខទាំងពួង ។ មួយទៀត ព្រះសម្មាសម្ពុទ្ធទាំងឡាយអង្គណា ព្រះអង្គរលត់កិលេសហើយ ទ្រង់ឃើញច្បាស់នូវធម៌ តាមសេចក្ដីពិតក្នុងលោក ព្រះសម្មាសម្ពុទ្ធទាំងនោះ ជាព្រះទីណាស្រេព ព្រះអង្គមិនមានសេចក្ដីញុះញង់ស៊កសៀត ( ទ្រង់ប្រសើរដោយគុណ ) មិនក្លៀវក្លា ( ដោយកិលេស ) ។ ទេវតា និងមនុស្សទាំងឡាយ តែងនមស្ការព្រះសម្មាសម្ពុទ្ធ ជាគោតមគោត្រ ព្រះអង្គជាប្រយោជន៍ដល់ទេវតា និងមនុស្សទាំងឡាយ ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ទ្រង់ប្រសើរដោយគុណ ព្រះអង្គឥតមានសេចក្ដីព្រើស្រើប ។

[ ៨១ ] ព្រះអាទិត្យ មានរស្មីដ៏ក្លៀវក្លា រះឡើងអំពីទីណា មានមណ្ឌលធំ ( ក្នុងទីនោះ ) កាលព្រះអាទិត្យរះឡើងហើយ រាត្រីក៏បាត់ទៅ ។ មួយទៀត កាលព្រះអាទិត្យរះឡើងហើយ មហាជននាំគ្នាហៅថា ថ្ងៃ សូម្បីអន្លង់ទឹក ក្នុងទីដែលព្រះអាទិត្យរះឡើងនោះ ជាសមុទ្រដ៏ជ្រៅមានទឹក

ហូរទៅ ( ពីនទីផ្សេងៗ ) ជនទាំងឡាយតែងសម្គាល់នូវអន្លង់ទឹកនោះ ត្រង់កន្លែងដែលព្រះអាទិត្យរះឡើងនោះ ថាជាសមុទ្រមានទឹកហូរទៅយ៉ាងនេះ ។ ស្តេចជាធំ ដ៏ទ្រង់យស ទ្រង់រក្សាទិសណា មហាជនតែងហៅទិសនោះថាបុរិមទិស អំពីក្នុងទិសនោះ ទ្រង់ជាអធិបតីលើគន្ធព្វទាំង-ឡាយ មានព្រះនាមថាធតរដ្ឋ មានពួកគន្ធព្វហែហម ទ្រង់ត្រេកត្រអាលដោយរបាំ និងចម្រៀង ។ ព្រះរាជបុត្តរបស់ស្តេចជាធំ នោះមានច្រើនដល់ម៉្លោះ ខ្ញុំព្រះអង្គបានស្តាប់មកថា មាននាមដូចៗ គ្នា ព្រះរាជបុត្តទាំង ៩១ ព្រះអង្គ សឹងមាននាមថា ឥន្ទៈ មានកម្លាំងច្រើន ឯព្រះរាជបុត្តទាំងនោះឃើញព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ភ្ញាក់អំពីការដេកលក់ គឺអវិជ្ជា ទ្រង់ប្រសើរ ( ដោយគុណ ) ឥតមានសេចក្តីព្រឺស្រៀប ក៏នមស្ការអំពីចម្ងាយ ។ បពិត្រព្រះអង្គជាបុរសជាអាជានេយ្យ ខ្ញុំព្រះអង្គសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គជាបុរសខ្ពង់ខ្ពស់ ខ្ញុំព្រះអង្គសូមនមស្ការចំពោះព្រះអង្គសូម្បីអមនុស្សទាំងឡាយ ក៏រមែងថ្វាយបង្គំព្រះអង្គថា ព្រះអង្គទតព្រះនេត្រមើលមហាជន ដោយសព្វញ្ញុតញ្ញាណដ៏ផូរផង់ ។ ពួកខ្ញុំព្រះអង្គបានស្តាប់មកយ៉ាងនេះរឿយៗ ព្រោះហេតុនោះ ពួកខ្ញុំព្រះអង្គតែងនិយាយយ៉ាងនេះថា អ្នកទាំង-

ឡាយថ្វាយបង្គំព្រះជិនស្រី ដែលជាគោតមគោត្រ ឬ ( ព្រះរាជបុត្រទាំងនោះតបថា ) យើងខ្ញុំទាំងឡាយថ្វាយបង្គំព្រះជិនស្រី ជាគោតមគោត្រ យើងខ្ញុំទាំងឡាយ ថ្វាយបង្គំព្រះពុទ្ធគោតមគោត្រ ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ។

[ ៨២ ] ជនជាអ្នកមានពាក្យញុះញង់ស៊កសៀត ជាអ្នកតិះដៀលគេ ក្នុងទីកំបាំងមុខ ដូចជាជនអ្នកស៊ីសាច់ខ្នង ជាអ្នកសម្លាប់សត្វ ជាអ្នកធ្វើអំពើអាក្រក់ ជាចោរ ជាមនុស្សមានកល-លល្បួង ជនទាំងនោះលុះធ្វើកាលកិរិយាទៅហើយ គេតែងថា ( ឲ្យនាំទៅ ) តាមទិសណា ។ ស្តេចជាធំទ្រង់យស ទ្រង់រក្សានូវទិសណា មហាជនតែងនាំគ្នាហៅទិសនោះថា ទក្ខិណាទិស ( រប់ ) អំពីភ្នំសិនេរុមក ស្តេចនោះជាអធិបតីលើកុម្ភណ្ឌទាំងឡាយ ទ្រង់ព្រះនាមវិរុឡ្ហៈដែលមានពួកកុម្ភណ្ឌចោមរោមហើយ ទ្រង់ត្រេកអរដោយរបាំ និងចម្រៀងទាំងឡាយ ។ ព្រះរាជបុត្តរបស់ស្តេចនោះមានច្រើនក៏មែន តែខ្ញុំព្រះអង្គបានស្តាប់មកថា មានព្រះនាមដូចៗ គ្នា ព្រះរាជបុត្តទាំង ៩១ ព្រះអង្គ សុទ្ធតែមានព្រះនាមថាឥន្ទៈ ទ្រង់មានកម្លាំងច្រើន ឯព្រះរាជបុត្តទាំងនោះ ឃើញព្រះអាទិច្ចវង្ស ព្រះអង្គភ្ញាក់ហើយអំពីការដេកលក់ គឺអវិជ្ជា ទ្រង់ប្រសើរ ( ដោយគុណ ) ឥតមាន

សេចក្តីព្រឺស្រើប ក៏នមស្ការអំពីចម្ងាយ ។ បពិត្រព្រះអង្គ ជាបុរសអាជានេយ្យ ខ្ញុំព្រះអង្គសូមនមស្ការ ចំពោះព្រះអង្គ បពិត្រព្រះអង្គជាបុរសឧត្តម ខ្ញុំព្រះអង្គសូមនមស្ការចំពោះ ព្រះអង្គ សូម្បីអមនុស្សទាំងឡាយ ក៏រមែងថ្វាយបង្គំព្រះ អង្គ ថាព្រះអង្គទតព្រះនេត្រមើលមហាជន ដោយសព្វញ្ញុ-តញ្ញាណដ៏ផូរផង់ ។ ខ្ញុំព្រះអង្គបានស្តាប់មកយ៉ាងនេះរឿយៗ ព្រោះហេតុនោះ ពួកខ្ញុំព្រះអង្គនិយាយយ៉ាងនេះថា អ្នក ទាំងឡាយ នមស្ការចំពោះព្រះជិនស្រីជាគោតមគោត្របូ ( ព្រះរាជបុត្តទាំងនោះតបថា ) យើងទាំងឡាយ ថ្វាយ បង្គំព្រះជិនស្រីជាគោតមគោត្រ យើងខ្ញុំទាំងឡាយថ្វាយបង្គំ ព្រះសម្ពុទ្ធជាគោតមគោត្រ ទ្រង់បរិបូណ៌ដោយវិជ្ជា និង ចរណៈ ។

[ ៨៣ ] ព្រះអាទិត្យមានរស្មីដ៏ភ្លឺរក្លា អស្តង្គតទៅក្នុងទី ណា មានមណ្ឌលដ៏ធំក្នុងទីនោះ កាលដែលព្រះអាទិត្យ អស្តង្គតទៅហើយ ពេលថ្ងៃក៏អស់ទៅ កាលបើព្រះអាទិត្យ អស្តង្គតទៅហើយ មហាជននាំគ្នាហៅថា យប់ ។ សូម្បី អន្លង់ទឹក ត្រង់កន្លែងដែលព្រះអាទិត្យអស្តង្គត នោះជា សមុទ្រដ៏ជ្រៅ មានទឹកហូរទៅ ជនទាំងឡាយតែងសម្គាល់ នូវអន្លង់ទឹកនោះ ត្រង់កន្លែងដែលព្រះអាទិត្យអស្តង្គតនោះ

ជាជាសមុទ្រមានទឹកហូរទៅយ៉ាងនេះ ។ ស្តេចជាធំ ទ្រង់យស ទ្រង់រក្សាទិសណា មហាជនតែងហៅទិសនោះថា បច្ឆិមទិស អំពីភ្នំសិនេរុមក ស្តេចជាធំនោះ ជាអធិបតីលើនាគទាំងឡាយ ទ្រង់ព្រះនាមថាវិរូបក្ខៈ ដែលមានពួកនាគចោមរោមហើយ ទ្រង់ត្រេកអរដោយពួករបាំ និងចម្រៀង ។ ព្រះរាជបុត្តទាំងឡាយរបស់ស្តេចវិរូបក្ខៈនោះ មានច្រើនក៏មែន តែខ្ញុំព្រះអង្គបានស្តាប់មកថា មានឈ្មោះដូចៗគ្នា ព្រះរាជបុត្តទាំង ៩១ ព្រះអង្គ ក៏ព្រះនាមថាឥន្ទៈ សុទ្ធតែមានកម្លាំងច្រើន ឯព្រះរាជបុត្តទាំងនោះ លុះឃើញព្រះសម្ពុទ្ធជាអាទិច្ចវង្ស ទ្រង់ភ្ញាក់ហើយចាកការដេកលក់ គឺអវិជ្ជា ទ្រង់ប្រសើរ ( ដោយគុណ ) ឥតមានសេចក្តីព្រឺស្រៀបក៏នាំគ្នានមស្ការអំពីចម្ងាយ ។ បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំព្រះអង្គសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គជាបុរសដ៏ខ្ពង់ខ្ពស់ ខ្ញុំព្រះអង្គសូមនមស្ការ ចំពោះព្រះអង្គសូម្បីអមនុស្សទាំងឡាយ ក៏តែងថ្វាយបង្គំព្រះអង្គថា ទ្រង់ទតព្រះនេត្រមើលមហាជន ដោយសព្វញ្ញុតញ្ញាណដ៏ផូរផង់ ។ ពួកខ្ញុំព្រះអង្គបានស្តាប់មកយ៉ាងនេះរឿយៗ ព្រោះហេតុនោះ ខ្ញុំព្រះអង្គតែងនិយាយយ៉ាងនេះថា អ្នកទាំងឡាយ នមស្ការចំពោះព្រះជិនស្រី ជាគោតមគោត្រឬ ( ព្រះ

រាជបុត្តទាំងនោះតបថា ) យើងខ្ញុំទាំងឡាយ នមស្ការចំពោះព្រះជិនស្រី ជាគោតមគោត្រ យើងខ្ញុំទាំងឡាយ នមស្ការព្រះពុទ្ធជាគោតមគោត្រ ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ។

[ ៨៤ ] ឧត្តរកុរុទ្វីប ជាទីរីករាយ មានភ្នំសិនេរុដ៏ធំ គួរជាទីមើល តាំងនៅក្នុងទីណា ពួកមនុស្សកើតក្នុងឧត្តរកុរុទ្វីបនោះ ឥតមានប្រកាន់របស់អ្វី ថាជារបស់ខ្លួនឡើយ ។ មនុស្សទាំងអម្បាលនោះ មិនចាំបាច់ព្រោះពូជ មិនចាំបាច់នាំនង្គ័លចេញទៅ ( ដោយគិតថា អាត្មាអញនឹងភ្ជួរក្នុងទីនោះៗ ) បរិភោគតែស្រូវសាលី ដែលកើតឯងក្នុងព្រៃ ជាស្រូវមិនមានកុណ្ឌក មិនមានអង្កាម ស្អាតមានក្លិនក្រអូប ផ្លែចេញជាអង្ករ មនុស្សទាំងឡាយដាក់អង្ករ នោះក្នុងឆ្នាំងចម្អិនដោយភ្លើងឥតផ្សែង មិនមានរងើក ទើបនាំគ្នាបរិភោគភោជនអំពីឆ្នាំងនោះ ។ មនុស្សទាំងនោះ ទឹមនូវមេគោមានក្រចកតែមួយ ( ដូចក្រចកសេះ ) បរទៅសព្វទិស ទឹមបសុសត្វ ( សត្វជើងបួនក្រៅពីមេគោ ) មានក្រចកតែមួយ បរទៅសព្វទិស ។ យកស្រីធ្វើជាវាហនៈត្រាច់ទៅសព្វទិស យកបុរសធ្វើជាវាហនៈត្រាច់ទៅសព្វទិស ។ យកកុមារីធ្វើជាវាហនៈ ត្រាច់ទៅសព្វទិស យកកុមារធ្វើជា

វាហនៈ ហើយត្រាច់ទៅសព្វទិស ។ មនុស្សទាំងអម្បាល នោះនាំគ្នាឡើងយាន ត្រាច់ទៅក្នុងទិសទាំងពួង ពួកស្រី ទាំងឡាយ ជាអ្នកបម្រើស្តេចនោះ ។ យានដំរី យានសេះ យានជាទិព្វ ប្រាសាទ និងវាំង ក៏មានសម្រាប់ស្តេចជាធំដ៏ ទ្រង់យស ។ មួយទៀត ស្តេចនោះ ទ្រង់កសាងនគរទុក ក្នុងអាកាស គឺអាដានាដានគរ កុសិនាដានគរ បរកុសិនា- ដានគរ នាដបរិយានគរ បរកុសិតនាដានគរ ។ សាងនគរ ឈ្មោះកបិវន្តក្នុងទិសខាងជើង ក្នុងចំណែកទិសដទៃទៀត បានសាងនគរឈ្មោះជនោឃៈ ឈ្មោះនវនវតិយៈ ឈ្មោះ អម្ពរអម្ពរវតិយៈ និងរាជធានីឈ្មោះអាឡកមន្ទា បពិត្រ ព្រះអង្គអ្នកនិទ្ទុក្ខ ស្តេចជាធំឈ្មោះកុវេរៈ មានរាជធានី ឈ្មោះវិសាណា ព្រោះហេតុនោះ ស្តេចជាធំ ទ្រង់ព្រះនាម កុវេរៈ មហាជននាំគ្នាហៅថា វេស្សវណ្ណ ។ ពួកយក្ខ ឈ្មោះតតោលា តត្តលា តតោតលា ឱជសី តេជសី តតោជសី សុរោ រាជា សុរោរាជា អរិដ្ឋ នេមិ អរិដ្ឋនេមិ តែងត្រួតត្រា ប្រកាសនូវប្រយោជន៍ផ្សេងៗ ។ មួយទៀត ភ្លៀងនាំទឹកអំពីស្រះបោក្ខរណីណាហើយ បង្អុរចុះ ភ្លៀងហូរ ចេញអំពីទីណា ត្រង់ទីនោះឯង មានអន្លង់ទឹកឈ្មោះធរណី ពួកយក្ខតែងអង្គុយប្រជុំគ្នា ក្នុងទីណា ត្រង់ទីនោះឯង មាន

សភាឈ្មោះកគលវតី ។ ត្រង់ទីនោះ មានដើមឈើផ្លែជានិច្ច ដេរដាសដោយហ្វូងបក្សីផ្សេងៗ កងរំពងដោយសំឡេងសត្វក្ងោក សត្វក្រៀល ( ព្រមទាំង ) ពួកតាវៅមានសំឡេងពីរោះ ។ សំឡេងបក្សីឈ្មោះជីវញ្ជីវក ក៏មានក្នុងទីនុ៎ះ មួយទៀត ពួកបក្សីឈ្មោះឱដ្ឋវចិត្តកៈ ហ្វូងមាន់ព្រៃ ក្តាម និងហ្វូងសត្វបោក្ខរសាតកៈ ក៏អាស្រ័យនៅក្នុងត្រពាំងឈូក ។ម្យ៉ាងទៀត សំឡេងសត្វសេក និងសារិកាក៏មានក្នុងទីនោះ មានទាំងពួកបក្សីឈ្មោះទណ្ឌមានវកៈ ស្រះឈូករបស់ស្តេចកុវេរៈនោះ ជាស្រះល្អសព្វកាល ឥតចន្លោះ ។ ស្តេចជាធំ ទ្រង់យស ទ្រង់អភិបាលទិសណាមហាជនតែងនាំគ្នាហៅទិសនោះថា ឧត្តរទិស រាប់អំពីភ្នំសិនេរុមក ។ ព្រះអង្គជាអធិបតីលើពួកយក្ខ ទ្រង់ព្រះនាមជាកុវេរៈ ដែលមានពួកយក្ខចោមរោមហើយ ទ្រង់ត្រេកត្រអាលដោយពួករបាំ និងចម្រៀង ។ ពួកព្រះរាជបុត្តរបស់ព្រះអង្គ ក៏មានច្រើន តែខ្ញុំព្រះអង្គបានស្តាប់មកថាមានព្រះនាមដូចៗ គ្នា ព្រះរាជបុត្រទាំង ៩១ ព្រះអង្គមានព្រះនាមថាឥន្ទៈ ទ្រង់មានកម្លាំងច្រើន ។ ឯព្រះរាជបុត្តទាំងនោះ លុះបានឃើញព្រះពុទ្ធជាអាទិច្ចវង្ស ទ្រង់ភ្ញាក់ហើយចាកការដេកលក់ គឺអវិជ្ជា ប្រសើរ ( ដោយគុណ )

ឥតមានសេចក្តីព្រឺស្រៀប ក៏នាំគ្នានមស្ការអំពីចម្ងាយ ។ បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំព្រះអង្គសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គជាបុរសឧត្តម ខ្ញុំព្រះអង្គសូមនមស្ការចំពោះព្រះអង្គ សូម្បីអមនុស្សទាំងឡាយ ក៏រមែងថ្វាយបង្គំព្រះអង្គថា ព្រះអង្គទតព្រះនេត្រមើលមហាជនដោយសព្វញ្ញុតញ្ញាណដ៏ផូរផង់ ។ ពួកខ្ញុំព្រះអង្គបានស្តាប់មកយ៉ាងនេះរឿយៗ ព្រោះហេតុនោះ ពួកខ្ញុំព្រះអង្គតែងនិយាយយ៉ាងនេះថា អ្នកទាំងឡាយ នមស្ការចំពោះព្រះជិនស្រីជាគោតមគោត្រឬ ព្រះរាជបុត្តទាំងនោះតបថា យើងទាំងឡាយ នមស្ការចំពោះព្រះជិនស្រី ជាគោតមគោត្រ យើងទាំងឡាយ នមស្ការចំពោះព្រះពុទ្ធ ជាគោតមគោត្រទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ។

[ ៨៥ ] បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ការរក្សាជាប់ទាក់ទងក្នុងអាដានាដានគរនេះឯង រមែងប្រព្រឹត្តទៅ ដើម្បីគ្រប់គ្រងរក្សា ដើម្បីមិនបៀតបៀន ដើម្បីនៅសប្បាយរបស់ពួកភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកា ។ ការរក្សា ជាប់ទាក់ទងក្នុងអាដានាដានគរនេះ ដែលបុគ្គលណាមួយ ទោះបីជាភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកា រៀនដោយប្រពៃ រៀនដោយសព្វគ្រប់ ជម្រះអត្ថ និងព្យញ្ជនៈឲ្យបរិបូណ៌ បើអមនុស្ស

ទោះបីជាយក្ខក្តី យក្ខិនីក្តី កូនប្រុសរបស់យក្ខក្តី កូនស្រីរបស់យក្ខក្តី អាមាត្យធំរបស់យក្ខក្តី បរិស័ទរបស់យក្ខក្តី អ្នកបម្រើរបស់យក្ខក្តី គន្ធព្វប្រុសក្តី គន្ធព្វស្រីក្តី កូនប្រុសរបស់គន្ធព្វក្តី កូនស្រីរបស់គន្ធព្វក្តី អាមាត្យធំរបស់គន្ធព្វក្តី បរិស័ទរបស់គន្ធព្វក្តី អ្នកបម្រើរបស់គន្ធព្វក្តី កុម្ភណ្ឌប្រុសក្តី កុម្ភណ្ឌស្រីក្តី កូនប្រុសរបស់កុម្ភណ្ឌក្តី កូនស្រីរបស់កុម្ភណ្ឌក្តី អាមាត្យធំរបស់កុម្ភណ្ឌក្តី បរិស័ទរបស់កុម្ភណ្ឌក្តី អ្នកបម្រើរបស់កុម្ភណ្ឌក្តី នាគឈ្មោលក្តី នាគញីក្តី កូនឈ្មោលរបស់នាគក្តី កូនញីរបស់នាគក្តី អាមាត្យធំរបស់នាគក្តី បរិស័ទរបស់នាគក្តី នាគជាអ្នកបម្រើក្តី ដែលជាអ្នកមានចិត្តប្រទូស្តនូវបុគ្គលនោះ ហើយដើរតាមភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកាដែលកំពុងដើរ ឬឈរជិតភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកាដែលកំពុងឈរ ឬអង្គុយជិតភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកាដែលកំពុងអង្គុយ ឬដេកជិតភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកាដែលកំពុងដេក ។ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ អមនុស្សនោះ មិនគប្បីបានសក្ការៈ និងសេចក្តីគោរពក្នុងស្រុក ឬនិគមទាំងឡាយនៃខ្ញុំឡើយ ។ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ អមនុស្សនោះ មិនគប្បីបានទីផ្ទះ ឬការនៅជានិច្ចក្នុងរាជធានី ឈ្មោះ

អាលកមន្ទារបស់ខ្ញុំឡើយ ។ បពិត្រព្រះអង្គ អ្នកនិទ៌ុក្ខ អមនុស្សនោះ មិនគប្បីបានចូលកាន់ទីប្រជុំ របស់ពួកយក្ខទាំងឡាយនៃខ្ញុំឡើយ ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ មួយទៀត អមនុស្សទាំងឡាយ មិនគប្បីធ្វើអាវាហមង្គល ឬវិវាហមង្គល និងអមនុស្សនោះទេ ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ អមនុស្សទាំងឡាយ គប្បីផ្តាសាអមនុស្សនោះ ដោយពាក្យផ្តាសាទាំងឡាយ ពេញបន្ទុកប្រៀបធៀបដោយខ្លួន ( អាក្រក់ ) ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ អមនុស្សទាំង-ឡាយ គប្បីផ្កាប់បាត្រទទេ លើក្បាលនៃអមនុស្សនោះ ។ មួយទៀត អមនុស្សទាំងឡាយ គប្បីបំបែកក្បាលអមនុស្សនោះជា ៧ ភាគ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ មានអមនុស្សទាំងឡាយក្រោធ ពិរោធក្រៃលែងជាងហេតុ អមនុស្សទាំងឡាយនោះ មិនធ្វើតាមអាជ្ញានៃស្តេចជាធំ មិនធ្វើតាមអាជ្ញានៃយក្ខ ជាសេនាបតី ២៨ នាក់របស់ស្តេចជាធំនោះ ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ អមនុស្សទាំងឡាយ របស់ស្តេចជាធំនោះ ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ អមនុស្សទាំងឡាយនោះៗ ឯង គេតែងហៅថា ជាសត្រូវនឹងស្តេចជាធំ ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ពួកចោរក្នុងដែននៃស្តេចមគធៈ មិនធ្វើតាមអាជ្ញានៃស្តេចមគធៈ មិនធ្វើតាមអាជ្ញានៃសេនាបតី

របស់ស្តេចមគធៈ មិនធ្វើតាមអាជ្ញានៃសេនាបតី ជាអ្នកប្រៀនប្រដៅរបស់ស្តេចមគធៈ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ពួកមហាចោរទាំងអម្បាលនោះ គេតែងហៅថា ជាសត្រូវនឹងស្តេចមគធៈ យ៉ាងណាមិញ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ មានអមនុស្សទាំងឡាយ ជាអ្នកក្រោធ ពិរោធក្រៃលែងជាងហេតុ អមនុស្សទាំងនោះ មិនធ្វើតាមអាជ្ញានៃស្តេចជាធំ មិនធ្វើតាមអាជ្ញានៃសេនាបតីរបស់ស្តេចជាធំ មិនធ្វើតាមអាជ្ញាពួកយក្ខសេនាបតី ជាអ្នកប្រៀនប្រដៅ របស់ស្តេចជាធំ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ អមនុស្សទាំងឡាយនោះៗ ឯង គេតែងហៅថា ជាសត្រូវនឹងស្តេចជាធំយ៉ាងដូច្នោះឯង ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ប្រសិនបើអមនុស្សណាមួយ ជាយក្ខប្រុសក្តី យក្ខស្រីក្តី កូនប្រុសរបស់យក្ខក្តី កូនស្រីរបស់យក្ខក្តី មហាមាត្យរបស់យក្ខក្តី បរិស័ទរបស់យក្ខក្តី អ្នកបម្រើរបស់យក្ខក្តី គន្ធព្វប្រុសក្តី គន្ធព្វស្រីក្តី កូនប្រុសរបស់គន្ធព្វក្តី កូនស្រីរបស់គន្ធព្វក្តី មហាមាត្យរបស់គន្ធព្វក្តី បរិស័ទរបស់គន្ធព្វក្តី អ្នកបម្រើរបស់គន្ធព្វក្តី កុម្ភណ្ឌប្រុសក្តី កុម្ភណ្ឌស្រីក្តី កូនប្រុសកុម្ភណ្ឌក្តី កូនស្រីកុម្ភណ្ឌក្តី អាមាត្យរបស់កុម្ភណ្ឌក្តី បរិស័ទរបស់កុម្ភណ្ឌក្តី អ្នកបម្រើរបស់កុម្ភណ្ឌក្តី នាគឈ្មោលក្តី នាគញីក្តី កូនឈ្មោល

របស់នាគក្តី កូនញីរបស់នាគក្តី មហាមាត្យរបស់នាគក្តី បរិស័ទរបស់នាគក្តី អ្នកបម្រើរបស់នាគក្តី ជាអ្នកមានចិត្តប្រទូស្ត ដើរទៅតាមភិក្ខុ ឬភិក្ខុនី ឧបាសក ឧបាសិកាដែលកំពុងដើរ ឬឈរជិតភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកាដែលកំពុងឈរ ឬអង្គុយជិតភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកាដែលកំពុងអង្គុយ ឬដេកជិតភិក្ខុ ភិក្ខុនី ឧបាសក ឧបា-សិកាដែលកំពុងដេក ។ អមនុស្សនោះ ត្រូវបុគ្គលពោលទោស កន្ទក់កន្ទេញ ត្រូវស្រែកប្តឹងដល់ពួកយក្ខ ពួកយក្ខជាធំ ពួកសេនាបតី ពួកសេនាបតីជាធំ ទាំងអម្បាលនេះថា យក្ខនេះចាប់គេ យក្ខនេះចូលគេ យក្ខនេះបៀតបៀនគេ យក្ខនេះបៀតបៀនផ្សេងៗ យក្ខនេះធ្វើទុក្ខគេ យក្ខនេះធ្វើឲ្យគេលំបាក យក្ខនេះមិនលែងគេ ។

[ ៨៦ ] ដល់ពួកយក្ខ ពួកមហាយក្ខ ពួកសេនាបតី ពួកមហាសេនាបតី ដូចម្តេចខ្លះ ។

យក្ខឈ្មោះឥន្ទៈ ១ សោមៈ ១ វរុណៈ ១ ភារទ្វាជៈ ១
បជាបតិ ១ ចន្ទនៈ ១ កាមសេដ្ឋៈ ១ កិន្នុឃណ្ឌុ ១
និឃណ្ឌុ ១ ។ បនាទៈ ១ ឱបមញ្ញៈ ១ ទេវសូតៈ ១
មាតលិ ១ អតិចសេនៈ ១ គន្ធព្វៈ ១ នឡោរាជៈ ១
ជនោសភៈ ១ ។ សាតាគិរៈ ១ ហេមវតៈ ១ បុណ្ណកៈ ១

ករតិយៈ ១ គុលៈ ១ សិវកៈ ១ មុចលិន្ទៈ ១ វេស្សា-
មិត្តៈ ១ យុគន្ធរៈ ១ ។ គោបាលៈ ១ សុប្បគេធៈ ១ ហិរិ
១ នេត្តិ ១ មន្ទិយៈ ១ បញ្ចាលចន្ទៈ ១ អាលវកៈ ១
បជុណ្ណៈ ១ សុមុខៈ ១ ទធិមុខៈ ១ មណិ ១ មានិចរៈ
១ ទីឃៈ ១ សេរិសកៈ ១ ។

[ ៨៧ ] ត្រូវពោលទោស ត្រូវកន្ទក់កន្ទេញ ត្រូវស្រែកប្តឹងដល់ពួកយក្ខ ពួកមហាយក្ខ ពួកសេនាបតី ពួកមហាសេនាបតី ទាំងអម្បាលនេះថា យក្ខនេះចាប់គេ យក្ខនេះចូលគេ យក្ខនេះបៀតបៀនគេ យក្ខនេះបៀតបៀនផ្សេងៗ យក្ខនេះធ្វើទុក្ខគេ យក្ខនេះធ្វើគេឲ្យលំបាក យក្ខនេះមិនលែងគេ ។

[ ៨៨ ] បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ការរក្សាជាប់តមកអំពីអាដានាដានគរនេះឯង ប្រព្រឹត្តទៅដើម្បីគ្រប់គ្រងរក្សា ដើម្បីមិនបៀតបៀនគ្នា ដើម្បីនៅជាសុខដល់ពួកភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកា ។ បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ណ្ហើយឥឡូវនេះ ពួកខ្ញុំព្រះអង្គមានរវល់ច្រើន មានកិច្ចគួរធ្វើច្រើន ខ្ញុំព្រះអង្គសូមក្រាបថ្វាយបង្គំលា ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បពិត្រមហារាជទាំងឡាយ ចូរព្រះអង្គកំណត់កាលគួរ ក្នុងកាលឥឡូវនេះចុះ ។

[ ៨៩ ] លំដាប់នោះ ស្តេចធំទាំង ៤ អង្គក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយ ក៏បាត់ទៅក្នុងទីនោះឯង ។ យក្ខទាំងអម្បាលនោះ លុះក្រោកចាកអាសនៈហើយ ពួកខ្លះ ថ្វាយបង្គំព្រះមានព្រះភាគធ្វើប្រទក្សិណហើយ ក៏បាត់ទៅក្នុងទីនោះ ពួកខ្លះគ្រាន់តែពោលពាក្យ

រាក់ទាក់សំណេះសំណាលជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររព្ញកហើយ ក៏បាត់ទៅក្នុងទីនោះ ពួកខ្លះ គ្រាន់តែប្រណម្យអញ្ជលីចំពោះព្រះមានព្រះភាគហើយ ក៏បាត់ទៅក្នុងទីនោះ ពួកខ្លះ គ្រាន់តែប្រកាសនាម និងគោត្ររបស់ខ្លួន ហើយក៏បាត់ទៅក្នុងទីនោះ ពួកខ្លះ គ្រាន់តែនៅស្ងៀមហើយ ក៏បាត់ទៅក្នុងទីនោះ ។

[ ៩០ ] លុះកន្លងរាត្រីនោះទៅហើយ ទើបព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ យប់មិញ ពួកស្តេចធំទាំង ៤ តាំងការរក្សាក្នុងទិសទាំង ៤ តាំងពលទុកក្នុងទិសទាំង ៤ តាំងអ្នកត្រួតត្រាទុកក្នុងទិសទាំង ៤ ដោយសេនាយក្ខដ៏ច្រើន សេនាគន្ធព្វដ៏ច្រើន សេនាកុម្ភណ្ឌដ៏ច្រើន សេនានាគដ៏ច្រើន លុះវេលារាត្រីកន្លងទៅហើយ ស្តេចទាំងនោះមានពន្លឺរុងរឿង ញុំាំងភ្នំគិជ្ឈកូដទាំងមូលឲ្យភ្លឺស្វាងហើយ ក៏នាំគ្នាចូលមករកតថាគត លុះចូលមកដល់ហើយ ក៏ថ្វាយបង្គំតថាគត អង្គុយក្នុងទីដ៏សមគួរ ។ ម្នាលភិក្ខុទាំងឡាយ យក្ខទាំងអម្បាលនោះឯង ពួកខ្លះថ្វាយបង្គំតថាគតហើយ អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះ គ្រាន់តែពោលពាក្យរាក់ទាក់សំណេះសំណាល ជាមួយនឹងតថាគត លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររព្ញកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះ គ្រាន់តែប្រណម្យអញ្ជលីចំពោះតថាគត អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះ គ្រាន់តែប្រកាសនាមនិងគោត្រ អង្គុយក្នុងទីដ៏សមគួរ ពួកខ្លះ គ្រាន់តែអង្គុយស្ងៀមៗ ក្នុងទីដ៏សមគួរ ។ ម្នាលភិក្ខុទាំងឡាយ ស្តេចជាធំ ទ្រង់ព្រះនាមវេស្សវ័ណ លុះ

អន្តយក្ខក្នុងទីដ៏សមគួរហើយ ក៏ពោលពាក្យនឹងគាថាគតយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកយក្ខជាន់ខ្ពស់ មិនជ្រះថ្លាចំពោះព្រះមានព្រះភាគក៏មាន បពិត្រព្រះអង្គដ៏ចម្រើន ពួកយក្ខជាន់ខ្ពស់ជ្រះថ្លាចំពោះព្រះមានព្រះភាគក៏មាន បពិត្រព្រះអង្គដ៏ចម្រើន ពួកយក្ខជាន់កណ្តាលខ្លះ មិនជ្រះថ្លាចំពោះព្រះមានព្រះភាគក៏មាន បពិត្រព្រះអង្គដ៏ចម្រើន ពួកយក្ខជាន់កណ្តាលជ្រះថ្លាចំពោះព្រះមានព្រះភាគក៏មាន បពិត្រព្រះអង្គដ៏ចម្រើន ពួកយក្ខជាន់ទាបមិនជ្រះថ្លាចំពោះព្រះមានព្រះភាគក៏មាន បពិត្រព្រះអង្គដ៏ចម្រើន ពួកយក្ខជាន់ទាបជ្រះថ្លាចំពោះព្រះមានព្រះភាគក៏មាន បពិត្រព្រះអង្គដ៏ចម្រើន ឯយក្ខដែលមិនជ្រះថ្លាចំពោះព្រះមានព្រះភាគមានច្រើនណាស់ ព្រោះហេតុអ្វី បពិត្រព្រះអង្គដ៏ចម្រើន ព្រោះថា ព្រះមានព្រះភាគទ្រង់សម្តែងធម៌ ដើម្បីឲ្យវៀរចាកបាណាតិបាត ទ្រង់សម្តែងធម៌ដើម្បីឲ្យវៀរចាកអទិន្នាទាន ទ្រង់ សម្តែងធម៌ដើម្បីឲ្យវៀរចាកកាមេសុមិច្ឆាចារ ទ្រង់សំដែងធម៌ដើម្បីឲ្យវៀរចាកមុសាវាទ ទ្រង់សម្តែងធម៌ដើម្បីឲ្យវៀរចាកទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ។ បពិត្រព្រះអង្គដ៏ចម្រើន ប៉ុន្តែ យក្ខទាំងឡាយច្រើនណាស់ ដែលមិនវៀរចាកបាណាតិបាត មិនវៀរចាកអទិន្នាទាន មិនវៀរចាកកាមេសុមិច្ឆាចារ មិនវៀរចាកមុសាវាទ មិនវៀរចាកទឹកស្រវឹង គឺសុរា និងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទសោះ ( ព្រោះហេតុនោះ ) អំពើវៀរនោះ មិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត របស់យក្ខទាំងឡាយនោះ បពិត្រព្រះអង្គដ៏ចម្រើន មានសាវ័ករបស់ព្រះមានព្រះភាគ អាស្រ័យនៅ

សេនាសនៈស្ងាត់ ដែលតាំងនៅក្នុងព្រៃ មានសូរសព្ទតិចតួចរំពងតិច ប្រាសចាកសម្លីរបស់មនុស្សអ្នកដើរទៅមក សមគួរដល់ការកំបាំងអំពីពួកមនុស្ស គួរជាទីលាក់ខ្លួនពួនអាត្មាបាន ពួកយក្ខជាន់ខ្ពស់តែងនៅជានិច្ចក្នុងព្រៃនោះ ក៏មាន បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់បង្រៀនព្រះបរិត្ត សម្រាប់រក្សាក្នុងអាដានាដានគរ ដើម្បីឲ្យពួកយក្ខដែលមិនទាន់ជ្រះថ្លាក្នុង សាសនាព្រះមានព្រះភាគនេះ បានជ្រះថ្លាឡើង ដើម្បីការគ្រប់គ្រងរក្សា ដើម្បី មិនបៀតបៀនគ្នា ដើម្បីនៅជាសុខដល់ភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកា ។ ម្នាលភិក្ខុទាំងឡាយ តថាគតបានទទួលនិមន្តន៍ដោយតុណ្ហីភាព ។ ម្នាលភិក្ខុ ទាំងឡាយ លំដាប់នោះឯង ស្តេចជាធំឈ្មោះវេស្សវ័ណជ្រាបច្បាស់ នូវតថាគត ទទួលនិមន្តន៍ហើយ ក៏ប្រកាសព្រះបរិត្តសម្រាប់រក្សាក្នុងអាដានាដានគរនេះ ក្នុងវេលានោះថា

[ ៩១ ] សូមនមស្ការចំពោះព្រះពុទ្ធ ទ្រង់ព្រះនាមវិបស្សី
ព្រះអង្គមានចក្ខុ ព្រះអង្គមានសិរី សូមនមស្ការចំពោះព្រះ
ពុទ្ធ ទ្រង់ព្រះនាមសិខី ព្រះអង្គមានសេចក្តីអនុគ្រោះដល់
សត្វទាំងពួងជាប្រក្រតី ។បេ។

( បេយ្យាលៈ ដែលមានហើយក្នុងខាងដើមនោះឯង បណ្ឌិតគប្បីឲ្យពិស្តារចុះ ) ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ការរក្សាជាប់ទាក់ទងក្នុងអាដានាដា-នគរនេះ ប្រព្រឹត្តទៅដើម្បីគ្រប់គ្រងរក្សា ដើម្បីមិនបៀតបៀនគ្នា ដើម្បីនៅជាសុខដល់ពួកភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកា ។ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខណ្ហើយឥឡូវនេះ ពួកខ្ញុំព្រះអង្គមានរវល់ច្រើន មានកិច្ចគួរធ្វើច្រើន ខ្ញុំព្រះអង្គសូមថ្វាយបង្គំលា ។ តថាគតពោលតបថា បពិត្រមហារាជ សូមព្រះអង្គទ្រង់កំណត់កាលគួរ ក្នុងកាលឥឡូវនេះ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង ស្តេចជាធំទាំង ៤ ក្រោកចាកអាសនៈ ហើយថ្វាយបង្គំតថាគត ធ្វើប្រទក្សិណ ហើយក៏បាត់ទៅក្នុងទីនោះឯង ។ ម្នាលភិក្ខុទាំងឡាយ យក្ខទាំងអម្បាលនោះឯង លុះក្រោកចាកអាសនៈហើយ ពួកខ្លះ ថ្វាយបង្គំតថាគតធ្វើប្រទក្សិណ ហើយក៏បាត់ទៅក្នុងទីនោះ ពួកខ្លះគ្រាន់តែពោលពាក្យរាក់ទាក់សំណេះសំណាលជាមួយនឹងតថាគត លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭក ហើយក៏បាត់ទៅក្នុងទីនោះ ពួកខ្លះ គ្រាន់តែប្រណម្យ-អញ្ជលីចំពោះតថាគត ហើយក៏បាត់ទៅក្នុងទីនោះ ពួកខ្លះ គ្រាន់តែប្រកាសនាម និងគោត្រ ហើយក៏បាត់ទៅក្នុងទីនោះ ពួកខ្លះ គ្រាន់តែស្ងៀមៗ ហើយក៏បាត់ទៅក្នុងទីនោះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូររៀនព្រះបរិត្ត

សម្រាប់រក្សាក្នុងអាដានាដានគរ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរទន្ទេញឲ្យចាំស្ទាត់នូវព្រះបរិត្ត សម្រាប់រក្សាក្នុងអាដានាដានគរ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរចាំទុកនូវព្រះបរិត្ត សម្រាប់រក្សាក្នុងអាដានាដានគរ ម្នាលភិក្ខុទាំងឡាយ ការរក្សាក្នុងអាដានាដានគរនេះ ប្រកបដោយប្រយោជន៍ ប្រព្រឹត្តទៅដើម្បីគ្រប់គ្រងរក្សា ដើម្បីមិនបៀតបៀន ដើម្បីនៅជាសុខដល់ពួកភិក្ខុ ភិក្ខុនី ឧបាសក និងឧបាសិកា ។ លុះព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ។ ភិក្ខុទាំងនោះ មានចិត្តត្រេកអរទទួលអនុមោទនានឹងភាសិតរបស់ព្រះមានព្រះភាគ ដោយប្រការដូច្នេះ ។

**អាដានាដិយសូត្រទី ៩ ចប់**

# អដ្ឋកថា

## អាដានាដិយសូត្រ

[ ៧៨ ] *អាដានាដិយសូត្រមានពាក្យផ្តើមថា* **ឯវម្មេ សុតំ** *ដូច្នេះ ។ តទៅនេះជាពណ៌នាបទ តាមលំដាប់ក្នុងសូត្រនោះ ។ បទថា* **ចតុទ្ទិសំ រក្ខំ ឋបេត្វា** *សេចក្តីថា រៀបចំការរក្សាដល់សក្កទេវរាជដែលជាស្តេចទេវតាទាំង-ឡាយ ក្នុងទិសទាំង ៤ ដើម្បីការពារទ័ពអសុរ ។ បទថា* **គុម្ពំ ឋបេត្វា** *គឺរៀបចំកងទ័ព ។ បទថា* **ឱវរណំ ឋបេត្វា** *គឺមេទ័ពរក្សាការពារក្នុងទិសទាំង ៤ ។ អធិប្បាយថា ស្តេចមហារាជទាំង ៤ បានចាត់ចែងរក្សាយ៉ាងល្អដល់សក្កទេវរាជយ៉ាងនេះ គង់ក្នុងអាដានាដានគរ ប្រារព្ធដល់ព្រះពុទ្ធទាំងឡាយ ៧ ព្រះអង្គ ហើយចងគ្រឿងការពារនេះ ហើយប្រកាសថា នរណាមិនស្តាប់ធម្ម-អាជ្ញារបស់ព្រះសាស្តា និងរាជអាជ្ញារបស់យើង យើងនឹងធ្វើវត្តនេះ វត្តនេះ ដល់អ្នកនោះ ដូច្នេះ ហើយចាត់ចែងរក្សាដោយសេនា ៤ ពួក មានសេនា-បតីយក្ខជាដើម ក្នុងទិសទាំង ៤ របស់ខ្លួន កាលរាត្រីកន្លងទៅហើយ ។បេ។ អង្គុយក្នុងកន្លែងដ៏សមគួរមួយ ។*

**អភិក្កន្ត** *សព្ទ ក្នុងបទនេះថា* **អភិក្កន្តាយ រត្តិយា** *នេះ រមែងប្រាកដក្នុងអត្ថថា អស់ទៅ ល្អក្រៃលែង រុងរឿងក្រៃលែង ត្រេកអរក្រៃលែង ។*

**អភិក្កន្ត** *សព្ទ ប្រាកដក្នុងការអស់ទៅ ដូចក្នុងប្រយោគជាដើមថា* **អភិក្កន្តា ភន្តេ រត្តិ និក្ខន្តោ បឋមោ យាមោ ចិរនិសិន្នោ ភិក្ខុសង្ឃោ ឧទ្ទិសតុ ភន្តេ ភគវា ភិក្ខូនំ ចាតិមោក្ខំ** *បពិត្រព្រះអង្គដ៏ចម្រើន វេលារាត្រី*

អស់ហើយ បឋមយាមកន្លងទៅហើយ ភិក្ខុសង្ឃអង្គុយចាំយូរហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ទ្រង់សម្ដែងបាតិមោក្ខដល់ភិក្ខុទាំងឡាយ ។

ប្រាកដក្នុងអត្ថថា ល្អក្រៃលែង ដូចក្នុងប្រយោគជាដើមថា **អយំ ឥមេសំ ចតុន្នំ បុគ្គលានំ អភិក្កន្តតរោ ច បណីតតរោ ច** បណ្ដាបុគ្គលទាំង ៤ ពួកនេះ បុគ្គលនេះល្អជាងផង ប្រសើរជាងផង រមែងគាប់ចិត្តដល់ខ្ញុំព្រះអង្គ ដូច្នេះ ។

ប្រាកដក្នុងអត្ថថា រុងរឿងក្រៃលែង ដូចក្នុងប្រយោគជាដើមថា **កោ មេ វន្ទតិ បាទានិ ឥទ្ធិយា យសសា ជលំ អភិក្កន្តេន វណ្ណេន សព្វា ឱភាសយំ ទិសា** អ្នកណាហ្ន៎ រុងរឿងដោយឫទ្ធិ និងយស មានសម្បុរល្អ ញុំាងទិសទាំងពួងឲ្យភ្លឺ មកថ្វាយបង្គំបាទានៃតថាគត ។

ប្រាកដក្នុងអត្ថថា គួរត្រេកអរក្រៃលែង ដូចក្នុងប្រយោគជាដើមថា **អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម** បពិត្រព្រះគោតមដ៏ចម្រើន គួរត្រេកអរក្រៃលែង បពិត្រព្រះគោតមដ៏ចម្រើន គួរត្រេកអរក្រៃលែង ដូច្នេះ ។ ដោយហេតុនោះ ទើបលោកពោលថា រាត្រីកន្លងទៅ គឺរាត្រីអស់ទៅ ដូច្នេះ ។ **អភិក្កន្ត** សព្ទ ក្នុងបទនេះថា មានរស្មីល្អក្រៃលែង ប្រព្រឹត្តទៅក្នុងរូបល្អក្រៃលែង ។

តែ **វណ្ណ** សព្ទ រមែងប្រាកដក្នុងអត្ថថា ពណ៌សម្បុរ សរសើរ ត្រកូល ហេតុ សណ្ឋាន ប្រមាណ រូបាយតនៈជាដើម ។ ក្នុងបទទាំងឡាយនោះ **វណ្ណ**

សព្ទ ប្រព្រឹត្តទៅក្នុងអត្ថថា ពណ៌សម្បុរ ដូចក្នុងប្រយោគជាដើមថា **សុវណ្ណវណ្ណោសិ ភគវា** បពិត្រព្រះមានបុណ្យ ទ្រង់មានសម្បុរដូចមាស ។ **វណ្ណ** សព្ទ ប្រព្រឹត្តទៅក្នុងអត្ថថា សរសើរ ដូចក្នុងប្រយោគជាដើមថា **កទា សញ្ញូឡ្ហា បន តេ គហបតិ ឥមេ សមណស្ស គោតមស្ស វណ្ណា** ម្នាលគហបតី ចុះគុណរបស់សមណគោតមទាំងអម្បាលនេះ អ្នកប្រមូលមក អំពីកាលណា ដូច្នេះ ។ ប្រព្រឹត្តទៅអត្ថថា ត្រកូល ដូចក្នុងប្រយោគជាដើមថា **ចត្តារោ មេ ភោ គោតម វណ្ណា** ព្រះគោតមដ៏ចម្រើន វណ្ណ ( ត្រកូល ) ទាំង ៤ នេះ ដូច្នេះ ។ ប្រព្រឹត្តទៅក្នុងសេចក្តីថា ហេតុ ដូចក្នុងប្រយោគជាដើមថា **អថ កេន នុ វណ្ណេន គន្ធត្ថេនោតិ វុច្ចតិ** ចុះហេតុដូចម្តេច បានជាអ្នកនិយាយថា អាត្មាលួចក្លិន ។ ប្រព្រឹត្តទៅក្នុងសេចក្តីថា សណ្ឋាន ដូចក្នុងប្រយោគជាដើមថា **មហន្តំ ហត្ថិរាជវណ្ណំ អភិនិម្មិនិត្វា** មារមានចិត្តបាបក៏និម្មិតភេទជាស្តេចដំរីធំ ។ ប្រព្រឹត្តទៅក្នុងសេចក្តីថា ប្រមាណ ដូចក្នុងប្រយោគជាដើមថា **តយោ បត្តស្ស វណ្ណា** ខ្នាតនៃបាត្រមាន ៣ យ៉ាង ។ ប្រព្រឹត្តទៅក្នុងអត្ថថា រូបាយតនៈ ដូចក្នុងប្រយោគជាដើមថា **វណ្ណោ គន្ធោ រសោ ឱជា** រូប ក្លិន រស ឱជៈ ដូច្នេះ ។

**វណ្ណ** សព្ទនោះ ក្នុងទីនេះគប្បីជ្រាបថា ប្រព្រឹត្តទៅក្នុងអត្ថថា ពណ៌សម្បុរ ។ ដោយហេតុនេះ ទើបលោកពោលថា **អភិក្កន្តវណ្ណា** ដូច្នេះ ។

**កេវល** សព្ទ ក្នុងបទថា **កេវលកប្បំ** នេះ មានអត្ថមិនតិចដូចជាមិនមានចំណែកសេសសល់ ដោយច្រើន មិនមានលាយឡំ មិនលើស តម្កល់មាំ បែកគ្នាជាដើម ។ មានអធិប្បាយថា **កេវល** សព្ទ មកក្នុងអត្ថថា មិនមាន

ចំណែកសេសសល់ ដូចក្នុងប្រយោគជាដើមថា **កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ** ទ្រង់ប្រកាសព្រហ្មចរិយៈ ដ៏ពេញបរិបូណ៌បរិសុទ្ធទាំងអស់ ។ មកក្នុងអត្ថថា ដោយច្រើន ដូចក្នុងប្រយោគជាដើមថា **កេវកប្បា ច អង្គមគធា បហូតំ ខាទនីយំ ភោជនីយំ អាទាយ អភិក្កមិតុកាមា ហោន្តិ** ព្រោះថា ជនអ្នកនៅក្នុងដែនអង្គៈ និងមគធៈទាំងអស់គ្នា ប្រាថ្នានឹងនាំយកខាទនីយភោជនីយាហារ មានប្រមាណច្រើន ចូលមកបូជា ។ មកក្នុងអត្ថថា មិនលាយឡំ ដូចក្នុងប្រយោគជាដើមថា **កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ** សេចក្ដីកើតឡើងនៃកងទុក្ខសុទ្ធៗ ទាំងអស់នេះ រមែងមានយ៉ាងនេះឯង ។ មកក្នុងអត្ថថា មិនលើស ដូចក្នុងប្រយោគជាដើមថា **កេវលំ សទ្ធាមត្តកំ នូន អយមាយស្មា** ព្រោះអាស្រ័យនូវគុណធម៌ ត្រឹមសទ្ធាតែម្យ៉ាងដោយពិត ។ មកក្នុងអត្ថថា តម្កល់មាំ ដូចក្នុងប្រយោគជាដើមថា **កេវលកប្បំ សង្ឃភេទាយ ឋិតោ** សទ្ធិវិហារិករបស់អនុរុទ្ធដ៏មានអាយុ ឈ្មោះវាហិយៈ នៅតែទទូចដើម្បីបំបែកយ៉ាងមុតមាំ ។ មកក្នុងអត្ថថា បែកគ្នា ដូចក្នុងប្រយោគជាដើមថា **បញ្ចង្គ វិប្បហីនោ ភិក្ខវេ ភិក្ខុ បញ្ចង្គសមន្នាគតោ ឥមស្មឹ ធម្មវិនយេ កេវលី វុសិតវា ឧត្តមបុរិសោតិ វុច្ចតិ** ម្នាលភិក្ខុទាំងឡាយ ភិក្ខុលះអង្គ ៥ ប្រកបដោយអង្គ ៥ ហៅថា ជាឧត្តមបុរស មានគុណគ្រប់គ្រាន់[១] ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងធម្មវិន័យនេះ ដូច្នេះ ។ តែក្នុងទីនេះ

---

១- ក្នុងទីនេះ សាន្តែតមើលទៅ ដូចជាមិនឃើញ ពាក្យថា បែកគ្នា ឃើញពាក្យថា បរិបូណ៌ ឬគ្រប់គ្រាន់ទៅវិញ ។

**កេវល** សព្ទ លោកបំណងយកសេចក្តី គឺមិនមានចំណែកសេសសល់ ។

ម្យ៉ាងវិញទៀត **កប្ប** សព្ទនេះ មានអត្ថច្រើនយ៉ាង ដូចជា ការជឿយ៉ាងក្រៃលែង វោហារ កាល បញ្ញត្តិ ការកាត់ វិកប្ប លេស ជុំវិញ ។ មានអធិប្បាយថា **កប្ប** សព្ទ មកក្នុងអត្ថថា ការជឿយ៉ាងក្រៃលែង ដូចក្នុងប្រយោគជាដើមថា **ឱកប្ប នីយមេតំ ភោតោ គោតមស្ស យថា តំ អរហតោ សម្មាសម្ពុទ្ធស្ស** ពាក្យរបស់ព្រះគោតមដ៏ចម្រើន ដែលជាអរហន្តសម្មាសម្ពុទ្ធនេះ ជាពាក្យគួរជឿពិតហើយ ។ មកក្នុងអត្ថថា វោហារ ដូចក្នុងប្រយោគជាដើមថា **អនុជានាមិ ភិក្ខវេ បញ្ចហិ សមណកប្បេហិ ផលំ បរិភុញ្ជិតុំ** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់ផ្លែឈើ ដោយសមណកប្ប ៥ យ៉ាង ។ មកក្នុងអត្ថថា កាល ដូចក្នុងប្រយោគជាដើមថា **យេន សុទំ និច្ចកប្បំ វិហរាមិ** តថាគតនោះឯង តែងនៅអស់កាលជានិច្ច ។ មកក្នុងអត្ថថា បញ្ញត្តិ ដូចក្នុងប្រយោគជាដើមថា **ឥច្ចា យស្មា កប្បោ** កប្បមាណពដ៏មានអាយុទូលសួរថា ។ មកក្នុងអត្ថថា ការកាត់ ដូចក្នុងប្រយោគជាដើមថា **អលង្កតោ មាល្យធរោ សុវត្ថោ សុកុណ្ឌលី កប្បិតកេសមស្សុ** អ្នកមានខ្លួនប្រដាប់ហើយ ទ្រទ្រង់នូវកម្រងផ្កា ស្លៀកដណ្តប់ល្អ មានប្រដាប់ត្រចៀកល្អ មានសក់ និងពុកចង្កាកាត់ចោលហើយ ។ មកក្នុងអត្ថថា វិកប្ប ដូចក្នុងប្រយោគជាដើមថា **កប្បតិ ទ្វង្គុលកប្បោ** កំណត់ដោយស្រមោលព្រះអាទិត្យជ្រេទៅប្រមាណ ២ ធ្នាប់គួរ ។ មកក្នុងអត្ថថា លេស ដូចក្នុងប្រយោគជាដើមថា **អត្ថិ កប្បោ និបជ្ជិតុំ** បើដូច្នោះ អាត្មាអញដេកសិន ។

មកក្នុងអត្ថថា ដោយជុំវិញ ដូចក្នុងប្រយោគជាដើមថា **កេវលកប្បំ គិជ្ឈកូដំ ឱភាសេត្វា** ញុំាងភ្នំគិជ្ឈកូដឲ្យភ្លឺស្វាងដោយជុំវិញ ។ **កប្ប** សព្ទ ក្នុងទីនេះ លោកបំណងយកអត្ថថា ដោយជុំវិញ ព្រោះដូច្នោះ ក្នុងបទនេះថា ញុំាងភ្នំគិជ្ឈកូដទាំងអស់ឲ្យភ្លឺស្វាង ដូច្នេះ គប្បីឃើញសេចក្តីយ៉ាងនេះថា ញុំាងភ្នំគិជ្ឈកូដឲ្យភ្លឺស្វាងដោយជុំវិញ មិនមានចំណែកសល់ ។

បទថា **ឱភាសេត្វា** សេចក្តីថា ផ្សាយព្រះរស្មីអំពីសរីរៈ ដែលប្រដាប់ដោយសំពត់ និងផ្កា អធិប្បាយថា ធ្វើឲ្យមានពន្លឺតែមួយ ឲ្យរុងរឿងតែម្យ៉ាងដូចព្រះចន្ទ និងព្រះអាទិត្យ ។ បទថា **ឯកមន្តំ និសីទឹសុ** សេចក្តីថា ឈ្មោះថាអាសនៈរបស់ទេវតាទាំងឡាយ ក្នុងសម្នាក់ព្រះទសពលមិនច្រើន ។ តែក្នុងព្រះសូត្រនេះ ពួកទេវតាអង្គុយដោយសេចក្តីគោរពព្រះបរិត្ត ។

[ ៧៩ ] បទថា **វេស្សវណោ** សេចក្តីថា ស្តេចមហារាជទាំង ៤ យាងមកក៏ពិត តែស្តេចវេស្សវណ ជាអ្នកស្និទ្ធស្នាលនឹងព្រះទសពល ឈ្លាសក្នុងការក្រាបទូល មានការសិក្សាយ៉ាងល្អ ព្រោះដូច្នោះ ទើបស្តេចវេស្សវណមហារាជ បានក្រាបទូលចំពោះព្រះមានព្រះភាគ ។ បទថា **ឧឡារា** គឺជាអ្នកមានសក្តិធំ ដល់ព្រមដោយអានុភាព ។ បទថា **ទាណាតិបាតា វេរមណិយា** សេចក្តីថា ព្រះមានព្រះភាគទ្រង់សម្តែងទោស ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងភពខាងមុខ ក្នុងបាណាតិបាត ហើយទ្រង់សម្តែងធម៌ ដើម្បីឲ្យវៀរចាកបាណាតិបាតនោះ ។ ក្នុងបទដ៏សេស ក៏ន័យនេះឯង ។ បទថា **តត្ថ សន្តិ ឧឡារា យក្ខា និវាសិនោ** សេចក្តីថា ក្នុងសេនាសនៈទាំងនោះ មានយក្ខជាន់

ខ្ពស់ស្នាក់នៅជាប្រចាំ ។ បទថា **អាដានាដិយំ** សេចក្តីថា ឈ្មោះយ៉ាងនេះ ព្រោះចងឡើងក្នុងអាដានាដានគរ ។ សួរថា ឈ្មោះថា ធម៌ដែលមិនជាក់ច្បាស់ មានហើយក្នុងព្រះមានព្រះភាគឬ ឆ្លើយថា មិនមាន ។ សួរថា កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបស្តេចវេស្សវ័ណក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់រៀនអាដានាដិយៈ រក្សាចុះ ដូច្នេះ ឆ្លើយថា ដើម្បីរកឱកាស ។ ព្រោះថា វេស្សវ័ណមហារាជនោះ រង់ចាំឱកាសដើម្បីបានស្តាប់ព្រះបរិត្តនេះជាមួយព្រះមានព្រះភាគ ទើបក្រាបទូលយ៉ាងនេះ ។ បុរាណកបណ្ឌិតពោលថា កាលវេស្សវ័ណក្រាបទូលចំពោះព្រះមានព្រះភាគហើយ ព្រះបរិត្តនេះនឹងជាគ្រូ ដូច្នេះខ្លះ ។ បទថា **ផាសុវិហារាយ** សេចក្តីថា ដើម្បីនៅជាសុខក្នុងឥរិយាបថទាំង ៤ មានដើរ ឈរជាដើម ។

[ ៨០ ] បទថា **ចក្ខុមន្តស្ស** សេចក្តីថា មិនមែនព្រះវិបស្សីសម្ពុទ្ធប៉ុណ្ណោះមានចក្ខុ សូម្បីព្រះពុទ្ធ ៧ ព្រះអង្គ ក៏មានចក្ខុ ព្រោះដូច្នោះ ព្រះពុទ្ធមួយអង្គៗ រមែងមានឈ្មោះ ៧ យ៉ាងនេះ ។ ព្រះពុទ្ធទាំងឡាយក៏មានចក្ខុទ្រង់អនុគ្រោះសត្វទូទៅ ទ្រង់ជម្រះកិលេស ព្រោះមានកិលេស ដែលទ្រង់ជម្រះហើយ ទ្រង់ញាំញីមារ និងសេនា ទ្រង់នៅចប់ព្រហ្មចរិយៈ ទ្រង់ផុតវិសេសហើយ មានព្រះនាមថា អង្គីរស ព្រោះរស្មីចេញចាកព្រះវរកាយ ។ ម្យ៉ាងទៀត ឈ្មោះទាំង ៧ នេះ មិនមែនរបស់ព្រះពុទ្ធទាំងឡាយ ដោយឥតសេសសល់នោះទេ ។ លោកពោលថា អ្នកស្វែងរកគុណធំ ព្រោះមានគុណរាប់មិនអស់ ។ វេស្សវ័ណមហារាជពោលយ៉ាងនេះ ដោយអំណាចព្រះនាម

ដែលប្រាកដដល់ខ្លួន ។ ក្នុងបទថា **តេ ជនា** នេះ លោកបំណងដល់បុគ្គលជាទីណាស្រេច ។ បទថា **អបិសុណា** នេះ ត្រឹមតែជាកំពូលនៃទេសនា អធិប្បាយថា មិននិយាយកុហក មិននិយាយញុះញង់ មិននិយាយទ្រគោះ និយាយល្មមប្រមាណ ។ បទថា **មហន្តា** សេចក្តីថា ដល់ភាពជាបុគ្គលធំក្រៃលែង ។ បាលីថា **មហត្តា** ដូច្នេះក៏មាន សេចក្តីថា ធំ ។ បទថា **វីត-សារទា** គឺមិនមានសេចក្តីព្រឺស្ញើប ប្រាសចាកការព្រឺរោម ព្រឺស្បែក ។ បទថា **ហិតំ** គឺជាប្រយោជន៍ដោយការផ្សាយមេត្តា ។ បទថា **យំ** ក្នុងបទនេះថា **យំ នមស្សន្តិ** ត្រឹមតែជានិបាត ។ បទថា **មហន្តំ** បានដល់ ធំ ។ ម្យ៉ាងទៀត បាលីក៏យ៉ាងនេះ ។ លោកពោលបទនេះទុកថា **យេ ចាបិ និព្វុតា លោកេ** សេចក្តីថា ព្រះពុទ្ធទាំងឡាយ រម្ងត់ហើយដោយការរម្ងត់កិលេស ទ្រង់ឃើញច្បាស់តាមសេចក្តីពិត ។ ម្យ៉ាងទៀត ទេវតា និងមនុស្សទាំងឡាយនមស្ការព្រះគោតម ទ្រង់អនុគ្រោះដល់ទេវតា និងមនុស្សទាំងឡាយ ទ្រង់បរិបូណ៌ដោយគុណ មានវិជ្ជាជាដើម ព្រះពុទ្ធទាំងឡាយនោះ មិនត្រាស់ពាក្យញុះញង់ សូមកិរិយានមស្ការ មានដល់ព្រះពុទ្ធទាំងនោះ ។ តែក្នុងអដ្ឋកថាពោលថា បទថា **តេ ជនា អបិសុណា** សេចក្តីថា ព្រះពុទ្ធទាំងឡាយនោះជាអ្នកមិនញុះញង់ ដូច្នេះ ។ វេស្សវ័ណមហារាជ ពោលសរសើរព្រះពុទ្ធទាំង-ឡាយ ដោយបឋមគាថាយ៉ាងនេះ ព្រោះដូច្នោះ វេស្សវ័ណមហារាជ ពោលបឋមគាថាបទ ដោយអំណាចនៃព្រះពុទ្ធទាំងឡាយ ៧ ព្រះអង្គ ។ បទថា **គោតមំ** ក្នុងគាថាទីពីរនេះ ត្រឹមតែជាប្រធាននៃទេសនា ។ គប្បីជ្រាបគាថា

ទី ២ នេះថា វេស្សវ័ណមហារាជ ពោលដោយអំណាចរបស់ព្រះពុទ្ធទាំង ៧ ព្រះអង្គដូចគ្នា ។ ក្នុងបទនេះ មានអធិប្បាយដូច្នេះថា ទេវតា និងមនុស្ស ទាំងឡាយ ដែលជាបណ្ឌិតក្នុងលោក រមែងនមស្ការព្រះគោតមព្រះអង្គណា កិរិយានមស្ការ សូមមានដល់ព្រះគោតមនោះ និងព្រះពុទ្ធទាំងឡាយដែលមាន មកអំពីមុនព្រះគោតមនោះ ។

[ ៨១ ] បទថា **យតោ ឧគ្គច្ឆតិ** សេចក្តីថា រះឡើងអំពីកន្លែងណា ។ បទថា **អាទិច្ចោ** បានដល់ បុត្ររបស់ព្រះអាទិត្យ ។ ម្យ៉ាងទៀត បទនេះ ត្រឹមតែជាវេវចនៈរបស់ **សុរិយ** សព្ទ ។ ព្រះអាទិត្យ ឈ្មោះថា **មណ្ឌលី មហា** ព្រោះមានមណ្ឌលធំ ។ បទថា **យស្ស ចុគ្គច្ឆមានស្ស** សេចក្តីថា កាលព្រះ អាទិត្យណាកំពុងរះ ។ បទថា **សំវរីបិ និរុជ្ឈតិ** សេចក្តីថា ពេលយប់រមែង បាត់ទៅ ។ បទថា **យស្ស ចុគ្គតេ** សេចក្តីថា កាលព្រះអាទិត្យរះឡើងហើយ ។ បទថា **រហទោ** សេចក្តីថា អន្លង់ទឹក ។ បទថា **តត្ថ** សេចក្តីថា ក្នុងទីដែល ព្រះអាទិត្យរះ ។ បទថា **សមុទ្ទោ** គឺសមុទ្រណា លោកពោលថា ជាអន្លង់ទឹក សមុទ្រនោះមិនមែនដទៃ គឺសមុទ្រនោះឯង ។ បទថា **សរិតោទកោ** គឺទឹកហូរ ជន់ សេចក្តីថា ស្ទឹងទាំងឡាយមានប្រការផ្សេងៗ ផ្សាយពេញទៅ ឬហូរចូល ទៅក្នុងទឹករបស់សមុទ្រនោះ ព្រោះហេតុនោះ ទើបឈ្មោះថា សមុទ្រ មានទឹក ពេញប្រៀប ។ បទថា **ឯវន្តំ តត្ថ ជានន្តិ** សេចក្តីថា រមែងដឹងអន្លង់ទឹកនោះ ក្នុងទីនោះយ៉ាងនេះ ។ សួរថា តើដឹងបានយ៉ាងដូចម្តេច ឆ្លើយថា ដឹងបាន យ៉ាងនេះថា សមុទ្រមានទឹកពេញប្រៀប ដូច្នេះ ។ បទថា **ឥតោ** សេចក្តីថា

ពីក្នុំសិនេរុ ឬពីកន្លែងដែលពួក ទេវតាទាំងនោះអង្គុយ ។ បទថា **ជនោ** គឺ មហាជននេះ ។ បទថា **ឯកនាមា** គឺមានឈ្មោះតែមួយថា **ឥន្ទ** ។ បានឮថា មហារាជទាំង ៤ បានតាំងឈ្មោះរបស់សក្កទេវរាជ ឲ្យជាឈ្មោះរបស់ឱរស ទាំងនោះគ្រប់ព្រះអង្គ ។ បទថា **អសីតិ ទស ឯកោ ច** គឺបុត្រ ៩១ អង្គ ។ បទថា **ឥន្ទនាម** គឺមានឈ្មោះយ៉ាងនេះថា ឥន្ទៈ ឥន្ទៈ ។ បទថា **ពុទ្ធំ អាទិច្ច-ពន្ធុំ** សេចក្តីថា ទ្រង់ភ្ញាក់ហើយ ព្រោះប្រាសចាកកិលេសនិទ្រា ទ្រង់ជាផៅពង្ស ព្រះអាទិត្យ ព្រោះទ្រង់មានគោត្រស្មើនឹងព្រះអាទិត្យ ។ បទថា **កុសលេន សមេក្ខសិ** សេចក្តីថា ទ្រង់ពិចារណាមើលមហាជនដោយព្រះសព្វញ្ញុតញ្ញាណ ដែលមិនមានទោស និងល្អិតសុខុម ។ បទថា **អមនុស្សាបិ តំ វន្ទន្តិ** សេចក្តីថា អមនុស្សទាំងឡាយពោលថា ព្រះសម្ពុទ្ធទ្រង់ពិចារណាមើលមហាជន ដោយ សព្វញ្ញុតញ្ញាណហើយ ក៏នាំគ្នាថ្វាយបង្គំព្រះពុទ្ធអង្គនោះ ។ បទថា **សុតំ នេតំ អភិណ្ហសោ** សេចក្តីថា សេចក្តីនោះ ខ្ញុំព្រះអង្គទាំងឡាយបានស្តាប់រឿយៗ ។ បទថា **ជិនំ វន្ទាម គោតមំ** សេចក្តីថា ពួកខ្ញុំព្រះអង្គសួរគេថា ពួកលោក ថ្វាយបង្គំព្រះជិនគោតមឬ ជនទាំងនោះនាំគ្នាឆ្លើយថា ថ្វាយបង្គំព្រះជិនគោតម ។

[ ៨២ ] បទថា **យេន បេតា បវុច្ចន្តិ** សេចក្តីថា ជនដែលស្លាប់ហើយ ឈ្មោះថា **បេត** ជនទាំងឡាយនាំគ្នាពោលថា នាំបេតជនទាំងនោះចេញទៅ តាមទិសណា ។ បទថា **បិសុណា បិដ្ឋិមំសិកា** សេចក្តីថា អ្នកពោល ញុះញង់ទុះឯង ដូចជាស៊ីសាច់ខ្នង និងតិះដៀលកំបាំងមុខ ជនទាំងឡាយនាំគ្នា

ពោលថា នឹងនាំជនទាំងនេះចេញទៅតាមទិសណា ។ លោកពោលយ៉ាងនេះថា ជនទាំងឡាយនាំអ្នកទាំងអស់នោះ ចេញតាមទិសទក្សិណ ចូរជុត ឬចូរទម្លាយ ឬចូរសម្លាប់ ខាងទិសទក្សិណនៃព្រះនគរ ដូច្នេះ ។

បទថា **ឥតោ សា ទក្ខិណា ទិសា** សេចក្តីថា ជនទាំងឡាយនាំគ្នាពោលថា ចូរនាំអ្នកដែលពោលញុះញង់ជាដើម ដែលស្លាប់ទៅហើយ ចេញទៅតាមទិសខាងត្បូង អំពីនេះទៅទិសដែលជនទាំងឡាយហៅថា ទិសទក្សិណនោះ ។ បទថា **ឥតោ** សេចក្តីថា ពីភ្នំសិនេរុត្តិ កន្លែងដែលទេវតាទាំងនោះអង្គុយក្តី ។ បទថា **កុម្ភណ្ឌានំ** សេចក្តីថា បានឮថា ទេវតាទាំងនោះ ជាអ្នកមានពោះធំ ។ ម្យ៉ាងទៀត អណ្ឌៈរបស់ទេវតាទាំងនោះ ធំដូចថ្នាំង ព្រោះដូច្នោះទើបលោកពោលថា កុម្ភណ្ឌៈ ។

[ ៨៣ ] បទថា **យត្ថ ចោគ្គច្ឆតិ សុរិយោ** សេចក្តីថា ព្រះអាទិត្យអស្តង្គតដោយទិសាភាគណា ។ ដោយទិសាភាគនោះ ។

[ ៨៤ ] បទថា **មហានេរុ** គឺស្តេចភ្នំឈ្មោះ សិនេរុ ។ បទថា **សុទស្សនោ** គឺគួរមើល ព្រោះសម្រេចដោយមាស ព្រោះថា ទិសខាងកើតនៃភ្នំសិនេរុ សម្រេចដោយប្រាក់ ទិសទក្សិណសម្រេចដោយកែវមណី ទិសបច្ចិមសម្រេចដោយកែវផលិក ទិសឧត្តរសម្រេចដោយមាស ទិសឧត្តរនោះជាជាចំណែកដែលគួរមើលក្រៃលែង ព្រោះដូច្នោះ ភ្នំសិនេរុ ជាភ្នំដែលគួរមើល ដោយទិសាភាគណា នេះជាអត្ថសារៈក្នុងភ្នំសិនេរុនេះ ។ បទថា **មនុស្សា តត្ថ ជាយន្តិ** សេចក្តីថា មនុស្សទាំងឡាយកើតក្នុងឧត្តរកុរុទ្វីបនោះ ។ បទថា **អមមា** សេចក្តី

ថា វៀរចាកសេចក្ដីប្រកាន់ថា ជារបស់អញ សូម្បីក្នុងសំពត់អាភរណៈ ទឹកផឹក និងរបស់បរិភោគជាដើម ។ បទថា **អបរិគ្គហា** គឺមិនហួងហែង ដោយសេចក្ដីហួងហែងក្នុងស្ត្រី អធិប្បាយថា បានឮថា មនុស្សទាំងនោះ មិនមានការហួងហែងថា នេះភរិយារបស់អញ ។ តម្រេកដោយឆន្ទរាគៈរមែងមិនកើតឡើង ព្រោះឃើញមាតា ឬប្អូនស្រី ។ បទថា **ឆបិ ធីយន្តិ ឆន្ទលា** សេចក្ដីថា សូម្បីនង្គ័ល ក៏មិនត្រូវនាំចេញទៅកាន់ស្រែ ដោយបំណងថា អញនឹងធ្វើការងារកសិកម្មក្នុងស្រែនោះ ។ បទថា **អកដ្ឋបាកិមំ** សេចក្ដីថា ស្រូវសាលីដុះឡើងឯង ក្នុងព្រៃដែលជាផ្ទៃដីមិនចាំបាច់ភ្ជួរ ។ បទថា **តណ្ឌុលប្ផលំ** គឺអង្ករនោះឯង ជាផ្លែកើតឡើងក្នុងផ្ទៃដីនោះ ។ បទថា **តុណ្ឌិកិរេ បចិត្វាន** គឺចាក់អង្ករចូលទៅក្នុងឆ្នាំង ហើយចម្អិនដោយភ្លើងដែលប្រាសចាកផ្សែង និងផេះ ។ បានឮថា ក្នុងទីនោះ ឈ្មោះជោតិកបាសាណ ។ ទីនោះ ជនទាំងឡាយដាក់ថ្ម ៣ ដុំ ហើយលើកឆ្នាំងដាក់ ភ្លើងកើតឡើងអំពីថ្ម ហើយចម្អិនបាយនោះ ។ បទថា **តតោ ភុញ្ជន្តិ ភោជនំ** សេចក្ដីថា បរិភោគភោជននោះឯង អំពីឆ្នាំងនោះ ។ មិនមានសូបៈ ឬព្យញ្ជនៈដទៃ ។ ម្យ៉ាងទៀត រសរបស់បាយនោះ ជារសតម្រូវចិត្តរបស់អ្នកបរិភោគយ៉ាងល្អ ។ ជនទាំងនោះរមែងឲ្យដល់អ្នកមកដល់ទីនោះ ។ គ្រប់គ្នា ឈ្មោះថា ចិត្តកំណាញ់ មិនមាន ។ សូម្បីព្រះពុទ្ធ និងព្រះបច្ចេកពុទ្ធជាដើម ទ្រទ្រង់នូវឫទ្ធិច្រើន និមន្តទៅក្នុងទីនោះរមែងទទួលបិណ្ឌបាត ។

បទថា **គាវី ឯកខុរំ កត្វា** សេចក្ដីថា យក្ខទាំងឡាយអ្នកនៅបម្រើ

វេស្សវណ្ណមហារាជ ចាប់មេគោដែលមានក្រចកតែមួយ ជាពាហនៈដូចសេះ ហើយជិះមេគោនោះ ជាប់តាមទៅកាន់ទិសតូចទិសធំ គឺត្រាច់តាមទៅក្នុងទិសនោះៗ ។ បទថា **បសុំ ឯកខុរំ កត្វា** សេចក្តីថា ធ្វើបសុសត្វជើង ៤ ដ៏សេសវៀរមេគោ ឲ្យមានក្រចកតែមួយជាពាហនៈ ហើយជិះទៅកាន់ទិសតូចទិសធំ ។ បទថា **ឥត្ថី វាហនំ កត្វា** សេចក្តីថា ធ្វើមាតុគ្រាមមានគភ៌ ឲ្យជាពាហនៈ ហើយអង្គុយលើខ្នងមាតុគ្រាមនោះត្រាច់ទៅ ។ បានឮថា ខ្នងរបស់ស្ត្រីមានគភ៌នោះអាចអត់ទ្រាំក្នុងកាលឱនចុះ ។ ស្ត្រីក្រៅពីនេះ ប្រើទឹមជាយាន ។ បទថា **បុរិសំ វាហនំ កត្វា** សេចក្តីថា ចាប់បុរសមកទឹមជាយាន ។ម្យ៉ាងទៀត កាលចាប់មិនអាចចាប់អ្នកជាសម្មាទិដ្ឋិបាន ។ ដោយច្រើន ចាប់ពួកជនដែលរស់នៅជាយដែន និងមនុស្សព្រៃ ។ បានឮថា អ្នកជនបទណាមួយ ក្នុងជនទាំងនោះ អង្គុយដេកលក់ជិតព្រះថេរៈមួយរូប ។ ព្រះថេរៈសួរថា ឧបាសក អ្នកដេកលក់ហើយឬ បុរសនោះឆ្លើយថា ករុណាលោកម្ចាស់ ថ្ងៃនេះខ្ញុំអស់កម្លាំង ព្រោះបម្រើស្តេចវេស្សវណ្ណអស់មួយយប់ ។ បទថា **កុមារី វាហនំ កត្វា** សេចក្តីថា ចាប់ក្មេងស្រីធ្វើជាពាហនៈដើម្បីទឹមរថ ។ សូម្បីក្នុងការចាប់ក្មេងប្រុសធ្វើជាពាហនៈ ក៏មានន័យនេះឯង ។ បទថា **បចារា តស្ស រាជិនោ** សេចក្តីថា ស្ត្រីដែលជាអ្នកបម្រើរបស់ព្រះរាជានោះ ។ បទថា **ហត្ថិយានំ អស្សយានំ** សេចក្តីថា មិនមែនយានគោតែម្យ៉ាងប៉ុណ្ណោះ ជិះយានដំរី យានសេះជាដើមត្រាច់ទៅ ។ បទថា **ទិព្វំ យានំ** សេចក្តីថា យានទិព្វច្រើនយ៉ាងដទៃក៏បានប្រាកដដល់មនុស្សទាំងនោះ ។ យានទាំងនេះ ជាយាន

ចូលទៅដល់មនុស្សទាំងនោះមុន ។ ឯមនុស្សទាំងនោះ ដេកលើដំណេកដ៏ប្រសើរ ត្រង់ប្រាសាទ និងអង្គុយលើតាំង និងវជាដើមត្រាច់ទៅ ។ ដោយហេតុនោះ ទើបលោកពោលថា **បាសាទា សិវិកា ចេវ** ដូច្នេះ ។ បទថា **មហារាជស្ស យសស្សិនោ** សេចក្ដីថា យានទាំងនេះ រមែងកើតឡើងដល់មហារាជអ្នកមានយស អ្នកដល់ព្រមដោយអានុភាពយ៉ាងនេះ ។

បទថា **តស្ស ច ឆគរា អហុ អន្តលិក្ខេ សុមាបិតា** សេចក្ដីថា ព្រះរាជានោះ ទ្រង់បាននិម្មិតនគរ មានអាដានាដានគរជាដើមទាំងនោះ ទុកក្នុងអាកាស គឺនគរទាំងឡាយមានហើយ ។ ឯនគរមួយរបស់មហារាជនោះ បានឈ្មោះអាដានាដា នគរមួយឈ្មោះកុសិនាដា នគរមួយឈ្មោះបរកុសិនាដា នគរមួយឈ្មោះនាដបរិយា នគរមួយឈ្មោះបរកុសិដនាដា ។ បទថា **ឧត្តរេន កបិវន្តោ** សេចក្ដីថា ត្រង់ទិសឧត្តរ មាននគរដទៃឈ្មោះកបិវន្តនគរ តាំងនៅក្នុងទិសឧត្តរនោះ ។ បទថា **ជនោឃមបរេន ច** សេចក្ដីថា ក្នុងភាគដទៃនៃទិសឧត្តរនោះ មាននគរដទៃឈ្មោះជនោឃៈ ។ បទថា **នវនវតិយោ** សេចក្ដីថា នគរមួយទៀតឈ្មោះនវនវតិយៈ ។ នគរមួយទៀតឈ្មោះអម្ពរអម្ពរវតិយៈ ។ បទថា **អាឡកមន្ទា** សេចក្ដីថា មានរាជធានីដទៃទៀតឈ្មោះអាឡកមន្ទា ។ បទថា **តស្មា កុវេរោ មហារាជា** នេះ មានរឿងតំណាលថា កាលព្រះសម្ពុទ្ធមិនទាន់កើតឡើង មហារាជនេះ ជាព្រាហ្មណ៍ឈ្មោះកុវេរៈ បានសាងរោងកៀបអំពៅ ប្រកបគ្រឿងយន្ត ៧ គ្រឿង ។ កុវេរព្រាហ្មណ៍បានឲ្យផលចំណេញដែលកើតឡើង ត្រង់រោងគ្រឿងយន្តមួយកន្លែង ដល់មហាជនដែល

មកហើយ បានធ្វើបុណ្យ ។ ផលចំណោញ ដែលច្រើនជាង បានតាំងឡើងក្នុងទីនោះ អំពីរោងដ៏សេស ។ កុវេរព្រាហ្មណ៍ ជ្រះថ្លាដោយបុណ្យនោះ ទើបកាន់យកផលចំណោញ ដែលកើតឡើងពីរោងដ៏សេស ឲ្យទានអស់ ២ ម៉ឺនឆ្នាំ ។ ព្រាហ្មណ៍នោះធ្វើកាលកិរិយា ទៅកើតជាទេវបុត្រឈ្មោះកុវេរៈ ក្នុងស្ថានចាតុម្មហារាជិកា ។ តមក បានគ្រងរាជសម្បត្តិក្នុងរាជធានីឈ្មោះវិសាណៈ ។ តាំងពីនោះមក ទើបហៅថា ស្តេចវេស្សវ័ណ ។ បទថា **បច្ចេសន្តោ បកាសេន្តិ** សេចក្ដីថា យក្ខអ្នករក្សាដែន ១២ នាក់ផ្សេងទៀត ចូលទៅពិចារណា ដាស់តឿននូវប្រយោជន៍ទាំងឡាយ រមែងប្រាកដជាអ្នកមានមុខនាទីមួយផ្នែក ។ បានពួថា យក្ខអ្នករក្សាដែនទាំងនោះ យកដំណឹងទៅប្រកាសដល់យក្ខអ្នករក្សាទ្វារ ១២ នាក់ ។ យក្ខអ្នករក្សាទ្វារទាំងឡាយ ប្រកាសដំណឹងនោះដល់មហារាជ ។ ឥឡូវនេះ មហារាជ កាលនឹងសម្ដែងឈ្មោះរបស់យក្ខអ្នករក្សាដែនទាំងនោះ ទើបពោលពាក្យថា **តតោល** ដូច្នេះជាដើម ។ បានពួថា បណ្ដាយក្ខទាំងនោះ យក្ខម្នាក់ឈ្មោះតតោលា ម្នាក់ឈ្មោះតត្តលា ម្នាក់ឈ្មោះតតោតលា ម្នាក់ឈ្មោះឱជសី ម្នាក់ឈ្មោះតេជសី ម្នាក់ឈ្មោះតតោជសី ។ បទថា **សុរោ រាជា** សេចក្ដីថា ម្នាក់ឈ្មោះសុរោ ម្នាក់ឈ្មោះរាជា ម្នាក់ឈ្មោះសុរោរាជា ។ បទថា **អរិដ្ឋោនេមិ** សេចក្ដីថា ម្នាក់ឈ្មោះអរិដ្ឋៈ ម្នាក់ឈ្មោះនេមិ ម្នាក់ឈ្មោះអរិដ្ឋនេមិ ។

បទថា **រហោទោបិ តត្ថ ធរណី នាម** សេចក្ដីថា ក្នុងវិសាណារាជធានីនោះ មានអន្លង់ទឹកមួយឈ្មោះធរណី ដោយឈ្មោះ ។ លោកពោលថា មាន

ស្រះបោក្ខរណីធំទទឹង ៥០ យោជន៍ ។ បទថា **យតោ មេឃា បវស្សន្តិ** សេចក្តីថា ពពកទាំងឡាយទទួលទឹកពីស្រះបោក្ខរណី ហើយធ្លាក់ចុះមក ។ បទថា **វស្សាយតោ បតាយំ** សេចក្តីថា ភ្លៀងធ្លាក់ជន់លិច ។ បានឮថា កាលពពកតាំងឡើងខ្មៅ ទឹកចាស់រមែងហូរចេញពីស្រះបោក្ខរណីនោះ ។ ពពកតាំងឡើងខ្មៅខាងលើ ញុំាងស្រះបោក្ខរណីនោះឲ្យពេញដោយទឹកថ្មី ។ ទឹកចាស់ជាទឹកមាននៅខាងក្រោម រមែងហូរចេញទៅ ។ កាលស្រះបោក្ខរណីមានទឹកពេញ ពពករមែងរសាត់ទៅ ។ បទថា **សភា** គឺទីកន្លែងប្រជុំ ។ ត្រង់ច្រាំងស្រះបោក្ខរណីនោះ មានមណ្ឌបកែវប្រមាណ ១២ យោជន៍ ព័ទ្ធដោយវល្លិឈ្មោះភគលវតី ។ នេះលោកពោលសំដៅដល់មណ្ឌបនោះ ។ បទថា **បយិរុទាសន្តិ** សេចក្តីថា កំពុងអង្គុយ ។ បទថា **តត្ថ និច្ចផលា រុក្ខា** សេចក្តីថា មណ្ឌបកែវរមែងសម្តែងដល់អត្ថថា ដើមឈើ មានស្វាយ និងព្រីងជាដើម ដុះឡោមព័ទ្ធមណ្ឌបនោះ ក្នុងទីនោះ ផ្សាយទៅសព្វកាល ដោយផ្កា មានផ្កាចម្ប៉ាជាដើម រីកស្គុះស្គាយជានិច្ច ។ បទថា **នានាទិជគណាយុតា** គឺដេរដាសដោយពួកបក្សីផ្សេងៗ ។ បទថា **មយូរកោញ្ចាភិរុទ** សេចក្តីថា សត្វក្ងោក សត្វក្រៀល មានសំឡេងពីរោះកងរំពង ។

បទថា **ជីវញ្ជីវកសទ្ទេត្ថ** សេចក្តីថា ក្នុងទីនេះ មានសំឡេងសត្វឈ្មោះ ជីវៈ ជីវកៈ ស្រែកយ៉ាងនេះថា ជីវៈ ជីវៈ ដូច្នេះ ។ បទថា **ឱដ្ឋវចិត្តកា** សេចក្តីថា សត្វមានសំឡេងគួរឲ្យរីករាយ ក៏ស្រែកយ៉ាងនេះ ក្រោកឡើងចិត្តៈ ក្រោកឡើងចិត្តៈ ដូច្នេះ រមែង ត្រាច់ទៅក្នុងទីនោះ ។ បទថា **កុក្កុដកា**

គឺមាន់ព្រៃ ។ បទថា **កុឡីរកា** គឺក្ដាមមាស ។ បទថា **វនេ** គឺព្រៃឈូក ។ បទថា **ពោក្ខរសាតកា** បានដល់ ពួកបក្សីឈ្មោះពោក្ខរសាតកា ។ បទថា **សុកសាលិកសទ្ទេត្ថ** សេចក្ដីថា ក្នុងស្រះនោះ មានសំឡេងសត្វសេកផង សត្វសាលិកាផង ។ បទថា **ឧណ្ណមានវកាពិ ច** គឺសត្វមានមុខដូចមនុស្ស ។ បានឮថា បក្សីទាំងនោះ យកជើងទាំងពីរទំត្រង់ឈើមាស ហើយដាន់ស្លឹកឈូកណាមួយ ដាក់ឈើមាសលើឈូក មិនឲ្យចន្លោះ ហើយត្រាច់ទៅ ។ បទថា **សព្វកាលំ សា** សេចក្ដីថា ស្រះពោក្ខរណីនោះ ល្អសព្វៗ កាល ។ បទថា **កុវេរនឡិនី** សេចក្ដីថា ស្រះនឡិនីរបស់ស្ដេចកុវេរៈ ជាស្រះបទុម ស្រះនោះឈ្មោះធរណី ស្អាតសព្វកាល ។

[ ៨៥ ] ស្ដេចវេស្សវណ ញ៉ាំងអាដានាដិយរក្ខាឲ្យសម្រេចហើយ កាលសម្ដែងដល់បរិកម្មព្រះបរិត្តនោះ ទើបពោលបទនេះថា **យស្ស កស្សចិ** ។ ក្នុងបទទាំងនោះ បទថា **សុគ្គហិតា** សេចក្ដីថា អាដានាដិយរក្ខា ដែលបុគ្គលណាម្នាក់ ជម្រះអត្ថ និងព្យញ្ជនៈ និងរៀនដោយល្អ ។ បទថា **សមត្តា បរិយាបុតា** សេចក្ដីថា មិនឲ្យបទ និងព្យញ្ជនៈសាបសូន្យ ហើយរៀនដោយសព្វគ្រប់ ។ លោកសម្ដែងថា ពិតហើយ ព្រះបរិត្តរមែងមិនមានតេជះដល់អ្នកពោលខុសអត្ថខ្លះ បាលីខ្លះ ឬថា មិនធ្វើឲ្យជំនាញ ។ ព្រះបរិត្តរមែងមានតេជះដល់អ្នកធ្វើឲ្យជំនាញ ដោយប្រការទាំងពួង ហើយពោលពិតប្រាកដ ។ សូម្បីកាលរៀនព្រោះលាភជាហេតុ ហើយពោល ក៏មិនសម្រេចប្រយោជន៍ ។ ព្រះបរិត្តរមែងមានប្រយោជន៍ ដល់អ្នកតាំងនៅក្នុងចំណែកនៃការចេញចាកទុក្ខ

ហើយ ធ្វើមេត្តាឲ្យជាបុរេចារិក ពោលទុំះឯង ។ បទថា **យក្ខបចារោ** គឺអ្នកបម្រើយក្ខ ។ បទថា **វត្ថុំ វា** បានដល់ វត្ថុ គឺផ្ទះក្តី ។ បទថា **វាសំ វា** បានដល់ ការនៅជានិច្ចក្នុងផ្ទះនោះក្តី ។ បទថា **សមិតឹ** គឺការប្រជុំ ។ បទថា **អនាវយ្ហំ** សេចក្តីថា មិនគួរធ្វើការអាវាហៈ ។ បទថា **អវិវយ្ហំ** សេចក្តីថា មិនគួរធ្វើវិវាហៈជាមួយយក្ខនោះ សេចក្តីថា មិនគប្បីធ្វើអាវាហៈ ឬវិវាហៈជាមួយនឹងយក្ខនោះ ។ បទថា **អត្តាហិបិ បរិបុណ្ណាហិ** សេចក្តីថា អមនុស្សទាំងឡាយ គប្បីបង្អោនចូលទៅកាន់អត្តភាពរបស់យក្ខទាំងនោះ យ៉ាងនេះថា អ្នកមានភ្នែកពណ៌ក្រហម អ្នកមានធ្មេញលឿង ដូច្នេះហើយ ជេរដោយពាក្យជេរដែលមានព្យញ្ជនៈបរិបូណ៌ ដូចដែលពោលហើយ អធិប្បាយថា គប្បីជេរដោយពាក្យរបស់យក្ខ ។ បទថា **រិត្តម្បិស្ស បត្តំ** សេចក្តីថា បាត្រលោហៈដូចគ្នានឹងបាត្ររបស់ភិក្ខុនោះឯង ។ គ្របបាត្រនោះលើក្បាលរហូតដល់ក ។ យកសសរដែកដំបាត្រនោះត្រង់កណ្តាល ។ បទថា **ចណ្ឌា** គឺក្រោធ **រុទ្ធា** បានដល់ កំហុស ។ បទថា **រភសា** គឺធ្វើហួសហេតុ ។ បទថា **មហារាជានំ អាធិយំ** គឺមិនកាន់យកពាក្យនិយាយ មិនធ្វើតាមការបង្គាប់ ។ បទថា **មហារាជានំ បរិសកានំ** គឺសេនាបតីយក្ខ ២៨ នាក់ ។ បទថា **បុរិសកានំ បុរិសកានំ** គឺអនុសាសន៍របស់សេនាបតីយក្ខ ។ បទថា **អវរុទ្ធា នាម** សេចក្តីថា បច្ចាមិត្រ គឺអ្នកមានពៀរ ។ បទថា **ឧជ្ឈាបេតព្វំ** សេចក្តីថា អ្នកមិនអាចនឹងពោលព្រះបរិត្ត ឲ្យពួកអមនុស្សចៀសចេញបាន គួរប្រកាសឲ្យយក្ខទាំងឡាយដឹង សេចក្តីថា ឲ្យយក្ខទាំងនោះដឹង ។ ប៉ុន្តែ គប្បីឈរក្នុងទីនេះ ហើយ

ពោលបរិកម្មព្រះបរិត្ត ។ តាមពិត មិនគួរសូត្រអាដានាដិយសូត្រមុនទេ ។ គួរសូធ្យព្រះសូត្រទាំងនេះ គឺមេត្តសូត្រ ធជគ្គសូត្រ រតនសូត្រ រហូត ៧ ថ្ងៃ ។ ប្រសិនបើរួចផុតទៅបាន ជាការល្អ ។ ប្រសិនបើមិនរួចផុត គួរសូត្រអាដា-នាដិយសូត្រ ។ ភិក្ខុដែលសូត្រអាដានាដិយសូត្រនោះ មិនគួរទំពាម្សៅ ឬសាច់ មិនគួរនៅក្នុងព្រៃស្មសាន ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ពួកអមនុស្សនឹងបានឱកាស ។ ទីដែលសូធ្យព្រះបរិត្ត គួរធ្វើទីសូធ្យឲ្យមានស្មៅខៀវស្រស់ ក្រាលអាសនៈឲ្យរៀបរយក្នុងទីនោះ ហើយគប្បីអង្គុយ ។ ភិក្ខុអ្នកសូធ្យព្រះបរិត្ត ដែលជនទាំងឡាយនាំចេញពីវិហារទៅកាន់ផ្ទះ គួរព័ទ្ធដោយគ្រឿងការពារ គឺក្តារ ហើយគប្បីនាំទៅ ។ មិនគួរអង្គុយសូធ្យក្នុងទីវាល ។ ភិក្ខុគួរបិទទ្វារ និងបង្អួចហើយសឹមអង្គុយ ឡោមព័ទ្ធដោយដៃជាអាវុធ គឺមេត្តាចិត្តជាខាងដើម ហើយសូត្រ ។ គួរឲ្យទទួលសិក្ខាបទមុន ហើយសូធ្យព្រះបរិត្តដល់អ្នកតាំងនៅក្នុងសីល ។ សូម្បីយ៉ាងនេះ ក៏មិនអាចនឹងរួចផុតបាន គួរនាំទៅកាន់វិហារ ឲ្យដេកលើលានព្រះចេតិយ ឲ្យធ្វើអាសនៈ បូជា អុជប្រទីប បោសសម្អាតលានព្រះចេតិយ ហើយសូធ្យមង្គលកថា ។ គួរប្រកាសឲ្យប្រជុំទាំងអស់ ។ ទីជិតវិហារ ដើមឈើធំ គួរបញ្ជូនដំណឹងទៅក្នុងទីនោះថា ពួកភិក្ខុរមែងរង់ចាំការមករបស់ពួកលោក ឈ្មោះថា ការមិនមកក្នុងទីប្រជុំទាំងអស់នឹងមិនបានទទួល បន្ទាប់ពីនោះ គួរសួរអ្នកដែលត្រូវអមនុស្សស្ថិតនៅថា អ្នកឈ្មោះអ្វី ។ កាលគេប្រាប់ឈ្មោះ ហើយ គួរហៅឈ្មោះនោះឯង ។ អ្នកគួរលែងបុគ្គលឈ្មោះនេះ ព្រោះចំណែកបុណ្យ ក្នុងការបូជាដោយវត្ថុ បានចងយកទុក

និងរបស់ក្រអូបជាដើម ចំណែកបុណ្យក្នុងការបូជាអាសនៈ ចំណែកបុណ្យក្នុងការថ្វាយបិណ្ឌបាតរបស់អ្នក ពួកភិក្ខុសូធ្យមហាមង្គលកថា ដើម្បីជាប្រយោជន៍ដល់បណ្ណាការរបស់អ្នក ដោយសេចក្តីគោរពក្នុងពួកភិក្ខុ សូមអ្នកលែងបុគ្គលនេះចុះ ដូច្នេះ បើអមនុស្សមិនចេញ គួរប្រាប់ដល់ទេវតាទាំងឡាយថា ពួកលោកចូរដឹងចុះ អមនុស្សនេះ មិនធ្វើតាមពាក្យរបស់ពួកយើង យើងនឹងធ្វើពុទ្ធអាជ្ញា ដូច្នេះ ។

គួរសូធ្យព្រះបរិត្តនេះ ជាបរិកម្មរបស់គ្រហស្ថមុន ។ បើភិក្ខុត្រូវអមនុស្សសណ្ឋិត គួរលាងអាសនៈហើយ ប្រកាសឲ្យប្រជុំភិក្ខុទាំងអស់ ឲ្យចំណែកបុណ្យក្នុងការបូជាផ្កាកម្រងគ្រឿងក្រអូបជាដើម ហើយគប្បីសូធ្យព្រះបរិត្ត នេះជាបរិកម្មរបស់ភិក្ខុទាំងឡាយ ។ បទថា **វិក្កន្ទិតព្វំ** សេចក្តីថា គប្បីប្រកាសឲ្យសេនាបតីយក្ខ ២៨ នាក់ ប្រជុំគ្នាទាំងអស់ ។ បទថា **វិរវិតព្វំ** សេចក្តីថា គប្បីប្រាប់ទេវតាទាំងឡាយនោះថា យក្ខនេះសណ្ឋិតក្នុងគេ ដូច្នេះជាដើម ។ ពាក្យថា ជាប់តាម ជាវេវចនៈរបស់ពាក្យថា សណ្ឋិត នោះឯង ។ ម្យ៉ាងទៀត លោកពោលថា ជាប់តាម គឺមិនចេញទៅ ។ បទថា **ហេឋេតិ** សេចក្តីថា បៀតបៀនធ្វើឲ្យរោគរើឡើងរឿយៗ ។ បទថា **វិហេឋេតិ** គឺជាវេវចនៈ នឹងបទថា **ហេឋេតិ** នោះឯង ។ បទថា **ហឹសតិ** គឺធ្វើឲ្យមានសាច់និងឈាមតិច ឲ្យកើតទុក្ខ ។ បទថា **វិហឹសតិ** ជាវេវចនៈ នឹងបទថា **ហឹសតិ** នោះឯង ។ បទថា **ឆមុញ្ចតិ** គឺជាអ្នកត្រូវក្រពើពាំ មិនប្រាថ្នានឹងលែង គប្បី

ប្រាប់ទេវតាទាំងនោះ ដោយប្រការដូច្នេះ ។

[ ៨៦ ] ឥឡូវនេះ ដើម្បីសម្តែងដល់យក្ខដែលគួរប្រាប់ ទើបពោលពាក្យជាដើមថា **កតមេសំ យក្ខានំ** ដូច្នេះ ក្នុងបទទាំងនោះ បទថា **ឥន្ទោ សោមោ** ជាឈ្មោះរបស់យក្ខទាំងឡាយនោះ ។ បណ្តាយក្ខទាំងឡាយនោះ យក្ខមួយអាស្រ័យនៅត្រង់ភ្នំឈ្មោះវេស្សាមិត្តៈ ឈ្មោះថា វេស្សាមិត្តយក្ខ ។ យក្ខដែលអាស្រ័យនៅត្រង់ភ្នំយុគន្ធរ ឈ្មោះថា យុគន្ធរយក្ខ យក្ខឈ្មោះហិរិនេត្តិ មណ្ឌិយៈ មណិ មណិវរៈ ទីឃៈ និងសេរីសកៈ មួយអន្លើដោយយក្ខទាំងនោះ ។

[ ៨៧ ] បទថា **ឥមេសំ យក្ខានំ មហាយក្ខានំ សេនាបតីនំ មហាសេនាបតីនំ ឧជ្ឈាបេតព្វំ** សេចក្តីថា គប្បីប្រាប់ដល់យក្ខសេនាបតីទាំងឡាយនេះ យ៉ាងនេះថា យក្ខនេះបៀតបៀនអ្នកនេះ ធ្វើអ្នកនេះឲ្យក្តៅក្រហាយ មិនលែងអ្នកនេះ ដូច្នេះ បន្ទាប់ពីនោះ យក្ខសេនាបតីទាំងឡាយនោះ នឹងធ្វើសេចក្តីខ្វល់ខ្វាយថា ពួកកិក្ខុរមែងធ្វើធម្មអាជ្ញារបស់ខ្លួន សូម្បីយើងនឹងធ្វើអាជ្ញារបស់ស្តេចយក្ខរបស់យើងទាំងឡាយ ។

[ ៨៨ ] ព្រះបាទវេស្សវណមហារាជ កាលសម្តែងថា ឱកាសរបស់ពួកអមនុស្សនឹងមិនមាន ដោយអាការយ៉ាងនេះ ពុទ្ធសាវកទាំងឡាយ ក៏នឹងនៅសប្បាយ ទើបក្រាបទូលពាក្យជាដើមថា **អយំ ខោ សា មារិស អាដានា-**

**ឋិយា រក្ខា** ដូច្នេះ ។ បទទាំងអស់នោះ និងបទដទៃអំពីនោះ មានអត្ថងាយ ហើយនោះឯង ។ អដ្ឋកថា អាដានាដិយសូត្រ ក្នុងទីឃនិកាយ ឈ្មោះ សុមង្គលវិលាសិនី ចប់ ៕

អាដានាដិយសូត្រ ចប់
សូត្រទី ៩ ចប់

# សុត្តន្តបិដក

## សង្គីតិសូត្រទី ១០

[ ៩២ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅកាន់ចារិក ក្នុងដែនមល្លៈ ជាមួយនឹងភិក្ខុសង្ឃជាច្រើន គឺភិក្ខុប្រមាណ ៥០០ រូប ទ្រង់ស្តេចទៅដល់ក្រុងឈ្មោះបាវាបរស់មល្លក្សត្រទាំងឡាយ ។ បានឮថា ព្រះមានព្រះភាគគង់ក្នុងអម្ពវ័នរបស់នាយចុន្ទកម្មារបុត្ត ( ជាកូនជាងលោហជាតិ ) ទៀបក្រុងបាវានោះ ។

[ ៩៣ ] សម័យនោះឯង ពួកមល្លក្សត្រនៅក្នុងក្រុងបាវា បានសាងនូវសណ្ឋាគារថ្មីៗ ឈ្មោះឧព្ភតកៈ មិនទាន់អស់កាលយូរប៉ុន្មាន សមណៈ ឬព្រាហ្មណ៍ ឬជាតិមនុស្សណាមួយ ក៏មិនទាន់បាននៅអាស្រ័យនៅឡើយ ។ ពួកមល្លក្សត្រអ្នកនៅក្នុងក្រុងបាវា បានឮដំណឹងថា ព្រះមានព្រះភាគទ្រង់ពុទ្ធដំណើរមកកាន់ចារិកក្នុងដែនមល្លៈ ជាមួយនឹងភិក្ខុសង្ឃជាច្រើន គឺភិក្ខុប្រមាណ ៥០០ រូប ទ្រង់ស្តេចមកដល់ក្រុងបាវា គង់នៅក្នុងអម្ពវ័នរបស់នាយចុន្ទកម្មារបុត្ត ទៀបក្រុងបាវា ។ ទើបពួកមល្លក្សត្រ អ្នកនៅក្នុងក្រុងបាវា បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ បានអភិវាទព្រះមានព្រះភាគហើយ អង្គុយក្នុងទីដ៏សមគួរ ។ លុះពួកមល្លក្សត្រអ្នកក្រុងបាវាអង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំព្រះមានព្រះភាគថា សូមទ្រង់ព្រះមេត្តាប្រោសពួកមល្លក្សត្រអ្នកក្រុងបាវា បានសាងនូវសណ្ឋាគារថ្មី ឈ្មោះឧព្ភតកៈ មិនទាន់អស់កាលយូរប៉ុន្មានក្នុងទីនេះ សមណៈ ឬព្រាហ្មណ៍ ឬជាតិមនុស្ស

ណាមួយ ក៏មិនទាន់បាននៅអាស្រ័យនៅឡើយ សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះមានព្រះភាគ ទ្រង់ប្រើប្រាស់សណ្ឋាគារនោះជាមុនចុះ លុះព្រះមានព្រះភាគ ប្រើប្រាស់ជាមុនរួចហើយ ពួកមល្លក្សត្រអ្នកក្រុងបាវា នឹងបានប្រើប្រាស់ជាខាងក្រោយ ការប្រើប្រាស់នោះ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ពួកមល្លក្សត្រអ្នកក្រុងបាវា អស់កាលជាយូរអង្វែង ។ ព្រះមានព្រះភាគ ក៏ទ្រង់ទទួលដោយតុណ្ហីភាព ។ គ្រានោះឯង ពួកមល្លក្សត្រអ្នកក្រុងបាវាដឹងថា ព្រះមានព្រះភាគទ្រង់ទទួលហើយ ក៏ក្រោកចាកអាសនៈ ហើយថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយចូលទៅរកសណ្ឋាគារ លុះចូលទៅដល់ហើយ បានក្រាលកម្រាលក្នុងសណ្ឋាគារពេញទាំងអស់ ហើយតាក់តែងអាសនៈទាំងឡាយ តម្កល់ក្អមទឹក អុចប្រទីបប្រេងរួចហើយ ក៏នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ បានអភិវាទព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីសមគួរ ។ លុះពួកមល្លក្សត្រអ្នកក្រុងបាវា ឋិតនៅក្នុងទីដ៏សមគួរ ហើយក្រាបបង្គំទូលព្រះមានព្រះភាគថា សូមទ្រង់ព្រះមេត្តាប្រោសសណ្ឋាគារ យើងខ្ញុំព្រះអង្គក្រាលដោយកម្រាលសព្វគ្រប់ បានតាក់តែងអាសនៈទាំងឡាយ ហើយបានតម្កល់ក្អមទឹកទុកហើយ បានអុជប្រទីបប្រេង រួចហើយ សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះមានព្រះភាគសម្គាល់នូវកាលគួរ ក្នុងកាលឥឡូវនេះ ។

[ ៩៤ ] លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់ស្បង់ និងបាត្រចីវរ ហើយចូលទៅកាន់សណ្ឋាគារ ជាមួយនឹងភិក្ខុសង្ឃ លុះចូលទៅដល់ហើយ

ទ្រង់លាងព្រះបាទទាំងគូហើយ ទ្រង់ចូលទៅកាន់សណ្ឋាគារ គង់ផ្អែកនឹងសសរកណ្ដាល បែរព្រះភក្ត្រទៅទិសខាងកើត ។ ចំណែកខាងភិក្ខុសង្ឃ ក៏លាងបាទាហើយចូលទៅកាន់សណ្ឋាគារ អង្គុយប្របជញ្ជាំងខាងលិច បែរមុខទៅទិសខាងកើត ផ្ដោះមុខទៅរកព្រះមានព្រះភាគ ចំណែកខាងពួកមល្លក្សត្រនៅក្នុងក្រុងបាវា ក៏លាងព្រះបាទ ចូលទៅកាន់សណ្ឋាគារ អង្គុយប្របជញ្ជាំងខាងកើត បែរមុខទៅទិសខាងលិច ផ្ដោះមុខទៅរកព្រះមានព្រះភាគដែរ ។ លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់ពន្យល់ពួកមល្លក្សត្រ អ្នកក្រុងបាវា ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ដល់យប់ជ្រៅ ហើយទ្រង់តឿនថា ម្នាលវាសេដ្ឋគោត្រទាំងឡាយ យប់ជ្រៅណាស់ហើយ ចូរអ្នកទាំងឡាយ សម្គាល់កាលគួរ ក្នុងកាលឥឡូវនេះចុះ ។ ពួកមល្លក្សត្រអ្នកក្រុងបាវា ទទួលព្រះបន្ទូលព្រះមានព្រះភាគដោយពាក្យថា ព្រះករុណាព្រះអង្គ ហើយក្រោកចាកអាសនៈ អភិវាទព្រះមានព្រះភាគ ធ្វើប្រទក្សិណ ហើយចៀសចេញទៅ ។

[ ៩៥ ] លំដាប់នោះឯង កាលដែលពួកមល្លក្សត្រ អ្នកក្រុងបាវា ចៀសចេញទៅមិនយូរប៉ុន្មាន ព្រះមានព្រះភាគ ទ្រង់ទតឃើញភិក្ខុសង្ឃនៅស្ងៀមស្ងាត់ ក៏ត្រាស់ហៅព្រះសារីបុត្តដ៏មានអាយុមកថា ម្នាលសារីបុត្ត ភិក្ខុសង្ឃ ប្រាសចាកសេចក្ដីងងុយងោកងក់ហើយ ម្នាលសារីបុត្ត ចូរអ្នកពន្យល់ភិក្ខុទាំងឡាយដោយធម្មីកថាចុះ តថាគតរួយខ្នងណាស់ តថាគតនឹងតម្រង់ខ្នង ( បន្តិច ) ។ ព្រះសារីបុត្តទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះ

ករុណាព្រះអង្គ ។ លំដាប់នោះឯង ព្រះមានព្រះភាគ ទ្រង់ឲ្យក្រាលសង្ឃាដិ មានជាន់ ៤ ហើយទ្រង់សម្រេចសីហសេយ្យា ដោយចំហៀងព្រះកាយខាងស្តាំ តម្រួតព្រះបាទលើព្រះបាទ មានព្រះសតិសម្បជញ្ញៈ ធ្វើនូវឧដ្ឋានសញ្ញា ទុកក្នុងព្រះហឫទ័យ ។

[ ៩៦ ] សម័យនោះឯង និគណ្ឋនាដបុត្ត ទើបធ្វើមរណកាលថ្មីៗ ក្នុងក្រុងបាវា ។ ដោយកាលកិរិយានៃនិគណ្ឋនាដបុត្តនោះ ពួកនិគ្រណ្ឋ ( ជាសិស្ស ) ក៏បែកគ្នាទៅជាពីរពួក កើតប្រកួតប្រកាន់ ឈ្លោះប្រកែក ទាស់ទែងពោលពាក្យចាក់ដោតគ្នានិងគ្នា ដោយលំពែង គឺមាត់ថា អ្នកឯងមិនចេះធម្មវិន័យនេះទេ អ្នកឯងនឹងចេះធម្មវិន័យនេះដូចម្តេចបាន អ្នកឯងប្រតិបត្តិខុសទេ យើងជាអ្នកប្រតិបត្តិត្រូវ ពាក្យយើងមានប្រយោជន៍ ពាក្យអ្នកឯងឥតប្រយោជន៍ទេ ពាក្យដែលគេត្រូវនិយាយមុន អ្នកឯងនិយាយក្រោយវិញ ពាក្យដែលគេត្រូវនិយាយក្រោយ អ្នកឯងនិយាយមុនវិញ ពាក្យដែលអ្នកឯងចេះចាំមកជាយូរអង្វែងហើយ ក៏សុទ្ធតែជាពាក្យខុសទទេ ទោសក្នុងវាទៈរបស់អ្នកឯង យើងបានលើកឡើងហើយ អ្នកឯងយើងសង្កត់សង្កិនបានហើយ ចូរអ្នកឯងទៅសិក្សាដើម្បីដោះស្រាយនូវទោសក្នុងវាទៈ ឬបើអ្នកឯងអង់អាច ចូរដោះចេញ ( ចាកសេចក្តីខុសចុះ ) ។ សេចក្តីស្លាប់តែមួយ ក៏ហាក់ដូចជាប្រព្រឹត្តតាមពួកនិគ្រណ្ឋ ដែលជាសិស្សរបស់នាដបុត្ត ។ ពួកសាវករបស់និគ្គណ្ឋនាដបុត្តណា ដែលជាគ្រហស្ថ ស្លៀកពាក់សំពត់ស ពួកសាវកទាំងនោះ ក៏មានសេចក្តីនឿយណាយ ធុញទ្រាន់ ជិនឆ្អន់នឹងពួកនិគ្រណ្ឋដែលជា

សិស្សរបស់នាដបុត្ត ដូចពួកជនដែលមានសេចក្តីនឿយណាយ ធុញទ្រាន់ ជិន ឆ្អន់នឹងធម្មវិន័យ ដែលគេពោលទុកដោយអាក្រក់ ដែលគេសម្តែងទុកដោយអាក្រក់ មិនមែននិយ្យានិកធម៌ មិនមែនប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ មិនមែនជាធម្មវិន័យ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងទុកហើយ ជាធម្មវិន័យមានទីពឹងបែកធ្លាយហើយ ជាធម្មវិន័យមិនមានទីពឹងឡើយ ។ លំដាប់នោះឯង ព្រះសារីបុត្តដ៏មានអាយុ ហៅភិក្ខុទាំងឡាយមកថា ម្នាលអាវុសោទាំង-ឡាយ និគណ្ឋនាដបុត្តធ្វើមរណកាលហើយថ្មីៗ ក្នុងក្រុងបាវា ដោយកាលកិរិយានៃនិគណ្ឋនាដបុត្តនោះ ពួកនិគ្រណ្ឋក៏បែកគ្នាទៅជាពីរពួក ។បេ។ ជាធម្មវិន័យ មានទីពឹងបែកធ្លាយហើយ ជាធម្មវិន័យមិនមានទីពឹងឡើយ ម្នាលអាវុសោទាំងឡាយ ដំណើរនោះប្រព្រឹត្តទៅក្នុងធម្មវិន័យ ដែលបុគ្គលពោលទុកអាក្រក់ហើយ ដែលបុគ្គលប្រកាសទុកអាក្រក់ហើយ មិនមែនជានិយ្យា-និកធម៌ មិនមែនប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ មិនមែនជាធម៌វិន័យដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងទុកយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ធម៌នេះឯង ព្រះមានព្រះភាគនៃយើងទាំងឡាយ បានពោលទុកល្អហើយ បានប្រកាសទុកល្អហើយ ជានិយ្យានិកធម៌ ប្រព្រឹត្តទៅដើម្បីស្ងប់រម្ងាប់ ជាធម៌ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងទុកហើយ គួរតែយើងទាំងអស់គ្នាសង្គាយនាក្នុងធម៌នោះ មិនគួរទាស់ទែងគ្នាឡើយ ព្រហ្មចរិយធម៌នេះឋិតនៅ តាំងនៅអស់កាលជាយូរអង្វែង ដោយហេតុណា ហេតុនោះឯង ប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់

សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ ចុះធម៌ដែលព្រះមានព្រះភាគនៃយើងទាំងឡាយពោលទុកល្អហើយ ប្រកាសទុកល្អហើយ ជានិយ្យានិកធម៌ ប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់ ជាធម៌ដែលព្រះសម្មា-សម្ពុទ្ធទ្រង់សម្តែងហើយនោះ ដូចម្តេចខ្លះ គួរយើងទាំងអស់គ្នាសង្គាយនាក្នុងធម៌នោះ មិនគួរទាស់ទែងគ្នាឡើយ ព្រហ្មចរិយធម៌នេះ ឋិតថេរ តាំងនៅអស់កាលជាយូរអង្វែង ដោយហេតុណា ហេតុនោះឯង ប្រព្រឹត្តទៅដើម្បីប្រ-យោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។

[ ៩៧ ] ម្នាលអាវុសោទាំងឡាយ ធម៌ ១ ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សម្តែងទុកហើយដោយប្រពៃ គួរតែយើងទាំងអស់គ្នា សង្គាយនាក្នុងធម៌នោះ មិនគួរទាស់ទែងគ្នាឡើយ ព្រហ្មចរិយធម៌នេះឋិតថេរតាំងនៅអស់កាលជាយូរអង្វែងដោយហេតុណា ហេតុនោះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។ ធម៌ ១ នោះតើដូចម្តេច ។ ពួកសត្វទាំងអស់ឋិតនៅបាន ព្រោះអាស្រ័យអាហារ ពួកសត្វទាំងអស់ឋិតនៅបាន ព្រោះអាស្រ័យសង្ខារ ។ ម្នាលអាវុសោទាំង-

ឡាយ នេះឯងជាធម៌ ១ ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងទុកហើយដោយប្រពៃ យើងទាំងអស់គ្នា គួរតែសង្គាយនាក្នុងធម៌នោះ មិនគួរទាស់ទែងគ្នាឡើយ ព្រហ្មចរិយធម៌នេះ ឋិតថេរ តាំងនៅអស់កាលជាយូរអង្វែង ដោយហេតុណា ហេតុនោះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។

**ពួកធម៌មួយៗ ដែលរាប់ក្នុងការសង្គាយនា ចប់**

[ ៩៨ ] ម្នាលអាវុសោទាំងឡាយ មានធម៌ពីរៗ ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងហើយដោយប្រពៃ យើងទាំងអស់គ្នាគួរតែសង្គាយនាក្នុងធម៌នោះ ។បេ។ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។ ពួកធម៌ពីរៗ តើអ្វីខ្លះ ។ ពួកធម៌ពីរៗ នោះ គឺនាម ១ រូប ១ ។ អវិជ្ជា ១ ភវតណ្ហា ១ ។ ភវទិដ្ឋិ ១ វិភវទិដ្ឋិ ១ ។ សេចក្តីមិនខ្មាសបាប ១ សេចក្តីមិនក្តៅនឹងបាប ឬមិនខ្លាចបាប ១ ។ សេចក្តីខ្មាសបាប ១ សេចក្តីក្តៅនឹងបាប ១ ។ ភាវៈជាអ្នកដែលគេប្រដៅក្រ ១ ភាវៈជាអ្នកមានមិត្តអាក្រក់ ១ ។ ភាវៈជាអ្នកដែលគេប្រដៅងាយ ១ ភាវៈជាអ្នកមានមិត្តល្អ ១ ។ សេចក្តីឈ្លាសក្នុងអាបត្តិ ១ សេចក្តីឈ្លាសក្នុងការចេញចាកអាបត្តិ ១ ។ សេចក្តីឈ្លាសក្នុងសមាបត្តិ ១ សេចក្តីឈ្លាសក្នុងការចេញចាក

សមាបត្តិ ១ ។ សេចក្តីឈ្លាសក្នុងធាតុ ១ សេចក្តីឈ្លាសក្នុងការធ្វើទុកក្នុងចិត្ត ១ ។ សេចក្តីឈ្លាសក្នុងអាយតនៈ ១ សេចក្តីឈ្លាសក្នុងបដិច្ចសមុប្បាទធម៌ ១ ។ សេចក្តីឈ្លាសក្នុងហេតុ ១ សេចក្តីឈ្លាសក្នុងមិនមែនហេតុ ១ ។ សេចក្តីស្លូតត្រង់ ១ ចិត្តទន់ ១ ។ សេចក្តីអត់ធ្មត់ ១ ការប្រព្រឹត្តល្អ ឬស្លូតមិនកោងកាច ១ ។ ពាក្យពីរោះ ១ ការទទួលរាក់ទាក់ ១ ។ សេចក្តីមិនបៀតបៀន ១ សេចក្តីស្អាត ១ ។ សេចក្តីភ្លាំងភ្លាត់សតិ ១ មិនដឹងខ្លួន ១ ។ សេចក្តីរឭក ១ ដឹងខ្លួន ១ ។ ភាវៈជាអ្នកមិនគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ១ ភាវៈជាអ្នកមិនដឹងប្រមាណក្នុងភោជន ១ ។ ភាវៈជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ១ ភាវៈជាអ្នកដឹងប្រមាណក្នុងភោជន ១ ។ កម្លាំង គឺប្រាជ្ញាជាគ្រឿងពិចារណា ១ កម្លាំង គឺភាវនា ១ ។ កម្លាំង គឺសតិ ១ កម្លាំង គឺសមាធិ ១ ។ សមថៈ ( ធម៌សម្រាប់រម្ងាប់ចិត្ត ) ១ វិបស្សនា ( ប្រាជ្ញាឃើញច្បាស់នូវនាមរូប ) ១ ។ សមថនិមិត្ត ១ បគ្គហនិមិត្ត ១ ។ សេចក្តីព្យាយាម ១ សេចក្តីមិនរាយមាយ ១ ។ សីលវិបត្តិ ១ ទិដ្ឋិវិបត្តិ ១ ។ សីលសម្បទា ១ ទិដ្ឋិសម្បទា ១ ។ សេចក្តីបរិសុទ្ធិនៃសីល ១ សេចក្តីបរិសុទ្ធិនៃទិដ្ឋិ ១ ។ សេចក្តីបរិសុទ្ធិនៃទិដ្ឋិ គឺញាណទស្សនៈ ១ សេចក្តីព្យាយាមនៃបុគ្គលដែលមានសេចក្តីយល់ឃើញតាមពិត ១ ។ សេចក្តីសង្វេគក្នុងហេតុទាំងឡាយគួរសង្វេគ ១ សេចក្តីព្យាយាមដោយឧបាយរបស់បុគ្គលអ្នកមានចិត្តសង្វេគ ១ ។ សេចក្តីមិនសន្តោស ក្នុងកុសលធម៌ទាំងឡាយ ១ មិនរួញរាក្នុងសេចក្តីព្យាយាម ១ ។ វិជ្ជា ១ វិមុត្តិ ១ ។

សេចក្តីដឹងក្នុងអរិយមគ្គ ជាគ្រឿងអស់ទៅនៃកិលេស ១ សេចក្តីដឹងក្នុងអរិយផលដែលធ្វើសត្វមិនឲ្យកើតឡើងដោយបដិសន្ធិ ១ ។ ម្នាលអាវុសោទាំងឡាយ នេះឯងជាពួកធម៌ពីរៗ ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងទុកហើយដោយប្រពៃ យើងទាំងអស់គ្នា គួរតែសង្គាយនាក្នុងធម៌នោះ ។បេ។ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។

## ពួកធម៌ពីរៗ ដែលរាប់ចូលក្នុងការសង្គាយនា ចប់

[ ៩៩ ] ម្នាលអាវុសោទាំងឡាយ មានពួកធម៌បីៗ ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងទុកហើយដោយប្រពៃ គួរតែយើងទាំងអស់គ្នា សង្គាយនាក្នុងធម៌នោះ ។បេ។ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំងឡាយ ។ ពួកធម៌បីៗ តើអ្វីខ្លះ ។ ពួកធម៌បីៗ គឺឫសអកុសល ៣ យ៉ាង គឺលោភៈជាឫសនៃអកុសល ១ ទោសៈជាឫសនៃអកុសល ១ មោហៈជាឫសនៃអកុសល ១ ។ ឫសកុសល ៣ យ៉ាង គឺអលោភៈជាឫសនៃកុសល ១ អទោសៈជាឫសនៃកុសល ១ អមោហៈជាឫសនៃកុសល ១ ។ ទុច្ចរិត ៣ យ៉ាង គឺទុច្ចរិតដោយកាយ ១ ទុច្ចរិតដោយវាចា ១ ទុច្ចរិតដោយចិត្ត ១ ។ សុចរិត ៣ យ៉ាង គឺសុចរិតដោយកាយ ១ សុចរិតដោយវាចា ១ សុចរិតដោយចិត្ត ១ ។ សេចក្តីត្រិះរិះជាអកុសល ៣ យ៉ាង គឺសេចក្តីត្រិះរិះប្រកបដោយកាម ១ សេចក្តីត្រិះរិះប្រកបដោយព្យាបាទ ១ សេចក្តីត្រិះរិះ

ប្រកបដោយការបៀតបៀន ១ ។ សេចក្តីត្រិះរិះជាកុសល ៣ យ៉ាង គឺសេចក្តីត្រិះរិះប្រកបដោយការចេញចាកកាម ១ សេចក្តីត្រិះរិះប្រកបដោយការមិនព្យាបាទ ១ សេចក្តីត្រិះរិះប្រកបដោយការមិនបៀតបៀន ១ ។ តម្រិះជាអកុសល ៣ យ៉ាង គឺតម្រិះប្រកបដោយកាម ១ តម្រិះប្រកបដោយការព្យាបាទ ១ តម្រិះប្រកបដោយការបៀតបៀន ១ ។ តម្រិះជាកុសល ៣ យ៉ាង គឺតម្រិះប្រកបដោយការចេញចាកកាម ១ តម្រិះប្រកបដោយការមិនព្យាបាទ ១ តម្រិះប្រកបដោយការមិនបៀតបៀន ១ ។ សេចក្តីសម្គាល់ជាអកុសល ៣ យ៉ាង គឺសេចក្តីសម្គាល់ប្រកបដោយកាម ១ សេចក្តីសម្គាល់ប្រកបដោយព្យាបាទ ១ សេចក្តីសម្គាល់ប្រកបដោយការបៀតបៀន ១ ។ សេចក្តីសម្គាល់ជាកុសល ៣ យ៉ាង គឺសេចក្តីសម្គាល់ប្រកបដោយការចេញចាកកាម ១ សេចក្តីសម្គាល់ប្រកបដោយការមិនព្យាបាទ ១ សេចក្តីសម្គាល់ប្រកបដោយការមិនបៀតបៀន ១ ។ ធាតុជាអកុសល ៣ យ៉ាង គឺធាតុប្រកបដោយកាម ១ ធាតុប្រកបដោយព្យាបាទ ១ ធាតុប្រកបដោយការបៀតបៀន ១ ។ ធាតុជាកុសល ៣ យ៉ាង គឺធាតុប្រកបដោយការចេញចាកកាម ១ ធាតុប្រកបដោយការមិនព្យាបាទ ១ ធាតុប្រកបដោយការមិនបៀតបៀន ១ ។ ធាតុ ៣ យ៉ាងដទៃទៀត គឺធាតុប្រកបដោយកាម ១ ធាតុប្រកបដោយរូប ១ ធាតុប្រកបដោយអរូប ១ ។ ធាតុ ៣ យ៉ាងដទៃទៀត គឺធាតុប្រកបដោយរូប ១ ធាតុប្រកបដោយអរូប ១ ធាតុប្រកបដោយសេចក្តីរលត់ គឺព្រះនិព្វាន ១ ។ ធាតុ ៣ យ៉ាងដទៃទៀត គឺធាតុយ៉ាងទាប ១ ធាតុយ៉ាងកណ្តាល ១ ធាតុ

យ៉ាងឧត្តម ១ ។ តណ្ហា ៣ យ៉ាង គឺកាមតណ្ហា ១ ភវតណ្ហា ១ វិភវ-តណ្ហា ១ ។ តណ្ហា ៣ យ៉ាងដទៃទៀត គឺកាមតណ្ហា ១ រូបតណ្ហា ១ អរូបតណ្ហា ១ ។ តណ្ហា ៣ យ៉ាងដទៃទៀត គឺរូបតណ្ហា ១ អរូបតណ្ហា ១ និរោធតណ្ហា ១ ។ សញ្ញោជនៈ ៣ យ៉ាង គឺសក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាស ១ ។ អាសវៈ ៣ យ៉ាង គឺកាមាសវៈ ១ ភវាសវៈ ១ អវិជ្ជាសវៈ ១ ។ ភព ៣ យ៉ាង គឺកាមភព ១ រូបភព ១ អរូបភព ១ ។ ការស្វែងរក ៣ យ៉ាង គឺការស្វែងរកកាម ១ ស្វែងរកភព ១ ស្វែងរកព្រហ្ម-ចរិយធម៌ ១ ។ មានះ ៣ យ៉ាង គឺមានះថា អាត្មាអញប្រសើរជាងគេ ១ មានះថា អាត្មាអញស្មើនឹងគេ ១ មានះថា អាត្មាអញអន់ជាងគេ ១ ។ កាល ៣ យ៉ាង គឺអតីតកាល ១ អនាគតកាល ១ បច្ចុប្បន្នកាល ១ ។ អន្តៈ គឺចំណែក ៣ យ៉ាង គឺសក្កាយជាចំណែក ១ ធម៌ជាគ្រឿងកើតនៃសក្កាយជាចំណែក ១ ធម៌ជាគ្រឿងរលត់នៃសក្កាយជាចំណែក ១ ។ វេទនា ៣ យ៉ាង គឺសុខវេទនា ១ ទុក្ខវេទនា ១ អទុក្ខមសុខវេទនា ១ ។ សេចក្តីលំបាក ៣ យ៉ាង គឺលំបាកព្រោះសេចក្តីទុក្ខ ១ លំបាកព្រោះសង្ខារ ១ លំបាកព្រោះសេចក្តីប្រែប្រួល ១ ។ គំនរ ៣ យ៉ាង គឺសភាវៈខុសដ៏ទៀងទាត់ជាគំនរ ១ សភាវៈត្រូវដ៏ទៀងទាត់ជាគំនរ ១ សភាវៈមិនទៀងទាត់ជាគំនរ ១ ។ សេចក្តីសង្ស័យ ៣ យ៉ាង គឺបុគ្គលរមែងសង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះស្រឡះព្រោះប្រារព្ធនូវអតីតកាល ១ សង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះស្រឡះព្រោះប្រារព្ធអនាគតកាល ១ សង្ស័យ ងឿងឆ្ងល់ មិនចុះចិត្ត

ស៊ប់ មិនជ្រះស្រឡះ ព្រោះប្រារព្ធនូវបច្ចុប្បន្នកាល ១ ។ អំពើដែលព្រះតថាគតមិនចាំបាច់រក្សា ឬរវាំងមាន ៣ យ៉ាង គឺម្នាលអាវុសោទាំងឡាយ ព្រះតថាគតមានកាយសមាចារបរិសុទ្ធ ព្រះតថាគតគប្បីរក្សានូវកាយទុច្ចរិតណាថា អ្នកដទៃកុំបីដឹងនូវកាយទុច្ចរិតរបស់អញនេះ កាយទុច្ចរិតនោះ មិនមានដល់ព្រះតថាគតឡើយ ១ ម្នាលអាវុសោទាំងឡាយ ព្រះតថាគតមានវចីសមាចារបរិសុទ្ធ ព្រះតថាគតគប្បីរក្សានូវវចីទុច្ចរិតណាថា អ្នកដទៃកុំបីដឹងនូវវចីទុច្ចរិតរបស់អញនេះ វចីទុច្ចរិតនោះ មិនមានដល់ព្រះតថាគតឡើយ ១ ម្នាលអាវុសោទាំងឡាយ ព្រះតថាគតមានមនោសមាចារបរិសុទ្ធ ព្រះតថាគតគប្បីរក្សានូវមនោទុច្ចរិតណាថា អ្នកដទៃកុំបីដឹងនូវមនោទុច្ចរិតរបស់អញនេះ មនោទុច្ចរិតនោះ មិនមានដល់ព្រះតថាគតឡើយ ១ ។ កង្វល់ ៣ យ៉ាង គឺរាគៈជាកង្វល់ ១ ទោសៈជាកង្វល់ ១ មោហៈជាកង្វល់ ១ ។ ភ្លើង ៣ យ៉ាង ភ្លើង គឺរាគៈ ១ ភ្លើង គឺទោសៈ ១ ភ្លើង គឺមោហៈ ១ ។ ភ្លើង ៣ យ៉ាងដទៃទៀត ភ្លើង គឺ អាហុនេយ្យបុគ្គល ១ ភ្លើង គឺទក្ខិណេយ្យបុគ្គល ១ ភ្លើង គឺគហបតី ១ ។ ការរាប់នូវរូបដោយចំណែក ៣ គឺរូបប្រកបដោយការឃើញផង ប្រកបដោយការប៉ះពាល់ផង ១ រូបមិនប្រកបដោយការឃើញ តែប្រកបដោយការប៉ះពាល់ ១ រូបមិនប្រកបដោយការឃើញផង មិនប្រកបដោយការប៉ះពាល់ផង ១ ។ សង្ខារ ៣ យ៉ាង គឺបុញ្ញាភិសង្ខារ ១ អបុញ្ញាភិសង្ខារ ១ អានេញ្ជាភិសង្ខារ ១ ។ បុគ្គល ៣ ពួក គឺបុគ្គលជាសេក្ខៈ ១ បុគ្គលជាអសេក្ខៈ ១ បុគ្គលមិនមែនជាសេក្ខៈមិនមែនជាអសេក្ខៈ ១ ។ ភិក្ខុ

ចាស់មាន ៣ ពួក គឺចាស់ដោយជាតិ ១ ចាស់ដោយធម៌ ១ ចាស់ដោយការសន្មតិ ១ ។ បុញ្ញកិរិយាវត្ថុ ៣ យ៉ាង គឺបុញ្ញកិរិយាវត្ថុសម្រេចដោយទាន ១ បុញ្ញកិរិយាវត្ថុសម្រេចដោយសីល ១ បុញ្ញកិរិយាវត្ថុសម្រេចដោយភាវនា ១ ។ ហេតុនៃការចោទ ៣ យ៉ាង គឺដោយឃើញ ១ ដោយឮ ១ ដោយរង្កៀស ១ ។ ការសេពកាម ៣ យ៉ាង ម្នាលអាវុសោទាំងឡាយ ពួកសត្វមានកាមតាំងឡើង ពួកសត្វទាំងនោះ ធ្វើអំណាចឲ្យប្រព្រឹត្តទៅក្នុងកាមទាំង-ឡាយដែលតាំងឡើង ដូចជាមនុស្សទាំងអស់ និងទេវតាពួកខ្លះ និងវិនិបាតិកពួកខ្លះ នេះជាការសេពកាមទី ១ ម្នាលអាវុសោទាំងឡាយ ពួកសត្វមានកាមដែលខ្លួននិម្មិតហើយ ពួកសត្វទាំងនោះ លុះនិម្មិតហើយៗ ក៏ធ្វើអំណាចឲ្យប្រព្រឹត្តទៅក្នុងកាមទាំងឡាយ ដូចជាពួកទេវតាក្នុងជាន់និម្មានរតី នេះជាការសេពកាមទី ២ ម្នាលអាវុសោទាំងឡាយ ពួកសត្វមានកាមដែលទេវតាដទៃនិម្មិតឲ្យ ពួកសត្វទាំងនោះ ធ្វើអំណាចឲ្យប្រព្រឹត្តទៅក្នុងកាមទាំងឡាយដែលទេវតាដទៃនិម្មិតឲ្យ ដូចជាពួកទេវតាក្នុងជាន់បរនិម្មិតវសវត្តី នេះជាការសេពកាមទី ៣ ។ ការបានសេចក្តីសុខ ៣ យ៉ាង ម្នាលអាវុសោទាំងឡាយ មានពួកសត្វធ្វើនូវសេចក្តីសុខឲ្យកើតឡើងរឿយៗ ហើយទទួលនូវសេចក្តីសុខ ( នោះ ) ដូចជាពួកទេវតានៅក្នុងពួកព្រហ្មលោក នេះជាការបាននូវសេចក្តីសុខទី ១ ម្នាលអាវុសោទាំងឡាយ ពួកសត្វដែលជោកជាំជ្រួតជ្រាបបរិបូណ៌ពាល់ត្រូវដោយសេចក្តីសុខហើយ ពួកសត្វទាំងនោះ ជួនកាលបន្លឺឧទានក្នុងកាលម្តងៗ ថា សុខណាស់ហ្ន៎ សុខណាស់ហ្ន៎ ដូចជាពួកទេវតានៅក្នុងជាន់

អាកស្សរព្រហ្មលោក នេះជាការបាននូវសេចក្តីសុខទី ២ ម្នាលអាវុសោទាំង-ឡាយ ពួកសត្វដែលជោកជាំជ្រួតជ្រាប បរិបូណ៌ពាល់ត្រូវដោយសេចក្តីសុខហើយ ពួកសត្វទាំងនោះ សន្តោសនឹងសេចក្តីសុខដ៏ល្អិតប៉ុណ្ណោះ ទទួលសេចក្តីសុខក្នុងចិត្ត ដូចពួកទេវតានៅក្នុងជាន់សុភកិណ្ហព្រហ្មលោក នេះជាការបាននូវសេចក្តីសុខទី ៣ ។ បញ្ញា ៣ យ៉ាង គឺបញ្ញាជារបស់សេក្ខបុគ្គល ១ បញ្ញាជារបស់អសេក្ខបុគ្គល ១ បញ្ញាជារបស់នេវសេក្ខានាសេក្ខបុគ្គល ១ ។ បញ្ញា ៣ យ៉ាងដទៃទៀត គឺបញ្ញាសម្រេចមកអំពីការគិត ១ បញ្ញាសម្រេចមកអំពីការស្តាប់ ១ បញ្ញាសម្រេចមកអំពីការចម្រើន ១ ។ អាវុធ ៣ យ៉ាង បានដល់ អាវុធ គឺសុតៈ ( ពុទ្ធវចនៈ ) ១ អាវុធ គឺសេចក្តីស្ងាត់ ១ អាវុធ គឺបញ្ញា ១ ។ ឥន្ទ្រិយ ៣ យ៉ាង គឺឥន្ទ្រិយដែលកើតឡើងដល់បុគ្គលអ្នកប្រតិបត្តិដោយគិតថា អាត្មាអញនឹងបានដឹងនូវធម៌ដែលមិនទាន់បានដឹង ( សោតាបត្តិ-មគ្គញាណ ) ១ ឥន្ទ្រិយ គឺញាណជាគ្រឿងដឹងច្បាស់ ( សោតាបត្តិផល-ញាណ ។បេ។ អរហត្តមគ្គញាណ ) ១ ឥន្ទ្រិយ គឺសេចក្តីដឹងក្នុងធម៌ ដែលបុគ្គលគួរដឹងច្បាស់ ជាធម៌ដល់នូវទីបំផុតនៃកិច្ចដោយកិរិយាដឹង ( អរហត្ត-ផលញាណ ) ១ ។ ចក្ខុ ៣ យ៉ាង គឺមំសចក្ខុ ១ ទិព្វចក្ខុ ១ បញ្ញាចក្ខុ ១ ។ សិក្ខា ៣ យ៉ាង គឺអធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។ ភាវនា ៣ យ៉ាង គឺកាយភាវនា ១ ចិត្តភាវនា ១ បញ្ញាភាវនា ១ ។ អនុត្តរិយៈ ៣ យ៉ាង គឺទស្សនានុត្តរិយៈ ការឃើញដ៏ប្រសើរ ១ បដិបទា-នុត្តរិយៈ សេចក្តីប្រតិបត្តិដ៏ប្រសើរ ១ វិមុត្តានុត្តរិយៈ ការរួចចាកកិលេសដ៏

ប្រសើរ ១ ។ សមាធិ ៣ យ៉ាង គឺសមាធិប្រកបដោយវិតក្កវិចារៈ ១ សមាធិមិនមានវិតក្ក មានត្រឹមតែវិចារៈ ១ សមាធិមិនមានវិតក្ក និងវិចារៈ ១ ។ សមាធិ ៣ យ៉ាងដទៃទៀត គឺសុញ្ញតសមាធិ ១ អនិមិត្តសមាធិ ១ អប្បណិហិតសមាធិ ១ ។ សេចក្តីស្អាត ៣ យ៉ាង គឺសេចក្តីស្អាតដោយកាយ ១ សេចក្តីស្អាតដោយវាចា ១ សេចក្តីស្អាតដោយចិត្ត ១ ។ ច្បាប់អ្នកប្រាជ្ញ ៣ យ៉ាង គឺច្បាប់អ្នកប្រាជ្ញផ្លូវកាយ ១ ច្បាប់អ្នកប្រាជ្ញផ្លូវវាចា ១ ច្បាប់អ្នកប្រាជ្ញផ្លូវចិត្ត ១ ។ សេចក្តីឈ្លាស ៣ យ៉ាង គឺសេចក្តីឈ្លាសក្នុងការចម្រើន ១ សេចក្តីឈ្លាសក្នុងការវិនាស ១ សេចក្តីឈ្លាសក្នុងឧបាយ ១ ។ សេចក្តីស្រវឹង ៣ យ៉ាង គឺស្រវឹងដោយការមិនមានរោគ ១ ស្រវឹងដោយវ័យ ១ ស្រវឹងដោយជាតិត្រកូល ១ ។ អធិបតេយ្យ ៣ យ៉ាង គឺអត្តាធិបតេយ្យ ១ លោកាធិបតេយ្យ ១ ធម្មាធិបតេយ្យ ១ ។ កថាវត្ថុ ៣ យ៉ាង គឺបុគ្គលប្រារព្ធអតីតកាល និយាយពាក្យថា រឿងយ៉ាងនេះ កើតមានក្នុងអតីតកាលហើយ ១ បុគ្គលប្រារព្ធអនាគតកាល និយាយពាក្យថា រឿងយ៉ាងនេះនឹងមានក្នុងអនាគតកាល ១ បុគ្គលប្រារព្ធបច្ចុប្បន្នកាលក្នុងកាល ឥឡូវនេះ និយាយពាក្យថា រឿងយ៉ាងនេះ កើតឡើងក្នុងកាលឥឡូវនេះ ១ ។ វិជ្ជា ៣ យ៉ាង គឺញាណជាគ្រឿងរឭកឃើញនូវខន្ធបញ្ចកៈ ដែលធ្លាប់នៅអាស្រ័យក្នុងកាលមុន ជាវិជ្ជា ១ សេចក្តីដឹងក្នុងចុតិ និងបដិសន្ធិរបស់ពួកសត្វ ជាវិជ្ជា ១ សេចក្តីដឹងក្នុងធម៌ជាគ្រឿងអស់ទៅនៃអាសវៈទាំងឡាយ ជាវិជ្ជា ១ ។ វិហារធម៌ ( ធម៌ជាគ្រឿងនៅ ) ៣ យ៉ាង គឺទិព្វវិហារ ១ ព្រហ្មវិហារ ១ អរិយ-

វិហារ ១ ។ បាដិហារ្យ ៣ យ៉ាង គឺឥទ្ធិបាដិហារ្យ ១ អាទេសនាបាដិហារ្យ ១ អនុសាសនីបាដិហារ្យ ១ ។ ម្នាលអាវុសោទាំងឡាយ ពួកធម៌បីៗ ទាំងនេះឯង ព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងហើយដោយប្រពៃ គួរយើងទាំងអស់គ្នាសង្គាយនាក្នុងធម៌នោះ មិនគួរទាស់ទែងគ្នាឡើយ ។បេ។ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។

**ពួកធម៌បីៗ ដែលរាប់ចូលក្នុងការសង្គាយនា ចប់**

[ ១០០ ] ម្នាលអាវុសោទាំងឡាយ ពួកធម៌បួនៗ ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងហើយដោយប្រពៃ គួរតែយើងទាំងអស់គ្នា សង្គាយនាក្នុងធម៌នោះ ។បេ។ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។ ពួកធម៌បួនៗ តើដូចម្តេច ។ សតិប្បដ្ឋាន ៤ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកពិចារណារឿយៗ នូវកាយក្នុងកាយ ជាបុគ្គលមានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងដោយល្អ មានស្មារតីកម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ១ ។ ពិចារណារឿយៗ នូវវេទនាក្នុងវេទនាទាំងឡាយ ១ ។ ពិចារណារឿយៗ នូវចិត្តក្នុងចិត្ត ១ ។ ពិចារណារឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ ជាបុគ្គលមានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងដោយល្អ មានស្មារតីកម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ១ ។

[ ១០១ ] សម្មប្បធាន ៤ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទៈឲ្យកើតឡើង សង្វាត ប្រារព្ធព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីបិទអកុសលធម៌ទាំងឡាយដ៏លាមក ដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ១ ញុំាងឆន្ទៈឲ្យកើតឡើង សង្វាត ប្រារព្ធនូវសេចក្តីព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីលះបង់នូវអកុសលធម៌ទាំងឡាយដ៏លាមក ដែលកើតឡើងហើយ ១ ញុំាងឆន្ទៈឲ្យកើតឡើង សង្វាត ប្រារព្ធនូវសេចក្តីព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីបណ្តុះបណ្តាលកុសលធម៌ទាំងឡាយដែលមិនទាន់កើត ឲ្យកើតឡើង ១ ញុំាងឆន្ទៈឲ្យកើតឡើង សង្វាត ប្រារព្ធនូវសេចក្តីព្យាយាម ផ្គងចិត្ត តម្កល់ចិត្ត ដើម្បីឲ្យកុសលធម៌ទាំងឡាយដែលកើតឡើងហើយ ឲ្យឋិតនៅ មិនឲ្យវិនាសទៅ ឲ្យរឹងរឹតតែចម្រើនឡើង ជំទូលាយ ចម្រើនពេញលេញ ១ ។

[ ១០២ ] ឥទ្ធិបាទ ៤ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនឥទ្ធិបាទដែលប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ១ ចម្រើនឥទ្ធិបាទដែលប្រកបដោយវីរិយសមាធិ និងបធានសង្ខារ ១ ចម្រើនឥទ្ធិបាទដែលប្រកបដោយចិត្តសមាធិ និងបធានសង្ខារ ១ ចម្រើនឥទ្ធិបាទដែលប្រកបដោយវីមំសាសមាធិ និងបធានសង្ខារ ១ ។

[ ១០៣ ] ឈាន ៤ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ បានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្ក ប្រកបដោយវិចារៈ មានបីតិ និងសុខដែល

កើតអំពីសេចក្តីស្ងប់ស្ងាត់នោះ ១ ភិក្ខុព្រោះស្ងប់ស្ងាត់ចាកវិតក្ក វិចារៈ ក៏បានដល់នូវទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តាននៃខ្លួន ប្រកបដោយសេចក្តីជ្រះថ្លា គឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កមិនមានវិចារៈ មានតែបីតិ និងសុខដែលកើតអំពីសមាធិ គឺបឋមជ្ឈាន ១ ភិក្ខុព្រោះនឿយណាយចាកបីតិផង ប្រកបដោយឧបេក្ខាផង មានស្មារតីដឹងខ្លួនដោយប្រពៃផង ទទួលនូវសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយតែងសរសើរនូវបុគ្គលដែលបាននូវតតិយជ្ឈាននោះថា បុគ្គលនោះ ប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានណា ក៏បានដល់នូវតតិយជ្ឈាននោះ ១ ភិក្ខុព្រោះលះបង់នូវសុខផង ព្រោះលះបង់នូវទុក្ខផង ព្រោះអស់ទៅនៃសោមនស្ស និងទោមនស្សក្នុងកាលមុន ក៏បានដល់នូវចតុត្ថជ្ឈាន មានអារម្មណ៍មិនមែនជាទុក្ខមិនមែនជាសុខ គឺជាឧបេក្ខា មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ១ ។

[ ១០៤ ] សមាធិភាវនា ៤ យ៉ាង ម្នាលអាវុសោទាំងឡាយ មានសមាធិភាវនាដែលបុគ្គលចម្រើន ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន ១ ។ ម្នាលអាវុសោទាំងឡាយ មានសមាធិភាវនាដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីបាននូវញាណទស្សនៈ ១ ។ ម្នាលអាវុសោទាំងឡាយ មានសមាធិភាវនា ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅដើម្បីសតិ និងសម្បជញ្ញៈ ១ ។ ម្នាលអាវុសោទាំងឡាយ មានសមាធិភាវនាដែលបុគ្គលចម្រើនហើយ ធ្វើឲ្យ

ច្រើនហើយ ប្រព្រឹត្តទៅដើម្បីអស់ទៅនៃអាសវៈទាំងឡាយ ១ ។ ម្នាលអាវុសោទាំងឡាយ ចុះសមាធិភាវនាដូចម្ដេច ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅដើម្បីជាសុខក្នុងបច្ចុប្បន្ន ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយបានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្ក ប្រកបដោយវិចារៈ ។បេ។ បានដល់ នូវចតុត្ថជ្ឈាន ម្នាលអាវុសោទាំងឡាយ នេះជាសមាធិភាវនា ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន ។ ម្នាលអាវុសោទាំងឡាយ ចុះសមាធិភាវនាដូចម្ដេច ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅដើម្បីបាននូវញាណទស្សនៈ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ធ្វើទុកក្នុងចិត្តនូវអាលោកសញ្ញា អធិដ្ឋាននូវទិវាសញ្ញាថា ថ្ងៃយ៉ាងណា យប់យ៉ាងនោះ យប់យ៉ាងណា ថ្ងៃយ៉ាងនោះ មានចិត្តបើកចេញស្រឡះ ឥតមានអ្វីរួបរឹតបិទបាំង ចម្រើនចិត្តដែលប្រកបដោយពន្លឺ ម្នាលអាវុសោទាំងឡាយ នេះជាសមាធិភាវនា ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅដើម្បីបាននូវញាណទស្សនៈ ។ ម្នាលអាវុសោទាំងឡាយ ចុះសមាធិភាវនាដូចម្ដេច ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅដើម្បីសតិនិងសម្បជញ្ញៈ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ វេទនាកើតឡើងក៏ដឹង តាំងនៅក៏ដឹងអស់ ទៅក៏ដឹង សញ្ញាកើតឡើងក៏ដឹង តាំងនៅក៏ដឹង អស់ទៅក៏ដឹង វិតក្កកើតឡើងក៏ដឹង តាំងនៅក៏ដឹង អស់ទៅក៏ដឹង ម្នាលអាវុសោ

ទាំងឡាយ នេះជាសមាធិភាវនា ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅ ដើម្បីសតិ និងសម្បជញ្ញៈ ។ ម្នាលអាវុសោទាំងឡាយ ចុះសមាធិភាវនាដូចម្តេច ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅដើម្បីអស់ទៅនៃអាសវៈទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកពិចារណារឿយៗ នូវសេចក្តីកើតឡើង និងសូន្យទៅក្នុងឧបាទានក្ខន្ធទាំង ៥ ថា រូបដូច្នេះ ការកើតឡើងនៃរូបដូច្នេះ ការរលត់ទៅនៃរូបដូច្នេះ ។ វេទនាដូច្នេះ ។ សញ្ញាដូច្នេះ ។ សង្ខារដូច្នេះ ។ វិញ្ញាណដូច្នេះ ការកើតឡើងនៃវិញ្ញាណដូច្នេះ ការរលត់ទៅនៃវិញ្ញាណដូច្នេះ ម្នាលអាវុសោទាំងឡាយ នេះជាសមាធិភាវនា ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយ ។

[ ១០៥ ] អប្បមញ្ញា ៤ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទី ២ ទី ៣ ទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ខាងក្រោម និងទិសទទឹង មានចិត្តប្រកបដោយមេត្តា ដ៏ធំទូលាយ រកប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយអាការទាំងពួង ក្នុងទីទាំងពួង ១ ។ មានចិត្តប្រកបដោយករុណា ១ ។ មានចិត្តប្រកបដោយមុទិតា ១ ។ មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទី ២ ទី ៣ ទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ខាងក្រោម និងទិសទទឹង មានចិត្តប្រកបដោយឧបេក្ខាដ៏ធំទូលាយ រកប្រមាណមិនបាន មិនមានពៀរ មិនមាន

ព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយអាការទាំងពួង ក្នុងទីទាំងពួង ១ ។

[ ១០៦ ] អរូបជ្ឈាន ៤ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះការប្រព្រឹត្តកន្លងនូវរូបសញ្ញា ដោយប្រការទាំងពួង ព្រោះការអស់បដិឃសញ្ញា ព្រោះការលែងធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ក៏បានដល់នូវអាកាសានញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ ១ ព្រោះប្រព្រឹត្តកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុតដូច្នេះ ១ ព្រោះប្រព្រឹត្តកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា វត្ថុតិចតួចមិនមានដូច្នេះ ១ ព្រោះប្រព្រឹត្តកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈានដោយប្រការទាំងពួង ក៏បានដល់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំងបួន ១ ។

[ ១០៧ ] អបស្សេនធម៌ គឺធម៌ជាទីពឹងផ្អែក ៤ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាហើយ ទើបសេពនូវរបស់ដែលគួរសេព ១ ពិចារណាហើយ អត់សង្កត់នូវហេតុដែលគួរអត់សង្កត់ ១ ( ពិចា-រណា ) ហើយ វៀរនូវរបស់ដែលគួរវៀរ ១ ( ពិចារណា ) ហើយបន្ទោបង់នូវ ហេតុដែលគួរបន្ទោបង់ ១ ។

[ ១០៨ ] អរិយវង្ស ៤ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុង

សាសនានេះ ជាអ្នកសន្តោស ដោយចីវរណាទីមួយ តែងសរសើរគុណនៃសេចក្តីសន្តោស ដោយចីវរណាទីមួយ មិនដល់នូវការស្វែងរកដែលមិនសមគួរ ព្រោះហេតុតែចីវរ មិនអន្ទះអន្ទែង ព្រោះមិនបានចីវរ បានចីវរហើយ មិនរីករាយ មិនជ្រុលជ្រប់ មិនបានឲ្យតណ្ហាគ្របសង្កត់ ជាអ្នកមានសេចក្តីឃើញទោសជាប្រក្រតី មានប្រាជ្ញាជាគ្រឿងរលាស់ចេញ ហើយបរិភោគ មិនលើកតម្កើងខ្លួនឯង មិនបន្អាប់អ្នកដទៃ ព្រោះសេចក្តីសន្តោស ដោយចីវរណាទីមួយនោះឯង មួយទៀត ភិក្ខុណា ជាអ្នកឈ្លាសវៃ ជាបុគ្គលមិនខ្ជិលច្រអូស មានសម្បជញ្ញៈ មានសតិតាំងនៅមាំ ក្នុងសេចក្តីសន្តោសនោះ ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ព្រះមានព្រះភាគត្រាស់ហៅថា អ្នកឋិតនៅក្នុងអរិយវង្ស ជាច្បាប់ទម្លាប់ចាស់ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកសន្តោសដោយបិណ្ឌបាតណាទីមួយ តែងសរសើរគុណនៃសេចក្តីសន្តោស ដោយបិណ្ឌបាតណាទីមួយ មិនដល់នូវការស្វែងរកដែលមិនសមគួរ ព្រោះហេតុតែបិណ្ឌបាត មិនអន្ទះអន្ទែង ព្រោះមិនបានបិណ្ឌបាត បានបិណ្ឌបាតហើយ មិនរីករាយ មិនជ្រុលជ្រប់ មិនបានឲ្យតណ្ហាគ្របសង្កត់ ជាអ្នកមានសេចក្តីឃើញទោសជាប្រក្រតី មានប្រាជ្ញាជាគ្រឿងរលាស់ចេញ ហើយបរិភោគ មិនលើកតម្កើងខ្លួនឯង មិនបន្អាប់អ្នកដទៃ ព្រោះសេចក្តីសន្តោសដោយបិណ្ឌបាតណាទីមួយនោះឯង ភិក្ខុណា ជាអ្នកឈ្លាសវៃ ជាបុគ្គលមិនខ្ជិលច្រអូស មានសម្បជញ្ញៈ មានសតិតាំងនៅមាំក្នុងសេចក្តីសន្តោសនោះ ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ព្រះមានព្រះភាគត្រាស់

ហៅថា អ្នកឋិតនៅក្នុងអរិយវង្ស ជាច្បាប់ទម្លាប់ចាស់ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកសន្តោសដោយសេនាសនៈណាទីមួយ តែងសរសើរគុណនៃសេចក្តីសន្តោស ដោយសេនាសនៈណាទីមួយ មិនដល់នូវការស្វែងរកដែលមិនសមគួរ ព្រោះហេតុតែសេនាសនៈ មិនអន្ទះអន្ទែងព្រោះមិនបានសេនាសនៈ បានសេនាសនៈហើយ មិនរីករាយ មិនជ្រុលជ្រប់ មិនបានឲ្យតណ្ហាគ្របសង្កត់ ជាអ្នកមានសេចក្តីឃើញទោសជាប្រក្រតី មានប្រាជ្ញាជាគ្រឿងរលាស់ចេញ ហើយបរិភោគ មិនលើកតម្កើងខ្លួនឯង មិនបន្អាប់អ្នកដទៃ ព្រោះសេចក្តីសន្តោស ដោយសេនាសនៈណាទីមួយនោះឯង មួយទៀត ភិក្ខុណាជាអ្នកឈ្លាសវៃ ជាបុគ្គលមិនខ្ជិលច្រអូស មានសម្បជញ្ញៈ មានសតិតាំងនៅមាំក្នុងសេចក្តីសន្តោសនោះ ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ព្រះមានព្រះភាគត្រាស់ហៅថា អ្នកឋិតនៅក្នុងអរិយវង្សជាច្បាប់ទម្លាប់ចាស់ ១ ។ ម្នាលអាវុសោទាំងឡាយ មួយវិញទៀត ភិក្ខុជាអ្នកមានការលះកិលេសទាំងពួង ជាទីត្រេកអរ ជាអ្នកត្រេកអរហើយ ក្នុងការលះ មានការចម្រើនជាទីត្រេកអរ ជាអ្នកត្រេកអរហើយក្នុងការចម្រើន មិនលើកតម្កើងខ្លួនឯង មិនបន្អាប់អ្នកដទៃ ព្រោះតែខ្លួនមានការលះ ជាទីត្រេកអរ ជាអ្នកត្រេកអរហើយក្នុងការលះ មានការចម្រើនជាទីត្រេកអរ ត្រេកអរហើយក្នុងការចម្រើននោះឯង មួយវិញទៀត ភិក្ខុណាជាអ្នកឈ្លាសវៃ ជាបុគ្គលមិនខ្ជិលច្រអូស មានសម្បជញ្ញៈ មានសតិតាំងនៅមាំក្នុងការត្រេកអរនោះ ម្នាលអាវុសោទាំងឡាយ ភិក្ខុនេះឯង ព្រះមានព្រះភាគត្រាស់ហៅថា អ្នកឋិតនៅ

ក្នុងអរិយវង្ស ជាច្បាប់ទម្លាប់ចាស់ ១ ។

[ ១០៩ ] ការព្យាយាមជាគ្រឿងតម្កល់ ៤ យ៉ាង គឺការព្យាយាម ក្នុងសេចក្តីសង្រួម ១ ការព្យាយាមក្នុងការលះ ១ ការព្យាយាមក្នុងការចម្រើន ១ ការព្យាយាមក្នុងការរក្សារឿយៗ ១ ។ ម្នាលអាវុសោទាំងឡាយ ចុះការព្យាយាមក្នុងសេចក្តីសង្រួមតើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយចក្ខុហើយ មិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈា និងទោមនស្សគប្បីជាប់តាមបុគ្គល ដែលមិនសង្រួមចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមចក្ខុន្ទ្រិយណា ប្រតិបត្តិដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ រក្សានូវចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ។ ឮសំឡេងដោយត្រចៀក ។ ធុំក្លិនដោយច្រមុះ ។ ទទួលរសដោយអណ្តាត ។ ពាល់ត្រូវសម្ផស្សដោយកាយ ។ ដឹងធម្មារម្មណ៍ដោយចិត្ត ហើយមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ អកុសល-ធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈា និងទោមនស្ស គប្បីជាប់តាមបុគ្គលដែលមិនសង្រួមមនិន្ទ្រិយនុ៎ះ ព្រោះហេតុមិនសង្រួមនូវមនិន្ទ្រិយណា ប្រតិបត្តិដើម្បីសង្រួមនូវមនិន្ទ្រិយនោះ រក្សានូវមនិន្ទ្រិយ ដល់នូវការសង្រួមក្នុងមនិន្ទ្រិយ ម្នាលអាវុសោទាំងឡាយ នេះព្រះមានព្រះភាគត្រាស់ហៅថា ការព្យាយាមក្នុងសេចក្តីសង្រួម ។ ម្នាលអាវុសោទាំងឡាយ ចុះការព្យាយាមក្នុងការលះ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនបណ្តោយឲ្យកាមវិតក្កដែលកើតឡើងហើយ ឲ្យអាស្រ័យនៅបាន គឺលះបង់ បន្ទោបង់ ធ្វើ

ឲ្យវិនាស មិនឲ្យកើតមាន មិនបណ្តោយឲ្យព្យាបាទវិតក្កដែលកើតឡើងហើយ ។បេ។ មិនបណ្តោយឲ្យវិហឹសាវិតក្កដែលកើតឡើងហើយ អាស្រ័យនៅបាន គឺលះបង់ ។បេ។ មិនបណ្តោយឲ្យអកុសលធម៌ទាំងឡាយដ៏អាក្រក់ ដែលកើតឡើងហើយរឿយៗ អាស្រ័យនៅបាន គឺលះបង់ បន្ទោបង់ ធ្វើឲ្យវិនាស មិនឲ្យកើតមាន ម្នាលអាវុសោទាំងឡាយ នេះព្រះមានព្រះភាគត្រាស់ហៅថា ការព្យាយាមក្នុងការលះ ។ ម្នាលអាវុសោទាំងឡាយ ចុះការព្យាយាមក្នុងការចម្រើនតើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើនសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវវិវេកធម៌ អាស្រ័យនូវវិរាគធម៌ អាស្រ័យនូវនិរោធធម៌ ជាធម៌បង្អោនទៅ ដើម្បីការលះកិលេស ។ ចម្រើនធម្មវិចយ-សម្ពោជ្ឈង្គ ។ ចម្រើនវិរិយសម្ពោជ្ឈង្គ។ ចម្រើនបីតិសម្ពោជ្ឈង្គ ។ ចម្រើនបស្សទ្ធិសម្ពោជ្ឈង្គ ។ ចម្រើនសមាធិសម្ពោជ្ឈង្គ ។ ចម្រើនឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យនូវវិវេកធម៌ អាស្រ័យនូវវិរាគធម៌ ចម្រើននូវនិរោធធម៌ ជាធម៌បង្អោនទៅ ដើម្បីលះកិលេស ម្នាលអាវុសោទាំងឡាយ នេះព្រះមានព្រះភាគត្រាស់ហៅថា ការព្យាយាមក្នុងការចម្រើន ។ ម្នាលអាវុសោទាំងឡាយ ចុះការព្យាយាមក្នុងការរក្សារឿយៗ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ រក្សារឿយៗ នូវសមាធិនិមិត្តដ៏ល្អ ដែលកើតឡើងហើយ គឺអដ្ឋិកសញ្ញា បុឡុវកសញ្ញា វិនីលកសញ្ញា វិច្ឆិទ្ទកសញ្ញា ឧទ្ធុមាតកសញ្ញា ម្នាលអាវុសោទាំងឡាយ នេះព្រះមានព្រះភាគត្រាស់ហៅថា ការព្យាយាមក្នុងការរក្សារឿយៗ ។

[ ១១០ ] ញាណ គឺសេចក្តីដឹង ៤ យ៉ាង គឺសេចក្តីដឹងក្នុងធម៌ គឺមគ្គផល ១ សេចក្តីដឹងក្នុងលំនាំរបស់ញាណនោះ ១ សេចក្តីដឹងក្នុងកិរិយាកំណត់ចិត្តរបស់បុគ្គលដទៃ ១ សេចក្តីដឹងក្នុងការសន្មតិ ១ ។ ញាណ គឺសេចក្តីដឹង ៤ យ៉ាងដទៃទៀត គឺសេចក្តីដឹងក្នុងទុក្ខ ១ សេចក្តីដឹងក្នុងទុក្ខសមុទយៈ ១ សេចក្តីដឹងក្នុងទុក្ខនិរោធ ១ សេចក្តីដឹងក្នុងទុក្ខនិរោធគាមិនីបដិបទា ១ ។

[ ១១១ ] អង្គនៃសោតាបត្តិមគ្គ ៤ យ៉ាង គឺការសេពគប់នូវសប្បុរស ១ ការស្តាប់ធម៌របស់សប្បុរស ១ ការធ្វើទុកក្នុងចិត្តដោយឧបាយប្រាជ្ញា ១ សេចក្តីប្រតិបត្តិធម៌សមគួរដល់លោកុត្តរធម៌ ១ ។

[ ១១២ ] អង្គរបស់សោតាបន្នបុគ្គល ៤ យ៉ាង ម្នាលអាវុសោទាំង-ឡាយ អរិយសាវ័កក្នុងសាសនានេះ ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ឆ្ងាយចាកកិលេសហើយ ទ្រង់ត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គឯង ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ទ្រង់មានដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណរកបុគ្គលណាស្មើគ្មាន ទ្រង់ជាអ្នកទូន្មាននូវបុរសដែលគួរទូន្មាន ទ្រង់ជាគ្រូរបស់ទេវតា និងមនុស្សទាំងឡាយ ទ្រង់បានត្រាស់ដឹងនូវអរិយ-សច្ចធម៌ ទ្រង់លែងមកកាន់ភពថ្មីទៀត ដោយហេតុនេះ ១ ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើក ក្នុងព្រះធម៌ថា ព្រះបរិយត្តិធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយដោយប្រពៃ ព្រះនព្វលោកុត្តរធម៌ដែលបុគ្គលគប្បីឃើញដោយខ្លួនឯង ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌គួរដល់ឯហិបស្សវិធី ជា

ធម៌គួរបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលពួកវិញ្ញូជនគប្បីដឹងច្បាស់ចំពោះខ្លួន ១ ប្រកបដោយសេចក្ដីជ្រះថ្លាមិនកម្រើក ក្នុងព្រះសង្ឃថា ពួកសាវករបស់ព្រះមានព្រះភាគ ប្រតិបត្តិល្អហើយ ពួកសាវករបស់ព្រះមានព្រះភាគ ប្រតិបត្តិត្រង់ហើយ ពួកសាវករបស់ព្រះមានព្រះភាគ ប្រតិបត្តិដើម្បីព្រះនិព្វាន ពួកសាវករបស់ព្រះមានព្រះភាគ ប្រតិបត្តិគួរហើយ បើរាប់ជាគូនៃបុរសបាន ៤ គូ បើរាប់រៀងជាបុរសបុគ្គលបាន ៨ ពួកសាវករបស់ព្រះមានព្រះភាគនេះ គួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកអំពីចម្ងាយហើយបូជា គួរទទួលនូវសក្ការៈ ដែលគេតាក់តែងដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណា ( ទាន ) គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ១ ប្រកបដោយសីលជាទីត្រេកអរនៃព្រះអរិយៈ គឺជាសីលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុស ជាភុជិស្សសីល ( មិនមែនជាខ្ញុំតណ្ហា ) ជាសីលដែលអ្នកប្រាជ្ញសរសើរ ជាសីលមិនជ្រោកជ្រាកដោយតណ្ហា និងទិដ្ឋិ ជាសីលប្រព្រឹត្តទៅ ដើម្បីបាននូវសមាធិ ១ ។

[ ១១៣ ] សាមញ្ញផល មាន ៤ យ៉ាង គឺសោតាបត្តិផល ១ សកទាគាមិផល ១ អនាគាមិផល ១ អរហត្តផល ១ ។

[ ១១៤ ] ធាតុ ៤ យ៉ាង គឺបឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ ។

[ ១១៥ ] អាហារ ៤ យ៉ាង គឺអាហារគួរធ្វើឲ្យជាពំនូតគ្រោតគ្រាតក្ដី ល្អិតក្ដី ១ ផស្សៈជាអាហារទី ២ មនោសញ្ចេតនាជាអាហារទី ៣ វិញ្ញាណ

ជាអាហារទី ៤ ។

[ ១១៦ ] វិញ្ញាណដ្ឋិតិ ( ធម្មជាតិជាទីតាំងនៅរបស់វិញ្ញាណ ) ៤ យ៉ាង ម្នាលអាវុសោទាំងឡាយ វិញ្ញាណដែលឋិតនៅក៏ស្ថិតនៅអាស្រ័យនឹងរូប មានរូបជាអារម្មណ៍ តាំងនៅក្នុងរូប ចូលទៅអាស្រ័យនូវសេចក្ដីត្រេកអរ តែងដល់នូវសេចក្ដីចម្រើនលូតលាស់ ធំទូលាយ ១ ។ ម្នាលអាវុសោទាំង-ឡាយ វិញ្ញាណអាស្រ័យវេទនា ១ ។ ម្នាលអាវុសោទាំងឡាយ វិញ្ញាណអាស្រ័យសញ្ញា ១ ។ ម្នាលអាវុសោទាំងឡាយ វិញ្ញាណដែលស្ថិតនៅក៏ស្ថិតនៅអាស្រ័យនឹងសង្ខារ មានសង្ខារជាអារម្មណ៍ តាំងនៅក្នុងសង្ខារ ចូលទៅអាស្រ័យនូវសេចក្ដីត្រេកអរ តែងដល់នូវសេចក្ដីចម្រើនលូតលាស់ ធំទូលាយ ១ ។

[ ១១៧ ] ការលុះអគតិ ៤ យ៉ាង គឺបុគ្គលលុះឆន្ទាគតិ ១ លុះទោសាគតិ ១ លុះមោហាគតិ ១ លុះភយាគតិ ១ ។

[ ១១៨ ] ការកើតឡើងនៃតណ្ហា ៤ យ៉ាង ម្នាលអាវុសោទាំងឡាយ តណ្ហាកាលកើតឡើងដល់ភិក្ខុ តែងកើតឡើងព្រោះហេតុតែចីវរ ១ ម្នាលអាវុសោទាំងឡាយ តណ្ហាកាលកើតឡើងដល់ភិក្ខុ តែងកើតឡើងព្រោះហេតុតែបិណ្ឌបាត ១ ម្នាលអាវុសោទាំងឡាយ តណ្ហាកាលកើតឡើងដល់ភិក្ខុ តែងកើតឡើងព្រោះហេតុតែសេនាសេនាសនៈ ១ ម្នាលអាវុសោទាំងឡាយ តណ្ហាកាលកើតឡើងដល់ភិក្ខុ តែងកើតឡើងព្រោះហេតុតែវត្ថុថ្លៃថ្លាយ៉ាងក្រៃលែង ១ ។

[ ១១៩ ] បដិបទា ៤ យ៉ាង គឺបដិបទាជាទុក្ខ ហើយត្រាស់ដឹងបាន ដោយយឺតយូរ ១ បដិបទាជាទុក្ខ ហើយត្រាស់ដឹងបានដោយឆាប់រហ័ស ១ បដិបទាជាសុខ តែត្រាស់ដឹងបានដោយយឺតយូរ ១ បដិបទាជាសុខ ហើយត្រាស់ដឹងបានដោយឆាប់រហ័ស ១ ។

[ ១២០ ] បដិបទា ៤ យ៉ាងដទៃទៀត គឺបដិបទាមិនអត់ធន់ ( នឹងត្រជាក់ជាដើម ) ១ បដិបទាអត់ធន់បាន ១ បដិបទាទូន្មាន ( នូវឥន្ទ្រិយ ) បាន ១ បដិបទារម្ងាប់ ( វិតក្ក ) បាន ១ ។

[ ១២១ ] ចំណែកធម៌ ៤ យ៉ាង គឺសេចក្តីមិនលោភជាចំណែកធម៌ ១ សេចក្តីមិនព្យាបាទជាចំណែកធម៌ ១ ការនឹករឭកត្រូវជាចំណែកធម៌ ១ ការតាំងចិត្តទុកត្រូវជាចំណែកធម៌ ១ ។

[ ១២២ ] ការសមាទានធម៌ ៤ យ៉ាង ម្នាលអាវុសោទាំងឡាយ ការសមាទានធម៌ជាទុក្ខក្នុងបច្ចុប្បន្នផង មានផលជាទុក្ខតទៅខាងមុខផង ១ ម្នាលអាវុសោទាំងឡាយ ការសមាទានធម៌ជាទុក្ខក្នុងបច្ចុប្បន្ន តែមានផលជាសុខតទៅខាងមុខ ១ ម្នាលអាវុសោទាំងឡាយ ការសមាទានធម៌ជាសុខក្នុងបច្ចុប្បន្ន តែមានផលជាទុក្ខតទៅខាងមុខ ១ ម្នាលអាវុសោទាំងឡាយ ការសមាទានធម៌ជាសុខក្នុងបច្ចុប្បន្នផង មានផលជាសុខតទៅខាងមុខផង ១ ។

[ ១២៣ ] ធម្មក្ខន្ធ ៤ យ៉ាង គឺសីលក្ខន្ធ ១ សមាធិក្ខន្ធ ១ បញ្ញាក្ខន្ធ ១ វិមុត្តិក្ខន្ធ ១ ។

[ ១២៤ ] កម្លាំង ៤ យ៉ាង គឺកម្លាំងព្យាយាម ១ កម្លាំងសតិ ១

កម្លាំងសមាធិ ១ កម្លាំងបញ្ញា ១ ។

[ ១២៥ ] អធិដ្ឋាន ៤ យ៉ាង គឺអធិដ្ឋាន គឺមគ្គផលបញ្ញា ១ អធិដ្ឋាន គឺវចីសច្ចៈ ១ អធិដ្ឋាន គឺការលះបង់នូវអាមិសៈ ១ អធិដ្ឋាន គឺការរម្ងាប់នូវកិលេស ១ ។

[ ១២៦ ] បញ្ហាព្យាករណ៍ ( ការឆ្លើយប្រស្នា ) ៤ យ៉ាង គឺប្រស្នាដែលគួរឆ្លើយទៅតែម្តង ១ ប្រស្នាដែលគួរសួរតបទៅវិញ ហើយទើបឆ្លើយ ១ ប្រស្នាដែលគួរឆ្លើយចែករំលែកឲ្យពិស្តារ ១ ប្រស្នាដែលគួរបញ្ឈប់ទុក ១ ។

[ ១២៧ ] កម្ម ៤ យ៉ាង ម្នាលអាវុសោទាំងឡាយ កម្មខ្មៅឲ្យផលខ្មៅក៏មាន ១ ម្នាលអាវុសោទាំងឡាយ កម្មសឲ្យផលសក៏មាន ១ ម្នាលអាវុសោទាំងឡាយ កម្មទាំងខ្មៅទាំងស ឲ្យផលទាំងខ្មៅទាំងសក៏មាន ១ ម្នាលអាវុសោទាំងឡាយ កម្មមិនខ្មៅមិនស ឲ្យផលទាំងមិនខ្មៅទាំងមិនស តែងប្រព្រឹត្តទៅដើម្បីអស់កម្ម ១ ។

[ ១២៨ ] ធម៌ដែលបុគ្គលត្រូវធ្វើឲ្យជាក់ច្បាស់ ៤ យ៉ាង គឺបុព្វេនិវាស ( ដែលខ្លួនអាស្រ័យនៅក្នុងកាលមុន ) ត្រូវធ្វើឲ្យជាក់ច្បាស់ដោយសតិ ១ ចុតូបបាត ( ចុតិ និងបដិសន្ធិ ) របស់សត្វទាំងឡាយ ត្រូវធ្វើឲ្យជាក់ច្បាស់ដោយទិព្វចក្ខុ ១ វិមោក្ខ ៨ ប្រការ ត្រូវធ្វើឲ្យជាក់ច្បាស់ដោយនាមកាយ ១ ធម៌ជាគ្រឿងអស់ទៅនៃអាសវៈទាំងឡាយ ត្រូវធ្វើឲ្យជាក់ច្បាស់ដោយអរហត្តផលបញ្ញា ១ ។

[ ១២៩ ] ឱឃៈ ( ធម៌ជាគ្រឿងពន្លិចសត្វ ) ៤ យ៉ាង គឺកាមោឃៈ

១ ភវោឃៈ ១ ទិដ្ឋោឃៈ ១ អវិជ្ជោឃៈ ១ ។

[ ១៣០ ] យោគៈ ( ធម៌ជាគ្រឿងប្រកបសត្វក្នុងវដ្តៈ ) ៤ យ៉ាង គឺ កាមយោគៈ ១ ភវយោគៈ ១ ទិដ្ឋិយោគៈ ១ អវិជ្ជាយោគៈ ១ ។

[ ១៣១ ] វិសំយោគ ( ធម៌ជាគ្រឿងដោះសត្វ ) ៤ យ៉ាង គឺធម៌ជាគ្រឿងដោះសត្វចាកកាមយោគៈ ១ ធម៌ជាគ្រឿងដោះសត្វចាកភវយោគៈ ១ ធម៌ជាគ្រឿងដោះសត្វចាកទិដ្ឋិយោគៈ ១ ធម៌ជាគ្រឿងដោះសត្វចាកអវិជ្ជាយោគ ១ ។

[ ១៣២ ] ធម៌ជាគ្រឿងចងព័ន្ធ ៤ យ៉ាង គឺអភិជ្ឈាជាគ្រឿងចងព័ន្ធកាយ ១ ព្យាបាទជាគ្រឿងចងព័ន្ធកាយ ១ សេចក្តីប្រកាន់ខុសដោយសីលនិងវត្តជាគ្រឿងចងព័ន្ធកាយ ១ សេចក្តីប្រកាន់មាំថា ពាក្យនេះជាពាក្យពិត ពាក្យដទៃជាពាក្យទទេ ជាគ្រឿងចងព័ន្ធកាយ ១ ។

[ ១៣៣ ] ធម្មជាតជាគ្រឿងប្រកាន់មាំ ៤ យ៉ាង គឺកាមជាគ្រឿងប្រកាន់មាំ ១ មិច្ឆាទិដ្ឋិជាគ្រឿងប្រកាន់មាំ ១ ការប្រកាន់មាំដោយសីលព្វ័ត ១ ការប្រកាន់មាំដោយពោលថាខ្លួន ១ ។

[ ១៣៤ ] កំណើត ៤ យ៉ាង គឺកំណើតរបស់សត្វដែលកើតក្នុងស៊ុត ១ កំណើតរបស់សត្វដែលកើតក្នុងទឹក ១ កំណើតរបស់សត្វដែលកើតក្នុងទីស្មោកគ្រោក ១ កំណើតរបស់សត្វដែលអណ្តែតទៅកើតភ្លាម ១ ។

[ ១៣៥ ] ការចុះកាន់គភ៌ ( របស់សត្វ ) ៤ យ៉ាង ម្នាលអាវុសោទាំងឡាយ សត្វពួកខ្លះក្នុងលោកនេះ ចុះកាន់ផ្ទៃមាតាក៏មិនដឹងខ្លួន ឋិតនៅក្នុង

ផ្ទៃមាតាក៏មិនដឹងខ្លួន សម្រាលចាកផ្ទៃមាតាក៏មិនដឹងខ្លួនទៀត នេះជាការចុះកាន់គភ៌ទី ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត សត្វពួកខ្លះក្នុងលោកនេះ ចុះកាន់ផ្ទៃមាតាដឹងខ្លួន តែនៅក្នុងផ្ទៃមាតាមិនដឹងខ្លួន សម្រាលចាកផ្ទៃមាតា ក៏មិនដឹងខ្លួនដែរ នេះជាការចុះកាន់ផ្ទៃមាតាទី ២ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត សត្វពួកខ្លះក្នុងលោកនេះ ចុះកាន់ផ្ទៃមាតាក៏ដឹងខ្លួន នៅក្នុងផ្ទៃមាតាក៏ដឹងខ្លួន តែសម្រាលចាកផ្ទៃមាតាមិនដឹងខ្លួន នេះជាការចុះកាន់គភ៌ទី ៣ ។ ម្នាលអាវុសោទាំងឡាយ មួយវិញទៀត សត្វពួកខ្លះក្នុងលោកនេះ ចុះកាន់ផ្ទៃមាតាក៏ដឹងខ្លួនទៀត នៅក្នុងផ្ទៃមាតាក៏ដឹងខ្លួន សម្រាលចាកផ្ទៃមាតាក៏ដឹងខ្លួន នេះជាការចុះកាន់គភ៌ទី ៤ ។

[ ១៣៦ ] ការបានទូវអត្តភាពមាន ៤ យ៉ាង ម្នាលអាវុសោទាំងឡាយ ចេតនារបស់ខ្លួន រមែងធ្វើខ្លួនឲ្យស្លាប់ ចេតនារបស់អ្នកដទៃពុំបានធ្វើឲ្យស្លាប់ឡើយ ក្នុងការបានទូវអត្តភាពណា ការបានទូវអត្តភាពនោះ រមែងមាន ១ ។ ម្នាលអាវុសោទាំងឡាយ ចេតនារបស់អ្នកដទៃ រមែងធ្វើខ្លួនឲ្យស្លាប់ ចេតនារបស់ខ្លួនមិនបានធ្វើឲ្យស្លាប់ឡើយ ក្នុងការបានទូវអត្តភាពណា ការបានទូវអត្តភាពនោះ រមែងមាន ១ ។ ម្នាលអាវុសោទាំងឡាយ ចេតនារបស់ខ្លួន រមែងធ្វើខ្លួនឲ្យស្លាប់ ទាំងចេតនារបស់អ្នកដទៃ ក៏រមែងធ្វើឲ្យស្លាប់ ក្នុងការបានទូវអត្តភាពណា ការបានទូវអត្តភាពនោះ រមែងមាន ១ ។ ម្នាលអាវុសោទាំងឡាយ ចេតនារបស់ខ្លួនក៏មិនធ្វើឲ្យស្លាប់ ចេតនារបស់អ្នកដទៃក៏មិនធ្វើឲ្យស្លាប់ដែរ ក្នុងការបានទូវអត្តភាពណា ការបានទូវអត្តភាពនោះរមែងមាន ១ ។

[ ១៣៧ ] សេចក្ដីបរិសុទ្ធិរបស់ទក្ខិណាមាន ៤ យ៉ាង ម្នាលអាវុសោទាំងឡាយ ទក្ខិណាបរិសុទ្ធអំពីទាយក ( អ្នកឲ្យ ) មិនបរិសុទ្ធអំពីបដិគ្គាហក ( អ្នកទទួល ) ១ ។ ម្នាលអាវុសោទាំងឡាយ ទក្ខិណាបរិសុទ្ធអំពីបដិគ្គាហក មិនបរិសុទ្ធអំពីទាយក ១ ។ ម្នាលអាវុសោទាំងឡាយ ទក្ខិណាមិនបរិសុទ្ធអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហក ១ ។ ម្នាលអាវុសោទាំងឡាយ ទក្ខិណាបរិសុទ្ធអំពីទាយកផង អំពីបដិគ្គាហកផង ១ ។

[ ១៣៨ ] សង្គហវត្ថុ មាន ៤ យ៉ាង គឺការឲ្យ ១ ការចរចាពាក្យជាទីស្រឡាញ់ ១ ការប្រព្រឹត្តឲ្យជាប្រយោជន៍ ១ ការៈជាបុគ្គលមានខ្លួនស្មោះស្មើ ១ ។

[ ១៣៩ ] វោហារមិនមែនជារបស់ព្រះអរិយៈ មាន ៤ យ៉ាង គឺពាក្យកុហក ១ សម្ដីញុះញង់ ១ សម្ដីទ្រគោះ ១ សម្ដីរោយរាយឥតប្រយោជន៍ ១ ។

[ ១៤០ ] វោហារជារបស់ព្រះអរិយៈ មាន ៤ យ៉ាង គឺការវៀរចាកពាក្យកុហក ១ ការវៀរចាកសម្ដីញុះញង់ ១ ការវៀរចាកសម្ដីទ្រគោះ ១ ការវៀរចាកសម្ដីរោយរាយឥតប្រយោជន៍ ១ ។

[ ១៤១ ] វោហារមិនមែនជារបស់ព្រះអរិយៈ មាន ៤ យ៉ាងដទៃទៀត គឺមិនឃើញ ថាឃើញ ១ មិនឮ ថាឮ ១ មិនប៉ះពាល់ ថាប៉ះពាល់ ១ មិនដឹងច្បាស់ ថាដឹងច្បាស់ ១ ។

[ ១៤២ ] វោហារជារបស់ព្រះអរិយៈមាន ៤ យ៉ាងដទៃទៀត គឺមិន

ឃើញ ថាមិនឃើញ ១ មិនឮ ថាមិនឮ ១ មិនប៉ះពាល់ ថាមិនប៉ះពាល់ ១ មិនដឹងច្បាស់ ថាមិនដឹងច្បាស់ ១ ។

[ ១៤៣ ] វោហារមិនមែនជារបស់ព្រះអរិយៈមាន ៤ យ៉ាងដទៃទៀត គឺឃើញ ថាមិនឃើញ ១ ឮ ថាមិនឮ ១ បានប៉ះពាល់ ថាមិនបានប៉ះពាល់ ១ ដឹងច្បាស់ ថាមិនដឹងច្បាស់ ១ ។

[ ១៤៤ ] វោហារជារបស់ព្រះអរិយៈ មាន ៤ យ៉ាងដទៃទៀត គឺ ឃើញ ថាឃើញ ១ ឮ ថាឮ ១ ប៉ះពាល់ ថាប៉ះពាល់ ១ ដឹងច្បាស់ ថាដឹងច្បាស់ ១ ។

[ ១៤៥ ] បុគ្គលមាន ៤ ពួក ម្នាលអាវុសោទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកធ្វើខ្លួនឲ្យក្តៅ ប្រកបព្យាយាមដើម្បីធ្វើខ្លួនឲ្យក្តៅ ១ ។ ម្នាលអាវុសោទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកធ្វើបុគ្គលដទៃឲ្យក្តៅ ប្រកបព្យាយាមដើម្បីធ្វើបុគ្គលដទៃឲ្យក្តៅ ១ ។ ម្នាលអាវុសោទាំង-ឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកធ្វើខ្លួនឲ្យក្តៅ ប្រកបព្យាយាមដើម្បីធ្វើខ្លួនឲ្យក្តៅផង ធ្វើបុគ្គលដទៃឲ្យក្តៅ ប្រកបព្យាយាមដើម្បីធ្វើបុគ្គលដទៃឲ្យក្តៅផង ១ ។ ម្នាលអាវុសោទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ មិនធ្វើខ្លួនឲ្យក្តៅ មិនប្រកបព្យាយាមដើម្បីធ្វើខ្លួនឲ្យក្តៅ មិនធ្វើបុគ្គលដទៃឲ្យក្តៅ មិនប្រកបព្យាយាមដើម្បីធ្វើបុគ្គលដទៃឲ្យក្តៅ បុគ្គលនោះ ឈ្មោះថាមិនធ្វើខ្លួនឲ្យក្តៅ មិនធ្វើបុគ្គលដទៃឲ្យក្តៅ ជាអ្នកលែងមានសេចក្តីស្រេកឃ្លាន មានទុក្ខរលត់ហើយ មានសេចក្តីត្រជាក់កើតហើយ ទទួលនូវសេចក្តីសុខ មាន

ខ្លួន ដូចជាព្រហ្មនៅក្នុងបច្ចុប្បន្ននេះ ១ ។

[ ១៤៦ ] បុគ្គលមាន ៤ ពួកដទៃទៀត ម្នាលអាវុសោទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន មិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ១ ។ ម្នាលអាវុសោទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ មិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន ១ ។ ម្នាលអាវុសោទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ មិនប្រតិបត្តិដើម្បីប្រយោជន៍ខ្លួន មិនប្រតិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ១ ។ ម្នាលអាវុសោទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ប្រតិបត្តិដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍អ្នកដទៃផង ១ ។

[ ១៤៧ ] បុគ្គលមាន ៤ ពួកដទៃទៀត គឺបុគ្គលងងឹត មានងងឹតប្រព្រឹត្តទៅខាងមុខទៀត ១ បុគ្គលងងឹត តែមានពន្លឺប្រព្រឹត្តទៅខាងមុខ ១ បុគ្គលមានពន្លឺ តែមានងងឹតប្រព្រឹត្តទៅខាងមុខ ១ បុគ្គលមានពន្លឺ មានពន្លឺប្រព្រឹត្តទៅខាងមុខទៀត ១ ។

[ ១៤៨ ] បុគ្គលមាន ៤ ពួកដទៃទៀត គឺសមណៈមិនកម្រើក ១ សមណៈដូចផ្កាឈូកក្រហម ១ សមណៈដូចផ្កាឈូកស ១ សមណៈជាអ្នកទន់ល្វិតល្អក្នុងពួកសមណៈ ១ ។ ម្នាលអាវុសោទាំងឡាយ ពួកធម៌បួនៗនេះឯង ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សម្តែងហើយដោយប្រពៃ យើងទាំងអស់គ្នា គួរសង្គាយនាក្នុងធម៌នោះ ។បេ។ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ដល់

ទេវតា និងមនុស្សទាំងឡាយ ។

ពួកធម៌បួនៗ ដែលរាប់ចូលក្នុងការសង្គាយនា ចប់

[ ១៤៩ ] ម្នាលអាវុសោទាំងឡាយ ពួកធម៌ប្រាំៗ ព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងហើយដោយប្រពៃ យើងទាំងអស់គ្នា គួរសង្គាយនាក្នុងធម៌ទាំងនោះ ។បេ។ ដើម្បីសេចក្ដីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់ទេវតា និងមនុស្សទាំងឡាយ ។ ពួកធម៌ប្រាំៗ តើដូចម្ដេច ។ ខន្ធ ៥ យ៉ាង គឺរូបក្ខន្ធ ១ វេទនាខន្ធ ១ សញ្ញាខន្ធ ១ សង្ខារក្ខន្ធ ១ វិញ្ញាណក្ខន្ធ ១ ។

[ ១៥០ ] ឧបាទានក្ខន្ធ ៥ យ៉ាង គឺរូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ ។

[ ១៥១ ] កាមគុណ ៥ យ៉ាង គឺរូបទាំងឡាយដែលគប្បីដឹងដោយភ្នែក ជាទីប្រាថ្នា ជាទីពេញចិត្ត ជាទីគាប់ចិត្ត មានសភាពជាទីស្រឡាញ់ អាស្រ័យនូវកាម ជាហេតុនៃសេចក្ដីត្រេកអរ ១ សំឡេងទាំងឡាយដែលគប្បីដឹងដោយត្រចៀក ១ ក្លិនទាំងឡាយដែលគប្បីដឹងដោយច្រមុះ ១ រសទាំង-ឡាយដែលគប្បីដឹងដោយអណ្ដាត ១ សម្ផស្សទាំងឡាយដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីពេញចិត្ត ជាទីគាប់ចិត្ត មានសភាពជាទីស្រឡាញ់ អាស្រ័យនូវកាម ជាហេតុនៃសេចក្ដីត្រេកអរ ១ ។

[ ១៥២ ] គតិ ៥ យ៉ាង គឺនរក ១ កំណើតតិរច្ឆាន ១ ប្រេតវិស័យ ១ ពួកមនុស្ស ១ ពួកទេវតា ១ ។

[ ១៥៣ ] សេចក្តីកំណាញ់ ៥ យ៉ាង គឺកំណាញ់អាវាស ១ កំណាញ់ត្រកូល ១ កំណាញ់លាភ ១ កំណាញ់សេចក្តីសរសើរ ១ កំណាញ់ធម៌ ១ ។

[ ១៥៤ ] នីវរណៈ ៥ យ៉ាង គឺកាមច្ឆន្ទនីវរណៈ ១ ព្យាបាទនីវរណៈ ១ ថីនមិទ្ធនីវរណៈ ១ ឧទ្ធច្ចកុក្កុច្ចនីវរណៈ ១ វិចិកិច្ឆានីវរណៈ ១ ។

[ ១៥៥ ] សំយោជនៈជាចំណែកខាងក្រោម ៥ យ៉ាង គឺសក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាសៈ ១ កាមច្ឆន្ទៈ ១ ព្យាបាទៈ ១ ។

[ ១៥៦ ] សំយោជនៈជាចំណែកខាងលើ ៥ យ៉ាង គឺរូបរាគៈ ១ អរូបរាគៈ ១ មានះ ១ ឧទ្ធច្ចៈ ១ អវិជ្ជា ១ ។

[ ១៥៧ ] សិក្ខាបទ ៥ យ៉ាង គឺការវៀរចាកការសម្លាប់សត្វ ១ វៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ ១ វៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ វៀរចាកការនិយាយកុហក ១ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ ព្រោះផឹកទឹកស្រវឹង គឺសុរា និងមេរ័យ ១ ។

[ ១៥៨ ] អភព្វដ្ឋាន ( ហេតុដែលមិនគួរ ) ៥ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុជាខីណាស្រព មិនគួរដើម្បីក្លែងញុំាងសត្វឲ្យធ្លាក់ចុះចាកជីវិត ១ ភិក្ខុជាខីណាស្រព មិនគួរដើម្បីកាន់យកទ្រព្យដែលគេមិនឲ្យដោយចំណែកគឺចិត្តលួច ១ ភិក្ខុជាខីណាស្រព មិនគួរដើម្បីសេពមេថុនធម្ម ១ ភិក្ខុជាខីណាស្រព មិនគួរពោលសម្បជានមុសាវាទ ១ ភិក្ខុជាខីណាស្រព មិនគួរបរិភោគនូវរបស់ដែលខ្លួនធ្វើសេចក្តីសន្សំទុកនឹងកាមទាំងឡាយ ដូចកាលខ្លួននៅជាគ្រហស្ថក្នុងកាលពីដើម ១ ។

[ ១៥៩ ] សេចក្តីវិនាស ៥ យ៉ាង គឺសេចក្តីវិនាសញាតិ ១ សេចក្តីវិនាសភោគសម្បត្តិ ១ សេចក្តីវិនាសព្រោះរោគ ១ សេចក្តីវិនាសសីល ១ សេចក្តីវិនាសទិដ្ឋិ ១ ម្នាលអាវុសោទាំងឡាយ ពួកសត្វលុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ មិនទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុតែសេចក្តីវិនាសញាតិក្តី ព្រោះហេតុតែសេចក្តីវិនាសភោគៈក្តី ព្រោះហេតុតែសេចក្តីវិនាសដោយរោគក្តី ( នោះទេ ) ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វលុះបែកធ្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅៗ កើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះហេតុតែសេចក្តីវិនាសសីល ឬព្រោះហេតុតែសេចក្តីវិនាសទិដ្ឋិ ។

[ ១៦០ ] សេចក្តីបរិបូណ៌ ៥ យ៉ាង បរិបូណ៌ដោយញាតិ ១ បរិបូណ៌ដោយភោគៈ ១ បរិបូណ៌ដោយភាពមិនមានរោគ ១ បរិបូណ៌ដោយសីល ១ បរិបូណ៌ដោយទិដ្ឋិ ១ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វលុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ មិនទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ព្រោះហេតុតែបរិបូណ៌ដោយញាតិក្តី ព្រោះហេតុតែបរិបូណ៌ដោយភោគៈក្តី ព្រោះហេតុតែបរិបូណ៌ដោយភាពមិនមានរោគក្តីនោះទេ ។ ម្នាលអាវុសោទាំង-ឡាយ ពួកសត្វលុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ តែងបានទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ព្រោះហេតុតែបរិបូណ៌ដោយសីល ឬព្រោះហេតុតែបរិបូណ៌ដោយទិដ្ឋិ ។

[ ១៦១ ] ទោសនៃសីលវិបត្តិ របស់បុគ្គលទ្រុស្តសីល ៥ យ៉ាង

ម្នាលអាវុសោទាំងឡាយ ក្នុងលោកនេះ បុគ្គលទ្រុស្តសីល វិបត្តិចាកសីល នេះ តែងដល់នូវសេចក្តីវិនាសនៃសម្បត្តិយ៉ាងធំ មានសេចក្តីប្រមាទជាហេតុ នេះជាទោសនៃសីលវិបត្តិ របស់បុគ្គលទ្រុស្តសីលទី ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត កិត្តិសព្ទអាក្រក់របស់បុគ្គលទ្រុស្តសីល វិបត្តិចាកសីល រមែងផ្សាយទៅសព្វទិស នេះជាទោសនៃសីលវិបត្តិ របស់បុគ្គលទ្រុស្តសីលទី ២ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត បុគ្គលទ្រុស្តសីល វិបត្តិចាកសីល ចូលទៅរកបរិស័ទណាៗ ទោះខត្តិយបរិស័ទក្តី ព្រាហ្មណ-បរិស័ទក្តី គហបតិបរិស័ទក្តី សមណបរិស័ទក្តី រមែងមិនក្លៀវក្លា មានមុខឱនចុះ នេះជាទោសនៃសីលវិបត្តិ របស់បុគ្គលទ្រុស្តសីលទី ៣ ។ ម្នាលអាវុសោទាំងឡាយ មួយវិញទៀត បុគ្គលទ្រុស្តសីល វិបត្តិចាកសីល តែងវង្វេងធ្វើមរណកាល នេះជាទោសនៃសីលវិបត្តិរបស់បុគ្គលទ្រុស្តសីលទី ៤ ។ ម្នាលអាវុសោទាំងឡាយ មួយវិញទៀត បុគ្គលទ្រុស្តសីល វិបត្តិចាកសីល លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ តែងទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក នេះជាទោសនៃសីលវិបត្តិ របស់បុគ្គលទ្រុស្តសីលទី ៥ ។

[ ១៦២ ] អានិសង្សនៃសីលសម្បទា ៥ យ៉ាង ម្នាលអាវុសោទាំង-ឡាយ ក្នុងលោកនេះ បុគ្គលមានសីល បរិបូណ៌ដោយសីល រមែងបាននូវគំនរទ្រព្យច្រើន មានសេចក្តីមិនប្រមាទជាហេតុ នេះជាអានិសង្សនៃសីល-សម្បទារបស់បុគ្គលមានសីលទី ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត

កិត្តិសព្ទដ៏ពីរោះរបស់បុគ្គលមានសីល បរិបូណ៌ដោយសីល តែងផ្សាយទៅសព្វទិស នេះជាអានិសង្សនៃសីលសម្បទា របស់បុគ្គលមានសីលទី ២ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត បុគ្គលមានសីល បរិបូណ៌ដោយសីល ចូលទៅរកបរិស័ទណាៗ ទោះបីខត្តិយបរិស័ទក្តី ព្រាហ្មណបរិស័ទក្តី គហបតិបរិស័ទក្តី សមណបរិស័ទក្តី រមែងក្លៀវក្លា មិនមានមុខឱនចុះ នេះជាអានិសង្សនៃសីលសម្បទារបស់បុគ្គលមានសីលទី ៣ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត បុគ្គលមានសីល បរិបូណ៌ដោយសីល រមែងមិនវង្វេងធ្វើមរណកាល នេះជាអានិសង្សនៃសីលសម្បទា របស់បុគ្គលមានសីលទី ៤ ។ ម្នាលអាវុសោទាំងឡាយ មួយវិញទៀត បុគ្គលមានសីល បរិបូណ៌ដោយសីល លុះបែកធ្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ តែងបានទៅកើតក្នុងសុគតិ សួគ៌ ទេវលោក នេះជាអានិសង្សនៃសីលសម្បទា របស់បុគ្គលមានសីលទី ៥ ។

[ ១៦៣ ] ម្នាលអាវុសោទាំងឡាយ ភិក្ខុអ្នកចោទមានប្រាថ្នានឹងចោទភិក្ខុដទៃ ត្រូវតម្កល់ធម៌ ៥ យ៉ាង ទុកក្នុងខ្លួនហើយសឹមចោទភិក្ខុដទៃដោយគិតថា អាត្មាអញនឹងនិយាយក្នុងកាលគួរ មិននិយាយក្នុងកាលមិនគួរ ១ អាត្មាអញនិយាយដោយពាក្យពិត មិននិយាយដោយពាក្យមិនពិត ១ អាត្មាអញនិយាយដោយពាក្យផ្អែមល្ហែម មិននិយាយដោយពាក្យទ្រគោះ ១ អាត្មាអញនិយាយដោយពាក្យប្រកបដោយប្រយោជន៍ មិននិយាយដោយពាក្យមិនប្រកបដោយប្រយោជន៍ ១ អាត្មាអញនិយាយដោយចិត្តប្រកបដោយមេត្តា

មិននិយាយដោយចិត្តប្រកបដោយទោស ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុអ្នកចោទមានប្រាថ្នានឹងចោទភិក្ខុដទៃ ត្រូវតម្កល់ធម៌ ៥ ប្រការនេះ ទុកក្នុងខ្លួនហើយ ទើបចោទភិក្ខុដទៃបាន ។

[ ១៦៤ ] អង្គនៃភិក្ខុដែលមានសេចក្តីព្យាយាម មាន ៥ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសទ្ធា ជឿសេចក្តីត្រាស់ដឹងរបស់ព្រះតថាគតថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ឆ្ងាយចាកកិលេសហើយ ទ្រង់ត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គឯង ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ទ្រង់មានដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណ រកបុគ្គលណាស្មើគ្មាន ទ្រង់ជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ទ្រង់ជាគ្រូរបស់ទេវតា និងមនុស្សទាំងឡាយ ទ្រង់បានត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងមកកាន់ភពថ្មីទៀត ដោយហេតុនេះៗ ១ ជាអ្នកមិនមានអាពាធ មិនមានសេចក្តីទុក្ខ ប្រកបដោយតេជោធាតុចាស់ល្មម មិនត្រជាក់ពេក មិនក្តៅពេក យ៉ាងកណ្តាល គួរដល់សេចក្តីព្យាយាម ១ មិនមែនជាអ្នកលេងបោកប្រាស មិនមានមាយា ជាអ្នកធ្វើឲ្យជាក់ច្បាស់នូវខ្លួនគួរតាមពិត ក្នុងសម្នាក់ព្រះសាស្តា ឬក្នុងសម្នាក់សព្រហ្មចារីទាំងឡាយ ដែលជាអ្នកចេះដឹង ១ ជាបុគ្គលប្រារព្ធព្យាយាម ដើម្បីលះបង់នូវធម៌ជាអកុសល ដើម្បីញុំាងកុសលឲ្យដុះដាលឡើង ជាបុគ្គលមានកម្លាំងចិត្ត មានសេចក្តីសង្វាតដ៏មាំ មិនដាក់ធុរៈចោលក្នុងកុសលធម៌ទាំងឡាយ ១ ជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញា ដែលអាចនឹងកំណាត់នូវសេចក្តីកើត និង

សេចក្ដីរលត់បាន ជាបញ្ញាដ៏បរិសុទ្ធ ជាបញ្ញាអាចទម្លុះទម្លាយនូវគំនរនៃលោភៈជាដើម ជាបញ្ញាញុំាងសត្វឲ្យដល់នូវកិរិយាអស់ទៅនៃទុក្ខដោយប្រពៃ ១ ។

[ ១៦៥ ] សុទ្ធាវាស មាន ៥ យ៉ាង គឺអវិហៈ ១ អតប្បៈ ១ សុទស្សៈ ១ សុទស្សី ១ អកនិដ្ឋ ១ ។

[ ១៦៦ ] អនាគាមិបុគ្គល ៥ ពួក គឺលោកដែលបរិនិព្វានក្នុងពាក់កណ្ដាលអាយុ ១ លោកដែលបរិនិព្វានដោយកន្លងហួសពាក់កណ្ដាលអាយុ ១ លោកដែលបរិនិព្វានដោយមិនមានសេចក្ដីព្យាយាម ១ លោកដែលបរិនិព្វានដោយសេចក្ដីព្យាយាមយ៉ាងខ្លាំង ១ លោកដែលមានខ្សែខាងលើហើយទៅកាន់អកនិដ្ឋភព ១ ។

[ ១៦៧ ] ចេតោខិលៈ ( សេចក្ដីរឹងត្អឹងរបស់ចិត្ត ) មាន ៥ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ សង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះថ្លាក្នុងព្រះសាស្ដា ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុណាសង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះថ្លាក្នុងព្រះសាស្ដា ចិត្តរបស់ភិក្ខុនោះមិនឱនទៅ ដើម្បីព្យាយាមដុតកម្ដៅកិលេស ដើម្បីព្យាយាមជាគ្រឿងប្រកបរឿយៗ ដើម្បីព្យាយាមជាប់តទៅ ចិត្តរបស់ភិក្ខុណា មិនឱនទៅដើម្បីព្យាយាមដុតកម្ដៅកិលេស ដើម្បីព្យាយាមជាគ្រឿងប្រកបរឿយៗ ដើម្បីព្យាយាមជាប់តទៅ នេះជាសេចក្ដីរឹងត្អឹងនៃចិត្តទី ១ របស់ភិក្ខុនោះ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុសង្ស័យក្នុងព្រះធម៌ ១ ។ ភិក្ខុសង្ស័យក្នុងព្រះសង្ឃ ១ ។ សង្ស័យ ងឿងឆ្ងល់ក្នុងសិក្ខា ១ ។ ភិក្ខុក្រោធអាក់អន់ចិត្ត

មានចិត្តត្រូវទោសៈខ្ទាំងខ្ទប់ មានចិត្តរឹងត្អឹងក្នុងសព្រហ្មចារីបុគ្គលទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុណា ជាបុគ្គលក្រោធអាក់អន់ចិត្ត មានចិត្តត្រូវទោសៈខ្ទាំងខ្ទប់ មានចិត្តរឹងត្អឹងក្នុងសព្រហ្មចារីបុគ្គលទាំងឡាយ ចិត្តរបស់ភិក្ខុនោះ រមែងមិនឱនទៅដើម្បីព្យាយាមដុតកម្តៅកិលេស ដើម្បីព្យាយាមជាគ្រឿងប្រកបរឿយៗ ដើម្បីព្យាយាមជាប់តទៅ ចិត្តរបស់ភិក្ខុណា មិនឱនទៅដើម្បីព្យាយាមដុតកម្តៅកិលេស ដើម្បីព្យាយាមជាគ្រឿងប្រកបរឿយៗ ដើម្បីព្យាយាមជាប់តទៅ នេះជាសេចក្តីរឹងត្អឹងនៃចិត្តទី ៥ របស់ភិក្ខុនោះ ។

[ ១៦៨ ] ចំណងរបស់ចិត្តមាន ៥ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកចំណង់ មិនទាន់ប្រាសចាកសេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្តីក្រវល់ក្រវាយ មិនទាន់ប្រាសចាកសេចក្តីប្រាថ្នាក្នុងកាមទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុណា មិនទាន់ប្រាសចាកតម្រេក មិនទាន់ប្រាសចាកចំណង់ មិនទាន់ប្រាសចាកសេចក្តីស្រឡាញ់ មិនទាន់ប្រាសចាកសេចក្តីស្រេកឃ្លាន មិនទាន់ប្រាសចាកសេចក្តីក្តៅក្រហាយ មិនទាន់ប្រាសចាកសេចក្តីប្រាថ្នាក្នុងកាមទាំងឡាយ ចិត្តរបស់ភិក្ខុនោះ រមែងមិនឱនទៅដើម្បីព្យាយាមដុតកម្តៅកិលេស ដើម្បីព្យាយាមជាគ្រឿងប្រកបរឿយៗ ដើម្បីព្យាយាមជាប់តទៅ ចិត្តរបស់ភិក្ខុណាមិនឱនទៅដើម្បីព្យាយាមដុតកម្តៅកិលេស ដើម្បីព្យាយាមជាគ្រឿងប្រកបរឿយៗ ដើម្បីព្យាយាមជាប់តទៅ នេះជាចំណងនៃចិត្តទី ១ របស់ភិក្ខុនោះ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត

ភិក្ខុមិនទាន់ប្រាសចាកតម្រេកក្នុងកាយ ។ សេចក្តីបង្រួញ ។ ភិក្ខុមិនទាន់ប្រាសចាកតម្រេកក្នុងរូប ។ សេចក្តីបង្រួញ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុបរិភោគត្រាតែឆ្អែតពេញពោះ ហើយប្រកបរឿយៗ នូវសេចក្តីសុខក្នុងទីដេក នូវសេចក្តីសុខ ( ព្រោះដេកប្រែប្រួលខាងស្តាំខាងឆ្វេង ) នូវសេចក្តីសុខ ព្រោះដេកលក់លង់ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុប្រព្រឹត្តព្រហ្មចរិយធម៌ ព្រោះប្រាថ្នានូវពួកទេវតាជាន់ណាមួយថា ដោយសីល ឬវត្ត ដោយសេចក្តីព្យាយាម ឬព្រហ្មចារ្យនេះឯង សូមឲ្យអាត្មាអញបានជាទេវតា ( មានសក្តិធំ ) ឬទេវតា ( មានសក្តិតូច ) ណាមួយ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុណា ប្រព្រឹត្តព្រហ្មចរិយធម៌ ព្រោះប្រាថ្នានូវពួកទេវតា ណាមួយថា ដោយសីល ឬវត្ត ដោយព្យាយាម ឬព្រហ្មចារ្យនេះឯង សូមឲ្យអាត្មាអញបានជាទេវតា ( មានសក្តិធំ ) ឬទេវតា ( មានសក្តិតូច ) ណាមួយ ចិត្តរបស់ភិក្ខុនោះ រមែងមិនឱនទៅដើម្បីព្យាយាមដុតកម្តៅកិលេស ដើម្បីព្យាយាមជាគ្រឿងប្រកបរឿយៗ ដើម្បីព្យាយាមជាប់តទៅ នេះជាចំណងរបស់ចិត្តទី ៥ ។

[ ១៦៩ ] ឥន្ទ្រិយមាន ៥ យ៉ាង គឺចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ ឃានិន្ទ្រិយ ១ ជិវ្ហិន្ទ្រិយ ១ កាយិន្ទ្រិយ ១ ។

[ ១៧០ ] ឥន្ទ្រិយមាន ៥ ដទៃទៀត គឺសុខិន្ទ្រិយ ១ ទុក្ខិន្ទ្រិយ ១ សោមនស្សិន្ទ្រិយ ១ ទោមនស្សិន្ទ្រិយ ១ ឧបេក្ខិន្ទ្រិយ ១ ។

[ ១៧១ ] ឥន្ទ្រិយមាន ៥ ដទៃទៀត គឺសទ្ធិន្ទ្រិយ ១ វីរិយិន្ទ្រិយ ១

សតិន្ទ្រិយ ១ សមាធិន្ទ្រិយ ១ បញ្ញិន្ទ្រិយ ១ ។

[ ១៧២ ] និស្សារណីយធាតុ ( ធាតុដែលគួររលាស់ចេញ ) មាន ៥ យ៉ាង ម្នាលអាវុសោទាំងឡាយ កាលដែលភិក្ខុក្នុងសាសនានេះ ធ្វើទុកក្នុងចិត្តនូវកាមទាំងឡាយ ចិត្តរមែងមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនជ្រុលជ្រប់នៅក្នុងកាមទាំងឡាយ តែបើកាលភិក្ខុនោះ ធ្វើទុកក្នុងចិត្តនូវនេក្ខម្មៈ ( ការចេញចាកកាម ) ចិត្តរមែងស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងនេក្ខម្មៈ ចិត្តរបស់ភិក្ខុនោះ ឈ្មោះថា ទៅល្អហើយ អប់រំល្អហើយ ចេញល្អហើយ រួចស្រឡះហើយ ប្រាសចាកហើយចាកកាមទាំងឡាយ អាសវៈទាំងឡាយណា ជាសភាវៈចង្អៀតចង្អល់ក្តៅក្រហាយ តែងកើតឡើងព្រោះកាមជាបច្ច័យ ភិក្ខុនោះ រួចហើយចាកអាសវៈទាំងឡាយនោះ ភិក្ខុនោះ រមែងមិនទទួលនូវវេទនានោះ នេះជាការរលាស់ចេញនូវកាមទាំងឡាយ ដែលព្រះមានព្រះភាគសម្តែងហើយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត កាលដែលភិក្ខុធ្វើទុកក្នុងចិត្តនូវព្យាបាទ ចិត្តរមែងមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនជ្រុលជ្រប់នៅក្នុងព្យាបាទ តែបើភិក្ខុនោះ ធ្វើទុកក្នុងចិត្តនូវសេចក្តីមិនព្យាបាទ ចិត្តរមែងស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងការមិនព្យាបាទ ចិត្តរបស់ភិក្ខុនោះ ឈ្មោះថា ទៅល្អហើយ អប់រំល្អហើយ ចេញល្អហើយ រួចស្រឡះល្អហើយ ប្រាសចេញហើយចាកព្យាបាទ អាសវៈទាំងឡាយណា ជាសភាវៈចង្អៀតចង្អល់ក្តៅក្រហាយ តែងកើតឡើងព្រោះព្យាបាទជាបច្ច័យ ភិក្ខុនោះ រួចហើយចាកអាសវៈទាំងឡាយនោះ ភិក្ខុនោះ រមែងមិនទទួលនូវវេទនានោះ នេះជា

ការរលាស់ចេញនូវព្យាបាទ ដែលព្រះមានព្រះភាគទ្រង់សំដែងហើយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត កាលដែលភិក្ខុធ្វើទុកក្នុងចិត្តនូវសេចក្តីបៀតបៀន ចិត្តរមែងមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនជ្រុលជ្រប់នៅក្នុងការបៀតបៀន តែបើភិក្ខុនោះធ្វើទុកក្នុងចិត្តនូវការមិនបៀតបៀន ចិត្តរមែងស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងការមិនបៀតបៀន ចិត្តរបស់ភិក្ខុនោះឈ្មោះថា ទៅល្អហើយ អប់រំល្អហើយ ចេញល្អហើយ រួចស្រឡះល្អហើយ ប្រាសចេញហើយចាកការបៀតបៀន អាសវៈទាំងឡាយណា ជាសភាវៈចង្អៀតចង្អល់ក្តៅក្រហាយ តែងកើតឡើងព្រោះការបៀតបៀនជាបច្ច័យ ភិក្ខុនោះ រួចហើយចាកអាសវៈទាំងឡាយនោះ ភិក្ខុនោះរមែងមិនទទួលនូវវេទនានោះ នេះជាការរលាស់ចេញនូវការបៀតបៀន ដែលព្រះមានព្រះភាគទ្រង់សំដែងហើយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត កាលដែលភិក្ខុធ្វើទុកក្នុងចិត្តនូវរូបទាំងឡាយ ចិត្តរមែងមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនជ្រុលជ្រប់នៅក្នុងរូបទាំងឡាយ តែបើភិក្ខុនោះធ្វើទុកក្នុងចិត្តនូវអរូប ចិត្តរមែងស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងអរូប ចិត្តរបស់ភិក្ខុនោះ ឈ្មោះថា ទៅល្អហើយ អប់រំល្អហើយ ចេញល្អហើយ រួចល្អហើយ ប្រាសចេញហើយចាករូបទាំងឡាយ អាសវៈទាំងឡាយណា ជាសភាវៈចង្អៀតចង្អល់ក្តៅក្រហាយ តែងកើតឡើងព្រោះរូបជាបច្ច័យ ភិក្ខុនោះ រួចហើយ ចាករូបទាំងឡាយនោះ ភិក្ខុនោះ រមែងមិនទទួលនូវវេទនានោះ នេះជាការរលាស់ចេញនូវរូបទាំងឡាយ ដែលព្រះមានព្រះភាគទ្រង់សំដែងហើយ ១ ។ ម្នាល

អាវុសោទាំងឡាយ មួយវិញទៀត កាលដែលភិក្ខុធ្វើទុកក្នុងចិត្តនូវសក្កាយ ( បញ្ចក្ខន្ធ ) ចិត្តរមែងមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅ មិនជ្រុលជ្រប់នៅក្នុងសក្កាយ តែបើភិក្ខុនោះ ធ្វើទុកក្នុងចិត្តនូវការរលត់ទៅនៃសក្កាយ ចិត្តរមែងស្ទុះទៅ ជ្រះថ្លា តាំងនៅ ចុះស៊ប់ក្នុងការរលត់ទៅនៃសក្កាយ ចិត្តរបស់ភិក្ខុនោះ ឈ្មោះថា ទៅល្អហើយ អប់រំល្អហើយ ចេញល្អហើយ រួចស្រឡះល្អហើយ ប្រាសចេញហើយចាកសក្កាយ អាសវៈទាំងឡាយណា ជាសភាវៈចង្អៀតចង្អល់ ក្តៅក្រហាយ តែងកើតឡើងព្រោះសក្កាយជាបច្ច័យ ភិក្ខុនោះរួចហើយចាកអាសវៈទាំងឡាយនោះ ភិក្ខុនោះ រមែងមិនទទួលនូវវេទនានោះ នេះជាការរលាស់ចេញនូវសក្កាយ ដែលព្រះមានព្រះភាគសម្តែងហើយ ១ ។

[ ១៧៣ ] វិមុត្តាយតនៈ ( ហេតុជាគ្រឿងរួច ) មាន ៥ យ៉ាង ម្នាលអាវុសោទាំងឡាយ ព្រះសាស្តា ឬសព្រហ្មចារីបុគ្គលណាមួយ ដែលគួរដល់ឋានៈជាគ្រូ រមែងសម្តែងធម៌ដល់ភិក្ខុក្នុងសាសនានេះ ។ ម្នាលអាវុសោទាំងឡាយ ព្រះសាស្តា ឬសព្រហ្មចារីបុគ្គលណាមួយ ដែលគួរដល់ឋានៈជាគ្រូ រមែងសម្តែងធម៌ដល់ភិក្ខុយ៉ាងណាៗ ភិក្ខុនោះ រមែងជាអ្នកដឹងច្បាស់នូវអត្ថរស ដឹងច្បាស់នូវធម៌រស ក្នុងធម៌នោះយ៉ាងនោះៗ ។ បាមោជ្ជ ( សេចក្តីរីករាយ ) រមែងកើតដល់ភិក្ខុនោះ ដែលជាអ្នកដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ លុះភិក្ខុមានសេចក្តីរីករាយហើយ បីតិក៏រមែងកើតឡើង កាលបើចិត្តប្រកបដោយបីតិហើយ នាមកាយក៏ស្ងប់រម្ងាប់ ភិក្ខុមាននាមកាយស្ងប់រម្ងាប់ហើយ រមែងទទួលនូវសេចក្តីសុខ លុះប្រកបសេចក្តីសុខហើយ ចិត្តក៏រមែង

តម្កល់មាំ នេះជាវិមុត្តាយតនៈទី ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ព្រះសាស្តា ឬសព្រហ្មចារីបុគ្គលណាមួយ ដែលគួរដល់ឋានៈជាគ្រូ មិនសម្តែងធម៌ដល់ភិក្ខុទេ តែថា ភិក្ខុនោះ រមែងសម្តែងធម៌ដែលខ្លួនបានស្តាប់មកហើយយ៉ាងណា បានរៀនមកហើយយ៉ាងណា ដោយសេចក្តីពិស្តារដល់ជនទាំងឡាយដទៃ ។ សេចក្តីបន្រ្ទញ ។ តែថា ភិក្ខុនោះ ធ្វើនូវការស្វាធ្យាយនូវធម៌ដែលខ្លួនបានស្តាប់មកហើយយ៉ាងណា បានរៀនមកហើយយ៉ាងណា ដោយសេចក្តីពិស្តារ ។បេ។ តែថា ភិក្ខុនោះត្រិះរិះរឿយៗ ពិចារណារឿយៗ ដោយចិត្ត ជញ្ជឹងក្នុងចិត្តរឿយៗ ចំពោះធម៌ដែលខ្លួនបានស្តាប់មកហើយយ៉ាងណា រៀនមកហើយយ៉ាងណា ។បេ។ តែថា សមាធិនិមិត្តណាមួយ ក៏ភិក្ខុនោះរៀនយកដោយល្អ ធ្វើទុកក្នុងចិត្តដោយល្អ ពិចារណាដោយល្អ ចាក់ធ្លុះដោយល្អ ដោយប្រាជ្ញាបាន ។ ម្នាលអាវុសោទាំងឡាយ សមាធិនិមិត្តណាមួយដែលភិក្ខុរៀនយកដោយល្អ ធ្វើទុកក្នុងចិត្តដោយល្អ ពិចារណាដោយល្អ ចាក់ធ្លុះដោយល្អ ដោយប្រាជ្ញាយ៉ាងណាៗ ភិក្ខុនោះរមែងជាអ្នកដឹងច្បាស់នូវអត្ថផង ដឹងច្បាស់នូវធម៌ផង ក្នុងធម៌នោះយ៉ាងនោះៗ ។ កាលភិក្ខុនោះបានដឹងច្បាស់នូវអត្ថ បានដឹងច្បាស់នូវធម៌ហើយ បាមោជ្ជរមែងកើតឡើង លុះបាមោជ្ជកើតឡើងហើយ បីតិរមែងកើតឡើង កាលបើចិត្តប្រកបដោយបីតិហើយ នាមកាយក៏រមែងស្ងប់រម្ងាប់ ភិក្ខុមាននាមកាយស្ងប់រម្ងាប់ហើយ តែងទទួលនូវសេចក្តីសុខ កាលភិក្ខុទទួលសេចក្តីសុខហើយ ចិត្តក៏តម្កល់នៅមាំ នេះជាវិមុត្តាយតនៈទី ៥ ។

[ ១៧៤ ] សញ្ញា ( សេចក្តីសម្គាល់ ) ញ៉ាំងវិមុត្តិឲ្យចាស់ក្លា មាន ៥ យ៉ាង គឺសេចក្តីសម្គាល់ថាមិនទៀង ១ សេចក្តីសម្គាល់ថាទុក្ខក្នុងរបស់មិនទៀង ១ សេចក្តីសម្គាល់ថាមិនមែនរបស់ខ្លួន ក្នុងរបស់ប្រកបដោយទុក្ខ ១ សេចក្តីសម្គាល់ក្នុងធម៌ជាគ្រឿងលះ ១ សេចក្តីសម្គាល់ក្នុងធម៌ជាគ្រឿងនឿយណាយ ១ ។ ម្នាលអាវុសោទាំងឡាយ ពួកធម៌ប្រាំៗ នេះឯង ដែលព្រះមានព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សម្តែងទុកហើយដោយប្រពៃ យើងទាំងអស់គ្នា គប្បីសង្គាយនាក្នុងធម៌ទាំងនោះ ។បេ។ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។

ពួកធម៌ប្រាំៗ ដែលរាប់ចូលក្នុងការសង្គាយនា ចប់

[ ១៧៥ ] ម្នាលអាវុសោទាំងឡាយ ពួកធម៌ប្រាំមួយៗ ដែលព្រះមានព្រះភាគអង្គនោះ ។បេ។ ជាសម្មាសម្ពុទ្ធទ្រង់សម្តែងទុកដោយប្រពៃ យើងទាំងអស់គ្នា គប្បីសង្គាយនាក្នុងធម៌ទាំងនោះ ។បេ។ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។ ពួកធម៌ប្រាំមួយៗ តើដូចម្តេច ។ អាយតនៈខាងក្នុង ៦ យ៉ាង គឺអាយតនៈ គឺភ្នែក ១ អាយតនៈ គឺត្រចៀក ១ អាយតនៈគឺច្រមុះ ១ អាយតនៈគឺអណ្តាត ១ អាយតនៈ គឺកាយ ១ អាយតនៈ គឺចិត្ត ១ ។

[ ១៧៦ ] អាយតនៈខាងក្រៅ ៦ យ៉ាង គឺអាយតនៈ គឺរូប ១ អាយតនៈ គឺសំឡេង ១ អាយតនៈ គឺក្លិន ១ អាយតនៈ គឺរស ១

អាយតនៈ គឺផ្សព្វ ១ អាយតនៈ គឺធម៌ ១ ។

[ ១៧៧ ] ប្រជុំនៃវិញ្ញាណ ៦ យ៉ាង គឺចក្ខុវិញ្ញាណ ១ សោតវិញ្ញាណ ១ ឃានវិញ្ញាណ ១ ជិវ្ហាវិញ្ញាណ ១ កាយវិញ្ញាណ ១ មនោវិញ្ញាណ ១ ។

[ ១៧៨ ] ប្រជុំនៃផស្សៈ ៦ យ៉ាង គឺចក្ខុសម្ផស្ស ១ ។បេ។ មនោសម្ផស្ស ១ ។

[ ១៧៩ ] ប្រជុំនៃវេទនា ៦ យ៉ាង គឺវេទនាកើតអំពីចក្ខុសម្ផស្ស ១ ។បេ។ វេទនាកើតអំពីមនោសម្ផស្ស ១ ។

[ ១៨០ ] ប្រជុំនៃសញ្ញា ៦ យ៉ាង គឺរូបសញ្ញា ១ ។បេ។ ធម្មសញ្ញា ១ ។

[ ១៨១ ] ប្រជុំនៃសញ្ចេតនា ៦ យ៉ាង គឺរូបសញ្ចេតនា ១ ។បេ។ ធម្មសញ្ចេតនា ១ ។

[ ១៨២ ] ប្រជុំនៃតណ្ហា ៦ យ៉ាង គឺរូបតណ្ហា ១ សទ្ទតណ្ហា ១ គន្ធតណ្ហា ១ រសតណ្ហា ១ ផោដ្ឋព្វតណ្ហា ១ ធម្មតណ្ហា ១ ។

[ ១៨៣ ] អគារវៈ ( សេចក្តីមិនគោរព ) ៦ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែងក្នុងព្រះសាស្តា ១ មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែងក្នុងព្រះធម៌ ១ មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែងក្នុងព្រះសង្ឃ ១ មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែងក្នុងសិក្ខា ១ មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែងក្នុងអប្បមាទធម៌ ១ មិនមានសេចក្តីគោរព មិនមានសេចក្តីកោតក្រែងក្នុងបដិសណ្ឋារៈ ១ ។

[ ១៨៤ ] សគារវៈ ( សេចក្តីគោរព ) ៦ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ប្រកបដោយសេចក្តីគោរព ប្រកបដោយសេចក្តីកោតក្រែងក្នុងព្រះសាស្តា ១ ប្រកបដោយសេចក្តីគោរព ប្រកបដោយសេចក្តីកោតក្រែងក្នុងព្រះធម៌ ១ ប្រកបដោយសេចក្តីគោរព ប្រកបដោយសេចក្តីកោតក្រែងក្នុងព្រះសង្ឃ ១ ប្រកបដោយសេចក្តីគោរព ប្រកបដោយសេចក្តីកោតក្រែងក្នុងសិក្ខា ១ ប្រកបដោយសេចក្តីគោរព ប្រកបដោយសេចក្តីកោតក្រែងក្នុងអប្បមាទធម៌ ១ ប្រកបដោយសេចក្តីគោរព ប្រកបដោយសេចក្តីកោតក្រែងក្នុងបដិសណ្ឋារៈ ១ ។

[ ១៨៥ ] សោមនស្សុបវិចារ ( ធម៌ជាគ្រឿងគន់គិតប្រកបដោយសោមនស្ស ) ៦ យ៉ាង គឺបុគ្គលឃើញរូបដោយភ្នែក ក៏គន់គិតនូវរូបដែលគួរជាទីតាំងនៃសោមនស្ស ១ ។ ស្តាប់សំឡេងដោយត្រចៀក ... ១ ។ ធុំក្លិនដោយច្រមុះ ... ១ ។ ទទួលរសដោយអណ្តាត ... ១ ។ ពាល់ត្រូវផ្សព្វដោយកាយ .... ១ ។ ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត ក៏គន់គិតនូវធម្មារម្មណ៍ ដែលគួរជាទីតាំងនៃសោមនស្ស ១ ។

[ ១៨៦ ] ទោមនស្សុបវិចារ ( ធម៌ជាគ្រឿងគន់គិតប្រកបដោយទោមនស្ស ) ៦ យ៉ាង គឺបុគ្គលឃើញរូបដោយភ្នែក ក៏គន់គិតនូវរូបដែលគួរជាទីតាំងនៃទោមនស្ស ១ ។ ស្តាប់សំឡេងដោយត្រចៀក ... ១ ។ ធុំក្លិនដោយច្រមុះ ... ១ ។ ទទួលរសដោយអណ្តាត ... ១ ។ ពាល់ត្រូវផ្សព្វដោយកាយ .... ១ ។ ដឹងធម្មារម្មណ៍ដោយចិត្ត ក៏គន់គិតនូវធម្មារម្មណ៍ដែល

គួរជាទីតាំងនៃទោមនស្ស ១ ។

[ ១៨៧ ] ឧបេក្ខូបវិចារ ( ធម៌ជាគ្រឿងគន់គិតប្រកបដោយឧបេក្ខា ) ៦ យ៉ាង គឺបុគ្គលឃើញរូបដោយភ្នែក ក៏គន់គិតនូវរូបដែលជាទីតាំងនៃឧបេក្ខា ១ ។ ស្តាប់សំឡេងដោយត្រចៀក ... ១ ។ ធុំក្លិនដោយច្រមុះ ... ១ ។ ទទួលរសដោយអណ្តាត ... ១ ។ ពាល់ត្រូវផ្សព្វដោយកាយ .... ១ ។ ដឹងធម្មារម្មណ៍ដោយចិត្ត ក៏គន់គិតនូវធម្មារម្មណ៍ដែលគួរជាទីតាំងនៃឧបេក្ខា ១ ។

[ ១៨៨ ] សារាណីយធម៌ ( ធម៌គួររឭក ) ៦ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ តម្កល់នូវកាយកម្មប្រកបដោយមេត្តាចំពោះសព្រហ្មចារីទាំងឡាយ ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ នេះជាធម៌គួររឭក ធ្វើសេចក្តីស្រឡាញ់ ធ្វើសេចក្តីគោរព ប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះ ដើម្បីមិនទាស់គ្នា ដើម្បីសាមគ្គី ដើម្បីឯកីភាព ( ភាពតែពួកមួយ ១ ) ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុតម្កល់នូវវចីកម្មប្រកបដោយមេត្តា ១ ។ ភិក្ខុតម្កល់នូវមនោកម្មប្រកបដោយមេត្តា ចំពោះសព្រហ្មចារីទាំងឡាយ ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ នេះជាធម៌គួររឭក ។បេ។ ប្រព្រឹត្តទៅដើម្បីឯកីភាព ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកបរិភោគមិនចែកមុខរបស់ ឬបុគ្គល ដោយលាភទាំងឡាយ ដែលប្រកបដោយធម៌ បានមកដោយធម៌ ដោយហោចទៅ សូម្បីលាភត្រឹមតែរបស់ដែលមានក្នុងបាត្រ គឺជាអ្នកមានការបរិភោគ ជាសាធារណៈ ដោយសព្រហ្មចារីទាំងឡាយដែលមានសីល នេះជាធម៌គួររឭក ។បេ។ ប្រព្រឹត្តទៅដើម្បីឯកីភាព ។ ម្នាល

អាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានសីលស្មើគ្នា ដោយសព្រហ្មចារីទាំងឡាយ ក្នុងសីលទាំងឡាយដែលជាសីលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុស ជាសីលរួចខ្លួន គឺមិនជាខ្ញុំតណ្ហា ដែលវិញ្ញូជនសរសើរហើយ មិនមានតណ្ហា និងទិដ្ឋិប៉ះពាល់បាន ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ នេះជាធម៌គួររឭក ។បេ។ ប្រព្រឹត្តទៅដើម្បីឯកីភាព ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុមានសេចក្តីយល់ឃើញស្មើគ្នានឹងសព្រហ្មចារីធម៌ទាំងឡាយ ក្នុងទិដ្ឋិដ៏ប្រសើរ ជាទីស្រោចស្រង់សត្វប្រព្រឹត្តទៅដើម្បីអស់ទៅនៃទុក្ខដោយប្រពៃ ដល់អ្នកធ្វើតាមទិដ្ឋិនោះ ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ នេះជាធម៌គួររឭក ធ្វើសេចក្តីស្រឡាញ់ ធ្វើសេចក្តីគោរព ប្រព្រឹត្តទៅដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសាមគ្គី ដើម្បីឯកីភាព ។

[ ១៨៩ ] មូលនៃសេចក្តីវិវាទ ៦ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានសេចក្តីក្រោធ ចងសេចក្តីក្រោធទុក ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុណាមានសេចក្តីក្រោធ ចងសេចក្តីក្រោធទុក ភិក្ខុនោះ មិនមានសេចក្តីគោរពកោតក្រែង ក្នុងព្រះសាស្តាខ្លះ មិនមានសេចក្តីគោរពកោតក្រែងក្នុងព្រះធម៌ខ្លះ មិនមានសេចក្តីគោរពកោតក្រែង ក្នុងព្រះសង្ឃខ្លះ ជាអ្នកមិនធ្វើឲ្យបរិបូណ៌ក្នុងសិក្ខាខ្លះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុណាមួយ មិនមានសេចក្តីគោរពកោតក្រែងក្នុងព្រះសាស្តា ក្នុងព្រះធម៌ ។បេ។ ក្នុងព្រះសង្ឃ ។បេ។ ជាអ្នកមិនធ្វើឲ្យបរិបូណ៌ក្នុងសិក្ខា ។ ភិក្ខុនោះ រមែង

បន្ទិវិវាទក្នុងសង្ឃ ដែលជាវិវាទកើតឡើង ដើម្បីមិនជាប្រយោជន៍ដល់ជនច្រើន ដើម្បីមិនជាសុខដល់ជនច្រើន ដើម្បីមិនចម្រើនដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដល់ទេវតា និងមនុស្សទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ បើលោកទាំងឡាយឃើញមូលហេតុនៃវិវាទ មានសភាពយ៉ាងនេះ ខាងក្នុង ឬខាងក្រៅហើយ ។ ម្នាលអាវុសោទាំងឡាយ លោកទាំងឡាយ ត្រូវព្យាយាមដើម្បីលះមូលហេតុនៃវិវាទដ៏លាមកនោះចេញ ។ ម្នាលអាវុសោទាំងឡាយ បើលោកទាំងឡាយ មិនឃើញមូលហេតុនៃវិវាទមានសភាពយ៉ាងនេះ ខាងក្នុង ឬខាងក្រៅទេ ។ ម្នាលអាវុសោទាំងឡាយ លោកទាំងឡាយ ត្រូវប្រតិបត្តិដើម្បីមិនឲ្យមូលហេតុនៃវិវាទដ៏លាមកនោះជាប់តាមតទៅ ។ ការលះមូលហេតុនៃវិវាទដ៏លាមកនុ៎ះ រមែងមានយ៉ាងនេះ ការមិនមានមូលហេតុនៃវិវាទដ៏លាមកនុ៎ះជាប់តាមតទៅ រមែងមានយ៉ាងនេះ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកលុបគុណ និងវាយឫកស្មើ ១ ។ ជាអ្នកមានសេចក្តីឫស្យា និងកំណាញ់ ១ ។ ជាអ្នកអួតអាង មានពុតត្បុត ១ ។ ជាអ្នកមានប្រាថ្នាលាមក មានទិដ្ឋិខុស ១ ។ ជាអ្នកស្ទាបអង្អែលតែទិដ្ឋិរបស់ខ្លួន ជាអ្នកប្រកាន់មាំ កម្រនឹងលះបង់បាន ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុណា ជាអ្នកស្ទាបអង្អែលតែទិដ្ឋិរបស់ខ្លួន ជាអ្នកប្រកាន់មាំ លះបង់បានដោយក្រ ភិក្ខុនោះរមែងមិនគោរព មិនកោតក្រែងក្នុងព្រះសាស្តាខ្លះ មិនគោរព មិនកោតក្រែងក្នុងព្រះធម៌ខ្លះ មិនគោរព មិនកោតក្រែងក្នុងព្រះសង្ឃខ្លះ មិនជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសិក្ខាខ្លះ ។ ម្នាលអាវុសោ

ទាំងឡាយ ភិក្ខុណាមួយជាអ្នកមិនគោរព មិនកោតក្រែងក្នុងព្រះសាស្តាខ្លះ ក្នុងព្រះធម៌ខ្លះ ។បេ។ ក្នុងព្រះសង្ឃខ្លះ ។បេ។ មិនធ្វើឲ្យពេញលេញក្នុងសិក្ខាខ្លះ ។ ភិក្ខុនោះរមែងបង្កវិវាទក្នុងសង្ឃ ដែលជាវិវាទកើតឡើង ដើម្បីមិនជាប្រយោជន៍ដល់ជនច្រើន ដើម្បីមិនជាសុខដល់ជនច្រើន ដើម្បីមិនចម្រើនដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខដល់ទេវតា និងមនុស្សទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ បើអ្នកទាំងឡាយ ពិចារណាឃើញមូលហេតុនៃវិវាទ មានសភាពយ៉ាងនេះ ខាងក្នុងឬខាងក្រៅហើយ ។ម្នាលអាវុសោទាំងឡាយ លោកទាំងឡាយត្រូវព្យាយាមលះមូលហេតុនៃវិវាទដ៏លាមកនោះឯងចេញ ។ ម្នាលអាវុសោទាំងឡាយ បើលោកទាំងឡាយមិនពិចារណាឃើញមូលហេតុនៃវិវាទ មានសភាពយ៉ាងនេះ ខាងក្នុង ឬខាងក្រៅទេ ។ ម្នាលអាវុសោទាំងឡាយ លោកទាំងឡាយត្រូវប្រតិបត្តិដើម្បីមិនឲ្យមានមូលហេតុនៃវិវាទដ៏លាមកនោះឯង ជាប់តាមតទៅបាន ។ ការលះមូលហេតុនៃវិវាទដ៏លាមកនុ៎ះ រមែងមានយ៉ាងនេះ ការមិនមានមូលហេតុនៃវិវាទដ៏លាមកជាប់តាមតទៅ រមែងមានយ៉ាងនេះ ១ ។

[ ១៩០ ] ធាតុ ៦ យ៉ាង គឺធាតុដី ១ ធាតុទឹក ១ ធាតុភ្លើង ១ ធាតុខ្យល់ ១ ធាតុអាកាស ១ ធាតុវិញ្ញាណ ១ ។

[ ១៩១ ] និស្សារណីយធាតុ ៦ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ និយាយយ៉ាងនេះថា មេត្តាចេតោវិមុត្តិ ខ្ញុំបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ ធ្វើឲ្យជាទីតាំងហើយ

តម្កល់មាំហើយ សន្សំទុកហើយ ប្រារព្ធល្អហើយ តែថា ព្យាបាទនៅតែគ្របសង្កត់ចិត្តខ្ញុំបាន ។ ភិក្ខុត្រូវនិយាយឃាត់ភិក្ខុនោះថា លោកកុំនិយាយយ៉ាងនេះឡើយ លោកដ៏មានអាយុ កុំនិយាយយ៉ាងនេះឡើយ កុំពោលបង្កាច់ព្រះមានព្រះភាគឡើយ ព្រោះការពោលបង្កាច់ព្រះមានព្រះភាគ ជាការមិនល្អទេ ព្រះមានព្រះភាគ មិនមានព្រះពុទ្ធដីកាយ៉ាងនេះសោះ ។ ម្នាលអាវុសោទាំងឡាយ ការនេះមិនមែនជាហេតុ មិនមែនជាបច្ច័យទេ មេត្តាចេតោវិមុត្តិដែលភិក្ខុចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ ធ្វើឲ្យជាទីតាំងហើយ តម្កល់មាំហើយ សន្សំទុកហើយ ប្រារព្ធល្អហើយ តែថាព្យាបាទនៅតែគ្របសង្កត់ចិត្តភិក្ខុនោះ ហេតុនេះមិនដែលមាន ។ ម្នាលអាវុសោទាំងឡាយ ព្រោះមេត្តាចេតោវិមុត្តិនុ៎ះ ជាគ្រឿងរលាស់ចេញនូវព្យាបាទ ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ និយាយយ៉ាងនេះថា ករុណាចេតោវិមុត្តិ ខ្ញុំបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ ធ្វើឲ្យដូចជាយានហើយ ធ្វើឲ្យជាទីតាំងហើយ តម្កល់មាំហើយ សន្សំទុកហើយ ប្រារព្ធល្អហើយ តែថា សេចក្តីបៀតបៀននៅតែគ្របសង្កត់ចិត្តខ្ញុំបាន ។ ភិក្ខុត្រូវនិយាយឃាត់ភិក្ខុនោះថា លោកកុំនិយាយយ៉ាងនេះឡើយ លោកដ៏មានអាយុកុំនិយាយយ៉ាងនេះឡើយ កុំពោលបង្កាច់ព្រះមានព្រះភាគឡើយ ព្រោះការពោលបង្កាច់ព្រះមានព្រះភាគជាការមិនល្អទេ ព្រះមានព្រះភាគមិនមានព្រះពុទ្ធដីកាយ៉ាងនេះសោះ ។ ម្នាលអាវុសោទាំងឡាយ ការនេះមិនមែនជាហេតុមិនមែនជាបច្ច័យទេ ករុណាចេតោវិមុត្តិដែលភិក្ខុបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បាន

ធ្វើឲ្យដូចជាយានហើយ ធ្វើឲ្យជាទីតាំងហើយ តម្កល់មាំហើយ សន្សំទុក ហើយ ប្រារព្ធល្អហើយ តែថា សេចក្តីបៀតបៀននៅតែគ្របសង្កត់ចិត្តភិក្ខុនោះបាន ហេតុនេះមិនដែលមាន ។ ម្នាលអាវុសោទាំងឡាយ ព្រោះករុណាចេតោ-វិមុត្តិនុ៎ះ ជាគ្រឿងរលាស់ចេញនូវសេចក្តីបៀតបៀន ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ និយាយយ៉ាងនេះថា មុទិតាចេតោវិមុត្តិ ខ្ញុំបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ ធ្វើឲ្យជាទីតាំងហើយ តម្កល់មាំហើយ សន្សំទុកហើយ ប្រារព្ធល្អហើយ តែថា សេចក្តីមិនត្រេកអរ នៅតែគ្របសង្កត់ចិត្តខ្ញុំបាន ។ ភិក្ខុត្រូវនិយាយឃាត់ភិក្ខុនោះថា លោកកុំនិយាយយ៉ាងនេះឡើយ លោកដ៏មានអាយុកុំនិយាយយ៉ាងនេះឡើយ កុំពោលបង្កាច់ព្រះមានព្រះភាគឡើយ ព្រោះការពោលបង្កាច់ព្រះមានព្រះភាគ ជាការមិនល្អទេ ព្រះមានព្រះភាគមិនមានព្រះពុទ្ធដីកាយ៉ាងនេះសោះ ។ ម្នាលអាវុសោទាំងឡាយ ការនេះមិនមែនជាហេតុមិនមែនជាបច្ច័យទេ មុទិតាចេតោវិមុត្តិដែលភិក្ខុបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ ធ្វើឲ្យជាទីតាំងហើយ តម្កល់មាំហើយ សន្សំទុកហើយ ប្រារព្ធល្អហើយ តែថា សេចក្តីមិនត្រេកអរនៅតែគ្របសង្កត់ចិត្តភិក្ខុនោះបាន ហេតុនេះមិនដែលមាន ។ ម្នាលអាវុសោទាំងឡាយ ព្រោះមុទិតា-ចេតោវិមុត្តិនុ៎ះ ជាគ្រឿងរលាស់ចេញនូវសេចក្តីមិនត្រេកអរ ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ និយាយយ៉ាងនេះថា ឧបេក្ខា-ចេតោវិមុត្តិ ខ្ញុំបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន

ហើយ ធ្វើឲ្យជាទីតាំងហើយ តម្កល់មាំហើយ សន្សំទុកហើយ ប្រារព្ធល្អហើយ តែថា រាគៈនៅតែគ្របសង្កត់ចិត្តខ្ញុំបាន ។ ភិក្ខុត្រូវនិយាយឃាត់ភិក្ខុនោះថា លោកកុំនិយាយយ៉ាងនេះឡើយ លោកដ៏មានអាយុកុំនិយាយយ៉ាងនេះឡើយ កុំពោលបង្កាច់ព្រះមានព្រះភាគឡើយ ព្រោះការពោលបង្កាច់ព្រះមានព្រះភាគ ជាការមិនល្អទេ ព្រះមានព្រះភាគមិនមានព្រះពុទ្ធដីកាយ៉ាងនេះសោះ ។ ម្នាលអាវុសោទាំងឡាយ ការនេះមិនមែនជាហេតុ មិនមែនជាបច្ច័យទេ ឧបេក្ខា-ចេតោវិមុត្តិ ដែលភិក្ខុបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ ធ្វើឲ្យជាទីតាំងហើយ តម្កល់មាំហើយ សន្សំទុកហើយ ប្រារព្ធល្អហើយ តែថា រាគៈនៅតែគ្របសង្កត់ចិត្តភិក្ខុនោះបាន ហេតុនេះមិនដែលមាន ។ ម្នាលអាវុសោទាំងឡាយ ព្រោះឧបេក្ខាចេតោវិមុត្តិនុ៎ះ ជាគ្រឿងរលាស់ចេញនូវរាគៈ ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ និយាយយ៉ាងនេះថា អនិមិត្តាចេតោវិមុត្តិ ( អរហត្តផលសមាបត្តិ ) ខ្ញុំបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ ធ្វើឲ្យជាទីតាំងហើយ តម្កល់មាំហើយ សន្សំទុកហើយ ប្រារព្ធល្អហើយ តែថា ខ្ញុំនៅតែមានវិញ្ញាណ ដែលរឭកតាមនូវនិមិត្ត ។ ភិក្ខុត្រូវនិយាយឃាត់ភិក្ខុនោះថា លោកកុំនិយាយយ៉ាងនេះឡើយ លោកដ៏មានអាយុកុំនិយាយយ៉ាងនេះឡើយ កុំពោលបង្កាច់ព្រះមានព្រះភាគឡើយ ព្រោះការពោលបង្កាច់ព្រះមានព្រះភាគ ជាការមិនល្អទេ ព្រះមានព្រះភាគមិនមានព្រះពុទ្ធដីកាយ៉ាងនេះសោះ ។ ម្នាលអាវុសោទាំងឡាយ ការនេះមិនមែនជាហេតុ មិនមែនជាបច្ច័យទេ អនិមិត្តា-

ចេតោវិមុត្តិដែលភិក្ខុបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយានហើយ ធ្វើឲ្យជាទីតាំងហើយ តម្កល់មាំហើយ សន្សំទុកហើយ ប្រារព្ធល្អហើយ តែថា ភិក្ខុនោះ នឹងមានវិញ្ញាណរឭកតាមនូវនិមិត្ត ហេតុនេះមិនដែលមាន ។ ម្នាលអាវុសោទាំងឡាយ ព្រោះអនិមិត្តាចេតោវិមុត្តិនោះ ជាគ្រឿងរលាស់ចេញនូវនិមិត្តទាំងអស់ ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ និយាយយ៉ាងនេះថា កាលបើសេចក្តីប្រកាន់របស់ខ្ញុំថា អាត្មាអញមានដូច្នេះ អស់រលីងទៅហើយ ខ្ញុំក៏ពិចារណាមិនឃើញថា របស់ឈ្មោះនេះ គឺអាត្មាអញនៅមានដូច្នេះដែរ តែថា ព្រួញ គឺសេចក្តីសង្ស័យ ងឿងឆ្ងល់ នៅតែគ្របសង្កត់ចិត្តខ្ញុំបាន ។ ភិក្ខុត្រូវនិយាយឃាត់ភិក្ខុនោះថា លោកកុំនិយាយយ៉ាងនេះឡើយ លោកដ៏មានអាយុកុំនិយាយយ៉ាងនេះឡើយ កុំពោលបង្កាច់ព្រះមានព្រះភាគឡើយ ព្រោះការពោលបង្កាច់ព្រះមានព្រះភាគជាការមិនល្អទេ ព្រះមានព្រះភាគមិនមានព្រះពុទ្ធដីកាយ៉ាងនេះសោះ ។ ម្នាលអាវុសោទាំងឡាយ ការនេះមិនមែនជាហេតុ មិនមែនជាបច្ច័យទេ កាលបើសេចក្តីប្រកាន់របស់ភិក្ខុនោះថា អាត្មាអញមានដូច្នេះ អស់រលីងទៅហើយ ភិក្ខុនោះក៏ពិចារណាមិនឃើញថា របស់ឈ្មោះនេះ គឺអាត្មាអញនៅមានដូច្នេះដែរ តែថា ព្រួញ គឺសេចក្តីសង្ស័យ ងឿងឆ្ងល់ នៅតែគ្របសង្កត់ចិត្តភិក្ខុនោះ ហេតុនេះមិនដែលមាន ។ ម្នាលអាវុសោទាំងឡាយ ព្រោះការគាស់រម្លើងសេចក្តីប្រកាន់ថា អាត្មានៅមានដូច្នេះនុ៎ះចេញបាន ជាគ្រឿងរលាស់ចេញនូវព្រួញ គឺសេចក្តីសង្ស័យ ងឿងឆ្ងល់បាន ១ ។

[ ១៩២ ] អនុត្តរិយៈ ( ធម្មជាតប្រសើរបំផុត ) មាន ៦ យ៉ាង គឺ ទស្សនានុត្តរិយៈ ( ប្រសើរបំផុតដោយការឃើញ ) ១ សវនានុត្តរិយៈ ( ប្រសើរបំផុតដោយការស្តាប់ ) ១ លាភានុត្តរិយៈ ( ប្រសើរបំផុតដោយការបាន ) ១ សិក្ខានុត្តរិយៈ ( ប្រសើរបំផុតដោយការសិក្សា ) ១ បារិចរិយានុត្តរិយៈ ( ប្រសើរបំផុតខាងការបម្រើ ) ១ អនុស្សតានុត្តរិយៈ ( ប្រសើរបំផុតដោយការរឭករឿយៗ ) ១ ។

[ ១៩៣ ] ទីតាំងនៃអនុស្សតិមាន ៦ យ៉ាង គឺពុទ្ធានុស្សតិ ១ ធម្មានុស្សតិ ១ សង្ឃានុស្សតិ ១ សីលានុស្សតិ ១ ចាគានុស្សតិ ១ ទេវតានុស្សតិ ១ ។

[ ១៩៤ ] ធម៌ជាគ្រឿងនៅដ៏ទៀងទាត់ ( របស់ព្រះខីណាស្រព ) មាន ៦ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយចក្ខុក៏មិនត្រេកអរ មិនអន់ចិត្ត គឺជាបុគ្គលនៅព្រងើយ តែមានសតិ និងសម្បជញ្ញៈ ១ ។ ឮសំឡេងដោយត្រចៀក ។បេ។ ធុំក្លិនដោយច្រមុះ ។បេ។ ទទួលរសដោយអណ្តាត ។បេ។ ពាល់ត្រូវផ្សព្វដោយកាយ ។បេ។ ដឹងធម្មារម្មណ៍ដោយចិត្ត មិនត្រេកអរ មិនអន់ចិត្ត គឺជាបុគ្គលនៅព្រងើយៗ តែមានសតិ និងសម្បជញ្ញៈ ១ ។

[ ១៩៥ ] អភិជាតិ ( កំណើត ) មាន ៦ យ៉ាង ម្នាលអាវុសោទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ កើតក្នុងត្រកូលខ្មៅ ( ត្រកូលទាប ) ហើយប្រព្រឹត្តធម៌ខ្មៅ ( ទុច្ចរិត ) ទៀត ១ ម្នាលអាវុសោទាំងឡាយ បុគ្គល

ពួកខ្លះក្នុងលោកនេះ កើតក្នុងត្រកូលខ្មៅ ហើយប្រព្រឹត្តធម៌ស ( សុចរិត ) ១ ម្នាលអាវុសោទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ កើតក្នុងត្រកូលខ្មៅ ហើយប្រព្រឹត្តធម៌មិនខ្មៅមិនស គឺព្រះនិព្វាន ១ ម្នាលអាវុសោទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ កើតក្នុងត្រកូលស ( ត្រកូលខ្ពស់ ) ហើយប្រព្រឹត្តធម៌ស ១ ។ ម្នាលអាវុសោទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ កើតក្នុងត្រកូលស ហើយប្រព្រឹត្តធម៌ខ្មៅ ១ ។ ម្នាលអាវុសោទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ កើតក្នុងត្រកូលស ហើយប្រព្រឹត្តធម៌មិនខ្មៅមិនស គឺព្រះនិព្វាន ១ ។

[ ១៩៦ ] និព្វេធភាគិយសញ្ញា ( សេចក្តីសម្គាល់នូវធម៌បែរទៅជិតព្រះនិព្វាន ) មាន ៦ យ៉ាង គឺសេចក្តីសម្គាល់ថាមិនទៀង ១ សេចក្តីសម្គាល់ក្នុងរបស់ដែលមិនទៀងថាជាទុក្ខ ១ សេចក្តីសម្គាល់ក្នុងរបស់ជាទុក្ខថាមិនមែនជារបស់ខ្លួន ១ សេចក្តីសម្គាល់ក្នុងរបស់គួរលះបង់ ១ សេចក្តីសម្គាល់ក្នុងរបស់គួរនឿយណាយ ១ សេចក្តីសម្គាល់ក្នុងធម៌ជាគ្រឿងរម្ងត់ទុក្ខ ១ ។ ម្នាលអាវុសោទាំងឡាយ នេះឯងធម៌ពួកប្រាំមួយៗ ដែលព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សម្តែងទុកល្អហើយ យើងទាំងអស់គ្នាត្រូវសង្គាយនាធម៌ពួកប្រាំមួយៗ នោះ ។បេ។ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំងឡាយ ។

ពួកធម៌ប្រាំមួយៗ ដែលរាប់ចូលក្នុងការសង្គាយនា ចប់

[ ១៩៧ ] ម្នាលអាវុសោទាំងឡាយ មានធម៌ពួកប្រាំពីរៗ ដែលព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ត្រាស់សំដែងទុកល្អហើយ យើងទាំងអស់គ្នាត្រូវសង្គាយនាក្នុងធម៌ពួកប្រាំពីរៗ នោះ ។បេ។ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយ ។ ធម៌ពួកប្រាំពីរដូចម្តេចខ្លះ ។ អរិយទ្រព្យមាន ៧ យ៉ាង គឺទ្រព្យ គឺសទ្ធា ១ ទ្រព្យ គឺសីល ១ ទ្រព្យ គឺហិរិ ១ ទ្រព្យ គឺឱត្តប្បៈ ១ ទ្រព្យ គឺសុតៈ ១ ទ្រព្យ គឺចាគៈ ១ ទ្រព្យ គឺបញ្ញា ១ ។

[ ១៩៨ ] ពោជ្ឈង្គមាន ៧ យ៉ាង គឺសតិសម្ពោជ្ឈង្គ ១ ធម្មវិចយសម្ពោជ្ឈង្គ ១ វីរិយសម្ពោជ្ឈង្គ ១ បីតិសម្ពោជ្ឈង្គ ១ បស្សទ្ធិសម្ពោជ្ឈង្គ ១ សមាធិសម្ពោជ្ឈង្គ ១ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។

[ ១៩៩ ] សមាធិបរិក្ខារ ( ធម៌ជាបរិវារសមាធិ ) មាន ៧ យ៉ាង គឺសម្មាទិដ្ឋិ ១ សម្មាសង្កប្ប ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១ សម្មាសតិ ១ ។

[ ២០០ ] អសទ្ធម្ម ( ធម៌របស់អសប្បុរស ) មាន ៧ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនជឿ ១ មិនខ្មាសបាប ១ មិនខ្លាចបាប ១ មានការចេះដឹងតិច ១ ខ្ជិលច្រអូស ១ ប្រហែស ១ អប្បឥតប្រាជ្ញា ១ ។

[ ២០១ ] សទ្ធម្ម ( ធម៌របស់សប្បុរស ) មាន ៧ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកជឿ ១ ខ្មាសបាប ១ ខ្លាច

បាប ១ មានការបេះដូងច្រើន ១ ផ្តើមសេចក្តីព្យាយាម ១ ប្រុងស្មារតី ១ មានប្រាជ្ញា ១ ។

[ ២០២ ] សប្បុរិសធម៌មាន ៧ យ៉ាង ( ទៀត ) ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកស្គាល់នូវហេតុ ១ ជាអ្នកស្គាល់នូវផល ( របស់ហេតុ ) ១ ជាអ្នកស្គាល់ខ្លួន ១ ជាអ្នកស្គាល់ប្រមាណ ( ក្នុងភោជន ) ១ ជាអ្នកស្គាល់កាលគួរ ១ ជាអ្នកស្គាល់បរិស័ទ ១ ជាអ្នកស្គាល់បុគ្គល ( គួរគប់ និងមិនគួរគប់ ) ១ ។

[ ២០៣ ] និទ្ទសវត្ថុ មាន ៧ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានបំណងដ៏ក្លៀវក្លា ក្នុងការសមាទានសិក្ខា មិនប្រាសចាកសេចក្តីស្រឡាញ់ ក្នុងការសមាទានសិក្ខាតទៅ ១ មានបំណងដ៏ក្លៀវក្លាក្នុងការពិចារណាធម៌ មិនប្រាសចាកសេចក្តីស្រឡាញ់ក្នុងការពិចារណាធម៌តទៅ ១ មានបំណងដ៏ក្លៀវក្លា ក្នុងការកម្ចាត់បង់នូវឥច្ឆា គឺតណ្ហា មិនប្រាសចាកសេចក្តីស្រឡាញ់ ក្នុងការកម្ចាត់បង់នូវឥច្ឆា គឺតណ្ហាតទៅ ១ មានបំណងដ៏ក្លៀវក្លាក្នុងការស្ងប់ស្ងាត់ មិនប្រាសចាកសេចក្តីស្រឡាញ់ ក្នុងការស្ងប់ស្ងាត់តទៅ ១ មានបំណងដ៏ក្លៀវក្លាក្នុងការប្រារព្ធព្យាយាម មិនប្រាសចាកសេចក្តីស្រឡាញ់ក្នុងការប្រារព្ធព្យាយាមតទៅ ១ មានបំណងដ៏ក្លៀវក្លាក្នុងការរឭកនិងភាវៈនៃខ្លួនមានប្រាជ្ញាចាស់ មិនប្រាសចាកសេចក្តីស្រឡាញ់ក្នុងការរឭកនិងភាវៈនៃខ្លួនមានប្រាជ្ញាចាស់តទៅ ១ មានបំណងក្នុងការត្រាស់ដឹងដោយទិដ្ឋិ គឺឃើញនូវមគ្គ មិនប្រាសចាកសេចក្តីស្រឡាញ់ក្នុងការត្រាស់ដឹងដោយទិដ្ឋិ

តទៅ ១ ។

[ ២០៤ ] សញ្ញាមាន ៧ យ៉ាង គឺអនិច្ចសញ្ញា ១ អនត្តសញ្ញា ១ អសុភសញ្ញា ១ អាទីនវសញ្ញា ១ បហានសញ្ញា ១ វិរាគសញ្ញា ១ និរោធសញ្ញា ១ ។

[ ២០៥ ] កម្លាំងមាន ៧ យ៉ាង គឺកម្លាំងសទ្ធា ១ កម្លាំងព្យាយាម ១ កម្លាំងហិរិ ១ កម្លាំងឱត្តប្បៈ ១ កម្លាំងសតិ ១ កម្លាំងសមាធិ ១ កម្លាំងបញ្ញា ១ ។

[ ២០៦ ] វិញ្ញាណដ្ឋិតិ ( ទីតាំងនៃវិញ្ញាណ ) មាន ៧ យ៉ាង ម្នាលអាវុសោទាំងឡាយ មានពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នា ដូចពួកមនុស្ស ទេវតាពួកខ្លះ និងវិនិបាតិកៈពួកខ្លះ នេះជាវិញ្ញាណដ្ឋិតិទី ១ ។ ម្នាលអាវុសោទាំងឡាយ មានពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ដូចទេវតាក្នុងពួកព្រហ្ម ដែលកើតក្នុងជាន់បឋមជ្ឈានភូមិ នេះជាវិញ្ញាណដ្ឋិតិទី ២ ។ ម្នាលអាវុសោទាំងឡាយ មានពួកសត្វមានកាយដូចគ្នា មានសញ្ញាផ្សេងគ្នា ដូចពួកទេវតាក្នុងជាន់អាភស្សរៈ នេះជាវិញ្ញាណដ្ឋិតិទី ៣ ។ ម្នាលអាវុសោទាំងឡាយ មានពួកសត្វមានកាយដូចគ្នា មានសញ្ញាដូចគ្នា ដូចពួកទេវតាក្នុងជាន់សុភកិណ្ហៈ នេះជាវិញ្ញាណដ្ឋិតិទី ៤ ។ ម្នាលអាវុសោទាំងឡាយ មានពួកសត្វចូលកាន់អាកាសានញ្ចាយតនជ្ឈាន ដោយគិតថា អាកាសមិនមានទីបំផុត ព្រោះកន្លងបង់នូវពួករូបសញ្ញា ព្រោះវិនាសទៅនៃពួកបដិឃសញ្ញា ព្រោះមិនធ្វើទុកក្នុងចិត្តនូវពួកនានត្តសញ្ញា ដោយប្រការទាំងពួង នេះ

ជាវិញ្ញាណដ្ឋិតិទី ៥ ។ ម្នាលអាវុសោទាំងឡាយ មានពួកសត្វកន្លងបង់នូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់វិញ្ញាណ-ញ្ចាយតនជ្ឈាន ដោយគិតថា វិញ្ញាណមិនមានទីបំផុត នេះជាវិញ្ញាណដ្ឋិតិទី ៦ ។ ម្នាលអាវុសោទាំងឡាយ មានពួកសត្វកន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន ដោយគិតថា វត្ថុតិចតួចមិនមាន នេះជាវិញ្ញាណដ្ឋិតិទី ៧ ។

[ ២០៧ ] បុគ្គលគួរទទួលនូវទក្ខិណាទាន មាន ៧ ពួក គឺលោកជាឧភតោភាគវិមុត្ត ១ បញ្ញាវិមុត្តិ ១ កាយសក្ខី ១ ទិដ្ឋិប្បត្ត ១ សទ្ធាវិមុត្តិ ១ ធម្មានុសារី ១ សទ្ធានុសារី ១ ។

[ ២០៨ ] អនុសយក្កិលេស មាន ៧ យ៉ាង គឺកាមរាគានុស័យ ១ បដិឃានុស័យ ១ ទិដ្ឋានុស័យ ១ វិចិកិច្ឆានុស័យ ១ មានានុស័យ ១ ភវរាគានុស័យ ១ អវិជ្ជានុស័យ ១ ។

[ ២០៩ ] សញ្ញោជនៈ មាន ៧ យ៉ាង គឺកាមសញ្ញោជនៈ ១ បដិ-ឃសញ្ញោជនៈ ១ ទិដ្ឋិសញ្ញោជនៈ ១ វិចិកិច្ឆាសញ្ញោជនៈ ១ មាន-សញ្ញោជនៈ ១ ភវរាគសញ្ញោជនៈ ១ អវិជ្ជាសញ្ញោជនៈ ១ ។

[ ២១០ ] អធិករណសមថៈមាន ៧ យ៉ាង គឺធម៌សម្រាប់រម្ងាប់នូវអធិករណ៍ដែលកើតឡើងហើយៗ សង្ឃត្រូវឲ្យសម្មុខាវិន័យ ១ ត្រូវឲ្យសតិ-វិន័យ ១ ត្រូវឲ្យអមូឡ្ហវិន័យ ១ ត្រូវធ្វើតាមសេចក្តីប្តេជ្ញា ១ យេភុយ្យសិកា ១ តស្សបាបិយសិកា ១ តិណវត្ថារកៈ ១ ។ ម្នាលអាវុសោទាំងឡាយ នេះ

ឯងជាពួកធម៌ប្រាំពីរ ដែលព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់ត្រាស់សម្តែងទុក ដោយប្រពៃហើយ ពួកយើងទាំងអស់គ្នា ត្រូវសង្គាយនាក្នុងធម៌ពួកប្រាំពីរនោះ ។បេ។ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំងឡាយ ។

**ពួកធម៌ប្រាំពីរៗ ដែលរាប់ចូលក្នុងការសង្គាយនា ចប់**

[ ២១១ ] ម្នាលអាវុសោទាំងឡាយ មានធម៌ពួកប្រាំបី ដែលព្រះមានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់ត្រាស់សម្តែងទុកល្អហើយ ពួកយើងទាំងអស់គ្នា ត្រូវសង្គាយនាក្នុងធម៌ពួកប្រាំបីនោះ ។បេ។ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំងឡាយ ។ ពួកធម៌ប្រាំបីតើដូចម្តេច ។ មិច្ឆត្តៈ ( ភាវៈដែលខុស ) មាន ៨ យ៉ាង គឺមិច្ឆាទិដ្ឋិ ១ មិច្ឆាសង្កប្ប ១ មិច្ឆាវាចា ១ មិច្ឆាកម្មន្តៈ ១ មិច្ឆាអាជីវៈ ១ មិច្ឆាវាយាមៈ ១ មិច្ឆាសតិ ១ មិច្ឆាសមាធិ ១ ។

[ ២១២ ] សម្មត្តៈ ( ភាវៈដែលត្រូវ ) មាន ៨ យ៉ាង គឺសម្មាទិដ្ឋិ ១ សម្មាសង្កប្ប ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មាសមាធិ ១ ។

[ ២១៣ ] បុគ្គលគួរទទួលនូវទក្ខិណាទាន មាន ៨ ពួក គឺលោកអ្នកដល់នូវសោតៈហើយ ១ ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ១ ជាសកទាគាមី ១ ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ១ ជាអនាគាមី ១ ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ១ ជាអរហន្ត ១

ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវភាវៈជាអរហន្ត ១ ។

[ ២១៤ ] កុសីតវត្ថុ ( ហេតុរបស់បុគ្គលខ្ជិល ) មាន ៨ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវធ្វើការងារ ភិក្ខុនោះមានគំនិតយ៉ាងនេះថា ការងារហ្នឹងឯង អាត្មាអញនឹងត្រូវធ្វើ តែថា បើអាត្មាអញធ្វើការងារទៅហើយ កាយនឹងលំបាក ណ្ហើយចុះអាត្មាអញដេកសិន ។ ភិក្ខុនោះក៏ដេក មិនប្រុងប្រៀបព្យាយាម ដើម្បីដល់នូវគុណវិសេស ដែលខ្លួនមិនទាន់ដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេសដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះជាកុសីតវត្ថុទី ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុបានធ្វើការងារហើយ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញបានធ្វើការងាររួចហើយ តែថាកាលដែលអាត្មាអញកំពុងធ្វើការងារ កាយក៏លំបាកទៅហើយ ណ្ហើយចុះអាត្មាអញដេកសិន ។ ភិក្ខុនោះក៏ដេក មិនប្រុងប្រៀបព្យាយាម ... នេះជាកុសីតវត្ថុទី ២ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវដើរផ្លូវ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងត្រូវដើរផ្លូវ តែថា បើអាត្មាអញដើរផ្លូវ កាយនឹងលំបាក ណ្ហើយចុះអាត្មាអញដេកសិន ។ ភិក្ខុនោះក៏ដេក មិនប្រុងប្រៀបព្យាយាម ... នេះជាកុសីតវត្ថុទី ៣ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុដើរផ្លូវរួចហើយ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញបានដើរផ្លូវរួចហើយ តែថាកាលដែលអាត្មាអញកំពុងដើរផ្លូវ កាយក៏លំបាកទៅហើយ ណ្ហើយចុះអាត្មាអញដេកសិន ។ ភិក្ខុនោះក៏ដេក មិនប្រុងប្រៀបព្យាយាម ... នេះជាកុសីតវត្ថុ

ទី ៤ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុដើរទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត តែមិនបានភោជនសៅហ្មង ឬថ្លៃថ្លា ឲ្យបរិបូណ៌ដរាបដល់ឆ្អែតទេ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញកាលដែលដើរទៅកាន់ស្រុក ឬនិគម មិនបានភោជនសៅហ្មង ឬថ្លៃថ្លា ឲ្យបរិបូណ៌ដរាបដល់ឆ្អែតសោះ កាយរបស់អាត្មាអញនេះ ក៏លំបាកទៅហើយ ធ្វើការងារមិនកើត ណ្ហើយចុះអាត្មាអញដេកសិន ។ ភិក្ខុនោះក៏ដេក មិនប្រុងប្រៀបព្យាយាម ... នេះជាកុសីតវត្ថុទី ៥ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុដើរទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត បានភោជនសៅហ្មង ឬថ្លៃថ្លា បរិបូណ៌ដរាបដល់ឆ្អែត ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញកាលដែលដើរទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត បានភោជនសៅហ្មង ឬថ្លៃថ្លា បរិបូណ៌ដរាបដល់ឆ្អែតដែរហើយ តែកាយរបស់អាត្មាអញក៏ធ្ងន់ ធ្វើការងារមិនកើត ទំនងដូចជាសណ្តែកដែលត្រូវទឹក ណ្ហើយចុះ អាត្មាអញដេកសិន ។ ភិក្ខុនោះក៏ដេក មិនប្រុងប្រៀបព្យាយាម ... នេះជាកុសីតវត្ថុទី ៦ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុកើតអាពាធតិចតួច ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញបានកើតអាពាធតិចតួចនេះហើយ មានទំនងនឹងដេកបាន បើដូច្នោះអាត្មាអញដេកសិន ។ ភិក្ខុនោះក៏ដេក មិនប្រុងប្រៀបព្យាយាម... នេះជាកុសីតវត្ថុទី ៧ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុសះស្បើយអំពីជំងឺហើយ ទើបនឹងសះស្បើយអំពីជំងឺមិនយូរប៉ុន្មាន ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញសះស្បើយអំពីជំងឺហើយ តែសះស្បើយអំពីជំងឺ មិនទាន់យូរប៉ុន្មាន កាយរបស់

អាត្មាអញនៅមិនទាន់មានកម្លាំង ធ្វើការងារមិនកើត ណ្ហើយចុះអាត្មាអញដេកសិន ។ ភិក្ខុនោះក៏ដេក មិនប្រុងប្រៀបព្យាយាម ដើម្បីដល់នូវគុណវិសេសដែលខ្លួនមិនទាន់ដល់ ដើម្បីបាននូវគុណវិសេស ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះជាកុសីតវត្ថុទី ៨ ។

[ ២១៥ ] អារព្ភវត្ថុ ( ហេតុរបស់បុគ្គលប្រុងប្រៀបព្យាយាម ) មាន ៨ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ត្រូវធ្វើការងារ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងត្រូវធ្វើការងារ តែថា បើអាត្មាអញធ្វើការងារទៅ នឹងធ្វើទុកក្នុងចិត្តនូវសាសនារបស់ព្រះពុទ្ធទាំងឡាយ មិនបានស្រួលឡើយ ណ្ហើយចុះ អាត្មាអញប្រុងប្រៀបព្យាយាម ដើម្បីដល់នូវគុណវិសេសដែលមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេសដែលមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ភិក្ខុនោះ ក៏ប្រុងប្រៀបព្យាយាម ដើម្បីដល់នូវគុណវិសេសដែលមិនទាន់បានដល់ ដើម្បីបាននូវគុណវិសេសដែលមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេសដែលមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះជាអារព្ភវត្ថុទី ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុបានធ្វើការងាររួចហើយ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញបានធ្វើការងាររួចហើយ កាលដែលអាត្មាអញធ្វើការងារ ក៏មិនអាចធ្វើទុកក្នុងចិត្តនូវសាសនា របស់ព្រះពុទ្ធទាំងឡាយបាន ណ្ហើយចុះ គួរអាត្មាអញប្រុងប្រៀបព្យាយាម ។បេ។ ភិក្ខុនោះ ក៏ប្រុងប្រៀប

ព្យាយាម ... នេះជាអារព្ភវត្ថុទី ២ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវដើរផ្លូវ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងត្រូវដើរផ្លូវ កាលបើអាត្មាអញនឹងដើរផ្លូវ មិនងាយធ្វើទុកក្នុងចិត្តនូវសាសនា របស់ព្រះពុទ្ធទាំងឡាយបាន ណ្ហើយចុះ អាត្មាអញប្រុងប្រៀបព្យាយាម ។បេ។ ភិក្ខុនោះក៏ប្រុងប្រៀបព្យាយាម ... នេះជាអារព្ភវត្ថុទី ៣ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុដើរផ្លូវរួចហើយ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញបានដើរផ្លូវរួចហើយ កាលដែលអាត្មាអញកំពុងដើរផ្លូវ មិនអាចធ្វើទុកក្នុងចិត្តនូវសាសនារបស់ព្រះពុទ្ធទាំងឡាយ ណ្ហើយចុះ អាត្មាអញប្រុងប្រៀបព្យាយាម ។បេ។ ភិក្ខុនោះក៏ប្រុងប្រៀបព្យាយាម ... នេះជាអារព្ភវត្ថុទី ៤ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុដើរទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត មិនបានភោជនសៅហ្មង ឬថ្លៃថ្លា បរិបូណ៌ដរាបដល់ឆ្អែត ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញដើរទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត មិនបានភោជនសៅហ្មង ឬថ្លៃថ្លាបរិបូណ៌ដរាបដល់ឆ្អែត កាយរបស់អាត្មាអញក៏ស្រាល គួរធ្វើការងារបាន ណ្ហើយចុះ អាត្មាអញប្រុងប្រៀបព្យាយាម ។បេ។ ភិក្ខុនោះក៏ប្រុងប្រៀបព្យាយាម ... នេះជាអារព្ភវត្ថុទី ៥ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុដើរទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត បានភោជនសៅហ្មង ឬថ្លៃថ្លាបរិបូណ៌ដរាបដល់ឆ្អែត ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញបានដើរទៅកាន់ស្រុក ឬនិគមដើម្បីបិណ្ឌបាត បានភោជនសៅហ្មង ឬថ្លៃថ្លា បរិបូណ៌ដរាបដល់ឆ្អែត កាយរបស់អាត្មាអញមានកម្លាំង

ល្មមធ្វើការងារបាន ណ្ហើយចុះ អាត្មាអញប្រុងប្រៀបព្យាយាម ។បេ។ ភិក្ខុនោះ ក៏ប្រុងប្រៀបព្យាយាម ... នេះជាអារព្ភវត្ថុទី ៦ ។ ម្នាលអាវុសោទាំង-ឡាយ មួយទៀត ភិក្ខុកើតអាពាធតិចតួច ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញកើតអាពាធតិចតួចនេះហើយ អាពាធរបស់អាត្មាអញគង់មានទំនងចម្រើនឡើងមិនខាន ណ្ហើយចុះ អាត្មាអញប្រុងប្រៀបព្យាយាម ។បេ។ ភិក្ខុនោះក៏ប្រុងប្រៀបព្យាយាម ... នេះជាអារព្ភវត្ថុទី ៧ ។ ម្នាលអាវុសោទាំង-ឡាយ មួយទៀត ភិក្ខុបានសះស្បើយអំពីជំងឺហើយ លុះស្បើយអំពីជំងឺមិនទាន់យូរប៉ុន្មាន ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញបានសះស្បើយអំពីជំងឺហើយ តែសះស្បើយអំពីជំងឺមិនទាន់យូរប៉ុន្មាន អាពាធរបស់អាត្មាអញគង់ មានទំនងរើឡើងវិញ ណ្ហើយចុះ អាត្មាអញប្រុងប្រៀបព្យាយាម ដើម្បីដល់នូវគុណវិសេសដែលមិនទាន់ដល់ ដើម្បីបាននូវគុណវិសេសដែលមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ភិក្ខុនោះក៏ប្រុងប្រៀបព្យាយាម ដើម្បីដល់នូវគុណវិសេសដែលមិនទាន់ដល់ ដើម្បីបាននូវគុណវិសេសដែលមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស ដែលមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះជាអារព្ភវត្ថុទី ៨ ។

[ ២១៦ ] ទានវត្ថុ មាន ៨ យ៉ាង គឺបុគ្គលឲ្យទានព្រោះបុគ្គល ស្រាប់តែមកដល់ ១ ឲ្យទានព្រោះខ្លាច ( គេតិះដៀល ឬខ្លាចអបាយភូមិ ) ១ ឲ្យទានដោយគិតថា គេធ្លាប់ឲ្យដល់អាត្មាអញហើយ ១ ឲ្យទានដោយគិតថា គេនឹងឲ្យដល់អាត្មាអញវិញ ១ ឲ្យទានដោយគិតថា ទានជាការឲ្យសម្រេច

ប្រយោជន៍ ១ ឲ្យទានដោយគិតថា អាត្មាអញមិនបានចម្អិន ជនទាំងនេះមិនបានចម្អិន កាលបើអាត្មាអញបានចម្អិន មិនគួរនឹងមិនឲ្យទានដល់ពួកជនដែលមិនបានចម្អិនទេ ១ ឲ្យទានដោយគិតថា កាលបើអាត្មាអញឲ្យទាននេះទៅហើយ កិត្តិសព្ទដ៏ល្អរមែងខ្ចរខ្ចាយទៅ ១ ឲ្យទានដើម្បីជាគ្រឿងប្រដាប់ចិត្ត ទាំងជាបរិវារបស់ចិត្ត ១ ។

[ ២១៧ ] ទានុបបត្តិ ( ការកើតឡើងព្រោះទាន ) មាន ៨ យ៉ាង ម្នាលអាវុសោទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ឲ្យទានបាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ និងវត្ថុសម្រាប់ប្រទីប ដល់សមណៈ ឬព្រាហ្មណ៍ បុគ្គលនោះឲ្យវត្ថុណា ប្រាថ្នាយកវត្ថុនោះវិញ ( ព្រោះ ) បុគ្គលនោះឃើញខត្តិយមហាសាលក្តី ព្រាហ្មណមហាសាលក្តី គហបតិមហាសាលក្តី ដែលឆ្អែតស្កប់ស្កល់ មូលមិត្ត បម្រើដោយកាមគុណ ៥ បុគ្គលនោះមានគំនិតយ៉ាងនេះថា ឱហ្ន៎ អាត្មាអញ លុះមានរាងកាយបែកធ្លាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ សូមឲ្យកើតរួមជាមួយនឹងខត្តិយមហាសាល ឬព្រាហ្មណមហាសាល ឬក៏គហបតិមហាសាល ។ បុគ្គលនោះក៏តម្កល់ចិត្តនោះទុក អធិដ្ឋានចិត្តនោះទុក អប់រំចិត្តនោះទុក ។ ចិត្តរបស់បុគ្គលនោះ ផុតស្រឡះចាកកាមគុណដ៏ថោកទាប តែមិនចម្រើនឡើងតទៅ តែងប្រព្រឹត្តទៅ ដើម្បីកើតក្នុងទីដែលខ្លួនប្រាថ្នានោះ ។ តែខ្ញុំពោលនូវដំណើរនោះចំពោះបុគ្គលមានសីល មិនពោលចំពោះបុគ្គលទ្រុស្តសីលឡើយ ។ ម្នាលអាវុសោទាំងឡាយ សេចក្តីតាំងចិត្តរបស់បុគ្គលមានសីល រមែងសម្រេចបាន

ព្រោះសេចក្ដីតាំងចិត្តនោះ ជារបស់បរិសុទ្ធ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត បុគ្គលពួកខ្លះក្នុងលោកនេះ ដល់សមណៈ ឬព្រាហ្មណ៍ បុគ្គលនោះឲ្យនូវវត្ថុណា ប្រាថ្នាយកវត្ថុនោះវិញ បុគ្គលនោះបានឮថា ពួកទេវតាក្នុងឋានចាតុម្មហារាជិកៈ មានអាយុវែង មានសម្បុរល្អ មានសេចក្ដីសុខច្រើន ។ បុគ្គលនោះមានគំនិតយ៉ាងនេះថា ឱហ្ន៎ អាត្មាអញលុះមានរាងកាយបែកធ្លាយខាងមុខបន្ទាប់អំពីសេចក្ដីស្លាប់ទៅ សូមឲ្យទៅកើតរួមជាមួយនឹងពួកទេវតាក្នុងឋានចាតុម្មហារាជិកៈ ។ បុគ្គលនោះក៏តាំងចិត្តនោះទុក អធិដ្ឋានចិត្តនោះទុក អប់រំចិត្តនោះទុក ចិត្តរបស់បុគ្គលនោះ ផុតស្រឡះចាកកាមគុណដ៏ថោកទាប តែមិនចម្រើនឡើងតទៅ តែងប្រព្រឹត្តទៅ ដើម្បីកើតក្នុងទីដែលខ្លួនប្រាថ្នានោះ ។ តែខ្ញុំពោលនូវដំណើរនោះ ចំពោះបុគ្គលមានសីល មិនពោលចំពោះបុគ្គលទ្រុស្ដសីលឡើយ ។ ម្នាលអាវុសោទាំងឡាយ សេចក្ដីតាំងចិត្តរបស់បុគ្គលមានសីល រមែងសម្រេចបានព្រោះសេចក្ដីតាំងចិត្តនោះ ជារបស់បរិសុទ្ធ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត បុគ្គលពួកខ្លះក្នុងលោកនេះ ឲ្យទានបាយ ទឹក សំពត់ យាន ផ្កា កម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ និងប្រដាប់ប្រទីប ដល់សមណៈឬ ព្រាហ្មណ៍ ។ បុគ្គលនោះ ឲ្យរបស់ណា ប្រាថ្នាយករបស់នោះវិញ បុគ្គលនោះ បានឮថា ពួកទេវតាក្នុងឋានតាវត្តិង្ស ។បេ។ ពួកទេវតាក្នុងឋានយាមៈ ។បេ។ ពួកទេវតាក្នុងឋានតុសិត ។បេ។ ពួកទេវតាក្នុងឋាននិម្មានរតី ។បេ។ ពួកទេវតា ក្នុងឋានបរនិម្មិតវសវត្តី មានអាយុវែង មានសម្បុរល្អ មានសេចក្ដីសុខច្រើន ។ បុគ្គលនោះ មានគំនិត

យ៉ាងនេះថា ឱហ្ន៎ អាត្មាអញលុះមានរាងកាយបែកធ្លាយ ខាងមុខបន្ទាប់អំពីសេចក្តីស្លាប់ទៅ សូមឲ្យទៅកើតរួមជាមួយនឹងពួកទេវតា ក្នុងឋានបរនិម្មិតវសវត្តី ។ បុគ្គលនោះក៏តាំងចិត្តនោះទុក អធិដ្ឋានចិត្តនោះទុក អប់រំចិត្តនោះទុក ចិត្តរបស់បុគ្គលនោះរួចស្រឡះចាកកាមគុណដ៏ថោកទាប តែមិនចម្រើនឡើងតទៅ តែងប្រព្រឹត្តទៅដើម្បីកើតក្នុងទីដែលខ្លួនប្រាថ្នានោះ ។ តែខ្ញុំពោលនូវដំណើរនោះ ចំពោះបុគ្គលមានសីល មិនពោលចំពោះបុគ្គលទ្រុស្តសីលឡើយ ។ ម្នាលអាវុសោទាំងឡាយ សេចក្តីតាំងចិត្តរបស់បុគ្គលមានសីល រមែងសម្រេចបាន ព្រោះសេចក្តីតាំងចិត្តនោះ ជារបស់បរិសុទ្ធ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត បុគ្គលពួកខ្លះក្នុងលោកនេះ ឲ្យទានបាយ ទឹក សំពត់ យាន ផ្កា កម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីនៅ និងប្រដាប់ប្រទីប ដល់សមណៈ ឬព្រាហ្មណ៍ បុគ្គលនោះ ឲ្យរបស់ណា ប្រាថ្នាយករបស់នោះវិញ បុគ្គលនោះបានឮថា ពួកទេវតាក្នុងព្រហ្មលោក មានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន ។ បុគ្គលនោះ មានគំនិតយ៉ាងនេះថា ឱហ្ន៎ អាត្មាអញ លុះមានរាងកាយបែកធ្លាយខាងមុខ បន្ទាប់អំពីសេចក្តីស្លាប់ទៅ សូមឲ្យទៅកើតរួមជាមួយនឹងទេវតាក្នុងព្រហ្មលោក ។ បុគ្គលនោះ ក៏តាំងចិត្តនោះទុក អធិដ្ឋានចិត្តនោះទុក អប់រំចិត្តនោះទុក ចិត្តរបស់បុគ្គលនោះ រួចស្រឡះចាកកាមគុណដ៏ថោកទាប តែមិនចម្រើនឡើងទៅ តែងប្រព្រឹត្តទៅ ដើម្បីកើតក្នុងទីដែលខ្លួនប្រាថ្នានោះ ។ តែខ្ញុំពោលនូវដំណើរនោះ ចំពោះបុគ្គលមានសីល មិនពោលចំពោះបុគ្គលទ្រុស្តសីលឡើយ ពោល

ចំពោះតែបុគ្គលប្រាសចាករាគៈ មិនពោលចំពោះបុគ្គលប្រកបដោយរាគៈឡើយ ។ ម្នាលអាវុសោទាំងឡាយ សេចក្តីតាំងចិត្តរបស់បុគ្គលមានសីល រមែងសម្រេចបាន ព្រោះសេចក្តីតាំងចិត្តនោះ ជារបស់ប្រាសចាករាគៈ ១ ។

[ ២១៨ ] លោកធម៌ មាន ៨ យ៉ាង គឺលាភ ១ អលាភ ១ យស ១ អយស ១ និន្ទា ១ សរសើរ ១ សុខ ១ ទុក្ខ ១ ។

[ ២១៩ ] បរិស័ទ មាន ៨ ពួក គឺខត្តិយបរិស័ទ ១ ព្រាហ្មណ-បរិស័ទ ១ គហបតិបរិស័ទ ១ សមណបរិស័ទ ១ ចាតុម្មហារាជិកបរិស័ទ ១ តាវត្តឹសបរិស័ទ ១ និម្មានរតិបរិស័ទ ១ ព្រហ្មបរិស័ទ ១ ។

[ ២២០ ] អភិភាយតនៈ មាន ៨ យ៉ាង គឺបុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ គ្របសង្កត់នូវរូបទាំងនោះ ដែលមានសម្បុរល្អ និងសម្បុរអាក្រក់ មានប្រមាណតិច ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ដូច្នេះ នេះជាអភិភាយតនៈទី ១ ។ បុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ គ្របសង្កត់នូវរូបទាំងនោះ ដែលមានសម្បុរល្អ និងសម្បុរអាក្រក់ រកប្រមាណមិនបាន ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ដូច្នេះ នេះជាអភិភាយតនៈទី ២ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ គ្របសង្កត់នូវរូបទាំងនោះ ដែលមានសម្បុរល្អ និងសម្បុរអាក្រក់ មានប្រមាណតិច ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញ

ឃើញដូច្នេះ នេះជាអភិភាយតនៈទី ៣ ។ បុគ្គលពួកមួយ មានសេចក្ដីសម្គាល់ នូវអរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ គ្របសង្កត់នូវរូបទាំងនោះ ដែលមានសម្បុរល្អ និងសម្បុរអាក្រក់ រកប្រមាណមិនបាន ហើយមានសេចក្ដីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ៤ ។ បុគ្គលពួកមួយ មានសេចក្ដីសម្គាល់នូវអរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ដែលជារូបខៀវ មានសម្បុរខៀវ ដ៏ច្នុះចេញនូវសម្បុរខៀវ មានពន្លឺខៀវ ប្រៀបដូចផ្កាត្រកៀតខៀវ មានសម្បុរខៀវ ដ៏ច្នុះចេញនូវសម្បុរខៀវ មានពន្លឺខៀវ ពុំនោះសោត ប្រៀបដូចសំពត់ខៀវ កើតក្នុងក្រុងពារាណសីនោះ រលីងទាំងពីរខាងមានពណ៌ខៀវ ដ៏ច្នុះចេញនូវពណ៌ខៀវ មានពន្លឺខៀវ យ៉ាងណាមិញ បុគ្គលពួកមួយ មានសេចក្ដីសម្គាល់នូវអរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ដែលជារូបខៀវ មានសម្បុរខៀវ ដ៏ច្នុះចេញនូវសម្បុរខៀវ មានពន្លឺខៀវ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្ដីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ យ៉ាងនេះឯង នេះជាអភិភាយតនៈទី ៥ ។ បុគ្គលពួកមួយ មានសេចក្ដីសម្គាល់នូវអរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ដែលជារូបលឿង មានពណ៌លឿង ដ៏ច្នុះចេញនូវពណ៌លឿង មានពន្លឺលឿង ប្រៀបដូចផ្កាកណិការលឿង មានពណ៌លឿង ដ៏ច្នុះចេញនូវពណ៌លឿង មានពន្លឺលឿង ពុំនោះសោត ប្រៀបដូចសំពត់លឿង កើតក្នុងក្រុងពារាណសីនោះ រលីងទាំងពីរខាង មានពណ៌លឿង ដ៏ច្នុះចេញនូវពណ៌លឿង មានពន្លឺលឿង យ៉ាងណាមិញ បុគ្គលពួកមួយ មានសេចក្ដីសម្គាល់

នូវអរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅដែលជារូបលឿង មានសម្បុរលឿង ដ៏ផ្ទុះចេញនូវសម្បុរលឿង មានពន្លឺលឿង គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ យ៉ាងនេះឯង នេះជាអភិភាយតនៈទី ៦ ។ បុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវអរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ដែលជារូបក្រហម មានសម្បុរក្រហម ដ៏ផ្ទុះចេញនូវសម្បុរក្រហម មានពន្លឺក្រហម ប្រៀបដូចផ្កាច្បាក្រហម មានពណ៌ក្រហម ដ៏ផ្ទុះចេញនូវពណ៌ក្រហម មានពន្លឺក្រហម ពុំនោះសោតប្រៀបដូចសំពត់ក្រហម កើតក្នុងក្រុងពារាណសីនោះ រលីងទាំងពីរខាង មានពណ៌ក្រហម ដ៏ផ្ទុះចេញនូវពណ៌ក្រហម មានពន្លឺក្រហម យ៉ាងណាមិញ បុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវអរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ដែលជារូបក្រហម មានសម្បុរក្រហម ដ៏ផ្ទុះចេញនូវសម្បុរក្រហម មានពន្លឺក្រហម គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ដូច្នេះយ៉ាងនេះឯង នេះជាអភិភាយតនៈទី ៧ ។ បុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវអរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ដែលជារូបស មានសម្បុរស ដ៏ផ្ទុះចេញនូវសម្បុរស មានពន្លឺស ប្រៀបដូចផ្កាយព្រឹកស មានពណ៌ស ដ៏ផ្ទុះចេញនូវពណ៌ស មានពន្លឺស ពុំនោះសោតប្រៀបដូចសំពត់កើតក្នុងក្រុងពារាណសីនោះ រលីងទាំងពីរខាង មានពណ៌ស ដ៏ផ្ទុះចេញនូវពណ៌ស មានពន្លឺស យ៉ាងណាមិញ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ដែលជារូបស មាន

សម្បុរស ដ៏ផ្ទុះចេញនូវសម្បុរស មានពន្លឺស គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ដូច្នេះ យ៉ាងនេះឯង នេះជាអភិភាយតនៈទី ៨ ។

[ ២២១ ] វិមោក្ខមាន ៨ យ៉ាង គឺបុគ្គលរមែងឃើញនូវរូបទាំងឡាយបាន នេះជាវិមោក្ខទី ១ ។ បុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវអរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ នេះជាវិមោក្ខទី ២ ។ សេចក្តីជឿស៊ប់ចំពោះកសិណដ៏ល្អ នេះជាវិមោក្ខទី ៣ ។ ព្រោះការកន្លងនូវពួករូបសញ្ញា វិនាសទៅនៃពួកបដិឃសញ្ញា មិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ដោយប្រការទាំងពួង បុគ្គលរមែងចូលកាន់អាកាសានញ្ចាយតនជ្ឈាន ដោយបរិកម្មថា អាកាសមិនមានទីបំផុតដូច្នេះ នេះជាវិមោក្ខទី ៤ ។ បុគ្គលកន្លងនូវអាកាសានញ្ចាយតនជ្ឈានដោយប្រការទាំងពួង រមែងចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុតដូច្នេះ នេះជាវិមោក្ខទី ៥ ។ បុគ្គលកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង រមែងចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន ដោយបរិកម្មថា វត្ថុបន្តិចបន្តួចមិនមានដូច្នេះ នេះជាវិមោក្ខទី ៦ ។ បុគ្គលកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង រមែងចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន នេះជាវិមោក្ខទី ៧ ។ បុគ្គលកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង រមែងចូលកាន់សញ្ញាវេទយិតនិរោធ នេះជាវិមោក្ខទី ៨ ។ ម្នាលអាវុសោទាំងឡាយ ធម៌ពួកប្រាំបីនេះឯង ដែលព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញ

ច្បាស់ ត្រាស់សម្តែងទុកល្អហើយ ពួកយើងទាំងអស់គ្នា ត្រូវសង្គាយនាក្នុងធម៌ពួកប្រាំបីនោះ ។បេ។ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំងឡាយ ។

## ពួកធម៌ប្រាំបីៗ ដែលរាប់ចូលក្នុងការសង្គាយនា ចប់

[ ២២២ ] ម្នាលអាវុសោទាំងឡាយ ធម៌ពួកប្រាំបួន ដែលព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សម្តែងទុកល្អហើយ រមែងមានប្រាកដ ពួកយើងទាំងអស់គ្នា ត្រូវសង្គាយនាក្នុងធម៌ពួកប្រាំបួននោះ ។បេ។ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំងឡាយ ។ ធម៌ពួកប្រាំបួន ដូចម្តេចខ្លះ ។ អាឃាតវត្ថុ ( ហេតុនៃសេចក្តីគុំកួន ) មាន ៩ យ៉ាង គឺបុគ្គលចងអាឃាតដោយគិតថា ជនឯណោះ បានប្រព្រឹត្តហើយ នូវអំពើមិនជាប្រយោជន៍ដល់អញ ។ ចងអាឃាត ដោយគិតថា ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើ មិនជាប្រយោជន៍ដល់អញ ។ ចងអាឃាត ដោយគិតថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អញ ។ ចងអាឃាត ដោយគិតថា ជនឯណោះ បានប្រព្រឹត្តហើយ នូវអំពើមិនជាប្រយោជន៍ ។ កំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ ។ នឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ ដល់បុគ្គលជាទីស្រឡាញ់ជាទីគាប់ចិត្តរបស់អញ ។ ចងអាឃាត ដោយគិតថា ជនឯណោះ បានប្រព្រឹត្តហើយ នូវអំពើជាប្រយោជន៍ ។ កំពុងប្រព្រឹត្តនូវអំពើជាប្រយោជន៍ ។ នឹងប្រព្រឹត្តនូវអំពើជាប្រយោជន៍ ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត

របស់អញ ។

[ ២២៣ ] អាឃាតប្បដិវិន័យ ( ការកម្ចាត់បង់អាឃាត ) មាន ៩ យ៉ាង គឺបុគ្គលកម្ចាត់បង់នូវអាឃាតដោយគិតថា ជនឯណោះ បានប្រព្រឹត្តហើយ នូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ ព្រោះហេតុនោះ ការប្រព្រឹត្តអំពើមិនជាប្រយោជន៍នោះ អាត្មាអញគប្បីបានក្នុងបុគ្គលនុ៎ះអំពីណា ។ បុគ្គលកម្ចាត់បង់នូវអាឃាត ដោយគិតថា ជនឯណោះ កំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ដល់អាត្មាអញ ព្រោះហេតុនោះ ការប្រព្រឹត្តអំពើមិនជាប្រយោជន៍នោះ អាត្មាអញគប្បីបាននូវបុគ្គលនុ៎ះអំពីណា ។ បុគ្គលកម្ចាត់បង់នូវអាឃាតដោយគិតថា ជនឯណោះ នឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ ដល់អាត្មាអញ ព្រោះហេតុនោះ ការប្រព្រឹត្តអំពើមិនជាប្រយោជន៍នោះ អាត្មាអញគប្បីបានក្នុងបុគ្គលនុ៎ះអំពីណា ។ បុគ្គលកម្ចាត់បង់នូវអាឃាតដោយគិតថា ជនឯណោះ បានប្រព្រឹត្តហើយ នូវអំពើមិនជាប្រយោជន៍ ។ កំពុងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ ។ នឹងប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍ ដល់បុគ្គលជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អាត្មាអញ ព្រោះហេតុនោះ ការប្រព្រឹត្តនូវអំពើមិនជាប្រយោជន៍នោះ អាត្មាអញគប្បីបានក្នុងបុគ្គលនុ៎ះអំពីណា ។ បុគ្គលកម្ចាត់បង់នូវអាឃាតដោយគិតថា ជនឯណោះបានប្រព្រឹត្តប្រយោជន៍ ។ កំពុងប្រព្រឹត្តប្រយោជន៍ ។ នឹងប្រព្រឹត្តប្រយោជន៍ ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញ ព្រោះហេតុនោះ ការប្រព្រឹត្តនោះ អាត្មាអញ គប្បីបានក្នុងបុគ្គលនុ៎ះអំពីណា ។

[ ២២៤ ] សត្តាវាស ( ប្រទេសជាទីនៅរបស់សត្វ ) មាន ៩ យ៉ាង ម្នាលអាវុសោទាំងឡាយ ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នា ដូចពួកមនុស្សទេវតាពួកខ្លះ និងវិនិបាតិកៈពួកខ្លះ នេះជាសត្តាវាសទី ១ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វមានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ដូចពួកទេវតាក្នុងជាន់ព្រហ្មលោក ដែលកើតក្នុងជាន់បឋមជ្ឈានភូមិ នេះជាសត្តាវាសទី ២ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វមានកាយដូចគ្នា មានសញ្ញាផ្សេងគ្នា ដូចពួកទេវតាក្នុងជាន់អាភស្សរៈ នេះជាសត្តាវាសទី ៣ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វមានកាយដូចគ្នា មានសញ្ញាដូចគ្នា ដូចពួកទេវតាក្នុងជាន់សុភកិណ្ហៈ នេះជាសត្តាវាសទី ៤ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វឥតសញ្ញា មិនដឹងច្បាស់ ( នូវអារម្មណ៍ ) ដូចពួកទេវតាជាអសញ្ញិ-សត្វ នេះជាសត្តាវាសទី ៥ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វចូលកាន់អាកាសានញ្ចាយតនជ្ឈាន ដោយបរិកម្មថា អាកាសមិនមានទីបំផុត ដូច្នេះ ព្រោះកន្លងបង់នូវពួករូបសញ្ញា ព្រោះវិនាសទៅនៃពួកបដិឃសញ្ញា ព្រោះមិនធ្វើទុកក្នុងចិត្តនូវពួកនានត្តសញ្ញាដោយប្រការទាំងពួង នេះជាសត្តាវាសទី ៦ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វកន្លងបង់នូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត ដូច្នេះ នេះជាសត្តាវាសទី ៧ ។ ម្នាលអាវុសោទាំង-ឡាយ ពួកសត្វកន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន ដោយបរិកម្មថា វត្ថុបន្តិចបន្តួចមិនមាន

ដូច្នេះ នេះជាសត្តាវាសទី ៨ ។ ម្នាលអាវុសោទាំងឡាយ ពួកសត្វកន្លងបង់នេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយបរិកម្មថា វត្ថុនេះស្ងប់រម្ងាប់ វត្ថុនេះប្រសើរ ដូច្នេះ នេះជាសត្តាវាសទី ៩ ។

[ ២២៥ ] អក្ខណអសម័យនៃការប្រព្រឹត្តព្រហ្មចារ្យ មាន ៩ យ៉ាង ម្នាលអាវុសោទាំងឡាយ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ កើតឡើងហើយក្នុងលោកនេះផង ធម៌ដែលធ្វើកិលេសឲ្យស្ងប់រម្ងាប់ ប្រព្រឹត្តទៅដើម្បីព្រះនិព្វានជាដំណើរដើម្បីត្រាស់ដឹង ជាធម៌ដែលព្រះសុគតប្រកាសទុក ព្រះអង្គក៏បានសម្តែងហើយផង ។ តែបុគ្គលនេះទៅកើតក្នុងនរក នេះជាអក្ខណអសម័យនៃការនៅប្រព្រឹត្តព្រហ្មចារ្យទី ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ កើតឡើងហើយក្នុងលោក ធម៌ដែលធ្វើកិលេសឲ្យស្ងប់រម្ងាប់ ប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ជាដំណើរដើម្បីត្រាស់ដឹង ជាធម៌ដែលព្រះសុគតប្រកាសទុក ព្រះអង្គក៏បានសម្តែងហើយផង ។ តែបុគ្គលនេះ ទៅកើតក្នុងកំណើតតិរច្ឆាន ។បេ។ ទៅកើតក្នុងបិត្តិវិស័យ ។បេ។ ទៅកើតក្នុងអសុរកាយ ។បេ។ ទៅកើតក្នុងពួកទេវតាមានអាយុវែងណាមួយ ។បេ។ ទៅកើតក្នុងពួកមិលក្ខជន ជាអ្នកមិនដឹងខុសត្រូវច្បាស់លាស់ ក្នុងពួកបច្ចន្តិមជនបទ ដែលជាប្រទេសគ្មានភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកាទៅដល់ ។ បានកើតក្នុងមជ្ឈិមជនបទហើយ តែអ្នកនោះជាមិច្ឆាទិដ្ឋិ មានសេចក្តីយល់ឃើញវិបរិតថា ទានដែលបុគ្គលឲ្យហើយគ្មានផល របស់ដែលគេបូជាហើយគ្មានផល ការបូជាធំ គ្មានផល ការបូជាតូច គ្មានផល ផល និងវិបាករបស់កម្ម

ដែលសត្វធ្វើល្អ ធ្វើអាក្រក់មិនមាន លោកនេះមិនមាន លោកដទៃមិនមាន មាតាមិនមាន បិតាមិនមាន ពួកសត្វជាឱបបាតិកៈមិនមាន ពួកសមណ-ព្រាហ្មណ៍ ក្នុងលោកជាអ្នកព្រមព្រៀងគ្នាប្រតិបត្តិដោយល្អ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ព្រោះដឹងច្បាស់ដោយខ្លួនឯង ហើយឲ្យអ្នកដទៃបានត្រាស់ដឹងផងមិនមាន ។ បានកើតក្នុងពួកមជ្ឈិមជនបទហើយ តែជាបុគ្គលអប្បឥតប្រាជ្ញាល្ងង់ខ្លៅ ជាមនុស្សគ មិនអង់អាចដើម្បីដឹងសេចក្តីនៃសុភាសិត និងទុព្ភាសិតបាន នេះជាអក្ខណអសម័យនៃការប្រព្រឹត្តព្រហ្មចារ្យទី ៨ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធមិនកើតឡើងក្នុងលោកផង ធម៌ធ្វើនូវសេចក្តីស្ងប់រម្ងាប់កិលេសប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ជាដំណើរដើម្បីត្រាស់ដឹង ជាធម៌ដែលព្រះសុគតទ្រង់ប្រកាសទុក ព្រះអង្គក៏មិនបានសម្តែងផង ។ តែបុគ្គលនេះបានកើតក្នុងមជ្ឈិមជនបទជាអ្នកមានប្រាជ្ញា មិនល្ងង់ខ្លៅ មិនជាមនុស្សគ អង់អាច ដើម្បីដឹងសេចក្តីនៃសុភាសិត និងទុព្ភាសិតបាន ។ នេះជាអក្ខណអសម័យនៃការប្រព្រឹត្តព្រហ្មចារ្យ ទី ៩ ។

[ ២២៦ ] អនុបុព្វវិហារ ( ធម៌ជាគ្រឿងនៅដែលបុគ្គលត្រូវចូលតាមលំដាប់ឈាន ) មាន ៩ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ស្រឡះចាកកាមទាំងឡាយ ស្ងាត់ស្រឡះចាកអកុសលធម៌ទាំង-ឡាយ ហើយចូលបឋមជ្ឈាន ប្រកបដោយវិតក្ក ប្រកបដោយវិចារៈ មានបីតិ និងសុខដែលកើតអំពីវិវេក ១ ព្រោះរម្ងាប់វិតក្ក និងវិចារៈទាំងឡាយ

រមែងចូលទុតិយជ្ឈាន ជាឈានកើតក្នុងសន្តាននៃខ្លួន ជាទីជ្រះថ្លា គឺសទ្ធាមានភាវៈជាចិត្តប្រសើរឯក គ្មានវិតក្កៈ គ្មានវិចារៈ មានតែបីតិ និងសុខដែលកើតអំពីសមាធិ ១ ព្រោះអស់ទៅនៃបីតិ ប្រកបដោយឧបេក្ខាផង មានសតិសម្បជញ្ញៈផង ទទួលនូវសេចក្ដីសុខដោយនាមកាយ ព្រះអរិយៈទាំងឡាយតែងសរសើរបុគ្គលចូលតតិយជ្ឈាននោះថា បុគ្គលនោះ ប្រកបដោយឧបេក្ខា មានសតិនៅជាសុខ ដោយអំណាចតតិយជ្ឈានណា បានចូលតតិយជ្ឈាន ( នោះ ) ១ ព្រោះលះសុខផង លះទុក្ខផង អស់សោមនស្ស និងទោមនស្សក្នុងកាលមុន ចូលចតុត្ថជ្ឈាន មិនទុក្ខ មិនសុខ មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ១ ព្រោះកន្លងបង់នូវពួករូបសញ្ញា អស់ពួកបដិឃសញ្ញា មិនធ្វើទុកក្នុងចិត្តនូវពួកនានត្តសញ្ញា ដោយប្រការទាំងពួង ចូលអាកាសានញ្ចាយតនជ្ឈាន ដោយគិតថា អាកាសមិនមានទីបំផុតដូច្នេះ ១ កន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលវិញ្ញាណញ្ចាយតនជ្ឈានដោយគិតថា វិញ្ញាណមិនមានទីបំផុត ដូច្នេះ ១ កន្លងនូវវិញ្ញាណញ្ចាយតនជ្ឈានដោយប្រការទាំងពួង ហើយចូលអាកិញ្ចញ្ញាយតនជ្ឈាន ដោយគិតថា វត្ថុអ្វីតិចតួចមិនមានដូច្នេះ ១ កន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលនេវសញ្ញានាសញ្ញាយតនជ្ឈាន ១ កន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលសញ្ញាវេទយិតនិរោធ ១ ។

[ ២២៧ ] អនុបុព្វនិរោធ ( ធម៌ជាគ្រឿងរលត់ដោយលំដាប់ឈាន ) មាន ៩ យ៉ាង គឺកាលបុគ្គលចូលបឋមជ្ឈាន កាមសញ្ញារលត់ ១ កាល

ដែលចូលទុតិយជ្ឈាន វិតក្កវិចារៈរលត់ ១ កាលដែលចូលតតិយជ្ឈាន បីតិរលត់ ១ កាលដែលចូលចតុត្ថជ្ឈាន អស្សាសៈ និងបស្សាសៈរលត់ ១ កាលដែលចូលអាកាសានញ្ចាយតនជ្ឈាន រូបសញ្ញារលត់ ១ កាលដែលចូលវិញ្ញាណញ្ចាយតនជ្ឈាន អាកាសានញ្ចាយតនសញ្ញារលត់ ១ កាលដែលចូលអាកិញ្ចញ្ញាយតនជ្ឈាន វិញ្ញាណញ្ចាយតនសញ្ញារលត់ ១ កាលដែលចូលនេវសញ្ញានាសញ្ញាយតនជ្ឈាន អាកិញ្ចញ្ញាយតនសញ្ញារលត់ ១ កាលដែលចូលសញ្ញាវេទយិតនិរោធ សញ្ញា និងវេទនារលត់ ១ ។ ម្នាលអាវុសោទាំងឡាយ នេះឯងជាធម៌ពួក ៩ ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ត្រាស់សម្តែងទុកល្អហើយ ពួកយើងទាំងអស់គ្នា ត្រូវសង្គាយនាក្នុងធម៌ពួក ៩ នោះ ។បេ។ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំងឡាយ ។ សេចក្តីបង្រួញធម៌ពួក ៩ ។

## ពួកធម៌ប្រាំបួនៗ ដែលរាប់ចូលក្នុងការសង្គាយនា ចប់

[ ២២៨ ] ម្នាលអាវុសោទាំងឡាយ មានធម៌ពួក ១០ ដែលព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ត្រាស់សម្តែងទុកល្អហើយ ពួកយើងទាំងអស់គ្នា ត្រូវសង្គាយនាក្នុងធម៌ពួក ១០ នោះ ។បេ។ ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំងឡាយ ។ ធម៌ពួក ១០ ដូចម្តេចខ្លះ ។ នាថករណធម៌ ( ធម៌គ្រឿងធ្វើនូវទីពឹង ) មាន ១០ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុ

ក្នុងសាសនានេះ មានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារ និងគោចរ ឃើញភ័យចំពោះទោសទាំងពួង សូម្បីមានប្រមាណតិច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារ និងគោចរ ឃើញភ័យចំពោះទោសទាំងឡាយ សូម្បីមានប្រមាណតិច សមាទានសិក្សាក្នុងសិក្ខាបទទាំង-ឡាយណា នេះជានាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាពហុស្សូត ចាំពុទ្ធវចនៈដែលខ្លួនបានស្តាប់ហើយ សន្សំពុទ្ធវចនៈដែលខ្លួនបានស្តាប់ហើយ ។ ពួកធម៌ណាមានពីរោះខាងដើម មានពីរោះក្នុងកណ្តាល មានពីរោះក្នុងទីបំផុត ប្រកាសនូវព្រហ្មចារ្យ ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈ ដ៏បរិសុទ្ធ បរិបូណ៌សព្វគ្រប់ ភិក្ខុនោះ បានស្តាប់ច្រើន បានចាំរត់មាត់ រំពឹងដោយចិត្ត ចាក់ធ្លុះដោយសេចក្តីយល់ នូវធម៌មានសភាពដូច្នោះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាពហុស្សូត ។បេ។ ចាក់ធ្លុះដោយសេចក្តីយល់ណា នេះជានាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុមានមិត្តល្អ មានសម្លាញ់ល្អ មានបុគ្គលស្និទ្ធស្នាលល្អ ។ ម្នាលអាវុសោទាំង-ឡាយ ភិក្ខុមានមិត្តល្អ មានសម្លាញ់ល្អ មានបុគ្គលស្និទ្ធស្នាលល្អណា នេះជានាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកដែលគេប្រដៅងាយ ប្រកបដោយពួកធម៌ជាគ្រឿងធ្វើនូវភាវៈជាអ្នកប្រដៅងាយ ជាអ្នកអត់ធន់ ទទួលយកពាក្យប្រៀនប្រដៅដោយចំណែកខាងស្តាំ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកដែលគេប្រដៅងាយ ប្រកបដោយពួកធម៌ ជា

គ្រឿងធ្វើនូវការៈជាអ្នកប្រដៅងាយ ជាអ្នកអត់ធន់ ទទួលយកពាក្យប្រៀនប្រដៅដោយចំណែកខាងស្តាំណា នេះជានាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត កិច្ចអ្វីដែលបុគ្គលត្រូវធ្វើ ទោះបីធំ ឬតូច របស់ពួកសព្រហ្មចារីណា ភិក្ខុជាអ្នកឈ្លាស មិនខ្ជិលច្រអូសក្នុងកិច្ចទាំងនោះ ប្រកបដោយការពិចារណា ជាឧបាយក្នុងកិច្ចនោះ អាចធ្វើបាន អាចចាត់ចែងបាន ។ ម្នាលអាវុសោទាំងឡាយ កិច្ចអ្វីៗ ដែលបុគ្គលត្រូវធ្វើរបស់ពួកសព្រហ្មចារីណា ភិក្ខុ ។បេ។ អាចចាត់ចែងបានណា នេះជានាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុមានសេចក្តីប្រាថ្នាក្នុងធម៌ ជាអ្នកមានសម្តីគួរស្រឡាញ់ មានសេចក្តីរីករាយដ៏លើសលុប ក្នុងអភិធម្ម ក្នុងអភិវិន័យ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានសេចក្តីប្រាថ្នាក្នុងធម៌ ជាអ្នកមានសម្តីគួរស្រឡាញ់ មានសេចក្តីត្រេកអរដ៏លើសលុប ក្នុងអភិធម្ម ក្នុងអភិវិន័យណា នេះជានាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារតាមមានតាមបាន ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខារតាមមាន តាមបានណា នេះជានាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុមានព្យាយាមប្រារព្ធហើយ ដើម្បីលះបង់ពួកអកុសលធម៌ ដើម្បីចម្រើនពួកកុសលធម៌ ជាអ្នកមានកម្លាំងចិត្ត មានសេចក្តីសង្វាតមាំមួន មិនដាក់ធុរៈចោលក្នុងកុសលធម៌ទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានព្យាយាម

ប្រារព្ធហើយ ដើម្បីលះបង់ពួកអកុសលធម៌ ដើម្បីចម្រើនពួកកុសលធម៌ ជាអ្នកមានកម្លាំងចិត្ត មានសេចក្តីសង្វាតមាំមួន មិនដាក់ធុរៈចោលក្នុងកុសលធម៌ទាំងឡាយណា នេះជានាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុមានសតិ ប្រកបដោយសតិ និងភាវៈជាបុគ្គលមានប្រាជ្ញាចាស់ក្លាក្រៃលែង ជាអ្នករឭកបាន រឭកបានរឿយៗ នូវការងារដែលបានធ្វើយូរហើយក្តី និយាយយូរហើយក្តី ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានសតិ ប្រកបដោយសតិ និងភាវៈជាបុគ្គលមានប្រាជ្ញាចាស់ក្លាក្រៃលែង ជាអ្នករឭកបាន រឭកបានរឿយៗ នូវការងារដែលបានធ្វើយូរហើយក្តី និយាយយូរហើយក្តីណា នេះជានាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុមានប្រាជ្ញា ប្រកបដោយប្រាជ្ញា ជាគ្រឿងធ្លុះយល់នូវសេចក្តីចម្រើន និងសេចក្តីវិនាស ជាប្រាជ្ញាចាក់ធ្លុះដ៏ប្រសើរ ដល់នូវសេចក្តីអស់ទៅនៃទុក្ខដោយប្រពៃ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានប្រាជ្ញា ប្រកបដោយប្រាជ្ញា ជាគ្រឿងធ្លុះយល់នូវសេចក្តីចម្រើន និងសេចក្តីវិនាស ជាប្រាជ្ញាចាក់ធ្លុះដ៏ប្រសើរ ដល់នូវសេចក្តីអស់ទៅនៃទុក្ខដោយប្រពៃណា នេះជានាថករណធម៌ ១ ។

[ ២២៩ ] កសិណាយតនៈ មាន ១០ យ៉ាង គឺបុគ្គលម្នាក់ចាំបាននូវបឋវីកសិណ ទាំងទិសខាងលើ ខាងក្រោម និងទិសទទឹងតាមលំដាប់ រកប្រមាណមិនបាន ។ បុគ្គលម្នាក់ចាំបាននូវអាបោកសិណ ។បេ។ បុគ្គលម្នាក់ចាំបាននូវតេជោកសិណ ។បេ។ បុគ្គលម្នាក់ចាំបាននូវវាយោកសិណ ។បេ។ បុគ្គលម្នាក់ចាំបាននូវនីលកសិណ ។បេ។ បុគ្គលម្នាក់ចាំបាននូវបីតកសិណ ។បេ។

បុគ្គលម្នាក់ចាំបាននូវលោហិតកសិណ ។បេ។ បុគ្គលម្នាក់ចាំបាននូវឱទាតកសិណ ។បេ។ បុគ្គលម្នាក់ចាំបាននូវអាកាសកសិណ ។បេ។ បុគ្គលម្នាក់ចាំបាននូវវិញ្ញាណកសិណ ទាំងទិសខាងលើ ខាងក្រោម និងទិសទទឹង តាមលំដាប់ រកប្រមាណមិនបាន ។

[ ២៣០ ] អកុសលកម្មបថមាន ១០ យ៉ាង គឺបាណាតិបាត ១ អទិន្នាទាន ១ កាមេសុមិច្ឆាចារ ១ មុសាវាទ ១ បិសុណាវាចា ១ ផរុសវាចា ១ សម្ផប្បលាប ១ អភិជ្ឈា ១ ព្យាបាទ ១ មិច្ឆាទិដ្ឋិ ១ ។

[ ២៣១ ] កុសលកម្មបថមាន ១០ យ៉ាង គឺចេតនាវៀរចាកបាណាតិបាត ១ ចេតនាវៀរចាកអទិន្នាទាន ១ ចេតនាវៀរចាកកាមេសុមិច្ឆាចារ ១ ចេតនាវៀរចាកមុសាវាទ ១ ចេតនាវៀរចាកបិសុណាវាចា ១ ចេតនាវៀរចាកផរុសវាចា ១ ចេតនាវៀរចាកសម្ផប្បលាប ១ មិនមានអភិជ្ឈា ១ មិនមានព្យាបាទ ១ សម្មាទិដ្ឋិ ១ ។

[ ២៣២ ] អរិយវាសៈ ( ធម៌ជាគ្រឿងនៅរបស់ព្រះអរិយៈ ) មាន ១០ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានអង្គ ៥ លះបង់ហើយ ១ ប្រកបដោយធម្មឡង្គ៦ ១ មានកិរិយារក្សាធម៌តែមួយ ១ មានធម៌ជាគ្រឿងពឹងផ្អែក ៤ យ៉ាង ១ លះបង់សច្ចៈដែលបុគ្គលប្រកាន់ផ្សេងៗ គ្នា ១ មានការស្វែងរកនូវវត្ថុទាំងពួង លះបង់ហើយដោយប្រពៃ ១ មានសេចក្ដីត្រិះរិះ មិនសៅហ្មង ១ មានកាយសង្ខារស្ងប់រម្ងាប់ហើយ ១ មាន ចិត្តរួចស្រឡះហើយដោយល្អ ១ មានប្រាជ្ញារួចស្រឡះហើយដោយល្អ

១ ។ ម្នាលអាវុសោទាំងឡាយ ឯភិក្ខុមានអង្គ ៥ លះបង់ហើយ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកលះបង់កាមច្ឆន្ទៈ ១ លះបង់ព្យាបាទ ១ លះបង់ថីនមិទ្ធៈ ១ លះបង់ឧទ្ធច្ចកុក្កុច្ចៈ ១ លះបង់វិចិកិច្ឆា ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានអង្គ ៥ លះបង់ហើយ ដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុប្រកបដោយឆឡង្គុបេក្ខា តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយចក្ខុ ក៏មិនសោមនស្ស មិនទោមនស្ស ជាបុគ្គលព្រងើយកន្តើយ មានសតិនិងសម្បជញ្ញៈ ។ ឮសំឡេងដោយត្រចៀក ។ ធុំក្លិនដោយច្រមុះ ។ ទទួលរសដោយអណ្តាត ។ ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ។ ដឹងធម្មារម្មណ៍ដោយចិត្ត ក៏មិនសោមនស្ស មិនទោមនស្ស ជាបុគ្គលព្រងើយកន្តើយ មានសតិនិងសម្បជញ្ញៈ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុប្រកបដោយឆឡង្គុបេក្ខាដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានកិរិយារក្សាធម៌តែមួយ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ប្រកបដោយចិត្ត មានសតិជាគ្រឿងរក្សាទុក ម្នាលអាវុសោទាំងឡាយ ភិក្ខុមានកិរិយារក្សាធម៌តែមួយ ដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំង-ឡាយ ភិក្ខុមានធម៌ជាគ្រឿងពឹងផ្អែក ៤ យ៉ាង តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាហើយ ទើបសេពវត្ថុដែលគួរសេព ១ ពិចារណាហើយ ទើបអត់សង្កត់វត្ថុដែលគួរអត់សង្កត់ ១ ពិចារណាហើយ ទើបវៀរវត្ថុដែលគួរវៀរ ១ ពិចារណាហើយទើបបន្ទោបង់វត្ថុដែលគួរបន្ទោបង់

១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានធម៌ជាគ្រឿងពឹងផ្អែក ៤ យ៉ាង ដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុលះបង់សច្ចៈដែលបុគ្គលប្រកាន់ផ្សេងៗ គ្នា តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ បាននាំចេញ បន្ទោបង់ លះចោល ខ្ជាក់ចេញ ផ្តាច់ចេញ លះបង់រលាស់ចោល នូវសច្ចធម៌ដែលបុគ្គលប្រកាន់ផ្សេងគ្នាច្រើនបាន របស់ពួកសមណព្រាហ្មណ៍ជាច្រើននោះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុលះបង់សច្ចៈដែលបុគ្គលប្រកាន់ផ្សេងៗ គ្នា ដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានការស្វែងរក លះបង់ហើយដោយល្អ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ លះបង់ការស្វែងរកកាម លះបង់ការស្វែងរកភព លះបង់ការស្វែងរកព្រហ្មចារ្យ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានការស្វែងរក លះបង់ហើយដោយល្អ ដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានសេចក្តីត្រិះរិះមិនសៅហ្មង តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ លះបង់សេចក្តីត្រិះរិះក្នុងកាម លះបង់សេចក្តីត្រិះរិះក្នុងព្យាបាទ លះបង់សេចក្តីត្រិះរិះក្នុងការបៀតបៀន ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានសេចក្តីត្រិះរិះមិនសៅហ្មង ដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានកាយសង្ខារស្ងប់រម្ងាប់ហើយ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចូលកាន់ចតុត្ថជ្ឈាន មិនទុក្ខ មិនសុខ មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ព្រោះលះបង់សុខផង លះបង់ទុក្ខផង ព្រោះអស់សោមនស្សនិងទោមនស្សក្នុងកាល

មុន ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានកាយសង្ខារស្ងប់រម្ងាប់ហើយ ដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តរួចស្រឡះហើយដោយល្អ តើដូចម្ដេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានចិត្តរួចស្រឡះហើយចាករាគៈ មានចិត្តរួចស្រឡះហើយចាកទោសៈ មានចិត្តរួចស្រឡះហើយចាកមោហៈ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តរួចស្រឡះហើយដោយល្អ ដោយអាការយ៉ាងនេះឯង ។ម្នាលអាវុសោទាំងឡាយ ភិក្ខុមានប្រាជ្ញារួចស្រឡះហើយដោយល្អ តើដូចម្ដេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់ថា រាគៈអាត្មាអញលះបង់បានហើយ គាស់រំលើងឫសចេញហើយ ធ្វើឲ្យលែងកើតទៀតដូចដើមត្នោត ( កំបុតក ) ហើយ ធ្វើមិនឲ្យមាន មិនឲ្យកើតឡើងតទៅជាធម្មតា ដឹងច្បាស់ថា ទោសៈអាត្មាអញលះបង់បានហើយ គាស់រំលើងឫសចេញហើយ ធ្វើឲ្យលែងកើតទៀតដូចដើមត្នោត ( កំបុតក ) ហើយ ធ្វើមិនឲ្យមាន មិនឲ្យកើតឡើងតទៅជាធម្មតា ដឹងច្បាស់ថា មោហៈ អាត្មាអញលះបង់បានហើយ គាស់រំលើងឫសចេញហើយ ធ្វើឲ្យលែងកើតទៀតដូចដើមត្នោត ( កំបុតក ) ហើយ ធ្វើមិនឲ្យមាន មិនឲ្យកើតឡើងតទៅជាធម្មតា ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានប្រាជ្ញារួចស្រឡះហើយដោយល្អ ដោយអាការយ៉ាងនេះឯង ។

[ ២៣៣ ] អសេក្ខធម៌ ( ធម៌របស់អសេក្ខបុគ្គល ) មាន ១០ យ៉ាង គឺសម្មាទិដ្ឋិ ជាអសេក្ខធម៌ ១ សម្មាសង្កប្ប ជាអសេក្ខធម៌ ១ សម្មាវាចា ជាអសេក្ខធម៌ ១ សម្មាកម្មន្តៈ ជាអសេក្ខធម៌ ១ សម្មាអាជីវៈ ជាអសេក្ខ-

ធម៌ ១ សម្មាវាយាមៈ ជាអសេក្ខធម៌ ១ សម្មាសតិ ជាអសេក្ខធម៌ ១ សម្មាសមាធិ ជាអសេក្ខធម៌ ១ សម្មាញាណៈ ជាអសេក្ខធម៌ ១ សម្មាវិមុត្តិ ជាអសេក្ខធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ នេះឯងធម៌ពួក ១០ ដែលព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ត្រាស់សម្តែងទុកស្រេចហើយ ពួកយើងទាំងអស់គ្នា ត្រូវសង្គាយនា មិនត្រូវទាស់ទែងគ្នាក្នុងធម៌ទាំងនោះ ព្រហ្មចរិយធម៌នេះ ដែលនឹងតាំងនៅមាំ ឋិតនៅអស់កាលយូរ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំងឡាយ ។

ពួកធម៌ដប់ៗ ដែលរាប់ចូលក្នុងការសង្គាយនា ចប់

[ ២៣៤ ] លំដាប់នោះឯង ព្រះមានព្រះភាគទ្រង់ក្រោកឡើង ត្រាស់នឹងព្រះសារីបុត្តដ៏មានអាយុថា ម្នាលសារីបុត្ត ល្អហើយ ល្អហើយ ម្នាលសារីបុត្ត អ្នកបានសម្តែងសង្គីតិបរិយាយដល់ភិក្ខុទាំងឡាយ ជាការប្រពៃពេកណាស់ ។ លុះព្រះសារីបុត្តបានសម្តែងសូត្រនេះចប់ ។ ព្រះសាស្តាក៏បានពេញព្រះហឫទ័យហើយ ។ ភិក្ខុទាំងឡាយនោះ ក៏មានចិត្តត្រេកអរនឹងភាសិតរបស់ព្រះសារីបុត្តដ៏មានអាយុ ។

សង្គីតិសូត្រទី ១០ ចប់

# អដ្ឋកថា

# សន្តិតិសូត្រ

# ពោលអំពីធម្មិពួក ១

[ ៩២ ] សន្តិតិសូត្រ មានពាក្យចាប់ផ្ដើមថា **ឯវមេ្មុ សុតំ** ជាដើម ។ ក្នុងសន្តិតិសូត្រនោះ មានពាក្យអធិប្បាយទៅតាមលំដាប់បទដូច្នេះ បទថា **ចារិកញ្ចរមានោ** សំដៅដល់ ទ្រង់យាងទៅបែបនិពទ្ធចារិក ។ បានឮថា ក្នុងគ្រានោះ ព្រះសាស្ដាទ្រង់ផ្សាយសំណាញ់ គឺព្រះញាណទៅក្នុងម៉ឺនចក្រវាល ពិចារណាមើលសត្វលោក ទ្រង់បានសម្លឹងឃើញពួកមល្លរាជ អ្នកក្រុងបាវា ទើបទ្រង់រំពឹងថា រាជាទាំងនេះមកប្រាកដក្នុងសំណាញ់ គឺសព្វញ្ញុតញ្ញាណរបស់តថាគត ។ នឹងមានហេតុដូចម្ដេច ។ ទ្រង់ក៏បានជ្រាបសេចក្ដីនេះថា រាជាទាំងឡាយឲ្យសាងសណ្ឋាគារឡើងមួយកន្លែង កាលតថាគតទៅ ក៏នឹងឲ្យតថាគតពោលមង្គល តថាគតពោលមង្គលដល់ព្រះរាជាទាំងនោះហើយ បញ្ជូនឲ្យ ( ត្រឡប់ ) ទៅវិញ នឹងត្រាស់បង្គាប់សារីបុត្រថា អ្នកចូរពោលធម្មកថាដល់ពួកភិក្ខុ ។ សារីបុត្រពិចារណាដោយព្រះត្រៃបិដកហើយ នឹងពោលសន្តិតិសូត្រដល់ពួកភិក្ខុ ប្រដាប់ទៅដោយបញ្ហា ១០១៤ ប្រការ ភិក្ខុ ៥០០ រូប រឭកដល់ព្រះសូត្រ ( នេះ ) ហើយ នឹងសម្រេចអរហត្ត ព្រមដោយបដិសម្ភិទា ដូច្នេះ ទើបបានទ្រង់ចារិកទៅ ព្រោះហេតុនោះ ទើបលោកពោលថា **មល្លេសុ ចារិកញ្ចរមានោ** ។

[ ៩៣ ] ពាក្យថា **ឧព្ភតកំ** ជាឈ្មោះរបស់សណ្ឋាគារនោះ ។ ន័យមួយ

ទៀត លោកហៅថា (**ឧព្ពតកំ**) យ៉ាងនោះ ព្រោះជាអាគារខ្ពស់ ។ ពាក្យថា **សណ្ឋាគារំ** សំដៅដល់សាលាប្រជុំកណ្តាលក្រុង ។ ក្នុងបទថា **សមណេន វា** នេះ ព្រោះហេតុដែលទេវតាទាំងឡាយ រមែងកាន់យកទីនៅរបស់ខ្លួន ក្នុងវេលាដែលកំណត់ផ្ទៃដី ( សាង ) ផ្ទះទុំះឯង ដូច្នោះ ទើបលោកមិនពោលថា **ទេវេន វា** តែពោលថា **សមណេន វា ព្រាហ្មណេន វា កេនចិ វា មនុស្សភូតេន** សមណព្រាហ្មណ៍ ឬអ្នកណាម្នាក់ដែលជាមនុស្ស ។

ពាក្យថា **យេន ភគវា តេនុបសង្កមឹសុ** សេចក្តីថា ពួកស្តេចមល្លៈបានស្តាប់ ( ដំណឹងថា ) ព្រះមានព្រះភាគទ្រង់យាងមក ទើបត្រិះរិះថា សូម្បីពួកយើង ក៏មិនបានទៅទូលអារាធនាព្រះមានព្រះភាគមក ទាំងមិនបានបញ្ជូនទូតទៅក្រាបទូលឲ្យទ្រង់យាងមក តែព្រះអង្គក៏មកដល់ទីនៅរបស់ពួកយើងដោយព្រះអង្គឯង មានភិក្ខុជាច្រើនជាបរិវារ ឯពួកយើងក៏បានសាងសណ្ឋាគារ-សាលាឡើងហើយ យើងនឹងយាងព្រះទសពលមក ឲ្យទ្រង់ប្រទានមង្គលក្នុងសណ្ឋាគារសាលានេះ ដូច្នេះ ទើបបានចូលទៅគាល់ ។ ពាក្យថា **យេន សណ្ឋាគារំ តេនុបសង្កមឹសុ** សេចក្តីថា ពួកមល្លក្សត្រទាំងនោះគិតថា បានឮថា ជាងធ្វើចិត្រកម្មក្នុងសណ្ឋាគារសម្រេចហើយ តែពួកប៉មយាម ទើបតែនឹងសម្រេចក្នុងថ្ងៃនោះ និងធម្មតាព្រះពុទ្ធទាំងឡាយ ទ្រង់មានព្រះអធ្យាស្រ័យត្រេកអរក្នុងព្រៃ រីករាយក្នុងព្រៃ ទ្រង់ពេញព្រះហឫទ័យប្រថាប់នៅខាងក្នុងស្រុកឬទេ ( ក៏មិនអាចជ្រាបបាន ) ព្រោះដូច្នោះ យើងជ្រាបដល់ព្រះហឫទ័យរបស់ព្រះមានព្រះភាគមុនហើយ ទើបនឹងត្រៀមការ ដូច្នេះហើយ ចូលទៅគាល់

ព្រះមានព្រះភាគ ។ តែឥឡូវនេះ ពួកមល្លក្សត្រប្រាថ្នានឹងត្រៀមការ ឲ្យត្រូវព្រះហឫទ័យព្រះមានព្រះភាគ ទើបចូលទៅកាន់សណ្ឋាគារ ។ បទថា **សព្វសន្ថរឹ** សេចក្តីថា ក្រាលសព្វទីកន្លែង ។

មួយទៀត ក្នុងពាក្យថា **យេន ភគវា តេនុបសង្កមឹសុ** នេះ សេចក្តីថា ពួកមល្លក្សត្រទាំងនោះ ចាត់ចែងសណ្ឋាគារស្រេចហើយ ទើបឲ្យបោសសម្អាតថ្នល់ក្នុងក្រុង ឲ្យលើកទង់ឡើង ហើយតាំងផ្ទាំងទឹកពេញប្រៀប ទាំងដើមចេកក្នុងទ្វារស្រុកទាំងឡាយ ធ្វើក្រុងទាំងអស់ឲ្យពាសពេញទៅដោយរបៀបនៃគោមភ្លើង ដូចជាដួងផ្កាយ ហើយឲ្យប្រកាសថា ពួកទារកដែលនៅមិនទាន់ផ្តាច់ដោះ ចូរឲ្យបៅដោះឲ្យហើយ ពួកក្មេងជំទង់ៗ ចូរប្រញាប់ឲ្យបរិភោគ ( អាហារ ) ហើយឲ្យដេក កុំធ្វើសំឡេងឲ្យលាន់ឮកងរំពង ថ្ងៃនេះព្រះសាស្តានឹងប្រថាប់ខាងក្នុងស្រុកមួយយប់ ទីព្រះពុទ្ធទាំងឡាយ រមែងទ្រង់ពេញព្រះហឫទ័យ ជាកន្លែងស្ងប់ស្ងាត់ ដូច្នេះហើយ នាំគ្នាកាន់គប់ភ្លើងដោយខ្លួនឯង ចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់ ។

[ ៩៤ ] ពាក្យថា **ភគវន្តំយេវ បុរក្ខិត្វា** ប្រែថា ធ្វើព្រះមានព្រះភាគទុកខាងមុខ ។ ព្រះមានព្រះភាគ ប្រថាប់គង់ត្រង់កណ្តាលភិក្ខុ និងឧបាសកទាំងឡាយ ក្នុងសណ្ឋាគារនោះ រមែងរុងរោចន៍ក្រៃលែងណាស់ ជាទីតាំងនៃសេចក្តីជ្រះថ្លាដោយជុំវិញ មានព្រះឆវីវណ្ណដូចមាសស្រស់ល្អ គួរសរសើរ ។ ព្រះរស្មីមានពណ៌ដូចជាមាស ផ្សាយចេញចាកព្រះវរកាយខាងមុខ ផ្សាយទៅដល់ ៨០ ហត្ថ ។ ព្រះរស្មី មានពណ៌ដូចមាស ផ្សាយចេញចាកព្រះវរកាយ

កណ្តាល ពីព្រះហស្តខាងស្តាំ ពីព្រះហស្តខាងឆ្វេង ក៏ផ្សាយទៅបានម្ខាង ៨០ ហត្ថ ( ដូចៗ គ្នា ) ។ ព្រះរស្មីមានពណ៌ដូចផ្កាកមយូរ ផ្សាយចេញពីជុំវិញព្រះកេសាទាំងអស់ទៅផ្នែកខាងលើ ផ្សាយទៅកាន់នភាកាសកម្ពស់ ៨០ ហត្ថ ។ ព្រះរស្មីមានពណ៌ដូចកែវប្រវាល ផ្សាយចេញពីបាតព្រះបាទខាងក្រោមទៅក្នុងផែនដីរហូតដល់ ៨០ ហត្ថ ។ ព្រះពុទ្ធរស្មីមានពណ៌ ៦ ប្រការ ផ្សាយចេញរុងរឿងចែងចាំង រហូតអស់ទីប្រមាណ ៨០ ហត្ថដោយជុំវិញ ដោយប្រការដូច្នេះ ។ សព្វទិសាភាគក៏ភ្លឺច្បាស់ច្បាស់ ដូចជារោយរាយទៅដោយផ្កាចម្បាមាស ដូចជាចាក់ស្រោចដោយសុវណ្ណរស ដែលហូរពីផ្ទាំងមាស ដូចដេរដាសទៅដោយផែនមាស និងដូចជាពាសពេញទៅដោយកម្ទេចផង់ផ្កាមាស និងកណិការ ដែលហុយដោយវេរម្ភវាត ។ សូម្បីព្រះវរកាយនៃព្រះមានព្រះភាគដែលរុងរឿងដោយអនុព្យញ្ជនៈ ៨០ ប្រការ ព្រះរស្មី ( ដោយប្រក្រតី ) ប្រមាណមួយព្យាម និងវរលក្ខណ៍ ៣២ ប្រការ ក៏រុងរោចន៍ដូចផ្ទៃមេឃ ដែលដេរដាសដោយពពួកផ្កាយ ដូចជាផ្កាបទុមដែលរីកស្គុះស្គាយ ដូចបារិច្ឆត្តក ប្រមាណ ១០០ យោជន៍ មានផ្ការពេញដើម ដូចនឹងផ្សាយព្រះសិរីគ្របសង្កត់នូវសិរីនៃព្រះអាទិត្យ ព្រះចន្ទ ស្តេចចក្រពត្តិ ទេវរាជ ( និង ) មហាព្រហ្ម នីមួយៗ មាន ៣២ ដែលតាំងទុកដោយលំដាប់គ្នា ( ឲ្យអាប់រស្មីទៅ ) ដូច្នោះ ។ សូម្បីភិក្ខុទាំងអស់ ដែលអង្គុយជុំវិញនៅទីនោះ ក៏សុទ្ធតែជាអ្នកប្រាថ្នាតិច សន្តោសស្ងប់ មិនច្របូកច្របល់ ធ្វើសេចក្តីព្យាយាម ជាអ្នកទូន្មាន អត់ធន់ចំពោះពាក្យទូន្មាន ជាអ្នកជាស់តឿន តិះដៀលបាប សម្បូរដោយសីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញាណទស្សនៈ ។ ព្រះមានព្រះភាគ ដែលភិក្ខុទាំងនោះ ហែហម

ហើយ រុងរោចន៍ដូចជាដុំមាស ដែលគ្របដណ្តប់ដោយសំពត់កម្ពលក្រហម ដូចផ្ទះមាសដែលអណ្តែតនៅត្រង់កណ្តាលព្រៃបទុមក្រហម ដូចប្រាសាទមាស ដែលឡោមព័ទ្ធជុំវិញ ដោយវេទិកាកែវប្រវាល ។ ឯព្រះអសីតិមហាថេរៈ ស្លៀកដណ្តប់សំពត់បង្សុកូលពណ៌ដូចពពក ជាមហានាគ ដូចដំបូកកែវមណី កម្ចាត់រាគៈហើយ ទម្លាយកិលេសអស់ហើយ កាត់ផ្តាច់ជដាចេញអស់ហើយ កាត់គ្រឿងចងបានហើយ មិនជាប់ជំពាក់ក្នុងត្រកូល ឬក្នុងពួកគណៈ ក៏អង្គុយជុំវិញព្រះមានព្រះភាគ ដោយប្រការដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់ប្រាសចាករាគៈដោយព្រះអង្គឯងហើយ ទ្រង់មានអ្នកប្រាសចាករាគៈនៅជុំវិញ ទ្រង់ប្រាសចាកទោសៈ ដោយព្រះអង្គឯងហើយ ទ្រង់មានអ្នកប្រាសចាកទោសៈនៅជុំវិញ ទ្រង់ប្រាសចាកមោហៈដោយព្រះអង្គឯង ទ្រង់មានអ្នកប្រាសចាកមោហៈនៅជុំវិញ ទ្រង់គ្មានតណ្ហាដោយព្រះអង្គឯង ទ្រង់មានអ្នកគ្មានតណ្ហានៅជុំវិញ ទ្រង់គ្មានកិលេសដោយព្រះអង្គឯង ទ្រង់មានអ្នកគ្មានកិលេសនៅជុំវិញ ទ្រង់ជាពុទ្ធៈដោយព្រះអង្គឯង ទ្រង់មានអ្នកជាពុទ្ធៈ មានអ្នកពហូសូតនៅជុំវិញ ដូចជាកេសរដែលហ៊ុមព័ទ្ធទៅដោយត្របក ដូចកណិការដែលហ៊ុមព័ទ្ធទៅដោយកេសរ ដូចស្តេចដំរីឆទ្ទន្តដែលហែហមទៅដោយដំរីបរិវារទាំង ៨ ពាន់ ដូចស្តេចហង្សធតរដ្ឋ ដែលហែហមទៅដោយហង្សបរិវារ ៩ សែន ដូចជាស្តេចចក្រពត្តិ ដែលហែហមទៅដោយពួកសេនាង្គនិករ ដូចសក្កទេវរាជ ដែលហែហមទៅដោយពួកទេវៈ ដូចហារិតមហាព្រហ្មដែលហែហមទៅដោយគណៈព្រហ្ម បានប្រថាប់គង់ត្រង់កណ្តាលបរិស័ទទាំងនោះ ដោយពុទ្ធកេទដែលរកអ្វីស្មើ ដូចបានដោយពុទ្ធវិលាស ដែលរកប្រមាណមិនបាន ទ្រង់ញ៉ាំង

ពួកមល្លក្សត្រនៃនគរបាវាឲ្យឃើញ ។ល។ ដោយធម្មីកថារហូតដល់យប់ជ្រៅហើយ ទ្រង់បញ្ជូនទៅ ។ ម្យ៉ាងទៀត ក្នុងទីនេះគប្បីជ្រាបថា បកិណ្ណកកថា ដែលប្រកបទៅដោយពាក្យអនុមោទនាក្នុងសណ្ឋាគារ ឈ្មោះថា ធម្មកថា ។ ពិតណាស់ ក្នុងគ្រានោះ ព្រះមានព្រះភាគបានត្រាស់បកិណ្ណកកថា ដែលនាំមកនូវប្រយោជន៍ និងសេចក្តីសុខដល់មល្លក្សត្រនៃនគរបាវា ដូចជាញុំាងអាកាសគង្គាឲ្យបង្ហូរចុះហើយ ដូចជាទ្រង់ប្រមូលមកនូវឱជៈនៃបឋវី ដូចជាទ្រង់ចាប់ចុងដើមមហាជម្ពូ ហើយអង្រួនឲ្យញាប់ញ័រ និងដូចជាទ្រង់រម្ងាស់សម្បុកឃ្មុំដែលគួរដល់ការរម្ងាស់ដោយគ្រឿងចក្រហើយ ញុំាងបុគ្គលឲ្យផឹកនូវទឹកផ្អែមដូច្នោះ ។

[ ៩៥ ] ពាក្យថា **តុណ្ហីភូតំ តុណ្ហីភូតំ** សេចក្តីថា ទ្រង់ឆ្មៀងមើលទិសណាៗ ពួកភិក្ខុក្នុងទិសនោះៗ ស្ងៀមស្ងាត់ ។ ពាក្យថា **អនុវិលោកេត្វា** សេចក្តីថា ឆ្មៀងមើលតាមទិសនោះៗ ដោយចក្ខុ ២ យ៉ាង គឺមំសចក្ខុ និងទិព្វចក្ខុ ។ ពិតហើយ ទ្រង់កំណត់ឥរិយាបថខាងក្រៅរបស់ភិក្ខុទាំងនោះ ដោយមំសចក្ខុ ។ ក្នុងពួកភិក្ខុទាំងនោះ មិនមានភិក្ខុដែលឃ្នើសឃ្នងដៃ ឃ្នើសឃ្នងជើង សូម្បីត្រឹមតែមួយរូប មិនមានរូបណាងើប សីសៈនិយាយចរចា ឬអង្គុយលក់ ។ ភិក្ខុទាំងពួងនោះ ជាអ្នកសិក្សាអប់រំមកហើយដោយត្រៃសិក្ខា អង្គុយស្ងប់ស្ងៀម ដូចជាអណ្តាតប្រទីបក្នុងទីដែលស្ងាត់ខ្យល់ ដូច្នោះ ។ ទ្រង់កំណត់ឥរិយាបថនេះ របស់ភិក្ខុទាំងនោះ ដោយមំសចក្ខុ ដោយប្រការដូច្នេះ ។

មួយទៀត ទ្រង់ចម្រើនអាលោក ( ពន្លឺ ) ជាបឃើញហទយៈរូបរបស់ភិក្ខុទាំងនោះ ហើយទ្រង់ត្រួតមើលសីលខាងក្នុង ដោយទិព្វចក្ខុ ។ ព្រះអង្គ

ទ្រង់បានឃើញសីល ដែលចូលដល់នូវអរហត្តរបស់ភិក្ខុច្រើនរយ ដូចប្រទីប ដែលភ្លឺឆ្អូឆ្អៅ នៅខាងក្នុងផ្ទាំង ។ ពិតហើយ ភិក្ខុទាំងនោះ ជាអ្នកប្រារព្ធ វិបស្សនា ។ ទ្រង់បានឃើញសីលរបស់ភិក្ខុទាំងនោះ ដោយប្រការដូច្នេះហើយ ទ្រង់ត្រិះរិះថា ភិក្ខុទាំងនេះជាគូគួរដល់តថាគត ទាំងតថាគត ក៏ជាគូគួរដល់ភិក្ខុ ទាំងនេះ ហើយទ្រង់តាំងនិមិត្តទុកក្នុងផ្ទៃដី ចក្ខុពិចារណាមើលពួកសង្ឃ ហើយ ត្រាស់ហៅព្រះសារីបុត្រថា តថាគតចុករោយខ្នង ។ ព្រោះហេតុអ្វី ទើបទ្រង់ ចុករោយខ្នង ។ ព្រោះកាលព្រះមានព្រះភាគ ទ្រង់បំពេញសេចក្ដីព្យាយាម យ៉ាងខ្លាំងក្លាអស់ ៦ ឆ្នាំ បានកើតសេចក្ដីលំបាកព្រះវរកាយជាច្រើន ។ លុះ កាលតមក ដល់ទ្រង់ព្រះជរា ខ្យល់ចាក់សៀតខ្នង រមែងកើតឡើងដល់ទ្រង់ បាន ( ជាធម្មតា ) ។ ពាក្យថា **សង្ឃាដឹ បញ្ញបេត្វា** សេចក្ដីថា បានឮថា មល្លក្សត្រទាំងនោះ ឲ្យក្រាលគ្រែដែលជាកប្បិយៈទុកត្រង់ផ្នែកម្ខាងនៃសណ្ឋាគារ ដោយសេចក្ដីថា ពេលខ្លះព្រះសាស្ដានឹងគប្បីផ្ទំ ។ ចំណែកព្រះសាស្ដា ទ្រង់ ត្រិះរិះថា គ្រែដែលតថាគតប្រើប្រាស់ដោយឥរិយាបថទាំង ៤ នឹងមានផលា-និសង្សច្រើនដល់មល្លក្សត្រទាំងនេះ ទើបត្រាស់បង្គាប់ឲ្យក្រាលសំពត់សង្ឃាដី លើគ្រែនោះ ហើយផ្ទំ ។

## ការធ្វើមរណកាលនៃនិគណ្ឋនាដបុត្ត

[ ៩៦ ] ពាក្យដែលគួរពោល ក្នុងពាក្យថា **តស្ស កាលកិរិយាយ** ជាដើម បានពោលទុកហើយទាំងអស់ក្នុងខាងក្រោយ ។

ពាក្យថា **អាមន្តេសិ** សេចក្ដីថា ទ្រង់ប្រាថ្នានឹងសម្ដែង **សង្គាគតធម៌**

ដែលធ្វើសេចក្ដីស្ងប់រម្ងាប់ ហេតុមានការទាស់ទែងគ្នាជាដើម ទើបបានត្រាស់ហៅ ។ ពាក្យថា **តត្ថ** ប្រែថា ក្នុងធម៌នោះ ។ ពាក្យថា **សង្គាយិតព្វំ** សេចក្ដីថា សង្ឃដែលព្រមព្រៀងគ្នា គប្បីសង្គាយនា គឺសង្ឃអ្នកមានពាក្យតែមួយ មានពាក្យមិនជំទាស់គ្នា គប្បីសូធ្យ ។ ពាក្យថា **ន វិវទិតព្វំ** សេចក្ដីថា មិនគួរពោលជំទាស់គ្នាក្នុងអត្ថក៏ដោយ ក្នុងព្យញ្ជនៈក៏ដោយ ។

[ ៩៧ ] ពាក្យថា **ឯកោ ធម្មោ** សេចក្ដីថា ព្រះថេរៈមានសេចក្ដីប្រាថ្នានឹងសម្ដែងសាមគ្គីរសច្រើនយ៉ាង ដូចពួក ១ ពួក ២ ពួក ៣ ជាដើម ទើបពោលថា **ឯកោ ធម្មោ** ( ធម៌មួយ ) ដូច្នេះ ជាលំដាប់ដំបូង ។

ពាក្យថា **សព្វេ សត្តា** សំដៅដល់ សត្វទាំងពួង ក្នុងភពទាំងពួង ដូចក្នុងកាមភពជាដើម ក្នុងសញ្ញីភពជាដើម និងក្នុងឯកវោការភពជាដើម ។

ពាក្យថា **អាហារដ្ឋិតិកា** មានបទនិយាមថា សត្វទាំងនោះ តាំងនៅបានព្រោះអាហារ ដូច្នោះ ទើបឈ្មោះថា **អាហារដ្ឋិតិកា** អ្នកតាំងនៅបានព្រោះអាហារ ។ អាហាររមែងជាហេតុនៃការតាំងនៅ បានដល់ សព្វសត្វដោយប្រការដូច្នេះ ។ ព្រះថេរៈសម្ដែងអត្ថថា លោកទាំងឡាយ ធម៌ ១ គឺសត្វទាំងឡាយតាំងនៅបាន ព្រោះអាហារនេះ ព្រះសាស្ដារបស់យើងទាំងឡាយ ទ្រង់ជ្រាបសេចក្ដីពិតហើយ បានត្រាស់ទុកជាការត្រឹមត្រូវ ។ កាលបើដូច្នេះ ពាក្យដែលត្រាស់ថា ពួកទេវតាជាអសញ្ញសត្វ ជាអហេតុកៈ មិនមានអាហារ មិនមានផស្សៈ ដូច្នេះជាដើម នឹងមិនជាការខុសទេឬ ។ មិនខុស ព្រោះទេវតាទាំងនោះ ក៏មានឈានជាអាហារ ។ បើដូច្នោះ សូម្បីពាក្យដែល

ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ដែលថា អាហារដើម្បីការតាំងនៅរបស់ពួកសត្វទាំងឡាយដែលកើតមកហើយ ឬដើម្បីអនុគ្រោះដល់ពួកសម្ភវេសី សត្វមាន ៤ យ៉ាង តើ ៤ យ៉ាង អ្វីខ្លះ ។ ១ **កវឡិង្ការាហារ** អាហារគ្រោតគ្រាតក៏ដោយ ល្អិតក៏ដោយ **២ ផស្សាហារ ៣ មនោសញ្ចេតនាហារ ៤ វិញ្ញា-ណាហារ** ដូច្នេះក៏ខុស ។ សូម្បីពាក្យនេះ ក៏មិនឃៀងឃាត ។ ព្រោះថាក្នុងព្រះសូត្រនោះ ត្រាស់ធម៌ទាំងឡាយ ដែលមានលក្ខណៈ ជាអាហារដោយត្រង់ទុំះឯងថា **អាហារ ។** តែក្នុងទីនេះ ត្រាស់ហៅបច្ច័យដោយអមថា **អាហារ** ពិតហើយ បច្ច័យគួរនឹងបានដល់ធម៌ទាំងពួង ។ ហើយបច្ច័យនោះ ញុំាងផលឯណាឲ្យកើត ក៏រមែងឈ្មោះថា នាំមកនូវផលនោះៗ ព្រោះដូច្នោះ ទើបហៅបានថា **អាហារ** ដោយហេតុនោះឯង ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សូម្បីអវិជ្ជា តថាគតក៏ពោលថា មានអាហារ មិនមែនមិនមានអាហារទេ ម្នាលភិក្ខុទាំងឡាយ ចុះអ្វីហ្ន៎ ជាអាហាររបស់អវិជ្ជា គប្បីនឹងពោលថា នីវរណៈ ៥ ជាអាហាររបស់អវិជ្ជា ម្នាលភិក្ខុទាំងឡាយ សូម្បីនីវរណៈ តថាគតក៏ពោលថា មានអាហារ មិនមែនមិនមានអាហារទេ ម្នាលភិក្ខុទាំងឡាយ ចុះអ្វីហ្ន៎ ជាអាហាររបស់នីវរណៈ ៥ នឹងពោលថា អយោនិសោមនសិការ ជាអាហាររបស់នីវរណៈ ដូច្នេះ អាហារ គឺបច្ច័យនេះជាបំណងក្នុងព្រះសូត្រនេះ ។ កាលកាន់យកបច្ច័យជាអាហារតែម្យ៉ាងហើយ រមែងជាការកាន់យកទាំងអស់ ទាំងអាហារដោយអម ទាំងអាហារដោយត្រង់ ។ ក្នុងអសញ្ញភពនោះ រមែងបានអាហារប្បច្ច័យ ។

កាលព្រះពុទ្ធទ្រង់មិនទាន់កើតឡើង ពួកអ្នកបួសក្នុងលទ្ធិតិត្ថិយ ធ្វើបរិកម្ម ក្នុងវាយោកសិណ ញុំាងឈានទី ៤ ឲ្យកើតឡើងបាន ចេញចាកឈាននោះ ញុំាងសេចក្តីត្រេកអរពេញចិត្តថា គួរតិះដៀលចិត្ត ចិត្តនេះ គួរតិះដៀលពិត ឈ្មោះថា ការមិនមានចិត្តនុ៎ះឯង ជាការល្អ ព្រោះអាស្រ័យចិត្ត ទើបកើតទុក្ខ ដែលមានការសម្លាប់ និងការឃុំឃាំងជាដើមជាបច្ច័យ កាលមិនមានចិត្ត ទុក្ខ នោះក៏មិនមាន ដូច្នេះ ឈានមិនវិនាស អស់ជីវិតហើយ ទៅកើតនៅក្នុង អសញ្ញភព ។ អ្នកណាតាំងនៅឥរិយាបថណាក្នុងមនុស្សលោក អ្នកនោះ ក៏កើតដោយឥរិយាបថនោះ ជាអ្នកឈរខ្លះ អង្គុយខ្លះ ដេកខ្លះ រហូត ៥០០ កប្ប ដូចជាការដេក នៅរហូតអស់កាលយូរដល់ត្រឹមនេះ ។ សូម្បីសត្វទាំង-ឡាយ ដែលមានរូបយ៉ាងនេះ ក៏រមែងបានអាហារប្បច្ច័យ ។ ពិតហើយ សត្វ ទាំងនោះ ចម្រើនឈានណាហើយទៅកើត ឈាននោះឯង រមែងជាបច្ច័យ របស់សត្វទាំងនោះ ។ បច្ច័យ គឺឈាននៅមានដរាបណា ក៏រមែងតាំងនៅ បានដរាបនោះ ឧបមាដូចកូនសរ ដែលបាញ់ទៅ ដោយកម្លាំងបញ្ចូននៃខ្សែ កម្លាំងបញ្ចូននៃខ្សែមានត្រឹមណា កូនសរទៅបានត្រឹមនោះ ដូច្នោះ ។ កាល បច្ច័យ គឺឈាននោះអស់ហើយ សត្វទាំងនោះ ក៏រមែងធ្លាក់ទៅ ដូចកូនសរ ដែលអស់កម្លាំងបញ្ចូននៃខ្សែ ដូច្នោះ ។

ចំណែកពួកសត្វនរក ដែលលោកពោលថា មិនបានរស់នៅដោយ ផលនៃសេចក្តីតាំងមាំ ទាំងមិនបានរស់នៅដោយផលនៃបុណ្យទាំងនេះ មាន អ្វីជាអាហារ ។ កម្មនុ៎ះឯងជាអាហាររបស់សត្វនរកទាំងនោះ ។ បើនឹងសួរថា អាហារមាន ៥ យ៉ាង ដូច្នោះឬ ។ ( ត្រូវឆ្លើយថា ) ពាក្យថា ៥ យ៉ាង ឬមិន

មែន ៥ យ៉ាងនេះ មិនគួរនិយាយ លោកពោលពាក្យនេះហើយ មិនមែនឬថា បច្ច័យ គឺអាហារ ព្រោះដូច្នោះ សត្វទាំងនោះ កើតក្នុងនរកដោយកម្មណា កម្ម នោះឯងចាត់ថា ជាអាហារ ព្រោះជាបច្ច័យនៃការតាំងនៅ របស់សត្វទាំងនោះ ដូចត្រាស់ទុកថា នឹងមិនទាន់អស់ជីវិតដរាបដែលបាបកម្មនោះ មិនទាន់អស់ ។ និងក្នុងទីនេះ មិនគួរនឹងពោលថា ត្រូវគ្នាដោយរឿងកវឡិង្ការាហារ ។ ព្រោះ សូម្បីតែទឹកមាត់ ដែលកើតក្នុងមាត់ ក៏ញុំាងឲ្យសម្រេចកិច្ចក្នុងរឿងអាហារ ដល់សត្វទាំងនោះបាន ។

ពិតហើយ ទឹកមាត់នោះ ក្នុងនរករាប់ថា ជាទីតាំងនៃទុក្ខវេទនា ក្នុង សួគ៌ រាប់ថា ជាទីតាំងនៃសុខវេទនា ចាត់ថា ជាបច្ច័យបាន ។

ដូច្នោះ ក្នុងកាមភព ដោយត្រង់ មានអាហារ ៤ យ៉ាង ក្នុងរូបភព និង អរូបភព វៀរលែងតែអសញ្ញសត្តៈដ៏សេសក្រៅពីនោះ មានអាហារ ៣ យ៉ាង សម្រាប់អសញ្ញសត្តៈ និងទេពដទៃៗ ( ក្រៅពីដែលពោលហើយ ) មានអាហារ គឺអាហារប្បច្ច័យ ដោយប្រការដូច្នេះ ។ ព្រះថេរៈពោលបញ្ហាប្រការទី ១ ថា សត្វទាំងពួងតាំងនៅបានព្រោះអាហារ ដោយអាហារតាមដែលសម្តែងមកនេះ ហើយ បានឆ្លើយបញ្ហាទី ២ ថា សត្វទាំងពួង ឋិតនៅបាន ព្រោះអាស្រ័យ សង្ខារ ដូច្នេះ ដោយមិនបានកំណត់យ៉ាងនេះថា **អយំ ខោ អាវុសោ** ( នេះឯង លោកទាំងឡាយ ) ទាំងមិនបានកែសេចក្តីទៀតថា **អត្ថិ ខោ អាវុសោ** ( មាន លោកទាំងឡាយ ) ។ ព្រោះហេតុអ្វី ទើបមិនបានកំណត់ ទាំងមិនបានកែសេចក្តី ទៀត ។ ព្រោះការដែលនឹងរៀន និងទន្ទានក្នុងកាលវល់តែកំណត់សំដៅ ទាំង វល់តែកែសេចក្តីហើយនោះ ជារឿងលំបាក ដូច្នោះ ទើបលោកកែសេចក្តី

ទាំងពីររួមគ្នា ។

សូម្បីក្នុងការកែបញ្ហាប្រការទី ២ នេះ បច្ច័យដែលបានពោលមកហើយនុ៎ះឯង ក៏ហៅថា សង្ខារ ព្រោះតាក់តែងផលរបស់ខ្លួន ។ អាហារប្បច្ច័យបានពោលមកហើយ សេចក្ដីផ្សេងគ្នាយ៉ាងតិចបំផុត ក្នុងបញ្ហាប្រការនេះ គឺប្រការនេះ ក្នុងទីនេះ ជាសង្ខារប្បច្ច័យ ។ ( តែ ) ព្រះមហាសិវត្ថេរពោលថា កាលកាន់យកយ៉ាងនេះថា អាហារដោយត្រង់បានកាន់យកហើយ ក្នុងទីនេះ សំដៅយក អាហារដោយអម ដូច្នេះ សេចក្ដីផ្សេងគ្នាក៏នឹងប្រាកដឡើង ប៉ុន្តែថា លោកមិនបានកាន់យក ( យ៉ាងនោះ ) ។ ពិតហើយ ធម៌ដែលជាប់ដោយឥន្ទ្រិយ មិនជាប់ដោយឥន្ទ្រិយ គួរនឹងបានបច្ច័យដូច្នេះឯង ។ ដែលឈ្មោះថា ធម៌ វៀរចាកបច្ច័យ រមែងមិនមាន ។ បណ្ដាធម៌ ២ យ៉ាងនោះ ធម៌ដែលមិនជាប់ដោយឥន្ទ្រិយ ដូច ស្មៅ ដើមឈើ និងវល្លិជាដើម រមែងមានរសផែនដី និងរសទឹកជាបច្ច័យ ។ ព្រោះកាលភ្លៀងមិនធ្លាក់ ស្មៅជាដើមក៏ស្វិត ។ តែនឹងស្រស់ខៀវ កាលភ្លៀងធ្លាក់ ។ រសផែនដី និងរសទឹកជាបច្ច័យដល់ស្មៅជាដើមទាំងនោះ ដោយប្រការ ដូច្នេះ ។ ធម៌ដែលជាប់ដោយឥន្ទ្រិយ មានវត្ថុជាដើមថា អវិជ្ជា តណ្ហា កម្ម អាហារជាបច្ច័យ បច្ច័យក្នុងកាលក្រោយនុ៎ះឯង លោកហៅថា អាហារ ( តែ ) ក្នុងទីនេះ លោកហៅថា សង្ខារ សេចក្ដីផ្សេងគ្នាក្នុងរឿងនេះ មានត្រឹមតែប៉ុណ្ណេះឯង ។ បទថា **អយំ ខោ អាវុសោ** សេចក្ដីថា លោកទាំងឡាយ ធម៌មួយនេះ ព្រះសាស្ដារបស់ពួកយើង ប្រថាប់ក្នុងមហាពោធិមណ្ឌល ទ្រង់ធ្វើឲ្យច្បាស់ដោយព្រះសព្វញ្ញុតញ្ញាណព្រះអង្គឯង ហើយទ្រង់បានសម្ដែង ជាធម៌មួយ ដែលលោកទាំង-

ឡាយ គប្បីសង្គាយនាព្រមព្រៀងគ្នា មិនគប្បីជំទាស់គ្នា ។ ពាក្យថា **យថយិទំ ព្រហ្មចរិយំ** សេចក្តីថា សាសនព្រហ្មចរិយៈនេះ គប្បីតាំងមាំបាន ដូចកាលដែលលោកទាំងឡាយសង្គាយនា ។ គឺកាលភិក្ខុមួយរូបពោលថា លោកទាំងឡាយ ធម៌ ១ ដែលព្រះសាស្តាត្រាស់ដោយប្រពៃហើយមាន ធម៌ ១ នោះគឺអ្វីសត្វទាំងពួងតាំងនៅបានព្រោះអាហារ សត្វទាំងពួងតាំងនៅបានព្រោះសង្ខារ ដូច្នេះ ភិក្ខុមួយរូបបានស្តាប់ពាក្យពោលរបស់ភិក្ខុរូបនោះហើយ ក៏ប្រាប់តទៅមួយរូបទៀតបានស្តាប់ ក៏ប្រាប់គ្នាតទៅទៀត ដោយកំណត់ពាក្យប្រាប់បន្តៗ គ្នាទៅ ដោយប្រការយ៉ាងនេះឯង ព្រហ្មចរិយៈនេះ ក៏នឹងតាំងនៅរហូតអស់កាលយូរ ដើម្បីប្រយោជន៍ដល់លោក ព្រមទាំងទេវលោក ព្រះធម្មសេនាបតីសារីបុត្របានសម្តែងសាមគ្គីរស ដោយអំណាចធម៌ពួកមួយ ដោយប្រការដូច្នេះឯង ។

**ធម្មពួក ១ ចប់**

## ពោលអំពីធម៌ពួក ២

[ ៩៨ ] កាលសម្តែងសាមគ្គីរស ដោយអំណាចធម៌ពួកមួយ ដូចពោលមកនេះហើយ ឥឡូវនេះ ព្រះថេរៈបានផ្តើមទេសនាតទៅ ដើម្បីសម្តែងដោយអំណាចធម៌ពួកពីរ ។

ក្នុងធម៌ពួកពីរ គឺ **នាមរូប** នោះ **នាម** បានដល់ អរូបខន្ធ ៤ និងនិព្វាន ១ ។ បណ្តាធម៌ទាំងនេះ ខន្ធ ៤ ឈ្មោះថា **នាម** ដោយអត្ថថា បង្អោនទៅ ។ ពាក្យថា ដោយអត្ថថា បង្អោនទៅ មានន័យថា ដោយអត្ថថា ធ្វើឈ្មោះ ។

ដូចសេចក្តីថា ព្រះបាទមហាសម្មត មានព្រះនាមថា **មហាសម្មត** ក៏ព្រោះមហាជនសន្មត ( លើកតម្កើង សំដៅដល់ ជឹងព្រមគ្នាឡើង ) ឬដូចជាឪពុកម្តាយ តាំងឈ្មោះឲ្យជាទីកំណត់ចំណាំ ដល់បុត្រយ៉ាងនេះថា អ្នកនេះឈ្មោះតិស្ស: អ្នកនេះឈ្មោះបុស្ស: ឬដូចឈ្មោះដែលបានមកដោយគុណសម្បត្តិថា ព្រះធម្មកថិក ព្រះវិនយធរ ដូច្នេះ យ៉ាងណា ខន្ធទាំងឡាយ មានវេទនាជាដើម នឹងបានឈ្មោះដូច្នោះ ក៏មិនមែន ។ ពិតហើយ វេទនាជាដើម រមែងមានឈ្មោះរបស់ខ្លួនកើតឡើង ( ឯង ) ដូចមហាប្រឹថពីជាដើម ។ កាលខន្ធទាំងនោះកើតឡើងហើយ ឈ្មោះរបស់ខន្ធទាំងនោះ ក៏ជាការកើតឡើងដូចគ្នា ។ ព្រោះមិនមានអ្នកណាដែលនឹងមកពោល កាលវេទនាដែលកើតឡើងថា អ្នកឯងចូរឈ្មោះថា វេទនា ។ និងធុរៈដែលនឹងត្រូវតាំងឈ្មោះដល់វេទនានោះ ដោយហេតុណាមួយ ក៏មិនមាន ។ ដូចកាលផែនដីកើតឡើង ក៏មិនមានធុរៈដែលនឹងត្រូវតាំងឈ្មោះថា អ្នកឯងចូរឈ្មោះផែនដី, កាលចក្រវាល ភ្នំព្រះសិនេរុ ព្រះចន្ទ ព្រះអាទិត្យ ផ្កាយនក្សត្រកើតឡើង ក៏មិនមានធុរៈ ដែលនឹងត្រូវតាំងឈ្មោះថា អ្នកឯងចូរឈ្មោះចក្រវាល ។ល។ អ្នកឯងចូរឈ្មោះនក្សត្រ ឈ្មោះជាការកើតឡើងតែម្តង ធ្លាក់ចុះជាបញ្ញត្តិ ដែលកើតឡើងបានឯង យ៉ាងណា កាលវេទនាកើតឡើង ក៏មិនមានធុរៈ ដែលនឹងត្រូវតាំងឈ្មោះថា អ្នកឯងចូរឈ្មោះវេទនា វេទនាដែលកើតឡើងហើយ រមែងកើតមានឈ្មោះថា វេទនាឡើងតែម្តង ដូច្នោះ ។ សូម្បីសញ្ញាជាដើម ក៏មានន័យយ៉ាងនេះ ។ វេទនាសូម្បីក្នុងអតីត ក៏ឈ្មោះថា វេទនា សញ្ញា សង្ខារ វិញ្ញាណ ក្នុងអតីត សូម្បីក្នុងអនាគត សូម្បីក្នុងបច្ចុប្បន្ន ក៏មានឈ្មោះថា វេទនា សញ្ញា សង្ខារ វិញ្ញាណ

ដូចគ្នា ។ មួយទៀត **និព្វាន** ទាំងក្នុងអនាគត ទាំងក្នុងបច្ចុប្បន្ន ក៏មានឈ្មោះថា **និព្វាន** គ្រប់កាលនោះឯង ។ ឈ្មោះថា **នាម** ដោយអត្ថថា ធ្វើឈ្មោះដោយប្រការដូច្នេះ ។ មួយទៀត ខន្ធ ៤ ក្នុងបណ្តាធម៌ទាំងនោះ ក៏ឈ្មោះថា **នាម** ដោយអត្ថថា បង្អោនទៅ ។ ព្រោះខន្ធទាំងនោះ រមែងបែរមុខបង្អោនទៅក្នុងអារម្មណ៍ ។ សូម្បីវត្ថុទាំងពួងដែលឈ្មោះថា **នាម** ដោយអត្ថថា បង្អោនទៅ ។ ខន្ធ ៤ រមែងញ៉ាំងគ្នានិងគ្នា ឲ្យបង្អោនទៅក្នុងអារម្មណ៍ ។ **និព្វាន** រមែងញ៉ាំងធម៌ ដែលមិនមានទោសឲ្យបង្អោនទៅក្នុងខ្លួន ព្រោះជាបច្ច័យនៃធម៌ដែលជាធំក្នុងអារម្មណ៍ ។ ពាក្យថា **រូប** សំដៅដល់មហាភូតរូប ៤ និងរូបដែលអាស្រ័យមហាភូតរូប ៤ ។ ទាំងអស់នោះ ឈ្មោះថា **រូប** ព្រោះអត្ថថា ត្រូវបែកធ្លាយទៅ ។ ពាក្យបរិយាយដោយល្អិតល្អន់ចំពោះរូបនោះ គប្បីជ្រាបតាមន័យដែលបានពោលហើយ ក្នុងវិសុទ្ធិមគ្គបករណ៍ ។

ពាក្យថា **អវិជ្ជា** បានដល់ ការមិនដឹងក្នុងសច្ចៈ មានទុក្ខជាដើម ។ រឿងនេះក៏បានពោលដោយល្អិតល្អន់ហើយក្នុងវិសុទ្ធិមគ្គដូចគ្នា ។ ពាក្យថា **ភវតណ្ហា** សំដៅដល់ការប្រាថ្នាភព ។ សមដូចដែលត្រាស់ទុកថា បណ្តាធម៌ទាំងនោះ ភវតណ្ហា គឺអ្វី ការពេញចិត្ត ការប្រព្រឹត្តទៅក្នុងភពទាំងឡាយ ដូច្នេះជាដើម ។

ពាក្យថា **ភវទិដ្ឋិ** ( នេះ ) សេចក្តីទៀង លោកហៅថា **ភវ** គឺទិដ្ឋិដែលកើតឡើងដោយអំណាចការឃើញថា ទៀង សូម្បីទិដ្ឋិនោះ លោកក៏សម្តែងល្អិតល្អន់ហើយក្នុងព្រះអភិធម្ម ដោយន័យថា បណ្តាទិដ្ឋិទាំងនោះ ភវទិដ្ឋិ គឺអ្វី

គឺទិដ្ឋិ បានដល់ ការឃើញថា ខ្លួនមាន លោកមាន ដូច្នេះ ។ ពាក្យថា **វិភវ-ទិដ្ឋិ** ( នេះ ) ការដាច់សូន្យ លោកហៅថា **វិភវ** គឺទិដ្ឋិដែលកើតឡើងដោយអំណាចឃើញថា ដាច់សូន្យ សូម្បីទិដ្ឋិនោះ លោកក៏សម្តែងល្អិតល្អន់ហើយ ក្នុងព្រះអភិធម្មដូចគ្នា ដោយន័យជាដើមថា បណ្តាទិដ្ឋិទាំងនោះ វិភវទិដ្ឋិ គឺអ្វី គឺទិដ្ឋិ បានដល់ ការឃើញយ៉ាងនេះថា ខ្លួនមិនមាន លោកមិនមាន ដូច្នេះ ។

ពាក្យថា **អហិរិកំ** បានដល់ សេចក្តីមិនខ្មាស ដែលលោកសម្តែងល្អិតល្អន់យ៉ាងនេះថា ការមិនខ្មាសចំពោះវត្ថុដែលគួរនឹងខ្មាស ។ ពាក្យថា **អនោត្តប្បំ** បានដល់ អាការដែលមិនភ័យខ្លាច ដែលលោកសម្តែងល្អិតល្អន់យ៉ាងនេះថា ការមិនតក់ស្លុតចំពោះវត្ថុដែលគួរនឹងតក់ស្លុត ។

ពាក្យថា **ហិរិ** ច **ឱត្តប្បញ្ច** បានដល់ ការខ្មាស និងការខ្លាច ដែលលោកសម្តែងល្អិតល្អន់យ៉ាងនេះថា ការមិនខ្មាសក្នុងវត្ថុដែលគួរនឹងខ្មាស ការមិនតក់ស្លុតក្នុងវត្ថុដែលគួរនឹងតក់ស្លុត ។ មួយប្រការទៀត បណ្តាធម៌ ២ យ៉ាងនេះ **ហិរិ** មានសមុដ្ឋានអំពីខាងក្នុង **ឱត្តប្ប** មានសមុដ្ឋានអំពីខាងក្រៅ **ហិរិ** មានខ្លួនជាធំ **ឱត្តប្ប** មានលោកជាធំ **ហិរិ** តាំងឡើងព្រោះសភាវៈ គឺសេចក្តីខ្មាសនៃចិត្ត **ឱត្តប្ប** តាំងឡើងព្រោះសភាវៈ គឺសេចក្តីខ្លាចនៃចិត្ត ។ ពាក្យអធិប្បាយដោយល្អិតល្អន់ ក្នុងរឿងហិរិឱត្តប្បៈនេះ បានពោលសព្វគ្រប់ហើយ ក្នុងវិសុទ្ធិមគ្គ ។

ពាក្យថា **ទោវចស្សតា** មានបទនិយាមដូច្នេះ ការពោលក្នុងបុគ្គលនេះថា អ្នកប្រាថ្នាកាន់យកតែវត្ថុគួរវៀរ ជាប់ចិត្តក្នុងវត្ថុដែលជាសត្រូវ មិនអើពើ

ជឿស្តាប់ ជាការលំបាក ដូច្នោះ ទើបបុគ្គលប្រភេទនេះ ឈ្មោះ **ទុព្វចោ** អ្នកលំបាកប្រដៅ ការធ្វើរបស់បុគ្គលដែលប្រដៅលំបាកនោះ ឈ្មោះថា **ទោវចស្សំ** ភាវៈរបស់ទោវចស្សៈនោះ ឈ្មោះថា **ទោវចស្សតា** ភាវៈនៃការធ្វើរបស់អ្នកលំបាកប្រដៅ ភាពជាអ្នកប្រដៅក្រ ។ ភាពជាអ្នកលំបាកប្រដៅនេះ សម្តែងល្អិតល្អន់ មានមកក្នុងព្រះអភិធម្មថា បណ្តាធម៌ទាំងនោះ **ទោវចស្សតា** គឺអ្វី គឺការប្រដៅក្រ ការទូន្មានលំបាក ក្នុងកាលមិត្តសហធម្មិកកំពុងប្រដៅ ពោលជាស់តឿន ។ **ទោវចស្សតា** នោះ ដោយន័យ ជាសង្ខារក្ខន្ធ ។ តែទីខ្វះ លោកពោលថា ពាក្យនេះ ជាឈ្មោះរបស់ខន្ធទាំង ៤ ដែលប្រព្រឹត្តទៅដោយអាការដូច្នេះ ។

ពាក្យថា **បាបមិត្តតា** មានបទនិយាមដូច្នេះ ។ មនុស្សអាក្រក់ទាំងឡាយមានអ្នកគ្មានសទ្ធាជាដើម ជាមិត្តរបស់អ្នកនោះ ដូច្នោះ ទើបគេឈ្មោះថា **បាប-មិត្តោ** ( អ្នកមានមនុស្សអាក្រក់ជាមិត្ត ) ភាវៈនៃបាបមិត្តនោះ ឈ្មោះថា **បាបមិត្តតា** ( ភាពអ្នកមានមិត្តអាក្រក់ ) ។ ភាពជាអ្នកមានមនុស្សអាក្រក់ជាមិត្តនេះ សេចក្តីល្អិតល្អន់ មានមកក្នុងព្រះអភិធម្មយ៉ាងនេះថា បណ្តាធម៌ទាំងនោះ **បាបមិត្តតា** គឺអ្វី ។ គឺការគប់រក ការសមាគម ជួបជុំ ស្មោះស្ម័គ្រប្រព្រឹត្តតាមបុគ្គលអ្នកគ្មានសទ្ធា ទ្រុស្តសីល គ្មានការសិក្សា កំណាញ់ និងមិនមានបញ្ញា ។ សូម្បី **បាបមិត្តតា** នោះ ដោយសេចក្តី ក៏គប្បីជ្រាបដូចគ្នានឹង **ទោវចស្សតា**។

ភាពជាអ្នកប្រដៅងាយ និងភាពមានមនុស្សល្អជាមិត្ត គប្បីជ្រាបដោយ

ន័យផ្សេងគ្នាដូចដែលពោលមកហើយ ។ គុណធម៌ទាំង ២ ប្រការនេះ ក្នុងទីនេះ លោកពោលលាយគ្នាទាំងលោកិយ និងលោកុត្តរ ។

ពាក្យថា **អាបត្តិកុសលតា** គឺភាពជាអ្នកឈ្លាសក្នុងរឿងអាបត្តិ ដែលលោកពោលយ៉ាងនេះថា ភាពជាអ្នកឈ្លាសក្នុងអាបត្តិ គឺការដឹង ការយល់ក្នុងរឿងអាបត្តិ ៥ កង អាបត្តិ ៧ កង ។ ពាក្យថា **អាបត្តិវុដ្ឋានកុសលតា** គឺការដឹង ការយល់ក្នុងរឿងកំណត់ចេញចាកអាបត្តិ ព្រមទាំងកម្មវាចា ដែលលោកពោលយ៉ាងនេះថា ភាពជាអ្នកឈ្លាស ការដឹង ការយល់ ក្នុងរឿងចេញចាកអាបត្តិទាំងនោះ ។

ពាក្យថា **សមាបត្តិកុសលតា** គឺការដឹង ការយល់ក្នុងរឿងកំណត់អប្បនាព្រមទាំងបរិកម្ម ដែលលោកពោលយ៉ាងនេះថា ភាពជាអ្នកឈ្លាស ការដឹង ការយល់ក្នុងរឿងសមាបត្តិទាំងនោះ ដែលមានទាំងដែលជាសមាបត្តិ ដែលមានវិតក្កវិចារៈ សមាបត្តិដែលមិនមានវិតក្ក មានត្រឹមតែវិចារៈ សមាបត្តិដែលមិនមានវិតក្កវិចារៈ ពាក្យថា **សមាបត្តិវុដ្ឋានកុសលតា** គឺបញ្ញាគ្រឿងកំណត់វេលាដែលនឹងចេញចាកសមាបត្តិថា ពេលថ្ងៃកន្លងទៅត្រឹមនេះ យើងនឹងចេញ ដែលជាបញ្ញា ដែលអាចនឹងចេញចាកសមាបត្តិបាន ត្រូវតាមវេលាដែលកំណត់ ដែលលោកពោលយ៉ាងនេះថា ភាពជាអ្នកឈ្លាស ការដឹង ការយល់ក្នុងរឿងចេញចាកសមាបត្តិទាំងនោះ ។

ពាក្យថា **ធាតុកុសលតា** គឺបញ្ញាក្នុងការស្តាប់ ការទ្រទ្រង់ចាំ ការពិចារណា និងការដឹងច្បាស់ ដែលជាគ្រឿងកំណត់សភាវៈនៃធាតុ ១៨ ដែល

លោកពោលយ៉ាងនេះថា ភាពជាអ្នកឈ្លាសក្នុងធាតុ គឺការដឹងច្បាស់ ការយល់ច្បាស់ក្នុងរឿងធាតុ គឺចក្ខុធាតុ ។បេ។ មនោវិញ្ញាណធាតុ ។ ពាក្យថា **មនសិការកុសលតា** បានដល់ បញ្ញាក្នុងការពិចារណា ការដឹងច្បាស់ ការសម្លឹងពិនិត្យក្នុងធាតុទាំងឡាយនោះឯង ដែលលោកពោលយ៉ាងនេះថា ភាពជាអ្នកឈ្លាស ការដឹងច្បាស់ ការយល់ច្បាស់ក្នុងធាតុទាំងឡាយនោះ ។

ពាក្យថា **អាយតនកុសលតា** គឺបញ្ញាក្នុងការរៀនដឹង ការធ្វើទុកក្នុងចិត្ត ការយល់ក្នុងអាយតនៈ ១២ ដែលលោកពោលយ៉ាងនេះថា ភាពជាអ្នកឈ្លាសក្នុងអាយតនៈ ១២ គឺចក្ខ្វាយតនៈ ។បេ។ ធម្មាយតនៈ ។

មួយប្រការទៀត ភាពជាអ្នកឈ្លាសក្នុងធាតុ ជាអ្នកឈ្លាសក្នុងមនសិការទាំងភាពជាអ្នកឈ្លាសក្នុងអាយតនៈ រមែងគួរក្នុងការរៀនដឹង ការធ្វើទុកក្នុងចិត្ត ការស្តាប់ ការពិចារណា ការដឹងច្បាស់ និងការសម្លឹងពិនិត្យ ។ ចំណែកសេចក្តីផ្សេងគ្នាក្នុងធម៌ទាំងនោះ មានដូច្នេះ ការស្តាប់ ការរៀនដឹង និងការសម្លឹងពិនិត្យ ជាលោកិយ ការដឹងច្បាស់ ជាលោកុត្តរ ការពិចារណា ការធ្វើទុកក្នុងចិត្ត ជាលោកិយ និងលោកុត្តរលាយគ្នា ។ ពាក្យថា **បដិច្ចសមុប្បាទ-កុសលតា** គឺបញ្ញាដែលប្រព្រឹត្តទៅ ដោយអំណាចការរៀនទូវបច្ចយាការ ១២ ដែលលោកពោលយ៉ាងនេះថា ការដឹងច្បាស់ ការយល់ច្បាស់បច្ចយាការ សេចក្តីថា ព្រោះអវិជ្ជាជាបច្ច័យ ទើបមានសង្ខារ ។បេ។ ការកើតឡើងនៃកងទុក្ខទាំងអស់នេះ រមែងមានដោយអាការដូច្នេះ ។

ពាក្យថា **ឋានកុសលតា** គឺបញ្ញា ក្នុងការកំណត់ឋានៈយ៉ាងនេះថា ចក្ខុ

រូប ជាឋានៈ និងជាហេតុនៃចក្ខុវិញ្ញាណដែលកើតឡើង ដោយធ្វើចក្ខុឲ្យជាទីតាំង និងធ្វើរូបឲ្យជាអារម្មណ៍ លោកពោលទុកក្នុងព្រះអភិធម្ម យ៉ាងនេះថា ការដឹងច្បាស់ ការយល់ច្បាស់ ក្នុងធម៌ទាំងឡាយណាៗ ដែលជាហេតុ ជាបច្ច័យ អាស្រ័យធម៌ពួកណាៗ ធម៌នោះៗ ឈ្មោះថា ចាត់ជាឋានៈ ។ ពាក្យថា **អដ្ឋានកុសលតា** គឺបញ្ញាក្នុងការកំណត់អឋានៈយ៉ាងនេះថា សោតវិញ្ញាណជាដើមទាំងនេះ រមែងមិនកើតឡើង ដោយធ្វើចក្ខុឲ្យជាទីតាំង និងការធ្វើរូបឲ្យជាអារម្មណ៍ ព្រោះដូច្នោះ **ចក្ខុ រូប** ទើបមិនមែនជាឋានៈ មិនមែនជាហេតុ នៃសោតវិញ្ញាណទាំងនោះជាដើម លោកពោលក្នុងព្រះអភិធម្មថា ការដឹងច្បាស់ ការយល់ច្បាស់ក្នុងធម៌ទាំងឡាយថា មិនមែនជាហេតុ មិនមែនជាបច្ច័យ អាស្រ័យធម៌ពួកណា ធម៌នោះៗ ចាត់ជាអឋានៈ ។ មួយប្រការទៀត គប្បីជ្រាបន័យ ក្នុងធម៌ពួកពីរនេះ ដោយព្រះសូត្រនេះថា បពិត្រព្រះអង្គដ៏ចម្រើន ដោយហេតុត្រឹមណា ទើបគួរនឹងពោលបានថា ភិក្ខុអ្នកឈ្លាសក្នុងឋានៈ និងអឋានៈ ។ម្នាលអានន្ទ ភិក្ខុក្នុងធម្មវិន័យនេះ ដឹងច្បាស់ថា បុគ្គលអ្នកសម្បូរដោយទិដ្ឋិ គប្បីចូលប្រកាន់នូវសង្ខារណាៗ ថា ដោយភាពជារបស់ទៀង នុ៎ះមិនជាឋានៈ មិនជាឱកាសដែលនឹងមានបាន ចំណែកបុថុជ្ជន នឹងគប្បីចូលទៅប្រកាន់សង្ខារណាៗ ដោយភាពជារបស់ទៀងនោះជាឋានៈដែលនឹងមានបាន ។

ពាក្យថា **អាដ្ឋវំ** បានដល់ សេចក្ដីមិនត្រង់ ៣ ប្រភេទ គឺ **គោមុត្តវង្កតា ចន្ទវង្កតា** និង **នង្គលកោដិវង្កតា** អធិប្បាយថា ភិក្ខុរូបខ្លះ ក្នុងបឋមវ័យប្រព្រឹត្តក្នុងអនេសនា ២១ និងអគោចរ ៦ តែក្នុងមជ្ឈិមវ័យ និងបច្ចិមវ័យ ជា

អ្នកមានសេចក្តីខ្មាស រអៀស ប្រាថ្នាការសិក្សា យ៉ាងនេះឈ្មោះថា **គោមុត្តវង្កតា** ( កោងដូចគោមូត្រ ) ។ ភិក្ខុមួយរូបក្នុងបឋមវ័យ និងបច្ឆិមវ័យ បំពេញចតុប្បារិសុទ្ធិសីល មានសេចក្តីខ្មាស រអៀស ប្រាថ្នាចំពោះការសិក្សា តែក្នុងមជ្ឈិមវ័យដូចនឹងភិក្ខុមុន យ៉ាងនេះឈ្មោះថា **ចន្ទវង្កតា** ( កោងដូចវង់ព្រះចន្ទ ) ។ ភិក្ខុមួយរូប ទាំងក្នុងបឋមវ័យ និងមជ្ឈិមវ័យ បំពេញចតុប្បារិសុទ្ធិសីល មានសេចក្តីខ្មាស រអៀស ប្រាថ្នាចំពោះការសិក្សា តែក្នុងបច្ឆិមវ័យ ដូចនឹងភិក្ខុមុន យ៉ាងនេះឈ្មោះថា **នង្គលកោដិវង្កតា** ( កោងដូចចុងនង្គ័ល ) ។ ភិក្ខុមួយរូប លះសេចក្តីកោងទាំងអស់នោះចេញហើយ មានសីល មានសេចក្តីខ្មាស រអៀស ប្រាថ្នាចំពោះការសិក្សាទាំង ៣ វ័យ ភាពត្រង់របស់ភិក្ខុរូបនោះ យ៉ាងនេះឯង ឈ្មោះថា **អាជ្ជវំ** ។ សូម្បីក្នុងព្រះអភិធម្មក៏ពោលថា បណ្តាធម៌ទាំងនោះ **អាវជ្ជំ** គឺអ្វី គឺភាពត្រង់ ការមិនធ្មេចធ្មៃ ការមិនវៀចវេរ ការមិនកោងកាច ប្រការនេះ ហៅថា ភាពត្រង់ ។ ពាក្យថា **លជ្ជវំ** បានដល់ភាពជាអ្នកមានសេចក្តីខ្មាស ដែលលោកពោលយ៉ាងនេះថា បណ្តាធម៌ទាំងនោះ **លជ្ជវ** គឺអ្វី គឺខ្មាសក្នុងវត្ថុដែលគួរខ្មាស ខ្មាសចំពោះការប្រព្រឹត្តបាបធម៌ អកុសលធម៌ដ៏លាមក ប្រការនេះ ហៅថា **លជ្ជវ** ។

ពាក្យថា **ខន្តិ** បានដល់ អធិវាសនខន្តី ដែលលោកពោលយ៉ាងនេះ បណ្តាធម៌ទាំងនោះ **ខន្តិ** គឺអ្វី គឺសេចក្តីអត់ធន់ ភាពអត់ធ្មត់ ការអត់សង្កត់ ភាពមិនកាច មិនព្រហើន ភាពត្រជាក់នៃចិត្ត ។ ពាក្យថា **សោរច្ចំ** បានដល់ សេចក្តីស្ងប់ស្ងៀម ដែលលោកពោលយ៉ាងនេះថា បណ្តាធម៌ទាំងនោះ **សោរច្ច**

គឺអ្វី គឺការមិនកន្ទងតាមផ្លូវកាយ ការមិនកន្ទងតាមវាចា ការមិនកន្ទងតាមកាយ និងវាចា នេះហៅថា **សោរច្ចំ** សូម្បីសីលសំវរៈទាំងអស់ ក៏ចាត់ថាជា **សោរច្ចំ** ។

ពាក្យថា **សាខល្យំ** បានដល់ ភាពជាអ្នកវីករាយ ទន់ភ្លន់ ដែលលោកពោលយ៉ាងនេះថា បណ្ដាធម៌ទាំងនោះ **សាខល្យ** គឺអ្វី គឺការមានវាចាទន់ភ្លន់ ការមានវាចាពីរោះ ការមានវាចាមិនគ្រោតគ្រាតក្នុងលោក អ្នកលះវាចាដែលគ្រោតគ្រាត រាលដាល ក្ដៅក្រហាយ អុចអាល ដល់អ្នកដទៃ គ្រេវក្រោធ មិនប្រព្រឹត្តទៅដើម្បីសេចក្ដីស្ងប់ ដូច្នោះ លះចេញហើយ និយាយតែពាក្យដែលសុភាព សប្បាយដល់ត្រចៀក ជាទីស្រឡាញ់ពេញចិត្ត ទាន់សម័យ ជាទីពេញចិត្ត ជាទីត្រេកអរនៃជនច្រើន ដូច្នោះ នេះហៅថា **សាខល្យំ** ។

ពាក្យថា **បដិសណ្ឋារោ** បានដល់ ការទទួលដោយអាមិស និងដោយធម៌ ដូចគ្នានឹងថា ក្រាលតាំងដោយកម្រាល ដោយលក្ខណៈ ដែលលោកសន្និវាសនេះ ដែលមានឱកាស ២ ប្រការ គឺឱកាសនៃអាមិស និងឱកាសនៃធម៌នោះ រមែងមិនប្រាកដឱកាសបានឡើយ ។ សូម្បីក្នុងព្រះអភិធម្ម ក៏ពោលថា បណ្ដាធម៌ទាំងនោះ **បដិសណ្ឋារ** គឺអ្វី បដិសណ្ឋារៈ មាន ២ យ៉ាង គឺអាមិសប្បដិសណ្ឋារៈ ការទទួលរាក់ទាក់ដោយអាមិស និងធម្មប្បដិសណ្ឋារៈ ការទទួលរាក់ទាក់ដោយធម៌ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកបដិសណ្ឋារៈដោយអាមិសប្បដិសណ្ឋារៈខ្លះ ដោយធម្មប្បដិសណ្ឋារៈខ្លះ នេះហៅថា **បដិ-សណ្ឋារ** ។ ក្នុងទីនោះ ការសង្គ្រោះដោយអាមិស ឈ្មោះថា **អាមិសប្ប-**

**ដិសណ្ឋារ** ។ កាលនឹងធ្វើអាមិសប្បដិសណ្ឋារៈនោះ ដល់មាតាបិតា ដល់អារាមិក ដល់វេយ្យាវច្ចករ ដល់ព្រះរាជា និងដល់ចោរ មិនគួរនឹងយកចំណែកល្អ ហើយឲ្យរបស់អន់ ( ចំណែកដែលមិនល្អ ) ព្រោះកាលកាន់យករបស់អន់ហើយ ទើបឲ្យ ( ដូច្នោះ ) ព្រះរាជា និងចោរ រមែងនឹងធ្វើសេចក្តីវិនាសឲ្យខ្លះ ឲ្យដល់អស់ជីវិតខ្លះ កាលមិនកាន់យករបស់អន់ហើយ ឲ្យព្រះរាជា និងចោរ រមែងនឹងពេញចិត្ត ។ ក្នុងករណីដូច្នេះ គួរនឹងនាំរឿងចោរនាគជាដើម ( ជាឧទាហរណ៍ ) ។ រឿងទាំងនោះ មានសម្តែងល្អិតល្អន់នៅក្នុង សមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យហើយ ។ ការតាំងចិត្តសង្គ្រោះដោយធម៌យ៉ាងនេះ គឺឲ្យឧទ្ទេស អធិប្បាយព្រះបាលី ពោលធម្មកថា ឈ្មោះថា **ធម្មប្បដិសណ្ឋារ** ។

ពាក្យថា **អវិហឹសា** សំដៅយកទាំងករុណា ទាំងបុព្វភាគនៃករុណា ។ សេចក្តីនេះ លោកពោលថា បណ្តាធម៌ទាំងនោះ **អវិហិង្សា** គឺអ្វី គឺសេចក្តីករុណាក្នុងសង្ខារ អាណិតក្នុងសត្វទាំងឡាយ រួមទាំងករុណាចេតោវិមុត្តិ(ការរួចផុតដោយចិត្ត ដោយអាស្រ័យករុណា ) នេះហៅថា **អវិហិង្សា** ។ ពាក្យថា **សោចេយ្យំ** សំដៅដល់ សេចក្តីស្អាតដោយអំណាចមេត្តា និងបុព្វភាគនៃមេត្តា ។ សេចក្តីនេះ លោកពោលថា បណ្តាធម៌ទាំងនោះ **សោចេយ្យ** គឺអ្វី គឺមេត្រីភាព មេត្តារាប់អានក្នុងសត្វទាំងឡាយ រួមទាំងមេត្តាចេតោវិមុត្តិ ( ការរួចផុតដោយចិត្ត ដោយអាស្រ័យមេត្តា ) នេះហៅថា **សោចេយ្យ** ។

ពាក្យថា **មុដ្ឋស្សច្ចំ** គឺការនៅដោយភ្លេចភ្លាំងសតិ សមដូចដែលពោលថា បណ្តាធម៌ទាំងនោះ **មុដ្ឋស្សច្ច** គឺអ្វី គឺមិនមានសតិរឭកតាមទៅ មិនបាន

បង្អោនរពួកទៅក៏មិនបាន នឹកមិនចេញ ចាំមិនបានកាន់ប្រឡំ វង្វេង ភ្លេច នេះហៅថា **មុដ្ឋស្សច្ចំ** ។ ពាក្យថា **អសម្បជញ្ញំ** បានដល់ អវិជ្ជានុ៎ះឯង ដែលលោកពោលយ៉ាងនេះថា បណ្ដាធម៌ទាំងនោះ **អសម្បជញ្ញ** គឺអ្វី គឺការមិនដឹង មិនឃើញ ។ល។ ជំទាស់ ព្រោះអវិជ្ជា សេចក្ដីវង្វេង អកុសលមូល ។

**សតិ** គឺសតិនុ៎ះឯង ។ **សម្បជញ្ញ** គឺញាណ ( សេចក្ដីដឹង ) ។

ពាក្យថា **ឥន្ទ្រិយេសុ អគុត្តទ្វារតា** សំដៅដល់ ការដាច់សេចក្ដីសង្រួមឥន្ទ្រិយ ដែលលោកសម្ដែងទុកយ៉ាងល្អិតល្អន់ ដោយន័យជាដើមថា បណ្ដាធម៌ទាំងនោះ ការមិនគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ គឺអ្វី គឺ ( អាការដែល ) ភិក្ខុរូបខ្លះ ក្នុងព្រះសាសនានេះ ឃើញរូបដោយចក្ខុហើយ ជាអ្នកកាន់យកនូវនិមិត្ត ។ ពាក្យថា **ភោជនេ អមត្តញ្ញុតា** គឺការមិនស្គាល់ប្រមាណក្នុងភោជន ដែលមកយ៉ាងនេះថា បណ្ដាធម៌ទាំងនោះ ការមិនដឹងប្រមាណក្នុងភោជន គឺអ្វី គឺភិក្ខុរូបខ្លះក្នុងព្រះសាសនានេះ មិនបានពិចារណាជាមុន ហើយបរិភោគអាហារ ដោយមិនប្រពៃ ដើម្បីលេង ដើម្បីស្រវឹង ដើម្បីប្រដាប់ ដើម្បីស្អិតស្អាង ការមិនសន្ដោស ការមិនដឹងប្រមាណក្នុងភោជន ដែលមិនបានពិចារណា ( ហើយបរិភោគ ) ។ ធម៌ពួកពីរក្នុងលំដាប់នោះ គប្បីជ្រាបដោយន័យផ្ទុយគ្នាពីការដែលពោលហើយ ។

ពាក្យថា **បដិសង្ខានពលំ** បានដល់ ញាណដែលមិនញាប់ញ័រ ព្រោះមិនបានពិចារណា ដែលលោកសម្ដែងល្អិតល្អន់យ៉ាងនេះថា បណ្ដាធម៌ទាំងនោះ **បដិសង្ខានពល** គឺអ្វី គឺការដឹង ការយល់ ។ ពាក្យថា **ភាវនាពលំ** បាន

ដល់ កម្លាំងដែលកើតឡើងដល់លោកអ្នកបានអប់រំហើយ ។ ដោយអត្ថ ក៏គឺពោជ្ឈង្គ ៧ ដោយមានវិរិយសម្ពោជ្ឈង្គជាប្រធាន ។ ដូចដែលលោកពោលថា បណ្ដាធម៌ទាំងនោះ **ភាវនាពល** គឺអ្វី គឺការសេពគប់ ការធ្វើឲ្យមាន ការធ្វើឲ្យច្រើននូវកុសលធម៌ទាំងឡាយ នេះហៅថា **ភាវនាពល** សូម្បីពោជ្ឈង្គ ៧ ក៏ចាត់ជាភាវនាពល ។

ពាក្យថា **សតិពលំ** គឺសតិនុ៎ះឯង ដែលមិនញាប់ញ័រ ព្រោះការមិនមានសតិ ។ ពាក្យថា **សមាធិពលំ** គឺសមាធិនុ៎ះឯង ដែលមិនញាប់ញ័រ ព្រោះការរវើរវាយ ។ សមថៈ គឺសមាធិ ។ វិបស្សនា គឺបញ្ញា ។

សមថៈនុ៎ះឯង ឈ្មោះថា សមថនិមិត្ត ដោយអំណាចនិមិត្តនៃសមថៈដែលកាន់យកអាការនោះហើយ គប្បីឲ្យប្រព្រឹត្តទៅទៀត ។ សូម្បីក្នុងបគ្គាហនិមិត្ត ( និមិត្តដែលកើតព្រោះសេចក្ដីព្យាយាម ) ក៏ន័យនេះដូចគ្នា ។

**បគ្គាហ** គឺសេចក្ដីព្យាយាម ។ **អវិក្ខេប** គឺការមានចិត្តតម្កល់មាំ ។ តពីធម៌ពួកពីរ ទាំង ៦ គូ នេះ គឺសតិ និងសម្បជញ្ញៈ ១ បដិសង្ខានពល និងភាវនាពល ១ សតិពល និងសមាធិពល ១ សមថៈ និងវិបស្សនា ១ សមថនិមិត្ត និងបគ្គាហនិមិត្ត ១ បគ្គាហៈ និងអវិក្ខេបៈ ១ ព្រះថេរៈបានពោលធម៌ទាំងលោកិយ និងលោកុត្តរលាយគ្នា គឺសីលសម្បទា និងទិដ្ឋិសម្បទាជាគូ ។

ពាក្យថា **សីលវិបត្តិ** សំដៅដល់ ការមិនសង្រួម ដែលជាការធ្វើសីលឲ្យវិនាស ដែលលោកពោលយ៉ាងនេះថា បណ្ដាធម៌ទាំងនេះ សីលវិបត្តិ គឺអ្វី

គឺការកន្លងល្មើសផ្លូវកាយ ។ល។ ភាពជាអ្នកទ្រុស្តសីលគ្រប់យ៉ាង ឈ្មោះថា សីលវិបត្តិ ។ ពាក្យថា **ទិដ្ឋិវិបត្តិ** សំដៅដល់មិច្ឆាទិដ្ឋិ ដែលជាការធ្វើសម្មា-ទិដ្ឋិឲ្យវិនាស ដែលមកហើយយ៉ាងនេះថា បណ្តាធម៌ទាំងនោះ **ទិដ្ឋិវិបត្តិ** គឺអ្វី គឺការឃើញថា ឲ្យទានមិនមានផល បូជាមិនមានផល ។

ពាក្យថា **សីលសម្បទា** សេចក្តីថា សោរច្ចៈទុំះឯង ដែលពោលខាងដើមយ៉ាងនេះថា បណ្តាធម៌ទាំងនោះ សីលសម្បទា គឺអ្វី គឺការមិនកន្លងល្មើសតាមផ្លូវកាយ ដូច្នេះ ហៅឈ្មោះថា **សីលសម្បទា** ព្រោះញ៉ាំងសីលឲ្យដល់ព្រម ។ តែពាក្យដែលពោលក្នុងទីនេះថា សីលសំវរៈទាំងអស់ ឈ្មោះថា **សីលសម្បទា** នេះ ពោលដើម្បីនឹងរួមយកការមិនកន្លងល្មើសតាមផ្លូវចិត្តចូលមកឲ្យគ្រប់គ្រាន់ ។

ពាក្យថា **ទិដ្ឋិសម្បទា** បានដល់ ញាណដែលជាគ្រឿងធ្វើទិដ្ឋិឲ្យបរិបូណ៌ ដែលមកហើយយ៉ាងនេះថា បណ្តាធម៌ទាំងនោះ **ទិដ្ឋិសម្បទា** តើដូចម្តេច គឺសេចក្តីដឹង សេចក្តីយល់ ដូច្នេះថា ឲ្យទានមានផល បូជាមានផល ។ល។ បណ្ឌិតទាំងឡាយធ្វើសេចក្តីនេះឲ្យច្បាស់ហើយ ទើបប្រកាស ។

ពាក្យថា **សីលវិសុទ្ធិ** គឺសីលដែលអាចនឹងឲ្យដល់សេចក្តីបរិសុទ្ធិបាន ។ ចំណែកក្នុងព្រះអភិធម្ម លោកបែងចែកសីលវិសុទ្ធិយ៉ាងនេះថា បណ្តាធម៌ទាំងនោះ **សីលវិសុទ្ធិ** គឺអ្វី គឺការមិនកន្លងល្មើសតាមផ្លូវកាយ ការមិនកន្លងល្មើសតាមវាចា ការមិនកន្លងល្មើសតាមកាយ និងវាចា នេះហៅថា **សីលវិសុទ្ធិ** ។ ពាក្យថា **ទិដ្ឋិវិសុទ្ធិ** គឺទស្សនៈ ដែលនឹងឲ្យដល់សេចក្តីបរិសុទ្ធិបាន ក្នុងព្រះ

អភិធម្មលោកពោលដល់ទិដ្ឋិវិសុទ្ធិយ៉ាងនេះថា បណ្ដាធម៌ទាំងនោះ ទិដ្ឋិវិសុទ្ធិ គឺអ្វី គឺកម្មស្សកតាញាណ សច្ចានុលោមិកញ្ញាណ មគ្គសមង្គិញាណ ផលសមង្គិញាណ ។ ម្យ៉ាងទៀត ក្នុងបណ្ដាញាណទាំងនេះ សេចក្ដីដឹងយ៉ាងនេះថា ទុច្ចរិត ៣ យ៉ាង ទាំងដែលខ្លួនឯងធ្វើ ទាំងដែលអ្នកដទៃធ្វើ មិនឈ្មោះថា ជាកម្មរបស់ខ្លួន ព្រោះមិនជាប្រយោជន៍ សុចរិត ៣ យ៉ាង ឈ្មោះថា ជាកម្មរបស់ខ្លួន ព្រោះឲ្យកើតប្រយោជន៍ ដូច្នេះ ឈ្មោះថា កម្មស្សកតាញាណ ។ អ្នកតាំងនៅក្នុងញាណ ហើយខ្វល់ខ្វាយ ( ធ្វើ ) កម្មដែលប្រព្រឹត្តទៅក្នុងវដ្ដៈជាចំណែកច្រើន និងសម្រេចព្រះអរហត្តដោយសប្បាយ មានចំនួនដ៏ច្រើនរាប់មិនបាន ។ ចំណែកវិបស្សនាញាណ លោកហៅថា សច្ចានុលោមិកញ្ញាណ ព្រោះអនុលោមតាមវចីសច្ចៈ ។ល។ និងមិនជំទាស់ ជាមួយបរមត្ថសច្ចៈ ។

ក្នុងពាក្យថា **ទិដ្ឋិវិសុទ្ធិ ខោ បន យថា ទិដ្ឋិស្ស ច បធានំ** ( សេចក្ដីបរិសុទ្ធិនៃទិដ្ឋិ និងសេចក្ដីព្យាយាមរបស់អ្នកប្រកបទិដ្ឋិ ) នេះ ញាណទស្សនៈលោកហៅថា **ទិដ្ឋិវិសុទ្ធិ** ។ ពាក្យថា **យថា ទិដ្ឋិស្ស ច បធានំ** បានដល់ សេចក្ដីព្យាយាមដែលប្រកបដោយញាណទស្សនៈនោះ ។ ម្យ៉ាងទៀត បទដំបូងសំដៅដល់ ចតុមគ្គញ្ញាណ បទក្រោយ សំដៅដល់ សេចក្ដីព្យាយាម ដែលប្រកបដោយចតុមគ្គញ្ញាណនោះ ។ ចំណែកក្នុងព្រះអភិធម្ម លោកចែកធម៌ពួកពីរគូនេះ យ៉ាងនេះថា ពាក្យថា **ទិដ្ឋិវិសុទ្ធិ ខោ បន** បានដល់ សេចក្ដីដឹងសេចក្ដីយល់ ។ល។ ការមិនវង្វេង ការបំភ្លឺធម៌ សម្មាទិដ្ឋិ ។ ពាក្យថា **យថា ទិដ្ឋិស្ស ច បធានំ** បានដល់ ការចាប់ផ្ដើមព្យាយាមផ្លូវចិត្ត ។ល។ សម្មាវា-

យាមៈ ។ ក្នុងពាក្យថា **សំវេគោ ច សំវេជនីយេសុ ឋានេសុ** នេះ ដែលឈ្មោះថា **សំវេគ** បានដល់ ញាណទស្សនៈ ដោយឃើញការកើតជាដើម ដោយភាពជាភ័យ យ៉ាងនេះថា ជាតិភ័យ ( ការកើតជាភ័យ ) ជរាភ័យ ( ការចាស់ជាភ័យ ) ព្យាធិភ័យ ( សេចក្ដីឈឺចាប់ជាភ័យ ) មរណភ័យ ( សេចក្ដីស្លាប់ជាភ័យ ) ។ ពាក្យថា **សំវេជនីយំ ឋានំ** សំដៅដល់ ជាតិ ជរា ព្យាធិ និងមរណៈ ។ ទាំង ៤ ប្រការនេះ លោកហៅថា ធម៌ជាទីតាំងនៃសេចក្ដីតក់ស្លុត ព្រោះជាហេតុឲ្យកើតសេចក្ដីសង្វេគ យ៉ាងនេះថា កើតជាទុក្ខ ចាស់ជាទុក្ខ ឈឺជាទុក្ខ ស្លាប់ជាទុក្ខ ។ ពាក្យថា **សំវិគ្គស្ស ច យោនិសោបធានំ** គឺសេចក្ដីព្យាយាមដោយឧបាយប្រពៃ របស់លោកអ្នកដែលកើតសេចក្ដីសង្វេគយ៉ាងនេះ ។ ពាក្យនេះ ជាឈ្មោះរបស់សេចក្ដីព្យាយាម ដែលមកហើយយ៉ាងនេះថា ភិក្ខុក្នុងព្រះសាសនានេះ រមែងញុំាងឆន្ទៈឲ្យកើតឡើង ដើម្បីការមិនកើតឡើងនៃបាបអកុសលធម៌ ដែលនៅមិនទាន់កើតឡើង ។

ពាក្យថា **អសន្តុដ្ឋិតា ច កុសលេសុ ធម្មេសុ** បានដល់ សេចក្ដីប្រាថ្នាដែលនឹងឲ្យក្រៃលែងឡើងៗ ទៅ របស់លោកអ្នកមិនទាន់ពេញចិត្ត ដោយការអប់រំកុសលធម៌ ។ សេចក្ដីពិត បុគ្គលដែលព្រមព្រៀងដោយអសន្តុដ្ឋិតានោះ បំពេញសីលហើយ រមែងញុំាងឈានឲ្យកើតឡើង បានឈានហើយ រមែងផ្ដើមវិបស្សនា ផ្ដើមវិបស្សនាហើយ នៅមិនទាន់សម្រេចព្រះអរហត្ត រមែងមិនធូរថយក្នុងចន្លោះ ។ ពាក្យថា **អប្បដិវានិតា ច បធានស្មិំ** សេចក្ដីថា អាការដែលនៅមិនទាន់បានសម្រេចព្រះអរហត្ត ហើយមិនបន្ធូរបន្ថយក្នុងការព្យាយាមដែលផ្ដើមឡើងដោយអំណាចជាគរិយានុយោគ ដែលធ្វើថ្ងៃ និងយប់មួយឲ្យ

ជា ៦ ចំណែក ដែលលោកពោលយ៉ាងនេះថា ការធ្វើដោយតាំងចិត្ត ការធ្វើជាប់តគ្នា ការធ្វើមិនឈប់ ការប្រព្រឹត្តមិនធូរថយ មិនលះបង់ចោល សេចក្តីពេញចិត្ត ការមិនដាក់ធុរៈ ការសេពគប់ ការធ្វើឲ្យមានឡើង ការធ្វើឲ្យច្រើនក្នុងការចម្រើនកុសលធម៌ទាំងឡាយ ។

ពាក្យថា **វិជ្ជា** បានដល់ វិជ្ជា ៣ ។ ពាក្យថា **វិមុត្តិ** បានដល់ វិមុត្តិ ២ យ៉ាង គឺអធិមុត្តិនៃចិត្ត និងនិព្វាន ។ និងក្នុងទីនេះ សមាបត្តិ ៨ ឈ្មោះថា អធិមុត្តិ ព្រោះរួចផុតហើយដោយល្អ ចាកកិលេសទាំងឡាយ មាននីវរណៈជាដើម ។ **និព្វាន** គប្បីជ្រាបថា ឈ្មោះថា **វិមុត្តិ** ព្រោះរួចផុតហើយចាកសង្ខតធម៌ទាំងពួង ។ ពាក្យថា **ខយេ ញាណំ** បានដល់ ញាណក្នុងអរិយមគ្គដែលធ្វើឲ្យកិលេសអស់ទៅ ។

ពាក្យថា **អនុប្បាទេ ញាណំ** បានដល់ ញាណក្នុងអរិយផល ជាផលដែលមិនញុំាងបដិសន្ធិកើតឡើង ឬដែលកើតឡើងក្នុងទីបំផុតនៃការមិនកើតឡើងនៃកិលេសដែលមគ្គនោះៗ សម្លាប់បានហើយ ។ ដោយហេតុនោះ ទើបលោកពោលថា ពាក្យថា **ខយេ ញាណំ** គឺញាណរបស់អ្នកព្រមព្រៀងដោយមគ្គ ។ ពាក្យថា **អនុប្បាទេញាណំ** គឺញាណរបស់អ្នកព្រមព្រៀងដោយផល ។

ពាក្យថា **ឥមេ ខោ អាវុសោ** ជាដើម គប្បីប្រកបសេចក្តីតាមន័យដែលពោលហើយ ក្នុងពួកមួយនុ៎ះឯង ។ ព្រះថេរៈសម្តែងសាមគ្គីរស ដោយអំណាចធម៌ពួកពីរ រួម ៣៥ គូ ដោយប្រការដូច្នេះឯង ។

**ធម៌ពួក ២ ចប់**

## ពោលអំពីធម៌ពួក ៣

[ ៩៩ ] កាលសម្ដែងសាមគ្គីរសដោយអំណាចធម៌ពួកពីរ ដូច្នេះហើយ ឥឡូវនេះ ព្រះថេរៈផ្ដើមទេសនាតទៅ ដើម្បីនឹងសម្ដែងដោយអំណាចធម៌ពួកបី ។

បណ្ដាធម៌ទាំងនោះ ឈ្មោះថា **លោភ** ដោយអត្ថថា ចង់បាន ។ អកុសល នោះផង ជាមូលផង ឬថា ( លោភៈជា ) មូលនៃអកុសលទាំងឡាយ ដូច្នោះ ទើបឈ្មោះថា អកុសលមូល ។ ឈ្មោះថា **ទោស** ដោយអត្ថថា ប្រទូស្ដ ។ ឈ្មោះថា **មោហ** ដោយអត្ថថា ល្ងង់ ។ ចំណែកអលោភៈជាដើម គប្បីជ្រាប ដោយន័យផ្ទុយគ្នានឹងលោភៈទាំងនោះជាដើម ។

ការប្រព្រឹត្តអាក្រក់ប្រទូស្ដ ឬថា ការប្រព្រឹត្តខុសប្រក្រតី ដូច្នោះ ទើប ឈ្មោះថា ទុច្ចរិត ។ ទុច្ចរិត ដោយកាយ ឬថា ទុច្ចរិតដែលប្រព្រឹត្តទៅផ្លូវកាយ ដូច្នោះ ទើបឈ្មោះថា កាយទុច្ចរិត ។ សូម្បីពាក្យដ៏សេស ក៏មានន័យដូចគ្នា ។ ការប្រព្រឹត្តត្រឹមត្រូវ ឬថា ការប្រព្រឹត្តល្អ ដូច្នោះ ទើបឈ្មោះថា សុចរិត ។ និងធម៌ពួកបី ទាំង ២ ប្រការនេះ គួរនឹងពោលដោយបញ្ញត្តិមួយ ន័យដោយ កម្មបថមួយន័យ ។ និងពោលដោយបញ្ញត្តិមុន ។ ការកន្លងល្មើសសិក្ខាបទ ដែលបញ្ញត្តទុកហើយ ក្នុងកាយទ្វារ ឈ្មោះថា **កាយទុច្ចរិត** ការមិនកន្លង ល្មើស ឈ្មោះថា កាយសុចរិត ។ ការកន្លងល្មើសសិក្ខាបទ ដែលបានបញ្ញត្ត ហើយក្នុងវចីទ្វារ ឈ្មោះថា វចីទុច្ចរិត ការមិនកន្លងល្មើសឈ្មោះថា វចី-សុចរិត ។ ការកន្លងល្មើសសិក្ខាបទ ដែលបញ្ញត្តហើយក្នុងទ្វារទាំង ២ នុ៎ះឯង ឈ្មោះថា មនោទុច្ចរិត ការមិនកន្លងល្មើស ឈ្មោះថា មនោសុចរិត ។ នេះ ពោលដោយបញ្ញត្តិ ។

ចំណែកចេតនា ៣ យ៉ាង មានបាណាតិបាតជាដើម ដែលកើតឡើង ទាំងក្នុងកាយទ្វារ ទាំងក្នុងវចីទ្វារ ឈ្មោះថា កាយទុច្ចរិត ។ ចេតនា ៤ យ៉ាង មានមុសាវាទជាដើម ឈ្មោះថា វចីទុច្ចរិត ។ ធម៌ ៣ យ៉ាង ដែលប្រកប ដោយចេតនា គឺអភិជ្ឈា (សម្លឹងរំពៃចង់បានរបស់គេ) ព្យាបាទ ( ប្រទូស្តគេ) មិច្ឆាទិដ្ឋិ ( ឃើញខុស ) ឈ្មោះថា មនោទុច្ចរិត ។ ចេតនាក្តី វិរតិក្តី ទាំង ៣ យ៉ាង ដែលកើតឡើងដល់អ្នកវៀរចាកបាណាតិបាតជាដើម ឈ្មោះថា កាយ-សុចរិត ចេតនាក្តី វិរតិក្តី ទាំង ៤ យ៉ាង ដែលកើតឡើងដល់អ្នកវៀរចាក មុសាវាទជាដើម ឈ្មោះថា វចីសុចរិត ។ ធម៌ ៣ យ៉ាង ដែលប្រកបដោយ ចេតនា គឺអនភិជ្ឈា ( មិនសម្លឹងរំពៃចង់បានរបស់គេ ) អព្យាបាទ ( មិនប្រទូស្ត គេ ) សម្មាទិដ្ឋិ ( ឃើញត្រូវ ) ឈ្មោះថា មនោសុចរិត នេះពោលដោយ កម្មបថ ។

វិតក្កដែលប្រកបដោយកាម ឈ្មោះថា កាមវិតក្ក ។ វិតក្កដែលប្រកប ដោយព្យាបាទ ឈ្មោះថា ព្យាបាទវិតក្ក ។ វិតក្កដែលប្រកបដោយវិហិង្សា ( ការ បៀតបៀន ) ឈ្មោះថា វិហិង្សាវិតក្ក ។ បណ្តាវិតក្កទាំងនេះ វិតក្ក ២ យ៉ាង រមែងកើតឡើងទាំងក្នុងសត្វ ទាំងក្នុងសង្ខារ ។ សេចក្តីពិត កាលគិតដល់ សត្វក៏ដោយ សង្ខារក៏ដោយ ដែលគួរស្រឡាញ់ពេញចិត្ត កាមវិតក្ក រមែង កើតឡើង ។ តាំងពីវេលាដែលក្រោធ ហើយសម្លឹងមើលសត្វក៏ដោយ សង្ខារ ក៏ដោយ ដែលមិនទីជាស្រឡាញ់ មិនជាទីពេញចិត្ត រហូតដល់ (ការឃើញសត្វ ឬសង្ខារនោះ ) វិនាសទៅ ព្យាបាទវិតក្ក រមែងកើតឡើង ។ វិហិង្សាវិតក្ក រមែងមិនកើតឡើងក្នុងសង្ខារ ។ ព្រោះសង្ខារ ដែលឈ្មោះថា គួរនឹងធ្វើឲ្យ

ដល់សេចក្តីលំបាកបាន មិនមាន ។ តែវិហិង្សាវិតក្ក រមែងកើតឡើងក្នុងសត្វ ក្នុងវេលាដែលគិតថា សត្វពួកនេះ ចូរសម្លាប់ ចូរដាច់សូន្យទៅ ចូរវិនាសទៅ ឬថា ចូរកុំមាន ។ វិតក្កដែលប្រកបដោយនេក្ខម្មៈ ( ការចេញចាកកាម ) ឈ្មោះថា នេក្ខម្មវិតក្ក ។ នេក្ខម្មវិតក្កនោះ ចាត់ជាកាមាវចរ ក្នុងបុព្វភាគនៃអសុភជ្ឈាន ចាត់ជារូបាវចរ ក្នុងអសុភជ្ឈាន ចាត់ជាលោកុត្តរ ក្នុងវេលាដែលធ្វើឈាននោះឲ្យជាបាទ ហើយកើតមគ្គផល ។ វិតក្កដែលប្រកបដោយអព្យាបាទ ឈ្មោះថា អព្យាបាទវិតក្ក ។ អព្យាបាទវិតក្កនោះ ចាត់ជាកាមាវចរ ក្នុងបុព្វភាគនៃមេត្តាឈាន ចាត់ជារូបាវចរ ក្នុងមេត្តាឈាន ចាត់ជាលោកុត្តរ ក្នុងវេលាដែលធ្វើឈានឲ្យជាបាទ ហើយកើតមគ្គផល ។ វិតក្កដែលប្រកបដោយអវិហិង្សា ឈ្មោះថា អវិហិង្សាវិតក្ក ។ អវិហិង្សាវិតក្កនោះ ចាត់ជាកាមាវចរ ក្នុងបុព្វភាគនៃករុណា ចាត់ជារូបាវចរ ក្នុងករុណាឈាន ចាត់ជាលោកុត្តរ ក្នុងវេលាដែលធ្វើឈាននោះឲ្យជាបាទ ហើយកើតមគ្គផល ។ កាលណា អលោភៈជាតួនាំ កាលនោះ ធម៌ ២ យ៉ាងក្រៅពីនេះ ក៏រមែងប្រព្រឹត្តតាម ។

កាលណាករុណាជាតួនាំ កាលនោះ ធម៌ ២ យ៉ាងក្រៅពីនេះ ក៏រមែងប្រព្រឹត្តតាមដោយប្រការដូច្នេះ ។ ចំណែកកាមសង្កប្បជាដើម គប្បីជ្រាបដោយន័យដែលពោលហើយនុ៎ះឯង ។ ព្រោះប្រការនេះ ត្រឹមតែជាទេសនាប៉ុណ្ណោះ ។ តែដោយអត្ថហើយ ទាំងកាមវិតក្កជាដើម និងកាមសង្កប្បជាដើម មិនមានអ្វីដែលធ្វើឲ្យផ្សេងគ្នា ។

សញ្ញាដែលប្រកបដោយកាម ឈ្មោះថា កាមសញ្ញា ។ សញ្ញាដែល

ប្រកបដោយព្យាបាទ ឈ្មោះថា ព្យាបាទសញ្ញា ។ សញ្ញាដែលប្រកបដោយវិហិង្សា ឈ្មោះថា វិហិង្សាសញ្ញា ។ សូម្បីអាការដែលកើតឡើងនៃសញ្ញាទាំងនោះ ក៏គប្បីជ្រាបដូចគ្នានឹងកាមវិតក្កជាដើម ។ ព្រោះសញ្ញាទាំងនេះ ក៏សុទ្ធតែប្រកបដោយកាមវិតក្កជាដើមនោះដូចគ្នា ។ សូម្បីនេក្ខម្មសញ្ញាជាដើម ក៏ប្រកបដោយនេក្ខម្មវិតក្កជាដើមដូចគ្នា ។ ព្រោះដូច្នោះ គប្បីជ្រាបភាពជាកាមាវចរជាដើមនៃសញ្ញាទាំងនោះ ដូចគ្នានឹងនេក្ខម្មវិតក្កជាដើមនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងធម៌ទាំងឡាយ មានកាមធាតុជាដើម ( តទៅ ) ។ សេចក្តីត្រិះរិះ វិតក្ក សេចក្តីត្រិះរិះខុស ដែលប្រកបដោយកាម នេះហៅថា កាមធាតុ អកុសលធម៌ទាំងពួង ឈ្មោះថា កាមធាតុ ដូចពោលមកនេះ គឺកាមធាតុ ។ សេចក្តីត្រិះរិះ វិតក្ក សេចក្តីត្រិះរិះខុស ដែលប្រកបដោយ ព្យាបាទ នេះហៅថា ព្យាបាទធាតុ សេចក្តីអាឃាត ការប៉ះខ្ទប់នៃចិត្ត ការមិនពេញចិត្ត ក្នុងបណ្តាវត្ថុនៃអាឃាតវត្ថុ ១០ យ៉ាង ដូចពោលមកនេះ គឺព្យាបាទធាតុ ។ សេចក្តីត្រិះរិះ វិតក្ក សេចក្តីត្រិះរិះខុស ដែលប្រកបដោយវិហិង្សា នេះហៅថា វិហិង្សាធាតុ បុគ្គលខ្លះក្នុងលោកនេះ រមែងបៀតបៀនសត្វទាំងឡាយ ដោយបាតដៃខ្លះ ដោយដុំដីខ្លះ ដោយកំណាត់ឈើខ្លះ ដោយសស្ត្រាខ្លះ ដោយខ្សែខ្លះ ដោយវត្ថុ ឬកិរិយាណានីមួយខ្លះ ដូចពោលមកនេះ គឺវិហិង្សាធាតុ ។ ក្នុងរឿងកាមធាតុនោះ មានកថា ២ យ៉ាង គឺ **សព្វសង្គាហិកកថា** និង **អសម្ភិន្នកថា** ក្នុងកថា ២ យ៉ាងនោះ កាន់យកកាមធាតុ រមែងជាការកាន់យកធាតុ ២ យ៉ាង ក្រៅនេះផង តែទ្រង់បែកចេញអំពីធាតុនោះ សម្តែងថា នេះ គឺព្យាបាទធាតុ នេះ គឺវិហិង្សាធាតុ ដូចពោលមកនេះ ឈ្មោះថា សព្វសង្គាហិកកថា ព្រះសាស្តា

កាលនឹងត្រាស់កាមធាតុ ក៏ទ្រង់វៀរព្យាបាទធាតុទុកក្នុងទីរបស់ព្យាបាទធាតុ ទ្រង់វៀរវិហិង្សាធាតុទុកក្នុងទីរបស់វិហិង្សាធាតុ ហើយត្រាស់ចំណែកដ៏សេស ថា នេះ គឺកាមធាតុ ដូចដែលពោលមកនេះ ឈ្មោះថា អសម្ភិន្នកថា ។ គប្បីជ្រាបវិនិច្ឆ័យក្នុងធម៌ទាំងឡាយ មាននេក្ខម្មធាតុជាដើម ។ សេចក្តីត្រិះរិះ វិតក្កសេចក្តីត្រិះរិះត្រូវ ដែលប្រកបដោយនេក្ខម្មៈ នេះហៅថា នេក្ខម្មធាតុ កុសលធម៌ទាំងពួង ឈ្មោះថា នេក្ខម្មធាតុ ដូចពោលមកនេះ គឺនេក្ខម្មធាតុ ។ សេចក្តីត្រិះរិះ ។បេ។ ដែលប្រកបដោយអព្យាបាទ នេះហៅថា អព្យាបាទធាតុ ។ មេត្រីភាព ក្នុងសត្វទាំងឡាយ ។បេ។ មេត្តាចេតោវិមុត្តិ ដូចពោលមកនេះ គឺអព្យាបាទធាតុ ។ សេចក្តីត្រិះរិះ ។បេ។ ដែលប្រកបដោយអវិហិង្សា នេះហៅថា អវិហិង្សាធាតុ សេចក្តីករុណាក្នុងសត្វទាំងឡាយ ។បេ។ ករុណាចេតោវិមុត្តិ ដូចពោលមកនេះ គឺអវិហិង្សាធាតុ សូម្បីកថា ២ យ៉ាងក្នុងទីនេះ ក៏គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងកាលមុនទុំះឯង ។ ពាក្យថា **អបរាបិ តិស្សោ-ធាតុយោ** សំដៅដល់ធាតុយ៉ាងដទៃ ៣ ទៀត ដោយអត្ថថា ទទេ ។បណ្តាធាតុពួកនោះ កាមភព ដែលលោកសម្តែងល្អិតល្អន់យ៉ាងនេះថា បណ្តាធាតុទាំងនោះ កាមធាតុ គឺអ្វី គឺកាមភព មានអវីចីនរក ខាងក្រោមឲ្យជាទីបំផុត ដូច្នេះ ឈ្មោះថា កាមធាតុ ។ ចំណែករូបភព និងអរូបភព ដែលលោកសម្តែងល្អិតល្អន់យ៉ាងនេះថា រូបភព មានព្រហ្មលោកជាន់ក្រោមជាទីបំផុត ។ អរូបភព មានទេវៈ ដែលចូលដល់អាកាសានញ្ចាយតនៈជាទីបំផុត ដូច្នេះ ឈ្មោះថា រូបធាតុ និងអរូបធាតុទាំង ២ ។ ក្នុងទីមកនៃធាតុ គប្បីកំណត់ខេត្តដោយភព ។ ក្នុងទីមកនៃភព គប្បីកំណត់ខេត្តដោយធាតុ ។ ក្នុងទីនេះ លោកសម្តែងការ

កំណត់ខេត្តដោយកត ។ គប្បីជ្រាបវិនិច្ឆ័យក្នុងរូបធាតុជាដើម ។ រូបធាតុ និង អរូបធាតុ គឺរូបភព និងអរូបភពទាំងឯង ។ លោកសម្តែងនិព្វានដោយនិរោធ-ធាតុ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងហីនធាតុជាដើម ។ ពាក្យថា **ហីនធាតុ** បានដល់ចិត្តុប្បាទដែលជាអកុសល ១២ ។ ធម៌ដ៏សេស ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា មជ្ឈិមធាតុ ។ លោកុត្តរធម៌ ៩ ឈ្មោះថា បណីតធាតុ ។

ពាក្យថា **កាមតណ្ហា** បានដល់ រាគៈដែលប្រកបដោយបញ្ចកាមគុណ ។ ចំណែករាគៈក្នុងរូបភព និងអរូបភព ចាត់ជាឈាននិកន្តិ ( ការជាប់ចិត្តក្នុងឈាន ) រាគៈដែលប្រកបដោយសស្សតទិដ្ឋិ គឺការប្រាថ្នា ដោយអំណាចភព ឈ្មោះថា ភវតណ្ហា ។ រាគៈដែលប្រកបដោយឧច្ឆេទទិដ្ឋិ ឈ្មោះថា វិភវតណ្ហា ។ ន័យមួយទៀត វៀរលែងតែតណ្ហា ២ យ៉ាង ក្រោយ ( គឺភវតណ្ហា និងវិភវ-តណ្ហា ) តណ្ហាដ៏សេស ឈ្មោះថា **កាមតណ្ហា** ។សមដូចដែលលោកពោលទុកថា បណ្តាតណ្ហាទាំងនោះ ភវតណ្ហា គឺអ្វី គឺរាគៈដែលប្រកបដោយសស្សតទិដ្ឋិ សារាគៈ ( តម្រេក ) ។ល។ សារាគៈនៃចិត្តនេះ ហៅថា ភវតណ្ហា, បណ្តាតណ្ហាទាំងនោះ **វិភវតណ្ហា** គឺអ្វី គឺរាគៈដែលប្រកបដោយឧច្ឆេទទិដ្ឋិ សារាគៈ ។ល។ សារាគៈនៃចិត្ត នេះហៅថា វិភវតណ្ហា ។ តណ្ហាដ៏សេស ឈ្មោះថា កាមតណ្ហា គប្បីជ្រាបវិនិច្ឆ័យក្នុងកាមតណ្ហាជាដើម មួយពួកទៀត ។ រាគៈដែលប្រកបដោយបញ្ចកាមគុណ ឈ្មោះថា កាមតណ្ហា ។ ឆន្ទរាគៈក្នុងរូបភព និងអរូបភព ឈ្មោះថា រូបតណ្ហា និងអរូបតណ្ហា ២ យ៉ាងក្រៅនេះ ។ ចំណែកក្នុងព្រះអភិធម្ម លោកសម្តែងល្អិតល្អន់រឿងតណ្ហាទាំងនេះយ៉ាងនេះថា ឆន្ទរាគៈដែលប្រកបដោយកាមធាតុ ។ល។ ដែលប្រកបដោយអរូបធាតុ ។ ដោយភារៈ

នេះ លោកសម្តែងយ៉ាងណា ។ លោករួមយកតណ្ហាទាំងអស់ ដោយកាមតណ្ហាថា ធម៌ទាំងពួងដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា ជាទីតាំងនៃតណ្ហា ដោយអត្ថថា គួរត្រេកអរ ហើយសម្តែងតណ្ហា ២ យ៉ាងក្រៅអំពីនេះ ចែកចេញអំពីកាមតណ្ហានោះ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងរូបតណ្ហាជាដើម ។ ឆន្ទរាគៈក្នុងរូបភព ឈ្មោះថា រូបតណ្ហា ។ ឆន្ទរាគៈក្នុងអរូបភព ឈ្មោះថា អរូបតណ្ហា ។ រាគៈដែលប្រកបដោយឧច្ឆេទទិដ្ឋិ ឈ្មោះថា និរោធតណ្ហា ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **សញ្ញោជន** ៣ យ៉ាង ។ ឈ្មោះថា សញ្ញោជនៈ ព្រោះអត្ថថា ចងរឹតទុកក្នុងវដ្តៈ ។ ការឃើញក្នុងកាយ ដូចរូបជាដើមថា មាន ឬថា ការឃើញក្នុងកាយ ដែលមានហើយ ដូច្នោះ ទើបឈ្មោះថា សក្កាយទិដ្ឋិ ។

កាលពិចារណាជ្រើសរើស រមែងសង្ស័យ គឺមិនអាចនឹងសម្រេចចិត្តបាន ព្រោះធម្មជាតនេះ ដូច្នោះ ទើបធម្មជាតនោះ ឈ្មោះថា វិចិកិច្ឆា ។ បុគ្គលរមែងស្ទាបអង្អែល ( ប្រកាន់ ) សីលផង វត្តផង ដូច្នោះ ទើបឈ្មោះថា សីលព្វតបរាមាស ។ បើពោលដោយន័យហើយ ទិដ្ឋិដែលមានវត្ថុ ២០ ដែលមកហើយដោយន័យជាដើមថា រមែងពិចារណាឃើញរូបថាជាតួខ្លួន ឈ្មោះថា សក្កាយទិដ្ឋិ ។ សេចក្តីសង្ស័យដែលមានវត្ថុ ៨ ដែលមកហើយដោយន័យជាដើមថា រមែងសង្ស័យក្នុងព្រះសាស្តា ឈ្មោះថា វិចិកិច្ឆា ។ ការប្រកាន់យ៉ាងខុសប្រក្រតី ដែលមកហើយដោយន័យជាដើមថា បុគ្គលខ្លះ ក្នុងលោកនេះ ស្ទាបអង្អែល ( ប្រកាន់ ) សីល ស្ទាបអង្អែលវត្ត ស្ទាបអង្អែលសីលវត្តថា បរិសុទ្ធបានដោយសីល បរិសុទ្ធបានដោយវត្ត បរិសុទ្ធបានដោយសីលវត្ត ទិដ្ឋិ ការឃើញខុស មានលក្ខណៈយ៉ាងនេះ ដូច្នេះ ឈ្មោះថា សីលព្វតបរាមាស ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យថា **តយោ អាសវា** នេះតទៅ ។ ឈ្មោះថា **អាសវៈ** ដោយអត្ថថា ជាឋានៈដែលអាស្រ័យនៅអស់កាលជាយូរអង្វែង ហើយខ្លះ ដោយអត្ថថា ហូរទូទៅខ្លះ ។

ក្នុង ២ ន័យនោះ គប្បីជ្រាបអាសវៈ ដោយន័យដែលថា ជាឋានៈដែលអាស្រ័យនៅអស់កាលជាយូរអង្វែងហើយមុន យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ខាងដើមនៃអវិជ្ជា រមែងមិនប្រាកដថា មុនអំពីនេះ អវិជ្ជាមិនមាន តមកខាងក្រោយទើបមាន ម្នាលភិក្ខុទាំងឡាយ ខាងដើមនៃភវតណ្ហា ភវទិដ្ឋិ រមែងមិនប្រាកដថា មុនអំពីនេះ ភវទិដ្ឋិមិនមាន តមកខាងក្រោយទើបមាន ដូច្នេះ ។ គប្បីជ្រាបអាសវៈ ដោយសេចក្តីថា ហូរទូទៅយ៉ាងនេះថា អាសវៈរមែងហូរទៅ ហូរទៅគ្រប់ ហូរទូទៅ ប្រព្រឹត្តទៅក្នុងរូប តាមផ្លូវភ្នែក ក្នុងសំឡេងតាមផ្លូវត្រចៀក ក្នុងក្លិន តាមផ្លូវច្រមុះ ក្នុងរស តាមផ្លូវអណ្តាត ក្នុងផោដ្ឋព្វៈតាមផ្លូវកាយ ។ រមែងហូរទៅ ហូរទៅគ្រប់ ហូរទូទៅ ប្រព្រឹត្តទៅក្នុងធម្មារម្មណ៍តាមផ្លូវចិត្ត ដូច្នេះ ។ តែក្នុងព្រះបាលីកន្លែងខ្លះ អាសវៈមានមក ២ យ៉ាង គឺ **ទិដ្ឋធម្មិកាសវៈ** ( អាសវៈក្នុងភពនេះ ) និង **សម្បរាយិកាសវៈ** ( អាសវៈក្នុងភពមុខ ) ។ កន្លែងខ្លះមានមក ៣ យ៉ាង ដូចសេចក្តីថា ម្នាលភិក្ខុទាំង-ឡាយ អាសវៈទាំង ៣ នេះ គឺកាមាសវៈ ភវាសវៈ អវិជ្ជាសវៈ ។ ក្នុងព្រះអភិធម្ម អាសវៈទាំង ៣ នោះឯង រួមជាមួយទិដ្ឋាសវៈ ជា ៤ ។ ក្នុងនិព្វេធិកបរិយាយសូត្រ មាន ៥ យ៉ាងនេះ គឺ ភិក្ខុទាំងឡាយ អាសវៈដែលញ៉ាំងឲ្យដល់នរកមានហើយ អាសវៈដែលញ៉ាំងឲ្យដល់កំណើតតិរច្ឆានមានហើយ អាសវៈដែលញ៉ាំងឲ្យដល់ប្រេតវិស័យមានហើយ អាសវៈដែលញ៉ាំង

ឲ្យដល់មនុស្សលោកមានហើយ អាសវៈដែលញ៉ាំងឲ្យដល់ទេវលោកមានហើយ ។ ក្នុងអាហុនេយ្យសូត្រ ឆក្កនិបាត មាន ៦ យ៉ាង គឺ ភិក្ខុទាំងឡាយ អាសវៈដែលគប្បីលះដោយសេចក្ដីសង្រួម ប្រុងប្រយ័ត្នមានហើយ អាសវៈដែលគប្បីលះដោយការសេពគប់រកមានហើយ អាសវៈដែលគប្បីលះដោយការវៀរមានហើយ អាសវៈដែលគប្បីលះដោយសេចក្ដីអត់ទ្រាំមានហើយ អាសវៈដែលគប្បីលះដោយការបន្ទោបង់មានហើយ អាសវៈដែលគប្បីលះដោយការអប់រំមានហើយ ។ ក្នុងសព្វាសវបរិយាយសូត្រ អាសវៈទាំង ៦ នេះឯង រួមជាមួយអាសវៈដែលគប្បីលះដោយទស្សនៈ ត្រូវជា ៧ ។ ចំណែកក្នុងសង្គីតិសូត្រនេះ អាសវៈមានមក ៣ យ៉ាង ។ បណ្ដាអាសវៈ ៣ យ៉ាងនោះ រាគៈដែលប្រកបដោយបញ្ចកាមគុណ ដែលលោកពោលយ៉ាងនេះថា កាមច្ឆន្ទៈក្នុងកាមទាំងឡាយ ដូច្នេះ ឈ្មោះថា **កាមាសវ** ។ រាគៈដែលប្រកបដោយសស្សតទិដ្ឋិ ដែលលោកពោលយ៉ាងនេះថា ភវឆន្ទៈក្នុងភពទាំងឡាយ ដូច្នេះ ឬសេចក្ដីប្រាថ្នាជាប់ដោយភព ឈ្មោះថា **ភវាសវ** ។ អវិជ្ជាដែលមកហើយដោយន័យជាដើមថា ការមិនដឹងទុក្ខ ឈ្មោះថា **អវិជ្ជាសវ** ដូច្នេះឯង ។ កាមភពជាដើម បានពោលមកហើយ ដោយជាប់ទាក់ទងនឹងកាមធាតុជាដើមនុ៎ះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **កាមេសនា** ជាដើម ។ រាគៈដែលស្វែងរកកាមដែលលោកពោលយ៉ាងនេះថា បណ្ដាធម៌ទាំងនោះ **កាមេសនា** គឺអ្វី គឺកាមច្ឆន្ទៈក្នុងកាមទាំងឡាយ ។ល។ ការលិចចុះក្នុងកាម នេះហៅថា **កាមេសនា** ( ស្វែងរកកាម ) ។ រាគៈដែលស្វែងរកភព ដែលលោកពោលយ៉ាងនេះថា បណ្ដាធម៌

ទាំងនោះ **ភវេសនា** គឺអ្វី គឺភវឆន្ទៈក្នុងភពទាំងឡាយ ។លៗ ការលិចចុះក្នុងភព នេះហៅថា **ភវេសនា** ( ស្វែងរកភព ) ។ ទិដ្ឋិដែលស្វែងរកព្រហ្មចរិយៈដែលបានដឹងថា ជាគតិនៃទិដ្ឋិ ដែលលោកពោលយ៉ាងនេះថា បណ្តាធម៌ទាំងនោះ **ព្រហ្មចរិយេសនា** គឺអ្វី គឺទិដ្ឋិ ការឃើញខាងទិដ្ឋិ ការប្រកាន់ខុសជាប្រក្រតី ដល់សភាពយ៉ាងនេះថា លោកទៀងខ្លះ ។លៗ សត្វស្លាប់ហើយមិនកើតទៀតខ្លះ សត្វស្លាប់ហើយមិនកើតទៀតក៏មិនមែនខ្លះ នេះហៅថា **ព្រហ្មចរិយេសនា** ( ស្វែងរកព្រហ្មចរិយ ) ដូច្នេះ ឈ្មោះថា **ព្រហ្មចរិយេសនា** ។ មិនមែនមានតែភវរាគទិដ្ឋិតែម្យ៉ាងប៉ុណ្ណោះ សូម្បីកម្មដែលមានន័យតែម្យ៉ាងនោះ ក៏ចាត់ជាឯសនាដូចគ្នា ។ សមដូចដែលលោកពោលថា បណ្តាឯសនាទាំងនោះ **កាមេសនា** គឺអ្វី គឺកាមរាគៈ កាយកម្ម វចីកម្ម មនោកម្មដែលជាអកុសល ដែលមានន័យតែម្យ៉ាងដូចគ្នានោះ នេះហៅថា **កាមេសនា** ។

បណ្តាឯសនាទាំងនោះ **ភវេសនា** គឺអ្វី គឺភវរាគៈ កាយកម្ម វចីកម្ម មនោកម្ម ដែលជាអកុសល ដែលមានន័យតែម្យ៉ាងដូចគ្នានោះ នេះហៅថា **ភវេសនា** បណ្តាឯសនាទាំងនោះ **ព្រហ្មចរិយេសនា** គឺអ្វី គឺទិដ្ឋិដែលប្រកាន់រហូតដល់ទីបំផុត កាយកម្ម វចីកម្ម មនោកម្ម ដែលជាអកុសល ដែលមានសេចក្តីតែម្យ៉ាងដូចគ្នានោះ នេះហៅថា **ព្រហ្មចរិយេសនា** ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **វិធា** ការតាំងនូវអាការ ដូចក្នុងប្រយោគថា បណ្ឌិតពោលដល់មនុស្សមានសីលដូចម្តេច ពោលដល់មនុស្សមានបញ្ញាដូចម្តេច ដូច្នេះ ឈ្មោះថា **វិធា** ។ ការចែក ក៏ឈ្មោះថា **វិធា** ដូចក្នុងប្រយោគថា

*ញាណវត្ថុ ១ ចំណែក ញាណវត្ថុ ២ ចំណែក ។* **មានះ** *ឈ្មោះថា* **វិធា** *ដូចក្នុងប្រយោគថា* **វិធា** *( មានះ ) ថាយើងប្រសើរជាងគេ ក្នុងទីនេះ បំណង យក* **វិធា** *ដែលប្រែថា មានះនោះ ។ សេចក្តីពិត មានះ លោកហៅថា* **វិធា** *ព្រោះចាត់ចែងដោយអំណាចដែលប្រកាន់ថា ប្រសើរជាងគេជាដើម ។ ដោយ ពាក្យថា* **សេយ្យោ ហមស្មិ** *នេះ លោកពោលដល់មានះ ៣ យ៉ាង គឺប្រសើរ ជាងគេ ស្មើគេ អាក្រក់ជាងគេ ។ សូម្បីក្នុង* **សធិសវិធា** *និង* **ហីនវិធា** *ក៏ មានន័យតែមួយដូចគ្នានេះ ។ ពិតហើយ មានះនេះ មាន ៩ យ៉ាង ។ គឺអ្នក ប្រសើរជាងគេ មានមានះ ៣ យ៉ាង អ្នកស្មើគេ មានមានះ ៣ យ៉ាង អ្នក អាក្រក់ជាងគេ មានមានះ ៣ យ៉ាង ។ បណ្តាមានះ ៩ យ៉ាងនោះ សម្រាប់ អ្នកប្រសើរជាងគេ មានះថា យើងប្រសើរជាងគេ រមែងកើតឡើងដល់ព្រះ រាជា និងបព្វជិត ។ ព្រះរាជា រមែងមានមានះដូច្នេះថា អ្នកណាហ្ន៎ នឹងមាន ដូចយើងបាន មិនថា ផ្លូវរាជាណាខេត្ត ផ្លូវរាជទ្រព្យ ឬថា ផ្លូវព្រៃ ពល-ពាហនៈ ។ ចំណែកបព្វជិត ក៏រមែងមានមានះដូច្នេះថា អ្នកណាហ្ន៎ មកផ្ទឹម នឹងយើងបាន ដោយសីលគុណ និងធុតង្គគុណជាដើម ។*

*សូម្បីមានះថា យើងស្មើគេ សម្រាប់អ្នកប្រសើរជាងគេ ក៏រមែងកើត ឡើង បានដល់ ព្រះរាជា និងបព្វជិតនោះដូចគ្នា ។ ព្រះរាជា រមែងមានមានះ ដូច្នេះថា អ្វីមែនទេ ដែលនឹងមានផ្សេងគ្នារវាងយើង និងរាជាដទៃៗ មិនថា នឹងផ្លូវរាជាណាខេត្ត ផ្លូវរាជទ្រព្យ ឬថា ផ្លូវព្រៃ ពលពាហនៈ ។ ចំណែក បព្វជិត ក៏រមែងមានមានះដូច្នេះថា អ្វីហ្ន៎ដែលនឹងមានខុសប្លែកគ្នា រវាងយើង*

និងកិច្ចដទៃ មិនថា ដោយសីលគុណ ឬធុតង្គគុណជាដើម ។ សូម្បីមានះថា យើងអាក្រក់ជាងគេ សម្រាប់អ្នកប្រសើរជាងគេ ក៏រមែងកើតឡើង បានដល់ព្រះរាជា និងបព្វជិតនោះដូចគ្នា ។ ព្រះរាជាអង្គណា មានរាជាណាខេត្ត រាជទ្រព្យ ឬព្រៃ ពលពាហនៈជាដើម មិនសម្បូរច្រើន ព្រះរាជាអង្គនោះ រមែងមានមានះដូច្នេះថា គេត្រឹមតែហៅយើងថា ព្រះរាជាយ៉ាងនោះឯង បុគ្គលដូចយើងឈ្មោះថា រាជា ។ ចំណែកបព្វជិត ដែលមានលាភសក្ការៈតិច ក៏រមែងមានមានះដូច្នេះថា គេក៏ត្រឹមតែហៅយើងថា ព្រះធម្មកថិក ពហូសូត ព្រះមហាថេរៈយ៉ាងនោះឯង ឯយើងមិនមានលាភសក្ការៈ នឹងជាព្រះធម្មកថិក ជាពហូសូតជាមហាថេរៈបានដូចម្តេច ។

សម្រាប់អ្នកស្មើគេ មានះថា យើងប្រសើរជាងគេជាដើម រមែងកើតឡើងដល់អមាត្យជាដើម ។ អមាត្យ ឬអ្នករាជការ រមែងមានមានះដូច្នេះថា អ្នករាជការដទៃៗ អ្នកណាហ្ន៎នឹងមានដូចយើងបាន មិនថា ជាភោគទ្រព្យ ឬយានពាហនៈជាដើម ដូច្នេះខ្លះ ថាអ្វីមែនទេដែលនឹងមកផ្សេងគ្នារវាងយើងនឹងអ្នកដទៃ ដូច្នេះខ្លះ ថាគេត្រឹមតែហៅយើង ថាអមាត្យយ៉ាងនោះឯង សូម្បីត្រឹមតែរបស់ស៊ី និងសំពត់អាវ យើងក៏មិនមាន ដូចជាយើងនេះឬ ដែលឈ្មោះថា អមាត្យ ដូច្នេះខ្លះ ។

ចំពោះអ្នកអាក្រក់ជាងគេ មានះថា យើងប្រសើរជាងគេជាដើម រមែងកើតឡើងដល់អ្នកបម្រើជាដើម ។ អ្នកបម្រើ រមែងមានមានះដូច្នេះថា ឈ្មោះថា អ្នកបម្រើដទៃៗ អ្នកណាហ្ន៎ នឹងដូចយើងបាន មិនថា ចំណែកខាងម្ចាស់ស្រី ឬចំណែកខាងម្ចាស់ប្រុសក៏ដោយ ពួកដទៃៗ ណា នឹងអាចចិញ្ចឹមជីវិតបាន

ទើបត្រូវមកបម្រើគេ តែយើងនេះប្រសើរជាង ព្រោះជាអ្នកបម្រើបន្តគ្នាមក តាមខ្សែស្រឡាយ ដូច្នេះខ្លះ ថា អ្វី មែនទេ ដែលនឹងមកផ្សេងគ្នារវាងយើង នឹងអ្នកបម្រើឯណោះ មិនថា នឹងដោយភាពជាអ្នកបម្រើតៗ គ្នាមកតាមខ្សែស្រឡាយ ឬពោលដោយភាពជាអ្នកបម្រើមកយូរហើយ ចំណែកម្ចាស់ស្រី និងចំណែកម្ចាស់ប្រុស ដូច្នេះខ្លះ ថា យើងនេះត្រូវជាអ្នកបម្រើគេ ក៏ព្រោះត្រូវចិញ្ចឹមមាត់ ចិញ្ចឹមផ្ទៃ ប៉ុន្តែថា បម្រើឲ្យដល់ទីបំផុតម្ចាស់ប្រុស ម្ចាស់ស្រីហើយ យើងមិនបានឋានៈ ជាអ្នកបម្រើឡើយ ដូចជាយើងនឹងឈ្មោះថា ជាអ្នកបម្រើ ដូច្នេះខ្លះ ។

សូម្បីពួកអ្នកស្នូម និងអ្នកចណ្ឌាលជាដើម ក៏រមែងមានមានះ ដូច្នេះ ដូចនឹងអ្នកបម្រើដូចគ្នា ។

បណ្តាមានះទាំងនេះ អ្នកប្រសើរជាង មានះថា យើងប្រសើរជាងគេ អ្នកស្មើគេ មានះថា យើងស្មើគេ និងអ្នកថោកទាបជាងគេ មានះថា យើងថោកទាបជាងគេ ទាំង ៣ ប្រភេទនេះ បានឈ្មោះថា ជាមានះ នឹងកម្ចាត់បានដោយអរហត្តមគ្គ ។ ធម៌ដ៏សេស បានឈ្មោះថា ជាមានះ មិនប្រព្រឹត្តទៅតាមសេចក្តីពិត កម្ចាត់បានដោយមគ្គជាន់ដើម ។

ពាក្យថា **តយោ អទ្ធា** សំដៅដល់កាល ៣ ។ ក្នុងពាក្យជាដើមថា **អតីតោ អទ្ធា** មានបរិយាយ ២ យ៉ាង គឺបរិយាយនៃព្រះសូត្រ និងបរិយាយនៃព្រះអភិធម្ម ។

ដោយបរិយាយនៃព្រះសូត្រ វេលាមុនបដិសន្ធិ ឈ្មោះថា **អតីតទ្ធា** ( កាលអតីត ) ខាងក្រោយអំពីចុតិ ឈ្មោះថា **អនាគតទ្ធា** ( កាលអនាគត )

ក្នុងចន្លោះនោះ គឺទាំងចុតិ និងបដិសន្ធិ ឈ្មោះថា **បច្ចុប្បន្នទ្ធា** (កាលបច្ចុប្បន្ន)។ ដោយបរិយាយនៃព្រះអភិធម្ម មុនអំពីកន្តក្ខណៈ ក្នុងបណ្តាខណៈទាំង ៣ ឈ្មោះថា **អតីតទ្ធា** ខាងមុខឧប្បាទក្ខណៈ ឈ្មោះថា **អនាគតទ្ធា** ក្នុងខណៈទាំង ៣ ឈ្មោះថា **បច្ចុប្បន្នទ្ធា** ។ ដែលថា **អទ្ធា** ផ្សេងដោយអតីតទ្ធាជាដើមនេះ រមែងមានដល់ធម៌ទាំងឡាយ មិនមែនមានដល់កាលវេលា ។ តែអាស្រ័យធម៌ដែលផ្សេងដោយអតីតទ្ធាជាដើម កាលវេលាសូម្បីនឹងមិនមានដោយបរមត្ថ ក្នុងទីនេះលោកក៏ហៅថា ( អតីតទ្ធាជាដើម ) ដោយវោហារនោះឯង ។ គប្បីជ្រាបតាមដែលពោលមកនេះ ។

ពាក្យថា **តយោ អន្តា** សំដៅដល់ចំណែកទាំង ៣ ទីបំផុតនុ៎ះឯង ឈ្មោះថា **អន្ត** ដូចក្នុងប្រយោគថា ជាយវត្ថពន្ធចង្កេះ រមែងចាស់ទៅ ។

ចំណែកដទៃ ឈ្មោះថា **អន្ត** ដូចក្នុងប្រយោគថា នុ៎ះឯង ជាចំណែកដទៃនៃទុក្ខ ។ សេចក្តីអាក្រក់ថោកទាប ឈ្មោះថា **អន្ត** ដូចក្នុងព្រះបាលីនេះថា ម្នាលភិក្ខុទាំងឡាយ នេះជាសេចក្តីអាក្រក់នៃការចិញ្ចឹមជីវិត ។ ជាការថោកទាបបំផុត ។ ចំណែក ឈ្មោះថា **អន្ត** ដូចក្នុងប្រយោគថា បពិត្រលោកដ៏មានអាយុទាំងឡាយ សក្កាយជាចំណែកទី ១ ក្នុងទីនេះសំដៅយក **អន្ត** ដែលប្រែថា ចំណែក ។ ពាក្យថា **សក្កាយោ** សំដៅដល់ ឧបាទានក្ខន្ធទាំង ៥ ។

ពាក្យថា **សក្កាយសមុទយោ** សំដៅដល់តណ្ហាខាងដើម ដែលជាតួធ្វើឲ្យកើតឧបាទានក្ខន្ធទាំងនោះ ។ ពាក្យថា **សក្កាយនិរោធោ** សំដៅដល់សេចក្តីរលត់ដែលធ្វើឲ្យឧបាទានក្ខន្ធ និងតណ្ហាទាំងពីរនោះ ប្រព្រឹត្តទៅមិនបាន ។ ឯមគ្គ

គប្បីជ្រាបថា កាលពោលដល់និរោធហើយ ក៏ជាការពោលដល់តែម្យ៉ាង ព្រោះជាឧបាយនៃការសម្រេចនិរោធ ។

ពាក្យថា **ទុក្ខទុក្ខតា** សំដៅយកទុក្ខ ព្រោះជាទុក្ខ ។ ពាក្យនេះ ជាឈ្មោះរបស់ទុក្ខវេទនា ។ ពាក្យថា **សង្ខារទុក្ខតា** សំដៅយកទុក្ខ ព្រោះជាសង្ខារ ។ ពាក្យនេះ ជាឈ្មោះរបស់អទុក្ខមសុខវេទនា ។ ភាពជាទុក្ខ ព្រោះសង្ខារនោះមានការកើតឡើង និងវិនាសទៅ ត្រូវសេចក្តីរលត់បៀតបៀន ព្រោះមានសភាពដែលត្រូវគាក់តែង ព្រោះដូច្នោះ ទើបលោកពោលភាពជាទុក្ខ ព្រោះសង្ខារទុក្ខ ដោយវៀរចាកសភាវៈនៃទុក្ខដទៃ ។ ពាក្យថា **វិបរិណាមទុក្ខតា** សំដៅយកទុក្ខ ព្រោះប្រែប្រួលទៅ ។ ពាក្យនេះ ជាឈ្មោះរបស់សុខវេទនា ។ ពិតហើយ ព្រោះសុខប្រែប្រួលទៅ ទើបទុក្ខកើតឡើង ព្រោះដូច្នោះ ទើបលោកហៅសុខថា ទុក្ខ ព្រោះប្រែប្រួល ។

ម្យ៉ាងទៀត ធម៌ទាំងពួងដែលប្រព្រឹត្តទៅក្នុងភូមិ ៣ វៀរទុក្ខវេទនា និងសុខវេទនា គប្បីជ្រាបថា ទុក្ខព្រោះសង្ខារ ដោយព្រះបាលីថា សង្ខារទាំងពួងជាទុក្ខ ។ ពាក្យថា **មិច្ឆត្តនិយតោ** គឺមានសភាពខុសដែលទៀង ។ ពាក្យនេះ ជាឈ្មោះរបស់អនន្តរិយកម្ម ព្រមទាំងនិយតមិច្ឆាទិដ្ឋិ ។ ឈ្មោះថា **សម្មត្តនិយតោ** ព្រោះទៀងសភាពដែលត្រូវ ។ ពាក្យនេះ ជាឈ្មោះរបស់អរិយមគ្គ ៤ ។ ឈ្មោះថា **អនិយតោ** ព្រោះមិនទៀង ។ ពាក្យនេះ ជាឈ្មោះរបស់ធម៌ដ៏សេស ។ អវិជ្ជា ឈ្មោះថា **តម** ( សេចក្តីងងឹត ) ក្នុងពាក្យថា **តយោ តមា** ព្រោះព្រះបាលីថា អន្លង់ទឹក គឺអវិជ្ជា ធ្វើឲ្យងងឹត ល្ងក់វង្វេង មានភ័យច្រើន ។

តែក្នុងទីនេះ លោកពោលដល់វិចិកិច្ឆា ដោយជាប្រធានថា អវិជ្ជា ។ ពាក្យថា **អារព្ភ** ស្មើនឹង **អាគម្ម** ( ប្រែថា មកដល់ ឬអាស្រ័យ ) ។ ពាក្យថា **កង្ខតិ** សេចក្តីថា ឲ្យកើតសេចក្តីសង្ស័យ ។ ពាក្យថា **វិចិកិច្ឆតិ** សេចក្តីថា កាលជ្រើសរើស រមែងដល់អាការងឿងឆ្ងល់ មិនអាចនឹងសម្រេចចិត្តបាន ។ ពាក្យថា **នាធិមុច្ចតិ** សេចក្តីថា មិនអាចនឹងបង្អោនជឿក្នុងកាលនោះ ។ បទថា **ន សម្បសីទតិ** សេចក្តីថា មិនអាចដើម្បីនឹងបណ្តុះសេចក្តីជ្រះថ្លា ដោយអាស្រ័យកាលនោះ ។

ពាក្យថា **អរក្ខេយ្យានិ** ប្រែថា មិនត្រូវរក្សាទុក ។ លោកសម្តែងអត្ថថា មិនមានទាទីនឹងត្រូវរក្សាជាចំណែកៗ ទៅក្នុងទ្វារទាំង ៣ គ្រប់យ៉ាងរក្សាទុកហើយដោយសតិតែម្យ៉ាង ។ ពាក្យថា **បដិច្ឆាទេមិ** សេចក្តីថា កាយទុច្ចរិតប្រការនេះកើតឡើង ព្រោះមិនហ្មត់ចត់របស់តថាគត តថាគតនឹងរក្សាទុក មិនឲ្យអ្នកដទៃដឹង ។

ពាក្យថា **នត្ថិ តថាគតស្ស** សេចក្តីថា កាយទុច្ចរិតដែលត្រូវរក្សាយ៉ាងនោះ មិនមានដល់ព្រះតថាគត ។ សូម្បីក្នុងចំណែកដ៏សេស ក៏មានន័យនេះដូចគ្នា ។ សួរថា ព្រះខីណាស្រពដទៃៗ មានកាយសមាចារជាដើម មិនបរិសុទ្ធដូច្នោះឬ ឆ្លើយថា មិនមែនមិនបរិសុទ្ធ ប៉ុន្តែថា បរិសុទ្ធមិនស្មើនឹងព្រះតថាគត ។ ព្រះខីណាស្រព ដែលស្តាប់មកតិច រមែងមិនត្រូវអាបត្តិដែលជាលោកវជ្ជៈក៏ពិតមែន តែព្រោះមិនឈ្លាសក្នុងក្នុងពុទ្ធប្បញ្ញត្តិ ក៏រមែងនឹងត្រូវអាបត្តិក្នុងកាយទ្វារ ប្រភេទធ្វើវិហារ ធ្វើកុដិ ( ឃ្លៀងឃ្លាតពីពុទ្ធប្បញ្ញត្តិ ) នៅផ្ទះរួមដេក

រួមគ្នា ( ជាមួយអនុបសម្បន្នជាដើម ) ។ រមែងត្រូវអាបត្តិក្នុងវចីទ្វារ ប្រភេទពោលធម៌ ដោយបទនិយាយលើសពី ៥-៦ ពាក្យប្រាប់អាបត្តិដែលពិត ( ជាដើម ) ។ រមែងត្រូវអាបត្តិព្រោះទទួលប្រាក់ ទទួលមាសក្នុងផ្លូវមនោទ្វារ ដោយអំណាចត្រេកអរនឹងមាសប្រាក់ ដែលគេរក្សាទុកដើម្បីខ្លួន ។ សូម្បីព្រះវីណាស្រេពដូចព្រះធម្មសេនាបតីសារីបុត្រ ក៏ញុំាំងមនោទុច្ចរិតកើតឡើងបាន ដោយអំណាចដែលទឹកតិះដៀល ក្នុងមនោទ្វារ ។ កាលសក្យបាតុតុមេយ្យក: សូមខមាទោសព្រះមានព្រះភាគ ដើម្បីប្រយោជន៍ដល់ព្រះសារីបុត្រ និងព្រះមោគ្គល្លាន ក្នុងគ្រាដែលទ្រង់ដាក់ទោស ព្រះថេរៈទាំងពីរនោះ ព្រមទាំងភិក្ខុប្រមាណ ៥០០ រូប ក្នុងរឿងបាតុម: ព្រះថេរ: ដែលព្រះមានព្រះភាគត្រាស់សួរថា អ្នកគិតដូចម្តេចសារីបុត្រ កាលភិក្ខុសង្ឃត្រូវតថាគតដាក់ទោសហើយ ។ ដូច្នេះ ក៏ឲ្យកើតសេចក្តីគិតឡើងថា យើងត្រូវព្រះសាស្តាដាក់ទោស ព្រោះមិនឈ្លាសក្នុងរឿងបរិស័ទ តាំងពីឥឡូវនេះទៅ យើងនឹងមិនទូន្មានអ្នកដទៃៗ ទើបបានក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានការគិតយ៉ាងនេះថា ភិក្ខុសង្ឃដែលព្រះមានព្រះភាគទ្រង់ដាក់ទោសហើយ ឥឡូវនេះ ព្រះមានព្រះភាគនឹងទ្រង់ខ្វល់ខ្វាយតិច ប្រកបទិដ្ឋធម្មសុខវិហារធម៌ សូម្បីយើងទាំងពីរ ក៏នឹងខ្វល់ខ្វាយតិច ប្រកបទិដ្ឋធម្មសុខវិហារធម៌ដែរ ។ លំដាប់នោះ ព្រះសាស្តាកាលនឹងទ្រង់លើកប្រការតិះដៀល ព្រោះមនោទុច្ចរិតនោះរបស់ព្រះថេរ: ទើបត្រាស់ថា អ្នកចូរចាំទុកសារីបុត្រ ។ ការគិតយ៉ាងនេះ មិនគួរមានដល់អ្នក នឹងឲ្យកើតឡើងទៀតឡើយសារីបុត្រ ។ សូម្បីត្រឹមតែការគិតថា យើងនឹងមិនពោលប្រៀនប្រដៅអ្នកដទៃយ៉ាងនេះ ក៏ឈ្មោះថា ជាមនោទុច្ចរិតរបស់ព្រះថេរ:

តែព្រះមានព្រះភាគ រមែងមិនមានព្រះតម្រិះដូច្នោះ និងការដែលព្រះមានព្រះភាគទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណហើយ នឹងមិនគប្បីមានទុច្ចរិតនោះ មិនមែនរបស់គួរអស្ចារ្យ ។ សូម្បីតាំងនៅក្នុងភូមិនៃព្រះពោធិសត្វ ទ្រង់ប្រកបសេចក្តីព្យាយាមអស់ ៦ ឆ្នាំ ព្រះអង្គក៏មិនមានទុច្ចរិត ។ សូម្បីកាលពួកទេវតាកើតសេចក្តីសង្ស័យឡើងយ៉ាងនេះថា ស្បែកពោះជាប់ឆ្អឹងខ្នង ( យ៉ាងនេះ ) ព្រះសមណគោតមដល់កាលកិរិយា ( ទេដឹង ) កាលត្រូវមារចិត្តបាបពោលថា សិទ្ធត្ថ លោកនឹងត្រូវមកធ្វើខ្លួនឲ្យលំបាក ព្រោះហេតុអ្វី លោកអាចនឹងសោយភោគសម្បត្តិផង បំពេញបុណ្យកុសលផង ដូច្នេះ សូម្បីត្រឹមតែការគិតថា យើងនឹង ( ត្រឡប់ទៅ ) សោយភោគសម្បត្តិក៏មិនកើត ។ គ្រានោះ មារក៏ជាប់តាមព្រះមានព្រះភាគ ក្នុងវេលាដែលនៅជាព្រះពោធិសត្វ អស់ ៦ ឆ្នាំ រហូតដល់បានត្រាស់ដឹងជាព្រះពុទ្ធហើយ ម្យ៉ាងទៀត ១ ឆ្នាំ ក៏មិនបានឃើញទោសកំហុសយ៉ាងណាមួយ ទើបពោលសេចក្តីនេះ ហើយត្រឡប់ទៅថា

យើងបានជាប់តាមព្រះមានព្រះភាគ អស់វេលា ៧ ឆ្នាំ ក៏មិន
បានឃើញសេចក្តីធ្វេសប្រហែសរបស់ព្រះសម្ពុទ្ធ អ្នកមាន
សតិបរិបូណ៌ឡើយ ។

មួយប្រការទៀត គប្បីជ្រាបការមិនមានទុច្ចរិត របស់ព្រះមានព្រះភាគ សូម្បីដោយអំណាចនៃពុទ្ធធម៌ ១៨ ប្រការ ។ ដែលថាពុទ្ធធម៌ ១៨ ប្រការ ដូច្នេះ

ព្រះតថាគត មិនមានកាយទុច្ចរិត ១ មិនមានវចីទុច្ចរិត ១ មិនមានមនោទុច្ចរិត ១ ពុទ្ធញាណមិនមានអ្វីរារាំងក្នុងអតីត ១ ពុទ្ធញាណមិនមានអ្វី

រារាំងក្នុងអនាគត ១ ពុទ្ធញ្ញាណមិនមានអ្វីរារាំងក្នុងបច្ចុប្បន្ន ១ កាយកម្មទាំងពួងរបស់ព្រះមានព្រះភាគ បណ្ដោយតាមព្រះញាណ ១ វចីកម្មទាំងពួងរបស់ព្រះមានព្រះភាគ បណ្ដោយតាមព្រះញាណ ១ មនោកម្មទាំងពួងរបស់ព្រះមានព្រះភាគ បណ្ដោយតាមព្រះញាណ ១ មិនមានសេចក្ដីសាបសូន្យឆន្ទៈ ១ មិនមានសេចក្ដីសាបសូន្យវិរិយៈ ១ មិនមានសេចក្ដីសាបសូន្យបាកសតិ ១ មិនមានការលេង ១ មិនមានការរត់ ១ មិនមានភ្ញាត់ភ្ញាំង ១ មិនមានការប្រញាប់ប្រញាល់ ១ មិនមានព្រះហឫទ័យ ដែលមិនខ្វល់ខ្វាយ ១ មិនមានអកុសលចិត្ត ១ ។

ពាក្យថា **កិញ្ចនា** សំដៅដល់ បលិពោធ គ្រឿងកង្វល់ ។

ពាក្យថា **រាគោ កិញ្ចនំ** មានពាក្យនិយាមថា រាគៈកាលកើតឡើង រមែងចងរឹតសត្វទុក ( មិនឲ្យរួចផុតពីវដ្ដៈ ) ដូច្នោះ ទើបលោកហៅថា **កិញ្ចន** ( គ្រឿងកង្វល់ ) ។ សូម្បី ២ បទក្រៅនេះ ក៏មានន័យតែមួយដូចគ្នានេះឯង ។

ពាក្យថា **អគ្គិ** មានពាក្យនិយាមថា ឈ្មោះថា **អគ្គិ** ព្រោះអត្ថថា តាមដុត ។ ពាក្យថា **រាគគ្គិ** មានពាក្យនិយាមថា រាគៈកាលកើតឡើង រមែងតាមដុតសត្វឲ្យក្ដៅ ដូច្នោះ ទើបលោកហៅថា **អគ្គិ** ។ សូម្បីក្នុង ២ បទក្រៅនេះ ក៏មានន័យតែមួយដូចគ្នា ។ ក្នុងករណីនោះ មានរឿង ( ដូចតទៅនេះជាឧទាហរណ៍ ) ។ ភិក្ខុនីក្រមុំមួយរូប ទៅកាន់រោងឧបោសថ ត្រង់ចិត្តលបព្វតវិហារ ឈរមើលរូបរាងរបស់បុរសយាមទ្វារ ។ ឃើញហើយ រាគៈក៏កើតឡើងខាងក្នុងចិត្តរបស់នាង ។ នាងត្រូវរាគៈនោះឯងដុត ដរាបដល់ស្លាប់ទៅ ( ក្នុងខណៈដែល

ឈរត្រង់នោះឯង ) ។ ពួកភិក្ខុនី កាលនឹងត្រឡប់ ទើបពោលឡើងថា ភិក្ខុនីរូបនេះ ឈរ ( ត្រង់នោះឯង ) ទៅហៅនាងមក ។ ភិក្ខុនីមួយរូបដើរទៅចាប់ដៃនិយាយថា នៅឈរធ្វើអ្វី ។ ពេលពាល់ត្រូវរាងកាយ ភិក្ខុនីក្រមុំនោះក៏ដួលចុះទៅ ។ នេះជារឿងដែលរាគៈតាមដុត ។

ចំណែករឿងដែលទោសៈតាមដុតនោះ ដូចជាពួកទេវតាប្រភេទមនោ-បទោសិកា ( ពួកត្រូវប្រទូស្តដោយចិត្ត គឺសេចក្តីក្រោធកើតឡើងហើយ ក៏ចុតិទៅ ) ។ រឿងដែលមោហៈតាមដុតនោះ គប្បីឃើញដូចជាពួកទេវតាប្រភេទខិឌ្ឌាបទោសិកា ( ពួកត្រូវប្រទូស្តដោយការលេង ) ។ គឺទេវតាទាំងនេះ វង្វេងភ្លេចសតិដោយអំណាចមោហៈ ។ ព្រោះដូច្នោះ ល្មមដល់វេលាអាហារហើយ វល់តែលេង ទើបត្រូវអស់ជីវិតទៅ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទថា **អាហុនេយ្យគ្គិ** ជាដើម ។ គ្រឿងសក្ការៈលោកហៅថា **អាហុន** ។ បុគ្គលដែលគួរដល់អាហុនៈ ឈ្មោះថា **អាហុនេយ្យ** ។ ពិតហើយ មាតាបិតា រមែងគួរដល់អាហុនៈ ព្រោះមានឧបការៈច្រើនដល់បុត្រ ។ បុត្រទាំងឡាយ កាលបដិបត្តិខុសក្នុងមាតា បិតា ក៏រមែងទៅកើតក្នុងអបាយមាននរកជាដើម ។ ដូច្នោះ សូម្បីថា មាតាបិតានឹងមិនតាមដុតបុត្រក៏ពិត តែក៏ជាដើមហេតុនៃការត្រូវដុត ។ លោកហៅថា **អាហុនេយ្យគ្គិ** ( ភ្លើង គឺអាហុនេយ្យបុគ្គល ) ដោយអត្ថថា តាមដុត ដោយប្រការដូច្នេះ ។ សេចក្តីនេះ គប្បីជ្រាបដោយរឿងនាយមិត្តវិន្ទុកៈ ។

មានរឿងថា នាយមិត្តវិន្ទុកៈ ត្រូវមាតាពោលថា កូនអើយ ថ្ងៃនេះ កូនឯង

ចូររក្សាឧបោសថ ស្តាប់ធម៌នៅវត្ត រហូតអស់ទាំងយប់ចុះ ម៉ែនឹងឲ្យអ្នកឯងមួយពាន់ ដោយការចង់បានទ្រព្យ ទើបទៅវត្ត សមាទានឧបោសថ សម្គាល់ថា ទីត្រង់នេះផុតភ័យ ទើបចូលទៅដេកនៅក្រោមធម្មាសនៈ លក់រហូតមួយយប់ (ព្រឹកឡើង) ក៏ត្រឡប់ទៅផ្ទះវិញ ។ ចំណែកមាតាដាំយាគូទុកពីព្រឹកព្រលឹមស្រេចហើយ ក៏លើកចូលទៅឲ្យ ។ នាយមិត្តវិន្ទុកៈហុតយាគូ ទាំងដែលនៅក្តាប់ប្រាក់ ១ ពាន់ ។ តមក គេគិតឡើងថា នឹងរួបរួមទ្រព្យ ។ ក៏គិតចង់នឹងទៅ (ធ្វើជំនួញ) ផ្លូវទូកតាមសមុទ្រ ។ ពេលនោះ មាតាហាមគេថា កូនអើយ ក្នុងត្រកូលនេះ មានទ្រព្យដល់ ៤០ កោដិហើយ កុំទៅឡើយ ។ គេមិនយកចិត្តទុកដាក់ចំពោះពាក្យអង្វររបស់មាតា ជម្នះទៅឲ្យបាន ។ ទើបមាតាឈរទទឹងមុខ ។ គេក្រោធនឹងមាតាថា ម៉ែនេះ មកឈរទទឹងមុខយើង ទើបប្រានមាតាឲ្យដួល ហើយដើរកន្លងទៅ ។ មាតាក្រោកឡើងពោលថា កូនអើយ អ្នកឯងគង់សម្គាល់ថា ធ្វើកម្មបែបនេះ ក្នុងអ្នកដែលជាមាតាដូចជាយើងហើយ ធ្វើដំណើរទៅ នឹងមានសេចក្តីសុខបានអំពីទីណា ។ កាលនាយមិត្តវិន្ទុកៈចុះទូកទៅ ដល់ថ្ងៃទី ៧ ទូកក៏គឿង មនុស្សទាំងឡាយ (ដែលនៅក្នុងទូក) នោះនាំគ្នាពោលថា ក្នុងទូកនេះ មានមនុស្សបាបពិត ចូរចាប់ស្លាកមើលចុះ ។ កាលចាប់ស្លាក ក៏ធ្លាក់ដល់នាយមិត្តវិន្ទុកៈនុ៎ះឯងដល់ទៅ ៣ ដង ។ អ្នកទាំងនោះក៏យកគេដាក់ពោងពាយ បណ្តែតទៅក្នុងសមុទ្រ ។ គេទៅដល់កោះមួយកន្លែង សោយសម្បត្តិនៅជាមួយពួកនាងវេមានិកប្រេត កាលពួកប្រេតនោះប្រាប់ថា កុំទៅតទៅទៀតឡើយ ក៏ត្រឡប់មើលឃើញសម្បត្តិ (ខាងមុខ) ជាពីរដង នៅតែទៅ ដរាបដល់បានជួបសត្វមួយមានចក្រមុត (វិលនៅត្រង់

ក្បាល ) ។ គេឃើញចក្រនោះដូចជាផ្កាឈូក ។ ទើបពោលនឹងសត្វនោះថា នែ អ្នកចូរឲ្យផ្កាឈូកដែលអ្នកប្រដាប់នេះដល់ខ្ញុំចុះ ។ សត្វនោះពោលថា នាយ អើយ នេះមិនមែនផ្កាឈូកទេ នេះវាជាចក្រមុត ។ គេត្រឡប់និយាយថា លោកកុហកខ្ញុំ ផ្កាឈូក ហេតុដូចម្ដេចខ្ញុំនឹងមិនធ្លាប់ឃើញ ដូច្នេះហើយ ពោល តទៅទៀតថា អ្នកលាបស្រឡាបចន្ទន៍ក្រហមហើយ មិនចង់ឲ្យផ្កាឈូកគ្រឿង ប្រដាប់ដល់ខ្ញុំ ។ សត្វនោះគិតថា បុរសនេះ គង់នឹងបានធ្វើកម្មតែម្យ៉ាងដូច ដែលយើងធ្វើ ទើបប្រាថ្នាសោយផលកម្មនោះ ។ គ្រានោះ ទើបពោលនឹង នាយមិត្តវិន្ទុកៈថា យកចុះខ្ញុំឲ្យ ហើយគ្រវែងចក្រទៅលើក្បាលរបស់គេ ។ ដោយហេតុនោះ ទើបលោកពោលថា

បាន ៤ ហើយ ចង់បាន ៨ បាន ៨ ហើយ ចង់បាន ១៦ បាន
១៦ ហើយចង់បាន ៣២ ទើបមកទូលចក្រ បុគ្គលដែលត្រូវ
សេចក្ដីប្រាថ្នាលេងសម្រស់ ចក្រកំពុងវិលនៅលើក្បាល ។

ម្ចាស់របស់ផ្ទះ លោកហៅថា **គហបតី** គហបតីនោះ ឈ្មោះថា មាន ឧបការៈច្រើនដល់មាតុគ្រាម ដោយការបន្ថែមឲ្យនូវវត្ថុ ដូចទីដេកសំលៀក បំពាក់ គ្រឿងតែងខ្លួនជាដើម ។ មាតុគ្រាមក្រៅចិត្តគហបតី រមែងទៅកើតក្នុង អបាយ មាននរកជាដើម ដូច្នោះ គហបតីនោះ ទើបលោកហៅថា **គហបតិគ្គិ** ដោយអត្ថថា តាមដុត ដោយន័យមុនដូចគ្នា ។

ក្នុងករណីនោះ មានរឿង ( នេះជាឧទាហរណ៍ ) ក្នុងសម័យព្រះពុទ្ធ កស្សប កិរិយារបស់ឧបាសកជាសោតាបន្នម្នាក់ ប្រព្រឹត្តក្បត់ចិត្ត ។ ឧបាសក

ឃើញហេតុនោះដោយប្រចក្ស ទើបពោលថា ហេតុអ្វី ទើបនាងធ្វើយ៉ាងនេះ ។ ភរិយាឆ្លើយថា បើខ្ញុំធ្វើបែបនោះ ( ពិតដូចលោកថា ) សូមឲ្យសុនខនេះខាំខ្ញុំចុះ ដូច្នេះហើយ ស្លាប់ទៅកើតជាវេមានិកប្រេត ត្រង់ស្រះកណ្ណមុណ្ឌកៈ ។ ពេលថ្ងៃសោយសម្បត្តិ ពេលយប់សោយទុក្ខ ។ គ្រានោះ ព្រះបាទពារាណសី ស្តេចយាងប្រមាញ់ម្រឹគចូលទៅក្នុងព្រៃ ស្តេចទៅដល់ស្រះកណ្ណមុណ្ឌកៈ ដោយលំដាប់ បានសោយសម្បត្តិជាមួយនាង ។នាងប្រេតលួងលោមព្រះរាជា ហើយទៅសោយទុក្ខ ក្នុងពេលយប់ ។ព្រះរាជាទ្រង់ជ្រាបសេចក្តីហើយ ទ្រង់សង្ស័យថា នាងទៅទីណាហ្ន៎ ទើបស្តេចតាមទៅពីខាងក្រោយ ទ្រង់ឈប់មិនឆ្ងាយ ទ្រង់ទតឃើញសុនខមួយក្បាលចេញមកពីស្រះកណ្ណមុណ្ឌកៈ ខាំស៊ីនាងឮសំឡេងគ្រុបៗ ទើបទ្រង់កាប់ដោយព្រះខាន់ដាច់ពីរកំណាត់ ។ សុនខក៏កើតឡើង ២ ក្បាល ។ កាលត្រូវកាប់ដាច់ទៀត ក៏ជា ៤ ក្បាល ។ កាលត្រូវកាប់ដាច់ទៀត ក៏ជា ៨ ក្បាល ។ កាលត្រូវកាប់ដាច់ទៀត ក៏ជា ១៦ ក្បាល ។ នាងទូលថា ព្រះស្វាមី ព្រះអង្គទ្រង់ធ្វើអ្វី ។ ព្រះរាជាត្រាស់ថា នេះ គឺអ្វី ។ នាងទូលថា ព្រះអង្គកុំធ្វើយ៉ាងនោះ សូមទ្រង់ស្តោះស្តេស្មចុះលើផែនដី ហើយជាន់ឈ្មើដោយព្រះបាទ ។ ស្តេចក៏ធ្វើតាមដែលនាងទូលប្រាប់ ។ សុនខទាំងឡាយវិនាសអស់ទៅ ។ ថ្ងៃនោះ ត្រូវនឹងពេលនាងអស់កម្ម ។ ព្រះរាជាទ្រង់មិនសប្បាយព្រះហឫទ័យ ទើបទ្រង់ផ្តើមនឹងស្តេចត្រឡប់ ។ នាងទូលថា ស្វាមី កម្មរបស់នាងខ្ញុំអស់ហើយ ស្តេចកុំទៅឡើយ ។ ព្រះរាជាទ្រង់មិនស្តាប់ ស្តេចយាងទៅទាល់បាន ។ ចំណែកក្នុងពាក្យថា **ទក្ខិណេយ្យគ្គិ** នេះ ពាក្យថា **ទក្ខិណា** គឺបច្ច័យ ៤ ។ ភិក្ខុសង្ឃ ឈ្មោះថា ទក្ខិណេយ្យបុគ្គល ។ ភិក្ខុសង្ឃ

ឈ្មោះថា មានឧបការៈច្រើនដល់គ្រហស្ថ ដោយការដឹកនាំឲ្យប្រព្រឹត្តក្នុងកល្យាណធម៌ទាំងឡាយជាដើមថា សរណៈ ៣ សីល ៥ សីល ១០ ការចិញ្ចឹមរក្សាមាតាបិតា ការទំនុកបម្រុងសមណព្រាហ្មណ៍អ្នកមានធម៌ ។ គ្រហស្ថដែលបដិបត្តិខុសក្នុងភិក្ខុសង្ឃ ជេរប្រទេចភិក្ខុសង្ឃ រមែងទៅកើតក្នុងអបាយមាននរកជាដើម ដូច្នោះ សូម្បីភិក្ខុសង្ឃលោកក៏ហៅថា **ឧក្កិលោយេត្តិ** ដោយអត្ថថា តាមដុត ដោយន័យមុនដូចគ្នា ។ ដើម្បីឲ្យសេចក្តីនេះជាក់ច្បាស់ គួរសម្តែងរឿងវិមានិកប្រេតដោយល្អិតល្អន់ផង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **តីហិ ឋេនេហិ រូបសង្គហោ** នេះតទៅ ។ ពាក្យថា **តីហិ ឋេនេហិ** បានដល់ ៣ ចំណែក ។ ពាក្យថា **សង្គហោ** សំដៅយកសង្គហៈ ៤ យ៉ាង គឺជាតិសង្គហៈ សញ្ជាតិសង្គហៈ កិរិយាសង្គហៈ និងគណនសង្គហៈ ។ បណ្តាសង្គហៈ ៤ យ៉ាងនោះ ការរួបរួមជាដើមថា ក្សត្រទាំងពួងចូរមក ដូច្នេះ ឈ្មោះថា **ជាតិសង្គហោ** ( រួបរួមតាមជាតិកំណើត ) ។ ការរួបរួមជាដើមថា អ្នកកោសលទាំងអស់ចូរមក ដូច្នេះ ឈ្មោះថា **សញ្ជាតិសង្គហោ** ( រួបរួមតាមសញ្ជាតិ ) ។ ការរួបរួមជាដើមថា ទ្រមាក់ដំរីទាំងអស់ចូរមក ដូច្នេះ ឈ្មោះថា **កិរិយសង្គហោ** ( រួបរួមតាមអាការដែលធ្វើ ) ។ ការរួបរួមនេះថា សួរថា អាយតនៈ គឺចក្ខុ រាប់បញ្ចូលក្នុងខន្ធណា ឆ្លើយថា អាយតនៈ គឺចក្ខុ រាប់បញ្ចូលក្នុងរូបខន្ធ សកវាទីពោលថា បើអាយតនៈ គឺចក្ខុ រាប់បញ្ចូលក្នុងរូបខន្ធ ដោយហេតុនោះ ដែលគួរនឹងពោលថា អាយតនៈ គឺចក្ខុ សង្គ្រោះចូលដោយរូបក្ខន្ធ ដូច្នេះ ឈ្មោះថា **គណនសង្គហោ** (រួបរួមតាមការរាប់បញ្ចូល

បាន ) ។ គណនសង្គហៈនោះ បំណងយកក្នុងទីនេះ ។ ព្រោះដូច្នោះ ពាក្យថា **តិវិធេន រូបសង្គហោ** ទើបមានន័យថា ការរាប់រូបជា ៣ ចំណែក ។ គប្បីជ្រាបវិនិច្ឆ័យក្នុងសនិទស្សនៈជាដើម ។ រូប ព្រមទាំងនិទស្សនៈ ពោល គឺចក្ខុវិញ្ញាណ ដែលប្រព្រឹត្តទៅប្រារព្ធខ្លួន ឈ្មោះថា សនិទស្សនៈ រូបព្រមទាំងបដិឃៈ ព្រោះអាចប៉ះខ្ទប់ចក្ខុបាន ឈ្មោះថា សប្បដិឃៈ ។ សប្បដិឃៈនោះ ដោយន័យ គឺរូបាយតនៈនុ៎ះឯង ។ និទស្សនៈ ពោល គឺចក្ខុវិញ្ញាណ របស់រូបនោះមិនមាន ដូច្នោះ ទើបឈ្មោះថា អនិទស្សនៈ ។ រូប ព្រមទាំងបដិឃៈ ព្រោះអាចប៉ះខ្ទប់សោតៈបាន ឈ្មោះថា សប្បដិឃៈ ។ សប្បដិឃៈនោះ ដោយន័យ គឺអាយតនៈ ៩ មានអាយតនៈ គឺចក្ខុជាដើម ។ និទស្សនៈមានប្រការដូចពោលមកហើយរបស់រូបនោះមិនមាន ដូច្នោះ ទើបឈ្មោះថា អនិទស្សនៈ ។ បដិឃៈរបស់រូបនោះមិនមាន ដូច្នោះ ទើបឈ្មោះថា អប្បដិឃៈ ។ អប្បដិឃៈនោះ ដោយន័យ គឺសុខុមរូបដ៏សេស វៀរលែងតែអាយតនៈ ១០ ។

ពាក្យថា **តយោ សង្ខារា** មានពាក្យនិយាមថា ឈ្មោះថា សង្ខារ ព្រោះតាក់តែងឡើង គឺធ្វើឲ្យមានឡើងនូវធម៌ដែលកើតរួមគ្នា និងធម៌ដែលមានផលក្នុងកាលតទៅ ។

ឈ្មោះថា **អភិសង្ខារ** ព្រោះតាក់តែងឡើងយ៉ាងក្រៃលែង ។ អភិសង្ខារ គឺបុណ្យ ឈ្មោះថា បុញ្ញាភិសង្ខារ ។

ពាក្យថា **បុញ្ញាភិសង្ខារ** នោះ ជាឈ្មោះរបស់មហាចិត្តចេតនា ដែលជាកាមាវចរកុសល ៨ ដួង និងចេតនាដែលជារូបាវចរកុសល ៥ ដួង ដែលលោកពោលយ៉ាងនេះថា បណ្ដាអភិសង្ខារទាំងនោះ បុញ្ញាភិសង្ខារ គឺអ្វី គឺ

កុសលចេតនាជាកាមាវចរ រូបាវចរសម្រេចដោយទាន សម្រេចដោយសីល សម្រេចដោយភាវនា ។ បណ្តាចេតនាទាំងនោះ ចំពោះចេតនា ៨ ដួង សម្រេចដោយទាន សម្រេចដោយសីល ។ ទាំង ១៣ ដួង សម្រេចដោយភាវនា ។ ឧបមាដូចបុគ្គលស្វាធ្យាយធម៌ ដែលខ្លួនជំនាញ សូម្បីទឹងថា ១ ឬ ២ មាតិកាហើយ ក៏មិនដឹងខាងក្រោយ រឭកឡើងមកទើបដឹង យ៉ាងណា លោកអ្នកធ្វើកសិណបរិកម្ម ពិចារណាឈានដែលខ្លួនជំនាញ ហើយភាវនា រមែងជាញាណវិប្បយុត្ត ( មិនប្រកបដោយបញ្ញា ) បានខ្លះ ដូច្នោះដែរ ។ ដោយហេតុនោះទើបពោលថា ទាំង ១៣ ដួង សម្រេចដោយភាវនា ។

បណ្តាបុញ្ញកិរិយាវត្ថុ ដែលសម្រេចដោយទានជាដើមនោះ ការតាំងចិត្ត ចំណង់ចំណូលចិត្ត ដែលប្រារព្ធទានកើតឡើង មានទានជាគោល នេះលោកហៅថា បុញ្ញកិរិយាវត្ថុដែលសម្រេចដោយទាន ការតាំងចិត្ត ចំណង់ចំណូលចិត្ត ដែលប្រារព្ធសីល ប្រារព្ធភាវនាកើតឡើង មានភាវនាជាគោល នេះលោកហៅថា បុញ្ញកិរិយាវត្ថុ ដែលសម្រេចដោយភាវនា ។ ដូចពោលមកនេះ ជាសង្ខេបទេសនា ។ ចេតនាដែលប្រព្រឹត្តទៅក្នុងកាលទាំង ៣ របស់អ្នកថ្វាយវត្ថុនោះៗ ក្នុងពួកបច្ច័យ ៤ មានចីវរជាដើម អារម្មណ៍ ៦ មានរូបារម្មណ៍ជាដើម ឬទានវត្ថុ ១០ យ៉ាង មានបាយជាដើម គឺក្នុងកាលខាងដើម តាំងពីញ៉ាំងវត្ថុទាំងនោះឲ្យកើតឡើង ១ ក្នុងកាលកំពុងបរិច្ចាគ ១ ក្នុងកាលដែលរឭកក្នុងខាងក្រោយដោយចិត្តសោមនស្ស ១ ដូច្នេះ ឈ្មោះថា ទានមយចេតនា ( ចេតនាដែលសម្រេចដោយទាន ) ។

ចំណែកចេតនាដែលប្រព្រឹត្តទៅហើយរបស់លោកអ្នកទៅវត្ត ដោយតាំង

ចិត្តថា នឹងបួសបំពេញសីល របស់អ្នកកំពុងបួស របស់អ្នកញ៉ាំងមនោរថឲ្យដល់ទីបំផុតហើយ នឹងរំពូកថា យើងបួសហើយហ្ន៎ សម្រេចប្រយោជន៍ដោយភាពជាអ្នកសង្រួមក្នុងបាតិមោក្ខ របស់អ្នកពិចារណាបច្ច័យទាំងឡាយ មានចីវរជាដើម របស់អ្នកសង្រួមទ្វារ មានចក្ខុទ្វារជាដើម ក្នុងអារម្មណ៍ មានរូបជាដើម ដែលមកកាន់គន្លង និងរបស់អ្នកជម្រះអាជីវៈឲ្យបរិសុទ្ធ ( ដូច្នេះ ) ឈ្មោះថា សីលមយចេតនា ( ចេតនាដែលសម្រេចដោយសីល ) ។ ចេតនាដែលប្រព្រឹត្តទៅហើយរបស់លោកអ្នកអប់រំចក្ខុ ដោយសភាពមិនទៀង ជាទុក្ខ ជាអនត្តា ដោយវិបស្សនា មគ្គដែលពោលក្នុងបដិសម្ភិទា របស់លោកអ្នកអប់រំចិត្ត ។ល។ របស់លោកអ្នកអប់រំចក្ខុវិញ្ញាណ មនោវិញ្ញាណ ចក្ខុសម្ផស្ស មនោសម្ផស្ស វេទនាដែលកើតពីចក្ខុសម្ផស្ស វេទនាដែលកើតពីមនោសម្ផស្ស ក្នុងរូបារម្មណ៍ ក្នុងធម្មារម្មណ៍របស់លោកអ្នកអប់រំរូបសញ្ញា ។ល។ជរា មរណៈ ដោយសភាពមិនទៀង ជាទុក្ខ ជាអនត្តា ឈ្មោះថា ភាវនាមយចេតនា ( ចេតនាដែលសម្រេចដោយភាវនា ) ដូចពោលមកនេះ ជាវិត្ថារកថា ។ អភិសង្ខារនោះផង មិនមែនបុណ្យ ( ជាបាប ) ផង ដូច្នោះ ទើបឈ្មោះថា **អបុញ្ញាភិសង្ខារ** ( អភិសង្ខារដែលជាបាប ) ។ ពាក្យថា អបុញ្ញាភិសង្ខារនេះ ជាឈ្មោះរបស់ចេតនាដែលសម្បយុត្តដោយអកុសលចិត្ត ។ សមដូចដែលលោកពោលថា បណ្តាអភិសង្ខារទាំងនោះ អបុញ្ញាភិសង្ខារដូចម្តេច គឺអកុសលចេតនា ដែលជាកាមាវចរ នេះហៅថា អបុញ្ញាភិសង្ខារ ។ ដែលឈ្មោះថា **អានេញ្ជាភិសង្ខារ** ព្រោះតាក់តែងឡើងយ៉ាងក្រៃលែងនូវអរូបទុំះឯង ដែលជាវិបាកមិនញាប់ញ័រ មិនកម្រើកស្ងប់ ។ ពាក្យថា អានេញ្ជាភិសង្ខារនេះ ជាឈ្មោះរបស់

កុសលចេតនា ដែលជាអរូបាវចរ ៤ ដួង ។ សមដូចដែលលោកពោល ទុកថា បណ្តាអភិសង្ខារទាំងនោះ អានេញ្ជាភិសង្ខារ ដូចម្តេច គឺកុសលចេតនាដែលជាអរូបាវចរ នេះហៅថា អានេញ្ជាភិសង្ខារ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបុគ្គលបញ្ញត្តិកៈតទៅ ។ បុរសបុគ្គល ៧ ប្រភេទ រមែងសិក្សាត្រៃសិក្ខា ដូច្នោះ ទើបឈ្មោះថា សេក្ខៈ ( អ្នកត្រូវសិក្សា ) ។ ព្រះខីណាស្រពមិនត្រូវសិក្សាទៀត ព្រោះសិក្សាត្រៃសិក្ខាចប់ហើយ ដូច្នោះ ទើបឈ្មោះថា អសេក្ខៈ ( អ្នកមិនត្រូវសិក្សា ) ។ បុថុជ្ជន ឈ្មោះថា សេក្ខៈ ក៏មិនមែន អសេក្ខៈក៏មិនមែន ព្រោះនៅខាងក្រៅអំពីសិក្ខាទាំងឡាយ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងថេរញ្ញត្តិកៈតទៅ ។ លោកជាអ្នកធំដោយជាតិ ឈ្មោះថា **ជាតិត្ថេរ** ។ លោកអ្នកប្រកបដោយធម៌តែម្យ៉ាង ឬច្រើនយ៉ាង ក្នុងបណ្តាធម៌ទាំងឡាយ ដែលលោកពោលយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ដែលធ្វើឲ្យជាថេរៈទាំង ៤ ប្រការនេះ គឺព្រះថេរៈក្នុងព្រះសាសនានេះ ជាអ្នកមានសីល ជាពហុស្សុត បានឈាន ៤ ព្រោះអស់អាសវៈទាំងឡាយ ។ល។ ចូលដល់ព្រមហើយ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលធ្វើឲ្យជាថេរៈទាំង ៤ ប្រការនេះឯង ដូច្នេះ ឈ្មោះថា **ធម្មត្ថេរ** ។ លោកអ្នកមានឈ្មោះថា ថេរៈយ៉ាងនេះ គឺភិក្ខុបណាមួយ ដែលឈ្មោះថា ព្រះថេរៈក្តី អ្នកទាំងឡាយឃើញអ្នកបួសដូចសាមណេរជាដើម ដែលបួសវេលាមានអាយុច្រើនហើយ ហៅថា ព្រះថេរៈ ព្រះថេរៈក្តី នេះឈ្មោះថា **សម្មតិត្ថេរ** ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបុញ្ញកិរិយាវត្ថុតទៅ ។ ទានទុំះឯង ឈ្មោះថា **ទានមយ** ។ ការធ្វើបុណ្យនោះដោយវត្ថុ (គឺទីតាំង) នៃបុញ្ញានិសង្សទាំងនោះ ដូច្នោះ

ទើបឈ្មោះថា **បុញ្ញកិរិយាវត្ថុ** ( ទីតាំងនៃការធ្វើបុណ្យ ) សូម្បីក្នុងបុញ្ញកិរិយាវត្ថុប្រការដទៃៗ ក៏មានន័យដូចគ្នា ។ តែដោយអត្ថ គប្បីជ្រាបបុញ្ញកិរិយាវត្ថុ ៣ យ៉ាងទាំងនេះ ព្រមទាំងបុព្វភាគចេតនា ( ការតាំងចិត្តមុននឹងធ្វើ ) និងអបរភាគចេតនា ( ការតាំងចិត្ត ខាងក្រោយអំពីធ្វើហើយ ) ដោយអំណាចនៃចេតនាដែលសម្រេចដោយទានជាដើម ដែលបានពោលហើយក្នុងខាងដើម ។ និងក្នុងរឿងនេះ បុគ្គលធ្វើកម្មណាមួយដោយកាយ រាប់តាំងពីបុព្វភាគចេតនាក៏ចាត់ជាកាយកម្ម ។ កាលថ្លែងវាចា ការមានន័យយ៉ាងនោះ ចាត់ជាវចីកម្ម ។ កាលមិនបានញ៉ាំងអង្គនៃកាយ និងអង្គនៃវាចាឲ្យកម្រើក គិតដោយចិត្ត ( តែម្យ៉ាង ) ក៏ចាត់ជាមនោកម្ម ន័យមួយទៀត សម្រាប់អ្នកឲ្យទានវត្ថុ មានបាយជាដើម ( ក្នុងវេលាដែលពោលថា ) ខ្ញុំឲ្យអន្នទាន ( ឲ្យបាយ ) ជាដើមក្តី ក្នុងវេលាដែលរឭកដល់ទានបារមី ហើយឲ្យក្តី ចាត់ជាបុញ្ញកិរិយាវត្ថុសម្រេចដោយទាន ។ តាំងនៅក្នុងសីល និងវត្ត ហើយឲ្យចាត់ជាបុញ្ញកិរិយាវត្ថុសម្រេចដោយសីល ។ ផ្តើមតាំងពីការពិចារណា ដោយការអស់ទៅ សាបសូន្យទៅហើយឲ្យចាត់ជាបុញ្ញកិរិយាវត្ថុ សម្រេចដោយភាវនា ។ បុញ្ញកិរិយាវត្ថុយ៉ាងដទៃមាន ៧ យ៉ាង គឺបុញ្ញកិរិយាវត្ថុ ដែលប្រកបដោយសេចក្តីគោរពកោតក្រែងប្រកបដោយការខ្វល់ខ្វាយ ( ជួយធ្វើកិច្ចរបស់អ្នកដទៃ ) ការឲ្យចំណែកបុណ្យការអនុមោទនា ចំណែកបុណ្យដែលសម្រេចដោយការសម្តែងធម៌ ដែលសម្រេចដោយការស្តាប់ធម៌ បុញ្ញកិរិយាវត្ថុ គឺការធ្វើសេចក្តីឃើញត្រង់ ដូច្នេះ ។ បណ្តាបុញ្ញកិរិយាវត្ថុទាំង ៧ នោះ សេចក្តីគោរពកោតក្រែង គប្បីជ្រាបដោយការឃើញភិក្ខុចាស់ ហើយក្រោកទទួលបាត្រ ចីវរ ថ្វាយបង្គំ ចៀសផ្លូវឲ្យ

ជាដើម ។ ការខ្វល់ខ្វាយ គប្បីជ្រាបដោយការធ្វើវត្តបដិបត្តិដល់ភិក្ខុដែលចាស់ជាងខ្លួន ដោយការដែលឃើញភិក្ខុចូលស្រុក ដើម្បីបិណ្ឌបាត ហើយកាន់បាត្រទៅបបួលរួបរួមភិក្ខាក្នុងស្រុក និងដោយការបានស្តាប់ថា ទៅយកបាត្ររបស់ពួកភិក្ខុមក ដូច្នេះ ហើយប្រញាប់ប្រញាល់ទៅនាំបាត្រមកជាដើម ។ ការឲ្យចំណែកបុណ្យ គប្បីជ្រាបដោយការដែលថ្វាយបច្ច័យ ៤ ហើយ ( តាំងចិត្តឧទ្ទិស ) ឲ្យប្រព្រឹត្តទៅថា ចំណែកបុណ្យចូរមានដល់សព្វសត្វ ។ ការអនុមោទនាចំណែកបុណ្យ គប្បីជ្រាបដោយការអនុមោទនាចំណែកបុណ្យដែលអ្នកដទៃឲ្យថា សាធុ ប្រពៃហើយ ។ ភិក្ខុមួយរូបតាំងនៅក្នុងសេចក្តីប្រាថ្នាថា មនុស្សទាំងឡាយនឹងស្គាល់យើងថាជាធម្មកថិក ដោយឧបាយយ៉ាងនេះ ជាអ្នកជូនក្នុងលាភសម្តែងធម៌ ប្រការនោះមិនមានផលច្រើន ។ ភិក្ខុមួយរូបសម្តែងធម៌ដែលខ្លួនជំនាញដល់ជនដទៃៗ ដោយមិនបានប្រាថ្នាផលតប ជំនួសនេះឈ្មោះថា បុញ្ញកិរិយាវត្ថុសម្រេចដោយការសម្តែងធម៌ ។ បុគ្គលម្នាក់កាលនឹងស្តាប់ធម៌ ក៏ស្តាប់ដោយបំណងថា មនុស្សទាំងឡាយ នឹងបានស្គាល់យើងថា មានសទ្ធាដោយអាការយ៉ាងនេះ ។ ប្រការនោះ មិនមានផលច្រើន ។ បុគ្គលម្នាក់ ស្តាប់ធម៌ដោយចិត្តដែលទន់ភ្លន់ ផ្សាយប្រយោជន៍ថា នឹងមានផលច្រើនដល់យើងដោយអាការយ៉ាងនេះ នេះឈ្មោះថា បុញ្ញកិរិយាវត្ថុសម្រេចដោយការស្តាប់ធម៌ ។ចំណែកការធ្វើសេចក្តីឃើញឲ្យត្រង់ ជាលក្ខណៈកំណត់ដល់បុញ្ញកិរិយាវត្ថុគ្រប់យ៉ាង ។ការពិតបុគ្គលធ្វើបុណ្យណាៗ មានផលច្រើនបានក៏ដោយសេចក្តីឃើញត្រង់នុ៎ះឯង ។ បុញ្ញកិរិយាវត្ថុទាំង ៧ យ៉ាងនេះ គប្បីជ្រាបថា រួមចូលបាននឹងបុញ្ញកិរិយាវត្ថុ ៣ យ៉ាង ខាងដើមនុ៎ះឯង ដោយប្រការ

ដូច្នេះ ។ ក្នុងទីនេះ ការគោរពកោតក្រែង និងការខ្វល់ខ្វាយ ( ជួយធ្វើកិច្ចការរបស់អ្នកដទៃ ) រួមចុះបានក្នុងសីលមយបុញ្ញកិរិយាវត្ថុ ការឲ្យចំណែកបុណ្យ និងការអនុមោទនាចំណែកបុណ្យ រួមចុះបានក្នុងទានមយបុញ្ញកិរិយាវត្ថុ ការសម្ដែងធម៌ និងការស្ដាប់ធម៌ រួមចុះបានក្នុងភាវនាមយបុញ្ញកិរិយាវត្ថុ ការធ្វើសេចក្ដីយល់ឃើញឲ្យត្រង់ រួមចុះបានទាំង ៣ យ៉ាង ។

ពាក្យថា **ចោទនាវត្ថូនិ** សំដៅដល់ហេតុដែលនឹងត្រូវចោទ ( ពោលរក ) គ្នា ។

ពាក្យថា **ទិដ្ឋេន** មានន័យថា ឃើញខុសដោយភ្នែកសាច់ក៏ដោយ ដោយភ្នែកទិព្វក៏ដោយ ហើយចោទឡើង ។ ពាក្យថា **សុតេន** មានន័យថា បានឮសំឡេងរបស់អ្នកដទៃ ដោយត្រចៀកធម្មតាក៏ដោយ ដោយត្រចៀកទិព្វក៏ដោយ ហើយចោទឡើង ។ ពាក្យថា **បរិសង្កាយ** មានន័យថា ចោទឡើងដោយសេចក្ដីសង្ស័យ ព្រោះបានឃើញមកក៏ដោយ ដោយសេចក្ដីសង្ស័យ ព្រោះបានឮមកក៏ដោយ ដោយសេចក្ដីសង្ស័យ ព្រោះបានជ្រាបមកក៏ដោយ ។ នេះជាសេចក្ដីសង្ខេបក្នុងរឿងនេះ ។ ចំណែកន័យល្អិតល្អន់ គប្បីជ្រាបតាមន័យដែលបានពោលហើយ ក្នុងសមន្តបាសាទិកាទុំះឯង ។

ពាក្យថា អ្នកចូលដល់កាម មានន័យថា អ្នកចូលទៅសេពកាម ឬបានចំពោះកាម ។ ពាក្យថា អ្នកមានកាមប្រាកដហើយ បានដល់ អ្នកមានកាមចង់រីតទុក គឺអ្នកមានអារម្មណ៍ចង់រីត ។ ពាក្យថា ប្រៀបដូចជាមនុស្ស គឺដូចពួកមនុស្ស ។ ព្រោះថា ពួកមនុស្សរមែងញ៉ាំងអំណាចឲ្យប្រព្រឹត្តទៅក្នុងវត្ថុដែលចង់រីតប៉ុណ្ណោះ មានចិត្តប្រតិព័ទ្ធក្នុងមាតុគ្រាមណា ក៏ឲ្យប្រាក់មួយរយខ្លះ

ពីរវេយ្យខ្ទះ ហើយនាំមាតុគ្រាមនោះមកបរិភោគ ភោគៈដែលចងព័ន្ធ ។ ទេវតាអ្នកនៅក្នុងទេវលោក ៤ ពួក ឈ្មោះថា ទេវតាពួកខ្ទះ ។ សូម្បីទេវតាទាំងនោះ ក៏ញុំាងអំណាចឲ្យប្រព្រឹត្តទៅ ក្នុងវត្ថុដែលចងព័ន្ធនោះឯង ។ ទេវតាដ៏សេសវៀរពួកសត្វនរក ឈ្មោះថា ពួកវិនិបាត ។ ព្រោះសូម្បីត្រី និងអណ្តើកជាដើម ក៏ញុំាងអំណាចឲ្យប្រព្រឹត្តទៅក្នុងវត្ថុដែលចងព័ន្ធនោះឯង ។ អធិប្បាយថា ត្រី ក៏ញុំាងអំណាចឲ្យប្រព្រឹត្តទៅនឹងនាងត្រី អណ្តើកក៏ញុំាងអំណាចឲ្យប្រព្រឹត្តទៅនឹងនាងអណ្តើក ។ ពីរពាក្យថា និម្មិតហើយ និម្មិតហើយ សេចក្តីថា និម្មិតរូបនោះៗ ដែលប្រាថ្នាសម្រាប់ខ្លួន ដោយមានរូបពណ៌ខៀវ និងរូបពណ៌លឿងជាដើម ដូចជាទេវតាពួកមនាបកាយិកា និម្មិតរូបខាងមុខព្រះអនុរុទ្ធ ដូច្នោះ ។ បទថា **និម្មានរតី** សេចក្តីថា ឈ្មោះថា ទេវតា ពួកនិម្មានរតី ព្រោះអត្ថថា ទេវតាទាំងនោះ ត្រេកអរក្នុងរបស់និម្មិត ដែលខ្លួននិម្មិតហើយៗ យ៉ាងនោះ ។ បទថា **បរនិម្មិតកាមា** សេចក្តីថា អ្នកមានកាមដែលអ្នកដទៃនិម្មិតឲ្យ ។ ព្រោះថា ទេវតាពួកដទៃ ដឹងចិត្តរបស់ទេវតាទាំងនោះ ហើយក៏និម្មិតកាមភោគៈ តាមដែលពេញចិត្តឲ្យទេវតាទាំងនោះ រមែងញុំាងអំណាចឲ្យប្រព្រឹត្តទៅក្នុងកាមភោគៈនោះឯង ។ សួរថា អ្នកដទៃដឹងចិត្តរបស់អ្នកដទៃបានយ៉ាងណា ។ ឆ្លើយថា ដឹងបានដោយអំណាចការសេព និងប្រើប្រាស់តាមប្រក្រតី ។ ឧបមាដូចចុងភៅ ដែលឈ្លាស កាលព្រះរាជាសោយហើយ រមែងដឹងបានថា ព្រះរាជាអង្គនោះ ទ្រង់ទទួលវត្ថុណាៗ ច្រើន ព្រះអង្គរមែងពេញចិត្តវត្ថុនោះៗ ។ អ្នកដទៃដឹងអារម្មណ៍ដែលគេពេញចិត្តច្រើន តាមប្រក្រតីដោយអាការយ៉ាងនេះហើយ ទើបនិម្មិតអារម្មណ៍ដូច្នោះនុ៎ះឯងឲ្យ ពួកគេរមែងញុំាងអំណាចឲ្យ

*ប្រព្រឹត្តទៅក្នុងវត្ថុ ដែលគេនិម្មិតឲ្យនោះ គឺសេពមេថុន ។ ចំណែកព្រះថេរៈខ្លះពោលថា កាមកិច្ច រមែងសម្រេចដល់ពួកគេដោយអាការត្រឹមតែសើច ត្រឹមតែសម្លឹងមើល និងត្រឹមតែការប៉ះពាល់ ។ ពាក្យរបស់ព្រះថេរៈខ្លះនោះ ត្រូវជំទាស់ក្នុងអដ្ឋកថាថា ពាក្យដែលពោលនោះមិនមាន ។ កាមកិច្ច ដែលគប្បីសម្រេចដល់អ្នកមិនពាល់ត្រូវដោយកាយ រមែងមិនមាន ។ ព្រោះថា កាមទាំងឡាយរបស់ពួកទេពជាន់ឆកាមាវចរ ប្រព្រឹត្តទៅតាមប្រក្រតីដូចគ្នា ។ សមពិត ដូចដែលត្រាស់ថា*

*ទេពពួកកាមាវចរទាំង ៦ ជាន់នោះ ដល់ព្រមដោយកាមទាំងពួង*
*អាយុរបស់ទេពទាំងនោះ កាលរាប់រួមគ្នានឹងមានប៉ុន្មាន ។*

*បទថា* **សុខូបបត្តិយោ** *ប្រែថា អ្នកបានចំពោះនូវសុខ ។ ពាក្យថា* **ឧប្បាទេត្វា ឧប្បាទេត្វា សុខំ វិហរន្តិ** *សេចក្ដីថា ញុំាងសេចក្ដីសុខក្នុងបឋមជ្ឈានឲ្យកើតឡើង ហើយសោយសេចក្ដីសុខក្នុងឈាន ដែលជាតួវិបាក ។ ពីរបទថា* **សុខេន អភិសន្នា** *ប្រែថា ជ្រួតជ្រាបដោយសុខ ក្នុងទុតិយជ្ឈាន ។ បទថា* **បរិសន្នា** *គឺជ្រួតជ្រាបដោយជុំវិញ ។ បទថា* **បរិបូរា** *គឺបរិបូណ៌ ។ បទថា* **បរិប្ផុដា** *ជាវេវចនៈរបស់ពាក្យថា* **បរិបូរា** *នុ៎ះឯង ។ សូម្បីពាក្យនេះដែលថា សុខហ្ន៎ សុខហ្ន៎ ក៏ទ្រង់ត្រាស់សំដៅយកសេចក្ដីសុខដែលជាតួវិបាកនោះឯង ។*

*បានឮថា ទេពទាំងនោះ កើតសេចក្ដីលោភក្នុងភពច្រើនជាន់ ព្រោះដូច្នោះទើបថ្លែងឧទានយ៉ាងនោះក្នុងទីកន្លែងខ្លះ ក្នុងវេលាខ្លះ ។ បទថា* **សន្តមេវ** *បានដល់ប្រណីតពិត ។ បទថា* **សន្តុសិតា** *មានន័យថា ជាអ្នកសន្តោស ព្រោះមិនត្រូវ*

ការសុខក្រៃលែងឡើងទៅជាងនោះ ។ ពីរបទថា **សុខំ បដិវេទេន្តិ** បានដល់សោយសុខក្នុងតតិយជ្ឈាន ។

បញ្ញារបស់ព្រះអរិយៈ ៧ ពួក ឈ្មោះថា សេក្ខប្បញ្ញា បញ្ញារបស់ព្រះអរហន្ត ជាអសេក្ខប្បញ្ញា បញ្ញាដ៏សេស ជានេវសេក្ខានាសេក្ខប្បញ្ញា ( ជាសេក្ខប្បញ្ញាក៏មិនមែន ជាអសេក្ខប្បញ្ញាក៏មិនមែន ) ។ ក្នុងបញ្ញាដែលសម្រេចដោយការគិតជាដើម មានសេចក្តីពិស្តារដូចតទៅនេះ

ដែលថា បណ្តាបញ្ញាទាំងនោះ បញ្ញាដែលសម្រេចដោយការគិត ដូចម្តេច ? ក្នុងអណ្តូងកើតរបស់ការងារ ដែលបង្អោនទាំចូលទៅដោយបញ្ញា ឬក្នុងអណ្តូងកើតរបស់សិល្បៈ ដែលបង្អោននាំទៅដោយបញ្ញា ឬក្នុងស្ថានទីរបស់វិជ្ជា ដែលបង្អោននាំចូលទៅដោយបញ្ញា បុគ្គលមិនបានស្តាប់មកពីអ្នកដទៃ តែបានកម្មស្សកតាញាណ ឬសច្ចានុលោមិកញ្ញាណ ឬអនុលោមិកខន្តិ ទិដ្ឋិ រុចិមុទី បេក្ខៈ ធម្មនិជ្ឈានខន្តិ បែបនេះ យ៉ាងនេះថា រូបមិនទៀង ។ល។ វិញ្ញាណមិនទៀង នេះហៅថា **ចិន្តាមយបញ្ញា** ។ ក្នុងបញ្ញា ៣ ប្រការនោះ បញ្ញាដែលសម្រេចដោយការស្តាប់ដូចម្តេច ? ក្នុងអណ្តូងកើតរបស់ការងារ ដែលបង្អោននាំចូលទៅដោយបញ្ញា បានស្តាប់ពីអ្នកដទៃប៉ុណ្ណោះ ទើបបាន ។ល។ ធម្មនិជ្ឈានខន្តិ នេះហៅថា **សុតមយបញ្ញា** ។ ក្នុងបញ្ញា ៣ ប្រការនោះ បញ្ញាដែលសម្រេចដោយការចម្រើនភាវនា ដូចម្តេច ? បញ្ញាសូម្បីទាំងអស់របស់អ្នកចូលសមាបត្តិ ឈ្មោះថា **ភាវនាមយបញ្ញា** ។

បទថា **សុតាវុធំ** អាវុធ គឺសុតៈ ។ អាវុធ គឺសុតៈនោះ ដោយសេចក្តីបានដល់ ព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដក ។ ព្រោះថា ភិក្ខុអាស្រ័យអាវុធនោះ

គឺអាស្រ័យអាវុធ ៥ ប្រការ រមែងជាអ្នកមិនខ្លាច ធ្វើសង្គ្រាមកន្ទារបាន ដូចទាហានខ្លាំងក្លា មិនញញើតក្នុងការធ្វើមហាកន្ទារបាន ដូច្នោះ ។ ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អរិយសាវកមានការចេះដឹងជាអាវុធ រមែងលះបង់នូវអកុសល ចម្រើននូវកុសល លះបង់នូវអំពើជាទោស ចម្រើននូវអំពើមិនមានទោស រមែងរក្សាខ្លួនឲ្យបរិសុទ្ធ ដូច្នេះ ។

បទថា **បវិវេកាវុធំ** សេចក្តីថា អាវុធ គឺវិវេក សូម្បីបីប្រការនេះ គឺកាយវិវេក ចិត្តវិវេក ឧបធិវិវេក ។ វិវេក ៣ ប្រការនោះ មានការធ្វើផ្សេងៗគ្នា ។ កាយវិវេក ចំពោះបុគ្គលដែលមានកាយចៀសចេញទៅ ត្រេកអរក្នុងនេក្ខម្មៈ ចិត្តវិវេក ចំពោះបុគ្គលដែលមានចិត្តបរិសុទ្ធិ សម្រេចដល់ភាពផូរផង់យ៉ាងកំពូល និងឧបធិវិវេក ចំពោះបុគ្គលដែលមិនមានឧបធិ ដល់នូវវិសង្ខារ ( គឺព្រះនិព្វាន ) ។ បុគ្គលដែលត្រេកអរក្រៃលែងហើយក្នុងវិវេក ៣ យ៉ាងនេះ រមែងមិនខ្លាចពីទីណាៗ ព្រោះដូច្នោះ សូម្បីវិវេកនេះក៏ហៅថា **អាវុធ** ព្រោះអត្ថថា ជាទីពឹងអាស្រ័យ ។ អាវុធ គឺបញ្ញាដែលជាលោកិយ និងលោកុត្តរចាត់ជាអាវុធ គឺបញ្ញា ។ ព្រោះថា បុគ្គលដែលមានអាវុធ គឺបញ្ញានោះ រមែងមិនខ្លាចពីទីណាៗ ទាំងនរណាៗ ក៏មិនខ្លាចបុគ្គលនោះ ព្រោះដូច្នោះ សូម្បីបញ្ញានោះ ក៏ហៅថា **អាវុធ** ព្រោះអត្ថថា ជាទីពឹងអាស្រ័យ ។

បទថា **អនញ្ញាតញ្ញស្សាមីតិន្ទ្រិយំ** សេចក្តីថា ឥន្ទ្រិយដែលកើតឡើងដល់អ្នកបដិបត្តិ ដោយប្រាថ្នាថា យើងដឹងធម៌ដែលមិនទាន់ដឹង មិនទាន់ជាក់ច្បាស់ក្នុងកាលមុនអំពីនេះ ។

ពាក្យថា **អនញ្ញាតញ្ញស្សាមីតិន្ទ្រិយំ** នេះ ជាឈ្មោះរបស់សោតាបត្តិ-មគ្គញ្ញាណ ។

បទថា **អញ្ញិន្ទ្រិយំ** បានដល់ ឥន្ទ្រិយដែលជាការដឹងទូទៅ គឺជាសេចក្តីដឹង ។ ពាក្យថា **អញ្ញិន្ទ្រិយំ** នេះ ជាឈ្មោះរបស់ញាណក្នុងឋានៈ ៦ ប្រការ ចាប់តាំងពីសោតាបត្តិផលទៅ ។ បទថា **អញ្ញាតាវិន្ទ្រិយំ** នេះ បានដល់ ឥន្ទ្រិយក្នុងធម៌ទាំងឡាយ ដែលជារបស់បុគ្គលអ្នកដឹងទូទៅ គឺដែលដល់ទីបំផុតកិច្ចនៃការដឹង ។ ពាក្យថា **អញ្ញាតាវិន្ទ្រិយំ**នេះ ជាឈ្មោះរបស់អរហត្តផលញ្ញាណ ។

**មំសចក្ខុ** បានដល់ ចក្ខុបសាទ ។ **ទិព្វចក្ខុ** បានដល់ ញាណអាស្រ័យពន្លឺ ។ **បញ្ញាចក្ខុ** បានដល់ បញ្ញាដែលជាលោកិយ និងលោកុត្តរ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងអធិសីលសិក្ខាជាដើមតទៅ ។ សីលដែលក្រៃលែងនោះ ដោយឈ្មោះថា **សិក្ខា** ព្រោះនឹងត្រូវសិក្សា ព្រោះហេតុនោះ ទើបឈ្មោះថា **អធិសីលសិក្ខា**។ សូម្បីក្នុងសិក្ខាទាំង ២ ក្រៅពីនេះ ក៏មានន័យនេះដូចគ្នា ។ ក្នុងអធិសីលសិក្ខាជាដើមនោះ សីល គឺសីលដែលក្រៃលែង ចិត្ត គឺចិត្តដែលក្រៃលែង បញ្ញា គឺបញ្ញាដែលក្រៃលែង ព្រោះហេតុនោះ គប្បីជ្រាបសេចក្តីផ្សេងគ្នាត្រឹមតែប៉ុណ្ណេះ ។ សីល ៥ និងសីល ១០ ឈ្មោះថា **សីល** ។ ការសង្រួមក្នុងព្រះបាតិមោក្ខ ឈ្មោះថា សីលដែលក្រៃលែង ។ សមាបត្តិ ៨ ចាត់ជាចិត្ត ( សមាធិ ) ។ ឈានដែលជាបាទរបស់វិបស្សនា ចាត់ជាចិត្តដែលក្រៃលែង ។ កម្មស្សកតាញ្ញាណ ចាត់ជាបញ្ញា ។ វិបស្សនា ចាត់ជាបញ្ញាដែលក្រៃលែង ។ ព្រោះថា សីល ៥ និងសីល ១០ រមែងមានក្នុងពុទ្ធុប្បាទកាល

សូម្បីមិនទាន់កើតឡើង ព្រោះហេតុនោះ សីល ៥ សីល ១០ ទើបគង់ជាសីលនោះឯង ។ បាតិមោក្ខសំវរសីល រមែងមានចំពោះតែក្នុងពុទ្ធុប្បាទកាលប៉ុណ្ណោះ ព្រោះហេតុនោះ ទើបបាតិមោក្ខសំវរៈ ចាត់ជាសីលដែលក្រៃលែង ។ សូម្បីក្នុងចិត្ត និងបញ្ញាក៏ន័យនេះដូចគ្នា ។ ម្យ៉ាងទៀត សីល ៥ក្តី សីល ១០ក្តី ដែលបុគ្គលប្រាថ្នាព្រះនិព្វាន សមាទានហើយ ចាត់ជាសីលដែលក្រៃលែងដូចគ្នា សូម្បីសមាបត្តិ ៨ ដែលបុគ្គលចម្រើនហើយ ក៏ចាត់ជាចិត្តដែលក្រៃលែងដូចគ្នា ។ ឬថា លោកិយសីលទាំងអស់ ជាសីលប៉ុណ្ណោះ ។ ( ចំណែក ) លោកុត្តរសីល ជាសីលដែលក្រៃលែង ។ សូម្បីក្នុងចិត្ត និងបញ្ញាក៏មានន័យនេះដូចគ្នា ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងភាវនាតទៅ កាយដែលប្រព្រឹត្តទៅក្នុងទ្វារ ៥ របស់ព្រះខីណាស្រព ឈ្មោះថា កាយភាវនា ។ សមាបត្តិ ៨ ឈ្មោះថា ចិត្តភាវនា ។ បញ្ញាក្នុងអរហត្តផល ឈ្មោះថា បញ្ញាភាវនា ។ ព្រះខីណាស្រពរមែងជាអ្នកអប់រំកាយ ដែលប្រព្រឹត្តទៅក្នុងទ្វារ ៥ មកល្អហើយ ដោយចំណែកតែមួយ ។ សមាបត្តិ ៨ របស់លោកក៏មិនទុព្វលដូចរបស់អ្នកដទៃ ។ និងបញ្ញារបស់លោកប៉ុណ្ណោះ ឈ្មោះថា អប់រំហើយ ព្រោះដល់សេចក្តីបរិបូណ៌ដោយបញ្ញា ។ ព្រោះដូច្នោះ ទើបខ្ញុំពោលយ៉ាងនេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងអនុត្តរិយៈតទៅ ។ វិបស្សនាចាត់ជាទស្សនានុត្តរិយៈ មគ្គចាត់ជាបដិបទានុត្តរិយៈ ផលចាត់ជាវិមុត្តានុត្តរិយៈ ។ ឬថា ផលជាទស្សនានុត្តរិយៈ មគ្គជាបដិបទានុត្តរិយៈ និព្វានជាវិមុត្តានុត្តរិយៈ ។ ឬថា និព្វានចាត់ជាទស្សនានុត្តរិយៈ ព្រោះថា ធម្មតាវត្ថុដែលនឹងគប្បីឃើញដ៏ក្រៃលែងជាងព្រះ

និព្វាននោះ រមែងមិនមាន មគ្គចាត់ជាបដិបទានុត្តរិយៈ ផលចាត់ជាវិមុត្តានុត្តរិយៈ ។ ពាក្យថា **អនុត្តរិយំ** ប្រែថា ប្រសើរបំផុត គឺចម្រើនបំផុត ។

គប្បីជ្រាបវិនិច្ឆ័យក្នុងសមាធិតទៅ ។ សមាធិក្នុងបឋមជ្ឈាន មានទាំងវិតក្ក និងវិចារៈ ។ ដោយបញ្ចកន័យ សមាធិក្នុងទុតិយជ្ឈាន មិនមានវិតក្ក មានតែវិចារៈ ។ សមាធិដ៏សេស ( ចាកសមាធិក្នុងទុតិយជ្ឈាន ) មិនមានទាំងវិតក្ក និងវិចារៈ ។ កថាក្នុងសុតៈជាដើម មាន ៣ យ៉ាង គឺដោយការសម្រេចដោយគុណរបស់ខ្លួន ដោយអារម្មណ៍ ។ ភិក្ខុមួយ រូបកាន់យកដោយសភាពជាអនត្តា ឃើញដោយសភាពជាអនត្តា រមែងចេញចាក ( គឺរួចផុត ) ដោយភាពជាអនត្តា ឈ្មោះថា ( សុតៈ ) ដោយសេចក្តីសម្រេច ។ វិបស្សនារបស់លោកឈ្មោះថា ជាសុតៈ ។ ព្រោះហេតុអ្វី ។ ព្រោះកិលេសធ្វើមិនឲ្យជាសុញ្ញតៈមិនមាន ។ មគ្គសមាធិ ឈ្មោះថា ជាសុញ្ញតៈ ព្រោះសម្រេចដោយវិបស្សនា ផលសមាធិ ឈ្មោះថា ជាសុញ្ញតៈ ព្រោះសម្រេចដោយមគ្គ ។ ភិក្ខុរូបដទៃទៀត កាន់យកដោយភាពជារបស់មិនទៀង ឃើញដោយភាពជារបស់មិនទៀង ហើយចេញចាកដោយភាពជារបស់មិនទៀង ។ វិបស្សនារបស់លោក ឈ្មោះថា អនិមិត្ត ។ ព្រោះហេតុអ្វី ។ ព្រោះមិនមានកិលេសដែលធ្វើជានិមិត្ត ។ មគ្គសមាធិ ឈ្មោះថា ជាអនិមិត្ត ព្រោះសម្រេចដោយវិបស្សនា ផល ឈ្មោះថា អនិមិត្ត ព្រោះសម្រេចដោយមគ្គ ។ ភិក្ខុរូបដទៃទៀត កាន់យកដោយភាពជាទុក្ខ ឃើញដោយភាពជាទុក្ខ ហើយចេញចាក ( រួចផុត ) ដោយភាពជាទុក្ខ ។ វិបស្សនារបស់លោកឈ្មោះថា ជាអប្បណិហិត រកទីតាំងមិនបាន ។ ព្រោះហេតុអ្វី ។ ព្រោះមិនមានកិលេសដែលធ្វើជាបណិធិ ។ មគ្គសមាធិ

ឈ្មោះថា ជាអប្បណិហិត ព្រោះសម្រេចដោយវិបស្សនា ផល ឈ្មោះថា អប្បណិហិត ព្រោះសម្រេចដោយមគ្គ ។ កថាដោយសេចក្ដីសម្រេចមានដូចដែលពណ៌នាមកនេះឯង ។ មគ្គសមាធិ ឈ្មោះថា សុញ្ញត ព្រោះសូន្យចាករាគៈជាដើម ឈ្មោះថា អនិមិត្ត ព្រោះមិនមានរាគៈជានិមិត្តជាដើម ឈ្មោះថា អប្បណិហិត ព្រោះមិនមានរាគៈជាទីតាំងអាស្រ័យជាដើម ។ កថាដោយគុណរបស់ខ្លួន មានដូចដែលពណ៌នាមកនេះឯង ។ ព្រះនិព្វាន ឈ្មោះថា សុញ្ញត អនិមិត្ត និងអប្បណិហិត ព្រោះសូន្យចាករាគៈ និងព្រោះមិនមានរាគៈជាដើមជាគ្រឿងសម្គាល់ និងជាទីតាំងអាស្រ័យ ។ មគ្គសមាធិ ដែលមាននិព្វាននោះជាអារម្មណ៍ ទើបជាសុញ្ញត អនិមិត្ត អប្បណិហិត ។ កថាពោលអំពីអារម្មណ៍មានត្រឹមតែប៉ុណ្ណេះ ។ ធម៌ដែលធ្វើសេចក្ដីស្អាត គឺបដិបទានៃសេចក្ដីស្អាត ឈ្មោះថា **សោចេយ្យានិ** ។ ក្នុងប្រការដែលពោលអំពីសេចក្ដីស្អាតនេះ គប្បីជ្រាបសេចក្ដីពិស្ដារដោយអំណាចសុចរិត ៣ ដែលត្រាស់ទុកដោយន័យមានអាទិដូច្នេះថា ក្នុងសេចក្ដីស្អាត ៣ យ៉ាងនោះ សេចក្ដីស្អាតផ្លូវកាយដូចម្ដេច ។ គឺចេតនាជាគ្រឿងវៀរចាកបាណាតិបាត ។

ធម៌ដែលធ្វើភាពជាមុនី បានដល់ មោនេយ្យបដិបទា ឈ្មោះថា **មោនេយ្យានិ** ។ សេចក្ដីពិស្ដារនៃធម៌ដែលធ្វើភាពជាមុនីទាំងនោះ ដូច្នេះថា ក្នុងភាពជាមុនីទាំងនោះ ភាពជាមុនីផ្លូវកាយ ដូចម្ដេច ។ គឺការលះកាយទុច្ចរិត ៣ យ៉ាង ជាកាយមោនេយ្យ កាយសុចរិត ៣ យ៉ាង ជាកាយមោនេយ្យ ញាណមានកាយជាអារម្មណ៍ ជាកាយមោនេយ្យ មគ្គដែលសហគតៈដោយការកំណត់ដឹង

កាយ ជាកាយមោនេយ្យ ការលះឆន្ទរាគៈក្នុងកាយ ជាកាយមោនេយ្យ ការចូលចតុត្ថជ្ឈានដែលរលត់ចាកកាយសង្ខារ ជាកាយមោនេយ្យ ក្នុងភាពជាមុនីទាំងនោះ ភាពជាមុនី ផ្លូវវាចា ដូចម្តេច ។ ការលះវចីទុច្ចរិត ៤ ជាវចីមោនេយ្យ វចីសុចរិត ៤ ញាណមានវាចាជាអារម្មណ៍ មគ្គដែលសហគតៈដោយការកំណត់ដឹងវាចា ការលះឆន្ទរាគៈក្នុងវាចា ការចូលទុតិយជ្ឈាន ដែលរលត់នូវវចីសង្ខារ ជាវចីមោនេយ្យ ។ ក្នុងភាពជាមុនីទាំងនោះ ភាពជាមុនីផ្លូវចិត្ត ដូចម្តេច ។ ការលះមនោទុច្ចរិត ៣ ជាមនោមោនេយ្យ មនោសុចរិត ៣ ញាណមានចិត្តជាអារម្មណ៍ មគ្គដែលសហគតៈដោយការកំណត់ដឹងចិត្ត ការលះឆន្ទរាគៈក្នុងចិត្ត ការចូលសញ្ញាវេទយិតនិរោធសមាបត្តិ ដែលរលត់ចិត្តសង្ខារ ជាមនោមោនេយ្យ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងភាពជាអ្នកឈ្លាសតទៅ ។ សេចក្តីចម្រើន ឈ្មោះថា **អាយ** ។ សេចក្តីមិនចម្រើនឈ្មោះថា **អបាយ** ។ ហេតុនៃសេចក្តីចម្រើន និងមិនចម្រើននោះៗ ជាឧបាយ ។ សេចក្តីដឹងទូទៅដល់សេចក្តីចម្រើន សេចក្តីមិនចម្រើន និងហេតុនៃសេចក្តីចម្រើន និងមិនចម្រើនទាំងនោះ ជាសេចក្តីឈ្លាស ។ សេចក្តីពិស្តារត្រាស់ក្នុងវិភង្គនោះឯង ។ សមពិត ដូចដែលត្រាស់ថា ក្នុងសេចក្តីឈ្លាសទាំងនោះ សេចក្តីឈ្លាសក្នុងសេចក្តីចម្រើន ដូចម្តេច ? បញ្ញា សេចក្តីដឹងទូទៅ ។លៗ សេចក្តីឃើញប្រពៃក្នុងសេចក្តីចម្រើននោះយ៉ាងនេះថា កាលយើងមនសិការដល់ធម៌ទាំងនេះ អកុសលធម៌ដែលមិនទាន់កើត រមែងមិនកើតឡើង និងអកុសលធម៌ដែលកើតឡើងហើយ រមែងរលត់ទៅ ឬក៏ថា កាលយើងមនសិការដល់ធម៌ទាំងនេះ កុសលធម៌ដែលមិនទាន់

កើត រមែងកើតឡើង និងកុសលធម៌ដែលកើតឡើងហើយ រមែងប្រព្រឹត្តទៅ ដើម្បីជាកិយ្យោភាព ដើម្បីសេចក្តីធំទូលាយ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីបរិបូណ៌ នេះហៅថា ភាពជាអ្នកឈ្លាសក្នុងសេចក្តីចម្រើន ។ ក្នុងសេចក្តីឈ្លាសទាំងនោះ សេចក្តីឈ្លាសក្នុងសេចក្តីមិនចម្រើនដូចម្តេច ។ បញ្ញា សេចក្តីដឹងទូទៅ ។ល។ សេចក្តីឃើញប្រពៃក្នុងសេចក្តីមិនចម្រើននោះ យ៉ាងនេះថា កាលយើងមនសិការដល់ធម៌ទាំងនេះ កុសលធម៌ដែលមិនទាន់កើត រមែងមិនកើត និងកុសលដែលកើតហើយ រមែងរលត់ទៅ ឬក៏ថា កាលយើងមនសិការដល់ធម៌ទាំងនេះ អកុសលធម៌ ដែលមិនទាន់កើត រមែងកើតឡើង និងអកុសលធម៌ដែលកើតឡើងហើយ រមែងប្រព្រឹត្តទៅដើម្បីកិយ្យោភាព ដើម្បីសេចក្តីធំទូលាយ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីបរិបូណ៌ នេះហៅថា ភាពជាអ្នកឈ្លាសក្នុងសេចក្តីមិនចម្រើន ។ បញ្ញាដែលជាឧបាយក្នុងសេចក្តីចម្រើន និងសេចក្តីមិនចម្រើននោះ សូម្បីទាំងអស់ ជាភាពឈ្លាសក្នុងឧបាយ ដូច្នេះ ។ សេចក្តីឈ្លាសក្នុងឧបាយនេះ គប្បីជ្រាបដោយអំណាចការដឹងហេតុនៃឋានៈដែលកើតឡើង ដើម្បីដោះស្រាយកិច្ចបន្ទាន់ភ្លាមៗ ឬភ័យនោះ ក្នុងពេលដែលកិច្ចបន្ទាន់ភ្លាមៗ ឬភ័យកើតឡើង ។

បទថា **មធា** សេចក្តីថា ប្រព្រឹត្តទៅដោយអំណាចនៃអាការស្រើង ។ក្នុងបណ្តាសេចក្តីស្រើងទាំងនោះ ការធ្វើមានះយ៉ាងនេះថា យើងជាអ្នកមិនមានរោគតាំងនៅ ៦០ ឬ ៧០ ឆ្នាំកន្លងទៅហើយ សូម្បីតែចំណិតសម៉ យើងមិនទាន់ធ្លាប់ទំពាស៊ី ចំណែកអ្នកដទៃទាំងនេះ ដើរនិយាយថា ពួកយើងនឹងទំពាស៊ីថ្នាំអ្នកដទៃណាឈ្មោះថា ជាអ្នកមិនមានរោគដូចយើង ដូច្នេះ ឈ្មោះថា សេចក្តី

ស្រវឹងក្នុងភាពជាអ្នកមិនមានរោគ ។ ការដែលនៅក្នុងភាពជាកំលោះក្រមុំ ហើយធ្វើមានះថា ពួកយើងនឹងធ្វើបុណ្យក្នុងវេលាចាស់ វេលានេះនៅជាកំលោះក្រមុំ ដូច្នេះ ឈ្មោះថា ស្រវឹងក្នុងភាពជាកំលោះក្រមុំ ។ ការធ្វើមានះយ៉ាងនេះថា យើងរស់នៅមកយូរហើយ រស់នៅបានយូរហើយ នឹងរស់នៅយូរតទៅទៀត យើងរស់នៅជាសុខមកហើយ កំពុងរស់នៅជាសុខ នឹងរស់នៅជាសុខ ( តទៅ ) ដូច្នេះ ឈ្មោះថា ស្រវឹងក្នុងជីវិត ។

គប្បីជ្រាបវិនិច្ឆ័យក្នុងភាពជាធំតទៅ ។ គុណជាតិដែលមកហើយ ចាកភាពជាធំ ឈ្មោះថា **អាធិបតេយ្យ** ។ ការធ្វើខ្លួនឲ្យជាធំ គឺឲ្យជាប្រធាន យ៉ាងនេះថា យើងជាអ្នកប្រកបដោយសីល សមាធិ បញ្ញា វិមុត្តិ ប្រការនោះមិនគួរដល់យើង ដូច្នេះហើយ មិនធ្វើសេចក្តីអាក្រក់ ឈ្មោះថា **អត្តាធិបតេយ្យ** ។ ការធ្វើមនុស្សលោកឲ្យជាធំ មិនធ្វើសេចក្តីអាក្រក់ ឈ្មោះថា **លោកាធិប-តេយ្យ** ។ ការធ្វើលោកុត្តរធម៌ឲ្យជាធំ ហើយមិនធ្វើសេចក្តីអាក្រក់ ឈ្មោះថា **ធម្មាធិបតេយ្យ** ។ ហេតុនៃការពោលពាក្យ ឈ្មោះថា **កថាវត្ថុ** ។ ពីរបទថា **អតីតំ វា អទ្ធានំ** ប្រែថា គតិធម៌ ដែលកន្លងទៅហើយ អធិប្បាយថា ខន្ធដែលជាអតីត ។ ម្យ៉ាងទៀត គប្បីសម្តែងសេចក្តីក្នុងពាក្យថា **អតីតំ វា អទ្ធានំ** នេះ ដោយនិរុត្តិបថសូត្រ ( សូត្រដែលពោលអំពីគោលភាសា ) ដែលមានមកយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ រូបណាកន្លងទៅហើយ រលត់ទៅហើយ ប្រែប្រួលទៅហើយ ដែលរាប់នូវរូបនោះថា បានមានហើយ ការបញ្ញត្តិរូបនោះថា បានមានហើយ ការឲ្យឈ្មោះរូបនោះថា បានមានហើយ រូបនោះ

មិនរាប់ថា នឹងមាន រូបនោះមិនរាប់ថា មានហើយ ។ បទថា **វិជ្ជា** សេចក្ដីថា ឈ្មោះថា វិជ្ជា ព្រោះអត្ថថា ចាក់ធ្លុះសេចក្ដីវង្វេង ។ ឈ្មោះថា វិជ្ជា ព្រោះអត្ថថា ធ្វើឲ្យដឹងច្បាស់ក៏បាន ។ បុព្វេនិវាសានុស្សតិញ្ញាណ ដែលកើតឡើង ឈ្មោះថា វិជ្ជា ព្រោះអត្ថថា ទម្លាយសេចក្ដីងងឹតដែលបិទបាំងខន្ធ ដែលធ្លាប់អាស្រ័យនៅក្នុងកាលមុន និងធ្វើខន្ធដែលធ្លាប់អាស្រ័យនៅក្នុងកាលមុន ឲ្យដឹងច្បាស់ ។ ចុតូបបាតញ្ញាណ ឈ្មោះថា វិជ្ជា ព្រោះអត្ថថា ទម្លាយសេចក្ដីងងឹតដែលបិទបាំងចុតិ និងបដិសន្ធិ ធ្វើចុតិ និងបដិសន្ធិនោះ ឲ្យដឹងច្បាស់ ។ ញាណ សេចក្ដីដឹងក្នុងការអស់អាសវៈទាំងឡាយ ឈ្មោះថា វិជ្ជា ព្រោះអត្ថថា ទម្លាយសេចក្ដីងងឹតដែលបិទបាំងសច្ចៈ ៤ និងធ្វើសច្ចធម៌ទាំង ៤ ឲ្យដឹងច្បាស់ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងវិហារធម៌តទៅ ។ សមាបត្តិ ៨ ឈ្មោះថា **ទិព្វវិហារធម៌** ។ អប្បមញ្ញា ៤ ឈ្មោះថា ព្រហ្មវិហារធម៌ ។ ផលសមាបត្តិ ឈ្មោះថា អរិយវិហារធម៌ ។ បាដិហារ្យទាំងឡាយ ទ្រង់ឲ្យពិស្ដារហើយក្នុងកេវដ្ដសូត្រ ។

ក្នុងពាក្យថា **ឥមេ ខោ អាវុសោ** ដូច្នេះជាដើម គប្បីប្រកបដោយន័យដូចពោលហើយនុ៎ះឯង ។ ព្រះថេរៈកាលពោលបញ្ហា ១៨០ ប្រការ ដោយអំណាចតិកៈ ៦០ គត់ ទើបបានសម្ដែងសាមគ្គីរសដោយប្រការ ដូច្នេះឯង ។

**ពួក ៣ ចប់**

## ពោលអំពីធម៌ពួក ៤

[ ១០០ ] ព្រះថេរៈគ្រាសម្តែងសាមគ្គីរស ដោយអំណាចពួក ៣ ដោយប្រការដូច្នេះហើយ ឥឡូវនេះប្រាថ្នានឹងសម្តែងដោយអំណាចពួក ៤ ទើបផ្តើមទេសនាទៀត ។ បណ្តាពួកទាំង ៤ នោះ ពួក ៤ ពោលដោយសតិប្បដ្ឋាន លោកឲ្យពិស្តារហើយក្នុងខាងដើមនុ៎ះឯង ។

[ ១០១ ] គប្បីជ្រាបអធិប្បាយក្នុងពួក ៤ ពោលដោយសម្មប្បធាន ។ ប្រការថា **ឆន្ទំ ជនេតិ** សេចក្តីថា ឲ្យកើតកត្តុកម្យតាឆន្ទៈ ដែលលោកពោលយ៉ាងនេះថា សេចក្តីពេញចិត្ត ភាពជាអ្នកមានសេចក្តីពេញចិត្ត ភាពជាអ្នកប្រាថ្នានឹងធ្វើយ៉ាងណា នោះចាត់ជាកុសល គឺភាពជាអ្នកមានសេចក្តីពេញចិត្តក្នុងធម៌ ។ ប្រការថា **វាយមតិ** សេចក្តីថា ធ្វើសេចក្តីព្យាយាម ។ ប្រការថា **វិរិយំ អារព្ភតិ** សេចក្តីថា ធ្វើសេចក្តីព្យាយាមឲ្យកើតឡើង ។

ប្រការថា **ចិត្តំ បគ្គណ្ហាតិ** សេចក្តីថា ឧបត្ថម្ភចិត្តទុក ។ នេះជាសេចក្តីសង្ខេបក្នុងទីនេះ ។

ចំណែកសេចក្តីពិស្តារ មកហើយក្នុងសម្មប្បធានវិភង្គនុ៎ះឯង ។

[ ១០២ ] ក្នុងឥទ្ធិបាទទាំងឡាយ គប្បីជ្រាបអធិប្បាយដូច្នេះ សមាធិដែលអាស្រ័យឆន្ទៈប្រព្រឹត្តទៅ ឈ្មោះថា **ឆន្ទសមាធិ** ។ សង្ខារទាំងឡាយដែលជាប្រធាន ឈ្មោះថា **បធានសង្ខារ** ។ ប្រការថា **សមន្នាគតំ** សេចក្តីថា ចូលដល់ហើយដោយធម៌ទាំងនេះ ។ បាទនៃឫទ្ធិ ឬផ្លូវដែលជាគ្រឿងឲ្យដល់នូវសេចក្តីសម្រេច ព្រោះហេតុនោះ ទើបឈ្មោះថា **ឥទ្ធិបាទ** ។

សូម្បីក្នុងឥទ្ធិបាទប្រការដ៏សេស ក៏ន័យនោះដូចគ្នា ។ នេះជាសេចក្តីសង្ខេបក្នុងទីនេះ ។ ចំណែកសេចក្តីពិស្តារមកហើយ ក្នុងឥទ្ធិបាទវិភង្គនុ៎ះឯង ។

ចំណែកសេចក្ដីរបស់ឥទ្ធិបាទនោះ លោកសម្ដែងហើយក្នុងវិសុទ្ធិមគ្គ ។

[ ១០៣ ] កថាពោលអំពីឈាន លោកឲ្យពិស្ដារហើយ ក្នុងវិសុទ្ធិមគ្គ ដូចគ្នា ។

[ ១០៤ ] ប្រការថា **ទិដ្ឋធម្មសុខវិហារាយ** សេចក្ដីថា ដើម្បីប្រយោជន៍ដល់ការនៅសប្បាយក្នុងអត្តភាពនេះឯង ។ ផលសមាបត្តិ និងឈាន ដែលព្រះខីណាស្រពឲ្យកើតឡើងហើយ ក្នុងវេលាតមក លោកពោលក្នុងទីនេះ ។ ប្រការថា **អាលោកសញ្ញំ មនសិករោតិ** សេចក្ដីថា ធ្វើទុកក្នុងចិត្តដល់ពន្លឺមានពន្លឺព្រះអាទិត្យ ព្រះចន្ទ និងកែវមណីជាដើម ទាំងពេលថ្ងៃ ឬពេលយប់ ថា **អាលោកោ** ដូច្នេះ ។

ប្រការថា **ទិវាសញ្ញំ អធិដ្ឋាតិ** សេចក្ដីថា លុះមនសិការយ៉ាងនេះហើយ ក៏តាំងសញ្ញាថា ពេលថ្ងៃ ដូច្នេះ ។ ប្រការថា **យថា ទិវា តថា រត្តឹ** សេចក្ដីថា ឃើញពន្លឺក្នុងពេលថ្ងៃយ៉ាងណា ក្នុងពេលយប់ក៏មនសិការយ៉ាងនោះ ។ ប្រការថា **យថា រត្តឹ តថា ទិវា** សេចក្ដីថា ឃើញពន្លឺក្នុងពេលយប់យ៉ាងណា ក្នុងពេលថ្ងៃ ក៏មនសិការទៅយ៉ាងនោះដែរ ។ ប្រការថា **ឥតិ វិវដេន ចេតសា** សេចក្ដីថា មានចិត្តដែលបើកហើយយ៉ាងនេះ ។ ប្រការថា **អបរិយោនទ្ធេន** សេចក្ដីថា មិនត្រូវចងរឹតដោយជុំវិញ ។ ប្រការថា **សប្បភាសំ** សេចក្ដីថា ប្រព្រឹត្តទៅជាមួយនឹងពន្លឺ ។ ប្រការថា **ញាណទស្សនបដិលាភាយ** សេចក្ដីថា ដើម្បីប្រយោជន៍ដល់ការបានញាណទស្សនៈ ។ លោកពោលអ្វីដោយពាក្យនេះ ។ លោកពោលដល់ពន្លឺ ដែលជាគ្រឿងបន្ទោបង់ថីនមិទ្ធៈ ឬពន្លឺក្នុងបរិកម្ម ។ សូម្បីដោយពាក្យនេះ លោកពោលដល់អ្វី ។ ជាប្រការដែល

លោកពោលដល់ទិព្វចក្ខុញ្ញាណរបស់ព្រះខីណាស្រព ។ម្យ៉ាងវិញទៀត កាល ទិព្វចក្ខុញ្ញាណនោះ មកហើយក៏ដោយ មិនទាន់មកក៏ដោយ លោកសំដៅដល់ សមាបត្តិដែលមានឈានជាបាទទ្រនុះឯង ទើបពោលពាក្យថា ញុំាងចិត្តដែល មានពន្លឺឲ្យកើតមានឡើង ។

ប្រការថា **សតិសម្បជញ្ញាយ** ដើម្បីសតិ និងសម្បជញ្ញៈ សេចក្តីថា ដើម្បី ប្រយោជន៍ដល់សតិសម្បជញ្ញៈ ដែលមានសត្វជាទីតាំង ។ ក្នុងប្រការថា **វិទិតា វេទនា ឧប្បជ្ជន្តិ** ជាដើម សេចក្តីថា វត្ថុដែលព្រះខីណាស្រពដឹងហើយ អារម្មណ៍ ក៏ជាការដឹងហើយ វេទនាទាំងឡាយរមែងកើតឡើងយ៉ាងនេះ រមែងតាំងនៅ យ៉ាងនេះ រមែងរលត់ទៅយ៉ាងនេះ ព្រោះដឹងទាំងវត្ថុ និងអារម្មណ៍ ។ មិនចំពោះ វេទនាតែម្យ៉ាងប៉ុណ្ណោះ លោកពោលក្នុងទីនេះ សូម្បីសញ្ញាជាដើម ក៏ជាការ ដឹងច្បាស់ហើយ រមែងកើតឡើង រមែងតាំងនៅ និងរមែងរលត់ទៅ ។

ម្យ៉ាងទៀត ការកើតឡើងនៃវេទនា ក៏គឺលោកដឹងហើយ ការតាំងនៅ ក៏គឺលោកដឹងហើយ ។ ភិក្ខុសូម្បីកាលឃើញលក្ខណៈនៃការកើតឡើងថា ព្រោះ អវិជ្ជាកើត ទើបវេទនាកើត ព្រោះតណ្ហាកើត ព្រោះកម្មកើត ព្រោះផស្សៈកើត ទើបវេទនាកើត ឈ្មោះថា រមែងឃើញការកើតរបស់វេទនាខន្ធ ។ ការកើតឡើង នៃវេទនា រមែងជាការដែលលោកជ្រាបហើយយ៉ាងនេះ ។ លោកជ្រាបដល់ ការតាំងនៅនៃវេទនាយ៉ាងណា ។ កាលលោកមនសិការ ដោយភាពជារបស់ មិនទៀង ក៏រមែងជាការជ្រាបដល់ការតាំងនៅដោយសភាពជារបស់អស់ទៅ ។ កាលមនសិការដោយសេចក្តីជាទុក្ខ រមែងជ្រាបដល់ការតាំងនៅដោយសភាព ជារបស់គួរខ្លាច ។

កាលមនសិការដោយភាពជាអនត្តា ក៏រមែងជ្រាបដល់ការតាំងនៅដោយភាពជារបស់សូន្យ ។ សេចក្តីតាំងនៅនៃវេទនា ជាការដែលលោកជ្រាបហើយយ៉ាងនេះ ។ លោករមែងដឹងដោយសភាពជារបស់អស់ទៅ ដោយសភាពជារបស់គួរខ្លាច ដោយសភាពជារបស់សូន្យ ។ សេចក្តីតាំងនៅមិនបាននៃវេទនាជាការដែលលោកជ្រាបហើយយ៉ាងណា ។ការតាំងនៅមិនបាននៃវេទនា រមែងមានយ៉ាងនេះថា ព្រោះអវិជ្ជារលត់ ទើបវេទនារលត់ ។ល។ ដូច្នេះ ។ ក្នុងសេចក្តីនេះ បណ្ឌិតគប្បីជ្រាបសេចក្តីតាមន័យនេះ ។ ពាក្យថា **រូបំ** ជាដើម មានន័យដូចពោលហើយទុំះឯង ដោយប្រការដូច្នេះ ។

ប្រការថា **អយំ អាវុសោ សមាធិភាវនា** សេចក្តីថា សមាធិភាវនាដែលមានឈានជាបាទនេះ រមែងមានដល់ញាណជាគ្រឿងដឹងដល់ការអស់អាសវៈ ។

[ ១០៥ ] ពាក្យថា **អប្បមញ្ញា** សេចក្តីថា អប្បមញ្ញាដោយអំណាចការកាន់យកប្រមាណមិនបានផ្សាយទូទៅ ។ ទស្សនការនា និងវិធីនៃសមាធិ ដែលពណ៌នាទៅតាមលំដាប់បទនៃអប្បមញ្ញាទាំងនោះ លោកឲ្យពិស្តារហើយនៅក្នុងវិសុទ្ធិមគ្គទុំះឯង ។

[ ១០៦ ] សូម្បីកថាពោលអំពីអរូប ( ឈាន ) លោកក៏ឲ្យពិស្តារហើយក្នុងវិសុទ្ធិមគ្គទុំះឯង ។

[ ១០៧ ] ប្រការថា **អបស្សេនានិ** សេចក្តីថា ដែលសម្រាប់ពឹង ។ ប្រការថា **សំខាយ** សេចក្តីថា ដោយញាណ ។ ប្រការថា **បដិសេវតិ** សេចក្តីថា ភិក្ខុដឹងដោយញាណហើយ រមែងសេពចំពោះរបស់ដែលគួរសេពបាន

ប៉ុណ្ណោះ ។ សេចក្ដីពិស្ដារនៃការសេពនោះ គប្បីជ្រាបដោយន័យមានអាទិថា ភិក្ខុពិចារណាដោយប្រពៃហើយ ទើបសេពចីវរ ។ បទថា **សំខាយេកំ អធិ-វាសេតិ** សេចក្ដីថា ភិក្ខុដឹងដោយញាណហើយ រមែងអត់ទ្រាំក្នុងអារម្មណ៍ដែលគួរនឹងអត់ទ្រាំបាននុ៎ះឯង ។ ក្នុងសេចក្ដីនេះ គប្បីជ្រាបសេចក្ដីពិស្ដារដោយន័យជាដើមថា ភិក្ខុពិចារណាដោយឧបាយនៃប្រាជ្ញាហើយ រមែងជាអ្នកអត់ធន់ចំពោះភាពត្រជាក់បាន ។ ប្រការថា **បរិវជ្ជេតិ** សេចក្ដីថា ភិក្ខុដឹងដោយញាណហើយ រមែងវៀរវត្ថុដែលគួរដើម្បីវៀរនុ៎ះឯង ។ សេចក្ដីពិស្ដារនៃការវៀរនោះ គប្បីជ្រាបដោយន័យមានជាអាទិថា ភិក្ខុពិចារណាដោយឧបាយនៃប្រាជ្ញាហើយ រមែងដូចជាការគេចចេញពីដំរីកាច ។ ប្រការថា **វិនោទេតិ** សេចក្ដីថា ភិក្ខុដឹងដោយញាណហើយ រមែងបន្ទោបង់វត្ថុគួរបន្ទោបង់នុ៎ះឯង គឺដកចេញ នាំចេញ មិនឲ្យនៅខាងក្នុង ។ សេចក្ដីពិស្ដារនៃការបន្ទោបង់នោះ គប្បីជ្រាបដោយន័យមានជាអាទិថា ភិក្ខុអត់ទ្រាំដល់កាមវិតក្កដែលកើតឡើងមិនបាន ដូច្នេះ ។

[ ១០៨ ] ប្រការថា **អរិយវំសា** សេចក្ដីថា វង្សរបស់ព្រះអរិយៈ ។ ដូចជាវង្សក្សត្រ វង្សព្រាហ្មណ៍ វង្សវេស្សៈ វង្សសូទ្រៈ វង្សសមណៈ វង្សត្រកូល វង្សព្រះរាជា យ៉ាងណា វង្សព្រះអរិយៈ បែបផែនព្រះអរិយៈទី ៨ នេះ ក៏ឈ្មោះថា ប្រពៃណីរបស់ព្រះអរិយៈ ដូច្នោះ ។ អរិយវង្សនេះឯង លោកពោលថា ប្រសើរជាងវង្សទាំងនោះ ដូចក្លិន មានក្លិនឈើទេព្សរូជាដើម ជាកំពូលលើសក្លិនដែលកើតពីឫសជាដើម ដូច្នោះ ។ វង្សទាំងនោះ មានដល់ព្រះអរិយៈណា ព្រះអរិយៈទាំងនោះ បានដល់ បុគ្គលណា បានដល់ ព្រះពុទ្ធ

ព្រះបច្ចេកពុទ្ធ និងព្រះសាវ័ករបស់ព្រះពុទ្ធ ដែលលោកហៅថា ព្រះអរិយៈ ។ វង្សរបស់ព្រះអរិយៈទាំងនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **អរិយវំសោ** ។ ពិតហើយ ក្នុងកាលមុននេះ មានព្រះពុទ្ធ ៤ អង្គ គឺព្រះពុទ្ធតណ្ហង្ករ ព្រះពុទ្ធមេធង្ករ ព្រះពុទ្ធសរណង្ករ ព្រះពុទ្ធទីបង្ករ ទ្រង់ឧប្បត្តិកឡើងហើយក្នុងទីបំផុត ៤ អសង្ខេយ្យ និងសែនកប្ប ព្រះពុទ្ធទាំងនោះ ឈ្មោះថា ព្រះអរិយវង្ស របស់ព្រះអរិយៈទាំងនោះ ព្រោះហេតុនោះ ទើបឈ្មោះថា អរិយវង្ស ។ ក្នុងកាលតមក អំពីបរិនិព្វានរបស់ព្រះពុទ្ធទាំងនោះ កន្លងទៅមួយអសង្ខេយ្យ ព្រះពុទ្ធព្រះនាមថាកោណ្ឌញ្ញៈ ទ្រង់ឧប្បត្តិកឡើងហើយ ។ល។ ក្នុងកប្បនេះ មានព្រះពុទ្ធកើតឡើង ៤ អង្គ គឺព្រះកកុសន្ធៈ ព្រះកោនាគមនៈ ព្រះកស្សបៈ ព្រះមានព្រះភាគរបស់ពួកយើងព្រះនាមថាគោតម វង្សរបស់ព្រះអរិយៈទាំងនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **អរិយវំសោ** ។ ម្យ៉ាងទៀត វង្សរបស់ព្រះអរិយៈ គឺព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងសាវ័ករបស់ព្រះពុទ្ធទាំងអស់ ទាំងក្នុងអតីត អនាគត និងបច្ចុប្បន្ន ព្រោះហេតុនោះ ទើបឈ្មោះថា **អរិយវំសោ** ។ ក៏អរិយវង្សទាំងនោះឯង គប្បីជ្រាបថា ជាវង្សថ្នាក់កំពូល ព្រោះបានដឹងថា ជាវង្សដែលខ្ពង់ខ្ពស់ គប្បីជ្រាបថា ប្រព្រឹត្តទៅរហូតដល់អស់កាលយូរ ព្រោះដឹងមកយូរ គប្បីជ្រាបថា ជាវង្ស ព្រោះដឹងថាជាវង្ស ។ ប្រការថា ជាវង្សចាស់ សេចក្តីថា មិនមែនទើបតែកើតឡើងឥឡូវនេះ ។

ប្រការថា មិនខ្ចាត់ខ្ចាយ សេចក្តីថា មិនរាត់រាយ គឺមិនត្រូវនាំចេញទៅ ។ ប្រការថា **អសង្កិណ្ណាបុព្វា** សេចក្តីថា ជាវង្សមិនធ្លាប់ត្រូវនាំចេញទៅ ព្រោះអត្ថថា ជាវង្សមិនធ្លាប់រាត់រាយ សូម្បីអតីតពុទ្ធទាំងឡាយនឹងរាត់រាយ ព្រះពុទ្ធ

ទាំងឡាយនេះបាន យ៉ាងណា ។ ប្រការថា **ន សត្ថិយន្តិ** សេចក្តីថា សូម្បីឥឡូវនេះ ក៏មិនបានត្រូវនាំចេញទៅ ។ ប្រការថា **ន សត្ថិយិស្សន្តិ** សេចក្តីថា សូម្បីព្រះពុទ្ធក្នុងអនាគតទាំងឡាយ ក៏នឹងមិននាំចេញទៅ ។ សមណៈ និងព្រាហ្មណ៍ដែលជាវិញ្ញូទាំងឡាយក្នុងលោក ក៏មិនត្រូវសមណៈ និងព្រាហ្មណ៍ដែលជាវិញ្ញូជនទាំងនោះ និន្ទាតិះដៀល ។

ប្រការថា **សន្តុដ្ឋោ ហោតិ** សេចក្តីថា ជាអ្នកសន្តោសដោយអំណាចសេចក្តីសន្តោសក្នុងបច្ច័យ ។ ប្រការថា **ឥតរីតរេន ចីវរេន** សេចក្តីថា ( ជាអ្នកសន្តោស ) ដោយបណ្តាចីវរ ដែលមានសាច់គ្រោតគ្រាត ល្អិត សៅហ្មង ប្រណីត រឹង ចាស់ ប្រភេទណាមួយ ក៏មិនមានដោយពិត ជាអ្នកសន្តោសដល់ចីវរ តាមដែលបានជាដើម ប្រភេទណាមួយតាមតែនឹងបាន ។ ក្នុងចីវរមានសន្តោស ៣ គឺសន្តោសតាមបាន សន្តោសតាមកម្លាំង សន្តោសតាមសមគួរ ។ សូម្បីក្នុងបិណ្ឌបាតជាដើម ក៏ន័យនោះដូចគ្នា ។ កថាដោយពិស្តារនៃសន្តោសទាំងនោះ គប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងសាមញ្ញផលសូត្រនោះឯង ។ ពាក្យថា ជាអ្នកសន្តោសដោយចីវរតាមដែលបានជាដើម ប្រភេទណាមួយ លោកពោលសំដៅយកសន្តោសទាំង ៣ នេះ ដោយប្រការដូច្នេះ ។ ក្នុងសេចក្តីនេះ គប្បីជ្រាបចីវរ គប្បីជ្រាបដែនខេត្រនៃចីវរ គប្បីជ្រាបបង្សុកូលចីវរ គប្បីជ្រាបសេចក្តីសន្តោសក្នុងចីវរ គប្បីជ្រាបធុតង្គដែលជាប់ទាក់ទងនឹងចីវរ ។

ប្រការថា **ចីវរំ ជានិតព្វំ** សេចក្តីថា គប្បីជ្រាបចីវរ ៦ ប្រភេទ មានសំពត់សម្បកឈើជាដើម អនុលោមចីវរ ៦ ប្រភេទ មានសំពត់បង្សុកូលជាដើម ចីវរទាំង ១២ ប្រភេទនេះ ឈ្មោះថា **កប្បិយចីវរ** ។ ចំណែកចីវរ មាន

ជាអាទិយ៉ាងនេះថា សំពត់ក្រងដោយស្បូវ សំពត់សម្បកឈើ សំពត់ត្បាញផែង សំពត់កម្ពលត្បាញដោយសក់មនុស្ស សំពត់កម្ពលត្បាញដោយរោមកន្ទុយសត្វ ស្បែកខ្លា ស្បែកសត្វ ស្លាបសត្វ សំពត់ដែលពាន់ដោយដើមឈើ សំពត់ដែលប្រើវល្លិក្រង សំពត់ដែលធ្វើដោយសម្បកដើមរំទេក សំពត់ដែលក្រងដោយស្រទបចេក សំពត់ដែលធ្វើដោយផ្កាឫស្សី ឈ្មោះថា **អកប្បិយ-ចីវរ** ( ចីវរដែលមិនសមគួរនឹងប្រើ ) ។

ប្រការថា **ចីវរក្ខេត្តំ** សេចក្តីថា ឈ្មោះថា ខេត្តមាន ៦ យ៉ាង ព្រោះកើតឡើងយ៉ាងនេះថា អំពីសង្ឃ អំពីគណៈ អំពីញាតិ អំពីមិត្រ អំពីទ្រព្យរបស់ខ្លួន ឬជាសំពត់បង្សុកូល ។ ចំណែកខេត្ត ៨ គប្បីជ្រាបដោយអំណាចមាតិកា ៨ ។

ប្រការថា **បំសុក្កូលំ** សេចក្តីថា គប្បីជ្រាបសំពត់បង្សុកូល ២៣ ប្រភេទ គឺ **សំពត់សោសានិក** សំពត់ដែលគេចោលក្នុងព្រៃស្មសាន ១ **សំពត់បាបណិក** សំពត់ដែលគេចោលនៅតាមផ្លូវចូលផ្សារ ១ **សំពត់រថិក** សំពត់ដែលគេចោលនៅតាមច្រកផ្លូវ ១ **សំពត់សង្ការចោឡក** សំពត់ដែលគេចោលក្នុងគំនរសំរាម ១ **សំពត់សោត្ថិយ** សំពត់ដែលគេប្រើជូតមន្ទិលគភ៌ហើយចោល ១ **សំពត់សិនាន** សំពត់ដែលគេផ្លាស់ងូតទឹកមន្តហើយចោល ១ **សំពត់តិត្ថ** សំពត់ដែលចោលនៅតាមកំពង់ទឹក ១ **សំពត់គតបច្ចាគត** សំពត់ដែលប្រើរុំសាកសព ក្នុងព្រៃស្មសានហើយនាំត្រឡប់មកចោល ១ **សំពត់អគ្គិទឌ្ឍ** សំពត់ត្រូវភ្លើងឆេះហើយគេចោល ១ **សំពត់គោខាយិត** សំពត់ដែលគោ

ទំពាហើយគេទុកចោល ១ **សំពត់ឧបចិក្ខាយិត** សំពត់កណ្តៀរស៊ីហើយគេចោល ១ **សំពត់ឧន្ទូរខាយិត** សំពត់កណ្តុរខាំកកេរហើយគេទុកចោល ១ **សំពត់អន្តច្ឆិន្ន** សំពត់ដាច់ជាយហើយគេទុកចោល ១ **សំពត់ឧសច្ឆិន្ន** សំពត់ដាច់ជាយហើយគេចោល ១ **សំពត់ធជាហដ** សំពត់ដែលគេធ្វើជាទង់ហើយចោល ១ **សំពត់ថូប** សំពត់ដែលគេបូជាជំបូកកណ្តៀរទុកចោល ១ **សំពត់សមណចីវរ** សំពត់របស់ភិក្ខុផងគ្នា ១ **សំពត់សាមុទ្ទិយ** សំពត់ដែលរលកសមុទ្របន្សាត់ឡើងលើច្រាំង ១ **សំពត់អាភិសេកិក** សំពត់ដែលគេចោលក្នុងទីរាជាភិសេក ១ **សំពត់បន្ថិក** សំពត់ដែលធ្លាក់នៅតាមផ្លូវមិនប្រាកដម្ចាស់របស់ ១ **សំពត់វាតាហដ** សំពត់ដែលខ្យល់កួចយកទៅមិនមានម្ចាស់របស់ជាប់តាម ១ **សំពត់ឥទ្ធិមយ** សំពត់ដែលសម្រេចអំពីឫទ្ធិចំពោះឯហិភិក្ខុ ១ **សំពត់ទេវទត្តិយ** សំពត់ដែលទេវតាថ្វាយ ១ ។

បណ្តាសំពត់ទាំងនេះ សំពត់ដែលឈ្មោះថា **សោត្ថិយ** បានដល់ សំពត់សម្រាប់ជូតមន្ទិលគភ៌ ។ សំពត់ដែលឈ្មោះថា **គតបច្ចាគត** បានដល់ សំពត់ដែលគេរំសាកសពនាំទៅព្រៃជាទីចោលសាកសព ហើយនាំត្រឡប់មក ។ សំពត់ដែលឈ្មោះថា **ធជាហដ** បានដល់ សំពត់ដែលគេធ្វើជាទង់ ហើយភិក្ខុនាំមកពីទីនោះ ។ សំពត់ដែលឈ្មោះថា **ថូប** បានដល់ សំពត់ដែលគេបូជាជំបូកកណ្តៀរ ។ សំពត់ដែលឈ្មោះថា **សាមុទ្ទិយ** បានដល់ សំពត់ដែលត្រូវរលកសមុទ្របន្សាត់ឡើងគោក ។ សំពត់ដែលឈ្មោះថា **បន្ថិក** បានដល់ សំពត់ដែលអ្នកធ្វើដំណើរប្រើជុំថ្មដំហើយដណ្តប់ ព្រោះខ្លាចចោរ ។ សំពត់

ដែល ឈ្មោះថា **ឥទ្ធិមយ** បានដល់ សំពត់របស់ឯហិភិក្ខុ ។ សំពត់ដ៏សេស ប្រាកដច្បាស់ហើយ ។

ប្រការថា **ចីវរសន្តោសោ** បានដល់ សេចក្ដីសន្ដោសក្នុងចីវរ ២០ ។ ក្នុងចីវរ មានសន្ដោស ២០ គឺសន្ដោសក្នុងការត្រិះរិះ ១ សន្ដោសក្នុងការទៅ ១ សន្ដោសក្នុងការស្វែងរក ១ សន្ដោសក្នុងការបាន ១ សន្ដោសក្នុងការទទួលតែល្មមប្រមាណ ១ សន្ដោសក្នុងការវៀរចាកសេចក្ដីចង់បាន ១ សន្ដោសតាមតែបាន ១ សន្ដោសតាមកម្លាំង ១ សន្ដោសតាមសេចក្ដីសមគួរ ១ សន្ដោសក្នុងទឹក ១ សន្ដោសក្នុងការធាក ( ទស់សំពត់បង្សុកូល ) ១ សន្ដោសក្នុងការធ្វើ ១ សន្ដោសក្នុងប្រមាណ ១ សន្ដោសក្នុងអំបោះ ១ សន្ដោសក្នុងការដេរ ១ សន្ដោសក្នុងការជ្រលក់ ១ សន្ដោសក្នុងការធ្វើកប្បៈ ១ សន្ដោសក្នុងការប្រើប្រាស់ ១ សន្ដោសក្នុងការវៀរចាកការសន្សំ ១ សន្ដោសក្នុងការលះបង់ ១ ។

បណ្ដាសន្ដោសទាំងនោះ ភិក្ខុអ្នកត្រេកអរនៅចាំវស្សាគ្រប់ត្រៃមាសនឹងត្រិះរិះត្រឹមតែមួយខែក៏គួរ ។

ភិក្ខុនោះបវារណាហើយ រមែងធ្វើចីវរក្នុងខែដែលធ្វើចីវរ ។ ភិក្ខុដែលទ្រទ្រង់សំពត់បង្សុកូល រមែងធ្វើដោយកន្លះខែប៉ុណ្ណោះ ។ការត្រិះរិះត្រឹមតែមួយខែ ឬកន្លះខែ ឈ្មោះថា សន្ដោសក្នុងការត្រិះរិះ ដោយប្រការដូច្នេះ ។ ភិក្ខុដែលសន្ដោសដោយការសន្ដោសក្នុងការត្រិះរិះ គប្បីជាអ្នកដូចនឹងព្រះបង្សុកូលត្ថេរ អ្នកចាំវស្សានៅក្នុងបាចីនខណ្ឌរាជីវិហារចុះ ។

មានរឿងតំណាលមកថា ព្រះថេរៈមកដោយសេចក្ដីប្រាថ្នាថា នឹងថ្វាយ

បង្គំព្រះចេតិយក្នុងចេតិយបព៌តវិហារ លុះថ្វាយបង្គំព្រះចេតិយហើយ ក៏គិតថា ចីវររបស់យើងចាស់ហើយ យើងនឹងបានក្នុងទីនៅរបស់ភិក្ខុច្រើន ។ ទើបលោកទៅកាន់មហាវិហារ ជួបព្រះសង្ឃត្ថេរ សួរដល់ទីនៅហើយក៏នៅទីនោះ ព្រឹកឡើង ទើបកាន់យកចីវរមកថ្វាយបង្គំព្រះថេរៈ ។ ព្រះថេរៈសួរថា អ្វីលោកម្ចាស់ ។ ឆ្លើយថា លោកម្ចាស់ ខ្ញុំនឹងទៅកាន់ស្រុក ។ ទើបព្រះថេរៈពោលថា លោកម្ចាស់ សូម្បីខ្ញុំក៏នឹងទៅ ។ ទើបពោលថា ល្អហើយលោកម្ចាស់ ក៏ដើរទៅឈរត្រង់ស៊ុមទ្វារម្ខាងនៃដើមមហាពោធិ៍ គិតថា យើងនឹងបានចីវរដែលគួរពេញចិត្ត ក្នុងទីនៅរបស់អ្នកមានបុណ្យ ហើយទើបត្រឡប់គិតទៀតថា ការត្រិះរិះរបស់យើងមិនបរិសុទ្ធ ក៏ត្រឡប់ពីទីនោះភ្លាម ស្អែកឡើង ទើបទៅកាន់ទីជិតទួលស្វាយ ស្អែកឡើង ក៏ត្រឡប់ពីទ្វារទិសខាងជើងរបស់មហាចេតិយដូច្នោះ សូម្បីក្នុងថ្ងៃទី ៤ ក៏បានទៅកាន់សម្នាក់របស់ព្រះថេរៈ ។ ព្រះថេរៈដឹងថា ភិក្ខុនេះនឹងមានសេចក្តីត្រិះរិះមិនបរិសុទ្ធ ទើបកាន់យកចីវរ សួរបញ្ហាបណ្តើរ ហើយចូលស្រុកជាមួយលោក ។ ក្នុងយប់នោះ មនុស្សម្នាក់ត្រូវឧច្ចារៈបៀតបៀន ទើបបន្ទោបង់ឧច្ចារៈដាក់ក្នុងសំពត់សាដកនោះ បោលសំពត់សាដកនោះក្នុងគំនរសំរាម ។ ព្រះបង្សុកូលិកត្ថេរឃើញសំពត់សាដកនោះមានរុយក្បាលខៀវចោមរោម ទើបផ្គងអញ្ជលី ។ ទើបព្រះមហាថេរៈសួរថា ហេតុដូចម្តេច ទើបលោកបានផ្គងអញ្ជលីចំពោះគំនរសំរាមហ្ន៎ ។ ឆ្លើយថា ករុណាលោកម្ចាស់ ខ្ញុំមិនបានផ្គងអញ្ជលីចំពោះគំនរសំរាមទេ ខ្ញុំផ្គងអញ្ជលីចំពោះព្រះទសពល ព្រះបិតារបស់ខ្ញុំទេតើលោកម្ចាស់ ការដែលភិក្ខុកាន់យកសំពត់បង្សុកូល ដែលគេរុំសាកសពរបស់នាងបុណ្ណទាសី ហើយចោល ដេញសត្វ

តូចៗ ប្រមាណមួយនាឡិចេញពីព្រៃស្មសាន ធ្វើបានលំបាក ។ ព្រះមហាថេរៈគិតថា ការត្រិះរិះរបស់ភិក្ខុដែលទ្រទ្រង់សំពត់បង្សុកូលបរិសុទ្ធហើយ ។ ព្រះថេរៈអ្នកទ្រទ្រង់សំពត់បង្សុកូល ឈរក្នុងទីនោះឯង ចម្រើនវិបស្សនា សម្រេចផល ៣ កាន់យកសំពត់សាដកនោះ ធ្វើជាចីវរដណ្តប់ ទៅកាន់បាចីនខណ្ឌរាជី វិហារសម្រេចព្រះអរហត្តដែលជាផលដ៏ប្រសើរ ។ ការដែលភិក្ខុកាលទៅដោយត្រូវការចីវរ មិនត្រូវគិតថា នឹងបានពីទីណា ហើយទៅដោយប្រាថ្នាកម្មដ្ឋានជាធំតែម្យ៉ាង ឈ្មោះថា សន្តោសក្នុងការទៅ ។ ភិក្ខុកាលស្វែងរក កុំស្វែងរកនឹងអ្នកណាបញ្ជូនទៅ នាំយកភិក្ខុដែលជាលជ្ជី មានសីលជាទីស្រឡាញ់ទៅស្វែងរក ឈ្មោះថា សន្តោសក្នុងការស្វែងរក ។ ភិក្ខុកាលស្វែងរកយ៉ាងនេះ ឃើញអ្នកនាំចីវរមកពីឆ្ងាយ កុំត្រិះរិះយ៉ាងនេះថា ចីវរនោះនឹងជារបស់គួរពេញចិត្ត ចីវរនោះមិនជារបស់គួរពេញចិត្ត ដូច្នេះហើយ ត្រេកអរជាមួយបណ្តាចីវរសាច់គ្រោតគ្រាត ឬសាច់ល្អិតជាដើម តាមតែនឹងបាន ឈ្មោះថា សន្តោសក្នុងការបាន ។ ភិក្ខុទទួលយកចីវរដែលបានហើយយ៉ាងនេះ ត្រេកអរដោយប្រមាណដែលត្រឹមតែល្មមដល់ខ្លួនប៉ុណ្ណោះថា សំពត់ប៉ុណ្ណោះនឹងមានដើម្បីចីវរ ២ ជាន់ សំពត់ប៉ុណ្ណោះនឹងមានដើម្បីចីវរមួយជាន់ ឈ្មោះថា សន្តោសក្នុងការទទួលតែល្មមប្រមាណ ។ ភិក្ខុកាលស្វែងរកចីវរ មិនត្រូវគិតថា យើងនឹងបានចីវរដែលគួរពេញចិត្តត្រង់ទ្វារផ្ទះរបស់អ្នកឯណោះ ដូច្នេះហើយ ត្រាច់ទៅតាមលំដាប់ផ្ទះ ឈ្មោះថា សន្តោសក្នុងការវៀរចាកសេចក្តីចង់បាន ។ ការដែលភិក្ខុអាចញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយបណ្តាចីវរដែលសៅហ្មង ឬប្រណីតយ៉ាងណានីមួយ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ

ដោយចីវរតាមដែលបានទុំះឯង ឈ្មោះថា សន្តោសតាមបាន ។ ការដែលភិក្ខុដឹងដល់កម្លាំងរបស់ខ្លួន ហើយអាចនឹងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយចីវរប្រភេទណា ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយចីវរនោះ ឈ្មោះថា សន្តោសតាមកម្លាំង ។ ភិក្ខុឲ្យចីវរដែលគួរពេញចិត្តដល់ភិក្ខុដទៃ ខ្លួនឯងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយចីវរយ៉ាងណាមួយ ឈ្មោះថា សន្តោសតាមសេចក្តីសមគួរ ។ ភិក្ខុមិនជ្រើសរើសថា ទឹកត្រង់ណាគួរពេញចិត្ត ត្រង់ណាមិនគួរពេញចិត្ត ដូច្នេះហើយ នាំដោយទឹកដែលល្មមនឹងនាំមកបានខ្លះ ឈ្មោះថា សន្តោសក្នុងទឹក ។ ការដែលភិក្ខុវៀរទឹកដែលល្អក់ទៅដោយដីពណ៌លឿង ដីភក់ និងក្នុងស្មៅស្អុយចេញក៏គួរ ។ ភិក្ខុកាលទាញ មិនប្រើដំបងជាដើម ប្រើដៃទាញមក ឈ្មោះថា សន្តោសក្នុងការទាញ ។ ភិក្ខុដាក់ស្លឹកឈើចុះទៅ ហើយទាញចីវរដែលមិនស្អាតយ៉ាងនោះ សូម្បីដោយទឹកក្តៅក៏គួរ ។ ការដែលភិក្ខុទាញយ៉ាងនេះ មិនឲ្យចិត្តកម្រើកថា សំពត់នេះសាច់គ្រោតគ្រាត សំពត់នេះសាច់ល្អិត ធ្វើទៅដោយទំនងដែលត្រឹមតែល្មមនោះឯង ឈ្មោះថា សន្តោសក្នុងការធ្វើ ។ ការធ្វើចីវរដែលត្រឹមតែល្មមនឹងបិទមណ្ឌល ៣ បានទុំះឯង ឈ្មោះថា សន្តោសក្នុងបរិមាណ ។ កាលនឹងធ្វើចីវរ ភិក្ខុមិនប្រមូលគ្នាថា យើងនឹងស្វែងរកអំបោះដែលត្រូវចិត្ត ដូច្នេះហើយ នាំអំបោះក្នុងស្ថានទីមានប្រកផ្លូវជាដើម ឬក្នុងទេវស្ថានមក ឬកាន់យកអំបោះយ៉ាងនីណាមួយនោះឯង ដែលគេទុកដាក់ជិតជើងមកធ្វើ ឈ្មោះថា សន្តោសក្នុងសរសៃអំបោះ ។ ក្នុងវេលាដេរកុសិគប្បីដេរបាន ៧ ដង ឆ្ងាយពីគ្នាប្រមាណ ១ ធ្នាប់ ។ កាលភិក្ខុធ្វើយ៉ាងនេះ ភិក្ខុរូបណាមិនមានសម្លាញ់ វត្តភេទ ក៏មិនមានដល់ភិក្ខុនោះ ។ តែគប្បីដេរ ៧

ដង ប្រមាណ ៣ ធ្នាប់ ។ ភិក្ខុដែលធ្វើយ៉ាងនេះ គប្បីមានសម្មាញ់អ្នកធ្វើដំណើរជាមួយគ្នាចុះ ។ ភិក្ខុណាមិនមានសម្មាញ់ ជាវត្តភេទដល់ភិក្ខុនោះ ។ នេះឈ្មោះថា សេចក្តីសន្តោសក្នុងការដេរ ។ ភិក្ខុកាលជ្រលក់ មិនគប្បីត្រាច់ស្វែងរកជ្រៃខ្មៅជាដើម បានវត្ថុណា បណ្តាសម្បកឈើពណ៌ខ្មៅជាដើម គប្បីជ្រលក់ដោយសម្បកឈើនោះ ។ កាលមិនបាន គប្បីកាន់យកទឹកជ្រលក់ដែលពួកមនុស្សកាន់យកក្នុងព្រៃហើយទុកចោល ឬកាកដែលពួកភិក្ខុស្ងោរហើយទុកចោលជ្រលក់ចុះ ។ នេះឈ្មោះថា សេចក្តីសន្តោសក្នុងការជ្រលក់ ។ ការដែលភិក្ខុកាន់យកបណ្តាពណ៌ខៀវ ពណ៌កក់ ពណ៌ខ្មៅ និងពណ៌ផ្ទៃមេឃក្រមៅយ៉ាងណានីមួយ ធ្វើកប្បៈខ្នាតប៉ុនមនុស្សអង្គុយលើខ្នងដំរី មើលឃើញ ឈ្មោះថា សន្តោសក្នុងការធ្វើកប្បៈ ។ ការប្រើប្រាស់ត្រឹមតែដើម្បីបិទបាំងអវយវៈ ដែលនឹងធ្វើឲ្យសេចក្តីខ្មាសកម្រើក ឈ្មោះថា សន្តោសក្នុងការបរិភោគ ។ ភិក្ខុបានក្រណាត់សំពត់ហើយ តែមិនទាន់បានអំបោះ ម្ជុល ឬអ្នក ( ជួយ ) ធ្វើ នឹងរក្សាទុកក៏គួរ ។ កាលបានហើយ រក្សាទុកមិនគួរ ។ បើប្រាថ្នានឹងឲ្យចីវរដែលធ្វើសម្រេចហើយ ដល់ពួកអន្តេវាសិកជាដើម តែពួកអន្តេវាសិកនោះមិននៅ គួររក្សាទុកដរាបដល់ពួកគេមក កាលពួកអន្តេវាសិកមកដល់ គប្បីឲ្យចុះ កាលមិនអាចឲ្យបាន គប្បីអធិដ្ឋានទុក កាលមានចីវរដទៃ នឹងអធិដ្ឋានជាសំពត់ក្រាលផែនដីក៏គួរ ចីវរដែលមិនបានអធិដ្ឋានប៉ុណ្ណោះ ទើបជាសន្និធិ ចីវរដែលអធិដ្ឋានហើយមិនជាសន្និធិទេ ព្រះមហាសិវត្ថេរពោលដូច្នេះ ។ នេះឈ្មោះថា សន្តោសក្នុងការវៀរចាកការសន្សំ ។ ភិក្ខុកាលលះបង់ មិនគប្បីឲ្យដោយយល់ដល់មុខ ។ គប្បីតាំងនៅក្នុងសារាណីយធម៌ ហើយ

លះបង់ចុះ ។ នេះឈ្មោះថា សន្តោសក្នុងការលះបង់ ។ បង្សុកូលិកង្គធុតង្គ និងតេចីវរិកង្គធុតង្គ ឈ្មោះថា ធុតង្គដែលជាប់ទាក់ទងដោយចីវរ ។ កថាយ៉ាងពិស្តារនៃធុតង្គទាំង ២ នោះ គប្បីជ្រាបអំពីគម្ពីរវិសុទ្ធិមគ្គ ។ ភិក្ខុដែលបំពេញមហាអរិយវង្សប្រការថា ការសន្តោសដោយចីវរ រមែងរក្សាធុតង្គ ២ ប្រការនេះបាន ដោយប្រការដូច្នេះ ។ ភិក្ខុកាលរក្សាធុតង្គ ២ ប្រការនេះបាន រមែងជាអ្នកឈ្មោះថា សន្តោសតាមមហាអរិយវង្សថា ការសន្តោសដោយចីវរ ។

បទថា **វណ្ណវាទី** គប្បីជ្រាបអធិប្បាយដូច្នេះ ភិក្ខុមួយរូបជាអ្នកសន្តោសពិតៗ តែមិនពោលពណ៌នាដល់សេចក្តីសន្តោស ។ មួយរូបទៀត មិនជាអ្នកសន្តោស តែត្រឡប់ជាពណ៌នាដល់សេចក្តីសន្តោស ។ មួយរូបទៀត ទាំងមិនសន្តោស ទាំងមិនពណ៌នាដល់សេចក្តីសន្តោស ។ មួយរូបទៀត ទាំងជាអ្នកសន្តោស ទាំងពណ៌នាដល់សេចក្តីសន្តោស ។ ដើម្បីសម្តែងហេតុផលប្រការនោះ ទើបលោកពោលពាក្យថា ជាអ្នកមានប្រក្រតីពណ៌នាដល់សេចក្តីសន្តោសក្នុងចីវរតាមមានតាមបាន ។ បទថា **អនេសនំ** សេចក្តីថា ការស្វែងរកដែលមិនសមគួរ មានការបញ្ជូនដំណឹង ការធ្វើដំណើរ និងការតាមប្រកបក្នុងកម្មទាំង ២ នោះ ដែលជាការងាររបស់ទូត ។ បទថា **អប្បដិរូបំ** សេចក្តីថា មិនគួរ ។ បទថា **អលទ្ធា ច** ប្រែថា មិនបាន ។ ភិក្ខុដែលសន្តោស មិនបានចីវរ ក៏មិនក្តៅក្រហាយ ដូចភិក្ខុរូបខ្លះគិតថា យើងនឹងបានចីវរយ៉ាងណាហ្ន៎ ហើយចូលជាមួយពួកភិក្ខុដែលមានបុណ្យ ធ្វើការបញ្ឆោតបន្លំ រមែងតក់ស្លុត រមែងក្តៅក្រហាយ ដូច្នោះ ។ បទថា **លទ្ធា ច** សេចក្តីថា បានដោយត្រឹមត្រូវតាមធម៌ ។ បទថា **អគធិតោ** សេចក្តីថា អ្នកមិនត្រូវសេចក្តីលោភ

ចងរឹតទុក ។ បទថា **អមុច្ឆិតោ** សេចក្តីថា មិនដល់សេចក្តីងប់ជ្រប់ ព្រោះចំណង់ខ្លាំង ។ បទថា **អនជ្ឈាបន្នោ** សេចក្តីថា មិនត្រូវតណ្ហាសង្កត់សង្កិន គឺរួបរឹត ។ បទថា **អាទីនវទស្សាវី** សេចក្តីថា ឃើញទោសក្នុងអាបត្តិដែលត្រូវព្រោះការស្វែងរកដែលមិនសមគួរ និងក្នុងការបរិភោគលាភ ដែលត្រូវចំណង់ចងរឹតទុក ។ បទថា **និស្សរណបញ្ញោ** សេចក្តីថា អ្នកដឹងដល់ការរលាស់ចេញ ដែលលោកពោលថា ត្រឹមតែដើម្បីបំបាត់សេចក្តីត្រជាក់ជាដើម ។ បទថា **ឥតរីតរចីវរសន្តុដ្ឋិយា** សេចក្តីថា ដោយការសន្តោស ដោយចីវរយ៉ាងណាទីមួយ ។ បទថា **នេវត្តានុក្កំសេតិ** សេចក្តីថា មិនធ្វើការលើកខ្លួនឡើងថា យើងជាអ្នកទ្រទ្រង់សំពត់បង្សុកូល យើងសមាទានបង្សុកូលិកង្គធុតង្គ តាំងអំពីនៅក្នុងរោងឧបសម្បទា នឹងមានអ្នកណាដូចយើង ដូច្នេះ ។ ពីរបទថា **ន បរំ វម្ភេតិ** សេចក្តីថា មិនគ្របសង្កត់អ្នកដទៃ យ៉ាងនេះថា ភិក្ខុពួកដទៃនេះ មិនជាអ្នកទ្រទ្រង់សំពត់បង្សុកូលទេ ឬថា ភិក្ខុពួកនេះ មិនមានត្រឹមតែបង្សុកូលិ-កង្គធុតង្គ ដូច្នេះ ។ ច្រើនបទថា **យោ ហិ តត្ថ ទក្ខោ** សេចក្តីថា ភិក្ខុណាជាអ្នកប្រឹងប្រែងឈ្លាស វាងវៃ ក្នុងការសន្តោសដោយចីវរនោះ ឬក្នុងគុណមានភាពជាអ្នកពណ៌នាជាដើម ។ បទថា **អនលសោ** សេចក្តីថា វៀរចាកសេចក្តីខ្ជិលច្រអូស ដោយការធ្វើជាប់ត ។ ពីរបទថា **សម្បជានោ បដិស្សតោ** សេចក្តីថា ប្រកបដោយបញ្ញាក្នុងការដឹងខ្លួន និងដោយការរឭកបាន ។ ពីរបទថា **អរិយវំសេ ឋិតោ** សេចក្តីថា តាំងនៅក្នុងអរិយវង្ស ។

ប្រការថា **ឥតរិតរេន បិណ្ឌបាតេន** សេចក្តីថា ដោយបិណ្ឌបាត យ៉ាង

ណាទីមួយ ។ សូម្បីក្នុងសេចក្តីនេះ បណ្ឌិតក៏គប្បីជ្រាបបិណ្ឌបាត ខេត្តក្នុងការត្រាច់បិណ្ឌបាត សេចក្តីសន្តោសក្នុងបិណ្ឌបាត ធុតង្គដែលជាប់ទាក់ទងដោយបិណ្ឌបាត ។

បណ្តា ៤ ប្រការនោះ ប្រការថា បិណ្ឌបាត ១៦ យ៉ាង គឺបាយ នំកុម្មាស សជូវ ត្រី សាច់ ទឹកដោះជូរ ទឹកដោះស្រស់ ទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ស្ករអំពៅ បបរ របស់គួរទំពា របស់គួរភ្លក្ស របស់គួរលិទ្ធ (ជញ្ជក់) ។

ប្រការថា **បិណ្ឌបាតក្ខេត្តំ** សេចក្តីថា ខេត្រនៃការត្រាច់បិណ្ឌបាត មាន ១៥ គឺភត្តដែលគេថ្វាយព្រះសង្ឃ ១ ភត្តដែលគេថ្វាយចំពោះ ១ ភត្តដែលបានក្នុងទីនិមន្ត ១ ភត្តដែលគេថ្វាយព្រមជាមួយស្លាក ១ ភត្តដែលគេថ្វាយប្រចាំបក្ខ ១ ភត្តដែលគេថ្វាយក្នុងថ្ងៃឧបោសថ ១ ភត្តដែលគេថ្វាយក្នុងថ្ងៃបាដិបទ (គឺថ្ងៃមួយកើត ឬរោច) ១ ភត្តដែលគេថ្វាយដល់ភិក្ខុដែលចរមក ១ ភត្តដែលគេថ្វាយដល់ភិក្ខុដែលត្រៀមនឹងទៅ ១ ភត្តដែលគេថ្វាយដល់ភិក្ខុឈឺ ១ ភត្តដែលគេថ្វាយដល់ភិក្ខុដែលឧបដ្ឋាកភិក្ខុឈឺ ១ ភត្តដែលគេថ្វាយក្នុងវិហារជិត ១ ភត្តដែលគេថ្វាយដល់ភិក្ខុដែលចាំកុដិ ១ ភត្តដែលគេថ្វាយប្រចាំថ្ងៃ ១ ភត្តដែលគេថ្វាយដល់ភិក្ខុដែលចាំវិហារ ១ ។

ប្រការថា **បិណ្ឌបាតសន្តោសោ** សេចក្តីថា សន្តោសមាន ១៥ គឺសន្តោសក្នុងការត្រិះរិះក្នុងបិណ្ឌបាត ១ សន្តោសក្នុងការទៅ ១ សន្តោសក្នុងការស្វែងរក ១ សន្តោសក្នុងការបានចំពោះ ១ សន្តោសក្នុងការទទួល ១ សន្តោសក្នុងការទទួលតែល្មមប្រមាណ ១ សន្តោសក្នុងការវៀរចាកសេចក្តីចង់បាន ១ សន្តោសតាមបាន ១ សន្តោសតាមកម្លាំង ១ សន្តោសតាមសមគួរ ១ សន្តោស

ក្នុងការទំនុកបម្រុង ១ សន្តោសក្នុងការកំណត់ ១ សន្តោសក្នុងការបរិភោគ ១ សន្តោសក្នុងការវៀរចាកការសន្សំ ១ សន្តោសក្នុងការលះបង់ ។

បណ្តាសន្តោសទាំងនោះ ភិក្ខុដែលត្រេកអរ លុបមុខហើយ រមែងត្រិះរិះ ។ ភិក្ខុដែលត្រាច់ទៅជាមួយគណៈ ភិក្ខុដែលត្រាច់បិណ្ឌបាតជាវត្ត ក្នុងវេលាឧបដ្ឋាកព្រះថេរៈក្នុងវេលាល្ងាច ត្រូវសួរថា ស្អែកនេះពួកយើងនឹងត្រាច់បិណ្ឌបាតទីណា ឆ្លើយថា ក្នុងស្រុកឈ្មោះឯណោះ លោកម្ចាស់ គិតត្រឹមតែប៉ុណ្ណោះ បន្ទាប់ពីនោះទៅ ក៏មិនគប្បីត្រិះរិះ ( ទៀត ) ។ ភិក្ខុដែលត្រាច់តែម្នាក់ឯងគប្បីឈរត្រិះរិះក្នុងរោងសម្រាប់ត្រិះរិះចុះ ។ ភិក្ខុដែលត្រិះរិះច្រើនជាងនោះ រមែងជាអ្នកឃ្លាតឆ្ងាយចាកអរិយវង្ស ។ ប្រការដែលពោលមកនេះ ឈ្មោះថា សន្តោសក្នុងការត្រិះរិះ ។ ភិក្ខុដែលនឹងចូលទៅបិណ្ឌបាត មិនត្រូវគិតថា នឹងបានទីណា គប្បីទៅដោយមានកម្មដ្ឋានជាធំចុះ ។ ប្រការនេះ ឈ្មោះថា សន្តោសក្នុងការទៅ ។ ភិក្ខុដែលស្វែងរក មិនត្រូវកំណត់ថា ជាអ្វី គប្បីនាំយកភិក្ខុដែលជាលជ្ជី មានសីលជាទីស្រឡាញ់ប៉ុណ្ណោះ ទៅស្វែងរកចុះ ។ ប្រការនេះ ឈ្មោះថា សន្តោសក្នុងការស្វែងរក ។ ភិក្ខុឃើញអ្នកនាំអាហារមកពីទីឆ្ងាយ មិនគប្បីឲ្យកើតសេចក្តីគិតឡើងថា របស់នោះគួរពេញចិត្ត របស់នោះមិនគួរពេញចិត្ត ដូច្នេះ ។ នេះឈ្មោះថា សន្តោសក្នុងការបានចំពោះ ។ ភិក្ខុមិនគប្បីគិតថា របស់នេះគួរពេញចិត្ត យើងនឹងទទួលរបស់នេះមិនគួរពេញចិត្ត យើងនឹងមិនទទួល ដូច្នេះហើយ ទទួលយកត្រឹមតែអាហារល្មមញ៉ាំងអត្តភាព យ៉ាងណានីមួយប៉ុណ្ណោះចុះ ។ នេះឈ្មោះថា សន្តោសក្នុងការទទួល ។ ក្នុងសន្តោសប្រការនេះ ទេយ្យធម៌មានច្រើន តែទាយកត្រូវការថ្វាយតែបន្តិចបន្តួច គប្បី

ទទួលយកតែបន្តិចបន្តួច ទេយ្យធម៌ក៏មានច្រើន ហើយទាយកក៏ត្រូវការថ្វាយច្រើន គប្បីទទួលយកតែល្មមប្រមាណប៉ុណ្ណោះ ទេយ្យធម៌មានមិនច្រើន ហើយទាយកក៏ត្រូវការនឹងថ្វាយមិនច្រើន គប្បីទទួលយកតែបន្តិចបន្តួច ទេយ្យធម៌មានមិនច្រើន តែទាយកត្រូវការថ្វាយច្រើន ក៏គប្បីទទួលយកតែល្មមប្រមាណប៉ុណ្ណោះ ។ ភិក្ខុដែលមិនស្គាល់ប្រមាណក្នុងការទទួល រមែងធ្វើសេចក្តីជ្រះថ្លារបស់ពួកមនុស្សឲ្យវិនាសទៅ ធ្វើសទ្ធាឲ្យធ្លាក់ចុះ មិនធ្វើពាក្យទូន្មាន មិនអាចនឹងទប់ចិត្តសូម្បីរបស់មាតាបង្កើតបាន ។ ភិក្ខុគប្បីស្គាល់ប្រមាណជាមុនហើយទើបទទួលដោយប្រការដូច្នេះឯង ។ នេះឈ្មោះថា សន្តោសក្នុងការទទួលតែល្មមប្រមាណ ។ ភិក្ខុមិនទៅកាន់ត្រកូលដែលស្គុកស្គម្ភប៉ុណ្ណោះ គប្បីទៅតាមលំដាប់ផ្ទះចុះ ។ នេះឈ្មោះថា សន្តោសក្នុងការវៀរចាក ការចង់បាន ។

យថាលាភសន្តោសជាដើម មានន័យដូចពោលហើយក្នុងចីវរនុ៎ះឯង ។

ការដែលភិក្ខុដឹងអ្នកឧបការៈយ៉ាងនេះថា យើងនឹងឆាន់បិណ្ឌបាតហើយរក្សាសមណធម៌ ដូច្នេះហើយ ឆាន់ ឈ្មោះថា ឧបការសន្តោស ។ ភិក្ខុមិនគប្បីទទួលបិណ្ឌបាតដែលគេដាក់ពេញបាត្រ ហើយនាំមក ( ប្រគេន ) កាលមានអនុបសម្បន្ន ( កូនសិស្ស ) គប្បីឲ្យអនុបសម្បន្ននោះនាំមក កាលមិនមានក៏គប្បីឲ្យគេនាំមក ហើយទទួលតែល្មមទទួលបាន ។ នេះឈ្មោះថា សន្តោសក្នុងការកំណត់ ។ កាលភិក្ខុឆាន់ដោយមនសិការ យ៉ាងនេះថា ការឆាន់នេះដើម្បីបន្ទោបង់សេចក្តីស្រេកឃ្លានបាន ការចេញចាកភពនឹងមានព្រោះការឆាន់នេះ ឈ្មោះថា សន្តោសក្នុងការបរិភោគ ។ ភិក្ខុមិនគប្បីរក្សាសន្សំទុកឆាន់ ។ នេះឈ្មោះថា សន្តោសក្នុងការវៀរចាកការសន្សំ ។ ភិក្ខុមិនគប្បីយល់ដល់មុខ

តាំងនៅក្នុងសាភណិយធម៌ហើយ គប្បីលះបង់ចុះ ។ នេះឈ្មោះថា សន្តោស ក្នុងការលះបង់ ។

ធុតង្គ ៥ ប្រការ គឺបិណ្ឌបាតិកង្គៈ សបទានចារិកង្គៈ ឯកាសនិកង្គៈ បត្តបិណ្ឌិកង្គៈ ខលុបច្ឆាភត្តិកង្គៈ ជាប់ទាក់ទងនឹងបិណ្ឌបាត ។

កថាយ៉ាងពិស្តាររបស់ធុតង្គទាំង ៥ ប្រការនោះ លោកពោលហើយ ក្នុងវិសុទ្ធិមគ្គ ។ ភិក្ខុដែលបំពេញមហាអរិយវង្ស ប្រការថា ការសន្តោសក្នុងបិណ្ឌបាត រមែងរក្សាធុតង្គ ៥ ប្រការនេះបាន ដោយប្រការដូច្នេះ ។ ភិក្ខុកាលរក្សាធុតង្គ ៥ ប្រការនេះបាន រមែងជាអ្នកសន្តោសតាមមហាអរិយវង្ស ប្រការថា ការសន្តោសដោយបិណ្ឌបាត ។ បទថា **វណ្ណវាទី** ជាដើម គប្បីជ្រាបតាមន័យដែលពោលហើយនុ៎ះឯង ។

ក្នុងបទថា **សេនាសនេន** នេះ បណ្ឌិតគប្បីជ្រាបសេនាសនៈ ខេត្រនៃសេនាសនៈ សេចក្តីសន្តោសក្នុងសេនាសនៈ ធុតង្គដែលជាប់ទាក់ទងនឹងសេនាសនៈ ។

បណ្តា ៤ ប្រការនោះ ប្រការថា **សេនាសនំ** សេចក្តីថា សេនាសនៈមាន ១៥ ប្រភេទនេះ គឺគ្រែ ១ តាំង ១ ពូក ១ ខ្នើយ ១ វិហារ ១ ភទហាល ១ ប្រាសាទ ១ ប្រាសាទត្រងិល ១ ល្អាង ១ ទីពួនសម្ងំ ១ ប៉ម ១ ផ្ទះកំពូលតែមួយ ១ គុម្ពឫស្សី ១ គល់ឈើ ១ ឬថា ទីដែលសមគួរដល់ភិក្ខុ ១ ។

ប្រការថា ខេត្ររបស់សេនាសនៈ សេចក្តីថា ខេត្តមាន ៦ គឺអំពីសង្ឃ ១ អំពីគណៈ ១ អំពីញាតិ ១ អំពីមិត្ត ១ អំពីទ្រព្យរបស់ខ្លួន ១ ឬខេត្តដែលជារបស់បង្សុកូល ១ ។

ប្រការថា សន្តោសក្នុងសេនាសនៈ សេចក្តីថា ក្នុងសេនាសនៈ មានសន្តោស ១៥ យ៉ាង មានសន្តោសក្នុងការត្រិះរិះជាដើម ។ សន្តោសទាំងនោះគប្បីជ្រាបតាមន័យដែលពោលហើយក្នុងបិណ្ឌបាតនុ៎ះឯង ។

ធុតង្គ ៥ ប្រការ គឺអារញ្ញិកង្គៈ រុក្ខមូលិកង្គៈ អព្ភោកាសិកង្គៈ សោសានិកង្គៈ យថាសន្ថតិកង្គៈ ជាប់ទាក់ទងដោយសេនាសនៈកថា យ៉ាងពិស្តាររបស់ធុតង្គទាំងនោះ លោកពោលហើយក្នុងវិសុទ្ធិមគ្គ ។ ភិក្ខុដែលបំពេញមហាអរិយវង្ស ប្រការថា ការសន្តោសក្នុងសេនាសនៈ រមែងឈ្មោះថា រក្សាធុតង្គ ៥ ប្រការនេះដោយប្រការដូច្នេះ ។ កាលរក្សាធុតង្គ ៥ ប្រការនេះបាន ចាត់ថាជាអ្នកសន្តោសតាមមហាអរិយវង្ស ប្រការថា ការសន្តោសក្នុងសេនាសនៈ ។

គិលានប្បច្ច័យ រួមចូលក្នុងបិណ្ឌបាតនុ៎ះឯង ។ ក្នុងគិលានប្បច្ច័យនោះ ភិក្ខុគប្បីជាអ្នកសន្តោសដោយការសន្តោសតាមបាន សន្តោសតាមកម្លាំង និងសន្តោសតាមសមគួរ ។ ភិក្ខុ ( កាលសមាទាន ) នេសជ្ជិកង្គធុតង្គ ឈ្មោះថារមែងសេពគប់អរិយវង្ស ប្រការថា ការត្រេកអរក្នុងភាវនា ។ សមពិតដូចពាក្យដែលលោកពោលថា

ក្នុងសេនាសនៈ លោកពោលធុតង្គទុក ៥ ប្រការ ធុតង្គ ៥ ប្រការ អាស្រ័យអាហារ ប្រការមួយជាប់ទាក់ទងនឹងសេចក្តីព្យាយាម និងពីរប្រការទៀត អាស្រ័យចីវរ ។

ព្រះធម្មសេនាបតីសារីបុត្តត្ថេរ ពោលអរិយវង្សប្រការថា ការសន្តោសក្នុងចីវរ ប្រការទីមួយ ដូចនឹងបែងចែកមហាបឋវី ដូចនឹងញ៉ាំងផ្ទៃទឹកឲ្យពេញ និងដូចជាពង្រីកអាកាសឲ្យធំទូលាយ ពោលអរិយវង្ស ប្រការថា ការសន្តោស

ក្នុងបិណ្ឌបាត ប្រការទី ២ ដូចជានឹងញ៉ាំងព្រះចន្ទឲ្យតាំងឡើង និងដូចជានឹងញ៉ាំងព្រះអាទិត្យឲ្យរះឡើងមក ពោលអរិយវង្សប្រការថា ការសន្តោសក្នុងសេនាសនៈ ប្រការទី ៣ ដូចជាលើកភ្នំសិនេរុឡើង ឥឡូវនេះ ដើម្បីនឹងពោលអរិយវង្សប្រការថា សេចក្តីត្រេកអរក្នុងភាវនាប្រការទី ៤ ដែលប្រដាប់ទៅដោយន័យមួយពាន់ ទើបផ្តើមទេសនាថា លោកដ៏មានអាយុ ប្រការដទៃទៅមានទៀត ភិក្ខុរមែងជាអ្នកត្រេកអរក្នុងការលះបង់ ដូច្នេះ ។

ក្នុងប្រការនោះ សេចក្តីត្រេកអរ ឈ្មោះថា **អារាមោ** អធិប្បាយថា សេចក្តីត្រេកអរក្រៃលែង ។ ភិក្ខុឈ្មោះថា ត្រេកអរក្នុងការលះ ព្រោះអត្ថថា មានសេចក្តីត្រេកអរក្នុងការលះ ៥ យ៉ាង ។ ភិក្ខុឈ្មោះថា ត្រេកអរហើយក្នុងការលះ ព្រោះអត្ថថា ត្រេកអរហើយក្នុងការលះយ៉ាងនេះថា កាលលះសេចក្តីពេញចិត្តក្នុងកាមបាន រមែងត្រេកអរ កាលចម្រើននេក្ខម្មៈ រមែងត្រេកអរ កាលលះព្យាបាទបាន រមែងត្រេកអរ ។ល។ កាលលះកិលេសទាំងអស់បាន រមែងត្រេកអរ កាលចម្រើនអរហត្តមគ្គ រមែងត្រេកអរ ។ ភិក្ខុឈ្មោះថា ត្រេកអរក្នុងភាវនា ព្រោះអត្ថថា មានសេចក្តីត្រេកអរក្នុងភាវនា តាមន័យដែលពោលនុ៎ះឯង ។ ឈ្មោះថា ត្រេកអរហើយក្នុងភាវនា ព្រោះអត្ថថា ជាអ្នកត្រេកអរហើយក្នុងភាវនា ។ បណ្តាអរិយវង្សទាំង ៤ ប្រការនេះ ដោយអរិយវង្សខាងដើម ៣ ប្រការដំបូង លោកពោលដល់វិនយបិដកទាំងអស់ ដោយអំណាចនៃធុតង្គ ១៣ ប្រការ និងការសន្តោសក្នុងបច្ច័យ ៤ ។ ដោយអរិយវង្សប្រការថា ការត្រេកអរក្នុងភាវនា លោកពោលដល់បិដក ២ ប្រការដ៏សេស ។ ភិក្ខុកាលពោលអរិយវង្សប្រការថា សេចក្តីត្រេកអរក្នុងភាវនានេះ គប្បីពោលតាម

បាលីនៃនេក្ខម្មៈក្នុងបដិសម្ភិទាមគ្គ គប្បីពោលដោយបរិយាយនៃទសុត្តរសូត្រ ក្នុងទីឃនិកាយ គប្បីពោលដោយបរិយាយនៃសតិប្បដ្ឋានសូត្រ ក្នុងមជ្ឈិមនិកាយ (និង) គប្បីពោលដោយបរិយាយនៃនិទ្ទេស ក្នុងអភិធម្មចុះ ។

ក្នុង ៤ ប្រការនោះ ប្រការថា **បដិសម្ភិទាមគ្គេ នេក្ខម្មបាលិយា** សេចក្តីថា ភិក្ខុគប្បីពោលតាមបាលីនៃនេក្ខម្មៈ ក្នុងបដិសម្ភិទាមគ្គ យ៉ាងនេះថា ភិក្ខុនោះកាលចម្រើននេក្ខម្មៈ រមែងត្រេកអរ កាលលះកាមច្ឆន្ទៈបាន រមែងត្រេកអរ កាលចម្រើនសេចក្តីមិនព្យាបាទ រមែងត្រេកអរ កាលលះការព្យាបាទបាន រមែងត្រេកអរ កាលចម្រើនអាលោកសញ្ញា រមែងត្រេកអរ កាលលះថីនមិទ្ធៈបាន រមែងត្រេកអរ កាលចម្រើនសេចក្តីស្ងប់ រមែងត្រេកអរ កាលលះឧទ្ធច្ចៈបាន រមែងត្រេកអរ កាលចម្រើនការកំណត់ធម៌ រមែងត្រេកអរ កាលលះវិចិកិច្ឆាបាន រមែងត្រេកអរ កាលចម្រើនញាណ (បញ្ញា) រមែងត្រេកអរ កាលលះអវិជ្ជាបាន រមែងត្រេកអរ កាលចម្រើនបាមោជ្ជ រមែងត្រេកអរ កាលលះសេចក្តីមិនត្រេកអរបាន រមែងត្រេកអរ កាលចម្រើនបឋមជ្ឈាន រមែងត្រេកអរ កាលលះនីវរណៈ ៥ បាន រមែងត្រេកអរ កាលចម្រើនទុតិយជ្ឈាន រមែងត្រេកអរ កាលលះវិតក្កវិចារៈបាន រមែងត្រេកអរ កាលចម្រើនតតិយជ្ឈាន រមែងត្រេកអរ កាលលះបីតិបាន រមែងត្រេកអរ កាលចម្រើនចតុត្ថជ្ឈាន រមែងត្រេកអរ កាលលះសុខ និងទុក្ខបាន រមែងត្រេកអរ កាលចម្រើនអាកាសានញ្ចាយតនសមាបត្តិ រមែងត្រេកអរ កាលលះរូបសញ្ញា បដិឃសញ្ញា នានត្តសញ្ញា រមែងត្រេកអរ កាលចម្រើនវិញ្ញាណញ្ចាយតនសមាបត្តិ ។ល។ នេវសញ្ញានាសញ្ញាយតនសមាបត្តិ រមែងត្រេកអរ កាលលះអាកិញ្ចញ្ញាយតនសមាបត្តិ

បាន រមែងត្រេកអរ កាលចម្រើនអនិច្ចានុបស្សនា រមែងត្រេកអរ កាលលះនិច្ចសញ្ញាបាន រមែងត្រេកអរ កាលចម្រើនទុក្ខានុបស្សនា រមែងត្រេកអរ កាលលះសុខសញ្ញាបាន រមែងត្រេកអរ កាលចម្រើនអនត្តានុបស្សនា រមែងត្រេកអរ កាលលះអត្តសញ្ញាបាន រមែងត្រេកអរ កាលចម្រើននិព្វិទានុបស្សនា រមែងត្រេកអរ កាលលះសេចក្តីពេញចិត្តបាន រមែងត្រេកអរ កាលចម្រើនវិរាគានុបស្សនា រមែងត្រេកអរ កាលលះរាគៈបាន រមែងត្រេកអរ កាលចម្រើននិរោធានុបស្សនា រមែងត្រេកអរ កាលលះសមុទ័យបាន រមែងត្រេកអរ កាលចម្រើនបដិនិស្សគ្គានុបស្សនាបាន រមែងត្រេកអរ កាលលះសេចក្តីប្រកាន់បាន រមែងត្រេកអរ កាលចម្រើនខយានុបស្សនា រមែងត្រេកអរ កាលលះឃនសញ្ញាបាន រមែងត្រេកអរ កាលចម្រើនវយានុបស្សនាបាន រមែងត្រេកអរ កាលលះអាយូហនៈ ( ការប្រមូល ) បាន រមែងត្រេកអរ កាលចម្រើនវិបរិណាមានុបស្សនា រមែងត្រេកអរ កាលលះធុវសញ្ញា (សេចក្តីសម្គាល់ថា ឋិតថេរ) បាន រមែងត្រេកអរ កាលចម្រើនអនិមិត្តានុបស្សនា រមែងត្រេកអរ កាលលះនិមិត្តបាន រមែងត្រេកអរ កាលចម្រើនអប្បណិហិតានុបស្សនា រមែងត្រេកអរ កាលលះបណិធិ រមែងត្រេកអរ កាលចម្រើនសុញ្ញតានុបស្សនា រមែងត្រេកអរ កាលលះអភិនិវេសបាន រមែងត្រេកអរ កាលចម្រើនអធិប្បញ្ញាធម្មវិបស្សនា រមែងត្រេកអរ កាលលះសារាទានាភិនិវេសបាន រមែងត្រេកអរ កាលចម្រើនយថាភូតញ្ញាណទស្សនៈ រមែងត្រេកអរ កាលលះសម្មោហាភិនិវេសបាន រមែងត្រេកអរ កាលចម្រើនអាទីនវានុបស្សនា រមែងត្រេកអរ កាលលះអាលយាភិនិវេស រមែងត្រេកអរ កាលចម្រើនបដិសង្ខាភិនិវេស រមែងត្រេកអរ កាល

លះអប្បដិសន្ធិៈបាន រមែងត្រេកអរ កាលចម្រើនវិវដ្ដានុបស្សនា រមែងត្រេកអរ កាលលះសំយោគាភិនិវេសបាន រមែងត្រេកអរ កាលចម្រើនសោតាបត្តិមគ្គ រមែងត្រេកអរ កាលលះកិលេសដែលតាំងនៅត្រង់ទីតែមួយជាមួយទិដ្ឋិបាន រមែងត្រេកអរ កាលចម្រើនសកទាគាមិមគ្គ រមែងត្រេកអរ កាលលះកិលេសយ៉ាងគ្រោតគ្រាតបាន រមែងត្រេកអរ កាលចម្រើនអនាគាមិមគ្គ រមែងត្រេកអរ កាលលះកិលេសយ៉ាងល្អិតបាន រមែងត្រេកអរ កាលចម្រើនអរហត្តមគ្គ រមែងត្រេកអរ កាលលះកិលេសទាំងអស់បាន រមែងត្រេកអរ ដូច្នេះ ។

ប្រការថា **ទីឃនិកាយេ ទសុត្តរសុត្តន្តបរិយាយេន ការេ ឥច្ឆា** សេចក្តីថា គប្បីពោលដោយបរិយាយនៃទសុត្តរសូត្រក្នុងទីឃនិកាយ យ៉ាងនេះថា ភិក្ខុកាលចម្រើនធម៌មួយ រមែងត្រេកអរ កាលលះធម៌មួយ រមែងត្រេកអរ ។ល។ កាលចម្រើនធម៌ ១០ រមែងត្រេកអរ កាលលះធម៌ ១០ រមែងត្រេកអរ ភិក្ខុកាលចម្រើនធម៌មួយ រមែងត្រេកអរ ដូចម្តេច ។ កាលចម្រើនកាយគតាសតិដែលជាធម៌សហគតៈដោយសេចក្តីត្រេកអរ រមែងត្រេកអរ ភិក្ខុកាលចម្រើនធម៌មួយនេះ រមែងត្រេកអរ ភិក្ខុកាលលះធម៌មួយ រមែងត្រេកអរ ដូចម្តេច ។ កាលលះអស្មិមានៈបាន រមែងត្រេកអរ ភិក្ខុកាលលះធម៌មួយនេះបាន រមែងត្រេកអរ ។ កាលចម្រើនធម៌ ២ យ៉ាង រមែងត្រេកអរដូចម្តេច ។ល។ កាលចម្រើនធម៌ ១០ យ៉ាង រមែងត្រេកអរដូចម្តេច ។ កាលចម្រើនកសិណ ១០ រមែងត្រេកអរ កាលចម្រើនធម៌ទាំងនេះ រមែងត្រេកអរ កាលលះធម៌ ១០ ពួកណាបាន រមែងត្រេកអរ កាលលះមិច្ឆត្តៈ ១០ បាន រមែងត្រេកអរ កាលលះធម៌ទាំង ១០ នេះបាន រមែងត្រេកអរ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នក

ត្រេកអរក្នុងការនៃទា យ៉ាងនេះឯង ។

ប្រការថា **មជ្ឈិមនិកាយេ សតិប្បដ្ឋានសុត្តន្តបរិយាយេ គមេ ភេទា** សេចក្តីថា គប្បីពោលដោយបរិយាយនៃសតិប្បដ្ឋានសូត្រ ក្នុងមជ្ឈិមនិកាយ យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះជាផ្លូវដំណើរទៅយ៉ាងឯក ។លៗ ត្រឹមតែដើម្បីសេចក្តីដឹង ត្រឹមតែដើម្បីជាទីអាស្រ័យរឭក អ្នកមិនជាប់នៅ និងមិនប្រកាន់អ្វីក្នុងលោក ម្នាលភិក្ខុទាំងឡាយ សូម្បីយ៉ាងនេះ ភិក្ខុរមែងជាអ្នកត្រេកអរក្នុងការនៃទា ជាអ្នកត្រេកអរហើយក្នុងការនៃទា ជាអ្នកត្រេកអរក្នុងការលះ ជាអ្នកត្រេកអរហើយក្នុងការលះ ម្នាលភិក្ខុទាំងឡាយ ក៏ប្រការដទៃនៅមាននៅទៀត ភិក្ខុកាលកំពុងទៅ ក៏ដឹងថា យើងកំពុងទៅ ។លៗ ម្នាលភិក្ខុទាំងឡាយ ក៏ប្រការដទៃនៅមាននៅទៀត ភិក្ខុគប្បីជាអ្នកឃើញនូវរាងកាយដែលគេទុកចោលក្នុងព្រៃស្មសាន ។លៗ ជារបស់ស្អុយរលួយ លោករមែងនាំចូលមកប្រៀបធៀបនឹងកាយនេះឯងថា សូម្បីរាងកាយនេះឯង ក៏មានធម៌យ៉ាងនេះ មានភាវៈយ៉ាងនេះ មិនកន្លងផុត ភាវៈយ៉ាងនេះទៅបាន ដូច្នេះ លោករមែងឃើញកាយក្នុងកាយដែលជាខាងក្នុង ដោយប្រការដូច្នេះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកត្រេកអរក្នុងការនៃទាសូម្បីយ៉ាងនេះឯង ។

ប្រការថា **អភិធម្មេ និទ្ទេសបរិយាយេ** សេចក្តីថា គប្បីពោលដោយបរិយាយនៃនិទ្ទេសក្នុងអភិធម្មយ៉ាងនេះថា ភិក្ខុកាលឃើញសង្ខតធម៌ សូម្បីទាំងពួងថា ជារបស់មិនទៀង ជាទុក្ខ ជារោគ ជាបូស ខ្ទោច ។លៗ ជាធម៌មានសេចក្តីសៅហ្មង រមែងត្រេកអរ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះឯង រមែងជាអ្នកត្រេកអរក្នុងការនៃទា ។

ប្រការថា **នេវ អត្តានុក្កំសេតិ** សេចក្តីថា ភិក្ខុរមែងមិនធ្វើការលើកខ្លួនឡើងយ៉ាងនេះថា កាលយើងធ្វើការងារក្នុងវិបស្សនាថា មិនទៀង ជាទុក្ខ ជាអនត្តា រហូតដល់អស់ ៦០ ឬ ៧០ ឆ្នាំ ក្នុងថ្ងៃនេះ នឹងមានអ្នកណាដូចយើងដូច្នេះ ។ ប្រការថា **ឆរំបរំ វម្ភេតិ** សេចក្តីថា ភិក្ខុរមែងមិនធ្វើការគ្រុបសង្កត់អ្នកដទៃយ៉ាងនេះថា សូម្បីត្រឹមតែហេតុវិបស្សនា ថាមិនទៀង ជាទុក្ខ ជាអនត្តា ក៏មិនមាន ( ដល់ភិក្ខុទាំងនេះ ) ហេតុដូចម្តេច ទើបភិក្ខុទាំងនេះ លះបង់ចោលកម្មដ្ឋាន ត្រាច់ទៅ ដូច្នេះ ។ ពាក្យដ៏សេសមានន័យដូចពោលហើយនុ៎ះឯង ។

[ ១០៩ ] ប្រការថា **បធានានិ** បានដល់ សេចក្តីព្យាយាមខ្ពស់បំផុត ។ ប្រការថា **សំវរប្បធានំ** សេចក្តីថា សេចក្តីព្យាយាមដែលកើតឡើងដល់ភិក្ខុដែលសង្រួមអាយតនៈ មានចក្ខុជាដើម ។

ប្រការថា **បហានប្បធានំ** សេចក្តីថា សេចក្តីព្យាយាមដែលកើតឡើងដល់ភិក្ខុដែលលះបង់កាមវិតក្កជាដើម ។ ប្រការថា **ភាវនាបធានំ** សេចក្តីថា សេចក្តីព្យាយាមដែលកើតឡើងដល់ភិក្ខុ ដែលចម្រើនពោជ្ឈង្គ ។ ប្រការថា **អនុរក្ខនាបធានំ** សេចក្តីថា សេចក្តីព្យាយាមដែលកើតឡើងដល់ភិក្ខុ ដែលតាមរក្សាសមាធិនិមិត្ត ។ ក្នុងប្រការថា **វិវេកនិស្សិតំ** ជាដើម សេចក្តីថា សូម្បីពាក្យទាំង ៣ គឺ **វិវេក វិរាគ និរោធ** ក៏ជាឈ្មោះរបស់ព្រះនិព្វាន ។

ពិតហើយ ព្រះនិព្វាន ឈ្មោះថា **វិវេក** ព្រោះស្ងាត់ចាកពីឧបធិកិលេស ឈ្មោះថា **វិរាគ** ព្រោះអត្ថថា កិលេសមានរាគៈជាដើមមកដល់ព្រះនិព្វាននោះរមែងប្រាសទៅ ឈ្មោះថា **និរោធ** ព្រោះអត្ថថា រលត់ ព្រោះហេតុនោះ ក្នុងពាក្យថា **វិវេកនិស្សិតំ** ជាដើម ទើបមានអធិប្បាយថា អាស្រ័យព្រះនិព្វាន

ដោយអំណាចជាអារម្មណ៍ ឬដោយអំណាចនៃសេចក្តីសម្រេច ។

ក្នុងពាក្យថា **វោស្សគ្គបរិណាមី** នេះ សេចក្តីថា ការលះបង់មាន ២ យ៉ាង ការលះបង់ គឺបរិច្ចាគ ១ ការលះបង់ គឺការត្រាច់ទៅ ១ ។ ក្នុង ២ យ៉ាងនោះ វិបស្សនា ឈ្មោះថា ការលះបង់ គឺបរិច្ចាគ ព្រោះអត្ថថា លះបង់កិលេស និងខន្ធបានដោយអង្គនោះ ។ មគ្គឈ្មោះថា ការលះបង់ គឺការត្រាច់ទៅ ព្រោះអត្ថថា ត្រាច់ទៅកាន់ព្រះនិព្វានដោយភាពជាអារម្មណ៍ ។ ព្រោះដូច្នោះ ក្នុងប្រការថា **វោស្សគ្គបរិណាមី** នេះ ទើបអធិប្បាយយ៉ាងនេះថា សតិសម្ពោជ្ឈង្គ ដែលភិក្ខុចម្រើនហើយ រមែងបង្អោនទៅដើម្បីសេចក្តីលះបង់ លោករមែងសម្រេចវិបស្សនាភាវនា និងមគ្គភាវនា យ៉ាងណា លោករមែងចម្រើនវោស្សគ្គៈដូច្នោះ ដូច្នេះ ។ សូម្បីក្នុងបទដ៏សេស ក៏ន័យនោះដូចគ្នា ។ សមាធិនិមិត្តដែលចម្រើន លោកហៅថា **ភទ្ទកំ** ។ សមាធិនុ៎ះឯង ជាការដែលភិក្ខុសម្រេចហើយ ដោយអំណាចអដ្ឋិកសញ្ញាជាដើម ។ ប្រការថា **អនុរក្ខតិ** សេចក្តីថា កាលភិក្ខុជម្រះរាគៈ ទោសៈ មោហៈ ដែលជាធម៌ចំណែកសត្រូវ រមែងរក្សាសមាធិបាន ។ ក្នុងសេចក្តីនេះ លោកពោលសញ្ញា ៥ ប្រការ មានអដ្ឋិកសញ្ញាជាដើម ។ ក្នុងឋានៈនេះ លោកពោលអសុភៈគ្រប់ទាំង ១០ ដោយពិស្តារ ។ សេចក្តីពិស្តាររបស់អសុភទាំងនោះ លោកពោលហើយ ក្នុងវិសុទ្ធិមគ្គនុ៎ះឯង ។

[ ១១០ ] ប្រការថា **ធម្មេ ញាណំ** សេចក្តីថា ញាណក្នុងសច្ចធម៌ ៤ និងញាណក្នុងនិរោធធម៌ ខាងក្នុងសច្ចៈ ៤ ដោយអំណាចការចាក់ធ្លុះតែម្យ៉ាង ។ ដូចដែលពោលហើយ ។ សួរថា ក្នុងញាណ ២ នោះ ញាណក្នុងធម៌ដូចម្តេច ។

ឆ្លើយថា ញាណក្នុងមគ្គ ៤ ផល ៤ ។ ប្រការថា **អន្វយេ ញាណំ** សេចក្ដីថា ញាណដែលប្រព្រឹត្តទៅតាមញាណនោះ យ៉ាងនេះថា ភិក្ខុឃើញសច្ចៈ ៤ ដោយប្រចក្សក្នុងឥឡូវនេះ យ៉ាងណា សូម្បីក្នុងអតីត សូម្បីក្នុងអនាគតក៏ដូច្នោះ ខន្ធទាំង ៥ នុ៎ះឯង ឈ្មោះថា ទុក្ខសច្ច តណ្ហានុ៎ះឯង ឈ្មោះថា សមុទយសច្ច និរោធនេះពិត ឈ្មោះថា និរោធសច្ច មគ្គនេះតែម្យ៉ាង ឈ្មោះថា មគ្គសច្ច ។ ព្រោះហេតុនោះ ទើបលោកពោលថា លោករមែងនាំន័យទៅក្នុងអតីត និងអនាគត ដោយការដឹង ការឃើញ ការសម្រេច ការដឹងច្បាស់ ការយល់ឃើញតាមធម៌នេះ ។ ប្រការថា **បរិច្ចេទេ ញាណំ** សេចក្ដីថា ញាណក្នុងការកំណត់ចិត្តរបស់អ្នកដទៃ ។ លោកបានពោលហើយ ។ បណ្ឌិតគប្បីឲ្យសេចក្ដីពិស្ដារថា ក្នុងញាណនោះ ញាណក្នុងការកំណត់ចិត្តដូចម្ដេច ។ ភិក្ខុក្នុងសាសនានេះ កំណត់ចិត្តរបស់សត្វដទៃ បុគ្គលដទៃបាន ដោយចិត្ត ក៏រមែងដឹងបាន ដូច្នេះ ។

ញាណដ៏សេស វៀរញាណទាំង ៣ នេះ ឈ្មោះថា សម្មតិញ្ញាណ ។ ដូចលោកពោលហើយថា ក្នុងសេចក្ដីនោះ សម្មតិញ្ញាណដូចម្ដេច ។ ញាណដ៏សេស វៀរញាណក្នុងធម៌ វៀរញាណក្នុងការទៅតាម វៀរញាណក្នុងការកំណត់ចិត្តចេញហើយ ឈ្មោះថា សម្មតិញ្ញាណ ដូច្នេះ ។ កម្មដ្ឋានក្នុងសច្ចៈ ៤ លោកពោលសរុបសម្រាប់ភិក្ខុមួយរូប ដែលសម្រេចអរហត្ត ដោយញាណក្នុងទុក្ខសច្ចជាដើម ។ បណ្ដាសច្ចៈ ៤ នោះ សច្ចៈ ២ ប្រការ ជាវដ្ដៈ ២ ប្រការទៀត ជាវិវដ្ដៈ ។ អភិនិវេសៈ ( សេចក្ដីប្រកាន់មាំ ) រមែងមានក្នុងវដ្ដៈ តែមិនមានក្នុងវិវដ្ដៈទេ ។ ភិក្ខុរៀនព្រះបរិយត្តិក្នុងសម្នាក់អាចារ្យ ឈ្មោះថា រមែង

ធ្វើការផ្សារក្នុងសច្ចៈ ២ ។ ភិក្ខុរមែងធ្វើការផ្សារក្នុងសច្ចៈ ២ ប្រការ ដោយអំណាចការស្តាប់ថា ធម្មតាថា និរោធសច្ចជារបស់ប្រសើរ គួរប្រាថ្នា គួរពេញចិត្ត ធម្មតាថា មគ្គសច្ច ជារបស់គួរប្រាថ្នា គួររីករាយ គួរពេញចិត្ត ។ ការចាក់ធ្លុះដោយអំណាចការរៀន ការសាកសួរ ការស្តាប់ ការទ្រទ្រង់ចាំ ការពិចារណាក្នុងសច្ចៈ ២ រមែងគួរ ។ ការចាក់ធ្លុះដោយអំណាចការស្តាប់ក្នុងសច្ចៈ ២ រមែងគួរ ។ លោករមែងចាក់ធ្លុះដល់សច្ចៈ ៣ ដោយអំណាចកិច្ច ។ រមែងចាក់ធ្លុះដល់សច្ចៈ ១ ដោយអំណាចភាពជាអារម្មណ៍ ។ សច្ចៈ ២ ប្រការ ជារបស់ជ្រាលជ្រៅ ព្រោះឃើញបានលំបាក ។ សច្ចៈ ២ ប្រការ ឈ្មោះថា ឃើញបានលំបាក ព្រោះមានសភាពជ្រាលជ្រៅ ។

[ ១១១ ] ប្រការថា **សោតាបត្តិយង្គានិ** សេចក្តីថា អង្គនៃការសម្រេចក្រសែ អធិប្បាយថា ហេតុនៃការបានសោតាបត្តិមគ្គ ។ ប្រការថា **សប្បុរិស–សំសេវោ** សេចក្តីថា ការចូលទៅសេពគប់សប្បុរស មានព្រះពុទ្ធជាដើម ។ ប្រការថា **សទ្ធម្មស្សវនំ** សេចក្តីថា ការស្តាប់ធម៌ គឺព្រះត្រៃបិដក ដែលជាទីសប្បាយ ។ ប្រការថា **យោនិសោមនសិការោ** សេចក្តីថា ការធ្វើទុកក្នុងចិត្តដោយអំណាចអនិច្ចលក្ខណៈជាដើម ។

ប្រការថា **ធម្មានុធម្មប្បដិបត្តិ** សេចក្តីថា បដិបត្តិបដិបទា ដែលមានក្នុងចំណែកខាងដើម ដែលជាធម៌បណ្តោយទៅតាមលោកុត្តរធម៌ ។

[ ១១២ ] ប្រការថា **អវេច្ចប្បសាទេន** សេចក្តីថា ដោយសទ្ធាដែលមុតមាំ ។ ព្រះពុទ្ធគុណថា **ឥតិបិ សោ ភគវា** ដូច្នេះជាដើម លោកឲ្យពិស្តារទុកហើយក្នុងវិសុទ្ធិមគ្គ ។

[ ១១៣-១១៥ ] ពួក ៤ នៃផល ធាតុ និងអាហារ មានសេចក្តីងាយ នោះឯង ។ ម្យ៉ាងទៀត ក្នុងសេចក្តីនេះ បណ្ឌិតគប្បីជ្រាបសេចក្តីជារបស់គ្រោតគ្រាត និងល្អិត ដោយអំណាចសេចក្តីជារបស់គ្រោតគ្រាត និងប្រណីត ។

[ ១១៦ ] ប្រការថា **វិញ្ញាណដ្ឋិតិយោ** សេចក្តីថា ដែលឈ្មោះថា វិញ្ញាណដ្ឋិតិ ព្រោះអត្ថថា ជាទីតាំងរបស់វិញ្ញាណ ។ ពាក្យនេះ លោកបានពោលហើយ ដោយអំណាចជាទីតាំងរបស់អារម្មណ៍ ។ ប្រការថា **រូបូបាយំ** សេចក្តីថា ជាសភាពចូលដល់រូប ។ ពិតហើយ អភិសង្ខារវិញ្ញាណ អាស្រ័យរូបក្ខន្ធ តាំងនៅក្នុងបញ្ចវោការភព ។ ពាក្យនេះ លោកពោលសំដៅដល់វិញ្ញាណនោះ ។ ប្រការថា **រូបារម្មណំ** សេចក្តីថា មានរូបក្ខន្ធជាអារម្មណ៍ ។ ប្រការថា **រូបប្បតិដ្ឋំ** សេចក្តីថា ជារបស់តាំងនៅ ចំពោះហើយក្នុងរូប ។ ប្រការថា **នន្ទូបសេវនំ** សេចក្តីថា ជាវត្ថុដែលសេចក្តីពេញចិត្តចូលទៅអាស្រ័យ ព្រោះសម្បយុត្តដោយចិត្តដែលសហគតៈដោយលោភៈ ។ ក្រៅពីនេះ ជារបស់ត្រូវចំណែកបំផុតនៃការប្រព្រឹត្តដែលធ្លាប់ហើយ ចូលទៅអាស្រ័យ ។ ប្រការថា **វុឌ្ឍឹ វិរុឡ្ហឹ វេបុល្លំ អាបជ្ជតិ** សេចក្តីថា ដល់សេចក្តីចម្រើនលូតលាស់ ធំទូលាយ ដែលប្រព្រឹត្តទៅហើយយ៉ាងនេះ ៦០ ឆ្នាំខ្លះ ៧០ ឆ្នាំខ្លះ ។ ន័យក្នុងឧបាយនៃវេទនាជាដើម ក៏ន័យនេះ ។ ក្នុងចតុវោការភព លោកពោលអភិសង្ខារវិញ្ញាណ ដោយបទទាំង ៣ នេះ ។ គប្បីជ្រាបការដល់សេចក្តីចម្រើនលូតលាស់ ធំទូលាយ ដោយអំណាចការប្រព្រឹត្តទៅ ដរាបស្មើនឹងអាយុរបស់វិញ្ញាណនោះ ។ លោកមិនពោលថា ឧបាយនៃវិញ្ញាណ ដូច្នេះ ព្រោះមកហើយ ដោយទេសនាតាមពួក ៤ ។ កាលពោលទៅយ៉ាងនេះ ក៏នឹងជាការវង្វេងធ្ងន់ឡើងថា ក្នុងទីនេះ

កម្មវិញ្ញាណដូចម្ដេច ។ វិបាកវិញ្ញាណដូចម្ដេច ។ ព្រោះហេតុនោះ ទើបមិនបានពោល ។

[ ១១៧ ] ការលុះក្នុងអគតិ លោកឲ្យពិស្ដារហើយនោះឯង ។

[ ១១៨ ] ប្រការថា ចីវរហេតុ សេចក្ដីថា កើតឡើងព្រោះមានចីវរជាហេតុថា យើងនឹងបានចីវរ ដែលពេញចិត្តក្នុងទីណា ។ **ឥតិ** សព្ទ ក្នុងប្រការថា **ឥតិ ភវាភវហេតុ** នេះ ជានិបាត ចុះក្នុងការចង្អុលបង្ហាញ អធិប្បាយថា ហេតុមានចីវរជាដើមយ៉ាងណា ហេតុមានកពា និងអកពជាដើម ( ហេតុដែលប្រណីត និងប្រណីតជាង ) យ៉ាងណា ។ ក្នុងប្រការថា **ភវាភវោ** នេះ លោកប្រាថ្នាយកប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើម ដែលប្រណីត និងប្រណីតជាង ។គប្បីជ្រាបថា អរិយវង្ស ៤ លោកសម្ដែងតាមលំដាប់តែម្យ៉ាង ដើម្បីលះតណ្ហា និងឧបាទានទាំង ៤ នេះ ។

[ ១១៩ ] ពួក ៤ នៃបដិបទា លោកពោលហើយទុំះឯង ។

[ ១២០ ] ក្នុងការអត់ធន់មិនបានជាដើម មានវិគ្រោះដូច្នេះ ភិក្ខុដែលឈ្មោះថា **អក្ខមា** ព្រោះអត្ថថា អត់ធន់ក្នុងភាពត្រជាក់មិនបានជាដើម ក្នុងវេលាធ្វើសេចក្ដីព្យាយាម ។ ឈ្មោះថា **ខមា** ព្រោះអត្ថថា ទ្រាំបាន ។ ការទូន្មានឥន្ទ្រិយ ឈ្មោះថា **ទមា** ។ សេចក្ដីស្ងប់វិតក្ក ដោយន័យជាដើមថា អត់ទ្រាំចំពោះកាមវិតក្ក ដែលកើតឡើងមិនបាន ឈ្មោះថា **សមា**។

[ ១២១ ] ប្រការថា **ធម្មបទានិ** សេចក្ដីថា ចំណែកនៃធម៌ ។ ការមិនសម្លឹងរំពៃ ឈ្មោះថា បទនៃធម៌ ម្យ៉ាងទៀត សេចក្ដីមិនលោភ ដោយមានសេចក្ដីមិនលោភជាធំ ឬការសម្រេចឈាន វិបស្សនា មគ្គ ផល និងនិព្វាន

ក៏ឈ្មោះថា បទនៃធម៌ ការមិនព្យាបាទ ឈ្មោះថា បទនៃធម៌ ឬការមិនក្រោធ ដោយមានមេត្តាជាគោល ឬការសម្រេចឈានជាដើម ឈ្មោះថា បទនៃធម៌ ។ សម្មាសតិ ឈ្មោះថា បទនៃធម៌ ម្យ៉ាងទៀត ការតាំងសតិមាំ ដោយមានសតិជាគោល ឬការសម្រេចឈានជាដើម ឈ្មោះថា បទនៃធម៌ ។ សម្មាសមាធិ ឈ្មោះថា បទនៃធម៌ ម្យ៉ាងទៀត សមាបត្តិ ដោយអំណាចសមាបត្តិ ៨ ឬការសម្រេចឈាន វិបស្សនា មគ្គ ផល និងនិព្វាន ឈ្មោះថា បទនៃធម៌ ។ ការសម្រេចឈានជាដើម ដោយអំណាចអសុភ ១០ ឬការមិនសម្លឹងរំពៃ ឈ្មោះថា បទនៃធម៌ ។ បទនៃធម៌ ដែលសម្រេចដោយអំណាចព្រហ្មវិហារ ៤ ( ឬ ) ការមិនព្យាបាទ ឈ្មោះថា បទនៃធម៌ ។ បទនៃធម៌ ដែលសម្រេចដោយអំណាចអនុស្សតិ ១០ និងអាហារេបដិកូលសញ្ញា ( ឬ ) សម្មាសតិ ឈ្មោះថា បទនៃធម៌ ។ បទនៃធម៌ដែលសម្រេចដោយអំណាចកសិណ ១០ និងអានាបានស្សតិ ( ឬ ) សម្មាសមាធិ ឈ្មោះថា បទនៃធម៌ ដូច្នេះឯង ។

[ ១២២ ] ក្នុងការសមាទានធម៌ទាំងឡាយ មានសេចក្ដីដូច្នេះ ការសមាទានប្រការដំបូង ជាបដិបទារបស់អចេលក៍ ។ ការសមាទានប្រការទី ២ ជាការប្រព្រឹត្តព្រហ្មចរិយៈដ៏បរិសុទ្ធរបស់បុគ្គល ដែលមានកិលេសខ្លាំងក្លា មិនអាចដើម្បីកាន់យកនូវអរហត្តបាន ជាបុគ្គលស្រែកយំ មានមុខទទឹកដោយទឹកភ្នែក ។ ការសមាទានប្រការទី ៣ ជាការសមាទានដែលធ្លាក់ទៅក្នុងកាមទាំងឡាយ ។ ការសមាទានប្រការទី ៤ ជាការប្រព្រឹត្តព្រហ្មចរិយៈក្នុងសាសនារបស់បុគ្គលដែលមិនបានបច្ច័យ ៤តែក៏ព្រមព្រៀងគ្នាដោយសេចក្ដីសុខ ដោយអំណាចឈាន និងវិបស្សនា ។

[ ១២៣ ] ក្នុងប្រការថា **ធម្មក្ខន្ធា** នេះ បានដល់ បុគ្គលដែលតាំងនៅក្នុងគុណ គឺតាំងនៅក្នុងខន្ធ ។ ប្រការថា **សីលក្ខន្ធោ** បានដល់ គុណរបស់សីល ។ ផលរបស់សីល លោកប្រាថ្នាយកក្នុងសេចក្តីនេះ ។ សូម្បីក្នុងបទដ៏សេស ក៏ន័យនេះដូចគ្នា ។ ផលទាំងឯង លោកពោលក្នុងឋានៈសូម្បីទាំង ៤ ដោយប្រការដូច្នេះ ។

[ ១២៤ ] ប្រការថា **ពលានិ** សេចក្តីថា ដែលឈ្មោះថា កម្លាំងទាំងឡាយ ព្រោះអត្ថថា ជាគ្រឿងឧបត្ថម្ភ និងព្រោះអត្ថថា មិនកម្រើក ។ បណ្ឌិតគប្បីជ្រាបកម្លាំងទាំងនោះ ជារបស់មិនកម្រើកដោយធម៌ មានកោសជ្ជៈជាដើម ដែលជាបដិបក្ខ ។ កម្លាំងសទាំងអស់ ទាំងដែលជាលោកិយ និងលោកុត្តរ លោកពោលហើយដោយអំណាចសមថៈ វិបស្សនា និងមគ្គ ។

[ ១២៥ ] **អធិ** សព្ទ ក្នុងប្រការថា **អធិដ្ឋានានិ** នេះ ត្រឹមតែជាឧបសគ្គ ។ តែពោលដោយអត្ថហើយ ក៏មានន័យថា ជាហេតុតាំងនៅ ជាទីតាំងនៅរបស់គុណធម៌ ឬថា ជាឋានៈ គឺការតាំងចិត្តមាំរបស់អ្នកដែលសន្សំគុណនោះៗ ។ ការតាំងចិត្តមាំ គឺបញ្ញា ឈ្មោះថា បញ្ញាធិដ្ឋាន ។ ក្នុងទីនេះ ព្រះមូសិយាកយត្ថេរពោលថា បណ្ឌិតគប្បីជ្រាបថា បញ្ញាក្នុងមគ្គ និងផល លោកពោលដោយអធិដ្ឋានប្រការទីមួយ វាចាសត្យ ពោលដោយអធិដ្ឋានប្រការទីពីរ បរិច្ចាគអាមិស ពោលដោយអធិដ្ឋានប្រការទីបី ការស្ងប់កិលេស ពោលដោយអធិដ្ឋានប្រការទីបួន ម្យ៉ាងទៀត បញ្ញាក្នុងផល ចាប់ផ្តើមតាំងពីកម្មស្សកតាបញ្ញា ឬវិបស្សនាបញ្ញា ពោលដោយអធិដ្ឋានប្រការទីមួយ ព្រះនិព្វានដែលជាបរមត្ថសច្ច ចាប់ផ្តើមតាំងពីវាចាសត្យ ពោលដោយអធិដ្ឋានប្រការទីពីរ ការលះបង់កិលេសដោយអរហត្តមគ្គ ចាប់ផ្តើមតាំងអំពីបរិច្ចាគ

អាមិស ពោលដោយអធិដ្ឋានប្រការទីបី ការស្ងប់កិលេសដោយអរហត្តមគ្គ ចាប់ផ្ដើមតាំងអំពីការគ្របសង្កត់កិលេសបាន ដោយសមាបត្តិ ពោលដោយអធិដ្ឋានប្រការទីបួន ម្យ៉ាងទៀត បញ្ញាក្នុងអរហត្តផល ពោលដោយបញ្ញា-ធិដ្ឋានប្រការទីមួយ បរមត្ថសច្ច ពោលដោយបញ្ញាធិដ្ឋាន ប្រការដ៏សេសម្យ៉ាងទៀត បរមត្ថសច្ច ពោលដោយសច្ចាធិដ្ឋានប្រការមួយ បញ្ញាក្នុងអរហត្តផល ពោលដោយបញ្ញាធិដ្ឋានដ៏សេស ដូច្នេះ ។

[ ១២៦ ] ព្យាករណបញ្ហា លោកឲ្យពិស្ដារហើយ ក្នុងកថាមហា-និទ្ទេសនោះឯង ។

[ ១២៧ ] ប្រការថា **កណ្ហំ** បានដល់ អកុសលកម្មបថ ១០ ដែលជាធម៌ចំណែកខ្មៅ ។

ប្រការថា **កណ្ហវិបាកំ** បានដល់ ផលរបស់អកុសលកម្ម ព្រោះឲ្យសត្វអ្នកធ្វើកើតក្នុងអបាយ ។ ប្រការថា **សុក្កំ** បានដល់ កុសលកម្មបថ ១០ ដែលជាធម៌ចំណែកស ។ ប្រការថា **សុក្កវិបាកំ** បានដល់ ផលរបស់កុសលកម្ម ព្រោះឲ្យសត្វអ្នកធ្វើកើតក្នុងសួគ៌ ។

ប្រការថា **កណ្ហសុក្កំ** បានដល់ កម្មដែលលាយគ្នា ។ ប្រការថា **កណ្ហ-សុក្កវិបាកំ** បានដល់ ផលដែលជាសុខ និងជាទុក្ខ ។ ពិតហើយ បុគ្គលដែលធ្វើកម្មលាយគ្នា ទៅកើតក្នុងកន្លែងដំរីមង្គលជាដើម ក្នុងកំណើតសត្វតិរច្ឆាន ព្រោះអកុសល សោយសុខក្នុងបច្ចុប្បន្នព្រោះកុសល ។ បុគ្គលដែលកើតក្នុងរាជត្រកូលព្រោះកុសល រមែងសោយទុក្ខក្នុងបច្ចុប្បន្ន ដោយអកុសល ។ ប្រការថា មិនខ្មៅមិនស សេចក្ដីថា លោកប្រាថ្នាយកញាណក្នុងមគ្គ ៤ ដែលធ្វើឲ្យអស់កម្ម ។ ពិតហើយ កម្មនោះ បើជាកម្មចំណែកខ្មៅ ( អកុសល )

ក៏គប្បីឲ្យផលរបស់កម្មចំណែកខ្មៅ បើជាកម្មចំណែកស (កុសល) ក៏គប្បីឲ្យផលរបស់កម្មចំណែកស ។ កម្មដែលឈ្មោះថា មិនខ្មៅមិនស ព្រោះមិនឲ្យផលទាំងពីរ ព្រោះមានផលមិនខ្មៅ មិនស ក្នុងសេចក្តីនេះ មានអធិប្បាយដូចពោលមកនេះ ។

[ ១២៨ ] ប្រការថា **សច្ចិករណីយានិ** សេចក្តីថា គប្បីធ្វើឲ្យច្បាស់ដោយធ្វើឲ្យប្រចក្ស និងដោយការបានចំពោះ ។ បទថា **ចក្ខុនា** បានដល់ទិព្វចក្ខុ ។ ប្រការថា **កាយេន** បានដល់ សហជាតនាមកាយ ។ ប្រការថា **បញ្ញាយ** បានដល់ ញាណក្នុងអរហត្តផល ។

[ ១២៩ ] ក្នុងបទថា **ឱឃ** មានវិគ្រោះថា ដែលឈ្មោះថា ឱឃៈ ព្រោះអត្ថថា ពន្លិច គឺធ្វើសត្វឲ្យលិចចុះក្នុងវដ្តៈ បណ្តាឱឃៈនោះ តម្រេកដែលជាប់ទាក់ទងនឹងកាមគុណ ៥ ឈ្មោះថា ឱឃៈ គឺកាម ។ តម្រេកដោយសេចក្តីពេញចិត្តក្នុងរូបភព និងអរូបភព ឈ្មោះថា ឱឃៈ គឺភព ។ សេចក្តីជាប់ចិត្តក្នុងញាណ និងតម្រេកដែលសហគតៈដោយសស្សតទិដ្ឋិ ក៏ដូចគ្នា ។ ទិដ្ឋិ ៦២ ឈ្មោះថា ឱឃៈ គឺទិដ្ឋិ ។

[ ១៣០ ] ដែលឈ្មោះថា **យោគ** ព្រោះអត្ថថា ប្រកបសត្វទុកក្នុងវដ្តៈ ។ យោគៈទាំងនោះគប្បីជ្រាបថា ដូចឱឃៈ ។

[ ១៣១ ] ដែលឈ្មោះថា **វិសំយោគ** ព្រោះអត្ថថា មិនប្រកបសត្វទុក ។ ក្នុងវិសំយោគនោះ អសុភជ្ឈាន ឈ្មោះថា ការមិនប្រកបដោយកាមយោគៈ អនាគាមិមគ្គ ដែលបុគ្គលសម្រេចដោយធ្វើអសុភជ្ឈាននោះឲ្យជាបាទ ឈ្មោះថា ការមិនប្រកបដោយកាមយោគៈ ដោយចំណែកមួយ ។ អរហត្តមគ្គ ឈ្មោះថា ការមិនប្រកបដោយភវយោគៈ ។ សោតាបត្តិមគ្គ ឈ្មោះថា ការមិនប្រកប

ក្នុងទិដ្ឋិយោគៈ ។ អរហត្តមគ្គ ឈ្មោះថា ការមិនប្រកបក្នុងអវិជ្ជាយោគៈ ។

[ ១៣២ ] កិលេសដែលឈ្មោះថា **គន្ថា** ដោយអំណាចចង ( សត្វ ) ។ ដែលឈ្មោះថា **កាយគន្ថ** ព្រោះអត្ថថា ចង គឺព័ទ្ធ បានដល់ រូបរីតនាមកាយ និងរូបកាយទុកក្នុងវដ្តៈ ។ ប្រការថា **ឥទំ សច្ចាភិនិវេសោ** សេចក្តីថា អភិនិវេស គឺទិដ្ឋិដែលប្រព្រឹត្តទៅយ៉ាងនេះថា នេះប៉ុណ្ណោះពិត យ៉ាងដទៃទទេ ដូច្នេះ ។

[ ១៣៣ ] ប្រការថា **ឧបាទានានិ** បានដល់ ការកាន់យកដោយការប្រកាន់មាំ ។ តម្រេក ឈ្មោះថា កាម ។ កាមនោះឯង ឈ្មោះថា កាមុបាទាន ព្រោះអត្ថថា ប្រកាន់មាំ ដោយអត្ថថា ប្រកាន់ទុក ។ មិច្ឆាទិដ្ឋិ ឈ្មោះថា ទិដ្ឋិ ។ ទិដ្ឋិនោះ ឈ្មោះថា ទិដ្ឋុបាទាន ព្រោះអត្ថថា ប្រកាន់មាំ ដោយអត្ថថា ប្រកាន់ទុក ។ ការប្រកាន់សីលវត្តយ៉ាងនេះថា សេចក្តីបរិសុទ្ធិមានដោយសីលវត្តនេះ ឈ្មោះថា ការប្រកាន់មាំដោយសីលវត្ត ។

ឈ្មោះថា **អត្តវាទុបាទាន** ព្រោះអត្ថថា ជាហេតុឲ្យហៅថា ខ្លួន និងជាហេតុនៃការប្រកាន់មាំ ។

[ ១៣៤ ] ប្រការថា **យោនិយោ** ប្រែថា ចំណែកទាំងឡាយ ។ ពួកសត្វដែលឈ្មោះថា **អណ្ឌជ** ព្រោះអត្ថថា កើតក្នុងពង ។ ឈ្មោះថា **ជលាពុជ** ព្រោះអត្ថថា កើតក្នុងគភ៌ ។

ឈ្មោះថា **សំសេទជ** ព្រោះអត្ថថា កើតអំពីញើសក្អែល ។ ពាក្យនេះជាឈ្មោះរបស់សត្វដែលកើតក្នុងទីជេក និងក្នុងទីស្មោកគ្រោក មានត្រីស្អុយជាដើម ។ ដែលឈ្មោះថា **ឱបបាតិក** ព្រោះអត្ថថា ដូចជាមកកើតឡើងដោយ

ធាប់របស់ ។ ក្នុងសេចក្ដីនោះ នេះជាសេចក្ដីផ្សេងគ្នា រវាងសត្វកើតអំពីញើស ក្អែល និងសត្វដែលកើតភ្លាមឡើងក្នុងពួកទេវតា និងមនុស្ស ។ សត្វជំពូក សំសេទជៈ កើតមានខ្លួនតូចៗ សត្វជំពូកឱបបាតិកៈ កើតមានខ្លួនស្មើនឹងអ្នក អាយុ ១៦ ឆ្នាំ ។ ពិតហើយ ក្នុងពួកមនុស្ស និងភុម្មទេវតា រមែងមានកំណើត ទាំងបួននេះ បានទាំងអស់ ។ ក្នុងពួកគ្រុឌ និងនាគជាដើម ដែលជាសត្វតិរច្ឆាន ក៏ដូចគ្នា ។ សមពិត ដូចព្រះតម្រាស់ដែលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បណ្ដាគ្រុឌ និងនាគនោះ ពួកគ្រុឌដែលជាសត្វកើតក្នុងពង រមែងចាប់ពួកនាគ ដែលជាសត្វកើតក្នុងពងដូចគ្នា តែចាប់ពួកសត្វជាជលាពុជៈ សំសេទជៈ ឱបបាតិកៈ មិនបាន ។ ទេវតាជាន់ខ្ពស់ៗ ឡើងទៅ តាំងពីជាន់ចាតុម្មហារាជិកា ចាត់ជាពួកឱបបាតិកៈនោះឯង ។ សត្វនរកក៏ដូចគ្នា ។ ក្នុងពួកប្រេត ក៏មាន កំណើតបានគ្រប់ទាំង ៤ ។

[ ១៣៥ ] ការឈានចុះកាន់គភ៌ លោកពោលមកហើយ **ក្នុងសម្បសាទនីយសូត្រ** នុ៎ះឯង ។

[ ១៣៦ ] ក្នុងការត្រឡប់បានអត្តភាពសត្វចំពូកទីមួយ គប្បីជ្រាប ដោយអំណាចការខ្វល់ខ្វាយក្នុងការលេង ជំពូកទីពីរ គប្បីជ្រាបដោយអំណាច សត្វខាងក្នុងជាដើម ដែលត្រូវសត្វខាងក្នុងជាដើមទម្លាយ ជំពូកទីបី គប្បីជ្រាប ដោយអំណាចការប្រទូស្តតាមផ្លូវចិត្ត ជំពូកទីបួន គប្បីជ្រាបដោយអំណាច ទេវតាដ៏សេសជាន់ខ្ពស់ឡើងទៅ ចាប់តាំងអំពីជាន់ចាតុម្មហារាជិកា ។ ពិតហើយ ទេវតាទាំងនោះ រមែងមិនស្លាប់ដោយសេចក្ដីពេញចិត្តរបស់ខ្លួនឯង ទាំងមិនស្លាប់ ដោយសេចក្ដីពេញចិត្តរបស់សត្វដទៃ ។

[ ១៣៧ ] ក្នុងប្រការថា **ទក្ខិណាវិសុទ្ធិយោ** មានវិគ្រោះថា ដែលឈ្មោះថា ទក្ខិណាវិសុទ្ធិ ព្រោះអត្ថថា ជាហេតុឲ្យទក្ខិណា ពោល គឺទានបរិសុទ្ធ មានផលច្រើន ។

ប្រការថា **ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ** សេចក្ដីថា ក្នុងទក្ខិណាណា ទាយកជាអ្នកមានសីល ថ្វាយទេយ្យធម៌ដែលកើតឡើងដោយធម៌ តែបដិគ្គាហក ( អ្នកទទួល ) ជាអ្នកទ្រុស្តសីល ទក្ខិណានេះ ដូចជាទក្ខិណារបស់ព្រះវេស្សន្តរមហារាជ ។

ប្រការថា **បដិគ្គាហកតោ វិសុជ្ឈតិ នោ ទាយកតោ** សេចក្ដីថា ក្នុងទក្ខិណាណា បដិគ្គាហកជាអ្នកមានសីល តែទាយកជាអ្នកមិនមានសីល ថ្វាយទេយ្យធម៌ដែលកើតឡើងមិនប្រកបដោយធម៌ ទក្ខិណានេះ ដូចជាទក្ខិណារបស់អ្នកសម្លាប់ចោរ ។ ប្រការថា **នេវ ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ** សេចក្ដីថា ក្នុងទក្ខិណាណា ទាំងពីរចំណែក ជាអ្នកទ្រុស្តសីល ឯទេយ្យធម៌ក៏កើតឡើងមិនប្រកបដោយធម៌ ។ ជំពូកទី ៤ គប្បីជ្រាបដោយបរិយាយផ្ទុយគ្នា ។

[ ១៣៨ ] ប្រការថា **សង្គហវត្ថូនិ** សេចក្ដីថា ហេតុនៃការសង្គ្រោះ ។ ការសង្គ្រោះទាំងនោះ លោកបានចែកហើយនុ៎ះឯង ។

[ ១៣៩ ] ប្រការថា **អនរិយវោហារា** សេចក្ដីថា វោហាររបស់បុគ្គលដែលមិនមែនអរិយៈ គឺរបស់បុគ្គលលាមក ។

[ ១៤០ ] ប្រការថា **អរិយវោហារា** សេចក្ដីថា វោហាររបស់ព្រះអរិយៈ គឺសប្បុរស ។

[ ១៤១-១៤៤ ] ប្រការថា **ទិដ្ឋវាទិតា** សេចក្ដីថា ភាពជាអ្នកមានប្រក្រតី

ពោលយ៉ាងនេះថា យើងឃើញមកជាដើម ក្នុងសេចក្ដីនេះ គប្បីជ្រាបខ្លឹមសារ ដោយអំណាចចេតនាជាហេតុឲ្យពាក្យទាំងនោះតាំងឡើង ។

[ ១៤៥ ] ក្នុងពួកជនដែលមានតបៈជារបស់ខ្លួនជាដើម មានអធិប្បាយ ដូច្នេះ ។ ពួកទីមួយ បានដល់ អចេលក៍ ។ ពួកទីពីរ បានដល់ បណ្ដាបុគ្គល ខាងក្នុងជាដើមណាមួយ ។ ពួកទីបី បានដល់ អ្នកបូជាយញ្ញ ។ ពួកទីបួន បានដល់ អ្នកបដិបត្តិត្រូវក្នុងសាសនា ។

[ ១៤៦ ] ក្នុងពួកជន អ្នកដែលបដិបត្តិដើម្បីប្រយោជន៍ដល់ខ្លួនជាដើម មានអធិប្បាយដូច្នេះ ។ ពួកទីមួយ បានដល់ អ្នកដែលខ្លួនឯងប្រកបព្រមដោយ គុណ មានសីលជាដើម តែមិនដឹកនាំអ្នកដទៃក្នុងគុណ មានសីលជាដើម ប្រៀប ដូចព្រះវក្កលិត្ថេរ ដូច្នោះ ។ ពួកទីពីរ បានដល់ អ្នកដែលខ្លួនឯងមិនសម្បូរ ដោយគុណ មានសីលជាដើម តែដឹកនាំអ្នកដទៃក្នុងគុណ មានសីលជាដើម ប្រៀបដូចព្រះឧបនន្ទ ដូច្នោះ ។ ពួកទីបី បានដល់ អ្នកដែលខ្លួនឯង ក៏មិន សម្បូរដោយគុណ មានសីលជាដើម និងមិនដឹកនាំអ្នកដទៃក្នុងគុណ មាន សីលជាដើម ប្រៀបដូចភិក្ខុទេវទត្ត ដូច្នោះ ។ ពួកទីបួន បានដល់ បុគ្គលដែល ខ្លួនឯងក៏សម្បូរដោយគុណ មានសីលជាដើម ទាំងដឹកនាំអ្នកដទៃក្នុងគុណ មានសីលជាដើម ប្រៀបដូចព្រះមហាកស្សប ដូច្នោះ ។

[ ១៤៧ ] ក្នុងបុគ្គលដែលឈ្មោះថា ងងឹតជាដើម មានអធិប្បាយដូច្នេះ ។ ប្រការថា **តមោ** បានដល់ បុគ្គលដែលងងឹតឈឹង ។ ប្រការថា **តមបរាយណោ** សេចក្ដីថា អ្នកដែលឈ្មោះថា **តមបរាយណោ** ព្រោះអត្ថថា មានសេចក្ដីងងឹត នុ៎ះឯង ជាផ្លូវដើរទៅ គឺទៅខាងមុខ ។

គ្រប់ៗ បទ គប្បីជ្រាបសេចក្តីយ៉ាងនេះ ។ ក្នុងបុគ្គលទាំង ៤ ជំពូកនេះ ជំពូកទីមួយ កើតក្នុងអត្តភាពដែលថោកទាប មានការរស់នៅយ៉ាងក្រីក្រ មានត្រកូលមនុស្សចណ្ឌាលជាដើម ដែលជាត្រកូលថោកទាប ធ្វើទុច្ចរិត ៣ ឲ្យបរិបូណ៌ ។ ជំពូកទីពីរក៏យ៉ាងនោះ តែបំពេញសុចរិត ៣ ឲ្យបរិបូណ៌ ។ ជំពូកទី ៣ កើតក្នុងអត្តភាពដែលសម្បូរ មានបាយ និងទឹកច្រើន មានត្រកូលក្សត្រជាដើម ដែលជាត្រកូលខ្ពង់ខ្ពស់ តែធ្វើទុច្ចរិត ៣ ឲ្យបរិបូណ៌ ។ ជំពូកទី ៤ ក៏យ៉ាងនោះដូចគ្នា តែបំពេញសុចរិត ៣ ឲ្យបរិបូណ៌ ។

[ ១៤៨ ] ប្រការថា **សមណមចលោ** សេចក្តីថា សមណៈអ្នកមិនញាប់ញ័រ ។ **ម** អក្ខរៈ ត្រឹមតែជាបទសន្ធិ ។ សមណៈអ្នកមិនញាប់ញ័រនោះ គប្បីជ្រាប ( ថា ) បានដល់ ព្រះសោតាបន្ន ។ ពិតហើយ ព្រះសោតាបន្ន ឈ្មោះថា សមណៈអ្នកមិនញាប់ញ័រ ព្រោះអត្ថថា ជាអ្នកមិនញាប់ញ័រ ដោយការពោលប្រទូស្តអំពីអ្នកដទៃ ដូចសសរខឿន មិនញាប់ញ័រ ព្រោះខ្យល់ទាំង ៤ ដូច្នោះ ជាអ្នកប្រកបដោយសទ្ធាដ៏មុតមាំ ។ សមពិត តាមពាក្យដែលលោកពោលហើយ សេចក្តីពិស្តារថា បុគ្គលណា ឈ្មោះថា សមណៈអ្នកមិនញាប់ញ័រ បុគ្គលខ្លះក្នុងលោកនេះ ( ដែលឈ្មោះថា សមណៈអ្នកមិនញាប់ញ័រ ) ព្រោះអស់សញ្ញោជនៈ ៣ ។ ចំណែកព្រះសកទាគាមី ឈ្មោះថា សមណៈផ្កាបទុម ព្រោះអត្ថថា មានរាគៈ ទោសៈ និងមោហៈស្រាលស្តើង ព្រោះហេតុនោះ ទើបលោកពោលថា បុគ្គលណាឈ្មោះថា សមណៈផ្កាបទុម បុគ្គលខ្លះក្នុងលោកនេះ មកកាន់លោកនេះតែម្តងទៀតប៉ុណ្ណោះ រមែងធ្វើទីបំផុតទុក្ខបាន បុគ្គលនេះ លោកហៅថា សមណៈផ្កាបទុម ។ ព្រះអនាគាមី ឈ្មោះថា សមណៈ

ផ្កាបុណ្ឌរិក ព្រោះអត្ថថា នឹងត្រាស់ដឹង (រីក) ឆាប់រហ័ស ព្រោះមិនមានរាគៈ និងទោសៈ ។ ព្រោះហេតុនោះ ទើបលោកពោលថា បុគ្គលណា ឈ្មោះថា សមណៈផ្កាបុណ្ឌរិក បុគ្គលខ្លះក្នុងលោកនេះ (លះ) សញ្ញោជនៈខាងក្រោម ៥ ។ល។ បុគ្គលនេះ លោកហៅថា សមណៈផ្កាបុណ្ឌរិក ។ ចំណែកព្រះអរហន្ត ឈ្មោះថា សមណៈសុខុមាល ( សមណៈអ្នកល្អិតល្អន់ទន់ខ្សោយ ) ក្នុងបណ្ដា សមណៈ (ជាមួយគ្នា) ព្រោះមិនមានកិលេសគ្រប់យ៉ាង ដែលធ្វើឲ្យរឹងត្អឹង ។ ព្រោះហេតុនោះ ទើបលោកពោលថា ក្នុងបណ្ដាសមណៈ បុគ្គលណា ឈ្មោះថា សមណៈសុខុមាល បុគ្គលខ្លះក្នុងលោកនេះ ព្រោះអស់អាសវៈទាំងឡាយ ។ល។ សម្រេចហើយ បុគ្គលនេះ លោកហៅថា សមណៈសុខុមាល ក្នុងបណ្ដាសមណៈទាំងឡាយ ។ ពាក្យថា **ឥមេ ខោ អាវុសោ** ជាដើម បណ្ឌិតគប្បីប្រកបចូលជាមួយគ្នា តាមន័យដែលពោលហើយនុ៎ះឯង ។ ព្រះថេរៈកាលពោល (ដោះស្រាយ) បញ្ហា ២០០ ប្រការ ដោយអំណាចនៃចតុក្កៈ ៥០ គត់ ដោយប្រការដូច្នេះ ក៏ឈ្មោះថា សម្ដែងហើយនូវសាមគ្គីរស ដូច្នេះឯង ។

**ធម៌ពួក ៤ ចប់**

## ពោលអំពីធម៌ពួក ៥

[ ១៤៩-១៥០ ] ព្រះថេរៈ គ្រាសម្ដែងសាមគ្គីរសដោយអំណាចពួក ៤ ដោយប្រការដូច្នេះហើយ ឥឡូវនេះប្រាថ្នានឹងសម្ដែងដោយអំណាចពួក ៥ ទើបផ្ដើមទេសនាទៀត ។ ក្នុងពួក ៥ នោះ គប្បីជ្រាបអធិប្បាយដូច្នេះ ។ បណ្ដាខន្ធ

៥ រូបក្ខន្ធ ជាលោកិយ ។ ខន្ធដ៏សេសមានទាំងលោកិយ និងលោកុត្តរ ។ ឧបាទានក្ខន្ធ ជាលោកិយតែម្យ៉ាង ។

កថាពោលអំពីខន្ធ លោកពោលដោយពិស្តារហើយ ក្នុងវិសុទ្ធិមគ្គ ។

[ ១៥១ ] កាមគុណទាំងឡាយ លោកឲ្យពិស្តារហើយ ។

[ ១៥២ ] ដែលឈ្មោះថា **គតិ** ព្រោះអត្ថថា សត្វគប្បីដំណើរទៅ ព្រោះកម្មដែលធ្វើល្អ និងកម្មដែលធ្វើមិនល្អជាដើម ។ ប្រការថា **ឆិរយោ** សេចក្តីថា អស់សេចក្តីត្រេកអរ ។ ខន្ធទាំងឡាយ លោកពោលព្រមជាមួយឱកាស ( ដែលនៅ ) រួមគ្នា ។ ខន្ធដែលកើតឡើងទី ៣ កន្លែងក្រៅពីនេះ លោកពោលហើយ ។ សូម្បីឱកាស លោកក៏ពោលក្នុងខន្ធទី ៤ ។

[ ១៥៣ ] សេចក្តីកំណាញ់ក្នុងអាវាស ឈ្មោះថា **អាវាសមច្ឆរិយ** ។ ភិក្ខុដែលប្រកបដោយអាវាសមច្ឆរិយៈនោះ ឃើញអាគន្តុកៈហើយ ពោលពាក្យជាដើមថា ក្នុងអាវាសខ្ទង់នេះ គេរក្សាបរិក្ខាររបស់ចេតិយ ឬរបស់សង្ឃ រមែងការពារអាវាស សូម្បីដែលជារបស់សង្ឃ ។ លោកស្លាប់ហើយ រមែងទៅកើតជាប្រេត ឬពស់ថ្លាន់ ។ សេចក្តីកំណាញ់ក្នុងត្រកូល ឈ្មោះថា **កុល-មច្ឆរិយ** ។ ភិក្ខុដែលប្រកបដោយសេចក្តីកំណាញ់ក្នុងត្រកូលនោះ រមែងរារាំងភិក្ខុពួកដទៃ មិនឲ្យចូលទៅក្នុងត្រកូលឧបដ្ឋាករបស់ខ្លួន ដោយហេតុនោះ ។ សេចក្តីកំណាញ់ក្នុងលាភ ឈ្មោះថា **លាភមច្ឆរិយ** ។ ភិក្ខុដែលប្រកបដោយសេចក្តីកំណាញ់ក្នុងលាភនោះ កំណាញ់លាភជារបស់សង្ឃ ញុំាងភិក្ខុពួកដទៃមិនឲ្យបានទូវលាភ យ៉ាងណា រមែងធ្វើដោយប្រការយ៉ាងនោះ ។ សេចក្តី

កំណាញ់ក្នុងវណ្ណៈ ឈ្មោះថា **វណ្ណមច្ឆរិយ** ។ ក្នុងពាក្យថា **វណ្ណ** នេះ បណ្ឌិតគប្បីជ្រាបទាំងសរីរវណ្ណៈ ទាំងគុណវណ្ណៈ ។ សេចក្តីកំណាញ់ក្នុងបរិយត្តិធម៌ ឈ្មោះថា **ធម្មមច្ឆរិយ** ។ ភិក្ខុដែលប្រកបដោយសេចក្តីកំណាញ់ក្នុងបរិយត្តិធម៌នោះ រមែងមិនឲ្យ ( បរិយត្តិធម៌ ) ដល់ភិក្ខុដទៃ ដោយគិតថា ភិក្ខុនេះរៀនធម៌នេះហើយ នឹងគ្របសង្កត់អញ ។ ចំណែកភិក្ខុណាមិនឲ្យព្រោះអនុគ្រោះធម៌ ឬអនុគ្រោះបុគ្គល ការណ៍នោះ មិនចាត់ជាសេចក្តីកំណាញ់ ( សម្រាប់ភិក្ខុនោះ ) ឡើយ ។

[ ១៥៤ ] ធម្មជាតដែលឈ្មោះថា **នីវរណា** ព្រោះអត្ថថា ហាម គឺរាំងចិត្ត ។ កាមច្ឆន្ទៈ ដែលដល់ភាពជានីវរណៈ សម្លាប់ដោយអរហត្តមគ្គ ។ **អនុសយ** គឺកាមរាគៈដែលដល់ភាពជាកាមរាគសញ្ញោជនៈ សម្លាប់ដោយអនាគាមិមគ្គ ។ **ថីន** ជាការជំទាស់ផ្លូវចិត្ត ។ **មិទ្ធ** ជាការជំទាស់របស់ខន្ធ ៣ ។ ថីនៈ និងមិទ្ធៈ សូម្បីទាំងពីរ សម្លាប់បានដោយអរហត្តមគ្គ ។ **ឧទ្ធច្ច** ក៏ដូចគ្នា ។ **កុក្កុច្ច** សម្លាប់បានដោយអនាគាមិមគ្គ ។ **វិចិកិច្ឆា** សម្លាប់បានដោយសោតាបត្តិមគ្គ ។

[ ១៥៥-១៥៦ ] ប្រការថា **សញ្ញោជនានិ** បានដល់ គ្រឿងចងរឹត ។ បណ្តាបុគ្គលដែលត្រូវសំយោជនៈទាំងនោះចង ព្រះសោតាបន្ន និងព្រះសកទាគាមី ដែលកើតក្នុងរូបភព និងអរូបភព ឈ្មោះថា ដេកហើយខាងក្រៅ ចាកគ្រឿងចងខាងក្នុង ។ ពិតហើយ ព្រះសោតាបន្ន និងព្រះសកទាគាមីទាំងនោះ នៅមានគ្រឿងចងក្នុងកាមភព ។ ព្រះអនាគាមី ឈ្មោះថា ដេកខាងក្នុងចាក

គ្រឿងចងខាងក្រៅ ក្នុងកាមភព ។ ពិតហើយ សម្រាប់ព្រះអនាគាមីទាំងនោះ នៅមានគ្រឿងចងក្នុងរូបភព និងអរូបភព ។ ព្រះសោតាបន្ន និងព្រះសកទាគាមី ឈ្មោះថា ដេកខាងក្នុងចាកគ្រឿងចងខាង ក្នុងកាមភព ។ ព្រះអនាគាមី ឈ្មោះថា ដេកខាងក្រៅចាកគ្រឿងចងខាងក្រៅ ក្នុងរូបភព និងអរូបភព ។ ព្រះខីណាស្រព មិនមានគ្រឿងចងគ្រប់ៗ ភព ។

[ ១៥៧ ] បទដែលគប្បីសិក្សា ឈ្មោះថា **សិក្ខាបទ** អធិប្បាយថា ចំណែកនៃសិក្ខា ។

ម្យ៉ាងទៀតថា បទនៃសិក្ខា ឈ្មោះថា **សិក្ខាបទ** អធិប្បាយថា ឧបាយ គ្រឿងសម្រេចអធិចិត្តសិក្ខា និងអធិប្បញ្ញាសិក្ខា ។ នេះជាសេចក្តីសង្ខេបក្នុង ទីនេះ ។ ចំណែកកថានៃសិក្ខាបទដោយពិស្តារ មកហើយ ក្នុងសិក្ខាបទវិភង្គ ក្នុងវិភង្គបករណ៍នុ៎ះឯង ។

[ ១៥៨ ] ពាក្យជាដើមថា អាវុសោ ភិក្ខុអ្នកជាខីណាស្រព ជាអ្នកមិន គួរនឹងក្លែងសម្លាប់សត្វ ដូច្នេះ នេះជាមាតិកានៃទេសនានុ៎ះឯង ។ សូម្បីព្រះ សោតាបន្នជាដើម ក៏ជាអ្នកមិនគួរ ។ ការនិន្ទា និងការសរសើរ លោកពោល យ៉ាងនេះ សម្រាប់បុថុជ្ជន និងព្រះខីណាស្រព ។ ធម្មតាថា បុថុជ្ជន ដែលជាបុគ្គលថោកទាប រមែងធ្វើការសម្លាប់មាតាក៏បាន ។ ចំណែក ព្រះខីណាស្រព ជាបុគ្គលខ្ពង់ខ្ពស់ មិនសម្លាប់ស្រមោចខ្មៅ ស្រមោចក្រហម ជាដើមឡើយ ។

[ ១៥៩ ] ក្នុងការវិនាសទាំងឡាយ មានសេចក្តីដូច្នេះ ប្រការថា

**ព្យសតិ** ប្រែថា សេចក្តីវិនាស អធិប្បាយថា បន្សាត់ទៅ គឺកម្ចាត់ប្រយោជន៍ និងសេចក្តីសុខចោល ។ សេចក្តីវិនាសនៃញាតិ ឈ្មោះថា **ញាតិព្យសន** អធិប្បាយថា សេចក្តីវិនាសនៃញាតិ ព្រោះចោរភ័យ និងរោគភ័យជាដើម ។ សេចក្តីវិនាសនៃភោគៈ ឈ្មោះថា **ភោគព្យសន** អធិប្បាយថា សេចក្តីវិនាស គឺភោគៈ ដោយអំណាចព្រះរាជា និងចោរជាដើម ។ សេចក្តីវិនាស គឺរោគ ឈ្មោះថា **រោគព្យសន** ។ ពិតហើយ រោគ រមែងទម្លាយ គឺញ៉ាំងសេចក្តីមិនមានរោគ ឲ្យវិនាសទៅ ព្រោះហេតុនោះ ទើបឈ្មោះថា **ព្យសន** ។ សេចក្តីវិនាសនៃសីល ឈ្មោះថា **សីលព្យសន** ។ ពាក្យនេះ ជាឈ្មោះនៃការទ្រុស្តសីល ។ សេចក្តីវិនាស គឺទិដ្ឋិដែលធ្វើសម្មាទិដ្ឋិឲ្យវិនាសកើតឡើង ឈ្មោះថា **ទិដ្ឋិព្យសន** ។ ក្នុងសេចក្តីនេះ សេចក្តីវិនាស ៣ យ៉ាង មានសេចក្តីវិនាសនៃញាតិជាដើម ជាអកុសលក៏មិនមែន ( ទាំង ) មិនទម្លាយលក្ខណៈ ៣ ផង ។ សេចក្តីវិនាសនៃសីល និងទិដ្ឋិទាំង ២ ជាអកុសលមិនទម្លាយលក្ខណៈ ៣ ព្រោះហេតុនោះឯង ទើបលោកពោលពាក្យជាដើមថា **នាវុសោ សត្តា ញាតិព្យសនហេតុ វា** ដូច្នេះ ។

[ ១៦០-១៦២ ] ប្រការថា **ញាតិសម្បទា** សេចក្តីថា ការដល់ព្រមសេចក្តីបរិបូណ៌នៃការមានញាតិច្រើន ។ សូម្បីក្នុងសេចក្តីដល់ព្រមនៃភោគៈជាដើម ក៏ន័យនេះ ។ សេចក្តីដល់ព្រមនៃភាពជាអ្នកមិនមានរោគ ឈ្មោះថា **អារោគ្យសម្បទា** បានដល់ ភាពជាអ្នកមិនមានរោគ រហូតអស់កាលយូរ ។ ក្នុងការដល់ព្រមនៃសីល និងទិដ្ឋិជាដើម ក៏ន័យនេះ ។ ក្នុងសេចក្តីនេះ ការ

ដល់ព្រមនៃញាតិជាដើម មិនមែនជាកុសល មិនទម្លាយលក្ខណៈ ៣ ។ សេចក្តីដល់ព្រមនៃសីល និងទិដ្ឋិជាកុសលមិនទម្លាយលក្ខណៈ ៣ ។ ព្រោះហេតុនោះឯង ទើបលោកពោលពាក្យជាដើមថា **ឆាវុសោ សន្តា ញាតិសម្បទាហេតុ** វាកថាពោលអំពីសីលវិបត្តិ និងសីលសម្បត្តិ លោកឲ្យពិស្តារហើយ ក្នុងមហាបរិនិព្វានសូត្រ ។

[ ១៦៣ ] ប្រការថា **ចោទកេន** សេចក្តីថា ត្រូវចោទដោយរឿងសម្រាប់ចោទ ៤ យ៉ាង គឺការប្រៀបផ្ទឹមរឿងរ៉ាវ ការប្រៀបផ្ទឹមអាបត្តិ ការហាមការនៅរួម ការហាមសាមីចិកម្ម ។ ក្នុងប្រការថា **កាលេន វក្ខាមិ នោ អកាលេន** សេចក្តីថា សម្រាប់ចម្លើយត្រូវប្រាប់វេលាសម្រាប់ចោទមិនត្រូវ ។ ពិតហើយ ភិក្ខុកាលនឹងចោទអ្នកដទៃ មិនគប្បីចោទត្រង់កណ្តាលបរិស័ទ ក្នុងរោងឧបោសថ ក្នុងរោងបវារណា ឬក្នុងរោងឆាន់រោងកត្តជាដើមឡើយ ។ គ្រាដែលលោកអង្គុយសម្រាកក្នុងទីសម្រាកពេលថ្ងៃ គប្បីឲ្យលោកឲ្យឱកាសជាមុនហើយ ទើបចោទឡើងយ៉ាងនេះថា លោកដ៏មានអាយុ លោកចូរឲ្យឱកាសខ្ញុំព្រះករុណាត្រូវការនិយាយជាមួយនឹងលោក ។ កាលដេញដោលសួរបុគ្គលហើយ អ្នកណាជាបុគ្គលឡេះឡោះ និយាយកុហកលើកទោស មិនមែនយសឡើងដល់ពួកភិក្ខុទាំងឡាយ អ្នកនោះ វៀរការធ្វើឱកាសក៏ចោទបាន ។ ប្រការថា **ភូតេន** សេចក្តីថា តាមសភាពពិត ។ ប្រការថា **សណ្ហេន** សេចក្តីថា ហ្មត់ចត់ គ្មានសល់ទន់ភ្លន់ ។ ប្រការថា **អត្ថសញ្ហិតេន** សេចក្តីថា ដោយការចូលដល់ ភាពជាអ្នកប្រាថ្នាប្រយោជន៍ ភាពជាអ្នកប្រាថ្នាសេចក្តីចម្រើន ។

[ ១៦៤ ] ប្រការថា **បធានិយង្គានិ** សេចក្ដីថា ភាវៈដែលជាទីតាំង លោក ហៅថា **បធាន** ។ បធានរបស់បុគ្គលនោះមានហើយ ហេតុនោះ បុគ្គលនោះ ឈ្មោះថា **បធានិយ** ។ អង្គនៃភិក្ខុដែលមានបធាន ឈ្មោះថា **បធានិយង្គ** ( អង្គនៃភិក្ខុដែលមានសេចក្ដីព្យាយាម ) ។

ប្រការថា **សទ្ធោ** សេចក្ដីថា ប្រកបដោយសទ្ធា ។ សទ្ធាមាន ៤ យ៉ាង គឺអាគមនសទ្ធា អធិគមនសទ្ធា ឱកប្បនសទ្ធា បសាទសទ្ធា ។

បណ្ដាសទ្ធា ៤ យ៉ាងនោះ សេចក្ដីជឿចំពោះបញ្ញាជាគ្រឿងត្រាស់ដឹង របស់ព្រះពោធិសត្វទាំងឡាយ ឈ្មោះថា **អាគមនសទ្ធា** ព្រោះមកហើយ តាំងពី ( ផ្ដើមធ្វើ ) អភិនីហារ ។ សេចក្ដីជឿចំពោះព្រះអរិយសាវ័កទាំងឡាយ ឈ្មោះថា **អធិគមនសទ្ធា** ព្រោះសម្រេចហើយដោយការចាក់ធ្លុះ ។ កាលមាន អ្នកពោលថា ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដូច្នេះហើយ ការដាក់ចិត្តជឿដោយ សេចក្ដីមិនញាប់ញ័រ ឈ្មោះថា **ឱកប្បនសទ្ធា** ។ ការកើតឡើងនៃសេចក្ដី ជ្រះថ្លា ឈ្មោះថា **បសាទសទ្ធា** ។

ក្នុងទីនេះលោកប្រាថ្នាយកសទ្ធា គឺការដាក់ចិត្តជឿ ។ ប្រការថា **ពោធិ** បានដល់ ញាណក្នុងមគ្គទី ៤ ។ បុគ្គលរមែងជឿថា ញាណក្នុងមគ្គទី ៤ នោះ ព្រះតថាគតត្រាស់ដឹងហើយ ។ ពាក្យនេះ ជាន័យទេសនានោះឯង ។ សេចក្ដី ជឿក្នុងរតនៈទាំង ៣ ប្រការ ដោយអង្គនេះ លោកបំណងយកហើយ ។ ពិត ហើយ សេចក្ដីជ្រះថ្លាក្នុងព្រះរតនត្រ័យ មានព្រះពុទ្ធជាដើម របស់បុគ្គលណា មានកម្លាំង សេចក្ដីព្យាយាមដែលតាំងទុករបស់បុគ្គលនោះ រមែងសម្រេច បាន ។ ប្រការថា **អប្បាពាធោ** ប្រែថា មិនមានរោគ ។ ប្រការថា **អប្បាតង្កោ** ប្រែថា អស់ទុក្ខ ។ ប្រការថា **សមវេបាកិនិយា** មានផលទុំជារ ។ ប្រការថា

**គហាណភិយា** បានដល់ គេជាធាតុដែលកើតពីកម្ម ។ ប្រការថា **ឆាតិសីតាយ ឆាចុណ្ហាយ** សេចក្ដីថា បុគ្គលដែលមានទឹករំលាយចេញមកត្រជាក់ច្រើន ។ រមែងខ្វាចចំពោះភាពត្រជាក់ បុគ្គលដែលមានទឹករំលាយចេញមកក្ដៅច្រើន រមែងខ្វាចចំពោះសេចក្ដីក្ដៅ ។ សេចក្ដីព្យាយាម រមែងមិនសម្រេចដល់ពួកគេ ។ ចំពោះបុគ្គលដែលមានទឹករំលាយជាកណ្ដាលសម្រេចបាន ព្រោះហេតុនោះ ទើបលោកពោលថា សមគួរដល់សេចក្ដីព្យាយាមលំដាប់កណ្ដាល ។ ប្រការថា **យថាភូតំ អត្តានំ អាវិកត្តា** សេចក្ដីថា ប្រកាសទោសរបស់ខ្លួនតាមពិត ។ ប្រការថា **ឧទយត្ថគាមិនិយា** សេចក្ដីថា អាចនឹងឡើងទៅ និងដែលកំណត់ដល់វេលាឡើង និងវេលាចុះ ។ ឧទយព្វយញ្ញាណ ដែលកំណត់យកលក្ខណៈ ៥០ ប្រការ លោកពោលដោយពាក្យនេះ ។ ប្រការថា **អរិយាយ** សេចក្ដីថា ស្អាតបរិសុទ្ធ ។ ប្រការថា **និព្វេធិកាយ** សេចក្ដីថា អាចដើម្បីចាក់ធ្លុះខន្ធ មានសេចក្ដីលោភជាដើម ដែលមិនធ្លាប់ធ្លុះមកពីមុន ។ ប្រការថា **សម្មាទុក្ខក្ខយគាមិនិយា** សេចក្ដីថា ទុក្ខឯណា នឹងអស់ទៅបាន ដំណើរនៃការអស់ទុក្ខនោះ ព្រោះលះកិលេសបានដោយអំណាចអង្គនោះ ។ វិបស្សនាបញ្ញា លោកពោលដោយបទទាំងនេះគ្រប់បទ ដោយប្រការដូច្នេះ ។ ពិតហើយ សេចក្ដីព្យាយាមមិនសម្រេចដល់អ្នកមិនមានបញ្ញា ។

[ ១៦៥ ] ប្រការថា **សុទ្ធាវាសា** សេចក្ដីថា ពួកព្រហ្មជាន់សុទ្ធាវាសនៅហើយ កំពុងនៅ ឬនឹងនៅ ព្រោះហេតុនោះ ទើបឈ្មោះថា សុទ្ធាវាស ។ ប្រការថា **សុទ្ធា** បានដល់ ព្រះអនាគាមី និងព្រះខីណាស្រព ដែលប្រាសចាកកិលេសមន្ទិល ។ ពាក្យណាដែលគប្បីពោលក្នុងប្រការថា អរិយាជាដើម ពាក្យនោះ លោកពោលហើយ ក្នុងមហាបទានសូត្រនោះឯង ។

[ ១៦៦ ] ក្នុងបណ្ដាព្រះអនាគាមីបុគ្គលទាំងឡាយ គប្បីជ្រាបដូចតទៅនេះ ព្រះអនាគាមី អ្នកនៅមិនទាន់កន្លងពាក់កណ្ដាលអាយុ ហើយសម្រេចអរហត្ត ដែលជាការរលត់កិលេសបានក្នុងចន្លោះនោះ ឈ្មោះថា **អន្តរាបរិ-និព្វាយី** ( បរិនិព្វានពាក់កណ្ដាលអាយុ ) ។ ព្រះអនាគាមីអ្នកកន្លងហួសកណ្ដាលអាយុទៅហើយ ទើបសម្រេច ឈ្មោះថា **ឧបហច្ចបរិនិព្វាយី** ( និព្វានដោយកន្លងហួសពាក់កណ្ដាលអាយុ ) ព្រះអនាគាមីដែលមិនលំបាក ព្រោះមិនត្រូវប្រកបសេចក្ដីព្យាយាម ដោយមិនមានសង្ខារ ( គ្រឿងតាក់តែង ) សម្រេចបានយ៉ាងងាយ ឈ្មោះថា **អសង្ខារបរិនិព្វាយី** ( និព្វានដោយមិនមានសង្ខារ ) ។ ព្រះអនាគាមី អ្នកលំបាកព្រោះត្រូវប្រកបសេចក្ដីព្យាយាមព្រមទាំងសង្ខារ សម្រេចបានដោយសេចក្ដីលំបាក ឈ្មោះថា **សសង្ខារបរិ-និព្វាយី** ( បរិនិព្វានព្រមដោយសង្ខារ ) ។ ព្រះអនាគាមីទាំង ៤ ពួកនេះ មិនបានក្នុងសុទ្ធាវាសទាំង ៥ ជាន់ ។ បណ្ឌិតគប្បីជ្រាបពួក ៤ ក្នុងប្រការថា **ឧទ្ធំសោតោ អកនិដ្ឋគាមី** នេះ តទៅ ។ ព្រះអនាគាមីអង្គណាជម្រះទេវលោក ៤ ជាន់ តាំងពីជាន់អវិហាទៅ ឲ្យបរិសុទ្ធ ទៅកាន់អកនិដ្ឋភព ហើយបរិនិព្វាន ព្រះអនាគាមីនេះ ឈ្មោះថា មានក្រសែខាងលើ ទៅកាន់អកនិដ្ឋភព ។ ព្រះអនាគាមីអង្គណា ទៅកាន់ទេវលោកជាន់ទី ២ ទី ៣ ឬទី ៤ តាំងអំពីជាន់អវិហាទៅ ហើយបរិនិព្វាន ព្រះអនាគាមីនេះ ឈ្មោះថា មានក្រសែខាងលើ មិនទៅកាន់អកនិដ្ឋភព ។ ព្រះអនាគាមីអង្គណា ចាកកាមភព ហើយកើតក្នុងអកនិដ្ឋភព ហើយបរិនិព្វាន ព្រះអនាគាមីនេះ ឈ្មោះថា មិនមានក្រសែខាងលើ ទៅកាន់អកនិដ្ឋភព ។ ព្រះអនាគាមីអង្គណា កើតក្នុងទីនោះឯង បណ្ដាទេវលោក ៤ ជាន់ខាងក្រោម ហើយបរិនិព្វាន ព្រះអនាគាមីនេះ ឈ្មោះថា មានក្រសែ

ខាងលើ មិនឈ្មោះថា ទៅកាន់អកនិដ្ឋកព ។

[ ១៦៧ ] ប្រការថា **ចេតោខិលា** សេចក្ដីថា ភាវៈរឹងត្អឹងរបស់ចិត្ត ។ ប្រការថា **សត្ថរិ កង្ខតិ** សេចក្ដីថា រមែងសង្ស័យក្នុងព្រះសរីរៈ ឬក្នុងព្រះគុណរបស់ព្រះសាស្ដា ។ បុគ្គលកាលសង្ស័យក្នុងព្រះសរីរៈ រមែងសង្ស័យថា ដែលឈ្មោះថា សរីរៈដែលប្រដាប់ដោយមហាបុរិសលក្ខណៈដ៏ប្រសើរ ៣២ ប្រការ មានពិតឬទេហ្ន៎ ។ បុគ្គលដែលសង្ស័យក្នុងព្រះគុណ រមែងសង្ស័យថា សព្វញ្ញុតញ្ញាណ ដែលអាចនឹងដឹងអតីត អនាគត និងបច្ចុប្បន្ន មានពិតឬទេហ្ន៎ ។ ប្រការថា **អាតប្បាយ** សេចក្ដីថា ដើម្បីបំពេញព្យាយាម ។

ប្រការថា **អនុយោគាយ** សេចក្ដីថា ដោយការប្រកបរឿយៗ ។ ប្រការថា **សាតច្ចាយ** សេចក្ដីថា ដោយធ្វើជាប់បន្ត ។ប្រការថា **បធានាយ** សេចក្ដីថា ដើម្បីការតាំងទុក ។

ប្រការថា **អយំ បឋមោ ចេតោខិលោ** នេះ សេចក្ដីថា ភាពដែលរឹងត្អឹងរបស់ចិត្តជាដំបូងនេះ បានដល់ សេចក្ដីសង្ស័យក្នុងព្រះសាស្ដា ។ ប្រការថា **ធម្មេ** សេចក្ដីថា ក្នុងបរិយត្តិធម៌ និងបដិវេធធម៌ ។ បុគ្គលដែលសង្ស័យក្នុងបរិយត្តិធម៌ រមែងសង្ស័យថា អ្នកទាំងឡាយនិយាយគ្នាថា ព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដក មាន ៨៤០០០ ព្រះធម្មក្ខន្ធ ព្រះពុទ្ធវចនៈនោះ មានពិតឬទេហ្ន៎ ។ បុគ្គលដែលសង្ស័យក្នុងបដិវេធធម៌ រមែងសង្ស័យថា អ្នកទាំងឡាយនាំគ្នានិយាយថា ផលរបស់វិបស្សនា ឈ្មោះថា **មគ្គ** ផលរបស់មគ្គឈ្មោះថា **ផល** ការលះបង់សង្ខារទាំងពួងចេញបាន ឈ្មោះថា **និព្វាន** និព្វាននោះ មានពិតឬទេហ្ន៎ ។

ប្រការថា **សង្ឃេ កង្ខតិ** សេចក្តីថា រមែងសង្ស័យថា ប្រជុំនៃបុគ្គលដែលបដិបត្តិបដិទាយ៉ាងនេះ ដោយអំណាចនៃបទជាដើមថា **ឧជុបដិបន្នោ** ដូច្នេះ មាន ៨ គឺភិក្ខុអ្នកតាំងនៅក្នុងមគ្គ ៤ ភិក្ខុអ្នកតាំងនៅក្នុងផល ៤ ឈ្មោះថា ព្រះសង្ឃ ព្រះសង្ឃនោះ មានពិតឬទេហ្ន៎ ។ បុគ្គលដែលសង្ស័យក្នុងសិក្ខា រមែងសង្ស័យថា អ្នកទាំងឡាយនិយាយថា ឈ្មោះថា អធិសីលសិក្ខា ឈ្មោះថា អធិចិត្តសិក្ខា ឈ្មោះថា អធិប្បញ្ញាសិក្ខា សិក្ខានោះ មានពិតឬទេហ្ន៎ ។ ប្រការថា **អយំ បញ្ចមោ** នេះ សេចក្តីថា ភាវៈនៃចិត្តរឹងត្អឹង ភាវៈនៃចិត្តដូចជាដង្គត់ ភាវៈនៃចិត្តជាទី ៥ បានដល់ សេចក្តីក្រោធក្នុងរឿងព្រហ្មចារីទាំងឡាយ ។

[ ១៦៨ ] ប្រការថា **ចេតសោ វិនិពន្ធា** សេចក្តីថា ពួកកិលេសដែលឈ្មោះថា ជាគ្រឿងចងរឹតចិត្តទុក ព្រោះអត្ថថា ចងចិត្តប្រកាន់ទុក ដូចធ្វើទុកក្នុងកណ្តាប់ដៃ ដូច្នោះ ។

ប្រការថា **កាមេសុ** សេចក្តីថា ទាំងក្នុងវត្ថុកាម ទាំងក្នុងកិលេសកាម ។ ប្រការថា **កាយេ** បានដល់ ករជកាយរបស់ខ្លួន ។ ប្រការថា **រូបេ** បានដល់ រូបខាងក្រៅ ។ ប្រការថា **យាវទត្ថំ** សេចក្តីថា តាមដែលត្រូវការ ។ ប្រការថា **ឧទរាវទេហកំ** សេចក្តីថា ពេញពោះ ។ ពិតហើយ ពោះនោះ លោកហៅថា **ឧទរាវទេហកំ** ព្រោះចិញ្ចឹមរាងកាយ ។ ប្រការថា **សេយ្យសុខំ** សេចក្តីថា មានសេចក្តីសុខ ព្រោះគ្រែ និងតាំង ។ ប្រការថា **បស្សសុខំ** សេចក្តីថា សម្រាប់បុគ្គលដែលដេកប្រមៀលទៅមក តាមសប្បាយដេកផ្អៀងស្តាំ ឬដេកផ្អៀងឆ្វេង ក៏មានសេចក្តីសុខ សេចក្តីសុខកើតឡើងហើយយ៉ាងនេះ ។ ប្រការថា **មិទ្ធសុខំ** សេចក្តីថា សុខដែលកើតពីការដេកលក់ ។ ប្រការថា **អនុយុត្តោ**

សេចក្ដីថា ប្រកបវត្ថុដែលសមគួរ ។

ប្រការថា **បណិធាយ** សេចក្ដីថា តាំងទុកហើយ ។ ប្រការថា **ព្រហ្មចរិយេន** សេចក្ដីថា ប្រព្រឹត្តព្រហ្មចរិយៈ វៀរចាកមេថុន ។ ប្រការថា **ទេវោ វា ភវិស្សាមិ** សេចក្ដីថា យើងនឹងជាទេពអ្នកមានសក្តិធំឬ ។ ប្រការថា **ទេវញ្ញតរោ វា** សេចក្ដីថា ឬថា បណ្ដាទេពអ្នកមានសក្តិតូចទាំងឡាយ ទេពអង្គណាមួយ ។

[ ១៦៩-១៧១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងឥន្ទ្រិយទាំងឡាយដូច្នេះ ឥន្ទ្រិយដែលជាលោកិយប៉ុណ្ណោះ លោកពោលហើយក្នុងបញ្ចកៈទី ១ ។ បឋមជ្ឈាន ទុតិយជ្ឈាន និងចតុត្ថជ្ឈានដែលជាលោកិយ លោកពោលហើយក្នុងបញ្ចកៈទី ២ តតិយជ្ឈាន និងបញ្ចមជ្ឈាន មានទាំងលោកិយ និងលោកុត្តរ ( លោកក៏ពោលក្នុងបញ្ចកៈទី ២ ) ។ ដែលជាលោកិយ និងលោកុត្តរ លោកពោលក្នុងបញ្ចកៈទី ៣ ដោយអំណាចសមថៈ វិបស្សនា និងមគ្គ ។

[ ១៧២ ] ប្រការថា **និស្សារណីយា** សេចក្ដីថា គ្រាប់ចេញទៅ គឺអស់ការទ្រទ្រង់ចាំ ។

ប្រការថា **ធាតុយោ** បានដល់ សភាវៈដែលដាក់ពីតួខ្លួន ។ ប្រការថា **កាមំ មនសិករោតិ** សេចក្ដីថា នឹកដល់តែរឿងកាម អធិប្បាយថា ចេញចាកអសុភជ្ឈានហើយ បញ្ជូនចិត្តប្រាថ្នាចំពោះកាម ដើម្បីនឹងសាកល្បងមើល ដូចអ្នកចាប់ពស់ ហើយសាកល្បងជាមួយពិស ដូច្នោះ ។

ប្រការថា **ន បក្ខន្ទតិ** សេចក្ដីថា មិនចូលទៅ ។ ប្រការថា **ន បសីទតិ** សេចក្ដីថា មិនដល់នឹងជ្រះថ្លា ។ ប្រការថា **ន សន្តិដ្ឋតិ** សេចក្ដីថា តាំងនៅមិនបាន ។ ប្រការថា **ន វិមុច្ចតិ** សេចក្ដីថា មិនរួចផុតទៅបាន ។ ពោមស្វាបមាន់

ឬសរសៃកំណាត់ ដែលអ្នកបោះចូលក្នុងភ្លើង រមែងរមូរចូល គឺមិនលាចេញ យ៉ាងណា ចិត្តនេះក៏ដូច្នោះដែរ រមែងរួញរា មិនរីករាយ ។ក្នុងប្រការថា **នេក្ខម្មំ ខោ បន** នេះ សេចក្តីថា បឋមជ្ឈានក្នុងអសុភ ១០ ឈ្មោះថា **នេក្ខម្ម**។ កាលបុគ្គលនោះ មនសិការដល់បឋមជ្ឈាននោះ ចិត្តក៏រមែងត្រាច់ទៅ ។ ប្រការថា **តស្ស តំ ចិត្តំ** សេចក្តីថា អសុភជ្ឈានចិត្តនោះ របស់បុគ្គលនោះ ។ ប្រការថា **សុគតំ** សេចក្តីថា ដំណើរទៅល្អ ព្រោះទៅក្នុងគោចរ ។ ប្រការថា **សុភាវិតំ** សេចក្តីថា អប់រំមកយ៉ាងល្អ ព្រោះជាចំណែកដែលមិនអាក្រក់ ។ ប្រការថា **សុវុដ្ឋិតំ** សេចក្តីថា ចេញចាកកាមបានដោយល្អ ។

ប្រការថា **សុវិមុត្តំ** សេចក្តីថា រួចផុតដោយល្អចាកកាមទាំងឡាយ ។ អាសវៈ ៤ ដែលមានកាមជាហេតុ ឈ្មោះថា អាសវៈមានកាមជាបច្ច័យ ។ ប្រការថា **វិឃាតា** ប្រែថា ជាទុក្ខ ។ ប្រការថា **បរិឡាហា** សេចក្តីថា ក្តៅផ្សា ព្រោះកាមរាគៈ ។ ប្រការថា **ន សោ តំ វេទនំ វេទេតិ** សេចក្តីថា បុគ្គលនោះ រមែងមិនសោយវេទនា ដែលកើតពីសេចក្តីប្រាថ្នា និងវេទនា ដែលកើតពីសេចក្តីចង្អៀតចង្អល់ និងសេចក្តីក្តៅក្រហាយនោះ ។ ប្រការថា **ឥទមក្ខាតំ កាមានំ និស្សរណំ** សេចក្តីថា អសុភជ្ឈាននេះ លោកពោលថា ជាគ្រឿងរលាស់ចេញចាកកាម ព្រោះរលាស់ចេញទៅចាកកាមទាំងឡាយ ។ បុគ្គលណាធ្វើឈាននោះឲ្យជាបាទ ពិចារណាសង្ខារទាំងឡាយ សម្រេចមគ្គទី ៣ ឃើញព្រះនិព្វានដោយអនាគាមិផល ដឹងថា ឈ្មោះថា កាមទាំងឡាយមិនមានទៀត ចិត្តរបស់បុគ្គលនោះ ក៏ជាការរលាស់ចេញទៅបានយ៉ាងពិតប្រាកដ ( ចាកកាមទាំងឡាយ) ។សូម្បីក្នុងបទទាំងឡាយដ៏សេស ក៏ន័យនេះដូចគ្នា ។នេះជាប្រការ

ដែលផ្សេងគ្នា ។ ក្នុងវារៈទី ២ មេត្តាឈាន ឈ្មោះថា ជាការរលាស់ចេញចាក ព្យាបាទ ។ ក្នុងវារៈទី ៣ករុណាឈាន ឈ្មោះថា ការរលាស់ចេញចាកសេចក្តី បៀតបៀន ។ ក្នុងវារៈទី ៤ អរូបជ្ឈាន ឈ្មោះថា ការរលាស់ចេញទៅនូវរូប ។

ក្នុងសេចក្តីនេះ គប្បីប្រកបអរហត្តផល ចូលក្នុងការរលាស់ចេញបាន យ៉ាងពិតប្រាកដ គប្បីជ្រាបអធិប្បាយក្នុងវារៈទី ៥ តទៅ ។

ប្រការថា **សក្កាយំ មនសិករោតោ** សេចក្តីថា ព្រះខីណាស្រព សុក្ខ-វិបស្សក: កំណត់យកសង្ខារដែលបរិសុទ្ធ ហើយសម្រេចអរហត្ត ចេញ ចាកផលសមាបត្តិ បញ្ជូនចិត្តត្រង់ទៅកាន់ឧបាទានក្ខន្ធ ៥ ដើម្បីនឹងសាកល្បង មើល ។ ប្រការថា **ឥធមក្ខាតំ សក្កាយស្ស និស្សរណំ** នេះ សេចក្តីថា ចិត្ត ដែលសម្បយុត្តដោយអរហត្តផលសមាបត្តិកើតឡើងថា រាងកាយរបស់យើង នឹងមិនមានតទៅទៀត របស់ភិក្ខុដែលឃើញព្រះនិព្វាន ដោយអរហត្តមគ្គ និង អរហត្តផល លោកហៅថា ការរលាស់ចេញចាកកាយរបស់ខ្លួន ។

[ ១៧៣ ] ប្រការថា **វិមុត្តាយតនានិ** សេចក្តីថា ហេតុនៃការរួចផុត ។ ប្រការថា **អត្ថប្បដិសំវេទិនោ** សេចក្តីថា ដឹងអត្ថនៃព្រះបាលី ។ ប្រការថា **ធម្មប្បដិសំវេទិនោ** សេចក្តីថា ដឹងព្រះបាលី ។ ប្រការថា **បាមោជ្ជ** បានដល់ បីតិយ៉ាងខ្សោយ ។ ប្រការថា **បីតិ** សេចក្តីថា បីតិយ៉ាងខ្លាំងក្លា ដែលជាហេតុ នៃការត្រេកអរ ។ ប្រការថា **កាយោ** សេចក្តីថា នាមកាយរមែងស្ងប់ ។ ប្រការថា **សុខំ វេទេតិ** សេចក្តីថា បានទទួលសេចក្តីសុខ ។ ប្រការថា **ចិត្តំ សមាធិយតិ** សេចក្តីថា ចិត្តតាំងមាំ ដោយអរហត្តផលសមាធិ ។ បុគ្គលនេះ កាលស្តាប់ធម៌នោះ រមែងដឹងឈាន វិបស្សនា មគ្គ និងផល ក្នុងឋានៈដែល

មកហើយ និងមកហើយ ។ កាលលោកដឹងយ៉ាងនេះ បីតិរមែងកើតឡើង ។ លោកមិនព្រមឲ្យបីតិនោះថយចុះក្នុងចន្លោះ ជាអ្នកប្រកបទៅដោយឧបចារកម្មដ្ឋាន ចម្រើនវិបស្សនា រមែងសម្រេចអរហត្ត ។ ពាក្យថា ចិត្តតាំងមាំដូច្នេះ លោកពោលសំដៅយកអរហត្តនោះ ។ ក្នុងពាក្យដ៏សេស ក៏ន័យនេះដូចគ្នា ។ នេះជាប្រការដែលផ្សេងគ្នា ។ ប្រការថា **សមាធិនិមិត្ត** សេចក្ដីថា បណ្ដាអារម្មណ៍ ៣៨ សមាធិណាមួយទុំះឯង ឈ្មោះថា សមាធិនិមិត្ត ។ ប្រការថា **សុគ្គហិតំ ហោតិ** សេចក្ដីថា កាលលោករៀនយកកម្មដ្ឋានក្នុងសម្នាក់អាចារ្យក៏ឈ្មោះថា ជាការរៀនយ៉ាងល្អ ។ ប្រការថា **សុមនសិកតំ** សេចក្ដីថា ធ្វើទុកក្នុងចិត្តយ៉ាងល្អ ។ ប្រការថា **សុបធារិតំ** សេចក្ដីថា ទ្រទ្រង់ចាំបានយ៉ាងល្អ ។

ប្រការថា **សុបដិវិទ្ធំ បញ្ញាយ** សេចក្ដីថា ធ្វើឲ្យប្រចក្សដោយល្អ ដោយបញ្ញា ។ ប្រការថា **តស្មឹ ធម្មេ** សេចក្ដីថា ធម៌ក្នុងព្រះបាលីពោលអំពីរៀងកម្មដ្ឋាននោះ ។

[ ១៧៤ ] ប្រការថា **វិមុត្តិបរិបាចនិយា** សេចក្ដីថា ការរួចផុត លោកហៅថា អរហត្ត គុណធម៌ពួកណា រមែងអប់រំអរហត្តនោះ ព្រោះហេតុនោះ គុណធម៌នោះ ទើបឈ្មោះថា **វិមុត្តិបរិបាចនិយា** ។ បទថា **អនិច្ចសញ្ញា** សេចក្ដីថា សញ្ញាដែលកើតឡើងក្នុងអនិច្ចានុបស្សនាញាណ ។ ប្រការថា **អនិច្ចេ ទុក្ខសញ្ញា** សេចក្ដីថា សញ្ញាដែលកើតឡើងក្នុងទុក្ខានុបស្សនាញាណ ។ ប្រការថា **ទុក្ខេ អនត្តសញ្ញា** សេចក្ដីថា សញ្ញាដែលកើតឡើងក្នុងអនត្តានុបស្សនាញាណ ។ ប្រការថា **បហានសញ្ញា** សេចក្ដីថា សញ្ញាដែលកើតឡើង ក្នុងបហានានុបស្សនាញាណ ។ ប្រការថា **វិរាគសញ្ញា** សេចក្ដីថា សញ្ញាដែល

កើតឡើងក្នុងវិភាគានុបស្សនាញាណ ។ ពាក្យជាដើមថា **ឥមេ ខោ អាវុសោ** គប្បីប្រកបចូលនឹងន័យដែលពោលហើយនុ៎ះឯង ។ ព្រះថេរៈកាលពោលបញ្ហា ១៣០ ដោយអំណាចនៃបញ្ចកៈ ២៦ ឈ្មោះថា សម្ដែងសាមគ្គីរសហើយ ដោយប្រការដូច្នេះ ។

**ពួក ៥ ចប់**

## ពោលអំពីឆក្កពួក ៦

[ ១៧៥ ] ព្រះថេរៈ ( ព្រះសារីបុត្រ ) គ្រាសម្ដែងសាមគ្គីរស ដោយអំណាចនៃធម៌ពួក ៥ ដោយប្រការដូច្នេះហើយ ឥឡូវនេះ ដើម្បីនឹងសម្ដែងសាមគ្គីរស ដោយអំណាចនៃធម៌ពួក ៦ ទើបផ្ដើមប្រារព្ធព្រះធម៌ទេសនាតទៅទៀត ។

បណ្ដាបទទាំងនោះ បទថា **អជ្ឈត្តិកានិ** បានដល់ អាយតនៈខាងក្នុង ។

[ ១៧៦ ] បទថា **ពាហិរានិ** បានដល់ អាយតនៈដែលមានខាងក្រៅអំពីអាយតនៈខាងក្នុងនោះ ។

ចំណែកថា អាយតនកថាដោយពិស្ដារ ខ្ញុំ ( ព្រះពុទ្ធឃោសាចារ្យ ) ពោលហើយក្នុងវិសុទ្ធិមគ្គនោះឯង ។

[ ១៧៧ ] បទថា **វិញ្ញាណកាយា** បានដល់ ពួកនៃវិញ្ញាណ ។

បទថា **ចក្ខុវិញ្ញាណំ** បានដល់ វិញ្ញាណដែលជាកុសលវិបាក ឬអកុសលវិបាកដែលអាស្រ័យចក្ខុប្រសាទ ។ ក្នុងវិញ្ញាណទាំងពួង ក៏ន័យនេះដូចគ្នា ។

[ ១៧៨ ] បទថា **ចក្ខុសម្ផស្សោ** បានដល់ សម្ផស្សដែលអាស្រ័យ

*ចក្ខុ ។ ក្នុងសោតសម្ផស្សជាដើម ក៏មានន័យនេះដូចគ្នា ។*

*បទថា* **មនោសម្ផស្សោ** *បានដល់ សម្ផស្សទាំងពួងដ៏សេស វៀរសម្ផស្ស ទាំង ១០ នេះចេញ ឈ្មោះថា* **មនោសម្ផស្ស** ។

*[១៧៩] សូម្បីពួក ៦ នៃវេទនាបណ្ឌិតក៏គប្បីជ្រាបដោយន័យនេះដូចគ្នា ។*

*[១៨០ ] បទថា* **រូបសញ្ញា** *បានដល់ សញ្ញាដែលធ្វើរូបឲ្យជាអារម្មណ៍ កើតឡើង ។ សូម្បីសញ្ញាដ៏សេស បណ្ឌិតក៏គប្បីជ្រាបដោយឧបាយនេះ ។*

*[១៨១ ] ក្នុងពួក ៦ នៃចេតនា ក៏ន័យនេះដូចគ្នា ។*

*[១៨២ ] ក្នុងពួក ៦ នៃតណ្ហា ក៏ដូចគ្នា ។*

*[១៨៣ ] បទថា* **អគារវោ** *បានដល់ វៀរចាកសេចក្ដីគោរព ។ បទថា* **អប្បដិស្សោ** *បានដល់ មិនកោតក្រែង គឺមិនប្រព្រឹត្តបន្ទាបខ្លួន ។ ភិក្ខុណាក្នុងព្រះសាសនានេះ កាលព្រះសាស្ដាទ្រង់នៅមានព្រះជន្ម រមែងមិនទៅកាន់ទីទំនុកបម្រុង ក្នុងកាលទាំង ៣ កាលព្រះសាស្ដាមិនពាក់ស្បែកជើង ទ្រង់ចង្ក្រម ក៏ពាក់ស្បែកជើងចង្ក្រម កាលព្រះបរមសាស្ដាទ្រង់ចង្ក្រមនៅក្នុងទីចង្ក្រមទាប ក៏ចង្ក្រមក្នុងទីចង្ក្រមខ្ពស់ កាលព្រះសាស្ដាស្ដេចនៅក្នុងខាងក្រោម ក៏នៅក្នុងខាងលើ ក្នុងពេលឃើញព្រះសាស្ដា ក៏បិទត្រចៀកទាំងពីរ បាំងឆត្រ ពាក់ស្បែកជើង ងូតទឹក បន្ទោបង់ឧច្ចារៈ ឬបស្សាវៈ ក៏ឬថា កាលព្រះសាស្ដាទ្រង់បរិនិព្វានហើយ រមែងមិនទៅដើម្បីនឹងថ្វាយបង្គំព្រះចេតិយ ធ្វើកិច្ចទាំងពួង តាមដែលពោលហើយ ក្នុងទីព្រះចេតិយ ញុំាងសេចក្ដីឲ្យប្រាកដ ( ឬ ) ក្នុងទីឃើញព្រះសាស្ដា ភិក្ខុនេះឈ្មោះថា មិនគោរពក្នុងព្រះសាស្ដា ។*

ភិក្ខុណា កាលគេប្រកាសការស្តាប់ធម៌ ក៏មិនទៅដោយគោរព មិនស្តាប់ធម៌ដោយគោរព អង្គុយដេកគ្នា មិនរៀន មិនស្តាប់ដោយគោរព ភិក្ខុនេះឈ្មោះថា មិនគោរពក្នុងព្រះធម៌ ។ ភិក្ខុណា ដែលភិក្ខុជាថេរៈមិនបានឲ្យឱកាស ក៏សម្តែងធម៌ អង្គុយពោលបញ្ហា បៀតបៀនភិក្ខុដែលចាស់ជាង ឈរ អង្គុយ ធ្វើការរឹតជង្គង់ដោយសំពត់ ឬដោយដៃ ត្រង់កណ្តាលសង្ឃ ក៏ដណ្តប់ឃ្លុំបិទស្មាទាំងពីរ ការពារម្ចប់ ឬពាក់ស្បែកជើង ភិក្ខុនេះឈ្មោះថា មិនគោរពក្នុងសង្ឃ ។ កាលភិក្ខុធ្វើសេចក្តីមិនគោរពក្នុងភិក្ខុមួយរូប សេចក្តីមិនគោរពក្នុងព្រះសង្ឃ ឈ្មោះថា លោកធ្វើហើយដូចគ្នា ។ ចំណែកភិក្ខុដែលមិនញ៉ាំងសិក្ខាទាំង ៣ ឲ្យបរិបូណ៌ហើយនុ៎ះឯង ឈ្មោះថា មិនគោរពក្នុងសិក្ខា ។ ភិក្ខុដែលមិនតាមកពូនទូវលក្ខណៈនៃសេចក្តីមិនប្រមាទ ឈ្មោះថា មិនគោរពក្នុងសេចក្តីមិនប្រមាទ ។ ភិក្ខុកាលមិនធ្វើបដិសណ្ឋារៈទាំង ២ យ៉ាង ឈ្មោះថា មិនគោរពក្នុងបដិសណ្ឋារៈ ។

[ ១៨៤ ] សេចក្តីគោរពបណ្ឌិត គប្បីជ្រាបដោយអំណាចន័យផ្ទុយគ្នាតាមដែលបានពោលហើយ ។

[ ១៨៥ ] បទថា **សោមនស្សុបវិចារា** បានដល់ វិចារៈ សម្បយុត្តដោយសោមនស្ស ។

បទថា **សោមនស្សដ្ឋានីយំ** គឺជាហេតុនៃសោមនស្ស ។ បទថា **ឧបវិចរតិ** បានដល់ ត្រិះរិះដោយវិតក្ក ( មុន ) ហើយទើបកំណត់ដោយវិចារៈ ។ ក្នុងពាក្យដ៏សេសទាំងពួង ក៏ន័យនេះដូចគ្នា ។

[ ១៨៦-១៨៧ ] សូម្បី **ទោមនស្សុបវិចារ** បណ្ឌិតក៏គប្បីជ្រាបយ៉ាង

នោះឯង ។ **ឧបេក្ខុបវិចារ** ក៏ដូចគ្នា ។

[ ១៨៨ ] សារាណីយធម៌ លោកឲ្យពិស្តារក្នុងខាងក្រោយ ។ ចំណែកបឋមមគ្គ លោកពោលទុកក្នុង **កោសម្ពិកសូត្រ** ដោយបទនេះថា **ទិដ្ឋិសាមញ្ញគតោ** ។ មគ្គទាំង ៤ លោកពោលក្នុងទីនេះ ។

[ ១៨៩ ] បទថា **វិវាទមូលានិ** គឺមូលនៃវិវាទ ។ បទថា **កោធនោ** បានដល់ អ្នកប្រកបដោយសេចក្ដីក្រោធ ដែលមានសេចក្ដីក្រោធជាលក្ខណៈ ។ បទថា **ឧបនាហិ** បានដល់ ប្រកបដោយសេចក្ដីចូលទៅចងក្រោធទុក ដែលមានការមិនលោះលះបង់ចាកការចងពៀរវេរជាលក្ខណៈ ។ ច្រើនបទថា **អហិតាយ ទុក្ខាយ ទេវមនុស្សានំ** បានដល់ វិវាទនៃភិក្ខុទាំងពីរ រមែងប្រព្រឹត្តទៅព្រមដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខនៃទេវតា និងមនុស្សទាំងឡាយយ៉ាងណា ។ ដូចយ៉ាងក្នុងកោសម្ពិកក្ខន្ធកៈ កាលភិក្ខុ ២ រូប វិវាទគ្នា ពួកអន្តេវាសិករបស់លោកទាំងពីរនោះ ក្នុងវិហារនោះ ក៏វិវាទគ្នា ។ ភិក្ខុនីសង្ឃ អ្នកទទួលឱវាទរបស់ពួកភិក្ខុទាំងនោះ ក៏វិវាទគ្នា តពីនោះ ពួកឧបដ្ឋាករបស់ភិក្ខុទាំងនោះក៏វិវាទគ្នា ។ លំដាប់នោះ ពួកអារក្ខទេវតារបស់ពួកមនុស្ស ក៏ ( បែក ) គ្នាជាពីរចំណែក ។ បណ្ដាទេវតាទាំងនោះ ពួកអារក្ខទេវតារបស់ពួកមនុស្ស អ្នកជាធម្មវាទី ក៏ជាធម្មវាទីផង ។ សម្រាប់ពួកមនុស្សអ្នកជាអធម្មវាទី ក៏ជាអធម្មវាទីផង ។ តអំពីនោះ ពួកភុម្មទេវតា ដែលជាមិត្ររបស់អារក្ខទេវតា ទើបបែកគ្នា ។ ទេវតា និងមនុស្សទាំងអស់ វៀរលែងតែព្រះអរិយសាវកចេញ គ្រប់ៗ គ្នាដរាបដល់ព្រហ្មលោកក៏ ( បែក ) ជាពីរចំណែក ដោយប្រការដូច្នេះ ។ ពួក

ដែលជាអធម្មវាទី មានចំនួនច្រើនជាងពួកធម្មវាទី ។ លំដាប់នោះ ពួកទេវតា និងមនុស្ស ក៏ប្រាថ្នានឹងប្រកាន់វត្ថុ ដែលជនជាច្រើននាំគ្នា ប្រកាន់ពួកអធម្មវាទី ដែលច្រើនជាងនុ៎ះឯង ក៏ដោះស្រាយសភាពដែលជាធម៌ហើយ នាំគ្នាប្រកាន់សភាពដែលមិនមែនធម៌ ។ ពួកអធម្មវាទីទាំងនោះ ធ្វើសភាពដែលមិនមែនធម៌ឲ្យនៅខាងមុខពោលហើយ ទើបកើតក្នុងអបាយទាំងឡាយ ។ វិវាទរបស់ភិក្ខុទាំងពីរបំណែក រមែងមានដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខនៃទេវតា និងមនុស្សទាំងឡាយ ដោយប្រការដូច្នេះ ។ បទថា **អជ្ឈត្តំ វា** បានដល់ ក្នុងខាងក្នុងបរិស័ទរបស់លោក ។ បទថា **ពហិទ្ធា** បានដល់ ក្នុងបរិស័ទរបស់ជនពួកដទៃ ។ បទថា **មក្ខិ** បានដល់ អ្នកប្រកបដោយសេចក្តីមើលងាយ ដែលមានការមើលងាយគុណរបស់ជនពួកដទៃជាលក្ខណៈ ។ បទថា **បលាសិ** បានដល់ អ្នកប្រកបដោយការវាយឫកស្មើ ដែលមានការប្រកួតប្រជែងជាលក្ខណៈ ។

បទថា **ឥស្សុកិ** បានដល់ អ្នកប្រកបដោយសេចក្តីឫស្យា ដែលមានការឫស្យាគ្រឿងសក្ការៈរបស់ជនដទៃជាដើមជាលក្ខណៈ ។ បទថា **មច្ឆរិ** បានដល់ អ្នកប្រកបដោយសេចក្តីកំណាញ់ទីនៅជាដើម ។ បទថា **សឋោ** បានដល់ អ្នកពេញទៅដោយការបញ្ឆោតបន្លំ ( អ្នកអួតអាង ) ។ បទថា **មាយាវី** បានដល់ អ្នកបិទបាំងសេចក្តីអាក្រក់ដែលខ្លួនធ្វើហើយ ។ បទថា **បាបិច្ឆោ** បានដល់ អ្នកប្រាថ្នានឹងឲ្យមានក្នុងវត្ថុដែលមិនមាន គឺអ្នកទ្រុស្តសីល ។

បទថា **មិច្ឆាទិដ្ឋិ** បានដល់ អ្នកមានប្រក្រតីពោលថា មិនមានអ្នកមានប្រក្រតីពោលថា រកហេតុមិនបាន អ្នកមានប្រក្រតីពោលថា មិនជាការធ្វើ ។ បទថា **សន្ទិដ្ឋិបរាមាសិ** គឺស្ទាបអង្អែលនូវទិដ្ឋិរបស់ខ្លួនឯងតែម្យ៉ាង ។ បទថា

**អាធានគ្គាហី** គឺអ្នកប្រកាន់យ៉ាងមាំ ។ បទថា **ឧប្បដិនិស្សគ្គី** បានដល់ មិនអាចនឹងលះបង់វត្ថុដែលខ្លួនប្រកាន់ ។

[ ១៩០ ] ធាតុដែលតាំងនៅចំពោះ ឈ្មោះថា **បឋវីធាតុ** ។ ធាតុដែលសើម ឈ្មោះថា **អាបោធាតុ** ។ ធាតុដែលញុំាងអាហារឲ្យរលួយ ឈ្មោះថា **តេជោធាតុ** ។ ធាតុដែលកម្រើកញ័របាន ឈ្មោះថា **វាយោធាតុ** ។ ធាតុដែលពាល់ត្រូវមិនបាន ឈ្មោះថា **អាកាសធាតុ** ។ ធាតុដែលដឹងច្បាស់ ឈ្មោះថា **វិញ្ញាណធាតុ** ។

[ ១៩១ ] ធាតុដែលរួចផុតទៅ ឈ្មោះថា **និស្សារណីយធាតុ** ។ ក្រើនបទថា **បរិយាទាយ តិដ្ឋតិ** បានដល់ គ្របសង្កត់ឲ្យវិនាសហើយតាំងនៅ ។ ក្រើនបទថា **មា ហេវន្តិស្ស វចនីយោ** បានដល់ ព្រោះហេតុដែលភិក្ខុព្យាករនូវពាក្យព្យាករដែលមិនពិត ដូច្នោះ គប្បីត្រូវពោលថា លោកកុំនិយាយយ៉ាងនេះ ។ ពីរបទថា **យមិទំ មេត្តា ចេតោវិមុត្តិ** បានដល់ មេត្តាចេតោវិមុត្តិនេះ ជាគ្រឿងរលាស់ចេញនូវការព្យាបាទ អធិប្បាយថា ចេញចាកសេចក្ដីព្យាបាទ ។ ភិក្ខុណាចេញចាកតតិយជ្ឈាន ឬចតុក្កជ្ឈានដោយមេត្តា ពិចារណាសង្ខារទាំងឡាយ សម្រេចតតិយមគ្គ ហើយឃើញព្រះនិព្វានដោយតតិយផលថា ព្យាបាទមិនមានទៀត ចិត្តរបស់ភិក្ខុនោះ ឈ្មោះថា ជាចិត្តដែលរលាស់ចេញនូវសេចក្ដីព្យាបាទដោយចំណែកតែមួយ ។ បណ្ឌិតគប្បីជ្រាបខ្លឹមសារ ក្នុងបទទាំងពួងដោយឧបាយនេះ ។ សមាបត្តិរបស់អរហត្តផល ឈ្មោះថា **អនិមិត្តាចេតោវិមុត្តិ** ។ សមាបត្តិរបស់អរហត្តផលនោះ លោកហៅថា មិនមាននិមិត្ត

ព្រោះមិនមានរាគនិមិត្តជាដើម ។ ព្រោះមិនមានរូបនិមិត្តជាដើម និងព្រោះមិនមាននិច្ចនិមិត្តជាដើម ។ បទថា **និមិត្តានុសារី** សេចក្តីថា ភិក្ខុដែលត្រាច់ទៅតាមនិមិត្ត ដែលមានប្រភេទតាមដែលពោលហើយ ព្រោះហេតុនោះ ទើបឈ្មោះថា **និមិត្តានុសារី** ( អ្នកត្រាច់ទៅតាមនិមិត្ត ) ។ បទថា **អស្មិ** បានដល់ការប្រកាន់ថា យើងមាន ( អស្មិមានះ ) ។

បទថា **អយមហមស្មិ** បានដល់ អរហត្ត ដែលលោកព្យាករណ៍ហើយ ដោយពាក្យមានប្រមាណប៉ុណ្ណេះថា យើងឈ្មោះនេះ មាននៅក្នុងខន្ធ ៥ ។ បទថា **វិចិកិច្ឆា កថំកថា សល្លំ** បានដល់ កូនសរ គឺសេចក្តីងឿងឆ្ងល់ សង្ស័យដែលជាតួវិចិកិច្ឆា ។

ច្រើនបទថា **មា ហេវន្តិស្ស វចនីយោ** សេចក្តីថា បើថា វិចិកិច្ឆា ដែលគួរកម្ចាត់ដោយបឋមមគ្គនឹងកើតឡើងដល់លោកសោត ការព្យាករណ៍អរហត្តក៏ជាការខុស ព្រោះហេតុនោះ អ្នកនោះ គប្បីត្រូវហាមថា លោកកុំពោលពាក្យដែលមិនពិត ។

បទថា **អស្មិ** សេចក្តីថា អរហត្តមគ្គ ឈ្មោះថា ដកមានះចេញបាន ។ កាលបុគ្គលឃើញព្រះនិព្វាន ដោយអំណាចនៃអរហត្តផលហើយ អស្មិមានះ ( សេចក្តីប្រកាន់ខ្លួនថាយើងមាន ) រមែងមិនមានទៀត ព្រោះហេតុនោះ ព្រះទើបអរហត្តមគ្គ លោកពោលថា ដកនូវអស្មិមានះចេញបាន ។

[ ១៩២ ] បទថា **អនុត្តរិយានិ** សេចក្តីថា មិនមានអ្វីដទៃខ្ពង់ខ្ពស់ជាង គឺប្រសើរជាទីបំផុត ។ មិនមានអ្វីដទៃក្រៃលែងជាងក្នុងការឃើញទាំងឡាយ ឈ្មោះថា **ទស្សនានុត្តរិយ** ។

ក្នុងបទដ៏សេស ក៏ន័យនេះដូចគ្នា ។ បណ្តាការឃើញទាំងនោះ ការឃើញដំរីកែវជាដើម មិនចាត់ជាទស្សនានុត្តរិយៈឡើយ ។ ឯចំពោះអ្នកមានសទ្ធាតាំងមាំហើយ ការឃើញព្រះទសពល ឬព្រះភិក្ខុសង្ឃ ដោយអំណាចសេចក្តីស្រឡាញ់ដែលតាំងមាំហើយ ឬថា ការឃើញបណ្តកសិណនិមិត្ត និងអសុភនិមិត្តជាដើមណានីមួយ ឈ្មោះថា **ទស្សនានុត្តរិយ** ។

ការស្តាប់គុណកថា របស់ក្សត្រជាដើម មិនចាត់ជាសវនានុត្តរិយៈ ។ ចំណែកអ្នកមានសទ្ធាតាំងមាំហើយ ការស្តាប់គុណកថា របស់ព្រះរតនត្រ័យ ដោយអំណាចសេចក្តីស្រឡាញ់ ដែលតាំងមាំហើយ ឬថា ការស្តាប់ព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដក ឈ្មោះថា **សវនានុត្តរិយ** ។

ការបានរតនៈ គឺកែវមណីជាដើម មិនចាត់ជាលាភានុត្តរិយៈ ។ ចំណែកការបានអរិយទ្រព្យ ៧ យ៉ាង ឈ្មោះថា **លាភានុត្តរិយ** ។

ការសិក្សាសិល្បៈ មានសិល្បៈដំរីជាដើម មិនចាត់ជាសិក្ខានុត្តរិយៈ ។ ចំណែកការបំពេញសិក្ខាទាំង ៣ ឲ្យបរិបូណ៌ ឈ្មោះថា **សិក្ខានុត្តរិយ** ។

ការបម្រើក្សត្រជាដើម មិនចាត់ជាបារិចរិយានុត្តរិយៈ ។ ចំណែកការបម្រើព្រះរតនត្រ័យ ឈ្មោះថា **ចារិចរិយានុត្តរិយ** ។

ការតាមរឭកដល់គុណរបស់ក្សត្រជាដើម មិនចាត់ជាអនុស្សរណានុត្តរិយៈ ( អនុស្សតានុត្តរិយៈ ) ។ ចំណែកការតាមរឭកដល់គុណរបស់ព្រះរតនត្រ័យ ឈ្មោះថា **អនុស្សរណានុត្តរិយ** ( អនុស្សតានុត្តរិយៈ ) ។

[ ១៩៣ ] អនុស្សតិទាំងឡាយនោះឯង ឈ្មោះថា **អនុស្សតិដ្ឋាន**(ទីតាំង

នៃការរឭកដល់ )។ ការរឭកដល់គុណរបស់ព្រះពុទ្ធ ឈ្មោះថា **ពុទ្ធានុស្សតិ** ។ កាលបុគ្គលរឭកដល់យ៉ាងនេះហើយ បីតិរមែងកើតឡើង ។ បុគ្គលនោះ ផ្តើមតាំងបីតិនោះដោយការអស់ទៅ ដោយការសាបសូន្យទៅ រមែងសម្រេចភាពជាព្រះអរហន្តបាន ។ ធម្មតាថា ឧបចារកម្មដ្ឋាននេះ សូម្បីគ្រហស្ថទាំងឡាយ រមែងបាន ( សម្រេចបាន ) ក្នុងកម្មដ្ឋានទាំងពួង ក៏ន័យនេះដូចគ្នា ។ ចំណែកកថាដោយពិស្តារ បណ្ឌិតគប្បីជ្រាបដោយន័យដែលខ្ញុំពោលហើយ ក្នុងវិសុទ្ធិមគ្គនោះឯង ។

[ ១៩៤ ] ការនៅប្រចាំរបស់ព្រះខីណាស្រព ឈ្មោះថា **សតតវិហារ** ។ ត្រង់បទថា **ចក្ខុនា រូបំ ទិស្វា** សេចក្តីថា កាលអារម្មណ៍នៃចក្ខុទ្វារទៅកាន់គន្លង ភិក្ខុឃើញរូបនោះដោយចក្ខុវិញ្ញាណហើយ មិនត្រេកអរក្នុងជវនក្ខណៈដែលគួរត្រេកអរ រមែងជាអ្នកមិនពេញចិត្ត មិនប្រទូស្តក្នុងជវនក្ខណៈ ដែលមិនគួរត្រេកអរ រមែងជាអ្នកមិនទាស់ចិត្ត មិនញុំាងមោហៈឲ្យកើតឡើង ព្រោះការសម្លឹងដែលមិនស្មើ ព្រងើយ មានខ្លួនជាកណ្តាល មានសតិ ព្រោះភាពជាអ្នកប្រកបដោយសតិ មានសម្បជញ្ញៈ ព្រោះភាពជាអ្នកប្រកបដោយសម្បជញ្ញៈ ។ ក្នុងបទដ៏សេសទាំងឡាយ ក៏ន័យនេះដូចគ្នា ។ ភិក្ខុរមែងនៅយ៉ាងព្រងើយ សូម្បីក្នុងទ្វារទាំង ៦ ដោយប្រការដូច្នេះ ។ លោកពោលឆឡង្គុបេក្ខាដោយបទនេះ ។ ព្រោះបទថា **សម្បជានោ** បណ្ឌិតរមែងបានញាណសម្បយុត្តចិត្ត ៤ ដួង ។ បទថា **សតតវិហារា** បណ្ឌិតរមែងបានមហាចិត្តសូម្បីទាំង ៨ ដួង ។ ព្រោះពាក្យថា **អរជ្ជន្តោ អទុស្សន្តោ** បណ្ឌិតរមែងបាន

នូវចិត្តទាំង ១០ ដួង ។ បើមានពាក្យសួរជ្រៀតចូលមកថា សោមនស្សនឹងមានដូចម្តេច ឆ្លើយថា មានព្រោះអាសេវនៈ ។

[ ១៩៥ ] ជាតិទាំងឡាយ ឈ្មោះថា **អភិជាតិ** ។ ពីរបទថា **កណ្ហាភិ-ជាតិកោ សមានោ** សេចក្តីថា អ្នកកើតហើយក្នុងទីខ្មៅ គឺក្នុងត្រកូលថោកទាប ។ ប្រើនបទថា **កណ្ហំ ធម្មំ អភិជាយតិ** សេចក្តីថា រមែងប្រសព្វ គឺធ្វើធម៌ គឺភាពជាអ្នកទ្រុស្តសីល ១០ ប្រការ ដែលជាធម៌ចំណែកខ្មៅ ។ បុគ្គលនោះប្រសព្វធម៌ គឺភាពជាអ្នកទ្រុស្តសីល ១០ ប្រការនោះហើយ រមែងកើតក្នុងនរក ។ ពីរបទថា **សុក្កំ ធម្មំ** សេចក្តីថា យើងកើតហើយក្នុងត្រកូលថោកទាប ព្រោះមិនបានធ្វើបុណ្យក្នុងកាលមុន ឥឡូវនេះ យើងនឹងធ្វើបុណ្យ ព្រោះហេតុនោះ គេរមែងប្រសព្វធម៌ចំណែកស ពោល គឺបុណ្យ ។ បុគ្គលនោះ រមែងកើតក្នុងសួគ៌ ដោយធម៌ចំណែកស ពោល គឺបុណ្យនោះ ។ ប្រើនបទថា **អកណ្ហំ អសុក្កំ និព្វានំ** សេចក្តីថា ព្រះនិព្វាន បើថា នឹងគប្បីជាធម៌ចំណែកខ្មៅសោត នឹងគប្បីឲ្យវិបាកដែលខ្មៅ បើថា នឹងគប្បីជាធម៌ចំណែកសសោត នឹងគប្បីឲ្យវិបាកដែលស តែព្រោះមិនឲ្យវិបាកទាំង ២ ទើបព្រះនិព្វាន លោកពោលថា មិនខ្មៅ មិនស ។ ធម្មតា ព្រះនិព្វានលោកប្រាថ្នាយកអរហត្ត ក្នុងអត្ថនេះ ។ ពិតមែន អរហត្តនោះ ឈ្មោះថា ព្រះនិព្វាន ព្រោះកើតក្នុងទីបំផុតនៃការរលត់កិលេស ។ បុគ្គលនោះ រមែងជួប គឺប្រសព្វធ្វើព្រះនិព្វាននោះ ។ ពីរបទថា **សុក្កាភិជាតិកោ សមានោ** សេចក្តីថា ជាអ្នកកើតហើយក្នុងទីស គឺក្នុងត្រកូលខ្ពស់ ។ ពាក្យដ៏សេសបណ្ឌិតគប្បីជ្រាបដោយ ន័យដែលពោលហើយទុំះឯង ។

[ ១៩៦ ] បទថា **និព្វេធភាគិយា** សេចក្ដីថា ព្រះនិព្វាន លោកហៅថា **និព្វេធ** ។ ជនទាំងឡាយ រមែងសេពគប់ គឺរមែងចូលទៅជិត ព្រះនិព្វាននោះ ព្រោះហេតុនោះ ឈ្មោះថា **និព្វេធភាគិយា** ( ចំណែកនៃការចាក់ធ្លុះ ) ។ អនិច្ចសញ្ញាជាដើម លោកពោលក្នុងពួក ៥ ។ សេចក្ដីកំណត់សំដៅក្នុងនិរោធានុបស្សនាញាណ ឈ្មោះថា **និរោធសញ្ញា** ។ ពាក្យជាដើមថា **ឥមេ ខោ អាវុសោ** បណ្ឌិតគប្បីប្រកបដោយន័យដែលពោលហើយនុ៎ះឯង ។ ព្រះថេរៈពោលនូវបញ្ហា ១៣២ បញ្ហា ដោយអំណាចនៃពួកប្រាំមួយ ២២ ពួក សម្ដែងសាមគ្គីរស ដោយប្រការដូច្នេះឯង ។

**ពួក ៦ ចប់**

## ពោលអំពីធម៌ពួក ៧

[ ១៩៧ ] ព្រះថេរៈគ្រាសម្ដែង សាមគ្គីរស ដោយអំណាចនៃពួក ៦ ដោយប្រការដូច្នេះហើយ ឥឡូវនេះ ដើម្បីនឹងសម្ដែងសាមគ្គីរស ដោយអំណាចនៃពួក ៧ ទើបផ្ដើមប្រារព្ធព្រះធម៌ទេសនាទៀត ។

បណ្ដាបទទាំងនោះ ទ្រព្យ គឺសទ្ធា ឈ្មោះថា ទ្រព្យ គឺសទ្ធាដោយអត្ថថា បានចំពោះនូវសម្បត្តិ ។ ក្នុងបទទាំងពួង ក៏ន័យនេះដូចគ្នា ។ បណ្ដាអរិយទ្រព្យទាំងនេះ ទ្រព្យ គឺបញ្ញាប្រសើរជាងទ្រព្យទាំងពួង ។ ព្រោះថា សត្វទាំងឡាយតាំងនៅក្នុងបញ្ញាហើយ បំពេញសុចរិត ៣ សីល ៥ សីល ១០ ឲ្យបរិបូណ៌ រមែងចូលដល់សួគ៌ គឺរមែងចាក់ធ្លុះនូវសាវកបារមីញាណ បច្ចេកពោធិញ្ញាណ និងព្រះសព្វញ្ញុតញ្ញាណបាន ។ បញ្ញា លោកហៅថា ទ្រព្យ គឺបញ្ញា ព្រោះជា

ហេតុនៃការបានចំពោះនូវសម្បត្តិទាំងនេះ ។ អរិយទ្រព្យទាំង ៧ ប្រការនេះ លោកពោលថា លាយដោយលោកិយ និងលោកុត្តរ ។

[ ១៩៨ ] ពោជ្ឈង្គកថា លោកបានពោលហើយនោះឯង ។

[ ១៩៩ ] បរិវារនៃសមាធិ ឈ្មោះថា **សមាធិបរិក្ខារា** ។ សម្មាទិដ្ឋិជាដើម មានអត្ថដូចដែលលោកពោលហើយនោះឯង ។

ដោយបទថា **សម្មាទិដ្ឋិ** ទាំងនេះជាដើម បរិក្ខារ ៧ លោកពោលថា ទាំងជាលោកិយ ទាំងជាលោកុត្តរនោះឯង ។

[ ២០០-២០១ ] ធម៌របស់អសប្បុរសទាំងឡាយ ឈ្មោះថា **អសទ្ធម្ម** ម្យ៉ាងទៀត ធម៌ដែលមិនស្ងប់ គឺធម៌ដ៏លាមក ព្រោះហេតុនោះ ទើបឈ្មោះថា **អសទ្ធម្ម**។ បណ្ឌិតគប្បីជ្រាបសទ្ធម្ម ដោយបរិយាយផ្ទុយគ្នា ។ បណ្ដាបទទាំងនោះ ពាក្យដ៏សេស មានសេចក្ដីងាយយល់ទាំងអស់ ។ បណ្ដាសទ្ធម្មទាំង-ឡាយ សទ្ធម្មទាំងពួង មានសទ្ធាជាដើម លោកពោលចំពោះវិបស្សនា ។ បញ្ញា សូម្បីក្នុងសទ្ធម្មទាំងនោះ មានទាំងជាលោកិយ ទាំងជាលោកុត្តរ ។ នេះសេចក្ដីសង្ខេប ។

[ ២០២ ] ពីរបទថា **សប្បុរិសានំ ធម្មា** បានដល់ ធម៌របស់សប្បុរស ។ ជនណាដឹងធម៌ ក្នុងបណ្ដាសប្បុរិសធម៌ទាំងនោះ មានសុត្តៈ និងគេយ្យៈជាដើម ព្រោះហេតុនោះ ជននោះ ឈ្មោះថា **ធម្មញ្ញូ** ( ស្គាល់ហេតុ ) ។ជនណាដឹងអត្ថនៃភាសិតនោះឯង ព្រោះហេតុនោះ ជននោះ ឈ្មោះថា **អត្ថញ្ញូ** ( ស្គាល់ផល ) ។ជនណាស្គាល់ខ្លួនយ៉ាងនេះថា អញជាអ្នកមានប្រមាណប៉ុណ្ណេះ ដោយសីល សមាធិ បញ្ញា ព្រោះហេតុនោះ ជននោះ ឈ្មោះថា **អត្តញ្ញូ** ( ស្គាល់ខ្លួន ) ។ ជនណាស្គាល់ប្រមាណក្នុងការទទួល និងការបរិភោគ ព្រោះហេតុនោះ

ជននោះ ឈ្មោះថា **មត្តញ្ញូ** ( ស្គាល់ប្រមាណ ) ។ ជនណាស្គាល់កាលយ៉ាង នេះថា នេះកាលសម្តែង នេះកាលសាកសួរ នេះកាលសម្រេចយោគធម៌ ព្រោះហេតុនោះ ជននោះ ឈ្មោះថា **កាលញ្ញូ** (ស្គាល់កាល) ។ បណ្តាកាល ទាំងនោះ កាលសម្តែង ៥ ឆ្នាំ កាលសាកសួរ ១០ ឆ្នាំ ។ នេះរាប់ថា ចង្អៀត ក្រៃលែងណាស់ ។ កាលសម្តែង ១០ ឆ្នាំ កាលសាកសួរ ២០ ឆ្នាំ ។ ខាង មុខអំពីនេះទៅ បណ្ឌិតគប្បីធ្វើកម្មក្នុងការប្រកបចុះ ។ ជនណាស្គាល់បរិស័ទ ៨ យ៉ាង ព្រោះហេតុនោះ ជននោះ ឈ្មោះថា **បរិសញ្ញូ** ( ស្គាល់បរិស័ទ ) ។ ជនណា ស្គាល់បុគ្គល ដែលគួរសេព ឬមិនគួរសេព ព្រោះហេតុនោះ ជន នោះ ឈ្មោះថា **បុគ្គលញ្ញូ** ( ស្គាល់បុគ្គល ) ។

[ ២០៣ ] វត្ថុមាននិទ្ទេសជាដើម ឈ្មោះថា **និទ្ទេសវត្ថុ** ។ ហេតុនៃពាក្យ យ៉ាងនេះថា ភិក្ខុមិនមាន ១០ ភិក្ខុមិនមាន ២០ មិនមាន ៣០ មិនមាន ៤០ មិនមាន ៥០ ។ បានឮមកថា បញ្ហានេះកើតឡើងក្នុងសម័យតិរ្ថិយ ។ ពួកតិរ្ថិយ ពោលដល់និគ្រន្ថអ្នកស្លាប់ក្នុងវេលា ១០ ឆ្នាំ ថាមិនមែន ១០ ។ បានឮមកថា និគ្រន្ថនោះ មានកាលនៃវស្សា ១០ ក៏មិនមែនទៀត ។ មួយទៀត នឹងថា ១០ ឆ្នាំតែម្យ៉ាងក៏មិនមែន សូម្បី ៩ ឆ្នាំ ។ល។ សូម្បី ១ ឆ្នាំក៏មិនមែន ។ ដោយ ន័យនោះឯង ពួកតិរ្ថិយពោលដល់និគ្រន្ថអ្នកស្លាប់ ក្នុងវេលា ២០ ឆ្នាំជាដើម ថា មិនមែន ២០ មិនមែន ៣០ មិនមែន ៤០ មិនមែន ៥០ ។ ព្រះអានន្ទត្រាច់ ទៅបិណ្ឌបាតក្នុងស្រុក ស្តាប់ពាក្យនោះហើយ ទើបទៅកាន់វិហារ ក្រាបទូល ចំពោះព្រះមានព្រះភាគ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ ន៎ុះមិនមែន ពាក្យរបស់ពួកតិរ្ថិយទេ ន៎ុះជាពាក្យរបស់ព្រះខីណាស្រព ក្នុងសាសនារបស់

តថាគត ដូច្នេះ ។ គឺថា ព្រះខីណាស្រពបរិនិព្វានហើយក្នុងវេលា ១០ ឆ្នាំ នឹងជាអ្នកមានឈ្មោះថា មានកាលនៃវស្សា ១០ ទៀតក៏មិនមែន ។ មួយទៀត ព្រះខីណាស្រព នឹងជាអ្នកឈ្មោះថា មានកាលនៃវស្សា ១០ តែម្យ៉ាងក៏មិនមែន សូម្បីនឹងជាអ្នកមានកាលនៃវស្សា ៩ ។ល។ សូម្បីនឹងជាអ្នកមានកាលនៃវស្សា ១ ។ មួយទៀត ព្រះខីណាស្រព នឹងជាអ្នកឈ្មោះថា មានកាលនៃវស្សា ១ តែម្យ៉ាងក៏មិនមែន នឹងជាអ្នកឈ្មោះថា ១០ ខែខ្លះ ។ល។ ១ ខែខ្លះ ១ ថ្ងៃខ្លះ គ្រូមួយខ្លះក៏មិនមែន ។ សួរថា ព្រោះហេតុអ្វី ។

ឆ្លើយថា ព្រោះការមិនមានបដិសន្ធិទៀត ។ សូម្បីក្នុងពាក្យថា មិនមាន ២០ ជាដើម ក៏ន័យនេះដូចគ្នា ។ ព្រះមានព្រះភាគ ត្រាស់ថា រាប់ជាពាក្យរបស់ព្រះខីណាស្រព ក្នុងសាសនារបស់តថាគត ដោយប្រការដូច្នេះ ដូច្នេះហើយ ដើម្បីនឹងទ្រង់សម្តែងហេតុដែលព្រះខីណាស្រពនោះ ជាអ្នកមិនមែន ( មានកាលនៃវស្សា ) ១០ ទើបទ្រង់សម្តែងនិទ្ទសវត្ថុ ៧ ប្រការ ។ សូម្បីព្រះថេរៈ កាលលើកព្រះធម៌ទេសនានោះឯងឡើងហើយ ទើបពោលនិទ្ទសវត្ថុ ៧ ប្រការ ដូចមានពាក្យជាអាទិថា ម្នាលអ្នកមានអាយុ ភិក្ខុក្នុងព្រះសាសនានេះ ជាអ្នកមានសេចក្តីពេញចិត្តដ៏ក្លៀវក្លា ក្នុងការសមាទានសិក្ខា ។ បណ្តាពាក្យទាំងនោះ ពាក្យថា **ឥធ** បានដល់ ក្នុងព្រះសាសនានេះ ។ ច្រើនបទថា **សិក្ខាសមាទានេ តិព្វច្ឆន្ទោ ហោតិ** សេចក្តីថា ជាអ្នកមានសេចក្តីពេញចិត្តដ៏ក្លៀវក្លា ក្នុងការបំពេញត្រៃសិក្ខា ។ ច្រើនបទថា **អាយតិញ្ច សិក្ខាសមាទានេ អវិគតប្បេមោ** សេចក្តីថា ជាអ្នកព្រមដោយសេចក្តីស្រឡាញ់ ដែលខ្ជួនសម្រេច

ហើយ ក្នុងការបំពេញសិក្ខា សូម្បីក្នុងថ្ងៃស្អែកជាដើម ក្នុងអនាគត ។ បទថា **ធម្មនិសន្តិយា** សេចក្តីថា ដោយការពិចារណាធម៌ ។ ពាក្យនោះជាឈ្មោះរបស់វិបស្សនា ។ បទថា **ឥច្ឆាវិនយេ** សេចក្តីថា ក្នុងការកម្ចាត់តណ្ហា ។ បទថា **បដិសល្លានេ** សេចក្តីថា ក្នុងភាពជាបុគ្គលតែម្នាក់ឯង ។ បទថា **វីរិយារម្ភេ** សេចក្តីថា ក្នុងការបំពេញសេចក្តីព្យាយាម ដែលប្រព្រឹត្តទៅផ្លូវកាយ និងប្រព្រឹត្តទៅផ្លូវចិត្ត ។ បទថា **សតិនេបក្កេ** សេចក្តីថា ក្នុងសតិ និងក្នុងភាពជាអ្នកមានបញ្ញាជាគ្រឿងរក្សាខ្លួន ។ បទថា **ទិដ្ឋិបដិវេធេ** សេចក្តីថា ក្នុងការឃើញមគ្គ ។ ពាក្យដ៏សេស បណ្ឌិតគប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងទីទាំងពួងចុះ ។

[ ២០៤ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងសញ្ញាទាំងឡាយ ។ សញ្ញាក្នុងអសុភានុបស្សនាញាណ ឈ្មោះថា **អសុភសញ្ញា** ។ សញ្ញាក្នុងអាទីនវានុបស្សនាញាណ ឈ្មោះថា **អាទីនវសញ្ញា** ។ សញ្ញាដ៏សេសលោកពោលហើយទុះឯង ។

[ ២០៥-២០៧ ] ពួក ៧ នៃពល ពួក ៧ នៃវិញ្ញាណដ្ឋិតិ និងពួក ៧ នៃបុគ្គល មានន័យដែលលោកពោលហើយនោះឯង ។

[ ២០៨ ] កិលេសទាំងឡាយពួកណា រមែងដេកត្រាំ ដោយអត្ថថា លះមិនបាន ព្រោះហេតុនោះ កិលេសទាំងនោះ ឈ្មោះថា **អនុសយ** ។ កាមរាគៈដែលមានកម្លាំងខ្លាំងក្លា ឈ្មោះថា **កាមរាគានុសយ** ។ ក្នុងរាគៈទាំងពួង ក៏ន័យនេះ ។

[ ២០៩ ] ពួក ៧ នៃសញ្ញោជនៈ មានសេចក្តីជាក់ច្បាស់ហើយ ។

[ ២១០ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអធិករណសមថៈតទៅនេះ អធិករណ៍ទាំងឡាយ រមែងស្ងប់ គឺចូលទៅរម្ងាប់ ព្រោះហេតុនោះ ទើបឈ្មោះថា **អធិករណសមថ** ។ បទថា **ឧប្បន្នុប្បន្នានំ** សេចក្តីថា កើតឡើងហើយ កើតឡើងហើយ ។ បទថា **អធិករណានំ** សេចក្តីថា នៃអធិករណ៍ទាំង ៤ នេះ គឺវិវាទាធិករណ៍ ១ អនុវាទាធិករណ៍ ១ អាបត្តាធិករណ៍ ១ កិច្ចាធិករណ៍ ១ ។ ពីរបទថា **សមថាយ វូបសមាយ** សេចក្តីថា ដើម្បីស្ងប់ និងដើម្បីចូលទៅរម្ងាប់ ។ ព្រះវិនយធរ គប្បីឲ្យសមថៈទាំង ៧ នេះ គឺគប្បីឲ្យសម្មុខាវិន័យ ។ល។ គប្បីឲ្យតិណវត្ថារកវិន័យ ។

ន័យក្នុងការវិនិច្ឆ័យ ក្នុងសមថៈទាំងនោះ ដូចតទៅនេះ

គប្បីជ្រាបវិនិច្ឆ័យ ក្នុងអធិករណ៍ទាំងឡាយមុន វិវាទយ៉ាងណា នៃភិក្ខុទាំងឡាយដែលវិវាទគ្នា ដោយវត្ថុ ១៨ ប្រការថា ធម៌ ឬមិនមែនធម៌ក៏ដោយ យ៉ាងនេះ ឈ្មោះថា **វិវាទាធិករណ** ការពោលទោស ។ ការពោលទោស ការតិះដៀល និងការចោទគ្នាយ៉ាងណា នៃភិក្ខុដែលពោលទោសគ្នាដល់សីលវិបត្តិក្តី ដល់អាចារវិបត្តិ និងអាជីវវិបត្តិក្តី យ៉ាងនេះ ឈ្មោះថា **អនុវាទាធិករណ** ។ កងនៃអាបត្តិទាំង ៧ គឺកងនៃអាបត្តិ ៥ មកក្នុងមាតិកានៃកងអាបត្តិ ២ មកក្នុងវិភង្គយ៉ាងនេះ ឈ្មោះថា **អាបត្តាធិករណ** ។ ការធ្វើកម្ម ៤ យ៉ាង មានអបលោកនកម្មជាដើមនៃសង្ឃ យ៉ាងនេះ ឈ្មោះថា **កិច្ចាធិករណ** ។

បណ្តាអធិករណ៍ទាំងនោះ វិវាទាធិករណ៍ រម្ងាប់បានដោយសមថៈ ២ គឺសម្មុខាវិន័យ ១ យេភុយ្យសិកា ១ ។ វិវាទាធិករណ៍ រម្ងាប់ហើយ ដោយ

សម្មុខាវិន័យប៉ុណ្ណោះ គឺវិវាទាធិករណ៍ កើតឡើងក្នុងវិហារណា ដែលសង្ឃវិនិច្ឆ័យហើយក្នុងវិហារនោះឯង រមែងរម្ងាប់ កាលភិក្ខុទៅដើម្បីនឹងរម្ងាប់ក្នុងទីដទៃ ដែលសង្ឃវិនិច្ឆ័យហើយក្នុងចន្លោះផ្លូវ ក៏រមែងរម្ងាប់បាន ដែលភិក្ខុប្រគល់ទៅឲ្យដល់សង្ឃក្នុងទីណា ដែលសង្ឃក្នុងទីនោះវិនិច្ឆ័យហើយ ក៏រមែងរម្ងាប់បាន ឬថា កាលសង្ឃមិនអាចដើម្បីនឹងរម្ងាប់ដល់បុគ្គលដែលសង្ឃសម្មតិហើយវិនិច្ឆ័យដើម្បីទាញចេញ (អំពីអាបត្តិ) ក្នុងទីនោះឯង រមែងរម្ងាប់បានដូចគ្នា ។ កាលវិវាទាធិករណ៍នោះរម្ងាប់ហើយយ៉ាងនេះ សេចក្តីព្រមព្រៀងចំពោះមុខសង្ឃ សេចក្តីព្រមព្រៀងចំពោះមុខធម៌ សេចក្តីព្រមព្រៀងចំពោះមុខវិន័យ សេចក្តីព្រមព្រៀងចំពោះមុខបុគ្គល យ៉ាងណា យ៉ាងនេះ ឈ្មោះថា **សម្មុខាវិនយ** ។ បណ្តាការព្រមព្រៀងចំពោះមុខទាំងនោះ សេចក្តីដែលសង្ឃអ្នកធ្វើ ( កម្ម ) ព្រមព្រៀងគ្នា ដោយអំណាចនៃការសាមគ្គីរបស់សង្ឃ យ៉ាងនេះ ឈ្មោះថា សេចក្តីព្រមព្រៀងចំពោះមុខសង្ឃ ។ កាលមានវត្ថុ ( រឿង ) ដែលនឹងគប្បីរម្ងាប់ ឈ្មោះថា សេចក្តីព្រមព្រៀងចំពោះមុខធម៌ ។ ការពិចារណា ដោយប្រការដែលវិវាទាធិករណ៍នឹងគប្បីរម្ងាប់ទៅ ឈ្មោះថា ការព្រមព្រៀងក្នុងវិន័យ ។ ភិក្ខុណាវិវាទគ្នា និងវិវាទដោយសេចក្តី យ៉ាងណា សេចក្តីព្រមព្រៀងគ្នានៃសេចក្តី និងគូករណី ( សត្រូវ ) ទាំងពីរនោះ ឈ្មោះថា សេចក្តីព្រមព្រៀងចំពោះមុខបុគ្គល ។ សេចក្តីព្រមព្រៀងចំពោះមុខសង្ឃ ក្នុងវិវាទាធិករណ៍នេះរមែងស្ងប់បាត់ទៅ ព្រោះការចូលទៅរម្ងាប់ ដើម្បីទាញចេញ ( ចាកអាបត្តិ) ។ វិវាទាធិករណ៍ រមែងរម្ងាប់ទៅដោយសម្មុខាវិន័យប៉ុណ្ណោះ យ៉ាងនេះមុន ។ បើ

វិវាទាធិករណ៍មិនរម្ងាប់ទៅ សូម្បីយ៉ាងនោះ កាលបើដូច្នេះ ពួកភិក្ខុដែលសង្ឃសម្មតិដើម្បីទាញចេញ ( ចាកអាបត្តិ ) រមែងប្រគល់រឿងនោះដល់សង្ឃវិញឯងដោយគិតថា ពួកយើងមិនអាចដើម្បីនឹងរម្ងាប់បាន ។ លំដាប់នោះ ទើបសង្ឃសម្មតិភិក្ខុ ដែលប្រកបដោយអង្គ ៥ ឲ្យជាអ្នកចាប់ទាញ ព្រោះកាលធម្មវាទីនៃបរិស័ទ អ្នកញ៉ាំងភិក្ខុរូបនោះឲ្យចាប់ស្លាក ព្រោះព្រះធម្មវាទីនៃបរិស័ទ អ្នកញ៉ាំងភិក្ខុរូបនោះឲ្យចាប់ស្លាក ដោយអំណាចនៃវិធីយ៉ាងណានីមួយ ក្នុងបណ្ដាការចាប់ស្លាក ៣ យ៉ាង គឺលាក់ខ្លួន ១ បើកផ្សាយ ១ ខ្សឹបជិតត្រចៀករបស់ខ្លួន ១ ប្រជុំគ្នាហើយមានច្រើន អធិករណ៍ដែលចូលទៅរម្ងាប់ ដោយប្រការដែលព្រះធម្មវាទីទាំងនោះពោល ក៏ចាត់ថា ជាការចូលទៅរម្ងាប់ហើយដោយសម្មុខាវិន័យ និងយេភុយ្យសិកា ។ សម្មុខាវិន័យក្នុងវិវាទាធិករណ៍នោះ មានន័យដូចលោកពោលទុកហើយនោះឯង ។ ការធ្វើកម្មដោយសំឡេង ខាងច្រើនជាប្រមាណយ៉ាងណា យ៉ាងនេះ ឈ្មោះថា **យេភុយ្យសិកា** ។ វិវាទាធិករណ៍រមែងរម្ងាប់ដោយសមថៈ ២ យ៉ាង ដោយប្រការដូច្នេះ ។ អនុវាទាធិករណ៍រមែងរម្ងាប់ដោយសមថៈ ៤ គឺសម្មុខាវិន័យ ១ ។ សតិវិន័យ ១ អមូឡ្ហវិន័យ ១ តស្សបាបិយសិកា ១ ។ អនុវាទាធិករណ៍ រម្ងាប់ដោយសម្មុខាវិន័យនោះឯង គឺភិក្ខុដែលចោទពោលទោស និងចោទពោលទោសអ្នកណា អនុវាទាធិករណ៍ដែលសង្ឃស្ដាប់ពាក្យទាំងពីរចំណែកនោះហើយ វិនិច្ឆ័យយ៉ាងនេះថា ប្រសិនបើអាបត្តិខ្លះមិនមាន ញ៉ាំងលោកទាំងពីរឲ្យអត់ទោសហើយ បើមានអាបត្តិក្នុងអនុវាទាធិករណ៍នោះ ឈ្មោះនេះ រមែងចូលទៅរម្ងាប់បាន ។ លក្ខណៈនៃ

សម្មុខាវិន័យ ក្នុងអនុវាទាធិករណ៍នោះ មានន័យដូចខ្ញុំពោលហើយនោះឯង ។ ក្នុងកាលណាសង្ឃឲ្យសតិវិន័យ ដោយញត្តិចតុត្ថកម្មដល់ភិក្ខុដែលជាព្រះខីណាស្រព អ្នកត្រូវចោទដោយសីលវិបត្តិ ដែលមិនមានមូល អ្នកសូមសតិ-វិន័យហើយ ក្នុងកាលនោះ អនុវាទាធិករណ៍ ជាការរម្ងាប់ទៅដោយសម្មុខា-វិន័យ និងសតិវិន័យ ។ កាលសង្ឃឲ្យសតិវិន័យហើយ ការពោលទោសរបស់អ្នកណា រមែងមិនឡើងក្នុងបុគ្គលនោះទៀត ។ ក្នុងកាលណា ភិក្ខុឆ្កួតត្រូវពួកភិក្ខុចោទថា លោកអ្នកមានអាយុ រឭកដល់អាបត្តិបែបនេះបានឬ ក្នុងការប្រព្រឹត្តដែលមិនមែនរបស់សមណៈ ដោយអំណាចនៃការឆ្កួត សូម្បីពោលហើយថា លោកដ៏មានអាយុទាំងឡាយ ខ្ញុំជាមនុស្សឆ្កួតធ្វើកម្មនោះហើយ ខ្ញុំរឭកមិនបានទេ ដូច្នេះហើយ ញុំាងពួកភិក្ខុអ្នកចោទនោះពិតមែន សូមអមូឡ្ហ-វិន័យ ដើម្បីប្រយោជន៍ដល់ការមិនចោទទៀត និងសង្ឃឲ្យអមូឡ្ហវិន័យ ដល់ភិក្ខុនោះ ដោយញត្តិចតុត្ថកម្ម ក្នុងកាលនោះ អនុវាទាធិករណ៍ ជាការចូលទៅរម្ងាប់ ដោយសម្មុខាវិន័យ និងអមូឡ្ហាវិន័យ ។ កាលសង្ឃឲ្យអមូឡ្ហវិន័យហើយ ការពោលទោសរបស់នរណា ព្រោះកាលដែលភិក្ខុនោះឆ្កួតជាបច្ច័យរមែងមិនឡើងក្នុងបុគ្គលនោះទៀត ។ ក្នុងកាលណា កាលបុគ្គលដ៏លាមកព្រោះច្រើនដោយសេចក្តីអាក្រក់ ត្រូវចោទដោយអាបត្តិបារាជិក ឬជិតបារាជិកត្រឡប់ប្រព្រឹត្តជាយ៉ាងដទៃ បើបុគ្គលនេះនឹងជាអ្នកមានមូល ដែលខ្ជូនត្រូវការហើយ ប្រព្រឹត្តដោយប្រពៃពិតមែន នឹងបានការរួមគ្នា ( ចូលពួក ) បើជាអ្នកមានមូលដែលខ្ជូនលះបង់ហើយ សង្ឃនៅសម្គាល់ថា ការបណ្តេញទុំះឯង នឹង

មានដល់បុគ្គលនោះ ទើបធ្វើតស្សបាបិយសិកា ( ការដាក់ទោសដល់អ្នកខុស ) ដោយញត្តិចតុត្ថកម្ម ក្នុងកាលនោះ អនុវាទាធិករណ៍ ជាការចូលទៅរម្ងាប់ ដោយសម្មុខាវិន័យ និងតស្សបាបិយសិកា ។ អនុវាទាធិករណ៍ រមែងរម្ងាប់ទៅដោយសមថៈ ៤ យ៉ាង ដោយប្រការដូច្នេះ ។ អាបត្តាធិករណ៍ រមែងរម្ងាប់ដោយសមថៈ ៣ គឺសម្មុខាវិន័យ ១ បដិញ្ញាតករណៈ ១ តិណវត្ថារកៈ ១ ។ អាបត្តាធិករណ៍នោះ មិនមានការចូលទៅរម្ងាប់ ដោយសម្មុខាវិន័យតែម្យ៉ាង ។ ក្នុងកាលណាភិក្ខុសម្តែងលហុកាបត្តិ ក្នុងសម្នាក់នៃភិក្ខុមួយរូប ឬក្នុងកណ្តាលគណៈសង្ឃ ក្នុងកាលនោះ អាបត្តាធិករណ៍ រមែងចូលទៅរម្ងាប់ ដោយសម្មុខាវិន័យ និងបដិញ្ញាតករណៈ ។ បណ្តាសមថៈទាំងនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងសម្មុខាវិន័យមុន ភិក្ខុដែលសម្តែង និងសម្តែងដល់អ្នកណា សេចក្តីព្រមព្រៀងចំពោះមុខគ្នានៃបុគ្គលទាំងពីរនោះ ឈ្មោះថា សេចក្តីព្រមព្រៀងចំពោះមុខបុគ្គល ។ ពាក្យដ៏សេស មានន័យដូចពោលហើយនុ៎ះឯង ។ សេចក្តីព្រមព្រៀងចំពោះមុខសង្ឃ រមែងស្ងប់បាត់ទៅ ក្នុងកាលដែលសម្តែងដល់បុគ្គល និងគណៈ ។ បណ្តាសមថៈទាំងនេះ ការធ្វើបដិញ្ញាថា បពិត្រលោកដ៏ចម្រើន ខ្ញុំត្រូវហើយនូវអាបត្តិឈ្មោះនេះ និងថា ខ្ញុំករុណាឃើញហើយ ( អ្នកទទួលសម្តែងអាបត្តិពោលថា ) លោកគប្បីសង្រួមប្រុងប្រយ័ត្នតទៅយ៉ាងណា យ៉ាងនោះ ឈ្មោះថា **បដិញ្ញាតករណៈ**។ ការសូមបរិវាសជាដើម ពីអាបត្តិសង្ឃាទិសេសទាំងឡាយ ឈ្មោះថា **បដិញ្ញា** ការឲ្យបរិវាសជាដើម ឈ្មោះថា **បដិញ្ញាតករណៈ**។ ពួកភិក្ខុដែលធ្វើការឈ្លោះគ្នា ចែកជាពីរចំណែកប្រព្រឹត្តកន្លងល្មើសកិច្ច ដែល

មិនមែនរបស់សមណៈជាច្រើន កាលលជ្ជីធម៌កើតឡើងទៀត ឃើញទោស ក្នុងការបបួលគ្នានិងគ្នាឲ្យធ្វើអាបត្តិថា បើថា ពួកយើងគប្បីធ្វើគ្នានិងគ្នា ដោយអាបត្តិទាំងនេះសោត អធិករណ៍នោះ សូម្បីនឹងមាន ក៏គប្បីប្រព្រឹត្តទៅព្រម ដើម្បីភាពជាអ្នកគ្រោតគ្រាតហើយ ទើបធ្វើតិណវត្ថារកកម្មក្នុងកាលណា ក្នុងកាលនោះ អាបត្តាធិករណ៍ រមែងរម្ងាប់ដោយសម្មុខាវិន័យ និងតិណវត្ថារកៈ ។ ភិក្ខុដែលចូលទៅនៅក្នុងហត្ថបាស ក្នុងកម្មនោះ មិនធ្វើកម្មឲ្យច្បាស់ ដែលខ្លួនឃើញយ៉ាងនេះថា កម្មនោះ មិនសមគួរដល់យើង ហើយនាំគ្នាត្រឡប់ចេញទៅ ។ អាបត្តិទាំងពួងរបស់ភិក្ខុទាំងពួងនោះ វៀរទោសដែលគ្រោតគ្រាត និងដែលបដិសំយុត្តជាមួយគ្រហស្ថ រមែងរួចផុតទៅបាន ។ អាបត្តាធិករណ៍ រមែងរម្ងាប់ដោយសមថៈ ៣ យ៉ាង ដោយប្រការដូច្នេះ ។ កិច្ចាធិករណ៍ រមែងរម្ងាប់ដោយសមថៈ ១ គឺសម្មុខាវិន័យប៉ុណ្ណោះ ។ អធិករណ៍ទាំង ៤ នេះ រមែងរម្ងាប់ដោយសមថៈ ៧ ប្រការនេះ តាមសមគួរ ។ ព្រោះហេតុនោះ ទើបលោកពោលថា ដើម្បីសេចក្តីស្ងប់រម្ងាប់អធិករណ៍ ដែលកើតឡើងហើយៗ គប្បីឲ្យសម្មុខាវិន័យ គប្បីឲ្យសតិវិន័យ គប្បីឲ្យអមូឡ្ហវិន័យ គប្បីពិន័យតាមបដិញ្ញា គប្បីកាន់យកសំឡេងភាគច្រើនជាប្រមាណ គប្បីពិន័យតាមសេចក្តីខុសរបស់ចុងចោទ ( ពិរុទ្ធជន ) គប្បីប្រើតិណវត្ថារកវិធី ដូច្នេះឯង ។ នេះជាន័យនៃការវិនិច្ឆ័យក្នុងអធិករណ៍ទាំងនេះ ។ ចំណែកសេចក្តីពិស្តារ មកហើយក្នុងសមថក្ខន្ធកៈនុ៎ះឯង ។ សូម្បីការវិនិច្ឆ័យនៃសេចក្តីពិស្តារនោះ ខ្ញុំពោលបានហើយក្នុងសមន្តប្បាសាទិកា ។ ពាក្យជាដើមថា **ឥមេ ខោ អាវុសោ** បណ្ឌិតគប្បី

ប្រកបដោយន័យដែលខ្ញុំពោលហើយនោះឯង ។ ព្រះថេរៈពោល ៩៨ បញ្ហា ដោយអំណាចនៃពួកប្រាំពីរ ១៤ ពួកសម្តែងសាមគ្គីរស ដោយប្រការដូច្នេះឯង ។

**ពួក ៧ ចប់**

## ពោលអំពីធម៌ពួក ៨

[ ២១១ ] ព្រះថេរៈលុះសម្តែងសាមគ្គីរស ដោយអំណាចនៃពួក ៧ ដោយប្រការដូច្នេះហើយ ឥឡូវនេះ ដើម្បីនឹងសម្តែងសាមគ្គីរសដោយអំណាចនៃពួក ៨ ទើបផ្តើមប្រារព្ធព្រះធម៌ទេសនាតទៅទៀត ។ បណ្តាបទទាំងនោះ បទថា **មិច្ឆត្តា** គឺមិនពិតប្រាកដ បានដល់ មានសភាពដែលខុស ។

[ ២១២-២១៣ ] បទថា **សម្មត្តា** គឺពិតប្រាកដ បានដល់ មានសភាពដែលត្រូវដោយប្រពៃ ។

[ ២១៤ ] បទថា **កុសីតវត្ថូនិ** បានដល់ រឿង គឺទីអាស្រ័យរបស់មនុស្សខ្ជិលច្រអូស គឺរបស់មនុស្សខ្ជិល អធិប្បាយថា ហេតុនៃសេចក្តីខ្ជិលច្រអូស ។ ក្រើនបទថា **កម្មំ កត្តព្វំ ហោតិ** សេចក្តីថា គប្បីធ្វើកម្ម មានការធ្វើចីវរជាដើម ។ ក្រើនបទថា **ន វីរិយំ អារភតិ** សេចក្តីថា មិនប្រារព្ធសេចក្តីព្យាយាមទាំង ២ យ៉ាង ។

បទថា **អប្បត្តស្ស** សេចក្តីថា ដើម្បីសម្រេចធម៌ គឺឈាន វិបស្សនា មគ្គ និងផល ដែលខ្លួនមិនទាន់សម្រេច ។ បទថា **អនធិគតស្ស** សេចក្តីថា ដើម្បីប្រយោជន៍ គឺការសម្រេចធម៌ គឺឈាន វិបស្សនា មគ្គ និងផលនោះឯង

ដែលខ្លួនមិនទាន់បានសម្រេច ។ បទថា **អសច្ឆិកតស្ស** សេចក្ដីថា ដើម្បីប្រយោជន៍ គឺការធ្វើឲ្យច្បាស់ធម៌ គឺឈាន វិបស្សនា មគ្គ និងផលនោះ ដែលខ្លួនមិនទាន់ធ្វើឲ្យច្បាស់ ។ ពីរពាក្យនេះថា **ឥធំ បឋមំ** បានដល់ ការអន្ទ្រយចុះ (ដោយការគិត) យ៉ាងនេះថា ណ្ហើយចុះ យើងនឹងដេក ដូច្នេះ ចាត់ជារឿងនៃសេចក្ដីខ្ជិលច្រអូសជាមុន ។ បណ្ឌិតគប្បីជ្រាបសេចក្ដីក្នុងបទទាំងពួង ដោយន័យនេះ ។ សណ្ដែករាជមាសដែលទទឹក ឈ្មោះថា **មាសាចិត្ត** ក្នុងពាក្យនេះថា **មាសាចិតំ មញ្ញេ** ដូច្នេះ អធិប្បាយថា ជាអ្នកធ្ងន់ដូចសណ្ដែករាជមាសដែលសើម ជារបស់ធ្ងន់ ដូច្នោះ ។ ពីរបទថា **គិលានា វុដ្ឋិតោ ហោតិ** សេចក្ដីថា ជំងឺសះស្បើយទៅក្នុងកាលខាងក្រោយ ។

[ ២១៥ ] បទថា **អារព្ភវត្ថូនិ** បានដល់ ហេតុនៃសេចក្ដីព្យាយាម បណ្ឌិតគប្បីជ្រាបនូវអត្ថ ដោយន័យនេះឯង នៃបទទាំងឡាយនោះ ។

[ ២១៦ ] បទថា **ទានវត្ថូនិ** គឺហេតុនៃទាន ។ ច្រើនបទថា **អាសជ្ជ ទានំ ទេតិ** សេចក្ដីថា ដល់ហើយទើបឲ្យទាន ។ បុគ្គលឃើញភិក្ខុដែលមកហើយ និមន្តលោកឲ្យគង់មួយភ្លែតប៉ុណ្ណោះ ទើបធ្វើសក្ការៈថ្វាយទាន រមែងមិនលំបាក ដោយការគិតថា យើងនឹងឲ្យ ។ សេចក្ដីប្រាថ្នាក្នុងការឲ្យនេះ ឈ្មោះថា ហេតុនៃការឲ្យដោយប្រការដូច្នេះ ។ ហេតុទាំងឡាយ មានសេចក្ដីខ្លាចជាដើម សូម្បីក្នុងពាក្យជាដើមថា ឲ្យទាន ព្រោះសេចក្ដីខ្លាច បណ្ឌិតគប្បីជ្រាបថា ជាហេតុនៃការឲ្យ ។

បណ្ដាហេតុទាំងនោះ សេចក្ដីខ្លាចចំពោះពាក្យតិះដៀល ឬសេចក្ដីខ្លាច

ចំពោះអបាយថា បុគ្គលពួកនេះ ជាអ្នកមិនឲ្យ (ទាន) ជាអ្នកមិនធ្វើ (សក្ការៈ) ឈ្មោះថា សេចក្តីខ្លាច ។ ពីរបទថា **អទាសិ មេ** សេចក្តីថា បុគ្គលរមែងឲ្យតប ដោយគិតថា បុគ្គលនោះ បានឲ្យវត្ថុឈ្មោះនេះដល់យើង ក្នុងកាលមុន ។ ពីរបទថា **ទស្សតិ មេ** សេចក្តីថា បុគ្គលរមែងឲ្យដោយគិតថា គេនឹងឲ្យវត្ថុឈ្មោះនេះក្នុងអនាគត ។ ពីរបទថា **សាហុទានំ** សេចក្តីថា បុគ្គលរមែងឲ្យ (ទាន) ដោយគិតថា ធម្មតាថា ការឲ្យ ជាការញ៉ាំងប្រយោជន៍ឲ្យសម្រេច គឺជាកម្មល្អ ដែលបណ្ឌិតទាំងឡាយ មានព្រះពុទ្ធជាដើម ទ្រង់សរសើរហើយ ។ ច្រើនបទថា **ចិត្តាលង្ការចិត្តបរិក្ខារត្ថំ ទានំ ទេតិ** សេចក្តីថា បុគ្គលរមែងឲ្យទាន ដើម្បីជាគ្រឿងប្រដាប់ និងដើម្បីជាបរិវាររបស់ចិត្តក្នុងសមថៈ និងវិបស្សនា ។ ពិតហើយ ទានរមែងធ្វើចិត្តឲ្យទន់បាន ។ ដែលអ្នកណាបានវត្ថុ សូម្បីអ្នកនោះ ក៏រមែងមានចិត្តទន់ថា យើងបានហើយ ។

ដែលអ្នកណាឲ្យហើយ សូម្បីអ្នកនោះ ក៏រមែងមានចិត្តទន់ថា យើងឲ្យហើយ ។ ទាន រមែងធ្វើចិត្តរបស់បុគ្គលទាំងពីរឲ្យទន់ ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ពាក្យជាដើមថា ការទូន្មានចិត្ត ដែលមិនទាន់ធ្លាប់ទូន្មាន (ឈ្មោះថាទាន) ។ ព្រះមានព្រះភាគត្រាស់ថា

ការទូន្មានចិត្ត ដែលមិនធ្លាប់ទូន្មាន ឈ្មោះថា ទាន ការមិនឲ្យ
ជាហេតុប្រទូសរ៉ាយនៃចិត្តដែលទូន្មានហើយ សត្វទាំងឡាយ
រមែងឡើង និងចុះ ដោយទាន និងវាចាដែលផ្អែមល្ហែម ដូច្នេះ ។

បណ្តាទានទាំង ៨ ប្រការនេះ ទាន ជាគ្រឿងប្រដាប់ចិត្តប៉ុណ្ណោះ ដែល

ខ្ពស់បំផុត ។

[ ២១៧ ] បទថា **ធានូបបត្តិយោ** សេចក្តីថា ចូលដល់ព្រោះទានជាបច្ច័យ ។ បទថា **ទហាតិ** ប្រែថា តាំងទុក ។ ពាក្យថា **អធិដ្ឋាតិ** ជាវេវចនៈរបស់ពាក្យថា **ទហាតិ** នោះឯង ។ បទថា **ភាវេតិ** ប្រែថា ឲ្យចម្រើន ។ ពីរបទថា **ហីនេ វិមុត្តំ** សេចក្តីថា រួចផុតកាមគុណ ៥ ដ៏ថោកទាប ។ បទថា **ឧត្តរិអភាវិតំ** សេចក្តីថា អំពីនោះ មិនអប់រំដើម្បីមគ្គផលដែលជាកំពូលដ៏ថ្មើម ។ ពីរបទថា **តត្រុបបត្តិយា សំវត្តតិ** សេចក្តីថា បុគ្គលប្រាថ្នា ( កើត ) ក្នុងទីណា ធ្វើនូវកុសល ក៏រមែងប្រព្រឹត្តទៅព្រមដើម្បីប្រយោជន៍ដល់ការកើតក្នុងទីនោះ ។ បទថា **វីតរាគស្ស** សេចក្តីថា អ្នកមានរាគៈដែលកាត់ផ្តាច់ដោយមគ្គ ឬអ្នកមានរាគៈដែលគ្របសង្កត់បានដោយសមាបត្តិ ។ ពិតហើយ សត្វមិនអាចកើតក្នុងព្រហ្មលោកបានដោយកុសលត្រឹមតែទានប៉ុណ្ណោះទេ ។ ទានរមែងជាគ្រឿងប្រដាប់ ជាបរិវាររបស់ចិត្តក្នុងសមាធិ និងវិបស្សនា ។ បុគ្គលដែលមានចិត្តទន់ព្រោះទាននោះ ចម្រើនព្រហ្មវិហារហើយ រមែងកើតក្នុងព្រហ្មលោកបាន ។ ព្រោះហេតុនោះ ទើបព្រះសារីបុត្រពោលថា នៃអ្នកមានរាគៈទៅប្រាសហើយ មិនមែនរបស់អ្នកមានរាគៈ ។ បរិស័ទរបស់ក្សត្រ ឈ្មោះថា **ខត្តិយបរិសា** ( បរិស័ទរបស់ក្សត្រ ) អធិប្បាយថា ពួក ។ ក្នុងបទទាំងពួង ក៏ន័យនេះឯង ។

[ ២១៨ ] ធម៌របស់លោក ឈ្មោះថា **លោកធម៌** ។ ធម្មតាបុគ្គលដែលផុតពីលោកធម៌ទាំងនោះមិនមាន ។ សូម្បីព្រះពុទ្ធទាំងឡាយ ក៏ត្រូវមាននោះ

ឯង ៗ សមពិតដូចព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ លោកធម៌ ៨ ទាំង ប្រការនេះ រមែងវិលទៅតាមលោក និងលោកក៏រមែងវិលទៅតាមលោកធម៌ ៨ ប្រការដូច្នេះ ។ ពីរបទថា **លាភោ អលាភោ** បណ្ឌិតគប្បីជ្រាបថា លុះលាភមក ការមិនមានលាភក៏មកផង ។ ក្នុងយសជាដើម ក៏ន័យនេះដូចគ្នា ។

[ ២២០-២២១ ] កថាថា អកិកាយតនៈ និងវិមោក្ខ លោកពោលហើយទុំះឯង ។ ពាក្យថា **នវ ខោ អាវុសោ** ជាដើម បណ្ឌិតគប្បីប្រកបដោយន័យដែលពោលហើយដូចគ្នា ។ ព្រះថេរៈពោលបញ្ហា ៨៨ បញ្ហា ដោយអំណាចនៃពួកប្រាំបី ១១ ពួក សម្តែងសាមគ្គីរសហើយ ដោយប្រការដូច្នេះឯង ។

**ពួក ៨ ចប់**

## ពោលអំពីធម៌ពួក ៩

[ ២២២ ] ព្រះថេរៈលុះសម្តែងសាមគ្គីរស ដោយអំណាចនៃពួក ៨ ដោយប្រការដូច្នេះហើយ ឥឡូវនេះ ដើម្បីសម្តែងសាមគ្គីរសដោយអំណាចនៃពួក ៩ ទើបប្រារព្ធព្រះធម៌ទេសនាជាបន្តទៀត ។

បណ្តាបទទាំងនោះ បទថា **អាឃាតវត្ថូនិ** ប្រែថា ហេតុនៃគំនុំ ។ ពីរបទថា **អាឃាតំ ពន្ធតិ** សេចក្តីថា ចង គឺធ្វើ បានដល់ ញុំាំងសេចក្តីក្រោធឲ្យកើតឡើង ។

[ ២២៣ ] ច្រើនបទថា **តំ កុតេត្ថ លព្ភា** សេចក្តីថា ការប្រព្រឹត្តវត្ថុដែលមិនជាប្រយោជន៍នោះ កុំបានមានឡើយ ព្រោះហេតុនោះ ដែលបុគ្គលគប្បីបាន

ពីទីណា គឺអាចដើម្បីបានដោយហេតុអ្វី ក្នុងបុគ្គលនេះ ។ បុគ្គលគិតយ៉ាងនេះថា ធម្មតា បុគ្គលដទៃ រមែងធ្វើសេចក្ដីវិនាសតាមសេចក្ដីពេញចិត្តនៃចិត្តរបស់ខ្លួនដល់បុគ្គលដទៃ ដូច្នេះ រមែងបន្ទោបង់សេចក្ដីអាឃាតបាន ។ម្យ៉ាងទៀត អធិប្បាយថា ប្រសិនបើយើងគប្បីធ្វើសេចក្ដីក្រោធតបសោត ការធ្វើសេចក្ដីក្រោធនោះ យើងនឹងគប្បីបានអំពីទីណាក្នុងបុគ្គលនេះ ឬគប្បីបានដោយហេតុអ្វី ។ បាលីថា **កុតោ លាភា** ដូច្នេះក៏មាន ។ បើយើងគប្បីធ្វើសេចក្ដីក្រោធក្នុងបុគ្គលនេះសោត ធម្មតាលាភដែលយើងបានអំពីទីណា ក្នុងការធ្វើសេចក្ដីក្រោធរបស់យើងនោះ អធិប្បាយថា លាភពួកណាគប្បីមាន ។ ក្នុងអត្ថនេះសព្ទថា **តំ** ត្រឹមតែជានិបាតប៉ុណ្ណោះ ។

[ ២២៤ ] បទថា **សត្តាវាសា** បានដល់ កន្លែងជាទីនៅរបស់សត្វទាំងឡាយ អធិប្បាយថា ដែលជាទីនៅ ។ បណ្ដាសត្តាវាសទាំងនោះ សូម្បីសុទ្ធាវាសទាំងឡាយ ក៏ចាត់ជាសត្តាវាសដូចគ្នា ប៉ុន្តែ លោកមិនបានចាត់ព្រោះមិនប្រព្រឹត្តទៅក្នុងកាលទាំងពួង ។ ពិតហើយ សុទ្ធាវាសទាំងឡាយដូចគ្នានឹងបន្ទាយ ( កន្លែងប្រថាប់ ) របស់ព្រះពុទ្ធទាំងឡាយ ។ព្រោះថា ក្នុងអសង្ខេយ្យកប្ប កាលព្រះពុទ្ធមិនទាន់កើតទីនោះ រមែងទទេ ព្រោះហេតុនោះទើបលោកមិនចាត់ថា ជាសត្តាវាស ព្រោះមិនប្រព្រឹត្តទៅក្នុងកាលទាំងពួង ។ពាក្យដ៏សេសក្នុងអត្ថនេះ បណ្ឌិតគប្បីជ្រាបដូចតទៅនេះ ពាក្យដែលគប្បីពោល លោកបានពោលហើយក្នុងទុំះឯង ។

[ ២២៥ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអក្ខណៈទាំងឡាយ ។ ត្រើនបទថា

**ធម្មោ ច ទេសិយតិ** សេចក្តីថា សច្ចធម៌ ៤ ដែលព្រះមានព្រះភាគទ្រង់សម្តែង ។ បទថា **ឱបសមិកោ** សេចក្តីថា ធ្វើការចូលទៅរម្ងាប់កិលេស ។ បទថា **បរិ-និព្វានិកោ** សេចក្តីថា នាំមកនូវការរលត់កិលេសដោយជុំវិញ ។បទថា **សម្ពោធ-គាមី** សេចក្តីថា អ្នកចាក់ធ្លុះដោយមគ្គញាណ ៤ ។ បទថា **អញ្ញតរំ** សេចក្តីថា អសញ្ញភព ឬថា អរូបភព ។

[ ២២៦ ] បទថា **អនុបុព្វវិហារា** សេចក្តីថា វិហារធម៌ដែលគប្បីចូលទៅតាមលំដាប់ ។

[ ២២៧ ] បទថា **អនុបុព្វនិរោធា** សេចក្តីថា រលត់ទៅតាមលំដាប់ ។ ពាក្យ ថា **ឥមេ ខោ អាវុសោ** ជាដើម បណ្ឌិតគប្បីប្រកបដោយន័យដូចដែលពោល ហើយនុ៎ះឯង ។ ព្រះថេរៈកាលពោល ៥៤ បញ្ហា ដោយអំណាចនៃពួកប្រាំបួន ៦ ពួក សម្តែងសាមគ្គីរសហើយ ដោយប្រការដូច្នេះឯង ។

**ពួក ៩ ចប់**

# ពោលអំពីធម៌ពួក ១០

[២២៨] ព្រះថេរៈ គ្រាសម្តែងសាមគ្គីរសដោយអំណាចនៃពួក ៩ ដោយប្រការដូច្នេះហើយ ឥឡូវនេះ ដើម្បីនឹងសម្តែងសាមគ្គីរសដោយអំណាចនៃពួក ១០ ទើបប្រារព្ធព្រះធម៌ទេសនាទៀត ។

បណ្តាបទទាំងនោះ បទថា **នាថករណា** សេចក្តីថា ធម៌ដែលធ្វើទីពឹងនៃខ្លួន ដែលព្រះមានព្រះភាគត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-

ទ្បាយ ចូរជាបុគ្គលមានទីពឹង កុំជាបុគ្គលមិនមានទីពឹងឡើយ ។ ម្នាលភិក្ខុទាំងឡាយ ធម៌សម្រាប់ធ្វើឲ្យមានទីពឹងនេះ មាន ១០ យ៉ាង ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **កល្យាណមិត្តោ** ជាដើម ។ មិត្រទាំងឡាយរបស់បុគ្គលនោះ ដល់ព្រមដោយគុណ មានសីលជាដើម គឺជាបុគ្គលល្អ ព្រោះហេតុនោះបុគ្គលនោះ ឈ្មោះថា **កល្យាណមិត្ត** ( អ្នកមានមិត្រល្អ ) ។

ម្យ៉ាងទៀត មិត្រទាំងនោះរបស់បុគ្គលនោះ ឈ្មោះថា **សហាយ** ព្រោះទៅរួមគ្នាក្នុងឥរិយាបថទាំងឡាយ មានការឈរ និងការអង្គុយជាដើម ព្រោះហេតុនោះ បុគ្គលនោះ ទើបឈ្មោះថា **កល្យាណសហាយ** ( អ្នកមានសម្លាញ់ល្អ ) ។ ការចូលជាពួកក្នុងកល្យាណមិត្រទាំងឯង បង្អោនទៅទាំងចិត្តទាំងកាយព្រោះ ហេតុនោះ ទើបឈ្មោះថា **កល្យាណសម្បវង្ក** ( អ្នកមានពួកល្អ ) ។ ពីរបទថា **សុវចោ ហោតិ** សេចក្តីថា ជាអ្នកដែលគេគប្បីប្រដៅបានដោយងាយ គឺដែលគេគប្បីតាមទូន្មានបានដោយងាយ ។ បទថា **ខមោ** សេចក្តីថា អ្នកត្រូវគេពោលដោយពាក្យដែលធ្ងន់ គឺគ្រោតគ្រាត បានដល់ ពាក្យខ្លាំងៗរមែងអត់ធន់បាន គឺមិនក្រោធ ។ ពីរបទថា **បទក្ខិណគ្គាហី អនុសាសនី** សេចក្តីថា អ្នកមិនធ្វើ ដូចបុគ្គលពួកខ្លះ ពេលត្រូវគេឲ្យឱវាទ ក៏ទទួលដោយចំណែកខាងឆ្វេង បែកចេញអំពីគ្នាទៅ ឬមិនស្តាប់ហើយចេញទៅ រមែងទទួលចំណែកខាងស្តាំ ដោយពោលថា លោកដ៏ចម្រើន សូមលោកឲ្យឱវាទ សូមតាមទូន្មានចុះ កាលលោកមិនឲ្យឱវាទអ្នកដទៃ អ្នកណាហ្ន៎ នឹងឲ្យឱវាទដូច្នេះ ។ បទថា **ឧច្ចាវចានិ** សេចក្តីថា ខ្ពស់ និងទាប ។ បទថា **កឹករណីយានិ** សេចក្តី

ថា ការងារដែលនឹងគប្បីពោលធ្វើយ៉ាងនេះថា ខ្ញុំនឹងធ្វើអ្វី ។ បណ្ដាការងារទាំងនោះ ការងារមានជាអាទិយ៉ាងនេះថា ការធ្វើចីវរ ការជ្រលក់ចីវរ ការសម្អាតត្រង់ទីលានព្រះចេតិយ ការងារដែលគប្បីធ្វើត្រង់រោងឧបោសថ រោងព្រះចេតិយ និងត្រង់រោងព្រះពោធិ៍ទាំងឡាយ ឈ្មោះថា ការងារខ្ពស់ ។ ការងារបន្តិចបន្តួចមានការលាងជើង និងលាបជើងជាដើម ឈ្មោះថា ការងារទាប ។ បទថា **តត្រុបាយាយ** សេចក្ដីថា គួរចូលទៅក្នុងទីនោះ ។ ពីរបទថា **អលំ កាតុំ** សេចក្ដីថា ជាអ្នកអាចដើម្បីនឹងធ្វើ ។ ពីរបទថា **អលំ សំវិធាតុំ** សេចក្ដីថា អ្នកអាចដើម្បីនឹងពិចារណា អធិប្បាយថា ជាអ្នកប្រាថ្នានឹងសម្ដែងដល់ពួកអ្នកដទៃ ។ សេចក្ដីប្រាថ្នា គឺសេចក្ដីស្រឡាញ់ក្នុងធម៌របស់បុគ្គលនោះមានហើយ ហេតុនោះ បុគ្គលនោះ ឈ្មោះថា **ធម្មកាមោ** ( អ្នកប្រាថ្នាក្នុងធម៌ ) អធិប្បាយថា រមែងស្រឡាញ់នូវព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដក ។

បទថា **បិយសមុទាហារោ** សេចក្ដីថា កាលបុគ្គលដទៃពោល រមែងស្ដាប់ដោយគោរព និងជាអ្នកប្រាថ្នា ដើម្បីនឹងសម្ដែងដល់ជនពួកដទៃនោះឯង ។ ក្នុងពួកពីរនៃបទនេះថា **អភិធម្មេ អភិវិនយេ** បណ្ឌិតគប្បីជ្រាបពួក ៤ នៃពាក្យថា **ធម្មោ អភិធម្មោ វិនយោ អភិវិនយោ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ធម្មោ** បានដល់ ព្រះសុត្តន្តបិដក ។ បទថា **អភិធម្មោ** បានដល់ សត្តប្បករណ៍ ( បករណ៍ទាំង ៧ ) ។

បទថា **វិនយោ** បានដល់ ឧភតោវិភង្គ ។ បទថា **អភិវិនយោ** បានដល់ ខន្ធកបរិវារ ។ម្យ៉ាងទៀត សូម្បីព្រះសុត្តន្តបិដក គឺព្រះធម៌ទុំះឯង មគ្គ និង

ផលទាំងឡាយ គឺព្រះអភិធម្ម ព្រះវិនយបិដកទាំងអស់ គឺព្រះវិន័យ ការធ្វើការចូលទៅរម្ងាប់កិលេស គឺអភិវិន័យ ។ បណ្ឌិតគប្បីជ្រាបអធិប្បាយ ក្នុងធម្ម អភិធម្ម វិន័យ និងអភិវិន័យ នេះទាំងអស់ ដោយប្រការដូច្នេះ ។ បទថា **ឧឡារបាមោជ្ជោ** សេចក្តីថា ជាអ្នកមានបាមោជ្ជច្រើន ។ **កុសលេសុ ធម្មេសុ** សេចក្តីថា ជាសត្តមីវិភត្តិ ចុះក្នុងអត្ថនៃតតិយាវិភត្តិ ។ ព្រោះហេតុនៃកុសល-ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ អធិប្បាយថា ជាអ្នកមិនដាក់ធុរៈ ចោលដើម្បីប្រយោជន៍ដល់ការសម្រេចកុសលធម៌ដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៤ នោះ ។

[ ២២៩ ] បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងពួក ១០ នៃកសិណដូច្នេះ

ដោយអត្ថទាំងអស់ កសិណទាំងឡាយ ឈ្មោះថា ជាដែន ដោយអត្ថថា ជាខេត្ត ឬដោយអត្ថថា ការតាំងចិត្តមាំនៃធម៌ទាំងឡាយដែលជាតទារម្មណ៍ ។ បទថា **ឧទ្ធំ** សេចក្តីថា អ្នកមានមុខឆ្ពោះទៅកាន់អាកាស ។បទថា **អធោ** សេចក្តីថា អ្នកមានមុខឆ្ពោះកាន់ផែនដី ។ បទថា **តិរិយំ** សេចក្តីថា កំណាត់ទទឹងដោយជុំវិញ ដូចមណ្ឌលនៃស្រែ ។ ពិតហើយ បុគ្គលពួកខ្លះ រមែងពង្រីកកសិណទៅខាងលើតែម្យ៉ាង បុគ្គលខ្លះពង្រីកទៅខាងក្រោម បុគ្គលខ្លះពង្រីកទៅដោយជុំវិញ ។ បុគ្គលដែលប្រាថ្នាក្នុងការឃើញរូប ប្រៀបដូចពន្លឺ រមែងផ្សាយចេញទៅយ៉ាងនោះ ឬដោយហេតុនោះៗ ព្រោះហេតុនោះ ទើបលោកពោលថា បុគ្គលម្នាក់ រមែងចាំបរិកសិណបានទាំងខាងលើ ខាងក្រោម ខាងទទឹង ។ ចំណែកពាក្យថា **អទ្វយំ** នេះ លោកពោលដើម្បីការចូលដល់ភាពជាយ៉ាងដទៃនៃបុគ្គលម្នាក់ ។ ដូចសេចក្តីថា កាលបុគ្គលមុជចុះទឹក ទឹកប៉ុណ្ណោះ រមែងប្រាកដមាន

ក្នុងទិសទាំងពួង វត្ថុដទៃមិនប្រាកដ យ៉ាងណា បឋវីកសិណ ក៏ដូច្នោះដែរ រមែងជាបឋវីកសិណនុ៎ះឯង ការលាយដោយកសិណយ៉ាងដទៃរបស់បុគ្គល នោះ រមែងមិនមាន ។ ក្នុងកសិណទាំងពួងក៏ន័យនេះ ។ ពាក្យថា **អប្បមាណំ** នេះ លោកពោលដោយអំណាចនៃការផ្សាយទៅមិនមានប្រមាណនៃបុគ្គល នោះៗ ។ ពិតហើយ បុគ្គលកាលផ្សាយកសិណនោះទៅដោយចិត្ត ឈ្មោះថា ផ្សាយទៅទាំងអស់តែម្តង គឺមិនកាន់យកប្រមាណថា នេះជាខាងដើម នេះជា កណ្តាលនៃកសិណនោះ ដូច្នេះឯង ។ ក្នុងពាក្យថា **វិញ្ញាណកសិណំ** នេះ បានដល់ វិញ្ញាណដែលប្រព្រឹត្តទៅក្នុងកសិណុគ្ឃាដិមាកាស ( អាកាសដែល បើកកសិណ ) ។ បណ្ឌិតគប្បីជ្រាបសេចក្តីជាខាងលើ ខាងក្រោម និងខាង ទទឹង ក្នុងវិញ្ញាណដែលប្រព្រឹត្តទៅក្នុងកសិណនោះ ដោយអំណាចនៃកសិ-ណុគ្ឃាដិមាកាស ដោយអំណាចនៃកសិណក្នុងវិញ្ញាណនោះ ។ នេះជាសេចក្តី សង្ខេបក្នុងកសិណនេះ ។ ឯកសិណទាំងឡាយ មានបឋវីកសិណ ជាដើមទាំង នោះ ខ្ញុំបានពោលហើយដោយពិស្តារក្នុងវិសុទ្ធិមគ្គនុ៎ះឯង ដោយការនាមយៈ នៃកម្មដ្ឋាន ។

[ ២៣០ ] គប្បីជ្រាបវិនិច្ឆ័យ ក្នុងកម្មបថទាំងឡាយដូចតទៅនេះ

កម្មទាំងឡាយនោះឯង ឈ្មោះថា ជាកម្មបថ ព្រោះជាផ្លូវនៃទុគ្គតិ និង សុគតិទាំងឡាយ ។

បណ្តាកម្មបថទាំងនោះ កម្មបថទាំង ៤ មានបាណាតិបាត អទិន្នាទាន និងមុសាវាទជាដើម លោកពោលពិស្តារហើយក្នុងព្រហ្មជាលសូត្រនុ៎ះឯង ។

ចំណែកក្នុងកម្មបថទី ៣ ថា **កាមេសុ មិច្ឆាចារោ** នេះ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ

បទថា **កាមេសុ** សេចក្តីថា ក្នុងការប្រព្រឹត្តមេថុន ឬក្នុងវត្ថុនៃមេថុន ។ បទថា **មិច្ឆាចារោ** សេចក្តីថា ការប្រព្រឹត្តដ៏លាមក ដែលបណ្ឌិតតិះដៀលដោយចំណែកមួយ ។ ចំណែកដោយលក្ខណៈ ចេតនាដែលឈានកន្លងឋានៈដែលមិនគប្បីដល់ ដែលប្រព្រឹត្តទៅផ្លូវកាយទ្វារ ដោយសេចក្តីប្រាថ្នានឹងសេពអសទ្ធម្ម ក៏ចាត់ជាកាមេសុមិច្ឆាចារ ។

ក្នុងកាមេសុមិច្ឆាចារនោះ ចំពោះបុរសទាំងឡាយជាមុន ស្ត្រី ១០ ពួក មានស្ត្រីដែលមាតារក្សាជាដើម គឺស្ត្រីដែលមាតារក្សា ១ ស្ត្រីដែលបិតារក្សា ១ ស្ត្រីដែលមាតា និងបិតារក្សា ១ ស្ត្រីដែលបងប្អូន ប្រុសរក្សា ១ ស្ត្រីដែលបងប្អូនស្រីរក្សា ១ ស្ត្រីដែលញាតិរក្សា ១ ស្ត្រីដែលត្រកូលរក្សា ១ ស្ត្រីដែលធម៌រក្សា ១ ស្ត្រីដែលមានគូដណ្តឹងរក្សា ១ ស្ត្រីដែលច្បាប់ហាម ១ និងស្ត្រី ១០ ពួកទៀត មានស្ត្រីដែលទិញមកដោយទ្រព្យទាំងនោះជាដើម គឺស្ត្រីដែលគេទិញមកដោយទ្រព្យ ១ ស្ត្រីដែលស្ម័គ្រចិត្តនៅរួមជាមួយប្រុសដទៃ ១ ស្ត្រីដែលនៅរួមជាមួយបុរសព្រោះសម្បត្តិ ១ ស្ត្រីដែលនៅរួមជាមួយបុរស ព្រោះគ្រឿងស្លៀកដណ្តប់ ១ ស្ត្រីដែលតែងការស្ត្រីអ្នកមានទឹក ( ដងទឹក ) ១ ស្ត្រីដែលជាភរិយា ដោយដាក់ទំនូលពីក្បាល ១ ស្ត្រីដែលទាំងជាទាសី និងភរិយាអ្នកដទៃ ភរិយាអ្នកជាទាសី ១ ស្ត្រីដែលជាកូនឈ្នួល និងភរិយាអ្នកដទៃ ភរិយាអ្នកធ្វើការងារ ១ ស្ត្រីដែលជាឈ្លើយសឹក ១ ស្ត្រីនៅជាមួយបុរសតែមួយគ្រា

( សោភិនី ) ១ រួមជាស្រី ២០ ពួក ឈ្មោះថា ឋានៈដែលមិនគប្បីដល់ ។

ចំណែកបណ្តាស្ត្រីទាំងឡាយ បុរសពួកដទៃ ឈ្មោះថា ជាឋានៈដែលមិនគប្បីដល់នៃស្រី ១២ ពួក គឺស្ត្រីដែលមានការរក្សា និងមានអាជ្ញា ២ និងស្ត្រីដែលទិញមកដោយទ្រព្យជាដើមទៀត ១០ ។ មិច្ឆាចារនេះ ចាត់ថា មានទោសតិចក្នុងឋានៈដែលមិនគប្បីដល់ ដែលវៀរចាកគុណ មានសីលជាដើម ចាត់ថា មានទោសច្រើន ក្នុងឋានៈដែលមិនគប្បីដល់ ដែលប្រកបដោយគុណមានសីលជាដើម ។ កាមេសុមិច្ឆាចារនោះ មានសម្ភារៈ ( អង្គ ) ៤ គឺវត្ថុដែលមិនគប្បីដល់ ១ ចិត្តគិតនឹងសេពក្នុងវត្ថុដែលមិនគប្បីដល់នោះ ១ សេចក្តីព្យាយាមក្នុងការសេព ១ ការឈប់នៃការបដិបត្តិចំពោះអង្គមគ្គដោយមគ្គ ១ ។ ការធ្វើដោយដៃរបស់ខ្លួន ក៏ជាសេចក្តីព្យាយាមតែម្យ៉ាងនុ៎ះឯង ។

បទថា **អភិជ្ឈាយតិ** ប្រែថា ការសម្លឹងរំពៃ អធិប្បាយថា ជាអ្នកមានមុខឆ្ពោះភណ្ឌៈរបស់អ្នកដទៃ ប្រព្រឹត្តទៅ ព្រោះការបង្អោនទៅក្នុងភណ្ឌៈរបស់អ្នកដទៃនោះ ។ អភិជ្ឈានោះ មានការសម្លឹងចំពោះភណ្ឌៈរបស់អ្នកដទៃជាលក្ខណៈយ៉ាងនេះថា ឱហ្ន៎ វត្ថុនេះគប្បីជារបស់យើង មានទោសតិច និងមានទោសច្រើន ដូចអទិន្នាទាន ។ អភិជ្ឈានោះ មានសម្ភារៈ ( អង្គ ) ២ គឺភណ្ឌៈរបស់អ្នកដទៃ ១ បង្អោនភណ្ឌៈនោះដើម្បីខ្លួន ១ ។ កាលសេចក្តីលោភ ដែលមានភណ្ឌៈរបស់អ្នកដទៃជាទីតាំង សូម្បីកើតឡើងហើយ បុគ្គលមិនបង្អោនភណ្ឌៈនោះដើម្បីខ្លួនថា ឱហ្ន៎ វត្ថុនេះគប្បីជារបស់យើង ដូច្នេះ ត្រឹមណា ការដាច់នៃកម្មបថ ក៏មិនមានត្រឹមនោះ ។ កិលេសណា ញុំាំងហិតសុខឲ្យវិនាសទៅ

ហេតុនោះ កិលេសនោះ ឈ្មោះថា **ព្យាបាទ** ។ ព្យាបាទនោះ មានលក្ខណៈប្រទូស្តតាមផ្លូវចិត្ត ដើម្បីសេចក្តីវិនាសរបស់អ្នកដទៃ មានទោសតិច និងមានទោសច្រើន ដូចផរុសវាចា ។ ព្យាបាទនោះ មានសម្ភារៈ ( អង្គ ) ២ គឺសត្វដទៃ ១ ការគិតដើម្បីឲ្យសេចក្តីវិនាស នៃសត្វដទៃនោះ ១ ។ កាលសេចក្តីក្រោធដែលមានសត្វដទៃជាទីតាំង សូម្បីកើតឡើងហើយ បុគ្គលមិនគិតដល់សេចក្តីវិនាសនៃសត្វដទៃនោះថា ឱហ្ន៎ បុគ្គលនេះ គប្បីដាច់សូន្យ គប្បីវិនាស ដូច្នេះត្រឹមណា ការដាច់នៃកម្មបថក៏មិនមានត្រឹមនោះ ។ ដែលឈ្មោះថា មិច្ឆាទិដ្ឋិ ព្រោះអត្ថថា ឃើញខុសដោយមិនមានការកាន់យកតាមសភាពដែលមានពិត ។ មិច្ឆាទិដ្ឋិនោះ មានលក្ខណៈ ឃើញខុសដោយន័យជាដើមថា ទានដែលឲ្យហើយមិនមានផល ដូច្នេះ មានទោសតិច និងមានទោសច្រើន ដូចសម្ផប្បលាបៈ ។ម្យ៉ាងទៀត មិច្ឆាទិដ្ឋិ ដែលមិនពិតប្រាកដ ( មិនរឹងមាំ ) មានទោសតិច ដែលពិតប្រាកដ (រឹងមាំ) មានទោសច្រើន ។ មិច្ឆាទិដ្ឋិនោះ មានសម្ភារៈ ( អង្គ ) ២ គឺវត្ថុខុសអំពីអាការដែលខ្លួនកាន់យក ១ ការបម្រើវត្ថុនោះ តាមអាការដែលខ្លួនកាន់យក ១ ។ចំណែកអកុសលកម្មបថទាំង ១០ ប្រការនេះ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យដោយអាការ ៥ គឺដោយធម៌ ១ ដោយចំណែក ១ ដោយអារម្មណ៍ ១ ដោយវេទនា ១ ដោយមូល ១ ។

បណ្តាបទទាំងនោះ បទថា **ធម្មតោ** សេចក្តីថា ចេតនាធម៌ ៧ ដោយលំដាប់នោះឯង រមែងមានក្នុងអកុសលកម្មបថទាំងនោះ ។ ចេតនាធម៌ ៣ មានអភិជ្ឈាជាដើម ឈ្មោះថា សម្បយុត្តដោយចេតនា ។ បទថា **កោដ្ឋាសតោ**

សេចក្តីថា ចេតនាធម៌ទាំង ៨ នេះ គឺដោយលំដាប់ ៧ និងមិច្ឆាទិដ្ឋិ ១ ទៀត ជាកម្មបថតែម្យ៉ាង តែមិនមែនជាមូល ។ អភិជ្ឈា និងព្យាបាទ ទាំងជាកម្មបថ និងទាំងជាមូល ។ ពិតហើយ អភិជ្ឈាដល់ភាពជាមូលហើយ រមែងជាលោភ-អកុសលមូល ។ ព្យាបាទ ជាទោសអកុសលមូល ។ បទថា **អារម្មណតោ** សេចក្តីថា បាណាតិបាត មានសង្ខារជាអារម្មណ៍ ដោយមានជីវិតិន្ទ្រិយជាអារម្មណ៍ ។ អទិន្នាទាន មានសត្វជាអារម្មណ៍ខ្លះ មានសង្ខារជាអារម្មណ៍ខ្លះ ។ មិច្ឆាចារ មានសង្ខារជាអារម្មណ៍ ដោយអំណាចនៃផោដ្ឋព្វៈ អាចារ្យមួយពួកពោលថា មានសត្វជាអារម្មណ៍ខ្លះ ។ មុសាវាទ មានសត្វជាអារម្មណ៍ខ្លះ មានសង្ខារជាអារម្មណ៍ខ្លះ បិសុណាវាចាក៏យ៉ាងនោះ ។ ផរុសវាចា មានសត្វជាអារម្មណ៍ ។ សម្ផប្បលាបៈ មានសត្វជាអារម្មណ៍ខ្លះ មានសង្ខារជាអារម្មណ៍ខ្លះ ដោយអំណាចនៃរូបដែលបានឃើញ សំឡេងដែលបានស្តាប់ និងអារម្មណ៍ដែលបានជ្រាប ហើយដឹងច្បាស់ ។ អភិជ្ឈាក៏យ៉ាងនោះ ។ ព្យាបាទ មានសត្វជាអារម្មណ៍ ។ មិច្ឆាទិដ្ឋិ មានសង្ខារជាអារម្មណ៍ ដោយអំណាចនៃធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ខ្លះ មានសត្វជាអារម្មណ៍ ដោយអំណាចនៃបញ្ញត្តិខ្លះ ។ បទថា **វេទនាតោ** សេចក្តីថា បាណាតិបាត ជាទុក្ខវេទនា ។

ដូចសេចក្តីថា ព្រះរាជាទាំងឡាយ ទ្រង់ឃើញចោរហើយ សូម្បីនឹងទ្រង់រីករាយ ហើយត្រាស់ថា ពួកអ្នកចូរសម្លាប់ចោរនោះទៅ ដូច្នេះក៏ពិត ដល់យ៉ាងនោះ សន្និដ្ឋាបកចេតនា ( ចេតនាដែលឲ្យសម្រេច ) ក៏ឈ្មោះថា សម្បយុត្តដោយទុក្ខពិត ។ អទិន្នាទាន មានវេទនា ៣ ។ មិច្ឆាចារ មានវេទនា ២ គឺសុខ

និងមជ្ឈត្តវេទនា ( ឧបេក្ខា ) ។

ចំណែកថា ក្នុងសន្និដ្ឋាបកចិត្ត ( ចិត្តដែលឲ្យសម្រេច ) មិច្ឆាចារ មិនជាមជ្ឈត្តវេទនា ។ មុសាវាទ មានវេទនា ៣ ។ បិសុណាវាចាក៏យ៉ាងនោះ ។ ផរុសវាចា ជាទុក្ខវេទនា ។ សម្ផប្បលាបៈ មានវេទនា ៣ ។ អភិជ្ឈា មានវេទនា ២ គឺសុខ និងមជ្ឈត្តវេទនា ( ឧបេក្ខា ) ។ មិច្ឆាទិដ្ឋិក៏យ៉ាងនោះ ។ ព្យាបាទ ជាទុក្ខវេទនា ។

បទថា **មូលតោ** សេចក្តីថា បាណាតិបាត មានមូល ២ គឺទោសៈ និងមោហៈ ។ អទិន្នាទាន ក៏មានមូល ២ ដូចគ្នា គឺទោសៈ និងមោហៈខ្លះ លោភៈ និងមោហៈខ្លះ ។ មិច្ឆាចារ មានមូល ២ គឺលោភៈ និងមោហៈ ។ មុសាវាទ ក៏មានមូល ២ គឺទោសៈ និងមោហៈខ្លះ លោភៈ និងមោហៈខ្លះ ។បិសុណាវាចា និងសម្ផប្បលាបៈក៏យ៉ាងនោះ ។ ផរុសវាចា មានមូល ២ គឺទោសៈ និងមោហៈ ។ អភិជ្ឈា មានមូលតែមួយ គឺមោហៈ ។ ព្យាបាទក៏យ៉ាងនោះ ។ មិច្ឆាទិដ្ឋិ មានមូល ២ គឺលោភៈ និងមោហៈ ដូច្នេះឯង ។

[ ២៣១ ] កុសលកម្មបថទាំងឡាយ មានចេតនាវៀរចាកបាណាតិបាតជាដើម បណ្ឌិតគប្បីជ្រាបដោយអំណាចនៃសមាទានវិរតិ សម្បត្តវិរតិ និងសមុច្ឆេទវិរតិ ។

ចំណែកដោយធម៌ ចេតនាទាំង ៧ ក្តី វិរតិទាំងឡាយក្តី រមែងប្រព្រឹត្តទៅដោយលំដាប់ក្នុងកុសលកម្មបថទាំងនោះ ។ ចេតនាធម៌ ៣ ក្នុងទីបំផុត ឈ្មោះថា សម្បយុត្តដោយចេតនាពិត ។ បទថា **កោដ្ឋាសតោ** សេចក្តីថា ចេតនាធម៌

៧ ដោយលំដាប់ ឈ្មោះថា ជាកម្មបថតែម្យ៉ាង តែមិនមែនមូល ។ ចេតនាធម៌ ៣ ខាងចុង ទាំងជាកម្មបថ និងជាមូល ។ ពិតហើយ អនភិជ្ឈា ដល់ភាពជាមូលហើយ រមែងជាអលោភកុសលមូល ។ អព្យាបាទ ជាអទោសកុសលមូល ។ សម្មាទិដ្ឋិ ជាអមោហកុសលមូល ។

បទថា **អារម្មណតោ** សេចក្ដីថា អារម្មណ៍នៃបាណាតិបាតជាដើមនោះឯង ជាអារម្មណ៍នៃកុសលកម្មបថទាំងនោះដោយលំដាប់ ។ ពិតហើយ ចេតនានោះ ឈ្មោះថា ជាចេតនាវៀរចាក ព្រោះមានសភាពដែលទីងគប្បីឈានកន្លង ។ អរិយមគ្គ ដែលមានព្រះនិព្វានជាអារម្មណ៍ រមែងលះកិលេសទាំងឡាយបាន យ៉ាងណា កម្មបថទាំងឡាយនោះ មានជីវិតិន្ទ្រិយជាដើម ជាអារម្មណ៍ បណ្ឌិតគប្បីជ្រាបថា រមែងលះភាពជាអ្នកទ្រុស្តសីលទាំងឡាយមានបាណាតិបាតជាដើម ដូច្នោះ ។ បទថា **វេទនាតោ** សេចក្ដីថា កុសលកម្មបថទាំងពួង ជាសុខវេទនាខ្លះ ជាមជ្ឈត្តវេទនា ( ឧបេក្ខាវេទនា ) ខ្លះ ។ ពិតហើយ ធម្មតា ទុក្ខវេទនា ដល់ភាពជាកុសលមិនមាន ។ ពោលដោយ **មូលតោ** កុសលកម្មបថ ៧ ដោយលំដាប់ រមែងមានមូល ៣ គឺអលោភៈ អទោសៈ និងអមោហៈ ដល់បុគ្គលដែលវៀរដោយញាណសម្បយុត្តចិត្ត ។ រមែងមានមូល ២ ដល់បុគ្គលដែលវៀរដោយញាណវិប្បយុត្តចិត្ត ។ **អនភិជ្ឈា** មានមូល ២ សម្រាប់អ្នកវៀរដោយញាណសម្បយុត្តចិត្ត មានមូល ១ ដល់បុគ្គលដែលវៀរដោយញាណវិប្បយុត្តចិត្ត ។ អលោភៈ មិនជាមូលដល់ខ្លួនដោយខ្លួនឯងឡើយ ។ ក្នុងអព្យាបាទ ក៏ន័យនេះដូចគ្នា ។ សម្មាទិដ្ឋិ មានមូល

២ គឺអលោភៈ និងអទោសៈប៉ុណ្ណោះ ដូច្នេះឯង ។

[ ២៣២ ] បទថា **អរិយវាសា** សេចក្តីថា ព្រះអរិយៈទាំងឡាយនោះឯង នៅហើយ គឺរមែងនៅ បានដល់ នឹងនៅក្នុងធម៌ទាំងនោះ ហេតុនោះធម៌ទាំងនោះ ឈ្មោះថា **អរិយវាស** ។ បទថា **បញ្ចង្គវិប្បហីនោ** សេចក្តីថា ជាអ្នកមិនប្រកបដោយអង្គ ៥ ព្រះខីណាស្រព បាននៅហើយ គឺរមែងនៅ បានដល់ នឹងនៅ ព្រោះហេតុដូចនោះ ភាពជាអ្នកលះអង្គ ៥ចេញបាននេះ លោកហៅថា **អរិយវាស** ព្រោះភាពនៃធម៌ជាគ្រឿងនៅរបស់ព្រះអរិយៈ ។ ក្នុងធម៌ទាំងពួងក៏ន័យនេះដូចគ្នា ។ ម្នាលលោកដ៏មានអាយុ ភិក្ខុជាអ្នកប្រកបដោយអង្គ ៦ យ៉ាងនេះឯង ព្រោះហេតុនោះ ទើបឈ្មោះថា ជាអ្នកប្រកបដោយឆឡង្គុបេក្ខា ។ សួរថា ធម៌ពួកណា ឈ្មោះថា **ឆឡង្គុបេក្ខា** ។

សូម្បីធម៌មានញាណជាដើម ឈ្មោះថា ឆឡង្គុបេក្ខា ។ កាលលោកពោលថា **ញាណ** បណ្ឌិតរមែងបានដល់ញាណសម្បយុត្តចិត្ត ៤ ដួង ដោយកិរិយា ។ កាលលោកពោលថា **សត្តវិហារ** រមែងបានមហាចិត្ត ៨ ដួង ។ កាលលោកពោលថា **រជ្ជនទុស្សនំ នត្ថិ** រមែងបានចិត្ត ១០ ដួង ។ សោមនស្ស បណ្ឌិតរមែងបានដោយអំណាចនៃអាសេវនៈ ។ ពីរបទថា **សតារក្ខេន ចេតសា** សេចក្តីថា ក៏សតិរមែងញុំាងកិច្ចនៃការរក្សាឲ្យសម្រេចអស់កាលទាំងពួង ក្នុងទ្វារទាំង ៣ របស់ព្រះខីណាស្រព ។ ព្រោះហេតុនោះឯង ញាណទស្សនៈដែលស្ងប់រម្ងាប់ហើយជាប់តគ្នា ទើបលោកហៅថា ជាញាណដែលប្រាកដចំពោះហើយ ដល់ព្រះខីណាស្រពនោះ អ្នកកំពុងត្រាច់ទៅហើយ អ្នកឈរ

ហើយ អ្នកលក់ហើយ និងអ្នកក្លាក់ ។

បទថា **បុថុសមណព្រាហ្មណានំ** សេចក្តីថា របស់សមណព្រាហ្មណ៍ជាច្រើន ។

បណ្តាពាក្យទាំងនោះ ដែលឈ្មោះថា សមណៈ បានដល់ អ្នកចូលដល់បព្វជ្ជា ។ ដែលឈ្មោះថា ព្រាហ្មណ៍ បានដល់ អ្នកមានប្រក្រតីពោលថាចម្រើន ។ បទថា **បុថុបច្ចេកសច្ចានិ** សេចក្តីថា សច្ចៈចំពោះខ្លួនច្រើន ។ អធិប្បាយថា សច្ចៈជាច្រើនដែលលោកកាន់យកចំពោះយ៉ាងនេះថា នេះប៉ុណ្ណោះពិត ។ បទថា **នុណ្ណានិ** សេចក្តីថា ត្រូវនាំចេញ ។ បទថា **បនុណ្ណានិ** សេចក្តីថា ត្រូវនាំចេញដោយល្អ ។ បទថា **ចត្តានិ** សេចក្តីថា លែងហើយ ។ បទថា **វន្តានិ** សេចក្តីថា ខ្ជាក់ចេញហើយ ។ បទថា **មុត្តានិ** សេចក្តីថា ធ្វើការកាត់គ្រឿងចង ។ បទថា **បហីនានិ** សេចក្តីថា លះបង់ហើយ ។ បទថា **បដិនិស្សដ្ឋានិ** សេចក្តីថា លះបង់ចំពោះ ដោយប្រការដែលកិលេសនឹងមិនឡើងកាន់ចិត្តទៀត ។ ពាក្យទាំងពួងនោះឯង ជាវេវចនៈនៃការលះបង់ការប្រកាន់ ដែលខ្លួនប្រកាន់នោះឯង ។ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **សមវយសដ្ឋេសនោ** នេះ ដូចតទៅនេះ បទថា **អវយា** បានដល់ មិនខ្វះខាត បទថា **សដ្ឋា** បានដល់ លះបង់ហើយ បុគ្គលនេះមានការស្វែងរក ដែលមិនខ្វះខាត គឺលះបង់ហើយដោយល្អ ព្រោះហេតុនេះ ទើបឈ្មោះថា អ្នកមានការស្វែងរក ដែលមិនខ្វះខាត និងលះបង់ហើយ ។ អធិប្បាយថា អ្នកមានការស្វែងរកទាំងពួង ដែលលះបង់ហើយដោយល្អ ។ ដោយពាក្យជាដើមថា ចិត្តរួចផុត

ហើយចាកភគៈ ជាការពោលដល់សេចក្ដីសម្រេចកិច្ចរបស់មគ្គ ។ ដោយពាក្យជាដើមថា យើងលះភគៈបានហើយ ជាការពោលដល់ផលនៃការពិចារណា ។

[ ២៣៣ ] ព្រះអសេក្ខៈ ឈ្មោះថា មានធម៌ដែលសម្បយុត្តដោយផលសូម្បីទាំងពួង មានសម្មាទិដ្ឋិជាដើម ។ ក្នុងបណ្ដាធម៌ទាំងនោះ បញ្ញាជាការលោកពោលទុកក្នុងឋានៈទាំង ២ គឺសម្មាទិដ្ឋិ ១ សម្មាញាណ ១ ។ ធម៌ គឺផលសមាបត្តិដ៏សេស លោកពោលដោយបទនេះថា សម្មាវិមុត្តិ បណ្ឌិតគប្បីជ្រាបថា លោកសង្គ្រោះចូលហើយ ។ ពាក្យថា **ឥមេ ខោ អាវុសោ** ជាដើម បណ្ឌិតគប្បីប្រកបដោយន័យដូចដែលពោលហើយនុ៎ះឯង ។ ព្រះថេរៈកាលពោលបញ្ហា ៦០ គត់ ដោយអំណាចនៃពួកដប់ ៦ ពួក ដោយប្រការដូច្នេះ សម្ដែងសាមគ្គីរសហើយ ដូច្នេះឯង ។

**ពួក ១០ ចប់**

ភិក្ខុតាំងនៅក្នុងសាសនានេះហើយ គប្បីប្រជុំបញ្ហាដូចតទៅនេះ

[ ២៣៤ ] ពិតហើយ ក្នុងព្រះសូត្រនេះ ជាការដែលលោកពោល ២ បញ្ហា ដោយអំណាចនៃពួក ១ ពោល ៧០ បញ្ហា ដោយអំណាចនៃពួក ២ ពោល ១៨០ បញ្ហា ដោយអំណាចនៃពួក ៣ ពោល ២០០ បញ្ហា ដោយអំណាចនៃពួក ៤ ពោល ១៣០ បញ្ហា ដោយអំណាចនៃពួក ៥ ពោល ១៣២ បញ្ហា ដោយអំណាចនៃពួក ៦ ពោល ៩៨ បញ្ហា ដោយអំណាចនៃពួក ៧ ពោល ៨៨ បញ្ហា ដោយអំណាចនៃពួក ៨ ពោល ៥៤ បញ្ហា ដោយអំណាច

នៃពួក ៩ ពោល ៦០ បញ្ហាគត់ ដោយអំណាចនៃពួក ១០ រួមជាការដែលលោកពោលបញ្ហា ១០១៤ បញ្ហា ដោយប្រការដូច្នេះ ។

ពិតហើយ វៀរព្រះសូត្រនេះចេញ ព្រះសូត្រដទៃក្នុងព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដក ដែលប្រដាប់ដោយបញ្ហាច្រើនយ៉ាងនេះមិនមាន ។ ព្រះសាស្តាទ្រង់ស្តាប់ព្រះសូត្រនេះទាំងអស់ តាំងពីដើមហើយ ទ្រង់ត្រិះរិះថា សារីបុត្រជាធម្មសេនាបតី សម្តែងកម្លាំងនៃព្រះពុទ្ធ បន្លឺសីហនាទ ក្នុងអប្បដិវត្តកាល កាលតថាគតពោលថា ជាសាវកភាសិត ការដាក់ចិត្តជឿក៏នឹងមិនមាន កាលតថាគតពោលថា ជាជិនភាសិតដូច្នេះ ការដាក់ចិត្តជឿ ទើបនឹងមាន ព្រោះហេតុនោះ តថាគតធ្វើឲ្យជាជិនភាសិត ហើយញ៉ាំងការដាក់ចិត្តជឿឲ្យកើតដល់ទេវតា និងមនុស្សទាំងឡាយ ក្នុងព្រះសូត្រនេះ ដូច្នេះហើយ ទើបស្តេចក្រោកចាកទីនោះ បានប្រទានសាធុការហើយ ។ ព្រោះហេតុនោះ ទើបលោកពោលថា គ្រានោះឯង ព្រះមានព្រះភាគស្តេចក្រោកឡើង ត្រាស់ហៅព្រះសារីបុត្រមកថា សារីបុត្រ ប្រពៃណាស់ ប្រពៃណាស់ សារីបុត្រ អ្នកបានពោលសង្គីតិ-បរិយាយសូត្រ ដល់ភិក្ខុទាំងឡាយហើយ ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **សង្គីតិបរិយាយំ** បានដល់ ហេតុនៃសេចក្តីសាមគ្គី ។ មានពាក្យដែលព្រះមានព្រះភាគត្រាស់ដូច្នេះថា សារីបុត្រ ប្រពៃហើយ អ្នកប្រៀបដូចនឹងសព្វញ្ញុ-តញ្ញាណរបស់តថាគត បានពោលសាមគ្គីរសដល់ភិក្ខុទាំងឡាយហើយ ។

ប្រើនបទថា **សមនុញ្ញោ សត្ថា អហោសិ** សេចក្តីថា ជាអ្នកពេញចិត្ត ដោយការអនុមោទនាហើយ ។ ព្រះសូត្រនេះឈ្មោះថា ជិនភាសិត កើតហើយ ដោយហេតុមានប្រមាណប៉ុណ្ណេះ ។ ក្នុងកាលចប់នៃព្រះទេសនា ភិក្ខុទាំងនោះ ធ្វើទុកក្នុងចិត្តនូវព្រះសូត្រនេះ សម្រេចអរហត្តហើយ ដូច្នេះឯង ៕

## សង្គីតិសូត្រទី ១០ ចប់

# សុត្តន្តបិដក

## ទសុត្តរសូត្រទី ១១

[ ២៣៥ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្បែរឆ្នេរស្រះបោក្ខរណី ឈ្មោះគគ្គរា ជិតក្រុងចម្បា ជាមួយនឹងភិក្ខុសង្ឃច្រើន ចំនួន ៥០០ រូប ។ ព្រះសារីបុត្តដ៏មានអាយុ បានហៅភិក្ខុទាំងឡាយ ( ដែលនៅ ) ក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយដ៏មានអាយុ ។ ភិក្ខុទាំងនោះ ឆ្លើយតបពាក្យព្រះសារីបុត្តដ៏មានអាយុថា ម្នាលអាវុសោ ។ ព្រះសារីបុត្តដ៏មានអាយុបានពោលយ៉ាងនេះថា

[ ២៣៦ ] ខ្ញុំនឹងសម្តែងទសុត្តរធម៌ ជាធម៌សម្រាប់ដោះស្រាយ
នូវគ្រឿងចាក់ស្រែះ គឺកិលេសទាំងអស់ ( មានអភិជ្ឈាជាដើម )
ដើម្បីបានដល់ព្រះនិព្វាន ដើម្បីធ្វើនូវទីបំផុតនៃវដ្តទុក្ខ ។

[ ២៣៧ ] ម្នាលអាវុសោទាំងឡាយ ធម៌មួយមានឧបការៈច្រើន ធម៌មួយគួរចម្រើន ធម៌មួយគួរកំណត់ដឹង ធម៌មួយគួរលះបង់ ធម៌មួយជាចំណែកនៃសេចក្តីវិនាស ធម៌មួយជាចំណែកវិសេស ធម៌មួយត្រាស់ដឹងបានដោយក្រ ធម៌មួយគួរឲ្យកើតឡើង ធម៌មួយគួរដឹងច្បាស់ ធម៌មួយគួរធ្វើឲ្យជាក់ច្បាស់ ។

[ ២៣៨ ] ធម៌មួយមានឧបការៈច្រើនតើដូចម្តេច ។ សេចក្តីមិនប្រមាទក្នុងធម៌ទាំងឡាយជាកុសល ។ នេះជាធម៌មួយដែលមានឧបការៈច្រើន ។

[ ២៣៩ ] ធម៌មួយដែលគួរចម្រើន តើដូចម្តេច ។ កាយគតាសតិដែលប្រកបដោយសេចក្តីត្រេកអរ ( សេចក្តីសុខ ) នេះជាធម៌មួយដែលគួរ

ចម្រើន ។

[ ២៨០ ] ធម៌មួយដែលគួរកំណត់ដឹង តើដូចម្តេច ។ ផស្សៈដែលប្រកបដោយអាសវៈ ជាទីតាំងនៃឧបាទាន ។ នេះជាធម៌មួយដែលគួរកំណត់ដឹង ។

[ ២៨១ ] ធម៌មួយដែលគួរលះបង់ តើដូចម្តេច ។ អស្មិមានះ គឺសេចក្តីប្រកាន់ខ្លួន ។ នេះជាធម៌មួយដែលគួរលះបង់ ។

[ ២៨២ ] ធម៌មួយដែលជាចំណែកនៃសេចក្តីវិនាស តើដូចម្តេច ។ អយោនិសោមនសិការ គឺការធ្វើទុកក្នុងចិត្តដោយមិនជាឧបាយនៃប្រាជ្ញា ។ នេះជាធម៌មួយដែលជាចំណែកនៃសេចក្តីវិនាស ។

[ ២៨៣ ] ធម៌មួយដែលជាចំណែកវិសេស តើដូចម្តេច ។ យោនិសោមនសិការ គឺការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ។ នេះជាធម៌មួយដែលជាចំណែកវិសេស ។

[ ២៨៤ ] ធម៌មួយដែលត្រាស់ដឹងបានដោយក្រ តើដូចម្តេច ។ អនន្តរិកចេតោសមាធិ ។ នេះជាធម៌មួយដែលត្រាស់ដឹងបានដោយក្រ ។

[ ២៨៥ ] ធម៌មួយដែលគួរឲ្យកើតឡើង តើដូចម្តេច ។ ញាណដែលមិនកម្រើក គឺបច្ចវេក្ខណបញ្ញា ។ នេះជាធម៌មួយដែលគួរឲ្យកើតឡើង ។

[ ២៨៦ ] ធម៌មួយដែលគួរដឹងច្បាស់ តើដូចម្តេច ។ បានដល់ពួកសត្វទាំងពួង តាំងនៅបានព្រោះអាហារ ។ នេះជាធម៌មួយដែលគួរដឹងច្បាស់ ។

[ ២៨៧ ] ធម៌មួយដែលគួរធ្វើឲ្យជាក់ច្បាស់ តើដូចម្តេច ។ អកុប្បា-

ចេតោសមាធិ ការរួចផុតនៃចិត្តមិនកម្រើក គឺអរហត្តផល ។ នេះជាធម៌មួយដែលគួរធ្វើឲ្យជាក់ច្បាស់ ។ ធម៌ទាំងឡាយ ១០ នេះ ជាធម៌ពិត ធម៌មែន ធម៌ទៀងទាត់ មិនប្រែប្រួលជាយ៉ាងដទៃឡើយ គឺព្រះតថាគតត្រាស់ដឹងហើយ ដោយប្រពៃ ដោយប្រការដូច្នេះ ។

[ ២៤៨ ] ធម៌ពីរមានឧបការៈច្រើន ធម៌ពីរគួរចម្រើន ធម៌ពីរគួរកំណត់ដឹង ធម៌ពីរគួរលះបង់ ធម៌ពីរជាចំណែកនៃសេចក្តីវិនាស ធម៌ពីរជាចំណែកវិសេស ធម៌ពីរត្រាស់ដឹងបានដោយក្រ ធម៌ពីរគួរឲ្យកើតឡើង ធម៌ពីរគួរដឹងច្បាស់ ធម៌ពីរគួរធ្វើឲ្យជាក់ច្បាស់ ។

[ ២៤៩ ] ធម៌ពីរដែលមានឧបការៈច្រើន តើដូចម្តេចខ្លះ ។ សតិ ( សេចក្តីរឭក ) ១ សម្បជញ្ញៈ ( សេចក្តីដឹងខ្លួន ) ១ ។ ធម៌ទាំងពីរនេះមានឧបការៈច្រើន ។

[ ២៥០ ] ធម៌ពីរដែលគួរចម្រើន តើដូចម្តេចខ្លះ ។ សមថៈ ១ វិបស្សនា ១ ។ ធម៌ទាំងពីរនេះគួរចម្រើន ។

[ ២៥១ ] ធម៌ពីរដែលគួរកំណត់ដឹង តើដូចម្តេចខ្លះ ។ នាម ១ រូប ១ ។ ធម៌ទាំងពីរនេះគួរកំណត់ដឹង ។

[ ២៥២ ] ធម៌ពីរដែលគួរលះបង់ តើដូចម្តេចខ្លះ ។ អវិជ្ជា ( សេចក្តីល្ងង់ ) ១ ភវតណ្ហា ( ចំណង់ក្នុងភព ) ១ ។ ធម៌ទាំងពីរនេះគួរលះបង់ ។

[ ២៥៣ ] ធម៌ពីរដែលជាចំណែកនៃសេចក្តីវិនាស តើដូចម្តេចខ្លះ ។ ភាវៈជាអ្នកដែលគេស្តីប្រដៅបានដោយក្រ ១ ភាវៈជាអ្នកគប់មិត្តអាក្រក់ ១ ។

ធម៌ទាំងពីរនេះជាចំណែកនៃសេចក្តីវិនាស ។

[ ២៥៤ ] ធម៌ពីរដែលជាចំណែកវិសេស តើដូចម្តេចខ្លះ ។ ភាវៈជាអ្នកដែលគេស្តីប្រដៅដោយងាយ ១ ភាវៈជាអ្នកគប់មិត្តល្អ ១ ។ ធម៌ទាំងពីរនេះជាចំណែកវិសេស ។

[ ២៥៥ ] ធម៌ពីរដែលត្រាស់ដឹងបានដោយក្រ តើដូចម្តេចខ្លះ ។ ហេតុនិងបច្ច័យ ដែលប្រព្រឹត្តទៅដើម្បីសេចក្តីសៅហ្មងរបស់សត្វទាំងឡាយ ១ ហេតុនិងបច្ច័យ ដែលប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធ របស់សត្វទាំងឡាយ ១ ។ ធម៌ទាំងពីរនេះត្រាស់ដឹងបានដោយក្រ ។

[ ២៥៦ ] ធម៌ពីរដែលគួរឲ្យកើតឡើង តើដូចម្តេចខ្លះ ។ ញាណ ( ការដឹង ) ពីរយ៉ាង ការដឹងក្នុងរបស់អស់ទៅ ១ ការដឹងក្នុងរបស់មិនទាន់កើតឡើង ១ ។ ធម៌ទាំងពីរនេះគួរឲ្យកើតឡើង ។

[ ២៥៧ ] ធម៌ពីរដែលគួរដឹងច្បាស់ តើដូចម្តេចខ្លះ ។ ធម៌ពីរយ៉ាង ធាតុដែលមានបច្ច័យតាក់តែង ១ ធាតុដែលគ្មានបច្ច័យតាក់តែង ១ ។ ធម៌ទាំងពីរនេះគួរដឹងច្បាស់ ។

[ ២៥៨ ] ធម៌ពីរដែលគួរធ្វើឲ្យជាក់ច្បាស់ តើដូចម្តេចខ្លះ ។ វិជ្ជា សេចក្តីដឹង ១ វិមុត្តិ សេចក្តីរួចផុតស្រឡះចាកកិលេស ១ ។ ធម៌ទាំងពីរនេះគួរធ្វើឲ្យជាក់ច្បាស់ ។ ធម៌ទាំងពីរនេះ ជាធម៌ពិត ធម៌មែន ធម៌ទៀងទាត់ មិនប្រែប្រួលជាយ៉ាងដទៃ ដែលព្រះមានព្រះភាគត្រាស់ដឹងដោយប្រពៃហើយ ដោយប្រការដូច្នេះ ។

[ ២៥៩ ] ធម៌បីមានឧបការៈច្រើន ធម៌បីគួរចម្រើន ធម៌បីគួរកំណត់ដឹង ធម៌បីគួរលះបង់ ធម៌បីជាចំណែកនៃសេចក្តីវិនាស ធម៌បីជាចំណែកវិសេស ធម៌បីត្រាស់ដឹងបានដោយក្រ ធម៌បីគួរឲ្យកើតឡើង ធម៌បីគួរឲ្យដឹងច្បាស់ ធម៌បីគួរធ្វើឲ្យជាក់ច្បាស់ ។

[ ២៦០ ] ធម៌បីមានឧបការៈច្រើន តើដូចម្តេចខ្លះ ។ ការសេពគប់នឹងសប្បុរស ១ ការស្តាប់ធម៌របស់សប្បុរស ១ សេចក្តីប្រតិបត្តិធម៌សមគួរដល់ធម៌ ១ ។ ធម៌ទាំងបីនេះមានឧបការៈច្រើន ។

[ ២៦១ ] ធម៌បីដែលគួរចម្រើន តើដូចម្តេចខ្លះ ។ សមាធិ ៣ យ៉ាង សមាធិដែលមានវិតក្ក ទាំងវិចារៈ ១ សមាធិដែលគ្មានវិតក្ក មានតែវិចារៈ ១ សមាធិដែលគ្មានវិតក្ក គ្មានទាំងវិចារៈ ១ ។ ធម៌ទាំង ៣ នេះគួរចម្រើន ។

[ ២៦២ ] ធម៌បីដែលគួរកំណត់ដឹង តើដូចម្តេចខ្លះ ។ វេទនាបីប្រការ វេទនាដែលជាសុខ ១ វេទនាដែលជាទុក្ខ ១ វេទនាដែលមិនជាទុក្ខ មិនជាសុខ ១ ។ ធម៌ទាំងបីនេះគួរកំណត់ដឹង ។

[ ២៦៣ ] ធម៌បីដែលគួរលះបង់ តើដូចម្តេចខ្លះ ។ តណ្ហាបីប្រការ គឺកាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។ ធម៌ទាំងបីនេះគួរលះបង់ ។

[ ២៦៤ ] ធម៌បីដែលជាចំណែកនៃសេចក្តីវិនាស តើដូចម្តេចខ្លះ ។ អកុសលមូល ( ឫសអកុសល ) បីយ៉ាង គឺលោភៈជាឫសអកុសល ១ ទោសៈជាឫសអកុសល ១ មោហៈជាឫសអកុសល ១ ។ ធម៌ទាំងបីនេះជាចំណែកនៃសេចក្តីវិនាស ។

[ ២៦៥ ] ធម៌បីដែលជាចំណែកវិសេស តើដូចម្តេចខ្លះ ។ កុសលមូល ( ឫសកុសល ) បីប្រការ គឺអលោភៈជាឫសកុសល ១ អទោសៈជាឫសកុសល ១ អមោហៈជាឫសកុសល ១ ។ ធម៌ទាំងបីនេះ ជាចំណែកវិសេស ។

[ ២៦៦ ] ធម៌បីដែលត្រាស់ដឹងបានដោយក្រ តើដូចម្តេចខ្លះ ។ និស្សារណីយធាតុ ( ធាតុដែលត្រូវលាស់ចេញ ) ៣ ប្រការ គឺនេក្ខម្មៈដែលជាធម្មជាតលាស់ចេញនូវកាមទាំងឡាយ ១ អរូបជ្ឈាន ដែលជាធម្ម-ជាតលាស់ចេញនូវរូបទាំងឡាយ ១ និរោធដែលជាធម៌លាស់ចេញនូវអ្វីមួយដែលកើតឡើង ព្រោះអាស្រ័យនឹងបច្ច័យដែលតាក់តែង ១ ។ ធម៌ទាំង ៣ នេះ ត្រាស់ដឹងបានដោយក្រ ។

[ ២៦៧ ] ធម៌បីដែលគួរឲ្យកើតឡើង តើដូចម្តេចខ្លះ ។ ញាណ ៣ យ៉ាង គឺញាណដែលជាចំណែកអតីត ១ ញាណដែលជាចំណែកអនាគត ១ ញាណដែលជាចំណែកបច្ចុប្បន្ន ១ ។ ធម៌ទាំងបីនេះ គួរឲ្យកើតឡើង ។

[ ២៦៨ ] ធម៌បីដែលគួរឲ្យដឹងច្បាស់ តើដូចម្តេចខ្លះ ។ ធាតុបីយ៉ាង គឺកាមធាតុ ១ រូបធាតុ ១ អរូបធាតុ ១ ។ ធម៌ទាំង ៣ នេះគួរដឹងច្បាស់ ។

[ ២៦៩ ] ធម៌បីគួរធ្វើឲ្យជាក់ច្បាស់ តើដូចម្តេចខ្លះ ។ វិជ្ជា ៣ ប្រការ គឺធម្មជាតជាគ្រឿងរឭកបាននូវខន្ធដែលអាស្រ័យនៅក្នុងកាលមុន ជាវិជ្ជា ១ ធម្មជាតជាគ្រឿងដឹងនូវចុតិនិងបដិសន្ធិរបស់សត្វទាំងឡាយ ជាវិជ្ជា ១ ធម្មជាតជាគ្រឿងដឹងក្នុងកិរិយាអស់ទៅនៃអាសវៈទាំងឡាយ ជាវិជ្ជា ១ ។ ធម៌ទាំង

៣ នេះ គួរធ្វើឲ្យជាក់ច្បាស់ ។ ធម៌ទាំង ៣០ នេះជាធម៌ពិត ធម៌មែន ជាធម៌ទៀងទាត់ មិនប្រែប្រួលជាយ៉ាងដទៃឡើយ ដែលព្រះតថាគតត្រាស់ដឹងដោយប្រពៃ ដោយប្រការដូច្នេះ ។

[ ២៧០ ] ធម៌ ៤ មានឧបការៈច្រើន ធម៌ ៤ គួរចម្រើន ធម៌ ៤ គួរកំណត់ដឹង ធម៌ ៤ គួរលះបង់ ធម៌ ៤ ជាចំណែកនៃសេចក្តីវិនាស ធម៌ ៤ ជាចំណែកវិសេស ធម៌ ៤ ត្រាស់ដឹងបានដោយក្រ ធម៌ ៤ គួរឲ្យកើតឡើង ធម៌ ៤ គួរឲ្យដឹងច្បាស់ ធម៌ ៤ គួរធ្វើឲ្យជាក់ច្បាស់ ។

[ ២៧១ ] ធម៌ ៤ មានឧបការៈច្រើន តើដូចម្តេចខ្លះ ។ ចក្កធម៌ ៤ យ៉ាង គឺការនៅក្នុងប្រទេសដ៏សមគួរ ១ ការសេពគប់សប្បុរស ១ ការតាំងខ្លួនទុកប្រពៃ ១ ភាពជាអ្នកបានធ្វើបុណ្យទុកក្នុងកាលមុន ១ ។ ធម៌ទាំង ៤ នេះ មានឧបការៈច្រើន ។

[ ២៧២ ] ធម៌ ៤ ដែលគួរចម្រើន តើដូចម្តេចខ្លះ ។ សតិប្បដ្ឋាន ៤ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកពិចារណាឃើញកាយក្នុងកាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានប្រាជ្ញាស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ១ ។ ក្នុងវេទនាទាំង-ឡាយ ។បេ។ ក្នុងចិត្ត ។បេ។ ជាអ្នកពិចារណាឃើញធម៌ ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានប្រាជ្ញា មានស្មារតី កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ១ ។ ធម៌ទាំង ៤ នេះគួរចម្រើន ។

[ ២៧៣ ] ធម៌ ៤ ដែលគួរកំណត់ដឹង តើដូចម្តេចខ្លះ ។ អាហារ ៤ គឺអាហារដែលពូតជាពំនូត ទោះគ្រោតគ្រាតក្តី ល្អិតក្តី ( ជាទី ១ ) ផស្សាហារជាទី ២ មនោសញ្ចេតនាហារជាទី ៣ វិញ្ញាណាហារជាទី ៤ ។ ធម៌ទាំង ៤ នេះគួរកំណត់ដឹង ។

[ ២៧៤ ] ធម៌ ៤ ដែលគួរលះបង់ តើដូចម្តេចខ្លះ ។ អន្លង់ ៤ គឺ អន្លង់ គឺកាម ១ អន្លង់ គឺភព ១ អន្លង់ គឺទិដ្ឋិ ១ អន្លង់ គឺអវិជ្ជា ១ ។ ធម៌ទាំង ៤ នេះគួរលះបង់ ។

[ ២៧៥ ] ធម៌ ៤ ដែលជាចំណែកនៃសេចក្តីវិនាស តើដូចម្តេចខ្លះ ។ យោគៈ ( គ្រឿងប្រកប ) ៤ គឺកាមយោគៈ ( គ្រឿងប្រកប គឺកាម ) ១ ភវយោគៈ ( គ្រឿងប្រកប គឺភព ) ១ ទិដ្ឋិយោគៈ ( គ្រឿងប្រកប គឺទិដ្ឋិ ) ១ អវិជ្ជាយោគៈ ( គ្រឿងប្រកប គឺអវិជ្ជា ) ១ ។ ធម៌ទាំង ៤ នេះ ជាចំណែកនៃសេចក្តីវិនាស ។

[ ២៧៦ ] ធម៌ ៤ ជាចំណែកវិសេស តើដូចម្តេចខ្លះ ។ ការប្រាសចាកគ្រឿងប្រកប ៤ គឺការប្រាសចាកគ្រឿងប្រកបគឺកាម ១ ការប្រាសចាកគ្រឿងប្រកប គឺភព ១ ការប្រាសចាកគ្រឿងប្រកប គឺទិដ្ឋិ ១ ការប្រាសចាកគ្រឿងប្រកប គឺអវិជ្ជា ១ ។ ធម៌ទាំង ៤ នេះ ជាចំណែកវិសេស ។

[ ២៧៧ ] ធម៌ ៤ ដែលត្រាស់ដឹងបានដោយក្រ តើដូចម្តេចខ្លះ ។ សមាធិ ៤ គឺសមាធិដែលជាចំណែកនៃសេចក្តីវិនាស ១ សមាធិដែលជាចំណែកនៃការឋិតថេរ ១ សមាធិដែលជាចំណែកវិសេស ១ សមាធិដែល

ជាចំណែកនៃកិរិយាទម្លាយនូវកិលេស ១ ។ ធម៌ទាំង ៤ នេះត្រាស់ដឹងបាន ដោយក្រ ។

[ ២៧៨ ] ធម៌ ៤ ដែលគួរឲ្យកើតឡើង តើដូចម្តេចខ្លះ ។ ញាណ ៤ គឺធម្មជាតជាគ្រឿងដឹងក្នុងធម៌ ១ ធម្មជាតជាគ្រឿងដឹងក្នុងការយល់ ១ ធម្មជាតជាគ្រឿងដឹងក្នុងការកំណត់ ១ ធម្មជាតជាគ្រឿងដឹងក្នុងការសម្មតិ ១ ។ ធម៌ទាំង ៤ នេះ គួរឲ្យកើតឡើង ។

[ ២៧៩ ] ធម៌ ៤ ដែលគួរដឹងច្បាស់ តើដូចម្តេចខ្លះ ។ អរិយសច្ច ៤ គឺទុក្ខអរិយសច្ច ១ ទុក្ខសមុទយអរិយសច្ច ១ ទុក្ខនិរោធអរិយសច្ច ១ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១ ។ ធម៌ទាំង ៤ នេះ គួរដឹងច្បាស់ ។

[ ២៨០ ] ធម៌ ៤ ដែលគួរធ្វើឲ្យជាក់ច្បាស់ តើដូចម្តេចខ្លះ ។ សាមញ្ញផល ៤ គឺសោតាបត្តិផល ១ សកទាគាមិផល ១ អនាគាមិផល ១ អរហត្តផល ១ ។ ធម៌ទាំង ៤ នេះ គួរធ្វើឲ្យជាក់ច្បាស់ ។ ធម៌ទាំង ៤០ នេះ ជាធម៌ពិត ធម៌មែន ជាធម៌ទៀងទាត់ មិនប្រែប្រួលជាយ៉ាងដទៃឡើយ ដែលព្រះតថាគតត្រាស់ហើយដោយប្រពៃ ដោយប្រការដូច្នេះ ។

[ ២៨១ ] ធម៌ ៥ មានឧបការៈច្រើន ធម៌ ៥ គួរចម្រើន ធម៌ ៥ គួរកំណត់ដឹង ធម៌ ៥ គួរលះបង់ ធម៌ ៥ ជាចំណែកនៃសេចក្តីវិនាស ធម៌ ៥ ជាចំណែកវិសេស ធម៌ ៥ ត្រាស់ដឹងបានដោយក្រ ធម៌ ៥ គួរឲ្យកើតឡើង ធម៌ ៥ គួរដឹងច្បាស់ ធម៌ ៥ គួរធ្វើឲ្យជាក់ច្បាស់ ។

[ ២៨២ ] ធម៌ ៥ មានឧបការៈច្រើន តើដូចម្តេចខ្លះ ។ អង្គដែលជា

ទីតាំងនៃសេចក្តីព្យាយាម ៥ ប្រការ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុង សាសនានេះ ជាអ្នកមានសទ្ធា រមែងជឿសេចក្តីត្រាស់ដឹងរបស់ព្រះតថាគត ព្រះមានព្រះភាគនោះ ព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ព្រះអង្គ ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ព្រះអង្គបរិបូណ៌ ដោយវិជ្ជា និងចរណៈ គឺសេចក្តីចេះដឹង និងកិរិយាដែលបុគ្គលគប្បីប្រព្រឹត្ត ព្រះអង្គមានដំណើរទៅកាន់ព្រះនិព្វាន ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គ ប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាសារថីអ្នក ទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាគ្រូនៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មី ទៀត ដូច្នេះ ជាអ្នកមិនមានអាពាធ មិនមានទុក្ខ ប្រកបដោយតេជោធាតុ ដែលកើតអំពីកម្មមានផលស្មើគ្នា មិនត្រជាក់ពេក មិនក្តៅពេក ជាយ៉ាង កណ្តាល គួរដល់សេចក្តីព្យាយាម ១ ជាអ្នកមិនអួតអាង មិនមានមាយា សម្តែងខ្លួនតាមពិតចំពោះគ្រូ ឬសព្រហ្មចារីបុគ្គល ដែលជាអ្នកចេះដឹងទាំង-ឡាយ ១ ជាអ្នកមានព្យាយាមប្រារព្ធហើយ ដើម្បីលះបង់ធម៌ទាំងឡាយ ដែល ជាអកុសល ដើម្បីញ៉ាំងធម៌ទាំងឡាយដែលជាកុសលឲ្យកើតឡើង ជាអ្នក មានកម្លាំង មានសេចក្តីប្រឹងប្រែង មិនដាក់ធុរៈចុះក្នុងធម៌ទាំងឡាយដែលជា កុសល ១ ជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញា ដែលជាគ្រឿងធ្វើដំណើរ ទៅកាន់សេចក្តីចម្រើន និងសេចក្តីវិនាស ជាគ្រឿងត្រាស់ដឹងរបស់ព្រះអរិយៈ ជាគ្រឿងធ្វើដំណើរទៅកាន់ការអស់ទៅនៃទុក្ខដោយប្រពៃ ១ ។ ធម៌ទាំង ៥

នេះ មានឧបការៈច្រើន ។

[ ២៨៣ ] ធម៌ ៥ ដែលគួរបម្រើន តើដូចម្តេចខ្លះ ។ ការតាំងចិត្តប្រពៃប្រកបដោយអង្គ ៥ គឺការផ្សាយទៅនៃបីតិ ១ ការផ្សាយទៅនៃសេចក្តីសុខ ១ ការផ្សាយទៅនៃចិត្ត ១ ការផ្សាយទៅនៃពន្លឺ ១ និមិត្តនៃការពិចារណា ១ ។ ធម៌ទាំង ៥ នេះ គួរបម្រើន ។

[ ២៨៤ ] ធម៌ ៥ ដែលគួរកំណត់ដឹង តើដូចម្តេចខ្លះ ។ ឧបាទានក្ខន្ធ ( គំនរនៃសេចក្តីប្រកាន់ ) ៥ គឺរូបជាឧបាទានក្ខន្ធ ១ វេទនាជាឧបាទានក្ខន្ធ ១ សញ្ញាជាឧបាទានក្ខន្ធ ១ សង្ខារជាឧបាទានក្ខន្ធ ១ វិញ្ញាណជាឧបាទានក្ខន្ធ ១ ។ ធម៌ទាំង ៥ នេះ គួរកំណត់ដឹង ។

[ ២៨៥ ] ធម៌ ៥ ដែលគួរលះបង់ តើដូចម្តេចខ្លះ ។ នីវរណៈ ( ធម៌ជាគ្រឿងរាំង ) ៥ គឺកាមច្ឆន្ទនីវរណៈ ១ ព្យាបាទនីវរណៈ ១ ថីនមិទ្ធ-នីវរណៈ ១ ឧទ្ធច្ចកុក្កុច្ចនីវរណៈ ១ វិចិកិច្ឆានីវរណៈ ១ ។ ធម៌ទាំង ៥ នេះ គួរលះបង់ ។

[ ២៨៦ ] ធម៌ ៥ ដែលជាចំណែកនៃសេចក្តីវិនាស តើដូចម្តេចខ្លះ ។ សេចក្តីរឹងត្អឹងនៃចិត្ត ៥ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ សង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះថ្លាក្នុងព្រះសាស្តា ចិត្តរបស់ភិក្ខុនោះមិនបង្អោនទៅ ដើម្បីសេចក្តីព្យាយាមជាគ្រឿងដុតកម្តៅ ដើម្បីសេចក្តីព្យាយាមជាគ្រឿងប្រកប ដើម្បីសេចក្តីព្យាយាមជាគ្រឿងប្រព្រឹត្តមិនដាច់ ដើម្បីសេចក្តីព្យាយាមជាគ្រឿងតាំងទុក ម្នាលអាវុសោទាំងឡាយ ភិក្ខុណាសង្ស័យ

ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះថ្លាក្នុងព្រះសាស្តា ចិត្តរបស់ភិក្ខុនោះមិនបានបង្អោនទៅដើម្បីសេចក្តីព្យាយាម ជាគ្រឿងដុតកម្តៅ ដើម្បីសេចក្តីព្យាយាម ជាគ្រឿងប្រកប ដើម្បីសេចក្តីព្យាយាម ជាគ្រឿងប្រព្រឹត្តមិនដាច់ ដើម្បីសេចក្តីព្យាយាម ជាគ្រឿងតាំងទុក ចិត្តរបស់ភិក្ខុណាមិនបង្អោនទៅ ដើម្បីសេចក្តីព្យាយាម ជាគ្រឿងដុតកម្តៅ ដើម្បីសេចក្តីព្យាយាម ជាគ្រឿងប្រកប ដើម្បីសេចក្តីព្យាយាម ជាគ្រឿងប្រព្រឹត្តមិនដាច់ ដើម្បីសេចក្តីព្យាយាមជាគ្រឿងតាំងទុក នេះជាសេចក្តីរឹងត្អឹងនៃចិត្តទី ១ ។ ម្នាលអាវុសោទាំងឡាយ ប្រការមួយទៀត ភិក្ខុសង្ស័យ ងឿងឆ្ងល់ មិនចុះចិត្តស៊ប់ មិនជ្រះថ្លាក្នុងធម៌ ។បេ។ សង្ស័យក្នុងព្រះសង្ឃ ។បេ។ សង្ស័យក្នុងសិក្ខា ។បេ។ ជាអ្នកខឹងអាក់អន់ចិត្ត មានចិត្តបងគំនុំ មានចិត្តរឹងត្អឹងចំពោះសព្រហ្មចារីបុគ្គលទាំងឡាយ ម្នាលអាវុសោទាំងឡាយ ភិក្ខុណាជាអ្នកខឹងអាក់អន់ចិត្ត មានចិត្តបងគំនុំ មានចិត្តរឹងត្អឹង ចំពោះសព្រហ្មចារីបុគ្គលទាំងឡាយ ចិត្តរបស់ភិក្ខុនោះ មិនបង្អោនទៅដើម្បីសេចក្តីព្យាយាម ជាគ្រឿងដុតកម្តៅ ដើម្បីសេចក្តីព្យាយាមជាគ្រឿងប្រកប ដើម្បីសេចក្តីព្យាយាមជាគ្រឿងប្រព្រឹត្តមិនដាច់ ដើម្បីសេចក្តីព្យាយាម ជាគ្រឿងតាំងទុក ចិត្តរបស់ភិក្ខុណាមិនបង្អោនទៅ ដើម្បីសេចក្តីព្យាយាម ជាគ្រឿងដុតកម្តៅ ដើម្បីសេចក្តីព្យាយាម ជាគ្រឿងប្រកប ដើម្បីសេចក្តីព្យាយាមជាគ្រឿងប្រព្រឹត្តមិនដាច់ ដើម្បីសេចក្តីព្យាយាមជាគ្រឿងតាំងទុក នេះជាសេចក្តីរឹងត្អឹងនៃចិត្តទី ៥ ។ ធម៌ទាំង ៥ នេះ ជាចំណែកនៃសេចក្តីវិនាស ។

[ ២៨៧ ] ធម៌ដែលជាចំណែកវិសេស តើដូចម្តេចខ្លះ ។ ឥន្ទ្រិយ ( ធម្មជាតដែលជាធំ ) ៥ គឺឥន្ទ្រិយ គឺសទ្ធា ១ ឥន្ទ្រិយ គឺវិរិយៈ ១ ឥន្ទ្រិយ គឺសតិ ១ ឥន្ទ្រិយ គឺសមាធិ ១ ឥន្ទ្រិយ គឺបញ្ញា ១ ។ ធម៌ទាំង ៥ នេះ ជាចំណែកវិសេស ។

[ ២៨៨ ] ធម៌ ៥ ដែលត្រាស់ដឹងបានដោយក្រ តើដូចម្តេចខ្លះ ។ និស្សារណីយធាតុ ( ធាតុជាគ្រឿងរលាស់ចេញ ) ៥ ម្នាលអាវុសោទាំង-ឡាយ កាលភិក្ខុក្នុងសាសនានេះ ធ្វើទុកក្នុងចិត្តនូវកាមទាំងឡាយ ចិត្តក៏មិនលឿនទៅ មិនជ្រះថ្លា មិនតាំងនៅ មិនជ្រប់នៅក្នុងកាមទាំងឡាយ តែកាលបើភិក្ខុនោះ ធ្វើទុកក្នុងចិត្ត នូវនេក្ខម្មៈ គឺបឋមជ្ឈាន ចិត្តក៏លឿនទៅ ជ្រះថ្លា តាំងនៅ ជ្រប់នៅក្នុងនេក្ខម្មៈ អសុភជ្ឈានចិត្តរបស់ភិក្ខុនោះ ឈ្មោះថា មានចំណែកល្អ អប់រំល្អ តាំងឡើងល្អ ផុតស្រឡះ ប្រាសចាកកាមទាំងឡាយ ភិក្ខុនោះ ឈ្មោះថាផុតហើយចាកអាសវៈទាំងឡាយ ជាគ្រឿងបៀតបៀន ជាគ្រឿងក្តៅក្រហាយ ដែលកើតឡើងព្រោះកាមជាបច្ច័យ ភិក្ខុនោះមិនបានទទួលនូវវេទនានោះទេ អសុភជ្ឈាននេះ ព្រះមានព្រះភាគត្រាស់ថា ជាគ្រឿងធ្វើសត្វឲ្យចេញចាកកាមទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត កាលភិក្ខុធ្វើទុកក្នុងចិត្តនូវព្យាបាទហើយ ចិត្តក៏មិនលឿនទៅ មិនជ្រះថ្លា មិនតាំងនៅ មិនជ្រប់នៅក្នុងព្យាបាទ តែថាកាលបើភិក្ខុនោះ ធ្វើទុកក្នុងចិត្តនូវការមិនព្យាបាទ ចិត្តក៏លឿនទៅ ជ្រះថ្លា តាំងនៅស៊ប់ ជ្រប់នៅក្នុងការមិនព្យាបាទ មេត្តាឈានចិត្តរបស់ភិក្ខុនោះ ឈ្មោះថាមានដំណើរល្អ អប់រំល្អ តាំងឡើងល្អ ផុតស្រឡះ

ប្រាសចាកការព្យាយាមហើយ ភិក្ខុនោះឈ្មោះថា ផុតចាកអាសវៈទាំងឡាយ ជាគ្រឿងបៀតបៀន ជាគ្រឿងក្តៅក្រហាយ ដែលកើតឡើងព្រោះការព្យាបាទជាបច្ច័យ ភិក្ខុនោះមិនបានទទួលវេទនានោះទេ មេត្តាឈាននេះ ព្រះមានព្រះភាគត្រាស់ថា ជាគ្រឿងធ្វើសត្វឲ្យចេញចាកការព្យាបាទ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត កាលភិក្ខុធ្វើទុកក្នុងចិត្តនូវសេចក្តីបៀតបៀន ចិត្តក៏មិនលឿនទៅ មិនជ្រះថ្លា មិនតាំងនៅស៊ប់ មិនជ្រប់នៅក្នុងសេចក្តីបៀតបៀន តែថាកាលបើភិក្ខុនោះ ធ្វើទុកក្នុងចិត្តនូវសេចក្តីមិនបៀតបៀន ចិត្តក៏លឿនទៅ ជ្រះថ្លា តាំងនៅស៊ប់ ជ្រប់នៅក្នុងសេចក្តីមិនបៀតបៀន ករុណាឈានចិត្តរបស់ភិក្ខុនោះ ឈ្មោះថាមានដំណើរល្អ អប់រំល្អ តាំងឡើងល្អ ផុតស្រឡះ ប្រាសចាកសេចក្តីបៀតបៀនហើយ ភិក្ខុនោះឈ្មោះថាផុតចាកអាសវៈទាំងឡាយ ជាគ្រឿងបៀតបៀន ជាគ្រឿងក្តៅក្រហាយ ដែលកើតឡើងព្រោះសេចក្តីបៀតបៀនជាបច្ច័យ ភិក្ខុនោះ មិនបានទទួលវេទនានោះទេ ករុណាឈាននេះ ព្រះមានព្រះភាគត្រាស់ថា ជាគ្រឿងធ្វើសត្វឲ្យចេញចាកការបៀតបៀន ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត កាលភិក្ខុធ្វើទុកក្នុងចិត្តនូវរូបទាំងឡាយហើយ ចិត្តក៏មិនលឿនទៅ មិនជ្រះថ្លា មិនតាំងនៅស៊ប់ មិនជ្រប់នៅក្នុងរូបទាំងឡាយ តែកាលបើភិក្ខុនោះ ធ្វើទុកក្នុងចិត្តនូវរបស់គ្មានរូប ចិត្តក៏លឿនទៅ ជ្រះថ្លា តាំងនៅស៊ប់ ជ្រប់នៅក្នុងរបស់ដែលគ្មានរូប អរូបជ្ឈានចិត្តរបស់ភិក្ខុនោះ ឈ្មោះថាមានដំណើរល្អ អប់រំល្អ តាំងឡើងល្អ ផុតស្រឡះប្រាសចាករូបទាំងឡាយហើយ ភិក្ខុនោះ ឈ្មោះថាផុតចាកអាសវៈទាំងឡាយ ជាគ្រឿង

បៀតបៀន ជាគ្រឿងក្តៅក្រហាយ ដែលកើតឡើងព្រោះរូបជាបច្ច័យ ភិក្ខុនោះ មិនបានទទួលវេទនានោះទេ អរូបជ្ឈាននេះ ព្រះមានព្រះភាគត្រាស់ថាជាគ្រឿងញ៉ាំងសត្វឲ្យចេញចាករូបទាំងឡាយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត កាលភិក្ខុធ្វើទុកក្នុងចិត្តនូវកាយរបស់ខ្លួន ចិត្តក៏មិនលឿនទៅ មិនជ្រះថ្លា មិនតាំងនៅស៊ប់ មិនជ្រប់នៅក្នុងកាយរបស់ខ្លួន តែកាលបើភិក្ខុនោះធ្វើទុកក្នុងចិត្តនូវការរំលត់នៃកាយរបស់ខ្លួន ចិត្តក៏លឿនទៅ ជ្រះថ្លា តាំងនៅស៊ប់ ជ្រប់នៅក្នុងសេចក្តីរំលត់នៃកាយរបស់ខ្លួន អរហត្តផលសមាបត្តិចិត្តរបស់ភិក្ខុនោះ ឈ្មោះថាមានដំណើរល្អ អប់រំល្អ តាំងឡើងល្អ ផុតស្រឡះ ប្រាសចាកកាយរបស់ខ្លួនហើយ ភិក្ខុនោះឈ្មោះថាផុតចាកអាសវៈទាំងឡាយ ជាគ្រឿងបៀតបៀន ជាគ្រឿងក្តៅក្រហាយ ដែលកើតឡើងព្រោះកាយរបស់ខ្លួនជាបច្ច័យ ភិក្ខុនោះ មិនបានទទួលវេទនានោះទេ អរហត្តផលសមាបត្តិចិត្តនេះ ព្រះមានព្រះភាគត្រាស់ថា ជាគ្រឿងញ៉ាំងសត្វឲ្យចេញចាកកាយជារបស់ខ្លួន ១ ។ ធម៌ទាំង ៥ នេះ ត្រាស់ដឹងបានដោយក្រ ។

[ ២៨៩ ] ធម៌ ៥ ដែលគួរឲ្យកើតឡើង តើដូចម្តេចខ្លះ ។ ការតាំងចិត្តត្រូវប្រកបដោយប្រាជ្ញា ៥ គឺប្រាជ្ញាកើតឡើងចំពោះខ្លួនឯងថា សមាធិនេះជាសុខក្នុងបច្ចុប្បន្ន នឹងឲ្យផលជាសុខតទៅមុខ ១ ។ ប្រាជ្ញាកើតឡើងចំពោះខ្លួនឯងថា សមាធិនេះជាធម៌ប្រសើរ ឥតមានអាមិសៈឡើយ ១ ។ ប្រាជ្ញាកើតឡើងចំពោះខ្លួនឯងថា សមាធិនេះមានតែបុរសល្អ ទើបសេពគប់បាន ១ ។ ប្រាជ្ញាកើតឡើងចំពោះខ្លួនឯងថា សមាធិនេះរម្ងាប់ដ៏ឧត្តម បាននូវ

សេចក្តីស្ងប់ស្ងាត់ ដល់នូវភាពជាធម៌មានអារម្មណ៍តែមួយ ទាំងជាគុណហាមឃាត់ សង្កត់សង្កិនធម៌ដែលប្រកបដោយសង្ខារ ១ ។ ប្រាជ្ញាកើតឡើងចំពោះខ្លួនឯងថា អាត្មាអញនោះឯងជាអ្នកមានស្មារតីចូលកាន់សមាធិនេះ ទាំងជាអ្នកមានស្មារតី ចេញចាកសមាធិនេះ ១ ។ ធម៌ ៥ នេះ គួរឲ្យកើតឡើង ។

[ ២៩០ ] ធម៌ ៥ គួរដឹងច្បាស់ តើដូចម្តេចខ្លះ ។ វិមុត្តាយតនៈ ( ហេតុជាគ្រឿងរួចស្រឡះ ) ៥ ម្នាលអាវុសោទាំងឡាយ គ្រូ ឬសព្រហ្មចារីបុគ្គលណាមួយក្នុងសាសនានេះ គួរជាទីគោរព តែងសម្តែងធម៌ដល់ភិក្ខុ ម្នាលអាវុសោទាំងឡាយ គ្រូឬសព្រហ្មចារីបុគ្គលណាមួយ គួរជាទីគោរព បានសម្តែងធម៌ដល់ភិក្ខុយ៉ាងណាៗ ភិក្ខុ ( នោះ ) ជាអ្នកបានដឹងច្បាស់ នូវអត្ថផង បានដឹងច្បាស់នូវធម៌ផង ក្នុងធម៌នោះ យ៉ាងនោះៗ កាលបើភិក្ខុនោះដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ហើយ បាមោជ្ជ គឺសេចក្តីត្រេកអរទន់ ក៏កើតឡើង កាលលោកមានសេចក្តីត្រេកអរទន់កើតឡើងហើយ បីតិ គឺសេចក្តីឆ្អែតចិត្តក៏កើតឡើង កាលលោកមានសេចក្តីឆ្អែតចិត្តកើតឡើងហើយ នាមកាយក៏ស្ងប់រម្ងាប់ លុះលោកមាននាមកាយស្ងប់រម្ងាប់ហើយ ក៏បានទទួលសេចក្តីសុខ កាលលោកមានសេចក្តីសុខហើយ ចិត្តក៏តម្កល់នៅនឹង នេះជាវិមុត្តាយតនៈទី ១ ។ ម្នាលអាវុសោទាំងឡាយ ប្រការមួយទៀត គ្រូ ឬសព្រហ្មចារីបុគ្គលណាមួយជាទីគោរព មិនបានសម្តែងធម៌ដល់ភិក្ខុសោះទេ តែលោកបានសម្តែងធម៌ដល់ជនទាំងឡាយដទៃដោយពិស្តារ តាមដែលបានស្តាប់មក តាមដែលបានរៀនមក ម្នាលអាវុសោទាំងឡាយ ភិក្ខុសម្តែងធម៌ដល់ជនទាំង-

ឡាយដទៃដោយពិស្តារ តាមដែលបានស្តាប់មក តាមដែលបានរៀនមក យ៉ាង ណាៗ ភិក្ខុនោះ ជាអ្នកបានដឹងច្បាស់នូវអត្ថផង ដឹងច្បាស់នូវធម៌ផង ក្នុង ធម៌នោះ យ៉ាងនោះៗ កាលលោកបានដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ ហើយ សេចក្តីត្រេកអរទន់ក៏កើតឡើង កាលលោកមានសេចក្តីត្រេកអរទន់ កើតហើយ សេចក្តីឆ្អែតចិត្តក៏កើតឡើង កាលលោកមានសេចក្តីឆ្អែតចិត្តកើត ឡើងហើយ នាមកាយក៏ស្ងប់រម្ងាប់ លុះលោកមាននាមកាយស្ងប់រម្ងាប់ហើយ ក៏បានទទួលសេចក្តីសុខ លុះលោកមានសេចក្តីសុខហើយ ចិត្តក៏តម្កល់នៅ នឹង នេះជាវិមុត្តាយតនៈទី ២ ។ ម្នាលអាវុសោទាំងឡាយ ប្រការមួយទៀត គ្រូ ឬសព្រហ្មចារីបុគ្គលណាមួយគួរជាទីគោរព មិនបានសម្តែងធម៌ដល់ភិក្ខុ ទាំងមិនបានសម្តែងធម៌ដល់ជនទាំងឡាយដទៃដោយពិស្តារ តាមដែលបាន ស្តាប់មក តាមដែលបានរៀនមក លោកគ្រាន់តែសូត្រធម៌ដោយពិស្តារ តាម ដែលបានស្តាប់មក តាមដែលបានរៀនមក លោកគ្រាន់តែសូត្រធម៌ដោយ ពិស្តារ តាមដែលបានស្តាប់មក តាមដែលបានរៀនមក ម្នាលអាវុសោទាំង- ឡាយ ភិក្ខុបានសូត្រធម៌ដោយពិស្តារ តាមដែលបានស្តាប់មក ដែលបានរៀន មកយ៉ាងណាៗ ភិក្ខុនោះជាអ្នកបានដឹងច្បាស់នូវអត្ថផង ដឹងច្បាស់នូវធម៌ផង ក្នុងធម៌នោះយ៉ាងនោះៗ កាលលោកបានដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ ហើយ សេចក្តីត្រេកអរទន់កើតឡើង កាលលោកមានសេចក្តីត្រេកអរទន់ កើតឡើងហើយ សេចក្តីឆ្អែតចិត្តក៏កើតឡើង កាលលោកមានសេចក្តីឆ្អែត ចិត្តកើតឡើងហើយ នាមកាយក៏ស្ងប់រម្ងាប់ លុះលោកមាននាមកាយស្ងប់

រម្ងាប់ហើយ ក៏បានទទួលសេចក្ដីសុខ លុះលោកមានសេចក្ដីសុខហើយ ចិត្ត ក៏តម្កល់នៅនឹង នេះជាវិមុត្តាយតនៈទី ៣ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត គ្រូ ឬសព្រហ្មចារីបុគ្គលណាមួយ គួរជាទីគោរព មិនបានសម្ដែងធម៌ដល់ភិក្ខុ មិនបានសម្ដែងធម៌ដល់ជនទាំងឡាយដទៃដោយពិស្ដារ តាមដែលបានស្ដាប់មក តាមដែលបានរៀនមក ទាំងមិនបានសូត្រធម៌ដោយពិស្ដារ តាមដែលបានស្ដាប់មក តាមដែលបានរៀនមកឡើយ លោកគ្រាន់តែត្រិះរិះរឿយៗ ពិចារណារឿយៗ ពិនិត្យរឿយៗ ក្នុងចិត្តនូវធម៌ តាមដែលបានស្ដាប់មក តាមដែលបានរៀនមក ម្នាលអាវុសោទាំងឡាយ ភិក្ខុត្រិះរិះរឿយៗ ពិចារណារឿយៗ ពិនិត្យរឿយៗ ក្នុងចិត្តនូវធម៌ តាមដែលបានស្ដាប់មក តាមដែលបានរៀនមក យ៉ាងណាៗ ភិក្ខុនោះ ជាអ្នកបានដឹងច្បាស់នូវអត្ថផង ដឹងច្បាស់នូវធម៌ផង ក្នុងធម៌នោះ យ៉ាងនោះៗ កាលលោកបានដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ហើយ សេចក្ដីត្រេកអរទន់ក៏កើតឡើង កាលលោកមានសេចក្ដីត្រេកអរទន់កើតឡើងហើយ សេចក្ដីឆ្អែតចិត្តក៏កើតឡើង កាលលោកមានសេចក្ដីឆ្អែតចិត្តកើតឡើងហើយ នាមកាយក៏ស្ងប់រម្ងាប់ លុះលោកមាននាមកាយស្ងប់រម្ងាប់ហើយ ក៏បានទទួលសេចក្ដីសុខ លុះលោកមានសេចក្ដីសុខហើយ ចិត្តក៏តម្កល់នៅនឹង នេះជាវិមុត្តាយតនៈទី ៤ ។ ម្នាលអាវុសោទាំង-ឡាយ មួយទៀត គ្រូ ឬសព្រហ្មចារីបុគ្គលណាមួយគួរជាទីគោរព មិនបានសម្ដែងធម៌ដល់ភិក្ខុផង មិនបានសម្ដែងធម៌ ដល់ជនទាំងឡាយដទៃផងដោយពិស្ដារ តាមដែលបានស្ដាប់មក តាមដែលបានរៀនមក មិនសូត្រធម៌ដោយ

ពិស្តារ តាមដែលបានស្តាប់មក តាមដែលបានរៀនមកផង ទាំងមិនបាន ត្រិះរិះរឿយៗ មិនពិចារណារឿយៗ មិនពិនិត្យរឿយៗ ក្នុងចិត្តនូវធម៌តាមដែលបានស្តាប់មក តាមដែលបានរៀនមកផង តែលោកបានរៀនសមាធិនិមិត្តណាមួយដោយល្អ ធ្វើទុកក្នុងចិត្តដោយល្អ ចេះចាំដោយល្អ ត្រាស់ដឹងដោយល្អ ដោយប្រាជ្ញា ម្នាលអាវុសោទាំងឡាយ សមាធិនិមិត្តណាមួយ ដែលភិក្ខុរៀនដោយល្អ ធ្វើទុកក្នុងចិត្តដោយល្អ ចេះចាំដោយល្អ ត្រាស់ដឹងដោយល្អ ដោយប្រាជ្ញា យ៉ាងណាៗ ភិក្ខុនោះ ជាអ្នកបានដឹងច្បាស់នូវអត្ថផង ដឹងច្បាស់នូវធម៌ផង ក្នុងធម៌នោះ យ៉ាងនោះៗ កាលលោកបានដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ហើយ សេចក្តីត្រេកអរទន់ក៏កើតឡើង កាលលោកមានសេចក្តីត្រេកអរទន់កើតឡើងហើយ សេចក្តីឆ្អែតចិត្តក៏កើតឡើង កាលលោកមានសេចក្តីឆ្អែតចិត្តកើតឡើងហើយ នាមកាយក៏ស្ងប់រម្ងាប់ លុះលោកមាននាមកាយស្ងប់រម្ងាប់ហើយ ក៏បានទទួលសេចក្តីសុខ លុះលោកមានសេចក្តីសុខហើយ ចិត្តក៏តាំងនៅមាំ នេះជាវិមុត្តាយតនៈទី ៥ ។ ធម៌ទាំង ៥ នេះ គួរដឹងច្បាស់ ។

[ ២៩១ ] ធម៌ ៥ ដែលគួរធ្វើឲ្យជាក់ច្បាស់ តើដូចម្តេចខ្លះ ។ ធម្មក្ខន្ធ ៥ គឺសីលក្ខន្ធ ១ សមាធិក្ខន្ធ ១ បញ្ញាខន្ធ ១ វិមុត្តិក្ខន្ធ ១ វិមុត្តិញាណ-ទស្សនក្ខន្ធ ១ ។ ធម៌ទាំង ៥ នេះ គួរធ្វើឲ្យជាក់ច្បាស់ ។ ធម៌ទាំង ៥ នេះ ជាធម៌ពិត ធម៌មែន ធម៌ទៀង មិនប្រែប្រួលជាយ៉ាងដទៃឡើយ ដែលព្រះតថាគតត្រាស់ដឹងដោយប្រពៃហើយ ដោយប្រការដូច្នេះ ។

[ ២៩២ ] ធម៌ ៦ មានឧបការៈច្រើន ធម៌ ៦ គួរចម្រើន ធម៌ ៦ គួរកំណត់ដឹង ធម៌ ៦ គួរលះបង់ ធម៌ ៦ ជាចំណែកនៃសេចក្តីវិនាស ធម៌ ៦ ជាចំណែកវិសេស ធម៌ ៦ ត្រាស់ដឹងបានដោយក្រ ធម៌ ៦ គួរឲ្យកើតឡើង ធម៌ ៦ គួរធ្វើឲ្យជាក់ច្បាស់ ។

[ ២៩៣ ] ធម៌ ៦ មានឧបការៈច្រើន តើដូចម្តេចខ្លះ ។ សារាណីយធម៌ ( ធម៌គួររឭក ) ៦ ប្រការ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ តែងតម្កល់ចំពោះនូវកាយកម្ម ( អំពើដែលធ្វើដោយកាយ ) ប្រកបដោយមេត្តាក្នុងសព្រហ្មចារីបុគ្គលទាំងឡាយ ទាំងចំពោះមុខទាំងកំបាំងមុខ នេះឯងជាធម៌គួររឭកគ្នា ជាធម៌ធ្វើសេចក្តីស្រឡាញ់ ធ្វើសេចក្តីគោរព ប្រព្រឹត្តទៅ ដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀង ដើម្បីឯកីភាព គឺមូលមិត្រគ្នា ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុតែងតម្កល់ចំពោះនូវវចីកម្ម ( អំពើដែលត្រូវធ្វើដោយសម្តី ) ប្រកបដោយមេត្តាក្នុងសព្រហ្មចារីបុគ្គលទាំងឡាយ ទាំងចំពោះមុខទាំងកំបាំងមុខ ធម៌នេះឯងជាធម៌គួររឭករកគ្នា ជាធម៌ធ្វើសេចក្តីស្រឡាញ់ ធ្វើសេចក្តីគោរព ប្រព្រឹត្តទៅដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀង ដើម្បីឯកីភាព ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុតែងតម្កល់ចំពោះនូវមនោកម្ម ( អំពើដែលត្រូវធ្វើដោយចិត្ត ) ប្រកបដោយមេត្តា ។បេ។ ប្រព្រឹត្តទៅដើម្បីឯកីភាព ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត លាភណាមួយកើតឡើងដោយធម៌ បានមកដោយធម៌ ដោយហោចទៅសូម្បីតែអាហារក្នុង

បាត្រ ភិក្ខុបរិភោគដោយមិនបានចែកមុខអាមិសៈ មុខបុគ្គល ដោយលាភមានសភាពដូច្នោះ គឺជាអ្នកបរិភោគជាសាធារណៈ ដោយសព្រហ្មចារីបុគ្គលទាំង-ឡាយ ដែលជាអ្នកមានសីល នេះឯងជាធម៌គួររឭករកគ្នា ជាធម៌ធ្វើសេចក្តីស្រឡាញ់ ធ្វើសេចក្តីគោរព ប្រព្រឹត្តទៅដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀង ដើម្បីឯកីភាព ១ ។ ម្នាលអាវុសោទាំងឡាយមួយទៀត សីលណាដែលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុស ជាសីលអ្នកជាពួកវិញ្ញូជនតែងសរសើរ ជាសីលដែលតណ្ហា និងទិដ្ឋិមិនបានស្ទាបអង្អែល ប្រព្រឹត្តទៅដើម្បីសមាធិ ភិក្ខុជាអ្នកមានសីលដ៏ស្មើដោយសព្រហ្ម-ចារីបុគ្គលទាំងឡាយ ក្នុងសីលទាំងឡាយមានសភាពដូច្នោះ ក្នុងទីចំពោះមុខនិងទីកំបាំង នេះឯងជាធម៌គួររឭកគ្នា ជាធម៌ធ្វើសេចក្តីស្រឡាញ់ ធ្វើសេចក្តីគោរព ប្រព្រឹត្តទៅដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀង ដើម្បីឯកីភាព ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ទិដ្ឋិណាដ៏ប្រសើរ គឺសម្មាទិដ្ឋិ ជាគ្រឿងនាំសត្វចេញចាកភព តែងស្រោចស្រង់សត្វដែលប្រព្រឹត្តតាមទិដ្ឋិនោះ ដើម្បីឲ្យអស់ទៅនៃទុក្ខដោយប្រពៃ ភិក្ខុជាអ្នកមានទិដ្ឋិដ៏ស្មើដោយសព្រហ្មចារីបុគ្គលទាំងឡាយ ក្នុងទិដ្ឋិមានសភាពដូច្នោះ ទាំងក្នុងទីចំពោះមុខ និងទីកំបាំង នេះឯងជាធម៌គួររឭករកគ្នា ជាធម៌ធ្វើនូវសេចក្តីស្រឡាញ់ ធ្វើសេចក្តីគោរព ប្រព្រឹត្តទៅដើម្បីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីសេចក្តីព្រមព្រៀង ដើម្បីឯកីភាព ១ ។ ធម៌ទាំង ៦ នេះ មានឧបការៈច្រើន ។

[ ២៩៤ ] ធម៌ ៦ គួរបម្រើន តើដូចម្តេចខ្លះ ។ អនុស្សតិដ្ឋានៈ ( ហេតុជាទីតាំងនៃសេចក្តីរឭករឿយៗ ) ៦ យ៉ាង សេចក្តីរឭកនូវព្រះពុទ្ធ ១ រឭកនូវព្រះធម៌ ១ រឭកនូវព្រះសង្ឃ ១ រឭកនូវគុណនៃសីល ១ រឭកនូវទានដែលបានបរិច្ចាគហើយ ១ រឭកដល់ធម៌ទេវតា ១ ។ ធម៌ទាំង ៦ នេះ គួរបម្រើន ។

[ ២៩៥ ] ធម៌ ៦ គួរកំណត់ដឹង តើដូចម្តេចខ្លះ ។ អាយតនៈខាងក្នុង ៦ គឺភ្នែកជាអាយតនៈ ១ ត្រចៀកជាអាយតនៈ ១ ច្រមុះជាអាយតនៈ ១ អណ្តាតជាអាយតនៈ ១ កាយជាអាយតនៈ ១ ចិត្តជាអាយតនៈ ១ ។ ធម៌ទាំង ៦ នេះ គួរកំណត់ដឹង ។

[ ២៩៦ ] ធម៌ ៦ គួរលះបង់ តើដូចម្តេចខ្លះ ។ ពួកតណ្ហា ៦ គឺរូបតណ្ហា ១ សទ្ទតណ្ហា ១ គន្ធតណ្ហា ១ រសតណ្ហា ១ ផោដ្ឋព្វតណ្ហា ១ ធម្មតណ្ហា ។ ធម៌ទាំង ៦ នេះ គួរលះបង់ ។

[ ២៩៧ ] ធម៌ ៦ ជាចំណែកនៃសេចក្តីវិនាស តើដូចម្តេចខ្លះ ។ សេចក្តីមិនគោរព ៦ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនគោរព មិនកោតក្រែងចំពោះព្រះសាស្តា ១ ជាអ្នកមិនគោរព មិនកោតក្រែងចំពោះព្រះធម៌ ១ ជាអ្នកមិនគោរព មិនកោតក្រែងចំពោះព្រះសង្ឃ ១ ជាអ្នកមិនគោរព មិនកោតក្រែងចំពោះសិក្ខា ១ ជាអ្នកមិនគោរព មិនកោតក្រែងចំពោះអប្បមាទធម៌ ១ ជាអ្នកមិនគោរព មិនកោតក្រែងចំពោះបដិសណ្ឋារៈ ១ ។ ធម៌ទាំង ៦ នេះ ជាចំណែកនៃសេចក្តីវិនាស ។

[ ២៩៨ ] ធម៌ ៦ ជាចំណែកវិសេស តើដូចម្តេចខ្លះ ។ សេចក្តីគោរព

៦ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសេចក្ដីគោរព កោតក្រែងចំពោះព្រះសាស្តា ១ ជាអ្នកមានសេចក្តីគោរព កោតក្រែងចំពោះព្រះធម៌ ១ ។ ចំពោះព្រះសង្ឃ ១ ។ ចំពោះសិក្ខា ១ ។ ចំពោះអប្បមាទធម៌ ១ ។ មានសេចក្តីគោរព កោតក្រែងចំពោះបដិសណ្ឋារៈ ១ ។ ធម៌ទាំង ៦ នេះ ជាចំណែកវិសេស ។

[ ២៩៩ ] ធម៌ ៦ ត្រាស់ដឹងបានដោយក្រ តើដូចម្តេចខ្លះ ។ និស្សារណីយធាតុ ៦ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពោលយ៉ាងនេះថា ចេតោវិមុត្តិប្រកបដោយមេត្តា ខ្ញុំបានអប់រំបន្ទុំឲ្យច្រើន ហើយបានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាដូច្នោះក៏ដោយ ព្យាបាទក៏គង់តែគ្របសង្កត់ចិត្តរបស់ខ្ញុំបាន ។ ( អ្នកផង ) គប្បីនិយាយឃាត់ភិក្ខុនោះថា លោកកុំនិយាយយ៉ាងនេះឡើយ លោកដ៏មានអាយុកុំនិយាយយ៉ាងនេះ កុំនិយាយបង្កាច់ព្រះមានព្រះមានព្រះភាគ ព្រោះការនិយាយបង្កាច់ព្រះមានព្រះភាគមិនល្អទេ តាមដែលពិតនោះ ព្រះមានព្រះភាគមិនបានត្រាស់យ៉ាងនេះទេ ម្នាលអាវុសោ ដំណើរនេះមិនមែនជាហេតុ មិនមែនជាបច្ច័យ ត្រង់ពាក្យដែលថា ចេតោវិមុត្តិប្រកបដោយមេត្តាដែលគេបានអប់រំបន្ទុំឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាដូច្នោះក៏ដោយ ព្យាបាទក៏គង់នៅគ្របសង្កត់ចិត្តរបស់គេបាន ដូច្នេះ នេះមិនមែនជាហេតុជាទីតាំងឡើយ ម្នាលអាវុសោ តាមដែលពិតនុ៎ះ គឺចេតោ-

វិមុត្តិដែលប្រកបដោយមេត្តាហ្នឹងឯង ជាធម៌សម្រាប់រលាស់ចោលនូវព្យាបាទ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ពោលយ៉ាងនេះថា ចេតោវិមុត្តិប្រកបដោយករុណា ខ្ញុំបានអប់រំបន្ទុំទុកឲ្យច្រើន ហើយបានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាធ្វើដូច្នោះក៏ដោយ វិហេសា ( សេចក្តីបៀតបៀន ) ក៏គង់តែគ្របសង្កត់ចិត្តរបស់ខ្ញុំបាន ។ ( អ្នកផង ) គប្បីនិយាយឃាត់ភិក្ខុនោះថា លោកកុំនិយាយយ៉ាងនេះឡើយ លោកដ៏មានអាយុ កុំនិយាយយ៉ាងនេះ កុំនិយាយបង្កាច់ព្រះមានព្រះភាគ ព្រោះការនិយាយបង្កាច់ ព្រះមានព្រះភាគមិនល្អទេ តាមដែលពិតនោះ ព្រះមានព្រះភាគមិនបានត្រាស់យ៉ាងនេះទេ ម្នាលអាវុសោ ដំណើរនេះ មិនមែនជាហេតុ មិនមែនជាបច្ច័យ ត្រង់ពាក្យដែលថា ចេតោវិមុត្តិប្រកបដោយករុណា ដែលគេបានអប់រំបន្ទុំឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាធ្វើដូច្នោះក៏ដោយ វិហេសាក៏គង់តែគ្របសង្កត់ចិត្តរបស់គេបាន ដូច្នេះនេះ មិនមែនជាហេតុជាទីតាំងឡើយ ម្នាលអាវុសោ តាមដែលពិតនុ៎ះ គឺចេតោវិមុត្តិ ដែលប្រកបដោយករុណាហ្នឹងឯង ជាធម៌សម្រាប់រលាស់ចោលនូវវិហេសា ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ពោលយ៉ាងនេះថា ចេតោវិមុត្តិប្រកបដោយមុទិតា ខ្ញុំបានអប់រំបន្ទុំឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាធ្វើដូច្នោះក៏ដោយ អរតិ ( សេចក្តី

មិនត្រេកអរ ) ក៏គង់តែគ្របសង្កត់ចិត្តរបស់ខ្ញុំបាន ។ ( អ្នកផង ) គប្បី និយាយឃាត់ភិក្ខុនោះថា លោកកុំនិយាយយ៉ាងនេះឡើយ លោកដ៏មានអាយុ កុំនិយាយយ៉ាងនេះ កុំនិយាយបង្កាច់ព្រះមានព្រះភាគ ព្រោះការនិយាយ បង្កាច់ព្រះមានព្រះភាគមិនល្អទេ តាមដែលពិតនោះ ព្រះមានព្រះភាគមិនបាន ត្រាស់យ៉ាងនេះទេ ម្នាលអាវុសោ ដំណើរនេះ មិនមែនជាហេតុ មិនមែនជា បច្ច័យ ត្រង់ពាក្យដែលថា មេត្តាចេតោវិមុត្តិប្រកបដោយមុទិតា ដែលគេបាន អប់រំបន្ទុំឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្ត រឿយៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាធ្វើដូច្នោះក៏ដោយ អរតិ ក៏គង់តែគ្របសង្កត់ចិត្តរបស់គេបាន ដូច្នេះនេះ មិនមែនជាហេតុ ជាទីតាំង ឡើយ ម្នាលអាវុសោ តាមដែលពិតនោះ គឺចេតោវិមុត្តិដែលប្រកបដោយ មុទិតាហ្នឹងឯង ជាធម៌សម្រាប់រលាស់ចោលនូវអរតិ ។ ម្នាលអាវុសោទាំង-ឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ពោលយ៉ាងនេះថា ចេតោវិមុត្តិប្រកប ដោយឧបេក្ខា ខ្ញុំបានអប់រំបន្ទុំឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានតម្កល់ ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាធ្វើ ដូច្នោះក៏ដោយ រាគៈក៏គង់តែគ្របសង្កត់ចិត្តរបស់ខ្ញុំបាន ។ ( អ្នកផង ) គួរ និយាយឃាត់ភិក្ខុនោះថា លោកកុំនិយាយយ៉ាងនេះឡើយ លោកដ៏មានអាយុ កុំនិយាយយ៉ាងនេះ កុំនិយាយបង្កាច់ព្រះមានព្រះភាគ ព្រោះការនិយាយបង្កាច់ ព្រះមានព្រះភាគមិនល្អទេ តាមដែលពិតនោះ ព្រះមានព្រះភាគមិនបានត្រាស់ យ៉ាងនេះទេ ម្នាលអាវុសោ ដំណើរនេះ មិនមែនជាហេតុ មិនមែនជាបច្ច័យ

ត្រង់ពាក្យដែលថា ចេតោវិមុត្តិប្រកបដោយឧបេក្ខា ដែលគេបានអប់រំបំប៉នឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាធ្វើដូច្នោះក៏ដោយ រាគៈក៏គង់តែគ្របសង្កត់ចិត្តរបស់គេបានដូច្នេះ នេះមិនមែនជាហេតុ ជាទីតាំងឡើយ ម្នាលអាវុសោ តាមដែលពិតនោះ គឺចេតោវិមុត្តិដែលប្រកបដោយឧបេក្ខាហ្នឹងឯងជាធម៌សម្រាប់រលាស់ចោលនូវរាគៈ ។ ម្នាលអាវុសោទាំងឡាយ មួយទៀតភិក្ខុក្នុងសាសនានេះពោលយ៉ាងនេះ ចេតោវិមុត្តិប្រកបដោយអនិមិត្ត ខ្ញុំបានអប់រំបំប៉នឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាធ្វើដូច្នោះក៏ដោយនិមិត្តានុសារិវិញ្ញាណ គឺវិញ្ញាណដែលរឭកឃើញនូវនិមិត្តរបស់ខ្ញុំ នៅតែមាន ។ ( អ្នកផង ) គប្បីនិយាយឃាត់ភិក្ខុនោះថា លោកកុំនិយាយយ៉ាងនេះឡើយ លោកដ៏មានអាយុកុំនិយាយយ៉ាងនេះ កុំនិយាយបង្កាច់ព្រះមានព្រះភាគ ព្រោះការនិយាយបង្កាច់ព្រះមានព្រះភាគមិនល្អទេ តាមដែលពិតនោះ ព្រះមានព្រះភាគមិនបានត្រាស់យ៉ាងនេះទេ ម្នាលអាវុសោ ដំណើរនេះ មិនមែនជាហេតុ មិនមែនជាបច្ច័យ ត្រង់ពាក្យដែលថា ចេតោវិមុត្តិប្រកបដោយអនិមិត្ត ដែលគេបានអប់រំបំប៉នឲ្យច្រើន បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំ បានប្រារព្ធល្អហើយ តែបើទុកជាដូច្នោះក៏ដោយ និមិត្តានុសារិវិញ្ញាណរបស់គេ គង់តែនៅមានដូច្នេះនេះ មិនមែនជាហេតុ ជាទីតាំងឡើយ ម្នាលអាវុសោ តាមដែលពិតនោះ ចេតោវិមុត្តិដែលប្រកបដោយ

អនិមិត្តហ្នឹងឯង ជាធម៌សម្រាប់រលាស់ចោលនូវនិមិត្តទាំងអស់ ។ ម្នាល អាវុសោទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ពោលយ៉ាងនេះថា អស្មិមានះរបស់ខ្ញុំនេះ ទៅប្រាស់ហើយ ខ្ញុំពិចារណាមិនឃើញថា អាត្មាអញ មានអស្មិមានះដូច្នេះឡើយ តែបើទុកជាដូច្នោះ កូនសរ គឺសេចក្តីសង្ស័យ និង សេចក្តីងឿងឆ្ងល់ ក៏គង់តែគ្របសង្កត់ចិត្តរបស់ខ្ញុំបាន ។ ( អ្នកផង ) គប្បី និយាយឃាត់ភិក្ខុនោះយ៉ាងនេះថា លោកកុំនិយាយយ៉ាងនេះ លោកដ៏មាន អាយុកុំនិយាយយ៉ាងនេះឡើយ លោកកុំនិយាយបង្កាច់នូវព្រះមានព្រះភាគ ព្រោះការនិយាយបង្កាច់ព្រះមានព្រះភាគមិនល្អទេ តាមដែលពិតនោះ ព្រះមាន ព្រះភាគមិនបានត្រាស់យ៉ាងនេះទេ ម្នាលអាវុសោ រឿងនេះមិនមែនជាហេតុ មិនមែនជាបច្ច័យ ត្រង់ពាក្យដែលថា អស្មិមានះរបស់គេនេះ ទៅប្រាសអស់ ហើយ គេពិចារណាមិនឃើញថា អាត្មាអញមានអស្មិមានះដូច្នេះឡើយ តែ បើទុកជាដូច្នោះ កូនសរ គឺសេចក្តីសង្ស័យនិងសេចក្តីងឿងឆ្ងល់ ក៏គង់តែគ្រប សង្កត់ចិត្តរបស់គេបានដូច្នេះ នេះមិនមែនជាហេតុ ជាទីតាំងឡើយ ម្នាល អាវុសោ តាមដែលពិតនោះ ការដកឡើងនូវអស្មិមានះបានហ្នឹងឯង ជាធម៌ សម្រាប់រលាស់ចេញនូវកូនសរ គឺសេចក្តីសង្ស័យនិងសេចក្តីងឿងឆ្ងល់ ។ ធម៌ ទាំង ៦ នេះ ត្រាស់ដឹងបានដោយក្រ ។

[ ៣០០ ] ធម៌ ៦ ដែលគួរឲ្យកើតឡើង តើដូចម្តេចខ្លះ ។ សតត- វិហារធម៌ ( ធម៌ជាគ្រឿងនៅមិនដាច់នៃព្រះខីណាស្រព ) ៦ យ៉ាង ម្នាល អាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានឃើញរូបដោយភ្នែកហើយ ជា

អ្នកមិនមានសោមនស្ស មិនមានទោមនស្ស ជាអ្នកព្រងើយកន្តើយផង មាន ស្មារតី និងប្រាជ្ញាផង ។ បានស្តាប់សំឡេងដោយត្រចៀក ។បេ។ បានហិត ក្លិនដោយច្រមុះ ។បេ។ បានទទួលរសដោយអណ្តាត ។បេ។ ពាល់ត្រូវដោយ កាយ ។បេ។ បានដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត ហើយជាអ្នកមិនមាន សោមនស្ស មិនមានទោមនស្ស ជាអ្នកព្រងើយកន្តើយផង មានស្មារតី និង ប្រាជ្ញាផង ។ ធម៌ទាំង ៦ នេះ គួរឲ្យកើតឡើង ។

[ ៣០១ ] ធម៌ ៦ ដែលគួរដឹងច្បាស់ តើដូចម្តេចខ្លះ ។ អនុត្តរិយៈ ( ធម្មជាតប្រសើរ ) ៦ គឺការឃើញប្រសើរ ១ ការស្តាប់ប្រសើរ ១ ការ បានប្រសើរ ១ ការសិក្សាប្រសើរ ១ ការបម្រើប្រសើរ ១ ការរឭកប្រសើរ ១ ។ ធម៌ទាំង ៦ នេះ គួរដឹងច្បាស់ ។

[ ៣០២ ] ធម៌ ៦ ដែលគួរធ្វើឲ្យជាក់ច្បាស់ តើដូចម្តេចខ្លះ ។ អភិញ្ញា ៦ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ សម្តែងឫទ្ធិបានច្រើន ប្រការ គឺមនុស្សតែម្នាក់ ធ្វើឲ្យទៅជាច្រើននាក់ក៏បាន ឬមនុស្សច្រើននាក់ ធ្វើឲ្យទៅជាមនុស្សម្នាក់វិញក៏បាន ដើរទៅមិនជាប់ជំពាក់នឹងទីវាល ទីខាង ក្រៅជញ្ជាំង ទីខាងក្រៅកំពែង និងទីខាងក្រៅភ្នំ ដូចជាដើរទៅក្នុងអាកាសក៏ បាន ធ្វើនូវការមុជងើបក្នុងផែនដី ដូចជាមុជងើបក្នុងទឹកក៏បាន ដើរទៅលើទឹក មិនបែកធ្លាយទឹក ដូចជាដើរទៅលើផែនដីក៏បាន ទៅឯអាកាសទាំងភ្នែន ដូច ជាសត្វសកុណជាតិដែលមានស្លាបក៏បាន យកដៃទៅស្ទាបអង្អែលចាប់ពាល់ ( មណ្ឌល ) ព្រះចន្ទ្រ និងព្រះអាទិត្យនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មាន

អានុភាពច្រើនយ៉ាងនេះក៏បាន ធ្វើអំណាចឲ្យប្រព្រឹត្តទៅ ដោយកាយដរាប ដល់ព្រហ្មលោកក៏បាន ១ ។ ភិក្ខុមានត្រចៀកទិព្វដ៏បរិសុទ្ធកន្លងហួសត្រចៀក មនុស្សធម្មតា រមែងឮសំឡេងពីរប្រការ គឺសំឡេងទិព្វ និងសំឡេងមនុស្ស ក្នុងទីឆ្ងាយក៏បាន ទីជិតក៏បាន ១ ។ ភិក្ខុអាចកំណត់ដឹងចិត្ត របស់សត្វដទៃ បុគ្គលដទៃដោយចិត្តរបស់ខ្លួនបាន គឺចិត្តដែលប្រកបដោយរាគៈក្តី ក៏ស្គាល់ថា ចិត្តប្រកបដោយរាគៈ ចិត្តដែលប្រាសចាករាគៈក្តី ក៏ស្គាល់ថា ចិត្តប្រាសចាក រាគៈ ចិត្តដែលប្រកបដោយទោសៈក្តី ក៏ស្គាល់ថា ចិត្តប្រកបដោយទោសៈ ចិត្តដែលប្រាសចាកទោសៈក្តី ក៏ស្គាល់ថា ចិត្តប្រាសចាកទោសៈ ចិត្តដែល ប្រកបដោយមោហៈក្តី ក៏ស្គាល់ថា ចិត្តប្រកបដោយមោហៈ ចិត្តដែលប្រាស ចាកមោហៈក្តី ចិត្តដែលរួញរាក្តី ក៏ស្គាល់ថា ចិត្តរួញរា ចិត្តដែលរាយមាយ ក្តី ក៏ស្គាល់ថា ចិត្តរាយមាយ ចិត្តដែលជាមហគ្គតៈ គឺរូបាវចរ និងអរូបាវចរក្តី ក៏ស្គាល់ថា ចិត្តជាមហគ្គតៈ ចិត្តដែលមិនមែនជាមហគ្គតៈក្តី ក៏ស្គាល់ថា ចិត្ត មិនមែនជាមហគ្គតៈ ចិត្តដែលមិនមែនជាសឧត្តរៈ គឺលោកិយចិត្តក្តី ក៏ស្គាល់ថា ចិត្តជាសឧត្តរៈ ចិត្តដែលជាអនុត្តរៈ គឺលោកុត្តរចិត្តក្តី ក៏ស្គាល់ថាចិត្តជាអនុត្តរៈ ចិត្តដែលតាំងនៅល្អដោយសមាធិក្តី ក៏ស្គាល់ថា ចិត្តតាំងនៅល្អដោយសមាធិ ចិត្តដែលមិនតាំងនៅល្អដោយសមាធិក្តី ក៏ស្គាល់ថា ចិត្តមិនតាំងនៅល្អដោយ សមាធិ ចិត្តដែលផុតស្រឡះចាកកិលេសាសវៈក្តី ក៏ស្គាល់ថា ចិត្តផុតស្រឡះ ចាកកិលេសាសវៈ ចិត្តដែលមិនបានផុតស្រឡះចាកកិលេសាសវៈក្តី ក៏ស្គាល់ ថា ចិត្តមិនផុតស្រឡះចាកកិលេសាសវៈ ១។ ភិក្ខុរឭកជាតិដែលបានអាស្រ័យ

នៅមកអំពីមុន ជាអនេកជាតិ គឺរឭកបាន ១ ជាតិ ២ ជាតិ ៣ ជាតិ ៤ ជាតិ ៥ ជាតិ ១០ ជាតិ ២០ ជាតិ ៣០ ជាតិ ៤០ ជាតិ ៥០ ជាតិ ១០០ ជាតិ ១ ពាន់ជាតិ ១ សែនជាតិក៏បាន រឭកបានច្រើនសំវដ្តកប្ប ច្រើនវិវដ្តកប្ប ច្រើនសំវដ្តវិវដ្តកប្បក៏បាន ដូច្នេះថា អាត្មាអញបានកើតក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ ទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណេះ អាត្មាអញ លុះច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងភពឯណោះ ដែលទៅកើតក្នុងភពនោះ អាត្មាអញ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណេះ អាត្មាអញច្យុតចាកអត្តភាពនោះហើយ ទើបមកកើតក្នុងភពនេះ ( ភិក្ខុ ) រឭកតាមនូវជាតិដែលអាស្រ័យនៅពីមុនបានច្រើនជាតិ ព្រមទាំងអាការ ព្រមទាំងឧទ្ទេសយ៉ាងនេះ ១ ។ ភិក្ខុមានចក្ខុទិព្វដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា បានឃើញពួកសត្វដែលច្យុត ដែលកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានរូបល្អ មានរូបអាក្រក់ មានគតិល្អ មានគតិអាក្រក់ ទាំងដឹងច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្ម ( របស់ខ្លួន ) ថា អើហ្ន៎ សត្វទាំងឡាយនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលនូវព្រះអរិយបុគ្គល មានសេចក្តីយល់ខុស ប្រកាន់នូវអំពើតាមសេចក្តីយល់ខុស សត្វទាំងនោះ លុះដល់ទម្លាយរាងកាយទៅ ខាងមុខអំពីសេចក្តីស្លាប់ រមែងទៅកាន់កំណើតសត្វតិរច្ឆាន ប្រេត អសុរកាយ និង

នរកពុំខាន អើហ្ន៎ ចំណែកពួកសត្វទាំងអម្បាលនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនតិះដៀលនូវព្រះអរិយបុគ្គល មានសេចក្តីយល់ត្រូវ ប្រកាន់នូវអំពើតាមសេចក្តីយល់ត្រូវ សត្វទាំងនោះ លុះទម្លាយរាងកាយទៅ ខាងមុខអំពីសេចក្តីស្លាប់ ក៏រមែងទៅកាន់សុគតិ សួគ៌ទេវលោក ។ ភិក្ខុនោះ មានចក្ខុទិព្វដ៏បរិសុទ្ធ កន្លងហួសចក្ខុរបស់មនុស្សធម្មតា បានឃើញពួកសត្វ ដែលច្យុត ដែលកើត ជាសត្វថោកទាប ជាសត្វឧត្តម មានរូបល្អ មានរូបអាក្រក់ មានគតិល្អ មានគតិអាក្រក់ ទាំងបានឃើញច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្ម ( របស់ខ្លួន ) ដោយប្រការដូច្នេះ ១ ។ ភិក្ខុនោះ ព្រោះធ្វើឲ្យអស់អាសវៈ ក៏បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ដោយប្រាជ្ញារបស់ខ្លួនឯងក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅ ដោយឥរិយាបថ ១ ។ ធម៌ទាំង ៦ នេះ គួរធ្វើឲ្យជាក់ច្បាស់ ។ ធម៌ទាំង ៦០ នេះ ជាធម៌ពិត ធម៌មែន ធម៌ទៀងទាត់ មិនប្រែប្រួលជាយ៉ាងដទៃឡើយ ដែលព្រះតថាគតបានត្រាស់ដឹងដោយប្រពៃហើយ ដោយប្រការដូច្នេះ ។

[ ៣០៣ ] ធម៌ ៧ មានឧបការៈច្រើន ធម៌ ៧ គួរចម្រើន ធម៌ ៧ គួរកំណត់ដឹង ធម៌ ៧ គួរលះបង់ ធម៌ ៧ ជាចំណែកខាងសេចក្តីវិនាស ធម៌ ៧ ជាចំណែកវិសេស ធម៌ ៧ ត្រាស់ដឹងបានដោយក្រ ធម៌ ៧ គួរឲ្យកើតឡើង ធម៌ ៧ គួរដឹងច្បាស់ ធម៌ ៧ គួរធ្វើឲ្យជាក់ច្បាស់ ។

[ ៣០៤ ] ធម៌ ៧ មានឧបការៈច្រើន តើដូចម្តេចខ្លះ ។ អរិយទ្រព្យ

៧ គឺសទ្ធាជាទ្រព្យ ១ សីលជាទ្រព្យ ១ ហិរិជាទ្រព្យ ១ ឱត្តប្បៈជាទ្រព្យ ១ សុតៈជាទ្រព្យ ១ ចាគៈជាទ្រព្យ ១ បញ្ញាជាទ្រព្យ ១ ។ ធម៌ទាំង ៧ នេះ មានឧបការៈច្រើន ។

[ ៣០៥ ] ធម៌ ៧ ដែលគួរចម្រើន តើដូចម្តេចខ្លះ ។ សម្ពោជ្ឈង្គ ( អង្គនៃធម៌ជាគ្រឿងត្រាស់ដឹង ) ៧ គឺសតិសម្ពោជ្ឈង្គ ១ ធម្មវិចយ-សម្ពោជ្ឈង្គ ១ វិរិយសម្ពោជ្ឈង្គ ១ បីតិសម្ពោជ្ឈង្គ ១ បស្សទ្ធិសម្ពោជ្ឈង្គ ១ សមាធិសម្ពោជ្ឈង្គ ១ ឧបេក្ខាសម្ពោជ្ឈង្គ ១ ។ ធម៌ទាំង ៧ នេះគួរចម្រើន ។

[ ៣០៦ ] ធម៌ ៧ ដែលគួរកំណត់ដឹង តើដូចម្តេចខ្លះ ។ វិញ្ញាណដ្ឋិតិ ៧ ម្នាលអាវុសោទាំងឡាយ សត្វទាំងឡាយ មានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នា ដូចយ៉ាងពួកមនុស្ស និងពួកទេវតាខ្លះ និងអសុរកាយពួកខ្លះ នេះជាវិញ្ញាណដ្ឋិតិទី ១ ។ ម្នាលអាវុសោទាំងឡាយ សត្វទាំងឡាយ មានកាយផ្សេងគ្នា តែមានសញ្ញាដូចគ្នា ដូចយ៉ាងពួកព្រហ្មកាយិកទេវតា ដែលកើតក្នុងបឋមជ្ឈានភូមិ នេះជាវិញ្ញាណដ្ឋិតិទី ២ ។ ម្នាលអាវុសោទាំងឡាយ សត្វទាំងឡាយ មានកាយដូចគ្នា តែមានសញ្ញាខុសគ្នា ដូចយ៉ាងពួកអាភស្សរទេវតា នេះជាវិញ្ញាណដ្ឋិតិទី ៣ ។ ម្នាលអាវុសោទាំងឡាយ សត្វទាំងឡាយ មានកាយដូចគ្នា មានសញ្ញាដូចគ្នា ដូចយ៉ាងពួកសុភកិណ្ហទេវតា នេះជាវិញ្ញាណ-ដ្ឋិតិទី ៤ ។ ម្នាលអាវុសោទាំងឡាយ សត្វទាំងឡាយដែលកន្លងនូវរូបសញ្ញាដល់នូវសេចក្តីវិនាសនៃបដិឃសញ្ញា មិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញាដោយប្រការទាំងពួង ហើយបរិកម្មថា អាកាសមិនមានទីបំផុត ដូច្នេះហើយ

ចូលដល់អាកាសានញ្ចាយតនជ្ឈាន នេះជាវិញ្ញាណដ្ឋិតិទី ៥ ។ ម្នាលអាវុសោទាំងឡាយ សត្វទាំងឡាយដែលកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបរិកម្មថា វិញ្ញាណមិនមានទីបំផុត ដូច្នេះហើយ ចូលដល់វិញ្ញាណញ្ចាយតនជ្ឈាន នេះជាវិញ្ញាណដ្ឋិតិទី ៦ ។ ម្នាលអាវុសោទាំងឡាយ សត្វទាំងឡាយដែលកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈានដោយប្រការទាំងពួង ហើយបរិកម្មថា វត្ថុតិចតួចមិនមាន ដូច្នេះហើយ ចូលដល់អាកិញ្ចញ្ញាយតនជ្ឈាន នេះជាវិញ្ញាណដ្ឋិតិទី ៧ ។ ធម៌ទាំង ៧ នេះ គួរកំណត់ដឹង ។

[ ៣០៧ ] ធម៌ ៧ ដែលគួរលះបង់ តើដូចម្តេចខ្លះ ។ អនុស័យ ( កិលេសជាគ្រឿងដេកត្រាំក្នុងសន្តាន ) ៧ គឺកាមរាគានុស័យ ១ បដិឃានុស័យ ១ ទិដ្ឋានុស័យ ១ វិចិកិច្ឆានុស័យ ១ មានានុស័យ ១ ភវរាគានុស័យ ១ អវិជ្ជានុស័យ ១ ។ ធម៌ទាំង ៧ នេះ គួរលះបង់ ។

[ ៣០៨ ] ធម៌ ៧ ជាចំណែកខាងសេចក្តីវិនាស តើដូចម្តេចខ្លះ ។ អសទ្ធម្ម ( ធម៌របស់អសប្បុរស ) ៧ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកគ្មានសទ្ធា ១ ជាអ្នកមិនខ្មាសបាប ១ ជាអ្នកមិនខ្លាចបាប ១ ជាអ្នកចេះដឹងតិច ១ ជាអ្នកខ្ជិលច្រអូស ១ ជាអ្នកភ្លេចស្មារតី ១ ជាអ្នកឥតប្រាជ្ញា ១ ។ ធម៌ទាំង ៧ នេះ ជាចំណែកខាងសេចក្តីវិនាស ។

[ ៣០៩ ] ធម៌ ៧ ជាចំណែកវិសេស តើដូចម្តេចខ្លះ ។ សទ្ធម្ម (ធម៌របស់សប្បុរស ) ៧ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសទ្ធា ១ ជាអ្នកមានសេចក្តីខ្មាសបាប ១ ជាអ្នកមានសេចក្តីខ្លាចបាប ១

ជាអ្នកចេះដឹងច្រើន ១ ជាអ្នកប្រារព្ធព្យាយាម ១ ជាអ្នកមានស្មារតីតម្កល់ខ្ជាប់ ១ ជាអ្នកមានប្រាជ្ញា ១ ។ ធម៌ទាំង ៧ នេះ ជាចំណែកវិសេស ។

[ ៣១០ ] ធម៌ ៧ ដឹងបានដោយក្រ តើដូចម្តេចខ្លះ ។ សប្បុរិសធម៌ ( ធម៌របស់សប្បុរស ) ៧ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកដឹងធម៌ ១ ជាអ្នកដឹងអត្ថ ១ ជាអ្នកដឹងខ្លួន ១ ជាអ្នកដឹងប្រមាណ ១ ជាអ្នកដឹងកាល ១ ជាអ្នកដឹងបរិស័ទ ១ ជាអ្នកដឹងបុគ្គលដទៃដែលគួរសេពគប់ ១ ។ ធម៌ទាំង ៧ នេះ ដឹងបានដោយកម្រ ។

[ ៣១១ ] ធម៌ ៧ គួរឲ្យកើតឡើង តើដូចម្តេចខ្លះ ។ សញ្ញា ៧ ប្រការ គឺអនិច្ចសញ្ញា ១ អនត្តសញ្ញា ១ អសុភសញ្ញា ១ អាទីនវសញ្ញា ១ បហានសញ្ញា ១ វិរាគសញ្ញា ១ និរោធសញ្ញា ១ ។ ធម៌ទាំង ៧ នេះ គួរឲ្យកើតឡើង ។

[ ៣១២ ] ធម៌ ៧ ដែលគួរដឹងច្បាស់ តើដូចម្តេចខ្លះ ។ និទ្ទសវត្ថុ ៧ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសេចក្តីពេញចិត្តខ្លាំងក្នុងការសមាទាននូវសិក្ខា សូម្បីតទៅកាលខាងមុខ ក៏នៅតែមិនលះបង់សេចក្តីពេញចិត្ត ក្នុងការសមាទាននូវសិក្ខា ១ ជាអ្នកមានសេចក្តីពេញចិត្តខ្លាំង ក្នុងការពិចារណានូវធម៌ សូម្បីតទៅកាលខាងមុខ ក៏នៅតែមិនលះបង់នូវសេចក្តីពេញចិត្ត ក្នុងការពិចារណានូវធម៌ ១ ជាអ្នកមានសេចក្តីពេញចិត្តខ្លាំង ក្នុងការកម្ចាត់បង់នូវឥច្ឆា គឺតណ្ហា សូម្បីតទៅកាលខាងមុខ ក៏នៅតែមិនលះបង់នូវសេចក្តីពេញចិត្ត ក្នុងការកម្ចាត់បង់នូវឥច្ឆា គឺតណ្ហា ១ ជាអ្នកមាន

សេចក្តីពេញចិត្តខ្លាំងក្នុងការពួនសម្ងំ សូម្បីតទៅកាលខាងមុខ ក៏នៅតែមិន លះបង់នូវសេចក្តីពេញចិត្ត ក្នុងការពួនសម្ងំ ១ ជាអ្នកមានសេចក្តីពេញចិត្ត ខ្លាំងក្នុងការប្រារព្ធព្យាយាម សូម្បីតទៅកាលខាងមុខ ក៏នៅតែមិនលះបង់នូវ សេចក្តីពេញចិត្ត ក្នុងការប្រារព្ធព្យាយាម ១ ជាអ្នកមានសេចក្តីពេញចិត្តខ្លាំង ក្នុងការតាំងស្មារតី និងភាពជាអ្នកមានប្រាជ្ញាចាស់ក្លា សូម្បីតទៅកាលខាងមុខ ក៏នៅតែមិនលះបង់នូវសេចក្តីពេញចិត្ត ក្នុងការតាំងស្មារតី និងភាពជាអ្នកមាន ប្រាជ្ញាចាស់ក្លា ១ ជាអ្នកមានសេចក្តីពេញចិត្តខ្លាំងក្នុងការចាក់ធ្លុះដោយទិដ្ឋិ គឺ ឃើញច្បាស់នូវមគ្គ សូម្បីតទៅកាលខាងមុខ ក៏នៅតែមិនលះបង់នូវសេចក្តី ពេញចិត្ត ក្នុងការចាក់ធ្លុះដោយទិដ្ឋិ ១ ។ ធម៌ទាំង ៧ នេះ គួរដឹងច្បាស់ ។

[ ៣១៣ ] ធម៌ ៧ ដែលគួរធ្វើឲ្យជាក់ច្បាស់ តើដូចម្តេចខ្លះ ។ កម្លាំង របស់ព្រះខីណាស្រព ៧ ម្នាលអាវុសោទាំងឡាយ សង្ខារទាំងពួងដែលភិក្ខុ ជាព្រះខីណាស្រព ក្នុងសាសនានេះ បានឃើញថា មិនទៀងតាមសេចក្តីពិត ដោយបញ្ញាដ៏ប្រពៃហើយ ម្នាលអាវុសោទាំងឡាយ ក៏សង្ខារទាំងពួង ដែល ភិក្ខុជាព្រះខីណាស្រព បានឃើញថា មិនទៀងតាមសេចក្តីពិត ដោយបញ្ញា ដ៏ប្រពៃ នេះឯងចាត់ជាកម្លាំងរបស់ភិក្ខុជាព្រះខីណាស្រព ព្រោះភិក្ខុជាព្រះ ខីណាស្រព អាស្រ័យនូវកម្លាំងនេះ ទើបប្តេជ្ញានូវការអស់ទៅនៃអាសវៈទាំង-ឡាយថា អាសវៈទាំងឡាយ របស់អាត្មាអញអស់ហើយ ១ ។ ម្នាលអាវុសោ ទាំងឡាយ មួយទៀត កាមទាំងឡាយមានឧបមាដូចរណ្តៅដ៏ពេញដោយរងើក ភ្លើង ដែលភិក្ខុជាព្រះខីណាស្រព បានឃើញតាមសេចក្តីពិត ដោយបញ្ញាដ៏

ប្រពៃហើយ ម្នាលអាវុសោទាំងឡាយ ក៏កាមទាំងឡាយមានឧបមាដូចរណ្តៅដ៏ពេញដោយរងើកភ្លើង ដែលភិក្ខុជាព្រះខីណាស្រព បានឃើញតាមសេចក្តីពិត ដោយបញ្ញាដ៏ប្រពៃ នេះឯងចាត់ជាកម្លាំងរបស់ភិក្ខុជាព្រះខីណាស្រព ព្រោះភិក្ខុជាព្រះខីណាស្រព អាស្រ័យនូវកម្លាំងនេះ ទើបប្តេជ្ញានូវការអស់ទៅនៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយរបស់អាត្មាអញអស់ហើយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ចិត្តរបស់ភិក្ខុជាព្រះខីណាស្រព តែងឱនទៅរកវិវេក ឈានទៅរកវិវេក តម្កល់នៅក្នុងវិវេក ត្រេកអរចំពោះក្នុងការចេញចាកកាម ជាចិត្តប្រាសចាកធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈដោយប្រការទាំងពួង ម្នាលអាវុសោទាំងឡាយ ក៏ចិត្តរបស់ភិក្ខុជាព្រះខីណា-ស្រព ដែលឱនទៅរកវិវេក ឈានទៅរកវិវេក បែរទៅរកវិវេក តម្កល់នៅក្នុងវិវេក ត្រេកអរចំពោះក្នុងការចេញចាកកាម ជាចិត្តប្រាសចាកធម៌ទាំងឡាយដែលជាទីតាំងនៃអាសវៈដោយប្រការទាំងពួង នេះឯងចាត់ជាកម្លាំងរបស់ភិក្ខុជាព្រះខីណាស្រព ព្រោះភិក្ខុជាព្រះខីណាស្រពអាស្រ័យនូវកម្លាំងនេះ ទើបប្តេជ្ញានូវការអស់ទៅនៃអាសវៈទាំងឡាយ ថាអាសវៈទាំងឡាយរបស់អាត្មាអញអស់ហើយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត សតិប្បដ្ឋាន ៤ ដែលភិក្ខុជាព្រះខីណាស្រពបានចម្រើនអប់រំល្អហើយ ម្នាលអាវុសោទាំងឡាយ ក៏សតិប្បដ្ឋាន ៤ ដែលភិក្ខុជាព្រះខីណាស្រព បានចម្រើនអប់រំល្អនេះឯងចាត់ជាកម្លាំងរបស់ភិក្ខុ ជាព្រះខីណាស្រព ព្រោះភិក្ខុជាព្រះខីណាស្រព អាស្រ័យនូវកម្លាំងនេះ ទើបប្តេជ្ញានូវការអស់ទៅ នៃអាសវៈទាំងឡាយថា

អាសវៈទាំងឡាយរបស់អាត្មាអញអស់ហើយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ឥន្ទ្រិយ ៥ ដែលភិក្ខុជាព្រះខីណាស្រព បានចម្រើនអប់រំល្អហើយ ម្នាលអាវុសោទាំងឡាយ ក៏ឥន្ទ្រិយ ៥ ដែលភិក្ខុជាព្រះខីណាស្រពបានចម្រើនអប់រំល្អនេះឯង ចាត់ជាកម្លាំងរបស់ភិក្ខុជាព្រះខីណាស្រព ព្រោះភិក្ខុជាព្រះខីណាស្រពអាស្រ័យនូវកម្លាំងយ៉ាងនេះ ទើបប្តេជ្ញានូវការអស់ទៅនៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយរបស់អាត្មាអញអស់ហើយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ពោជ្ឈង្គទាំង ៧ ដែលភិក្ខុជាព្រះខីណាស្រព បានចម្រើនអប់រំល្អហើយ ម្នាលអាវុសោទាំងឡាយ ពោជ្ឈង្គ ៧ ដែលភិក្ខុជាព្រះខីណាស្រពបានចម្រើនអប់រំល្អនេះឯង ចាត់ជាកម្លាំងរបស់ភិក្ខុជាព្រះខីណាស្រព ព្រោះភិក្ខុជាព្រះខីណាស្រព អាស្រ័យនូវកម្លាំងនេះ ទើបប្តេជ្ញានូវការអស់ទៅ នៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយរបស់អាត្មាអញអស់ហើយ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដែលភិក្ខុជាព្រះខីណាស្រព បានចម្រើនអប់រំល្អហើយ ម្នាលអាវុសោទាំងឡាយ ក៏មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដែលភិក្ខុជាព្រះខីណាស្រព បានចម្រើនអប់រំល្អនេះឯង ចាត់ជាកម្លាំងរបស់ភិក្ខុជាព្រះខីណា-ស្រព ព្រោះភិក្ខុជាព្រះខីណាស្រព អាស្រ័យនូវកម្លាំងនេះ ទើបប្តេជ្ញាច្បាស់នូវការអស់ទៅនៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយរបស់អាត្មាអញអស់ហើយ ១ ។ ធម៌ទាំង ៧ នេះ គួរធ្វើឲ្យជាក់ច្បាស់ ។ ធម៌ទាំង ៧០ នេះ ជាធម៌ពិត ធម៌មែន ធម៌ទៀងទាត់ មិនប្រែប្រួលជាយ៉ាងដទៃឡើយ ដែលព្រះ

តថាគតបានត្រាស់ដឹងហើយដោយប្រពៃ ដោយប្រការដូច្នេះ ។

## បឋមភាណវារៈ ចប់

[ ៣១៤ ] ធម៌ ៨ មានឧបការៈច្រើន ធម៌ ៨ គួរចម្រើន ធម៌ ៨ គួរកំណត់ដឹង ធម៌ ៨ គួរលះបង់ ធម៌ ៨ ជាចំណែកនៃសេចក្ដីវិនាស ធម៌ ៨ ជាចំណែកវិសេស ធម៌ ៨ ត្រាស់ដឹងបានដោយក្រ ធម៌ ៨ គួរឲ្យកើតឡើង ធម៌ ៨ គួរដឹងច្បាស់ ធម៌ ៨ គួរធ្វើឲ្យជាក់ច្បាស់ ។

[ ៣១៥ ] ធម៌ ៨ មានឧបការៈច្រើន តើដូចម្ដេចខ្លះ ។ ហេតុ ៨ ប្រការ បច្ច័យ ៨ ប្រការ រមែងប្រព្រឹត្តទៅ ដើម្បីបាននូវបញ្ញាជាខាងដើមនៃមគ្គព្រហ្មចារ្យដែលខ្លួនមិនទាន់បាន ដើម្បីធ្វើបញ្ញាដែលខ្លួនបានស៊ប់ហើយ ឲ្យជាកិយ្យោភាព ធំទូលាយ ចម្រើនបរិបូណ៌ឡើង ហេតុ ៨ ប្រការ បច្ច័យ ៨ ប្រការនោះ តើដូចម្ដេច ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានចូលទៅអាស្រ័យនៅនឹងគ្រូ ឬសព្រហ្មចារីបុគ្គលណាមួយ គួរជាទីគោរព បានតម្កល់ចំពោះនូវហិរិ និងឱត្តប្បៈដ៏មានកម្លាំងផង នូវសេចក្ដីស្រឡាញ់ និងសេចក្ដីគោរពផង ក្នុងគ្រូ ឬសព្រហ្មចារីបុគ្គល នេះជាហេតុទី ១ បច្ច័យទី ១ រមែងប្រព្រឹត្តទៅដើម្បីបាននូវបញ្ញា ជាខាងដើមនៃមគ្គព្រហ្មចារ្យ ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើបញ្ញាដែលខ្លួនបានស៊ប់ហើយ ឲ្យជាកិយ្យោភាព ធំទូលាយ ចម្រើនបរិបូណ៌ឡើង ។ លុះភិក្ខុនោះ ចូលទៅអាស្រ័យនៅនឹងគ្រូនោះ ឬសព្រហ្មចារីបុគ្គលណាមួយ ដែលគួរជាទីគោរពនោះ ហើយតម្កល់ចំពោះនូវ

ហិរិ និងឱត្តប្បៈដ៏មានកម្លាំងផង នូវសេចក្តីស្រឡាញ់ និងសេចក្តីគោរពផង ក្នុងគ្រូ ឬសព្រហ្មចារីបុគ្គល បានចូលទៅសាកសួរពិគ្រោះនឹងគ្រូ ឬសព្រហ្មចារី បុគ្គលទាំងនោះ តាមកាលដ៏គួរថា បពិត្រលោកដ៏ចម្រើន វត្ថុនេះដូចម្តេច វត្ថុនេះមានប្រយោជន៍ដូចម្តេច គ្រូ ឬសព្រហ្មចារីបុគ្គលដ៏មានអាយុទាំងនោះ បានបើកបង្ហាញសេចក្តីដែលកំបាំងផង បានធ្វើសេចក្តីដែលជ្រៅឲ្យរាក់ផង បានបន្ទោបង់នូវសេចក្តីសង្ស័យក្នុងធម៌ទាំងឡាយដែលគួរសង្ស័យដ៏ច្រើនផង ដល់ភិក្ខុនោះ នេះជាហេតុទី ២ បច្ច័យទី ២ រមែងប្រព្រឹត្តទៅ ដើម្បីបាននូវបញ្ញាជាខាងដើមនៃមគ្គព្រហ្មចារ្យ ដែលខ្លួនមិនទាន់បាន ដើម្បីធ្វើបញ្ញាដែលខ្លួនបានស៊ប់ហើយ ឲ្យជាកិយ្យោភាព ធំទូលាយ ចម្រើនបរិបូណ៌ឡើង ។ លុះភិក្ខុនោះបានស្តាប់ធម៌នោះហើយ ក៏បានបរិបូណ៌ដោយសេចក្តីស្ងប់ស្ងាត់ពីរប្រការ គឺស្ងាត់កាយ ១ ស្ងាត់ចិត្ត ១ នេះជាហេតុទី ៣ បច្ច័យទី ៣ រមែងប្រព្រឹត្តទៅ ដើម្បីបាននូវបញ្ញាជាខាងដើមនៃមគ្គព្រហ្មចារ្យដែលខ្លួនមិនទាន់បាន ដើម្បីធ្វើបញ្ញាដែលខ្លួនបានស៊ប់ហើយ ឲ្យជាកិយ្យោភាព ធំទូលាយ ចម្រើនបរិបូណ៌ឡើង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរសីល បរិបូណ៌ដោយអាចារៈ និងគោចរៈ ជាអ្នកឃើញភ័យក្នុងទោសសូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ នេះជាហេតុទី ៤ បច្ច័យទី ៤ រមែងប្រព្រឹត្តទៅ ដើម្បីបាននូវបញ្ញាជាខាងដើម នៃមគ្គព្រហ្មចារ្យដែលមិនទាន់បាន ដើម្បីធ្វើបញ្ញាដែលខ្លួនបានស៊ប់ហើយ ឲ្យជាកិយ្យោភាព ធំទូលាយ ចម្រើនបរិបូណ៌ឡើង ។ ម្នាលអាវុសោទាំងឡាយ

មួយទៀត ភិក្ខុជាពហុស្សូត ចេះចាំនូវពុទ្ធវចនៈដែលខ្លួនបានស្តាប់ហើយ សន្សំទុកនូវពុទ្ធវចនៈដែលខ្លួនបានស្តាប់ហើយ ធម៌ទាំងឡាយណា ពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ប្រកាសនូវព្រហ្មចារ្យ ព្រមទាំងអត្ថ ទាំងព្យញ្ជនៈដ៏បរិសុទ្ធបរិបូណ៌ទាំងអស់ ធម៌ដែលមានសភាពដូច្នោះ ភិក្ខុនោះឯងក៏បានស្តាប់ច្រើន បានចាំទុក ចាំរត់មាត់ ចាំជាប់ក្នុងចិត្ត បានចាក់ធ្លុះល្អដោយទិដ្ឋិ នេះជាហេតុទី ៥ បច្ច័យទី ៥ រមែងប្រព្រឹត្តទៅ ដើម្បីបាននូវបញ្ញាជាខាងដើមនៃមគ្គព្រហ្មចារ្យដែលមិនទាន់បាន ដើម្បីធ្វើបញ្ញាដែលខ្លួនបានសិប់ហើយ ឲ្យជាកិយ្យោភាព ធំទូលាយ ចម្រើនបរិបូណ៌ឡើង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុអ្នកមានសេចក្តីព្យាយាមប្រារព្ធ ដើម្បីលះបង់នូវធម៌ទាំងឡាយជាអកុសល ដើម្បីញុំាងធម៌ទាំងឡាយជាកុសលឲ្យកើតឡើង ជាអ្នកមានកម្លាំង មានសេចក្តីប្រឹងប្រែងខ្ជាប់ខ្ជួន មិនដាក់ចុះនូវធុរៈក្នុងធម៌ទាំងឡាយជាកុសល នេះជាហេតុទី ៦ បច្ច័យទី ៦ រមែងប្រព្រឹត្តទៅ ដើម្បីបាននូវបញ្ញាជាខាងដើមនៃមគ្គព្រហ្មចារ្យដែលមិនទាន់បាន ដើម្បីធ្វើបញ្ញាដែលខ្លួនបានសិប់ហើយ ឲ្យជាកិយ្យោភាព ធំទូលាយ ចម្រើន បរិបូណ៌ឡើង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានស្មារតី ប្រកបដោយស្មារតី និងភាពជាអ្នកមានប្រាជ្ញាចាស់ក្លាដ៏ខ្ពង់ខ្ពស់ នឹកឃើញនូវអំពើដែលខ្លួនធ្វើរួចយូរហើយផង នូវសម្តីដែលខ្លួននិយាយរួចយូរហើយផង នេះជាហេតុទី ៧ បច្ច័យទី ៧ ប្រព្រឹត្តទៅ ដើម្បីបាននូវបញ្ញាជាខាងដើមនៃមគ្គព្រហ្មចារ្យដែលមិនទាន់បាន ដើម្បីធ្វើបញ្ញាដែលខ្លួនបានសិប់ហើយ ឲ្យជាកិយ្យោភាព

ធំទូលាយ ចម្រើនបរិបូណ៌ឡើង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកពិចារណាឃើញនូវទីកើតទីរលត់ក្នុងឧបាទានក្ខន្ធទាំង ៥ ថា រូបដូច្នេះ ហេតុជាទីកើតរបស់រូបដូច្នេះ ការរលត់ទៅនៃរូបដូច្នេះ វេទនាដូច្នេះ ហេតុជាទីកើតរបស់វេទនាដូច្នេះ ការរលត់ទៅនៃវេទនាដូច្នេះ សញ្ញាដូច្នេះ ហេតុជាទីកើតរបស់សញ្ញាដូច្នេះ ការរលត់ទៅនៃសញ្ញាដូច្នេះ សង្ខារទាំងឡាយដូច្នេះ ហេតុជាទីកើតរបស់សង្ខារទាំងឡាយដូច្នេះ ការរលត់ទៅនៃសង្ខារទាំងឡាយដូច្នេះ វិញ្ញាណដូច្នេះ ហេតុជាទីកើតនៃវិញ្ញាណដូច្នេះ ការរលត់ទៅនៃវិញ្ញាណដូច្នេះ នេះជាហេតុទី ៨ បច្ច័យទី ៨ រមែងប្រព្រឹត្តទៅ ដើម្បីបាននូវបញ្ញាជាខាងដើមនៃមគ្គព្រហ្មចារ្យដែលមិនទាន់បាន ដើម្បីធ្វើបញ្ញាដែលខ្លួនបានស៊ប់ហើយ ឲ្យជាភិយ្យោភាព ធំទូលាយ ចម្រើនបរិបូណ៌ឡើង ។ ធម៌ទាំង ៨ នេះ មានឧបការៈច្រើន ។

[ ៣១៦ ] ធម៌ ៨ ដែលគួរចម្រើន តើដូចម្តេចខ្លះ ។ ផ្លូវដ៏ប្រសើរប្រកបដោយអង្គ ៨ គឺសេចក្តីឃើញត្រូវ ១ សេចក្តីត្រិះរិះត្រូវ ១ និយាយត្រូវ ១ ធ្វើការងារត្រូវ ១ ចិញ្ចឹមជីវិតត្រូវ ១ ព្យាយាមត្រូវ ១ ការរឭកត្រូវ ១ ការតាំងចិត្តត្រូវ ១ ។ ធម៌ទាំង ៨ នេះ គួរចម្រើន ។

[ ៣១៧ ] ធម៌ ៨ ដែលគួរកំណត់ដឹង តើដូចម្តេចខ្លះ ។ លោកធម៌ ៨ ប្រការ គឺមានលាភ ១ ឥតលាភ ១ មានយស ១ ឥតយស ១ សេចក្តីនិន្ទា ១ សេចក្តីសរសើរ ១ សុខ ១ ទុក្ខ ១ ។ ធម៌ទាំង ៨ នេះ គួរកំណត់ដឹង ។

[ ៣១៨ ] ធម៌ ៨ ដែលគួរលះបង់ តើដូចម្តេចខ្លះ ។ សភាពដែល

ខុស ៨ យ៉ាង គឺសេចក្តីឃើញខុស ១ សេចក្តីត្រិះរិះខុស ១ ពោលពាក្យខុស ១ ធ្វើការងារខុស ១ ចិញ្ចឹមជីវិតខុស ១ ព្យាយាមខុស ១ ការរឭកខុស ១ ការតាំងចិត្តនឹងខុស ១ ។ ធម៌ទាំង ៨ នេះ គួរលះបង់ ។

[ ៣១៩ ] ធម៌ ៨ ជាចំណែកនៃសេចក្តីវិនាស តើដូចម្តេចខ្លះ ។ កុសីតវត្ថុ ( ហេតុនៃបុគ្គលខ្ជិល ) ៨ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកត្រូវធ្វើការងារ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញនឹងត្រូវធ្វើការងារហ្នឹងឯង តែកាលបើអាត្មាអញធ្វើការងារទៅ កាយនឹងលំបាក បើដូច្នោះ មានតែអាត្មាអញដេកសិន ។ ភិក្ខុនោះ ក៏ដេកទៅ មិនបានប្រារព្ធសេចក្តីព្យាយាម ដើម្បីដល់នូវគុណធម៌ដែលខ្លួនមិនទាន់ដល់ ដើម្បីត្រាស់ដឹងនូវគុណធម៌ដែលខ្លួនមិនទាន់ត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ នេះជាកុសីតវត្ថុទី ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ការងារដែលភិក្ខុនោះធ្វើរួចហើយ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញធ្វើការងាររួចហើយ តែថា កាលដែលអាត្មាអញធ្វើការងារនុ៎ះឯង កាយក៏លំបាក បើដូច្នោះ មានតែអាត្មាអញដេកសិន ។ ភិក្ខុក៏ដេកទៅ មិនបានប្រារព្ធសេចក្តីព្យាយាម ។បេ។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ នេះជាកុសីតវត្ថុទី ២ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុត្រូវដើរទៅកាន់ផ្លូវ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញត្រូវដើរទៅកាន់ផ្លូវហ្នឹងឯង តែកាលបើអាត្មាអញដើរទៅកាន់ផ្លូវនុ៎ះ កាយនឹងលំបាក បើដូច្នោះ មានតែអាត្មាអញដេកសិន ។ ភិក្ខុ

នោះ ក៏ដេកទៅ មិនបានប្រុងប្រៀបសេចក្តីព្យាយាម ។បេ។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះជាកុសីតវត្ថុទី ៣ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុបានដើរទៅកាន់ផ្លូវរួចហើយ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញបានដើរទៅកាន់ផ្លូវរួចហើយ តែកាលដែលអាត្មាអញដើរទៅកាន់ផ្លូវនុ៎ះឯង កាយក៏លំបាក បើដូច្នោះ មានតែអាត្មាអញដេកសិន ។ ភិក្ខុនោះ ក៏ដេកទៅ មិនបានប្រុងប្រៀបសេចក្តីព្យាយាម ។បេ។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះជាកុសីតវត្ថុទី ៤ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុកាលដើរទៅបិណ្ឌបាតក្នុងស្រុក ឬនិគម មិនបានភោជនសៅហ្មង ឬថ្លៃថ្លា ល្មមនឹងឆ្អែតគ្រប់គ្រាន់បាន ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញ កាលដើរទៅបិណ្ឌបាតក្នុងស្រុក ឬនិគម មិនបានភោជនសៅហ្មង ឬថ្លៃថ្លា ល្មមនឹងឆ្អែតគ្រប់គ្រាន់បានឡើយ កាយរបស់អាត្មាអញនោះទៀយហាត់ ជាកាយមិនគួរនឹងប្រកបការងារបាន បើដូច្នោះ មានតែអាត្មាអញដេកសិន ។ ភិក្ខុនោះ ក៏ដេកទៅ មិនផ្តួចផ្តើមសេចក្តីព្យាយាម ។បេ។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះជាកុសីតវត្ថុទី ៥ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុដើរទៅបិណ្ឌបាតក្នុងស្រុក ឬនិគម ក៏បានភោជនសៅហ្មង ឬថ្លៃថ្លា ល្មមនឹងឆ្អែតគ្រប់គ្រាន់បាន ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញកាលដើរទៅបិណ្ឌបាតក្នុងស្រុក ឬនិគម បានភោជនសៅហ្មង ឬថ្លៃថ្លា ល្មមនឹងឆ្អែតគ្រប់គ្រាន់ហើយ កាយរបស់អាត្មាអញនោះ

ធ្ងន់ ជាកាយមិនគួរនឹងប្រកបការងារបាន ទំនងដូចជាសណ្តែករាជមាសដែលត្រូវទឹកហើយ បើដូច្នោះ មានតែអាត្មាអញដេកសិន ។ ភិក្ខុនោះ ក៏ដេកទៅ មិនបានផ្តួចផ្តើមសេចក្តីព្យាយាម ។បេ។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះជាកុសីតវត្ថុទី ៦ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកកើតអាពាធបន្តិចបន្តួចសោះទេ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញជាអ្នកទើបនឹងកើតអាពាធនេះ មានប្រមាណតិចទេ តែជាអាពាធគួរនឹងសម្ងំដេក បើដូច្នោះ មានតែអាត្មាអញដេកសិន ។ ភិក្ខុនោះក៏ដេកទៅ ។បេ។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះជាកុសីតវត្ថុទី ៧ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុទើបតែនឹងបានជាសះស្បើយពីជំងឺថ្មីៗ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញបានជាសះស្បើយពីជំងឺថ្មីៗ ហើយ ឯកាយរបស់អាត្មាអញក៏នៅទុព្វលភាព មិនគួរប្រកបការងារបាននៅឡើយ ណ្ហើយចុះ អាត្មាអញដេកសិន ។ ភិក្ខុនោះក៏ដេកទៅ មិនបានប្រុងប្រៀបសេចក្តីព្យាយាម ដើម្បីបានដល់នូវគុណធម៌ ដែលខ្លួនមិនទាន់បានដល់ ដើម្បីត្រាស់ដឹងនូវគុណធម៌ដែលខ្លួនមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះជាកុសីតវត្ថុទី ៨ ។ ធម៌ទាំង ៨ នេះ ជាចំណែកខាងសេចក្តីវិនាស ។

[ ៣២០ ] ធម៌ ៨ ជាចំណែកវិសេស តើដូចម្តេចខ្លះ ។ អារព្ភវត្ថុ ( ហេតុនៃការប្រារព្ធសេចក្តីព្យាយាម ) ៨ ម្នាលអាវុសោទាំងឡាយ ភិក្ខុ

ក្នុងសាសនានេះ ជាអ្នកត្រូវធ្វើការងារ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញនឹងត្រូវធ្វើការហ្នឹងឯង តែកាលបើអាត្មាអញធ្វើការងារទៅហើយ មិនងាយនឹងធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធទាំងឡាយបានឡើយ បើដូច្នោះ មានតែអាត្មាអញនឹងតាំងផ្តើមសេចក្តីព្យាយាម ដើម្បីដល់នូវគុណធម៌ដែលអាត្មាអញមិនទាន់បានដល់ ដើម្បីត្រាស់ដឹងនូវគុណធម៌ ដែលអាត្មាអញមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលអាត្មាអញមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ភិក្ខុនោះ ក៏តាំងផ្តើមសេចក្តីព្យាយាម ដើម្បីដល់នូវគុណធម៌ដែលខ្លួនមិនទាន់បានដល់ ដើម្បីត្រាស់ដឹងនូវគុណធម៌ ដែលខ្លួនមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះជាអារព្ភវត្ថុទី ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ការងារភិក្ខុបានធ្វើរួចហើយ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញបានធ្វើការងាររួចហើយ ឯអាត្មាអញកាលដែលធ្វើការងារទុំះឯង មិនអាចធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយបានឡើយ បើដូច្នោះ មានតែអាត្មាអញ តាំងផ្តើមសេចក្តីព្យាយាម ដើម្បីដល់នូវគុណធម៌ដែលអាត្មាអញមិនទាន់បានដល់ ដើម្បីត្រាស់ដឹងនូវគុណធម៌ ដែលអាត្មាអញមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលអាត្មាអញមិនទាន់បានធ្វើឲ្យជាក់ច្បាស ។បេ។ នេះជាអារព្ភវត្ថុទី ២ ។ ម្នាលអាវុសោទាំង-ឡាយ មួយទៀត ភិក្ខុត្រូវដើរទៅកាន់ផ្លូវ ភិក្ខុនោះមានគំនិតយ៉ាងនេះថា ផ្លូវហ្នឹងឯង អាត្មាអញនឹងត្រូវដើរទៅ តែកាលបើអាត្មាអញដើរទៅកាន់ផ្លូវ មិន

ឆាយនឹងធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយបានទេ បើដូច្នោះ មានតែអាត្មាអញតាំងផ្ដើមសេចក្ដីព្យាយាម ដើម្បីដល់នូវគុណធម៌ដែលអាត្មាអញមិនទាន់បានដល់ ដើម្បីត្រាស់ដឹងនូវគុណធម៌ ដែលអាត្មាអញមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលអាត្មាអញមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ភិក្ខុនោះ តាំងផ្ដើមសេចក្ដីព្យាយាម ដើម្បីដល់នូវគុណធម៌ដែលខ្លួនមិនទាន់បានដល់ ដើម្បីត្រាស់ដឹងនូវគុណធម៌ ដែលខ្លួនមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះជាអារព្ភវត្ថុទី ៣ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុទៅកាន់ផ្លូវរួចហើយ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញបានដើរទៅកាន់ផ្លូវរួចហើយ ឯអាត្មាអញកាលដែលដើរទៅកាន់ផ្លូវនុ៎ះឯង មិនអាចធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធទាំងឡាយបានឡើយ បើដូច្នោះ មានតែអាត្មាអញតាំងផ្ដើមសេចក្ដីព្យាយាម ដើម្បីដល់នូវគុណធម៌ដែលអាត្មាអញមិនទាន់បានដល់ ដើម្បីត្រាស់ដឹងនូវគុណធម៌ដែលអាត្មាអញមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ដែលអាត្មាអញមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ភិក្ខុនោះក៏តាំងធ្វើសេចក្ដីព្យាយាម ដើម្បីដល់នូវគុណធម៌ដែលខ្លួនមិនទាន់បានដល់ ដើម្បីត្រាស់ដឹងនូវគុណធម៌ ដែលខ្លួនមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ នេះជាអារព្ភវត្ថុទី ៤ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុកាលដើរទៅបិណ្ឌបាតក្នុងស្រុក ឬនិគម មិនបានភោជនសៅហ្មង ឬថ្លៃថ្លា

ល្មមនឹងឆ្អែតគ្រប់គ្រាន់បាន ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញកាលដើរទៅបិណ្ឌបាតក្នុងស្រុក ឬនិគម មិនបានភោជនសៅហ្មង ឬថ្លៃថ្លា ល្មមនឹងឆ្អែតគ្រប់គ្រាន់ កាយរបស់អាត្មាអញនោះស្រាល ជាកាយគួរប្រកបការងារបាន បើដូច្នោះ អាត្មាអញតាំងផ្តើមសេចក្តីព្យាយាម ។បេ។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលអាត្មាអញមិនទាន់ធ្វើឲ្យជាក់ច្បាស់ ។ ភិក្ខុនោះក៏តាំងផ្តើមសេចក្តីព្យាយាម ដើម្បីដល់នូវគុណធម៌ដែលខ្លួនមិនទាន់បានដល់ ដើម្បីត្រាស់ដឹងនូវគុណធម៌ ដែលខ្លួនមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះជាអារព្ភវត្ថុទី ៥ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុកាលដើរទៅបិណ្ឌបាតក្នុងស្រុក ឬនិគម មិនបានភោជនសៅហ្មង ឬថ្លៃថ្លា ល្មមនឹងឆ្អែតគ្រប់គ្រាន់បាន ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញកាលដើរទៅបិណ្ឌបាតក្នុងស្រុក ឬនិគម បានភោជនសៅហ្មង ឬថ្លៃថ្លា ល្មមនឹងឆ្អែតគ្រប់គ្រាន់បានហើយ កាយរបស់អាត្មាអញនោះ មានកម្លាំងគួរនឹងប្រកបការងារបាន បើដូច្នោះ មានតែអាត្មាអញតាំងផ្តើមសេចក្តីព្យាយាម ដើម្បីដល់នូវគុណធម៌ ដែលអាត្មាអញមិនទាន់បានដល់ ដើម្បីត្រាស់ដឹងនូវគុណធម៌ ដែលអាត្មាអញមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលអាត្មាអញមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ភិក្ខុនោះក៏តាំងផ្តើមសេចក្តីព្យាយាម ដើម្បីដល់នូវគុណធម៌ ដែលខ្លួនមិនទាន់បានដល់ ដើម្បីត្រាស់ដឹងនូវគុណធម៌ ដែលខ្លួនមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់

នេះជាអារព្ភវត្ថុទី ៦ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកទើបនឹងកើតអាពាធបន្តិចបន្តួចទេ ភិក្ខុនោះ មានគំនិតយ៉ាងនេះថា អាត្មាអញកើតអាពាធបន្តិចបន្តួចហើយ តែអាពាធរបស់អាត្មាអញគង់តែនឹងចម្រើនឡើងដោយហេតុនេះមិនខាន បើដូច្នោះ មានតែអាត្មាអញតាំងផ្តើមសេចក្តីព្យាយាមដើម្បីដល់នូវគុណធម៌ ដែលអាត្មាអញមិនទាន់បានដល់ ដើម្បីត្រាស់ដឹងនូវគុណធម៌ ដែលអាត្មាអញមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលអាត្មាអញមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ភិក្ខុនោះ ក៏តាំងផ្តើមសេចក្តីព្យាយាម ដើម្បីដល់នូវគុណធម៌ ដែលខ្លួនមិនទាន់បានដល់ ។បេ។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះជាអារព្ភវត្ថុទី ៧ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុទើបតែនឹងបានជាសះស្បើយពីជំងឺថ្មីៗ ភិក្ខុនោះមានគំនិតយ៉ាងនេះថា អាត្មាអញបានជាសះស្បើយពីជំងឺថ្មីៗ ហើយ អាពាធអាត្មាអញសមជាត្រឡប់កម្រើកឡើងវិញ ( លាប់ ) ដោយហេតុនោះមិនខាន បើដូច្នោះ មានតែអាត្មាអញតាំងផ្តើមសេចក្តីព្យាយាម ដើម្បីដល់នូវគុណធម៌ ដែលអាត្មាអញមិនទាន់បានដល់ ដើម្បីត្រាស់ដឹងនូវគុណធម៌ ដែលអាត្មាអញមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ ដែលអាត្មាអញមិនទាន់បានធ្វើឲ្យជាក់ច្បាស់ ។ ភិក្ខុនោះក៏តាំងផ្តើមសេចក្តីព្យាយាម ដើម្បីដល់នូវគុណធម៌ដែលខ្លួនមិនទាន់បានដល់ ដើម្បីត្រាស់ដឹងនូវគុណធម៌ដែលខ្លួនមិនទាន់បានត្រាស់ដឹង ដើម្បីធ្វើឲ្យជាក់ច្បាស់នូវគុណធម៌ដែលខ្លួនមិនទាន់បានធ្វើឲ្យជាក់ច្បាស់ នេះជាអារព្ភវត្ថុ

ទី ៨ ។ ធម៌ទាំង ៨ នេះ ជាចំណែកវិសេស ។

[ ៣២១ ] ធម៌ ៨ ដែលយល់បានដោយក្រ តើដូចម្ដេចខ្លះ ។ ខណៈមិនគួរ សម័យមិនគួរ ដើម្បីទៅប្រព្រឹត្តព្រហ្មចារ្យ មាន ៨ យ៉ាង ម្នាលអាវុសោទាំងឡាយ ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ត្រាស់ដឹងហើយក្នុងលោកនេះ ទាំងបានសម្ដែងធម៌ដែលប្រព្រឹត្តទៅដើម្បីសេចក្ដីស្ងប់រម្ងាប់កិលេស ជាធម៌ប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ជាផ្លូវធ្វើដំណើរទៅកាន់សេចក្ដីត្រាស់ដឹង ជាធម៌ដែលព្រះសុគតទ្រង់ប្រកាសហើយ តែបុគ្គលនេះឯង ត្រឡប់ជាទៅកើតក្នុងនរកវិញ នេះឈ្មោះថា ខណៈមិនគួរ សម័យមិនគួរ ដើម្បីនៅប្រព្រឹត្តព្រហ្មចារ្យទី ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ត្រាស់ហើយក្នុងលោក ទាំងបានសម្ដែងធម៌ដែលប្រព្រឹត្តទៅដើម្បីសេចក្ដីស្ងប់រម្ងាប់កិលេស ជាធម៌ប្រព្រឹត្តទៅដើម្បីបានព្រះនិព្វាន ជាផ្លូវធ្វើដំណើរទៅកាន់សេចក្ដីត្រាស់ដឹង ជាធម៌ដែលព្រះសុគតទ្រង់ប្រកាសហើយ តែបុគ្គលនេះឯង ត្រឡប់ជាទៅកើតក្នុងកំណើតតិរច្ឆានវិញ នេះឈ្មោះថា ខណៈមិនគួរ សម័យមិនគួរ ដើម្បីនៅប្រព្រឹត្តព្រហ្មចារ្យទី ២ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ត្រាស់ឡើងហើយក្នុងលោក ទាំងបានសម្ដែងធម៌ដែលប្រព្រឹត្តទៅដើម្បីសេចក្ដីស្ងប់រម្ងាប់កិលេស ជាធម៌ប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ជាផ្លូវធ្វើដំណើរទៅកាន់សេចក្ដីត្រាស់ដឹង ជាធម៌ដែលព្រះសុគតទ្រង់ប្រកាសហើយ តែបុគ្គលនេះឯង ត្រឡប់ជាទៅកើតក្នុងកំណើតប្រេតវិស័យវិញ នេះឈ្មោះថា ខណៈមិនគួរ

សម័យមិនគួរ ប្រព្រឹត្តនូវព្រហ្មចារ្យទី ៣ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ត្រាស់ឡើងហើយក្នុងលោក ទាំងបានសម្តែងធម៌ដែលប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់កិលេស ។បេ។ តែបុគ្គលនេះឯងត្រឡប់ជាទៅកើតក្នុងពួកទេវតាណាមួយ ដែលមានអាយុវែងនេះឈ្មោះថា ខណៈមិនគួរ សម័យមិនគួរ ដើម្បីនៅប្រព្រឹត្តព្រហ្មចារ្យទី ៤ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ត្រាស់ឡើងហើយក្នុងលោក ទាំងបានសម្តែងធម៌ ។បេ។ តែបុគ្គលនេះឯងត្រឡប់ជាទៅកើត ក្នុងពួកមិលក្ខជនដែលក្រ ល្ងង់ខ្លៅ ក្នុងបច្ចន្តជនបទ ដែលជាប្រទេសឥតមានគតិរបស់ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកាឡើយ នេះឈ្មោះថា ខណៈមិនគួរ សម័យមិនគួរ ដើម្បីនៅប្រព្រឹត្តព្រហ្មចារ្យទី ៥ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ ត្រាស់ឡើងហើយក្នុងលោក ។បេ។ ឯបុគ្គលនេះត្រឡប់មកកើតក្នុងមជ្ឈិមជនបទដែរ តែបុគ្គលនេះជាមិច្ឆាទិដ្ឋិ មានសេចក្តីឃើញខុសថា ទានដែលបុគ្គលឲ្យហើយគ្មានផលការបូជាធំគ្មានផល ការបូជាតូចគ្មានផល ផលវិបាករបស់កម្មទាំងឡាយដែលបុគ្គលធ្វើល្អធ្វើអាក្រក់មិនមាន លោកនេះមិនមាន លោកខាងមុខមិនមាន មាតាមិនមាន បិតាមិនមាន សត្វជាឱបបាតិកៈមិនមាន ពួកសមណព្រាហ្មណ៍ក្នុងលោក ដែលជាអ្នកដល់នូវសេចក្តីស្ងប់រម្ងាប់ ប្រតិបត្តិត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខដោយប្រាជ្ញារបស់ខ្លួន ហើយទើបញុំាងអ្នកដទៃឲ្យដឹងផង ក៏មិនមាន ដូច្នេះ នេះឈ្មោះថា ខណៈមិនគួរ សម័យមិន

គួរ ដើម្បីនៅប្រព្រឹត្តព្រហ្មចារ្យទី ៦ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ បានត្រាស់ឡើងហើយក្នុងលោក ។បេ។ ឯបុគ្គលនេះ បានត្រឡប់មកកើតក្នុងមជ្ឈិមជនបទដែរ តែបុគ្គលនោះ ជាអ្នកឥតប្រាជ្ញា ជាមនុស្សល្ងង់ខ្លៅ ជាមនុស្សគ ជាមនុស្សមិនអាច ដើម្បីដឹងសេចក្តីអធិប្បាយរបស់ពាក្យ ដែលគេនិយាយល្អ ឬនិយាយអាក្រក់បានឡើយ នេះឈ្មោះថា ខណៈមិនគួរ សម័យមិនគួរ ដើម្បីនៅប្រព្រឹត្តព្រហ្មចារ្យទី ៧ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ព្រះតថាគតអរហន្តសម្មា-សម្ពុទ្ធ មិនបានត្រាស់ឡើងហើយក្នុងលោក ទាំងមិនបានសម្តែងធម៌ ដែលប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់កិលេស ប្រព្រឹត្តទៅដើម្បីបានទូវព្រះនិព្វាន ជាផ្លូវធ្វើដំណើរទៅកាន់សេចក្តីត្រាស់ដឹង ជាធម៌ដែលព្រះសុគតទ្រង់ប្រកាសហើយ បុគ្គលនេះឯង បានត្រឡប់មកកើតក្នុងមជ្ឈិមជនបទហើយៗ ជាអ្នកមានប្រាជ្ញា មិនល្ងង់ មិនមែនជាមនុស្សគ ជាអ្នកអាចដើម្បីដឹងសេចក្តីអធិប្បាយរបស់ពាក្យគេនិយាយល្អ ឬអាក្រក់បាន នេះឈ្មោះថា ខណៈមិនគួរ សម័យមិនគួរ ដើម្បីនៅប្រព្រឹត្តព្រហ្មចារ្យទី ៨ ។ ធម៌ទាំង ៨ នេះ យល់បានដោយក្រ ។

[ ៣២២ ] ធម៌ ៨ ដែលគួរឲ្យកើតឡើង តើដូចម្តេចខ្លះ ។ សេចក្តីត្រិះរិះរបស់មហាបុរស ៨ យ៉ាង ( ត្រិះរិះថា ) នេះជាធម៌របស់បុគ្គលអ្នកមានសេចក្តីប្រាថ្នាតិច នេះមិនមែនជាធម៌របស់បុគ្គលអ្នកមានសេចក្តីប្រាថ្នាច្រើន ១ នេះជាធម៌របស់បុគ្គលអ្នកមានសេចក្តីសន្តោស ( ក្នុងបច្ច័យ ៤ )

នេះមិនមែនជាធម៌របស់បុគ្គលគ្មានសេចក្តីសន្តោស ១ នេះជាធម៌របស់បុគ្គលអ្នកមានសេចក្តីស្ងប់ស្ងាត់ នេះមិនមែនជាធម៌របស់អ្នកត្រេកអរក្នុងពួកក្រុម ១ នេះជាធម៌របស់បុគ្គលអ្នកប្រារព្ធសេចក្តីព្យាយាម មិនមែនជាធម៌របស់បុគ្គលអ្នកខ្ជិលច្រអូស ១ នេះជាធម៌របស់បុគ្គលអ្នកមានស្មារតីខ្ជាប់ខ្ជួន នេះមិនមែនជាធម៌របស់បុគ្គលអ្នកភ្លេចស្មារតី ១ នេះជាធម៌របស់បុគ្គលអ្នកមានចិត្តតាំងមាំ នេះមិនមែនជាធម៌របស់បុគ្គលអ្នកមានចិត្តមិនតាំងមាំ ១ នេះជាធម៌របស់បុគ្គលអ្នកមានបញ្ញា នេះមិនមែនជាធម៌របស់បុគ្គលអ្នកឥតបញ្ញា ១ នេះជាធម៌របស់បុគ្គលអ្នកមានសេចក្តីត្រេកអរក្នុងដំណើរមិនយឺតយូរ មានតម្រេកក្នុងដំណើរមិនយឺតយូរ នេះមិនមែនជាធម៌របស់បុគ្គលអ្នកមានសេចក្តីត្រេកអរក្នុងដំណើរយឺតយូរ មានតម្រេកក្នុងដំណើរយឺតយូរ ១ ។ ធម៌ទាំង ៨ នេះ គួរឲ្យកើតឡើង ។

[ ៣២៣ ] ធម៌ ៨ ដែលគួរដឹងច្បាស់ តើដូចម្តេចខ្លះ ។ អភិភាយតនៈ ( ហេតុជាគ្រឿងគ្របសង្កត់នូវធម៌ជាសត្រូវផង នូវអារម្មណ៍ផង ) ៨ យ៉ាង គឺបុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ មានប្រមាណតិច មានពណ៌ល្អ ឬពណ៌អាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ១ ។ បុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ មានប្រមាណច្រើន មានពណ៌ល្អ ឬពណ៌អាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង

អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ២ ។ បុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវអរូបខាងក្នុង ឃើញនូវរូបខាងក្រៅ មានប្រមាណតិច មានពណ៌ល្អ ឬពណ៌អាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ៣ ។ បុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវអរូបខាងក្នុង ឃើញនូវរូបខាងក្រៅ មានប្រមាណច្រើន មានពណ៌ល្អ ឬពណ៌អាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ៤ ។ បុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវអរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបខៀវ មានពណ៌ខៀវ ជាទីចង្អុលប្រាប់ថា នេះមានពណ៌ខៀវ មានពន្លឺខៀវ ប្រៀបដូចជាផ្កាត្រកៀតខៀវ មានពណ៌ខៀវ ជាទីចង្អុលប្រាប់ថា នេះមានពណ៌ខៀវ មានពន្លឺខៀវ ពុំនោះសោត រូបនោះប្រៀបដូចជាសំពត់ ដែលកើតក្នុងក្រុងពារាណសី មានសាច់ម៉ដ្ឋទាំងពីរខាង ហៅថា សំពត់ខៀវ មានពណ៌ខៀវ ជាទីចង្អុលប្រាប់ថា នេះមានពណ៌ខៀវ មានពន្លឺខៀវ យ៉ាងណាមិញ បុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវអរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបខៀវ មានពណ៌ខៀវ ជាទីចង្អុលប្រាប់ថា នេះមានពណ៌ខៀវ មានពន្លឺខៀវ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ ក៏យ៉ាងនោះឯង នេះជាអភិភាយតនៈទី ៥ ។ បុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវអរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបលឿង មានពណ៌លឿង ជាទីចង្អុលប្រាប់ថា

នេះមានពណ៌លឿង មានពន្លឺលឿង ប្រៀបដូចផ្កាកណិការលឿង មានពណ៌លឿង ជាទីចង្អុលប្រាប់ថា នេះមានពណ៌លឿង មានពន្លឺលឿង ពុំនោះសោត រូបនោះប្រៀបដូចជាសំពត់ ដែលកើតក្នុងក្រុងពារាណសី មានសាច់ម៉ដ្ឋទាំងពីរខាង ហៅថា សំពត់លឿង មានពណ៌លឿង ជាទីចង្អុលប្រាប់ថា នេះមានពណ៌លឿង មានពន្លឺលឿង យ៉ាងណាមិញ បុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវអរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបលឿង មានពណ៌លឿង ជាទីចង្អុលប្រាប់ថា នេះមានពណ៌លឿង មានពន្លឺលឿង គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ ក៏យ៉ាងនោះឯង នេះជាអភិភាយតនៈទី ៦ ។ បុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវអរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបក្រហម មានពណ៌ក្រហម ជាទីចង្អុលប្រាប់ថា នេះមានពណ៌ក្រហម មានពន្លឺក្រហម ប្រៀបដូចផ្កាចប្បាក្រហម មានពណ៌ក្រហម ជាទីចង្អុលប្រាប់ថា នេះមានពណ៌ក្រហម មានពន្លឺក្រហម ពុំនោះសោត រូបនោះប្រៀបដូចជាសំពត់ដែលកើតក្នុងក្រុងពារាណសី មានសាច់ម៉ដ្ឋទាំងពីរខាង ហៅថា សំពត់ក្រហម មានពណ៌ក្រហម ជាទីចង្អុលប្រាប់ថា នេះមានពណ៌ក្រហម មានពន្លឺក្រហម យ៉ាងណាមិញ បុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវអរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបក្រហម មានពណ៌ក្រហម ជាទីចង្អុលប្រាប់ថា នេះមានពណ៌ក្រហម មានពន្លឺក្រហម គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ ក៏យ៉ាងនោះដែរ នេះជា

អភិភាយតនៈទី ៧ ។ បុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវអរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ប្រៀបដូចផ្កាយព្រឹកដែលស មានពណ៌ស ជាទីចង្អុលប្រាប់ថា នេះមានពណ៌ស មានពន្លឺស ពុំនោះសោត រូបនោះ ប្រៀបដូចជាសំពត់ដែលកើតក្នុងក្រុងពារាណសី មានសាច់ម៉ដ្តទាំងពីរខាង ហៅថា សំពត់ស មានពណ៌ស ជាទីចង្អុលប្រាប់ថា នេះមានពណ៌ស មានពន្លឺស យ៉ាងណាមិញ បុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវអរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបស មានពណ៌ស ជាទីចង្អុលប្រាប់ថា នេះមានពណ៌ស មានពន្លឺស គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ ក៏យ៉ាងនោះឯង នេះជាអភិភាយតនៈទី ៨ ។ ធម៌ទាំង ៨ នេះ គួរដឹងច្បាស់ ។

[ ៣២៤ ] ធម៌ ៨ ដែលគួរធ្វើឲ្យជាក់ច្បាស់ តើដូចម្តេចខ្លះ ។ វិមោក្ខ ៨ ប្រការ បុគ្គលបានរូបជ្ឈាន រមែងឃើញនូវរូប គឺកសិណទាំងឡាយ មាននីលកសិណជាដើម នេះជាវិមោក្ខទី ១ ។ បុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវអរូបខាងក្នុង រមែងឃើញនូវរូបខាងក្រៅទាំងឡាយ គឺកសិណ មាននីលកសិណជាដើម នេះជាវិមោក្ខទី ២ ។ បុគ្គលមានចិត្តចុះស៊ប់កាន់ឈានក្នុងវណ្ណកសិណដ៏បរិសុទ្ធ នេះជាវិមោក្ខទី ៣ ។ បុគ្គលដែលកន្លងរូបនូវរូបសញ្ញា ដល់នូវសេចក្តីវិនាសនៃបដិឃសញ្ញា មិនបានធ្វើទុកក្នុងចិត្ត នូវនានត្តសញ្ញា ដោយប្រការទាំងពួង ហើយបានដល់នូវអាកាសានញ្ចាយតនជ្ឈាន ព្រោះធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ នេះជាវិមោក្ខទី ៤ ។ បុគ្គល

ដែលកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបាន ដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ព្រោះធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទី បំផុតដូច្នេះ នេះជាវិមោក្ខទី ៥ ។ បុគ្គលដែលកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ព្រោះធ្វើទុក ក្នុងចិត្តថា អ្វីតិចតួចមិនមានដូច្នេះ នេះជាវិមោក្ខទី ៦ ។ បុគ្គលដែលកន្លងនូវ អាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់នូវនេវសញ្ញា- នាសញ្ញាយតនជ្ឈាន នេះជាវិមោក្ខទី ៧ ។ បុគ្គលដែលកន្លងនូវនេវសញ្ញា- នាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយបានដល់សញ្ញាវេទយិត- និរោធ ( សេចក្តីរលត់នៃសញ្ញា និងវេទនា ) នេះជាវិមោក្ខទី ៨ ។ ធម៌ទាំង ៨ នេះ គួរធ្វើឲ្យជាក់ច្បាស់ ។ ធម៌ទាំង ៨០ នេះ ជាធម៌ពិត ធម៌មែន ធម៌ ទៀងទាត់ មិនប្រែប្រួលជាយ៉ាងដទៃឡើយ ដែលព្រះតថាគតបានត្រាស់ដឹង ហើយដោយប្រពៃ ដោយប្រការដូច្នេះ ។

[ ៣២៥ ] ធម៌ ៩ មានឧបការៈច្រើន ធម៌ ៩ គួរចម្រើន ធម៌ ៩ គួរ កំណត់ដឹង ធម៌ ៩ គួរលះបង់ ធម៌ ៩ ជាចំណែកនៃសេចក្តីវិនាស ធម៌ ៩ ជាចំណែកវិសេស ធម៌ ៩ យល់បានដោយក្រ ធម៌ ៩ គួរឲ្យកើតឡើង ធម៌ ៩ គួរដឹងច្បាស់ ធម៌ ៩ គួរធ្វើឲ្យជាក់ច្បាស់ ។

[ ៣២៦ ] ធម៌ ៩ មានឧបការៈច្រើន តើដូចម្តេចខ្លះ ។ ធម៌ដែលមាន យោនិសោមនសិការជាឫស ៩ យ៉ាង កាលភិក្ខុធ្វើទុកក្នុងចិត្តដោយឧបាយ ប្រាជ្ញា សេចក្តីត្រេកអរទន់ក៏កើតឡើង ១ កាលលោកត្រេកអរហើយ សេចក្តី

ឆ្អែតចិត្តកើតឡើង ១ កាលលោកមានសេចក្តីឆ្អែតចិត្តកើតឡើងហើយ កាយក៏ស្ងប់រម្ងាប់ ១ លុះលោកមានកាយស្ងប់រម្ងាប់ហើយ ក៏បានសោយសេចក្តីសុខ ១ លុះលោកមានសេចក្តីសុខហើយ ចិត្តក៏តាំងនៅមាំ ១ លុះលោកមានចិត្តតាំងនៅមាំហើយ ក៏ដឹងឃើញច្បាស់តាមសភាវៈពិត ១ កាលលោកបានដឹង បានឃើញច្បាស់ តាមសភាវៈពិតហើយ តែងនឿយណាយដោយខ្លួនឯង ១ លុះលោកនឿយណាយហើយ រមែងប្រាសចាកតម្រេក រមែងផុតស្រឡះចាកតម្រេក ១ ។ ធម៌ទាំង ៩ នេះ មានឧបការៈច្រើន ។

[ ៣២៧ ] ធម៌ ៩ ដែលគួរចម្រើន តើដូចម្តេចខ្លះ ។ អង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធិ ៩ យ៉ាង គឺសីលវិសុទ្ធិ ជាអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធិ ១ ចិត្តវិសុទ្ធិ ជាអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធិ ១ ទិដ្ឋិវិសុទ្ធិ ជាអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធិ ១ កង្ខាវិតរណវិសុទ្ធិ ជាអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធិ ១ មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ ជាអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធិ ១ បដិបទាញាណទស្សនវិសុទ្ធិ ជាអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធិ ១ ញាណទស្សនវិសុទ្ធិ ជាអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធិ ១ បញ្ញាវិសុទ្ធិ ជាអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធិ ១ វិមុត្តិសុទ្ធិ ជាអង្គនៃសេចក្តីព្យាយាម ដើម្បីសេចក្តីបរិសុទ្ធិ ១ ។ ធម៌ទាំង ៩ នេះ គួរចម្រើន ។

[ ៣២៨ ] ធម៌ ៩ ដែលគួរកំណត់ដឹង តើដូចម្តេចខ្លះ ។ សត្តាវាសៈ

( ប្រទេសជាទីនៅរបស់សត្វ ) មាន ៩ ម្នាលអាវុសោទាំងឡាយ សត្វទាំង-ឡាយ មានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នាក៏មាន ដូចពួកមនុស្ស និងទេវតាពួកខ្លះ និងអសុរកាយពួកខ្លះ នេះជាសត្តាវាសៈទី ១ ។ ម្នាលអាវុសោទាំងឡាយ សត្វទាំងឡាយ មានកាយផ្សេងគ្នា តែមានសញ្ញាដូចគ្នាក៏មាន ដូចព្រហ្មកាយិកទេវតា ដែលកើតក្នុងជាន់បឋមជ្ឈានភូមិ នេះជាសត្តាវាសទី ២ ។ ម្នាលអាវុសោទាំងឡាយ សត្វទាំងឡាយ មានកាយដូចគ្នា តែមានសញ្ញាផ្សេងគ្នាក៏មាន ដូចពួកទេវតាក្នុងជាន់អាភស្សរៈ នេះជាសត្តាវាសទី ៣ ។ ម្នាលអាវុសោទាំងឡាយ សត្វទាំងឡាយ មានកាយដូចគ្នា មានសញ្ញាដូចគ្នាក៏មាន ដូចពួកទេវតាក្នុងជាន់សុភកិណ្ហៈ នេះជាសត្តាវាសៈទី ៤ ។ ម្នាលអាវុសោទាំងឡាយ សត្វទាំងឡាយឥតសញ្ញា ឥតមានសោយអារម្មណ៍ ដូចពួកទេវតាជាអសញ្ញិសត្វ នេះជាសត្តាវាសទី ៥ ។ ម្នាលអាវុសោទាំងឡាយ សត្វទាំងឡាយលុះបានកន្លងនូវរូបសញ្ញា បានរម្ងាប់នូវបដិឃសញ្ញា មិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញាដោយប្រការទាំងពួង ហើយចូលដល់អាកាសា-នញ្ចាយតនជ្ឈាន ដោយបរិកម្មថា អាកាសមិនមានទីបំផុតដូច្នេះក៏មាន នេះជាសត្តាវាសៈទី ៦ ។ ម្នាលអាវុសោទាំងឡាយ សត្វទាំងឡាយកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានចូលដល់វិញ្ញាណ-ញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានចូលដល់វិញ្ញាណញ្ចាយតនជ្ឈាន ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុតដូច្នេះក៏មាន នេះជាសត្តាវាសៈទី ៧ ។ ម្នាលអាវុសោទាំងឡាយ សត្វទាំងឡាយ កន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន

ដោយប្រការទាំងពួង ក៏បានចូលដល់អាកិញ្ចញ្ញាយតនជ្ឈាន ដោយបរិកម្មថា វត្ថុតិចតួចមិនមានដូច្នេះក៏មាន នេះជាសត្តាវាសៈទី ៨ ។ ម្នាលអាវុសោទាំង-ឡាយ កន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលដល់នេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយបរិកម្មថា របស់នេះល្អិត របស់នេះឧត្តមដូច្នេះក៏មាន នេះជាសត្តាវាសៈទី ៩ ។ ធម៌ទាំង ៩ នេះ គួរកំណត់ដឹង ។

[ ៣២៩ ] ធម៌ ៩ គួរលះបង់ តើដូចម្តេចខ្លះ ។ ធម៌ដែលមានតណ្ហាជាឫសគល់ ៩ យ៉ាង គឺការអាស្រ័យតណ្ហា ទើបមានការស្វែងរក ១ អាស្រ័យការស្វែងរក ទើបកើតលាភ ១ អាស្រ័យលាភ ទើបកើតសេចក្តីត្រិះរិះ ១ អាស្រ័យសេចក្តីត្រិះរិះ ទើបកើតសេចក្តីប្រាថ្នា សេចក្តីត្រេកអរ ១ អាស្រ័យសេចក្តីប្រាថ្នា សេចក្តីត្រេកអរ ទើបកើតសេចក្តីជឿស៊ប់ ១ អាស្រ័យសេចក្តីជឿស៊ប់ ទើបកើតការហួងហែងទុក ១ អាស្រ័យការហួងហែងទុក ទើបកើតសេចក្តីកំណាញ់ ១ អាស្រ័យសេចក្តីកំណាញ់ ទើបកើតការរក្សាទុក ១ អាស្រ័យនូវការរក្សាទុកជាហេតុហើយ ទើបអកុសលធម៌ទាំងឡាយដ៏លាមកជាច្រើន គឺការកាន់ដំបង កាន់គ្រឿងសស្ត្រាវុធ ឈ្លោះទាស់ទែងគ្នា ជជែកគ្នាថា ឯងៗ ទាំងនិយាយញុះញង់ និយាយកុហក ក៏ប្រព្រឹត្តទៅ ១ ។ ធម៌ទាំង ៩ នេះ គួរលះបង់ ។

[ ៣៣០ ] ធម៌ ៩ ជាចំណែកនៃសេចក្តីវិនាស តើដូចម្តេចខ្លះ ។ អាឃាតវត្ថុ ( ហេតុនៃការចងគំនុំ ) ៩ យ៉ាង គឺបុគ្គលចងគំនុំ ដោយគិតថា អ្នកនេះបានប្រព្រឹត្តអំពើមិនជាប្រយោជន៍ដល់អញហើយ ១ ។ ចងគំនុំដោយ

គិតថា អ្នកនេះកំពុងប្រព្រឹត្តអំពើមិនជាប្រយោជន៍ដល់អញ ១ ។ ចងគំនុំដោយគិតថា អ្នកនេះនឹងប្រព្រឹត្តអំពើមិនជាប្រយោជន៍ដល់អញ ១ ។ ចងគំនុំដោយគិតថា អ្នកនេះបានប្រព្រឹត្តអំពើមិនជាប្រយោជន៍ ដល់បុគ្គលជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អញហើយ ១ ។ ចងគំនុំដោយគិតថា អ្នកនេះកំពុងតែប្រព្រឹត្តអំពើមិនជាប្រយោជន៍ ដល់បុគ្គលជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អញ ១ ។ ចងគំនុំដោយគិតថា អ្នកនេះនឹងប្រព្រឹត្តអំពើមិនជាប្រយោជន៍ដល់បុគ្គលជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អញ ១ ។ ចងគំនុំដោយគិតថា អ្នកនេះបានប្រព្រឹត្តអំពើជាប្រយោជន៍ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អញហើយ ១ ។ ចងគំនុំដោយគិតថា អ្នកនេះ កំពុងតែប្រព្រឹត្តអំពើជាប្រយោជន៍ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អញ ១ ។ ចងគំនុំដោយគិតថា អ្នកនេះនឹងប្រព្រឹត្តអំពើជាប្រយោជន៍ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត របស់អញ ១ ។ ធម៌ទាំង ៩ នេះ ជាចំណែកនៃសេចក្តីវិនាស ។

[ ៣៣១ ] ធម៌ ៩ ជាចំណែកវិសេស តើដូចម្តេចខ្លះ ។ អាឃាតប្បដិវិន័យ ( ហេតុសម្រាប់កម្ចាត់បង់គំនុំ ) ៩ យ៉ាង គឺបុគ្គលកម្ចាត់បង់នូវគំនុំដោយគិតថា អ្នកនេះបានប្រព្រឹត្តអំពើមិនជាប្រយោជន៍ដល់អាត្មាអញហើយ ព្រោះហេតុនោះ ( បើ ) អាត្មាអញ ( ធ្វើតបទៅ ) អ្នកនេះវិញ តើនឹងបានជាការអ្វី ១ ។ បុគ្គលកម្ចាត់បង់នូវគំនុំដោយគិតថា អ្នកនេះកំពុងប្រព្រឹត្តអំពើមិនជាប្រយោជន៍ដល់អាត្មាអញ ព្រោះហេតុនោះ ( បើ ) អាត្មា

អញ ( ធ្វើតបទៅ ) អ្នកនេះវិញ តើនឹងបានជាការអ្វី ១ ។ បុគ្គលកម្ចាត់បង់នូវគំនុំដោយគិតថា អ្នកនេះ នឹងប្រព្រឹត្តអំពើមិនជាប្រយោជន៍ដល់អាត្មាអញ ព្រោះហេតុនោះ ( បើ ) អាត្មាអញ ( ធ្វើតបទៅ ) អ្នកនេះវិញ តើនឹងបានជាការអ្វី ១ ។ បុគ្គលកម្ចាត់បង់នូវគំនុំដោយគិតថា អ្នកនេះបានប្រព្រឹត្តអំពើមិនជាប្រយោជន៍ដល់បុគ្គលជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អាត្មាអញហើយ ព្រោះហេតុនោះ ( បើ ) អាត្មាអញ ( ធ្វើតបទៅ ) អ្នកនេះវិញ តើនឹងបានជាការអ្វី ១ ។ បុគ្គលកម្ចាត់បង់នូវគំនុំដោយគិតថា អ្នកនេះកំពុងតែប្រព្រឹត្តអំពើមិនជាប្រយោជន៍ដល់បុគ្គលជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អាត្មាអញ ព្រោះហេតុនោះ ( បើ ) អាត្មាអញ ( ធ្វើតបទៅ ) អ្នកនេះវិញ តើនឹងបានជាការអ្វី ១ ។ បុគ្គលកម្ចាត់បង់នូវគំនុំដោយគិតថា អ្នកនេះនឹងប្រព្រឹត្តអំពើមិនជាប្រយោជន៍ដល់បុគ្គលជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់អាត្មាអញ ព្រោះហេតុនោះ ( បើ ) អាត្មាអញ ( ធ្វើតបទៅ ) អ្នកនេះវិញ តើនឹងបានជាការអ្វី ១ ។ បុគ្គលកម្ចាត់បង់នូវគំនុំដោយគិតថា អ្នកនេះបានប្រព្រឹត្តអំពើជាប្រយោជន៍ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញហើយ ព្រោះហេតុនោះ ( បើ ) អាត្មាអញ ( ធ្វើតបទៅ ) អ្នកនេះវិញ តើនឹងបានជាការអ្វី ១ ។ បុគ្គលកម្ចាត់បង់នូវគំនុំដោយគិតថា អ្នកនេះកំពុងតែប្រព្រឹត្តអំពើជាប្រយោជន៍ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញ ព្រោះហេតុនោះ ( បើ ) អាត្មាអញ ( ធ្វើតបទៅ ) អ្នកនេះវិញ តើនឹងបានជាការអ្វី ១ ។ បុគ្គលកម្ចាត់បង់នូវគំនុំ ដោយគិតថា

អ្នកនេះនឹងប្រព្រឹត្តអំពើជាប្រយោជន៍ ដល់បុគ្គលមិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្តរបស់អាត្មាអញ ព្រោះហេតុនោះ ( បើ ) អាត្មាអញ ( ធ្វើតបទៅ ) អ្នកនេះវិញ តើនឹងបានជាការអ្វី ១ ។ ធម៌ទាំង ៩ នេះ ជាចំណែកវិសេស ។

[ ៣៣២ ] ធម៌ ៩ ដែលយល់បានដោយក្រ តើដូចម្តេចខ្លះ ។ ធម៌ផ្សេងៗ ៩ យ៉ាង គឺផស្សៈផ្សេងៗ អាស្រ័យធាតុផ្សេងៗ ហើយ ទើបកើតឡើង ១ វេទនាផ្សេងៗ អាស្រ័យផស្សៈផ្សេងៗ ហើយ ទើបកើតឡើង ១ សញ្ញាផ្សេងៗ អាស្រ័យវេទនាផ្សេងៗ ហើយ ទើបកើតឡើង ១ សេចក្តីត្រិះរិះផ្សេងៗ អាស្រ័យសញ្ញាផ្សេងៗ ហើយ ទើបកើតឡើង ១ សេចក្តីប្រាថ្នាផ្សេងៗ អាស្រ័យសេចក្តីត្រិះរិះផ្សេងៗ ហើយ ទើបកើតឡើង ១ សេចក្តីក្តៅក្រហាយផ្សេងៗ អាស្រ័យសេចក្តីប្រាថ្នាផ្សេងៗ ហើយ ទើបកើតឡើង ១ ការស្វែងរកផ្សេងៗ អាស្រ័យសេចក្តីក្តៅក្រហាយផ្សេងៗ ហើយ ទើបកើតឡើង ១ លាភផ្សេងៗ អាស្រ័យការស្វែងរកផ្សេងៗ ហើយ ទើបកើតឡើង ១ ។ ធម៌ទាំង ៩ នេះ យល់បានដោយក្រ ។

[ ៣៣៣ ] ធម៌ ៩ ដែលគួរឲ្យកើតឡើង តើដូចម្តេចខ្លះ ។ សេចក្តីសម្គាល់ ៩ យ៉ាង គឺសេចក្តីសម្គាល់ថាមិនល្អ ១ សេចក្តីសម្គាល់ដោយមរណានុបស្សនាញាណ ១ សេចក្តីសម្គាល់ក្នុងអាហារថា ជារបស់គួរខ្ពើម ១ សេចក្តីសម្គាល់របស់បុគ្គលអ្នកមិនត្រេកអរ ក្នុងលោកទាំងពួង ១ សេចក្តីសម្គាល់ថាមិនទៀង ១ សេចក្តីសម្គាល់ក្នុងរបស់ដែលមិនទៀងថាជាទុក្ខ ១ សេចក្តីសម្គាល់ក្នុងរបស់ដែលជាទុក្ខ ថាមិនមែនរបស់ខ្លួន ១ សេចក្តីសម្គាល់

នូវរបស់ដែលត្រូវលះបង់ ១ សេចក្តីសម្គាល់ថាគួរនឿយណាយ ១ ។ ធម៌ទាំង ៩ នេះ គួរឲ្យកើតឡើង ។

[ ៣៣៤ ] ធម៌ ៩ ដែលគួរដឹងច្បាស់ តើដូចម្តេចខ្លះ ។ អនុបុព្វវិហារៈ ( ធម៌ជាគ្រឿងសម្រេចសម្រាន្តនៅតាមលំដាប់ ) ៩ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយហើយ ក៏បានចូលដល់បឋមជ្ឈាន ដែលប្រកបដោយវិតក្កវិចារៈ និងបីតិសុខដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ១ លុះរម្ងាប់វិតក្ក និងវិចារៈទាំងឡាយហើយ ក៏បានចូលទុតិយជ្ឈានជាទីផូរផង់ ប្រព្រឹត្តទៅខាងក្នុង ដ៏ញុំាងចិត្តជាសមាធិឲ្យចម្រើនឡើង គ្មានវិតក្កវិចារៈ មានតែបីតិ និងសុខដែលកើតអំពីសមាធិ ១ លុះលះបង់បីតិចេញហើយ ជាបុគ្គលព្រងើយកន្តើយ ប្រកបដោយបីតិ និងសម្បជញ្ញៈ សោយសុខដោយកាយផង ក៏បានចូលដល់តតិយជ្ឈាន ដែលព្រះអរិយៈទាំងឡាយ តែងសម្តែងថា បុគ្គលអ្នកបានតតិយជ្ឈាន រមែងជាអ្នកមានចិត្តព្រងើយ មានស្មារតី នៅជាសុខដូច្នេះ ១ លុះលះបង់នូវសុខផង លះបង់នូវទុក្ខផង រំលត់នូវសោមនស្ស និងទោមនស្ស អំពីមុនផង ក៏បានចូលដល់ចតុត្ថជ្ឈាន ឥតសុខឥតទុក្ខ មានតែសតិដ៏ស្អាតដោយឧបេក្ខា ១ លុះកន្លងបង់នូវរូបសញ្ញា រំលត់នូវបដិឃសញ្ញា មិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញាដោយប្រការទាំងពួង ហើយក៏បានចូលដល់អាកាសានញ្ចាយតនជ្ឈានដោយបរិកម្មថា អាកាសមិនមានទីបំផុត ១ លុះកន្លងអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួងហើយ ក៏បានចូលដល់

វិញ្ញាណញ្ចាយតនជ្ឈានដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត ១ លុះកន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួងហើយ ក៏បានចូលដល់អាកិញ្ចញ្ញាយតនជ្ឈានដោយប្រការទាំងពួងហើយ ក៏បានចូលដល់នេវសញ្ញានាសញ្ញាយតនជ្ឈាន ១ លុះកន្លងបង់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួងហើយ ក៏បានចូលដល់សញ្ញាវេទយិតនិរោធ ១ ។ ធម៌ទាំង ៩ នេះ គួរដឹងច្បាស់ ។

[ ៣៣៥ ] ធម៌ ៩ ដែលគួរធ្វើឲ្យជាក់ច្បាស់ តើដូចម្តេចខ្លះ ។ អនុបុព្វនិរោធ ( ធម៌ជាគ្រឿងរំលត់តាមលំដាប់ ) ៩ យ៉ាង គឺបុគ្គលចូលកាន់បឋមជ្ឈាន រលត់កាមសញ្ញា ១ ចូលកាន់ទុតិយជ្ឈាន រលត់វិតក្កវិចារៈ ១ ចូលកាន់តតិយជ្ឈាន រលត់បីតិ ១ ចូលកាន់ចតុត្ថជ្ឈាន រលត់អស្សាសបស្សាសៈ ១ ចូលកាន់អាកាសានញ្ចាយតនជ្ឈាន រលត់រូបសញ្ញា ១ ចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន រលត់អាកាសានញ្ចាយតនសញ្ញា ១ ចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន រលត់វិញ្ញាណញ្ចាយតនសញ្ញា ១ ចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន រលត់អាកិញ្ចញ្ញាយតនសញ្ញា ១ ចូលកាន់សញ្ញាវេទយិតនិរោធ រលត់សញ្ញា និងវេទនា ១ ។ ធម៌ទាំង ៩ នេះ គួរធ្វើឲ្យជាក់ច្បាស់ ។ ធម៌ទាំង ៩០ នេះ ជាធម៌ពិត ជាធម៌មែន ធម៌ទៀងទាត់ មិនប្រែប្រួលជាយ៉ាងដទៃឡើយ ដែលព្រះតថាគតបានត្រាស់ដឹងហើយដោយប្រពៃ ដោយប្រការដូច្នេះ ។

[ ៣៣៦ ] ធម៌ ១០ មានឧបការៈច្រើន ធម៌ ១០ គួរចម្រើន ធម៌ ១០

គួរកំណត់ដឹង ធម៌ ១០ គួរលះបង់ ធម៌ ១០ ជាចំណែកនៃសេចក្តី វិនាស ធម៌ ១០ ជាចំណែកវិសេស ធម៌ ១០ យល់បានដោយក្រ ធម៌ ១០ គួរឲ្យកើតឡើង ធម៌ ១០ គួរដឹងច្បាស់ ធម៌ ១០ គួរធ្វើឲ្យជាក់ច្បាស់ ។

[ ៣៣៧ ] ធម៌ ១០ មានឧបការៈច្រើន តើដូចម្តេចខ្លះ ។ នាថករណ-ធម៌ ( ធម៌ធ្វើឲ្យជាទីពឹង ) ១០ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈ និងគោចរៈ ជាអ្នកឃើញភ័យក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈ និងគោចរៈ ជាអ្នកឃើញភ័យក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ នេះឯងជានាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយមួយទៀត ភិក្ខុជាពហុស្សូត ចេះចាំនូវពុទ្ធវចនៈដែលខ្លួនបានស្តាប់ហើយ សន្សំទុកនូវពុទ្ធវចនៈដែលខ្លួនបានស្តាប់ហើយ ធម៌ទាំងឡាយ មានលម្អបទដើម មានលម្អបទកណ្តាល មានលម្អបទចុង ប្រកាសនូវព្រហ្មចារ្យ ព្រមទាំងអត្ថ ព្រមទាំងព្យញ្ជនៈដ៏បរិសុទ្ធបរិបូណ៌ទាំងអស់ ធម៌ទាំងឡាយមានសភាពដូច្នោះ ភិក្ខុនោះឯងក៏បានស្តាប់ច្រើន បានចាំទុក ចាំរត់មាត់ ចាំជាប់ក្នុងចិត្ត ចាក់ធ្លុះល្អដោយទិដ្ឋិ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាពហុស្សូត ។បេ។ ចាក់ធ្លុះល្អដោយទិដ្ឋិ នេះឯង ជានាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុមានមិត្តល្អ មានសម្លាញ់ល្អ មានបុគ្គលស្និទ្ធស្នាល

ល្អ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានមិត្តល្អ មានសម្លាញ់ល្អ មានបុគ្គលស្និទ្ធស្នាលល្អ នេះឯង ជានាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកដែលគេប្រដៅងាយ ប្រកបដោយធម៌ជាគ្រឿងធ្វើនូវភាវៈជាអ្នកប្រដៅងាយ ជាអ្នកអត់ធន់ ទទួលយកនូវពាក្យប្រៀនប្រដៅដោយចំណែកខាងស្តាំ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកដែលគេប្រដៅងាយ ប្រកបដោយធម៌ជាគ្រឿងធ្វើនូវភាវៈជាអ្នកប្រដៅងាយ ជាអ្នកអំណត់ ទទួលយកនូវពាក្យប្រៀនប្រដៅដោយចំណែកខាងស្តាំ នេះឯង ជានាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត កិច្ចការណានីមួយ ធំឬតូចរបស់សព្រហ្មចារីបុគ្គលទាំងឡាយ ភិក្ខុជាអ្នកប៉ិនប្រសប់ មិនខ្ជិលច្រអូសក្នុងកិច្ចការទាំងនោះឡើយ ប្រកបដោយការពិចារណាជាឧបាយក្នុងកិច្ចការទាំងនោះជាអ្នកអាចធ្វើបាន អាចចាត់ចែងបាន ។ ម្នាលអាវុសោទាំងឡាយ កិច្ចការណានីមួយ ធំឬតូចរបស់សព្រហ្មចារីបុគ្គលទាំងឡាយ ភិក្ខុជាអ្នកប៉ិនប្រសប់ មិនខ្ជិលច្រអូស ក្នុងកិច្ចការទាំងនោះឡើយ ប្រកបដោយការពិចារណាជាឧបាយក្នុងកិច្ចការទាំងនោះ ជាអ្នកអាចធ្វើបាន អាចចាត់ចែងបាន នេះឯង ជានាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុមានសេចក្តីប្រាថ្នាក្នុងធម៌ ជាអ្នកស្តាប់ដោយយកចិត្តទុកដាក់ ទាំងប្រាថ្នាប្រកាសប្រាប់ជនឯទៀត ដោយខ្លួនឯង ជាអ្នកច្រើនដោយសេចក្តីត្រេកអរដ៏ទន់ក្នុងអភិធម្មក្នុងអភិវិន័យ ។ ម្នាលអាវុសោទាំងឡាយ ការដែលភិក្ខុមានសេចក្តីប្រាថ្នាក្នុងធម៌ ជាអ្នកស្តាប់ដោយយកចិត្តទុកដាក់ ទាំងប្រាថ្នាប្រកាសប្រាប់ជនឯ

ទៀត ដោយខ្លួនឯង ជាអ្នកច្រើនដោយសេចក្តីត្រេកអរដ៏ទន់ក្នុងអភិធម្ម ក្នុងអភិវិន័យ នេះឯង ជានាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ និងគ្រឿងបរិក្ខារ គឺថ្នាំជាបច្ច័យសម្រាប់អ្នកជំងឺ តាមមាន តាមបាន ។ ម្នាលអាវុសោទាំង-ឡាយ ភិក្ខុជាអ្នកសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ និងគ្រឿងបរិក្ខារ គឺថ្នាំជាបច្ច័យសម្រាប់អ្នកជំងឺ តាមមាន តាមបាន នេះឯង ជានាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកតាំងផ្តើមសេចក្តីព្យាយាម ដើម្បីលះបង់អកុសលធម៌ទាំងឡាយ ដើម្បីធ្វើកុសលធម៌ទាំងឡាយឲ្យបរិបូណ៌ ជាអ្នកមានកម្លាំង មានសេចក្តីប្រឹងប្រែងមាំមួន មិនដាក់ធុរៈក្នុងកុសលធម៌ទាំង-ឡាយ ។ ម្នាលអាវុសោទាំងឡាយ ការដែលភិក្ខុជាអ្នកផ្តើមសេចក្តីព្យាយាម ។បេ។ នេះឯង ជានាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានស្មារតី មួយទៀត ភិក្ខុជាអ្នកមានស្មារតី ប្រកបដោយ ( ការតាំង ) ស្មារតី និងការៈជាអ្នកមានប្រាជ្ញាចាស់ក្លាដ៏ខ្ពង់ខ្ពស់ នឹកឃើញនូវអំពើដែលខ្លួនធ្វើរួចយូរហើយផង នូវសម្តីដែលខ្លួននិយាយយូរហើយផង ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកមានស្មារតី ប្រកបដោយការតាំងស្មារតីនិងភាពជាអ្នកមានប្រាជ្ញាដ៏ខ្ពង់ខ្ពស់ នឹកឃើញនូវអំពើដែលខ្លួនធ្វើរួចយូរហើយផង នូវសម្តីដែលខ្លួននិយាយយូរហើយផង នេះឯង ជានាថករណធម៌ ១ ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញាដែលអាចកំណត់នូវការកើតឡើង និងការវិនាសទៅ ( នៃខន្ធបញ្ចកៈ ) ជាគ្រឿង

ទម្លាយនូវកិលេសដ៏ប្រសើរ ជាធម្មជាតដល់នូវកិរិយាអស់ទៅនៃទុក្ខដោយប្រពៃ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកមានប្រាជ្ញា ។បេ។ ជាធម្មជាតដល់នូវកិរិយាអស់ទៅនៃទុក្ខដោយប្រពៃ នេះឯង ជានាថករណធម៌ ១ ។ ធម៌ទាំង ១០ នេះ មានឧបការៈច្រើន ។

[ ៣៣៨ ] ធម៌ ១០ ដែលគួរចម្រើន តើដូចម្តេចខ្លះ ។ កសិណាយតនៈ ( ខេត្ត ឬទីតាំងរបស់ពួកធម៌ដែលមានកសិណជាអារម្មណ៍ ) មាន ១០ យ៉ាង គឺបុគ្គលពួកមួយ ស្គាល់ច្បាស់នូវបឋវីកសិណខាងលើ ខាងក្រោម និងទទឹង ជាកសិណតែបែបមួយ ឥតមានលាយឡំ ( នឹងកសិណឯទៀត ) មានការផ្សាយទឹងប្រមាណមិនបាន ១ ។ បុគ្គលពួកមួយ ស្គាល់ច្បាស់នូវអាបោ-កសិណ ១ ។ បុគ្គលពួកមួយ ស្គាល់ច្បាស់នូវតេជោកសិណ ១ ។ បុគ្គលពួកមួយ ស្គាល់ច្បាស់នូវវាយោកសិណ ១ ។ បុគ្គលពួកមួយ ស្គាល់ច្បាស់នូវនីលកសិណ ១ ។ បុគ្គលពួកមួយ ស្គាល់ច្បាស់នូវបីតកសិណ ១ ។ បុគ្គលពួកមួយ ស្គាល់ច្បាស់នូវលោហិតកសិណ ១ ។ បុគ្គលពួកមួយ ស្គាល់ច្បាស់នូវឱទាតកសិណ ១ ។ បុគ្គលពួកមួយ ស្គាល់ច្បាស់នូវអាកា-សកសិណ ១ ។ បុគ្គលពួកមួយ ស្គាល់ច្បាស់នូវវិញ្ញាណកសិណ ខាងលើ ខាងក្រោម និងទទឹង ជាកសិណបែបមួយ ឥតមានលាយឡំ ( នឹងកសិណឯទៀត ) ហើយ មានការផ្សាយទឹងប្រមាណមិនបាន ១ ។ ធម៌ ទាំង ១០ នេះ គួរចម្រើន ។

[ ៣៣៩ ] ធម៌ ១០ ដែលគួរកំណត់ដឹង តើដូចម្តេចខ្លះ ។ អាយតនៈ

( ហេតុជាទីកើតនៃចិត្ត ) ១០ គឺភ្នែកជាកន្លែងកើតចិត្ត ១ រូបជាកន្លែងកើតចិត្ត ១ ត្រចៀកជាកន្លែងកើតចិត្ត ១ សំឡេងជាកន្លែងកើតចិត្ត ១ ច្រមុះជាកន្លែងកើតចិត្ត ១ ក្លិនជាកន្លែងកើតចិត្ត ១ អណ្តាតជាកន្លែងកើតចិត្ត ១ រសជាកន្លែងកើតចិត្ត ១ កាយជាកន្លែងកើតចិត្ត ១ ផោដ្ឋព្វៈជាកន្លែងកើតចិត្ត ១ ។ ធម៌ទាំង ១០ នេះ គួរកំណត់ដឹង ។

[ ៣៤០ ] ធម៌ ១០ ដែលគួរលះបង់ តើដូចម្តេចខ្លះ ។ សភាពដែលខុស ១០ យ៉ាង គឺការយល់ខុស ១ ការត្រិះរិះខុស ១ ពោលពាក្យខុស ១ ការងារខុស ១ ចិញ្ចឹមជីវិតខុស ១ សេចក្តីព្យាយាមខុស ១ ការរឭកខុស ១ ការតាំងចិត្តខុស ១ ការដឹងខុស ១ ការរួចខុស ១ ។ ធម៌ទាំង ១០ នេះ គួរលះបង់ ។

[ ៣៤១ ] ធម៌ ១០ ជាចំណែកនៃសេចក្តីវិនាស តើដូចម្តេចខ្លះ ។ គន្លងនៃអកុសលកម្ម ១០ យ៉ាង គឺការសម្លាប់សត្វ ១ លួចទ្រព្យគេ ១ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ ពោលពាក្យកុហក ១ ពោលពាក្យញុះញង់ ១ ពោលពាក្យទ្រគោះ ១ ពោលពាក្យឥតប្រយោជន៍ ១ ចិត្តគិតសម្លឹងរំពៃបង្អោនទ្រព្យអ្នកដទៃ មកជាទ្រព្យរបស់ខ្លួន ១ ចិត្តគុំកួន ១ ការយល់ខុស ១ ។ ធម៌ទាំង ១០ នេះ ជាចំណែកនៃសេចក្តីវិនាស ។

[ ៣៤២ ] ធម៌ ១០ ដែលជាចំណែកវិសេស តើដូចម្តេចខ្លះ ។ គន្លងនៃកុសលកម្ម ១០ គឺចេតនាជាហេតុវៀរចាកការសម្លាប់សត្វ ១ វៀរចាកការលួចទ្រព្យគេ ១ វៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ វៀរចាក

ការពោលពាក្យកុហក ១ វៀរចាកការពោលពាក្យញុះញង់ ១ វៀរចាកការពោលពាក្យទ្រគោះ ១ វៀរចាកការពោលពាក្យរោយរាយ ឥតប្រយោជន៍ ១ ចិត្តមិនសម្លឹងរំពៃ បង្អោនទ្រព្យអ្នកដទៃ មកជាទ្រព្យរបស់ខ្លួន ១ ចិត្តមិនគុំកួន ១ ការយល់ត្រូវ ១ ។ ធម៌ទាំង ១០ នេះជាចំណែកវិសេស ។

[ ៣៤៣ ] ធម៌ទាំង ១០ ដែលយល់បានដោយក្រ តើដូចម្តេចខ្លះ ។ ធម៌ជាគ្រឿងនៅអាស្រ័យរបស់អរិយៈ ១០ យ៉ាង ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកលះបង់អង្គប្រាំ ១ ប្រកបដោយឆឡង្គុបេក្ខា ១ ជាអ្នករក្សាធម៌តែមួយ ១ មានធម៌ជាបង្អែក ៤ យ៉ាង ១ ជាអ្នកកម្ចាត់បង់នូវសច្ចធម៌ដោយឡែក ១ ជាអ្នកលះបង់ដោយប្រពៃនូវការស្វែងរក ១ មានសេចក្តីត្រិះរិះមិនសៅហ្មង ១ មានកាយសង្ខារស្ងប់រម្ងាប់ ១ មានចិត្តរួចស្រឡះហើយដោយល្អ ១ មានប្រាជ្ញាដឹងថា ចិត្តរួចស្រឡះដោយល្អ ១ ។ ម្នាលអាវុសោទាំងឡាយ ចុះភិក្ខុជាអ្នកលះបង់អង្គ ៥ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកលះបង់កាមច្ឆន្ទៈ ១ លះបង់ព្យាបាទ ១ លះបង់ថីនមិទ្ធៈ ១ លះបង់ឧទ្ធច្ចកុក្កុច្ចៈ ១ លះបង់វិចិកិច្ឆា ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុលះបង់អង្គ ៥ ដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ចុះភិក្ខុប្រកបដោយឆឡង្គុបេក្ខា តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានឃើញរូបដោយភ្នែកហើយ ជាអ្នកមិនមានសោមនស្ស មិនមានទោមនស្ស ជាអ្នកព្រងើយ ប្រកបដោយសតិ និងសម្បជញ្ញៈ ។ បានឮសំឡេង ដោយត្រចៀក ។ បានធុំក្លិន

ដោយប្រមុះ ។ បានទទួលរសដោយអណ្តាត ។ បានពាល់ត្រូវផោដ្ឋព្វៈដោយ កាយ ។ បានដឹងធម្មារម្មណ៍ដោយចិត្តហើយ ជាអ្នកមិនមានសោមនស្ស មិនមានទោមនស្ស ជាអ្នកព្រងើយ ប្រកបដោយសតិ និងសម្បជញ្ញៈ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុប្រកបដោយឆឡង្គុបេក្ខា ដោយអាការៈយ៉ាង នេះឯង ។ ម្នាលអាវុសោទាំងឡាយ ចុះភិក្ខុរក្សាធម៌តែមួយ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ប្រកបដោយចិត្ត មានសតិជា គ្រឿងរក្សាទុក ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុរក្សាធម៌តែមួយដោយអាការ យ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណា ហើយទើបសេពរបស់ដែលគួរសេព ១ ពិចារណាហើយទើបអត់សង្កត់របស់ ដែលគួរអត់សង្កត់ ១ ពិចារណាហើយទើបវៀររបស់ដែលគួរវៀរ ១ ពិចារណា ទើបបន្ទោបង់របស់ដែលគួរបន្ទោបង់ ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុ មានបង្អែក ៤ យ៉ាង ដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ចុះភិក្ខុជាអ្នកកម្ចាត់បង់នូវសច្ចធម៌ដោយឡែក តើដូចម្តេច ។ ម្នាលអាវុសោ ទាំងឡាយ ភិក្ខុក្នុងសាសនានេះ បាននាំចេញ បន្ទោបង់ លះចោល ខ្ជាក់ ចោល ស្រាយចេញ លះបង់ ផ្តាច់ផ្តិលនូវសច្ចៈដ៏ផ្សេងគ្នាជាច្រើន របស់ សមណៈ និងព្រាហ្មណ៍ដ៏ច្រើន ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកកម្ចាត់ បង់នូវសច្ចធម៌ដោយឡែក ដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំង-ឡាយ ចុះភិក្ខុជាអ្នកលះបង់ដោយប្រពៃ នូវការស្វែងរក តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកលះបង់ការស្វែងរក

កាម លះបង់ការស្វែងរកភព លះបង់ការស្វែងរកព្រហ្មចារ្យចេញហើយ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកលះបង់ដោយប្រពៃនូវការស្វែងរកដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ចុះភិក្ខុមានសេចក្តីត្រិះរិះមិនបានសៅហ្មង តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកលះបង់សេចក្តីត្រិះរិះក្នុងកាម លះបង់សេចក្តីត្រិះរិះក្នុងការព្យាបាទ លះបង់សេចក្តីត្រិះរិះក្នុងការបៀតបៀន ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានសេចក្តីត្រិះរិះមិនបានសៅហ្មងដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំង-ឡាយ ចុះភិក្ខុមានកាយសង្ខារស្ងប់រម្ងាប់ហើយ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ព្រោះលះបង់សុខផង លះបង់ទុក្ខផង ព្រោះរំលត់នូវសោមនស្ស និងទោមនស្ស ក្នុងកាលមុនផង ហើយក៏បានចូលចតុត្ថជ្ឈាន ដែលគ្មានទុក្ខ គ្មានសុខ មានតែឧបេក្ខា និងសតិដ៏បរិសុទ្ធ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានកាយសង្ខារ ស្ងប់រម្ងាប់ហើយ ដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ចុះភិក្ខុមានចិត្តរួចស្រឡះហើយដោយល្អ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ មានចិត្តរួចស្រឡះហើយចាករាគៈ មានចិត្តរួចស្រឡះហើយចាកទោសៈ មានចិត្តរួចស្រឡះហើយចាកចាកមោហៈ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានចិត្តរួចស្រឡះហើយដោយល្អ ដោយអាការយ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ចុះភិក្ខុមានប្រាជ្ញាដឹងថា ចិត្តរួចស្រឡះហើយដោយល្អ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់ថា រាគៈ អាត្មាអញ

បានលះបង់ហើយ គាស់រំលើងឫសចេញហើយ ធ្វើឲ្យលែងកើតទៀត ដូចដើមត្នោត ( កំបុតក ) ហើយធ្វើមិនឲ្យមានទៀត មិនឲ្យកើតតទៅទៀតជាធម្មតា ។ ដឹងច្បាស់ថា ទោសៈអាត្មាអញបានលះបង់ចោលហើយ ។បេ។ មោហៈអាត្មាអញបានលះបង់ហើយ គាស់រំលើងឫសចេញហើយ ធ្វើឲ្យលែងកើតទៀត ដូចដើមត្នោត ( កំបុតក ) ហើយធ្វើមិនឲ្យមានទៀត មិនឲ្យកើតតទៅទៀតជាធម្មតា ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុមានប្រាជ្ញាដឹងថា ចិត្តរួចស្រឡះហើយដោយល្អ ដោយអាការយ៉ាងនេះឯង ។ ធម៌ទាំង ១០ នេះ យល់បានដោយក្រ ។

[ ៣៨៤ ] ធម៌ ១០ ដែលគួរឲ្យកើតឡើង តើដូចម្តេចខ្លះ ។ សេចក្តីសម្គាល់ ១០ យ៉ាង គឺសេចក្តីសម្គាល់ថា មិនល្អ ១ សេចក្តីសម្គាល់ចំពោះមរណៈ ១ សេចក្តីសម្គាល់ក្នុងអាហារថា ជារបស់គួរខ្ពើម ១ សេចក្តីសម្គាល់របស់បុគ្គលជាអ្នកមិនត្រេកអរ ក្នុងលោកទាំងពួង ១ សេចក្តីសម្គាល់ថាមិនទៀង ១ សេចក្តីសម្គាល់ក្នុងរបស់ដែលមិនទៀងថាជាទុក្ខ ១ សេចក្តីសម្គាល់ក្នុងរបស់ដែលជាទុក្ខថា មិនមែនរបស់ខ្លួន ១ សេចក្តីសម្គាល់នូវរបស់ដែលត្រូវលះបង់ ១ សេចក្តីសម្គាល់ថា គួរនឿយណាយ ១ សេចក្តីសម្គាល់ថា រលត់ទៅនៃកងទុក្ខ ១ ។ ធម៌ទាំង ១០ នេះ គួរឲ្យកើតឡើង ។

[ ៣៨៥ ] ធម៌ ១០ ដែលគួរដឹងច្បាស់ តើដូចម្តេចខ្លះ ។ ហេតុនៃសេចក្តីសាបសូន្យ ១០ គឺបុគ្គលមានគំនិតយល់ត្រូវហើយ ការយល់ខុសក៏សាបសូន្យអស់ ទាំងអកុសលធម៌ដ៏លាមកច្រើនយ៉ាង ដែលកើតឡើង

ព្រោះការយល់ខុស ជាបច្ច័យ ក៏សាបសូន្យទៅដែរ ឯកុសលធម៌ដ៏ច្រើន ក៏ដល់នូវការចម្រើន បរិបូណ៌ឡើង ព្រោះគំនិតយល់ត្រូវ ជាបច្ច័យ ១ ។ បុគ្គលមានសេចក្ដីត្រិះរិះត្រូវហើយ សេចក្ដីត្រិះរិះខុស ក៏សាបសូន្យអស់ ទាំងអកុសលធម៌ដ៏លាមកច្រើនយ៉ាង ដែលកើតឡើងព្រោះសេចក្ដីត្រិះរិះខុស ជាបច្ច័យ ក៏សាបសូន្យទៅដែរ ឯកុសលធម៌ដ៏ច្រើន ក៏ដល់នូវការចម្រើន បរិបូណ៌ឡើង ព្រោះសេចក្ដីត្រិះរិះត្រូវ ជាបច្ច័យ ១ ។ បុគ្គលមានវាចាត្រូវហើយ វាចាខុស ក៏សាបសូន្យទៅអស់ ទាំងអកុសលធម៌ដ៏លាមកច្រើនយ៉ាង ដែលកើតឡើង ព្រោះវាចាខុសជាបច្ច័យ ក៏សាបសូន្យទៅដែរ ឯអកុសលធម៌ច្រើន ក៏ដល់នូវការចម្រើន បរិបូណ៌ឡើង ព្រោះវាចាត្រូវ ជាបច្ច័យ ១ ។ បុគ្គលមានការងារត្រូវហើយ ការងារខុស ក៏សាបសូន្យទៅអស់ ទាំងអកុសលធម៌ដ៏លាមកច្រើនយ៉ាង ដែលកើតឡើង ព្រោះការងារខុស ជាបច្ច័យ ក៏សាបសូន្យទៅដែរ ឯកុសលធម៌ដ៏ច្រើន ក៏ដល់នូវការចម្រើន បរិបូណ៌ឡើង ព្រោះការងារត្រូវ ជាបច្ច័យ ១ ។ បុគ្គលមានការចិញ្ចឹមជីវិតត្រូវហើយ ការចិញ្ចឹមជីវិតខុស ក៏សាបសូន្យទៅអស់ ទាំងអកុសលធម៌ ដ៏លាមកច្រើនយ៉ាងដែលកើតឡើង ព្រោះការចិញ្ចឹមជីវិតខុស ជាបច្ច័យ ក៏សាបសូន្យទៅដែរ ឯកុសលធម៌ដ៏ច្រើន ក៏ដល់នូវសេចក្ដីចម្រើន បរិបូណ៌ឡើង ព្រោះការចិញ្ចឹមជីវិតត្រូវជាបច្ច័យ ១ ។ បុគ្គលដែលមានព្យាយាមត្រូវហើយ សេចក្ដីព្យាយាមខុស ក៏សាបសូន្យអស់ ទាំងអកុសលធម៌ដ៏លាមកច្រើនយ៉ាង ដែលកើតឡើង ព្រោះសេចក្ដីព្យាយាមខុស ជា

បច្ច័យ ក៏សាបសូន្យទៅដែរ ឯកុសលធម៌ដ៏ច្រើនប្រការ ក៏ដល់នូវសេចក្តីចម្រើន បរិបូណ៌ឡើង ព្រោះសេចក្តីព្យាយាមត្រូវ ជាបច្ច័យ ១ ។ បុគ្គលមានការរឭកត្រូវហើយ ការរឭកខុស ក៏សាបសូន្យទៅអស់ ទាំងអកុសលធម៌ដ៏លាមកច្រើនប្រការ ដែលកើតឡើងព្រោះការរឭកខុស ជាបច្ច័យ ក៏សាបសូន្យទៅដែរ ឯកុសលធម៌ដ៏ច្រើនប្រការ ក៏ដល់នូវសេចក្តីចម្រើន បរិបូណ៌ឡើង ព្រោះការរឭកត្រូវ ជាបច្ច័យ ១ ។ បុគ្គលដែលមានការស្ទឹងស្មាធិ៍ត្រូវហើយ ការស្ទឹងស្មាធិ៍ខុស ក៏សាបសូន្យទៅអស់ ទាំងអកុសល-ធម៌ដ៏លាមកច្រើនប្រការ ដែលកើតឡើងព្រោះការស្ទឹងស្មាធិ៍ខុស ជាបច្ច័យ ក៏សាបសូន្យទៅដែរ ឯកុសលធម៌ច្រើនប្រការ ក៏ដល់នូវសេចក្តីចម្រើន បរិបូណ៌ឡើង ព្រោះការស្ទឹងស្មាធិ៍ត្រូវជាបច្ច័យ ១ ។ បុគ្គលដែលមានកិរិយាដឹងត្រូវហើយ កិរិយាដឹងខុស ក៏សាបសូន្យទៅអស់ ទាំងអកុសលធម៌ដ៏លាមកច្រើនប្រការដែលកើតឡើង ព្រោះកិរិយាដឹងខុសជាបច្ច័យ ក៏សាបសូន្យទៅដែរ ឯកុសលធម៌ដ៏ច្រើនប្រការក៏ដល់នូវសេចក្តីចម្រើនបរិបូណ៌ឡើង ព្រោះកិរិយាដឹងត្រូវជាបច្ច័យ ១ ។ បុគ្គលមានកិរិយារួច ត្រឹមត្រូវហើយ កិរិយារួចខុស ក៏សាបសូន្យទៅអស់ ទាំងអកុសលធម៌ដ៏លាមកច្រើនប្រការ ដែលកើតឡើង ព្រោះកិរិយារួចខុស ជាបច្ច័យ ក៏សាបសូន្យទៅដែរ ឯកុសលធម៌ដ៏ច្រើនប្រការ ក៏ដល់នូវសេចក្តីចម្រើនបរិបូណ៌ឡើង ព្រោះកិរិយារួចត្រូវ ជាបច្ច័យ ១ ។ ធម៌ទាំង ១០ នេះ គួរដឹងច្បាស់ ។

[ ៣៨៦ ] ធម៌ ១០ គួរធ្វើឲ្យជាក់ច្បាស់ តើដូចម្តេចខ្លះ ។ ធម៌ជា

របស់អសេក្ខៈ ១០ យ៉ាង គឺសម្មាទិដ្ឋិ ជារបស់អសេក្ខៈ ១ សម្មាសង្កប្ប ជារបស់អសេក្ខៈ ១ សម្មាវាចា ជារបស់អសេក្ខៈ ១ សម្មាកម្មន្តៈ ជារបស់អសេក្ខៈ ១ សម្មាអាជីវៈ ជារបស់អសេក្ខៈ ១ សម្មាវាយាមៈ ជារបស់អសេក្ខៈ ១ សម្មាសតិ ជារបស់អសេក្ខៈ ១ សម្មាសមាធិ ជារបស់អសេក្ខៈ ១ សម្មាញាណៈ ជារបស់អសេក្ខៈ ១ សម្មាវិមុត្តិ ជារបស់អសេក្ខៈ ១ ។ ធម៌ទាំង ១០ នេះគួរធ្វើឲ្យជាក់ច្បាស់ ។ ធម៌ទាំង ១០០ នេះ ជាធម៌ពិត ធម៌មែន ធម៌ទៀងទាត់ មិនប្រែប្រួលជាយ៉ាងដទៃឡើយ ដែលព្រះតថាគតត្រាស់ដឹងហើយ ដោយប្រពៃ ដោយប្រការដូច្នេះ ។ លុះព្រះសារីបុត្តមានអាយុ បានសម្តែងសូត្រនេះចប់ហើយ ។ ភិក្ខុទាំងនោះក៏មានចិត្តត្រេកអររីករាយ ចំពោះភាសិតរបស់ព្រះសារីបុត្តដ៏មានអាយុ ។

ទសុត្តរសូត្រទី ១១ ចប់

បាដិកវគ្គតែប៉ុណ្ណេះ ចប់

បញ្ជីឈ្មោះសូត្រនៃបាដិកវគ្គនោះដូច្នេះគឺ

បាដិកសូត្រ ១ ឧទុម្ពរិកសូត្រ ១ ចក្កវត្តិសូត្រ ១ អគ្គញ្ញសូត្រ ១ សម្បសាទនិយសូត្រ ១ បាសាទិកសូត្រ ១ លក្ខណសូត្រ ១ សិង្គាលកសូត្រ ១ អាដានាដិយសូត្រ ១ សង្គីតិសូត្រ ១ និងទសុត្តរសូត្រ ១ រួមត្រូវជា ១១ សូត្រ ។

គម្ពីរទីឃនិកាយ ប្រដាប់ដោយសូត្រ ៣៤ ចប់

និកាយណា សង្គ្រោះដោយសូត្រ ៣៤ និងវគ្គ ៣ និកាយនុ៎ះ ឈ្មោះថា ទីឃនិកាយ ជានិកាយអនុលោមដំបូង ។ ចុះនិកាយនោះ ដែលលោកហៅថា ទីឃនិកាយ តើព្រោះហេតុអ្វី ។ បានជាលោកហៅថា ទីឃនិកាយ ព្រោះជាទីប្រជុំ ជាទីនៅអាស្រ័យ ជាទីប្រជុំរួបរួមនៃសូត្រទាំងឡាយ ដែលមានប្រមាណវែងៗ ។

# អដ្ឋកថា

# ទសុត្តរសូត្រ

[ ២៣៥ ] ទសុត្តរសូត្រថា **ឯវម្មេ សុតំ** ជាដើម ពណ៌នាបទដែលមិនធ្លាប់មានក្នុងទសុត្តរសូត្រនោះ ដូចតទៅនេះ

ពាក្យថា **អាវុសោ ភិក្ខវេ** នោះ ជាពាក្យហៅព្រះសាវកទាំងឡាយ ។ ពិតហើយ ព្រះពុទ្ធទាំងឡាយ កាលនឹងត្រាស់ហៅបរិស័ទ រមែងត្រាស់ថា **ភិក្ខវេ** ដូច្នេះ ។ ពួកព្រះសាវកគិតថា យើងនឹងតាំងព្រះសាស្តាទុកក្នុងទីដែលខ្ពស់ ដូច្នេះហើយ មិនហៅដោយការហៅព្រះសាស្តា រមែងហៅថា អាវុសោ ដូច្នេះ ។ ពីរបទថា **តេ ភិក្ខូ** សេចក្តីថា ភិក្ខុដែលអង្គុយហែហមព្រះធម្មសេនាបតីទាំងនោះ ។ សួរថា ភិក្ខុទាំងនោះ គឺពួកណា ។ ឆ្លើយថា ភិក្ខុដែលនៅមិនប្រចាំ គឺអ្នកទៅកាន់ទិស ។

ពិតហើយ ក្នុងគ្រាពុទ្ធកាល ពួកភិក្ខុរមែងប្រជុំគ្នា ២ វារៈ គឺក្នុងកាលចូលវស្សាដែលជិតចូលហើយ ១ ក្នុងកាលបវារណា ១ ។ កាលតិថីចូលវស្សាជិតចូលមក ពួកភិក្ខុ ១០ រូបខ្លះ ២០ រូបខ្លះ ៣០ រូបខ្លះ ៤០ រូបខ្លះ ៥០ រូបខ្លះ ជាពួកៗ រមែងមកដើម្បីកម្មដ្ឋាន ។ ព្រះមានព្រះភាគ ទ្រង់រីករាយនឹងភិក្ខុទាំងនោះ ហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុអ្វី កាលតិថីចូលវស្សាជិតចូលហើយ ពួកអ្នកទើបនាំគ្នាត្រាច់ទៅ ។ គ្រានោះ ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះមានព្រះភាគ ពួកខ្ញុំព្រះអង្គមកដើម្បីព្រះកម្មដ្ឋាន សូមព្រះអង្គប្រទាន ព្រះកម្មដ្ឋានដល់ខ្ញុំព្រះអង្គទាំងឡាយចុះ ដូច្នេះ ។ ដោយអំណាចនៃការប្រព្រឹត្តរបស់ភិក្ខុទាំងនោះ ទើបព្រះសាស្តាឲ្យអសុភកម្មដ្ឋានដល់ភិក្ខុជា

រាគចរិត ឲ្យមេត្តាកម្មដ្ឋានដល់ភិក្ខុជាទោសចរិត ឲ្យឧទ្ទេស បរិបុច្ឆា ការស្តាប់ធម៌តាមកាល ការសន្ទនាធម៌តាមកាល ដល់ភិក្ខុដែលជាមោហចរិត ត្រាស់ប្រាប់ថា កម្មដ្ឋាននេះ ជាទីសប្បាយរបស់ពួកអ្នក ដូច្នេះ ទ្រង់ឲ្យអានាបានស្សតិ-កម្មដ្ឋាន ដល់ភិក្ខុអ្នកវិតក្កចរិត ទ្រង់ប្រកាសភាពជាអ្នកត្រាស់ដឹងដ៏ប្រសើរនៃព្រះពុទ្ធ ភាពជាធម៌ដ៏ប្រសើរនៃព្រះធម៌ និងភាពជាអ្នកបដិបត្តិដ៏ប្រពៃនៃព្រះសង្ឃ ក្នុងបសាទនីយសូត្រ ដល់ភិក្ខុដែលជាសទ្ធាចរិត ទ្រង់ត្រាស់ព្រះសូត្រទាំងឡាយដ៏ជ្រាលជ្រៅ ដែលបដិសំយុត្តដោយអនិច្ចតាជាដើម ដល់ភិក្ខុដែលជាញាណចរិត ។ ពួកភិក្ខុទាំងនោះ រៀនយកព្រះកម្មដ្ឋានហើយ បើកន្លែងណាជាទីសប្បាយ ក៏នៅក្នុងទីនោះឯង បើថាមិនមានទីសប្បាយ សួរដល់សេនាសនៈជាទីសប្បាយហើយ ទើបទៅ ។ ពួកភិក្ខុទាំងនោះ នៅក្នុងទីនោះ រៀនបដិបទារហូតអស់ ៣ ខែ ប្រារព្ធព្យាយាម ព្យាយាមហើយ ជាព្រះសោតាបន្នខ្លះ ជាព្រះសកទាគាមីខ្លះ ជាព្រះអនាគាមីខ្លះ ជាព្រះអរហន្តខ្លះ ចេញវស្សាបវារណាហើយ ចាកទីនោះ ទើបទៅកាន់សម្នាក់ព្រះសាស្តាប្រាប់នូវគុណ ដែលខ្លួនបានចំពោះថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គរៀនយកព្រះកម្មដ្ឋានក្នុងសម្នាក់របស់ព្រះអង្គ សម្រេចព្រះសោតាបត្តិផលហើយ ។ល។ ខ្ញុំព្រះអង្គសម្រេចព្រះអរហត្តដែលជាផលដ៏ប្រសើរហើយ ដូច្នេះ ។ ពួកភិក្ខុទាំងនេះ មកក្នុងទីនោះ ក្នុងតិថីជាទីចូលវស្សាដែលជិតចូលមកហើយ ។ ព្រះមានព្រះភាគទ្រង់បញ្ជូនពួកភិក្ខុដែលមកហើយ ទៅកាន់សម្នាក់របស់ព្រះអគ្គសាវកទាំង-ឡាយ ។ ដូចដែលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ បានលា

សារីបុត្រ និងមោគ្គល្លានហើយឬ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គមិនទាន់បានលាព្រះសារីបុត្រ និងព្រះមោគ្គល្លានទៅឡើយទេ ដូច្នេះ ។

ពេលនោះ ទើបព្រះមានព្រះភាគបញ្ជូនភិក្ខុទាំងនោះទៅ ដើម្បីការឃើញព្រះអគ្គសាវកទាំងនោះ ដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយ ចូរសេពគប់នូវសារីបុត្រ និងមោគ្គល្លានចុះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរគប់រកនូវសារីបុត្រ និងមោគ្គល្លានចុះ ព្រោះសារីបុត្រ និងមោគ្គល្លានជាបណ្ឌិត ជាអ្នកអនុគ្រោះសព្រហ្មចារីទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ សារីបុត្រ ប្រៀបដូចជាម្តាយបង្កើតកូន ។ មោគ្គល្លានប្រៀបដូចជាអ្នកចិញ្ចឹមកូន ដែលកើតហើយ ។ ម្នាលភិក្ខុទាំងឡាយ សារីបុត្រ ទូន្មានបុគ្គលក្នុងសោតាបត្តិផល មោគ្គល្លាន ទូន្មានបុគ្គលក្នុងប្រយោជន៍ដ៏ខ្ពង់ខ្ពស់ ដូច្នេះ ។ ម្យ៉ាងទៀត សូម្បីក្នុងកាលនោះ ព្រះមានព្រះភាគ ទ្រង់ធ្វើបដិសណ្ឋារៈជាមួយភិក្ខុទាំងនេះ ហើយពិចារណាអាសយៈរបស់ភិក្ខុទាំងនោះ ទ្រង់ឃើញថា ភិក្ខុទាំងនេះ ជា **សាវកវេនេយ្យ** ដូច្នេះ ។ ធម្មតា ព្រះសាវកវេនេយ្យ រមែងត្រាស់ដឹងដោយព្រះធម៌ទេសនារបស់ព្រះពុទ្ធខ្លះ របស់ព្រះសាវកទាំងឡាយខ្លះ ។ ប៉ុន្តែ ពួកព្រះសាវក មិនអាចដើម្បីនឹងញុំាងពុទ្ធវេនេយ្យឲ្យត្រាស់ដឹងបាន ។ ព្រះសាស្តាទ្រង់ជ្រាបថា ភិក្ខុទាំងនោះ ជាសាវកវេនេយ្យ ទ្រង់ពិចារណាមើលហើយថា នឹងត្រាស់ដឹងដោយទេសនារបស់ភិក្ខុរូបណា ក៏ទ្រង់ឃើញថា ព្រះសារីបុត្រ ដូច្នេះហើយ ទើបទ្រង់បញ្ជូនទៅកាន់សម្នាក់របស់ព្រះថេរៈ ។ ព្រះ

ថេរៈសួរភិក្ខុទាំងនោះថា អ្នកមានអាយុទាំងឡាយ ពួកលោកទៅសម្នាក់ព្រះសាស្តាហើយ ទើបមកឬ ។ ភិក្ខុទាំងនោះឆ្លើយថា ករុណា ពួកខ្ញុំទៅហើយ ព្រះសាស្តាទ្រង់បញ្ជូនពួកខ្ញុំមកកាន់សម្នាក់របស់លោកម្ចាស់ ។ លំដាប់នោះ ព្រះថេរៈគិតថា ភិក្ខុទាំងនេះនឹងត្រាស់ដឹងដោយទេសនារបស់យើង ទេសនាដូចម្តេចហ្ន៎ ទើបទីនឹងសមគួរដល់ភិក្ខុទាំងនោះ ដូច្នេះ ទើបធ្វើការដាក់ចិត្តថា ភិក្ខុទាំងនេះជាអ្នកមានការសាមគ្គី ជាទីត្រេកអរ អ្នកសម្តែងសាមគ្គីរស ព្រះទេសនា ( នេះឯង ) សមគួរដល់លោកទាំងនោះ ដូច្នេះហើយ អ្នកបំណងដើម្បីនឹងសម្តែងព្រះទេសនានោះ ទើបពោលពាក្យមានជាអាទិថា យើងនឹងពោលទសុត្តរសូត្រ ដូច្នេះជាដើម ។

[ ២៣៦ ] បណ្តាបទទាំងនោះ ដែលឈ្មោះថា **ទសុត្តរ** ព្រោះអត្ថវិគ្រោះថា ដែលលោកចែកជាមាតិកាដប់ៗ ។ ដែលឈ្មោះថា **ទសុត្តរ** ព្រោះអត្ថវិគ្រោះថា តាំងពីមាតិកាមួយៗ ទៅរហូតដល់ពួក ១០ ។ ដែលឈ្មោះថា **ទសុត្តរ** ព្រោះអត្ថវិគ្រោះថា ដែលលោកធ្វើឲ្យពិសេស បញ្ហាមួយយ៉ាង ១០ ក្នុងបទ្ទៈមួយៗ នូវទសុត្តរសូត្រនោះ ។ បទថា **បវក្ខាមិ** បានដល់ នឹងពោល ។

បទថា **ធម្មំ** បានដល់ ព្រះសូត្រ ។ បទថា **និព្វានប្បត្តិយា** សេចក្តីថា ដើម្បីប្រយោជន៍នៃការបានចំពោះនូវព្រះនិព្វាន ។ បទថា **ទុក្ខស្សន្តកិរិយាយ** សេចក្តីថា ដើម្បីធ្វើទីបំផុតជុំវិញនៃវដ្តទុក្ខទាំងអស់ ។ បទថា **សព្វគន្ថប្បមោចនំ** សេចក្តីថា ការលះកិលេសជាគ្រឿងរួបរឹតទាំងពួង មានអភិជ្ឈាកាយគន្ថៈជាដើម ។ ព្រះថេរៈកាលនឹងធ្វើព្រះទេសនាឲ្យខ្ពស់ ញុំាងសេចក្តីស្រឡាញ់

ក្នុងព្រះទេសនានោះ ឲ្យកើតដល់ពួកភិក្ខុ ទើបពោលពណ៌នាដោយ ៤ បទថា ពួកភិក្ខុនឹងសម្គាល់ទសុត្តរសូត្រនោះ ដែលខ្លួនគប្បីរៀន គប្បីសិក្សា គប្បីទ្រទ្រង់ចាំ គប្បីប្រាប់ ដោយប្រការដូច្នេះ ដូចព្រះមានព្រះភាគត្រាស់ពណ៌នាព្រះសូត្រនោះៗ ដោយន័យជាដើមថា **ឯកោ ធម្មោ ភិក្ខវេ មគ្គោ** ។

## ពណ៌នាធម៌ពួក ១

[ ២៣៧ ] បណ្ដាបទទាំងនោះ បទថា **ពហុការោ** សេចក្ដីថា មានឧបការៈច្រើន ។ បទថា **ភាវេតព្វោ** សេចក្ដីថា គួរចម្រើន ។ បទថា **បរិញ្ញេយ្យោ** សេចក្ដីថា គួរកំណត់ដឹងដោយបរិញ្ញា ៣ ។ បទថា **បហាតព្វោ** សេចក្ដីថា គួរលះដោយបហានានុបស្សនា ។ បទថា **ហានភាគិយោ** សេចក្ដីថា មានប្រក្រតីឲ្យទៅកាន់អបាយ ប្រព្រឹត្តទៅព្រមដើម្បីសេចក្ដីសាបសូន្យ ។

បទថា **វិសេសភាគិយោ** សេចក្ដីថា មានប្រក្រតីឲ្យដល់នូវគុណវិសេស ប្រព្រឹត្តទៅព្រមដើម្បីសេចក្ដីវិសេស ។ បទថា **ទុប្បដិវិជ្ឈោ** សេចក្ដីថា ធ្វើឲ្យប្រចក្សបានលំបាក ។ បទថា **ឧប្បាទេតព្វោ** សេចក្ដីថា គួរឲ្យសម្រេច ។

បទថា **អភិញ្ញេយ្យោ** សេចក្ដីថា គួរដឹងក្រៃលែង ដោយញាតបរិញ្ញា ។

បទថា **សច្ឆិកាតព្វោ** សេចក្ដីថា គួរធ្វើឲ្យប្រចក្ស ។ ក្នុងមាតិកាទាំងពួងបណ្ឌិតគប្បីជ្រាបសេចក្ដី ដោយប្រការដូច្នេះ ។

[ ២៣៨ ] ព្រះសារីបុត្រ ពិចារណាដល់ព្រះទេសនាដែលជាទីសប្បាយរបស់ភិក្ខុទាំងនោះហើយ ទើបតាំងមាតិកាដោយចំណែក ១០ ចែកបទមួយៗក្នុងចំណែកមួយៗ ប្រារព្ធដើម្បីនឹងញ៉ាំងព្រះទេសនាឲ្យពិស្ដារ ដោយន័យជា

*ដើមថា ធម៌មួយ មានឧបការៈច្រើនដូចម្ដេច ។ គឺការមិនប្រមាទក្នុងកុសលធម៌ទាំងឡាយ ដូចជាជាងអ្នកឈ្លាស កាត់ឫស្សីដែលនៅត្រង់មុខហើយ ធ្វើឲ្យជាបាច់ហើយ លើកចេញដោយចំណែក ១០ ធ្វើកំណាត់មួយៗ ឲ្យជាចម្រៀកៗ ពុះចេញដូច្នោះ ដោយប្រការដូច្នេះ ។*

*បណ្ដាបទទាំងនោះ ច្រើនបទថា* **អប្បមាទោ កុសលេសុ ធម្មេសុ** *សេចក្ដីថា ព្រះថេរៈពោលសេចក្ដីមិនប្រមាទ ដែលជាឧបការៈក្នុងប្រយោជន៍ទាំងពួង ។ ពិតហើយ ធម្មតា សេចក្ដីមិនប្រមាទនេះ មានឧបការៈច្រើន ក្នុងកុសលធម៌ទាំងឡាយទាំងពួង ដោយអត្ថថា មិនមានទោស គឺក្នុងការញុំាងសីលឲ្យបរិបូណ៌ ក្នុងឥន្ទ្រិយសំវរៈ ក្នុងភាពជាអ្នកស្គាល់ប្រមាណក្នុងភោជន ក្នុងជាគរិយានុយោគ ក្នុងសទ្ធម្ម ៧ ក្នុងការឲ្យកាន់យកនូវវិបស្សនា ក្នុងបដិសម្ភិទាទាំងឡាយ មានអត្ថប្បដិសម្ភិទាជាដើម ក្នុងធម្មក្ខន្ធ ៥ មានសីលក្ខន្ធជាដើម ក្នុងឋានៈ និងអឋានៈ ក្នុងមហាវិហារសមាបត្តិ ក្នុងអរិយសច្ច ក្នុងពោធិបក្ខិយធម៌ មានសតិប្បដ្ឋានជាដើម ក្នុងវិជ្ជា ៨ ប្រការ មានវិបស្សនាញាណជាដើម ។ ព្រោះហេតុនោះឯង ព្រះមានព្រះភាគ កាលនឹងទ្រង់ប្រៀបដោយគ្រឿងប្រៀបធៀបទាំងឡាយ មានស្នាមជើងដំរីជាដើម ទ្រង់សរសើរព្រះថេរៈនោះ មានប្រការផ្សេងៗ ក្នុងអប្បមាទវគ្គ ក្នុងសំយុត្តនិកាយ ដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ សត្វមិនមានជើងក្ដី ។ល។ មានប្រមាណត្រឹមណា ព្រះតថាគត ដែលបណ្ឌិតរមែងពោលថា ជាបុគ្គលប្រសើរជាងពួកសត្វទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ កុសលធម៌ទាំងឡាយឯណានីមួយ*

កុសលធម៌ មានអប្បមាទជាទីប្រជុំចុះ មានសេចក្តីមិនប្រមាទ ដែលបណ្ឌិតរមែងពោលថា ជាកំពូលនៃធម៌ទាំងនោះ ដូច្នេះ ។ ព្រះថេរៈសង្គ្រោះសេចក្តីមិនប្រមាទទាំងអស់នោះ ដោយបទមួយ ហើយពោលថា សេចក្តីមិនប្រមាទក្នុងកុសលធម៌ទាំងឡាយ ដូច្នេះ ។ ម្យ៉ាងទៀត សេចក្តីដែលមិនប្រមាទនោះមានឧបការៈច្រើន ដែលបណ្ឌិតគប្បីសម្តែងដោយអប្បមាទវគ្គ ក្នុងធម្មបទចុះ ។ គប្បីសម្តែងដោយរឿងរបស់ព្រះបាទអសោក ។ ពិតហើយ ព្រះបាទអសោកទ្រង់ស្តាប់គាថា របស់និគ្រោធសាមណេរថា សេចក្តីមិនប្រមាទ ជាផ្លូវមិនស្លាប់ដូច្នេះប៉ុណ្ណោះ ទ្រង់ជ្រះថ្លាក្នុងសាមណេរ ដោយត្រាស់ថា ឈប់សិនបា ! លោកពោលព្រះពុទ្ធវចនៈ គឺព្រះត្រៃបិដកដល់ញោមហើយ ដូច្នេះ ទើបត្រាស់បង្គាប់ឲ្យកសាងវិហារ ៨៤០០០ ខ្នង ។ សេចក្តីដែលមិនប្រមាទ មានឧបការៈច្រើន ដែលភិក្ខុអ្នកព្រមដោយកម្លាំងពលំ គប្បីសម្តែងដោយបិដកទាំង ៣ ដូចពោលចុះ ដោយប្រការដូច្នេះ ។ បុគ្គលអ្នកនាំមកនូវព្រះគាថាយ៉ាងណាមួយ ដើម្បីសម្តែងការមិនប្រមាទ ដែលនរណាមិនពោលថា លោកតាំងនៅក្នុងទីមិនមែនជាឋានៈនាំមកហើយ ដូច្នេះ ។ កម្លាំងពល និងកម្លាំងរបស់ព្រះធម្មកថិកប៉ុណ្ណោះ ជាប្រមាណក្នុងទីនេះ ។

[ ២៣៩ ] ពាក្យថា **កាយគតាសតិ** នោះ ជាឈ្មោះរបស់សតិដែលកើតឡើងក្នុងកម្មដ្ឋានទាំងនេះ គឺខ្យល់ដកដង្ហើមចូល-ចេញ ឥរិយាបថ ៤ សតិសម្បជញ្ញៈ អាការ ៣២ ការកំណត់ធាតុ ៤ អសុភ ១០ សិវថិកសញ្ញា ៩ ការធ្វើទុកក្នុងចិត្តក្នុងសក់ជាដើមថា ជារបស់ល្អិតល្អន់ រូបជ្ឈាន ៤ ។

បទថា **សាតសហគតា** សេចក្ដីថា វៀរចតុត្ថជ្ឈានចេញ កាយគតាសតិរមែងសហគតៈដោយសេចក្ដីត្រេកអរក្នុងអារម្មណ៍ដទៃ ប្រកបដោយសេចក្ដីសុខ ។ ពាក្យថា **សាតសហគតា** នោះ លោកពោលសំដៅយក **កាយ-គតាសតិ** នោះ ។

[ ២៨០ ] ពីរបទថា **សាសវា ឧបាទានិយា** សេចក្ដីថា ជាបច្ច័យនៃអាសវៈ និងឧបាទានទាំងឡាយ ។ ព្រះថេរៈកំណត់ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដោយប្រការដូច្នេះ ។

[ ២៨១ ] បទថា **អស្មិមានោ** សេចក្ដីថា មានះថាយើង មានក្នុងរូបជាដើម ។

[ ២៨២ ] បទថា **អយោនិសោមនសិការោ** សេចក្ដីថា មនសិការក្រៅផ្លូវ ដែលប្រព្រឹត្តទៅដោយន័យជាដើមថា ទៀងក្នុងវត្ថុដែលមិនទៀង ។

[ ២៨៣ ] បណ្ឌិតគប្បីជ្រាបយោនិសោមនសិការ ដោយបរិយាយផ្ទុយគ្នា ។

[ ២៨៤ ] ពីរបទថា **អានន្តរិកោ ចេតោសមាធិ** សេចក្ដីថា ផលក្នុងលំដាប់នៃមគ្គក្នុងទីដទៃ ឈ្មោះថា **អានន្តរិកចេតោសមាធិ** ( ចេតោសមាធិដែលមិនមានចន្លោះ ) តែក្នុងទីនេះ មគ្គក្នុងលំដាប់នៃវិបស្សនា លោកប្រាថ្នាយកថា **អានន្តរិកចេតោសមាធិ** ព្រោះមានក្នុងលំដាប់នៃវិបស្សនា ឬព្រោះឲ្យផលក្នុងលំដាប់នៃខ្លួន ។

[ ២៨៥ ] ពីរបទថា **អកុប្បំ ញាណំ** សេចក្ដីថា ផលបញ្ញាក្នុងទីដទៃឈ្មោះថា ញាណដែលមិនកម្រើក ក្នុងទីនេះ លោកបំណងយកបញ្ញាដែល

ជាគ្រឿងពិចារណា ។

[ ២៨៦ ] បទថា **អាហារដ្ឋិតិកា** សេចក្ដីថា តាំងនៅព្រោះបច្ច័យ ។ ច្រើនបទថា **អយំ ឯកោ ធម្មោ** សេចក្ដីថា សត្វទាំងនោះ តាំងនៅព្រោះបច្ច័យណា បច្ច័យនេះ គឺធម៌មួយ ។ គួរដឹងក្រៃលែងដោយញាតបរិញ្ញា គឺដោយអភិញ្ញា ។

[ ២៨៧ ] ការរួបផុតនៃព្រះអរហត្តផល ឈ្មោះថា **អកុប្បា ចេតោ-វិមុត្តិ** ។ ក្នុងវារៈនេះ លោកពោលញាតបរិញ្ញា ដោយអភិញ្ញា ពោលតីរណបរិញ្ញា ដោយបរិញ្ញា ។ ការកំណត់ដឹងក្នុងការលះ ដោយកិច្ចដែលគួរលះ និងគួរធ្វើឲ្យជាក់ច្បាស់ ។ លោកពោលមគ្គក្នុងបទនេះថា **ឧប្បដិ-វិជ្ឈោ** ។ លោកពោលផលក្នុងបទថា **សច្ឆិកាតព្វោ** នេះ ។ បណ្ឌិតរមែងបានមគ្គក្នុងបទ មួយប៉ុណ្ណោះ ។ តែរមែងបានផល សូម្បីក្នុងច្រើនបទនោះឯង ។

បទថា **ភូតា** សេចក្ដីថា មានដោយសភាវៈ ។ បទថា **តច្ឆា** សេចក្ដីថា ពិតប្រាកដ ។ បទថា **តថា** សេចក្ដីថា មានសភាវៈដូចពោលហើយ ។ បទថា **អវិតថា** សេចក្ដីថា មិនមានសភាវៈដូចដែលពោលហើយ ក៏មិនមែន ។ បទថា **អនញ្ញថា** សេចក្ដីថា មិនមានដោយប្រការដទៃអំពីប្រការដែលពោលហើយ ។ ច្រើនបទថា **សម្មា តថាគតេន អភិសម្ពុទ្ធា** សេចក្ដីថា ធម៌ទាំងឡាយដែលព្រះតថាគត ប្រថាប់ អង្គុយត្រង់ពោធិបល្ល័ង្ក ត្រាស់ដឹងហើយ គឺជ្រាបហើយ ដឹងច្បាស់ហើយ បានដល់ ធ្វើឲ្យច្បាស់ហើយ ដោយព្រះអង្គឯងតែម្យ៉ាង ដោយហេតុ គឺដោយការណ៍ ។ ដោយហេតុនេះ ព្រះថេរៈកាលនឹងសម្ដែងជិនសូត្រ

ញុំាងសេចក្តីជាក់ចិត្តជឿឲ្យកើតថា ធម៌ទាំងនេះ ដែលព្រះតថាគតត្រាស់ដឹងហើយ ចំណែកយើងដូចគ្នានឹងអ្នកប្រាប់ផ្លូវរបស់ព្រះរាជា នៃពួកលោក ដូច្នេះ ។

**ពណ៌នាធម៌ពួក ១ ចប់**

## ពណ៌នាធម៌ពួក ២

[ ២៤៩ ] ត្រង់បទថា **ឥមេ ទ្វេ ធម្មា ពហុការា** សេចក្តីថា ធម៌ គឺសតិ និងសម្បជញ្ញៈ ទាំង ២ នេះ មានឧបការៈ គឺនាំប្រយោជន៍មកឲ្យក្នុងទីទាំងពួង ដូចសេចក្តីមិនប្រមាទ មានឧបការៈក្នុងកិច្ចទាំងឡាយ មានការបំពេញសីលដូច្នោះជាដើម ។

[ ២៥០ ] ត្រង់បទថា **សមថោ ច វិបស្សនា ច** សេចក្តីថា ធម៌ដែលជាលោកិយ និងលោកុត្តរ ទាំង ២ នេះ លោកពោលទុកក្នុងសង្គីតិសូត្រ ។

ចំណែកខាងដើម លោកពោលក្នុងទសុត្តរសូត្រនេះ ។

[ ២៥៥ ] ត្រង់បទថា **សត្តានំ សង្កិលេសាយ សត្តានំ វិសុទ្ធិយា** សេចក្តីថា អយោនិសោមនសិការជាហេតុ និងជាបច្ច័យដើម្បីសេចក្តីសៅហ្មងនៃសត្វទាំងឡាយ យោនិសោមនសិការជាហេតុ និងជាបច្ច័យ ដើម្បីសេចក្តីហ្មត់ចត់នៃសត្វទាំងឡាយ ។ ដូច្នោះ ភាពជាអ្នកលំបាក ភាពជាអ្នកមានមិត្តអាក្រក់ ក៏ជាហេតុ ជាបច្ច័យ ដើម្បីសេចក្តីសៅហ្មងនៃសត្វទាំងឡាយ ភាពជាអ្នកប្រដៅងាយ ភាពជាអ្នកមានកល្យាណមិត្ត ក៏ជាហេតុ ជាបច្ច័យដើម្បីសេចក្តីបរិសុទ្ធិនៃសត្វទាំងឡាយដូចគ្នា ។ អកុសលមូល ៣ កុសលមូល ៣

យោគៈ ៤ វិសំយោគៈ ៤ ចេតោខីលៈ ៥ ឥន្ទ្រិយ ៥ អគារវៈ ៦ គារវៈ ៦ អសទ្ធម្ម ៧ សទ្ធម្ម ៧ កុសីតវត្ថុ ៨ អារព្ភវត្ថុ ៨ អាឃាតវត្ថុ ៩ អាឃាត-ប្បដិវិន័យ ៩ អកុសលកម្មបថ ១០ កុសលកម្មបថ ១០ ជាធម៌តែមួយៗ មាន ២ ប្រភេទ ដូចដែលពោលមកនេះ ទាំងនេះ បណ្ឌិតគប្បីជ្រាបថា ត្រាស់ដឹងបានដោយក្រ ។

[ ២៥៧ ] ពីរបទថា **សង្ខតា ធាតុ** សេចក្តីថា ខន្ធ ៥ ដែលបច្ច័យទាំងឡាយតាក់តែងហើយ ។ ពីរបទថា **អសង្ខតា ធាតុ** សេចក្តីថា ព្រះនិព្វានដែលបច្ច័យទាំងឡាយមិនបានតាក់តែង ។

[ ២៥៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងពីរបទនេះថា **វិជ្ជា ច វិមុត្តិ ច** ដូច្នេះ វិជ្ជា ៣ ឈ្មោះថា **វិជ្ជា** អរហត្តផល ឈ្មោះថា **វិមុត្តិ** ។ ក្នុងវារៈនេះ គុណពិសេសទាំងឡាយ មានអភិញ្ញាជាដើម ក៏ដូចគ្នានឹងគុណវិសេសតែមួយៗ ។ ចំណែកមគ្គ លោកពោលក្នុងបទដែលគួរឲ្យកើតឡើង ។

ផល លោកពោលក្នុងបទដែលគួរធ្វើឲ្យជាក់ច្បាស់ ។

**ពណ៌នាធម៌ពួក ២ ចប់**

## ពណ៌នាធម៌ពួក ៣

[ ២៦៦ ] អនាគាមិមគ្គ លោកប្រាថ្នាយកនេក្ខម្មៈ ក្នុងពាក្យនេះថា គុណជាតិ គឺនេក្ខម្មៈនោះ ជាគ្រឿងរលាស់ចេញនូវកាមទាំងឡាយ ដូច្នេះ ។ ពិតហើយ អនាគាមិមគ្គនោះ ជាគ្រឿងរលាស់ចេញចាកកាមទាំងឡាយ ដោយ

ប្រការទាំងពួង ។ អរហត្តមគ្គរមែងមានសូម្បីក្នុងអរូប ក្នុងពាក្យនេះថា គុណ-ជាត គឺអរូបនោះ ជាគ្រឿងរលាស់ចេញចាករូបទាំងឡាយ ដូច្នេះ ។ អរហត្តមគ្គ ឈ្មោះថា ជាគ្រឿងរលាស់ចេញចាករូបទាំងឡាយ ដោយប្រការទាំងពួង ព្រោះហាមការកើតឡើងទៀត ។ ត្រង់បទថា **និរោធោ តស្ស និស្សរណំ** សេចក្ដីថា អរហត្តផល លោកបំណងយកថា ជានិរោធក្នុងព្រះសាសនានេះ ។ ពិតហើយ កាលព្រះនិព្វាន ដែលព្រះអរហត្តផលឃើញហើយ សង្ខារទាំងពួង ក៏រមែងមិនមានតទៅទៀត ព្រោះហេតុនោះ ទើបអរហត្ត លោកពោលថា ជានិរោធ ព្រោះជាបច្ច័យនៃសង្ខតនិរោធ ។

[ ២៦៧ ] បទថា **អតីតំសញ្ញាណំ** សេចក្ដីថា ញាណដែលមានអតីតជាអារម្មណ៍ ។ សូម្បីក្នុងញាណក្រៅនេះ ក៏ន័យនេះដូចគ្នា ។

[ ២៦៨ ] សូម្បីក្នុងវារៈនេះ អភិញ្ញាជាដើម ក៏ដូចគ្នានឹងគុណវិសេសមួយៗ ។ លោកពោលមគ្គ ក្នុងបទដែលត្រាស់ដឹងបានដោយក្រ ។ ពោលផលក្នុងបទដែលគួរធ្វើឲ្យជាក់ច្បាស់ ។

**ពណ៌នាធម៌ពួក ៣ ចប់**

# ពណ៌នាធម៌ពួក ៤

[ ២៧១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងពីរបទនេះថា **ចត្តារិ ចក្កានិ** ដូច្នេះ ធម្មតាចក្រមាន ៥ យ៉ាង គឺចក្រ គឺឈើ ១ ចក្រ គឺកែវ ១ ចក្រ គឺធម៌ ១ ចក្រ គឺឥរិយាបថ ១ ចក្រ គឺសមាបត្តិ ១ ។ បណ្ដាចក្រទាំងនោះ ចក្រនេះ គឺនៃជាងរថ ជាអ្នកធ្វើចក្រឲ្យសម្រេចហើយ ក្នុងវេលា ៦ ខែ ៦ រាត្រី ឈ្មោះថា ចក្រ

គឺឈើ ។

ចក្រនេះ គឺបុគ្គលប្រព្រឹត្តទៅតាមចក្រ ដែលបិតាឲ្យប្រព្រឹត្តទៅហើយ ឈ្មោះថា ចក្រ គឺកែវ ។

ចក្រនេះ គឺចក្រដែលតថាគតឲ្យប្រព្រឹត្តទៅ ឈ្មោះថា ចក្រ គឺធម៌ ។

ចក្រនេះ គឺអវយវៈ ដែលមានចក្ក ៤ មានទ្វារ ៩ ឈ្មោះថា ចក្រ គឺឥរិយាបថ ។ ចក្រនេះ គឺម្ចាលភិក្ខុទាំងឡាយ ចក្រ ៤ រមែងប្រព្រឹត្តទៅទូទាំងទេវតា និងមនុស្សទាំងឡាយ អ្នកប្រកបដោយចក្រ ៤ ពួកណា ចក្រទាំង ៤ នេះ ឈ្មោះថា ចក្រ គឺសមាបត្តិ ។ ចក្រ គឺសមាបត្តិនោះឯង លោកប្រាថ្នាយកក្នុងទីនេះ ។

បទថា **បដិរូបទេសវាសោ** សេចក្តីថា បរិស័ទ ៤ រមែងប្រាកដក្នុងទីណា ការនៅក្នុងប្រទេសដែលសមគួរបែបនោះ ក្នុងទីនោះ ។ បទថា **សប្បុរិសូ-បនិស្សយោ** សេចក្តីថា ការអាស្រ័យ គឺការសេព ការសេពគប់ បានដល់ការចូលទៅអង្គុយជិតសប្បុរសទាំងឡាយមានព្រះពុទ្ធជាដើម ។ បទថា **អត្ត-សម្មាបណិធិ** សេចក្តីថា ការតម្កល់នូវខ្លួនទុកដោយប្រពៃ ។ ប្រសិនបើបុគ្គលជាអ្នកប្រកបហើយដោយទោសៈទាំងឡាយ មានភាពជាអ្នកមិនមានសទ្ធាជាដើម ក្នុងកាលមុន ការលះនូវទោសៈ មានភាពជាអ្នកមិនមានសទ្ធាជាដើមទាំងនោះហើយ តាំងនៅក្នុងគុណ មានសទ្ធាជាដើម ។ ពីរបទថា **បុញ្ញេ ច កតបុញ្ញតា** សេចក្តីថា ភាពជាអ្នកមានកុសលដែលខ្លួនសន្សំទុកហើយ ក្នុងកាលមុន ។ គុណជាត គឺភាពជាអ្នកមានកុសលដែលខ្លួនសន្សំទុកហើយ ក្នុង

កាលមុននុ៎ះឯង ជាប្រមាណក្នុងទីនេះ ។ ពិតហើយ កុសលកម្ម រមែងជាកម្មដែលបុរសធ្វើដោយញាណសម្បយុត្តចិត្តណា ញាណសម្បយុត្តចិត្តនុ៎ះឯងដែលជាកុសល រមែងនាំបុរសនោះទៅក្នុងប្រទេសដែលសមគួរ គឺឲ្យសេពគប់សប្បុរសទាំងឡាយ ។ ម្យ៉ាងទៀត បុគ្គលនោះឯង ឈ្មោះថា តាំងខ្លួនដោយប្រពៃហើយ លោកិយតែ ១ លោកពោលក្នុងអាហារ ៤ ។ ចំណែកដ៏សេស លោកពោលក្នុងសង្គីតិសូត្រថា លាយដោយលោកិយ និងលោកុត្តរ ។ លោកពោលលោកិយទាំងនោះឯង ទុកក្នុងចំណែកខាងដើមក្នុងទីនេះ ។

[ ២៧៥-២៨០ ] បណ្ឌិតគប្បីជ្រាបធម៌ទាំងឡាយ មានកាមយោគៈ និងកាមវិសំយោគៈជាដើម ដោយអំណាចនៃអនាគាមិមគ្គជាដើម ។ សញ្ញា និងមនសិការ ដែលសហគតៈដោយកាម រមែងរួបរឹតបុគ្គលដែលបានបឋមជ្ឈានក្នុងធម៌ដែលប្រព្រឹត្តទៅ ក្នុងចំណែកខាងសាបសូន្យជាដើម **សមាធិ** ក៏ជាហានភាគិយៈ ( ប្រព្រឹត្តទៅក្នុងចំណែកខាងសាបសូន្យ ) **សតិ** ដែលកើតរួមជាមួយសមាធិនោះ រមែងតាំងមាំ ទើបសមាធិ ជាឋិតិភាគិយៈ សញ្ញា និងមនសិការដែលសហគតៈដោយអវិតក្ក រមែងប្រាកដសមាធិ ក៏ជាវិសេសភាគិយៈ សញ្ញា និងមនសិការ ដែលសហគតៈដោយនិព្វិទា រមែងប្រាកដសមាធិ ក៏ជានិព្វេធភាគិយៈ ដែលវិរាគៈកើតរួមហើយ ព្រោះហេតុនោះ បណ្ឌិតគប្បីញុំាងសមាបត្តិទាំងពួងឲ្យពិស្តារ ហើយគប្បីជ្រាបសេចក្តីដោយន័យនេះ ។ ចំណែកក្នុងវិសុទ្ធិមគ្គ លោកពោលវិនិច្ឆយកថា សេចក្តីនោះហើយ ។ ក្នុងវារៈនេះ អភិញ្ញាជាដើម ក៏ដូចគ្នានឹងគុណវិសេសមួយៗ ។ មគ្គលោកពោលក្នុងទីនេះ

ក្នុងអភិញ្ញាបទ ។ ពោលផលក្នុងបទដែលគួរធ្វើឲ្យច្បាស់ ។

**ពណ៌នាធម៌ពួក ៨ ចប់**

## ពណ៌នាធម៌ពួក ៩

[ ២៨៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងបីតិផ្សាយទៅជាដើមតទៅ បីតិកាលផ្សាយទៅ រមែងកើតឡើង ព្រោះហេតុនោះ បញ្ញាក្នុងឈាន ២ ឈ្មោះថា បីតិផ្សាយទៅ ។ សុខកាលផ្សាយទៅ រមែងកើតឡើង ព្រោះហេតុនោះ បញ្ញាក្នុងឈាន ៣ ឈ្មោះថា សុខផ្សាយទៅ ។ បញ្ញាកាលផ្សាយទៅកាន់ចិត្តរបស់ជនពួកដទៃកើតឡើង ព្រោះហេតុនោះ បញ្ញាដែលកំណត់ដឹងចិត្ត ឈ្មោះថា ចិត្តផ្សាយទៅ ។ បញ្ញាកើតឡើងក្នុងពន្លឺផ្សាយទៅ ព្រោះហេតុនោះ បញ្ញាក្នុងទិព្វចក្ខុ ឈ្មោះថា ពន្លឺផ្សាយទៅ ។ ញាណជាគ្រឿងពិចារណា ឈ្មោះថា និមិត្តជាគ្រឿងពិចារណា ។ សមពិតដូចពាក្យដែលលោកពោលដូច្នេះថា បញ្ញាក្នុងឈាន ២ ឈ្មោះថា បីតិផ្សាយទៅ បញ្ញាក្នុងឈាន ៣ ឈ្មោះថា សុខផ្សាយទៅ បញ្ញាក្នុងចិត្តរបស់អ្នកដទៃ ( ដឹងចិត្តរបស់អ្នកដទៃ ) ឈ្មោះថា ចិត្តផ្សាយទៅ ទិព្វចក្ខុ ឈ្មោះថា ពន្លឺផ្សាយទៅ ញាណជាគ្រឿងពិចារណា របស់លោកអ្នកចេញចាកសមាធិនោះៗ ឈ្មោះថា និមិត្តជាគ្រឿងពិចារណា ។ បណ្តាបទទាំងនោះ បីតិផ្សាយទៅ សុខផ្សាយទៅ ប្រៀបដូចជើងទាំង ២ ។ ចិត្តផ្សាយទៅ ពន្លឺផ្សាយទៅ ប្រៀបដូចដៃទាំង ២ ។ ឈានដែលជាបាទនៃអភិញ្ញា ប្រៀបដូចកាយកំណាត់កណ្តាល និមិត្តជាគ្រឿងពិចារណា ប្រៀបដូចសិរសា ។ ព្រះសារីបុត្តត្ថេរ សម្តែងសម្មាសមាធិ ដែលប្រកបដោយអង្គ ៥ ធ្វើឲ្យដូចជាបុរស

អ្នកសម្បូរដោយអវយវៈតូចធំ ដោយប្រការដូច្នេះ ។

[ ២៨៩ ] សមាធិក្នុងអរហត្តផល លោកប្រាថ្នាយកក្នុងពាក្យជាដើមថា សមាធិនេះ ជាសុខក្នុងបច្ចុប្បន្នផងនោះឯង ។

ពិតហើយ សមាធិក្នុងអរហត្តផលនោះ ឈ្មោះថា សុខក្នុងបច្ចុប្បន្ន ព្រោះជាសុខក្នុងខណៈដែលសម្រេចហើយ ។ សមាធិដើមៗ ជាវិបាកនៃសុខតទៅ ព្រោះជាបច្ច័យនៃសុខក្នុងសមាធិក្រោយៗ ដែលឈ្មោះថា អរិយៈ ព្រោះភាពជាអ្នកឃ្លាតឆ្ងាយចាកកិលេសទាំងឡាយ ។ ដែលឈ្មោះថា និរាមិសៈ ព្រោះការមិនមាននៃអាមិសៈ គឺកាមាមិសៈ គឺវដ្តៈ និងអាមិសៈ គឺលោក ។ ដែលឈ្មោះថា មិនសេពបុគ្គលអាក្រក់ ព្រោះភាពជាអ្នកសេពមហាបុរសទាំងឡាយមានព្រះពុទ្ធជាដើម ។ ដែលឈ្មោះថា សប្បុរស ព្រោះអវយវៈស្ងប់ ព្រោះអារម្មណ៍ស្ងប់ និងព្រោះសេចក្តីខ្វល់ខ្វាយ គឺកិលេសទាំងពួងស្ងប់ ។ ដែលឈ្មោះថា ប្រណីត ព្រោះអត្ថថា មិនក្តៅក្រហាយ ។ ដែលឈ្មោះថា បានសេចក្តីស្ងប់ស្ងាត់ ព្រោះបានសេចក្តីស្ងប់រម្ងាប់កិលេស ឬព្រោះបានភាព គឺការស្ងប់រម្ងាប់កិលេស ។ ពិតហើយ ពីរបទនេះ គឺ **បដិប្បស្សទ្ធំ បដិប្បស្សទ្ធិ** ដោយសេចក្តីក៏ដូចគ្នា ។ ម្យ៉ាងទៀត ឈ្មោះថា បានសេចក្តីស្ងប់រម្ងាប់ ព្រោះការដែលព្រះអរហន្តអ្នកមានកិលេសស្ងប់រម្ងាប់ហើយ ។ ដែលឈ្មោះថា សម្រេចភាពជាធម៌ឯកកើតឡើង (ការចូលសមាធិដែលមានការសម្គាល់) ព្រោះសម្រេចដោយឯកោទិភាវៈ ឬព្រោះសម្រេចនូវឯកោទិភាវៈ ។ ឈ្មោះថា សម្រេចឯកោទិភាវៈ ព្រោះព្រះយោគាវចរគ្រប់សង្កត់បច្ចនិកធម៌ ហាមកិលេសហើយ

មិនសម្រេចដោយសម្បយោគចិត្ត ដែលជាសសង្ខារ ដូចជាសាសវៈសមាធិ ដែលមានគុណតិច ដូច្នោះ និងព្រោះមិនគ្របសង្កត់សម្បយោគចិត្ត ដែលជាសសង្ខារ ។ម្យ៉ាងទៀត ព្រះយោគាវចរកាលចូលសមាធិនោះ ឬកាលចេញអំពីសមាធិនោះ រមែងមានសតិចូល រមែងមានសតិចេញ ព្រោះភាពជាអ្នកដល់សេចក្តីបរិបូរនៃសតិ ។ម្យ៉ាងទៀត ព្រះយោគាវចរ ឈ្មោះថា មានស្មារតីចូលកាន់សមាធិនេះ និងមានស្មារតីចេញអំពីសមាធិនេះ ដោយអំណាចនៃកាលតាមដែលខ្លួនកំណត់ ។ ព្រោះហេតុនោះ ក្នុងទីនេះ កាលព្រះយោគាវចរពិចារណាយ៉ាងនេះថា សមាធិនេះ មានសុខក្នុងបច្ចុប្បន្ន និងមានសុខជាវិបាកតទៅ ដូច្នេះ **អបរបច្ចយាណា** ដែលជារបស់ចំពោះខ្លួនទុំះឯង រមែងកើតឡើង អបរបច្ចយាណនោះ ក៏ជាអង្គមួយ ។ ក្នុងបទដ៏សេស ក៏ន័យនេះដូចគ្នា ។

សមាធិនេះ លោកហៅថា សម្មាសមាធិ ប្រកបដោយញាណ ៥ ដោយបច្ចវេក្ខណញ្ញាណទាំង ៥ នេះ ដោយប្រការដូច្នេះ ។

ក្នុងវារៈនេះ លោកពោលមគ្គ ក្នុងបទដែលជាចំណែកនៃគុណវិសេស ។ ពោលផលក្នុងបទគួរធ្វើឲ្យច្បាស់ ។ ពាក្យដ៏សេសដូចគ្នានឹងពាក្យដើមទុំះឯង ។

## ពណ៌នាធម៌ពួក ៥ ចប់

# ពណ៌នាធម៌ពួក ៦

[ ២៩២ ] ពាក្យទាំងពួងក្នុងពួក ៦ មានសេចក្តីជាក់ច្បាស់ហើយនោះឯង ។ លោកពោលមគ្គក្នុងទីនេះ ក្នុងពាក្យថា ចាក់ធ្លុះបានលំបាក ។ ពាក្យ

ដ៏សេសដូចគ្នានឹងពាក្យដើម ។

**ពណ៌នាធម៌ពួក ៦ ចប់**

## ពណ៌នាធម៌ពួក ៧

[ ៣១៣ ] ត្រើនបទថា **សម្មប្បញ្ញាយ សុទិដ្ឋា ហោន្តិ** សេចក្តីថា រមែងជាអ្នកឃើញល្អ ដោយវិបស្សនាញាណ ដោយហេតុទាំង ២ ។ បទថា **កាមា** គឺវត្ថុកាម និងកិលេសកាម ។ កាមទាំងពីរ មានសភាពដែលព្រះយោគាវចរឃើញដោយល្អ ដូចរណ្តៅរងើកភ្លើង ព្រោះអត្ថថា មានសេចក្តីក្តៅផ្សា ។ បទថា **វិវេកនិន្នំ** សេចក្តីថា បង្អោនទៅព្រះនិព្វាន ។ ពាក្យថា ឈានទៅ បែរទៅ នោះ ជាវេវចនៈនៃការបង្អោនទៅ ។ បទថា **ព្យន្តីភូតំ** សេចក្តីថា អ្នកមានទីបំផុតដែលគួរនាំទៅ ទៅប្រាសហើយ អធិប្បាយថា អ្នកមានតណ្ហាប្រាសទៅហើយ ។ ដោយធម៌ដែលជាទីតាំងនៃអាសវៈ ដោយប្រការទាំងពួង យ៉ាងណា អធិប្បាយថា ដោយធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ ក្នុងទីនេះ លោកពោលមគ្គ ក្នុងបទដែលគួរចម្រើន ។ ពាក្យដ៏សេស ដូចគ្នានឹងពាក្យដើមទាំងឯង ។

**ពណ៌នាធម៌ពួក ៧ ចប់**

## ពណ៌នាធម៌ពួក ៨

[ ៣១៥ ] ពីរបទថា **អាទិព្រហ្មចរិយកាយ បញ្ញាយ** សេចក្តីថា នៃសមថៈ និងវិបស្សនាបញ្ញាទន់ខ្សោយ ក្នុងចំណែកខាងដើម ព្រោះជាខាងដើម

នៃមគ្គព្រហ្មចរិយៈ សង្គ្រោះដោយត្រៃសិក្ខា ។ម្យ៉ាងទៀត នៃបញ្ញាក្នុងសម្មាទិដ្ឋិ ដែលជាខាងដើមនៃមគ្គមានអង្គ ៨ ។ បទថា **តិព្វំ** គឺមានកម្លាំង ។

បទថា **ហិរោត្តប្បំ** បានដល់ ហិរិ និងឱត្តប្បៈ ។ បទថា **បេមំ** បានដល់ សេចក្ដីស្រឡាញ់អាស្រ័យផ្ទះ ។ បទថា **គារវោ** បានដល់ ភាពជាអ្នកមានចិត្តធ្ងន់ ។ ពិតហើយ កាលបុគ្គលចូលទៅអាស្រ័យបុគ្គលដែលគួរដល់ការគោរព កិលេសទាំងឡាយ រមែងមិនកើតឡើង បុគ្គលនោះរមែងបានឱវាទ និងពាក្យទូន្មាន ព្រោះហេតុនោះ ការអាស្រ័យបុគ្គលនោះហើយ រមែងជាបច្ច័យនៃការបានបញ្ញា ។

[ ៣២១ ] គប្បីជ្រាបវិនិច្ឆ័យក្នុងអក្ខណៈតទៅ ព្រោះហេតុដែលពួកប្រេតដល់អាវាហៈ ដល់វិវាហៈនឹងពួកអសុរ ដូច្នោះ អសុរកាយ បណ្ឌិតគប្បីជ្រាបថា លោកកាន់យកដោយបិត្តិវិស័យនុ៎ះឯង ( វិស័យនៃប្រេត ) ។

[ ៣២២ ] គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យនេះថា **អប្បិច្ឆស្ស** តទៅ សេចក្ដីប្រាថ្នាតិច ៤ យ៉ាង គឺសេចក្ដីប្រាថ្នាតិចក្នុងបច្ច័យ ១ សេចក្ដីប្រាថ្នាតិចក្នុងគុណធម៌ជាគ្រឿងសម្រេច ១ សេចក្ដីប្រាថ្នាតិចក្នុងបរិយត្តិ ១ សេចក្ដីប្រាថ្នាតិចក្នុងធុតង្គ ១ ។ បណ្ដាសេចក្ដីប្រាថ្នាតិចទាំងនោះ បុគ្គលដែលប្រាថ្នាតិចដោយបច្ច័យ កាលគេឲ្យច្រើន ក៏ទទួលយកតែតិច កាលគេឲ្យតិច ក៏ទទួលយកតិចជាង ឬថា មិនទទួលយកឡើយ រមែងជាអ្នកមិនទទួលយកដោយមិនសល់ទុក ។

បុគ្គលដែលប្រាថ្នាតិច ក្នុងគុណធម៌ជាគ្រឿងសម្រេច រមែងមិនឲ្យជន

ពួកដទៃដឹងគុណធម៌ ជាគ្រឿងសម្រេចរបស់ខ្លួន ដូចព្រះមជ្ឈន្តិកត្ថេរ ដូច្នោះ ។

បុគ្គលដែលប្រាថ្នាតិចក្នុងបរិយត្តិ សូម្បីជាអ្នកទ្រទ្រង់ព្រះត្រៃបិដក ក៏មិនប្រាថ្នាឲ្យអ្នកដទៃដឹងថា ខ្លួនជាពហុស្សូត ដូចព្រះសាកេតតិស្សត្ថេរ ដូច្នោះ ។

បុគ្គលដែលប្រាថ្នាតិចក្នុងធុតង្គ រមែងមិនឲ្យជនពួកដទៃដឹងដល់ការរក្សាធុតង្គ ដូចព្រះជេដ្ឋកត្ថេរ ដែលជាព្រះថេរៈបងប្អូនប្រុសគ្នា ២ អង្គ ដូច្នោះ ។ លោកពោលរឿងទុកក្នុងវិសុទ្ធិមគ្គហើយ ។

ពីរបទថា **អយំ ធម្មោ** សេចក្តីថា លោកុត្តរធម៌ ៩ នេះ រមែងសម្រេចដល់បុគ្គល ដែលមានសេចក្តីប្រាថ្នាតិច ព្រោះពួនសម្ងំក្នុងគុណដែលមានហើយ និងព្រោះភាពជាអ្នកស្គាល់ប្រមាណក្នុងការទទួល មិនសម្រេចដល់បុគ្គលដែលប្រាថ្នាច្រើនឡើយ ។ បណ្ឌិតគប្បីប្រកបពាក្យក្នុងទីទាំងពួងដោយប្រការដូច្នេះ ។

បទថា **សន្តុដ្ឋស្ស** សេចក្តីថា អ្នកសន្តោស ដោយការសន្តោស ៣ យ៉ាងក្នុងបច្ច័យ ៤ ។ **បវិវិត្តស្ស** សេចក្តីថា អ្នកស្ងាត់ហើយដោយកាយវិវេក ចិត្តវិវេក និងឧបធិវិវេក ។ បណ្តាវិវេកទាំងនោះ ភាពជាអ្នកបន្ទោបង់ការនៅប្រឡូកប្រឡំដោយពួក រស់នៅតែម្នាក់ឯង ដោយអំណាចនៃអារព្ភវត្ថុ ៨ ឈ្មោះថា **កាយវិវេក** ។ កម្ម រមែងមិនសម្រេចដោយហេតុត្រឹមតែថា ការរស់នៅតែម្នាក់ឯង ព្រោះហេតុនោះ ព្រះយោគាវចរធ្វើបរិកម្មកសិណហើយ ញ៉ាំងសមាបត្តិ ៨ ឲ្យកើតយ៉ាងនេះ ឈ្មោះថា **ចិត្តវិវេក** ។ កម្ម រមែងមិនសម្រេចដោយហេតុត្រឹមតែសមាបត្តិប៉ុណ្ណោះ ព្រោះហេតុនោះ ព្រះយោគាវចរធ្វើឈានឲ្យជាបាទ ពិចារណាសង្ខារទាំងឡាយហើយ សម្រេចអរហត្តព្រមទាំងបដិសម្ភិទា

ទាំងឡាយ យ៉ាងនេះឈ្មោះថា **ឧបធិវិវេក** ដោយហេតុនោះ ទើបព្រះមានជោគ ត្រាស់ថា កាយវិវេក រមែងមានដល់បុគ្គលដែលមានកាយតាំងនៅក្នុង សេចក្ដីស្ងប់ស្ងាត់ អ្នកត្រេកអរក្រៃលែងហើយក្នុងនេក្ខម្មៈ ចិត្តវិវេក រមែងមាន ដល់បុគ្គលដែលមានចិត្តបរិសុទ្ធ អ្នកបរិបូណ៌នូវសេចក្ដីផូរផង់យ៉ាងក្រៃលែង និងឧបធិវិវេក រមែងមានដល់បុគ្គលដែលអស់ឧបធិ អ្នកបរិបូណ៌នូវភាពជា វិសង្ខារ ដូច្នេះ ។

បទថា **សង្គណិកាភាមស្ស** សេចក្ដីថា អ្នកត្រេកអរហើយ ដោយការ នៅច្របូកច្របល់ដោយពួក និងការនៅច្របូកច្របល់ដោយកិលេស ។ បទថា **អារទ្ធវិរិយស្ស** សេចក្ដីថា អ្នកប្រារព្ធសេចក្ដីព្យាយាម ដោយអំណាចនៃសេចក្ដី ព្យាយាម ដែលប្រព្រឹត្តទៅផ្លូវកាយ និងប្រព្រឹត្តទៅផ្លូវចិត្ត ។ បទថា **ឧបដ្ឋិតស្ស-តិស្ស** សេចក្ដីថា អ្នកមានសតិតាំងមាំ ដោយអំណាចនៃសតិប្បដ្ឋាន ៤ ។ បទ ថា **សមាហិតស្ស** សេចក្ដីថា អ្នកប្រកបដោយចិត្តមានអារម្មណ៍ខ្ពង់ខ្ពស់ ។

បទថា **បញ្ញវតោ** សេចក្ដីថា អ្នកមានបញ្ញា ដោយកម្មស្សកតាបញ្ញា ។ បទថា **និប្បបញ្ចស្ស** សេចក្ដីថា អ្នកមានសេចក្ដីយឺតយូរ គឺមានះ តណ្ហា និង ទិដ្ឋិខាងក្នុង ប្រាសទៅហើយ ។ លោកពោលមគ្គទុកក្នុងបទដែលគួរចម្រើន ក្នុងទីនេះ ។ ពាក្យដ៏សេស ដូចគ្នានឹងពាក្យដើមទាំងឯង ។

**ពណ៌នាធម្មិក្លក ៨ ចប់**

## **ពណ៌នាធម៌ពួក ៩**

[ ៣២៧ ] បទថា **សីលវិសុទ្ធិ** សេចក្តីថា បារិសុទ្ធិសីល ៤ អាចនឹងឲ្យសត្វដល់នូវសេចក្តីបរិសុទ្ធិបាន ។ បទថា **ចារិសុទ្ធិប្បធានិយង្គំ** សេចក្តីថា អង្គដែលជាប្រធាននៃសេចក្តីបរិសុទ្ធិ ។ បទថា **ចិត្តវិសុទ្ធិ** សេចក្តីថា សមាបត្តិដែលស្ទាត់ជំនាញ ៨ យ៉ាង ជាបទដ្ឋាននៃវិបស្សនា ។ បទថា **ទិដ្ឋិវិសុទ្ធិ** សេចក្តីថា ការឃើញនាមរូបព្រមទាំងបច្ច័យ ។ បទថា **កង្ខាវិតរណវិសុទ្ធិ** បានដល់ សេចក្តីដឹងក្នុងបច្ចយាការ ។ ពិតហើយ កាលបុគ្គលឃើញថា ធម៌ទាំងឡាយ រមែងប្រព្រឹត្តទៅ ដោយអំណាចនៃបច្ច័យ សូម្បីក្នុងកាលទាំង ៣ នុ៎ះឯង ដូច្នេះ រមែងឆ្លងសេចក្តីសង្ស័យចេញបាន ។ បទថា **មគ្គាមគ្គញ្ញាណ-ទស្សនវិសុទ្ធិ** បានដល់ សេចក្តីដឹងថា ផ្លូវ និងមិនមែនផ្លូវយ៉ាងនេះថា ឧបក្កិ-លេស មានពន្លឺជាដើម មិនមែនផ្លូវ ឧទយព្វយញ្ញាណដែលជាដំណើរទៅកាន់វីថិ ជាផ្លូវ ( សម្រេច ) ដូច្នេះ ។

បទថា **បដិបទាញាណទស្សនវិសុទ្ធិ** សេចក្តីថា វិបស្សនាដែលជាវុដ្ឋានគាមិនី លោកពោលក្នុងរថវិនីតវត្ថុ វិបស្សនាទន់ខ្សោយ លោកពោលទុកក្នុងទីនេះ ។ បទថា **ញាណទស្សនវិសុទ្ធិ** សេចក្តីថា លោកពោលមគ្គក្នុងរថវិនីតវត្ថុ ពោលវុដ្ឋានគាមិនីវិបស្សនាទុកក្នុងទីនេះ ។ វិសុទ្ធិទាំង ៧ នេះ លោកពោលទុកក្នុងវិសុទ្ធិមគ្គដោយពិស្តារហើយ ។ បទថា **បញ្ញា** បានដល់ បញ្ញារបស់អរហត្តផល ។ បទថា **វិមុត្តិ** បានដល់ ការរួចផុតរបស់អរហត្តផលនុ៎ះឯង ។

[ ៣៣២ ] ប្រើនបទថា **ធាតុនានត្តំ បដិច្ច ឧប្បជ្ជតិ ផស្សនានត្តំ** សេចក្តីថា ព្រោះអាស្រ័យសេចក្តីផ្សេងគ្នានៃធាតុ មានចក្ខុធាតុជាដើម សេចក្តីផ្សេងគ្នានៃចក្ខុសម្ផស្សជាដើម ទើបកើតឡើង ដូច្នេះ ។ ពីរបទថា **ផស្សនានត្តំ បដិច្ច** សេចក្តីថា ព្រោះអាស្រ័យសេចក្តីផ្សេងគ្នានៃចក្ខុសម្ផស្សជាដើម ។

បទថា **វេទនានានត្តំ** សេចក្តីថា សេចក្តីផ្សេងគ្នានៃវេទនា មានចក្ខុ-សម្ផស្សជាវេទនាជាដើម ។ ពីរបទថា **សញ្ញានានត្តំ បដិច្ច** សេចក្តីថា ព្រោះអាស្រ័យសេចក្តីផ្សេងគ្នានៃសញ្ញា មានកាមសញ្ញាជាដើម ។ បទថា **សង្កប្ប-នានត្តំ** សេចក្តីថា សេចក្តីផ្សេងគ្នានៃសេចក្តីត្រិះរិះ មានសេចក្តីត្រិះរិះក្នុងកាមជាដើម ។ ប្រើនបទថា **សង្កប្បនានត្តំ បដិច្ច ឧប្បជ្ជតិ ឆន្ទនានត្តំ** សេចក្តីថា សេចក្តីផ្សេងគ្នានៃសេចក្តីពេញចិត្ត រមែងកើតឡើងយ៉ាងនេះថា សេចក្តីពេញចិត្តក្នុងរូប សេចក្តីពេញចិត្តក្នុងសំឡេង ព្រោះសេចក្តីផ្សេងគ្នានៃសេចក្តីត្រិះរិះ ។

បទថា **បរិឡាហនានត្តំ** សេចក្តីថា សេចក្តីផ្សេងគ្នានៃសេចក្តីក្តៅក្រហាយរមែងកើតឡើងយ៉ាងនេះថា សេចក្តីក្តៅក្រហាយក្នុងរូប សេចក្តីក្តៅហាយក្នុងសំឡេងរមែងមាន ព្រោះសេចក្តីផ្សេងគ្នានៃសេចក្តីពេញចិត្ត ។ បទថា **បរិយេ-សនានានត្តំ** សេចក្តីថា សេចក្តីផ្សេងគ្នានៃការស្វែងរករូបជាដើម រមែងកើតឡើង ព្រោះសេចក្តីផ្សេងគ្នានៃសេចក្តីក្តៅក្រហាយ ។ បទថា **លាភនានត្តំ** សេចក្តីថា សេចក្តីផ្សេងគ្នានៃការ បានចំពោះនូវរូបជាដើម រមែងកើតឡើង ព្រោះសេចក្តីផ្សេងគ្នានៃការស្វែងរក ។

[ ៣៣៣ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសញ្ញាទាំងឡាយតទៅ ។ ដែលឈ្មោះ

ថា **មរណសញ្ញា** បានដល់ សេចក្ដីសម្គាល់ដោយមរណានុបស្សនាញាណ ។ ដែលឈ្មោះថា **អាហារេបដិក្កូលសញ្ញា** បានដល់ សេចក្ដីសម្គាល់ដែលកើតឡើង ដល់បុគ្គលដែលកំណត់អាហារ ។ ដែលឈ្មោះថា **សព្វលោកេអនភិរតសញ្ញា** បានដល់ សញ្ញាដែលកើតឡើងដល់បុគ្គលដែលមិនពេញចិត្តក្នុងវដ្ដៈទាំងពួង ។ សញ្ញាដ៏សេស លោកពោលទុកក្នុងវិបស្សនាទាំងឯង ។ លោកពោលមគ្គទុកក្នុងបទ ដែលមានឧបការៈច្រើនក្នុងទីនេះ ពាក្យដ៏សេស ដូចគ្នានឹងពាក្យខាងដើមទាំងឯង ។

**ពណ៌នាធម៌ពួក ៩ ចប់**

## ពណ៌នាធម៌ពួក ១០

[ ៣៤៥ ] បទថា **និជ្ជិណ្ណាវត្ថូនិ** បានដល់ ហេតុដែលអស់កម្លាំង ។ ច្រើនបទថា **មិច្ឆាទិដ្ឋិ និជ្ជិណ្ណា ហោតិ** សេចក្ដីថា មិច្ឆាទិដ្ឋិនេះ អស់កម្លាំង គឺបុគ្គលដែលឃើញប្រពៃលះបានហើយដោយវិបស្សនា ព្រោះហេតុអ្វី ទើបលោកចាត់ទុកទៀត ។ ឆ្លើយថា ព្រោះនៅលះមិនទាន់បាន ។ ពិតហើយ មិច្ឆាទិដ្ឋិ រមែងអស់កម្លាំងដោយវិបស្សនាក៏ពិត តែព្រះយោគាវចរនៅលះមិនទាន់បាន ។ មគ្គកើតឡើងហើយ រមែងលះមិច្ឆាទិដ្ឋិនោះ មិនឲ្យកើតតទៅទៀត ព្រោះហេតុនោះ ទើបលោកចាត់ទុកទៀត ។ បណ្ឌិតគប្បីនាំន័យក្នុងបទទាំងពួងដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត ក្នុងទីនេះ ធម៌ ៦៤ រមែងដល់សេចក្ដីចម្រើនសម្បូរ ព្រោះការរួបផុតដោយប្រពៃជាបច្ច័យ ។ ធម៌ ៦៤ ដូចម្ដេច ។ ធម៌

៦៤ តែមួយយ៉ាងៗ ៨ ក្នុងមគ្គ ៤ ផល ៤ ដល់ភាពបរិបូណ៌យ៉ាងនេះ គឺក្នុងខណៈនៃសោតាបត្តិមគ្គ **សទ្ធិន្ទ្រិយ** រមែងបរិបូណ៌ដោយអត្ថ គឺអធិមោក្ខ **វីរិយិន្ទ្រិយ** រមែងបរិបូណ៌ដោយអត្ថ គឺការលើកតម្កើង **សតិន្ទ្រិយ** រមែងបរិបូណ៌ដោយអត្ថ គឺការរឭកដល់ **សមាធិន្ទ្រិយ** រមែងបរិបូណ៌ដោយអត្ថ គឺសេចក្តីមិនរវើរវាយ **បញ្ញិន្ទ្រិយ** រមែងបរិបូណ៌ដោយអត្ថ គឺការឃើញ **មនិន្ទ្រិយ** រមែងបរិបូណ៌ដោយអត្ថ គឺការដឹងច្បាស់ **សោមនស្សិន្ទ្រិយ** រមែងបរិបូណ៌ដោយអត្ថ គឺសេចក្តីភ្លើតភ្លើនក្រៃលែង **ជីវិតិន្ទ្រិយ** រមែងបរិបូណ៌ដោយអត្ថ គឺភាពជាធំនៃការបន្តឲ្យប្រព្រឹត្តទៅហើយ ។ល។ ក្នុងខណៈនៃអរហត្តផល សទ្ធិន្ទ្រិយ រមែងបរិបូរណ៌ដោយអត្ថ គឺអធិមោក្ខ ។ល។ ជីវិតិន្ទ្រិយ រមែងបរិបូរណ៌ដោយអត្ថ គឺភាពជាធំនៃការបន្តឲ្យប្រព្រឹត្តទៅហើយ ។ ក្នុងទីនេះលោកពោលមគ្គទុកក្នុងបទដែលគួរដឹងដ៏ក្រៃលែង ។ ពាក្យដ៏សេសដូចគ្នានឹងពាក្យដើមនុ៎ះឯង ។ ភិក្ខុតាំងនៅក្នុងព្រះសាសនានេះហើយ គប្បីប្រជុំបញ្ហាដូច្នេះ ។ ជាការដែលលោកពោល ៥៥០ បញ្ហា គឺពោល ១០០ បញ្ហា ក្នុងពួក ១០ ពោល ១០០ បញ្ហា ក្នុងពួក ១ និងពួក ៩ ពោល ១០០ បញ្ហា ក្នុងពួក ២ និងពួក ៨ ពោល ១០០ បញ្ហា ក្នុងពួក ៣ និងពួក ៧ ពោល ១០០ បញ្ហា ក្នុងពួក ៤ និងពួក ៦ ពោល ៥០ បញ្ហាក្នុងពួក ៥ ។

ព្រះសារីបុត្របានពោលពាក្យនេះហើយ ពួកភិក្ខុទាំងនោះ រីករាយក្នុងភាសិតរបស់ព្រះសារីបុត្រ រីករាយហើយដោយពោលថា ប្រពៃណាស់ ប្រពៃណាស់ ដូច្នេះហើយ ទទួលទុកដោយសិរសា ។ ឯពួកភិក្ខុសូម្បីទាំង ៥០០ រូប

នោះ នឹកដល់ព្រះសូត្រនុ៎ះឯង ក៏តាំងនៅក្នុងអរហត្ត ព្រមទាំងបដិសម្ភិទា ទាំងឡាយហើយ ក៏ព្រោះភាពនៃខ្លួនមានចិត្តរីករាយនោះ ដូច្នេះឯង ។

ពណ៌នាសេចក្តីក្នុងទសុត្តរសូត្រ នៃអដ្ឋកថាទីឃនិកាយ ឈ្មោះ ថា សុមង្គលវិលាសិនី ចប់ហើយ ដោយប្រការដូច្នេះ ។

**ពួក ១០ ចប់**

**ពណ៌នាបាដិកវគ្គ ក៏ចប់ហើយដូច្នេះឯង**

មួយវិញទៀត ខ្ញុំដែលព្រះទាឋានាគសង្ឃត្ថេរ អ្នកនៅក្នុងទីដែលជា មង្គលល្អ ជាអ្នកមានគុណធំ ឈ្មោះថា **ថេរវង្ស** អារាធនាហើយ ដោយពាក្យ មានប្រមាណប៉ុណ្ណេះ ប្រារព្ធអដ្ឋកថាណា ឈ្មោះថា **សុមង្គលវិលាសិនី** ដោយ ឈ្មោះនៃគម្ពីរដែលវែងដ៏ប្រសើរ ដែលសម្តែងនូវពួកនៃគុណរបស់ព្រះសាស្តា ក៏អដ្ឋកថានោះ ដែលខ្ញុំកាន់យកសារៈ ក្នុងមហាអដ្ឋកថា ឲ្យចប់ស្រេចហើយ ។ អដ្ឋកថានោះ ចប់ហើយដោយភាណវារទាំងឡាយនៃបាលីប្រមាណ ៨១ ។ សូម្បី វិសុទ្ធិមគ្គ ដែលមានប្រមាណ ៥៩ ដែលខ្ញុំបានរចនាគម្ពីរ ក៏ដើម្បីប្រយោជន៍ ដល់ការប្រកាសសេចក្តីដោយភាណវារទាំងឡាយ ព្រោះហេតុនោះ អដ្ឋកថានេះ ព្រមទាំងវិសុទ្ធិមគ្គនោះ ដែលខ្ញុំរាប់កំណត់ល្អហើយ ដោយការរាប់ភាណវារ ទើបបាន ១៤០ ។ ពោលដោយភាណវារ ពាក្យទាំងពួងប្រមាណ ១៤០ ពួក ដោយប្រការដូច្នេះ ។

ខ្ញុំអ្នកកាន់យកសារៈក្នុងមូលអដ្ឋកថា ដែលប្រកាសលទ្ធិនៃព្រះថេរៈ អ្នក នៅក្នុងមហាវិហារធ្វើកម្មនេះ ចូលទៅកពូនបុណ្យណាទុក ដោយបុណ្យនោះ

សូមមនុស្សលោកទាំងឡាយ មានសុខចុះ ដូច្នេះឯង ។

អដ្ឋកថានៃទីឃនិកាយ ឈ្មោះថា **សុមង្គលវិលាសិនី** នេះ ដែលព្រះថេរៈអ្នកមាននាមធេយ្យៈ ដែលគ្រូទាំងឡាយតាំងនាមថា **ពុទ្ធឃោស** អ្នកប្រដាប់ដោយសទ្ធា ប្រាជ្ញា និងសេចក្តីព្យាយាមដ៏ហ្មត់ចត់ក្រៃលែង ជាអ្នកដែលប្រកបដោយគុណ មានសីល អាចារៈ សេចក្តីស្មោះត្រង់ និងភាពជាអ្នកទន់ភ្លន់ជាដើម តាំងឡើងហើយ អ្នកប្រកបដោយសមត្ថភាព ក្នុងការសិក្សារៀនសូត្រលទ្ធិរបស់ខ្លួន និងលទ្ធិដទៃ អ្នកប្រកបដោយសេចក្តីឈ្លាសវៃដោយបញ្ញា អ្នកមានអំណាចនៃញាណដែលអ្វីៗ កម្ចាត់មិនបានក្នុងព្រះសាសនារបស់ព្រះសាស្តា ព្រមដោយអដ្ឋកថា ដែលផ្សេងដោយការសិក្សាព្រះត្រៃបិដក ជាអ្នកវេយ្យាករណ៍ធំ អ្នកប្រកបដោយសេចក្តីសុខ ដែលករណសម្បត្តិឲ្យកើតហើយ និងសេចក្តីស្អាតនៃពាក្យដែលរហ័សរហួន ផ្អែមល្ហែមពីរោះ អ្នកនិយាយពាក្យដែលគួរ និងប្រាសចាកអំពីទោស ជាអ្នកនិយាយប្រសើរ ជាមហាកវី ជាអ្នកប្រាជ្ញដ៏ធំហ្មត់ចត់ ដែលជាគ្រឿងប្រដាប់វង្សនៃព្រះថេរៈទាំងឡាយ អ្នកសម្តែងថេរវង្ស អ្នកមានប្រក្រតីនៅក្នុងមហាវិហារ អ្នកមានសេចក្តីដឹងដែលតាំងមាំល្អហើយ ក្នុងឧត្តរិមនុស្សធម៌ ដែលប្រដាប់ហើយដោយគុណមានអភិញ្ញា ៦ ជាដើម ជាប្រភេទដែលមានបដិសម្ភិទា ដែលខ្ជួនបែកធ្លាយហើយជាបរិវាររចនាហើយ ។

សូម្បីព្រះនាមថា ពុទ្ធោ របស់ព្រះមានព្រះភាគ អ្នកមានចិត្ត

បរិសុទ្ធ អ្នកមាំទាំ អ្នកប្រសើរបំផុតក្នុងលោក អ្នកស្វែងរកគុណដ៏ធំក្រៃលែង នៅប្រព្រឹត្តទៅក្នុងលោកត្រឹមណា សូមអដ្ឋកថា ឈ្មោះថា សុមង្គលវិលាសិនីនេះ ដែលសម្តែងហើយដោយន័យ ដើម្បីសេចក្តីបរិសុទ្ធិនៃទិដ្ឋិរបស់កុលបុត្រទាំងឡាយអ្នកស្វែងរកគ្រឿងរលាស់ចេញចាកលោក ចូរតាំងនៅក្នុងលោកត្រឹមនោះចុះ ។ មួយវិញទៀត ពណ៌នាសេចក្តីនៃអដ្ឋកថាទីឃនិកាយ ក៏ចប់ស្រេចហើយ ។

**ធសុត្តរសូត្រទី ១១ ចប់**

# ក្បាលទី ១២

## សុត្តន្តបិដក បាលីប្រែ -១៨

### សន្ទឹកចង្អុលប្រាប់មាតិកា

មាតិកា លេខទំព័រ


ចក្កវត្តិសូត្រទី ៣ ...... ...... ...... ...... ...... ...... ...... ២

អដ្ឋកថា ចក្កវត្តិសូត្រ ...... ...... ...... ...... ...... ...... ...... ៣៧

*វត្តរបស់ស្តេចចក្រពត្តិ* ...... ...... ...... ...... ...... ...... ...... ៤៧

អគ្គញ្ញសូត្រទី៤ ...... ...... ...... ...... ...... ...... ...... ៦៤

អដ្ឋកថា អគ្គញ្ញសូត្រ ...... ...... ...... ...... ...... ...... ...... ៩៤

*រឿងនាងវិសាខា* ...... ...... ...... ...... ...... ...... ...... ៩៤

សម្បសាទនីយសូត្រទី ៥ ...... ...... ...... ...... ...... ...... ...... ១២២

អដ្ឋកថា សម្បសាទនីយសូត្រ ...... ...... ...... ...... ...... ...... ១៥១

បាសាទិកសូត្រទី ៦ ...... ...... ...... ...... ...... ...... ...... ២១៥

អដ្ឋកថា បាសាទិកសូត្រ ...... ...... ...... ...... ...... ...... ២៥៥


## សុត្តន្តបិដក បាលីប្រែ -១៩


លក្ខណៈសូត្រទី ៧ ...... ...... ...... ...... ...... ...... ...... ២៧៩

អដ្ឋកថា លក្ខណៈសូត្រ ...... ...... ...... ...... ...... ...... ...... ៣២៩

សិង្គាលកសូត្រទី៨ ...... ...... ...... ...... ...... ...... ...... ៣៧៤

អដ្ឋកថា សិង្គាលកសូត្រ ...... ...... ...... ...... ...... ...... ...... ៣៩៤

*អបាយមុខ ៦ យ៉ាង មានភាពជាអ្នកលេងសុរាជាដើម ... ......* ៤០១

*អធិប្បាយទិស ៦* ...... ...... ...... ...... ...... ...... ...... ៤១៦

អាដានាដិយសូត្រទី៩ ...... ...... ...... ...... ...... ...... ...... ៤៣០

**អដ្ឋកថា អាដានាដិយសូត្រ** ...... ...... ...... ...... ...... ...... ៤៥២
**សង្គីតិសូត្រទី ១០** ...... ...... ...... ...... ...... ...... ...... ៤៧៤
**អដ្ឋកថា សង្គីតិសូត្រ** ...... ...... ...... ...... ...... ...... ...... ៥៦៧
*ពោលអំពីធម៌ពួក ១* ...... ...... ...... ...... ...... ...... ...... ៥៦៧
*ការធ្វើមរណកាលនៃនិគណ្ឋនាដបុត្ត* ...... ...... ...... ...... ៥៧៣
*ពោលអំពីធម៌ពួក ២* ...... ...... ...... ...... ...... ...... ...... ៥៧៩
*ពោលអំពីធម៌ពួក ៣* ...... ...... ...... ...... ...... ...... ...... ៥៩៦
*ពោលអំពីធម៌ពួក ៤* ...... ...... ...... ...... ...... ...... ...... ៦៣៩
*ពោលអំពីធម៌ពួក ៥* ...... ...... ...... ...... ...... ...... ...... ៦៨០
*ពោលអំពីធម៌ពួក ៦* ...... ...... ...... ...... ...... ...... ...... ៦៩៥
*ពោលអំពីធម៌ពួក ៧* ...... ...... ...... ...... ...... ...... ...... ៧០៥
*ពោលអំពីធម៌ពួក ៨* ...... ...... ...... ...... ...... ...... ...... ៧១៦
*ពោលអំពីធម៌ពួក ៩* ...... ...... ...... ...... ...... ...... ...... ៧២០
*ពោលអំពីធម៌ពួក ១០* ...... ...... ...... ...... ...... ...... ...... ៧២២
**ទសុត្តរសូត្រទី ១១** ...... ...... ...... ...... ...... ...... ...... ៧៣៨
**អដ្ឋកថា ទសុត្តរសូត្រ** ...... ...... ...... ...... ...... ...... ...... ៨១៥
*ពណ៌នាធម៌ពួក ១* ...... ...... ...... ...... ...... ...... ...... ៨១៩
*ពណ៌នាធម៌ពួក ២* ...... ...... ...... ...... ...... ...... ...... ៨២៤
*ពណ៌នាធម៌ពួក ៣* ...... ...... ...... ...... ...... ...... ...... ៨២៥
*ពណ៌នាធម៌ពួក ៤* ...... ...... ...... ...... ...... ...... ...... ៨២៦
*ពណ៌នាធម៌ពួក ៥* ...... ...... ...... ...... ...... ...... ...... ៨២៩
*ពណ៌នាធម៌ពួក ៦* ...... ...... ...... ...... ...... ...... ...... ៨៣១
*ពណ៌នាធម៌ពួក ៧* ...... ...... ...... ...... ...... ...... ...... ៨៣២

ពណ៌នាធម៌ពូក ៨ ...... ...... ...... ...... ...... ...... ...... ៨៣២

ពណ៌នាធម៌ពូក ៩ ...... ...... ...... ...... ...... ...... ...... ៨៣៦

ពណ៌នាធម៌ពូក ១០ ...... ...... ...... ...... ...... ...... ...... ៨៣៨